Sweden Sverige

arrow
asian-pacific resource & research centre for women

UN WOMEN



# សៀវភៅណែនាំ សម្រាប់គ្រូបង្គោល

## យេនឌ័រ និងភាពធន់ នឹងការប្រែប្រួលអាកាសធាតុ

ΣmPower
Women for Climate-Resilient Societies

**©២០២១ Arrow និង UN Women។ រក្សាសិទ្ធិគ្រប់យ៉ាង**

ការយល់ឃើញនៅក្នុងការបោះពុម្ពផ្សាយនេះ គឺជារបស់អ្នកនិពន្ធ និងអ្នកចូលរួមចំណែក ហើយវាមិនឆ្លុះបញ្ចាំង ឬតំណាងឱ្យទស្សនៈនៃ Arrow, UN Women និងអង្គការសហប្រជាជាតិ ឬអង្គការចំណុះពាក់ព័ន្ធណាមួយនោះឡើយ។ ការបោះពុម្ពផ្សាយត្រូវបានរៀបចំឡើងផ្អែកលើមូលដ្ឋាននៃព័ត៌មានដែលមានស្រាប់ ឬដែលអាចទទួលបានគិតត្រឹមថ្ងៃនៃការបោះពុម្ពផ្សាយ។ ការទទួលខុសត្រូវនៃមតិយោបល់ដែលបានបង្ហាញ និងភាពត្រឹមត្រូវជាក់លាក់នៃខ្លឹមសារ នៅក្នុងការចូលរួមនេះ ត្រូវបានធ្វើឡើងដោយអ្នកនិពន្ធផ្ទាល់។ សម្រាប់បញ្ជីនៃកំហុសឆ្គងនិងការលុបតម្រូវត្រង់ចំណុចណាមួយដែលអាចត្រូវបានរកឃើញបន្ទាប់ពីការបោះពុម្ពផ្សាយរួចសូមចូលទៅកាន់គេហទំព័រ Empower របស់យើង។

UN Women សូមថ្លែងអំណរគុណដល់ទីភ្នាក់ងារសហប្រតិបត្តិការអភិវឌ្ឍន៍អន្តរជាតិស៊ុយអែត (SIDA) សម្រាប់ការចូលរួមគាំទ្រផ្នែកហិរញ្ញវត្ថុសម្រាប់ការរៀបចំនិងផលិតកម្មនៃសៀវភៅណែនាំបណ្តុះបណ្តាលនេះ ដែលជាផ្នែកមួយនៃគម្រោងការពង្រឹងសិទ្ធមនុស្ស និងសមភាពយេនឌ័រតាមរយៈសកម្មភាពនៃការប្រែប្រួលអាកាសធាតុ និងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ (EmPower) របស់ UN Women។

## សិទ្ធិ និងការអនុញ្ញាត

ការងារនេះ ត្រូវបានផ្តល់អាជ្ញាបណ្ណ ក្រោមអាជ្ញាបណ្ណអន្តរជាតិ ៤.0 ដែលមានលក្ខណៈមិនមែនជាពាណិជ្ជកម្មនៃភាពជាម្ចាស់កម្មសិទ្ធប្រកបដោយភាពច្នៃប្រឌិត (creative commons attributions-non-commerical international license)។ ដើម្បីមើលច្បាប់ចម្លងនៃអាជ្ញាបណ្ណនេះ សូមចូលទៅកាន់គេហទំព័រ https://creativecommons.org/licenses/by-nc-nd/4.0/។ ផ្នែកណាមួយនៃអត្ថបទនៃការបោះពុម្ព អាចត្រូវបានថតចម្លង ផលិតឡើងវិញ រក្សាទុកក្នុងប្រព័ន្ធទាញយក ឬបញ្ជូនតាមទម្រង់ណាមួយ ឬកែសម្រួល និងបកប្រែដើម្បីបំពេញតម្រូវការក្នុងស្រុក សម្រាប់គោលបំណងមិនមែនពាណិជ្ជកម្ម និងមិនស្វែងរកប្រាក់ចំណេញ។ ទោះជាយ៉ាងណាក៏ដោយ ការរក្សាសិទ្ធិសម្រាប់រូបភាពដែលបានប្រើនៅតែជារបស់ម្ចាស់កម្មសិទ្ធិនីមួយៗ។ គ្រប់ទម្រង់នៃច្បាប់ចម្លង ការផលិតឡើងវិញ ការយកលំនាំតាម និងការបកប្រែ តាមរយៈមធ្យោបាយមេកានិច អគ្គិសនី ឬអេឡិចត្រូនិក គួរតែទទួលស្គាល់ARROWជាប្រភពដើម។ ច្បាប់ចម្លងនៃការផលិតឡើងវិញ ការយកលំនាំតាម និង/ឬការបកប្រែ គួរតែត្រូវបានផ្ញើទៅកាន់ ARROW ឬ UN Women។ នៅក្នុងករណីនៃការប្រើប្រាស់ពាណិជ្ជកម្ម ARROW ឬ UN Women ត្រូវតែត្រូវបានទាក់ទងសម្រាប់ការអនុញ្ញាត តាមរយៈ arrow@arroworg.my ឬ info.th@unwomen.org ហើយត្រូវតែបំពេញតាមលក្ខខណ្ឌខាងក្រោម៖

**ភាពជាម្ចាស់កម្មសិទ្ធិ** - សូមយោងសម្រង់នៃខ្លឹមសារឯកសារតាម៖ Chauhan, Dharmistha. 2021. Training Manual on Gender and Climate Change Resilience. Kuala Lumpur and Bangkok: The Asian-Pacific Resource and Research Centre for Women (ARROW) and UN Women Regional Office for Asia and the Pacific.

**ការបកប្រែ** - ប្រសិនបើអ្នកបង្កើតការបកប្រែនៃការងារនេះ សូមបន្ថែមសេចក្តីអះអាងខាងក្រោម រួមជាមួយនឹងភាពជាកម្មសិទ្ធ៖ ការបកប្រែនេះមិនត្រូវបានបង្កើតឡើងដោយ ARROW ឬ UN Women និងមិនគួរចាត់ទុកថាជាការបកប្រែជាផ្លូវការដោយ ARROW ឬ UN Women ឡើយ។ ARROW ឬ UN Women នឹងមិនទទួលខុសត្រូវចំពោះខ្លឹមសារ ឬកំហុសណាមួយនៅក្នុងការបកប្រែនេះទេ។

**ការយកលំនាំតាម**-ប្រសិនបើអ្នកបង្កើតការយកលំនាំតាមនៃការងារនេះ សូមបន្ថែមសេចក្តីអះអាងខាងក្រោម រួមជាមួយនឹងភាពជាកម្មសិទ្ធ៖ នេះគឺជាការយកលំនាំតាមស្នាដៃដើមរបស់ ARROW និង UN Women។ ទស្សនៈ និងមតិដែលបានបង្ហាញនៅក្នុងការយកលំនាំតាមនេះ គឺជាទំនួលខុសត្រូវតែមួយគត់របស់អ្នកនិពន្ធ ឬអ្នកនិពន្ធនៃការងារយកលំនាំតាម ហើយមិនត្រូវបានគាំទ្រនិងទទួលស្គាល់ដោយ ARROW និង UN Women នោះឡើយ។

**ខ្លឹមសារដោយភាគីទីបី** - ARROW និង UN Women មិនមែនម្ចាស់នៃខ្លឹមសារនីមួយៗដែលមាននៅក្នុងការងារនោះទេ។ ARROW និង UN Women មិនធានាថា ការប្រើប្រាស់ខ្លឹមសារបុគ្គល ឬផ្នែកដែលមានក្នុងការងារដោយ ភាគីទីបី នឹងមិនបំពានលើសិទ្ធិរបស់តតិយជននោះទេ។ ហានិភ័យនៃការអះអាងនេះកើតឡើងពីការបំពាននេះគឺស្ថិតនៅលើអ្នកតែម្នាក់ឯង។ ប្រសិនបើអ្នកមានបំណងចង់ប្រើឡើងវិញនូវខ្លឹមសារនៃការងារនោះវាគឺជាទំនួលខុសត្រូវរបស់អ្នកក្នុងការកំណត់ថាតើការអនុញ្ញាតគឺចាំបាច់សម្រាប់ការប្រើប្រាស់ឡើងវិញនោះ និងដើម្បីទទួលបានការអនុញ្ញាតពីម្ចាស់កម្មសិទ្ធិបញ្ញា។ ឧទាហរណ៍នៃសមាសធាតុខ្លឹមសារ អាចរួមបញ្ចូល ប៉ុន្តែមិនកំណត់ចំពោះតារាង រូបភាព ឬរូបថតណាមួយ។

**អ្នកនិពន្ធ**

Dharmisth a Chauhan

**អ្នកកែសម្រួល**

Prakriti Naswa (ARROW)

**ការពិនិត្យឡើងវិញ និងរួមចំណែកជាធាតុចូល**

Biplabi Shrestha, Deepa Chandra ( ARROW )
Bobae Lee, Inkar Kadyrzhanova, Katherine Gifford, Pairach Homtong, Paulene Maria Isabelle Santos, Riina Haavisto Priodarshine Auvi, Dilruba Haider, Tran Thi Thuy Anh, Sereyroth Lim, Leakena Duong and Rotvatey Sovann ( UN Women )
Amy Reggers, Annette Wallgren, Parimita Mohanty, and Prashanthi Subramaniam ( UNEP )

**ការពិនិត្យ និងកែសម្រួលភាសា**
Faye F. Melegrito
សុវណ្ណ រ័ត្នវតី, ឈន ឈុនលី ( UN Women Cambodia )
ហុង រស្មី, សន ពុទ្ធី, អ៊ីន សម្ផស្ស ( Action Aid Cambodia )

**ការរចនារូបភាព និងទម្រង់ ( កំណែភាសាអង់គ្លេស )**
Nicolette de Lange Mallari

**ការស្រាវជ្រាវរូបភាព**
Deepa Chandra and Prakriti Naswa ( ARROW )
Nicolette de Lange Mallari

**ក្រេឌីតរូបភាព**
រូបភាពគម្របៈ កសិករម្នាក់កំពុងធ្វើការនៅក្នុងវាលស្រែនៅក្នុងក្រុងតាមីលណាឌូ ( Tamilnadu ) នៃប្រទេសឥណ្ឌា VS. Anandhakrishna/ Shutterstock; ម៉ូឌុល១៖ កសិករម្នាក់ដែលបានបង្កើនប្រាក់ចំណូលដោយការដាំដំឡូងមីដែលផ្តល់ទិន្នផលខ្ពស់ នៅខេត្តដុងណៃ ប្រទេសវៀតណាម។ CIAT/ Georgina Smith/Flickr, ម៉ូឌុល២៖ កសិករម្នាក់បង្ហាញត្រាក់ទ័រដែលទិញដោយប្រើប្រាស់ថវិកាពីការលក់ដំឡូងមី នៅចំប៉ាសាក់ ប្រទេសឡាវ។ CIAT/Georgina Smith/Flickr;; ម៉ូឌុល៣៖ កម្មករម្នាក់នៅស្រុកតង់ហ្គាល ( Tangail ) ប្រទេសបង់ក្លាដែស កែច្នៃនិងសម្ងួតសរសៃអំបោះពីស្លឹកម្នាស់។ Jahangir Alam Onuchcha/Shutterstock; ម៉ូឌុល៤៖ ស្ត្រីមកពីប្រទេសរ៉ាន់ដាអាទូកាន់ផ្កាចម្រុះពណ៌ដែលកម្រ។ Cavan-Images/Shutterstock; ; ម៉ូឌុល៥៖ កសិករជនជាតិដើមភាគតិចនៅខេត្តដាកឡាក់ ប្រទេសវៀតណាម។ CIAT/Georgina Smith/Flickr, and ; ម៉ូឌុលបញ្ចប់៖ បុគ្គលិកសុខាភិបាលកំពុងរៀបចំការចាក់ថ្នាំបង្ការជំងឺកូវីដ១៩ នៅមន្ទីរពេទ្យក្នុងក្រុងដាកា ប្រទេសបង់ក្លាដែស។ Mamunur Rashid/Shutterstock

**មជ្ឈមណ្ឌលធនធាន និងស្រាវជ្រាវអាស៊ីប៉ាស៊ីហ្វិកសម្រាប់ស្ត្រី ( ARROW )**
1 & 2 Jalan Scott, Brickfields, ទីក្រុងកូឡាឡាំពួរ, ប្រទេសម៉ាឡេស៊ី ៥០៤៧០
**អ៊ីម៉ែល៖** arrow@arrow.org.my
**គេហទំព័រ៖** arrow.org.my
**ហ្វេសប៊ុក៖** facebook.com/ARROW.Women
**អ៊ីនស្តាក្រាម៖** arrow_women
**ធ្វីតធ័រ៖** @ARROW_Women

**ការិយាល័យ UN Women ប្រចាំតំបន់អាស៊ី និងប៉ាស៊ីហ្វិក**
អគារអង្គការសហប្រជាជាតិ, វិថី Rajdamnern Nok ទីក្រុងបាងកក, ប្រទេសថៃ ១០២០០
**អ៊ីម៉ែល៖** info.th@un women.org
**គេហទំព័រ៖** asiapaciflc.unwomen.org
**ហ្វេសប៊ុក៖** @unwomenasia
**អ៊ីនស្តាក្រាម៖** @unwomenasia
**ធ្វីតធ័រ៖** @unwomenasia

# មាតិកា

## ផ្នែកណែនាំ


៥ - បុព្វកថា, UN Women និង ARROW
៧ - អំពីសៀវភៅណែនាំនេះ
៧ - អក្សរកាត់
១១ - សេចក្ដីផ្ដើម


## ម៉ូឌុល១


១៥ យេនឌ័រ និងការប្រែប្រួលអាកាសធាតុ
១៦ - ម៉ូឌុល១ វគ្គ ក
១៨ - សិទ្ធិមនុស្ស និងវិធីសាស្ត្រផ្អែកលើសិទ្ធិមនុស្សជាមូលដ្ឋាន
២១ - មិនមានអ្នកណាម្នាក់ត្រូវបានទុកចោល
២៣ - វិសមភាព និងអន្តរវិស័យភាពខាងយេនឌ័រ
២៩ - ម៉ូឌុល១ វគ្គ ខ
៣០ - ហានិភ័យអាកាសធាតុសកល, ភាពបន្សាំ, ការកសាងភាពធន់, និងការកាត់បន្ថយគ្រោះមហន្តរាយ
៤០ - ម៉ូឌុល១ វគ្គ គ
៤២-វិសាលភាពយេនឌ័រនៃការប្រែប្រួលអាកាសធាតុនិងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ (CCDRR) និងការកសាងភាពធន់ (RB)
៥២ - ការធ្វើសមាហរណកម្មយេនឌ័រនៅក្នុង CCDRR និង RB
៦២ - លំហាត់សម្រាប់ម៉ូឌុល១
៧៦ - ឯកសារចែកជូនសម្រាប់ម៉ូឌុល១


## ម៉ូឌុល២


៩៥- ការបង្កើតគោលនយោបាយ CCDRR និងផែនការថ្នាក់ជាតិ
៩៦ - ម៉ូឌុល២ វគ្គ ក
៩៨ - ក្របខណ្ឌការងារគោលនយោបាយការប្រែប្រួលអាកាសធាតុនិងការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ (CCDRR) សកល
១០២ - ក្របខណ្ឌថ្នាក់ជាតិនានាសម្រាប់ CCDRR និងការបញ្ជ្រាបយេនឌ័រ
១១០ - ម៉ូឌុល២ វគ្គ ខ
១១១ - គម្លាត និងបញ្ហាប្រឈមក្នុងការបញ្ជ្រាបយេនឌ័រនៅក្នុងគោលនយោបាយ និងផែនការថ្នាក់ជាតិ
១១៥ - យុទ្ធសាស្ត្រសម្រាប់ការបញ្ជ្រាបយេនឌ័រ និងចំណុចចាប់ផ្ដើម/ច្រកចូលសម្រាប់អង្គការសង្គមស៊ីវិល
១២៨ - លំហាត់សម្រាប់ម៉ូឌុល២
១៣៧ - ឯកសារចែកជូនសម្រាប់ម៉ូឌុល២


## ម៉ូឌុល៣


១៥៤ ឧបករណ៍សម្រាប់ការបញ្ជ្រាបយេនឌ័រ
១៥៥ - ម៉ូឌុល៣ វគ្គ ក
១៥៧ - ការបញ្ជ្រាបយេនឌ័រ និងការវិភាគយេនឌ័រ
១៧០ - ឧបករណ៍ប៉ាន់ប្រមាណ ភាពងាយរងគ្រោះដែលមានទស្សនៈយេនឌ័រ
១៨៤ - ការរៀបចំផែនការដែលឆ្លើយតបយេនឌ័រ ការរៀបចំ និងបង្កើតគម្រោង
១៨៩ - ម៉ូឌុល៣ វគ្គ ខ
១៩០ - ដំណើរការអនុវត្តដែលមានទស្សនៈយេនឌ័រ
១៩៨ - ការតាមដាន និងវាយតម្លៃរញ្ជោចយេនឌ័រ
២០២ - លំហាត់សម្រាប់ម៉ូឌុល៣
២១៣ - ឯកសារចែកជូនសម្រាប់ម៉ូឌុល៣


## ម៉ូឌុល៤


២៣១ យេនឌ័រក្នុងវិធីសាស្ត្របន្សាំ និងសកម្មភាពតាមវិស័យ
២៣២ - ម៉ូឌុល៤ វគ្គ ក
២៣៣ - ម៉ូឌែលបន្សាំ និងយេនឌ័រ
២៤៨ - ម៉ូឌុល៤ វគ្គ ខ
២៤៩-វិស័យទី១៖ការប្រែប្រួលអាកាសធាតុកសិកម្មនិងសន្តិសុខស្បៀង
២៥៥ - វិស័យទី២៖ ការប្រែប្រួលអាកាសធាតុ សុខភាពសាធារណៈ និងការឆ្លងរាលដាលជំងឺ
២៦៣ - វិស័យទី៣៖ ការប្រែប្រួលអាកាសធាតុ និងតំបន់ឆ្នេរ
២៦៩ - លំហាត់សម្រាប់ម៉ូឌុល៤
២៧៩ - ឯកសារចែកជូនសម្រាប់ម៉ូឌុល៤


## ម៉ូឌុល៥


៣២៦ - ហិរញ្ញវត្ថុអាកាសធាតុសម្រាប់សកម្មភាពអាកាសធាតុដែលឆ្លើយតបនឹងតម្រូវការយេនឌ័រ-ហិរញ្ញវត្ថុអាកាសធាតុសម្រាប់សកម្មភាពអាកាសធាតុដែលឆ្លើយតបនឹងតម្រូវការយេនឌ័រ
៣២៧ - ម៉ូឌុល៥ វគ្គ ក
៣២៩ - ទិដ្ឋភាពហិរញ្ញវត្ថុអាកាសធាតុសកល
៣៣៦ - មូលនិធិនៃបន្សាំសំខាន់ៗ និងវិសាលភាពសម្រាប់ការចូលរួមរបស់ CSOs
៣៤៥ - ម៉ូឌុល៥ វគ្គ ខ
៣៤៦-ទិដ្ឋភាពទូទៅនៃការរៀបចំថវិកាដែលឆ្លើយតបនឹងតម្រូវការយេនឌ័រ (GRB)
៣៤៩ - ការអនុវត្ត GRB ក្នុងហិរញ្ញវត្ថុអាកាសធាតុក្នុងស្រុក
៣៥៥ - ឧបករណ៍ និងបច្ចេកទេស GRB ជាមួយនឹងចំណុចចាប់ផ្ដើម/ច្រកចូលសម្រាប់អង្គការសង្គមស៊ីវិល (CSOs)
៣៦០-ការរៀបចំថវិកាដែលឆ្លើយតបនឹងតម្រូវការយេនឌ័រ(GRB) សម្រាប់ហិរញ្ញវត្ថុអាកាសធាតុ៖ របាយការណ៍ថវិកាយេនឌ័រ និងអាកាសធាតុ
៣៦៣ - លំហាត់សម្រាប់ម៉ូឌុល៥
៣៧១ - ឯកសារចែកជូនសម្រាប់ម៉ូឌុល៥


## ផ្នែកបញ្ចប់


៣៨៨ - ការអនុវត្តការរៀនសូត្រ៖ ការបង្កើតគម្រោង CCDRR ដែលឆ្លើយតបនឹងតម្រូវការយេនឌ័រ
៣៨៩ - លំហាត់
៣៩០ - ឯកសារចែកជូនសម្រាប់ផ្នែកបញ្ចប់

៣៩៥ ឧបសម្ព័ន្ធ

៤០៧ ឯកសារយោង



## បុព្វកថា

ក្នុងរយៈពេល ២៥ឆ្នាំកន្លងមក ចាប់តាំងពីការអនុម័តសេចក្តីប្រកាសទីក្រុងប៉េកាំង និងវេទិកាសម្រាប់សកម្មភាព ការផ្លាស់ប្តូរជាវិជ្ជមានសំខាន់ៗត្រូវបានធ្វើឡើងក្នុងទម្រង់ជាច្រើននៃសមភាពយេនឌ័រនិងការពង្រឹងភាពអង់អាចរបស់ ស្ត្រី។ ទោះជាយ៉ាងណាក្តី បញ្ហាប្រឈមនៅតែមានក្នុងវិស័យផ្សេងៗជាច្រើន ជាពិសេសក្នុងការបញ្ជ្រាបយេនឌ័រ នៅក្នុងទិដ្ឋភាពនៃគោលនយោបាយស្តីពីការប្រែប្រួលអាកាសធាតុ។

ការបញ្ជ្រាបសមភាពយេនឌ័រក្នុងការប្រែប្រួលអាកាសធាតុ គឺពាក់ព័ន្ធជាពិសេសសម្រាប់តំបន់អាស៊ី-ប៉ាស៊ីហ្វិកដែលជាតំបន់មួយក្នុងចំណោមតំបន់ងាយរងគ្រោះបំផុត ដោយផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុនិងគ្រោះមហន្តរាយលើពិភពលោក។ស្ត្រី និងក្មេងស្រីនៅក្នុងតំបន់ទទួលរងផលប៉ះពាល់ពីប្រព័ន្ធរចនាសម្ព័ន្ធដែលមិនមានតុល្យភាព និងវិសមភាពយេនឌ័រក្នុងសង្គមដែលមានស្រាប់។កត្តាដែលជាប់ទាក់ទងគ្នាទាំងនេះជាលទ្ធផលបង្កើននូវភាពងាយរងគ្រោះរបស់ពួកគេទៅនឹងផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ។នៅពេលដែលមានគ្រោះមហន្តរាយកើតឡើង ស្ត្រី និងក្មេងស្រី ទទួលរងផលប៉ះពាល់ជាញឹកញាប់ ពីការរំលោភបំពានសិទ្ធិមនុស្ស, អំពើហិង្សាផ្អែកលើយេនឌ័រ, ជម្លោះ និងភាពតានតឹងលើការទទួលបានធនធាន, ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងមុនអាយុរៀបការ, ការធ្វើចំណាកស្រុកដោយបង្ខំដោយសារអាកាសធាតុ និងការជួញដូរមនុស្សជាដើម។ ស្ត្រីភាគច្រើននៅតំបន់អាស៊ី និងប៉ាស៊ីហ្វិក ទទួលបានជីវភាពរស់នៅរបស់ ពួកគេពីការធ្វើកសិកម្ម និងធនធានធម្មជាតិដែលមានភាពរសើបនឹងអាកាសធាតុដែលធ្វើឱ្យពួកគេកាន់តែងាយនឹងទទួលរងផលប៉ះពាល់ ពីការប្រែប្រួលអាកាសធាតុ។ សមត្ថភាព ជំនាញ និងចំណេះដឹងរបស់ស្ត្រី ក្នុងការដោះស្រាយបញ្ហានៃការប្រែប្រួលអាកាសធាតុ និងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយប្រកបដោយប្រសិទ្ធភាព ជាញឹកញាប់ នៅមិនទាន់បានយកមកប្រើប្រាស់នៅឡើយ ដោយសារតែទម្លាប់និងផ្នត់គំនិតរើសអើង និងបទដ្ឋានសង្គមដែលឱ្យតម្លៃទាបលើចំណេះដឹងរបស់ពួកគេនិងនាំទៅដល់ការផាត់ចេញពីការធ្វើសេចក្តីសម្រេចចិត្ត។ លទ្ធភាពរបស់ពួកគេក្នុងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ គឺបានធ្លាក់ចុះ ដោយសារស្ថានភាពមិនអំណោយផល និងភាពជាចំណុះរបស់ពួកគេ។

ការិយាល័យ UN Women ប្រចាំតំបន់អាស៊ី និងប៉ាស៊ីហ្វិក បាន និងកំពុងធ្វើការជាមួយភាគីពាក់ព័ន្ធជាច្រើន ដើម្បីអនុវត្តរបៀបវារៈ ទីក្រុងប៉េកាំង+២៥ ខណៈពេលខិតខំប្រឹងប្រែងជាខ្លាំង ក្នុងការបញ្ជ្រាបយេនឌ័រនៅក្នុងសកម្មភាព, គោលនយោបាយ, និងផែនការអាកាសធាតុ ព្រមទាំងគាំទ្រនូវសកម្មភាពរួមរបស់សហគមន៍។យើងដឹងពីសម្ពាធដែលប្រឈមដោយអ្នកដែលងាយរងគ្រោះបំផុត ដោយសារការប្រែប្រួលអាកាសធាតុ និងការលំបាករបស់ពួកគេដែលត្រូវបានធ្វើឱ្យកាន់តែធ្ងន់ធ្ងរឡើងដោយជំងឺរាតត្បាតសកល។ យើងធ្វើការជិតស្និទ្ធជាមួយស្ត្រីនៅក្នុងសហគមន៍លើការស្តារឡើងវិញពីជំងឺកូវីដ១៩,ការទទួលស្គាល់សារសំខាន់នៃការស្តារបៃតងឡើងវិញ និងប្រកបដោយបរិយាប័ន្ន, ការបង្ការការត្រឡប់ទៅរកការអនុវត្តដែលគ្មាននិរន្តរភាព និងផុយស្រួយ, និងការធានាបាននូវសុវត្ថិភាព និងការត្រៀមខ្លួនកាន់តែប្រសើរ ចំពោះគ្រោះមហន្តរាយ និងហានិភ័យផ្សេងៗរួមទាំងការគំរាមកំហែងជាសកលទៅលើសុខភាពសាធារណៈ។

យើងជឿថានៅពេលដែលមនុស្សគ្រប់គ្នានៅគ្រប់ជ្រុងនៃសង្គមរបស់យើង ធ្វើសកម្មភាពលើការប្រែប្រួលអាកាសធាតុ យើងអាចកសាងជាមួយគ្នានូវពិភពលោក ដែលកាន់តែមានភាពធន់ និងនិរន្តរភាព។ នៅពេលដែលស្ត្រី និងក្មេងស្រីរួមគ្នាបង្កើតភាពជាសមូហភាព និងបង្កើតទំនួលខុសត្រូវរបស់ពួកគេដោយខ្លួនឯង សំឡេងរបស់ពួកគេត្រូវបានពង្រឹងអំណាច និងត្រូវបានគេស្តាប់ឮ ហើយសកម្មភាពរបស់ពួកគេត្រូវបានគេមើលឃើញនិងពង្រីកកាន់តែធំឡើង។យើងជឿជាក់យ៉ាងមុតមាំថា សកម្មភាពអាកាសធាតុអាចមានប្រសិទ្ធភាព នៅពេលដែលយើងទាំងអស់គ្នាខិតខំប្រឹងប្រែងអស់ពីសមត្ថភាពរបស់យើង រួមទាំងស្ត្រី និងបុរស, ក្មេងស្រី និងក្មេងប្រុស, មនុស្សជាតិទាំងអស់ ដោយមិនគិតពីទំនោរផ្លូវភេទ, អាយុ, ពិការភាព ឬមិនមានពិការភាព, និងពូជសាសន៍។ ដោយគ្មានការចូលរួមរបស់ស្ត្រី ក្នុងគ្រប់ផ្នែកនៃដំណើរការសម្រេចចិត្តដំណោះស្រាយដើម្បីកាត់បន្ថយផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ តែងតែនឹងមិនមានភាពគ្រប់គ្រាន់នោះឡើយ។

សៀវភៅណែនាំពីការបញ្ជ្រាបយេនឌ័រក្នុងការប្រែប្រួលអាកាសធាតុ និងការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ សម្រាប់អង្គការសង្គមស៊ីវិលនេះ គឺជា ជំហានសំខាន់មួយ ដើម្បីរៀបចំត្រៀមមនុស្សគ្រប់រូបជាពិសេសស្ត្រី និងក្មេងស្រីនៅកម្រិតមូលដ្ឋាន ឱ្យក្លាយជាអ្នកបង្កើតការផ្លាស់ប្តូរនៅក្នុងសកម្មភាពអាកាសធាតុ។

MOHAMMAD NACIRI
នាយកតំបន់
ការិយាល័យ UN Women ប្រចាំតំបន់អាស៊ី និងប៉ាស៊ីហ្វិក



## បុព្វកថា

ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ មិនមានភាពអព្យាក្រឹតយេនឌ័រទេ។ ភាពងាយរងគ្រោះដោយភាពខុសគ្នារវាងយេនឌ័រ កើតឡើងពីស្ថានភាពសង្គមរបស់ស្ត្រីក្នុងសង្គមលទ្ធភាពទទួលបានធនធានតិចនិងមានកម្រិត តំណាងមិនពេញលេញក្នុងដំណើររៀបចំ និងអភិវឌ្ឍន៍គោលនយោបាយ ក៏ដូចជាកម្រិតជំនាញ និងចំណេះដឹងទាប។ ផលប៉ះពាល់មិនសមាមាត្រនៃការប្រែប្រួលអាកាសធាតុលើស្ត្រីនិងក្មេងស្រីនៅក្នុងគ្រប់រូបភាពចម្រុះរបស់ពួកគេរួមមានកង្វះលទ្ធភាពទទួលបានសេវាសុខភាពផ្លូវភេទនិងសុខភាពបន្តពូជការកើនឡើងនៃអាពាហ៍ពិពាហ៍មុនអាយុរៀបការ អាពាហ៍ពិពាហ៍កុមារ និងអាពាហ៍ពិពាហ៍ដោយបង្ខំ អំពើហិង្សាផ្អែកលើយេនឌ័រ គម្លាត និងការផាត់ចេញនៃសង្គម និងសេដ្ឋកិច្ច ឧបសគ្គក្នុងការទទួលបានការអប់រំ និងមានកត្តាពាក់ព័ន្ធជាច្រើនទៀត។ ផលប៉ះពាល់ទាំងនេះ គឺជាការបង្ហាញពីវិសមភាពយេនឌ័រ ដែលកាន់តែធ្ងន់ធ្ងរឡើងដោយផ្អែកលើដំណោះស្រាយអាកាសធាតុដែលមិនមានការមើលឃើញឬយល់ដឹងអំពីយេនឌ័រ។

វិសមភាពពិតជាចាក់ឫសយ៉ាងជ្រៅ ជាពិសេសក្នុងប្រទេសកំពុងអភិវឌ្ឍន៍។ទន្ទឹមនឹងនេះមានភស្តុតាងគ្រប់គ្រាន់ដើម្បីបង្ហាញថាការពង្រឹងភាពអង់អាចដល់ស្ត្រី ក៏ពង្រីកវិសាលភាពនៃការពង្រឹងភាពអង់អាចដល់គ្រួសារ និងសហគមន៍របស់ពួកគេ ដោយហេតុនេះជួយពួកគេសម្របខ្លួនទៅនឹងការប្រែប្រួលអាកាសធាតុ។ យើងត្រូវតែជួយអភិវឌ្ឍអ្នកដឹកនាំជាស្ត្រីនៅក្នុងសកម្មភាពមូលដ្ឋាន កសាងជំនាញ និងសមត្ថភាពរបស់ពួកគេ និងផ្តល់សំឡេងនិងការគាំទ្រដល់ការចូលរួមរបស់ពួកគេក្នុងការបង្កើតគោលនយោបាយ។ ស្ត្រី គឺជាអ្នកបង្កើតការផ្លាស់ប្តូរ ដើរតួនាទីយ៉ាងសំខាន់ក្នុងសកម្មភាពមូលដ្ឋានដើម្បីកាត់បន្ថយនិងគ្រប់គ្រងហានិភ័យនៃអាកាសធាតុនិងគ្រោះមហន្តរាយហើយយើងត្រូវការអង្គការសង្គមស៊ីវិលដែលត្រូវបានពង្រឹងសិទ្ធិអំណាច ដើម្បីជួយសម្រេចគោលដៅនេះ និងធ្វើឱ្យវាក្លាយជាការពិត។

ការងារនិងការស្រាវជ្រាវរបស់យើងជាមួយអង្គការសង្គមស៊ីវិលនៅអាស៊ីខាងត្បូង និងអាស៊ីអាគ្នេយ៍ បង្ហាញថា អង្គការសង្គមស៊ីវិល មានការយល់ដឹងអំពីគម្លាតយេនឌ័រនិងវិសមភាពយេនឌ័រក្នុងការប្រែប្រួលអាកាសធាតុ និងគោលនយោបាយ និងកម្មវិធីកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ។ ទោះជាយ៉ាងណាក៏ដោយ ពួកគេជួបប្រទះនឹងឧបសគ្គសមត្ថភាពជាច្រើន ក្នុងការបញ្ជ្រាបយេនឌ័រ ទាំងនៅក្នុងសកម្មភាពកម្រិតគម្រោងរបស់ពួកគេ ឬក្នុងការតស៊ូមតិនៅកម្រិតមូលដ្ឋាន និងថ្នាក់ក្រោម/ជាតិ។ ការបំពេញគម្លាតសមត្ថភាពទាំងនេះនៃអង្គការសង្គមស៊ីវិលអាចពង្រឹងទំនាក់ទំនងរវាងការបញ្ជ្រាបយេនឌ័រនៅកម្រិតផ្សេងៗគ្នាហើយថែមទាំងបង្ហាញរូបភាពនៃសកម្មភាពនៅមូលដ្ឋានដែលកាន់តែមានប្រសិទ្ធភាពជាងមុនពាក់ព័ន្ធនឹងបញ្ហាមូលដ្ឋានក្នុងអំឡុងពេលបង្កើតគោលនយោបាយនៅគ្រប់កម្រិត។

សៀវភៅណែនាំបណ្តុះបណ្តាលនេះគឺជាសមិទ្ធផលចំណេះដឹងដ៏គ្រប់ជ្រុងជ្រោយ ដែលត្រូវបានបង្កើតឡើងនៅក្នុងគម្រោង Empower។ វាគឺជាលទ្ធផលនៃការវាយតម្លៃតម្រូវការលម្អិតដែលបានធ្វើឡើងនៅក្នុងប្រទេសសាកល្បងចំនួនបីគឺប្រទេសបង់ក្លាដែស កម្ពុជា និងវៀតណាម ដែលយើងបានទាក់ទងនិងធ្វើការជាមួយអង្គការសង្គមស៊ីវិលមួយចំនួនដើម្បីកំណត់គម្លាតសមត្ថភាព និងតម្រូវការរបស់ពួកគេ។ សៀវភៅណែនាំនេះត្រូវបានរចនាឡើង សម្រាប់ការប្រើប្រាស់ ដោយអង្គការសង្គមស៊ីវិលក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក ដែលធ្វើការជាមួយសហគមន៍ស្តីពីយេនឌ័រ ភាពធន់នឹងការប្រែប្រួលអាកាសធាតុ សិទ្ធិមនុស្ស និងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ។ វាគ្របដណ្តប់លើទស្សនទានសំខាន់ៗបញ្ហាក្របខណ្ឌគោលនយោបាយ និងការអនុវត្តនៅក្នុងដែនវិស័យទាំងនេះ ហើយអនុវត្តវិធីសាស្ត្រតម្រង់ទិសលើការអនុវត្តជាក់ស្តែងក្នុងការសិក្សាដែលអាចធ្វើឡើងក្នុងស្ថានភាពជីវិតពិតដើម្បីបង្កើនការសម្រេចចិត្តពង្រឹងភាពធន់របស់ស្ត្រីក្នុងសហគមន៍ តស៊ូមតិសម្រាប់ការបញ្ជ្រាបយេនឌ័រ និងរចនាគម្រោងឆ្លើយតបនឹងយេនឌ័រ។ ការគ្របដណ្តប់នៃឧទាហរណ៍ និងករណីសិក្សាដែលមានក្នុងសៀវភៅណែនាំនេះគឺមិនផ្តោតលើតែប្រទេសសាកល្បងប៉ុណ្ណោះទេ ដែលធ្វើឱ្យវាមានភាពពាក់ព័ន្ធសម្រាប់ការប្រើប្រាស់ក្នុងបរិបទអាស៊ីប៉ាស៊ីហ្វិកកាន់តែទូលំទូលាយ។

តាមរយៈសៀវភៅណែនាំនេះយើងក៏ផ្តោតសំខាន់ទៅលើសិទ្ធិនិងសុខភាពផ្លូវភេទនិងសុខភាពបន្តពូជជាបញ្ហាសំខាន់ដែលជារឿយៗមិនទទួលបានការយកចិត្តទុកដាក់នៅក្នុងសមីការនៃការអភិវឌ្ឍនោះឡើយ។ការមានស្វ័យភាពនៃរាងកាយ និងលទ្ធភាពទទួលបានសេវាសុខភាពផ្លូវភេទ និងសុខភាពបន្តពូជ គឺមានសារសំខាន់ចំពោះសមភាពយេនឌ័រ និងសិទ្ធិសុខភាពដូច្នេះហើយជាមូលដ្ឋានគ្រឹះក្នុងការកសាងសង្គមដែលធន់នឹងអាកាសធាតុ។ គោលបំណងរយៈពេលវែងរបស់យើង គឺដើម្បីជំរុញឱ្យមានការប្រើប្រាស់យ៉ាងទូលំទូលាយនៃសៀវភៅណែនាំនេះក្នុងការលើកកម្ពស់សកម្មភាពអាកាសធាតុដែលឆ្លើយតបនឹងយេនឌ័រនៅកម្រិតមូលដ្ឋាន និងពង្រឹងភាពអង់អាចដល់ស្ត្រី ជាអ្នកបង្កើតការផ្លាស់ប្តូរនៅក្នុងសង្គម។ យើងសង្ឃឹមថា អង្គការសង្គមស៊ីវិល នឹងប្រើប្រាស់សៀវភៅណែនាំនេះជាអត្ថប្រយោជន៍សម្រាប់ការជំរុញការងាររបស់ពួកគេនៅក្នុងសកម្មភាពនៃភាពធន់នឹងអាកាសធាតុ ដែលឆ្លើយតបនឹងយេនឌ័រ។

SIVANANTHI THANENTHIRAN
នាយកប្រតិបត្តិ
មជ្ឈមណ្ឌលធនធាន និងស្រាវជ្រាវអាស៊ីប៉ាស៊ីហ្វិកសម្រាប់ស្ត្រី ( ARROW )

# អំពីសៀវភៅណែនាំ

សៀវភៅណែនាំស្តីពីការបណ្តុះបណ្តាលគ្រូបង្គោលនេះ ត្រូវបានរៀបចំឡើងសម្រាប់អង្គការសង្គមស៊ីវិល (CSOs) នៅអាស៊ីដែលធ្វើការងារជាមួយសហគមន៍លើផ្នែកយេនឌ័រ ភាពធន់នឹងការប្រែប្រួលអាកាសធាតុ និងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ។ សៀវភៅណែនាំនេះ មានគោលដៅលើកកម្ពស់ការយល់ដឹងអំពីទំនាក់ទំនងយេនឌ័រ និងការប្រែប្រួលអាកាសធាតុ ជំនាញ និងសមត្ថភាពរបស់ CSOs ដើម្បីពង្រឹងភាពធន់របស់ស្ត្រីផ្អែកលើសហគមន៍ និងការបន្សាំខ្លួនទៅនឹងការប្រែប្រួលអាកាសធាតុ។ គោលបំណងរយៈពេលវែងគឺដើម្បីលើកកម្ពស់សកម្មភាពភាពធន់នឹងអាកាសធាតនៅមូលដ្ឋាន ដោយផ្អែកលើទិដ្ឋភាពសមភាពយេនឌ័រជាអាទិភាព។

# បញ្ជីពាក្យកាត់

| | |
|---|---|
| °C | អង្សាសេ |
| 100 RC | ១០០ទីក្រុងដែលមានភាពធន់ |
| ACCCRN | បណ្តាញភាពធន់នឹងការប្រែប្រួលអាកាសធាតុទីក្រុងនៅអាស៊ី |
| ADB | ធនាគារអភិវឌ្ឍន៍អាស៊ី |
| AE | អង្គភាពដែលត្រូវបានទទួលស្គាល់ |
| AF | មូលនិធិបន្សាំ |
| APF | ក្របខ័ណ្ឌគោលនយោបាយបន្សាំ |
| APR | របាយការណ៍សកម្មភាពប្រចាំឆ្នាំ |
| APRCEM | យន្តការចូលរួមរបស់អង្គការសង្គមស៊ីវិលក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក |
| AR | របាយការណ៍វាយតម្លៃ (ក្រុមការងារអន្តររដ្ឋាភិបាលស្តីពីការប្រែប្រួលអាកាសធាតុ) |
| ARC | កាកបាទក្រហមអូស្ត្រាលី |
| ARROW | មជ្ឈមណ្ឌលធនធាន និងស្រាវជ្រាវអាស៊ីប៉ាស៊ីហ្វិកដើម្បីស្ត្រី |
| ASAP | ការបន្សាំសម្រាប់កម្មវិធីកសិកម្មខ្នាតតូច |
| ASHA | សកម្មជនសុខភាពសង្គមដែលមានការទទួលស្គាល់ |
| BCAS | មជ្ឈមណ្ឌលសម្រាប់ការសិក្សាភាពជឿនលឿនបង់ក្លាដែស |
| BCCRF | មូលនិធិភាពធន់នឹងការប្រែប្រួលអាកាសធាតុបង់ក្លាដែស |
| BCCSAP | យុទ្ធសាស្ត្រ និងផែនការសកម្មភាពការប្រែប្រួលអាកាសធាតុបង់ក្លាដែស |
| BCCT | មូលនិធិការប្រែប្រួលអាកាសធាតុបង់ក្លាដែស |
| BCCTF | ហិរញ្ញបទានមូលនិធិការប្រែប្រួលអាកាសធាតុបង់ក្លាដែស |
| BCFA | អាជ្ញាធរមូលនិធិការប្រែប្រួលអាកាសធាតុបង់ក្លាដែស |
| BPfA | សេចក្តីប្រកាស និងវេទិកាទីក្រុងប៉េកាំងដើម្បីសកម្មភាព |
| CAG | ក្រុមសកម្មភាពសហគមន៍ |
| CBA | ការបន្សាំផ្អែកលើសហគមន៍ |
| CBD | អនុសញ្ញាស្តីពីជីវចម្រុះ |
| CBO | អង្គការសហគមន៍មូលដ្ឋាន |
| CBVAT | ឧបករណ៍ប៉ាន់ប្រម៉ាណភាពងាយរងគ្រោះសហគមន៍មូលដ្ឋាន |
| CC | ការប្រែប្រួលអាកាសធាតុ |
| CCA | ការបន្សាំនឹងការប្រែប្រួលអាកាសធាតុ |
| CCAFS | ការប្រែប្រួលអាកាសធាតុ កសិកម្ម និងសន្តិសុខស្បៀង |
| CCCO | ការិយាល័យសម្របសម្រួលការប្រែប្រួលអាកាសធាតុ (ទីក្រុងដាណាង ប្រទេសវៀតណាម) |
| CCCSP | ផែនការយុទ្ធសាស្ត្រស្តីពីការប្រែប្រួលអាកាសធាតុកម្ពុជា |
| CCDRR | ការប្រែប្រួលអាកាសធាតុ និងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ |
| ccGAP | ការប្រែប្រួលអាកាសធាតុ និងផែនការសកម្មភាពយេនឌ័រ |
| CCS | បុព្វហេតុ ផលវិបាក និងដំណោះស្រាយ (ក្របខ័ណ្ឌការងារ) |
| CEDAW | អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ |
| CERF | មូលនិធិឆ្លើយតបគ្រោះអាសន្ន ថ្នាក់កណ្តាលរបស់អង្គការសហប្រជាជាតិ |
| CETF | ក្របខ័ណ្ឌឃ្លាំមើលការចំណាយលើអាកាសធាតុ |
| CFF | ក្របខ័ណ្ឌសារពើពន្ធអាកាសធាតុ |
| CFU | ការធ្វើបច្ចុប្បន្នភាពហិរញ្ញវត្ថុអាកាសធាតុ |
| CFW | ប្រាក់សម្រាប់ការងារ |
| CIDA | ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិកាណាដា |
| CIF | មូលនិធិវិនិយោគលើអាកាសធាតុ |
| COP | សន្និសីទ រដ្ឋភាគី |
| CPEIR | ការពិនិត្យស្ថាប័ន និងការចំណាយសាធារណៈលើការងារអាកាសធាតុ |
| CPI | គំនិតផ្តួចផ្តើមគោលនយោបាយអាកាសធាតុ |

| | |
|---|---|
| CrFS | សាលាជំនាញភាពធន់នឹងអាកាសធាតុ |
| CSA | កសិកម្មឆ្លាតវៃដែលធន់នឹងអាកាសធាតុ |
| CSOs | អង្គការសង្គមស៊ីវិល |
| CTF | មូលនិធិបច្ចេកវិទ្យាស្អាត |
| CVA | ការប៉ាន់ប្រម៉ានភាពងាយរងគ្រោះ និងសមត្ថភាព (ក្របខ័ណ្ឌការងារ) |
| DAE | អង្គភាពចូលដំណើរការដោយផ្ទាល់ |
| DALY | អាយុកាលនៃជីវិតពិការភាពដែលត្រូវបានកែសម្រួល |
| DFAT | នាយកដ្ឋានកិច្ចការបរទេស និងពាណិជ្ជកម្ម (អូស្ត្រាលី) |
| DFID | នាយកដ្ឋានអភិវឌ្ឍន៍អន្តរជាតិ |
| DFIs | ស្ថាប័នហិរញ្ញវត្ថុអភិវឌ្ឍន៍ |
| DRM | ការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ |
| DRR | ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ |
| EbA | ការបន្សាំផ្អែកលើប្រព័ន្ធអេកូឡូស៊ី |
| EGI | សន្ទស្សន៍បរិស្ថាន និងយេនឌ័រ |
| EIAs | ការវាយតម្លៃផលប៉ះពាល់បរិស្ថាន |
| EPSC | ការត្រៀមបង្ការទប់ទល់នឹងគ្រោះរញ្ជួយដីដើម្បីសហគមន៍កាន់តែមានសុវត្ថិភាព |
| ESS | ការការពារបរិស្ថាន និងសង្គម |
| EU | សហភាពអឺរ៉ុប |
| FAO | អង្គការស្បៀងអាហារ និងកសិកម្មរបស់អង្គការសហប្រជាជាតិ |
| FCPF | មូលនិធិកាបូនព្រៃឈើ |
| FGDs | កិច្ចពិភាក្សាក្រុម |
| FIP | កម្មវិធីវិនិយោគលើព្រៃឈើ |
| GACSA | សម្ព័ន្ធសកលដើម្បីកសិកម្មឆ្លាតវៃដែលធន់នឹងអាកាសធាតុ |
| GAD | យេនឌ័រ និងការអភិវឌ្ឍ |
| GAM | ម៉ាទ្រិចវិភាគយេនឌ័រ |
| GAP | ផែនការសកម្មភាពយេនឌ័រ |
| GBS | របាយការណ៍ថវិកាយេនឌ័រ |
| GBV | អំពើហិង្សាផ្អែកលើយេនឌ័រ |
| GCBS | យេនឌ័រ និងរបាយការណ៍ថវិកាអាកាសធាតុ |
| GCCA | សម្ព័ន្ធការប្រែប្រួលអាកាសធាតុសកល |
| GCCC | គណៈកម្មាធិការយេនឌ័រ និងការប្រែប្រួលអាកាសធាតុ (កម្ពុជា) |
| GCCI | គំនិតផ្តួចផ្តើមសម្រាប់ការប្រែប្រួលអាកាសធាតុសកល (សហរដ្ឋអាមេរិក) |

| | |
|---|---|
| GCF | មូលនិធិអាកាសធាតុបៃតង |
| GCPF | មូលនិធិភាពជាដៃគូអាកាសធាតុសកល |
| GCVCA | ការប៉ាន់ប្រម៉ានភាពងាយរងគ្រោះអាកាសធាតុ និងសមត្ថភាពដោយផ្អែកលើយេនឌ័រ |
| GDP | ផលិតផលក្នុងស្រុកសរុប |
| GEF | មូលនិធិបរិស្ថានពិភពលោក |
| GESI | បរិយាបន្នសមភាពយេនឌ័រ និងសង្គម |
| GFDRR | មូលនិធិសកលសម្រាប់ការកាត់បន្ថយគ្រោះមហន្តរាយ និងការស្តារឡើងវិញ |
| GGCA | សម្ព័ន្ធយេនឌ័រ និងអាកាសធាតុសកល |
| GHG | ឧស្ម័នផ្ទះកញ្ចក់ |
| GIZ | កិច្ចសហប្រតិបត្តិការបច្ចេកទេសអាល្លឺម៉ង់ |
| GMMX | ម៉ាទ្រិចតាមដានយេនឌ័រ |
| GNA | ការប៉ាន់ប្រម៉ាណតម្រូវការយេនឌ័រ |
| GoB | រដ្ឋាភិបាលបង់ក្លាដែស |
| GoI | រដ្ឋាភិបាលឥណ្ឌា |
| GoN | រដ្ឋាភិបាលនេប៉ាល់ |
| GRAS | មាត្រដ្ឋានប៉ាន់ប្រម៉ាណដែលឆ្លើយតបនឹងតម្រូវការយេនឌ័រ |
| GRB | ការរៀបចំថវិកាដែលឆ្លើយតបនឹងតម្រូវការយេនឌ័រ |
| HBS | Heinrich-Böll-Stiftung |
| HFA | ក្របខ័ណ្ឌការងារ Hyogo ដើម្បីសកម្មភាព |
| HH | គ្រួសារ |
| HIEWS | ប្រព័ន្ធប្រកាសឲ្យដឹងមុនស្តីពីព័ត៌មានសុខភាព |
| HIMAP | ភាពជាដៃគូបន្សាំនឹងតំបន់ភ្នំខ្ពស់ |
| HRBA | វិធីសាស្ត្រផ្អែកលើសិទ្ធិមនុស្ស |
| IAE | អង្គភាពចូលដំណើរការជាអន្តរជាតិ |
| IASC | គណៈកម្មាធិការអចិន្ត្រៃយ៍អន្តរទីភ្នាក់ងារ |
| ICCCAD | មជ្ឈមណ្ឌលអន្តរជាតិដើម្បីការប្រែប្រួលអាកាសធាតុ និងអភិវឌ្ឍន៍ (បង់ក្លាដែស) |
| ICPD | សន្និសីទអន្តរជាតិស្តីពីប្រជាជន និងអភិវឌ្ឍន៍ |
| IDPs | ជនចំណាកស្រុកក្នុងប្រទេស |
| IFRC | សហព័ន្ធអន្តរជាតិកាកបាទក្រហម និងអឌ្ឍចន្ទក្រហម |
| IIED | វិទ្យាស្ថានអន្តរជាតិដើម្បីបរិស្ថាន និងអភិវឌ្ឍន៍ |
| ILO | អង្គការពលកម្មអន្តរជាតិ |

| | |
|---|---|
| INDCs | ការចូលរួមចំណែករបស់ជាតិ ដើម្បីអនុវត្តអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ |
| IPCC | ក្រុមការងារអន្តររដ្ឋាភិបាលស្តីពីការប្រែប្រួលអាកាសធាតុ |
| IPs | ផែនការវិនិយោគ |
| ISET | វិទ្យាស្ថានដើម្បីផ្លាស់ប្តូរសង្គម និងបរិស្ថាន |
| IUCN | សហភាពអន្តរជាតិដើម្បីការអភិរក្សធម្មជាតិ |
| IVRS | សេវាកម្មឆ្លើយតបជាសំឡេង |
| KfW | ធនាគារអភិវឌ្ឍន៍អាល្លឺម៉ង់ |
| KKPKP | Kagad Kach Patra Kashtakari Panchayat |
| LAPAs | ផែនការសកម្មភាពបន្សាំនៅមូលដ្ឋាន |
| LDCF | មូលនិធិប្រទេសអភិវឌ្ឍន៍តិចតួច |
| LDCs | ប្រទេសអភិវឌ្ឍន៍តិចតួច |
| LGBTIQ | ក្រុមអ្នកស្រលាញ់ភេទដូចគ្នា LGBTIQ |
| LNOB | គ្មានអ្នកណាម្នាក់ត្រូវបានទុកចោល |
| LWPG | កម្មវិធីការងារក្រុងលីម៉ាស្តីពីយេនឌ័រ |
| M & E | ការតាមដាន និងវាយតម្លៃ |
| McRAM | យន្តការប៉ាន់ប្រម៉ាណហានិភ័យពហុវិស័យ |
| MDB | ធនាគារអភិវឌ្ឍន៍ពហុភាគី |
| MDF | ហិរញ្ញប្បទានមូលនិធិឥតសំណងពហុភាគី |
| MEA | ការប៉ាន់ប្រម៉ាណប្រព័ន្ធអេកូឡូស៊ីសហសវត្សរ៍ |
| MIE | អង្គភាពអនុវត្តពហុភាគី |
| MNC | កិច្ចសហប្រតិបត្តិការអន្តរជាតិ |
| MoF | ក្រសួងហិរញ្ញវត្ថុ |
| MoWA | ក្រសួងកិច្ចការនារី |
| MRCS | សង្គមកាកបាទក្រហមមីយ៉ាន់ម៉ា |
| NAMA | សកម្មភាពជាតិកាត់បន្ថយសមស្រប |
| NAPA | ផែនការសកម្មភាពជាតិបន្សាំនឹងការប្រែប្រួលអាកាសធាតុ |
| NAPCC | ផែនការសកម្មភាពជាតិស្តីពីការប្រែប្រួលអាកាសធាតុ (ឥណ្ឌា) |
| NAPs | ផែនការបន្សាំជាតិ |
| NDA | អាជ្ញាធរជាតិទទួលបន្ទុក |
| NDCs | ការចូលរួមចំណែករបស់ជាតិដើម្បីអនុវត្តអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ |
| NDMA | ទីភ្នាក់ងារជាតិគ្រប់គ្រងគ្រោះមហន្តរាយ |
| NGOs | អង្គការមិនមែនរដ្ឋាភិបាល |
| NIE | អង្គភាពអនុវត្តថ្នាក់ជាតិ |

| | |
|---|---|
| NTFP | អនុផលព្រៃឈើ |
| OCHA | ការិយាល័យអង្គការសហប្រជាជាតិទទួលបន្ទុកសម្របសម្រួលកិច្ចការមនុស្សធម៌ |
| ODA | ជំនួយអភិវឌ្ឍន៍ក្រៅប្រទេស |
| ODI | វិទ្យាស្ថានអភិវឌ្ឍន៍ក្រៅប្រទេស |
| OECD | អង្គការកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍន៍ |
| OHCHR | ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស |
| PCP | ការរៀបចំផែនការយុទ្ធនាការដែលមានការចូលរួម |
| PCVA | ការវិភាគសមត្ថភាព និងភាពងាយរងគ្រោះដែលមានការចូលរួម |
| PKSF | មូលនិធិ Palli Karma-Sahayak |
| PLA | ការរៀនសូត្រ និងសកម្មភាពដែលមានការចូលរួម |
| PNPM | កម្មវិធីជាតិ Nasional Pemberdayaan Mandiri |
| PPCR | កម្មវិធីសាកល្បងស្តីពីភាពធន់នឹងអាកាសធាតុ |
| PRA | ការវាយតម្លៃនៅជនបទដែលមានការចូលរួម |
| PTSD | ជំងឺស្ត្រេសក្រោយប៉ះទង្គិចផ្លូវចិត្ត |
| RB | ការកសាងភាពធន់ |
| REDD | ការកាត់បន្ថយការបញ្ចេញឧស្ម័នពីការបាត់បង់ និងរេចរឹលព្រៃឈើ |
| REE-CALL | ភាពធន់តាមរយៈការផ្តល់អំណាចសេដ្ឋកិច្ច ការបន្សាំនឹងអាកាសធាតុ ភាពជាអ្នកដឹកនាំ និងការរៀនសូត្រ |
| RGC | រាជរដ្ឋាភិបាលកម្ពុជា |
| RIE | អង្គភាពអនុវត្តថ្នាក់តំបន់ |
| SADDD | ទិន្នន័យបែងចែកតាមភេទ អាយុ និងពិការភាព |
| SAN | បណ្តាញប្រឹក្សាយោបល់ភាគីពាក់ព័ន្ធ |
| SAP | គម្រោងសាកល្បងលើដំណើរការអនុម័តសាមញ្ញ |
| SCCF | មូលនិធិការប្រែប្រួលអាកាសធាតុពិសេស |
| SCF | មូលនិធិអាកាសធាតុយុទ្ធសាស្ត្រ |
| SDG | គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព |
| SFVC | ការប្តេជ្ញាចិត្តដោយស្ម័គ្រចិត្តចំពោះក្របខ័ណ្ឌទីក្រុងសេនដាយ |
| SGP | កម្មវិធីជំនួយខ្នាតតូច |
| SIDA | ទីភ្នាក់ងារអភិវឌ្ឍន៍ និងកិច្ចសហប្រតិបត្តិការអន្តរជាតិស៊ុយអែត |
| SMART | ជាក់លាក់ អាចវាស់វែងបាន អាចសម្រេចបាន ជាប់ពាក់ព័ន្ធ និងពេលវេលាជាក់លាក់ |
| SME | សហគ្រាសខ្នាតតូច និងមធ្យម |
| SREP | កម្មវិធីពង្រីកថាមពលកកើតឡើងវិញ |

| | |
|---|---|
| SRHR | សិទ្ធិសុខភាពផ្លូវភេទ និងសុខភាពបន្តពូជ |
| SURE | ការពង្រឹងភាពធន់នៅទីក្រុង និងការចូលរួម |
| SWOT | ភាពខ្លាំង ចំណុចខ្សោយ ឱកាស ការគំរាមកំហែង |
| TMI | វិទ្យាស្ថានភ្នំ |
| ULBs | អង្គភាពនៅមូលដ្ឋានក្នុងទីក្រុង |
| UN | អង្គការសហប្រជាជាតិ |
| UN DESA | នាយកដ្ឋានកិច្ចការសេដ្ឋកិច្ច និងសង្គមអង្គការសហប្រជាជាតិ |
| UN Women | អង្គភាពអង្គការសហប្រជាជាតិលើកកម្ពស់សមភាពយេនឌ័រ និងផ្តល់ភាពអង់អាចដល់ស្ត្រី |
| UNCCD | អនុសញ្ញាអង្គការសហប្រជាជាតិដើម្បីប្រយុទ្ធប្រឆាំងហោស្ថានកម្ម |
| UNCED | សន្និសីទអង្គការសហប្រជាតិស្តីពីបរិស្ថាន និងអភិវឌ្ឍន៍ |
| UNCHE | សន្និសីទអង្គការសហប្រជាតិស្តីពីបរិស្ថានមនុស្ស |
| UNDP | កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ |
| UNDRR | ការិយាល័យអង្គការសហប្រជាជាតិទទួលបន្ទុកការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ |
| UNECE | គណៈកម្មការសេដ្ឋកិច្ចអង្គការសហប្រជាជាតិសម្រាប់តំបន់អឺរ៉ុប |
| UNEP | កម្មវិធីបរិស្ថានអង្គការសហប្រជាជាតិ |
| UNFCCC | អនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ |
| UNFPA | មូលនិធិប្រជាជនអង្គការសហប្រជាជាតិ |
| UNIFEM | មូលនិធិអភិវឌ្ឍន៍អង្គការសហប្រជាជាតិសម្រាប់ស្ត្រី |
| UNISDR | យុទ្ធសាស្ត្រអន្តរជាតិអង្គការសហប្រជាជាតិសម្រាប់ការកាត់បន្ថយគ្រោះមហន្តរាយ |
| UNSDG | គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពអង្គការសហប្រជាជាតិ |
| USAID | ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ |
| USD | ដុល្លារសហរដ្ឋអាមេរិក |
| USP | កន្លែងលក់ |
| VDC | គណៈកម្មាធិការគ្រោះមហន្តរាយភូមិ |
| VDMC | គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយភូមិ |
| VRA | ការប៉ាន់ប្រម៉ាណការកាត់បន្ថយភាពងាយរងគ្រោះ |
| VTRC | គណៈកម្មាធិការស្តារភូមិ |
| WASH | ទឹក អនាម័យបរិស្ថាន និងអនាម័យខ្លួនប្រាណ |
| WCC | សន្និសីទអាកាសធាតុពិភពលោក |
| WDF | មូលនិធិគណៈប្រតិភូស្ត្រី |
| WDR | របាយការណ៍អភិវឌ្ឍន៍ពិភពលោក |
| WEDO | អង្គការស្ត្រីដើម្បីបរិស្ថាន និងអភិវឌ្ឍន៍ |
| WGC | មជ្ឈមណ្ឌលស្ត្រី និងយេនឌ័រ |
| WGWLO | ក្រុមការងារទទួលបន្ទុកស្ត្រី និងកម្មសិទ្ធិដីធ្លី |
| WHO | អង្គការសុខភាពពិភពលោក |
| WID | ស្ត្រីក្នុងកិច្ចអភិវឌ្ឍន៍ |
| WIL | ស្ត្រីក្នុងភាពជាអ្នកដឹកនាំ |
| WMG | ក្រុមស្ត្រី (Women's Major Group) |
| WOCAN | អង្គការស្ត្រីដើម្បីការផ្លាស់ប្តូរការគ្រប់គ្រងកសិកម្ម និងធនធានធម្មជាតិ |
| WOREC | មជ្ឈមណ្ឌលស្តារនីតិសម្បទាស្ត្រី |
| WRI | វិទ្យាស្ថានធនធានពិភពលោក |
| WRI | សន្ទស្សន៍ភាពធន់របស់ស្ត្រី |
| WU | សហជីពស្ត្រី (វៀតណាម) |

## សេចក្តីផ្តើម

ការប្រែប្រួលអាកាសធាតុត្រូវបានទទួលស្គាល់ថាជាការគម្រាមកំហែងសកល(របាយការណ៍ក្រុមការងារអន្តររដ្ឋាភិបាលស្តីពីការប្រែប្រួលអាកាសធាតុ ទី៥ ឆ្នាំ២០១៥)។ ប្រទេសភាគ ច្រើននៅអាស៊ីងាយរងគ្រោះនឹងហានិភ័យអាកាសធាតុនិងគ្រោះមហន្តរាយ ហើយប្រទេសជាច្រើនទៀតនៅក្នុងតំបន់ ស្ថិតក្នុងចំណាត់ថ្នាក់កំពូលនៃប្រទេសដែលងាយរងគ្រោះខ្លាំងបំផុតនៅលើពិភពលោក យោងតាមរបាយការណ៍ប៉ាន់ប្រម៉ាណហានិភ័យសកល (របាយការណ៍ក្រុមការងារអន្តររដ្ឋាភិបាលស្តីពីការប្រែប្រួលអាកាសធាតុទី៥៖អាស៊ីឆ្នាំ២០១៤)។នៅថ្នាក់សកលនិងថ្នាក់ជាតិអ្នកបង្កើតគោលនយោបាយ អ្នកវិទ្យាសាស្ត្រ អ្នកស្រាវជ្រាវ និងអ្នកតស៊ូមតិសង្គមស៊ីវិលកំពុងធ្វើការងារ ដើម្បីឆ្ពោះទៅរកការបង្កើតផែនការសកម្មភាពកាត់បន្ថយ និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ។ ជាកុសល រហូតមកទល់នឹងប៉ុន្មានឆ្នាំចុងក្រោយនេះ ស្ត្រីជាច្រើនពុំមានវត្តមានធ្វើជាតួអង្គសំខាន់នៅក្នុងការចរចាអំពីអាកាសធាតុទេ ហើយការពិចារណាលើយេនឌ័រក្នុងការសម្រេចចិត្ត ក៏នៅតែពុំមែនជាអាទិភាព សម្រាប់រដ្ឋាភិបាលមួយចំនួន។

វាមានភាពចាំបាច់ក្នុងការដាក់បញ្ចូលការពិចារណាលើយេនឌ័រ និងវិធីសាស្ត្រ ឆ្លើយតបទៅនឹងយេនឌ័រទៅក្នុងការធ្វើផែនការ និងការអនុវត្តភាពធន់នឹងការប្រែប្រួលអាកាសធាតុព្រមទាំងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ។ កិច្ចការនេះ អាចមានបញ្ចូលទាំងការប៉ាន់ប្រម៉ាណហានិភ័យអាកាសធាតុផ្តើមចេញពីទស្សនៈយេនឌ័រ យន្តការ ការស្តាប់ឮពីទស្សនៈឬគំនិតរបស់បុរស និងស្ត្រី ការទទួលស្គាល់សិទ្ធិស្មើគ្នារបស់បុរសនិងស្ត្រីក្នុងនាមជាភាគី ពាក់ព័ន្ធក្នុងការរៀបចំផែនការ និងដំណើរការសម្រេចចិត្ត ការចែករំលែកដោយសមធម៌នូវអត្ថប្រយោជន៍នៃហិរញ្ញវត្ថុអាកាសធាតុនិងអាទិភាពសកម្មភាព ក៏ដូចជាការតាមដាន និងវាយតម្លៃការឆ្លើយតបនឹងយេនឌ័រ។ អង្គការសង្គមស៊ីវិលមានតួនាទីចម្បងក្នុងការជួយជំរុញការងារទាំងនេះ នៅគ្រប់កម្រិតនៃការសម្រេចចិត្តពាក់ព័ន្ធនឹងភាពធន់នឹងអាកាសធាតុ (UN Women ឆ្នាំ២០១៦)។

ម៉ូឌុលនេះត្រូវបានរៀបចំឡើងដោយផ្តោតលើតួនាទីដ៏សំខាន់របស់អង្គការសង្គមស៊ីវិល ជាពិសេសអង្គការសង្គមស៊ីវិល ទាំងឡាយណា ដែលកំពុងធ្វើការងារលើផ្នែកយេនឌ័រ និងសិទ្ធិស្ត្រី ដើម្បីស្វែងយល់អំពីសារៈសំខាន់នៃការបញ្ជ្រាបយេនឌ័រទៅក្នុងគោលនយោបាយ កម្មវិធី និងថវិកាស្តីពីអាកាសធាតុ នៅថ្នាក់តំបន់ ថ្នាក់ជាតិ និង ថ្នាក់មូលដ្ឋាន។

## គោលបំណង

គោលបំណងសំខាន់នៃសៀវភៅណែនាំនេះគឺដើម្បីលើកកម្ពស់ការយល់ដឹងអំពី ទំនាក់ទំនងយេនឌ័រ និងការប្រែប្រួលអាកាធាតុ ជំនាញនិងសមត្ថភាពនៃអង្គការសង្គមស៊ីវិលដើម្បីពង្រឹងភាពធន់របស់ស្ត្រីនៅសហគមន៍ និងការបន្សាំ នឹងការប្រែប្រួលអាកាសធាតុ។ អត្ថប្រយោជន៍ជាក់ស្តែងនៃការយល់ដឹងនាំងនេះ គឺជាការលើកកម្ពស់សកម្មភាពភាពអាកាសធាតុនៅមូលដ្ឋានដោយផ្តោតលើទស្សនៈ សមភាពយេនឌ័រជាអាទិភាព។ ជាមួយនឹង ទស្សនៈនេះ សៀវភៅណែនាំនេះ នឹងលើកយក ឧទាហរណ៍/ករណីសិក្សាតាមប្រទេសដែលសមស្របដែលយកចេញពីក្នុងតំបន់។សៀវភៅណែនាំនេះនឹងបង្កើតឡើងដោយប្រើប្រាស់ឯកសារបណ្តុះបណ្តាលមានស្រាប់ និងបន្ថែមគុណតម្លៃទៅលើឯកសារ បណ្តុះបណ្តាលទាំងនោះ ហើយវាទូលំទូលាយ ដែលអាចប្រើប្រាស់បាន ទាំងអ្នកមានចំណេះដឹងកម្រិតមបឋមនិងអ្នកមានចំណេះដឹងកម្រិតខ្ពស់។ ទោះបីជាសៀវភៅណែនាំនេះផ្តោទៅលើយេនឌ័រប៉ុន្តែក៏ផ្តោតលើយេនឌ័រដែលមានភាពប្រទាក់ក្រឡា រាប់បញ្ចូលទាំង អាយុ ភេទ និន្នាការផ្លូវភេទ (គ្រប់ក្រុម LGBTIQ) ពិការភាព ស្ថានភាព សង្គម ។ល។

## អ្នកចូលរួមគោលដៅ

ការបណ្តុះបណ្តាលសម្រាប់អង្គការសង្គមស៊ីវិលដែលកំពុងធ្វើការនៅកម្រិតសហគមន៍លើផ្នែកយេនឌ័រ និងផ្នែកភាពធន់នឹងការប្រែប្រួលអាកាសធាតុ/ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ។ ការបណ្តុះបណ្តាលនេះគឺផ្តោតលើតំបន់ជាក់លាក់នៅអាស៊ី ប៉ុន្តែជាពិសេសនៅប្រទេសក្នុងតំបន់អាស៊ីខាងត្បូង និងអាស៊ីអាគ្នេយ៍ រួមមានប្រទេសបង់ក្លាដែស ប្រទេសកម្ពុជា និងប្រទេសវៀតណាម។

## វិសាលភាព

សៀវភៅណែនាំនេះនឹងផ្តោតលើបញ្ហាមួយចំនួនដូចខាងក្រោម៖

- ការពិចារណាលើផ្នែកយេនឌ័រ និងសិទ្ធិមនុស្ស
- ស្ថានភាពអាកាសធាតុនិងភាពងាយរងគ្រោះ/ការកំណត់គ្រោះមហន្តរាយ (រាប់បញ្ចូលទាំងការបែងចែងភាពខុសគ្នានៃភាពងាយរងគ្រោះរវាងស្ត្រី និងកុមារី)
- ក្របខ័ណ្ឌការងារគោលនយោបាយ និងផែនការសកម្មភាពអំពីភាពធន់នឹងអាកាសធាតុ/ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ នៅថ្នាក់តំបន់ និងថ្នាក់ជាតិ។
- ឧបករណ៍ហិរញ្ញវត្ថុអាកាសធាតុដែលបានជ្រើសរើសនិងឱកាសវិនិយោគនៅថ្នាក់សកល និងថ្នាក់ជាតិ។
- វិធីសាស្ត្រដើម្បី រៀបចំផែនការ/សកម្មភាពបន្សាំ និងភាពធន់នៅសហគមន៍។
- យន្តការប្រមូលនិងតាមដានទិន្នន័យសម្រាប់សកម្មភាពអាកាសធាតុ។

# មាតិកា

សៀវភៅណែនាំនេះបែងចែកជា ៥ម៉ូឌុលដែលមានវគ្គចម្រុះ ដូចខាងក្រោម៖

ម៉ូឌុល ១៖ យេនឌ័រ និងភាពធន់នឹងអាកាសធាតុ ៖ ទស្សនៈមូលដ្ឋាន

វគ្គ ក៖ សិទ្ធិមនុស្ស គ្មានអ្នកណាម្នាក់ត្រូវបានទុកចោល (LNOB) និងសមភាពយេនឌ័រ

វគ្គ ខ៖ ការប្រែប្រួលអាកាសធាតុ និងហានិភ័យពាក់ព័ន្ធ ភាពធន់ និងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ

វគ្គ គ៖ ទំនាក់ទំនងរវាងយេនឌ័រ ការប្រែប្រួលអាកាសធាតុ និងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ

ម៉ូឌុល២៖ ការបង្កើតគោលនយោបាយ និងផែនការថ្នាក់ជាតិស្តីពី CCDDR

វគ្គក៖ ការស្វែងយល់ពីទិដ្ឋភាពគោលនយោបាយការបន្សាំនឹងការប្រែប្រួលអាកាសធាតុនិងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ

វគ្គខ៖ ការបញ្ជ្រាបបញ្ហាយេនឌ័រទៅក្នុងគោលនយោបាយ និង ផែនការថ្នាក់ជាតិ

ម៉ូឌុល ៣៖ ឧបករណ៍សម្រាប់ការបញ្ជ្រាបយេនឌ័រ

វគ្គ ក៖ ក្របខ័ណ្ឌការងារបញ្ជ្រាបយេនឌ័រ និងឧបករណ៍សម្រាប់អង្គការសង្គមស៊ីវិល (ការវិភាគ ការប៉ាន់ប្រមាណ និងការរៀបចំផែនការ)

វគ្គ ខ៖ ក្របខ័ណ្ឌការងារបញ្ជ្រាបយេនឌ័រ និងឧបករណ៍សម្រាប់អង្គការសង្គមស៊ីវិល (ការអនុវត្ត ការតាមដាន និងការវាយតម្លៃ)

ម៉ូឌុល ៤៖ យេនឌ័រក្នុងវិធីសាស្ត្របន្សាំ និងសកម្មភាពតាមវិស័យ

វគ្គ ក៖ ម៉ូដែលបន្សាំ និងយេនឌ័រ

វគ្គ ខ៖ វិធីសាស្ត្របន្សាំតាមវិស័យ និងយេនឌ័រ

ម៉ូឌុល ៥៖ ហិរញ្ញវត្ថុអាកាសធាតុសម្រាប់សកម្មភាពអាកាសធាតុឆ្លើយតបនឹងយេនឌ័រ

វគ្គក៖ ការស្វែងយល់អំពីស្ថាបត្យកម្មហិរញ្ញវត្ថុអាកាសធាតុសកល និងសមាសធាតុយេនឌ័ររបស់វា

វគ្គ ខ៖ ការរៀបចំចំរឹកាឆ្លើយតបទៅនឹងយេនឌ័រសម្រាប់ហិរញ្ញវត្ថុអាកាសធាតុ

**វគ្គបញ្ចប់៖** ការរៀបចំគម្រោងការប្រែប្រួលអាកាសធាតុ និង ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយឆ្លើយតបទៅនឹងយេនឌ័រ

# កំណត់សម្គាល់សម្រាប់អ្នកប្រើប្រាស់

សៀវភៅណែនាំនេះមានលក្ខណៈសាមញ្ញនិងត្រូវបានរៀបចំឡើងសម្រាប់វគ្គសិក្សាពីប្រភេទ ពោលគឺកម្រិតមូលដ្ឋាន និងកម្រិតខ្ពស់។ គ្រូឧទ្ទេសអាចជ្រើសរើសប្រធានបទ និងលំហាត់ស្របតាមក្រុមគោលដៅ និងរយៈពេលនៃការបណ្តុះបណ្តាល។ ឧបសម្ព័ន្ធរួមមានកម្មវិធីបណ្តុះបណ្តាលគំរូសម្រាប់វគ្គបណ្តុះបណ្តាលមូលដ្ឋានដែលមានរយៈពេលបួនថ្ងៃ។ បញ្ជីត្រួតពិនិត្យ (checklist) ត្រូវបានចែកជូនដើម្បីណែនាំអំពីការជ្រើសរើសប្រធានបទដោយផ្អែកលើប្រភេទនៃអ្នកចូលរួម។ អនុសាសន៍ និងគន្លឹះ មានដាក់បញ្ចូលទៅក្នុងផែនការតាមវគ្គនីមួយៗ សម្រាប់ជាជំនួយបន្ថែមដល់គ្រូឧទ្ទេស ។

ម៉ូឌុលនីមួយៗ រួមមាន ទិដ្ឋភាពទូទៅ គោលបំណង ផែនការតាមវគ្គ និងសារសំខាន់ៗ។ វគ្គនីមួយៗមានពន្យល់បន្ថែមទៀតពីមាតិកា ឯកសារដែលត្រូវការ ពេលវេលានៃវគ្គ និងការណែនាំផ្សេងៗទៀត។ វគ្គនីមួយៗនឹងមានកំណត់សម្គាល់បច្ចេកទេស (សម្រាប់អ្នកសម្របសម្រួល) ដែលគួរយកមកប្រើដើម្បីបង្កើត Powerpoint/ មេរៀនសម្រាប់ការបណ្តុះបណ្តាល។ ការពន្យល់បន្ថែមលម្អិតពីមាតិកាត្រូវបានបញ្ចូលផងដែរដើម្បីធ្វើឲ្យមានភាពងាយស្រួលក៏ដូចជាពង្រឹងបន្ថែមដល់ចំណេះដឹងមូលដ្ឋានរបស់គ្រូឧទ្ទេស។ គ្រូឧទ្ទេសគួរអានមេរៀនទាំងអស់ ដើម្បីយល់ពីមាតិកាទាំងមូល របស់មេរៀន និងអាស្រ័យលើអ្នកចូលរួមសម្រេច ថាតើផ្នែកណា ដែលចាំបាច់ត្រូវដាក់បញ្ចូលទៅក្នុងបទបង្ហាញ។ សូមចងចាំថាគ្រូឧទ្ទេសត្រូវប្រើប្រាស់ព័ត៌មានដែលពាក់ព័ន្ធនឹងបរិបទដែលអ្នកចូលរួមធ្វើប្រតិបត្តិការជារៀងរាល់ថ្ងៃ មិនថានៅ ថ្នាក់មូលដ្ឋាន ថ្នាក់ជាតិ ឬថ្នាក់តំបន់ ការធ្វើដូចនេះ នឹងធ្វើឱ្យការបណ្តុះបណ្តាលកាន់តែច្បាស់លាស់និងមានគុណភាព។ មាតិកាបច្ចេកទេសក៏ត្រូវបញ្ចូលក្នុងចំណុចពិភាក្សា និងតម្រុយសម្រាប់អ្នកសម្របសម្រួលដើម្បីឲ្យកម្មវិធីបណ្តុះបណ្តាលមានការចូលរួមកាន់តែច្រើន។

ផែនការតាមវគ្គនីមួយៗ មានបញ្ចូលនូវលំហាត់មួយចំនួន និងកិច្ចការជាក្រុម ដែលត្រូវបានរៀបចំឡើងដោយផ្តល់នូវបទពិសោធន៍ជាក់ស្តែងនៅពេល ប្រើប្រាស់ឧបករណ៍ និងទ្រឹស្តី។ ការពន្យល់ពីលំហាត់ដែលត្រូវបានប្រើប្រាស់ក្នុងម៉ូឌុលនីមួយៗ បានផ្តល់បន្ទាប់ពី កំណត់សម្គាល់បច្ចេកទេស ។ សៀវភៅណែនាំនេះមានលំហាត់ផ្សេងៗគ្នាជាច្រើនជាមួយនឹងជំហាននៃដំណើរការលម្អិត ដែលអ្នកអាច យកមកប្រើនៅក្នុងវគ្គបណ្តុះបណ្តាលរបស់អ្នក។ ទោះបីយ៉ាងណាក៏ដោយ ជំហានទាំងនេះគ្រាន់តែជាមតិយោបល់ ដែលលោកអ្នកនឹងយកមកប្រើឱ្យស៊ីទៅនឹងបរិបទ និងគោលបំណងរបស់អ្នក។ ឯកសារមាតិកាដែលនឹងយកមកប្រើនៅក្នុងលំហាត់ (គំនិត (chits) សំណួរចំណោទ ករណីសិក្សា។ល។) មានផ្តល់ជាឯកសារចែកជូន។

អ្នកអាចរកឯកសារចែកជូនទាំងអស់នៅក្នុងផ្នែកទីមួយនៃម៉ូឌុល ដែលអ្នកអាចថតចម្លង និងចែកចាយតាមដែលចាំបាច់។ នៅផ្នែកបញ្ចប់នៃសៀវភៅណែនាំនេះ អ្នកក៏អាចស្វែងរកគន្ថនិទ្ទេសដែលអាចប្រើប្រាស់សម្រាប់ការអាននិងឯកសារយោងនៅពេលក្រោយ។

## ឧបសម្ព័ន្ធ

បញ្ជីត្រួតពិនិត្យដែលបានស្នើឡើងសម្រាប់ការរៀបចំកម្មវិធីបណ្តុះបណ្តាលប្រភេទផ្សេងទៀត។
គំរូនៃកម្មវិធីបណ្តុះបណ្តាលកម្រិតមូលដ្ឋានដែលមានរយៈពេលបួនថ្ងៃ។
គំរូនៃកម្មវិធីបណ្តុះបណ្តាលកម្រិតខ្ពស់ដែលមានរយៈពេលប្រាំថ្ងៃ។
ឧបករណ៍វាយតម្លៃការបណ្តុះបណ្តាល។
ឯកសារយោង។

ΣmPower Women for Climate-Resilient Societies
Sweden Sverige
arrow asian-pacific resource & research centre for women
UN WOMEN

# សៀវភៅណែនាំ បណ្តុះបណ្តាលស្តីពី យេនឌ័រនិងភាពធន់នឹង ការប្រែប្រួលអាកាសធាតុ



## ម៉ូឌុល ១៖

## យេនឌ័រ និង ការប្រែប្រួលអាកាសធាតុ

1

# ម៉ូឌុល ១៖ យេនឌ័រ និងការប្រែប្រួលអាកាសធាតុ

**ផែនការតាមវគ្គ៖**

ម៉ូឌុលនេះបែងចែកចេញជាបីវគ្គ។ វគ្គនីមួយៗមានលម្អិតអំពីកំណត់សម្គាល់បច្ចេកទេស ដែលមានលំហាត់/ការងារតាមក្រុមមួយឈុត ដែលតម្រូវឱ្យផ្សារភ្ជាប់គ្នា ដើម្បីធ្វើឱ្យបរិយាកាសសិក្សាកាន់តែអំណោយផល។

**វគ្គ ក** : សិទ្ធិមនុស្ស មិនមានអ្នកណាម្នាក់ត្រូវបានទុកចោល និងសមភាពយេនឌ័រ

**វគ្គ ខ** : ការប្រែប្រួលអាកាសធាតុ និងហានិភ័យពាក់ព័ន្ធ ភាពធន់ និងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ

**វគ្គ គ** : ទំនាក់ទំនងរវាងយេនឌ័រ ការប្រែប្រួលអាកាសធាតុ និងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ

ម៉ូឌុលនេះផ្ដោតលើការណែនាំអំពីទស្សនៈមូលដ្ឋានទាក់ទងនឹងសិទ្ធិមនុស្ស យេនឌ័រ ភាពធន់នឹងអាកាសធាតុ និងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ។ ម៉ូឌុលនេះចាប់ផ្ដើមជាមួយនឹងការជម្រុញនូវគុណតម្លៃចំនួនបីនៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពនោះគឺវិធីសាស្ត្រផ្អែកលើសិទ្ធិមនុស្សជាមូលដ្ឋានគ្មានអ្នកណាម្នាក់ត្រូវបានទុកចោល សមភាពយេនឌ័រ និងការបង្កើនភាពអង់អាចដល់ស្ត្រី។ការផ្ដោតនេះបន្តពង្រីកវិសាលភាពលើផលប៉ះពាល់ផ្សេងៗគ្នានៃការប្រែប្រួលអាកាសធាតុនៅក្នុងតំបន់ និងថាតើការប្រែប្រួលអាកាសធាតុផ្ដល់ផលប៉ះពាល់ដល់មនុស្សផ្សេងៗគ្នាយ៉ាងដូចម្ដេចផ្អែកលើចលករសង្គម និងរចនាសម្ព័ន្ធវិសមភាពមានស្រាប់ ដែលមាននៅក្នុងតំបន់ទាំងនោះ។ ជាមួយនឹងវិសមភាពយេនឌ័រ ដែលកំពុងរីករាលដាលនៅលើពិភពលោក ស្ត្រី (ជាពិសេស) ច្រើនតែងាយរងផលប៉ះពាល់ផ្សេងៗគ្នាពីការប្រែប្រួលអាកាសធាតុ។ ទោះបីយ៉ាងណា ស្ត្រីពុំមែនជាក្រុមដូចគ្នាហេតុដូច្នេះហើយសមភាពយេនឌ័រចាំបាច់ត្រូវយកមកធ្វើជាប្រធានបទឆ្លងវិស័យនៅគ្រប់សកម្មភាពការប្រែប្រួលអាកាសធាតុ និងការកាត់បន្ថយហានិភ័យ គ្រោះមហន្តរាយទាំងអស់ វាក៏មានសារៈសំខាន់ក្នុងការយល់ដឹងពីឥទ្ធិពលដែលប្រទាក់ក្រឡាផ្នែកផ្សេងៗគ្នាទៀត ដូចជា អាយុ លំនៅឋាន វណ្ណៈ ជាតិសាសន៍ និងលទ្ធភាព ខណៈដែលត្រូវពិនិត្យលើទំនាក់ទំនងរវាងយេនឌ័រ និងការប្រែប្រួលអាកាសធាតុ។ វាមានសារៈសំខាន់ដូចគ្នាក្នុងការមើលទៅស្ត្រីថាពុំត្រឹមជាជនរងគ្រោះ ប៉ុន្តែជាដៃគូស្មើភាព ជាតួអង្គសំខាន់ និង ចូលរួមចំណែកក្នុងសកម្មភាពភាពធន់នឹងអាកាសធាតុ ហើយគុណតម្លៃនៃទស្សនៈ និងវិធីសាស្ត្រនេះអាចជួយ បន្ថែមដល់ការឆ្លើយតបទៅនឹងបញ្ហាអាកាសធាតុ។ ហេតុដូច្នេះហើយ វាចាំបាច់ណាស់ក្នុងការពង្រឹងការចូលរួមភាពជាអ្នកដឹកនាំនិងសមត្ថភាពរបស់ស្ត្រីសម្រាប់ធ្វើជាអ្នកកាន់ទង់ជាតិដើម្បីការផ្លាស់ប្ដូរ។

## គោលបំណងនៃម៉ូឌុល៖

> ស្វែងយល់ពីសារៈសំខាន់នៃការជ្រើសរើសវិធីសាស្ត្រផ្អែកលើសិទ្ធិមនុស្សជាមូលដ្ឋានដែលថាមិនមានអ្នកណាម្នាក់ត្រូវបានទុកចោល ដោយផ្ដោតលើសមភាពយេនឌ័រសម្រាប់ការជម្រុញឱ្យមានការអភិវឌ្ឍប្រកបដោយចីរភាព។

> ទទួលស្គាល់ហានិភ័យ និងភាពងាយរងគ្រោះនានាដែលបណ្ដាលមកពីការប្រែប្រួលអាកាសធាតុនៅក្នុងតំបន់អាស៊ី

> ទទួលស្គាល់ភាពងាយគ្រោះទាក់ទងនឹងយេនឌ័រនៃហានិភ័យអាកាសធាតុ ដែលកំពុងកើតមាន និងផលប៉ះពាល់ខុសគ្នានៃការប្រែប្រួលអាកាសធាតុទៅលើស្ត្រី។

> កំណត់ចំណុចខ្វះខាត ការប្រឈម និងសមត្ថភាពចាំបាច់សម្រាប់សកម្មភាពអាកាសធាតុឆ្លើយតបនឹងយេនឌ័រ ជាពិសេសសម្រាប់ការជម្រុញឱ្យស្ត្រីក្លាយជា "ភ្នាក់ងារនៃការផ្លាស់ប្ដូរ"។

## សារគន្លិះសំខាន់៖

> សិទ្ធិមនុស្សគឺជាសិទ្ធិទទួលបានជាសកលដែលមានជាប់ពីកំណើតសម្រាប់មនុស្សគ្រប់រូប ដោយពុំគិតពីសញ្ជាតិ ទីកន្លែង ភេទ ដើមកំណើតជាតិ ពណ៌សម្បុរ សាសនា ភាសា ឬស្ថានភាពដទៃទៀត។

> ការប្រែប្រួលអាកាសធាតុផ្ដល់ផលប៉ះពាល់ដោយផ្ទាល់ឬប្រយោលដល់យើងទាំងអស់គ្នាជាពិសេសដល់មនុស្ស ទាំងឡាយណាដែលបានចូលរួមតិចតួចបណ្ដាលឲ្យមានការប្រែប្រួលអាកាសធាតុបែបនេះបានធ្វើឱ្យមានភាពអយុត្តិធម៌ខាងអាកាសធាតុ។

> វិធីសាស្ត្រផ្អែកលើសិទ្ធិមនុស្សជាមូលដ្ឋាន ដើម្បីការអភិវឌ្ឍប្រកបដោយចីរភាពពិចារណាលើគ្រប់ផ្នែកនៃវិសមភាពនៅពេលរៀបចំកម្មវិធី និងអាចធ្វើការផ្លាស់ប្ដូរបានយ៉ាងពិតប្រាកដប្រសិនបើយកទៅអនុវត្ត។

> ហានិភ័យអាកាសធាតុមិនត្រឹមតែធ្វើឱ្យដំណើរការអភិវឌ្ឍន៍ដែលបានធ្វើរហូតមកទល់ពេលបច្ចុប្បន្នដើរថយក្រោយប៉ុណ្ណោះទេប៉ុន្តែវាថែមទាំងធ្វើឱ្យមនុស្សជាច្រើនធ្លាក់ចូលក្នុងភាពក្រីក្រដោយសារពួកវារារាំងដល់ដំណើរការដែលត្រូវធ្វើដើម្បីសម្រេចឱ្យបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព។

> វាមានសារៈសំខាន់ក្នុងការធ្វើការងារលើការបន្សាំនឹងការប្រែប្រួលអាកាសធាតុការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងការកសាងភាពធន់ជាមួយក្រុមងាយរងគ្រោះដោយយកចិត្តទុកដាក់លើតម្រូវការក្នុងការដោះស្រាយផលប៉ះពាល់

នៃការប្រែប្រួលអាកាសធាតុលើស្ត្រី និងប្រជាជនក្រីក្រ។

> ស្ត្រី និងកុមារី ជាពិសេស គឺជាក្រុមងាយរងគ្រោះបំផុតដោយសារតួនាទី ការទទួលខុសត្រូវ និងរចនាសម្ព័ន្ធអំណាចខុសគ្នាខាងយេនឌ័រ ដែលកំពុងកើតមាននៅក្នុងសង្គមភាគច្រើន។

> វិសមភាពយេនឌ័រធ្វើឱ្យស្ត្រី និងកុមារីប្រឈមទៅនឹងភាពក្រីក្រទាំងពេលវេលា ទាំងប្រាក់ចំណូល ក៏ដូចជាបាត់បង់អាយុជីវិត របរចិញ្ចឹមជីវិត និង ទ្រព្យសម្បត្តិ។ សិទ្ធិមនុស្សរបស់ស្ត្រី និងកុមារី ព្រមទាំងយេនឌ័រផ្សេងទៀត ច្រើនតែមិនត្រូវបានគេទទួលស្គាល់នៅពេលដែលគោលនយោបាយស្តីពីការប្រែប្រួលអាកាសធាតុនិងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយពុំបានបញ្ចូល ទិដ្ឋភាព យេនឌ័រ តាមរយៈវិធីសាស្ត្រផ្អែកលើសិទ្ធិមនុស្សជាមូលដ្ឋាន។

> សមភាពយេនឌ័រមានសារៈសំខាន់នៅក្នុងសិទ្ធិរបស់ខ្លួន ប៉ុន្តែវាក៏ជាធាតុផ្សំមួយដ៏សំខាន់ ដើម្បីសម្រេចបាននូវការបន្សាំ និងការកាត់បន្ថយហានិភ័យ។ ស្ត្រីចាំបាច់ត្រូវចូលរួមជាដៃគូ និងតួអង្គដោយស្មើភាពក្នុងដំណើរ ការកសាងភាពធន់ប្រកបដោយបរិយាបន្ន។

## ម៉ូឌុល១ វគ្គ ក៖

**3:00:00** — **សិទ្ធិមនុស្ស មិនមានអ្នកណាម្នាក់ត្រូវ បានទុកចោល និងសមភាពយេនឌ័រ**

### ទិដ្ឋភាពទូទៅ

នៅចុងបញ្ចប់នៃវគ្គនេះ អ្នកចូលរួមគួរតែអាចយល់ និងពន្យល់បានអំពីទស្សនៈនៃវិធីសាស្ត្រផ្អែកលើសិទ្ធិមនុស្សជាមូលដ្ឋាននិងមិនមានអ្នកណាម្នាក់ត្រូវបានទុកចោលក្នុងក្របខ័ណ្ឌអភិវឌ្ឍន៍ប្រកបដោយចីរភាព។ អ្នកចូលរួមគួរតែអាចយល់ដឹងអំពីសារៈសំខាន់នៃសមភាពយេនឌ័រ និងផ្នែកផ្សេងទៀតក្នុងបរិបទ វិធីសាស្ត្រផ្អែកលើសិទ្ធិមនុស្សជាមូលដ្ឋាន និងមិនមាន អ្នកណាម្នាក់ត្រូវបានទុកចោល។

### មាតិកា

ក) សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស
- ការប្រែប្រួលអាកាសធាតុ និងសិទ្ធិមនុស្ស

ខ) វិធីសាស្ត្រផ្អែកលើសិទ្ធិមនុស្សជាមូលដ្ឋាន
- វិសមភាពនិងវិធីសាស្ត្រផ្អែកលើសិទ្ធិមនុស្ស

គ) មិនមានអ្នកណាម្នាក់ត្រូវបានទុកចោល

ឃ) សមភាពយេនឌ័រ និងភាពចម្រុះប្រសព្វរួមផ្នែកផ្សេងទៀតនៃយេនឌ័រ
- ការប្រតិបត្តិវិធីសាស្ត្រផ្អែកលើសិទ្ធិមនុស្សជាមូលដ្ឋាន និងមិនមាន អ្នកណាម្នាក់ត្រូវបានទុកចោល តាមរយៈវ៉ែនតា យេនឌ័រ

### ឯកសារ

បទបង្ហាញជា Power point
ខ្សែភាពយន្តនៅលើ YouTube
ទីលំហ ឬល្បែងក្តារអុក
គំនិតស្តីពីទស្សនៈយេនឌ័រ
ក្តារខៀន និងប៊ិចហ្វឺត
ក្រដាសផ្ទាំងធំ និងប៊ិច
ឯកសារចែកជូន

### តារាងពេលវេលា

| រយៈពេល | សកម្មភាព |
|---|---|
| ៥ នាទី | >ការចែករំលែកអំពីទិដ្ឋភាពទូទៅ និងមាតិកានៃវគ្គ |
| ៤០ នាទី | >ការបង្កើតភាពប្រទាក់ក្រឡា "សិទ្ធិមនុស្ស" (សូមមើលលំហាត់ទី១) |
| ១៥ នាទី | >បទបង្ហាញជា PowerPoint ឬការបង្រៀនអំពី "សិទ្ធិមនុស្ស និងវិធីសាស្ត្រផ្អែកលើសិទ្ធិមនុស្សជាមូលដ្ឋាន" |
| ៤៥ នាទី | >ល្បែង "ការដើរប្រកបដោយថាមពល" (សូមមើលលំហាត់ទី២) |
| ១៥ នាទី | >បទបង្ហាញជា PowerPoint ស្តីពី "មិនមានអ្នកណាម្នាក់ត្រូវបានទុកចោល" |
| ៣០ នាទី | >គំនិតស្តីពី "ទស្សនៈយេនឌ័រ" (សូមមើលលំហាត់ទី៣ និងឯកសារចែកជូនទី១) |
| ៣០ នាទី | >បទបង្ហាញជា PowerPoint ស្តីពី "សមភាពយេនឌ័រ និងភាពចម្រុះប្រសព្វខាងយេនឌ័រ" (សូមមើលផងដែរនូវចែកជូនទី២) |

### កំណត់សម្គាល់ណែនាំ

ចាប់ផ្តើមវគ្គជាមួយនឹងការចែករំលែកពត៌មានម៉ូឌុលរួមមាន៖ គោលបំណង ទិដ្ឋភាពទូទៅ និងមាតិកានៃវគ្គ។ សូមប្រាប់ពួកគេថា អ្នកនឹងចាប់ផ្តើមជាមួយនឹងលំហាត់ដែលនឹងជួយពួកគេឱ្យស្គាល់គ្នា និងស្គាល់ពីមូលដ្ឋាននៃការបណ្តុះបណ្តាលឱ្យកាន់តែប្រសើរ។ សូមចាប់ផ្តើមជាមួយ "លំហាត់ភាពប្រទាក់ក្រឡាគ្នាស្តីពីសិទ្ធិមនុស្ស" ( សូមមើលលំហាត់ទី១ )។ បញ្ចប់លំហាត់ជាមួយបទបង្ហាញជា PowerPoint ដោយប្រើមាតិកាបច្ចេកទេសស្តីពី "សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស" "ការប្រែប្រួលអាកាសធាតុ និងសិទ្ធិមនុស្ស" និង "វិធីសាស្ត្រផ្អែកលើសិទ្ធិមនុស្សជាមូលដ្ឋាន"។ អ្នកក៏អាចយកមកប្រើនៅក្នុងវិធីសាស្ត្របង្រៀនបានដែរ អាចជួយកំណត់លក្ខណៈក្រៅផ្លូវការបន្ថែមទៀតសម្រាប់វគ្គបណ្តុះបណ្តាល ដោយជួយឱ្យអ្នកចូលរួមយកចិត្តទុកដាក់ក្នុងការស្តាប់។ ប្រើប្រាស់ចំណុចពិភាក្សាដើម្បីបន្តឱ្យអ្នកចូលរួមចូលរួមសកម្មក្នុងដំណើរការ។

ប្រសិនបើមានពេលនិងទីកន្លែងសូមឱ្យអ្នកចូលរួមចេញក្រៅដើម្បីអនុវត្ត "លំហាត់ការដើរប្រកបដោយថាមពល" បើមិនដូច្នោះទេសូមប្រើគន្លឹះក្តារអុក ( សូមមើលលំហាត់ទី២ )។ បន្ទាប់មកបន្តវាជាមួយនឹងបទបង្ហាញជា PowerPoint ដោយប្រើមាតិកាបច្ចេកទេសស្តីពី "មិនមានអ្នកណាម្នាក់ត្រូវបានទុកចោល"។ សូមប្រើ PowerPoint ដោយសារវាអាចជួយបង្កើត សន្ទស្សន៍មិនមានអ្នកណាម្នាក់ត្រូវបានទុកចោល និងលទ្ធផលក្នុងប្រទេស។ ប្រសិនបើមានអ្នកចូលរួមមកពីប្រទេសតែមួយ ឬពីរ សូមលើកឡើងតែលទ្ធផលនៃប្រទេសទាំងនោះនៅក្នុងស្លាយថ៍ ហើយឱ្យអ្នកចូលរួមគិតពី ស្ថានភាពជាក់ស្តែងនៃប្រទេសរបស់ពួកគេ ហើយអ្វីដែលមានស្ថានភាពដូចគ្នា។ ការធ្វើដូចនេះនឹងធ្វើឱ្យវគ្គនេះមានការចូលរួមកាន់តែច្រើនពីអ្នកចូលរួម។

ទិដ្ឋភាពសំខាន់មួយសម្រាប់ការបញ្ជ្រាបយេនឌ័រក្នុងវិធីសាស្ត្រផ្អែកលើសិទ្ធិមនុស្សជាមូលដ្ឋាន និងមិនមានអ្នកណាម្នាក់ត្រូវបានទុកចោល គឺជាការយល់ដឹងដ៏ត្រឹមត្រូវមួយនៃបច្ចេកស័ព្ទទាក់ទងនឹងភេទ និងយេនឌ័រ។ ឯកសារចែកជូនទី១ នាំមកនូវទស្សនៈសំខាន់ៗមួយចំនួនទាក់ទងនឹងយេនឌ័រ ដែលនឹងមានប្រយោជន៍ ក្នុងការប្រើប្រាស់ក្នុងដំណើរការបញ្ជ្រាបយេនឌ័រសម្រាប់សមភាពយេនឌ័រ។ ខណៈដែលគេរំពឹងថា អ្នកទទួលការបណ្តុះបណ្តាលភាគច្រើននឹងបានដឹងអំពីទស្សនៈទាំងនេះ វាក៏អាចជួយបញ្ជាក់ដូចគ្នានៅក្នុងកាលៈទេសៈជាក់លាក់។ សូមប្រើប្រាស់ "គំនិតអំពីយេនឌ័រ" ( សូមមើលលំហាត់ទី៣ និងឯកសារចែកជូនទី១ ) ដើម្បីធ្វើកិច្ចការនេះ។ សូមបញ្ជាក់ថា ការពិភាក្សានេះពុំមែនជាការជំនួសការបណ្តុះបណ្តាលតម្រង់ទិស និងការយល់ដឹងពីយេនឌ័រ ដែលត្រូវតែអនុវត្តលំហាត់ជាចាំបាច់សម្រាប់កម្មវិធី និងគម្រោងទាំងអស់នោះទេ។ សូមបន្តជាមួយនឹង PowerPoint ដោយប្រើប្រាស់មាតិកាបច្ចេកទេសយកចេញពី "សមភាពយេនឌ័រដើម្បីសិទ្ធិមនុស្សនិងការអភិវឌ្ឍ" និង "ការប្រតិបត្តិវិធីសាស្ត្រផ្អែកលើសិទ្ធិមនុស្សជាមូលដ្ឋាន និងមិនមានអ្នកណាម្នាក់ត្រូវបានទុកចោលជាមួយតាមរយៈវ៉ែនតាយេនឌ័រ"។ សូមប្រើក្រាហ្វិក ព័ត៌មានដែលបានផ្តល់ជូននៅក្នុងឯកសារចែកជូនទី២សម្រាប់បទបង្ហាញនេះ។ សូមបញ្ចប់វគ្គ ជាមួយនឹងការពិភាក្សាអំពីឧទាហរណ៍នៃគម្រោងការបញ្ជ្រាបយេនឌ័រ និងគម្រោងមានទស្សនៈផ្លាស់ប្តូរយេនឌ័រ។

# សិទ្ធិមនុស្ស និងវិធីសាស្ត្រផ្អែកលើសិទ្ធិមនុស្សជាមូលដ្ឋាន

## សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស

សិទ្ធិមនុស្សគឺជាសិទ្ធិមូលដ្ឋាន/ពីធម្មជាតិ ដែលមានជាប់ពីកំណើត ចំពោះមនុស្សគ្រប់រូប ដោយពុំគិតពីសញ្ជាតិ ទីនិវេសនដ្ឋាន ភេទ ដើមកំណើតជាតិ ពណ៌សម្បុរ សាសនា ភាសា ឬស្ថានភាពដទៃទៀតរបស់ពួកគេឡើយ។ សិទ្ធិមនុស្សគឺជាសិទ្ធិទទួលបានជាសកលដែលត្រូវបានធានាដោយច្បាប់អន្តរជាតិនិងសន្ធិសញ្ញាដែលត្រូវបានទទួលស្គាល់ដោយរដ្ឋាភិបាលថ្នាក់ជាតិ។រដ្ឋាភិបាលទាំងអស់បានផ្តល់សច្ចាប័ន យ៉ាងហោចណាស់ចំនួនមួយ និងរដ្ឋចំនួន៨០%ទៀតបានផ្តល់សច្ចាប័នលើសន្ធិសញ្ញាសិទ្ធិមនុស្សជាមូលដ្ឋានចំនួនបួន ឬច្រើនជាងនេះ ដោយឆ្លុះបញ្ចាំងពីការព្រមព្រៀងរបស់ពួកគេ ដែលបង្កើតបានជាកាតព្វកិច្ចផ្លូវច្បាប់ និងការសម្តែងមតិជាក់ស្តែងដល់សកលលោក។ ច្បាប់អន្តរជាតិដាក់ចេញនូវកាតព្វកិច្ចរបស់រដ្ឋាភិបាល ក្នុងការធ្វើសកម្មភាពតាមមធ្យោបាយមួយ ចំនួន ឬហាមឃាត់ពីការធ្វើសកម្មភាពមួយចំនួន ដើម្បីលើកកម្ពស់ និងការពារសិទ្ធិមនុស្សរបស់បុគ្គលគ្រប់រូប។ ការផ្តោតសំខាន់ជាដំបូងនៅក្នុងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សឆ្នាំ ១៩៤៨ សេចក្តីប្រកាសទាំង នេះត្រូវបានបញ្ជាក់ជាថ្មី នៅក្នុងអនុសញ្ញាអន្តរជាតិ សេចក្តីប្រកាស និងសេចក្តីសម្រេចជាអន្តរជាតិស្តីពីសិទ្ធិមនុស្ស ដែល ភាគច្រើនគឺសន្និសីទពិភពលោក ទីក្រុងវីយែនឆ្នាំ ១៩៩៣ ស្តីពីសិទ្ធិមនុស្ស។

សិទ្ធិទាំងនេះ រួមមាន សិទ្ធិស៊ីវិល វប្បធម៌ សេដ្ឋកិច្ច នយោបាយ និងសង្គម ដូចជា៖

ក ) សិទ្ធិរស់រានមានជីវិត សេរីភាព សន្តិសុខ និងសេចក្តីថ្លៃថ្នូ

ខ ) សិទ្ធិស្មើគ្នាចំពោះមុខច្បាប់ សិទ្ធិសុំឱ្យតុលាការពិនិត្យរឿងក្តីខ្លួនដោយសមធម៌ ឯករាជ្យ និងជាសាធារណៈ និងរកដំណោះស្រាយជាក់ស្តែង។

គ ) សិទ្ធិសេរីភាពខាងការគិត សតិសម្បជញ្ញៈ សាសនា ការមានមតិ និងការសម្តែងមតិ។

ឃ ) សិទ្ធិទទួលបានសញ្ជាតិ សេរីភាពក្នុងការជ្រើសរើសនិវេសនដ្ឋាន ការធ្វើដំណើរ និងការស្វែងរកកន្លែងជ្រកកោន និង

ង ) សិទ្ធិទទួលបានការអប់រំ សុខុមាលភាព ( ចំណីអាហារ សុខភាព ទឹក អនាម័យបរិស្ថាន លំនៅឋាន ) ការងារ និងសន្តិសុខសង្គម។

សិទ្ធិទាំងនេះ មិនត្រឹមតែសិទ្ធិជាសកល និងមិនអាចដកហូតបាន ប៉ុន្តែវាក៏មានទំនាក់ទំនងគ្នាទៅវិញទៅមក ពឹងផ្អែកគ្នាទៅវិញទៅមក និងមិនអាចបំបែកបាន។ ឧទាហរណ៍ នៅពេលដែលសិទ្ធិស៊ីវិលរស់រានមានជីវិតរួមបញ្ចូលទាំងសិទ្ធិសេដ្ឋកិច្ចដើម្បីទទួលបានសន្តិសុខសង្គម និងសិទ្ធិអភិវឌ្ឍន៍។ ជាការពិត ការដកហូតសិទ្ធិណាមួយ វាធ្វើឱ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សិទ្ធផ្សេងទៀត ព្រោះសិទ្ធទាំងនោះវាមានទំនាក់ទំនងគ្នាទៅវិញទៅមក។

## ការប្រែប្រួលអាកាសធាតុ និងសិទ្ធិមនុស្ស

ការប្រែប្រួលអាកាសធាតុជះឥទ្ធិពលជាអវិជ្ជមានដោយផ្ទាល់ ឬដោយប្រយោលទៅលើការទទួលស្គាល់សិទ្ធិមនុស្សដោយពេញលេញ។ វាជះឥទ្ធិពលយ៉ាងខ្លាំង ជាពិសេសទៅលើសិទ្ធិរស់រានមានជីវិត និងសេចក្តីថ្លៃថ្នូរ និងសិទ្ធិទាំងឡាយណាដែលទាក់ទងនឹងការអភិវឌ្ឍ ការងារ ចំណីអាហារ សុខភាព ទឹក អនាម័យបរិស្ថាននិងលំនៅដ្ឋាន។វាជាការចាំបាច់សម្រាប់រដ្ឋាភិបាលដែលជាអ្នកមានកាតព្វកិច្ចដើម្បីការពារ និងដោះស្រាយផលប៉ះពាល់ពីអាកាសធាតុ និងធានាឱ្យបានថា សិទ្ធិរបស់មនុស្សគ្រប់រូបត្រូវបានការពារ ជាពិសេស អ្នកទាំងឡាយណាដែលបានចូលរួមចំណែកតិចតួចក្នុងការបង្កឱ្យមានការប្រែប្រួលអាកាសធាតុប៉ុន្តែទំនងជាទទួលរងឥទ្ធិពលខ្លាំងបំផុត។ ហេតុនេះ សញ្ញាណនៃយុត្តិធម៌អាកាសធាតុ ផ្សារភ្ជាប់សិទ្ធិមនុស្ស និងការអភិវឌ្ឍ សម្រាប់វិធីសាស្ត្រផ្តោតលើមនុស្សជាមូលដ្ឋានចំពោះការប្រែប្រួលអាកាសធាតុ។ វិធីសាស្ត្រផ្អែកលើសិទ្ធិមនុស្សជាមូលដ្ឋានចំពោះការប្រែប្រួលអាកាសធាតុ ដែលផ្តោតលើមនុស្សគ្រប់រូប ក្នុងការសម្រេចឱ្យបានយ៉ាងហោចណាស់នូវស្ថានភាពអប្បបរមាសម្រាប់ការរស់នៅប្រកបដោយសេចក្តីថ្លៃថ្នូរតាមរយៈការទទួលស្គាល់នូវសិទ្ធិមនុស្សរបស់ពួកគេ គឺជាអ្វីដែលគួរតែលើកកម្ពស់ ទាំងនៅថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន។ ការពិចារណាសំខាន់ៗដែលចង្អុលបង្ហាញដល់វិធីសាស្ត្រនេះ ត្រូវបានចងក្រងយ៉ាងល្អនៅក្នុងការដាក់ស្នើពី ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុក សិទ្ធិមនុស្ស ( ឆ្នាំ២០១៥ ) រហូតដល់សន្និសីទបណ្តាភាគីលើក ទី២១ ដែលការពិចារណាទាំងនេះ រួមមាន៖

- > កាត់បន្ថយការប្រែប្រួលអាកាសធាតុនិងបង្ការផលប៉ះពាល់ជាអវិជ្ជមានលើសិទ្ធិមនុស្ស
- > ធានាថាមនុស្សគ្រប់រូបមានសមត្ថភាពក្នុងការសម្របខ្លួនទៅនឹងការប្រែប្រួលអាកាសធាតុ
- > ធានាគណនេយ្យភាព និងដំណោះស្រាយជាក់ស្តែងសម្រាប់ការធ្វើឱ្យប៉ះពាល់ដល់សិទ្ធិមនុស្ស ដែលបង្កឡើងដោយការប្រែប្រួលអាកាសធាតុ
- > កៀរគរធនធានដែលអាចរកបានឱ្យបានជាអតិបរមា ដើម្បីការអភិវឌ្ឍផ្អែកលើសិទ្ធិមនុស្សជាមូលដ្ឋានប្រកបដោយចីរភាព
- > កិច្ចសហប្រតិបត្តិការអន្តរជាតិ - ការឆ្លើយតបជាសកល ដែលគាំទ្រដោយសាមគ្គីភាពអន្តរជាតិ
- > ធានាឱ្យបាននូវសមធម៌ក្នុងសកម្មភាពអាកាសធាតុ
- > ធានាថាមនុស្សគ្រប់រូបរីករាយនឹងអត្ថប្រយោជន៍នៃវិទ្យាសាស្ត្រ និងការអនុវត្តរបស់វា
- > ធានាសមធម៌ និងការមិនរើសអើង
- > ធានាការចូលរួមប្រកបដោយអត្ថន័យ និងដោយមានការជូនដំណឹងជាមុន។

**គន្លឹះសម្រាប់គ្រូឧទ្ទេស**

វគ្គនេះផ្តោតលើទស្សនៈជាមូលដ្ឋាន ហើយហេតុនេះ វាមានសារៈសំខាន់សម្រាប់កម្មវិធីតម្រង់ទិសក្នុងចំណោមសមាជិក សហគមន៍ អ្នកកៀរគរថ្នាក់មូលដ្ឋាន។ល។ សម្រាប់វគ្គសិក្សាកម្រិតខ្ពស់ គ្រូឧទ្ទេសអាចពិចារណារំលងការធ្វើបទបង្ហាញដោយជំនួសមកវិញនូវវគ្គពិភាក្សា សំនួរបំផុសគំនិត ដោយប្រើវីដេអូស្តីពី "ការដាក់បញ្ចូលសិទ្ធិមនុស្ស មិនមានអ្នកណាម្នាក់ត្រូវបានទុកចោល និងសមភាពយេនឌ័រទៅក្នុងក្របខ័ណ្ឌសហប្រតិបត្តិការ អង្គការសហប្រជាជាតិ" ដែលយកចេញពីគេហទំព័រ https://unsdg.un.org/2030-agenda/universal-values. និងពិភាក្សាលើសំណួរខាងក្រោមនេះ៖

ក ) តើអ្វីជាទំនាក់ទំនងរវាងវិធីសាស្ត្រផ្អែកលើសិទ្ធិមនុស្សជាមូលដ្ឋាន មិនមានអ្នកណាម្នាក់ត្រូវបានទុកចោល និងការអភិវឌ្ឍន៍ប្រកបដោយចីរភាព/ការប្រែប្រួលអាកាសធាតុ?

ខ ) តើអ្វីជាទម្រង់ទូទៅបំផុតនៃវិសមភាពដែលត្រូវតែដោះស្រាយនៅក្នុងវិធីសាស្ត្រផ្អែកលើសិទ្ធិមនុស្សជាមូលដ្ឋាន និងមិនមានអ្នកណាម្នាក់ត្រូវបានទុកចោល?

គ ) តើអ្វីជាតួនាទីរបស់ "អ្នកមានកាព្វកិច្ច" ក្នុងការជួយ

**ចំណុចពិភាក្សា**

ពាក្យ "ម្ចាស់ សិទ្ធិ" និង "អ្នកមានកាព្វកិច្ច" ច្រើនតែឮនៅក្នុងបរិបទសិទ្ធិមនុស្ស។ សូមសាកសួរអ្នកចូលរួមថាតើពួកគេយល់ដឹងអ្វីខ្លះអំពីពាក្យទាំងនេះ?

តម្រុយសម្រាប់អ្នកសម្របសម្រួល

>ម្ចាស់សិទ្ធិ សំដៅលើគ្រប់រូបវន្តបុគ្គល ដែលមានសិទ្ធិទទួលបានសិទ្ធិមនុស្សដែលមិនអាចដកហូតបាន និងជាសកល ដោយពុំមានការរើសអើង។

> អ្នកមានកាព្វកិច្ច រួមមាន រដ្ឋាភិបាល ឬរដ្ឋ ដែលជាធម្មតាតំណាងដោយស្ថាប័នសាធារណៈ ដែលមានកាតព្វកិច្ចក្នុងការធានា និងទទួលស្គាល់សិទ្ធិមនុស្សរបស់មនុស្សគ្រប់រូប។

**វិធីសាស្ត្រផ្អែកលើសិទ្ធិមនុស្សជាមូលដ្ឋាន**

យុទ្ធសាស្ត្រសម្រាប់ការអនុវត្តសិទ្ធិមនុស្ស ត្រូវបានគេហៅថាជាវិធីសាស្ត្រផ្អែកលើសិទ្ធិមនុស្សជាមូលដ្ឋាន។ វាគឺជាគោលការណ៍ណែនាំមួយនៃក្របខ័ណ្ឌអង្គការសហប្រជាជាតិស្តីពីកិច្ចសហប្រតិបត្តិការសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព។ វិធីសាស្ត្រផ្អែកលើសិទ្ធិមនុស្សជាមូលដ្ឋាន គឺជាក្របខ័ណ្ឌទស្សនាទានសម្រាប់ "ដំណើរការនៃការអភិវឌ្ឍមនុស្សតាមបទប្បញ្ញត្តិដែលផ្អែកលើស្តង់ដារសិទ្ធិមនុស្សអន្តរជាតិ ហើយត្រូវបានប្រតិបត្តិដោយផ្ទាល់ដើម្បីលើកកម្ពស់ និងការពារសិទ្ធិមនុស្ស។ វារិះរកការវិភាអំពីវិសមភាពដែលស្ថិតនៅចំបេះដូងនៃបញ្ហាអភិវឌ្ឍន៍និងដោះស្រាយការអនុវត្តដែលមានលក្ខណៈរើសអើង និងការបែងចែកអំណាចដោយអយុត្តិធម៌ដែលរារាំងដល់វឌ្ឍនភាពនៃការអភិវឌ្ឍ និងជារឿយៗបណ្តាលឱ្យក្រុមមនុស្សត្រូវបានទុកចោល" (គេហទំព័រ UNSDG)។

មានសន្និទានភាពចម្បងចំនួន ពីរសម្រាប់វិធីសាស្ត្រផ្អែកលើសិទ្ធិមនុស្សជាមូលដ្ឋាន៖(ក)សន្និទានភាពខាងក្នុងដោយទទួលស្គាល់ថាវិធីសាស្ត្រផ្អែកលើសិទ្ធិមនុស្សជាមូលដ្ឋាន គឺជារឿងត្រឹមត្រូវដែលត្រូវធ្វើទាំងខាងសីលធម៌ ទាំងតាមផ្លូវច្បាប់ និង (ខ) សន្និទានភាពឧបករណ៍ដោយទទួលស្គាល់ថា វិធីសាស្ត្រផ្អែកលើសិទ្ធិមនុស្សជាមូលដ្ឋាននាំទៅរកលទ្ធផលនៃការអភិវឌ្ឍមនុស្សកាន់តែប្រសើរ និងកាន់តែមានចីរភាព។ ក្នុងការអនុវត្តជាក់ស្តែងហេតុផលសម្រាប់ការបន្តវិធីសាស្ត្រផ្អែកលើសិទ្ធិមនុស្សជាមូលដ្ឋានជាធម្មតា គឺជាការបញ្ចូលគ្នារវាងសន្និទានភាពទាំងពីរនេះ (OHCHR ឆ្នាំ២០០៦)។

**វិធីសាស្ត្រផ្អែកលើសិទ្ធិមនុស្សជាមូលដ្ឋានតម្រូវថា៖**

ក ) កម្មវិធីណាមួយ និងទាំងអស់គួរមានគោលដៅទទួលស្គាល់ និងធ្វើឱ្យប្រសើរឡើងនូវសិទ្ធិមនុស្សនៃក្រុមគោលដៅដែលពាក់ព័ន្ធ

ខ ) ដំណាក់កាលនៃការរៀបចំផែនការ និងការអនុវត្តកម្មវិធីទាំងអស់ គួរត្រូវបាននាំមុខដោយគោលការណ៍សិទ្ធិមនុស្សជាសកល

មិនអាចបំបែកបាន មានសមភាព និងមិនរើសអើង មានការចូលរួម និងគណនេយ្យភាព និង

គ) កម្មវិធីទាំងអស់គួរតែផ្តោតលើការអភិវឌ្ឍសមត្ថភាពទាំងសម្រាប់ "អ្នកមានកាតព្វ កិច្ច" ដើម្បីឆ្លើយតបនឹងកាតព្វកិច្ចរបស់ពួកគេ និងទាំងសម្រាប់ "ម្ចាស់ សិទ្ធិ" ដើម្បីយល់ពីការទាមទារ សិទ្ធិរបស់ពួកគេ។

ប្រសិនបើបកស្រាយតាមការអនុវត្តជាក់ស្តែងនេះមានន័យថា ជាការទទួលស្គាល់ថាវិសមភាពពិតជាកើតមាននៅក្នុងសង្គមតាមរយៈការប្រមូលទិន្នន័យដែលបានបែងចែកលម្អិត ការផ្តល់អំណាច និងការចូលរួមរបស់ក្រុមដែលប្រឈមនឹងការរើសអើងក្នុងការរៀបចំនិងការកសាងផែនការ និងដំណើរការនៃការធ្វើសេចក្តីសម្រេចចិត្តផ្សេងៗការបែងចែកធនធានជាពិសេសសម្រាប់ការដោះស្រាយកង្វល់នៃក្រុមទាំងនេះនិងការលុបបំបាត់ចោលនូវការរារាំងឧបសគ្គរចនាសម្ព័ន្ធចំពោះវិសមភាព។

### វិសមភាព និងវិធីសាស្ត្រផ្អែកលើសិទ្ធិមនុស្ស

ការផ្តោតជាចម្បងលើវិធីសាស្ត្រផ្អែកលើសិទ្ធិមនុស្សជាមូលដ្ឋាន គឺជាការទទួលស្គាល់ថា ការកើនឡើងនូវវិសមភាពគឺជាកង្វល់ដ៏ធំសម្រាប់សង្គម ដោយសារវាប៉ះពាល់មិនត្រឹមតែទៅលើការកាត់បន្ថយភាពក្រីក្រ និងគំនិតផ្តួចផ្តើមសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច ប៉ុន្តែវាក៏ធ្វើឱ្យអន្តរាយដល់ការទទួលបាននូវសិទ្ធិមនុស្ស ទំនាក់ទំនងក្នុងសង្គម សន្តិភាព និងការអភិវឌ្ឍប្រកបដោយចីរភាព។

វិសមភាពទាំងនេះផ្តើមចេញពីទម្រង់ចម្រុះ ដូចជា៖

ក) វិសមភាពនៃទ្រព្យធន និងប្រាក់ចំណូល

ខ) វិសមភាពនៃឱកាស និងលទ្ធផលទាក់ទងនឹងការអប់រំ សុខភាព សន្តិសុខស្បៀង ការងារ លំនៅដ្ឋាន និងសេវាសុខាភិបាល និង

គ) វិសមភាពដោយសារតែពូជសាសន៍ ជាតិពន្ធុ សាសនា អាយុ ពិការភាព និន្នាការផ្លូវភេទ និងអត្តសញ្ញាណយេនឌ័រ។

ការចាក់ឫសដោយកត្តាជម្រុញជារចនាសម្ព័ន្ធនិងឧបសគ្គនៅគ្រប់ផ្នែកនៃសេដ្ឋកិច្ច សង្គម នយោបាយ ទីក្រុងវប្បធម៌ និងបរិស្ថានវិសមភាពទាំងនេះច្រើនតែនាំទៅរកគុណវិបត្តិជាប្រព័ន្ធ ការបន្តការរើសអើងពីមួយជំនាន់ទៅមួយជំនាន់ និងវិសមភាពនៃការបែងចែកអំណាច ធនធាន និងឱកាស។ វិសមភាពទាំងនេះគម្រាមកំហែងដល់សិទ្ធិទទួលបានការអភិវឌ្ឍ ហើយការឆ្លើយ តបទៅនឹងវិសមភាពទាំងនេះ គឺមានសារៈសំខាន់ក្នុងការទទួលស្គាល់របៀបវារៈ ឆ្នាំ២០៣០ សម្រាប់ ការអភិវឌ្ឍប្រកបដោយចីរភាព។ទោះបីជាយ៉ាងណាការឆ្លើយតបទៅនឹងវិសមភាពទាំងនេះ បង្ហាញឱ្យឃើញពីការដោះស្រាយឧបសគ្គជារចនាសម្ព័ន្ធ និងការប្រឈមនឹងការរើសអើង ពាក់ព័ន្ធនឹងច្បាប់ គោលនយោបាយ បទដ្ឋានសង្គម និងផ្នត់គំនិតនឹងអាចធ្វើទៅបានដរាបណាគេដាក់បញ្ចូលរបៀបវារៈ ស្តីពីសិទ្ធិមនុស្សជាអាទិភាពនៅក្នុងកម្មវិធីអភិវឌ្ឍន៍ទាំងអស់។

**ចំណុចពិភាក្សា**

សូមសួរទៅ អ្នកចូល៖ តើអ្វីដែលពួកគេគិតថាជាទម្រង់ទូទៅនៃវិសមតាពដែលចាំបាច់ត្រូវតែដោះស្រាយនៅតាមរយៈវិធីសាស្ត្រផ្អែកលើសិទ្ធិមនុស្សជាមូលដ្ឋាន?

តម្រុយសម្រាប់អ្នកសម្របសម្រួល

>ទម្រង់ទូទៅបំផុតនៃវិសមភាពគឺការរើសអើងផ្អែកលើយេនឌ័រដែលកំពុងកើតមាននៅគ្រប់តំបន់ ហើយបាននឹងកំពុងរំលេចឱ្យឃើញយ៉ាងច្បាស់នៅក្នុងអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ។ (សូមប្រាប់អ្នកចូលរួមថា អ្នកនឹងពិភាក្សាអំពីអនុសញ្ញា ស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ បន្ថែមទៀតតាមរយៈការធ្វើលំហាត់នៅក្នុងវគ្គ គ)។

> ការចាក់ឫសយ៉ាងជ្រៅក្នុងវប្បធម៌ ការប្រតិបត្តិក្នុងសង្គម និងនៅពេលខ្លះ សូម្បីតែច្បាប់ដែលទទួលឥទ្ធិពលពីផ្នត់គំនិត ការរើសអើង និងការប្រតិបត្តិពាក់ព័ន្ធនឹងយេនឌ័រ រារាំងដល់ការទទួលស្គាល់ពេញលេញនូវសិទ្ធិមនុស្សរបស់ស្ត្រី។

> អ្វីដែលលេចធ្លោជាពិសេសក្នុងចំណោមការរឹតត្បិតទាំងនេះ គឺការរឹតត្បិតលើលទ្ធភាពទទួលបាន និងការគ្រប់គ្រងធនធាន ព័ត៌មាន និងការអប់រំ ឱកាសដែលមានកម្រិតចំពោះការងារសមរម្យ និងប្រាក់ឈ្នួលសមស្រប និងស្ថិតក្រោមតំណាងក្នុងស្ថាប័ន និងដំណើរការសម្រេចចិត្ត។

> ហេតុនេះ វិធីសាស្ត្រផ្អែកលើសិទ្ធិមនុស្សជាមូលដ្ឋានចំពោះការអភិវឌ្ឍ បំពេញបន្ថែម និងជំរុញឲ្យមានការបញ្ជ្រាបយេនឌ័រ ឬការដាក់បញ្ចូលទិដ្ឋភាពយេនឌ័រទៅក្នុងសកម្មភាពអភិវឌ្ឍន៍។

> វិធីសាស្ត្រផ្អែកលើសិទ្ធិមនុស្សត្រូវមានសមាសភាគជាក់លាក់ ក្នុងការរួមបញ្ចូលសិទ្ធិមនុស្សរបស់ស្ត្រី និងការហាមឃាត់ការរើសអើងផ្លូវភេទ។

# មិនមានអ្នកណាម្នាក់ត្រូវបានទុកចោល

**ការស្វែងយល់អំពី មិនមានអ្នកណាម្នាក់ត្រូវបានទុកចោល**

មិនមានអ្នកណាម្នាក់ត្រូវបានទុកចោល គឺជាការសន្យាស្នូលនៅក្នុងរបៀបវារៈ ឆ្នាំ ២០៣០ នៃការអភិវឌ្ឍប្រកបដោយចីរភាព និងគោលដៅអភិវឌ្ឍប្រកបដោយចីរភាព។ មិនមានអ្នកណាម្នាក់ត្រូវបានទុកចោលចែងថា "មិនត្រឹមតែទៅឱ្យដល់ប្រជាជនក្រីក្របំផុតនៃប្រជាជនក្រីក្រប៉ុន្តែថែមទាំងលុបបំបាត់ការរើសអើងនិងវិសមភាព ដែលរារាំងមនុស្សមិនឱ្យទទួលស្គាល់ពីសក្តានុពលពេញលេញ របស់ពួកគេ។" (គេហទំព័រ UNSDG)។ បញ្ហានៃមិនមានអ្នកណាម្នាក់ត្រូវបានទុកចោលមានដូចជាការទុកមនុស្សចោលឱ្យរស់នៅជាមួយភាពក្រីក្រដោយពុំមានលទ្ធភាពទទួលបានទឹកលំនៅដ្ឋានការអប់រំការគាំពារសង្គម។ល។គឺជាការបំពានធ្ងន់ធ្ងរលើសិទ្ធិមនុស្ស។ ទោះបីជាយ៉ាងណា វាក៏ជាកង្វល់នៃការអភិវឌ្ឍផងដែរ ដោយសារកំណើននៃវិសមភាព មិនត្រឹមតែធ្វើឱ្យសេដ្ឋកិច្ចដើរយឺតទេ ប៉ុន្តែវាក៏បានធ្វើឱ្យមានភាពតានតឹងក្នុងសង្គម និងអស្ថិរភាពនយោបាយ ដូច្នេះហើយ វានឹងធ្វើឱ្យការវិវត្តឆ្ពោះទៅរកការសម្រេច បាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកាន់តែយឺត (UNSDG ឆ្នាំ២០១៩)។

គោលការណ៍សំខាន់នៃមិនមានអ្នកណាម្នាក់ត្រូវបានទុកចោល គឺត្រូវតែរីកចំរើនឱ្យហួសពីកម្រិតមធ្យម ខណៈដែលត្រូវវាស់វែងវឌ្ឍនភាពលើសុចនាករអភិវឌ្ឍន៍និងធានាឱ្យបានថាក្រុមប្រជាជនទាំងអស់បានទទួលផលប្រយោជន៍ពីវឌ្ឍនភាពនេះ។ កិច្ចការនេះតម្រូវឱ្យមានការបែងចែកទិន្នន័យច្បាស់លាស់សម្រាប់ការរៀបចំកំណត់ក្រុមដែលត្រូវបានផាត់ចេញ ឬរើសអើង ក៏ដូចជាស្វែងយល់អំពីការរារាំងជារចនាសម្ព័ន្ធក្នុងការទទួលបានធនធាន និងឱកាសព្រមទាំងដោះស្រាយពីបញ្ហាឫសគល់នៃការផាត់ចេញនេះ (UNSDGឆ្នាំ២០១៩)។សរុបមកមិនមានអ្នកណាម្នាក់ត្រូវបានទុកចោល ជម្រុញយើងឱ្យផ្តោតលើការរើសអើង និងវិសមភាព (ដែលច្រើនតែចម្រុះនិងឆ្លងវិស័យ)ដែលកំណត់នូវទីភ្នាក់ងារនៃមនុស្សថាជាអ្នកកាន់កាប់សិទ្ធិ (គេហទំព័រ UNSDG)។

កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ UNDP (ឆ្នាំ២០១៨) បានទទួលស្គាល់កត្តាសំខាន់ៗចំនួន៥ដែលជះឥទ្ធិពលដល់មិនមានអ្នកណាម្នាក់ត្រូវបានទុកចោល និងបានរំលេចឱ្យឃើញក្នុងរូបទី១ ដែលរួមមាន ការរើសអើង ភូមិសាស្ត្រ វិបត្តិ និងភាពផុយស្រួយ អភិបាលកិច្ច ព្រមទាំងស្ថានភាពសង្គមសេដ្ឋកិច្ច។

ការអនុវត្ត មិនមានអ្នកណាម្នាក់ត្រូវបានទុកចោល តម្រូវឱ្យមានវិធីសាស្ត្រដាក់បញ្ចូលមួយដើម្បីកំណត់ថាតើអ្នកណាដែលត្រូវបានទុកចោល និងមូលហេតុអ្វី? ការកំណត់គោលដៅកម្មវិធីការកំណត់វិធានការមានប្រសិទ្ធភាពដើម្បីដោះស្រាយឫសគល់បញ្ហាការត្រួតពិនិត្យតាមដាន និងការវាស់វែងវឌ្ឍនភាព ព្រមទាំងការធានានូវគណនេយ្យភាពសម្រាប់មិនមានអ្នកណាម្នាក់ត្រូវបានទុកចោល (UNSDG ឆ្នាំ២០១៩)។ ការអនុវត្តទាំងនេះ ត្រូវបានសង្ខេបជាបីកម្រិត៖

ក) ពិនិត្យមើលថា ហេតុអ្វីមនុស្សត្រូវបានគេទុកចោល។ ប្រមូល និងប្រើប្រាស់ទិន្នន័យបែងចែកកាន់តែច្រើនជាងមុននិងប្រសើរជាងមុន និងព័ត៌មានជំរុញប្រជាជន។

ខ) ផ្តល់អំណាចដល់អ្នកទាំងឡាយណាដែលត្រូវបានទុកចោល ដោយធានាឱ្យបាននូវការចូលរួមប្រកបដោយអត្ថន័យរបស់ពួកគេក្នុងការសម្រេចចិត្តនិងការបង្កើតយន្តការមានសុវត្ថិភាព និងប្រកបដោយបរិយាប័ន្នសម្រាប់ការចូលរួមរបស់ពលរដ្ឋរបស់ពួកគេ។

គ) អនុម័តគោលនយោបាយ ច្បាប់ កំណែទម្រង់ ការចូលអន្តរាគមន៍ ដែលមានគោលដៅទប់ស្កាត់វិសមភាព និងលើកកម្ពស់ស្តង់ដារសុខុមាលភាពអប្បបរមា។

ទោះបីជាយ៉ាងនេះក្តី សមាសធាតុសំខាន់បំផុត គឺធ្វើឲ្យបុគ្គលនិងក្រុម បាត់បង់ឱកាស និងជួបការលំបាកក្នុងការចូលរួមយ៉ាងសកម្មក្នុងដំណើរការសម្រេចចិត្ត នៅគ្រប់កម្រិតនៃការរៀបចំកម្មវិធី។ ភាពជោគជ័យនៃគោលនយោបាយ និងកម្មវិធីដែលបានដៅទុកក៏ដូចជាការដោះស្រាយវិសមភាពបែបរចនាសម្ព័ន្ធ គឺពឹងផ្អែកយ៉ាងខ្លាំងទៅលើកម្រិតនៃការចូលរួមប្រកបដោយប្រសិទ្ធភាព និងការពិគ្រោះយោបល់ប្រកបដោយអត្ថន័យរបស់ក្រុមគោលដៅ។

## FIGURE 1-1: FACTORS FOR ASSESSING LNOB



**DISCRIMINATION**

**On the basis of assumed or ascribed identity or status.** ***Consider:*** SDG outcomes and opportunities by sex, age, disability, and social groups (as specified in the 2030 Agenda); evidence and recommendations from international human rights mechanisms and national human rights institutions.

**GEOGRAPHY**

**Isolation, risk or exclusion due to location; includes environmental degradation, transport, and technology.** ***Consider:*** SDG outcomes and opportunities broken down by sub-national locality; inequities in mobility related to transport and internet access.

**VULNERABILITY TO SHOCKS**

**Includes conflict, climate, and environmental causes.** ***Consider:*** Places or populations that endure more frequent and/or severe setbacks due to natural or environmental disasters, violence, crime or conflict, economic or other shocks.

**GOVERNANCE**

**Laws, policies, institutions, voice and participation (includes informal and traditional governing systems).** ***Consider:*** Impact of laws, policies, taxes, budgets, formal and traditional practices by sub-population and locality (i.e. distributional impacts); ability to participate in government and decision-making; civic spaces.

**SOCIO-ECONOMIC STATUS**

**Multi-dimensional poverty; inequalities.** ***Consider:*** Multi-dimensional poverty of women, men and children; Gini Coefficient; Inequalities-weighted Human Development Index; SDG outcomes and opportunities by income (and/or Multi-dimensional Poverty Index) quintile; sources on informal and vulnerable employment such as ILO statistics.

*Source: UNDP (2018).*

**ចំណុចពិភាក្សា**

សាកសួរអ្នកចូលរួម ថាតើអ្នកណាខ្លះដែលត្រូវបានគេ "ទុកចោល"?

តម្រុយសម្រាប់អ្នកសម្របសម្រួល

> អ្នកដែលត្រូវបានគេទុកចោលក្នុងការងារអភិវឌ្ឍ ច្រើនតែជាអ្នកដែលត្រូវបានគេផាត់ចេញផ្នែកសេដ្ឋកិច្ចសង្គម ទីកន្លែង និង/ឬនយោបាយ (ឧទាហរណ៍ ដោយសារតែមូលហេតុជាតិពន្ធុ ពូជសាសន៍ យេនឌ័រ អាយុ ពិការភាព) ដែលជាមូលហេតុនាំទៅរកការរើសអើងចម្រុះ។

> ពួកគេច្រើនតែពុំមានសម្លេង (ឧទាហរណ៍ កុមារ សហគមន៍ជនជាតិដើមភាគតិច) និងត្រូវបានផ្តាច់ចេញពីស្ថាប័នសង្គម កង្វះព័ត៌មានក្នុងការទទួលបានផលប្រយោជន៍ពីស្ថាប័ន បណ្តាញ និងប្រព័ន្ធគាំទ្រសេដ្ឋកិច្ច និងសង្គមក្នុងការលើកកម្ពស់ស្ថានភាពរបស់ពួកគេ និងមិនត្រូវបានពិគ្រោះយោបល់ ។

> ពួកគេមិនត្រូវរាប់បញ្ចូលដោយឡែក (ឧទាហរណ៍ ស្ត្រី មនុស្សចាស់ ជនពិការ) ឬមិនមានព័ត៌មានទាល់តែសោះ (ឧទាហរណ៍ ជនអន្តោប្រវេសន៍ខុសច្បាប់និងជនភៀសខ្លួន)នៅក្នុងទិន្នន័យផ្លូវការ។ពួកគេពុំមានទិន្នន័យនៅក្នុងគោលនយោបាយនិងកម្មវិធីអភិវឌ្ឍន៍។

# សន្ទស្សន៍គ្មានអ្នកណាម្នាក់ត្រូវបានទុកចោល

វិទ្យាស្ថានអភិវឌ្ឍន៍ក្រៅប្រទេស (ឆ្នាំ ២០១៩) បានពិនិត្យឡើងវិញលើការត្រៀមខ្លួនរួចជាស្រេចរបស់ប្រទេសចំនួន ១៥៩ ចំពោះ "មិនមានអ្នកណាម្នាក់ត្រូវបានទុកចោល"។ ចាប់ពីឆ្នាំ ២០១៨ សន្ទស្សន៍ក៏មានសូចនាករគោលនយោបាយបន្ថែមទៅលើភាពធន់។សន្ទស្សន៍នេះក៏បានដាក់បញ្ចូលនូវពិន្ទុនៃលទ្ធផល "មិនមានអ្នកណាម្នាក់ត្រូវបានទុកចោល"សម្រាប់ប្រទេសនីមួយៗ ដែលផ្តោតលើវិសាលភាពដែលលទ្ធផលនៃពិភពលោកដាក់ស្តែងលើភាពមិនមានអ្នកណាម្នាក់ត្រូវបានទុកចោលត្រូវបានលើកកម្ពស់។ សន្ទស្សន៍បង្ហាញថា ប្រទេសចំនួន ៨១ បាន "ត្រៀមខ្លួនរួចរាល់" ដើម្បីឆ្លើយតបនឹងការប្តេជ្ញាចិត្តចំពោះ "មិនមានអ្នកណាម្នាក់ត្រូវបានទុកចោល" ប្រទេសចំនួន ៥៤ បាន "ត្រៀមខ្លួនបានខ្លះ" ប្រទេសចំនួន ១២ បច្ចុប្បន្ន "ពុំទាន់បានត្រៀមខ្លួន" និងប្រទេស ចំនួន ១២ទៀតមាន "ទិន្នន័យមិនគ្រប់គ្រាន់"។ ស្ថានភាពនៃការជ្រើសរើសប្រទេសចេញពីអាស៊ី (តារាងទី១) បង្ហាញថាប្រទេសភាគច្រើនស្ថិតក្នុងចំណាត់ថ្នាក់ ត្រៀមខ្លួនរួចរាល់ ឬត្រៀមខ្លួនបានខ្លះ។

**តារាងទី ១៖ មិនមានអ្នកណាម្នាក់ត្រូវបានទុកចោល**

| ប្រទេស | ទិន្នន័យ (ការអង្កេតគ្រួសារ) | គោលនយោបាយ (លទ្ធភាពទទួលបានការងារ ដី និងសុខភាពដោយស្មើភាព) | ហិរញ្ញវត្ថុ (ការអប់រំ សុខភាព និងការគាំពារសង្គម) | ពិន្ទុត្រៀងខ្លួនរួចរាល់ជារួមសម្រាប់មិនមានអ្នកណាម្នាក់ត្រូវបានទុកចោល | ពិន្ទុលទ្ធផល (អត្រាមរណភាពក្រោម ៥ឆ្នាំកង្វះអាហារូបត្ថម្ភ លទ្ធភាពទទួលបានហិរញ្ញវត្ថុ និងអគ្គិសនី) |
|---|---|---|---|---|---|
| បង់ក្លាដែស | ត្រៀមខ្លួនរួចរាល់ | ពុំទាន់បានត្រៀមខ្លួន | ពុំទាន់បានត្រៀមខ្លួន | ត្រៀមខ្លួនបានខ្លះ | វិវត្តដោយផ្នែក |
| កម្ពុជា | ត្រៀមខ្លួនរួចរាល់ | ត្រៀមខ្លួនបានខ្លះ | ពុំទាន់បានត្រៀមខ្លួន | ត្រៀមខ្លួនបានខ្លះ | វិវត្តដោយផ្នែក |
| ចិន | ពុំទាន់បានត្រៀមខ្លួន | ត្រៀមខ្លួនរួចរាល់ | ត្រៀមខ្លួនបានខ្លះ | ត្រៀមខ្លួនបានខ្លះ | ទាន់ផែនការ |
| ឥណ្ឌា | ត្រៀមខ្លួនរួចរាល់ | ពុំទាន់បានត្រៀមខ្លួន | ត្រៀមខ្លួនបានខ្លះ | ត្រៀមខ្លួនបានខ្លះ | វិវត្តដោយផ្នែក |
| ឥណ្ឌូណេស៊ី | ត្រៀមខ្លួនរួចរាល់ | ត្រៀមខ្លួនបានខ្លះ | ត្រៀមខ្លួនបានខ្លះ | ត្រៀមខ្លួនរួចរាល់ | វិវត្តដោយផ្នែក |
| ម៉ាឡេស៊ី | ត្រៀមខ្លួនរួចរាល់ | ត្រៀមខ្លួនបានខ្លះ | ត្រៀមខ្លួនបានខ្លះ | ត្រៀមខ្លួនរួចរាល់ | ទាន់ផែនការ |
| នេប៉ាល់ | ត្រៀមខ្លួនរួចរាល់ | ពុំទាន់បានត្រៀមខ្លួន | ពុំទាន់បានត្រៀមខ្លួន | ត្រៀមខ្លួនបានខ្លះ | វិវត្តដោយផ្នែក |
| ហ្វីលីពីន | ត្រៀមខ្លួនរួចរាល់ | ត្រៀមខ្លួនបានខ្លះ | ត្រៀមខ្លួនបានខ្លះ | ត្រៀមខ្លួនរួចរាល់ | វិវត្តដោយផ្នែក |
| ស្រីលង្កា | ត្រៀមខ្លួនរួចរាល់ | ត្រៀមខ្លួនបានខ្លះ | ត្រៀមខ្លួនបានខ្លះ | ត្រៀមខ្លួនរួចរាល់ | ទាន់ផែនការ |
| | ត្រៀមខ្លួនរួចរាល់ | ត្រៀមខ្លួនបានខ្លះ | ពុំទាន់បានត្រៀមខ្លួន | ត្រៀមខ្លួនបានខ្លះ | វិវត្តដោយផ្នែក |

*Source: Chattopadhyay and Manea (2019).*

# វិសមភាព និងអន្តរវិស័យភាពខាងយេនឌ័រ

**វិសមតាពយេនឌ័រសម្រាប់សិទ្ធិមនុស្ស និងការអភិវឌ្ឍ**

បើទោះបីជាការមិនរើសអើងដោយផ្អែកលើមូលដ្ឋានភេទនិងអត្តសញ្ញាណយេនឌ័រ គឺជាគោលការណ៍ សិទ្ធិមនុស្សសកលជាមូលដ្ឋានប៉ុន្តែវាមានសារៈសំខាន់ណាស់ក្នុងការផ្តោតលើសមភាពយេនឌ័រក្នុងគោលនយោបាយនិងកម្មវិធីអភិវឌ្ឍន៍ (UNWomen ឆ្នាំ២០១៤)។ ក្រៅពីនេះ វាក៏ជាបុរេនិច្ឆ័យមួយសម្រាប់ការពន្លឿនរបៀបវារៈអភិវឌ្ឍន៍សំខាន់ៗ (ធនាគារពិភពលោក ឆ្នាំ២០១២)៖

ក) លើកកម្ពស់ផលិតភាព និងកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាពនៅថ្នាក់ជាតិ។

ខ) លើកកម្ពស់លទ្ធផលអភិវឌ្ឍន៍សង្គម និងមនុស្ស ជាពិសេសលើផ្នែកចំណីអាហារ អាហារូបត្ថម្ភ ការអប់រំ សុខភាព និងសុខមាលភាពគ្រួសារ និង

គ) លើកកម្ពស់ការសម្រេចចិត្តលើគោលនយោបាយដែលចាំបាច់សម្រាប់សង្គមដែលកាន់តែមានសន្តិភាព និងសមធម៌។

យោងតាមសន្និទានភាពនេះ ការសម្រេចបាននូវសមភាពយេនឌ័រ គឺជាគោលដៅដែលគេចង់បាន ដើម្បីអនុវត្តការអភិវឌ្ឍអន្តរជាតិ (UN Women ឆ្នាំ២០១៤)។ ប៉ុន្មានឆ្នាំកន្លងមកនេះ ធម្មនុញ្ញ និងអនុសញ្ញាអន្តរជាតិជាច្រើន បានទទួលស្គាល់ និងជំរុញតម្រូវការក្នុងការផ្តោតលើការផ្តល់ភាពអង់អាចដល់ស្ត្រី និងសមភាពយេនឌ័រ (សូមមើលតារាងទី២)។

**តារាងទី១៖ ការប្តេជ្ញាចិត្តជាអន្តរជាតិសំខាន់ៗចំពោះសមភាពយេនឌ័រ**

| ការប្តេជ្ញាចិត្តជាអន្តរជាតិសំខាន់ៗចំពោះសមភាពយេនឌ័រ | ឆ្នាំអនុម័ត | គោលការណ៍សំខាន់ៗ/សេចក្តីសម្រេចដែលបានអនុម័ត |
|---|---|---|
| ធម្មនុញ្ញ អង្គការសហប្រជាជាតិ | ឆ្នាំ១៩៤៥ | សិទ្ធិសមភាពនៃស្ត្រី និងបុរស។ មាត្រា ១ នៃធម្មនុញ្ញនេះគឺ "សម្រេចឱ្យបាននូវកិច្ចសហប្រតិបត្តិការជាអន្តរជាតិ... ដើម្បីលើកកម្ពស់ និងជំរុញឱ្យមានការគោរពដល់សិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋានសម្រាប់ប្រជាជនទាំងអស់ដោយពុំមានការ បែងចែកលើពូជសាសន៍ ភេទ ភាសា ឬសាសនា"។ |
| អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ (CEDAW) | ឆ្នាំ១៩៧៩ | ប្តេជ្ញាទទួលស្គាល់សិទ្ធិមនុស្សរបស់ស្ត្រី។ អនុសញ្ញាផ្តល់ជាមូលដ្ឋានសម្រាប់ការទទួល ស្គាល់សមភាពរវាងស្ត្រី និងបុរស តាមរយៈការធានាឱ្យបាននូវលទ្ធភាពទទួលបានដោយស្មើភាព និងឱកាសដោយស្មើភាពរបស់ស្ត្រីនៅក្នុងជីវិតនយោបាយ និងជីវិតសាធារណៈ រាប់បញ្ចូលទាំងសិទ្ធិបោះឆ្នោត និងឈរឈ្មោះឱ្យគេបោះឆ្នោត ក៏ដូចជាការអប់រំ សុខាភិបាល និងការងារ។ រដ្ឋភាគីព្រមព្រៀងដាក់ចេញនូវវិធានការចាំបាច់ទាំងអស់រាប់បញ្ចូលទាំងការដាក់ចេញនូវបទប្បញ្ញត្តិ និងវិធានការពិសេសជាបណ្តោះអាសន្ន ដើម្បីឱ្យស្ត្រីអាចទទួលបានសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋានរបស់ពួកគេ។ អនុសញ្ញាគឺជាសន្ធិសញ្ញាសិទ្ធិមនុស្សតែមួយគត់ដែលបញ្ជាក់អំពីសិទ្ធិបន្តពូជរបស់ស្ត្រី និងកំណត់ទិសដៅវប្បធម៌ និងប្រពៃណីដែលមានឥទ្ធិពលក្នុងការកំណត់តួនាទីយេនឌ័រ និងទំនាក់ទំនងគ្រួសារ។<br>ក្នុងឆ្នាំ២០១៨ គណៈកម្មាធិការអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់ នៃការរើសអើង ប្រឆាំងនឹងស្ត្រីភេទ ក៏បានអនុម័តអនុសាសន៍ទូទៅលេខ ៣៧ ស្តីពីវិសាលភាពពាក់ព័ន្ធយេនឌ័រនៃការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយក្នុងបរិបទការប្រែប្រួលអាកាសធាតុ។ (បញ្ហានេះនឹងត្រូវលើកយកមកពិភាក្សាបន្ទាប់ទៀតនៅក្នុងផ្នែកស្តីពីសមភាពយេនឌ័រ វគ្គ គ)។ |
| សន្និសីទអន្តរជាតិស្តីពីប្រជាជន និងអភិវឌ្ឍន៍ (ICPD) | ឆ្នាំ១៩៩២ | បានអនុម័តកម្មវិធីសកម្មភាព ដោយលើកឡើងពីការផ្សារភ្ជាប់គ្នារវាងប្រជាជន និងការអភិវឌ្ឍដែលផ្តោតលើតួនាទីមូលដ្ឋាននៃផលប្រយោជន៍របស់ស្ត្រីក្នុងបញ្ហារបស់ប្រជាជន។ សន្និសីទអន្តរជាតិស្តីពីប្រជាជន និងអភិវឌ្ឍន៍ ក៏បានដាក់ចេញនូវទស្សនាទានសុខភាពផ្លូវភេទ និងបន្តពូជ និងសិទ្ធិបន្តពូជ។ |
| សេចក្តីប្រកាស និងវេទិកាទីក្រុងប៉េកាំងដើម្បីសកម្មភាព | ឆ្នាំ១៩៩៥ | បានដាក់បញ្ចូលនូវសមភាពយេនឌ័រ និងសិទ្ធិរបស់ស្ត្រីនៅគ្រប់ផ្នែកនៃជីវិត។ វេទិកាដើម្បីសកម្មភាពចង់ឃើញពិភពលោកមួយដែលស្ត្រី និងកុមារីម្នាក់ៗ អាចប្រើប្រាស់សេរីភាព និងជម្រើសរបស់ពួកគេ និងទទួលស្គាល់សិទ្ធិរបស់ពួកគេ ដូចជា ការរស់នៅដោយគ្មានអំពើហិង្សា ទៅសាលារៀន ចូលរួមក្នុងការសម្រេចចិត្ត និងទទួលបានប្រាក់ឈ្នួលស្មើគ្នាសម្រាប់ការងារដូចគ្នា។ វេទិកាដើម្បីសកម្មភាពគ្របបណ្តប់លើបញ្ហាសំខាន់ៗចំនួន ១២ ដែលពាក់ព័ន្ធនឹងថ្ងៃនេះដូចកាលពី ២០ឆ្នាំមុន៖ ភាពក្រីក្រ ការអប់រំ និងការបណ្តុះបណ្តាល សុខភាព អំពើហិង្សា ជម្លោះប្រដាប់អាវុធ សេដ្ឋកិច្ច អំណាច និងការសម្រេចចិត្ត យន្តការតាមស្ថាប័ន សិទ្ធិមនុស្ស ប្រព័ន្ធផ្សព្វផ្សាយ បរិស្ថាន និងស្ត្រី និងកុមារី។ |

**តារាងទី១៖ ការប្តេជ្ញាចិត្តជាអន្តរជាតិសំខាន់ៗចំពោះសមភាពយេនឌ័រ (ត)**

| ការប្តេជ្ញាចិត្តជាអន្តរជាតិសំខាន់ៗចំពោះសមភាពយេនឌ័រ | ឆ្នាំអនុម័ត | គោលការណ៍សំខាន់ៗ/សេចក្តីសម្រេចដែលបានអនុម័ត |
|---|---|---|
| គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDGs) | ឆ្នាំ២០១៧ | ដាក់បញ្ចូលគោលដៅជាក់លាក់ (គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ទី៥) សម្រាប់សមភាពយេនឌ័រ ដោយបញ្ជាក់អំពីភាពចាំបាច់ក្នុងការទទួលស្គាល់ថានេះជាគោលដៅអភិវឌ្ឍន៍មួយនិងដាក់បញ្ចូលទិសដៅដើម្បីបញ្ចប់អំពើហិង្សាផ្អែកលើយេនឌ័រ លុបបំបាត់ការរៀបអាពាហ៍ពិពាហ៍កុមារ ការកាត់ប្រដាប់បន្តពូជកុមារ និងធានាឱ្យបាននូវសុខភាពផ្លូវភេទ និងបន្តពូជ លទ្ធភាពទទួលបានការអប់រំដោយស្មើភាព ការពង្រីកឱកាសសេដ្ឋកិច្ចរបស់ស្ត្រី និងការកាត់បន្ថយបន្ទុកនៃការងារថែទាំលើស្ត្រី និងកុមារ។ គោលដៅនេះក៏បានសន្យាអំពី "ការបង្កើនការវិនិយោគឱ្យបានច្រើន ដើម្បីបំពេញចំណុចខ្វះខាតនៃយេនឌ័រ និងពង្រឹងការគាំទ្រសម្រាប់ស្ថាប័ននានាពាក់ព័ន្ធនឹងសមភាពយេនឌ័រ និងការផ្តល់ភាពអង់អាចដល់ស្ត្រីនៅថ្នាក់សកល ថ្នាក់តំបន់ និងថ្នាក់ជាតិ"។ |

*Source: Adapted from UN Women (2014).*

**គន្លឹះសម្រាប់គ្រូឧទ្ទេស**

អ្នកក៏អាចប្រើក្រាហ្វិកព័ត៌មានដែលអាចចែករំលែកបានមួយចំនួនចេញពីឯកសារចែកជូនទី២ សម្រាប់ការធ្វើបទបង្ហាញ។ ឯកសារចែកជូនទី២ នាំជូនអ្នកនូវក្រាហ្វិកព័ត៌មានសំខាន់ៗមួយចំនួន យកចេញពីរបាយការណ៍ដែលលើកឡើងពីចំណុចខ្វះខាតចម្បងៗនៃយេនឌ័រ។

ការគាំពារសិទ្ធិមនុស្សរបស់ស្ត្រីនិងការលុបបំបាត់ការរើសអើងផ្អែកលើយេនឌ័រទាំងអស់ត្រូវបានទទួលស្គាល់ថាជាការទទួលខុសត្រូវសំខាន់ៗនៃរដ្ឋាភិបាលទាំងអស់ដែលជា "អ្នកមានកាតព្វកិច្ច"។ ហេតុនេះ ការរើសអើងផ្អែកលើយេនឌ័រនៅតែជាទម្រង់នៃការដកហូតសិទ្ធិរបស់មនុស្សភាគច្រើននៅជុំវិញពិភពលោក ដូចបានបង្ហាញនៅក្នុង (របាយការណ៍ស្តីពីចំណុចខ្វះខាតនៃយេនឌ័រជាសកលឆ្នាំ២០២០)។ ស្ត្រីជាច្រើនមិនត្រឹមតែមិនទាន់ទទួលបានបទពិសោធន៍ពេញលេញអំពីសិទ្ធិសមភាព និងច្រើនតែត្រូវបានបដិសេធសមភាពនៃឱកាសក្នុងការទទួលបានការអប់រំ សុខាភិបាល ការងារ និងភាពជាកម្មសិទ្ធិលើធនធាន ប៉ុន្តែពួកគេក៏មិនស្ថិតនៅក្នុងក្រុមអ្នកមានអំណាចនិងការសម្រេចចិត្តដែរ។ នេះមិនត្រឹមតែធ្វើឱ្យរារាំងដល់ការរីកចម្រើនផ្ទាល់ខ្លួនរបស់ពួកគេ ប៉ុន្តែវាក៏បានបាត់បង់ឱកាសសាកលក្នុងការទទួលបានអត្ថប្រយោជន៍ពីសក្តានុពលរបស់ពួកគេ ដូចជាភ្នាក់ងារផ្លាស់ប្តូរសេដ្ឋកិច្ច សង្គម និងការអភិវឌ្ឍប្រកបដោយចីរភាព។

ហេតុនេះវាមានសារៈសំខាន់ក្នុងការផ្តល់ភាពអង់អាចដល់ស្ត្រីដើម្បីអាចពង្រីកកំណើនសេដ្ឋកិច្ច លើកកម្ពស់ការអភិវឌ្ឍសង្គម និងបង្កើតសង្គមមួយដែលមានភាពនឹងនរ និងយុត្តិធម៌។ ហេតុនេះ ការផ្តល់ភាពអង់អាចដល់ស្ត្រី បានក្លាយជាវិធីសាស្ត្រមួយដ៏សំខាន់នៅក្នុងវិធីសាស្ត្រអភិវឌ្ឍន៍ទាំងអស់។

ទោះបីជាយ៉ាងនេះក្តី នៅពេលដែលផ្លាស់ប្តូរទៅកាន់ការបង្កើតសង្គមមួយកាន់តែមានសមភាព វាមានសារៈសំខាន់ក្នុងការផ្លាស់ប្តូរឱ្យហួសពីការផ្តល់ភាពអង់អាចដល់ស្ត្រីដើម្បីផ្តោតលើសមភាពយេនឌ័រ៖

> វា តម្រូវឱ្យគិតលើសពីតែស្ត្រី និងសម្លឹងទៅរកការលុបបំបាត់អំពើហិង្សាផ្លូវភេទ និងផ្អែកលើយេនឌ័រ ក៏ដូចជាបុគ្គលម្នាក់ៗនៅក្រុម LGBTIQ។ វាមានសារៈសំខាន់ក្នុងការទទួលស្គាល់ថាពាក្យយេនឌ័របានពង្រីកវិសាលភាពរបស់ខ្លួនលើសពីទស្សនៈគោលពីរនៃបុរស និងស្ត្រី ហើយវាចាំបាច់ដែលត្រូវមានទិដ្ឋភាពអ្នកស្ត្រីនិយមមនុស្សស្រឡាញ់ភេទដូចគ្នា (queer) និងភាពចម្រុះប្រសព្វខាងយេនឌ័រ (intersectionality) ខណៈដែលនៅតែដោះស្រាយកង្វល់យេនឌ័រ។

> វា មានភាពចាំបាច់ក្នុងការទទួលស្គាល់ថា ក្រុមស្ត្រីទាំងអស់មិនដូចគ្នាទេ ហើយក្រុមស្ត្រីប្រភេទខ្លះ ជួបប្រទះនូវទម្រង់នៃការរើសអើងផ្សេងៗបញ្ចូលគ្នា ដោយសារកត្តាអាយុ ជាតិពន្ធ ពិការភាពឬស្ថានភាពសង្គមសេដ្ឋកិច្ចបន្ថែមលើយេនឌ័ររបស់ពួកគេ។ ឧទាហរណ៍ ស្ត្រីជនជាតិដើមភាគតិច ច្រើនតែជួបប្រទះបទពិសោធន៍ផ្សេងៗគ្នា ដែលជាប្រភេទផ្សេងៗគ្នានៃការរើសអើង។ ស្ត្រីជនជាតិដើមភាគតិចដែលរស់នៅក្នុងសហគមន៍ក្រីក្រ និងដាច់ស្រយាល និងទទួលបានការអប់រំក្នុងប្រព័ន្ធតិចតួច ទំនងជាជួបប្រទះនូវការដកហូតសិទ្ធិ និងការលំបាកខ្លាំងជាងអ្នកផ្សេង ។

ហេតុនេះ វិធីសាស្ត្រផ្អែកលើសិទ្ធិមនុស្សជាមូលដ្ឋានចំពោះសមភាពយេនឌ័រប្រើប្រាស់ទស្សនៈភាពចម្រុះប្រសព្វខាងយេនឌ័រ ដែលទទួលស្គាល់ថា ស្ត្រីមានបទពិសោធន៍ និងទស្សនៈផ្សេងគ្នាផ្អែកលើទិដ្ឋភាពអត្តសញ្ញាណរបស់ពួកគេ រាប់បញ្ចូលទាំងពូជសាសន៍ ថ្នាក់ វណ្ណៈ ជាតិពន្ធ និន្នាការផ្លូវភេទ និងអត្តសញ្ញាណ

យេនឌ័រ ពិការភាព សាសនា អាយុ ស្ថានភាពអាពាហ៍ពិពាហ៍ ស្ថាន ភាពក្រុមស្ត្រីជនជាតិដើមភាគតិច និងស្ថានភាពចំណាកស្រុក។ ការផ្តោតជាសំខាន់គឺទៅចូលឱ្យដល់ក្រុមជួបការលំបាកបំផុតនិងដោះស្រាយប្រភេទផ្សេងៗគ្នានៃវិសមភាពដែលជាផ្នែកមួយនៃ មិនមានអ្នកណាម្នាក់ត្រូវបានទុកចោល។ វាមានសារៈសំខាន់ផ្តើមចេញពីទិដ្ឋភាពយេនឌ័រ ដោយសារវាអាចបង្ហាញឱ្យឃើញពីស្ត្រីដែលជួបប្រទះនូវទម្រង់ចម្រុះនៃការរើសអើង និងត្រូវបានផាត់ចេញជាប្រវត្តិសាស្ត្រ។ ទស្សនៈនៃទម្រង់ចម្រុះ និងប្រភេទផ្សេងគ្នានៃការរើសអើងពិពណ៌នាអំពីវិសមភាពផ្អែកលើអត្តសញ្ញាណត្រួតគ្នាដែលបង្កើតឱ្យមានទម្រង់ផ្សេងទៀតនៃការរើសអើង។

**ចំណុចពិភាក្សា**

សាកសួរអ្នកចូលរួមថា ហេតុអ្វីបានជាពួកគេគិតថាវាមានសារៈសំខាន់ក្នុងការផ្លាស់ប្តូរឱ្យហួសពីអត្តសញ្ញាណយេនឌ័រគោលពីរ ទៅរកយេនឌ័រ និងភាពចម្រុះប្រសព្វខាងយេនឌ័រ។

តម្រុយសម្រាប់អ្នកសម្របសម្រួល

> សមភាពយេនឌ័រចំពោះបុរស និងស្ត្រី ច្រើនតែមិនអើពើទៅលើតម្រូវការ និងកង្វល់របស់ក្រុម LGBTIQ (អ្នកដែលមាននិន្នាការផ្លូវភេទ និងអត្តសញ្ញាណផ្សេងទៀត)។ ក្រុមទាំងនេះមានកង្វល់ជាក់លាក់ដែលមិនអាចធ្វើឱ្យមានសមភាពជាមួយអត្តសញ្ញាណគោលពីរណាមួយ។ ឧទាហរណ៍ ក្នុងសង្គមអាស៊ីភាគច្រើន ក្រុមមនុស្សប្តូរភេទមិនត្រូវបានផ្តល់ការទទួលបាន ទីជម្រកមេ និង/ឬត្រូវបានបង្ខំឱ្យនៅក្នុងជម្រកជាមួយបុរស ដែលធ្វើឱ្យពួកគេប្រឈមទៅនឹងការបៀតបៀនផ្លូវភេទ ។

> ដូចគ្នាដែរស្ត្រីពុំមែនជាក្រុមដែលមានភាពដូចគ្នាទេ។ទស្សនៈប្រពៃណីនៃស្ត្រីទោះបីជានៅក្នុងសុន្ទរកថាយេនឌ័រច្រើនតែធ្វើឱ្យមានសមភាពជាមួយសប្បុរស សក់ត្រង់ រាងកាយមាំមួន និងស្ត្រីវ័យក្មេងក្នុងវ័យបន្តពូជ។ ដូចយើងបានដឹងស្រាប់ហើយថា តួនាទីយេនឌ័រ ការទទួលខុសត្រូវ និងផ្នត់គំនិតពុំមែនជាសកលទេ ហេតុនេះវាមានសារៈសំខាន់ក្នុងការស្វែងយល់ពីតួនាទី ការទទួលខុសត្រូវពាក់ព័ន្ធនឹងស្ត្រីដែលមានពូជសាសន៍ ក្រុមជនជាតិដើម និន្នាការផ្លូវភេទ សមត្ថភាព និងអាយុផ្សេងៗគ្នា។ ការវិភាគបែបនេះ នឹងមិនត្រឹមតែជួយឱ្យយល់អំពីកង្វល់ជាក់ស្តែងដែលស្ត្រីទាំងនោះកំពុងជួបប្រទះ ប៉ុន្តែវាក៏អាចផ្តល់ជាពន្លឺដល់ការដកហូតសិទ្ធិ និងការរើសអើងចម្រុះដែលពួកគេកំពុងប្រឈម។ឧទាហរណ៍ បញ្ហាដែលប្រឈមដោយស្ត្រីពិការវ័យជំទង់ និងកុមារីដែលមកពីសហគមន៍ដើមជនជាតិភាគតិច នឹងខុសគ្នា (ច្រើនតែបន្ថែមទៀត)ពីកុមារីនិងស្ត្រីវ័យជំទង់ដែលមកពីសហគមន៍ភាគច្រើន ក៏ដូចជាពីកុមារី និងស្ត្រីដែលមកពីសហគមន៍របស់ខ្លួន។

**គន្លឹះសម្រាប់គ្រូឧទ្ទេស**

អ្នកក៏អាចមើលវគ្គទី២ នៃម៉ូឌុលអន្តរវិស័យភាព ខាងយេនឌ័រនៅផ្នែកសញ្ញាព្រួញ ដើម្បីកាន់តែជ្រាបច្បាស់។
ដូចគ្នាដែរ អ្នកក៏អាចទាញយកពីគេហទំព័រ៖ https://arrow.org.my/wp-content/uploads/2019/03/E-Module_InterSEXionality.pdf.

## ការអនុវត្តវិធីសាស្ត្រផ្អែកលើសិទ្ធិមនុស្ស និងមិនមាន អ្នកម្នាក់ត្រូវបានទុកចោល តាមរយៈវ៉ែនតាយេនឌ័រ

ការប្រើវ៉ែនតាយេនឌ័រពុំមែនតែងតែមានន័យថា ជាការប្រព្រឹត្តចំពោះស្ត្រី និងក្រុមយេនឌ័រផ្សេងទៀតជាពិសេសនោះទេ ប៉ុន្តែវាចាំបាច់ក្នុងការកំណត់ដោយឡែកនូវភាពលម្អៀងខាងយេនឌ័រឬ "បទដ្ឋានបុរស" នៅគ្រប់ដំណាក់កាលនៃការរៀបចំកម្មវិធី និងដើម្បីអាចរំញោចដល់ឥរិយាបថមិនច្បាស់លាស់អំពីបុរសនិងស្ត្រីដែលអាចនាំទៅរកលទ្ធផលដោយអចេតនាដែលបណ្តាលមកពីការសម្រេចចិត្តដោយលម្អៀង។ នៅពេលដែលភាពរំញោចនេះអាចសម្រេចបាន នោះវាចាំបាច់ត្រូវជំរុញបន្ថែមដោយការវិភាគយេនឌ័រ។ ដើម្បីអាចវិភាគបាន វាចាំបាច់ត្រូវមានទិន្នន័យអំពីភេទ អាយុនិងការបែងចែកចម្រុះ។ទិន្នន័យនេះចាំបាច់ត្រូវទទួលស្គាល់នូវភាពចម្រុះនៃបញ្ហានេះ ដែលទទួលស្គាល់ភាពចម្រុះនៃអត្តសញ្ញាណយេនឌ័រ តួនាទីយេនឌ័រ និងតម្រូវការផ្សេងៗគ្នា ជាជាងចាត់ទុកយេនឌ័រថាជាក្រុមស្ត្រីដែលមានភាពដូចគ្នា។ ការវិភាគនេះចាំបាច់ត្រូវយកមកប្រើដើម្បីវាយតម្លៃផលវិបាកនៃសកម្មភាពដែលបានធ្វើផែនការរាប់បញ្ចូលទាំងការរៀបចំបទប្បញ្ញត្តិគោលនយោបាយ ឬកម្មវិធីសម្រាប់បុរស និងស្ត្រី និង ការកំណត់អត្តសញ្ញាណយេនឌ័រ និងអត្តសញ្ញាណសង្គមផ្សេងទៀត។ បន្ថែមពីលើនេះ សកម្មភាព/ការការពារចាំបាច់ត្រូវដាក់បញ្ចូលទៅក្នុងកម្មវិធីដើម្បីធានាឱ្យបានថាអត្ថប្រយោជន៍ត្រូវបានឈានទៅដល់គ្រប់ក្រុមយេនឌ័រ និង គ្រប់ក្រុមសង្គម។

ដំណើរទាំងអស់នេះចាំបាច់ត្រូវតែជាផ្នែកមួយនៃការរៀបចំកម្មវិធីជាមូលដ្ឋាន និងមិនត្រូវមកដាក់បញ្ចូលនៅពេលក្រោយ។ ការដាក់បញ្ចូលការអនុវត្តការរៀបចំកម្មវិធី/ការបង្កើតគម្រោងស្តង់ដារទាំងនេះ នៅគ្រប់កម្រិត និងនៅគ្រប់វិស័យ គឺជាដំណើរការ នៃការបញ្ជ្រាបយេនឌ័រ។ ដូចបានកំណត់ដោយក្រុមប្រឹក្សាសេដ្ឋកិច្ចនិងសង្គមរបស់អង្គការសហប្រជាជាតិ (ឆ្នាំ១៩៩៧) ការបញ្ជ្រាបយេនឌ័រគឺជា "ដំណើរការនៃការវាយតម្លៃផលវិបាកសម្រាប់ស្ត្រីបុរស (និងអត្តសញ្ញាណយេនឌ័រផ្សេងទៀត) នៃសកម្មភាពដែលបានធ្វើផែនការណាមួយ រាប់បញ្ចូលទាំងការរៀបចំបទប្បញ្ញត្តិ

គោលនយោបាយ ឬកម្មវិធី នៅគ្រប់ផ្នែក និងគ្រប់កម្រិត។ វាជាយុទ្ធសាស្ត្រមួយសម្រាប់បង្កើតឱ្យមានកង្វល់យេនឌ័រផ្សេងគ្នា និងបទពិសោធន៍នានាដែលជាផ្នែកមួយនៃវិសាលភាពស្នូលនៃការរៀបចំ ការអនុវត្ត ការតាមដាន និងវាយតម្លៃគោលនយោបាយ និងកម្មវិធីនៅគ្រប់ទិដ្ឋភាពនយោបាយ សេដ្ឋកិច្ច និងសង្គម ដើម្បីឱ្យមនុស្សគ្រប់រូបទទួលបានអត្ថប្រយោជន៍ដោយស្មើភាព ហើយវិសមភាពនឹងលែងមានជារៀងរហូត។″

**FIGURE 1-2: GENDER EQUALITY STRATEGIES**




*Source: Adapted from UN Women (2014).*

ស្របតាមវិធីសាស្ត្រនេះ អង្គភាពអង្គការសហប្រជាជាតិ លើកកំពស់សមភាពយេនឌ័រនិងផ្ដល់ភាពអង់អាចដល់ស្ត្រី (ឆ្នាំ២០១៤) ក៏បានផ្ដល់អនុសាសន៍លើការដាក់បញ្ចូលគោលដៅសមភាពយេនឌ័រតែឯកឯងដែលដោះស្រាយលើ៖សេរីភាពពីអំពើហិង្សាប្រឆាំងនឹងស្ត្រី និងកុមារី វិសមភាពយេនឌ័រក្នុងការបែងចែកសមត្ថភាព និងវិសមភាពយេនឌ័រក្នុងការសម្រេចចិត្ត នៅគ្រប់ទិដ្ឋភាពនៃជីវិតសាធារណៈ និងឯកជន ដើម្បីសម្រេចនូវអនុសាសន៍នេះ បន្ថែមលើការបញ្ជ្រាបយេនឌ័រ។អនុសាសន៍នេះតម្រូវឱ្យវិធីសាស្ត្រផ្លាស់ប្ដូរផ្នត់គំនិតយេនឌ័រ ដែលផ្ដោតថា″ការប្ដេជ្ញាចិត្តចំពោះសមភាពយេនឌ័រគួរតែជាសកលដោយដោះស្រាយលើមូលដ្ឋានរចនាសម្ព័ន្ធនៃវិសមភាពផ្អែកលើយេនឌ័រ រាប់បញ្ចូលទាំងវិសាលភាពចំនួនបីនៃការអភិវឌ្ឍប្រកបដោយចីរភាព នោះគឺសង្គម សេដ្ឋកិច្ច និងបរិស្ថាន និងធានាគណនេយ្យភាព″ (UN Women ឆ្នាំ២០១៤)។ សម្រាប់កិច្ចការនេះ វាចាំបាច់ត្រូវស្វែងយល់អំពីឌីណាមិក រចនាសម្ព័ន្ធ អំណាច និងនយោបាយដែលជំរុញក្រុមដាក់លាក់ឱ្យបន្តដំណើរទៅមុខ និងធ្វើឱ្យវិសមភាពកាន់តែស៊ីជម្រៅ ព្រមទាំងកញ្ចប់គោលនយោបាយ និងកម្មវិធីដ៏ទូលំទូលាយមួយដែលដាក់បញ្ចូលនូវការគាំពារសង្គមជាសកល និងសេវាចាំបាច់ដើម្បីធានានូវស្តង់ដារជីវភាពរស់នៅគ្រប់គ្រាន់និងគោលនយោបាយពន្ធដែលបែងចែកឡើងវិញនិងកំណើនតាមថ្នាក់ដើម្បីដោះស្រាយវិសមភាពប្រាក់ចំណូល។

គោលដៅចុងក្រោយនៃវិធីសាស្ត្រទាំងពីរនេះគឺ សមភាពយេនឌ័រ។ ទោះបីជាយ៉ាងនេះក្ដី អង្គការអភិវឌ្ឍន៍ភាគច្រើន បានដាក់ចេញនូវវិធីសាស្ត្រតាមដានភ្លោះ (Twin-track approach) ដើម្បីជំរុញឱ្យមានសមភាពយេនឌ័រ ដែលរួមបញ្ចូលទាំងការផ្ដោតទៅលើការបញ្ចូលកង្វល់អំពីយេនឌ័រនិងការផ្ដល់ភាពអង់អាចដល់ក្រុមស្ត្រីដាក់លាក់និងអ្នកទាំងឡាយណាដែលមានអត្តសញ្ញាណយេនឌ័រផ្សេងទៀត។

## សមភាពយេនឌ័រ៖ករណីសម្រាប់ការកែតម្រូវបរាជ័យនៃទីផ្សារ

សមភាពយេនឌ័រគឺជាបញ្ហាស្មុគស្មាញលក្ខណៈនយោបាយ។ ចំពោះទិដ្ឋភាពម្ខាង មានការបង្កើនការយល់ដឹង និងការទទួលស្គាល់ក្នុងការធានាឱ្យបាននូវសមភាពយេនឌ័រ។ចំពោះទិដ្ឋភាពម្ខាងទៀត សេចក្ដីសម្រេចចំពោះគោលនយោបាយជាក់ស្ដែងផ្សេងទៀតដែលទទួលស្គាល់លើការបែងចែកធនធានប្រកបដោយសមធម៌ក្នុងចំណោមយេនឌ័រផ្សេងទៀត នៅតែមានផ្លូវវែងឆ្ងាយទៅមុខទៀត។ បើទោះបីជាសមធម៌យេនឌ័រមិនត្រឹមតែជា "បញ្ហាយេនឌ័រ" ប៉ុន្តែបញ្ហាសិទ្ធិមនុស្សគួរតែមើលឃើញថាជាលក្ខខណ្ឌដំបូង និងជាសុចនាករសម្រាប់ការអភិវឌ្ឍប្រជាជនកណ្ដាលប្រកបដោយចីរភាព។

ការអភិវឌ្ឍប្រកបដោយចីរភាពពឹងផ្អែកលើការបញ្ចប់ការរើសអើងលើយេនឌ័រ និងការផ្ដល់ឱកាសដោយស្មើភាពដល់មនុស្សគ្រប់រូប ជាពិសេសសម្រាប់ការអប់រំ និងការងារ។ ការសម្រេចបានទិសដៅគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព និងរបៀបវារៈឆ្នាំ ២០៣០ តម្រូវឱ្យមានការបញ្ជ្រាបយេនឌ័រ និងវិធីសាស្ត្រផ្លាស់ប្ដូរផ្នត់គំនិតយេនឌ័រដោយយកចិត្តទុកដាក់ដែលត្រូវយកមកអនុវត្តនៅគ្រប់គោលនយោបាយ និងកម្មវិធីទាំងអស់។ វាបង្ហាញថា ផលប្រយោជន៍ តម្រូវការ និងអាទិភាពរបស់ទាំងស្ត្រី និងបុរសនឹងចាំបាច់ត្រូវយកមកពិចារណានៅគ្រប់ការរៀបចំកម្មវិធី ខណៈដែលនៅតែទទួលស្គាល់ពីភាពចម្រុះនៃក្រុមផ្សេងគ្នានៃស្ត្រីនិងបុរស។

ទោះបីយ៉ាងណា ភាពជាប់ទាក់ទងដ៏ស្មុគស្មាញនៃសមភាពយេនឌ័រជាមួយនឹងការសម្រេចចិត្តក្នុងគ្រួសារ ច្រើនតែបង្កើតឱ្យមានបញ្ហានេះ ដោយសាររដ្ឋាភិបាលព្យាយាមរារាំងពីការជ្រៀតជ្រែកចូលក្នុងជម្រើសផ្ទាល់ខ្លួន ហើយក្នុងវិសាលភាពខ្លះ រដ្ឋាភិបាលផ្ដល់នូវការអនុម័តផ្អែកបច្ចេកទេសចំពោះបទដ្ឋាន សង្គមវប្បធម៌យេនឌ័រដែលមានស្រាប់។ទោះបីជាយ៉ាងនេះក្ដី ករណីមួយចាំបាច់

ត្រូវបង្កើតឡើងដើម្បីដោះស្រាយវិសមភាពយេនឌ័រក្នុងការបែងចែកធនធានក្នុងគ្រួសារតាមរយៈការស្វែងយល់ថាវាទទួលឥទ្ធិពលពីសញ្ញាទីផ្សារ និងបទដ្ឋានស្ថាប័នដែលពុំបានចាប់យកប្រយោជន៍ពេញលេញសម្រាប់សង្គមនៃការវិនិយោគលើសមភាពនៃជីវិតរបស់ស្ត្រី។ វាច្រើនតែបង្កើតឱ្យមានភាពមិនច្បាស់លាស់ក្នុងប្រសិទ្ធភាព និងកំណើនសេដ្ឋកិច្ច។ ហេតុនេះ គោលនយោបាយសាធារណៈចាំបាច់ត្រូវទូទាត់ជួសបរាជ័យនៃទីផ្សារទាំងនេះដោយធានាឱ្យបាននូវធនធានចំពោះការវិនិយោគទាំងនេះជាមួយនឹងលទ្ធផលសង្គមកម្រិតខ្ពស់បំផុត និងដែលធ្វើឱ្យមានភាពស្មើភាពចំពោះក្រុមយេនឌ័រ និងក្រុមសង្គមផ្សេងៗគ្នា។ វាក៏មានសារៈសំខាន់ដោយសារថា ប្រសិនបើគ្មានការដោះស្រាយបញ្ហាវិសមភាពដែលមានស្រាប់នោះនឹងគ្មានការអភិវឌ្ឍប្រកបដោយចីរភាពនិងការទទួលស្គាល់សក្តានុពលពេញលេញនៃសិទ្ធិមនុស្ស។

**ចំណុចពិភាក្សា**

បញ្ចប់វគ្គដោយសាកសួរអ្នកចូលរួមឱ្យចែករំលែកឧទាហរណ៍នៃការបញ្ជ្រាបយេនឌ័រ និងគម្រោង ផ្លាស់ប្តូរផ្នត់គំនិតយេនឌ័រ?

**គម្រុយសម្រាប់អ្នកសម្របសម្រួល**

> ផ្តល់ការបណ្តុះបណ្តាលអំពីបរចិញ្ចឹមជីវិតការងាររបស់ស្ត្រីក្នុងសកម្មភាពបង្កើតគម្រោង ការចូលរួមរបស់ស្ត្រីក្នុងការរៀបចំផែនការ មីក្រូហិរញ្ញវត្ថុសម្រាប់ស្ត្រី គ្រឿងបរិក្ខាសាលារៀនដាច់ដោយឡែក ជម្រក បង្គន់។ល។ គឺជាឧទាហរណ៍នៃការបញ្ជ្រាបយេនឌ័រនៅក្នុងគម្រោង។ ឧទាហរណ៍ ធនាគារអភិវឌ្ឍន៍អាស៊ីបានផ្តល់មូលនិធិគម្រោងអភិវឌ្ឍន៍ទីប្រជុំជនរបៀងសេដ្ឋកិច្ចភាគខាងត្បូងនៃមហាអនុតំបន់ទន្លេមេគង្គសម្រាប់វិធានការការពារទឹកជំនន់សម្រាប់ស្ត្រី ទាក់ទងនឹងទឹកជំនន់ដែលបណ្តាលមកពីការប្រែប្រួលអាកាសធាតុនិងដើម្បីសម្រាលបន្ទុកពួកគេពីការសម្អាតក្រោយទឹកជំនន់និងផ្តល់ការថែទាំដល់សមាជិកគ្រួសារដែលមានជំងឺទាក់ទងនឹងទឹកជំនន់។ ពាក់ព័ន្ធហេដ្ឋារចនាសម្ព័ន្ធបន្សាំ ផ្លូវថ្នល់ដែលបានបញ្ចូលទៅក្នុងគម្រោងការងារទឹកជំនន់ នឹងអាចឱ្យស្ត្រីមានលទ្ធភាពទទួលបានកាន់តែប្រសើរនូវសេវា និងទីផ្សារ ព្រមទាំងលើកកម្ពស់ការចល័តរបស់ពួកគេ។ គម្រោងដឹកជញ្ជូនតាមទីក្រុងចំនួនពីរនៅប្រទេសវៀតណាម បានពង្រឹងមធ្យោបាយធ្វើដំណើរនៅទីក្រុងប្រកបដោយចីរភាពសម្រាប់រថភ្លើងខ្សែទី៣ ដោយបានទុកកន្លែងទំនេរសម្រាប់ហាងលក់ដូររបស់ស្ត្រី និងអ្នកលក់ដូរជាស្ត្រី និងបានផ្តល់កន្លែងអង្គុយអាទិភាពសម្រាប់ស្ត្រី និងការរៀបចំពេលវេលាដោយផ្អែកលើតម្រូវការមធ្យោបាយដឹកជញ្ជូនរបស់ស្ត្រីហើយមធ្យោបាយធ្វើដំណើរនៅទីក្រុងប្រកបដោយចីរភាពសម្រាប់ខ្សែដឹកជញ្ជូនឆ្លងកាត់រហ័សទី២នៅទីក្រុងហូជីមិញត្រូវបានរចនាឡើងដោយទុកកន្លែងរង់ចាំសម្រាប់តែស្ត្រីប៉ុណ្ណោះដោយមានពន្លឺសុវត្ថិភាព បង្គន់ដាច់ដោយឡែក និងកន្លែងលក់ដូរសម្រាប់អាជីវកម្មខ្នាតតូចដែលកាន់កាប់ឬដំណើរការដោយស្ត្រី (ធនាគារអភិវឌ្ឍន៍អាស៊ី ឆ្នាំ២០១៦)។

> គម្រោងដែលផ្តល់នូវបំណិនជីវិតសម្រាប់កុមារី និងកុមារាវ័យជំទង់និងការចូលរួមយ៉ាងសកម្មនៃភាគីពាក់ព័ន្ធសំខាន់ៗ (គ្រូបង្រៀន តំណាងរដ្ឋាភិបាលមូលដ្ឋាន អ្នកផ្តល់សេវាសុខាភិបាល) ដើម្បីស្វែងយល់ និងតតាំងចំពោះការអនុវត្តដែលមានលក្ខណៈរើសអើងខាងយេនឌ័រដោយដោះស្រាយអំពើហិង្សាផ្អែកលើយេនឌ័រនិងការបង្កើតយន្តការឆ្លើយតបតាមស្ថាប័ន ដោយជំរុញឱ្យស្ត្រីមានសិទ្ធិកាន់កាប់ដី ផ្ទះសម្បែង និងទ្រព្យសម្បត្តិផ្សេងទៀតនឹងបង្កើតឱ្យមានគម្រោងដែលផ្លាស់ប្តូរផ្នត់គំនិតយេនឌ័រ។ ឧទាហរណ៍ គម្រោងដែលផ្តល់ភាពអង់អាចដល់ស្ត្រីដែលជាជនជាតិដើមភាគតិចតាមរយៈអង្គការអន្តរជាតិ CARE នៅប្រទេសវៀតណាម ដែលផ្តោតលើភាពអង់អាចដល់ស្ត្រីដែលជាជនជាតិដើមភាគតិចនៅតំបន់ដាច់ស្រយាលឱ្យចូលរួមក្នុងការរៀបចំផែនការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចនិងការសម្រេចចិត្តក្នុងមូលដ្ឋាន (Gender Just Climate Solution ឆ្នាំ២០១៦)។

# ម៉ូឌុល១ វគ្គ ខ៖

2:00:00

## ហានិភ័យការប្រែប្រួលអាកាសធាតុ ភាពធន់ និង ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ

**ទិដ្ឋភាពទូទៅ**

នៅចុងបញ្ចប់នៃវគ្គនេះ អ្នកចូលរួមគួរតែអាចស្គាល់ពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុនៅអាស៊ី និងអាចផ្សារភ្ជាប់រូបភាពជាម៉ាក្រូទៅនឹងហានិភ័យអាកាសធាតុ និងគ្រោះមហន្តរាយដែលបានកើតនៅក្នុងតំបន់ភូមិសាស្ត្ររបស់ពួកគេ។ អ្នកចូលរួមនឹងអាចកំណត់វាងទស្សនៈនៃភាពតានតឹង និងភាពតក់ស្លុតដែលបណ្តាលមកពីអាកាសធាតុនិងភាពចាំបាច់ដែលត្រូវបញ្ចូលចំណុចទាំងពីរនេះទៅក្នុងយុទ្ធសាស្ត្រភាពធន់ និង ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយជារួម។

**មាតិកា**

ក ) តថភាពនៃការឡើងកម្តៅសកល និងការប្រែប្រួលអាកាសធាតុ
ខ ) ការយល់ឃើញអំពីហានិភ័យនៃការប្រែប្រួលអាកាសធាតុ និងផលប៉ះពាល់នៅអាស៊ី
គ ) ហានិភ័យអាកាសធាតុ គ្រោះមហន្តរាយ និងការអភិវឌ្ឍប្រកបដោយចីរភាព
ឃ ) វិសមភាព និងភាពងាយរងគ្រោះដែលកំពុងកើតមានចំពោះហានិភ័យអាកាសធាតុ
ង ) ការបន្សាំនឹងការប្រែប្រួលអាកាសធាតុ ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងការកសាងភាពធន់
ច ) ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ការបន្សាំនឹងការប្រែប្រួលអាកាសធាតុ និងការកសាងភាពធន់សម្រាប់សហគមន៍ក្រីក្រ ការបង្កើតផែនទីឧបសគ្គ។

**ឯកសារ**

ការធ្វើបទបង្ហាញជា Power point
ឧបករណ៍សម្រាប់មើលខ្សែភាពយន្តនៅលើ YouTube
គំនូសអ៊ីស្តូក្រាមដែលបិទនៅលើជញ្ជាំង ឬក្រដាសថតចម្លង
ក្តារខៀន និងប៊ិចហ្វឺត
ឯកសារចែកជូន

**តារាងពេលវេលា**

| រយៈពេល | សកម្មភាព |
|---|---|
| ៥ នាទី | > ការចែករំលែកអំពីទិដ្ឋភាពទូទៅ និងមាតិកានៃវគ្គ |
| ៤០ នាទី | > "អ៊ីស្តូក្រាម" ស្តីពីការប្រែប្រួលអាកាសធាតុ ( សូមមើលលំហាត់ទី៤ ) |
| ៤៥ នាទី | ការមើលខ្សែភាពយន្តស្តីពី "របាយការណ៍វាយតម្លៃ លើកទី៥ របស់ IPCC" បន្តដោយការពិភាក្សាជាក្រុមលើប្រធានបទ"ការអង្កេតលើការប្រែប្រួលអាកាសធាតុនិងផលប៉ះពាល់" ដោយប្រើប្រាស់ឯកសារចែកជូនទី៣ (ត្រូវបានផ្តល់អនុសាសន៍សម្រាប់វគ្គសិក្សាមូលដ្ឋាន)។<br>ឬ<br>• ការធ្វើបទបង្ហាញជា Power point ស្តីពី "ហានិភ័យអាកាសធាតុជាសកល ការបន្សាំ ការកសាងភាពធន់ និងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ" (ត្រូវបានផ្តល់អនុសាសន៍សម្រាប់វគ្គសិក្សាមូលដ្ឋាន)។ |
| ៣០ នាទី | • "ការអង្កេតលើការប្រែប្រួលអាកាសធាតុនិងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងទស្សនៈភាពធន់" ( សូមមើលលំហាត់ទី៥ និងឯកសារចែកជូនទី៤ )។ |

**កំណត់សម្គាល់ណែនាំ**

ចាប់ផ្តើមវគ្គជាមួយនឹងការចែករំលែកពីទិដ្ឋភាពទូទៅ និងមាតិកា។ ត្រូវធានាថាគំនូសអ៊ីស្តូក្រាមត្រូវបានបិទនៅលើជញ្ជាំងទុកជាមុន ឬនៅលើក្រដាសថតចម្លងសម្រាប់ការពិភាក្សាក្រុមតូច។ សម្របសម្រួល "លំហាត់គំនូសអ៊ីស្តូក្រាម" ( សូមមើលលំហាត់ទី៤ )។

សម្រាប់វគ្គសិក្សាមូលដ្ឋាន សូមតាមដានវាជាមួយការមើលវីដេអូស្តីពី "របាយការណ៍វាយតម្លៃ ( ក្រុមលើកទី៥ របស់ IPCC" ដែលអាចរកបាននៅលើគេហទំព័រ

https://www.youtube.com/watch?v=fGH0dAwM-QE&feature=youtu.be។

សង្កត់ធ្ងន់លើចំណុចដែលថាការប្រែប្រួលអាកាសធាតុគឺជាការពិតនិងផ្តល់ផលប៉ះពាល់ដល់យើងគ្រប់គ្នា។ ផ្តល់ឯកសារថតចម្លងនៃឯកសារចែកជូនទី៣ដល់អ្នកចូលរួមគ្រប់គ្នា និងសម្របសម្រួលឱ្យមានការ

**កំណត់សម្គាល់ណែនាំ**

ពិភាក្សាជាក្រុមតូចលើប្រធានបទដដែលនេះ។

សម្រាប់ក្រុមដែលមានការយល់ដឹងកម្រិតខ្ពស់ សូមបន្តវាជាមួយនឹង PowerPoint ដោយប្រើប្រាស់មាតិកាបច្ចេកទេសដែលយកចេញពី "ហានិភ័យអាកាសធាតុជាសកល ការបន្សាំ ការកសាងភាពធន់ និងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ"។

បញ្ចប់វគ្គជាមួយនឹងលំហាត់ដែលមានការចូលរួម ដើម្បីជួយពួកគេឱ្យមានការយល់ដឹងកាន់តែប្រសើរអំពីទស្សនៈភាពធន់ (សូមមើលលំហាត់ទី៥ និងឯកសារចែកជូនទី៤)។

## ហានិភ័យអាកាសធាតុសកល ការបន្សាំ ការកសាង ភាពធន់ និងការកាត់បន្ថយគ្រោះមហន្តរាយ

**តថភាពនៃការកើនឡើងកម្តៅសកល និងការប្រែប្រួលអាកាសធាតុ**

ជាញឹកញាប់យើងលាន់មាត់ដូចជា "ថ្ងៃនេះពិតជាល្អណាស់!" "ត្រជាក់ណាស់។ ម្រាមដៃរបស់ខ្ញុំចង់ជ្រុះហើយ!" "ថ្ងៃនេះក្តៅខ្លាំងជាងម្សិលមិញ" "តើអ្នកគិតថាវាអាចភ្លៀងទេថ្ងៃនេះ?" ទាំងនេះគឺជាការពិភាក្សាដែលពាក់ព័ន្ធនឹងធាតុអាកាស។ធាតុអាកាសគឺជាអ្វីដែលធ្វើដែលរំញោចអារម្មណ៍របស់យើងក្នុងអំឡុងពេលថ្ងៃ ឬពេលយប់។ ធាតុអាកាសផ្លាស់ប្តូរនៅពេលវេលាផ្សេងៗក្នុងអំឡុងពេលថ្ងៃខ្លួនឯងផ្ទាល់ និងពីរដូវមួយទៅរដូវមួយ។

**យើងដឹងថាតើធាតុអាកាសអ្វីនឹងកើតមានឡើង៖**

ក្នុងអំឡុងរដូវនីមួយៗ៖ វាក្តៅក្នុងរដូវក្តៅ។ ស្ថានីយ Hill មានធាតុអាកាសត្រជាក់នៅអំឡុងពេលរដូវក្តៅ។ និង
ឆ្លងទីតាំង៖ នៅតំបន់ភ្នំមានភ្លៀងខ្លាំងជាងនៅតំបន់ឆ្នេរ។ ព្រិលធ្លាក់នៅភ្នំហិម៉ាឡៃក្នុងអំឡុងសិសិររដូវ។
ការព្យាករពីស្ថានភាពធាតុអាកាសក្នុងអំឡុងរដូវ ខែ ឬនៅទីតាំងជាក់លាក់មួយ គឺជា "អាកាសធាតុ" របស់តំបន់នោះ។ អាកាសធាតុគឺជាធាតុអាកាសមធ្យមនៃតំបន់ជាក់លាក់មួយក្នុងរយៈពេលមួយ។ អាកាសធាតុនៅទីកន្លែងណាមួយនៅលើផែនដីរបស់យើងអាចត្រូវបានពិពណ៌នាយ៉ាងល្អទៅតាមលទ្ធផលនៃតុល្យភាពងាយប្រែប្រួលមួយរវាងព្រះអាទិត្យ បរិយាកាស សមុទ្រ ប្រព័ន្ធទឹក រុក្ខជាតិ សារពាង្គកាយមានជីវិត និងឋានលេខាសាស្ត្រ។ កត្តាសំខាន់បំផុតដែលត្រូវយកមកពិចារណាគឺភ្លៀង ពន្លឺព្រះអាទិត្យ សំណើម ខ្យល់ និងសីតុណ្ហភាព។

ការប្រែប្រួលស្ថានភាពធាតុអាកាសមធ្យមក្នុងតំបន់ជាក់លាក់មួយគឺជាការប្រែប្រួលអាកាសធាតុ។ការណ៍នេះរាប់បញ្ចូលទាំងការប្រែប្រួលសីតុណ្ហភាពសណ្ឋានខ្យល់និងកំណកអាកាសធាតុផងដែរ។ ការប្រែប្រួលនេះកើតមាននៅក្នុងពិភពលោក និងបង្កឱ្យមានក្តីកង្វល់ដល់ភពផែនដីទាំងមូល។ ការប្រែប្រួលទាំងនេះជាច្រើនបង្កឱ្យមានការកើនឡើងកម្តៅសកល។

ការកើនឡើងកម្តៅសកលគឺជាការកើនឡើងសីតុណ្ហភាពនៃផ្ទៃខាងលើនិងខ្យល់របស់ភពផែនដីក្នុងរយៈពេលមួយ។ ផ្ទៃខាងលើនិងខ្យល់របស់ភពផែនដីបានកើនឡើងកម្តៅសន្សឹមៗក្នុងរយៈពេលរាប់ពាន់ឆ្នាំដោយសារបុព្វហេតុធម្មជាតិ។ទោះជាយ៉ាងណានៅក្នុងមួយសតវត្សរ៍ចុងក្រោយនេះ ផែនដីរបស់យើងបានកើនឡើងកម្តៅលឿនមិនធ្លាប់មានដោយសារការកើនឡើងការប្រមូលផ្តុំឧស្ម័នផ្ទះកញ្ចក់។

ក្រុមការងារអន្តររដ្ឋាភិបាលស្តីពីការប្រែប្រួលអាកាសធាតុ (IPCC) តាមរយៈរបាយការណ៍វាយតម្លៃ (ARs) ផ្សេងៗរបស់ខ្លួន អះអាងថា ឥទ្ធិពលរបស់មនុស្សលើប្រព័ន្ធអាកាសធាតុកើតមានច្បាស់ណាស់ និងកំពុងកើនឡើង ហើយកត្តានេះគឺជាបុព្វហេតុមួយក្នុងចំណោមបុព្វហេតុធំៗនៃការកើនឡើងកម្តៅសកល និងការប្រែប្រួលអាកាសធាតុ។ នៅក្នុងរបាយការណ៍វាយតម្លៃទី៥ របស់ខ្លួន (ឆ្នាំ២០១៥) IPCC បានលើកឡើងថា៖ "ការប្រែប្រួលដែលត្រូវបានសង្កេតមើលជាច្រើនចាប់តាំងពីទសវត្សរ៍ឆ្នាំ១៩៥០ មកមិនធ្លាប់កើតមានពីមុនមកនោះទេក្នុងរយៈពេលប៉ុន្មានទសវត្សរ៍ រហូតមកដល់សហវត្សរ៍។ ឥឡូវនេះ IPCC មានភាពប្រាកដប្រជា ៩៥%ថាមនុស្សគឺជាបុព្វហេតុចម្បងនៃការកើនឡើងកម្តៅសកលបច្ចុប្បន្ន"។ ការប្រែងប្រួលដែលត្រូវបានសង្កេតឃើញសំខាន់ៗដែលត្រូវបានរំលេចក្នុងរបាយការណ៍វាយតម្លៃទី៥ រួមមាន៖

> ការកើនឡើងកម្តៅពិភពលោកដោយសារសកម្មភាពរបស់មនុស្សបានបង្កឱ្យមានការកើនឡើងសីតុណ្ហភាពពិភពលោកប្រហែល ១អង្សាសេគិតចាប់ពីកម្រិតមុនឧស្សាហ៍វូនីយកម្ម។
> ចន្លោះពីឆ្នាំ១៩០១ដល់ឆ្នាំ២០១០កម្រិតទឹកសមុទ្រជាមធ្យមក្នុងពិភពលោកបានកើនឡើង០,១៩ម៉ែត្រ។អត្រានៃការកើនឡើងកម្រិតទឹកសមុទ្រចាប់តាំងពីពាក់កណ្តាលសតវត្សរ៍ទី ១៩ មានទំហំធំជាងអត្រាមធ្យមក្នុងអំឡុងពេលពីរសហវត្សរ៍កន្លងមកនេះ ហើយវាទំនងជាខ្លាំងថា ការកើនឡើងកម្រិតទឹកសមុទ្រដ៏ខ្លាំងដូចទៅនឹងជំនន់ទឹកសមុទ្រ បានកើនឡើងគិតចាប់ពីឆ្នាំ១៩៧០មក។
> ការបាត់បង់ដោយផ្ទាល់និងការបាត់បង់ដែលត្រូវបានធានាដោយសារគ្រោះមហន្តរាយពាក់ព័ន្ធនឹងធាតុអាកាសបានកើនឡើងជាបន្តបន្ទាប់ក្នុងរយៈពេលប៉ុន្មានទសវត្សរ៍ថ្មីៗនេះនៅទាំងពិភពលោក និងតំបន់។

របាយការណ៍ដដែលនេះឱ្យដឹងបន្តទៀតដោយមានទំនុកចិត្តខ្ពស់ថា៖ "ផលប៉ះពាល់ពីភាពធ្ងន់ធ្ងរដែលពាក់ព័ន្ធនឹងអាកាសធាតុថ្មីៗនេះដូចជារលកកម្តៅ ភាពរាំងស្ងួត ទឹកជំនន់ ព្យុះស៊ីក្លូន និងភ្លើងឆេះព្រៃបង្ហាញពីភាពងាយរងគ្រោះខ្លាំង និងការប្រឈមនៃប្រព័ន្ធអេកូឡូស៊ីមួយចំនួន និងប្រព័ន្ធមនុស្សជាច្រើនទៅនឹងវិសមរូបអាកាសធាតុបច្ចុប្បន្ន"។របាយការណ៍វាយតម្លៃទី៥ ( IPCC AR 5 ឆ្នាំ២០១៥ ) និងរបាយការណ៍របស់ក្រុមការងារដែលពាក់ព័ន្ធ ( IPCC Emergent Risks and Vulnerabilities ឆ្នាំ២០១៤ ) រំលេចបន្ថែមទៀតអំពីហានិភ័យអាកាសធាតុសំខាន់ៗជាពិសេសហានិភ័យដែលមានហេតុផលដែលត្រូវបារម្ភ។

**ហានិភ័យការប្រែប្រួលអាកាសធាតុដែលត្រូវបានមើលឃើញ និងផលប៉ះពាល់ក្នុងតំបន់អាស៊ី**

តំបន់ភាគច្រើននៅអាស៊ីដែលងាយរងគ្រោះខ្លាំងទៅនឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុនិងការកើនឡើងកម្តៅសកលជាបន្ត នឹងមិនត្រឹមតែបំផ្លាញសមិទ្ធផលដែលសម្រេចបានថ្មីៗក្នុងកំណើនសេដ្ឋកិច្ចប៉ុណ្ណោះទេប៉ុន្តែថែមទាំងបង្កើតឱ្យមានបញ្ហាប្រឈមបន្ថែមសម្រាប់ការកាត់បន្ថយភាពក្រីក្រនិងការអភិវឌ្ឍមនុស្សឥតឈប់ឈរទៀតផង។

ជាធម្មតា តំបន់អាស៊ីត្រូវបានរំពឹងថានឹងមើលឃើញកំណើនសីតុណ្ហភាពមធ្យមខ្ពស់ និន្នាការកំណកអាកាសធាតុមិនទៀងទាត់ ដែលមានផលប៉ះពាល់កាន់តែធំឡើងទៅលើធនធានទឹក ហើយក៏មានការកើនឡើងហានិភ័យជំនន់ទឹកទន្លេផងដែរ។ សីតុណ្ហភាពកាន់តែខ្ពស់ និងស្ថានភាពកាន់តែក្តៅ ឬទឹកជំនន់ បង្កការគំរាមកំហែងដល់កសិកម្ម ហើយសំខាន់ជាងនេះទៀតនោះ គឺដល់សន្តិសុខស្បៀងក្នុងតំបន់ ជាទីដែលកង្វះអាហារូបត្ថម្ភ គឺជាក្តីបារម្ភដ៏ធំរួចទៅហើយនោះ។ ការកើនឡើងកម្រិតទឹកសមុទ្រ និងការកើនឡើងផលវិបាកដែលបង្កឡើងដោយព្យុះស៊ីក្លូនត្រូពិក និងជំនន់ទឹកសមុទ្រ នឹងជះឥទ្ធិពលបន្ថែមទៀតដល់ដំណើរការនគរូបនីយកម្ម ដែលបំផ្លាញប្រព័ន្ធគាំទ្រហេដ្ឋារចនាសម្ព័ន្ធដែលខ្សត់ខ្សោយស្រាប់ទៅហើយនោះនៅក្នុងប្រទេសជាច្រើន។

នៅក្នុងតំបន់អាស៊ីតំបន់អាស៊ីខាងត្បូងនិងអាស៊ីអាគ្នេយ៍នឹងរងគ្រោះខ្លាំងជាងគេដែលមើលឃើញរួចហើយក្នុងការកើនឡើងភាពញឹកញាប់ និងប្រពលភាពនៃហេតុការណ៍ធាតុអាកាសខ្លាំងនានា ដូចជា រលកកម្តៅ ភាពរាំងស្ងួត ទឹកជំនន់ និងព្យុះស៊ីក្លូនត្រូពិក ក្នុងរយៈពេលប៉ុន្មានទសវត្សរ៍ថ្មីៗនេះ។ការប្រែប្រួលដែលត្រូវបានសង្កេតមើលសំខាន់ៗមួយចំនួនចំពោះអាកាសធាតុក្នុងតំបន់នេះត្រូវបានផ្តល់ជូនក្នុងរូបទី៣។

**រូបទី៣៖ សង្ខេបការប្រែប្រួលនៃការប្រែប្រួលអាកាសធាតុក្នុងតំបន់អាស៊ីខាងត្បូងនិងអាស៊ីអាគ្នេយ៍**



**ការកើនឡើងកម្រិតទឹកសមុទ្រ**

កម្រិតទឹកសមុទ្របានកើនឡើងពី ១ ទៅ ៣ មីលីម៉ែត្រក្នុងមួយឆ្នាំក្នុងរយៈពេល ៥០ឆ្នាំ ចុងក្រោយនេះក្នុងតំបន់អាស៊ីអាគ្នេយ៍ ដែលបង្កឱ្យមានកើនឡើងទឹកជំនន់/ខ្យល់ព្យុះដល់កម្រិតខ្ពស់បំផុតមិនធ្លាប់មាន ជាពិសេសក្នុងប្រទេសហ្វីលីពីន។ កម្រិតទឹកសមុទ្រជា មធ្យមត្រូវបានព្យាករថាកើនឡើង ៧០ សង់ទី ម៉ែត្រដែលធ្វើឱ្យមនុស្សជាង ៥០០លាននាក់ ដែលរស់នៅតាមឆ្នេរសមុទ្រប្រឈមនឹង បញ្ហានេះ។

តំបន់អាស៊ីខាងត្បូងបានមើលឃើញរួចហើយនូវការប្រែប្រួលភាពញឹកញាប់ឬប្រពលភាពនៃព្យុះស៊ីក្លូន។ ប៉ុន្តែតំបន់ឆ្នេរដែលជាតំបន់ទាបនិងមានប្រជាជនរស់នៅច្រើនក្នុងតំបន់អាស៊ីខាងត្បូងនឹងស្ថិតនៅក្នុងហានិភ័យកាន់តែខ្លាំងទៅនឹងការកើនឡើងខ្យល់ព្យុះ។



**ហេតុការណ៍កំណកអាកាសធាតុខ្លាំង**

តំបន់អាស៊ីអាគ្នេយ៍កំពុងមើលឃើញនិន្នាការធ្លាក់ចុះកំណកអាកាសធាតុ។ ប្រទេសឥណ្ឌូនេស៊ី ថៃនិងវៀងណាមត្រូវបានរំពឹងថានឹងជួបប្រទះស្ថានភាពធាតុអាកាសកាន់តែក្តៅខ្លាំងឡើង ក្នុងរយៈពេល ២ ទៅ ៣ទសវត្សរ៍ខាងមុខ បើទោះជានិន្នាការនេះទំនងជាធ្លាក់ចុះមកវិញនៅពាក់កណ្តាលសតវត្សរ៍នេះក៏ដោយ។

ថ្ងៃដែលមានភ្លៀងធ្លាក់ខ្លាំងនិងញឹកញាប់កាន់តែច្រើនថ្ងៃត្រូវបានព្យាករថានឹងកើតមាននៅក្នុងតំបន់ខ្លះនៃតំបន់អាស៊ីខាងត្បូង។ ហានិភ័យកើតមានទឹកជំនន់ និងការបាត់បង់ជីវិតនិងទ្រព្យសម្បត្តិពាក់ព័ន្ធនឹងទឹកជំនន់ កើតមានខ្ពស់បំផុត ក្នុងប្រទេសឥណ្ឌានិងបង់ក្លាដែស។



**ការកើនឡើងសីតុណ្ហភាព**

សីតុណ្ហភាពជាមធ្យមរបស់តំបន់អាស៊ីអាគ្នេយ៍បានកើនឡើងក្នុងអត្រាពី ០,១ ទៅ ០,៣ អង្សាសេក្នុងមួយទសវត្សរ៍ ហើយសីតុណ្ហភាពជាមធ្យមប្រចាំឆ្នាំត្រូវបានព្យាករថាកើនឡើង៤,៨ អង្សាសេជាមធ្យមនៅត្រឹមឆ្នាំ២១០០ ធៀបនឹងកម្រិតឆ្នាំ១៩៩០។

តំបន់អាស៊ីខាងត្បូងក៏កំពុងមើលឃើញការកើនឡើងភាពញឹកញាប់នៃថ្ងៃនិងយប់ដែល មានអាកាសធាតុក្តៅ និងការធ្លាក់ចុះចំនួនថ្ងៃ និងយប់ដែលមានអាកាសធាតុត្រជាក់។

ប្រភព៖ ផ្អែកលើទិន្នន័យពី ( IPPCC AR5៖ អាស៊ី ឆ្នាំ២០១៤ )

ផលប៉ះពាល់មិនល្អពីហេតុការណ៍ទាំងនេះនឹងមានច្រើនចំពោះកង្វះខាតទឹកដែលកើតមានកាន់តែខ្លាំង ផលិតកម្មកសិកម្មដែលជួបឧបសគ្គដែលបង្កឱ្យមានការធ្លាក់ចុះទិន្នផលដំណាំ ការគំរាមកំហែងដល់សន្តិសុខស្បៀងភ្លើងឆេះព្រៃនិងការបាត់បង់ព្រៃសម្បូរបែប ជំនន់ទឹកភ្លៀង ការរេចរឹលតំបន់ឆ្នេរ និងការខូចខាតធនធានតំបន់ឆ្នេរ និងហានិភ័យសុខភាពកាន់តែខ្លាំងដោយសារការកើនឡើងការផ្ទុះជំងឺដែលអណ្តែតតាមទឹក និងជំងឺឆ្លងតាមភ្នាក់ងារចម្លងជំងឺ និងការខាតបង់សេដ្ឋកិច្ចដែលពាក់ព័ន្ធ និងការឈឺចាប់របស់មនុស្ស។ របាយការណ៍វាយតម្លៃទី៥ របស់ IPCC បានរំលេចផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុក្នុងតំបន់អាស៊ីដូចខាងក្រោម។

**កង្វះទឹកត្រូវបានរំពឹងថានឹងក្លាយជាបញ្ហាប្រឈមដ៏ធំមួយសម្រាប់តំបន់ភាគច្រើននៅតំបន់អាស៊ីដោយសារការកើនឡើងតម្រូវការទឹកនិងកង្វះការគ្រប់គ្រងធនធានធម្មជាតិ**

តំបន់អាស៊ីកំពុងជួបប្រទះអស្ថិរភាពរួចហើយជាមួយនឹងកង្វះទឹក ជាពិសេសនៅតំបន់អាស៊ីខាងត្បូង ជាទីដែលប្រជាជនជាច្រើនសូម្បីតែសព្វថ្ងៃនេះបាត់បង់ឋបនីយភណ្ឌទឹកជាមូលដ្ឋាន។ ការធ្លាក់ចុះបន្ថែមទៀតនៃភាពអាចរក ទឹកបាន នឹងបង្កើនបញ្ហានៅក្នុងតំបន់នេះយ៉ាងខ្លាំង។ហើយបើទោះជាមានទំនុកចិត្តទាបចំពោះការព្យាករអំពីនិន្នាការកំណកអាកាសធាតុក្នុងតំបន់នេះក្តីក៏មានការរំពឹងថានឹងមានការធ្លាក់ចុះភាពអាចរក ទឹកសាបបានផងដែរ ដែលមិនត្រឹមតែបង្កឡើងដោយសារកម្ពស់ទឹកភ្លៀងទាបប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងដោយសារការកើនឡើងសីតុណ្ហភាពផងដែរដែលនឹងប៉ះពាល់ដល់ការរលាយផ្ទាំងទឹកកកនៅតំបន់ភ្នំហិម៉ាឡៃយ៉ាដែលជាប្រភពទឹកសាបដ៏សំខាន់មួយសម្រាប់ប្រទេសជាច្រើនក្នុងតំបន់អាស៊ីខាងត្បូង។

**ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុលើផលិតកម្មស្បៀង និង សន្តិសុខស្បៀងក្នុងតំបន់អាស៊ី នឹងមានភាពខុសគ្នាតាមតំបន់ ដោយតំបន់ជាច្រើនជួបប្រទះការធ្លាក់ចុះផលិតភាព**

ដំណាំធញ្ញជាតិសំខាន់បំផុតចំនួនពីរក្នុងតំបន់គឺស្រូវនៅក្នុងតំបន់អាស៊ីអាគ្នេយ៍និងអាស៊ីខាងត្បូងនិងស្រូវសាលីក្នុងតំបន់ទំនាប Indo-Gangeticនៃតំបន់អាស៊ីខាងត្បូងត្រូវបានរំពឹងថានឹងបង្ហាញពីការធ្លាក់ចុះទិន្នផលដោយសាររយៈពេលដាំដុះកាន់តែខ្លី ដែលបណ្តាលមកពីសីតុណ្ហភាពកាន់តែខ្ពស់ ភាពរាំងស្ងួតញឹកញាប់និងកង្វះខាតទឹកសម្រាប់កសិកម្ម និងការកើនឡើងទឹកជំនន់នៅតំបន់ឆ្នេរនិងកើនឡើងកម្ពស់ទឹកសមុទ្រដែលជន់លិចតំបន់ទំនាបសម្រាប់ដាំដុះស្រូវ។

**ប្រព័ន្ធតំបន់ឆ្នេរ និងសមុទ្រក្នុងតំបន់អាស៊ីស្ថិតក្រោមភាពតានតឹងកាន់តែខ្លាំងពីកត្តាអាកាសធាតុ និងកត្តាមិនអាកាសធាតុ**

វាទំនងថា ការកើនឡើងកម្រិតទឹកសមុទ្រជាមធ្យម នឹងចូលរួមចំណែកដល់និន្នាការកើនឡើងកម្រិតទឹកខ្ពស់ខ្លាំងនៅតំបន់ឆ្នេរ។ ដើមកោងកាង តំបន់ដីសើមទឹកប្រៃ និងស្រទាប់ស្មៅសមុទ្រ អាចធ្លាក់ចុះលុះត្រាតែតំបន់នោះប្រែក្លាយជាគោក ខណៈតំបន់ដីសើមទឹកសាបនិងទំនាបបឹង នឹងងាយរងគ្រោះពីការហូរចូលទឹកប្រៃដោយសារការកើនឡើងកម្រិតទឹកសមុទ្រ។ ការខូចខាតជួរផ្កាថ្មប៉ប្រះទឹក កំពុងមានការបានរាយការណ៍រួចហើយ ហើយត្រូវបានទស្សទាយថានឹងកើនឡើងដោយសារការកើនឡើងកម្តៅ និងអាស៊ីតកម្មសមុទ្រ។

**ហេតុការណ៍អាកាសធាតុធំៗ នឹងមានផលប៉ះពាល់កាន់តែខ្លាំងលើសុខភាពមនុស្ស សន្តិសុខ ជីវភាពរស់នៅ និងភាពក្រីក្រ ដោយប្រភេទ និងទំហំផលប៉ះពាល់មានខុសៗគ្នានៅទូទាំងតំបន់អាស៊ី**

ការកើនឡើងភាពញឹកញាប់និងប្រពលភាពកាន់តែខ្លាំងនៃរលកកម្តៅនៅទូទាំងតំបន់អាស៊ីជាពិសេសនៅតំបន់អាស៊ីខាងត្បូង នឹងបង្កើនមរណភាពនិងព្យាធិភាពក្នុងចំណោមមនុស្សចាស់កុមារជាពិសេសទារកកម្មករក្នុងវិស័យក្រៅប្រព័ន្ធ និងអ្នករស់នៅក្នុងសំណង់អាណាធិប្បតេយ្យ។ ការកើនឡើងការធ្លាក់ភ្លៀងខ្លាំង និងសីតុណ្ហភាព ក៏នឹងបង្កើនហានិភ័យជំងឺដែលអណ្តែតតាមទឹក និងជំងឺដែលឆ្លងតាមភ្នាក់ងារចម្លងជំងឺនានាដូចជាជំងឺរាករូសជំងឺគ្រុនឈាម និងជំងឺគ្រុនចាញ់ជាដើម។ យោងតាមការប៉ាន់ប្រមាណនាពេលថ្មីៗនេះដោយអង្គការសុខភាពពិភពលោក (អង្គការ WHO ឆ្នាំ២០១៤)បានឱ្យដឹងថាការស្លាប់ពាក់ព័ន្ធនឹងកម្តៅក្នុងចំណោមមនុស្សចាស់ (មានអាយុច្រើនជាង ៦៥ឆ្នាំ) នៅក្នុងតំបន់ ត្រូវបានគិតថាកើនឡើងប្រហែល ២០.០០០ ករណីដោយសារការប្រែប្រួលអាកាសធាតុនៅត្រឹមឆ្នាំ២០៣០ និងប្រហែល ៥២.០០០ ករណីនៅត្រឹមឆ្នាំ២០៥០។ យោងតាមអង្គការដដែលនេះ មរណភាពដែលពាក់ព័ន្ធនឹងជំងឺដែលឆ្លងតាមភ្នាក់ងារចម្លងជំងឺ (ដូចជាជំងឺគ្រុនចាញ់ និងជំងឺគ្រុនឈាម) ក៏ត្រូវបានប៉ាន់ប្រមាណផងដែរថានឹងមានចំនួន ៣.០០០នាក់ ក្នុងមួយឆ្នាំក្នុងទសវត្សរ៍ឆ្នាំ២០៣០ និង១០.០០០នាក់ក្នុងមួយឆ្នាំក្នុងទសវត្សរ៍ឆ្នាំ២០៥០នៅក្នុងតំបន់។ ជំងឺផ្លូវចិត្តនិងជំងឺបាក់ស្បាតក៏ត្រូវបានសង្កេតឃើញផងដែរក្នុងតំបន់ងាយរងគ្រោះដោយសារគ្រោះមហន្តរាយ។

ភាពក្រីក្រនៅតំបន់ជនបទក្នុងតំបន់អាស៊ីខាងត្បូងត្រូវបានរំពឹងថានឹងបន្តរីករាលដាលខ្លាំងជាងភាពក្រីនៅតំបន់ទីក្រុងក្នុងរយៈពេលជាច្រើនទសវត្សរ៍ខាងមុខ។ ឧទាហរណ៍ ក្នុងប្រទេសបង់ក្លាដែស កត្តាទាំងនេះនឹងបង្កឱ្យមានការកើនឡើងភាពក្រីក្រសុទ្ធចំនួន១៥ % នៅត្រឹមឆ្នាំ២០៣០ (IPCC AR5៖ តំបន់អាស៊ីឆ្នាំ២០១៤)។ ការកើនឡើងនៃទឹកជំនន់ និងភាពរាំងស្ងួត នឹងធ្វើឱ្យភាពក្រីក្រនៅតំបន់ជនបទកាន់តែមានភាពធ្ងន់ធ្ងរឡើងដោយសារផលប៉ះពាល់អវិជ្ជមានលើផលិតកម្មស្បៀង ដែលបង្កឱ្យមានការកើនឡើងតម្លៃស្បៀង និងការចំណាយលើជីវភាពរស់នៅ។ យោងតាមការវាយតម្លៃរបស់អង្គការ WHO ដដែលបានឱ្យដឹងថា នៅក្នុងទសវត្សរ៍ឆ្នាំ

២០៣០ នឹងមានការស្លាប់កុមារតូចអាយុក្រោម ៥ឆ្នាំ ប្រហែលចំនួន២៦.០០០នាក់នៅទូទាំងតំបន់អាស៊ីនឹងប៉ាស៊ីហ្វិកដោយសារកង្វះអាហារូបត្ថម្ភ(ក្រិន)ដែលបង្កឡើងដោយការប្រែប្រួលអាកាសធាតុ។ទោះជាយ៉ាងណាអសន្តិសុខស្បៀងដែលពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ ក៏នឹងជះឥទ្ធិពលលើតំបន់អាស៊ីខាងត្បូងដែលកំពុងធ្វើនគរូបនីយកម្មផងដែរ។អ្នកក្រនៅតំបន់ទីក្រុងក៏អាចជួបប្រទះបន្ថែមទៀតនូវការកើនឡើងតម្លៃស្បៀងផងដែរ។ អ្នករស់នៅក្នុងទីក្រុងប្រភេទខ្លះដូចជាកម្មករអាចងាយរងគ្រោះជាពិសេស។ ភាពតានតឹងជាច្រើនដែលបង្កឡើងដោយសារនគរូបនីយកម្មយ៉ាងឆាប់រហ័ស ឧស្សាហកម្ម និងការអភិវឌ្ឍសេដ្ឋកិច្ច នឹងកាន់តែកើនឡើងបន្ថែមទៀតដោយសារការប្រែប្រួលអាកាសធាតុ។

**ចំណុចពិភាក្សា**

ប្រជាជនតាគច្រើននៅក្នុងតំបន់ទាំងនេះបានប្រឈមនឹងការគំរាមកំហែងនានាជាយូរមកហើយពាក់ព័ន្ធនឹងហេតុការណ៍ទាក់ទងនឹងធាតុអាកាសនានាដូចជា សីតុណ្ហភាពក្តៅខ្លាំង និងកំណកអាកាសធាតុធ្ងន់ (ដែលអាចបង្កឱ្យមានទឹកជំនន់) ជាដើម។ ចូរសួរអ្នកចូលរួមថា តើហេតុអ្វីបានជាពួកគេគិតថា ការប្រែប្រួលអាកាសធាតុឆ្លាមៗបានបង្កឱ្យជីវិតរបស់ពួកគេប្រែប្រួល?

តម្រុយសម្រាប់អ្នកសម្របសម្រួល

ដើម្បីស្វែងយល់កត្តានេះមនុស្សម្នាក់ត្រូវតែស្វែងរកសមាធាតុសំខាន់ៗចំនួនពីរនៃហានិភ័យណាមួយ

> ភាពអាចកើតមានគ្រោះមហន្តរាយ ឬការកើតមានហេតុការណ៍មិនល្អ។ និង
> ផលវិបាក និងផលប៉ះពាល់ដែលអាចកើតមាននៃហេតុការណ៍។

ការប្រែប្រួលអាកាសធាតុបង្កើនភវនីយភាព ឬភាពអាចកើតមាននៃហេតុការណ៍ខ្លាំងនានាដូចជាទឹកជំនន់ ជំនន់ទឹកសមុទ្រ ការកើតមានរលកកម្តៅហេតុដូច្នេះវានឹងនាំឱ្យមានការកើនឡើងចំនួននៃការកើតមានហេតុការណ៍មិនល្អ។លើសពីនេះទៅទៀតការប្រែប្រួលអាកាសធាតុបង្កើនប្រពលភាពនៃហេតុការណ៍ទាំងនេះ និងរួមផ្សំជាមួយហានិភ័យដែលពាក់ព័ន្ធនានាតាមរយៈទំនាក់ទំនងដោយប្រយោលជាមួយហានិភ័យផ្សេងទៀត។

ដូច្នេះ នៅក្នុងករណីខាងលើ ភាពញឹកញាប់និងប្រពលភាពនៃហេតុការណ៍ពាក់ព័ន្ធនឹងធាតុអាកាសនានាដូចជាទឹកជំនន់ នឹងកើនឡើងដោយសារការប្រែប្រួលអាកាសធាតុ ដែលមិនត្រឹមតែបង្កឱ្យមានការផ្លាស់សណ្ឋានកំណកអាកាសធាតុប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបង្កឱ្យមានការរេចរឹលតំបន់ឆ្នេរ និងការកើនឡើងកម្រិតទឹកសមុទ្រទៀតផង។ ធាតុអាកាសកាន់តែក្តៅនឹងចូលរួមចំណែកដល់ការកើនឡើងបរិមាណអូហ្សូននៅលើដី (ផ្សែងលាយអ័ព្ទ) នៅក្នុងតំបន់បំពុល ដែលធ្វើឱ្យការគំរាមកំហែងដែលមានស្រាប់ចំពោះសុខភាពមនុស្សកាន់តែមានភាពធ្ងន់ធ្ងរឡើង ជាពិសេសចំពោះមនុស្សចាស់ និងក្មេង និងអ្នកដែលមានសុខភាពខ្សោយស្រាប់។ លើសពីនេះទៀត ផលប៉ះពាល់ទាំងនេះក៏អាចបង្កឱ្យមានការខូចខាតដល់ហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗផងដែរដូចជាប្រព័ន្ធថែទាំសុខភាពសាធារណៈ ដែលនឹងកាត់បន្ថយសក្តានុពលក្នុងការដោះស្រាយបញ្ហារបស់សហគមន៍ដែលរងផលប៉ះពាល់។

### ហានិភ័យអាកាសធាតុ គ្រោះមហន្តរាយ និងការអភិវឌ្ឍប្រកបដោយចីរភាព

គ្រោះថ្នាក់ធម្មជាតិនានា (រញ្ជួយដី រលកយក្សស៊ូណាមិ ទឹកជំនន់ ព្យុះស៊ីក្លូន ភាពរាំងស្ងួត។ល។) បាននិងកំពុងកើតមានឡើងចាប់តាំងពីយូរលង់មកហើយនិងត្រូវបានគេដឹងថាមានឥទ្ធិពលដ៏គ្រោះថ្នាក់លើជីវិតមនុស្សនិងជីវភាពរស់នៅ។ ក្នុងរយៈពេលជាច្រើនឆ្នាំផ្លូវអភិវឌ្ឍន៍ដែលត្រូវបានគេដើរតាមនៅជុំវិញពិភពលោកបានបង្កើតគំរូមួយដែលធ្វើឱ្យគ្រោះថ្នាក់ធម្មជាតិទាំងនោះក្លាយជាគ្រោះមហន្តរាយដែលអាចកើតមាន។ ទិន្នន័យហានិភ័យគ្រោះមហន្តរាយបង្ហាញថា មនុស្សជាង ២២៦លាននាក់ ក្នុងមួយឆ្នាំបានទទួលរងផលប៉ះពាល់ពីគ្រោះមហន្តរាយដែលពាក់ព័ន្ធនឹងគ្រោះថ្នាក់ធម្មជាតិ ហើយប្រហែល ៨១% នៃគ្រោះមហន្តរាយទាំងនេះគឺជាគ្រោះមហន្តរាយដែលពាក់ព័ន្ធនឹងធាតុអាកាស(ទឹកជំនន់ ព្យុះស៊ីក្លូន ភាពរាំងស្ងួត។ល។)។គ្រោះមហន្តរាយដែលពាក់ព័ន្ធនឹងធាតុអាកាស ក៏មានចំនួន ២៣% នៃមហន្តរាយនានា និងមាន ៧២% នៃការខាតបង់សេដ្ឋកិច្ចទាំងអស់ផងដែរ ដែលជាញឹកញាប់បង្ខំឱ្យមនុស្សជាច្រើននាក់ធ្លាក់ចូលទៅក្នុងភាពក្រីក្រ។ របាយការណ៍ពិសេសស្តីពីហេតុការណ៍ធ្ងន់ធ្ងរ និងរបាយការណ៍វាយតម្លៃទី៥ របស់ IPCC បានអះអាងជាថ្មីថា ការប្រែប្រួលអាកាសធាតុកំពុងដឹកនាំទៅរកការកើតមានហេតុការណ៍ធាតុអាកាសកាន់តែញឹកញាប់ និង/ឬកាន់តែធ្ងន់ធ្ងរខ្លាំង ហើយនឹងធ្វើឱ្យគ្រោះថ្នាក់ធម្មជាតិបែបនេះកាន់តែមានភាពធ្ងន់ធ្ងរឡើងនៅក្នុងរយៈពេលប៉ុន្មានទសវត្សរ៍ខាងមុខ។

ការណ៍នេះនឹងក្លាយជាគ្រោះមហន្តរាយដែលអាចកើតមានមួយដែលធ្វើឱ្យវឌ្ឍនភាពនៃការអភិវឌ្ឍដើរថយក្រោយរាប់ទសវត្សរ៍ និងជាការកំណត់ដ៏សំខាន់មួយក្នុងសមិទ្ធិផលរបស់ SDGs។ SDGs ជាច្រើន (សូមមើលតារាងទី៣) នឹងទទួលរងផលប៉ះពាល់ខ្លាំងអាស្រ័យលើថាតើការកើនឡើងកម្តៅសកលត្រូវបានធ្វើឱ្យមាន

ស្ថិរភាពត្រឹមកម្រិត ១,៥អង្សាសេ ឬកើនឡើងខ្ពស់ជាងកម្រិតនេះ។ របាយការណ៍វាយតម្លៃទី៥ (ឆ្នាំ២០១៥) របស់ IPCC លើកឡើងយ៉ាងច្បាស់ថា ការកំណត់ការកើនឡើងកម្តៅត្រឹម ១,៥អង្សាសេ នឹងធ្វើឱ្យវាកាន់តែមានភាពងាយស្រួលខ្លាំងដើម្បីសម្រេចបាន SDGs សម្រាប់ការលុបបំបាត់ភាពក្រីក្រ ការទទួលបានទឹកទីក្រុងសុវត្ថិភាព សន្តិសុខស្បៀង ជីវិតដែលមានសុខភាពល្អ និងកំណើនសេដ្ឋកិច្ចប្រកបដោយបរិយាបន្ន ហើយនឹងជួយការពារប្រព័ន្ធអេកូឡូស៊ីលើគោក និងជីវចម្រុះ។ លើសពីនេះទៀត SDGs ជាច្រើនតម្រូវឱ្យមានវិធានការការពារសង្គមសំខាន់ៗនិងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធដែលនឹងទទួលរងឥទ្ធិពលខ្លាំងពីគ្រោះមហន្តរាយនេះ។

## តារាងទី៣៖ ផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុលើគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព

| ផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ | ស្ថានភាពនៃការឡើងកម្តៅ ១,៥°C | ស្ថានភាពនៅ ២°C | គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពដែលរងផលប៉ះពាល់ |
|---|---|---|---|
| កង្វះខាតទឹក | ប្រជាជន ៤៩៦លាននាក់ ប្រឈមនឹងភាពតានតឹងនៃ ទឹក | ប្រជាជន៥៨៦លាននាក់ (៨%បន្ថែមទៀត) ប្រឈមនឹងភាពតានតឹងនៃទឹក | គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៦ ៖ ធានាការរកបាន និងការគ្រប់គ្រងទឹក និងអនាម័យបរិស្ថានប្រកបដោយចីរភាពសម្រាប់មនុស្សគ្រប់រូប |
| ប្រព័ន្ធអេកូឡូស៊ី | ប្រមាណ ៧%នៃការផ្លាស់ប្តូរជីវឧស្ម័ននៅលើដី ធ្វើឱ្យផ្កាថ្ម ៧០ ទៅ ៩០% ប្រឈមនឹងការធ្វើឱ្យស។ | ប្រមាណ១៣%នៃការផ្លាស់ប្តូរជីវឧស្ម័ននៅលើដី ធ្វើឱ្យផ្កាថ្ម ៩០% ប្រឈមនឹងការធ្វើឱ្យស។ | គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី១៥ ៖ ការពារ ជួសជុល និងលើកកម្ពស់ការប្រើប្រាស់មុខងារអេកូឡូស៊ីប្រកបដោយចីរភាព គ្រប់គ្រងព្រៃឈើប្រកបដោយចីរភាព និងប្រឆាំងភាពវហោស្ថាន និងបញ្ឈប់ និងបម្រុងភាពសឹករេចរឹលនៃដី និងទប់ស្កាត់ការបាត់បង់ជីវចម្រុះបន្តទៀត។ |
| ទីក្រុងឆ្នេរ | ប្រជាជនពី ៣១ ទៅ ៦៩លាននាក់ ប្រឈមនឹងការជន់លិចនៅតំបន់ឆ្នេរ។ ទីក្រុងមួយចំនួនតូចប្រឈមនឹងការកើនឡើងកម្រិតទឹកសមុទ្រនិងហេតុការណ៍ធ្ងន់ធ្ងរ។ | ប្រជាជនពី ៣២ ទៅ ៧២លាននាក់ ប្រឈមនឹងការជន់លិចនៅតំបន់ឆ្នេរ។ ទីក្រុងភាគច្រើន និងមនុស្សប្រឈមនឹងការជន់លិច។ | គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី១១៖ធ្វើឱ្យទីក្រុងនិងទីកន្លែងតាំងទីលំនៅថ្មីសម្រាប់ប្រជាជនមានលក្ខណៈបរិយាបន្ន សុវត្ថិភាព ធន់ និងមានចីរភាព។ |
| ប្រព័ន្ធស្បៀង | ការធ្លាក់ចុះយ៉ាងគំហុកនូវទិន្នផលដំណាំធ្វើឱ្យប្រជាជនពី៣២ ទៅ៣៦លាននាក់ថយចុះទិន្នផល។ | ទិន្នផលដំណាំជាមធ្យមធ្លាក់ចុះ ធ្វើឱ្យប្រជាជន ៣៣០ ទៅ ៣៩៦លាននាក់ថយចុះទិន្នផល។ | គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី២ ៖ បញ្ចប់ការអត់ឃ្លាន សម្រេចឱ្យបានសន្តិសុខស្បៀងធ្វើឱ្យប្រសើរឡើងស្ថានភាពអាហារូបត្ថម្ភនិងលើកកម្ពស់កសិកម្មប្រកបដោយចីរភាព។ |
| សុខភាព | ហានិភ័យទាបនៃអត្រាសីតុណ្ហភាពនិងកម្រិតមូសតិចតួច។ ប្រជាជន ៣.៥៤៦ និង ៤.៥០៨លាននាក់ប្រឈមនឹងរលកកម្តៅ។ | ហានិភ័យខ្ពស់នៃអត្រាសីតុណ្ហភាព និងអត្រាមរណភាពដែលបណ្តាលមកពីមូសក្នុងតំបន់ភូមិសាស្ត្រកាន់តែធំ។ ប្រជាជន ៥.៤១៧ និង ៦.៧១០លាននាក់ប្រឈមនឹងរលកកម្តៅ។ | គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៣៖ ធានាឱ្យជីវភាពរស់នៅរបស់ប្រជាជនប្រកបដោយសុខភាពល្អនិងលើកកម្ពស់សុខុមាលភាពរបស់មនុស្សគ្រប់រូប និងគ្រប់វ័យ។ |

ប្រភព៖ ដកស្រង់ចេញពី IPCC របាយការណ៍វាយតម្លៃទី ៥ (ឆ្នាំ២០១៥)

## រូបទី៤៖ ការបង្ហាញអំពីទំនាក់ទំនងរវាងការប្រែប្រួលអាកាសធាតុ ហានិភ័យគ្រោះមហន្តរាយ និងការអភិវឌ្ឍ




ប្រភព៖ (ក្រុមការងារ IPCC II ឆ្នាំ២០១៤)

អន្តរាគមន៍ទាំងនេះចាំបាច់ត្រូវមានការបន្សាំនឹងការប្រែប្រួលអាកាសធាតុ និងទស្សនៈភាពធន់ដែលត្រូវដាក់បញ្ចូលទៅក្នុងយន្តការរៀបចំផែនការអភិវឌ្ឍ ការកៀរគរធនធាន និងការគាំពារសង្គមនិងការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ។វាពិតជាមានសារៈសំខាន់ខ្លាំងដែលទាំងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ទាំងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ ត្រូវដាក់បញ្ចូលទៅក្នុងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទាំងអស់ ដែលមិនកំហិតត្រឹមតែគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី១៣ដែលត្រូវចាត់វិធានការបន្ទាន់ក្នុងការប្រឆាំងនឹងការប្រែប្រួលអាកាសធាតុ និងផលប៉ះពាល់ដែលបណ្ដាលមកពីការប្រែប្រួលអាកាសធាតុ។

**ការប្រែប្រួលអាកាសធាតុ ហានិភ័យគ្រោះមហន្តរាយ និងការអភិវឌ្ឍ**

អាកាសធាតុរបស់ផែនដីកំពុងបន្តប្រែប្រួលចាប់តាំងពីពេលដែលវាត្រូវបានបង្កើត។ ដំណើរការធម្មជាតិនេះដែលហៅថា ការផ្លាស់ប្ដូរដោយកត្តាធម្មជាតិនៃអាកាសធាតុ គឺខុសគ្នានឹងការប្រែប្រួលអាកាសធាតុ។ អនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្ដីពីការប្រែប្រួលអាកាសធាតុ កំណត់ការប្រែប្រួលអាកាសធាតុថាជា "ការប្រែប្រួលអាកាសធាតុ ដែលត្រូវបានកំណត់ថាជាសកម្មភាពរបស់មនុស្សដោយផ្ទាល់ ឬដោយប្រយោល និងការផ្លាស់ប្ដូរសមាសភាពនៃបរិយាកាសជាសកល"។ ដំណើរការនេះគឺជាការបន្ថែមលើការផ្លាស់ប្ដូរដោយកត្តាធម្មជាតិនៃអាកាសធាតុដែលត្រូវបានអង្កេតក្នុងរយៈពេលដែលអាចប្រៀបធៀបបាន។ ការប្រែប្រួលដែលបង្កឡើងដោយមនុស្សច្រើនហៅថាជា "ការប្រែប្រួលអាកាសធាតុដោយសកម្មភាពមនុស្ស"ដែលបណ្ដាលមកពីលទ្ធផលនៃកំណើនសកម្មភាពឧស្សាហកម្ម ជាពិសេសគឺចាប់ពីបដិវត្តន៍ឧស្សាហកម្ម (industrialrevelation) ដែលរួមចំណែកធ្វើឱ្យមានស្តុកនៃការបញ្ចេញឧស្ម័នផ្ទះកញ្ចក់។

ការផ្លាស់ប្ដូរដោយកត្តាធម្មជាតិ និងការប្រែប្រួលអាកាសធាតុដែលបង្កដោយឡើងដោយកត្តាមនុស្សបង្កើតឱ្យមានហេតុការណ៍ ឬគ្រោះថ្នាក់ពាក់ព័ន្ធនឹងធាតុអាកាស និងអាកាសធាតុ។ IPCC កំណត់គ្រោះថ្នាក់ថាជា "ការកើតឡើងជាសក្ដានុពលនៃហេតុការណ៍ធម្មជាតិ ឬហេតុការណ៍ដែលបង្កដោយមនុស្ស ដែលអាចធ្វើឱ្យបាត់បង់អាយុជីវិត បង្ករបួសស្នាម ឬផលប៉ះពាល់លើសុខភាពផ្សេងទៀត ក៏ដូចជាធ្វើឱ្យខូចខាត ឬបាត់បង់ទ្រព្យសម្បត្តិ ហេដ្ឋារចនាសម្ព័ន្ធ របរចិញ្ចឹមជីវិត ការផ្ដល់សេវា និងធនធានបរិស្ថាន"។ ការប្រែប្រួលនូវស្តុកនៃការបញ្ចេញឧស្ម័ន ដោយសារសកម្មភាពរបស់មនុស្សធ្វើឱ្យមានការប្រែប្រួលក្នុងការបែងចែកអថេរអាកាសធាតុ។ វាមានការលំបាកក្នុងការកំណត់ថាតើគ្រោះថ្នាក់មួយ គឺជាលទ្ធផលបណ្ដាលមកពីការផ្លាស់ប្ដូរដោយកត្តាធម្មជាតិនិងការប្រែប្រួលដែលបង្កឡើងដោយកត្តាមនុស្ស។ទោះបីយ៉ាងណាមានការស្វែងយល់ជាលក្ខណៈវិទ្យាសាស្ត្រថាភាពញឹកញាប់និងប្រពលភាពនៃគ្រោះមហន្តរាយបានកើនឡើងដោយសារតែការប្រែប្រួលអាកាសធាតុ។

គ្រោះថ្នាក់ទាំងនេះបង្កហានិភ័យដល់ប្រព័ន្ធសង្គម និងសេដ្ឋកិច្ច របស់យើង។ ហានិភ័យតំណាងឱ្យសក្ដានុពលនៃការបាត់បង់។ ផលប៉ះពាល់ចុងក្រោយដែលហានិភ័យអាចមានអាស្រ័យលើភាព

ញឹកញាប់ និងប្រពលភាពនៃគ្រោះថ្នាក់ ការប្រឈមនឹងគ្រោះថ្នាក់ និងភាពងាយរងគ្រោះនៃប្រព័ន្ធ។ IPCC បានកំណត់និយមន័យនៃការប្រឈម (exposure) ថាជាមានរបស់ប្រជាជនវត្តរបរចិញ្ចឹមជីវិត សេវាកម្ម និងធនធានបរិស្ថាន ហេដ្ឋារចនាសម្ព័ន្ធ ឬទ្រព្យសម្បត្តិសេដ្ឋកិច្ចសង្គមឬវប្បធម៌នៅកន្លែងដែលអាចរងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរ"។មុខសញ្ញាគ្រោះថ្នាក់អាចមានប្រពលភាពខ្ពស់ ប៉ុន្តែប្រសិនបើវាប៉ះពាល់នៅទីតាំងដែលគ្មានមនុស្ស និងហេដ្ឋារចនាសម្ព័ន្ធ ផលប៉ះពាល់ជាលទ្ធផលនឹងទាប។ ម្យ៉ាងវិញទៀត ភាពងាយរងគ្រោះ គឺជាបាតុភូតស្មុគស្មាញមួយបន្ថែមទៀត និងមានលក្ខណៈជាប្រព័ន្ធ ដោយសារលក្ខខណ្ឌសង្គមសេដ្ឋកិច្ច វប្បធម៌ ប្រវត្តិសាស្ត្រ ស្ថាប័ន។ល។ (វាត្រូវបានកំណត់ថាជា "ទំនោដែលត្រូវរងឥទ្ធិពលអាក្រក់។ ភាពងាយរងគ្រោះរួមមាន ទស្សនៈ និងសមាសធាតុផ្សេងៗគ្នារាប់បញ្ចូលទាំងភាពរំញោចឬភាពងាយរងគ្រោះទៅនឹងគ្រោះថ្នាក់និងកង្វះសមត្ថភាពក្នុងការទប់ទល់ និងសម្របខ្លួន"។

នៅពេលដែលហានិភ័យបណ្តាលមកពីគ្រោះមហន្តរាយត្រូវបានគេទទួលស្គាល់វាបណ្តាលឱ្យមានផលប៉ះពាល់និងជះឥទ្ធិពលដល់ដំណើរការអភិវឌ្ឍយ៉ាងធ្ងន់ធ្ងរ។ គំរូនៃការអភិវឌ្ឍរបស់យើងគឺជាអ្វីមួយដែលរួមចំណែកដល់ស្តុកនៃការបញ្ចេញឧស្ម័ន ដែលរួមចំណែកដល់ការប្រែប្រួល អាកាសធាតុ។ វាក៏ជាព្រំដែនមួយដែលការកាត់បន្ថយការញ្ចេញឧស្ម័ន GHG ការគ្រប់គ្រងគ្រោះមហន្តរាយ និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ កើតឡើងដោយសារតែជម្រើសគោលនយោបាយបុគ្គលនិងសមូហភាព។

## វិសមភាពដែលមានស្រាប់ និងភាពងាយរងគ្រោះនៅនឹងហានិភ័យអាកាសធាតុ

ការគំរាមកំហែងដែលត្រូវបានគេមើលឃើញនៃហានិភ័យអាកាសធាតុ គឺជាបញ្ហាសកល ប៉ុន្តែភាពងាយរងគ្រោះទៅនឹងហានិភ័យនេះ នឹងក្លាយជាបរិបទជាក់លាក់ និងកាន់តែត្រូវបានផ្តោតទៅលើកត្តាមិនមែនអាកាសធាតុនិងវិសមភាពលើសពីកម្រិតដែលមានស្រាប់។ ដូច្នេះ វាមិនមែនជារឿងភ្ញាក់ផ្អើលទេ ដែល IPCC AR5 បានគូសបញ្ជាក់ថា ក្រុមស្ត្រី មនុស្សក្រីក្រ មនុស្សចាស់ កុមារ សហគមន៍ជនជាតិដើមភាគតិច ប្រជាជនតាមតំបន់ឆ្នេរនិងមនុស្សមានពិការភាពនឹងកាន់តែងាយរងគ្រោះថែមទៀតទៅនឹងហានិភ័យអាកាសធាតុ។ ហើយអំឡុងពេលដែលគ្មានការស្រាវជ្រាវ/ព័ត៌មានពីភាពងាយរងគ្រោះនៃសហគមន៍ LGBTIQដែលជាការយល់ដឹងបញ្ហារើសអើងទាំងមូលដែលពួកគេជួបប្រទះនោះវាមិនខុសទេក្នុងការសន្នត់ថាពួកគេក៏ទទួលរងផលប៉ះពាល់មិនស្មើគ្នាដែរជាពិសេសនៅហេតុការណ៍គ្រោះមហន្តរាយ។

ឧទាហរណ៍ចំនួនប្រជាជនដ៏កកកុញនៅទីក្រុងនៃតំបន់អាស៊ីខាងត្បូងនិងអាស៊ីអាគ្នេយ៍គឺឆាប់ទទួលនូវភាពអវិជ្ជមាននៃការប្រែប្រួលអាកាសធាតុ ជាពិសេសស្ថានភាពសីតុណ្ហភាព ទឹកជំនន់ និងជំងឺឆ្លងតាមភ្នាក់ងារចម្លង ជំងឺ ហើយអ្នកដែលងាយរងគ្រោះបំផុត គឺមនុស្សទាំងឡាយដែលរស់នៅក្នុងទីតាំងមិនរៀបរយ។ ហានិភ័យកើតចេញពីស្រ្តេសដោយសារកម្តៅអាកាសធាតុ នឹងកាន់តែមានកម្រិតខ្ពស់ថែមទៀតសម្រាប់អ្នកទាំងឡាយដែលរស់នៅដោយគ្មានគ្រឿងបរិក្ខារបញ្ចេញបញ្ចូលខ្យល់ត្រឹមត្រូវ ឬអ្នកទាំងឡាយណាដែលពាក់ព័ន្ធនឹងការងារក្រៅការិយាល័យ ដូចជា អ្នកលក់ដូរតាមចិញ្ចើមថ្នល់។ ស្រដៀងគ្នាផងដែរ ទឹកជំនន់នៅតំបន់ឆ្ងាយពីមាត់សមុទ្រ និងតំបន់ឆ្នេរ ជំនន់ទឹកសមុទ្រ នឹងប៉ះពាល់ទៅដល់សហគមន៍ទាំងឡាយណារស់នៅតំបន់ទំនាប និងតំបន់ដែលងាយប្រឈមគ្រោះថ្នាក់។ កង្វះខាតទឹក និងជំងឺទាក់ទងនឹងទឹកនឹងកាន់តែរីករាលដាលលើអ្នកទាំងឡាយណាដែលពុំទទួលបាននូវសេវា និងហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋាន។

តំបន់ជនបទដែលជួបជាញឹកញាប់នូវភាពរាំងស្ងួត និងទឹកភ្លៀងខ្លាំងនឹងមើលឃើញផលប៉ះពាល់លើជីវភាពរស់នៅមូលដ្ឋានរបស់ពលករក្នុងវិស័យកសិកម្មក្រុមកសិករជួបការលំបាកនិងក្រុមអ្នកចិញ្ចឹមសត្វ។ ជាមួយនឹងការទទួលបានការប្រើប្រាស់ដី ហិរញ្ញវត្ថុធាតុចូលកសិកម្មទំនើប ហេដ្ឋារចនាសម្ព័ន្ធ និងការអប់រំដែលនៅមានកម្រិតនៅឡើយនោះសហគមន៍ទាំងនេះនឹងទទួលរងគ្រោះកាន់តែខ្លាំងថែមទៀត។ ជាទូទៅ ប្រជាជនក្រីក្រទាំងនៅតំបន់ទីក្រុង និងតំបន់ជនបទ ក៏ទទួលផលប៉ះពាល់ពីបញ្ហាអសន្តិសុខស្បៀង កំណើនតម្លៃម្ហូបអាហារ ក៏ដូចជាកំណើនហានិភ័យសុខភាព និងគ្រោះមហន្តរាយនានា។

ជាញឹកញាប់ កុមារ និងមនុស្សចាស់ មានហានិភ័យខ្ពស់ជាងគេ ដោយសារតែចល័តភាពរបស់ពួកគេមានកម្រិត ភាពងាយរងគ្រោះនឹងជំងឺឆ្លងនានា ការទទួលបានអាហារមានកាឡូរីទាប និងការរស់នៅដាច់ឆ្ងាយពីសង្គម ប៉ុន្តែកុមារតូចៗកាន់តែងាយស្លាប់ ឬរងគ្រោះថ្នាក់ធ្ងន់ធ្ងរបង្ករឡើងដោយជំងឺរាគរូស និងទឹកជំនន់។ មនុស្សចាស់ ក៏ទទួលរងគ្រោះថ្នាក់ផ្នែករាងកាយមិនស្មើគ្នាដែរ និងស្លាប់ដោយសារស្រ្តេសកើតចេញពីកម្តៅ ភាពរាំងស្ងួត និងភ្លើងឆេះព្រៃ។

ភាពងាយរងគ្រោះទាំងនេះ ជាញឹកញាប់ទាក់ទងដោយផ្ទាល់នឹងវិសមភាពកំពុងមានស្រាប់ ដែលនេះហើយជាមូលហេតុត្រូវការនូវវិធីសាស្ត្រផ្អែកលើសិទ្ធិមនុស្សជាមូលដ្ឋានសម្រាប់ការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ។ វិធីសាស្ត្រនេះ តម្រូវឱ្យមាននូវការវិភាគស៊ីជម្រៅនៃហានិភ័យ ភាពប្រឈម និងភាពងាយរងគ្រោះរបស់សហគមន៍ជាក់លាក់ ទៅនឹងការប្រែប្រួលអាកាសធាតុ។ កត្តាកំណត់សំខាន់ៗមួយចំនួននៃវិសមភាពដែលកំពុងមានដែលនឹងមានផលប៉ះពាល់

ដូចគ្នា ត្រូវលើកយកមកពិភាក្សាដូចខាងក្រោម៖

ក) ភាពប្រឈមខាងភូមិសាស្ត្រ៖ មានទីតាំងភាគច្រើនស្ថិតនៅក្នុងតំបន់ប្រឈមខ្លាំងនឹងមុខសញ្ញាគ្រោះថ្នាក់-តំបន់ដីទំនាបដែលជាញឹកញាប់ជួបនឹងទឹកជំនន់/ការលិចទឹកឬតំបន់រយៈកម្ពស់ខ្ពស់ (កូនភ្នំ និងភ្នំ) មានកម្រិតទឹកក្រោមដីទាប។ អសន្តិសុខ

សិទ្ធិកាន់កាប់ដីធ្លីរារាំងបន្ថែមទៀតទៅដល់ការវិនិយោគទុននៅលើទីតាំងលំនៅឋានទាំងនេះ។ មនុស្ស ៤៥០លាននាក់នៅតំបន់ប្រឈមនឹងទឹកជំនន់ នឹងកាន់តែប្រឈមនឹងទឹកជំនន់ម្តងហើយម្តងទៀតជាញឹកញាប់ ហើយហានិភ័យទឹកជំនន់លើសាកលលោក នឹងកើនឡើងគួរឱ្យកត់សម្គាល់ (Arnell និង Gosling ឆ្នាំ២០១៤)។

ខ) ភាពប្រឈមខាងមុខរបរ៖ អាស្រ័យលើមុខរបរដែលត្រូវការកម្លាំងពលំខ្លាំង ការងារក្រៅការិយាល័យ ដូចជាការងារសំណង់ការលក់ដូរតាមចិញ្ចើមថ្នល់និង/ឬជីវភាពរស់នៅក្រៅប្រព័ន្ធ រួមមាន ការលក់ដូរតាមរដូវកាល ការងារតាមផ្ទះ ដែលអាចរងផលប៉ះពាល់ដោយផ្ទាល់ពីគ្រោះមហន្តរាយ។ រាល់កំណើនសីតុណ្ហភាព ១ អង្សា អាចកាត់បន្ថយផលិតភាពការងារចន្លោះពី ១ភាគរយ ទៅ ៣ភាគរយ សម្រាប់មនុស្សធ្វើការងារក្រៅការិយាល័យឬកន្លែងគ្មានម៉ាស៊ីនត្រជាក់ជាពិសេសស្រទាប់ទាបជាងគេនៃកម្លាំងពលកម្ម (Park et al. ឆ្នាំ២០១៥ យោងពី (Roy et al ឆ្នាំ២០១៨) ។ ស្រដៀងគ្នាអ្នកទាំងឡាយដែលពឹងអាស្រ័យលើធនធានធម្មជាតិ និងកសិកម្ម ក៏នឹងត្រូវរងផលប៉ះពាល់ផងដែរដោយការបាត់បង់ជីវភាពរស់នៅ។ ឧទាហរណ៍ ប្រទេសបង់ក្លាដេស ការខូចខាត និងការបាត់បង់ ត្រូវបានរំពឹងថាកើតឡើងលើគ្រួសារក្រីក្រដែលពឹងផ្អែកលើផលស្តុកមច្ឆាជាតិទឹកសាបដោយសារកង្វះចល័តភាព ការទទួលបានការប្រើប្រាស់ដីនៅមានកម្រិត និងការពឹងផ្អែកខ្លាំងលើប្រព័ន្ធអេកូឡូស៊ីមូលដ្ឋាន (Dasgupta et al ឆ្នាំ២០១៧)។

គ) ភាពខ្សត់ខ្សោយខាងហេដ្ឋារចនាសម្ព័ន្ធ៖ ការរស់នៅក្នុងតំបន់តាំងទីលំនៅដែលមិនមានគ្រប់គ្រាន់នូវប្រព័ន្ធបង្ហូរទឹកសំណល់ ថាមពល និងប្រព័ន្ធទំនាក់ទំនង ជាទីដែលផលប៉ះពាល់បណ្តាលមកពីហេតុការណ៍មួយដូចជាទឹកជំនន់ ឬភាពរាំងស្ងួតនឹងធ្វើឱ្យអារម្មណ៍ថាមានកម្រិតស្រួចស្រាវជាងទីកន្លែងផ្សេងទៀត។ ផ្ទះសម្បែងមានគុណភាពអន់ដែលមានគ្រឿងបរិក្ខារបញ្ចេញបញ្ចូលខ្យល់មានកម្រិត បរិក្ខារផ្តល់ភាពត្រជាក់មិនគ្រប់គ្រាន់ធ្វើឱ្យពួកគេកាន់តែងាយរងគ្រោះទៅនឹងការប្រែប្រួលអាកាសធាតុ ដូចជា ស្រ្តេសកម្តៅអាកាសធាតុ។

ឃ) ភាពងាយរងផលប៉ះពាល់ខាងហិរញ្ញវត្ថុ៖ កង្វះប្រភពចំណូល ដីធ្លី និងទ្រព្យសម្បត្តិធម្មជាតិដទៃទៀត និងការទទួលបានឥណទាននិងធានារ៉ាប់រង ជាញឹកញាប់បង្ខំឱ្យការសន្សំប្រាក់ឬទ្រព្យសម្បត្តិសម្រាប់ឆ្លើយតប ប្រែជាខ្សត់ខ្សោយ។ ជាមួយនឹងមូលដ្ឋានជីវភាពកម្រិតទាប និងជម្រើសដកថយមានកម្រិតសមត្ថភាពរបស់ពួកគេក្នុងការតទល់នឹងស្រ្តេស និងបញ្ហាអាកាសធាតុ នៅមានកម្រិតនៅឡើយ ដែលបណ្តាលឱ្យពួកគេជាប់ផុងក្នុង«អន្ទាក់ភាពក្រីក្រ»-ពួកគេនឹងកាន់តែក្រថែមទៀត ដោយសារតែការប្រែប្រួលអាកាសធាតុ ប៉ុន្តែ មិនអាចបង្កើតឱ្យមានការបណ្តាក់ទុនភាពធន់ដែលចាំបាច់នោះឡើយពីព្រោះពួកគេក្រីក្រហើយដំណោះស្រាយរយៈខាងសេដ្ឋកិច្ចមិនអាចកើតឡើងបានឡើយ។ របាយការណ៍វាយតម្លៃទី៥ (AR5) បានសន្និដ្ឋានដោយទំនុកចិត្តខ្ពស់ថា អ្នកក្រនឹងបន្តជួបប្រទះការប្រែប្រួលអាកាសធាតុធ្ងន់ធ្ងរ ហើយការប្រែប្រួលអាកាសនឹងធ្វើឱ្យភាពក្រីក្រកាន់តែធ្ងន់ធ្ងរឡើង។ Hallegatte និង Rozenberg (ឆ្នាំ២០១៧) បានរាយការណ៍ថា នៅឆ្នាំ២០៣០ (កម្តៅកើនឡើងប្រមាណ ១,៥អង្សា) ប្រជាជនចំនួន ១២២នាក់លានបន្ថែមទៀត អាចជួបនឹងភាពក្រីក្រីខ្លាំងមូលហេតុសំខាន់ដោយសារតម្លៃស្បៀងអាហារឡើងខ្ពស់ថែមទៀត និងការធ្លាក់ចុះខាងសុខភាព ដោយបាត់បង់ចំណូល ២០ភាគរយបន្ថែមទៀតសម្រាប់អ្នកក្រីក្របំផុតនៅតាមបណ្តាប្រទេសចំនួន ៩២។

ង) ភាពលំបាកខាងសង្គម៖ មានជម្រើសដកថយតិចតួច មានធនធាន និងលទ្ធភាពទទួលបានព័ត៌មានមានកម្រិត ប៉ុន្តែមានការរារាំងក្នុងការទទួលស្គាល់ជាពលរដ្ឋ និងមនុស្សជាតិ។ ជាឧទាហរណ៍ សំណង់អាណាធិបតេយ្យនិងការតាំងទីលំនៅមិនរៀបរយ ជាញឹកញាប់ ត្រូវបានផាត់ចេញពីប្រព័ន្ធប្រកាសអាសន្ន ឬហេដ្ឋារចនាសម្ព័ន្ធទប់ស្កាត់ទឹកជំនន់។ បន្ថែមពីនេះទៀត ភាគច្រើននៃក្រុមងាយរងគ្រោះ ត្រូវបានបាត់បង់«បទដ្ឋានបុរស» ឬ ប្រព័ន្ធវិភាគទិន្នន័យការបែងចែកតាមភេទសម្រាប់ការរៀបចំផែនការ។ ប្រព័ន្ធការជម្លៀស ជាញឹកញាប់មិនត្រូវបានរៀបចំឡើងដោយគិតគូរដល់តម្រូវការរបស់មនុស្សចាស់ និងអ្នកមានពិការភាពឡើយ។ ភាពក្រីក្រ និងភាពងាយរងគ្រោះផ្នែកសេដ្ឋកិច្ច នឹងបង្កឱ្យមានកំណើនលំហូរចំណាកស្រុកមនុស្សជាតិ នៅតាមទីកន្លែង និងពេលវេលាជាក់លាក់ដែលជាញឹកញាប់បង្កឱ្យមានហានិភ័យជាក់លាក់ខាងជម្លោះ និងអំពើហិង្សា។

ច) ការរើសអើងខាងយេនឌ័រ៖ ដោយទទួលយកនូវតួនាទីយេនឌ័រនៅក្នុងសង្គមនេះ ជាពិសេសការទទួលខុសត្រូវក្នុងគ្រួសារដូចជា ស្វែងរកទឹក សន្តិសុខស្បៀង និងការថែទាំ ស្រ្តីកាន់តែងាយរងគ្រោះ និងរែកពន់បន្ទុក ទ្វេដងនៃហេតុការណ៍ពាក់ព័ន្ធនឹងអាកាសធាតុទាំងនេះ។ ស្រ្តី មិនត្រឹមតែទទួលបានអត្ថប្រយោជន៍តិចជាងបុរស ទាក់ទងនឹង ការរកប្រាក់ចំណូលទេ ប៉ុន្តែវារួមទាំង ការទទួលបានកិច្ចគាំពារសង្គម និងការទទួលបានសេវាកម្មហិរញ្ញវត្ថុផង ដែរ ការណ៍នេះនឹងធ្វើឲ្យស្រ្តីកាន់តែងាយរងគ្រោះថែមទៀត។ ជាសាកល ស្រ្តីរកប្រាក់ចំណូលបានត្រឹមតែ ៧៧%នៃចំណូលដែលបុរសរកបាន ដោយមានគម្លាតយេនឌ័រប្រមាណ ២៣ភាគរយ (អង្គការ UN Women ឆ្នាំ២០១៨)។ ការិយាល័យពលកម្មអន្តរជាតិ (Women at Work Trends ឆ្នាំ២០១៦) បានគូសបញ្ជាក់ថា នៅទូទាំងពិភពលោក ស្រ្តីប្រមាណ ៤០% ដែលស្ថិតនៅក្នុងវិស័យការងារទទួលបានប្រាក់ឈ្នួល មិនទទួលបានកិច្ចគាំពារសង្គមទេ។ ស្រដៀងគ្នាដែរ កម្រងទិន្នន័យ Findex សកលឆ្នាំ២០១៤

របស់ធនាគារពិភពលោក (Demirguc-Kunt et al ឆ្នាំ ២០១៥) រាយការណ៍ថា ខណៈដែលបុរសប្រមាណ ៦៥% សុទ្ធតែមានគណនីនៅក្នុងស្ថាប័នហិរញ្ញវត្ថុ និង/ឬ ធនាគារ ស្ត្រីត្រឹមតែ ៥៨%ប៉ុណ្ណោះមានគណនីដូចគ្នានេះ។ លើសពីនេះទៀត ស្ត្រី និងក្មេង ងាយទទួលរងនូវអំពើហិង្សាទាក់ទងនឹងយេនឌ័រ ជាពិសេសអំពើហិង្សាក្នុងគ្រួសារ ការជួញដូរមនុស្ស និងការរៀបការនៅវ័យក្មេង។ល។ (IFRC ឆ្នាំ ២០១៥)។ អំពើហិង្សាផ្លូវភេទលើស្ត្រី ក្មេងស្រី និងក្រុម LGBTIQ ជារឿយៗ មានការកើនឡើង ក្រោយពីគ្រោះមហន្តរាយ (Mian និង Namasivayam ឆ្នាំ២០១៧)។

**ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ការបន្ស៊ាំទៅនឹងការប្រែប្រួលអាកាសធាតុ និងការកសាងភាពធន់សម្រាប់សហគមន៍ក្រីក្រ៖ ការបង្កើតផែនទីរបាំង**

មិនថាអ្នកណាមួយជ្រើសរើសយកយុទ្ធសាស្ត្រការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយឬការបន្ស៊ាំទៅនឹងការប្រែប្រួលអាកាសធាតុ/យុទ្ធសាស្ត្រការកសាងភាពធន់នោះទេ-ការសម្រេចបាននូវលទ្ធផល ត្រូវការសហគមន៍ គោលដៅយល់ដឹងពីហានិភ័យអាកាសធាតុនិងការព្យាករធ្វើការវាយតម្លៃហានិភ័យនិងភាពងាយរងគ្រោះផ្ទាល់ខ្លួន រួមបញ្ចូលនូវទស្សនៈទានហានិភ័យអាកាសធាតុ ជាពិសេសអ្នកទាំងឡាយដែលមានទំនាក់ទំនងជាមួយភាពត្រៀមបង្ការទៅនឹងគ្រោះមហន្តរាយ ការប្រើប្រាស់ដីធ្លី/ធនធាន និងការរៀបចំផែនការហិរញ្ញវត្ថុកម្រិតគ្រួសារ។ ទោះជាយ៉ាងណាសហគមន៍ក្រីក្រពិសេសស្ត្រីជួបប្រទះបញ្ហាប្រឈមជាច្រើនខាងព័ត៌មាន បច្ចេកវិទ្យា ឥរិយាបថ ស្ថាប័ន និងហិរញ្ញវត្ថុ ដើម្បីកសាងភាពធន់ទៅនឹងអាកាសធាតុ (រូបភាព ៤)។

របាំងព័ត៌មាន៖ សហគមន៍ជួបប្រទះជាមួយនឹងរបាំងចំណេះដឹងចំនួនពីរប្រភេទ- ទីមួយ គឺការយល់ដឹងទាបពីហានិភ័យដ៏ខ្លាំងនៃការប្រែប្រួលអាកាសធាតុ ដោយសារកង្វះនូវទិន្នន័យកម្រិតតូច និងកង្វះការទទួលបាននូវព័ត៌មានពាក់ព័ន្ធនឹងអាកាសធាតុ និងមួយទៀតគឺកម្រិតសមត្ថភាពមានកំណត់ក្នុងការវាយតម្លៃហានិភ័យ និងភាពងាយរងគ្រោះតាមបែបវិទ្យាសាស្ត្រ។ បន្ថែមពីនេះទៀត គម្លាតជំនាញក្នុងចំណោមរដ្ឋាភិបាលមូលដ្ឋាននិងអ្នកវិទ្យាសាស្ត្រអាកាសធាតុ ដើម្បីធ្វើការរួមជាមួយសហគមន៍ បង្កើននូវឧបសគ្គដល់ដំណើរការចូលរួមថែមទៀត។ Preston et al (ឆ្នាំ២០១១) តាមរយៈការពិនិត្យមើលឡើងវិញនូវលំហាត់គូសវាសផែនទីបង្ហាញនូវភាពងាយរងគ្រោះចំនួន ៤៥ បានរកឃើញថា មានតែ ៤០% ប៉ុណ្ណោះដែលរួមបញ្ចូលនូវការចូលរួមរបស់ភាគីពាក់ព័ន្ធ ដែលគូសបង្ហាញពីបញ្ហាប្រឈមខាងបច្ចេកទេស ជំនាញ ធនធាន និង ស្ថាប័ន ក្នុងការអនុវត្តដំណើរការដែលមានការចូលរួម។

របាំងការទទួលយកបច្ចេកវិទ្យា៖ ខណៈពេលដែលភាពច្នៃប្រឌិតបច្ចេកវិទ្យាមានសារសំខាន់នោះ វិសាលភាពនៃដោះស្រាយភាពធន់ទៅនឹងអាកាសធាតុសម្រាប់ការទប់ទល់នឹងកម្តៅអាកាសធាតុ (ការរចនាគ្រឿងបញ្ចេញបញ្ចូលខ្យល់ក្នុងបន្ទប់ សម្ភារជាជម្រើសថ្មី ទេសភាពបៃតង) និងការគ្រប់គ្រងទឹក (ទឹកភ្លៀង ការដាំដុះ វិធានការបំពេញឡើងវិញតូចៗ ផែនការទឹកប្រព័ន្ធអេកូ ឧបករណ៍តេស្តទឹក ជាដើម) សុទ្ធតែមានរួចហើយ។ ទោះជាយ៉ាងណា សហគមន៍មិនបានទទួលយកពួកគេទេដោយសារកង្វះការយល់ដឹង។ ជាមួយគ្នានេះដែរបច្ចេកវិទ្យាទាំងនេះសហគមន៍តែងតែមិនទទួលបានហើយពួកគេមិនមែនជាគំរូសាកសមនឹងតម្រូវការជាក់ស្តែងនោះឡើយ (Nagrath ឆ្នាំ២០១៣)។ ជាញឹកញាប់បច្ចេកវិទ្យាលដែលគេផ្តល់ឱ្យនោះមិនស៊ីគ្នានឹងហេដ្ឋរចនាសម្ព័ន្ធដែលមានស្រាប់ ឬឧបសគ្គលំហកំពុងមានស្រាប់។ លើសពីនេះទៀត មនុស្សម្នាក់ក៏ចាំបាច់ត្រូវយល់ផងដែរថា អ្នកក្រីក្រចូលចិត្តដំណោះស្រាយខាងបច្ចេកវិទ្យាដែលបង្កើតឡើងលើការវិនិយោគដែលមានស្រាប់របស់ពួកគេ។ ការដោះស្រាយឧបសគ្គនេះ ទាមទារការចូលរួមរបស់សហគមន៍ជាមួយនឹងអ្នកវិទ្យាសាស្ត្រសង្គម និងអ្នកជំនាញបច្ចេកទេស ដើម្បីរៀបចំដំណោះស្រាយប្រកបដោយប្រសិទ្ធិភាព និងតាមជាក់ស្តែង។ បន្ថែមពីនេះទៀត ដោយសារបរិបទសង្គម-សេដ្ឋកិច្ចរបស់ពួកគេ អ្នកក្រីក្រត្រូវបង្ខំចិត្តគិត និងធ្វើសេចក្តីសម្រេចសម្រាប់អត្ថប្រយោជន៍រយៈពេលខ្លីជាជាងអត្ថប្រយោជន៍រយៈពេលវែង ដូច្នេះ ហើយ ជាញឹកញាប់ ពួកគេបង្ហាញនូវភាពមិនប្រក្រតីផ្នែកឥរិយាបថជាក់លាក់នៅពេលប្រឈមនឹងហានិភ័យ។ ភាពមិនអាចទស្សន៍ទាយបាននៃហានិភ័យទាក់ទងនឹងអាកាសធាតុគឺកាន់តែធ្វើឱ្យលេចចេញនូវភាពមិនប្រក្រតីផ្នែកឥរិយាបថ ដូចជា បាត់បង់បំណងប្រាថ្នា ជំហរមិននឹងនរ និង/ឬការបង្រួមតូច។ដូច្នេះព័ត៌មានធម្មតានឹងមិនធ្វើឱ្យមានការផ្លាស់ប្តូរ ឬការទទួលយកឥរិយាបថឡើយ។ ត្រូវការផ្តល់នូវការលើកទឹកចិត្តផ្សេងៗ (មិនចាំបាច់តែហិរញ្ញវត្ថុ) សម្រាប់ការផ្លាស់ប្តូរនេះ (អង្គការ WHO និង IFRC ឆ្នាំ២០១០)។ ការផ្លាស់ប្តូរនេះត្រូវការការសិក្សាមួយពីវប្បធម៌ក៏ដូចជាឌីណាមិកសង្គមស្របទៅនឹងលក្ខណៈឥរិយាបថរបស់ប្រជាជនក្រីក្រ - វិធីសាស្ត្រជាក់ស្តែងទៅតាមបរិបទ (Nygaard និង Hansen ឆ្នាំ២០១៥)។

របាំងស្ថាប័ន៖ ការបន្ស៊ាំនិងការរៀបចំផែនការការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ (DRR) ជាញឹកញាប់មិនមានលក្ខណៈបរិយាបន្នទោះឡើយ ហើយពិសេស ប្រជាជនក្រីក្រចូលរួមបានតិចតួច ។ តម្រូវការសំខាន់បំផុតនៃភាពធន់ គឺការបង្កើតមូលធនសង្គម ឬស្ថាប័នរបស់ប្រជាជន ពាសពេញតំបន់សំណង់អាណាធិបតេយ្យ និងទីក្រុង ជាពិសេសតំបន់ទាំងឡាយណាដែលមានការបញ្ចូលស្ត្រី និងអ្នកមានសមត្ថភាពជំរុញការផ្លាស់ប្តូរនៅក្នុងរដ្ឋាភិបាល (Boonyabancha, S., Mitlin, D. ឆ្នាំ២០១២)។ នៅពេលដូចគ្នានេះដែរ ត្រូវការរដ្ឋាភិបាលមូលដ្ឋាន និងអ្នកផ្តល់សេវាមូលដ្ឋានឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាជនក្រីក្រ។ ទោះបីយ៉ាងណាក៏ដោយរដ្ឋាភិបាលមូលដ្ឋានភាគច្រើនខ្វះសមត្ថភាព

និងការសម្របសម្រួលអន្តរស្ថាប័ន ដើម្បីអភិវឌ្ឍ និងអនុវត្តផែនការ សកម្មភាពភាពធន់ទៅនឹងអាកាសធាតុដែលមានលក្ខណៈការចូលរួមដែលមានទំនោរទៅរកប្រជាជនក្រី ក្រ។ IPCC (2014) ក៏បានគូសបញ្ជាក់ពីគម្លាតភាពជាដៃគូដ៏សំខាន់រវាងអ្នកជំនាញបច្ចេកទេស រដ្ឋាភិបាលមូលដ្ឋាន និងសហគមន៍ ដើម្បីធ្វើការប៉ាន់ប្រម៉ាណហានិភ័យដែលមានការចូលរួម និងរៀបចំដំណោះស្រាយបច្ចេកទេសរួម។

របាំងហិរញ្ញវត្ថុ៖ ការកាត់បន្ថយគ្រោះមហន្តរាយ និងបច្ចេកវិទ្យាភាពធន់ ជាញឹកញាប់មានតម្លៃថ្លៃ និងត្រូវការទុនវិនិយោគ និងមានតម្លៃថែទាំខ្ពស់ដែលធ្វើឱ្យសហគមន៍ក្រីក្រមិនអាចចូលទៅប្រើពួកវាបាន។ រដ្ឋាភិបាលមូលដ្ឋាន ក៏មិនវិនិយោគលើដំណោះស្រាយហេដ្ឋារចនាសម្ព័ន្ធបែបនេះសម្រាប់ប្រជាជនក្រីក្រផងដែរដោយសារការបែងចែកថវិកាភាគច្រើន គឺសម្រាប់សកម្មភាពកិច្ចគាំពារសង្គម និងសុខមាលភាព-មានតម្រូវការច្រើនប៉ុន្តែការដោះស្រាយបានត្រឹមតែបញ្ហាបច្ចុប្បន្ន។ របាំងហិរញ្ញវត្ថុ កាន់តែមានលក្ខណៈធ្ងន់ធ្ងរនៅតំបន់ទីក្រុងដែលជាទីដែលប្រជាជនក្រីក្រប្រមូលផ្តុំនៅក្នុងសំណង់អាណាធិបតេយ្យនិងតំបន់តាំងទីលំនៅមិនរៀបរយដូច្នេះពួកគេស្ថិតនៅក្រៅរង្វង់ នៃការវិនិយោគហេដ្ឋារចនាសម្ព័ន្ធទីក្រុងរបស់រដ្ឋាភិបាល ។ ប្រភព៖ យកពី (ត្រឹះ Mahila Housing SEWA ឆ្នាំ២០១៥)។

**FIGURE 1-5: BARRIERS TO CLIMATE ADAPTATION AND RESILIENCE BUILDING FOR THE POOR**




ប្រភព៖ ដកស្រង់ចេញពី IPCC របាយការណ៍វាយតម្លៃទី ៥ (ឆ្នាំ២០១៥)

# ម៉ូឌុល១ វគ្គ គ:

3:30:00

## ទំនាក់ទំនងរវាងយេនឌ័រ ការប្រែប្រួលអាកាសធាតុ និងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ

### ទិដ្ឋភាពទូទៅ

ចុងបញ្ចប់នៃវគ្គនេះ អ្នកចូលរួមគួរតែយល់ដឹងនូវផលប៉ះពាល់ផ្សេងៗនៃការប្រែប្រួលអាកាសធាតុ និងពាក់ព័ន្ធនឹងគ្រោះមហន្តរាយទៅលើយេនឌ័រ។ ពួកគេគួរត្រូវបានពន្យល់ណែនាំដើម្បីបញ្ជ្រាបកង្វល់យេនឌ័រទៅក្នុងការបន្សុំាទៅនឹងការប្រែប្រួលអាកាសធាតុ ភាពធន់ និងកម្មវិធីគ្រប់គ្រងគ្រោះមហន្តរាយទាំងអស់។

### មាតិកា

ក)វិសាលភាពយេនឌ័រនៃការប្រែប្រួលអាកាសធាតុនិងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ(CCDRR)
ខ) វិសមភាពយេនឌ័រកាន់តែរីកធំដោយសារការប្រែប្រួលអាកាសធាតុ
គ) តួនាទីយេនឌ័រ និងផលប៉ះពាល់ខុសគ្នានៃការប្រែប្រួលអាកាសធាតុ
ឃ) វិសមភាពយេនឌ័រ ការកសាងសមត្ថភាពបន្សុំាទៅនឹងការប្រែប្រួលអាកាសធាតុ ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងការកសាងភាពធន់
ង) តម្រូវការនៃការរួមបញ្ចូលយេនឌ័រក្នុងគោលនយោបាយ ការប្រែប្រួលអាកាសធាតុ និង ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ (CCDRR)
ច) យុទ្ធសាស្ត្រដែលធ្លាប់មាន ចំណុចខ្វះខាត និងបញ្ហាប្រឈមការបញ្ជ្រាបយេនឌ័រ
ឆ) ស្ត្រីជាដៃគូមានសិទ្ធិស្មើគ្នា និងជាតួអង្គក្នុងសកម្មភាពអាកាសធាតុ

### សម្ភារៈ

បទបង្ហាញ Power point
កាតតួនាទីយេនឌ័រ
ប័ណ្ណព័ត៌មានយេនឌ័រនិង CCDRR
ក្តារខៀន និង ប៊ិចហ្វឺត
ក្រដាសផ្ទាំងធំ និង ប៊ិច
ឯកសារចែកជូន
ឧបករណ៍សម្រាប់ចាក់វីឌីអូលើយូធូប

### តារាងពេលវេលា

| រយៈពេល | សកម្មភាព |
|---|---|
| ៥នាទី | >ចែករំលែកផ្នែកទូទៅ និងរចនាសម្ព័ន្ធ |
| ៤០នាទី | >ផ្គូរផ្គងកាត«តួនាទីយេនឌ័រនិងផលប៉ះពាល់ខុសៗគ្នា»(សូមមើលលំហាត់៦និងឯកសារ ៥) (សម្រាប់កម្រិតមូលដ្ឋាន) |
| | ឬ |
| ៦០នាទី | >«ក្របខ័ណ្ឌការងារ Moser» សម្រាប់ការរៀបចំផែនទីហានិភ័យអាកាសធាតុលក្ខណៈយេនឌ័រ (សូមមើលលំហាត់ ៧) (សម្រាប់វគ្គកម្រិតខ្ពស់)<br>>បទបង្ហាញជាប័ណ្ណព័ត៌មានស្តីពី«វិសាលភាពយេនឌ័រនៃ CCDRR» ដោយប្រើរូបភាព ៥ (សម្រាប់កម្រិតមូលដ្ឋាន) |
| | ឬ |
| ៤៥នាទី | >បទបង្ហាញ Power Point ស្តីពី«វិសាលភាពយេនឌ័រនៃ CCDRR» (សម្រាប់កម្រិតខ្ពស់) |
| ៦០នាទី | >បទបង្ហាញ Power Point ស្តីពី«ការ បញ្ជ្រាបយេនឌ័រក្នុង CCDRR» «ស្ត្រីជាភ្នាក់ងារការផ្លាស់ប្តូរ» ពិនិត្យមើលករណីសិក្សា (សូមមើលលំហាត់ ៨ និងឯកសារ ៦) |

## កំណត់សម្គាល់ណែនាំ

ចាប់ផ្តើមផ្នែកនេះដោយការចែករំលែកនូវមាតិកា និងរចនាសម្ព័ន្ធ។ សូមពន្យល់ថា ការប្រែប្រួលអាកាសធាតុ និងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ (CCDRR) មិនមែនអព្យាក្រិត្យភាពខាងយេនឌ័រទេ។ តួនាទីយេនឌ័រដែលមានស្រាប់ - ទាក់ទងនឹងតម្រូវការ និងការអនុគ្រោះ ក៏ដូចជាវិសមភាពក្នុងការចែករំលែកធនធាន និងអំណាចក្នុងការធ្វើសេចក្តីសម្រេចផងដែរនោះ ជះឥទ្ធិពលទៅលើរបៀបដែលមនុស្សមកពីក្រុមសង្គមផ្សេងៗគ្នានិងអត្តសញ្ញាណយេនឌ័រខុសៗគ្នាជួបប្រទះនឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុនិងការឆ្លើយទៅនឹងបញ្ហាទាំងនេះ។ទស្សនៈយេនឌ័រអាយុនិងភាពក្រីក្រមានឥទ្ធិពលខ្លាំងលើភាពងាយរងគ្រោះ និងសមត្ថភាពឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ និងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ។ ជាលទ្ធផលការប្រែប្រួលអាកាសធាតុពិតជាធ្វើឱ្យកាន់តែរីកធំនូវវិសមភាពយេនឌ័រដែល មានស្រាប់។ សូមប្រាប់ពួកគេថា ឥលូវនេះអ្នកនឹងឈ្វេងយល់ពីទស្សនៈទាំងនេះរួមគ្នាតាមរយៈការអនុវត្តលំហាត់មួយចំនួន។ចាប់ផ្តើមកិច្ចការពីការផ្លូវផ្គងតួនាទីយេនឌ័រនិងផលប៉ះពាល់ ( សូមមើលលំហាត់៦ )។សម្រាប់វគ្គមូលដ្ឋានគ្រឹះ និងបញ្ចប់វាជាមួយបទបង្ហាញជាផ្ទាំងព័ត៌មានស្តីពី វិសាលភាពយេនឌ័រនៃ CCDRR។ សម្រាប់វគ្គកម្រិតខ្ពស់ ចាប់ផ្តើមជាមួយការបង្កើតផែនទីក្របខ័ណ្ឌការងារ Moser ( សូមមើលលំហាត់ ៧ ) បន្ទាប់មកធ្វើបទបង្ហាញ Power Point លម្អិត ដើម្បីពន្យល់ពីវិសាលភាពយេនឌ័រ នៃ CCDRR ផ្សេងៗទៀត។

ផ្នែកបន្ទាប់នៃ វគ្គនេះ នឹងមានព័ត៌មានកាន់តែច្រើនដែលត្រូវផ្តោត តាមរយៈការធ្វើបទបង្ហាញ Power Point ដើម្បីពន្យល់ពីតម្រូវការសមាហ័រណកម្មយេនឌ័រនៅក្នុង CCDRR និងការកសាងភាពធន់ ក៏ដូចជាយុទ្ធសាស្រ្តចំណុចខ្វះខាតនិងបញ្ហាប្រឈមដែលធ្លាប់មាន ដើម្បីឱ្យអាចកើតឡើងដូចគ្នា។ សូមឱ្យប្រាកដថា អ្នកចូលរួមបានចូលរួមក្នុងកិច្ចពិភាក្សាទាំងអស់គ្នា ។ សូមបញ្ចប់បទបង្ហាញ ជាមួយនឹងទិដ្ឋភាពទូទៅអំពីស្រ្តីជាភ្នាក់ងារនៃការផ្លាស់ប្តូរ។ បន្ទាប់មកទៀត បែងចែកអ្នកចូលរួមជាបីក្រុមសម្រាប់ករណីសិក្សាដែលពិនិត្យមើលការអនុវត្តលំហាត់«ស្រ្តីជាភ្នាក់ងារនៃការផ្លាស់ប្តូរ»។ ( សូមមើលលំហាត់ ៨ )

# វិសាលភាពយេនឌ័រនៃការប្រែប្រួលអាកាសធាតុ និងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ (CCDRR) និងការកសាងភាពធន់ (RB)

## ភាពងាយរងគ្រោះទាក់ទងនឹងយេនឌ័រ និងផលប៉ះពាល់ខុសគ្នានៃការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ

ការប្រែប្រួលអាកាសធាតុនិងគ្រោះមហន្តរាយប៉ះពាល់ខុសៗគ្នាទៅលើក្រុមយេនឌ័រផ្សេងគ្នា និងអត្តសញ្ញាណសង្គម ជាញឹកញាប់ធ្វើឱ្យស្ត្រី និងក្រុម LGBTIQ កាន់តែងាយរងគ្រោះ។ បញ្ហាទាំងនេះជាច្រើនមិនមែនដោយសារតែភាពខុសគ្នាខាងផ្នែកជីវសាស្ត្រទេ ប៉ុន្តែដោយសារតួនាទី និងទំនួលខុសត្រូវខុសគ្នាខាងយេនឌ័រនៅកម្រិតគ្រួសារ និងសហគមន៍ (Neumayer និង Plümper ឆ្នាំ២០០៧)។ភាពងាយរងគ្រោះទាក់ទងនឹងយេនឌ័រមានកម្រិតកាន់តែធ្ងន់ធ្ងរឡើងដោយសារភាពខុសគ្នាយេនឌ័រដែលមានស្រាប់ ជាពិសេសការទទួលបានដីធ្លី និងធនធានដទៃទៀត ការចូលរួមក្នុងអភិបាលកិច្ច និងការធ្វើសេចក្តីសម្រេច និងរឹតតែសំខាន់ទៅទៀតនោះគឺការទទួលបានការអប់រំសុខភាព សេវាកម្មបន្ថែម និងសេវាកម្មហិរញ្ញវត្ថុ។ ភាពងាយរងគ្រោះទាក់ទងនឹងយេនឌ័រសំខាន់ៗ នៃការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយត្រូវបានពិភាក្សានៅខាងក្រោមនេះ៖

### ក) កំណើនការងារក្នុងគ្រួសារ និងការមិនមានពេលវេលាផ្ទាល់ខ្លួន

នៅក្នុងការវិភាគតាមវិស័យដ៏ស្មុគស្មាញរបស់យើង ការថែទាំរបស់ស្ត្រីមានសារសំខាន់ក្នុងការផ្តល់នូវការគាំទ្រដ៏រឹងប៉ឹង។ ចំណុចនេះកាន់តែជាក់ច្បាស់ថែមទៀតនៅតំបន់អាស៊ីដែលស្ត្រីធ្វើរហូតដល់ទៅ ៤ដងនូវការងារថែទាំ និងការងារក្នុងគ្រួសារដែលគ្មានប្រាក់កម្រៃ បើធៀបនឹងបុរស (អង្គការ ILO ឆ្នាំ២០១៨) បើប្រៀបធៀបនឹងទិន្នន័យពិភពលោកស្មើនឹង ២,៦ដង (អង្គការ UN Women ឆ្នាំ២០១៨)។ផ្អែកលើការវាស់វែងប្រាក់ឈ្នួលអប្បបរមា Oxfam (Coffey et al ឆ្នាំ២០២០) រាយការណ៍ថា តម្លៃគិតជាប្រាក់នៃការងារថែទាំដែលគ្មានប្រាក់ឈ្នួល ជាសកល មានទំហំខ្ទង់ ១០,៨ពាន់លានដុល្លារអាមេរិក។ តួនាទីការថែទាំ និងការងារដែលពុំទទួលបានប្រាក់ឈ្នួលរបស់ស្ត្រីមានកើនឡើងពេលវេលាច្រើនទ្វេដង ដោយសារការប្រែប្រួលអាកាសធាតុ ជាពិសេសក្នុងស្ថានភាពគ្រោះមហន្តរាយ។ស្ត្រីក្រីក្រនិងអ្នកទាំងឡាយណារស់នៅតំបន់ជនបទដែលកាន់តែមានការចូលរួមក្នុងការថែទាំក្រៅប្រព័ន្ធ (អង្គការ ILO ឆ្នាំ២០១៨) កាន់តែទទួលផលប៉ះពាល់ខ្លាំងបំផុត។ តួនាទីការថែទាំខាងយេនឌ័រសំខាន់មួយចំនួន នឹងផ្តល់ផលប៉ះពាល់ដល់ស្ត្រីកាន់តែច្រើនដូចខាងក្រោម៖

ក១) ការចាត់ចែងសន្តិសុខស្បៀង៖ ដោយសារប្រេកពស្បៀងអាហារកាន់តែមិនអាចព្យាករបាននិងកាន់តែក្រខ្សត់ស្របពេលនឹងតម្លៃម្ហូបអាហារមានការកើនឡើង ស្ត្រីនឹងកាន់តែពិបាកក្នុងការចាត់ចែងសន្តិសុខស្បៀងនៅក្នុងគ្រួសាររបស់ពួកគេ។ ស្ត្រីក្រីក្រីដែលទទួលបានដីធ្លី សេវាផ្សព្វផ្សាយ និងប្រាក់កម្រៃមានកម្រិត នឹងរងផលប៉ះពាល់ខ្លាំងបំផុត។

ក២) ការរកទឹកសម្រាប់បរិភោគ និងប្រើក្នុងគ្រួសារ៖ វិសាលភាពយេនឌ័រនៃការចាត់ចែងទឹកត្រូវបានគេដឹងទូទៅ។នៅក្នុងសង្គមភាគច្រើន ស្ត្រី និងក្មេងស្រីទទួលខុសត្រូវចម្បងលើការរកទឹកសម្រាប់ប្រើក្នុងគ្រួសារ និងបរិភោគ។ ដោយបានកើតឡើងរួចមកហើយនៅក្នុងផ្នែកជាច្រើននៃតំបន់អាស៊ីខាងត្បូង ភាពក្រខ្សត់ទឹក និងកង្វះហេដ្ឋារចនាសម្ព័ន្ធផ្គត់ផ្គង់ទឹកត្រឹមត្រូវ ធ្វើឱ្យស្ត្រីដើររកទឹកនៅចម្ងាយជាច្រើនគីឡូម៉ែត្រ ឬតម្រង់ជួររង់ចាំជាច្រើនម៉ោងដើម្បីយកទឹក។ ដោយរកឃើញថាមនុស្សជាងពីរពាន់លាននាក់ជុំវិញពិភពលោក ត្រូវរំពឹងថា នឹងប្រឈមនឹងការខ្វះខាតទឹកនៅឆ្នាំ២០២៥ (Hameeteman ឆ្នាំ២០១៣) នោះ វានឹងជះឥទ្ធិពលធ្ងន់ធ្ងរដល់ស្ត្រីនិងក្មេងស្រី។នៅក្នុងតំបន់ប្រឈមនឹងភាពរាំងស្ងួត ការចំណាយពេលរបស់ស្ត្រី និងក្មេងស្រីដើម្បីរកទឹក នឹងកើនឡើងពេលវេលាច្រើនដងថែមទៀតដោយសារពួកគេត្រូវធ្វើដំណើរចម្ងាយឆ្ងាយជាងមុននៅក្នុងតំបន់ដូចគ្នា។ នៅក្នុងតំបន់ប្រឈមទឹកជំនន់ ការខូចខាតហេដ្ឋារចនាសម្ព័ន្ធផ្គត់ផ្គង់ទឹកដែលធ្លាប់មាន នឹងកាន់តែធ្លាក់ចុះនូវការទទួលបានទឹកសម្រាប់សហគមន៍ជាច្រើន ជាពិសេសអ្នកទាំងឡាយរស់នៅក្នុងសំណង់អាណាធិបតេយ្យតាមបណ្តាទីក្រុង ដែលនឹងបណ្តាលឱ្យស្ត្រីទទួលរងគ្រោះកាន់តែច្រើនថែមទៀត។

ក៣) ការរៀបចំចំណីសត្វ៖ ដោយសារសម្ពាធដីធ្លីសម្រាប់ផលិតកម្មដំណាំគ្រប់ប្រភេទ ជីវឧស្ម័ន ការកើនឡើង ថាមពលកកើតឡើងវិញភាពអាចរកបានដីសម្រាប់ចិញ្ចឹមសត្វនឹងថយចុះ។ ស្ត្រីដែលមានការទទួលខុសត្រូវចម្បងសម្រាប់រៀបចំចំណីសម្រាប់សត្វគោជាពិសេសសត្វពាហនៈតូចៗដែលជាញឹកញាប់ពួកគេគ្រប់គ្រងនោះ ការថយចុះនូវភាពដែលរកចំណីបាន នឹងជះឥទ្ធិពលលើការមិនមានពេលវេលាផ្ទាល់ខ្លួនរបស់ពួកគេទាំងពីរ (សម្រាប់រៀបចំណីសត្វ) និងភាពក្រីក្រប្រាក់ចំណូលសម្រាប់ស្ត្រី (បាត់បង់សត្វពាហនៈ)។

ក៤) ការរកអុសសម្រាប់ចម្អិន៖ វិធានការម៉ឺងម៉ាត់សម្រាប់ការការពារព្រៃឈើ ក៏ដូចគ្នានឹងគោលនយោបាយកាត់បន្ថយការបញ្ចេញឧស្ម័ន ក៏នឹងជះឥទ្ធិពលបន្ថែមលើភាពរកបានឥន្ធនៈសម្រាប់ចម្អិន ជាពិសេសសម្រាប់ស្ត្រីក្រីក្រដែលមិនអាចលៃលកកេប្រាក់ទិញប្រភពថាមពលស្អាត។ អង្គការ FAO ប៉ាន់ប្រមាណថា នៅក្នុងប្រទេសជាច្រើនដែល កំពុងអភិវឌ្ឍន៍ ប្រើអុសសម្រាប់ដុតច្រើនរហូតដល់ ៩០ភាគរយនៃតម្រូវការថាមពល។ ជាងនេះទៀត តួនាទី និងការរើស

**FIGURE 1-6: POSTER ON GENDER DIMENSIONS OF CCDRR**



# Women and LGBTIQ People are Affected More by Climate Change and Disasters



## INCREASE IN DOMESTIC WORK AND TIME POVERTY

- Asian women's unpaid care and domestic work, already four times that of men, will increase.
- With reduced food crop production and increased food prices, poor women will be strained to maintain food security.
- With more than 2 billion people expected to face water shortage by 2025, women and girls will have to travel longer distances and spend more time to fetch water.
- Damage to water supply infrastructure in floods and cyclones will also hurt women in urban areas.
- As pressure on land for food and fuel grows, grazing land will reduce, increasing the workload of women for arranging fodder.
- Forest protection and clean energy policies will affect fuel and wood availability – a source of 90% energy for poor women.



## EXACERBATED HEALTH BURDEN AND CARING RESPONSIBILITIES

- Skewed intra-household food distribution will result in women and girls being deprived of basic food intake and nutrition.
- Women being more exposed to standing water due to water fetching responsibilities will be at higher risk of water-borne diseases.
- Physiological characteristics also make women, especially pregnant women, more susceptible to vector-borne diseases like Malaria.
- Drinking saltier water (a direct result of sea water ingress) will also have severe impacts, especially on pregnant women, as rates of hypertension and pre-eclampsia will escalate.
- After disasters, women' sexual and reproductive health needs are further marginalized.



## GREATER RISK OF DEATH, INJURY, AND VIOLENCE

- Women  and children are 14 times more likely to die or be injured in a disaster than men due to gender inequalities.
- Forced to sleep in insecure homes and emergency shelters without privacy and hygiene facilities, women and LGBTIQ people are particularly vulnerable to physical and sexual assault.
- Women and girls also often face elevated levels of violence if they have to travel long distances to fetch water, firewood or fuelwood after a disaster.
- Adolescent girls especially report higher levels of sexual violence in the aftermath of disasters. The risk and likelihood of early marriage increases.
- Post-traumatic Stress Disorder among men  often leads to hegemonic masculinity crisis increasing pre-existing levels of violence.
- Women and children also face greater risk of trafficking and being pushed into sex trade.



## HIGHER LIKELIHOOD OF LOSS OF LIVELIHOODS AND ASSETS

- Women are more dependent on natural resource-based livelihood and hence will face more loss due to droughts, flooding, etc.
- Women are often more involved in subsistence farming and provision of agriculture labour and their livelihoods will be more impacted by  loss of crop yield coupled with water scarcity.
- Women also own only smaller livestock such as chickens, ducks, goats, which are not only less likely to be rescued but also more prone to be sold for immediate cash after disasters, thereby resulting loss of limited assets.
- With more women being employed in informal sector, with low paid jobs and lack of social security, their loss of livelihoods will hurt more.
- Already deprived of access to land and resources, their profound vulnerability will be further exacerbated.

*Source: Adapted from GGCA (2016).*

អើងខាងយេនឌ័រ នឹងរារាំងស្ត្រីមិនឱ្យចូលរួមក្នុងដំណើរការធ្វើសេចក្តីសម្រេចពាក់ព័ន្ធនឹងដំណើរការគ្រប់គ្រងព្រៃឈើមូលដ្ឋានដែលនឹងធ្វើឱ្យអុសដុតកាន់តែខ្សត់ហើយធ្វើឱ្យស្ត្រីត្រូវធ្វើដំណើរកាន់តែឆ្ងាយថែមទៀតដើម្បីទៅដល់តំបន់ព្រៃឈើមិនត្រូវបានការពារ។

ក៥) ការគ្រប់គ្រងសំរាមក្នុងគ្រួសារ៖ រដ្ឋាភិបាលទាំងអស់ កំពុងព្យាយាមដោះស្រាយការគ្រប់គ្រងសំរាមដោយមិនត្រឹមត្រូវនៅទីលានចាក់សំរាម និងផ្លូវទឹក។ ដោយសារស្ត្រីទទួលខុសត្រូវចម្បងក្នុងការគ្រប់គ្រងសំរាមនៅក្នុងគ្រួសារពួកគេនឹងរងផលប៉ះពាល់បំផុតដោយសារតួនាទីបន្ថែមក្នុងការញែកសំរាម និងការយកសំរាមទៅកែច្នៃឡើងវិញ។
ទឹកជំនន់ ព្យុះស៊ីក្លូន និងគ្រោះមហន្តរាយដទៃទៀតបំផ្លាញទាំងធនធានធម្មជាតិនិងហេដ្ឋារចនាសម្ព័ន្ធផ្គត់ផ្គង់សម្រាប់សេវាចាំបាច់នានា ដូចជា ទឹក អុសដុត។ល។ ស្ត្រីនិងក្មេងស្រី ទទួលខុសត្រូវសំខាន់ក្នុងការគ្រប់គ្រងកិច្ចការទាំងនេះ ដូច្នេះត្រូវធ្វើដំណើរកាន់តែឆ្ងាយដើម្បីរៀបចំកិច្ចការទាំងនេះ។ចំនួនម៉ោងធ្វើការកាន់តែកើនឡើងដោយមានការផ្តល់ការថែទាំសម្រាប់អ្នករងរបួស និងអ្នកជំងឺ និងការងារស្តាបនាឡើងវិញបន្ទាប់ពីគ្រោះមហន្តរាយ។
ដូចការកត់សម្គាល់របស់ UN Women និង BCAS (ប្រទេសបង់ក្លាដេស) ក្នុងឆ្នាំ២០១៤ «...អាកាសធាតុ [ការប្រែប្រួល]បង្កអន្តរាយដល់ជីវភាពរស់នៅរបស់ស្ត្រីងាយរងគ្រោះ។ រួចពីទឹកជំនន់ ភាពរាំងស្ងួត ព្យុះស៊ីក្លូន កំណើនជាតិប្រៃ ការហូរច្រោះ និងបញ្ហាជាំទឹក មួយថ្ងៃៗរបស់ស្ត្រីត្រូវបានរុំព័ទ្ធទៅដោយការចូលទៅប្រើប្រាស់ធនធានធម្មជាតិហើយពួកគេពឹងអាស្រ័យធនធានធម្មជាតិទាំងនេះដើម្បីថែទាំក្រុមគ្រួសារ និងសហគមន៍របស់ពួកគេ។ ការប្រែប្រួលអាកាសធាតុស្ទើរតែទាំងអស់ នាំទៅរកកំណើនពលកម្មរបស់ស្ត្រី ជាពិសេសវាទាក់ទងនឹងការចូលទៅប្រើប្រាស់ទឹកស្អាត ថាមពល និងម្ហូបអាហារ» (អង្គការ UN Women ឆ្នាំ២០១៦)។

## ខ) បន្ទុកសុខភាព និងការទទួលខុសត្រូវថែទាំកាន់តែធ្ងន់ធ្ងរ

ខ១) ការកើនឡើងបន្ទុកសុខភាព៖ការរើសអើងខាងយេនឌ័រក្នុងគ្រួសារ ជាពិសេសផ្នែកផ្គត់ផ្គង់ម្ហូបអាហារ និងអាហារូបត្ថម្ភ ការទទួលបាននូវទឹកស្អាត។ល។ក៏បង្កើនហានិភ័យសុខភាពដល់ស្ត្រីផងដែរ។ ការបែងចែកម្ហូបអាហារនៅក្នុងគ្រួសារ ដែលគ្មានតុល្យភាព នឹងធ្វើឱ្យសុខភាពស្ត្រី និងក្មេងស្រីកាន់តែចុះទន់ខ្សោយដោយសារមិនទទួលបានម្ហូបអាហារ និងអាហារូបត្ថម្ភមូលដ្ឋាន។ ទឹកដក់ អាចបង្កការគំរាមកំហែងខាងសុខភាពធ្ងន់ធ្ងរតាមរយៈជំងឺឆ្លងតាមទឹក ដូចជា ជំងឺគ្រុនពោះវៀន និងអាសន្នរោគ ឬជំងឺឆ្លងតាមភ្នាក់ងារចម្លងជំងឺ រួមមានជំងឺគ្រុនចាញ់ ជំងឺគ្រុនឈាម ជំងឺគ្រុនលឿង និងជំងឺគ្រុនឈីក (chikungunya)។ស្ត្រីជាទូទៅប្រឈមមុខទៅនឹងតំបន់ទឹកដក់ខ្លាំងជាងបុរស ដោយសារតែតួនាទីដែលបានកំណត់របស់ពួកគេ ដើម្បីរកទឹកបរិភោគ រៀបចំម្ហូបអាហារ និងថែទាំសមាជិកគ្រួសារ និងសត្វពាហនៈ។បន្ថែមពីនេះទៀតស្ត្រីពេលខ្លះងាយទទួលជំងឺឆ្លងតាមភ្នាក់ងារចម្លងជាងបុរស ដោយសារលក្ខណៈជីវសាស្ត្រ។ ឧទាហរណ៍ ស្ត្រីមានផ្ទៃពោះងាយនឹងមូសខាំទ្វេដង ដែលស្លាប់ចំនួនជាងមួយលាននាក់ក្នុងមួយឆ្នាំ។ស្រដៀងគ្នានេះដែរការបរិភោគទឹកដែលមានជាតិប្រៃ (ប៉ះពាល់ដោយផ្ទាល់ពីកំណើននីវ៉ូទឹកសមុទ្រ) អាចមានផលប៉ះពាល់ដល់សុខភាពធ្ងន់ធ្ងរជាពិសេសស្ត្រីដែលផ្ទៃពោះ ដែលអត្រាឡើងសំពាធឈាម និងកន្ត្រាក់ស្បូនកើតមុនពេលនៅក្នុងតំបន់ខ្លះចាប់ផ្តើមកើនឡើង។ ឧទាហរណ៍ នៅតំបន់ឆ្នេរប្រទេសបង់ក្លាដេស ការសិក្សាមួយនៅឆ្នាំ២០១១ បានសង្កត់ធ្ងន់ថា កំណើននីវ៉ូសមុទ្រដែលបណ្តាលមកពីការប្រែប្រួលអាកាសធាតុធ្វើឱ្យប៉ះពាល់ដល់សុខភាពធ្ងន់ធ្ងរសម្រាប់ប្រជាជនក្នុងតំបន់និងជាពិសេសស្ត្រីមានផ្ទៃពោះ (Khan et al ឆ្នាំ២០១១)។

ខ២) ការថែទាំកុមារ អ្នកជំងឺ និងមនុស្សចាស់៖ ក្នុងនាមជាអ្នកថែទាំបឋមស្ត្រីនិងក្មេងស្រីក៏កាន់តែមានការទទួលខុសត្រូវថែមទៀតខាងថែទាំសុខភាពនៅពេលសមាជិកគ្រួសាររឹតតែប្រឈមនឹងជំងឺឆ្លងតាមទឹក និងជំងឺឆ្លងតាមភ្នាក់ងារចម្លងជំងឺ ដូចជា ជំងឺគ្រុនចាញ់ ជំងឺគ្រុនឈាម អាសន្នរោគ និងជំងឺស្រ្តេសឡើងកម្តៅ។

ខ៣) កង្វល់ផ្លូវភេទនិងកង្វល់សុខភាពបន្តពូជរបស់ស្ត្រី៖ ក្រោយគ្រោះមហន្តរាយ ជាញឹកញាប់ឃើញថាសិទ្ធិសុខភាពផ្លូវភេទ និងសុខភាពបន្តពូជរបស់ស្ត្រីជួបការលំបាក។ ការសិក្សានានានៅក្នុងតំបន់អាស៊ីខាងត្បូង និងអាស៊ីអាគ្នេយ៍បង្ហាញពីដំណើរការសង្គ្រោះគ្រោះមហន្តរាយមិនរាប់បញ្ចូលនូវតម្រូវការសុខភាពផ្លូវភេទ និងសុខភាពបន្តពូជស្ត្រីទេ។ ស្ត្រីមកពីសហគមន៍នេសាទនៅក្នុងប្រទេសហ្វីលីពីនរាយការណ៍ពីអត្រាកំណើតកើនឡើងបន្ទាប់ពីគ្រោះមហន្តរាយ និងជាដំណើរការមួយពាក់ព័ន្ធនឹងការធ្លាក់ចុះប្រាក់ចំណូលបានមកពីមុខរបរនេសាទ ដែលរងផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ (Castro និង Hernandez ឆ្នាំ២០១៥)។ ការសិក្សាមួយពីប្រទេសនេប៉ាល់បានបង្ហាញការរៀបរាប់ពីស្ត្រីដែលរាយការណ៍ពីក្រោយគ្រោះមហន្តរាយ ស្ត្រីមានផ្ទៃពោះជាច្រើនមិនបានទទួលម្ហូបអាហារមានជីវជាតិត្រឹមត្រូវបណ្តាលឱ្យមានបញ្ហាកង្វះសារជាតុចិញ្ចឹមនិងបញ្ហាពេលឆ្លងទន្លេ (Singh ឆ្នាំ២០១៥) នៅម៉ាល់ឌីវ ស្ត្រីរាយការណ៍ពីឧបករណ៍សង្គ្រោះមិនបានបញ្ចូលនូវសម្ភារចាំបាច់ជាក់លាក់ខាងយេនឌ័រ។ការរៀបចំផែនការគ្រួសារនិងសេវាកម្មSRH

នានាក្លាយជាឧបសគ្គ និងមិនអាចចូលទៅប្រើបាននៅលើកោះម៉ាល់ឌីវបន្ទាប់ពីគ្រោះមហន្តរាយ (Shazly និង Mohamed ឆ្នាំ២០១៥)។ ការសិក្សាមួយពីស្ត្រីនៅតំបន់ជនបទ និងតំបន់ដាច់ស្រយាលនៅប្រទេសឡាវការទទួលបានសូម្បីតែសេវាសុខភាពផ្លូវភេទចាំបាច់និងសេវាសុខភាពបន្តពូជក៏មិនអាចទទួលបានដោយសារផ្លូវនិងស្ពានមិនអាចធ្វើដំណើរបាននៅរដូវវស្សាឬបន្ទាប់ពីទឹកជំនន់បណ្តាលឱ្យខូចខាត។អំឡុងពេលរដូវប្រាំងស្ត្រីត្រូវដើរយ៉ាងតិចចម្ងាយ ១២-២០គីឡូម៉ែត្រ ក្រោមកម្តៅថ្ងៃ ដើម្បីទទួលបានសេវាកម្មថែទាំទាំងនេះនៅមណ្ឌលសុខភាព (Thikeo និង Sychareun ឆ្នាំ២០១៥)។ បន្ទុកការងារផ្ទះសម្បែង និងបន្ទុកការងារមិនទទួលប្រាក់ឈ្នួលកើនឡើងបន្ទាប់ពីគ្រោះមហន្តរាយនានា និងគ្រឿងបរិក្ខារអនាម័យបរិស្ថានកាន់តែយ៉ាប់យ៉ឺនឡើងប៉ះពាល់សុខភាពស្ត្រី (Bisan and I ឆ្នាំ ២០១៥)។ នៅប្រទេសបង់ក្លាដេស ទីជម្រកព្យុះស៊ីក្លូនជាច្រើនមិន បរិយាបន្នតម្រូវការជាក់លាក់ខាងយេនឌ័រ។ ពេលខ្លះផ្លូវទៅកាន់ទីជម្រកឬការចូលទៅប្រើបង្គន់ឬសូម្បីតែលំហដាច់ដោយឡែកសម្រាប់ស្ត្រី និងម្តាយបំបៅដោះកូនដែលផាត់ស្ត្រីមិនឱ្យទទួលបានទីជម្រកព្យុះស៊ីក្លូន។ ស្ត្រីពីប្រទេសប៉ាគីស្ថានរាយការណ៍ពីបញ្ហាសុវត្ថិភាពនិងឯកជនភាពក្នុងការផ្លាស់ទៅទីជម្រកបែបនេះ (Hussain ឆ្នាំ២០១៥)។ ជំនួសមកវិញការមានផ្ទៃពោះដែលមិនចង់បាននិងការរំលូតកូនដែលគ្មានសុវត្ថិភាពកើនឡើងបន្ទាប់ពីគ្រោះមហន្តរាយ។

**FIGURE 1-7: GENDER DIFFERENCES IN MORTALITY RATES DURING DISASTERS**




*Source: UN Women (2016).*

## គ) ហានិភ័យខ្ពស់នៃការស្លាប់ ការរបួស និងអំពើហិង្សា

គ១) ស្ត្រីងាយនឹងស្លាប់ជាងបុរសអំឡុងពេលគ្រោះមហន្តរាយ៖ ស្ត្រីងាយបាត់បង់ជីវិតជាងបុរសអំឡុងពេលគ្រោះមហន្តរាយ។ អត្រាមរណៈភាពទាក់ទងនឹងគ្រោះមហន្តរាយដូចមានបង្ហាញនៅរូបភាព ៦ គូសបញ្ជាក់យ៉ាងច្បាស់ពីភាពខុសគ្នានេះ (អង្គការ UNE Women ឆ្នាំ២០១៦)។ ការសិក្សាមួយទៀតក៏ (Neumayer និង Plumper ឆ្នាំ២០០៧) បញ្ជាក់ផងដែរថា ស្ត្រី និងកុមារ មានអត្រាប្រឈមនឹងការស្លាប់ និងរងរបួសខ្ពស់ជាងបុរសចំនួន ១៤ដង នៅពេលគ្រោះមហន្តរាយ។ការសិក្សានេះក៏បង្ហាញថាវាមិនមែនដោយសារភាពខ្សោយធម្មជាតិ និងភាពខ្សោយរាងកាយនោះទេ ប៉ុន្តែ ភាគច្រើនដោយសារវិសមភាពយេនឌ័រ។ ផ្អែកលើការត្រួតពិនិត្យឡើងពីយេនឌ័រនិងគ្រោះមហន្តរាយនានានៅក្នុងប្រទេសចំនួន១៤១ ការសិក្សានៅឆ្នាំ២០០៧នេះ បានបង្ហាញយ៉ាងច្បាស់ ពេលសិទ្ធិសេដ្ឋកិច្ច និងសិទ្ធិសង្គមត្រូវបានបែងចែកស្មើគ្នា អត្រាមរណៈភាព មានកម្រិតស្រដៀងគ្នា។ ការរើសអើងខាងយេនឌ័រសំខាន់ៗ ដែលដើរតួនាទីចម្បង មានគូសបញ្ជាក់នៅខាងក្រោមនេះ៖

- រលកស៊ូណាមិនៅអាស៊ីឆ្នាំ២០០៤ស្ត្រីនិងកុមារជាច្រើនបានស្លាប់ពីព្រោះពួកគេជាប់នៅក្នុងផ្ទះរបស់ពួកគេ (ដោយសារបទដ្ឋានយេនឌ័រ) ខណៈដែរបុរសចេញទៅកណ្តាលវាល។ អង្គការ UN Women (Dankelman ឆ្នាំ២០១៦) ក៏គូសបញ្ជាក់ពីរបៀបនៃការស្លាប់នេះខ្ពស់សម្រាប់ស្ត្រីក្រីក្រដោយសារផ្ទះសម្បែងដែលពួកគេស្នាក់នៅជាញឹកញាប់សាងសង់

គុណភាពអន់និងខ្វះការការពារទប់ទល់នឹងគ្រោះមហន្តរាយ។

- ស្ត្រីទទួលបាននូវព័ត៌មានមានកម្រិត និងក៏ទទួលបាននូវព័ត៌មានប្រកាសអាសន្នទាន់ពេលវេលាបានតិចតួចផងដែរ (អង្គការ Oxfam ឆ្នាំ២០០៥)។ ស្ត្រីមានអនក្ខរភាព ជួបការលំបាកបន្ថែមក្នុងការអាននិងពិបាកធ្វើតាមការប្រកាសអាសន្នគ្រោះមហន្តរាយ (Aguilar et al ឆ្នាំ២០១៥)។
- ទោះបីពេលពួកគេទទួលបានសេចក្តីជូនដំណឹងពីការជម្លៀសព្រំដែនវប្បធម៌ដូចជាការទទួលខុសត្រូវមនុស្សចាស់ និងកុមារ ធ្វើឱ្យខកខានក្នុងការសម្រេចចិត្តភ្លាមៗ មិនអាចរើទីតាំងទៅកន្លែងផ្សេងដោយគ្មានសាច់ញាតិខាងបុរសដែលធ្វើឱ្យការឆ្លើយតបមានការយឺតយ៉ាវ។ ឧទាហរណ៍ មានការចងក្រងឯកសារពីស្ត្រីនៅប្រទេសបង់ក្លាដេសមិនចាកចេញពីផ្ទះរបស់ពួកគេអំឡុងពេលទឹកជំនន់ ដោយសារឧបសគ្គវប្បធម៌លើការផ្លាស់ទីរបស់ពួកគេ និងស្ត្រីទាំងឡាយណាដែលបានផ្លាស់ទីមិនអាចហែលទឹកជំនន់បាន (Rohr, U ឆ្នាំ២០១៦ ដែលយោងពី (Espen ឆ្នាំ២០០៨)។
- នៅក្នុងសង្គមមួយចំនួន ការប្រតិបត្តិ (ភាពនៅដាច់ពីគេ) បង្ហាញនូវកម្រិតណាមួយដែលស្ត្រី និងក្មេងស្រីអាចចាកចេញពីផ្ទះសម្បែង ដើម្បីទៅស្វែងរកទីជម្រក (Sultana ឆ្នាំ២០១៨)។ ឪពុកម្តាយជាច្រើន គិតថាទីជម្រកព្យុះស៊ីក្លូន មិនមានសុវត្ថិភាពសម្រាប់ក្មេងស្រី ហើយសុខចិត្តទុកពួកគេនៅផ្ទះជាជាងឱ្យពួកគេប្រឈមនឹងគ្រោះថ្នាក់ដែលអាចកើតមានឡើងនៅកន្លែងដែលដេករួមគ្នានិងខ្វះគ្រឿងបរិក្ខារអនាម័យគ្រប់គ្រាន់ និងឯកជនភាព (Swarup et al ឆ្នាំ២០១១)។
- ស្ត្រីនិងក្មេងស្រីជាញឹកញាប់ទទួលបាននូវការបណ្តុះបណ្តាលការឆ្លើយតបទៅនឹងគ្រោះមហន្តរាយតិចតួចឬគ្មានទាល់តែសោះ (ឧ. ការហែលទឹក និងការឡើងដើមឈើ) និងការរឹតបណ្តឹងការស្លៀកពាក់ (ដូចជាការស្លៀកសំពត់ sarees) អាចផ្តល់គ្រោះថ្នាក់បន្ថែមដល់ចល័តភាពដោយសេរីរបស់ស្ត្រី និងក្មេងស្រីអំឡុងពេលគ្រោះមហន្តរាយ។ ការសិក្សាមួយនៅឆ្នាំ២០០៩ នៅរដ្ឋ Gujarat ប្រទេសឥណ្ឌា បានបង្ហាញថា ស្ត្រីភាគច្រើនមិនចេះហែលទឹកកម្រិតណា ប៉ុន្តែបុរស ៤០% ចេះហែល (Ahmed ឆ្នាំ២០០៩)។
- បន្ថែមពីនេះទៀត ស្ត្រី និងក្រុម LGBTIQ ក៏ជួបប្រទះផលលំបាកអវិជ្ជមានផងដែរនៅក្រោយគ្រោះមហន្តរាយជាពិសេសពាក់ព័ន្ធនឹងការសង្គ្រោះនិងការស្តារឡើងវិញ (អង្គការ UN Women ឆ្នាំ២០១៦)។

គ២) កំណើនអំពើហិង្សាផ្លូវភេទ និងអំពើហិង្សាផ្អែកលើយេនឌ័រ៖ ស្ត្រី និងក្រុមមនុស្ស LGBTIQ ងាយរងគ្រោះជាពិសេសហិង្សាខាងរាងកាយនិងផ្លូវភេទពីព្រោះជាញឹកញាប់ត្រូវបង្ខំឱ្យដេកនៅក្នុងផ្ទះដែលគ្មានសុវត្ថិភាព និងទីជម្រកសង្គ្រោះបន្ទាន់ដែលមិនមានឯកជនភាព និងបន្ទប់អនាម័យដាច់ដោយឡែក ។ ជាពិសេស ក្មេងស្រីពេញវ័យ រាយការណ៍ពីការបៀតបៀនរំខានផ្លូវភេទនិងការរំលោភបំពានផ្លូវភេទនៅក្រោយគ្រោះមហន្តរាយមានកម្រិតកាន់តែខ្ពស់ (Bartlett ឆ្នាំ២០០៨)។ ស្ត្រី និងក្មេងស្រីក៏ជួបប្រទះអំពើហិង្សាកម្រិតខ្ពស់ដែរ បើសិនពួកគេត្រូវធ្វើដំណើរឆ្ងាយដើម្បីស្វែងរកទឹក អុសដុត ឬម្ហូបអាហារ បន្ទាប់ពីគ្រោះមហន្តរាយ។

លើសពីនេះទៀត កំណើនភាពតានតឹង និងអារម្មណ៍អស់កម្លាំងពលំដោយសារការបាត់បង់សាច់ញាតិ ការបាត់បង់ទ្រព្យសម្បត្តិនិងការបាត់បង់ជីវភាពរស់នៅបញ្ហាសុខភាពផ្លូវចិត្ត ដូចជា ជំងឺបាក់ស្បាត កង្វះខាតការផ្តល់តម្រូវការមូលដ្ឋាន និងកត្តាផ្សេងៗទៀតដែលបណ្តាលឱ្យមានវិបត្តិដឹកនាំដោយបុរសភេទ ចូលរួមចំណែកដល់អំពើហិង្សាលើសកម្រិតដែលធ្លាប់មានក្នុងចំណោមបុរស។វាជាញឹកញាប់រួមផ្សំជាមួយនឹងការបាត់បង់ការការពារពីសមាជិកគ្រួសារដែលស្លាប់ឬធ្វើចំណាកស្រុក ក៏ដូចគ្នានឹងការល្មើសនឹងច្បាប់ (អង្គការ UN Women ឆ្នាំ២០១៦)។

កំណើននៃភាពក្រីក្រនិងការតស៊ូដើម្បីឈានដល់ចំណុចបញ្ចប់ចំនួនពីរដែលធ្វើឱ្យមានកំណើនអាពាហ៍ពិពាហ៍ទាំងបង្ខំនៅវ័យក្មេងក្នុងចំណោមក្មេងស្រីអនីតិជន។ ស្ត្រី និងកុមារក៏ស្ថិតនៅក្នុងកម្រិតហានិភ័យខ្ពស់បំផុតនៃការជួញដូរនៅក្នុងពេលគ្រោះមហន្តរាយនិងពួកគេប្រឈមនឹងកម្រិតហានិភ័យខ្ពស់បំផុតក្លាយជាគោលដៅនៃការគេងប្រវ័ញ្ច ធ្លាក់ទៅក្នុងទាសភាព និងពលកម្មផ្លូវភេទ (Nelleman et al ឆ្នាំ២០១១)។ ក៏មានភស្តុតាងការងារនៅក្នុងវិស័យផ្លូវភេទកើនឡើងអំឡុងពេលវិបត្តិអាកាសធាតុដែរ (IFRC ឆ្នាំ២០១៥)។

**ចំណុចពិភាក្សា**

សូមសួរអ្នកចូលរួមតើពួកគេមានអង្កេតឃើញមានករណីកំណើនអំពើហិង្សាផ្លូវភេទនិងអំពើហិង្សាផ្អែកលើយេនឌ័រអំឡុងពេលគ្រោះមហន្តរាយដែរឬទេ?

**តម្រុយសម្រាប់អ្នកសម្របសម្រួល**

> បន្ទាប់ពីព្យុះស៊ីក្លូនឆ្នាំ១៩៩១ នៅប្រទេសបង់ក្លាដេស ស្ត្រីវ័យក្មេងជាច្រើនបានរាយការណ៍ពីការចាប់ជំរិត និងការរំលោភបំពានជាពិសេសនៅកន្លែងណាដែលគ្មានការបំបែកដោយឡែកនូវកន្លែងសុវត្ថិភាពសម្រាប់ការគេង ការផ្លាស់ប្តូរសំលៀកបំពាក់ ការងូតទឹក និងបង្គន់នានា។

> អាពាហ៍ពិពាហ៍វ័យក្មេងតែងតែជាបញ្ហាមួយនៅប្រទេសបង់ក្លាដេស ប៉ុន្តែថ្មីៗនេះពួកវាក៏ត្រូវភ្ជាប់ទំនាក់ទំនងជាមួយ

គ្រោះមហន្តរាយនិងអាពាហ៍ពិពាហ៍វ័យក្មេងផងដែរ។បញ្ហានេះកើតឡើងដោយសារតែគ្រួសារក្រីក្រតែងតែមើលឃើញថា ក្មេងស្រីម្នាក់ស្មើមាត់មួយដែលត្រូវដកចេញការផ្គត់ផ្គង់ ខណៈដែរខាងគ្រួសារកូនកម្លោះវិញមើលឃើញនាងជាដៃជាជើងជួយការងារ។ លើសពីនេះទៀត បញ្ហាសង្គម ដូចជា បណ្ណាការនិងជំនូនជាញឹកញាប់ធ្លាក់មកលើក្មេងស្រីវ័យក្មេងដែលបានលក់ទៅឱ្យអនាគតស្វាមី។

> ការសិក្សានៅប្រទេសបង់ក្លាដេសនិងប្រទេសឥណ្ឌូនេស៊ីដោយ ARROW ( Mian និង Namasivayam ឆ្នាំ២០១៧ ) បានរាយការណ៍ថាស្ត្រីនិងក្មេងស្រីកាន់តែស្ថិតក្នុងហានិភ័យនៃអំពើហិង្សាផ្លូវភេទ ដោយសារការប្រែប្រួលអាកាសធាតុ ត្រូវដើរកាន់តែឆ្ងាយដើម្បីទៅរកទឹក រកអុសដុត ម្ហូបអាហារ។ល។

> កំណើនអំពើហិង្សាលើស្ត្រីក្រោយគ្រោះមហន្តរាយនិងអំឡុងពេលធាតុអាកាសក្តៅក៏មានចងក្រងនៅប្រទេសវៀតណាមដែរ (អង្គការ OXFAM ឆ្នាំ២០០៩ )។

> ការសិក្សាមួយដោយអង្គការ ActionAid (Chanthy និង Samchan ឆ្នាំ២០១៤ ) ចំនួនករណីអំពើហិង្សាក្នុងគ្រួសារត្រូវបានរាយការណ៍ថា មានការកើនឡើងទ្វេដងនៅខេត្តបន្ទាយមានជ័យ និងខេត្តស្វាយរៀង ក្រោយទឹកជំនន់ បើប្រៀបធៀបទៅនឹងមុនពេលទឹកជំនន់។

> ក្រោយការរញ្ជួយដីនៅប្រទេសនេប៉ាល់ឆ្នាំ២០១៥ គ្រួសារដែលមានស្ត្រីជាមេគ្រួសារជាច្រើនបានរាយការណ៍ពីអារម្មណ៍គ្មានសុវត្ថិភាពនៅក្នុងតង់បណ្តោះអាសន្ន ជាពិសេស មានកំណើនការផឹកគ្រឿងស្រវឹងក្នុងចំណោមបុរស។

> ប្រទេសនេប៉ាល់ ក៏បង្ហាញពីកំណើននៃការជួញដូរមនុស្សប្រមាណពី ៣ ទៅ ៥ពាន់ករណីជារៀងរាល់ឆ្នាំនៅឆ្នាំ ១៩៩០ ទៅ ១២ ទៅ ២០ពាន់ករណីក្នុងមួយឆ្នាំក្រោយការរញ្ជួយដី។

> នៅក្នុងរដ្ឋ Bengal ភាគខាងលិចនៃប្រទេសឥណ្ឌា មានការអង្កេតពីលំនាំរវាងការជួញដូរស្ត្រី និងក្មេងស្ត្រី និងទឹកជំនន់ប្រចាំឆ្នាំ។ របាយការណ៍ស្រដៀងៗគ្នានេះ បានបង្ហាញឡើងបន្ទាប់ពីព្យុះស៊ីក្លូន Phallin នៅឆ្នាំ២០១៣។

> ក៏មានភស្តុតាងមួយចំនួនទៀតបង្ហាញថាការចាប់ជំរិតគឺជាបញ្ហាចម្បងមួយបន្ទាប់ពីព្យុះទីហ្វុង Haiyan នៅប្រទេសហ្វីលីពីនឆ្នាំ២០១៣។

> បន្ទាប់ពីរលកស៊ូណាមិឆ្នាំ២០០៥ ប្រទេសស្រីលង្កាក៏បានរាយការណ៍ពីករណីការបៀតបៀននិងការរំលោភបំពានដែរ។

> ការបិទខ្ទប់នៅពេលជំងឺកូវីដ-១៩ឆ្នាំ២០២០ឃើញមានការកើនឡើងយ៉ាងគំហុកនូវករណីអំពើហិង្សាក្នុងគ្រួសារជុំវិញពិភពលោក។

### ឃ) ទំនោរនៃការបាត់បង់ជីវភាពរស់នៅ និងទ្រព្យសម្បត្តិកាន់តែខ្ពស់

មានភាពខុសគ្នាសំខាន់ៗមួយចំនួននៅក្នុងលំនាំនៃជីវភាពរស់នៅរបស់បុរស និងស្ត្រីមនៅក្នុងសង្គមជាច្រើន។ ទោះបីជាភាពខុសគ្នាទាំងនេះធាតុផ្សំទៅតាមបរិបថមួយក៏ដោយ ក៏ធាតុផ្សំទាំងនេះមានគូសបញ្ជាក់ដូចខាងក្រោម៖

ក ) ស្ត្រីពឹងពាក់លើជីវភាពរស់នៅដែលពឹងផ្អែកលើធនធានធម្មជាតិជាងបុរស៖ ស្ត្រីក៏មានកាន់កាប់ទ្រព្យសម្បត្តិចំនួនពីបីដែរ និងពឹងផ្អែកច្រើនលើធនធានធម្មជាតិសម្រាប់ជីវភាពរស់នៅ។ ការបាត់បង់ជីវភាពរស់នៅ ជាពិសេសកសិករខ្នាតតូច និងអ្នកទាំងឡាយណាដែលជីវភាពរស់នៅពឹងផ្អែកលើកសិកម្ម ក៏បង្កើតឱ្យមានផលប៉ះពាល់ខុសគ្នាសម្រាប់ស្ត្រី និងបុរសដែរ។ស្ត្រីជាញឹកញាប់ទាក់ទងនឹងការធ្វើកសិកម្មដំណាំសម្រាប់បរិភោគនិងការផ្តល់ពលកម្មក្នុងកសិកម្មកាន់តែរងផលប៉ះពាល់ដោយការបាត់បង់ទិន្នផលដំណាំទាក់ទងនឹងកង្វះខាតទឹក។ហើយខណៈពេលបន្ទាប់ការបែងចែកពលកម្មមានក្នុងសកម្មភាពដែលជាប់ទាក់ទងដូចជាការចិញ្ចឹមសត្វពាហនៈ ស្ត្រីជាញឹកញាប់កាន់កាប់និងគ្រប់គ្រងតែសត្វពាហនៈតូចៗ ដូចជាមាន់ ទា និងពពែ។ អំឡុងពេលគ្រោះមហន្តរាយ សត្វទាំងនេះទំនងជាត្រូវបានជួយសង្គ្រោះតិចតួចណាស់ដោយសារតែឧបសគ្គក្នុងការប្រតិបត្តិការសង្គ្រោះ។ ជលផល ជាវិស័យមួយទៀតដែលមានចំនួនស្ត្រីច្រើននៅក្នុងអាស៊ី នឹងរងផលប៉ះពាល់ដោយការថយចុះគុណភាពប្រព័ន្ធអេកូឡូស៊ីសមុទ្រដោយសារការប្រែប្រួលអាកាសធាតុ។

ខ ) ការជាប់ទាក់ទងតាមវិស័យ៖ ក្រៅពីកសិកម្ម និងសកម្មភាពជាប់ពាក់ព័ន្ធកសិកម្ម ស្ត្រីជាពិសេសស្ត្រីក្រីក្រនៅអាស៊ី ជាញឹកញាប់ប្រមូលផ្តុំក្នុងការងារការផលិតនៅក្នុងឧស្សាហកម្មកាត់ដេរ និងវិស័យបដិសណ្ឋាកិច្ច/ទេសចរណ៍។ ជាពិសេស ឧស្សាហកម្មកាត់ដេរនឹងរងផលប៉ះពាល់ដោយការប្រែប្រួលអាកាសធាតុទីមួយដោយសារការធ្លាក់ចុះនូវផលិតផលកប្បាសនៅអាស៊ី និងទីពីរដោយសារផលប៉ះពាល់នៃរលកកម្តៅលើផលិតភាព។ ឧទាហរណ៍ នៅប្រទេសកម្ពុជា ការសិក្សានានាបង្ហាញពីនិន្នាការធ្លាក់ចុះនៃផលិតភាពសម្រាប់ថ្ងៃកាន់តែក្តៅមានសារសំខាន់តាមលក្ខណៈស្ថិតិនៅក្នុងឧស្សាហកម្មកាត់ដេរ ( Kjellstrom និង Phan ឆ្នាំ២០១៧ )។កម្មករធ្វើការតាមផ្ទះក៏រងផលប៉ះពាល់ខ្លាំងដែរដោយសាររលកកម្តៅ។ តាមការពិភាក្សាក្រុមដោយ Mahila Housing Sewa Trust ជាមួយកម្មករស្ត្រីធ្វើការតាមផ្ទះនៅក្នុងសំណង់អាណាធិបតេយ្យចំនួន៥០ នៅតាមបណ្តាទីក្រុង នៅប្រទេសឥណ្ឌា បង់ក្លាដេស និងប្រទេសនេប៉ាល់ មានការរាយការណ៍ពីស្ត្រីជិត ៣០% ធ្លាក់ចុះផលិតភាពអំឡុងពេលខែក្តៅដោយសាររលកកម្តៅ ( Mahita Housing SEWA Trust ឆ្នាំ២០១៥ )។ បន្ថែមពីនេះទៀតកម្មករធ្វើការតាមផ្ទះកាន់តែងាយរងងាយគ្រោះដោយ

សារការបាត់បង់នូវវត្ថុធាតុដើម និងកន្លែងការងារ ពេលផ្ទះលិចលង់អំឡុងពេលទឹកជំនន់ និង/ឬ ត្រូវបានបំផ្លាញអំឡុងពេលគ្រោះមហន្តរាយធំៗផ្សេងទៀត។

គ) ការបាត់បង់ទ្រព្យសម្បត្តិ៖ស្ត្រីក៏មានចំណងនឹងការបាត់បង់ទ្រព្យសម្បត្តិដែលមានកំណត់របស់ពួកគេអំឡុងពេល និងក្រោយពេលគ្រោះមហន្តរាយ។ឧទាហរណ៍នៅប្រទេសនេប៉ាល់ស្ត្រីគ្រប់គ្រងលើសត្វពាហនៈតូចៗ ដែលផ្តល់ឱ្យពួកគេដោយឪពុកម្តាយរបស់ពួកគេ ដើម្បីចាប់ផ្តើមគ្រួសារថ្មីមួយ។ វាត្រូវបានកត់សម្គាល់ថាក្រោយការរញ្ជួយដីឆ្នាំ២០១៥ការលក់ដូរប្រេកបដោយភាពតានតឹងនូវទ្រព្យសម្បត្តិដើម្បីដោះស្រាយបញ្ហាគ្រោះមហន្តរាយមាននិន្នាការផ្តោតលើសត្វពាហនៈតូចដូចជាសត្វពពែនិងសត្វមាន់ដែលកាន់កាប់និងគ្រប់គ្រងដោយស្ត្រី។ ស្រដៀងគ្នានឹងដែរ ទឹកជំនន់នៅប្រទេសមីយ៉ាន់ម៉ាឆ្នាំ២០១៥ ស្ត្រីបានបាត់បង់សត្វចិញ្ចឹមទាំងអស់ ៨០ភាគរយដែលស្លាប់នៅក្នុងទឹកជំនន់ ខណៈដែរបុរសបាត់បង់សត្វចិញ្ចឹម ២០ភាគរយ ដូចជាសត្វក្របី គោ និងសត្វជ្រូក (អង្គការ UN Women ឆ្នាំ២០១៦)។ នៅប្រទេសឥណ្ឌា មានរបាយការណ៍ជាច្រើនគូសបញ្ជាក់ពីទំហំសត្វចិញ្ចឹមកាន់តែតូច គឺទីមួយពាក់ព័ន្ធនឹងយុទ្ធសាស្ត្រដោះស្រាយភាពរាំងស្ងួតដែលអនុវត្តដោយគ្រួសារក្រីក្រ។ ការបំផ្លិចបំផ្លាញអគារក្នុងស្រុកអំឡុងពេលទឹកជំនន់ ក៏មិនមែនមានន័យត្រឹមតែបាត់បង់ផ្ទះសម្បែងប៉ុណ្ណោះទេ ប៉ុន្តែវាជាទីបញ្ចប់នៃជីវភាពរស់នៅ របស់ពួកគេផងដែរ រួមទាំងលទ្ធភាពដោះស្រាយជាមួយនឹងភាពស្រេសនាពេលអនាគត។ ស្ត្រីជាច្រើននៅក្នុងតំបន់អាស៊ីអាគ្នេយ៍មិនមានប្រើធនាគារ ប៉ុន្តែ លាក់លុយ/គ្រឿងអលង្ការនៅក្នុងផ្ទះ ដែលអាចបាត់បង់ក្នុងករណីការជម្លៀសពេលគ្រោះអាសន្ន និង/ឬ ជួបការចំណាយភ្លាមៗ ដែលបណ្តាលឱ្យស្ត្រីបាត់បង់នូវការសន្សំស្តួចស្តើងបន្ថែមទៀត។ កម្រិតដែនកំណត់មួយទៀតគឺស្ត្រីក៏មិនមានធានារ៉ាប់រង ឬការរ៉ាប់រងចំណាយលើការបាត់បង់នៅពេលជួបគ្រោះមហន្តរាយហើយក៏មិនមានរាប់បញ្ចូលក្នុងការប៉ាន់ប្រម៉ាណការបាត់បង់ខាងសេដ្ឋកិច្ចក្រោយគ្រោះមហន្តរាយផងដែរ។

ង) ស្ត្រីហាក់ស្ថិតនៅក្នុងវិស័យក្រៅប្រព័ន្ធ ច្រើនមានការងារបានប្រាក់ឈ្នួលទាបនិងខ្វះសុវត្ថិភាពសង្គម៖ នៅក្នុងប្រទេសជាច្រើនស្ត្រីទទួលបាននូវការងារក្នុងប្រព័ន្ធត្រូវបានរឹតត្បិតដោយសារឧបសគ្គច្បាប់ ការអប់រំ និងបញ្ហាសង្គម។ សូម្បីតែឡូវមានតែប្រទេសចំនួន ៨ នៃប្រទេសចំនួន ១៩០ មានសិទ្ធិស្មើគ្នាចំពោះមុខច្បាប់សម្រាប់ស្ត្រីនៅក្នុងការងារ។ នៅជុំវិញពិភពលោកមានច្បាប់មួយចំនួនរារាំងដល់ឱកាសសេដ្ឋកិច្ចរបស់ស្ត្រី- មិនឱ្យធ្វើការរោងចក្រ ការងារពេលយប់ ការសុំការអនុញ្ញាតពីប្តីទៅធ្វើការ។ល។ (ធនាគារពិភពលោក ឆ្នាំ ២០២០)។ការទទួលបានការអប់រំតិចតួចរបស់ស្ត្រីនិងបន្ទុកការទទួលខុសត្រូវបន្ថែមក្នុងគ្រួសារ ការកើតកូន និងតួនាទីមើលថែទាំកូន ដែលពាក់ព័ន្ធនឹងការរើសអើងខាងយេនឌ័រ សុទ្ធតែការដាក់កម្រិតបន្ថែមទៀតមិនឱ្យទទួលបានការងារមានប្រាក់ឈ្នួលខ្ពស់ និងតួនាទីធំនោះឡើយ។ ជាសកលមានគម្លាតប្រាក់ឈ្នួលខាងយេនឌ័រ ៥០% (អត្រានៃប្រាក់ឈ្នួលសរុប និងប្រាក់ចំណូលគ្មានប្រាក់ឈ្នួលរបស់ស្ត្រី បើប្រៀបធៀបទៅនឹងបុរស) និងមាន ៣៦% ប៉ុណ្ណោះជាអ្នកគ្រប់គ្រងកម្រិតខ្ពស់នៅក្នុងវិស័យឯកជននិងមន្ត្រីរាជការនៅក្នុងវិស័យសាធារណៈជាស្ត្រី (ប្រហែល ២% ខ្ពស់ជាងតួលេខដែលបានរាយការណ៍នៅឆ្នាំមុន)(របាយការណ៍គម្លាតយេនឌ័រពិភពលោក ឆ្នាំ២០២០)។

ច) ការរើសអើងដែលមានស្រាប់នៅក្នុងសិទ្ធិទទួលបានធនធាន និងសេវាបង្កើនភាពងាយរងគ្រោះផ្អែកលើយេនឌ័រកាន់តែធ្ងន់ធ្ងរ៖ ការប្រតិបត្តិទំនៀមទម្លាប់ និងប្រពៃណីនៅក្នុងសង្គមបិតាធិបតេយ្យ នៅក្នុងតំបន់អាស៊ី គឺជាឧបសគ្គដ៏ធំដល់ស្ត្រីក្នុងការទទួលបាននូវដីធ្លីនិងធនធាន(ទឹកនិងផលិតផលព្រៃឈើ)។ ស្ត្រីខ្វះការទទួលបាននូវដីធ្លី (និងធនធានដទៃទៀតដែលមានលើដីធ្លី)ពីព្រោះពួកគេជាញឹកញាប់ជាប់ខ្សែត្រកូល ពេលគេគិតពីសិទ្ធិបន្តមរតកដើម្បីកាន់កាប់ដីធ្លី បើប្រៀបធៀបនឹងសមាជិកគ្រួសារជាបុរស។ នៅពេលគ្មានដីធ្លី (រួមមានដីស្រែចម្ការ) សុវត្ថិភាពម្ហូបអាហារក្នុងគ្រួសារ ជាពិសេសគ្រួសារដែលមានស្ត្រីជាមេគ្រួសារ នឹងរងផលប៉ះពាល់ដោយសារប្រជាជននៅតំបន់ជនបទភាគច្រើននៅតំបន់អាស៊ីជាសង្គមពឹងផ្អែកលើកសិកម្ម។ការរើសអើងខាងយេនឌ័រដែលធ្លាប់មានទាំងនេះក្នុងភាពជាម្ចាស់ ការកាន់កាប់ និងការចាត់ចែងធនធាន ជាពិសេសដីធ្លី សត្វពាហនៈ ទឹក និងព្រៃឈើ នឹងធ្វើឱ្យផលប៉ះពាល់កាន់តែធ្ងន់ធ្ងរលើរបៀបការប្រែប្រួលអាកាសធាតុប៉ះពាល់លើលក្ខណៈជីវភាពរស់នៅរបស់ស្ត្រី និងបុរស។ ឧទាហរណ៍ដកស្រង់មួយចំនួនមានបង្ហាញនៅខាងក្រោមនេះ៖

- ដោយសារមានការប្រកួតប្រជែងលើធនធានដីធ្លីដែលក្រខ្សត់ជាការពិតស្ត្រីខ្វះប័ណ្ណកម្មសិទ្ធិមានន័យថាពួកគេនឹងបាត់បង់ការគ្រប់គ្រងដី ដែលនៅសេសសល់តិចតួចដែលពួកគេធ្វើស្រែចម្ការនាពេលបច្ចុប្បន្ននេះ។
- ជាទូទៅ ស្ត្រីកាន់កាប់សត្វពាហនៈតូចៗដូចជាសត្វពពែពឹងផ្អែកលើដីវាលស្មៅសម្រាប់គង្វាលសត្វរួម ដែលនឹងក្លាយជាក្រខ្សត់ដោយសារផលប៉ះពាល់អាកាសធាតុ។ បសុបក្សី ក៏ទទួលរងផលប៉ះពាល់ដោយការស្លាប់ និងជំងឺពាក់ព័ន្ធកម្តៅ។
- ពេលទឹកក្លាយជាក្រខ្សត់ ពួកវាត្រូវបង្វែរទិសដៅសម្រាប់ការប្រើប្រាស់ឧស្សាហកម្ម និង/ឬ សម្រាប់ផលិតផលកសិកម្មផ្អែកលើសាច់ប្រាក់ដូចជាកប្បាស ការសាកវប្បកម្ម។ល។ ដែលចូលរួមចំណែកច្រើនក្នុង ផលិតផលក្នុងស្រុកសរុប

(GDP) របស់ប្រទេស។ ស្ត្រីដែលចូលរួមក្នុងការធ្វើកសិកម្មសម្រាប់បរិភោគនឹងកាន់តែបាត់បង់ដំណាំរបស់ពួកគេដោយសារកង្វះទឹក។ កង្វះប័ណ្ណកម្មសិទ្ធដីធ្លីរបស់ស្ត្រីមានន័យថា ពួកគេក៏នឹងគ្មានសំឡេងនៅក្នុងគណៈកម្មាធិការប្រព័ន្ធស្រោចស្រពដែលជាញឹកញាប់មានទំនាក់ទំនងជាមួយនឹងប័ណ្ណកម្មសិទ្ធិដីធ្លី ជាពិសេសនៅក្នុងតំបន់អាស៊ីខាងត្បូង។

- អង្គការ FAO (ឆ្នាំ២០១៥) រាយការណ៍ពីប្រជាជនពិភពលោកចំនួន ២៥%- ស្មើនឹង ១,៦ ពាន់លាននាក់ ភាគច្រើនជាសហគមន៍ជនជាតិភាគតិច ក្រុមគ្មានដីធ្លី និងស្ត្រី - ពឹងអាស្រ័យលើព្រៃឈើ និងផលិតផលព្រៃឈើសម្រាប់ជីវភាពរស់នៅរបស់ពួកគេ។ កម្មវិធីអភិរក្សដែលមានគោលបំណងការពារតំបន់ព្រៃឈើពីការបំផ្លាញព្រៃឈើ អាចធ្វើឱ្យតំបន់នេះជួបការលំបាកសម្រាប់ស្ត្រីជនជាតិភាគតិច ដើម្បីទទួលបាននូវតំបន់អភិរក្សក្នុងការប្រមូលនូវអនុផលិតផលព្រៃឈើដែលពួកគេពឹងអាស្រ័យដើម្បីផ្តល់នូវសន្តិសុខស្បៀងសម្រាប់គ្រួសាររបស់ពួកគេ។
- ស្ត្រីជាញឹកញាប់ចាប់យកការងារតាមផ្ទះ ហេតុនេះការបាត់បង់ផ្ទះសម្បែងដោយសារគ្រោះមហន្តរាយឬការផ្លាស់ទីជម្រកដោយសារកំណើននីវ៉ូទឹកសមុទ្រមានន័យថាពួកគេមិនត្រឹមតែបាត់បង់នូវកន្លែងទីជម្រករបស់ពួកគេទេ ប៉ុន្តែក៏កន្លែងធ្វើការរបស់ពួកគេផងដែរ។ លើសពីនេះទៀត វត្ថុធាតុដើម និងគ្រឿងបរិក្ខារស្តុកទុកនៅផ្ទះគឺមិនត្រូវបានរាប់គិតបញ្ចូលក្នុងការបាត់បង់ផ្នែកសេដ្ឋកិច្ចដោយសារគ្រោះមហន្តរាយ ដែលមានន័យថាពួកគេត្រូវអត់ទ្រាំជាបន្ទុកនៃការបាត់បង់ទាំងនេះ។
- កំណើនកម្តៅក៏នឹងធ្វើឱ្យមានផលប៉ះពាល់ខ្លាំងលើជីវភាពរស់ផ្អែកលើការងារតាមផ្ទះរបស់ស្ត្រី។ ស្ត្រីក្រីក្រជាទូទៅរស់នៅក្នុងផ្ទះតូច ជាញឹកញាប់ធ្វើពីវត្ថុធាតុដើមកាន់កម្តៅ ដូចជាបន្ទះហ្វីប្រូដែលមានការបញ្ចេញបញ្ចូលខ្យល់តិចតួច ឬគ្មានជាពិសេសនៅក្នុងសំណង់អាណាធិបតេយ្យនៅប្រទេសឥណ្ឌា និង ប្រទេសបង់ក្លាដេស។ ដោយសារកម្តៅថ្ងៃកើនឡើង សីតុណ្ហភាពក្នុងបន្ទប់ទាំងនេះកើនឡើងច្រើនដងបណ្តាលឱ្យកាត់បន្ថយនូវផលិតភាពរបស់ស្ត្រីស្មើនឹង ៣០% (Mahila Housing SEWA Trust ឆ្នាំ២០១៥)។

កង្វះការទទួលបាននូវឥណទាន សេវាផ្សព្វផ្សាយ និងការផ្លាស់ទីមានកម្រិត ដោយសារការទទួលខុសត្រូវក្នុងគ្រួសារ ធ្វើឲ្យស្ត្រីក្រីក្រកាន់តែងាយរងគ្រោះទៅនឹងភាពរាំងស្ងួត ទឹកជំនន់ និងការបាត់បង់ធនធានធម្មជាតិដោយសារការប្រែប្រួលអាកាសធាតុ។ ជាងនេះទៀតជាញឹកញាប់ផលិតកម្មរបស់ស្ត្រីមិនឃើញមានក្នុងស្ថិតិជាតិនិងក្នុងដំណើរការរៀបចំផែនការគោលនយោបាយនោះឡើយ។ ដោយសារការប្រែប្រួលអាកាសធាតុទាក់ទងនឹងការប្រែប្រួលក្នុងលក្ខណៈនៃផលិតកម្ម និងជម្រើសនៃជីវភាពរស់នៅ ស្ត្រីដែលគ្រប់គ្រងលើធនធានតិចតួចនិងចូលរួមតិចតួចក្នុងការរៀបចំគោលនយោបាយនឹងកាន់តែងាយរងគ្រោះ។ ជាមួយគ្នាដែរ ស្ត្រីដែលរកបានប្រាក់ឈ្នួលតិចជាងបុរសធ្វើឱ្យពួកគេកាន់តែងាយរងគ្រោះទៅនឹងការប្រែប្រួលនៅក្នុងបរិស្ថានកន្លែងការងារដោយសារកត្តាខាងក្រៅផ្សេងៗ។ ចំណុចដូចគ្នានេះក៏អនុវត្តចំពោះការប្រែប្រួលអាកាសធាតុផងដែរ។

បន្ថែមលើបញ្ហានានា គឺការធ្វើសេចក្តីសម្រេច ព្រោះនៅកម្រិតគ្រួសារជាញឹកញាប់គ្រប់គ្រងដោយបុរស។ ស្ត្រីជាញឹកញាប់ត្រូវផាត់ចេញពិការសម្រេចចិត្តសំខាន់ៗ ដូចជាការលក់ដូរដីធ្លី ផ្ទះសម្បែងនិងទ្រព្យសម្បត្តិដទៃទៀតដែលមានផលប៉ះពាល់សំខាន់លើកម្មសិទ្ធិទ្រព្យសម្បត្តិទាំងមូលរបស់ពួកគេ។ បញ្ហាធនធានអចលនៈទ្រព្យសំខាន់ជាពិសេសសិទ្ធិកាន់កាប់ដីធ្លីនិងផ្ទះសម្បែងត្រូវបានយកទៅក្នុងការពិភាក្សាអាកាសធាតុ Sultana (ឆ្នាំ២០១៤) ដោយសារវាមានផលប៉ះពាល់ខ្លាំងលើភាពងាយរងគ្រោះរបស់ស្ត្រី។ ម្យ៉ាងទៀតកង្វះការយល់ដឹងនៃវិសាលភាពយេនឌ័រអាចរារាំងដល់ការបែងចែកដោយសមធម៌នៃជំនួយការស្តារឡើងវិញ។ឧទាហរណ៍ កម្មវិធីការផ្តល់សិទ្ធិមានទម្លាប់ឱ្យតម្លៃបុរសជាងស្ត្រី អ្នកកាន់កាប់សំណៅឯកសារ អ្នកកាន់កាប់គណនីធនាគារ និងការយល់ឃើញអ្នកដឹកនាំគ្រួសារ។

## ភាពចម្រុះប្រសព្វខាងយេនឌ័រ និង CCDRR

គ្រោះមហន្តរាយនិងយេនឌ័របុរសៈមិនត្រឹមតែស្ត្រីទេដែលរងផលប៉ះពាល់ដែលមិនស្មើគ្នាដោយសារតួនាទីយេនឌ័រ។ ការរំពឹងទុកខាងវប្បធម៌នៃហានិភ័យបុរស ជាញឹកញាប់មានឥរិយាបថធ្វើឱ្យបុរស និងក្មេងប្រុសស្ថិតនៅក្នុងហានិភ័យធ្ងន់ធ្ងរនៃការស្លាប់ និងរបួសអំឡុងពេលគ្រោះមហន្តរាយពាក់ព័ន្ធនឹងអាកាសធាតុ។ នៅប្រទេសវៀតណាមភស្តុតាងខ្លីៗផ្តល់ពីបុរសត្រូវសម្លាប់ដោយសារការបំបែកចេញតាមការងារ-ឧទាហរណ៍ជាអ្នកនេសាទ។ បុរសក៏មិនត្រូវគេអើពើ ប្រាប់ការជម្លៀសច្រើនជាងស្ត្រី។ ការធ្លាក់ចុះសុវត្ថិភាពម្ហូបអាហារ និងឱកាសជីវភាពរស់នៅក៏អាចបណ្តាលស្ត្រេសខ្លាំងសម្រាប់បុរស និងក្មេងប្រុសដែរ ជាមួយនឹងការរំពឹងទុកដែលកំណត់ដោយសង្គមលើពួកបុរសនឹងផ្តល់នូវសេដ្ឋកិច្ចសម្រាប់គ្រួសារ។ បន្ថែមពីលើនេះទៀត ការពិតគឺបុរសអាចពិបាកស្វែងរកជំនួយសម្រាប់បញ្ហាសុខភាពស្ត្រេស និងសុខភាពផ្លូវចិត្តជាងស្ត្រី និងក្មេងស្រី (Masika ឆ្នាំ២០០២) ដែលអាចជាបញ្ហាធ្ងន់ធ្ងរសម្រាប់ពួកគេ។ បែបនេះបង្ហាញពីរបៀបដែលបុរសមានទុកព្រួយរហូតដល់ចំណុចចង់សម្លាប់ខ្លួននៅប្រទេសឥណ្ឌាដោយសារការបាត់បង់ខាងកសិកម្មបណ្តាលឱ្យអលទ្ធភាព ដើម្បីបង់បំណុល (Keneddy និង King ឆ្នាំ២០១៤)។ បុរសក៏មានតម្រូវការជាក់លាក់ដូចជាភាពស្ត្រេសការប្រឹក្សាជាតិអាល់កុលឬការអភិវឌ្ឍជំនាញពាក់ព័ន្ធនឹងការក្លាយជាឪពុកម្តាយទោលក្រោយគ្រោះមហន្តរាយ។ ចំណុចទាំងអស់នេះពាក់ព័ន្ធលក្ខណៈធម្មជាតិនៃយេនឌ័រ និងតម្រូវការការវិភាគយេនឌ័រនៅក្នុង CCDRR។

**កង្វល់ក្រុម LGBTIQ និងសុខទាពះ** វិបិត្តកូវីដ-១៩ថ្មីៗ នេះមានផលប៉ះពាល់សុខភាពមនុស្សរាប់លាននាក់ពាសពេញពិភពលោក។ ទោះបីយ៉ាងណាផលប៉ះពាល់ទាំងនេះហាក់មានកម្រិតខ្ពស់សម្រាប់ប្រជាជនងាយរងគ្រោះបំផុតមួយចំនួន ជាពិសេស ក្រុម LGBTIQ (ប្លុករបស់ធនាគារពិភពលោក WB Blog ឆ្នាំ២០២០)។ វិសមភាពលើសកម្រិតដែលពួកគេធ្លាប់មានហាក់ក្លាយទៅជាកាន់តែអាក្រក់ដោយសារវិបត្តិជំងឺឆ្លងសកលធ្វើឱ្យកាន់តែមានភាពលំបាកសម្រាប់ក្រុមទាំងនេះ ដើម្បីទទួលបាននូវសេវាសំខាន់ៗ-រួមមានកិច្ចគាំពារសុខភាព និងសង្គម។ នៅពេលដែលទិន្នន័យកម្រិតពិភពលោកឬតំបន់អាស៊ី មានសារសំខាន់ខ្លាំងក្នុងការស្វែងយល់ឱ្យកាន់តែច្បាស់នូវផលប៉ះពាល់អវិជ្ជមានដែលមានសក្តានុពលនៃការរីករាលដាលជំងឺកូវីដ-១៩ លើអនីតិភាពផ្លូវភេទ និងយេនឌ័រមិនទាន់មាននៅឡើយ។ ទិន្នន័យពី Western Balkans របាយការណ៍ដោយធនាគារពិភពលោកបង្ហាញថា១២ភាគរយនៃការស្ទាប់ស្ទង់មតិក្រុម LGBTIQមិនបានទទួលការព្យាបាលវេជ្ជសាស្ត្រចាំបាច់ដោយសារតែការភ័យខ្លាចនៃការរើសអើងដោយអ្នកផ្តល់វេជ្ជសាស្ត្រ។ នៅប្រទេសស៊ែប៊ី ការស្រាវជ្រាវមុនៗរបស់ធនាគារពិភពលោក (ឆ្នាំ២០១៩) ក៏រកឃើញតែមួយភាគបីនៃអ្នកឆ្លើយតបក្រុម LGBTIQ បានធ្វើការប៉ាន់ប្រម៉ាន សុខភាពរបស់ពួកគេ «ល្អណាស់» បើប្រៀបធៀបទៅនឹងចំនួន៥៥ភាគរយនៃចំនួនប្រជាជនទូទៅ។ជាថ្មីម្តងទៀតក្រុមមនុស្សកែភេទភ័យខ្លាចសុខភាពកាន់តែអាក្រក់ខ្លាំងតែ១៨ភាគរយប៉ុណ្ណោះធ្វើការប៉ាន់ប្រម៉ានសុខភាពខ្លួនរបស់ពួកគេ «ល្អណាស់»។ ការធ្វើការប៉ាន់ប្រម៉ានសុខភាពខ្លួនឯងម្នាក់ៗដូចជាអាក្រក់ និងអាក្រក់ខ្លាំងកើនឡើងជាលំដាប់ក្នុងចំណោមក្រុមLGBTIQដែលត្រូវជកហូតសម្ភារ (១១ភាគរយ) ជកហូតសម្ភារធ្ងន់ធ្ងរ (១៤ភាគរយ) និងជកហូតសម្ភារធ្ងន់ធ្ងរបំផុត (២០ភាគរយ) បើប្រៀបធៀបនឹងសំណាក LGBTIQ ទាំងមូលស្មើនឹង ៥ភាគរយ។ វាមានសារសំខាន់ដើម្បីវិភាគនិន្នាការស្រដៀងគ្នានៅក្នុងបិរបទមូលដ្ឋាន ដោយសារហានិភ័យសុខភាពជាមួយការប្រែប្រួលអាកាសធាតុពឹងថាកើនឡើងនៅទសវត្សរ៍បន្ទាប់ លុះត្រាសកម្មភាពត្រូវចាត់ចែងដើម្បីលុបបំបាត់ការរើសអើងយេនឌ័រ និងធ្វើឱ្យប្រសើរឡើងនូវវិធីឃាបថស្វែងរកសុខភាពនៃសហគមន៍LGBTIQផលប៉ះពាល់សុខភាពនៃការប្រែប្រួលអាកាសធាតុលើសហគមន៍ទាំងនេះនឹងកាន់តែមានកម្រិតខ្ពស់ដែលមិនអាចស្មើគ្នា។

**ការប្រែប្រួលអាកាសធាតុ និងមនុស្សចាស់៖** ជាញឹកញាប់ មនុស្សចាស់ត្រូវបានលើកឡើងជាក្រុមមួយស្ថិតនៅក្នុងហានិភ័យណាស់អំឡុងពេលរលកកម្តៅដូចមានបង្ហាញកាលរលកកម្តៅឆ្នាំ២០០៣ នៅអឺរ៉ុប ក៏ដូចគ្នានឹងគ្រោះ មហន្តរាយពាក់ព័ន្ធនឹងអាកាសធាតុ (Kuzuya ឆ្នាំ២០១៣)។ទោះបីជាយ៉ាងណាជាញឹកញាប់ពួកគេមិនមានវត្តមាននៅក្នុងផែនការកាបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុដូចក្រុមគោលដៅជាក់លាក់ទេ។ស្ត្រីវ័យចំណាស់ងាយរងគ្រោះណាស់ជាពិសេសនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ដែលធនធានខ្វះខាត និងសំណាញ់សុវត្ថិភាពសង្គមមានកម្រិត ឬមិនមាន។ ស្ត្រីវ័យចំណាស់ក៏មានការទទួលខុសត្រូវគ្រួសារខ្លាំង និងការថែទាំដែលបណ្តាលឱ្យស្ត្រេសនិងការអស់កម្លាំងពលំខណៈដែលមានការទប់ស្កាត់ការចូលរួមសង្គម និងសេដ្ឋកិច្ចដោយទូលំទូលាយផងដែរ និងប្រាក់ចំណូលរបស់ពួកគេអាចមានកម្រិតទាប ពីព្រោះពួកគេមិនអាចទទួលបានការងារមានប្រាក់ឈ្នួលទៀតទេ។ពួកគេក៏មិនយល់ពីសិទ្ធិរបស់ពួកគេដើម្បីទទួលបាននូវសេវាពីសហគមន៍ និងវិស័យឯកជនដូចជាគ្លីនិកនៅតាមមូលដ្ឋាន។ទោះបីជាពួកគេយល់ដឹងពីសេវាទាំងនេះ ប៉ុន្តែពួកគេមិនអាចលៃលកទៅកគ្លីនិក និងទិញឱសថតាមចំនួនដូចមានវាយនាមនោះឡើយ។ការទទួលនូវសេវាបានរឹតបណ្តឹងបន្ថែមសម្រាប់ស្ត្រីវ័យចំណាស់រស់នៅតាមតំបន់ជនបទដែលជាញឹកញាប់មិនអាចធ្វើដំណើរផ្លូវឆ្ងាយទៅមន្ទីរពេទ្យដែលជិតបំផុត (អង្គការ WHO ឆ្នាំ២០១០)។ បុរសវ័យចំណាស់ក៏មានផលវិបាកសំខាន់ដោយនិន្នាការរបស់ពួកគេដែលមានបណ្តាញសង្គមតិចជាងស្ត្រី ហើយដូច្នេះពួកគេមិនអាចស្វែងរកជំនួយពីក្នុងសហគមន៍បាន ពេលពួកគេត្រូវការវា (អង្គការ WHO ឆ្នាំ២០១០)។

## វិសមភាពយេនឌ័រកាន់តែរីកធំដោយសារការប្រែប្រួលអាកាសធាតុ

សមភាពយេនឌ័រ គឺជាសិទ្ធិមនុស្ស និងជាគោលបំណងអភិវឌ្ឍន៍សំខាន់មួយនៅក្នុងផ្នែកយេនឌ័រ។ ក្នុងរយៈពេលជាច្រើនទសវត្សរ៍ចុងក្រោយនេះ តួអង្គជាច្រើនរួមមានអង្គការសហប្រជាជាតិ និងអង្គការអន្តរជាតិដទៃទៀត រដ្ឋាភិបាលជាតិ និងមូលដ្ឋាន ក៏ដូចគ្នានឹងអង្គការសង្គមស៊ីវិលបានបន្តនូវរបៀបវារៈនៃសមភាពយេនឌ័រ។ បើទោះបីនៅមានផ្លូវវែងឆ្ងាយដែលត្រូវទៅសម្រេចបានតាមគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ទី៥ ពិតប្រាកដនៅឆ្នាំ២០៣០ ពិភពលោកបានឈានទៅមុខយ៉ាងខ្លាំងលើភាពស្មើគ្នានៃយេនឌ័របន្ទាប់ពីកន្លែងដែលវាមាននៅពីរបីទសវត្សរ៍កន្លងមកនេះ។

ការសិក្សាជាច្រើន (របាយការណ៍សង្គមពិភពលោក ឆ្នាំ២០២០, កម្មវិធីអង្គការសហប្រជាជាតិ ឆ្នាំ២០១៩, សម្ព័ន្ធយេនឌ័រនិងអាកាសធាតុសកល ឆ្នាំ២០១៦) បង្ហាញថា ការប្រែប្រួលអាកាសធាតុពិតជាទាញត្រឡប់ក្រោយនូវវឌ្ឍនភាពដែលបានធ្វើដំណើរឆ្ពោះទៅរកការសម្រេចបាននូវសមភាពយេនឌ័រក្នុងរយៈពេលជាច្រើនឆ្នាំនេះ និងអាចកើតឡើងដោយសារហេតុផលខាងក្រោមនេះ៖

ក) ជាទូទៅមនុស្សទាំងអស់នឹងកាន់តែមានហានិភ័យខ្ពស់ហើយស្ត្រីមានធនធានតិចតួចនិងជម្រើសអន់ថយនឹងមានអារម្មណ៍កាន់តែទទួលរងផលប៉ះពាល់។

ខ) ផលប៉ះពាល់ជាពិសេសលើធនធានធម្មជាតិ- ដីធ្លី ទឹក ម្ហូបអាហារ ថាមពល សុខភាព ការជះឥទ្ធិពលលើការប្រើប្រាស់ពេលវេលារបស់ស្ត្រី និងក្មេងស្រី និងលក្ខណៈនៃជីវភាពរស់នៅ។ ឧទាហរណ៍ ស្ត្រី និងក្មេងស្រីអាចចំណាយពេលវេលាច្រើនក្នុងការស្វែងរកទឹកការមើលថែទាំអ្នកជំងឺនិងអ្នករបួស

និង/ឬ ជ្រើសរើសការងារសំណង់បន្ទាប់ពីគ្រោះមហន្តរាយ។

គ) កំណើនបន្ទុកការងារមានន័យថាស្ត្រីមានពេលវេលាតិចតួចសម្រាប់សកម្មភាពបង្កើតប្រាក់ចំណូលជាពិសេសការងារពេញម៉ោង ដែលផ្តល់នូវសន្តិសុខសង្គមដ៏ធំ (Bradshaw និង Linnekar, ការផ្លាស់ប្តូរយេនឌ័រ និងការប្រែប្រួលបរិស្ថានក្នុងពិភពលោកដែលកំពុងអភិវឌ្ឍ ឆ្នាំ២០១៤)។

ឃ) កំណើនបន្ទុកការងារសម្រាប់ក្មេងស្រីក៏អាចបង្ខំពួកគេឱ្យបោះបង់ការសិក្សាដើម្បីជួយកិច្ចការផ្ទះសម្បែងហេតុដូចនេះការលុបបំបាត់ភាពស្មើគ្នានៃយេនឌ័រទទួលបាននូវការអប់រំបានធ្វើក្នុងរយៈពេលជាច្រើនទសវត្សរ៍ (Davis et al ឆ្នាំ២០០៥ ដែលយោងពី (អង្គការ UNDP ឆ្នាំ២០០៩)។ វានឹងបង្កើនគម្លាតកាន់តែធំនៅក្នុងឱកាសការងារសម្រាប់ក្មេងស្រីបើប្រៀបធៀបនឹងក្មេងប្រុស។

ង) ជីវភាពរស់នៅ រឹងដោយមានការរំខាននៅក្នុងរបៀបបទដ្ឋានសង្គម និងបណ្តាញផ្សេងៗ ដែលធ្វើឲ្យ ការរឹងទុកនៃតួនាទីយេនឌ័រដែលមានលក្ខណៈប្រពៃណីនឹងកើតឡើងជាថ្មី។ ឧទាហរណ៍បន្ទាប់ពីទឹកជំនន់ឆ្នាំ២០១៥នៅប្រទេសមីយ៉ាន់ម៉ាស្ត្រីនៅតំបន់ជនបទដែលពឹងផ្អែកលើពលកម្មកសិកម្មសម្រាប់ប្រាក់ចំណូល ដោយមិនមានសល់នូវជម្រើសជីវភាពរស់នៅផ្សេងឡើយ ខណៈដែរបុរសផ្លាស់ទីទៅរកការងារនៅកន្លែងផ្សេង (អង្គការ UN Women ឆ្នាំ២០១៦)។

ច) ការធ្លាក់ចុះនូវអំណាចការអប់រំនិងសេដ្ឋកិច្ចពាក់ព័ន្ធនឹងកំណើនស្ត្រេសផ្នែកសេដ្ឋកិច្ចក្នុងចំណោមបុរសដែលជាអ្នករកប្រាក់ចំណូលចម្បងកាន់តែមានលំបាកក្រោយគ្រោះមហន្តរាយដែលអាចបង្កើនអំពើហិង្សាក្នុងគ្រួសារបន្ថែម (Masson et al ឆ្នាំ២០១៦)។

ឆ) ប្រវាំឡង់ទម្រង់ផ្សេងទៀតនៃអំពើហិង្សាទាក់ទងនឹងយេនឌ័រដូចជាការជួញដូរមនុស្ស និងអាពាហ៍ពិពាហ៍វ័យក្មេងក៏រីកធំដែរការលុបបំបាត់នូវបញ្ហានេះគឺជាចំណុចសារសំខាន់ដើម្បីសម្រេចនូវគោលដៅអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពចំណុចទី៥។ ឧទាហរណ៍ នៅប្រទេសបង់ក្លាដេស អង្គការឃ្លាំមើលសិទ្ធិមនុស្ស (Human Rights Watch) រកឃើញគ្រោះមហន្តរាយជាកត្តាមួយនៃកត្តាចំនួនប្រាំបីផ្សេងទៀតដែលចូលរួមចំណែកដល់ការរៀបអាពាហ៍ពិពាហ៍ទាំងវ័យក្មេងនេះ (IFRC ឆ្នាំ២០១៥, Mian និង Namasivayam ឆ្នាំ២០១៧)។

ជ) ការសិក្សានានាក៏បង្ហាញពីកំណើនហានិភ័យនៃអំពើហិង្សាផ្លូវភេទសម្រាប់ក្មេងស្រីវ័យក្មេង ស្ត្រី និងអ្នកទាំងឡាយណាជាមួយនឹងអត្តសញ្ញាណយេនឌ័រ ជាពិសេសនៅក្រោយគ្រោះមហន្តរាយ (Swarup និងផ្សេងទៀង ឆ្នាំ២០១១, Mian និង Namasivayam ឆ្នាំ២០១៧)។

ឈ) ក៏មានហានិភ័យដែលសកម្មភាពសម្រាប់ការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុនិងការគ្រប់គ្រងគ្រោះមហន្តរាយនាំឱ្យមានការបែងចែកធនធានថវិការដ្ឋាភិបាលពីសេវាសុខភាពអប់រំនិងសេវាសង្គមផ្សេងៗដែលអាចមាននិន្នាការកើនឡើងការរើសអើងយេនឌ័រនៅក្នុងប្រទេស(អង្គការUNFPAនិងអង្គការ WEDO ឆ្នាំ២០០៩)។

ទោះបីជាកង្វល់ដ៏ធ្ងន់ធ្ងរគឺថាសកម្មភាពទាំងនេះនឹងមិនអាចដំណើរការដោច់ដោយឡែកឡើយប៉ុន្តែអាចមានលទ្ធផលធ្លាក់ចុះនិងអាចនាំឱ្យមានវដ្តនៃវិសមភាពយេនឌ័រវិលចុះឡើង។

## វិសមភាពយេនឌ័រនៅក្នុងសមត្ថភាពសម្រាប់CCDRR&RB

មិនមែនតែការប្រែប្រួលអាកាសធាតុប៉ះពាល់លើបុរស និងស្ត្រីខុសគ្នា ប៉ុន្តែអំណាចទាក់ទងនឹងភាពខុសយេនឌ័រ តួនាទី និងការទទួលខុសត្រូវរបស់ពួកគេ ក៏ប៉ះពាល់ដល់សមត្ថភាពបន្សាំ និងភាពធន់របស់ពួកគាត់ដែរ។ ដូច្នេះ ស្ត្រី និងបុរសបង្ហាញវិធីសាស្ត្រខុសៗគ្នាក្នុងការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ។ ឧទាហរណ៍ ស្ត្រីត្រូវបានទទួលស្គាល់ថាមានការទទួលហានិភ័យខ្ពស់ពីគ្រោះមហន្តរាយ បើប្រៀបធៀបនឹងបុរស និងមាននិន្នាការយកចិត្តទុកដាក់នឹងប្រព័ន្ធប្រកាសជម្លៀសក្នុងគ្រាមានអាសន្ន និងចែករំលែកសុសសាយព័ត៌មានច្រើនជាងដែរ (អង្គការ UNDP និងអង្គការ UN Women ឆ្នាំ២០១៨)។

ស្ត្រីក៏ច្បាស់លាស់ពីតម្រូវការ និងអាទិភាពរបស់ពួក ផ្អែកលើចំណេះដឹងដែលជាទម្លាប់ ហើយបានចាប់ផ្តើមចាត់វិធានការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ។ Mitchell et al (ឆ្នាំ២០០៧) រាយការណ៍ពីរបៀបស្ត្រីមកពីសហគមន៍ជនបទនៅអាងទន្លេGangaនៅក្នុងប្រទេសបង់ក្លាដេស ឥណ្ឌា និងប្រទេសនេប៉ាល់ បានផ្លាស់ប្តូរការធ្វើកសិកម្មពូជធន់នឹងទឹកជំនន់ និងភាពរាំងស្ងួត ឬដាំដំណាំដែលអាចប្រមូលផលបានមុនរដូវទឹកជំនន់ឬប្រភេទស្រូវចម្រុះពូជដែលនឹងលូតលាស់កម្ពស់គ្រប់គ្រាន់នៅលើទឹកពេលទឹកជំនន់មកដល់។ នៅតំបន់ប្រឈមនឹងទឹកជំនន់នៅប្រទេសបង់ក្លាដេសស្ត្រីរៀបចំធ្វើលើកឡើងឱ្យខ្ពស់សម្រាប់សមាជិកគ្រួសារដែលពិការភាព ដោយប្រើ chouki (គ្រែបុរាណ) និងឬស្សី។ពួកគេក៏មានបម្រុងទុកនូវឥន្ធនៈឈើគូស អាហារក្រៀម (ដូចជាអង្ករ សណ្តែកក្រាម អង្ករបំពង អំបុក និងប្រេង) ខ្សែពួរ និងថ្នាំនៅផ្ទះសម្បែង និងរៀបចំចង្ក្រានដីដែលអាចយួរបានសម្រាប់ប្រើនាពេលអនាគត។ជាញឹកញាប់ស្ត្រីកអុសស្តុកទុកនៅកន្លែងស្ងួតសម្រាប់ប្រើប្រាស់ពេលក្រោយ។

ការពិតនៅតែមាន តាមរយៈវិសមភាពយេនឌ័រលើសកម្រិតដែលធ្លាប់មាន និងឋានៈសង្គមទាបរបស់ស្ត្រីនៅក្នុងស្ថានភាពជាច្រើន បានដាក់កម្រិតសមត្ថភាពរបស់ពួកគេដើម្បីឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ។ស្ត្រីជាពិសេសស្ត្រីក្រីក្រដែលទទួលបាននូវការអប់រំ និងព័ត៌មានមិនគ្រប់គ្រាន់ កម្មសិទ្ធិនិងការគ្រប់គ្រង

លើធនធានធម្មជាតិមានកម្រិត ដីធ្លីនិងហិរញ្ញវត្ថុ និងការរឹតត្បឹតការចូលរួមនៅក្នុងដំណើរការរដ្ឋាភិបាល និងការធ្វើសេចក្ដីសម្រេចកាន់តែរាំងដល់សមត្ថភាពរបស់ពួកគេដើម្បីបន្សុំាទៅនឹងការប្រែប្រួលអាកាសធាតុ។

**ចំណុចពិភាក្សា**

សូមសួរអ្នកចូលរួមឲ្យលើកឡើងពីឧទាហរណ៍ពីតួនាទីសង្គមរបស់ស្ត្រី និងវិសមភាពយេនឌ័រដែលធ្លាប់មាននៅក្នុងតំបន់របស់គេរាំងដល់សមត្ថភាពបន្សុំារបស់ស្ត្រី?

**តម្រុយសម្រាប់អ្នកសម្របសម្រួល**

> ស្ត្រី និងក្មេងស្រីជាញឹកញាប់ត្រូវបានរឹតត្បឹតពីការចូលរួមជាមួយគណៈកម្មាធិការមូលដ្ឋានការគ្រប់គ្រងគ្រោះមហន្តរាយ ឬ ការបន្សុំាការប្រែប្រួលអាកាសធាតុក្នុងតំបន់។ ទោះបីពេល មិនមានរឹតត្បឹត ពួកគេជាញឹកញាប់មិនអាចចូលរួមដោយសារបញ្ហាពេលវេលា។

> ស្ត្រីដែលខ្វះកម្មសិទ្ធិដីធ្លីជាញឹកញាប់ធ្វើឱ្យពួកគេមិនអាចធ្វើសេចក្ដីសម្រេចចិត្តពាក់ព័ន្ធនឹងគំរូដំណាំទោះបីជាពួកគេចង់ក៏ដោយ។ សេចក្ដីសង្ខេបមួយរបស់ FAO ស្ដីពីវិធីសាស្ត្រឆ្លើយតបយេនឌ័រទៅនឹងអាកាសធាតុកសិកម្មឆ្លាតវៃ (Nelson និង Hyyer ឆ្នាំ២០១៦) រាយការណ៍ថា នៅប្រទេសកេនយ៉ា ការជ្រើសរើសពូជធន់នឹងភាពរាំងស្ងួតរហ័សបំផុតស្ថិតនៅក្នុងចំណោមស្ត្រីដែលប្ដីទៅឆ្ងាយ និងមិនធ្វើសេចក្ដីសម្រេចពីមួយថ្ងៃទៅមួយថ្ងៃ។

> ស្ត្រីចូលរួមធ្វើការធ្វើសេចក្ដីសម្រេចតិចតួចនិងមានឥទ្ធិពលតិចជាងបុរសក្នុងដំណើរការកសាងគោលនយោបាយ និងការធ្វើអាទិភាពហិរញ្ញវត្ថុអាកាសធាតុថាប្រើយ៉ាងដូចម្ដេច។ ដោយសារតម្រូវការសម្រាប់សកម្មភាពការកាត់បន្ថយនិងការបន្សុំាការប្រែប្រួលអាកាសធាតុរីកលូតលាស់ ការបែងចែកពាក់ព័ន្ធនឹងហិរញ្ញវត្ថុនឹងកើនឡើង-ដោយគម្លាតដែលមានឥទ្ធិពលនៅក្នុងការទទួលបាន និងការគ្រប់គ្រងលើធនធានរវាងបុរសនិងស្ត្រីក្រោមប្រព័ន្ធនិងយន្តការដែលត្រូវអនុវត្តន៍វានឹងបង្កើនការរារាំងដល់សមត្ថភាពបន្សុំារបស់ស្ត្រី។

## ការធ្វើសមាហរណកម្មយេនឌ័រនៅក្នុង CCDRR & RB

**តម្រូវការធ្វើសមាហរណកម្មយេនឌ័រទៅក្នុងគោលនយោបាយប្រែប្រួលអាកាសធាតុ និងកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ(CCDRR)**

គោលនយោបាយ និងវិធានការទាំងអស់ ជះឥទ្ធិពលលើស្ត្រី និងបុរសផ្សេងៗគ្នា ដែលហេតុដូច្នេះហើយបានជាការអនុវត្តការវិភាគយេនឌ័រ និងការរួមបញ្ចូលវិសាលភាពយេនឌ័រទៅក្នុងការរៀបចំផែនការគោលនយោបាយមានសារៈសំខាន់។ សមាហរណកម្មយេនឌ័រជួយស្វែងរកមធ្យោបាយនានាដើម្បីកាត់បន្ថយហានិភ័យដែល អាចធ្វើឱ្យវិសមភាពយេនឌ័រកាន់តែធ្ងន់ធ្ងរឡើង និងរំលេចឱកាសដើម្បីពង្រឹងលទ្ធផលវិជ្ជមាន។ នៅក្នុងបរិបទនៃការកាត់បន្ថយការប្រែប្រួលអាកាសធាតុនិងហានិភ័យគ្រោះមហន្តរាយនេះមានភាពជំពាក់ជំពិនច្រើន។

សមភាពយេនឌ័រគឺជាបញ្ហាសិទ្ធិមនុស្ស និងគោលដៅអភិវឌ្ឍមួយនៅក្នុងខ្លួនឯងផ្ទាល់។ ការប្រែប្រួលអាកាសធាតុនឹងមិនត្រឹមតែបង្កឱ្យមានវិសមភាពយេនឌ័រប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបង្កើនអំពើហិង្សាលើស្ត្រី អាពាហ៍ពិពាហ៍កុមារ និងការជួញដូរកុមារទៀតផងដែលទាំងអស់នេះសុទ្ធតែជាបទល្មើសធ្ងន់ធ្ងរប្រឆាំងនឹងសិទ្ធិមនុស្ស (អង្គការសហប្រជាជាតិដើម្បីស្ត្រី ឆ្នាំ២០១៦)។ វិធីសាស្ត្រផ្អែកលើសិទ្ធិមនុស្សជាមូលដ្ឋាន (HRBA) តម្រូវឱ្យមានការការពារសិទ្ធិទាំងនេះស្ថិតនៅចំណុចកណ្ដាលចំពោះកម្មវិធីអភិវឌ្ឍន៍ការបន្សុំា ការកាត់បន្ថយហានិភ័យ និងការកសាងភាពធន់។

លើសពីនេះទៀត ការមិនយកស្ត្រី និងក្រុម LGBTIQ មកពិចារណារួមជាមួយបុរសនៅក្នុងគោលនយោបាយ CCDRR នឹងមានន័យថាជាការមិនអើពើនឹងផ្នែកដ៏ធំមួយនៃប្រជាជនដែលយើងព្យាយាមធ្វើឱ្យសុខុមាលភាពរបស់ពួកគេមានភាពប្រសើរឡើង។ ការណ៍នេះនឹងក្លាយជាការរំលោភវិធីសាស្ត្រមិនមានអ្នកណាម្នាក់ត្រូវបានទុកចោល (LNOB) ដែលប្រទេសជាច្រើនបានឯកភាពគ្នាថាជាផ្នែកមួយនៃរបៀបវារៈអភិវឌ្ឍន៍ប្រកបដោយចីរភាពឆ្នាំ២០៣០។ ស្ត្រីនិងកុមារី ដែលនៅតែស្ថិតក្នុងចំណោមក្រុមដែលជួបការលំបាកនៅក្នុងសង្គម និងងាយរងគ្រោះពិសេសទៅនឹងការប្រែប្រួលអាកាសធាតុ និងហានិភ័យគ្រោះមហន្តរាយនាពេលបច្ចុប្បន្ននិងអនាគតចាំបាច់ត្រូវតែជាទិសដៅសំខាន់នៃវិធីសាស្ត្រ LNOB នៅពេលដែលអនុវត្តចំពោះ CCDRR។ ការអនុវត្តទស្សនវិស័យយេនឌ័រចំពោះ CCDRR អាចសម្រេចបានលទ្ធផលដែលចង់បាននៅក្នុងបរិបទទាំងនេះ។

ឧទាហរណ៍ នៅពេលដែលព្យុះស៊ីក្លូន Sidr វាយប្រហារប្រទេសបង់ក្លាដែសក្នុងឆ្នាំ២០០៧មិនត្រឹមតែប្រជាជនបានបាត់បង់ជីវិតប្រហែល៣.០០០នាក់ប៉ុណ្ណោះទេប៉ុន្តែថែមទាំងមានការធ្លាក់ចុះគម្លាតយេនឌ័រក្នុងអត្រាមរណភាពដល់ ៥៖១ ថែមទៀតផង។ កត្តានេះអាចកើតមានដូចទៅនឹងចន្លោះឆ្នាំ១៩៩១ (នៅពេលព្យុះស៊ីក្លូន Gorky បានសម្លាប់មនុស្សរាប់ពាន់នាក់) និងឆ្នាំ២០០៧

ជាពេលដែលប្រទេសបង់ក្លាដែសបានបោះជំហានទៅមុខយ៉ាងខ្លាំងក្នុងការតាមដានគ្រោះថ្នាក់ភាពត្រៀមបង្ការរបស់សហគមន៍ និងកិច្ចប្រឹងប្រឹងឆ្លើយតបសមាហរណកម្ម ក៏ដូចជាការផ្តោតទៅលើការដោះស្រាយជាពិសេសនូវមូលហេតុវប្បធម៌ ដែលស្ត្រីមានភាពស្ទាក់ស្ទើរក្នុងការប្រើប្រាស់ទីជម្រកការពារពីព្យុះស៊ីក្លូន រួមទាំងការ យកចិត្តទុកដាក់ពិសេសដល់ការចូលរួម របស់ស្ត្រីទៅក្នុងកិច្ចប្រឹងប្រែងទាំងនេះ ជា អ្នកកៀរគរសហគមន៍ និង បង្កើតទីកន្លែងសម្រាប់តែស្ត្រីនៅក្នុងទីជម្រកការពារពីព្យុះស៊ីក្លូន។

ការអនុវត្តទស្សនវិស័យយេនឌ័រមិនមែនជាសកម្មភាពសប្បុរសធម៌សម្រាប់ស្ត្រីនោះទេ ប៉ុន្តែដូចរបាយការណ៍អភិវឌ្ឍន៍ពិភពលោក (WDR ឆ្នាំ២០១២) ចែងថាជា "សេដ្ឋកិច្ចឆ្លាតវៃ"។ ប្រសិនបើប្រទេសទាំងអស់ត្រូវបន្សុីវឌ្ឍនភាពគ្នាឆ្ពោះទៅរកសមភាពយេនឌ័រគិតជាតួលេខរបស់ប្រទេសនៅក្នុងតំបន់របស់ពួកគេ ជាមួយនឹងភាពប្រសើរឡើងយ៉ាងឆាប់រហ័សបំផុតលើវិសមភាពយេនឌ័រនោះ ទឹកប្រាក់ចំនួនដ៏ច្រើនរហូតដល់ទៅ ១២ពាន់ពាន់លានដុល្លារ អាចត្រូវបានបន្ថែមទៅក្នុងកំណើនផលិតផលក្នុងស្រុកសរុបពិភពលោកប្រចាំឆ្នាំក្នុងឆ្នាំ២០២៥។ ដូច្នេះ ក្របខ័ណ្ឌរបាយការណ៍ WDR ឆ្នាំ២០១២ ក៏ជំរុញឱ្យមានវិធីសាស្ត្រប្រកបដោយបរិយាបន្នឆ្ពោះទៅមុខផ្សេងៗជាច្រើនទៀងផងដែរសម្រាប់យេនឌ័រ និងការប្រែប្រួលអាកាសធាតុ។

នៅក្នុងបរិបទនេះវាក៏មានសារៈសំខាន់ផងដែរដែលត្រូវយល់ដឹងថា វិសមភាពយេនឌ័រនិងតួនាទីយេនឌ័រដើរតួនាទីដ៏សំខាន់ក្នុងការកំណត់ជម្រើសយុទ្ធសាស្ត្របន្សាំដែលបុរស និងស្ត្រីមានតម្រូវការ យុទ្ធសាស្ត្រ និងឱកាសផ្សេងគ្នាសម្រាប់ការបន្សាំ និងការស្តារឡើងវិញ។ លុះត្រាតែស្ត្រីត្រូវបានបញ្ចូលយ៉ាងសកម្មទៅក្នុងដំណើរការរៀបចំផែនការ CCDRR ហើយយេនឌ័របានក្លាយជាផ្នែកដ៏សំខាន់មួយនៃសកម្មភាពនេះបើមិនដូច្នេះទេវានឹងមានភាពលំអៀងទៅរកបុរសនៅក្នុងកម្មវិធីដែលអាចឈានទៅរកការបែងចែកដោយគ្មានប្រសិទ្ធផលនូវធនធានដែលខ្វះខាត។សកម្មភាពដែលមិនយកចិត្តដាក់លើទំនាក់ទំនងរវាងយេនឌ័រ និងការប្រែប្រួលអាកាសធាតុ និងការខកខានមិនបានកំណត់ស្ត្រីថាជាក្រុមគោលដៅសម្រាប់វិធានការដាក់លាក់អាចបែងចែកធនធានដោយគ្មានប្រសិទ្ធផល។ ឧទាហរណ៍ ការសន្មត់ថាបុរសគឺជាកសិករអាចឈានទៅរកការផ្តោតលើបុរសសម្រាប់ការបណ្តុះបណ្តាលអំពីបច្ចេកវិទ្យាកសិកម្មភាគច្រើន។ ស្ត្រីដែលការពិតធ្វើការងារកសិកម្មជាងពាក់កណ្តាលនោះ នឹងមិនមានលទ្ធភាពទទួលបានព័ត៌មាននោះឡើយ ដែលអាចឈានទៅរកការបន្សាំបច្ចេកវិទ្យាមិនត្រឹមត្រូវ។ (សេចក្តីសង្ខេបរបស់គណៈកម្មាធិការប្រតិបត្តិបច្ចេកវិទ្យារបស់អនុសញ្ញា UNFCCC ដែលយោងពី (GGCA និងអង្គការ UNDP ឆ្នាំ២០១៦)។ ដូចគ្នានេះដែរ ការបង្វែរទឹកសម្រាប់ដំណាំលក់យកប្រាក់ដែលផ្អែកលើចំណង់ចំណូលចិត្តរបស់បុរសនឹងធ្វើឱ្យអសន្តិសុខស្បៀងកើនឡើងថែមទៀតហើយមិនត្រឹមតែប៉ះពាល់ដល់ស្ត្រីប៉ុណ្ណោះទេ ថែមទាំងដល់សង្គមទាំងមូលផងដែរ។ កត្តានេះក៏នឹងធ្វើឱ្យការងារផ្ទះរបស់ស្ត្រី (ពេលវេលាសម្រាប់ការដងទឹក) កើនឡើងថែមទៀតផងដែរដែលកាត់បន្ថយពេលវេលារបស់ស្ត្រីសម្រាប់សកម្មភាពផលិតហើយជាថ្មីម្តងទៀតប៉ះពាល់ដល់គោលដៅអភិវឌ្ឍន៍ និងការលុបបំបាត់ ភាពក្រីក្រជារួម។

ហេតុដូចនេះ សកម្មភាព CCDRR អាចពង្រឹងឬធ្វើឱ្យវិសមភាពកាន់តែធ្ងន់ធ្ងរឡើងប្រសិនបើសកម្មភាពនេះខកខានឆ្លើយតបទៅនឹងតម្រូវការផ្សេងៗគ្នារបស់អ្នកទទួលផល។ ទោះជាយ៉ាងណាសកម្មភាពនេះក៏អាចមានចេតនាជម្នះ និងផ្លាស់ប្តូរវិសមភាពទាំងនេះផងដែរ ខណៈដែលកសាងភាពធន់របស់មនុស្សទាំងអស់។ គោលនយោបាយ ផែនការ និងគម្រោងពាក់ព័ន្ធនឹងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ (និងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ) ដែលមិនយកបញ្ហានិងតម្រូវការរបស់ស្ត្រីមកពិចារណាអាចធ្វើឱ្យវិសមភាពយេនឌ័រដែលមានស្រាប់កាន់តែធ្ងន់ធ្ងរឡើងដោយអចេតនា។ ម្យ៉ាងវិញទៀត សកម្មភាពអាកាសធាតុក៏អាចជាឱកាសមួយផងដែរ ដើម្បីប្រើប្រាស់លទ្ធភាពចំណេះដឹង និងទេពកោសល្យដែលមិនត្រូវបានប្រើប្រាស់គ្រប់គ្រាន់ (និងមិនត្រូវបានទទួលស្គាល់គ្រប់គ្រាន់) នាពេលកន្លងមក។ តាមរយៈការពិនិត្យមើលឧបសគ្គដែលមានស្រាប់នៅក្នុងរចនាសម្ព័ន្ធសង្គម និង វប្បធម៌ ខណៈដែលបង្កើតការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុវិសមភាពយេនឌ័រដែលកើតមានជាយូរមកហើយអាចត្រូវបានកំណត់និងត្រូវបានដោះស្រាយផងដែរ។ ឧទាហរណ៍៖

- ឧទាហរណ៍ គោលនយោបាយថាមពលកាបូនទាប អាចបង្កឱ្យមានការចំណាយបន្ថែមទៀតចំពោះស្ត្រីរួមទាំងកាត់បន្ថយឱកាសប្រកបរបរចិញ្ចឹមជីវិតផ្អែកលើព្រៃឈើផងដែរ។ ទោះជាយ៉ាងណា ប្រសិនបើត្រូវបានអនុវត្តជាមួយនឹងវិធីសាស្ត្រគាំទ្រប្រជាជនក្រីក្រនិងឆ្លើយតបនឹងតម្រូវការយេនឌ័រគោលនយោបាយទាំងនេះ ក៏មានសក្តានុពលខ្ពស់ផងដែរក្នុងការផ្តល់ឱកាសប្រកបរបរចិញ្ចឹមជីវិតនិងឱកាសក្លាយជាសហគ្រិនសម្រាប់ស្ត្រី។
- គោលនយោបាយលើកកម្ពស់ជីវិតន្ទនៈនិងគោលនយោបាយបច្ចេកវិទ្យាកសិកម្មប្រហាក់ប្រហែលផ្សេងទៀតអាចបង្កើនឬបន្ថយផលិតកម្មស្បៀងតាមរយៈការបង្វែរដីពីការប្រើប្រាស់បច្ចុប្បន្ន។
- គោលនយោបាយដឹកជញ្ជូនសាធារណៈអាចជួយកាត់បន្ថយការមិនមានពេលវេលាផ្ទាល់ខ្លួនរបស់ស្ត្រីឬបង្កឱ្យមានការចំណាយបន្ថែមសម្រាប់ពួកគេ។
- អាទិភាវូបនីយកម្មនៃការបែងចែកថវិកានៅក្នុងវិស័យសុខាភិបាលសម្រាប់ជំងឺឆ្លងផ្ទុយពីការថែទាំងខុសភាពបន្តពូជ និងសុខភាពកុមារ។

- កម្មវិធីអភិរក្សព្រៃឈើដែលរឹតបន្តឹងដល់លទ្ធភាពទទួលបានអនុផលព្រៃឈើរបស់ស្ត្រីជនជាតិដើម ដែលពួកគេពឹងផ្អែកលើអនុផលទាំងនោះដើម្បីផ្តល់សន្តិសុខស្បៀង និងប្រាក់ចំណូលបន្ថែមសម្រាប់គ្រួសាររបស់ពួកគេ។

ជាការពិត ទទ្បីករណីខាងលើបង្កើតបានជាករណីមួយសម្រាប់ការវិភាគយេនឌ័រ ដែលបន្ទាប់មកនឹងដាក់បញ្ចូលទៅក្នុងបរិបទគោលនយោបាយ និងការវិភាគស្ថានភាព ហើយគួរត្រូវបានរួមផ្សំជាមួយការប្តេជ្ញាចិត្តថ្នាក់ជាតិចំពោះសិទ្ធិមនុស្ស និងសមភាពយេនឌ័រហើយក្រោយមកធ្វើសមាហរណកម្មទៅក្នុងគោលនយោបាយនានា និងផែនការសកម្មភាពជាបន្តបន្ទាប់។ ទោះជាយ៉ាងណាខណៈដែលសមភាពយេនឌ័រពិតជាមានសារៈសំខាន់នៅក្នុងសិទ្ធិផ្ទាល់របស់ខ្លួនវាក៏សំខាន់ផងដែរសម្រាប់សកម្មភាពអាកាសធាតុប្រកបដោយប្រសិទ្ធភាព (ធនាគារពិភពលោកឆ្នាំ២០១១)។

យេនឌ័រគឺជាឌីណាមិកដ៏ សំខាន់មួយនៅក្នុងកិច្ចប្រឹងប្រែងកាត់បន្ថយហានិភ័យអាកាសធាតុ និងគ្រោះមហន្តរាយ។ ទី១ចំណេះដឹង ជំនាញ និងធាតុចូលរបស់ស្ត្រីមានសារៈសំខាន់ខ្លាំងសម្រាប់ការបង្កើតគោលនយោបាយនិងយុទ្ធសាស្ត្របន្សាំ និង DRR ផ្អែកតាមបរិបទ។ បើទោះជាភាពងាយរងគ្រោះរបស់ស្ត្រីជានិច្ចកាលស្ទើរតែត្រូវបានគេសន្មត់កើតមានក្តី ក៏សមត្ថភាពប្លែកពីគេនិងការចូលរួមចំណែករបស់ស្ត្រីទៅក្នុងការបន្សាំនិងនៅទូទាំងវដ្តគ្រប់គ្រងគ្រោះមហន្តរាយ (ការកាត់បន្ថយ ភាពត្រៀមបង្ការ ការឆ្លើយតប និងការស្តារឡើងវិញ) មិនមានភាពល្អប្រសើរនោះទេ (Bradshaw និង Fordham ឆ្នាំ២០១៣)។ ការពិតចំណេះដឹង និងបទពិសោធរបស់បុគ្គល និងសមូហភាពរបស់ស្ត្រីខាងផ្នែកគ្រប់គ្រងធនធានធម្មជាតិ និងសកម្មភាពសង្គមផ្សេងទៀតនៅក្នុងកម្រិតគ្រួសារ និងកម្រិតសហគមន៍ ផ្តល់ជូនពួកគេនូវជំនាញប្លែកពីគេដែលផ្តល់អត្ថប្រយោជន៍ដល់កិច្ចប្រឹងប្រែងបន្សាំ និងគ្រោះមហន្តរាយនៅទូទាំងកម្រិត និងវិស័យ (O'Neil et al ឆ្នាំ២០១៤)។

ទី២ យុទ្ធសាស្ត្របន្សាំ និង DRR ដែលអនុវត្តប្រកបដោយប្រសិទ្ធភាពគឺ ស្ត្រីក៏ត្រូវបានជូនដំណឹង រៀបចំខ្លួន និងផ្តល់ជូនអ្វីដែលចាំបាច់ច្រើនដូច នឹងបុរសដែរ ។ ជាចុងក្រោយ ការធ្វើសមាហរណកម្មយេនឌ័រទៅក្នុងសកម្មភាព CCDRR ជួយឱ្យមានការសម្រេចបានលទ្ធផលរួមកាន់តែមានប្រសិទ្ធផល។ ក៏មានភស្តុតាងរឹងមាំ និងកាន់តែច្រើនឡើងផងដែរនៅកម្រិតប្រទេសដែលបង្ហាញថា ការធ្វើឱ្យសមភាពយេនឌ័រមានភាពប្រសើរឡើងចូលរួមចំណែកដល់ជម្រើសគោលនយោបាយដែលឈានទៅរកអភិបាលកិច្ចបរិស្ថានកាន់តែប្រសើរ មិនថាតាមរយៈការកើនឡើងការធ្វើជាតំណាង និងសំឡេងរបស់ស្ត្រីនៅក្នុងសហគមន៍របស់ពួកគេ នៅក្នុងសង្គមទូទៅ និងនៅកម្រិតនយោបាយ ឬតាមរយៈការកើនឡើងការចូលរួមកម្លាំងពលកម្មនោះទេ (ធនាគារពិភពលោកឆ្នាំ២០១១)។

### ស្ត្រី និងគោលនយោបាយការកាត់បន្ថយ

ស្ត្រីនិងបុរសមានឥទ្ធិពលខុសៗគ្នាលើផ្លូវបញ្ចេញឧស្ម័នកាបូន ហើយដូច្នេះស្ត្រីក៏មានតួនាទីធំមួយផងដែរនៅក្នុងសកម្មភាពកាត់បន្ថយ។ ក្នុងនាមជា "មេផ្ទះ" ស្ត្រីអាចត្រូវបានមើលឃើញថាមានភាពវិជ្ជមាន/ជាជម្រើសមួយ ឬជាការកាត់បន្ថយការងារក្នុងគ្រួសារ និងការងារថែទាំដែលមិនទទួលបានប្រាក់ឈ្នួលរបស់ស្ត្រី។ ពួកគេក៏ជះឥទ្ធិពលលើជម្រើសធំៗ និងសណ្ឋាននៃប្រើប្រាស់ផងដែរ ដូចជាការប្រើប្រាស់ឥន្ធនៈសម្រាប់ចម្អិនអាហារ អគ្គិសនីនិងទឹក ការទិញផលិតផលអាហារ សម្ភារវេចខ្ចប់ សម្លៀកបំពាក់។ល។ ដែលនឹងចាំបាច់ត្រូវដោះស្រាយសម្រាប់ផ្លូវអភិវឌ្ឍន៍ការបញ្ចេញឧស្ម័នទាប។ ដូចគ្នានេះដែរ ភាគច្រើនស្ត្រីគឺជាអ្នកសម្រេចចិត្តថា តើផលិតផលអាហារមួយណាដែលត្រូវទិញ និងរបៀបបោះចោលសំរាមក្នុងគ្រួសារ។វដ្តគ្រប់គ្រងសំរាមអាចត្រូវបានធ្វើឱ្យកាន់តែមានប្រសិទ្ធភាព ប្រសើរបើបុរស ស្ត្រី និងកូនរបស់ពួកគេទាំងអស់គ្នាទទួលបានការជូនដំណឹងអំពីរបៀបបែងចែកសំរាមរបស់ពួកគេហើយបោះចោលសំរាមទាំងនោះនៅកម្រិតគ្រួសារនិងកម្រិតសហគមន៍។

### ចំណុចពិភាក្សា

សួរអ្នកចូលរួមថា តើពួកគេអាចកំណត់ឧទាហរណ៍នានាដើម្បីគាំទ្រដល់ទិដ្ឋភាពណាមួយក្នុងចំណោមទិដ្ឋភាពខាងលើដែរឬអត់?

**គម្រុយសម្រាប់អ្នកសម្របសម្រួល**

> ការបន្សាំនឹងការប្រែប្រួលអាកាសធាតុតម្រូវឱ្យមានការវាយតម្លៃឡើងវិញលើការអនុវត្តកសិកម្មថ្នាក់តំបន់។ស្ត្រីដែលមានតួនាទីច្រើនជាង ៥០% នៅក្នុងផលិតកម្មកសិកម្ម មានចំណេះដឹងសំខាន់ៗច្រើនដែលនឹងជួយដល់ការវាយតម្លៃឡើងវិញលើការអនុវត្តកសិកម្មដែលចាំបាច់ទាំងនេះ។ លើសពីនេះទៀត ដោយតំណាង ៤៣% នៃកម្លាំងពលកម្មកសិកម្មនៅក្នុងពិភពលោកស្ត្រីក៏នឹងជាផ្នែកដ៏សំខាន់មួយផងដែរក្នុងការអនុវត្តដំណោះស្រាយ។

> ស្ត្រីមានតួនាទីដ៏សំខាន់មួយនៅក្នុងការឆ្លើយតបនឹងគ្រោះមហន្តរាយបើគិតពីគុណធម៌នៃការទទួលខុសត្រូវលើគ្រួសាររបស់ពួកគេ។ ស្ត្រីមើលឃើញហានិភ័យជាមុន ហើយចាត់វិធានការបង្ការជាមុនតាមរយៈការបង្កើតចង្ក្រានដែលអាចយួរបាន ការរកអុសស្តុកទុក ការរក្សាទុកអាហារក្រៀម រក្សាទុកទឹកទិញទំនិញសំខាន់ៗសន្សំប្រាក់និងបង្កើតបណ្តាញសង្គមនៅក្នុងសហគមន៍របស់ពួកគេ។

> នៅក្នុងទីក្រុងឡាម៉ាស៊ីកា (La Masica) ប្រទេសហុងឌូរ៉ាស មិនមានការរាយការណ៍អំពីមរណភាពបន្ទាប់ពីមានព្យុះសង្ឃរា

HurricaneMitchនោះឡើយពីព្រោះទីភ្នាក់ងារគ្រោះមហន្តរាយមួយបានផ្តល់ការបណ្តុះបណ្តាលរំញោចយេនឌ័រ និង ឱ្យស្ត្រី និងបុរសចូលរួមស្មើគ្នានៅក្នុងសកម្មភាពគ្រប់គ្រងគ្រោះមហន្តរាយ ហើយស្ត្រីបានគ្រប់គ្រងប្រព័ន្ធប្រកាសអាសន្ន។ កត្តានេះបានឈានទៅរកការវាយតម្លៃយ៉ាងរហ័សមួយនៅពេលដែលព្យុះសង្ឃរាវាយប្រហារ (Newman និង Stephenson ឆ្នាំ២០១០)។

នៅក្នុងសៀវភៅបណ្តុះបណ្តាលស្តីពីយេនឌ័រ និងការប្រែប្រួលអាកាសធាតុរបស់ខ្លួន (ADB ឆ្នាំ២០១៥) ធនាគារអភិវឌ្ឍន៍អាស៊ីមានការបូកសរុបដ៏សមស្របខ្លាំងអំពីសារៈសំខាន់នៃសកម្មភាពអាកាសធាតុដែលមានការរួមបញ្ចូលយេនឌ័រដោយផ្អែកលើប៉ារ៉ាម៉ែត្រចំនួន ៤ ដែលធ្វើឱ្យ៖

- √ កាន់តែមានមានប្រសិទ្ធភាព ពីព្រោះសកម្មភាពអាកាសធាតុនេះកំណត់ក្រុមគោលដៅដែលពាក់ព័ន្ធ និងភាគីពាក់ព័ន្ធទាំងអស់។
- √ កាន់តែមានប្រសិទ្ធផល ពីព្រោះសកម្មភាពអាកាសធាតុនេះសម្រេចបានលទ្ធផលកាន់តែធំធេងជាមួយនឹងធនធានដែលត្រូវបានផ្តល់ជូន។
- √ កាន់តែមានសមធម៌ ពីព្រោះសកម្មភាពអាកាសធាតុនេះកំណត់ និងកាត់បន្ថយវិសមភាព។
- √ កាន់តែមានមាននិរន្តរភាពពីព្រោះសកម្មភាពអាកាសធាតុនេះឈានទៅរកការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ចរយៈពេលវែង។

## យុទ្ធសាស្ត្រដែលមានស្រាប់គម្លាតនិងបញ្ហាប្រឈមចំពោះការបញ្ជ្រាបយេនឌ័រ

ដោយទទួលស្គាល់វិសាលភាពយេនឌ័រនៃការកាត់បន្ថយការប្រែប្រួលអាកាសធាតុនិងហានិភ័យគ្រោះមហន្តរាយ ទីភ្នាក់ងារការពារសិទ្ធិស្ត្រីនានាដូចជា អង្គការសហប្រជាជាតិដើម្បីស្ត្រី (UN Women) សម្ព័ន្ធយេនឌ័រ និងអាកាសធាតុសកល (GGCA) អង្គការ WEDO ។ល។ រួមជាមួយទីភ្នាក់ងារអន្តរជាតិនានាដូចជា អង្គការ UNDP ធនាគារពិភពលោក (WB) ធនាគារអភិវឌ្ឍន៍អាស៊ី(ADB)បាននិងកំពុងបង្កើតកិច្ចប្រឹងប្រែងនានាដើម្បីបង្កើតសកម្មភាពអាកាសធាតុ និងគ្រោះមហន្តរាយ។

លទ្ធផលគឺថា បណ្តុំគោលនយោបាយការប្រែប្រួលអាកាសធាតុពិភពលោកនិងUNFCCCក៏បានរួមបញ្ចូលយេនឌ័រថាជាគោលបំណងសំខាន់មួយផងដែរនៅក្នុងរបៀបវារៈរបស់ខ្លួន ដែលជាផ្នែកមួយនៃសន្និសីទបណ្តាភាគី (COP) ផ្សេងៗ ដែលមានការអនុម័តជាពិសេសនូវកម្មវិធីការងារក្រុងលីម៉ាស្តីពីយេនឌ័រក្នុងសន្និសីទបណ្តាញភាគីចំនួន ២០ (ឆ្នាំ២០១៤) និងផែនការសកម្មភាពយេនឌ័រដែលត្រូវបានពង្រឹងក្នុងសន្និសីទបណ្តាញភាគីចំនួន ២៥ (ឆ្នាំ២០១៩)។ ក្របខ័ណ្ឌក្រុងសេនដៃសម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ក៏មានការប្តេជ្ញាចិត្តចំពោះយេនឌ័រខ្លាំងផងដែរ។ រដ្ឋាភិបាលថ្នាក់ជាតិផ្សេងៗក៏បាននឹងកំពុងចាត់វិធានការផ្សេងៗឆ្ពោះទៅរកការបង្កើតគោលនយោបាយនិងផែនការ CCDRR ក្នុងស្រុកផងដែរ។ (ទាំងអស់នេះត្រូវបានពិភាក្សាលម្អិតបន្ថែមទៀតក្នុងម៉ូឌុល ២ ផ្នែក ក)។

ទោះជាយ៉ាងណា មានកិច្ចការជាច្រើនទៀតដែលត្រូវធ្វើ។ យុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រសំខាន់ៗដែលកំពុងត្រូវបានអនុវត្តនាពេលបច្ចុប្បន្ន និងគម្លាតនិងបញ្ហាប្រឈមក្នុងការអនុវត្ត កំពុងត្រូវបានយកមកពិភាក្សាជាមួយគ្នា។

ក) **វិធានការគោលនយោបាយ៖** មានការកើនឡើងការយល់ដឹងក្នុងចំណោមរដ្ឋាភិបាលថ្នាក់ជាតិ និងទីភ្នាក់ងារអភិវឌ្ឍន៍នានាអំពីតម្រូវការសម្រាប់ការបញ្ជ្រាបយេនឌ័រក្នុងគោលនយោបាយនិងផែនការប្រែប្រួលអាកាសធាតុនិងកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ។ អង្គការសហប្រជាជាតិដើម្បីស្ត្រី (Dankelman ឆ្នាំ២០១៦) រាយការណ៍ថា មានការលើកឡើងពិតប្រាកដនូវពាក្យ "យេនឌ័រ" ក្នុងច្បាប់គោលនយោបាយ និងយុទ្ធសាស្ត្រ CCDRR។ ទោះជាយ៉ាងណាក៏ដោយ របាយការណ៍ដដែលនេះក៏ចង្អុលបង្ហាញផងដែរ ថាពាក្យ "យេនឌ័រ" ត្រូវបានគេយល់យ៉ាងទូលំទូលាយថាជាស្ត្រី និងជាជនរងគ្រោះពីការប្រែប្រួលអាកាសធាតុ ដែលចាំបាច់ត្រូវមានវិធានការការពារ។លើសពីនេះទៀតបើទោះជាមានវឌ្ឍនភាពទាំងអស់នេះក៏ដោយ ក៏រដ្ឋាភិបាលថ្នាក់ជាតិជាច្រើនមិនសូវយកបញ្ហាយេនឌ័រជាអាទិភាពចម្បងនោះទេនៅក្នុងសកម្មភាពអាកាសធាតុ ដែលត្រូវគ្រប់គ្រងបញ្ហាឆ្លងវិស័យជាច្រើន។ ដោយជាញឹកញាប់ប្រឈមនឹងការបង្កើតជម្រើសលំបាកៗលើការបែងចែងធនធានកម្រគោលនយោបាយទាំងនេះនៅតែនៅលើក្រដាសហើយមិនទទួលបានការគាំទ្រដោយកម្មវិធីនិងការបែងចែកថវិកានានានោះឡើយ។

អង្គការសង្គមស៊ីវិលអាចដឹកនាំក្នុងការលើកកម្ពស់កិច្ចសន្ទនាអំពីគោលនយោបាយដែលមានការរួមបញ្ចូល និងផ្លាស់ប្តូរយេនឌ័រដោយប្រើប្រាស់ការប្តេជ្ញាចិត្តចំពោះCEDAW ក្នុងដំណើរការរៀបចំផែនការការប្រែប្រួលអាកាសធាតុថ្នាក់ជាតិ។អង្គការសង្គមស៊ីវិលក៏អាចតស៊ូមតិផងដែរឱ្យមានការអនុម័តការរៀបចំថវិកាដែលឆ្លើយតបនឹងតម្រូវការយេនឌ័រ (GRB) នៅក្នុងវិស័យ CCDRR សម្រាប់ការបកប្រែការប្តេជ្ញាចិត្តចំពោះគោលនយោបាយទាំងនេះទៅក្នុងការបែងចែកថវិកា។

ខ) **យន្តការស្ថាប័ន៖** មានកង្វះភាពស៊ីគ្នារវាងយុទ្ធសាស្ត្រថ្នាក់ជាតិ ការរៀបចំផែនការ CCDDR ថ្នាក់ជាតិ និងកិច្ចព្រមព្រៀងអន្តរជាតិស្តីពីយេនឌ័ររបស់រដ្ឋាភិបាលថ្នាក់ជាតិដូចជា

CEDAW ជាដើម ដែលរដ្ឋាភិបាលទាំងនេះបានផ្ដល់សច្ចាប័ន (Otzelberger ឆ្នាំ២០១១)។

ឧបសគ្គមួយក្នុងចំណោមឧបសគ្គធំៗឆ្ពោះទៅរកភាពមិនស៊ីគ្នានេះគឺថាយុទ្ធសាស្ត្រថ្នាក់ជាតិត្រូវបានដឹកនាំដោយក្រសួងផែនការ និងក្រសួងហិរញ្ញវត្ថុ ហើយផែនការ CCDRR ស្ថិតនៅក្រោមក្រសួងបច្ចេកទេសនានាដូចជា ក្រសួងកសិកម្ម ក្រសួងធនធានទឹក ក្រសួងរុក្ខាប្រម៉ាញ់ និងក្រសួងបរិស្ថាន ខណៈដែលគោលនយោបាយយេនឌ័រត្រូវបានដឹកនាំដោយក្រសួងសង្គមកិច្ច និងក្រសួងកិច្ចការនារី។ នៅក្នុងប្រទេសជាច្រើនក្រសួងផែនការក្រសួងហិរញ្ញវត្ថុក្រសួងបច្ចេកទេសនានាមានការយល់ដឹងតិចតួច ឬមិនមានការយល់ដឹងអំពីយេនឌ័រនោះទេ ខណៈដែលក្រសួងសង្គមកិច្ច និងក្រសួងកិច្ចការនារីដែលមានសិទ្ធិអំណាចយេនឌ័រ ខ្វះខាតចំណេះដឹងអំពី CCDRR។ ក្រៅពីនេះ មានយន្តការស្ថាប័នដែលកំពុងដំណើរការដើម្បីនាំយកក្រសួងទាំងនេះមកធ្វើការងាររួមគ្នាក្នុងការបង្កើត និងអនុវត្តគោលនយោបាយ CCDRR។ បទប្បញ្ញត្តិគោលនយោបាយយេនឌ័រនឹងមិនប្រែក្លាយទៅជាការអនុវត្តនោះទេ។គម្លាតកាន់តែខ្លាំងឡើងនៅក្នុងយន្តការស្ថាប័នគឺកង្វះកន្លែងសម្រាប់អង្គការសង្គមស៊ីវិលជាពិសេសអង្គការដែលធ្វើការងារពាក់ព័ន្ធនឹងស្ត្រី ដើម្បីចូលរួមក្នុងដំណើរការរៀបចំផែនការ និងអភិវឌ្ឍន៍ថ្នាក់ជាតិ។

អង្គការសង្គមស៊ីវិលអាចគាំទ្រដល់ក្រសួងបច្ចេកទេសក្នុងការអនុវត្តការវិភាគយេនឌ័រតាមវិស័យសម្រាប់CCDRR ដើម្បីអាចឱ្យមានលទ្ធភាពរៀបចំផែនការផ្ដែកលើភស្តុតាង។ អង្គការសង្គមស៊ីវិលក៏អាចធ្វើការជាដៃគូជាមួយក្រសួងបច្ចេកទេសផងដែរសម្រាប់ការកសាងសមត្ថភាពអំពីការបញ្ជ្រាបយេនឌ័រ។

គ) **ការវិភាគយេនឌ័រ និងការគ្រប់គ្រងចំណេះដឹង៖** ការឆ្លើយតបវិញ្ញាចយេនឌ័រទាមទារឱ្យមានការយល់ដឹងកាន់តែស៊ីជម្រៅខ្លាំងអំពីវិសមភាពដែលមានស្រាប់រវាងស្ត្រីនិងបុរសនិងការវិភាគបរិបទនៃវិធីនានាដែលការប្រែប្រួលអាកាសធាតុអាចធ្វើឱ្យវិសមភាពទាំងនេះកាន់តែធ្ងន់ធ្ងរឡើង។ ឧទាហរណ៍ ខណៈដែលស្ត្រីអាចស្លាប់ច្រើនជាងក្នុងអំឡុងពេលកើតមានទឹកជំនន់និងខ្យល់ព្យុះក្នុងប្រទេសបង់ក្លាដែសដោយសារមូលហេតុវប្បធម៌ បុរសអាចស្លាប់ច្រើនជាងនៅក្នុងប្រទេសវៀតណាមដោយសារមូលហេតុអាជីព។ ការឈានមកដល់កម្រិតនៃការវិភាគយេនឌ័រនេះតម្រូវឱ្យមានការប្រមូលទិន្នន័យបែងចែកតាមយេនឌ័រ ព្រមទាំងការចូលរួមរបស់សហគមន៍ក្នុងការប៉ាន់ប្រម៉ាណហានិភ័យ និងការវិភាគអំពីភាពងាយរងគ្រោះ។ ជាអកុសល មានកង្វះខាតកត្តាទាំងពីរនេះនៅកម្រិតសហគមន៍ ថ្នាក់ជាតិ និងថ្នាក់តំបន់ ដែលជាក់កម្រិតដល់ការវិភាគ និងការរៀបចំផែនការផ្អែកលើភស្តុតា(អង្គការ UN Women ឆ្នាំ២០១៦)។

ដំណឹងល្អគឺថា មានស្ថាប័នមួយដែលធ្វើការងារលើយេនឌ័រ និងការប្រែប្រួលអាកាសធាតុដែលបាននឹងកំពុងពង្រីកឥតឈប់ឈរលើវិស័យរំញោចអាកាសធាតុ"ដោយផ្ទាល់"ដូចជាសន្តិសុខស្បៀង និងកសិកម្ម ព្រៃឈើ ទឹក គ្រោះមហន្តរាយ និងលើវិស័យសង្គមនានាដូចជាសុខាភិបាលនិងការអប់រំជាដើម។ ទោះជាយ៉ាងណា វិស័យដែលវិសាលភាពយេនឌ័រទំនងជា មានភាពមិនច្បាស់លាស់ ដូចជាវិស័យដឹកជញ្ជូន និងហេដ្ឋារចនាសម្ព័ន្ធ ការទទួលបានថាមពល លំនៅឋាន និងការងារក្នុងប្រព័ន្ធឬក្រៅប្រព័ន្ធ ត្រូវបានយកមកពិនិត្យមើលតិចតួចឆ្ងាយ។ សូម្បីតែការស្រាវជ្រាវដែលតិចតួចជាងនេះត្រូវបានធ្វើឡើងទៅលើភាពស្មុគស្មាញដែលកំពុងកើតមានឡើង ដែលត្រូវបាននាំយកមកដោយភាពមិនប្រាកដប្រជានៃការប្រែប្រួលអាកាសធាតុចំពោះសមភាពយេនឌ័រដែលបង្កើតឱ្យគំរូជាថ្មីនៃតួនាទីយេនឌ័រអំពើហិង្សាទាក់ទងនឹងផ្លូវភេទនិងយេនឌ័រអាពាហ៍ពិពាហ៍កុមារ។ល។ ដូច្នេះមិនមានអ្វីគួរឱ្យភ្ញាក់ផ្អើលនោះទេដែលអង្គការ UN Women (Dankelman ឆ្នាំ២០១៦) រាយការណ៍ថា ការបង្កើតចំណេះដឹង និងការគ្រប់គ្រង នៅតែជាឧបសគ្គដ៏សំខាន់ចំពោះការរួមបញ្ចូលសមភាពយេនឌ័រពោរពេញដោយអត្ថន័យទៅក្នុង CCDRR។

សកម្មភាពសំខាន់មួយនៅក្នុងបញ្ហានេះនឹងជាការអនុវត្តការស្រាវជ្រាវ ជាពិសេសការស្រាវជ្រាវក្នុងវិស័យដែលផលប៉ះពាល់យេនឌ័រមិនមើលឃើញផ្ទាល់ដូចជាវិស័យដឹកជញ្ជូន ការងារក្រៅប្រព័ន្ធ ការធ្វើចំណាកស្រុកជាដើម។ អង្គការសង្គមស៊ីវិលអាចបោះផ្សាយស្ថិតិ និងផលិតផលចំណេះដឹង ដែលរំលេចវិសាលភាពយេនឌ័រនៅក្នុងវិស័យទាំងនេះសម្រាប់ការបង្កើនការយល់ដឹងទៅតាមតម្រូវការសម្រាប់ការធ្វើសមាហរណកម្មយេនឌ័រ ហើយក៏ដើម្បីធ្វើជាឯកសារដែលមានប្រយោជន៍ដែលអាចត្រូវបានប្រើប្រាស់ដោយផ្ទាល់ដោយក្រសួងបច្ចេកទេសផងដែរ។

ឃ) **អភិបាលកិច្ចដែលឆ្លើយតបនឹង យេនឌ័រ និងការចូលរួម និងនាពជាអ្នកដឹកនាំរបស់ស្ត្រី៖** សមាសធាតុសំខាន់បំផុតក្នុងសកម្មភាពអាកាសធាតុដែលឆ្លើយតបទៅនឹង យេនឌ័រ គឺការចូលរួម និងតួនាទីភាពជាអ្នកដឹកនាំដោយសហគមន៍ខ្លួនឯងផ្ទាល់ ជាពិសេសស្ត្រីនិងកុមារី។រដ្ឋាភិបាលនានាចាំបាច់ត្រូវអនុម័តដំណើរការដែលមានការចូលរួម ជាពិសេសនៅថ្នាក់មូលដ្ឋាន ដើម្បីឱ្យយុទ្ធសាស្ត្រ CCDRR និងការអន្តរាគមន៍នានាអាចកំណត់បាន និងឆ្លើយតបយ៉ាងពិតប្រាកដទៅនឹងតម្រូវការរបស់អ្នកទាំងឡាយណាដែលពួកគេមានបំណងជួយ។ នៅ

ក្នុងវិធីនេះ ដំណើរការអាចត្រូវបានបង្កើតឡើងដែលឆ្លើយតបនឹងភាពជាក់ស្តែងក្នុងមូលដ្ឋានខណៈដែលដាក់បញ្ចូលទៅក្នុងចក្ខុវិស័យកាន់តែទូលំទូលាយនៃការបន្ថយល្បឿនការប្រែប្រួលអាកាសធាតុ។វិញ្ញោចយេនឌ័រនិងការចូលរួមរបស់ស្ត្រីក៏ត្រូវបានតម្រូវឱ្យមានផងដែរនៅក្នុងដំណើរការដែលមានការចូលរួម ការពិគ្រោះយោបល់ និងដំណើរការធ្វើសេចក្តីសម្រេចចិត្តទាំងអស់នេះពាក់ព័ន្ធនឹងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ។ កត្តានេះចាំបាច់ត្រូវធ្វើឱ្យលើសពីការណ៍ដែលត្រឹមតែបង្កើត ឲ្យមានវត្តមានស្ត្រី ប៉ុន្តែត្រូវទទួលស្គាល់សមត្ថភាព និងចំណេះដឹងរបស់ពួកគេ ដែលពួកគេអាចចូលរួមចំណែកដល់ដំណើរការបែបនេះ។ ស្ត្រីចាំបាច់ត្រូវចូលរួមជាពិសេសក្នុងការកំណត់ និងតាមដានហានិភ័យអាកាសធាតុ រួមទាំងការបង្កើតផែនទី និងទិន្នន័យអំពីហានិភ័យ និងគ្រោះថ្នាក់ ការកំណត់ទិដ្ឋភាពហានិភ័យនិងភាពងាយរងគ្រោះដែលមានទស្សនៈយេនឌ័រដាក់លាក់និងការបង្កើតការឆ្លើយតបនឹងហានិភ័យ។ ស្ត្រីត្រូវតែចូលរួមឱ្យបានពេញលេញនៅក្នុងក្រុម/គណៈកម្មាធិការសកម្មភាពបរិស្ថានអាកាសធាតុថ្នាក់សហគមន៍ ការបណ្តុះបណ្តាលអំពីការឆ្លើយតបនឹងគ្រោះមហន្តរាយ និងសកម្មភាពដែលពាក់ព័ន្ធផ្សេងៗ។ល។

អង្គការសង្គមស៊ីវិលអាចពង្រឹងមូលដ្ឋានចំណេះដឹងក្នុងស្រុក និងអាចចូលរួមដោយផ្ទាល់ ដើម្បីស្វែងយល់អំពីគំនិតនិងចំណេះដឹងរបស់បុរស ស្ត្រី និងអ្នកទាំងឡាយណាដែលមានអត្តសញ្ញាណយេនឌ័រផ្សេងទៀត។ ការបង្កើតនិងការពង្រឹងក្រុមនិងសហព័ន្ធនានានៅក្នុងមូលដ្ឋានរបស់ស្ត្រីដោយសារក្តីបារម្ភអំពី CCDRR ទាំងនៅក្នុងតំបន់ជនបទនិងក្នុងទីក្រុងអាចជាសកម្មភាពសំខាន់របស់អង្គការសង្គមស៊ីវិល។

លើសពីនេះទៀត ប្រការសំខាន់គឺត្រូវផ្តល់អំណាចដល់សហគមន៍ជាពិសេសស្ត្រីដើម្បីលើកឡើងពីបញ្ហានិងកង្វល់របស់ពួកគេនៅក្នុងគោលយោបាយ និងផែនការ CCDRR ថ្នាក់ជាតិ។ ចំណុចចាប់ផ្តើមដ៏ងាយស្រួលមួយសម្រាប់ការណ៍នេះអាចជាការបង្កើនការចូលរួមនិងឥទ្ធិពលនយោបាយរបស់អង្គការសង្គមស៊ីវិល ដែលធ្វើការងារលើកកម្ពស់សិទ្ធិរបស់ស្ត្រីនៅក្នុងវេទិកាCCDRRនិងដំណើរការបង្កើតគោលនយោបាយថ្នាក់ជាតិ។បច្ចុប្បន្ននេះបើទោះជាអង្គការសង្គមស៊ីវិលបែបនេះមានសំឡេងនៅថ្នាក់តំបន់ក៏ដោយ ក៏ការចូលរួមរបស់អង្គការទាំងនោះនៅក្នុងការធ្វើសេចក្តីសម្រេចចិត្តថ្នាក់ជាតិនៅមានកម្រិតនៅឡើយ។ ការពិត គឺនៅមានកង្វះយន្តការស្ថាប័ន ដែលអាចឱ្យមានការចូលរួមប្រកបប្រសិទ្ធភាពរបស់អង្គការសង្គមស៊ីវិលទាំងនេះ រួមទាំងស្ត្រីខ្លួនឯងផ្ទាល់នៅក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្ត។

លើសពីនេះទៀត ក៏មានការធ្វើជាតំណាងរបស់ស្ត្រីមិនគ្រប់គ្រាន់ផងដែរនៅក្នុងការចូលរួមក្នុងនយោបាយនៅតំបន់អាស៊ីក៏ដូចជានៅជុំវិញពិភពលោកផងដែរ។ស្ត្រីនៅតែកាន់កាប់អសនៈត្រឹមតែ ២៥% ប៉ុណ្ណោះនៃអសនៈសភាថ្នាក់ជាតិនៅក្នុងពិភពលោក(របាយការណ៍គម្លាតយេនឌ័រពិភពលោក ឆ្នាំ២០២០)។ ការលើកកម្ពស់អភិបាលកិច្ចដែលឆ្លើយតបនឹងយេនឌ័រ និងការមានមេដឹកនាំជាស្ត្រីកាន់តែច្រើនឡើងថែមទៀតក្នុងមុខតំណែងដែលកើតចេញពីការបោះឆ្នោត និងមុខតំណែងប្រតិបត្តិក្នុងរដ្ឋាភិបាល មានភាពចាំបាច់ប្រសិនបើសំឡេងរបស់ស្ត្រីត្រូវបានគេឮហើយពួកគេត្រូវបានរួមបញ្ចូលក្នុងការរៀបចំកសាងផែនការនិងការអនុវត្តគំនិតផ្តួចផ្តើមនិងយុទ្ធសាស្ត្រCCDRR។កត្តានេះក៏អាចត្រូវបានធ្វើឡើងផងដែរនៅថ្នាក់មូលដ្ឋាន។ ឧទាហរណ៍ ក្នុងប្រទេសឥណ្ឌា មានបទប្បញ្ញត្តិស្ថាប័នមួយដើម្បីធានាថាយ៉ាងហោចណាស់មួយភាគបីនៃអ្នកតំណាងរាស្ត្រជាប់ឆ្នោតនិងមេដឹកនាំនៅក្នុងស្ថាប័នមូលដ្ឋាននៅជនបទនិងទីក្រុងគឺជាស្ត្រី។

អង្គការសង្គមស៊ីវិលក៏អាចគាំទ្រផងដែរដល់ការចូលរួមរបស់មេដឹកនាំដែលជាស្ត្រី ជាពិសេសស្ត្រីដែលមកពីសហគមន៍ក្រីក្រនិងក្រុមដែលជួបការលំបាកនៅក្នុងការចរចាអំពីអាកាសធាតុថ្នាក់ជាតិ និងអន្តរជាតិដែលឆ្លើយតបនឹងតម្រូវការយេនឌ័រ។ ការកំណត់អត្តសញ្ញាណ និងការបណ្តុះបណ្តាលមេដឹកនាំដែលជាស្ត្រីមកពីសហគមន៍ងាយរងគ្រោះដើម្បីលើកឡើងពីបញ្ហា និងកង្វល់របស់ពួកគេដោយផ្ទាល់គួរជាសកម្មភាពដ៏សំខាន់មួយរបស់អង្គការសង្គមស៊ីវិល។

**ចំណុចពិភាក្សា**

សួរអ្នកចូលរួមថា៖ តើអ្វីខ្លះដែលពួកគេគិតថានឹងជាការពិចារណាដ៏សំខាន់ដែលចាំបាច់ត្រូវរក្សាទុកក្នុងចិត្តនៅពេលដែលអនុវត្តការវិភាគយេនឌ័រ ឬផ្តល់លទ្ធភាពឱ្យមានភាពជាអ្នកដឹកនាំជាស្ត្រីនិងការចូលរួមក្នុងការធ្វើសេចក្តីសម្រេចចិត្តអំពីអាកាសធាតុ

**តម្រុយសម្រាប់អ្នកសម្របសម្រួល**

> វាមានសារៈសំខាន់ណាស់ក្នុងការធានាថា កង្វល់យេនឌ័រមិនត្រូវកំណត់ត្រឹមបុរសនិងស្ត្រីនោះទេនិងថាអត្តសញ្ញាណយេនឌ័រទាំងអស់ត្រូវបានវិភាគក្នុងបរិបទក្នុងស្រុក ខណៈដែលអនុវត្តការវិភាគយេនឌ័រការប្រមូលទិន្នន័យយេនឌ័រឬការផ្តល់លទ្ធភាពឱ្យមានការតំណាងយេនឌ័រក្នុងការធ្វើសេចក្តីសម្រេចចិត្ត។ ឧទាហរណ៍ ខណៈដែលវិភាគអំពីអំពើហិង្សាផ្លូវភេទបន្ទាប់ពីមានគ្រោះមហន្តរាយ វាគួរតែត្រូវបានវិភាគនៅទូទាំងយេនឌ័រទាំងអស់ហើយមិនកំណត់ត្រឹម

តែស្ត្រីនិងកុមារីនោះទេ។ ការប៉ាន់ប្រម៉ាណតម្រូវការយេនឌ័រគួររាប់បញ្ចូលការប៉ាន់ប្រម៉ាណតម្រូវការរបស់ក្រុមLGBTIQសម្រាប់ភាពឯកជន និងបែងចែកបបនីយកណ្ឌអនាម័យ។ ដូចគ្នានេះដែរ សម្ពាធវប្បធម៌លើបុរសឱ្យរកប្រាក់ ឬប្រថុយនឹងហានិភ័យ ដែលអាចបង្កើនភាពតានតឹងរបស់ពួកគេ ក៏គួរមានការយល់ដឹងផងដែរ ដើម្បីបង្កើតការធ្វើអន្តរាគមន៍នានាដូចជាការពិគ្រោះយោបល់អំពីគ្រឿងស្រវឹងបន្ទាប់ពីគ្រោះមហន្តរាយជាដើម។

> ដូចគ្នានេះដែរភាពចម្រុះប្រសព្វយេនឌ័រ( Intersectionalities) ដែលពាក់ព័ន្ធនឹងអាយុ ជាតិពន្ធ វណ្ណៈ ថ្នាក់ ឬអត្តសញ្ញាណសង្គមក៏ចាំបាច់ត្រូវយកមកពិចារណាផងដែរ។ ឧទាហរណ៍ទិន្នន័យអំពីមរណភាពក្នុងអំឡុងគ្រោះមហន្តរាយត្រូវរាប់បញ្ចូលព័ត៌មានអំពីអាយុដើម្បីស្វែងយល់ថាតើមានកង្វល់បន្ថែមណាមួយអំពីកុមារី មនុស្សស្រីជំទង់ ឬស្ត្រីវ័យចំណាស់ ឬអត់។ នៅពេលផ្ដល់លទ្ធភាពឱ្យមានការធ្វើជាតំណាងរបស់ស្ត្រីក្នុងវេទិកាធ្វើសេចក្ដីសម្រេចចិត្តនានាមិនគួរមានការកំណត់ចំពោះក្រុមស្ត្រីដែលមានការអប់រំនោះទេ ប៉ុន្តែរាប់បញ្ចូលស្ត្រីជនជាតិដើមភាគតិចស្ត្រីជាជនពិការស្ត្រីមកពីប្រភេទអាជីពផ្សេងៗ ស្ត្រីមានប្រវត្តិមកពីជនបទ និងទីក្រុង។ល។ ផងដែរ។

ង ) **វិធីសាស្ត្របញ្ជ្រាបយេនឌ័រ និងវិធីសាស្ត្រផ្លាស់ប្ដូរផ្នត់គំនិត យេនឌ័រ៖** ការបញ្ជ្រាបយេនឌ័រទៅក្នុងដំណើរការគោលនយោបាយកម្មវិធី និងគម្រោង អាចជួយធានាថា ដំណើរការបែបនេះផ្ដល់អត្ថប្រយោជន៍ប្រកបដោយសមធម៌ដល់មនុស្សគ្រប់គ្នាដូចដែលមានចែងក្នុងវិធីសាស្ត្រផ្អែកលើសិទ្ធិមនុស្សជាមូលដ្ឋាន និងគោលការណ៍មិនមានអ្នកណាម្នាក់ត្រូវបានទុកចោល( LNOB) ដែលមានសារៈសំខាន់ចំពោះការសម្រេចបានSDGs។ទោះជាយ៉ាងណាក៏ដោយខណៈដែលវិធានការទាំងនេះអាចពន្លឿនគោលនយោបាយសង្គម(រួមទាំងសមភាពយេនឌ័រ)វិធានការទាំងនេះជានិច្ចកាលមិនអាចជួយឱ្យមានការផ្លាស់ប្ដូរទំនាក់ទំនងយេនឌ័របែបរចនាសម្ព័ន្ធ ដែលមានការផ្លាស់ប្ដូរបាននោះទេ។សម្រាប់ការណ៍នេះវាមានសារៈសំខាន់ខណៈដែលយេនឌ័រត្រូវបានធ្វើសមាហរណកម្មទៅក្នុងផែនការ និងវិធានការឆ្លើយតប ការផ្ដោតការយកចិត្តទុកដាក់មិនត្រឹមតែធ្វើទៅលើការដោះស្រាយភាពងាយរងគ្រោះប៉ុណ្ណោះទេប៉ុន្តែថែមទាំងលើការទាញយកប្រយោជន៍ពីឱកាសដែលអាចមានផងដែរដើម្បីពន្លឿនបន្ថែមទៀតនូវគោលដៅសមភាពយេនឌ័រ។ក្នុងពេលជាមួយគ្នានេះដែរការណ៍នេះក៏អំពាវនាវផងដែរឱ្យមានតម្រូវការធ្វើលើសពីការផ្ដោតការយកចិត្តទុកដាក់តែលើស្ត្រី ប៉ុន្តែត្រូវផ្ដោតផងដែរលើបុរស និងយេនឌ័រផ្សេងទៀត ខណៈដែលរៀបចំផែនការ និងអនុវត្តកម្មវិធី CCDRR។

ដោយតស៊ូមតិឱ្យមានការបញ្ជ្រាបយេនឌ័រក្នុងគោលនយោបាយ និងកម្មវិធីថ្នាក់ជាតិ អង្គការសង្គមស៊ីវិលអាចផ្ដោតលើការបង្កើត និងដឹកនាំគម្រោងដែលមានទស្សនៈផ្លាស់ប្ដូរយេនឌ័រ។ដោយអនុវត្តក្នុងទម្រង់គម្រោងដែលមានសមាសធាតុវាយតម្លៃខ្លាំងនៅក្នុងនោះ។ ទាំងនេះនឹងមានសក្ដានុពលចំពោះគម្រោងដែលត្រូវបានអនុម័តដោយរដ្ឋាភិបាលសម្រាប់ការ

ច ) **ការរួមបញ្ចូលក្នុងផែនការ និងវិធានការការឆ្លើយតប៖** មានការទទួលស្គាល់កាន់តែខ្លាំងថា ផែនការ CCDRR និងវិធានការឆ្លើយតប គួរពិចារណាលើហានិភ័យ ភាពងាយរងគ្រោះ និងសមត្ថភាពដែលមានភាពខុសគ្នានៃយេនឌ័រ។ ជាអកុសលក្នុងការអនុវត្តផែនការនិងកម្មវិធីជាក់ស្ដែងនៅតែត្រូវបានគ្របដណ្ដប់ដោយបច្ចេកវិទ្យានិងដំណោះស្រាយសេដ្ឋកិច្ចដែលត្រូវបានចាត់ទុកថាជាអព្យាក្រឹត្យយេនឌ័របើទោះជាផែនការនិងកម្មវិធីទាំងនេះជាញឹកញាប់មានមូលដ្ឋានលើបទដ្ឋានបុរសក៏ដោយ។ ឧទាហរណ៍ នៅពេលការប្រកាសអាសន្នត្រូវបានផ្ដល់តាមរយៈទូរស័ព្ទដៃ វាផ្ដល់អត្ថប្រយោជន៍ដល់បុរសច្រើនជាងស្ត្រីមិនត្រឹមតែដោយសារភាពខុសគ្នានៃការទទួលបានបច្ចេកវិទ្យាទូរស័ព្ទប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងការកម្រិតកំណត់វប្បធម៌នៃការធ្វើសេចក្ដីសម្រេចចិត្តភ្លាមៗផងដែរ។ នៅតែមានតម្រូវការដ៏ធំមួយដែលត្រូវផ្ដោតលើវិធានការឆ្លើយតបទាំងអស់ដែលត្រូវបានវាយតម្លៃលើការផ្សព្វផ្សាយយេនឌ័រ និងផ្ដោតលើការរួមបញ្ចូលវិធានការទាំងនេះក្នុងផែនការ CCDRR និងវិធានការឆ្លើយតប។ ទោះជាយ៉ាងណាគោលនយោបាយនិងវិធានការដែលផ្ដោតជាចម្បងលើភាពងាយរងគ្រោះយេនឌ័រជាក់លាក់មានហានិភ័យធ្វើឱ្យស្ត្រីក្លាយជាជនរងគ្រោះ។ ដូច្នេះ ប្រការសំខាន់គឺថា បុរស ស្ត្រី និងអ្នកដែលមកពីអត្តសញ្ញាណយេនឌ័រផ្សេងទៀត ត្រូវតែចូលរួមទាំងអស់គ្នាដោយផ្ទាល់ក្នុងដំណើរការរៀបចំ និងអនុវត្តផែនការ។ កម្មវិធី CCDRR ដែលដឹកនាំដោយស្ត្រីសហគមន៍ គួរតែជាវិធីសាស្ត្របញ្ជ្រាបយេនឌ័រដ៏សំខាន់។ ជាអកុសល កម្មវិធីទាំងនេះមិនត្រឹមតែមិនត្រូវបានទទួលស្គាល់នៅក្នុងគោលនយោបាយនិងកម្មវិធីថ្នាក់ជាតិប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងមានម្ចាស់ជំនួយតិចតួចខ្លាំងដែលផ្ដល់មូលនិធិសម្រាប់ការអនុវត្ត និងពង្រីកកម្មវិធីបែបនេះ ដែលមានសារៈសំខាន់ខ្លាំងសម្រាប់ការសម្រេចបានការបញ្ជ្រាបយេនឌ័រ។

អង្គការសង្គមស៊ីវិលគួរផ្ដោតការយកចិត្តទុកដាក់លើការបង្កើតនិងការអនុវត្តគម្រោង CCDRR ផ្អែកលើសង្គម ដែលជា

គម្រោងដឹកនាំឬមិនដឹកនាំដោយស្ត្រី និង/ឬផ្តោតការយកចិត្តទុកដាក់លើប្រជាជនដែលងាយរងគ្រោះដាក់លាក់ដូចជា មនុស្សចាស់ ជនពិការ ក្រុម LGBTIQ សហគមន៍ជនជាតិដើម ជនជាតិភាគតិច ជនអន្តោប្រវេសន៍/ជនភៀសខ្លួន។ល។

ឆ) **ការដោះស្រាយភាពងាយរងគ្រោះធៀបនឹងការទាញយកប្រយោជន៍ពីឱកាស៖** វិធីសាស្ត្របញ្ជ្រាបយេនឌ័របច្ចុប្បន្នក៏មានការផ្តោតការយកចិត្តទុកដាក់ខ្លាំងផងដែរលើភាពងាយរងគ្រោះជាក់លាក់របស់ស្ត្រីនិងមានការធ្វើអន្តរាគមន៍ទៅតាមការចង់បានដែលដាក់ស្ត្រីឱ្យស្ថិតនៅស្ថិតចុងក្រោយគេនៃការឆ្លើយតបនឹងការបន្សាំ។ សម្រាប់ផ្នែកដ៏ធំមួយ វិធីសាស្ត្រទាំងនេះ មិនបានដោះស្រាយវិសមភាពយេនឌ័រដែលបង្កឱ្យមានភាពងាយរងគ្រោះខុសៗគ្នាទាំងនេះឡើយហើយខ្វះការពិចារណាលើតួនាទី ចំណង់ចំណូលចិត្ត តម្រូវការ ចំណេះដឹង និងសមត្ថភាពរបស់បុរសនិងស្ត្រីកុមារានិងកុមារីនៅគ្រប់កម្រិតជាពិសេសនៅថ្នាក់ជាតិ និងថ្នាក់តំបន់។ វាមានសារៈសំខាន់សម្រាប់ប្រទេសនានា អង្គការសង្គមស៊ីវិល និងសហគមន៍ដែលត្រូវសម្លឹងមើលកាន់តែជិតទៅលើវិសាលភាពវិសមភាពយេនឌ័រជាលក្ខណៈរចនាសម្ព័ន្ធ និងប្រើប្រាស់កម្មវិធីបន្សាំនឹងអាកាសធាតុធ្វើជាមធ្យោបាយដើម្បីដោះស្រាយបញ្ហាទាំងនេះ។ ឱកាសយេនឌ័របែបនេះ សំដៅលើសក្តានុពលនៃការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ដែលពិចារណាទៅលើតួនាទី ទិដ្ឋភាព គំនិត តម្រូវការ និងសមត្ថភាពរបស់បុរស និង ស្ត្រី ដើម្បី i) លើកកម្ពស់សមភាពយេនឌ័រ ii) កាត់បន្ថយភាពក្រីក្រ និង iii) ចូលរួមចំណែកទៅនឹងយុទ្ធសាស្ត្របន្សាំ និងកាត់បន្ថយការប្រែប្រួលអាកាសធាតុប្រកបដោយជោគជ័យ (Otzelberger ឆ្នាំ២០១១)។ យុទ្ធសាស្ត្រដ៏សំខាន់មួយឆ្ពោះទៅរកការណ៍នេះគឺត្រូវលើកកម្ពស់ជម្រើសរបរចិញ្ចឹមជីវិតចម្រុះសម្រាប់ស្ត្រី ដើម្បីបង្កើនភាពធន់ទៅនឹងគ្រោះថ្នាក់ និងដើម្បីធានាថា ហានិភ័យនានាដែលស្ត្រីប្រឈមមិនត្រូវបានធ្វើឱ្យកាន់តែធ្ងន់ធ្ងរឡើងដោយសារគោលនយោបាយអភិវឌ្ឍន៍និងការអនុវត្តដែលមិនសមស្របនានា (ធនាគារពិភពលោក ឆ្នាំ២០១១)។

អង្គការសង្គមស៊ីវិលអាចលើកកម្ពស់ការយល់ដឹងអំពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុទៅលើយេនឌ័រនៅក្នុងបរិបទថ្នាក់ជាតិនិងថ្នាក់មូលដ្ឋាន និងយុទ្ធសាស្ត្រឆ្លើយតបសមស្របតាមរយៈកម្មវិធីបណ្តុះបណ្តាល និងសិក្ខាសាលាស្តីពីយេនឌ័រ និង CCDRR។ ការចូលរួមរយៈពេលវែងជាមួយស្ថាប័នបណ្តុះបណ្តាលរបស់រដ្ឋាភិបាលដែលមានស្រាប់ដែលផ្តោតលើ CCDRR នឹងកាន់តែមានប្រសិទ្ធភាពថែមទៀត។

ជ) **ភាពអាចរកបានហិរញ្ញវត្ថុអាកាសធាតុ៖** សមាសធាតុដ៏សំខាន់មួយផ្សេងទៀតនៃសកម្មភាពអាកាសធាតុដែលឆ្លើយតបនឹងតម្រូវការយេនឌ័រគឺការផ្តល់ធនធានហិរញ្ញវត្ថុ។មានការបោះជំហានទៅមុខមួយចំនួនក្នុងការបង្កើតយន្តការហិរញ្ញវត្ថុអាកាសធាតុ ដែលមានការឆ្លើយតបនឹងតម្រូវការយេនឌ័រជាពិសេសជាមួយនឹងយេនឌ័រដែលបានក្លាយជាសមាសធាតុមួយនៅក្នុងការវិនិយោគដែលត្រូវបានជំរុញដោយម្ចាស់ជំនួយ។ ទោះជាយ៉ាងណា ដោយសាររចនាសម្ព័ន្ធសេដ្ឋកិច្ចដែលមានស្រាប់ ធនធានហិរញ្ញវត្ថុដើម្បីផ្តល់ជំនួយក្នុងការកាត់បន្ថយនិងការបន្សាំនឹងការប្រែប្រួលអាកាសធាតុមិនទំនងជាអាចរកបានសម្រាប់ស្ត្រីនោះទេធៀបនឹងបុរស(ធនាគារពិភពលោក ឆ្នាំ២០១១)។ ការបែងចែកថវិកាសម្រាប់ការអនុវត្ត CCDRR នៅទូទាំងកម្រិតនិងវិស័យ គួរត្រូវបានផ្តល់អាទិភាពសម្រាប់សកម្មភាពដែលដោះស្រាយតម្រូវការយេនឌ័រ។ លើសពីនេះទៀត ការធានាបាននូវការចូលរួមរបស់ស្ត្រី និងយេនឌ័រផ្សេងទៀតក្នុងការធ្វើសេចក្តីសម្រេចចិត្តលើទិដ្ឋភាពទាំងអស់នៃការផ្តល់ហិរញ្ញប្បទានពាក់ព័ន្ធនឹងអាកាសធាតុដែលមានសារៈសំខាន់ខ្លាំងចំពោះប្រសិទ្ធភាពនិងប្រសិទ្ធផលនៃធនធាននិងសមធម៌នៅតែស្ថិតនៅផ្លូវដ៏វែងឆ្ងាយនៅឡើយ។

ឈ) **ការដោះស្រាយទិន្នន័យបែងចែងតាមភេទ អាយុ និងពិការភាព (SADDD)៖** វាគឺជា ក្តីបារម្ភអន្តរវិស័យ ទាំងអស់ដែលពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ និងជាពិសេសក្នុងអំឡុងពេលកើតមានគ្រោះមហន្តរាយ។ហានិភ័យពីគ្រោះមហន្តរាយជាញឹកញាប់ត្រូវបានធ្វើឱ្យកើតមានកាន់តែធ្ងន់ធ្ងរដោយសារភាពខុសគ្នានៃភាពងាយរងគ្រោះរបស់បុរស និងស្ត្រី និន្នាការផ្លូវភេទ អាយុ ពិការភាព ជាតិសាសន៍ ជាតិពន្ធជាដើម (GFDRR nd)។ ជាអកុសល ការប៉ាន់ប្រម៉ាណគ្រោះមហន្តរាយ ភាគច្រើនមិនផ្តោតលើការអនុវត្តការ ប៉ាន់ប្រម៉ាណតាមការបែងចែកទិន្នន័យនោះទេ ដោយជាង ៩០% នៃប្រទេសដែលរាយការណ៍ទៅកាន់កិច្ចព្រមព្រៀងក្របខ័ណ្ឌការងារ Hyogo មិនបានប្រមូល SADDD (UNDRR ឆ្នាំ២០១៥) ឡើយ។ លុះត្រាតែទិន្នន័យអាចរកបានដើម្បីប៉ាន់ប្រម៉ាណលើភាពងាយរងគ្រោះខុសៗគ្នានៅទូទាំងវិសាលភាពសង្គមទាំងនេះការផ្តល់លទ្ធភាពឱ្យមានគោលនយោបាយនិងកម្មវិធីដែលឆ្លើយតបនឹងតម្រូវការយេនឌ័រនិងភាពចម្រុះប្រសព្វ ខាងយេនឌ័រ (Intersectionalities) ជានិច្ចកាលនឹងនៅតែជាបញ្ហារប្រឈមដដែល។

ការបង្កើតឧបករណ៍យេនឌ័រនិងឧបករណ៍ប្រែប្រួលអាកាសធាតុដែលគ្របដណ្តប់លើវដ្តកម្មវិធីទាំងមូលដោយមានការផ្តោតការយកចិត្តទុកដាក់ជាក់លាក់លើការតាមដាននិងការរាយការណ៍។

៣) **ផ្តោតការយកចិត្តទុកដាក់លើបុរស និងអត្តសញ្ញាណយេនឌ័រផ្សេងទៀត៖** ជាចុងក្រោយ ប្រការសំខាន់គួរកាត់សម្គាល់ថា វិធីសាស្ត្រផ្អែកលើយេនឌ័រចំពោះការប្រែប្រួលអាកាសធាតុមិនគួរគ្រាន់តែជាវិធីសាស្ត្រសម្រាប់តែស្ត្រីនោះទេ។ បុរស និងកុមារា ក៏ជាអ្នកដែលស្ថិតក្នុងអត្តសញ្ញាណយេនឌ័រផ្សេងទៀតផងដែរនោះ ហើយពួកគេក៏ងាយរងគ្រោះទៅនឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុផងដែរប៉ុន្តែជាញឹកញាប់ពួកគេរងផលប៉ះពាល់ក្នុងរបៀបផ្សេងៗគ្នាហើយផលប៉ះពាល់ទាំងនេះ ចំបាច់ត្រូវកំណត់ និងផ្សព្វផ្សាយ។ ជាអកុសលដូចដែលមានការរាយការណ៍ក្នុងរបាយការណ៍របស់អង្គការ UN Women ( Dankelman ឆ្នាំ២០១៦ ) គោលនយោបាយការប្រែប្រួលអាកាសធាតុបច្ចុប្បន្ននៅតែមាននិន្នាការចាត់ទុកដូចគ្នារវាងពាក្យថា "យេនឌ័រ" និងពាក្យថា "ស្ត្រី"។

## សមត្ថភាពសម្រាប់ការបញ្ជ្រាបយេនឌ័រ

កិច្ចប្រឹងប្រែងរបស់ទីភ្នាក់ងារផ្សេងៗក្នុងរយៈពេលប៉ុន្មានឆ្នាំមកនេះបានមើលឃើញការកើនឡើងកម្រិតនៃការយល់ដឹង ការប្តេជ្ញាចំពោះគោលនយោបាយ ព្រមទាំងការអនុវត្តគម្រោងសាកល្បងនានា ដើម្បីដោះស្រាយកង្វល់យេនឌ័រ។ មានកម្មវិធីដែលដឹកនាំដោយស្ត្រីប្រកបដោយភាពច្នៃប្រឌិតមួយចំនួនដែលកំពុងត្រូវបានអនុវត្តដោយទទួលបានការគាំទ្រពីទីភ្នាក់ងារពហុភាគី និងម្ចាស់ជំនួយផ្សេងៗ។ ទោះជាយ៉ាងណា បើទោះជាមានផែនការពង្រីកក្តី ក៏កម្មវិធីទាំងនេះភាគច្រើនមិនត្រូវបានពង្រីកឡើយ ជាចម្បងដោយសារកង្វះសមត្ថភាពនៅថ្នាក់ជាតិ។ ដូចដែលបានលើកឡើងមុននេះ ក្រសួងបច្ចេកទេសភាគច្រើនមានការយល់ដឹងតិចតួច ឬមិនមានការយល់ដឹងសោះអំពីយេនឌ័រហើយដូច្នេះខ្វះសមត្ថភាពសម្រាប់ការធ្វើសមាហរណកម្មយេនឌ័រជាលក្ខណៈប្រព័ន្ធនៅក្នុងការងារ CCDRR។ ហេតុដូច្នេះសូម្បីតែនៅពេលអំណាចយេនឌ័រមានស្រាប់ហើយក្តី ក៏ជាញឹកញាប់វាមិនមានទំនាក់ទំនងទៅនឹងការអនុវត្តជាក់ស្តែងឡើយ។ ជាញឹកញាប់មានការផ្តាច់ទំនាក់ទំនងយេនឌ័រនៅក្នុងវដ្តគម្រោង និងកម្មវិធី រវាងការវិភាគយេនឌ័រដែលមានកម្រិតខ្លាំងក្នុងមូលដ្ឋានទ្រឹស្តី និងការរៀបចំផែនការរបស់គម្រោង ហើយម្យ៉ាងវិញទៀតមានការធ្វើសមាហរណកម្មទស្សនៈយេនឌ័រកាន់តែតិចទៅៗទៅក្នុងការអនុវត្ត ការតាមដាន និងវាយតម្លៃគំនិតផ្តួចផ្តើម CCDRR។ ដូច្នេះ បញ្ហាប្រឈមមួយក្នុងចំណោមបញ្ហាប្រឈមធំបំផុតនានាសម្រាប់ការបញ្ជ្រាបយេនឌ័រ គឺការកសាងសមត្ថភាពរបស់ក្រសួងបច្ចេកទេសសម្រាប់ការធ្វើសមាហរណកម្ម និងការបញ្ជ្រាបយេនឌ័រទៅក្នុងគោលនយោបាយ និងកម្មវិធីដែលពាក់ព័ន្ធនឹង CCDRR។

## ស្ត្រីគឺជាដៃគូ និងតួអង្គស្មើភាពក្នុងសកម្មភាពអាកាសធាតុ

ស្ត្រីអាចជាភ្នាក់ងារដែលពោរពេញដោយអំណាចនៃការផ្លាស់ប្តូរសម្រាប់សកម្មភាពអាកាសធាតុ។ ជាអកុសលសក្តានុពលនេះនៅតែមិនត្រូវបានទាញយកមកប្រើប្រាស់នៅឡើយ ដោយសារកង្វះការធ្វើសមាហរណកម្មយេនឌ័រទៅក្នុងការរៀបចំផែនការសកម្មភាពការប្រែប្រួលអាកាសធាតុ និងកាន់តែសំខាន់ជាងនេះទៀតនោះគឺដោយសារកង្វះកន្លែងសម្រាប់ស្ត្រីដើម្បីចូលរួមក្នុងការរៀបចំកសាងផែនការ និងការធ្វើសេចក្តីសម្រេចចិត្ត ឬដឹកនាំមុខគេក្នុងការអនុវត្តសកម្មភាពអាកាសធាតុ។ ស្ត្រីអាចជាភ្នាក់ងារដ៏សំខាន់នៃការផ្លាស់ប្តូរ ហើយរាល់សកម្មភាពអាកាសធាតុទាំងអស់ជាពិសេសនៅថ្នាក់ជាតិនិងថ្នាក់មូលដ្ឋាន មានការចូលរួមពីស្ត្រីដែលជាដៃគូ និងតួអង្គស្មើភាព។ ស្ត្រីគ្រាន់តែត្រូវការការផ្ត ល់ភាពអង់អាចដើម្បីទទួលបានប្រយោជន៍ពីកិច្ចប្រឹងប្រែងភាពធន់ប៉ុណ្ណោះ។

មានឧទាហរណ៍ជាច្រើនរាប់មិនអស់នៅទីដែលការផ្តល់ភាពអង់អាចដល់ស្ត្រីឱ្យធ្វើការងារភាពជាអ្នកដឹកនាំនៅក្នុងសហគមន៍របស់ពួកគេ ចូលរួមចំណែកដល់ភាពធន់នឹងអាកាសធាតុ។ វាមានសារៈសំខាន់ដែលត្រូវដឹង និងរៀនសូត្រអំពីរឿងរ៉ាវរបស់ស្ត្រីដែលជាភ្នាក់ងារនៃការផ្លាស់ប្តូរទាំងនេះ។

ស្ត្រីអាចដើរតួនាទីដ៏សំខាន់នៅក្នុងភាពត្រៀមបង្ការទប់ទល់នឹងគ្រោះមហន្តរាយ។ ឧទាហរណ៍ នៅពេលដែលកម្ពស់ទឹកកើនឡើង ស្ត្រីមួយចំនួនផ្លាស់ប្តូរទៅកាន់ទីទួលខ្ពស់ដែលនៅជិតបំផុត និងធ្វើទីជម្រកបណ្តោះអាសន្នដើម្បីធានាបាននូវសុវត្ថិភាពរបស់ពួកគេ និងសមាជិកគ្រួសាររបស់ពួកគេ។ ស្ត្រីផ្សេងទៀតស្វែងរកទីជម្រកនៅផ្ទះរបស់សាច់ញាតិ ឬមិត្តភក្តិនៅទីកន្លែងដែលខ្ពស់ជាងផ្ទះរបស់ខ្លួន។ ស្ត្រីដែលមានធនធានចាំបាច់ ដំឡើងកម្រិតជើងតាំងផ្ទះរបស់ពួកគេ ឬផ្ទះកសិដ្ឋានរបស់ពួកគេ។ ដើម្បីការពារទ្រព្យសម្បត្តិ និងរបរចិញ្ចឹមជីវិតរបស់ខ្លួន ស្ត្រីព្យាយាមរក្សាទុកគ្រាប់ពូជនៅទីកន្លែងខ្ពស់មុនពេលទឹកជំនន់មកដល់ដែលអាចឱ្យពួកគេដាំដុះឡើងវិញបានយ៉ាងឆាប់រហ័សបន្ទាប់ពីទឹកជំនន់បានស្រកចុះវិញ។ ជួនកាលសត្វពាហនៈត្រូវបាននាំយកទៅទីទួលខ្ពស់ ប៉ុន្តែទីកន្លែងដែលមានសុវត្ថិភាពសម្រាប់គោក្របីជាញឹកញាប់ពិបាកស្វែងរក។ ស្ត្រីក៏បន្សាំទៅនឹងគំរូកសិកម្មរបស់ពួកគេផងដែរ រួមទាំងការបង្កើនកិច្ចប្រឹងប្រែងក្នុងផលិតកម្មកសិកម្ម និងស្វែងរកជម្រើសផលិតកម្មមិនមែនកសិកម្ម។ កសិករជាស្ត្រីមួយចំនួនបានផ្លាស់ប្តូរទៅដាំដំណាំដែលអាចប្រមូលផលបានមុនពេលរដូវទឹកជំនន់ ឬពូជស្រូវដែលដុះលូតខ្ពស់ជាងទឹកនៅពេលទឹកជំនន់មកដល់។

ការពិភាក្សាជាច្រើនអំពីយេនឌ័រនៅក្នុងបរិបទការប្រែប្រួលអាកាសធាតុបានផ្តោតការយកចិត្តទុកដាក់លើការរុករក និងការរំលេចភាពងាយរងគ្រោះជាក់លាក់របស់ស្ត្រីទៅនឹងផលប៉ះពាល់ការប្រែប្រួលអាកាសធាតុដោយសារតួនាទីនិងការទទួលខុសត្រូវ

ផ្អែកយេនឌ័ររបស់ពួកគេ។ ទោះជាយ៉ាងណា ដោយសារតួនាទីទាំងនេះ និងការពឹងផ្អែករបស់ពួកគេលើធនធានធម្មជាតិ ស្ត្រីជាញឹកញាប់មានការយល់ដឹងប្លែកពីគេមួយអំពីបរិស្ថានធម្មជាតិរបស់ពួកគេ។ ការសិក្សានានាបង្ហាញថា ស្ត្រីបង្ហាញកង្វល់កាន់តែខ្លាំងអំពីគ្រោះមហន្តរាយដែលបង្កឡើងដោយអាកាសធាតុជាងបុរសដែលខ្វល់ខ្វាយអំពីបញ្ហាបរិស្ថាន។ ហេតុដូចនេះ ស្ត្រីអាចដើរតួនាទីបែបស្ថាបនាមួយក្នុងការអភិរក្សាបរិស្ថាន ពោលគឺអ្វីមួយដែលជាញឹកញាប់ត្រូវបានមើលរំលង។ នៅក្នុងប្រទេសជាច្រើនក្នុងតំបន់អាស៊ីខាងត្បូង និងអាស៊ីអាគ្នេយ៍ដូចជាប្រទេសឥណ្ឌា នេប៉ាល់ ហ្វីលីពីន ស្ត្រីជនជាតិដើមភាគតិចដើរតួនាទីយ៉ាងសំខាន់មួយក្នុងការរក្សានិរន្តរភាពនិងគ្រប់គ្រងព្រៃឈើដែលមានសារៈសំខាន់សម្រាប់ការកាត់បន្ថយការប្រែប្រួលអាកាសធាតុការបន្សាំ និងការកាត់បន្ថយគ្រោះមន្តរាយ។

ស្ត្រីក៏ស្ថិតនៅជួរមុខផងដែរក្នុងការប្រយុទ្ធប្រឆាំងនឹងការប្រែប្រួលអាកាសធាតុ និងការជួយសហគមន៍របស់ពួកគេឱ្យបន្សាំនឹងការប្រែប្រួលបរិស្ថាន។ ក៏មានភស្តុតាកាន់តែច្រើនឡើងផងដែរដែលបង្ហាញថានៅទីណាដែលស្ត្រីត្រូវបានផ្តល់អំណាចឱ្យបង្កើតវេទិកាស្ថាប័នដែលពង្រីកមូលនិធិ ទីភ្នាក់ងារ និងឱកាសផ្ទាល់របស់ខ្លួនរបស់គ្រួសារនិងសហគមន៍របស់ពួកគេការណ៍នេះអាចបម្រើជាចំណុចចាប់ផ្តើមពោរពេញដោយអំណាចមួយសម្រាប់ការកសាងភាពធន់នឹងអាកាសធាតុឱ្យកាន់តែទូលំទូលាយថែមទៀត។

ក្នុងប្រទេសវៀតណាមតាមរយៈសហជីពស្ត្រីវៀតណាម(Viet Nam Women's Union) ស្ត្រីរៀបចំផែនការនិងរៀបចំវគ្គបណ្តុះបណ្តាលព័ត៌មានសម្រាប់ស្ត្រីផ្សេងទៀតនៅថ្នាក់ឃុំ។ ពួកគេសម្តែងរឿងអំពីការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ (DRR) ការបង្ការជំងឺ និងរៀបចំសកម្មភាពលើកកម្ពស់ការយល់ដឹងនៅក្នុងសហគមន៍របស់ពួកគេ។ស្ត្រីក៏ដើរតួនាទីផងដែរក្នុងការពង្រឹងផ្ទះរបស់ពួកគេទប់ទល់នឹងខ្យល់ព្យុះ។ ក្នុងប្រទេសកម្ពុជាស្ត្រីបានរាយការណ៍ថា ក្នុងពេលមានភាពរាំងស្ងួត ពួកគេខ្ចីប្រាក់ពីក្រុមសន្សំប្រាក់របស់ស្ត្រី ទៅឱ្យកូនប្រុសរបស់ខ្លួន ដើម្បីឱ្យពួកគេអាចស្វែងរកការងារធ្វើនៅរាជធានីភ្នំពេញ ឬធ្វើចម្ការ។ ទោះជាយ៉ាងណាក៏ដោយ អ្វីដែល មានសារៈសំខាន់ផងដែរនោះថាតើ ទីកន្លែងសមូហភាពទាំងនេះអាចក្លាយជាវេទិកាសម្រាប់ការលើកកម្ពស់ជីវភាពរបស់ស្ត្រីបានដោយរបៀបណា។

# លំហាត់

**លំហាត់ទី១៖ សំបុកពីងពាងសិទ្ធិមនុស្ស**

គោលបំណងចម្បងរបស់លំហាត់នេះគឺដើម្បីរំញោចអ្នកចូលរួមឱ្យមានការយល់ដឹងអំពីសារៈសំខាន់នៃសកលភាវូនីយកម្ម និងភាពមិនអាចចែកជាចំណែកបាននៃសិទ្ធិមនុស្ស។

**សម្ភារៈដែលតម្រូវឱ្យមាន៖** ក្រដាសគគី ប៊ិចហ្វឺតធំ ជ័រកៅស៊ូសម្រាប់បាញ់ជាតំណក់តូចៗ (Spray Gum) ប័ណ្ណ ខ្សែមួយដុំ ផ្ទាំងក្រដាសធំ និងប៊ិចហ្វឺតតូច (អ្នកក៏អាចប្រើក្តាខៀនធម្មតា និងហ្វឺតផងដែរប្រសិនបើត្រូវការ)។

**ដំណើរការ៖**

**ជំហានទី១៖** ស្នើអ្នកចូលរួមគ្រប់គ្នាឱ្យឈរជាជួរ។ អ្នកក៏អាចប្រើបន្ទប់សន្និសីទតុមូលស្តង់ដារផងដែរដែលអ្នកចូលរួមទាំងអស់អង្គុយនៅជុំវិញតុនោះ។ ប្រាប់ពួកគេថា ពួកគេត្រូវណែនាំខ្លួនឯង និងចែករំលែករឿងរ៉ាវសំខាន់បំផុតចំនួនពីរអំពីពួកគេ។

- រឿងអ្វីមួយដែលពួកគេត្រូវធ្វើដើម្បីបំពេញឬពង្រឹងអំណាចក្នុងជីវិត?
- រឿងមួយផ្សេងទៀត គឺអ្វីដែលបាត់បង់ឬត្រូវបានគេយកទៅបាត់ វានឹងធ្វើឱ្យពួកគេមានអារម្មណ៍ថាត្រូវបានគេដកហូតអំណាច/គ្មានជំនួយ?

រឿងរ៉ាវទាំងពីរនេះអាចមានមូលដ្ឋានលើតម្រូវការជាមូលដ្ឋាននានា ដូចជាអាហារ ទឹក ទីជម្រក សុខាភិបាល ការអប់រំ ការងារ និង/តម្រូវការជាយុទ្ធសាស្ត្រនានា ដូចជាការទទួលយកដោយសង្គម ចលតភាព ការបញ្ចេញមតិជាដើម។

បន្ទាប់មកកាន់ខ្សែមួយដុំអ្នកចូលរួមម្នាក់ៗណែនាំខ្លួនឯងក្នុងរបៀបដូចគ្នាហើយបោះដុំខ្សែនោះទៅកាន់មនុស្សម្នាក់ផ្សេងទៀតខណៈដែលអ្នកនៅតែកាន់កន្ទុយម្ខាងនៃខ្សែ។ ស្នើឱ្យមនុស្សម្នាក់នោះណែនាំខ្លួនគាត់ និងហុចដុំខ្សែនោះបន្តទៅកាន់មនុស្សម្នាក់ផ្សេងទៀត ខណៈដែលពួកគេនៅតែបន្តកាន់ខ្សែក្នុងដៃរបស់ពួកគេ។ ធ្វើរបៀបនេះដដែលៗរហូតអស់អ្នកចូលរួមទាំងអស់ ហើយនៅចុងបញ្ចប់ ត្រូវមានសំបុកខ្សែធំមួយ ដែលអ្នកចូលរួមទាំងអស់កាន់វា។

**ជំហានទី២៖** សរសេរចំណុចទាំងអស់ដែលមាននៅលើប័ណ្ណ ហើយភ្ជាប់ប័ណ្ណទាំងនោះនៅលើផ្ទាំងក្រដាសធំស/គគីឬសរសេរនៅលើក្តារខៀនជារង្វង់។ (សូមមើលរូប) បំលែងចំណុចទាំងនេះទៅជាឧទាហរណ៍ដែលកាន់តែមានអត្ថន័យ និងអាចអនុវត្តបានជាលក្ខណៈសកលដូចខាងក្រោម៖

- ត្រូវការការអប់រំ
- ត្រូវការបេបនីយកណ្ឌទឹក
- ត្រូវការសុខាភិបាលល្អ
- ត្រូវការមិត្តភក្តិ/គ្រួសារ
- ត្រូវការជីវភាពកាន់តែប្រសើរ
- ត្រូវការភាពសម្បូរបែបជាមូលដ្ឋាន
- ត្រូវការទីធ្លាទីផ្សារ
- ត្រូវការផ្ទះផ្ទាល់ខ្លួន
- ត្រូវការសន្តិសុខ
- ត្រូវការមានសេរីភាពធ្វើដំណើរទៅកន្លែងដែលខ្ញុំចង់ទៅ
- ត្រូវការមានសេរីភាពនិយាយស្តី អ្វីដែលខ្ញុំចង់និយាយ
- ត្រូវការចូលរួមក្នុងការធ្វើសេចក្តីសម្រេចចិត្តដែលជះឥទ្ធិពលដល់ខ្ញុំ
- ត្រូវការមានពេលសម្រាក លំហែ និងរីករាយ
- ត្រូវការមានលុយ/ទ្រព្យសម្បត្តិផ្ទាល់របស់ខ្លួន

**ជំហានទី៣៖** បន្ទាប់ពីអ្នកចូលរួមទាំងអស់ធ្វើកិច្ចការនេះរួចហើយ ចូរសួរពួកគេថាតើសំបុកពីងពាងដែលពួកគេបានធ្វើមានតំណាងភ្ជាប់ទៅកាន់ចំណុចប៉ុន្មាន។ សួរពួកគេថា៖ "តើមានចំណុចណាមួយនៅក្នុងក្រុមមានការពាក់ព័ន្ធគ្នាទៅវិញទៅមកដែរឬទេ? ឧទាហរណ៍តើចំណុចណាមួយមានផលប៉ះពាល់លើចំណុចមួយផ្សេងទៀត ឬមានផលប៉ះពាល់បញ្ច្រាសមកវិញដែរទេ?"។ ប្រសិនបើមាន តើមានអ្វីកើតឡើង៖

- ប្រសិនបើអ្នកណាម្នាក់មិនកាន់ខ្សែរបស់ពួកគេ នៅពេលនោះសំបុកពីងពាងទាំងមូលនឹងធូរ។ ការចូលរួមទាំងអស់គ្នាមានសារៈសំខាន់។
- ប្រសិនបើអ្នកណាម្នាក់ទាញចុងខ្សែរបស់គាត់ វាប៉ះពាល់សំបុកពីងពាងទាំងមូល។ គ្មានអ្នកណាម្នាក់គ្រប់គ្រងសំបុកពីងពាងនេះទេ។
- ប្រសិនបើមនុស្សពីរនាក់កំពុងទាញខ្សែទៅវិញទៅមកវាធ្វើឱ្យអ្នកចូលរួមផ្សេងទាំងអស់អាក់អន់ចិត្ត។មិនគួរមានក្រុមនិយមទេ

ស្នើឱ្យពួកគេគិតថា សំបុកពីងពាងគឺជាសង្គមទាំងមូល ហើយពន្យល់ពួកគេអំពីថាតើវិធានសំបុកពីងពាងនេះមានភាពប្រហាក់ប្រហែលគ្នាយ៉ាងដូចម្តេចទៅនឹងអ្វីកើតឡើងនៅក្នុងសង្គម។ ឥឡូវស្នើឱ្យអ្នកចូលរួមចាកចេញពីសំបុកពីងពាង និងមកកាន់ក្តារខៀនវិញ

**ជំហានទី៤៖** ឥឡូវសួរពួកគេថាតើមានចំណុចណាមួយក្នុងចំណោម

ចំណុចចំនួនពីរនៅលើក្តារខៀន គឺជាលក្ខខណ្ឌតម្រូវបំពេញបន្ថែមដែរឬទេដូចជាយើងមិនអាចមានមួយដោយគ្មានមួយទៀតបានទេ។ ឧទាហរណ៍វាពិបាកដែលមានការអប់រំដោយគ្មានចល័តភាពនិងវាលំបាកដែលមានចល័តភាពដោយគ្មានការគាំទ្រពីសង្គម។ ភ្ជាប់ទំនាក់ទំនងរវាងចំណុចទាំងនេះនៅលើក្តារខៀន។ ឥឡូវសួរពួកគេថា តើមានចំណុចបែបនេះផ្សេងទៀតណាមួយដែលមានអន្តរទំនាក់ទំនងដែរឬអត់។ ពួកគេអាចគូរបន្ទាត់/ព្រួញរវាងចំណុចបែបនេះនៅលើក្តារខៀនរហូតទាល់តែវាលេចចេញជាសំបុកពីងពាង។ (ឧទាហរណ៍អំពីដ្យាក្រាមចុងក្រោយមាននៅក្នុងរូបទី ៧)។

**ជំហានទី៥៖** ឥឡូវស្នើពួកគេឱ្យភ្ជាប់ទំនក់ទំនងសំបុកពីងពាងនេះជាមួយនឹងវិធានសង្គម/វិធានសំបុកពីងពាង ហើយគិតថា តើអត្ថប្រយោជន៍ទាំងនេះត្រូវបានបែងចែកយ៉ាងដូចម្តេចក្នុងចំណោមសង្គម។ សួរសំណួរដូចខាងក្រោម៖

- តើមានទំនាក់ទំនងណាមួយរវាងចំណុច/តម្រូវការទាំងនេះ និងសិទ្ធិមនុស្សដែលត្រូវបានទទួលស្គាល់ជាលក្ខណៈអន្តរជាតិដែរឬទេ?
- តើអ្វីកើតឡើងនៅពេលដែលមនុស្សម្នាក់មិនទទួលបានតម្រូវការ/សិទ្ធិរបស់គាត់?
- តើអ្វីកើតឡើងនៅពេលដែលមនុស្សម្នាក់ប្រមូលយកអត្ថប្រយោជន៍ទាំងអស់តែម្នាក់ឯង?
- តើមានទំនាក់ទំនងណាមួយរវាងវិធានសង្គម/វិធានសំបុកពីងពាង និងវិធីសាស្រ្តអភិវឌ្ឍន៍មនុស្សដែរឬទេ?

**រូបទី៨៖ សំបុកពីងពាងសិទ្ធិមនុស្ស**




ប្រភព៖ ផ្អែកលើលំហាត់ដែលត្រូវបានអនុវត្តដោយអាផ្វាធរក្នុងអំឡុងពេលបណ្តុះបណ្តាលអំពីការធ្វើឱ្យមានរំញោចយេនឌ័រនៅក្នុងកម្មវិធីគាំទ្រជនបទ Aga Khan (ប្រទេសឥណ្ឌា)

**លទ្ធផលនៃការរៀនសូត្រ៖** បញ្ចប់ការពិភាក្សាដោយនិយាយថា នេះគឺជាមូលហេតុដែលបញ្ហាទាំងនេះត្រូវបានធានាចំពោះយើងថាជាសិទ្ធិមនុស្ស និងនិយាយថា៖ "មនុស្សគ្រប់រូបដោយមិនគិតពីថ្នាក់ វណ្ណៈ ភេទ សាសនា ឬទីកន្លែងរស់នៅ ឬលំនៅឋាន មានសិទ្ធិទទួលបានទាំងអស់នេះដោយគ្មានការរើសអើង។ នេះគឺជាទស្សនាទាននៃសកលភាវូនីយកម្មសិទ្ធិមនុស្ស។ ហើយការពឹងផ្អែកគ្នាទៅវិញទៅមកនៃបញ្ហាទាំងនេះគឺជាមូលហេតុដែលសិទ្ធិមនុស្សត្រូវបានចាត់ទុកថាមានទំនាក់ទំនងទៅវិញទៅមកហើយដូច្នេះមិនអាចចែកជាចំណែកបានទេ"។

---

**លំហាត់ទី២៖** Power Walk

គោលបំណងដ៏សំខាន់របស់លំហាត់នេះគឺ ដើម្បីរំញោចអ្នកចូលរួមឱ្យស្វែងយល់អំពីតួនាទីនៃការស្ថាបនាសង្គម និងអំពីយេនឌ័រនៅក្នុងបរិបទមិនមានអ្នកណាម្នាក់ត្រូវបានទុកចោល (LNBO)។

**សម្ភារៈដែលតម្រូវឱ្យមាន៖** កន្លែងទំនេរធំ អាចជាទីធ្លាលំហរគ្រប់គ្រាន់សម្រាប់អ្នកចូលរួម ដើម្បីឱ្យពួកគេ អាចឈរជាជួរ និងដើរពី១២ទៅ ១៥ជំហានទៅមុខ។ ក្រដាស់តូចសរសេរពីឈុតឆាក សម្លេងតួ និងជបទឹក។

តួនាទី Power Walk គំរូ (ដោយផ្អែកលើបរិបទរបស់ប្រទេស)៖

> ស្ត្រីសមាជិកសភាអាយុ ៤៥ឆ្នាំ មកពីទីក្រុងធំមួយ
> បុរសកម្មកររោងចក្រអាយុ ៣៥ឆ្នាំ ដែលមានបញ្ហារាងកាយ
> បុរសកសិករអាយុ ៣៥ឆ្នាំ ដែលមានដីធំ និងធ្វើកសិកម្មដោយគ្រឿងចក្រ
> ស្ត្រីកសិករអាយុ ៤៥ឆ្នាំ ដែលមានដីតូច និងកូនបីនាក់
> អ្នកអាជីពដែលជាមនុស្សស្រីស្រលាញ់ស្រីអាយុ ៣០ឆ្នាំ ម្នាក់ដែលបម្រើការងារនៅក្រុមហ៊ុនអន្តរជាតិ (MNC) មួយ
> ស្ត្រីកម្មកររោងចក្រអាយុ៣០ឆ្នាំដែលមានកូន២នាក់រស់នៅក្នុងសំណង់អាណាធិបតេយ្យ
> បុរសជាមន្ត្រីរដ្ឋាភិបាលថ្នាក់ខ្ពស់អាយុ ៥០ឆ្នាំ ម្នាក់ដែលធ្វើការងារនៅក្រសួងហិរញ្ញវត្ថុ
> កុមារីអាយុ ១៥ឆ្នាំ ដែលថែទាំងបងប្អូននិងម្តាយដែលមានជំងឺ
> បុរសបើកបររថយន្តតាក់ស៊ីអាយុ ២៥ឆ្នាំ ដែលបានធ្វើអន្តោប្រវេសន៍ពីប្រទេសជិតខាង
> បុរសមេភូមិអាយុ ៦០ឆ្នាំ ដែលមានទំនាក់ទំនងនយោបាយល្អ

| គន្លឹះសម្រាប់គ្រូឧទ្ទេស | ប្រសិនបើពុំមានកន្លែងសរសេរ អ្នកអាចប្រើក្តារអុកដែលមានរូបផ្សេងៗនិងផ្តល់ទៅឱ្យអ្នកស្ម័គ្រចិត្តឱ្យបន្លាស់ទីរូបទាំងនោះ។ ចាប់ផ្តើមពីចុងទីមួយនៃក្តារអុកទៅដល់ផ្នែកផ្សេងទៀត។ |
|---|---|

## ដំណើរការ៖

**ជំហានទី១៖** នាំអ្នកចូលរួមទាំងអស់ទៅកាន់ទីធ្លា ចំហរ និងស្នើសុំឱ្យមានអ្នកស្ម័គ្រចិត្តចំនួន ១០នាក់។ ស្នើឱ្យអ្នកស្ម័គ្រចិត្តម្នាក់ចាប់យកក្រដាសតូច (ដែលមានសរសេរអំពីតួនាទីដែលត្រូវសម្តែង) ពីថានគោម។ ប្រាប់ពួកគេឱ្យរក្សាការសម្ងាត់សិននូវព័ត៌មានអំពីតួនាទីដែលត្រូវបានចាត់តាំងឱ្យពួកគេធ្វើនៅក្នុងក្រដាសតូចនោះ។

**ជំហានទី២៖** ស្នើអ្នកស្ម័គ្រចិត្តឱ្យចេញឆ្ងាយពីអ្នកចូលរួមផ្សេងទៀត។ ស្នើឱ្យពួកគេគិតស្រម៉ៃក្នុងចិត្តអំពីតួនាទីដែលត្រូវបានចាត់តាំងរបស់ខ្លួន ដោយគិតអំពីថា តើប្រភេទផ្ទះ និងទីកន្លែងអ្វីដែលពួកគេនឹងកំពុងរស់នៅ តើសម្ភារបរិក្ខា ប្រភេទអ្វីដែលពួកគេមាននៅផ្ទះ តើអ្វីនឹងជាគុណសម្បត្តិរបស់ការអប់រំ អាជីព ប្រាក់ចំណូលប្រចាំខែ មិត្តភាព និងឋានៈសង្គមរបស់ពួកគេ។

**ជំហានទី៣៖** បែងចែកអ្នកចូលរួមផ្សេងទៀតជាពីរក្រុម ហើយស្នើឱ្យពួកគេឈរជាពីរជួរនៅជួរម្ខាងម្នាក់ដែលបង្កើតបានជាផ្លូវសម្រាប់អ្នកស្ម័គ្រចិត្តដើរជាជួរត្រង់នៅចន្លោះកណ្តាលពួកគេ។ប្រាប់ពួកគេឱ្យសង្កេតមើលឥរិយាបថរបស់អ្នកស្ម័គ្រចិត្ត និងព្យាយាមទស្សទាយថា តើប្រូហ្វាលសង្គម និងយេនឌ័រដែលអាចកើតមានរបស់អ្នកនោះគឺជាអ្វី។

**ជំហានទី៤៖** ស្នើឱ្យអ្នកស្ម័គ្រចិត្តឈរជាជួរត្រង់នៅចន្លោះក្រុមទាំងពីរ (ពួកគេទាំងអស់ចាប់ផ្តើមដោយស្មើភាព)។ រក្សាដបទឹកមួយចំនួន (២ ទៅ ៣ដប) នៅម្ខាងទៀត។ គួរតែមានរយៈចម្ងាយប្រហែលពី ១២ទៅ១៥ជំហានរវាងអ្នកស្ម័គ្រចិត្តទាំងនោះ និងដប។

**ជំហានទី៥៖** ឥឡូវប្រាប់អ្នករាល់គ្នាថា អ្នកនឹងអានសេចក្តីអធិប្បាយមួយ ហើយប្រសិនបើអ្នកស្ម័គ្រចិត្តគិតថា សេចក្តីអធិប្បាយនេះត្រូវនឹងខ្លួនឯង ពួកគេបោះជំហានមួយជំហានមកមុខ អ្នកផ្សេងទៀតស្ថិតនៅកន្លែងខ្លួនឯងដដែល។ប្រាប់ពួកគេថាមិនមានចម្លើយខុសឬចម្លើយត្រូវនោះទេ ហើយដើម្បីបង្កើតបានជាជម្រើសមួយដោយផ្អែកលើអ្វីដែលពួកគេគិត ចូរអនុវត្តតួនាទីដែលត្រូវបានចាត់តាំងដល់ពួកគេឱ្យបានប្រសើរបំផុតនៅក្នុងប្រទេសរបស់ខ្លួន។

| គំរូសេចក្តីអធិប្បាយ Power Walk (កែសម្រួលទៅតាមបរិបទប្រទេស)៖ |
|---|
| ខ្ញុំញ៉ាំអាហារពីរពេលក្នុងមួយថ្ងៃដោយមិនគិតពីរដូវ |
| ខ្ញុំមិនស្ថិតក្នុងគ្រោះថ្នាក់នៃការបៀតបៀនដោយនគរបាល |
| ខ្ញុំមានសម្ភារបរិក្ខាបឋម ទាំងអស់ដូចជាទឹកបង្គន់អគ្គិសនី។ល។ នៅក្នុងផ្ទះរបស់ខ្ញុំ |
| ខ្ញុំអាចជួបមន្ត្រីរដ្ឋាភិបាលណាម្នាក់ទៅតាមការតម្រូវ |
| ខ្ញុំមានឯកសារទាំងអស់ដែលតម្រូវឱ្យមានដើម្បីទទួលបានអត្ថប្រយោជន៍សន្តិសុខសង្គមរបស់រដ្ឋាភិបាល |
| ខ្ញុំអាចជះឥទ្ធិពលលើសេចក្តីសម្រេចចិត្តក្នុងសហគមន៍/សង្កាត់របស់ខ្ញុំ |
| ខ្ញុំមិនស្ថិតក្នុងគ្រោះថ្នាក់នៃការបៀតបៀនឬរំលោភបំពានផ្លូវភេទទេ |
| ខ្ញុំអាចរៀបការទៅតាមការចង់បាន និងនៅពេលដែលខ្ញុំចង់ |
| ខ្ញុំមានការគ្រប់គ្រងលើហិរញ្ញវត្ថុគ្រួសាររបស់ខ្ញុំ |
| ខ្ញុំមានលទ្ធភាពទទួលបានហិរញ្ញវត្ថុ និងកម្ចី |
| ខ្ញុំទទួលបានប្រាក់ឈ្នួលអប្បបរមា/ប្រាក់ចំណូលទៅតាមច្បាប់ |
| ខ្ញុំបានបញ្ចប់ការអប់រំថ្នាក់មហាវិទ្យាល័យ |
| ខ្ញុំមិនត្រូវធ្វើការនៅផ្ទះច្រើនជាងមួយម៉ោងក្នុងមួយថ្ងៃនោះទេ |
| ខ្ញុំអាចធ្វើដំណើរទៅសាលារៀន/មានលទ្ធភាពផ្តល់ការអប់រំនៅសាលារៀនដល់កូនរបស់ខ្ញុំ |
| ខ្ញុំមានលទ្ធភាពល្អក្នុងការទទួលបានសេវាសុខភាព |
| ខ្ញុំមិនទំនងជានឹងប្រឈមនឹងអំពើហិង្សាក្នុងគ្រួសារទេ |

| |
|---|
| ខ្ញុំអាចធ្វើដំណើរទៅទីកន្លែងណា និងនៅពេលណាដែលខ្ញុំចង់ |
| ខ្ញុំមានពេលវេលាសម្រាក និងរីករាយនឹងសកម្មភាពកម្សាន្តរបស់ខ្ញុំ |

**ជំហានទី៦៖** ពីបញ្ជីខាងលើ ចូរជ្រើសរើសសេចក្តីអធិប្បាយចំនួន ៨ដែលសាកសមបំផុតចំពោះអ្នកចូលរួមឬបរិបទរបស់ប្រទេស។ ឥឡូវអានសេចក្តីអធិប្បាយម្តងមួយៗ។ អានសេចក្តីអធិប្បាយបន្ទាប់បានលុះត្រាតែអ្នកចូលរួមទាំងអស់បានបង្កើតជម្រើសរបស់ពួកគេរួចហើយ។បន្ទាប់ពីសេចក្តីអធិប្បាយទាំងអស់ត្រូវបានអាន ស្នើអ្នកស្ម័គ្រចិត្តឱ្យរក្សានៅទីកន្លែងដែលពួកគេស្ថិតនៅ។

**ជំហានទី៧៖** ឥឡូវស្នើឱ្យអ្នកចូលរួមដែលពួកគេទាំងអស់គ្នាគិតថានឹងអាចទៅយកជបទឹកបាន។ នៅពេលដែលពួកគេអាចកំណត់មនុស្សពី ២ ទៅ ៤នាក់រួចហើយ ចូរស្នើឱ្យពួកគេទស្សទាយប្រូហ្វាយរបស់មនុស្ស ដោយផ្អែកលើការឆ្លើយតបទៅនឹងសេចក្តីអធិប្បាយរបស់ពួកគេ។

**ជំហានទី៨៖** នៅពេលអ្នកចូលរួមបានបញ្ចប់ការទស្សទាយទៅលើមនុស្សទាំងនោះ ចូរស្នើឱ្យពួកគេកំណត់អត្តសញ្ញាណរបស់អ្នកទាំងនោះ និងប្រូហ្វាលរបស់មនុស្សទាំងបីនាក់ចុងក្រោយ ដែលពួកគេគិតថាមានឱកាសតិចតួចក្នុងការទទួលជបទឹក។ ស្នើឱ្យពួកគេលើកឡើងនូវហេតុផលសម្រាប់ការទស្សទាយរបស់ខ្លួន។ ឥឡូវស្នើអ្នកស្ម័គ្រចិត្តទាំងអស់ឱ្យចែករំលែកអ្វីដែលជាតួនាទីរបស់ពួកគេ និងមូលហេតុដែលពួកគេស្ថិតនៅក្រោយគេ។ ធ្វើដូចគ្នានេះដដែលជាមួយអ្នកចូលរួមផ្សេងទៀត ដោយឆ្លុះបញ្ចាំងពីតួនាទីសង្គម និងអ្វីដែលជាបុព្វហេតុដែលបង្កឱ្យមនុស្សទៅដល់មុនគេ ឬស្ថិតនៅក្រោយគេ។

**ជំហានទី៩៖** បញ្ចប់វគ្គតាមរយៈការស្នើឱ្យអ្នកចូលរួមទាំងអស់ឆ្លើយសំណួរខាងក្រោម៖

ក ) តើពួកគេគិតថា តើអ្នកគ្រប់គ្នាអាចមានលទ្ធភាពស្មើគ្នាក្នុងការទៅយកជបទឹកដែលត្រូវបានផ្តល់ជូនពួកគេដែរឬទេ និងថា តើអ្នកសម្របសម្រួលកំពុងធានាឱ្យបាននូវគោលការណ៍ HRBA នៃការមិនរើសអើងដែរឬទេ ?

ខ ) តើអ្នកដែលស្ថិតនៅខាងក្រោយគេពិតជាទទួលខុសត្រូវលើតួនាទីរបស់ពួកគេដែរឬទេ ? ប្រសិនបើមិនទទួលខុសត្រូវទេ តើដោយសារអ្វី ?

គ ) តើអាចធ្វើអ្វីបានដើម្បីដោះស្រាយស្ថានភាពនេះ និងនាំយកមកនូវការមិនរើសអើង និងសមភាព ?

**លទ្ធផលនៃការរៀនសូត្រ៖** បញ្ចប់ការពិភាក្សាតាមរយៈការនិយាយថា៖ "ការផ្តល់លទ្ធភាពដោយចំហរក្នុងការទទួលបានធនធាន និងឱកាស (ឬអត្ថប្រយោជន៍ពីកម្មវិធី) នឹងមិនធានាថា មនុស្សគ្រប់គ្នាអាចយកបានធនធាន និងឱកាសទាំងនោះឡើយ។ ប្រការសំខាន់នោះគឺត្រូវកំណត់ថា តើអ្នកណាគឺជាអ្នកដែលត្រូវបានគេទុកចោលក្រោយគេបំផុត និងថា តើមកពីហេតុអ្វី។ ក្រោយមករៀបចំផែនការដើម្បីធានាថាពួកគេទាំងអស់គ្នាមានលទ្ធភាពទទួលបានស្មើគ្នា និងថា មិនមានអ្នកណាម្នាក់ត្រូវបានទុកចោលទេ"។

## លំហាត់ទី៣៖ ទស្សនាទានយេនឌ័រ

គោលបំណងដ៏សំខាន់របស់លំហាត់នេះគឺដើម្បីនាំមកនូវការយល់ដឹងរួមមួយក្នុងចំណោមអ្នកចូលរួមអំពីទស្សនាទានយេនឌ័រ។

**សម្ភារៈដែលតម្រូវឱ្យមាន៖** ក្រដាសតូចពីសំណៅឯកសារ១ (រៀបចំឯកសារមួយឈុតសម្រាប់ក្រុមនីមួយៗដោយប្រើប្រាស់ពុម្ពអក្សរទំហំធំលើក្រដាសទំហំA2។រួមបញ្ចូលការពន្យល់នៅក្នុងក្រដាសតូចទាំងនោះ។ ផ្ទាំងក្រដាសស/គគី និងជ័រកៅស៊ូ។

**ដំណើរការ៖**

**ជំហានទី១៖** បែងចែកអ្នកចូលរួមជាគូដែលមានគ្នា ២នាក់ (ឬ ៣នាក់) ហើយផ្តល់ជូនពួកគេនូវក្រដាសតូចមួយសន្លឹកនៅលើឈុតណាមួយនៃឈុតឯកសារដែលត្រូវបានផ្តល់ជូននៅក្នុងសំណៅឯកសារ១។ ចូរប្រាកដថា ក្រុមទាំងអស់មានឯកសារមួយឈុត ប្រសិនបើមានមនុស្សបន្ថែមទៀតសូមបញ្ចូលគេទៅក្នុងក្រុមដែលមានស្រាប់។

**ជំហានទី២៖** ស្នើឱ្យអ្នកចូលរួមពិភាក្សាអំពីទស្សនាទានក្នុងក្រដាសតូចទាំងនោះក្នុងចំណោមពួកគេផ្ទាល់។ ផ្តល់ពេលវេលា ១០នាទីដើម្បីពិភាក្សា ហើយក្រោយមកផ្តល់ការពន្យល់បែបងាយៗអំពីវាក្យស័ព្ទ ឧទាហរណ៍ជាក់ស្តែង ព្រមទាំងលក្ខណៈពិសេសខុសគ្នា/បន្ថែមណាមួយដែលពួកគេដឹង។

**ជំហានទី៣៖** ឥឡូវស្នើឱ្យពួកគេចែករំលែកចម្លើយរបស់ពួកគេទៅកាន់ក្រុមធំ និងបំពេញបន្ថែមចម្លើយទាំងនោះតាមរយៈការបន្ថែមព័ត៌មានពីសំណៅឯកសារ ១។

**លទ្ធផលនៃការរៀនសូត្រ៖** ខណៈដែលមានពិភាក្សាអំពីឈុតឯកសារនីមួយៗចូរបិទក្រដាសតូចនៅលើផ្ទាំងក្រដាសសធំ (បិទនៅជាប់ជញ្ជាំង) សម្រាប់វាក្យស័ព្ទដែលត្រូវឱ្យមនុស្សគ្រប់គ្នាអាចមើលឃើញបានពេញមួយថ្ងៃនៃការបណ្តុះបណ្តាល។ ចូររក្សាការឆ្លុះបញ្ចាំងអំពីវាក្យស័ព្ទទាំងនោះ សម្រាប់តម្រូវការពេលក្រោយ ក្នុងអំឡុងពេល/វគ្គបណ្តុះបណ្តាលផ្សេងទៀត។

### លំហាត់ទី៤៖ អ៊ីស្តូក្រាមអំពីការប្រែប្រួលអាកាសធាតុ

គោលបំណងដ៏សំខាន់របស់លំហាត់នេះគឺដើម្បីណែនាំប្រធានបទអំពីការប្រែប្រួលអាកាសធាតុ និងឱ្យអ្នកចូលរួមដឹងអំពីដំណើរការនៃការប្រែប្រួលអាកាសធាតុ។

**គន្លឹះសម្រាប់គ្រូឧទ្ទេស**

សម្រាប់អ្នកចូលរួមពីតំបន់អាកាសធាតុផ្សេងៗគ្នា អ្នកក៏អាចធ្វើលំហាត់ជាក្រុមតូចៗផងដែរ តាម រយៈការកំណត់អ្នកសម្របសម្រួលម្នាក់សម្រាប់ក្រុមនីមួយៗ និង ពន្យល់ពួកគាត់សង្ខេបអំពីដំណើរការនេះ។

**រូបទី៩៖ ដ្យាក្រាមអ៊ីស្តូក្រាមគំរូ**

| STRESS | BEFORE 10 YEARS | PRESENT STATUS |
|---|---|---|
|  | | |
|  | | |
|  | | |
|  | | |
|  | | |

ប្រភព៖ ដកស្រង់ចេញពីឧបករណ៍ ប៉ាន់ប្រម៉ាណភាពងាយរងគ្រោះ និងភាពធន់សហគមន៍មូលដ្ឋាន (Mahila Housing Sewa Trust ឆ្នាំ២០១៦)

**សម្ភារៈដែលតម្រូវឱ្យមាន៖** ផ្ទាំងក្រដាសផ្ទាំងស/គគីធំដែលមានប័ណ្ណរូបភាពអំពីការផ្លាស់ប្ដូរ និងផលប៉ះពាល់ផ្សេងៗដែលត្រូវបានសង្កេតឃើញមានពាក់ព័ន្ធនឹងអាកាសធាតុ ដែលបិទនៅលើប័ណ្ណទាំងនោះ ដូចដែលមានបង្ហាញក្នុងរូបទី៨ និងបិច។

**ដំណើរការ៖**

**ជំហានទី១៖** ចាប់ផ្ដើមជាមួយនឹងការពិភាក្សាអំពីជាតុអាកាសនៅថ្ងៃនេះថាតើជាតុអាកាសកើតមានដូចទៅនឹងសព្វមួយដងនៃរដូវរបស់វាឬវាខុសពីរដូវរបស់វា។សួរអ្នកចូលរួមថាតើពួកគេបាននឹងកំពុងសង្កេតមើលធាតុអាកាសប្រែប្រួលបែបនេះដែរឬទេក្នុងពេលណាមួយនៅពេលឥឡូវនេះ។

**ជំហានទី២៖** បន្ទាប់ពីមានការលើកឡើងពីឧទាហរណ៍មួយចំនួនរួចហើយ លាផ្ទាំងក្រដាសផ្ទាំងស/គគីធំ នៅលើជញ្ជាំង ហើយ

**រូបទី១០៖ ឧទាហរណ៍អំពីចម្លើយ**

| សីតុណ្ហភាព | ១០ឆ្នាំមុន | ស្ថានភាពបច្ចុប្បន្ន |
|---|---|---|
|  | កន្លងមកមិនដែលមានលើសពី ៤០អង្សាសេ | បច្ចុប្បន្ន វាកើនលើសពី ៤៥អង្សាសេក្នុងរដូវក្ដៅ |
| | រដូវក្ដៅខ្លាំងមានត្រឹមតែ ៣ខែប៉ុណ្ណោះ | រយៈពេលរដូវក្ដៅខ្លាំងបានកើនឡើងដល់ ៥ខែ |
| | វាធ្លាប់ត្រជាក់នៅពេលល្ងាច | សីតុណ្ហភាពមិនធ្លាក់ចុះទេរហូតទាល់តែពេលយប់ជ្រៅ |
| | បុណ្យណូអែល (ឬពិធីបុណ្យក្នុងមូលដ្ឋានណាមួយ) នឹងពិតជាត្រជាក់ | វាមិនត្រជាក់ខ្លាំងទេក្នុងអំឡុងពេលថ្ងៃ |

ប្រាប់ពួកគេថា អ្នកចង់កត់ត្រាការប្រែប្រួលទាំងនេះជាលក្ខណៈប្រព័ន្ធជាងនេះ (អ្នកក៏អាចប្រើប្រាស់ក្តារខៀនដោយមានការសរសេរចំណងជើងផងដែរ ប្រសិនបើក្រុមមានការជជែកគ្នាច្រើន)។
**ជំហានទី៣៖** ចង្អុលទៅកាន់រូបភាពដែលបង្ហាញអំពីហេតុការណ៍អាកាសធាតុដំបូង និងសីតុណ្ហភាព ហើយសួរពួកគេថា តើការផ្លាស់ប្តូរសីតុណ្ហភាពអ្វីដែលពួកគេបានសង្កេតឃើញនៅក្នុងតំបន់នេះក្នុងរយៈពេល១០ឆ្នាំចុងក្រោយនេះ(ប្រសិនបើសមាជិកក្រុមមានទាំងក្មេងនិងមនុស្សចាស់វានឹងប្រសើរក្នុងការសួរពីការផ្លាស់ប្តូរសីតុណ្ហភាពក្នុងរយៈពេល ២០ ទៅ ៣០ឆ្នាំចុងក្រោយ)។ កត់ត្រាទុកការផ្លាស់ប្តូរដែលពួកគេលើកឡើង។ នាំផ្លូវអ្នកចូលរួមឱ្យផ្តល់ចម្លើយនៅក្នុងសូចនាករដូចដែលត្រូវបានប្រើប្រាស់ក្នុងសំណៅឯកសារ ២ នៅពេលណាដែលអាចធ្វើបាន។ ចម្លើយគួរតែមានដូចក្នុងតារាងខាងក្រោម៖
**ជំហានទី៤៖** ដូចគ្នានេះដែរ បន្តទៅកាន់ប្រធានបទផ្សេងទៀត។ ជួនកាល អ្នកចូលរួមអាចនិយាយអំពីបញ្ហាផ្សេងទៀតក្នុងអំឡុងពេលកំពុងពិភាក្សា។វាមិនអីនោះទេ គ្រាន់តែធ្វើឱ្យប្រាកដថាអ្នកបានកត់ត្រាវានៅក្នុងប្រអប់ត្រឹមត្រូវហើយមិនលើកឡើងចំណុចនេះឡើងវិញទេ។

**ជំហានទី៥៖** នៅពេលបញ្ចប់ដ្យាក្រាមហើយចូរស្នើឱ្យអ្នកចូលរួមឆ្លុះបញ្ចាំងរួមគ្នាអំពីករណីដូចគ្នា។ សួរសំណួរដូចជា៖

- តើអ្នកពិតជាសង្កេតឃើញមាននិន្នាការណាមួយនៅក្នុងការប្រែប្រួលធាតុអាកាសក្នុងរយៈពេលប៉ុន្មានឆ្នាំនេះមែនទេ?
- តើវាគ្រាន់តែជាធាតុអាកាសធម្មតា ឬតើវាជះឥទ្ធិពលដល់ជីវិតនិងជីវភាពរស់នៅរបស់អ្នក?
- តើហេតុអ្វីបានជាពួកគេគិតថាការណ៍នេះកំពុងកើតមានឡើង?

**លទ្ធផលនៃការរៀនសូត្រ៖** បញ្ចប់ការពិភាក្សាដោយនិយាយថានោះគឺជាអ្វីដែលត្រូវបានយល់ថាជាការប្រែប្រួលអាកាសធាតុពេលគឺជា"ការប្រែប្រួលស្ថានភាពធាតុអាកាសរដូវកាលជាក់លាក់ក្នុងតំបន់មួយ។ ខណៈដែលបុព្វហេតុធម្មជាតិក៏ចូលរួមចំណែកដល់សកម្មភាពរបស់មនុស្សនេះដែរដែលជាការទទួលខុសត្រូវចម្បងចំពោះ ការប្រែប្រួលអាកាសធាតុ"។

## លំហាត់ទី៥៖ ទស្សនាទាន CCDRR និងភាពធន់

គោលបំណងដ៏សំខាន់របស់លំហាត់នេះ គឺដើម្បីបញ្ជាក់បំភ្លឺអំពីទស្សនាទានមួយចំនួនក្នុងចំណោមទស្សនាទានស្នូលដែលពាក់ព័ន្ធនឹង CCDRR និងភាពធន់។

**សម្ភារដែលតម្រូវឱ្យមាន៖** ប៉េងប៉ោង ម្ជុល កូនបាល់កៅស៊ូ ដុំកង់រ៉ឺស័រ (កង់រ៉ឺស័រលោតចុះឡើង) ទឹកមួយកែវ ក្រដាស ក្តារកិន ប្លាស្ទិក។

**ដំណើរការ៖**
**ជំហានទី១៖** បែងចែកអ្នកចូលរួមជាគូដែលមាន ២ ឬ ៣នាក់ ហើយផ្តល់ជូនពួកគេនូវសំណៅទស្សនាទានមួយពីសំណៅឯកសារ។ ស្នើពួកគេឱ្យអាននិយមន័យរបស់ទស្សនាទាននោះ ហើយកំណត់ឧទាហរណ៍មួយដើម្បីពន្យល់អំពីទស្សនាទាននោះ។ ផ្តល់ពេលវេលាដល់ពួកគេ ១០ នាទីដើម្បីពិភាក្សា ។

**ជំហានទី២៖** ឥឡូវស្នើពួកគេឱ្យមកចូលរួមជាមួយក្រុមធំ និងចែករំលែកឧទាហរណ៍គ្នា។ ផ្តល់សុពលភាព ឬកែតម្រូវឧទាហរណ៍បើអាចធ្វើបាន។

**ជំហានទី៣៖** ប្រាប់ពួកគេថា ជួនកាលមិនមានវាក្យស័ព្ទជាក់លាក់នោះទេសម្រាប់ពាក្យការប្រឈមភាពងាយរងគ្រោះភាពធន់។ល។ ក្នុងភាសាអាស៊ីភាគច្រើន ហើយជួនកាលវាមានការលំបាកក្នុងការផ្សព្វផ្សាយពាក្យទាំងនេះនៅថ្នាក់ឃុំ។ ដើម្បីពន្យល់អំពីកត្តានេះ យើងអាចប្រើប្រាស់ឧទាហរណ៍មួយចំនួន។

**ជំហានទី៤៖** យកទឹកមួយកែវ និងក្រដាសមួយចំណែកចេញមក។ ឥឡូវសួរអ្នកចូលរួមថាតើអ្វីនឹងកើតឡើងប្រសិនបើអ្នកបង្ហូរទឹកទៅលើអ្វីមួយ។ ប្រតិបត្តិកម្មជាទូទៅនឹងថា របស់នោះនឹងទទឹក។ ឥឡូវសួរពួកគេថាតើអ្វីនឹងកើតឡើងប្រសិនបើអ្នកបង្ហូរទឹកទៅលើដី។ តើវានឹងជះឥទ្ធិពលទៅលើក្រដាសនេះយ៉ាងដូចម្តេច? វានឹងមិនជះឥទ្ធិពលទៅលើក្រដាសទេ។ទោះជាយ៉ាងណាប្រសិនបើក្រដាសត្រូវបានដាក់នៅកន្លែងដែលទឹកកំពុងហូរនៅពេលនោះ វានឹងធ្វើឱ្យក្រដាសនោះទទឹកជោគ។ ពន្យល់ថា នេះគឺជាអ្វីដែលបង្ហាញពីអត្ថន័យនៃពាក្យ "ការប្រឈម (Exposure)" ពេលគឺជាស្ថានភាពនៃការដាក់អ្វីមួយនៅទីកន្លែងណាមួយដែលឱកាសនៃទទួលរងការប៉ះពាល់អ្វីមួយដោយគ្មានអ្វីគ្របមានកម្រិតខ្ពស់។ ឥឡូវសួរពួកគេថាតើអ្វីនឹងកើតឡើងប្រសិនបើអ្នកដាក់ប្លាស្ទិកនៅលើក្រដាស ហើយបន្ទាប់មកអ្នកបង្ហូរទឹក។ លទ្ធផលនឹងថា ក្រដាសនឹងមិនទទឹក ឬមិនជោគ។ ពន្យល់ថា នេះគឺជាអ្វីដែលគេហៅថា "ភាពងាយរងប៉ះពាល់ (Susceptibility)" ពេលគឺភវនីយភាពនៃការទទួលរងឥទ្ធិពលឬគ្រោះថ្នាក់ពីអ្វីជាក់លាក់មួយ។ដូច្នេះ នៅក្នុងឧទាហរណ៍ខាងលើ ក្រដាសដែលមិនមានអ្វីគ្របលើវា ងាយរងគ្រោះទៅនឹងគ្រោះថ្នាក់។

**ជំហានទី៥៖** ឥឡូវបង្ហាញក្តារកិនហើយសួរថាប្រសិនបើអ្នកបង្ហូរទឹកទៅលើក្រដាសដែលគ្មានអ្វីគ្របពីលើ និងក្តារកិន តើនឹងមានអ្វីកើត

ឡើង។ ប្រតិកម្មនឹងថា ទាំងក្រដាស និងក្តារកិននឹងទទឹក ប៉ុន្តែថា តើក្តាររឹងនឹងទទួលជោគកម្រិតណានោះនឹងអាស្រ័យលើបរិមាណទឹកដែលចាក់បង្ហូរលើវា។ ទឹកតិចនឹងមិនធ្វើឱ្យក្តារកិនខូចទ្រង់ទ្រាយទេ ខណៈដែលក្រដាសអាចខូចរូបរាង។ ចូរពន្យល់ថា នេះគឺជាអត្ថន័យរបស់ពាក្យ "ភាពងាយរងគ្រោះ (Vulnerability)" ពោលគឺជាកម្រិតនៃភាពងាររងប៉ះពាល់ទៅនឹងឥទ្ធិពល។ភាពងាយរងគ្រោះជាញឹកញាប់ក៏មានមូលដ្ឋានលើបរិមាណនៃការប្រឈមផងដែរ។

**ជំហានទី៦៖** ឥឡូវយកម្សៅ និងបាល់រុញ និងប៉េងប៉ោងចេញមក។ សួរពួកគេថាតើអ្វីនឹងកើតឡើងនៅពេលអ្នកយកម្សៅចាក់បាល់រុញ និងប៉េងប៉ោង។ បាល់រុញស្រូបម្សៅ ខណៈដែលប៉េងប៉ោងផ្ទុះនៅពេលចាក់។ ចូរពន្យល់ថា ប្រសិនបើការចាក់ត្រូវបានគេចាត់ទុកថាជា "គ្រោះមហន្តរាយ (Disaster)" នៅពេលនោះ "ភាពធន់ (Resilience)" គឺជាសមត្ថភាពរបស់យើងក្នុងការស្រូបយកបញ្ហា។ដូច្នេះ ខណៈដែលប៉េងប៉ោងមិនអាចរស់បានពីគ្រោះមហន្តរាយ បាល់រុញអាចស្រូបបញ្ហាបាន ហើយដូច្នេះវាមានភាពធន់ជាង។ ចូរនិយាយបន្ថែមថា នេះគឺជាអ្វីដែលយើងមានបំណងសម្រេចបានតាមរយៈការកសាងភាពធន់ និងបង្កើនលទ្ធភាពនៃការស្តារឡើងវិញ។ ចូរប្រើប្រាស់ដុំកងរ៉ឺស័ររស់ (កងរ៉ឺស័រលោតចុះឡើង) ដើម្បីពន្យល់អំពីទស្សនាទាននៃការ "ត្រលប់មករកភាពដើមវិញ (Bouncing back)" ឬការវិលត្រលប់ទៅរកស្ថានភាពដើមវិញ។

លទ្ធផលនៃការរៀនសូត្រ៖ បញ្ចប់វគ្គបណ្តុះបណ្តាលជាមួយនឹងឧទាហរណ៍អំពីជំងឺ។ ចូរពន្យល់រឿងរ៉ាវនៅពេលមនុស្សពីរនាក់ចេញទៅផ្សារ ហើយមេឃក៏ភ្លៀងភ្លាម ក្រោយមកអ្នកទាំងពីរក៏ប្រឈមនឹងទឹកភ្លៀង។ ទោះជាយ៉ាងណា ប្រសិនបើមនុស្សម្នាក់ក្នុងចំណោមអ្នកទាំងពីរនាក់បើកឆ័ត្រទទូរនៅពេលនោះលទ្ធភាពនៃការដែលគាត់អាចប្រឈមនឹងការទទឹកជោគនឹងថយចុះ ហើយដូច្នេះនឹងមានភាពងាយរងប៉ះពាល់ទៅនឹងការមានជំងឺ។ លើសពីនេះទៀត បើទោះជាពួកគេទាំងពីរនាក់ទទឹកក្តី នៅពេលនោះ អាយុ សុខភាពទូទៅ និងភាពរឹងមាំ។ល។របស់ពួកគេ នឹងជាប៉ារ៉ាម៉ែត្រដែលនឹងកំណត់ថាតើពួកគេមានភាពងាយរងគ្រោះទៅនឹងការធ្លាក់ខ្លួនឈឺយ៉ាងដូចម្តេច។ប៉ារ៉ាម៉ែត្រដូចគ្នាទាំងនេះរួមជាមួយនឹងសមត្ថភាព (ភាពធន់) ដូចជាលទ្ធភាពទទួលបានឱសថបនីយកណ្ឋវេជ្ជសាស្ត្រ អាហារូបត្ថម្ភ និងផ្សេងៗទៀត នឹងកំណត់ថា តើអ្នកណាអាចវិលត្រលប់មករកសុខភាពល្អវិញបានលឿនកម្រិតណា។

| គន្លឹះសម្រាប់គ្រូឧទ្ទេស | ប្រសិនបើមានកុំព្យូទ័រយួរដៃ អ្នកក៏អាចធ្វើលំហាត់នេះលើប្រព័ន្ធផងដែរដោយប្រើប្រាស់ឯកសារចម្លងរូបភាពជាស្លាយ ដើម្បីរក្សាទុកឯកសារ។ |
|---|---|

## លំហាត់ទី៦៖ ប័ណ្ណផ្គូរផ្គងសម្រាប់តួនាទីយេនឌ័រ និងផលប៉ះពាល់ខុសៗគ្នានៃ CCDRR

គោលបំណងដ៏សំខាន់របស់លំហាត់នេះគឺដើម្បីរំញោចអ្នកចូលរួមឱ្យយល់ដឹងពីតួនាទីយេនឌ័រដែលមានស្រាប់ និងផលប៉ះពាល់ខុសៗគ្នានៃ CCDRR។

**សម្ភារដែលតម្រូវឱ្យមាន៖** ប័ណ្ណដែលមានសរសេរចូលអំពីតួនាទីយេនឌ័រផ្សេងៗ (សូមមើលសំណៅឯកសារ ៤ សម្រាប់តួនាទីផ្សេងៗ។ ចូរកុំសរសេរយេនឌ័រនៅលើប័ណ្ណ)។ ផ្ទាំងក្រដាសស/គគីធំ ជ័រកៅស៊ូ និងស្កុតក្រដាស។

### ដំណើរការ៖

**ជំហានទី១៖** បិទផ្ទាំងក្រដាសស/គគីធំនៅលើជញ្ជាំងដោយប្រើស្កុតក្រដាស។ គូសបែងចែកជាតារាងជួរឈរ និងជួរដេកដូចដែលមានបង្ហាញខាងក្រោម។

**ជំហានទី២៖** បែងចែកប័ណ្ណតួនាទីយេនឌ័រជូនអ្នកចូលរួម។ ស្នើឱ្យពួកគេដាក់ប័ណ្ណនៅក្នុងតារាងរបស់បុរសឬតារាងរបស់ស្ត្រីដោយផ្អែកលើយេនឌ័រដែលមានការពាក់ព័ន្ធនឹងតួនាទីនោះជាទូទៅនៅក្នុងប្រទេសរបស់ពួកគេ។ ប្រាប់ពួកគេថា ពួកគេត្រូវពិភាក្សាជាក្រុម ហើយក្រោយមកបិទប័ណ្ណនៅតារាងជួរដេកដែលពាក់ព័ន្ធនឹងវិស័យជាក់លាក់។ ផ្តល់ពេលវេលាឱ្យពួកគេ ១៥នាទី ដើម្បីបិទប័ណ្ណទាំងអស់នេះ។

**ជំហានទី៣៖** ឥឡូវសួរពួកគេថា តើពួកគេគិតថា ការប្រែប្រួលអាកាសធាតុនឹងប៉ះពាល់ដល់វិស័យជាក់លាក់នោះយ៉ាងដូចម្តេច។ ឧទាហរណ៍ ទឹក ឬសន្តិសុខស្បៀង ឬថាមពល។ ក្រោយមកសួរពួកគេថា តើផលប៉ះពាល់នេះនឹងជះឥទ្ធិពលដល់បុរសយ៉ាងដូចម្តេច ហើយតើផលប៉ះពាល់នេះនឹងជះឥទ្ធិពលដល់ស្ត្រីយ៉ាងដូចម្តេច។សរសេរចម្លើយជាចំណុចតូចៗនៅលើប្រអប់តារាងរៀងៗខ្លួន។ ធ្វើដូច្នេះដដែលសម្រាប់វិស័យមួយចំនួនទៀត ហើយក្រោយមកផ្តល់ជូនពួកគេនូវសំណៅឯកសារ ៤ មួយច្បាប់ដើម្បីអានបន្ថែម។ ប្រាប់ពួកគេថា ពួកគេនឹងពិភាក្សាកិច្ចការនេះលម្អិតជាងនេះនៅក្នុងវគ្គបន្ទាប់។

**រូបភាពទី ១-១១ : គំរូសម្រាប់លំហាត់ទី ៦**

| វិស័យ | | តួនាទីយេនឌ័រ | ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ | ភាពងាយរងគ្រោះទាក់ទងនឹងយេនឌ័រ |
|---|---|---|---|---|
| ទឹក | បុរស | | | |
| | ស្ត្រី | | | |
| ស្បៀង | បុរស | | | |
| | ស្ត្រី | | | |
| ចំណីសត្វ | បុរស | | | |
| | ស្ត្រី | | | |
| ថាមពល | បុរស | | | |
| | ស្ត្រី | | | |

រូបទី១១៖ គំរូសកម្មភាព ៦

**លទ្ធផលនៃការរៀនសូត្រ៖** បញ្ចប់វគ្គដោយការពង្រឹងចំណុចដែលថា តួនាទីយេនឌ័រដែលមានស្រាប់ក្នុងសង្គម នឹងបង្កឱ្យបុរស និងស្ត្រី ទទួលរងផលប៉ះពាល់ខុសៗគ្នាពីការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ។

### លំហាត់ទី៧៖ ក្របខ័ណ្ឌការងារ Moser សម្រាប់ការបង្កើតផែនទីហានិភ័យអាកាសធាតុទាក់ទងនឹងយេនឌ័រ

គោលបំណងដ៏សំខាន់របស់លំហាត់នេះគឺដើម្បីទទួលបានការយល់ដឹងជាមូលដ្ឋានអំពីអន្តរទំនាក់ទំនងរវាងការប្រែប្រួលអាកាសធាតុ និងតួនាទីយេនឌ័រដែលត្រូវបានចាត់តាំងឱ្យស្ត្រី។

**សម្ភារដែលតម្រូវឱ្យមាន៖** ផ្ទាំងក្រដាស់ធំ និងប៊ិច។

**ដំណើរការ៖**

**ជំហានទី១៖** បែងចែកអ្នកចូលរួមជា ៤ក្រុម។ ព្យាយាមបង្កើតក្រុមដែលសមាជិកក្រុមមានភាពប្រហាក់ប្រហែលគ្នាឱ្យបានច្រើនតាមដែលអាចធ្វើបាន។ ឥឡូវស្នើឱ្យក្រុមនីមួយៗគិតអំពីប្រភេទអាជីពពិសេសមួយរបស់ស្ត្រីវ័យកណ្តាល ដែលសមាជិកក្រុមភាគច្រើនដឹងឮពីរបៀបរស់នៅរបស់គាត់។ពួកគេអាចជ្រើសរើសអាជីពនេះពីប្រភេទនានាដូចជាកសិករអ្នកនេសាទអ្នកឃ្វាលសត្វអ្នកលក់ដូរតាមផ្លូវ កម្មករធ្វើការតាមផ្ទះ កម្មកររោងចក្រ។ ស្នើឱ្យពួកគេនិយាយអំពីទីតាំងភូមិសាស្ត្ររបស់ស្ត្រីរូបនេះ។

**ជំហានទី២៖** ឥឡូវស្នើឱ្យក្រុមនីមួយៗសរសេរអំពីសកម្មភាពប្រចាំថ្ងៃដែលស្ត្រីរូបនេះធ្វើក្នុងអំឡុងពេល ២៤ម៉ោង។ ប្រាប់ពួកគេឱ្យសសេរសកម្មភាពទាំងអស់នេះនៅទូទាំងរដូវទាំងអស់ដែលស្ថិតក្នុងវិស័យការងាររបស់ស្ត្រីរូបនេះ។

**ជំហានទី៣៖** ឥឡូវស្នើឱ្យក្រុមសរសេរសកម្មភាពទាំងនេះនៅក្នុងដ្យាក្រាមក្នុងទម្រង់ខាងក្រោម៖

ពន្យល់ថា ភាពខុសគ្នារវាងកម្មភាពផ្សេងៗដូចជាផលិតកម្ម ឬការបង្កើតប្រាក់ចំណូលគឺជាសកម្មភាពដែលជាចុងក្រោយផ្តល់ប្រាក់ជូនពួកគេដូចជាការធ្វើស្រែចម្ការការចិញ្ចឹមពពែចិញ្ចឹមសត្វ យកទឹកដោះ លក់ត្រី កាត់ដេរ ការគ្រប់គ្រងចំណីសត្វ ការប្រមូលអនុផលព្រៃឈើ ការចិញ្ចឹមឃ្មុំ។ល។ ស្នើឱ្យពួកគេរួមបញ្ចូលសកម្មភាពដែលស្ត្រីមិនទទួលបានប្រាក់ឈ្នួលដោយផ្ទាល់ ប៉ុន្តែចូលរួមចំណែកដល់ប្រាក់ចំណូលរួមក្នុងគ្រួសាររបស់ពួកគេ។ សកម្មភាពការងារក្នុងផ្ទះរួមមានសកម្មភាពទាំងឡាយណាដែលត្រូវបានតម្រូវឱ្យគ្រប់គ្រងគ្រួសាររបស់ពួកគេដូចជាចម្អិនអាហារបោកសម្អាត លាងសម្អាត ដងទឹក ថែទាំកូន ថែទាំមនុស្សចាស់ ថែទាំអ្នកមានជំងឺ។ល។ សកម្មភាពសង្គមរាប់បញ្ចូលទាំងការចូលរួមក្នុងសកម្មភាពរួមនានាដូចជាពិធីបុណ្យ អាពាហ៍ពិពាហ៍ បុណ្យសព កិច្ចប្រជុំសាធារណៈ។ល។

ស្នើឱ្យពួកគេស្វែងរកការបញ្ជាក់ប្រសិនបើចាំបាច់។ ឧទាហរណ៍អ្នកចូលរួមជាញឹកញាប់គិតថាសកម្មភាពរបស់ស្ត្រីដូចជាសម្អាតរោងគោ ឬយកទឹកដោះសត្វថាជាការងារក្នុងគ្រួសារ ដោយហេតុថា ពួកគេឃើញថាវាជាសកម្មភាពផលិតកម្ម។ ប្រាប់ពួកគេឱ្យរក្សាទុកតារាងជួរឈរមួយជួរនៅចន្លោះក្រុមនីមួយៗដោយសារតារាងជួរឈរនោះនឹងត្រូវបានប្រើប្រាស់នៅផ្នែកក្រោយនៃលំហាត់។

## រូបទី១២៖ គំរូក្របខ័ណ្ឌការងារ Moser សម្រាប់សកម្មភាព ៧

| ម៉ោង | សកម្មភាពពាក់ព័ន្ធនឹងផលិតកម្ម/ប្រាក់ចំណូល | | ការបន្តពូជ/ការងារក្នុងគ្រួសារ | | ការកម្សាន្ត/តួនាទីសង្គម | |
|---|---|---|---|---|---|---|
| ៤ព្រឹកដល់ ៨ព្រឹក | | | | | | |
| ៨ព្រឹកដល់ ១២ថ្ងៃត្រង់ | | | | | | |
| ១២ថ្ងៃត្រង់ដល់ ៤ល្ងាច | | | | | | |
| ៤ល្ងាចដល់ ៨យប់ | | | | | | |
| ៨យប់ដល់ ១២យប់ | | | | | | |

**ជំហានទី៤៖** ស្នើឱ្យអ្នកចូលរួមវិភាគដ្យាក្រាមដែលបានលេចឡើង និងសរសេរចូលបញ្ហា។ ឧទាហរណ៍៖

- ការងារផលិតកម្មរបស់ស្ត្រីមិនត្រូវបានគេទទួលស្គាល់ និងគ្មានប្រាក់ឈ្នួល។
- ជារួមស្ត្រីធ្វើការងារច្រើនជាង និងមានពេលវេលាតិចតួចសម្រាប់ការកម្សាន្ត។
- ស្ត្រីដើរតួនាទីតិចតួចឬមិនបានដើរតួនាទីក្នុងសកម្មភាពគ្រប់គ្រងសហគមន៍ ហើយនេះគឺជាតំបន់ជាទីដែលការសម្រេចចិត្តត្រូវធ្វើឡើង ហើយការសម្រេចចិត្តទាំងនេះប៉ះពាល់ជីវិតរបស់ពួកគេ។

**ជំហានទី៥៖** ឥឡូវស្នើឱ្យពួកគេសរសេរអំពីហានិភ័យផ្សេងៗនៅក្នុងតំបន់របស់ពួកគេ។ការណ៍នេះគួរតែជាការសង្ខេបវគ្គមុនស្តីពីហានិភ័យអាកាសធាតុ។ នៅពេលពួកគេបានកំណត់ហានិភ័យទាំងអស់រួចហើយស្នើឱ្យពួកគេគូសចំណាំថាតើហានិភ័យមួយណានឹងប៉ះពាល់ដល់តួនាទីផ្សេងៗរបស់ស្ត្រី និងថាតើវិស័យអ្វីដែលពួកគេមើលឃើញនៅក្នុងតួនាទីរបស់ស្ត្រីដែលពួកគេអាចពិភាក្សាអំពី DRR ការបន្សាំនឹងការប្រែប្រួលអាកាសធាតុ និងសកម្មភាពភាពធន់។ ពួកគេក៏អាចកំណត់ហានិភ័យអាកាសធាតុជាច្រើនទៀតផងដែរសម្រាប់ការងារដូចគ្នានេះ។ការណ៍នេះអាចត្រូវបានរួមបញ្ចូលទៅក្នុងដ្យាក្រាមមុនដូចដែលមានបង្ហាញនៅក្នុងឧទាហរណ៍បន្ទាប់៖

## រូបទី១៣៖ គំរូក្របខ័ណ្ឌការងារ Moser ដែលត្រូវបានធ្វើបច្ចុប្បន្នភាពជាមួយហានិភ័យអាកាសធាតុ

| ម៉ោង | សកម្មភាពពាក់ព័ន្ធនឹងផលិតកម្ម/ប្រាក់ចំណូល | ហានិភ័យអាកាសធាតុប៉ះពាល់ដល់ការងារ | ការបន្តពូជ/ការងារក្នុងគ្រួសារ | ហានិភ័យអាកាសធាតុប៉ះពាល់ដល់ការងារ | ការកម្សាន្ត/តួនាទីសង្គម | ហានិភ័យអាកាស/សកម្មភាពអាកាសធាតុ |
|---|---|---|---|---|---|---|
| ៤ព្រឹក ដល់ ៨ព្រឹក | | | ឌ. ដងទឹក | ស្រ្គួសទឹក | | |
| ៨ព្រឹកដល់ ១២ថ្ងៃត្រង់ | ឌ. ដាក់ចំណីឱ្យគោ | កម្តៅ ស្រ្គួសទឹក | | | ឌ. ថែទាំអ្នកមានជំងឺ | ហានិភ័យសុខភាព |
| ១២ថ្ងៃត្រង់ ដល់ ៤ល្ងាច | ឌ. ធ្វើស្រែ | កម្តៅ ស្រ្គួសទឹក | | | ឌ. ការចូលរួមក្នុងកិច្ចប្រជុំរបស់សហគមន៍ | ការរៀបចំផែនការសម្រាប់ DRR |
| ៤ល្ងាច ដល់ ៨យប់ | ឌ. កាត់ដេរ | កម្តៅ ទឹកជំនន់ | ឌ. ចម្អិនអាហារ | កម្តៅ ស្រ្គួសថាមពល | ឌ.ការចូលរួមក្នុងកិច្ចប្រជុំរបស់ស្ត្រី | ការរៀបចំ ផែនការសម្រាប់ការប្រែប្រួលអាកាសធាតុ |
| ៨យប់ ដល់ ១២យប់ | | | | | ឌ. ដេក | កម្តៅ ស្រ្គួសថាមពល |

**ជំហានទី៦៖** ឥឡូវស្នើឱ្យពួកគេពិភាក្សាអំពីចំណុចខាងក្រោមនៅក្នុងក្រុមរបស់ពួកគេ និងបង្ហាញការពិភាក្សានេះជូនក្រុមធំនៅក្នុងទម្រង់ដែលបានស្នើ៖

**FIGURE 1-14: GROUP DISCUSSION TEMPLATE**

តើសកម្មភាពផលិតកម្មណាមួយរបស់ស្ត្រីដែលទទួលរងប៉ះពាល់ខ្លាំងបំផុតពីការប្រែប្រួលអាកាសធាតុ?

តើសកម្មភាពការងារក្នុងគ្រួសារណាមួយរបស់ស្ត្រីដែលទទួលរងប៉ះពាល់ខ្លាំងបំផុតពីការប្រែប្រួលអាកាសធាតុ?

តើសកម្មភាពផលិតកម្មទាំងនេះទទួលរងប៉ះពាល់យ៉ាងដូចម្តេច? តើសកម្មភាពការងារក្នុងគ្រួសារទាំងនេះទទួលរងប៉ះពាល់យ៉ាងដូចម្តេច?

តើអ្នកគិតថាស្ត្រីទទួលរងប៉ះពាល់ខ្លាំងដោយសារការប្រែប្រួលអាកាសធាតុឬទេ? ហេតុអ្វី?

**លទ្ធផលនៃការរៀនសូត្រ៖** បញ្ចប់ដោយការសរុបសេចក្តីអំពីចំណុចដែលថា៖ "ការប្រែប្រួលអាកាសធាតុនឹងប៉ះពាល់យ៉ាងខ្លាំងដល់ស្ត្រីជាពិសេសស្ត្រីដែលមកពីសហគមន៍ក្រីក្រនិងសហគមន៍ដែលជួបការលំបាក។មានតម្រូវការចាំបាច់ដែលត្រូវរួមបញ្ចូលស្ត្រីដែលមកពីសហគមន៍បែបនេះនៅក្នុងដំណើរការ DRR និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ/ដំណើរការភាពធន់ដើម្បីឱ្យការប៉ាន់ប្រម៉ាណពីតម្រូវការកាន់តែមានភាពប្រាកដនិយមហើយផែនការក្នុងមូលដ្ឋានកាន់តែមានការរួមបញ្ចូលយេនឌ័រ"។ ដូចគ្នានេះដែរប្រាប់ពួកគេថាCarolineMoserបានបង្កើតក្របខ័ណ្ឌការងារនេះឡើងក្នុងឆ្នាំ១៩៧៩ សម្រាប់វិភាគយេនឌ័រ ហើយយើងកំពុងប្រើប្រាស់កំណែដែលត្រូវបានកែសម្រួលឱ្យមានភាពសាមញ្ញសម្រាប់ធ្វើជាឯកសារយោងរបស់យើង។

**គន្លឹះសម្រាប់គ្រូឧទ្ទេស**

ជំនួសឱ្យការស្នើពួកគេឱ្យអានករណីសិក្សាទាំងនេះ អ្នកក៏អាចបង្ហាញពួកគេនូវខ្សែភាពយន្តខ្លីៗទាំងនេះនិងការឆ្លុះបញ្ចាំងផងដែរ។ បែងចែកពួកគេជាក្រុមដែលមានគ្នា២នាក់ជំនួសឱ្យ៣នាក់ហើយចែករំលែកតំណភ្ជាប់សម្រាប់វីដេអូខ្លីទាំងនេះដើម្បីមើលតាមទូរស័ព្ទដៃ។

a) នាងគឺជាការផ្លាស់ប្តូរ ដែលអាចមើលបានតាមរយៈ https://youtu.be/1FNOk84DUB8 (ករណីព្រៃឈើនៅប្រទេសនេប៉ាល់)

b) SWaCH Pune Seva Sahakari Sanstha ដែលអាចមើលបានតាមរយៈ https://www.youtube.com/watch?v=ybhX9e0K8KY (ករណីការគ្រប់គ្រងសំណល់នៅប្រទេសឥណ្ឌា)

## លំហាត់ទី៨៖ ការពិនិត្យមើលករណីសិក្សាសម្រាប់ស្ត្រីជាភ្នាក់ងារនៃការផ្លាស់ប្តូរ

គោលបំណងដ៏សំខាន់របស់លំហាត់នេះគឺដើម្បីរំលេចតួនាទីវិជ្ជមានដែលស្ត្រីអាចធ្វើបាននៅក្នុងការកសាងភាពធន់នឹងការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ។

**សម្ភារដែលតម្រូវឱ្យមាន៖** ឯកសារករណីសិក្សាពីសំណៅឯកសារ ៥។

**ដំណើរការ៖**

**ជំហានទី១៖** បែងចែកអ្នកចូលរួមចេញជា ៣ក្រុម ហើយផ្តល់ជូនពួកគេនូវឯកសារករណីសិក្សាពីសំណៅឯកសារ ៥ ដើម្បីអាន និងពិភាក្សា។ ផ្តល់ពេលជូនពួកគេ ១៥នាទីសម្រាប់ធ្វើកិច្ចការនេះ។

**ជំហានទី២៖** ឥឡូវស្នើឱ្យពួកគេពិភាក្សាជាពិសេសអំពីសំណួរខាងក្រោម៖

ក) តើពួកគេមើលឃើញតួនាទីរបស់ស្ត្រីនៅក្នុងគម្រោងទាំងនេះយ៉ាងដូចម្តេច?

ខ) តើតួនាទីទាំងនេះមានភាពខុសគ្នាយ៉ាងដូចម្តេចពីតួនាទីយេនឌ័រដែលមានស្រាប់?

គ) តើគម្រោងទាំងនេះដោះស្រាយភាពងាយរងគ្រោះទាក់ទងនឹងយេនឌ័រយ៉ាងដូចម្តេច?

ឃ) តើមានសមាសធាតុវិធីសាស្ត្រ HRBA/LNOB ណាមួយត្រូវបានរួមបញ្ចូលក្នុងគម្រោងទាំងនេះដែរឬទេ?

**ជំហានទី៣៖** ផ្តល់ពេលវេលាជូនពួកគេ ៣០នាទី ដើម្បីពិភាក្សាសំណួរទាំងនេះ និងហើយឱ្យពួកគេមកផ្តោតអារម្មណ៍លើក្រុមធំវិញ។ ផ្តល់ពេលឱ្យក្រុមនីមួយៗ ៥នាទី ដើម្បី ធ្វើបទបង្ហាញរបស់ពួកគេ។

**លទ្ធផលនៃការរៀនសូត្រ៖** បញ្ចប់តាមរយៈការសង្ខេបថា៖ "ស្ត្រីក៏ស្ថិតនៅជួរមុខនៃការប្រយុទ្ធប្រឆាំងនឹងការប្រែប្រួលអាកាសធាតុ និងជួយសហគមន៍របស់ពួកគេឱ្យបន្សាំនឹងការប្រែប្រួលបរិស្ថានផងដែរ។ភស្តុតាងកាន់តែច្រើនក៏កំពុងបង្ហាញផងដែរថានៅទីកន្លែង

ណាដែលស្ត្រីត្រូវបានផ្តល់ភាពអង់អាចឱ្យបង្កើតវេទិកាស្ថាប័ននានា ដែលពង្រីកមូលនិធិ ទីភ្នាក់ងារ និងឱកាសផ្ទាល់ខ្លួនរបស់ពួកគេ របស់គ្រួសាររបស់ពួកគេ និងរបស់សហគមន៍របស់ពួកគេការណ៍នេះអាចបម្រើជាចំណុចចាប់ផ្តើមដ៏ពោរពេញដោយអំណាចមួយសម្រាប់ការកសាងភាពធន់នឹងអាកាសធាតុកាន់តែមានភាពទូទៅថែមទៀត”។

## ធ្វើតេស្តចំណេះដឹងរបស់អ្នក

| សំណួរ សេចក្តីអធិប្បាយ | ត្រូវ | ខុស |
|---|---|---|
| ១. សិទ្ធិមនុស្សត្រូវបានធានាដោយរដ្ឋាភិបាល ហើយដូច្នេះអនុវត្តចំពោះតែប្រជាពលរដ្ឋប៉ុណ្ណោះ។ | | ✓ |
| ២. សិទ្ធិមនុស្សមួយចំនួនមានសារៈសំខាន់ជាងសិទ្ធិមនុស្សផ្សេងទៀត។ | | ✓ |
| ៣. កំណើនសេដ្ឋកិច្ចគឺជាគន្លឹះចំពោះការអភិវឌ្ឍ ហើយនឹងដោះស្រាយរាល់ទម្រង់នៃវិសមភាពទាំងអស់។ | | ✓ |
| ៤. ការប្រែប្រួលអាកាសធាតុនឹងប៉ះពាល់ដល់វិសមភាពប្រាក់ចំណូលខ្លាំងជាងទម្រង់វិសមភាពផ្សេងទៀត។ | | ✓ |
| ៥. ស្ត្រីមានភាពងាយរងគ្រោះទៅនឹងការប្រែប្រួលអាកាសធាតុខ្លាំងជាង | ✓ | |
| ៦. ស្ត្រីនិងកុមារីទាំងអស់នឹងទទួលរងផលប៉ះពាល់ស្មើគ្នាដោយសារការប្រែប្រួលអាកាសធាតុ។ | | ✓ |
| ៧. ទិន្នផលស្រូវនៅតំបន់អាស៊ីនឹងកើនឡើងដោយសារការកើនឡើងកម្តៅពិភពលោក។ | | ✓ |
| ៨. DRR និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុគឺជាពាក្យដូចគ្នា ហើយអាចប្រើជំនួសគ្នាបាន។ | | ✓ |
| ៩. ស្ត្រី និងកុមារីទំនងជាមានអត្រាស្លាប់ខ្ពស់ជាង ១០ដងធៀបនឹងបុរសក្នុងអំឡុងកើតមានគ្រោះមហន្តរាយ។ | ✓ | |
| ១០. ហិរញ្ញវត្ថុអាកាសធាតុនឹងមិនប៉ះពាល់ដល់ហិរញ្ញវត្ថុអភិវឌ្ឍន៍ទេ។ | | ✓ |

## អានបន្ថែម


1) Aguilar Revelo, L. (2009). Training Manual on Gender and Climate Change. IUCN, UNDP and GGCA. Retrieved from https://portals.iucn.org/library/sites/library/files/documents/2009-012.pdf
2) Dankelman, I. (2016). Action not words: Confronting Gender Inequality through Climate Change Action and Disaster Risk Reduction in Asia: An overview of progress in Asia with evidence from Bangladesh, Cambodia and Vietnam. UN Women Regional Office for Asia and the Pacific. Retrieved from http://www.wocan.org/sites/default/files/Action-NotWords_CCDRR_130317-s.pdf
3) Global Gender and Climate Alliance. (2016). Gender and Climate Change: A closer look at existing evidence. WEDO, Oak Foundation, GGCA. Retrieved from https://wedo.org/wp-content/uploads/2016/11/GGCA-RP-FINAL.pdf
4) Nellemann, C., Verma, R., and Hislop, L. (2011). Women at the frontline of climate change: Gender risks and hopes. A Rapid Response Assessment. United Nations Environment Programme. Retrieved from https://www.ipcc.ch/apps/njlite/ar5wg2/njlite_download2.php?id=9719
5) OHCHR. (2015). Understanding Human Rights and Climate Change. Office of the High Commissioner for Human Rights. Retrieved from https://www.ohchr.org/Documents/Issues/ClimateChange/COP21.pdf
6) Oppenheimer, M., M. Campos, R.Warren, J. Birkmann, G. Luber, B. O'Neill, and K. Takahashi. (2014). Emergent Risk and key vulnerabilities. In: Climate Change 2014: Impacts, Adaptation, and Vulnerability. Part A: Global and. Cambridge University Press. Retrieved from https://www.ipcc.ch/site/assets/uploads/2018/02/WGIIAR5-Chap19_FINAL.pdf

**TRAINOR'S NOTES**

MODULE ____ SESSION PLAN ____ PAGE ____

AGENDA

REMINDERS

## TRAINOR’S GRID NOTES

MODULE ____ SESSION PLAN ____ PAGE ____

AGENDA

REMINDERS

យេនឌ័រ និង
ការប្រែប្រួលអាកាសធាតុ

# HANDOUTS

# ម៉ូឌុល ១៖

# 1

## ឯកសារមេរៀនទី១៖ ទស្សនាទានយេនឌ័រ និងបច្ចេកសព្ទ

### ភេទ និងយេនឌ័រ

**ភេទ** សំដៅលើលក្ខណៈកំណត់ពីកំណើតដែលជាទូទៅ គឺភេទប្រុស ឬភេទស្រី។ ភេទទាំងពីរនេះមានមូលដ្ឋានចម្បងលើសេនេទិចអាណាតូមីកាយវិភាគសាស្ត្រសរីរសាស្ត្រនិងសមត្ថភាពបន្តពូជ។ វាជាកត្តាទូទៅ និងធម្មជាតិ (មនុស្សកើតមកជាមួយវា)។ វានឹងគ្មានការប្រែប្រួលឡើយបើគ្មានការព្យាបាលដោយវេជ្ជសាស្ត្រ និង/ឬការវះកាត់។

**យេនឌ័រ** សំដៅលើបណ្ដុំតួនាទី និងការទទួលខុសត្រូវ ដែលត្រូវបានបង្កើតឡើងដោយសង្គម ដែលមានការពាក់ព័ន្ធនឹងភាពជាកុមារី និងកុមារា ឬភាពជាស្ត្រី និងបុរស ហើយនៅក្នុងវប្បធម៌ខ្លះមានភេទទីពាឬភេទផ្សេងទៀត។យេនឌ័ររួមបញ្ចូលទាំងលក្ខណៈនិងឱកាសសេដ្ឋកិច្ច សង្គម នយោបាយ និងវប្បធម៌ ដែលពាក់ព័ន្ធនឹងក្រុមមនុស្សមួយចំនួនដែលសំដៅលើភេទនិងចំណង់ផ្លូវភេទរបស់ពួកគេ។

ដោយត្រូវបានរៀនសូត្រទៅតាមពេលវេលាដោយសារដំណើរការលក្ខខណ្ឌសង្គមតួនាទីយេនឌ័រមានភាពខុសគ្នាខ្លាំងក្នុងសង្គមវប្បធម៌ និងអំឡុងពេលប្រវត្តិសាស្ត្រផ្សេងៗ ហើយតួនាទីយេនឌ័រក៏ពឹងផ្អែកលើកត្តាសង្គមនិងសេដ្ឋកិច្ច អាយុ ការអប់រំ ជាតិពន្ធុនិងសាសនាផងដែរហើយបើទោះជាចាក់ស្រេះយ៉ាងជ្រៅក៏ដោយក៏តួនាទីយេនឌ័រអាចត្រូវបានផ្លាស់ប្ដូរទៅតាមពេលវេលាផងដែរដោយសារតម្លៃ និងបទដ្ឋានសង្គមមិនផ្លាស់ប្ដូរ។

ឧទាហរណ៍៖ មានតែស្ត្រីប៉ុណ្ណោះដែលអាចផ្ដល់កំណើតដល់កូននិងបំបៅដោះកូន។ នេះគឺជា ភាពខុសគ្នាពាក់ព័ន្ធនឹងភេទ។ ម្យ៉ាងវិញទៀតការរំពឹងទុកបុរសថាជាអ្នកផ្ដល់សេដ្ឋកិច្ចដល់គ្រួសារហើយការរំពឹងទុកស្ត្រីថាជាអ្នកផ្ដល់ការថែទាំ គឺជាបទដ្ឋាយេនឌ័រមួយ បើទោះជាប្រៅឡង់ក្នុងវប្បធម៌ជាច្រើនបានបង្ហាញថាវាមិនមានភាពសកលក៏ដោយ។

#### ចំណុចដែលត្រូវអនុវត្តៈ

នៅពេលកើត ភាពខុសគ្នាក្នុងលក្ខណៈជីវសាស្ត្ររវាងកុមារា និងកុមារ គឺភេទរបស់ពួកគេ។ ទោះជាយ៉ាងណា លក្ខណៈជីវសាស្ត្រទាំងនេះមិនមានលក្ខណៈបែបនេះទាំងស្រុងឡើយ ហើយមានបុគ្គលដែលមានលក្ខណៈភេទប្រុស និងភេទស្រីទាំងពីរតែម្ដង។

- ខណៈដែលមនុស្សចម្រើនធំជាត់ សង្គមផ្ដល់តួនាទី លក្ខណៈ ឱកាស ឯកសិទ្ធិ និងសិទ្ធិផ្សេងៗគ្នាដល់ពួកគេ ដែលនៅចុងបញ្ចប់បង្កើតបានជាភាពខុសគ្នាផ្នែកសង្គមរវាងបុរសនិងស្ត្រី។
- និន្នាការផ្លូវភេទ៖ ខណៈដែលជាទូទៅនិន្នាការផ្លូវភេទសំដៅដល់ការទាក់ទាញផ្លូវភេទ ឬអារម្មណ៍ស្រើបស្រាល វាក៏រួមបញ្ចូលទាំងអត្តសញ្ញាណផ្លូវភេទឥរិយាបថផ្លូវភេទនិងចំណង់ផ្លូវភេទផងដែរ។

### អ្នកប្ដូរភេទ និងភាពចម្រុះប្រសព្វ

**អ្នកប្ដូរយេនឌ័រ** (Transgender) គឺជាពាក្យមួយដែលសំដៅលើបុគ្គលដែលមិនមានអត្តសញ្ញាណក្នុងប្រភេទភេទ ដែលត្រូវបានកំណត់នៅពេលកើត ឬអត្តសញ្ញាញ ឬឥរិយាបថរបស់ពួកគេមិនស្ថិតនៅក្នុងបទដ្ឋានយេនឌ័រតាមផ្នត់គំនិតសង្គម។

**អន្តរភេទ** សំដៅលើបម្រែបម្រួលជីវសាស្ត្រក្នុងលក្ខណៈភេទ រួមទាំងក្រូម៉ូសូម ក្រពេញភេទ និង/ឬប្រដាប់ភេទ ដែលមិនអាចឱ្យបុគ្គលម្នាក់ត្រូវបានកំណត់ថាជាស្រី/ប្រុសនៅពេលកើត។ កត្តាទាំងនេះរួមមានមនុស្សស្រីស្រលាញ់ស្រី មនុស្សប្រុសស្រលាញ់ប្រុស មនុស្សទ្វេភេទ មនុស្សស្រលាញ់មនុស្សគ្រប់ភេទ និងមនុស្សប្ដូរភេទ។

**អ្នកប្ដូរភេទ**សំដៅលើមនុស្សដែលកំណត់អត្តសញ្ញាណទាំងស្រុងទៅលើតួនាទីយេនឌ័រដែលផ្ទុយពីភេទកំណើតហើយព្យាយាមរស់នៅជាអចិន្ត្រៃយ៍ជាមួយនឹងតួនាទីយេនឌ័រដែលខ្លួនចូលចិត្ត។មនុស្សប្ដូរភេទអាចមានបំណងប្ដូរប្រដាប់ភេទផងដែរ (ដែលអាចឬមិនអាចពាក់ព័ន្ធនឹងការព្យាបាលអ័រមូន ឬការវះកាត់)។

**ភាពចម្រុះប្រសព្វ** (Intersectionality) មានវិសាលភាពលើសពីសញ្ញាណបែបប្រពៃណីនៃយេនឌ័រគោលពីរពោលគឺបុរសនិងស្ត្រីហើយសម្លឹងមើលទម្រង់នៃការរើសអើងសង្គមផ្សេងទៀតដែលរួមបញ្ចូលគ្នា ត្រួតស៊ីគ្នា ឬប្រសព្វគ្នាជាមួយការរើសអើងយេនឌ័រដែលមានស្រាប់។ភាពចម្រុះប្រសព្វ ទទួលស្គាល់ថា កត្តាកំណត់អត្តសញ្ញាណ (ឧ. "ស្រី" និង "ពិការ") មិនមានឯករាជ្យភាពពីគ្នាឡើយ និងថា កត្តាកំណត់អត្តសញ្ញាណប្រាប់អត្តសញ្ញាណផ្សេងទៀតដែលជាញឹកញាប់បង្កើតបានជាប្រមូលផ្ដុំការកៀបសង្កត់ដ៏ស្មុគស្មាញមួយ។ ការប្រើប្រាស់ក្របខ័ណ្ឌអន្តរវិស័យភាពមានន័យថាជាការទទួលស្គាល់ថា មនុស្សម្នាក់ឬមនុស្សមួយក្រុមបានទទួលរងប៉ះពាល់ដោយការរើសអើងមួយចំនួន ហើយជាញឹកញាប់ជួបប្រទះនូវប្រភេទកៀបសង្កត់មួយចំនួនដូចជាជាតិសាសន៍ ថ្នាក់ វណ្ណៈ កុលសម្ព័ន្ធ អត្តសញ្ញាណយេនឌ័រ និន្នាការផ្លូវភេទ សាសនារបស់ពួកគេ និងកត្តាកំណត់អត្តសញ្ញាណផ្សេងទៀត។

ឧទាហរណ៍៖ និយាយបែបសាមញ្ញ ការណ៍នេះមានន័យថា ការរើសអើងដែលប្រឈមដោយស្ត្រីពិការ មិនអាចបំបែកចេញពីគ្នាដោយផ្អែកលើលទ្ធភាព និងយេនឌ័ររបស់នាងបានឡើយប៉ុន្តែថា

ការរើសអើងពីរប្រភេទនេះមិនត្រឹមតែកើនឡើងប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបង្កើនការធ្វើឱ្យមនុស្សម្នាក់នេះស្ថិតក្នុងបញ្ហាលំបាកកាន់តែខ្លាំងឡើង។ ឧទាហរណ៍មួយផ្សេងទៀតអំពីភាពចម្រុះប្រសព្វ អាចសម្លឹងមើលទៅលើរបៀបដែលដៃគូ ជាស្ត្រីភេទ មានសិទ្ធិស្របច្បាប់ក្នុងការសុំកូនមកចិញ្ចឹម និងការចាក់បញ្ចូលមេជីវិតឈ្មោលខណៈដែលជាញឹកញាប់មានការសុំកូនមកចិញ្ចឹមតែមួយប៉ុណ្ណោះដែលមានចំពោះដៃគូជាបុរសភេទ។

### ចំណុចដែលត្រូវអនុវត្ត៖

- ការអង្កេត/បញ្ជីសំណួរទាំងអស់គួររួមបញ្ចូលជម្រើសភេទទី៣ក្រៅពីភេទស្រី/ភេទប្រុស (ឧ. "ផ្សេងទៀត/មិនមាន" "អត្តសញ្ញាណយេនឌ័រផ្សេងទៀត" ឬ "យេនឌ័រផ្សេងទៀត")។
- ក៏សួរខ្លួនអ្នកផងដែរថាតើសវតាផ្សេងៗដែលប្រែប្រួល អាចមានការពាក់ព័ន្ធដែរឬទេ (ឧ. អាយុ ជាតិសាសន៍ តំបន់រស់នៅ ជាតិពន្ធុ លទ្ធភាព)។
- ខណៈដែលទទួលបានទិន្នន័យសម្រាប់ការវិភាគពីទីភ្នាក់ងារផ្សេងៗ ជាពិសេសរដ្ឋាភិបាល មិនត្រឹមតែមានការទទួចឱ្យបែងចែកទិន្នន័យតាមភេទប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងឱ្យបែងចែងតាមយេនឌ័រ និងសង្គមផ្សេងទៀតផងដែរ។

## ផ្នត់គំនិតសង្គមយេនឌ័រ និងទាពលំអៀងយេនឌ័រ

**ផ្នត់គំនិតសង្គមយេនឌ័រ** គឺជាគំនិតដែលថា មនុស្សមានភាពជាប្រុស និងភាពជាស្រី ពោលគឺអ្វីដែលបុរស និងស្ត្រីគ្រប់ជំនាន់ទាំងអស់គួរមានលក្ខណៈដូចគ្នា និងមានសមត្ថភាពធ្វើអ្វីមួយ។

**ទាពលំអៀងយេនឌ័រ** គឺជាទិន្នាការក្នុងការធ្វើសេចក្ដីសម្រេចចិត្ត ឬចាត់វិធានការដោយផ្អែកលើសញ្ញាណសមត្ថភាពដែលគិតទុកមុនដោយផ្អែកលើយេនឌ័រ។ជាញឹកញាប់គឺសំដៅភាពលំអៀងយេនឌ័រនៃការទទួលយក "បទដ្ឋានបុរស" ធ្វើជាស្តង់ដារសម្រាប់ការវិភាគ និងការធ្វើសេចក្ដីសម្រេចចិត្តផងដែរ។

ឧទាហរណ៍៖ កុមារីគួរតែស្តាប់បង្គាប់ និងគួរឱ្យស្រលាញ់ អាចយំបានហើយកុមារាត្រូវបានរំពឹងថាមានភាពក្លាហាននិងមិនយំស្រ្តី និងកុមារីគឺជាអ្នកថែទាំប្រសើរជាង ហើយបុរស និងកុមារាពូកែគណិតវិទ្យាជាង។ ភាពលំអៀងដែលពាក់ព័ន្ធគឺថា ស្ត្រីចូលចិត្តការងារថែទាំ ខណៈដែលបុរសចូលចិត្តការងារវិស្វកម្ម។
ឧទាហរណ៍មួយផ្សេងទៀត អំពីភាពលម្អៀងគឺថា សេវាដឹកជញ្ជូនសាធារណៈត្រូវការជាចម្បងសម្រាប់អ្នកធ្វើដំណើរទៅធ្វើការ ហើយដូច្នេះរាល់ការរៀបចំផែនការទាំងអស់ត្រូវបានធ្វើឡើងដោយពិចារណាទៅលើចំណុចនេះ។ ទោះជាយ៉ាងណា បើទោះជាកត្តានេះមានសារៈសំខាន់សម្រាប់ទាំងបុរស និងស្ត្រីក្តី ក៏វាមានភាពលំអៀងបទដ្ឋានបុរសផងដែរ ដោយសារបុរសប្រើប្រាស់សេវាដឹកជញ្ជូនសាធារណៈច្រើនជាងសម្រាប់ការធ្វើដំណើរទៅធ្វើការតែប៉ុណ្ណោះខណៈដែលស្ត្រីត្រូវការសេវាដឹកជញ្ជូនសាធារណៈសម្រាប់ការងារ និងសកម្មភាពផ្សេងទៀត។

### ចំណុចដែលត្រូវអនុវត្ត៖

- អនុវត្តការវិភាគយេនឌ័រលម្អិតតាមវិស័យ និងវិភាគបញ្ហាមុនពេលបង្កើតគម្រោងឬកម្មវិធីណាមួយ។
- កំណត់តម្រូវការមូលដ្ឋានរបស់បុរស ស្ត្រី និងយេនឌ័រផ្សេងទៀតនៅក្នុងបរិបទបញ្ហាដែលពួកគេប្រឈម និងមិនមែនអំពីរបៀបដែលដំណោះស្រាយដែលត្រូវបានទទួលយកអាចត្រូវបានកែលម្អដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់គ្រប់យេនឌ័រនោះទេ។

## ការនិយមស្រលាញ់ភេទផ្ទុយគ្នា និងការព្រួយបារម្ភអំពីការស្រលាញ់ភេទដូចគ្នា

ការនិយមស្រលាញ់ភេទផ្ទុយគ្នា គឺជាការសន្មត់ជាមុនថាមនុស្សគ្រប់គ្នាស្រលាញ់ភេទផ្ទុយគ្នានិង/ឬគឺជាជំនឿដែលថាអ្នកស្រលាញ់ភេទផ្ទុយគ្នាមានភាពប្រសើរជាងពីធម្មជាតិបើធៀបនឹងអ្នកស្រលាញ់ភេទដូចគ្នា និងអ្នកស្រលាញ់មនុស្សទាំងពីរភេទ។ ផ្អែកលើទស្សនៈដែលយល់ថាទំនាក់ទំនងមនោសញ្ចេតនាផ្លូវភេទ និង/ឬ អារម្មណ៍ផ្លូវភេទរវាងបុរសនិងស្ត្រីគឺអាចទទួលយកបានហើយទំនាក់ទំនងផ្លូវភេទឬអារម្មណ៍ផ្លូវភេទខុសពីនេះគឺមិនអាចទទួលយកបានឬមិនត្រូវ "បទដ្ឋាន" ទំនាក់ទំនងផ្លូវភេទតាមបែបធម្មជាតិ។
ការព្រួយបារម្ភអំពីការស្រលាញ់ភេទដូចគ្នាគឺជាការបារម្ភដោយគ្មានហេតុផលពីការស្អប់ខ្ពើម ឬការរើសអើងចំពោះអ្នកស្រលាញ់ភេទដូចគ្នាឬឥរិយាបថស្រលាញ់ភេទដូចគ្នា។ ការព្រួយបារម្ភអំពីការស្រលាញ់ភេទដូចគ្នា ក៏សំដៅលើការស្អប់ខ្លួនឯង នៃអ្នកស្រលាញ់ភេទដូចគ្នាទាំងនោះក៏ដូចជាការព្រួយបារម្ភរបស់បុរសនិងស្ត្រីដែលមិនស្របតាមស្តង់ដារសង្គមដែលថាអ្វីគឺជា"បុរសពិត" ឬអ្វីជា "ស្ត្រីពិត"។
ឧទាហរណ៍៖ ការហៅអ្នកណាម្នាក់ថា "អាខ្ទើយ" ដោយអ្នកស្រលាញ់ភេទផ្ទុយគ្នានិយមនៅក្នុងរបៀបអវិជ្ជមាន (ឧ. នោះអាខ្ទើយ) នៅសាលារៀន និងការិយាល័យ។ ការមានបង្គន់សាធារណៈដាច់ដោយឡែកពីគ្នាសម្រាប់បុរសនិងស្ត្រីដោយមិនមានការបញ្ជាក់ច្បាស់លាស់សម្រាប់មនុស្សខ្ទើយ។ ដូចគ្នានេះដែរ គឺករណីនៅទីជម្រកក្នុងអំឡុងពេលមានគ្រោះមហន្តរាយ។ មនុស្សស្រីស្រលាញ់ស្រីដូចគ្នា និងមនុស្សស្រីស្រលាញ់មនុស្សទាំងពីរភេទ មិនទំនងជាទទួលបានការធ្វើតេស្តកោសិកាមាត់ស្បូនទេ ធៀបនឹងស្ត្រីជាទូទៅ។ ការស្អប់ការស្រលាញ់ភេទដូចគ្នារួមបញ្ចូលទាំងបទឧក្រិដ្ឋស្អប់ខ្ពើមដោយសារទិន្នាការផ្លូវភេទរបស់ជនរងគ្រោះប៉ុន្តែក៏មានការរំលោភបំពានក្នុងគ្រួសារក្នុងកម្រិតខ្ពស់ផងដែរដែលប្រឈមដោយមនុស្សប្រុសស្រលាញ់ប្រុសនិងមនុស្ស

ស្រលាញ់មនុស្សទាំងពីរភេទ។

ចំណុចដែលត្រូវអនុវត្តៈ

- កំណត់ប្រជាជនដែលជាមនុស្សខ្ចើយនៅក្នុងសហគមន៍របស់អ្នក និងគាំទ្រពួកគេឱ្យដើរឆ្ពោះទៅមុខ។
- បង្កើតក្រុមគាំទ្រ ជាពិសេសសម្រាប់ការទទួលបានការអប់រំ

ការថែទាំសុខភាព និងក្នុងអំឡុងពេលមានសកម្មភាពជំនួយគ្រោះមហន្តរាយ។

ដកស្រង់និងប្រមូលផ្ដុំមកពីប្រភពជាជាច្រើនៈមិនមានប្រភពជាក់លាក់, មិនមានប្រភពជាក់លាក់, មិនមានប្រភពជាក់លាក់

## ឯកសារមេរៀនទី២ៈ ក្រាហ្វិកព័ត៌មានអំពីគម្លាតយេនឌ័រ



The global **gender pay gap** is stuck at **16%** with women paid **35%** less than men in some countries.



**740 million** women globally work in the informal economy.

### For every dollar a man earns, women earn...




Wage equality for similar work has increased in high-income countries, while it has declined in developing countries




Average woman income
**11.5k a year**

Average man income
**21.5k a year**

### Workplace Gap



Share of women in the labor force **49%**

Share of women in skilled roles **40%**

*Source: Sharable infographics retrieved and adapted from Global Gender Gap Report, 2020 (WEF 2020) and Policy Brief: The impact of COVID-19 on women (UN Women 2020b).*

## INFOGRAPHICS ON GENDER GAPS

### EDUCATION GAP

Globally,

**65%**
of women







**72%**
of men

had an **account at a financial institution** in 2017, compared to

Women aged **25 to 34** globally are **25%** more likely than men to live in extreme poverty

**125 women**

**for every 100 men**

### POLITICAL EMPOWERMENT

**Women's Political Empowerment**

**Global** (153 countries)
**Parliament** (lower house seats)




Share of congresswomen

**Global ministries** (153 countries)




Share of women-ministers

Percentage of countries where a woman took head of state office at least once in the past 50 years




*Source: Sharable infographics retrieved and adapted from Global Gender Gap Report, 2020 (WEF 2020) and Policy Brief: The impact of COVID-19 on women (UN Women 2020b).*

## INFOGRAPHICS ON GENDER GAPS

### EDUCATION GAP

| | Primary<br>Net enrollment rate | Secondary<br>Net enrollment rate | Tertiary<br>Gross enrollment rate |
|---|---|---|---|
| Women | 88% | 66% | 41% |
| Men | 91% | 66% | 36% |

### VIOLENCE AGAINST WOMEN AND GIRLS

**Share of women who suffered intimate-partner physical and/or sexual violence**

| Region | Share |
|---|---|
| Middle East and North Africa | 45% |
| South Asia | 38% |
| North America | 32% |
| Sub-Saharan Africa | 31% |
| Latin America and the Caribbean | 27% |
| East Asia and the Pacific | 23% |
| Western Europe | 22% |
| Eastern Europe and Central Asia | 19% |

**31%** Global

### CARE GIVING ROLE

Women spend




as many hours as men in **unpaid care and domestic work**, limiting their access to decent work.

More men between the ages of 25 to 54 are in the **labour force** than women:




*Source: Sharable infographics retrieved and adapted from Global Gender Gap Report, 2020 (WEF 2020) and Policy Brief: The impact of COVID-19 on women (UN Women 2020b).*

## ឯកសារមេរៀនទី៣៖
## ការប្រែប្រួលអាកាសធាតុ និងផលប៉ះពាល់ដែលបានសង្កេតឃើញ

| ភាពមិនទៀងទាត់នៃអាកាសធាតុ | ការប្រែប្រួលអាកាសធាតុ ដែលបានសង្កេត និងដែលអាចកើតមាន | ហានិភ័យ និងផលប៉ះពាល់ដែលអាចកើតមាន |
|---|---|---|
| **កម្តៅខ្លាំង និងការកើនឡើងសីតុណ្ហភាព** | • ថ្ងៃដែលមានសីតុណ្ហភាពខ្ពស់/ក្តៅខ្លាំង មានកាន់តែច្រើនថ្ងៃ រលកកម្តៅមានកាន់តែខ្លាំង<br>• ថ្ងៃដែលមានសីតុណ្ហភាពទាប/ក្តៅខ្លាំង មានកាន់តែច្រើនថ្ងៃ រលកត្រជាក់មានកាន់តែខ្លាំង<br>• វាទំនងជាខ្លាំង ថារលកកម្តៅនឹងកើតឡើងកាន់តែញឹកញាប់ និងមានរយៈពេលកាន់តែយូរ | > មរណភាពនិងព្យាធិភាពក្នុងអំឡុងពេលមានកម្តៅខ្លាំង ជាពិសេសក្នុងចំណោមប្រជាជនទីក្រុងដែលងាយរងគ្រោះដូចជាអ្នករស់នៅក្នុងខ្ទមអ្នកដែលធ្វើការខាងក្រៅនៅក្នុងទីក្រុង ឬទីជនបទ ចាស់ជរា និងអ្នកដែលមានស្ថានភាពសុខភាពមិនល្អពីមុនមកស្រាប់។<br>> ហានិភ័យតាមរយៈជំងឺឆ្លងតាមភ្នាក់ងារចម្លងដែលកើនឡើងដោយសារបរិស្ថានបន្តពូជអំណោយផលដែលជំងឺទាំងនេះទទួលបានពីការប្រែប្រួលសីតុណ្ហភាព និងលក្ខខណ្ឌសំណើម។<br>> ការធ្លាក់ចុះធនធានទឹកលើផ្ទៃដីនិងទឹកក្រោមដីដែលកកើតឡើងវិញក្នុងតំបន់ក្បែរត្រូពិចដែលក្តៅបំផុត។ |
| **ការប្រែប្រួលកម្រិតកំណកអាកាស** | • កើនឡើងចំនួនថ្ងៃក្តៅ។ ធាតុអាកាសក្តៅរយៈពេលយូរកាន់តែវែងជាងមុន។<br>• កើនឡើងការភ្លៀងធ្លាក់នៅរដូវសិសិររដូវ។<br>• ការកើនឡើងប្រពលភាពខ្ពស់នៃហេតុការណ៍កំណកអាកាសរីករាលដាលនៅទូទាំងថ្ងៃដែលមានភ្លៀងដែលមានរយៈពេលខ្លីជាងមុន។<br>• ការពន្យាពេលការចាប់ផ្តើមរដូវវស្សា។<br>• វាទំនងជាខ្លាំង ថា ហេតុការណ៍កំណកអាកាសខ្លាំងនឹងកើតមានកាន់តែខ្លាំង និងញឹកញាប់នៅពេលអនាគត។ | > កើនឡើងអសន្តិសុខស្បៀង និងដួលរលំប្រព័ន្ធស្បៀងដែលមានទំនាក់ទំនងទៅនឹងបម្រែបម្រួលនិងភាពធ្ងន់ធ្ងរនៃការកើនឡើងកម្តៅ ភាពរាំងស្ងួត ទឹកជំនន់ និងកំណកអាកាស ជាពិសេសសម្រាប់ប្រជាជនក្រីក្រនៅក្នុងទីក្រុង និងជនបទ។<br>> ហានិភ័យនៃការកើតមានសុខភាពមិនល្អធ្ងន់ធ្ងរ និងការអាក់ខានដល់របរចិញ្ចឹមជីវិតសម្រាប់ប្រជាជនទីក្រុងជាច្រើនដោយសារទឹកជំនន់នៅតំបន់ឆ្ងាយពីសមុទ្រក្នុងតំបន់មួយចំនួន។<br>> ការបាត់បង់របរចិញ្ចឹមជីវិតនៅជនបទ និងប្រាក់ចំណូលដោយសារការទទួលបានមិនគ្រប់គ្រាន់នូវទឹកស្រោចស្រពនិងការធ្លាក់ចុះផលិតភាពកសិកម្ម ជាពិសេសសម្រាប់កសិករនិងអ្នកឃ្វាលសត្វដែលមានដើមទុនតិចតួចនៅក្នុងតំបន់ពាក់កណ្តាលស្ងួតហែង។ |
| **ទឹកជំនន់តំបន់ឆ្នេរនិងកើនឡើងកម្រិតទឹកសមុទ្រ** | • ប្រព័ន្ធតំបន់ឆ្នេរ និងតំបន់ទំនាប នឹងជួបប្រទះកាន់តែច្រើននូវការជន់លិចទឹកជំនន់ និងការរេចរឹលដោយសារការកើនឡើងកម្រិតទឹកសមុទ្រ។ | > ការស្លាប់ របួស សុខភាពមិនល្អ ឬការអាក់ខានរបរចិញ្ចឹមជីវិតនៅតំបន់ឆ្នេរទំនាប និងរដ្ឋដីកោះតូចៗដែលកំពុងអភិវឌ្ឍន៍និងកោះតូចៗផ្សេងទៀតដោយសារការកើនឡើងខ្យល់ព្យុះ ទឹកជំនន់តំបន់ឆ្នេរ និងការកើនឡើងកម្រិតទឹកសមុទ្រ។<br>> ប្រព័ន្ធអេកូឡូស៊ីសមុទ្រជាពិសេសជួរផ្កាថ្មប៉ប្រះទឹក និងប្រព័ន្ធអេកូឡូស៊ីតំបន់ប៉ូលស្ថិតក្នុងហានិភ័យពីអាស៊ីតកម្មសមុទ្រ។<br>ការបាត់បង់ប្រព័ន្ធអេកូឡូស៊ីសមុទ្រ និងប្រព័ន្ធ |

## ឯកសារមេរៀនទី៣៖
## ការប្រែប្រួលអាកាសធាតុ និងផលប៉ះពាល់ដែលបានសង្កេតឃើញ

| ភាពមិនទៀងទាត់នៃអាកាសធាតុ | ការប្រែប្រួលអាកាសធាតុដែលបានសង្កេត និងដែលអាចកើតមាន | ហានិភ័យ និងផលប៉ះពាល់ដែលអាចកើតមាន |
|---|---|---|
| | | អេកូឡូស៊ីតំបន់ឆ្នេរ ជីវៈចម្រុះ និងទំនិញ មុខងារ និងសេវាប្រព័ន្ធអេកូឡូស៊ីដែលផ្តល់សម្រាប់ជារបរចិញ្ចឹមជីវិតនៅតំបន់ឆ្នេរ ជាពិសេសសម្រាប់សហគមន៍នេសាទ។ |
| **ការរំខានពីព្យុះស៊ីក្លូន** | • ការប្រែប្រួលភាពញឹកញាប់និងប្រពលភាពនៃការរំខានពីព្យុះស៊ីក្លូន | > ហានិភ័យសុខភាពដោយសារការផឹកទឹកមិនគ្រប់គ្រាន់ និងទឹកក្នុងគ្រួសារមិនគ្រប់គ្រាន់ និងការធ្លាក់ចុះគុណភាពទឹកដែលឈានទៅរកជំងឺឆ្លងតាមទឹក។<br>> ហានិភ័យជាលក្ខណៈប្រព័ន្ធដោយសារហេតុការធាតុអាកាសប្រែប្រួលខ្លាំងដែលឈានទៅរកការដួលរលំបណ្តាញហេដ្ឋារចនាសម្ព័ន្ធ និង សេវាសំខាន់ៗដូចជាការផ្គត់ផ្គង់អគ្គិសនី ទឹក និងសេវាសុខភាព និងសេវាសង្គ្រោះបន្ទាន់។<br>> ហានិភ័យនៃការបាត់បង់ប្រព័ន្ធអេកូឡូស៊ីផ្ទៃទឹកលើដីគោក និងប្រព័ន្ធអេកូឡូស៊ីផែនដី ជីវៈចម្រុះ និងទំនិញ មុខងារ និងសេវាប្រព័ន្ធអេកូឡូស៊ីដែលផ្តល់សម្រាប់ជារបរចិញ្ចឹមជីវិត។ |

ប្រភព៖ (ហានិភ័យដែលលេចឡើងនិងភាពងាយរងគ្រោះរបស់ IPCC ឆ្នាំ២០១៤), (IPCC AR៥ ឆ្នាំ២០១៥)

## ឯកសារមេរៀនទី៤៖
## ពាក្យបច្ចេកទេស CCDRR និងភាពធន់

| ពាក្យបច្ចេកទេស | និយមន័យ |
|---|---|
| **អាកាសធាតុ** | អាកាសធាតុជាធម្មតាត្រូវបានកំណត់ថាជាធាតុអាកាសមធ្យម ឬធ្ងន់ធ្ងរខ្លាំង ជាការពិពណ៌នាអំពីស្ថិតិទាក់ទងនឹងកម្រិតមធ្យមនិងការប្រែប្រួលបរិមាណដែលពាក់ព័ន្ធក្នុងអំឡុងពេលរាប់ចាប់ពីរាប់ខែ រហូតដល់រាប់ពាន់ ឬរាប់លានឆ្នាំ។ ភាពលំអៀងគឺ ៣០ឆ្នាំ ដូចដែលត្រូវបានកំណត់ដោយអង្គការឧតុនិយមពិភពលោក (WMO)។ បរិមាណដែលពាក់ព័ន្ធជាញឹកញាប់បំផុត គឺជាភាពលំអៀងផ្ទៃខាងលើ ដូចជាសីតុណ្ហភាព កំណកអាកាស និងខ្យល់។ ក្នុងទិដ្ឋភាពទូលំទូលាយ អាកាសធាតុ គឺជាស្ថានភាពនៃប្រព័ន្ធអាកាសធាតុ រួមទាំងការពិពណ៌នាអំពីស្ថិតិផងដែរ។ |
| **ការប្រែប្រួលអាកាសធាតុ** | ការប្រែប្រួលអាកាសធាតុសំដៅលើការប្រែប្រួលស្ថានភាពអាកាសធាតុដែលអាចកំណត់បាន(ឧ. ដោយប្រើប្រាស់ការធ្វើតេស្តស្ថិតិ) តាមរយៈការផ្លាស់ប្តូរមធ្យោបាយ និង/ឬវិសមរូបនៃទ្រព្យសម្បត្តិរបស់អាកាសធាតុ និងដែលកើតមានក្នុងរយៈពេលយូរ ជាធម្មតារាប់ទសវត្សរ៍ ឬយូរជាងនេះ។<br>ទោះជាយ៉ាងណា UNFCCC ផ្តោតលើការប្រែប្រួលអាកាសធាតុដែលបង្កឡើងដោយសកម្មភាពមនុស្ស និងកំណត់និយមន័យការប្រែប្រួលអាកាសធាតុថាជាការប្រែប្រួលអាកាសធាតុ ដែលត្រូវបានបង្កឡើងដោយផ្ទាល់ឬដោយប្រយោលដោយសកម្មភាពរបស់មនុស្សដែលផ្លាស់ប្តូរសមាសភាពរបស់បរិយាកាសពិភពលោក និងដែលក្រៅពីវិសមរូបអាកាសធាតុ ត្រូវបានសង្កេតក្នុងរយៈពេលដែលអាចប្រៀបធៀបបាន។ |
| **ការកើនឡើងកម្ដៅសកល** | ការកើនឡើងកម្តៅសកលសំដៅដល់ការកើនឡើងសីតុណ្ហភាពលើផ្ទៃដីពិភពលោកសន្សឹមៗដែលសង្កេតឃើញមាន និងត្រូវបានព្យាករ ដែលជាផលវិបាកមួយក្នុងចំណោមផលវិបាកនានានៃកម្លាំងវិភាយកាំរស្មី ដែលបង្កឡើងដោយការបញ្ចេញឧស្ម័នដោយសកម្មភាពមនុស្ស។ |
| **គ្រោះមហន្តរាយ** | ការផ្លាស់ប្តូរធ្ងន់ធ្ងរចំពោះមុខងារជាប្រក្រតីរបស់សហគមន៍ ឬសង្គមមួយ ដោយសារហេតុការណ៍រូបវន្តប្រកបដោយគ្រោះថ្នាក់ ដែលមានទំនាក់ទំនងជាមួយស្ថានភាពសង្គមដែលងាយរងគ្រោះ ដែលឈានទៅរកឥទ្ធិពលមិនល្អដល់មនុស្ស សម្ភារ សេដ្ឋកិច្ច ឬបរិស្ថានដែលមានលក្ខណៈរីករាលដាល ដែលទាមទារឱ្យមានការឆ្លើយតបបន្ទាន់ភ្លាមៗដើម្បីឆ្លើយតបទៅនឹងតម្រូវការសំខាន់ៗរបស់មនុស្ស និងដែលអាចតម្រូវឱ្យមានការគាំទ្រពីខាងក្រៅសម្រាប់ការស្តារឡើងវិញ។<br>UNISDR(ឆ្នាំ២០១៧)កំណត់និយមន័យគ្រោះមហន្តរាយថាជាការអាក់ខានធ្ងន់ធ្ងរមួយនៃមុខងាររបស់សហគមន៍ ឬសង្គមមួយនៅក្នុងកម្រិតណាមួយ ដោយសារហេតុការណ៍គ្រោះថ្នាក់ ដែលមានទំនាក់ទំនងទៅនឹងលក្ខខណ្ឌប្រឈម ភាពងាយរងគ្រោះ និងសមត្ថភាព ដែលឈានទៅរកការខាតបង់ និងផលប៉ះពាល់មួយ ឬច្រើនដូចជា៖ ការខាតបង់ និងផលប៉ះពាល់ដល់មនុស្ស សម្ភារ សេដ្ឋកិច្ច និងបរិស្ថាន។ |
| **មុខសញ្ញាគ្រោះថ្នាក់** | ការដែលអាចកើតមានឡើងនូវហេតុការណ៍ឬនិន្នាការរូបវន្តធម្មជាតិឬដែលបង្កឡើងដោយសកម្មភាពមនុស្សឬផលប៉ះពាល់រូបវន្តដែលអាចបង្កឱ្យមានការបាត់បង់ជីវិតរបួសឬផលប៉ះពាល់សុខភាពផ្សេងទៀត ព្រមទាំងការខូចខាត និងបាត់បង់ទ្រព្យសម្បត្តិ ហេដ្ឋារចនាសម្ព័ន្ធ របរចិញ្ចឹមជីវិត ការផ្តល់សេវា ប្រព័ន្ធអេកូឡូស៊ី និងធនធានធម្មជាតិ។ នៅក្នុងរបាយការណ៍ នេះ ពាក្យ "មុខសញ្ញាគ្រោះថ្នាក់" ជាធម្មតាសំដៅដល់ហេតុការណ៍ ឬនិន្នាការរូបវន្តដែលពាក់ព័ន្ធនឹងអាកាសធាតុ ឬផលប៉ះពាល់រូបវន្តនៃហេតុការណ៍ឬនិន្នាការនេះ។ |
| **ហានិភ័យ** | UNISDR (ឆ្នាំ២០១៧) កំណត់និយមន័យគ្រោះថ្នាក់ថាជាដំណើរការ បាតុភូត ឬសកម្មភាពមនុស្សមួយ ដែលអាចបង្កឱ្យមានការបាត់បង់ជីវិត ការរងរបួស ឬផលប៉ះពាល់សុខភាពផ្សេងទៀត ការខូចខាតទ្រព្យសម្បត្តិ ការអាក់ខានសង្គម និងសេដ្ឋកិច្ច ឬការរេចរឹលបរិស្ថាន។ សក្តានុពលនៃការ |

## ឯកសារមេរៀនទី៤៖
## ទស្សនាទាន CCDRR និងភាពធន់

| ទស្សនាទាន | និយមន័យ |
|---|---|
| ហានិភ័យ | កើតមានផលវិបាកដែលអ្វីមួយមានតម្លៃស្ថិតក្នុងហានិភ័យនិងដែលលទ្ធផលមានភាពមិនប្រាកដប្រជា ដោយទទួលស្គាល់ភាពចម្រុះនៃតម្លៃ។ហានិភ័យជាញឹកញាប់តំណាងឱ្យភាពអាចកើតមានឬភវនីយភាពនៃការកើតឡើងហេតុការណ៍ ឬនិន្នាការគ្រោះថ្នាក់ រួមផ្សំជាមួយនឹងផលប៉ះពាល់ ប្រសិនបើហេតុការណ៍ ឬនិន្នាការទាំងនេះកើតឡើង។ នៅក្នុងរបាយការណ៍នេះ ពាក្យថា "ហានិភ័យ" ជាញឹកញាប់ត្រូវបានប្រើប្រាស់ដើម្បីសំដៅដល់សក្តានុពលនៃការកើតមានផលវិបាកលើជីវិត ជីវភាពរស់នៅ សុខភាព ប្រព័ន្ធអេកូឡូស៊ីនិងប្រភេទពូជសត្វ និងរុក្ខជាតិ ទ្រព្យសម្បត្តិសេដ្ឋកិច្ច សង្គម និងវប្បធម៌ សេវា (រួមទាំងសេវាបរិស្ថាន) និងហេដ្ឋារចនាសម្ព័ន្ធ នៅពេលលទ្ធផលមានភាពមិនប្រាកដប្រជា។ |
| ការប្រឈម | វត្តមានរបស់មនុស្ស របរចិញ្ចឹមជីវិត ពូជសត្វ ឬរុក្ខជាតិ ឬប្រព័ន្ធអេកូឡូស៊ី មុខងារ សេវា និងធនធានបរិស្ថាន ហេដ្ឋារចនាសម្ព័ន្ធ ឬទ្រព្យសម្បត្តិសេដ្ឋកិច្ច សង្គម ឬវប្បធម៌នៅទីកន្លែង និងបរិស្ថាននានាដែលអាចទទួលរងផលប៉ះពាល់ត្រលប់។ |
| ភាពងាយរងគ្រោះ | ជាទំនោរដែលទទួលរងផលប៉ះពាល់ត្រលប់។ភាពងាយរងគ្រោះក្តោបទស្សនទាននិងសមាសធាតុជាច្រើន រួមទាំងភាពរំញោច ឬភាពងាយរងប៉ះពាល់ទៅនឹងគ្រោះថ្នាក់ ឬកង្វះសមត្ថភាពក្នុងការដោះស្រាយ និងបន្សាំ។<br>UNISDR (ឆ្នាំ២០១៧) កំណត់និយមន័យភាពងាយរងគ្រោះថាជាស្ថានភាពដែលត្រូវបានកំណត់ដោយកត្តាឬដំណើរការរូបវន្ត សង្គម សេដ្ឋកិច្ច និងបរិស្ថាន ដែលបង្កើនភាពងាយរងប៉ះពាល់របស់បុគ្គល សហគមន៍ ទ្រព្យសម្បត្តិ ឬប្រព័ន្ធ ទៅនឹងផលប៉ះពាល់នៃមុខសញ្ញាគ្រោះថ្នាក់។ |
| ភាពរំញោច | វិសាលភាពដែលអ្វីមួយនឹងទទួលរងផលប៉ះពាល់ដោយវិជ្ជមានឬអវិជ្ជមានប្រសិនបើវាប្រឈមទៅនឹងកត្តាដែលបង្កឱ្យមានភាពតានតឹងអាកាសធាតុ (USAID ឆ្នាំ២០១៤)។ |
| ស្រ្តេស | ស្រ្តេសត្រូវបានកំណត់និយមន័យថាជា "សម្ពាធដែលតម្រូវគ្នា និងបន្តកើតមាន ដូចជាកង្វះខាតតាមរដូវកាល និងវិសមរូបអាកាសធាតុ ការរេចរឹលដី និងសម្ពាធប្រជាជន (ODI ឆ្នាំ២០១០)។ |
| ភាពតក់ស្លុត | ភាពតក់ស្លុត គឺជាហេតុការណ៍ភ្លាមៗដូចជាទឹកជំនន់ ការឆ្លងរាលដាលជំងឺ ភាពរាំងស្ងួត ប៉ុន្តែក៏អាចជាសង្គ្រាម ការធ្វើទុក្ខបុកម្នេញ និងអំពើហិង្សាក្នុងស្រុក (ODI ឆ្នាំ២០១០)។ |
| ផលប៉ះពាល់ (នៃ CCDRR) | ឥទ្ធិពលលើប្រព័ន្ធធម្មជាតិ និងប្រព័ន្ធមនុស្ស។ នៅក្នុងរបាយការណ៍នេះ ពាក្យ "ផលប៉ះពាល់" ត្រូវបានប្រើប្រាស់ជាចម្បងដើម្បីសំដៅដល់ឥទ្ធិពលលើប្រព័ន្ធធម្មជាតិ និងប្រព័ន្ធមនុស្សនៃហេតុការណ៍ធាតុអាកាស និងអាកាសធាតុធ្ងន់ធ្ងរ និងនៃការប្រែប្រួលអាកាសធាតុ។ ផលប៉ះពាល់ជាទូទៅសំដៅដល់ឥទ្ធិពលលើជីវិត ជីវភាពរស់នៅ សុខភាព ប្រព័ន្ធអេកូឡូស៊ី សេដ្ឋកិច្ច សង្គម វប្បធម៌ សេវា និងហេដ្ឋារចនាសម្ព័ន្ធ ដោយសារទំនាក់ទំនងការប្រែប្រួលអាកាសធាតុ ឬហេតុការណ៍អាកាសធាតុប្រកបដោយគ្រោះថ្នាក់ ដែលកើតឡើងនៅក្នុងអំឡុងពេលជាក់លាក់មួយ និងភាពងាយរងគ្រោះនៃសង្គម ឬប្រព័ន្ធដែលត្រូវបានប្រឈម។ ផលប៉ះពាល់ក៏ត្រូវបានសំដៅផងដែរថាជាផលវិបាក និងលទ្ធផល។ ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុលើប្រព័ន្ធធរណីរូបសាស្ត្រ រួមទាំងទឹកជំនន់ ភាពរាំងស្ងួត និងការកើនឡើងកម្រិតទឹកសមុទ្រ គឺជាផ្នែកមួយនៃផលប៉ះពាល់ ដែលហៅថាផលប៉ះពាល់រូបសាស្ត្រ។ |

## ឯកសារមេរៀនទី៤៖
## ទស្សនាទាន CCDRR និងភាពធន់

| ទស្សនាទាន | និយមន័យ |
|---|---|
| **ការកាត់បន្ថយ** | អន្តរាគមន៍របស់មនុស្សដើម្បីកាត់បន្ថយប្រភព ឬពង្រឹងអាងស្រូបឧស្ម័នផ្ទះកញ្ចក់។ របាយការណ៍នេះក៏ប៉ាន់ប្រម៉ាណផងដែរលើអន្តរគមន៍របស់មនុស្សដើម្បីកាត់បន្ថយប្រភពសារធាតុផ្សេងទៀតដែលអាចចូលរួមចំណែកដោយផ្ទាល់ឬប្រយោលដល់ការកំណត់ការប្រែប្រួលអាកាសធាតុរួមទាំងឧទាហរណ៍ការកាត់បន្ថយការបញ្ចេញអង្គធាតុតូចល្អិតដែលអាចផ្លាស់ប្តូរដោយផ្ទាល់នូវតុល្យភាពវិភាយរស្មី (ឧ. កាបូនខ្មៅ) ឬវិធានការដែលគ្រប់គ្រងការបញ្ចេញឧស្ម័នកាបូនម៉ូណូឌីអុកស៊ីត អាសូតអុកស៊ីត ល្បាយសរីរាង្គដែលប្រែប្រួលខ្លាំង (Volatile Organic Compounds) និងសារធាតុបំពុលផ្សេងទៀតដែលអាចផ្លាស់ប្តូរការផ្តោតរបស់ស្រទាប់អូហ្សូនត្រូប៉ូស្វៃ ដែលមានឥទ្ធិពលដោយប្រយោលលើអាកាសធាតុ។<br>យោងតាម UNISDR (ឆ្នាំ២០១៧) ការកាត់បន្ថយគឺជាការធ្វើឱ្យថមថយ ឬការធ្វើឱ្យធ្លាក់ចុះផលប៉ះមិនល្អនៃហេតុការណ៍គ្រោះថ្នាក់។ |
| **ការគ្រប់គ្រងហានិភ័យ** | ផែនការសកម្មភាព ឬគោលនយោបាយដើម្បីកាត់បន្ថយភវនីយភាព និង/ឬផលវិបាកនៃហានិភ័យ ឬដើម្បីឆ្លើយតបទៅនឹងផលវិបាកនានា។<br>UNISDR (ឆ្នាំ២០១៧) កំណត់បន្ថែមទៀតនូវនិយម័យនៃការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយថាជាការអនុវត្តគោលនយោបាយនិងយុទ្ធសាស្រ្តកាត់បន្ថយហានិភ័យគ្រោះមហន្តរាយដើម្បីបង្ការហានិភ័យគ្រោះមហន្តរាយថ្មីកាត់បន្ថយហានិភ័យគ្រោះមហន្តរាយដែលមានស្រាប់និងគ្រប់គ្រងហានិភ័យនៅសល់ដែលចូលចំណែកដល់ការពង្រឹងភាពធន់ និងការកាត់បន្ថយការខាតបង់ដោយសារគ្រោះមហនត្រាយ។ ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយមានគោលបំណងបង្ការហានិភ័យគ្រោះមហន្តរាយថ្មី និងកាត់បន្ថយហានិភ័យគ្រោះមហន្តរាយដែលមានស្រាប់ និងគ្រប់គ្រងហានិភ័យនៅសល់ ដែលទាំងអស់នេះចូលរួមចំណែកដល់ការពង្រឹងភាពធន់ ហើយដូច្នេះចូលរួមចំណែកដល់ការទទួលបានជោគជ័យនៃការអភិវឌ្ឍប្រកបដោយនិរន្តរភាព។ |
| **ការបន្សាំ** | ដំណើរការសម្របខ្លួនទៅនឹងអាកាសធាតុជាក់ស្តែង ឬអាកាសធាតុដែលរំពឹងទុក និងឥទ្ធិពលរបស់អាកាសធាតុ។ នៅក្នុងប្រព័ន្ធរបស់មនុស្ស ការបន្សាំព្យាយាមសម្របសម្រួល ឬចៀងវាងគ្រោះថ្នាក់ ឬទាញយកឱកាសដែលមានប្រយោជន៍នានា។ នៅក្នុងប្រព័ន្ធធម្មជាតិមួយចំនួន ការធ្វើអន្តរាគមន៍របស់មនុស្សអាចសម្របសម្រួលការបន្សាំទៅនឹងអាកាសធាតុ និងឥទ្ធិពលរបស់អាកាសធាតុ |
| **សមត្ថភាពបន្សាំ** | លទ្ធភាពរបស់ប្រព័ន្ធ ស្ថាប័ន មនុស្ស និងសត្វផ្សេងៗ ក្នុងការសម្របខ្លួនទៅនឹងគ្រោះថ្នាក់ដែលអាចកើតមាន ទាញយកឱកាស ឬឆ្លើយតបទៅនឹងផលវិបាកនានា។ |
| **យុទ្ធសាស្រ្តដោះស្រាយ** | លទ្ធភាពរបស់ប្រជាជន ស្ថាប័ន និងប្រព័ន្ធ ដោយប្រើប្រាស់ជំនាញ និងធនធានដែលមាន ដើម្បីគ្រប់គ្រងស្ថានភាពមិនល្អ ហានិភ័យ ឬគ្រោះមហន្តរាយ។ សមត្ថភាពដោះស្រាយ តម្រូវឱ្យមានការយល់ដឹងជាបន្ត ធនធាន និងការគ្រប់គ្រងល្អ ទាំងក្នុងពេលវេលាធម្មតា ព្រមទាំងក្នុងអំឡុងពេលមានគ្រោះមហន្តាយ ឬស្ថានភាពមិនល្អ។ សមត្ថភាពដោះស្រាយចូលរួមចំណែកដល់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ។ |
| **ភាពធន់** | សមត្ថភាពរបស់ប្រព័ន្ធសង្គម សេដ្ឋកិច្ច និងបរិស្ថានក្នុងការដោះស្រាយជាមួយហេតុការណ៍គ្រោះថ្នាក់ ឬនិន្នាការ ឬការរំខាន ដែលឆ្លើយតប ឬរៀបចំឡើងវិញតាមមធ្យោបាយនានាដែលរក្សាមុខងារអត្តសញ្ញាណ និងរចនាសម្ព័ន្ធសំខាន់ៗ ហើយក៏រក្សាបានសមត្ថភាពសម្រាប់ការបន្សុំ ការរៀនសូត្រ និងការផ្លាស់ប្តូរ។<br>UNISDR (ឆ្នាំ២០១៧) កំណត់និយមន័យភាពធន់ថា ជាលទ្ធភាពរបស់ប្រព័ន្ធ សហគមន៍ ឬ |

## ឯកសារមេរៀនទី៤៖
## ទស្សនាទាន CCDRR និងភាពធន់

| ទស្សនាទាន | និយមន័យ |
|---|---|
| ភាពធន់ | សង្គមដែលប្រឈមនឹងគ្រោះថ្នាក់ ដើម្បីតតាំង ស្រូបយក ទទួលយក បន្សាំ ផ្លាស់ប្ដូរ និងស្ដារឡើងវិញពីឥទ្ធិពលនៃគ្រោះថ្នាក់មួយឱ្យបានទាន់ពេលវេលា និងប្រកបដោយប្រសិទ្ធភាព រួមទាំងតាមរយៈការអភិរក្ស និងការស្ដារឡើងវិញនូវរចនាសម្ព័ន្ធ និងមុខងារមូលដ្ឋានសំខាន់ៗរបស់ប្រព័ន្ធ សហគមន៍ ឬសង្គមនោះតាមរយៈការគ្រប់គ្រងហានិភ័យ។ |
| សមត្ថភាពភាពធន់ | លទ្ធភាពរបស់សហគមន៍ដើម្បីរស់រាន បន្សាំ និងបង្កើតវឌ្ឍភាពក្នុងគ្រាដែលមានស្ត្រេស ដោយគ្មានការឈឺចាប់ឬការបាត់បង់ទ្រព្យសម្បត្តិ ខណៈដែលលើកកម្ពស់កម្រិតជីវិភាពរស់នៅបច្ចុប្បន្ន និងស្ថានភាពសុខភាពរបស់ពួកគេ។ |

## ឯកសារមេរៀនទី៥៖
## តួនាទីយេនឌ័រ និងភាពខុសគ្នានៃភាពងាយរងគ្រោះ

| វិស័យ | តួនាទីយេនឌ័រចម្បងៗ * | | ផលប៉ះពាល់ការប្រែប្រួលអាកាសធាតុ | ភាពងាយរងគ្រោះទាក់ទងនឹងយេនឌ័រនៅនឹងផលប៉ះពាល់ |
|---|---|---|---|---|
| ទឹក | បុរស | ស្រោចស្រពដំណាំនិងផលិត | បង្កើនស្ត្រេសទឹកដោយសារភាពរាំងស្ងួតការធ្លាក់ភ្លៀងមិនទៀងទាត់ និងការធ្លាក់ចុះទឹកក្រោមដី។ | កើនឡើងជម្លោះដោយសារធនធានទឹកដែលខ្វះខាត។ |
| | ស្ត្រី | ផឹក និងប្រើប្រាស់ក្នុងគ្រួសារ<br><br>ស្រោចស្រពដំណាំស្បៀង | | កើនឡើងពេលវេលានិងចម្ងាយផ្លូវដែលធ្វើដំណើរទៅដឹកជញ្ជូនទឹកស្អាត។<br>ការបង្វែរទឹក នឹងឈានទៅរកការមានទឹកកាន់តែតិចសម្រាប់ដំណាំស្បៀង។ |
| អាហារ | បុរស | ប្រាក់សម្រាប់ទិញអាហារ | > ការធ្លាក់ចុះផលិតកម្មស្បៀងនៅទូទាំងពិភពលោក ហើយដូច្នេះកើនឡើងតម្លៃស្បៀងអាហារ។<br>> គោលនយោបាយអភិរក្សព្រៃឈើ និងកាត់បន្ថយការចូលទៅរកអាហារ។ | > កើនឡើងភាពក្រីក្រ ដោយសារចំណែកកាចាយរ៉ាយលើការចំណាយលើស្បៀងអាហារនៅក្នុងគ្រួសារកើនឡើង * *។<br>> កើនឡើងស្ត្រេសផ្លូវចិត្តដោយសារការចង់បានចំណូលបន្ថែម និងដោយសារការគ្រប់គ្រងហិរញ្ញវត្ថុ។ |
| | ស្ត្រី | ការគ្រប់គ្រងអាហារនិងអាហារូបត្ថម្ភ<br><br>ការចម្អិនអាហារ | | > ការកើនឡើងភាពក្រីក្រដោយសារចំណែកការចាយរ៉ាយលើស្បៀងអាហារនៅក្នុងគ្រួសារកើនឡើង * *។<br>> កើនឡើងស្ត្រេសដោយសារសន្តិសុខស្បៀងនិងអាហា |

## ឯកសារមេរៀនទី៥៖
## តួនាទីយេនឌ័រ និងភាពខុសគ្នានៃភាពងាយរងគ្រោះ

| វិស័យ | តួនាទីយេនឌ័រចម្បងៗ* | | ផលប៉ះពាល់ការប្រែប្រួលអាកាសធាតុ | ភាពងាយរងគ្រោះទាក់ទងនឹងយេនឌ័រទៅនឹងផលប៉ះពាល់ |
|---|---|---|---|---|
| | | | | រូបត្ថម្ភក្នុងគ្រួសារ។<br>> គំរូបែងចែងអាហារក្នុងគ្រួសារមិនត្រឹមត្រូវនឹងឈានទៅរកការធ្លាក់ចុះទទួលទានអាហារ និងអាហារូបត្ថម្ភសម្រាប់ស្ត្រី និងកុមារី។<br>> ស្ត្រីជនជាតិភាគតិច និងក្រីក្រដែលពឹងផ្អែកលើព្រៃឈើនឹងប្រឈមនឹងបញ្ហាកាន់តែខ្លាំង។ |
| ចំណីសត្វ | បុរស | ទិញជីសម្រាប់ឃ្វាលសត្វ | ការបង្វែរធនធានដីជាពិសេសសម្រាប់ជីវៈឥន្ទនៈអាចឈានទៅរកការធ្លាក់ចុះភាពអាចរកបានចំណីសត្វ។ | កើនឡើងការចំណាយលើចំណីសត្វ។ |
| | ស្ត្រី | ប្រមូលជីសម្រាប់ឃ្វាលសត្វ | | ពេលវេលានិងកិច្ចប្រឹងប្រែងដែលចំណាយលើការប្រមូលចំណីសត្វកើនឡើង។ |
| ថាមពល | បុរស | អគ្គិសនីនិងប្រេងឆៅសម្រាប់ម៉ាស៊ីន និងយានយន្ត | > គោលនយោបាយថាមពលបញ្ចេញឧស្ម័នទាបនឹងបង្កើនការចំណាយ។<br>> គោលនយោបាយអភិរក្សព្រៃឈើ និងកាត់បន្ថយការចូលទៅកាន់ព្រៃ។ | > បង្កើនការចំណាយលើថាមពល។<br>> កើនឡើនភាពក្រីក្រដោយសារចំណែកការចំណាយក្នុងការចំណាយលើថាមពលនៅក្នុងគ្រួសារកើនឡើង**។ |
| | ស្ត្រី | ប្រេងឥន្ទនៈ និងឧស្ម័នសម្រាប់ចម្អិនអាហារ<br><br>អគ្គិសនីសម្រាប់ផ្ទះ និងធ្វើការងារ | | > ពេលវេលា និងកិច្ចប្រឹងប្រែក្នុងការរកអុសកើនឡើង។<br>> កើនឡើនភាពក្រីក្រដោយសារចំណែកការចំណាយទៅលើថាមពលនៅក្នុងគ្រួសារកើនឡើង**។ |
| សុខភាព | បុរស | ប្រាក់សម្រាប់ការចំណាយលើវេជ្ជសាស្ត្រ<br><br>ការធានារ៉ាប់រងវេជ្ជសាស្ត្រ | > ការកើនឡើងចល័តភាពដោយសាររលកកម្តៅ។<br>> ការកើនឡើងជំងឺឆ្លងតាមភ្នាក់ងារចម្លង និងជំងឺឆ្លងតាមទឹក។ | ការកើនឡើងការចំណាយលើវេជ្ជសាស្ត្រអាចធ្វើឱ្យគ្រួសារឈានទៅរកការធ្លាក់ចុះទៅក្នុងភាពក្រីក្រវិញ។ |
| | ស្ត្រី | ការថែទាំអ្នកជំងឺ | | > កើនឡើងបន្ទុកថែទាំអ្នកជំងឺ។<br>> ២២% នៃស្ត្រីបាត់បង់ប្រាក់ឈ្នួលដោយសារអវត្តមានការងារដោយសារកូនឈឺ។ |

## ឯកសារមេរៀនទី៥៖
## តួនាទីយេនឌ័រ និងភាពខុសគ្នានៃភាពងាយរងគ្រោះ

| វិស័យ | តួនាទីយេនឌ័រចម្បងៗ* | | ផលប៉ះពាល់ការប្រែប្រួលអាកាសធាតុ | ភាពងាយរងគ្រោះទាក់ទងនឹងយេនឌ័រនៅនឹងផលប៉ះពាល់ |
|---|---|---|---|---|
| **ការដាំដំណាំ** | បុរស | ផលិតកម្មដំណាំលក់យកប្រាក់ និងការធ្វើទីផ្សារ<br>ស៊ីឈ្នួលពលកម្មធ្វើកសិកម្ម | ទិន្នផលដំណាំជាមធ្យមធ្លាក់ចុះដែលធ្វើឱ្យកសិកររាប់លាន់នាក់ប្រឈមនឹងការទទួលបានទិន្នផលកាន់តែទាប។ | ការធ្លាក់ចុះប្រាក់ចំណូលពីកសិកម្មនឹងឈានទៅរកការធ្វើចំណាកស្រុកកាន់តែខ្ពស់ដើម្បីស្វែងរកប្រាក់ចំណូលជំនួស។ |
| | ស្ត្រី | ផលិតកម្មដំណាំស្បៀង និងការរក្សាទុក<br>ស៊ីឈ្នួលពលកម្មធ្វើកសិកម្ម | | ការមានថ្ងៃធ្វើការកាន់តែតិចនឹងកាត់បន្ថយប្រាក់ចំណូលបន្ថែមទៀត។<br>> Farmers ការធ្លាក់ចុះទិន្នផលដំណាំស្បៀង នឹងឈានទៅរកអសន្តិសុខស្បៀង ជាពិសេសសម្រាប់កសិករធ្វើកសិកម្មសម្រាប់បរិភោគ។ |
| **ការចិញ្ចឹមសត្វពាហនៈ** | បុរស | ការគ្រប់គ្រងកសិដ្ឋានសត្វគោធំៗ និងគោយកទឹកដោះ | សត្វពាហនៈនឹងទទួលរងប៉ះពាល់មិនល្អពីការកើនឡើងសីតុណ្ហភាពដោយអាស្រ័យលើវិសាលភាពនៃការប្រែប្រួលគុណភាពចំណីការរីករាលដាលជំងឺ និងភាពអាចរកបានធនធានទឹក។ | កសិដ្ឋានសត្វគោធំៗអាចទទួលបានប្រាក់ចំណូលកាន់តែតិចឬសូម្បីតែមិនអាចរស់រានបាន។ |
| | ស្ត្រី | ការគ្រប់គ្រងកសិដ្ឋានសត្វពាហនៈតូចៗ កសិដ្ឋានបក្សី | | > ការកើនឡើងការចំណាយលើការគ្រប់គ្រងសត្វគោតូចៗ ជាពិសេសការរៀបចំចំណី និងទឹក។<br>> ការកើនឡើងពេលវេលាដែលចំណាយលើការគ្រប់គ្រងសត្វពាហនៈ។ |
| **ការនេសាទ** | បុរស | ចាប់ត្រី | ការខូចខាតប្រព័ន្ធអេកូឡូស៊ី នឹងកាត់បន្ថយផលិតភាពនៃការនេសាទ និងវារីវប្បកម្ម ជាពិសេសនៅតំបន់ជិតខ្សែអេក្វាទ័រ។ | > ចំណាយពេលវេលាកាន់តែច្រើននៅក្នុងសមុទ្រ។<br>> ចាំបាច់ត្រូវផ្សងព្រេងក្នុងសមុទ្រឆ្ងាយៗ ដែលនឹងបង្កើនការចំណាយលើប្រេងឥន្ធនៈ និងត្រូវការទូកដែលមានម៉ាស៊ីនធំ។<br>> ការកើនឡើងការចំណាយនឹងកាត់បន្ថយប្រាក់ចំណេញពីការនេសាទ។ |
| | ស្ត្រី | កែច្នៃ និងលក់ចេញ<br>កសិកដ្ឋានចិញ្ចឹមត្រី | | > សីតុណ្ហភាពកាន់តែខ្ពស់នឹងធ្វើឱ្យការកែច្នៃត្រី និងការលក់ត្រីកាន់តែមានការលំបាក |

## ឯកសារមេរៀនទី៥៖
## តួនាទីយេនឌ័រ និងភាពខុសគ្នានៃភាពងាយរងគ្រោះ

| វិស័យ | តួនាទីយេនឌ័រផ្សេងៗ* | | ផលប៉ះពាល់ការប្រែប្រួលអាកាសធាតុ | ភាពងាយរងគ្រោះទាក់ទងនឹងយេនឌ័រទៅនឹងផលប៉ះពាល់ |
|---|---|---|---|---|
| ការងារធ្វើនៅផ្ទះ | បុរស | ឧបករណ៍ត្បាញដោយដៃនិងម៉ាស៊ីនត្បាញ | > ការកើនឡើងចំនួនថ្ងៃក្ដៅ និងរលក កម្ដៅ។<br>> ការកើនឡើងជំនន់ទឹកទន្លេ និងតំបន់ឆ្នេរ។ | > រលកកម្ដៅនឹងកាត់បន្ថយផលិតភាព។<br>> ការចំណាយលើថាមពលនឹងកើនឡើង។<br>> ការធ្លាក់ចុះវត្ថុធាតុដើម និងការជន់លិចហេដ្ឋារចនាសម្ព័ន្ធ។<br>> ការបាត់បង់កន្លែងធ្វើការដោយសារគ្រោះមហន្តរាយ<br>> ការមិនមានការគ្របដណ្ដប់ហានិភ័យហិរញ្ញវត្ថុ/ការមិនទទួលបានឥណទាននឹងមានន័យថាជាការធ្លាក់ចូលទៅក្នុងភាពក្រីក្រវិញ។ |
| | | | | |
| | ស្ត្រី | កាត់ដេរ ប៉ាក់ កែច្នៃអាហារ ផលិតធូប សិប្បកម្ម។ល។ | | |
| ការដឹកជញ្ជូន | បុរស | ការដឹកញ្ជូនឯកជន និងសាធារណៈ | គោលនយោបាយដឹកជញ្ជូនដែលបញ្ចេញឧស្ម័នទាប នឹងដាក់អនុវត្ត | ការកើនឡើងការចំណាយលើប្រេងឥន្ធនៈ និងដឹកជញ្ជូនអាចកាត់បន្ថយការប្រើប្រាស់សេវាដឹកជញ្ជូនឯកជនសម្រាប់គ្រួសារក្រីក្រ។<br><br>ការកើនឡើងសម្ពាធលើការដឹកជញ្ជូនសាធារណៈ នឹងប៉ះពាល់ដល់សុវត្ថិភាពនិងការទទួលបានសេវាដឹកជញ្ជូនសាធារណៈរបស់ស្ត្រី។ |
| | ស្ត្រី | ការដឹកជញ្ជូនសាធារណៈប្រកបដោយសុវត្ថិភាព | | |
| គ្រោះមហន្តរាយតំបន់ឆ្នេរ | បុរស | ឥរិយាបថទទួលយកហានិភ័យ<br><br>សង្គ្រោះជីវិត និងទ្រព្យសម្បត្តិ<br><br>បច្ចុប្បន្នភាពព័ត៌មាន<br><br>ធានារ៉ាប់រងនិងការស្ដារឡើងវិញ | ការកើនឡើងការជ្រៀតចូលទឹកប្រៃ ទឹកជំនន់ និងការខូចខាតចំពោះហេដ្ឋារចនាសម្ព័ន្ធ។ | > ការបាត់បង់ជីវិត<br>> ហានិភ័យសម្រាប់អ្នកនេសាទ<br>> ការកើនឡើងការធ្វើចំណាកស្រុក<br>> ការកើនឡើងស្ត្រេស និងសុខភាពផ្លូវចិត្ត<br>> ការញៀនគ្រឿងស្រវឹង និងអត្រាធ្វើអត្តឃាតអាចកើនឡើង |

## ឯកសារមេរៀនទី៥៖
## តួនាទីយេនឌ័រ និងភាពខុសគ្នានៃភាពងាយរងគ្រោះ

| វិស័យ | តួនាទីយេនឌ័រផ្សេងៗ * | | ផលប៉ះពាល់ការប្រែប្រួលអាកាសធាតុ | ភាពងាយរងគ្រោះទាក់ទងនឹងយេនឌ័រទៅនឹងផលប៉ះពាល់ |
|---|---|---|---|---|
| | ស្ត្រី | ការរក្សាទុកសម្ភារក្នុងគ្រួសារ និងសម្រាប់គ្រាអាសន្ន<br><br>ការងារផ្ទះ៖ការដឹកជញ្ជូនទឹក និងការចម្អិនអាហារ<br><br>ថែទាំកូន និងមនុស្សចាស់<br><br>រក្សាសេចក្តីថ្លៃថ្នូរ និងទំនៀមទម្លាប់វប្បធម៌ | | > ស្ត្រី និងកុមារ ទំនងជាស្លាប់/រងរបួសច្រើនជាងបុរស ១៤ដង។<br>> ៨៩% នៃប្រជាជនដែលផ្លាស់ប្តូរទីលំនៅ គឺជាស្ត្រី។<br>> បន្ទុកការងារផ្ទះកើនឡើង។<br>> កង្វល់សុខភាពដោយសារការទទួលទានទឹកប្រៃ។<br>> អំពើហិង្សារផ្លូវភេទ និងយេនឌ័រកើនឡើង។ |

* តួនាទីយេនឌ័រដែលបានលើកឡើងនៅទីនេះមិនមែនមិនអាចកែប្រែបាននោះទេ ហើយចាំបាច់ត្រូវកែសម្រួលទៅតាមបរិបទ។ ទាំងអស់នេះគ្រាន់តែបង្ហាញពីអ្វីដែលអាចជាតួនាទីដែលមានភាពខុសគ្នាតាមយេនឌ័រប៉ុណ្ណោះ។

** គ្រួសារដែលមានចំណែកការចំណាយលើស្បៀង និងថាមពលកាន់តែខ្ពស់នៅក្នុងការចំណាយក្នុងគ្រួសារ ជាទូទៅស្ថិតក្នុងផ្នែកប្រាក់ចំណូលកាន់តែទាប (គ្រួសារក្រីក្រ)។

## ឯកសារមេរៀនទី៦៖ ករណីសិក្សាអំពីស្ត្រីដែលជាភ្នាក់ងារនៃការផ្លាស់ប្ដូរ

### ស្ត្រីដឹកនាំក្នុងភាពត្រៀមបង្ការទប់ទល់នឹងគ្រោះមហន្តរាយ៖ ករណីសិក្សានៅទីក្រុង Barishal ប្រទេសបង់ក្លាដែស

ទីក្រុង Barishal ដែលស្ថិតនៅតាមដងទន្លេ Kirtonkhola ក្នុងប្រទេសបង់ក្លាដែស មានប្រជាជនច្រើនលើសលុបរស់នៅក្នុងសំណង់អាណាធិបតេយ្យ។ កម្រិតភាពក្រីក្រខ្ពស់នៅក្នុងទីក្រុងនេះកាន់តែមានភាពធ្ងន់ធ្ងរឡើងដោយសារស្ថានភាពធាតុអាកាសពោលគឺព្យុះស៊ីក្លូននិងភ្លៀងរដូវមូសុងជន់លិចមាត់ទន្លេនេះដែលបង្កឱ្យប៉ះពាល់ដល់ហេដ្ឋារចនាសម្ព័ន្ធរបស់ទីក្រុងនេះ និងកកស្ទះពេញដោយសំរាម។ នេះមានន័យថា ការរីករាលដាលជំងឺ ជានិច្ចកាលគឺជាការគំរាមកំហែងមួយ។ ក្នុងឆ្នាំ២០១៧ ប្រជាជនជាង ១០.០០០នាក់បានស្លាប់នៅពេលព្យុះស៊ីក្លូន Sidr បានបោកបក់មកលើទីក្រុងនេះ។ ការប្រែប្រួលអាកាសធាតុមានន័យថា ស្ថានភាពនៅទីនេះនឹង កាន់តែអាក្រក់ឡើង។ ហើយជាធម្មតា មានបុរសតិចតួចប៉ុណ្ណោះដែលជួយដោះស្រាយបញ្ហាគ្រោះមហន្តរាយ ខណៈដែលស្ត្រី គឺជាអ្នកដែលជួយស្តារស្ថានការណ៍នេះឱ្យវិលត្រលប់មករកស្ថានភាពប្រក្រតីវិញ។

ប៉ុន្តែស្ត្រីទាំងនេះ គឺជាមនុស្សដ៏រឹងមាំ។ នាង Josna និងមិត្តរបស់នាងឈ្មោះ Mahmuda រួមជាមួយស្ត្រីក្នុងមូលដ្ឋានផ្សេងទៀត បានបង្កើតក្រុមដែលផ្តោតលើស្ត្រីមួយឈ្មោះថា គណៈកម្មធិការគ្រប់គ្រងគ្រោះមហន្តរាយសហគមន៍Hatkholaដោយមានជំនួយពីអង្គការអុកស្វាមក្រហមបង់ក្លាដែស។ គណៈកម្មធិការនេះត្រូវបានបង្កើតឡើងដើម្បីផ្តល់ជូនស្ត្រីនូវវេទិកាមួយ ដើម្បីនិយាយចេញនូវបញ្ហាដែលមានសារៈសំខាន់ចំពោះពួកគេបំផុត។

គណៈកម្មាធិការនេះបានផ្តោតលើការអភិវឌ្ឍតំបន់ កែលម្អផ្លូវ ប្រព័ន្ធបង្ហូរទឹក បន្ទប់ទឹក និងប្រព័ន្ធបង្គន់ ព្រមទាំងផ្តោតលើការបណ្តុះបណ្តាលមនុស្សអំពីការត្រៀមបង្ការទប់ទល់នឹងគ្រោះមហន្តរាយ។ ប៉ុន្តែពួកគេបានធ្វើកិច្ចការច្រើនជាងនេះ។ ពួកគេបានទទួលការបណ្តុះបណ្តាលស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ និងបានត្រៀមខ្លួនរួចជាស្រេចនៅខែវិច្ឆិកាឆ្នាំ២០១៩នៅពេលព្យុះស៊ីក្លូនបោកបក់មកលើតំបន់នេះ។

គណៈកម្មធិការរបស់នាង Josna និងនាង Mahmuda បានឆ្លើយតបទៅនឹងការសង្គ្រោះបន្ទាន់។គណៈកម្មាធិការនេះបានធ្វើឱ្យប្រាកដថា កុមារ ចាស់ជរា ស្ត្រីមានផ្ទៃពោះ និងជនពិការ ត្រូវបានយកទៅកាន់មណ្ឌលជម្លៀស។មនុស្សម្នាក់ក្នុងចំណោមអ្នកទាំងនោះគឺនាង Kobita អាយុ ១៨ឆ្នាំ មានផ្ទៃពោះ ៨ខែ នៅពេលព្យុះស៊ីក្លូន Bulbul បានបោកបក់មក។ ខណៈដែលកម្រិតទឹកបានចាប់ផ្តើមកើនឡើង និងហូរចូលក្រោមទ្វារសង្កសីនៃខ្ទមរបស់នាង នាង Kobita បានចាប់ផ្តើមភ័យខ្លាច។ នៅពេលទឹកបានកើនឡើងដល់ជម្រៅកជើងភ្លាមៗនោះនាងបានឮសំឡេងពីមេក្រូចេញពីព្រះវិហារក្នុងមូលដ្ឋានបន្លឺឡើង។ ប៉ុន្តែជំនួសឱ្យសំឡេងសូត្រថ្វាយបង្គំដែលធ្លាប់ធ្វើឡើងជាធម្មតា សំឡេងខ្លាំងៗកងរំពងបានប្រកាសភាពអាសន្ន។ ជាសំណាងល្អ គណៈកម្មធិការ Hatkhola បានមកដល់ភ្លាមៗ និងបានគ្រានាង Kobita ដើរយឺតៗឆ្ពោះទៅកាន់ជម្រកសង្គ្រោះបន្ទាន់។ Josna បានថ្លែងថា៖ "យើងរក្សាទុកបញ្ជីឈ្មោះអ្នកដែលងាយរងគ្រោះបំផុត។ នាង Kobita ស្ថិតក្នុងអាទិភាពមួយ ដូច្នេះយើងទៅជួយនាងឱ្យបានឆាប់ៗ រហ័សតាមដែលអាចធ្វើទៅបាន"។ គណៈកម្មធិការ Hatkhola ដែលផ្តោតលើស្ត្រីនេះ បានធ្វើការងារដោយមិនចេះហត់នឿយទាំងយប់ ដែលធ្វើឱ្យប្រាកដថា មនុស្សគ្រប់គ្នានៅក្នុងសំណង់អាណាធិបតេយ្យបានទៅដល់ទីជម្រក។ពួកគេបីកូនៗរបស់អ្នកដែលជួបការលំបាក និងបានផ្តល់ការធានាជាប្រចាំទៅដល់គ្រួសារដែលភ័យខ្លាច។

នៅពេលព្យុះស៊ីក្លូននេះបានចប់ គណៈកម្មធិការ Hatkhola បានធ្វើឱ្យប្រាកដថា ទីជម្រកមានសុវត្ថិភាព សម្អាតសំណល់ពីខ្យល់ព្យុះ និងរៀបចំការបរិច្ចាគស្បៀងអាហារ ដែលត្រូវបានចែកចាយទៅកាន់គ្រួសារដែលត្រូវការជំនួយ។បន្ទាប់ពីព្យុះស៊ីក្លូនបានផុតរលត់ទៅស្ត្រីបានជួយសម្អាតសំណល់និងរៀបចំឱ្យគ្រួសារវិលត្រលប់ទៅកាន់គេហដ្ឋានរបស់ពួកគេវិញ។ ពួកគេក៏បានរៀបចំឱ្យមានការបរិច្ចាគក្នុងមូលដ្ឋាននូវអាហារក្រៀមសម្រាប់អ្នកខ្វះខាត និងងាយរងគ្រោះផងដែរ។

ស្ត្រីក៏បានទទួលការកោតសរសើរពីនគបាលក្នុងមូលដ្ឋានផងដែរ។ មន្ត្រីនគបាលមួយរូបឈ្មោះ Abu Bakar Siddik និយាយថា៖ "ក្រុមការងាររបស់Hatkholaមានសារៈសំខាន់ក្នុងការទទួលបានការប្រកាសអាសន្នចំពោះសហគមន៍។ យើងសង្ឃឹមថា កត្តានេះនឹងជំរុញស្ត្រីកាន់តែច្រើនឡើងក្នុងទីក្រុង Barishal ឱ្យចូលរួមក្នុងបេសកកម្មរុករក និងសង្គ្រោះនាពេលអនាគត។

ប្រភព៖ ដកស្រង់ចេញពី (យើងផ្តល់ភាពអង់អាចដល់ស្ត្រី n.d.)

## ស្ត្រីដឹកនាំការគ្រប់គ្រងព្រៃឈើក្នុងប្រទេសនេប៉ាល់

ក្នុងប្រទេសនេប៉ាល់ ដូចទៅនឹងប្រទេសផ្សេងទៀតក្នុងតំបន់អាស៊ីខាងត្បូងផងដែរ ស្ត្រីទទួលខុសត្រូវលើការប្រមូល និងការគ្រប់គ្រងផលព្រៃឈើដែលមានសារៈសំខាន់ចំពោះជីវិតប្រចាំថ្ងៃរបស់គ្រួសាររបស់ពួកគេ។ ទោះជាយ៉ាងណា ស្ត្រីជាញឹកញាប់ត្រូវបានគេមិនអើពើនៅក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្តនៅក្នុងស្ថាប័នកម្រិតសហគមន៍ដែលផ្តោតលើការគ្រប់គ្រងធនធានធម្មជាតិ។ អង្គការ WWF និងដៃគូរជាច្រើនរបស់អង្គការនេះធ្វើការងារជាមួយរដ្ឋាភិបាល និងសហគមន៍មូលដ្ឋាន ដើម្បីជួយលើកកម្ពស់ជីវិត និងស្តារព្រៃឈើឡើងវិញដែលជាផ្នែកមួយនៃយុទ្ធសាស្ត្រជារួមដើម្បីអភិរក្សទេសភាពនិងជីវិតសត្វព្រៃទ្រង់ទ្រាយធំក្នុងប្រទេសនេប៉ាល់។ ការផ្តោតនេះ ធ្វើឡើងចំពោះការផ្តល់ភាពអង់អាចដល់ស្ត្រី ដើម្បីចូលរួមនៅក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្តក្នុងមូលដ្ឋាន និងក្រោកឈរឡើងដើម្បីសិទ្ធិរបស់ពួកគេក្នុងការទទួលបានធនធានព្រៃឈើ និងអត្ថប្រយោជន៍ដែលព្រៃឈើផ្តល់ជូន។ គម្រោងទាំងនេះក៏រួមបញ្ចូលការដាក់ដំណើរការវិធីសាស្ត្រថាមពលស្អាតផងដែរដើម្បីកាត់បន្ថយពេលវេលាដែលស្ត្រីចំណាយលើការរកអុសនិងបន្ទូរសម្ពាធទៅលើព្រៃឈើ។ វិធីសាស្ត្របែបនេះ រួមបញ្ចូលជីវៈឧស្ម័ន (ឧស្ម័នដែលផលិតចេញពីវត្ថុធាតុដើមនានាដូចជាកាកសំណល់កសិកម្ម និងលាមកសត្វ) ថាមពលពន្លឺព្រះអាទិត្យ រោងចក្រវារីអគ្គិសនីខ្នាតតូច និងចង្ក្រានចម្អិនអាហារដែលសន្សំថាមពល។ ទាំងអស់នេះលើកកម្ពស់ជីវិតនិងអភិរក្សធម្មជាតិហើយស្ត្រីគឺជាអ្នកការពារព្រៃឈើដ៏ខ្លាំងនៅក្នុងមូលដ្ឋានរបស់ពួកគេ។

ការទទួលស្គាល់តួនាទីដ៏សំខាន់ដែលស្ត្រីធ្វើនៅក្នុងការគ្រប់គ្រងព្រៃឈើអាចបង្កើតឱ្យមានភាពខុសគ្នាទាក់ទងនឹងការអភិរក្សព្រៃឈើ។ ការណ៍នេះ កើតមានឡើងជាចម្បងដោយសារស្ត្រីមានចំណាប់អារម្មណ៍ផ្សេងគ្នានិងបំពេញឱ្យគ្នាទៅវិញទៅមកធៀបនឹងបុរស នៅក្នុងគណៈកម្មាធិការព្រៃឈើមួយ ដែលកើតចេញមកពីភាពខុសគ្នានៃកង្វល់ និងលក្ខណៈពឹងផ្អែកលើព្រៃឈើដែលស្ត្រីមាន ធៀបនឹងបុរស។ ស្ថានភាពព្រៃឈើប្រសើរបំផុតជះឥទ្ធិពលផ្ទាល់ដល់ជីវភាពរស់នៅនិងសុខុមាលភាពរបស់ប្រជាជនជនបទមួយផ្នែកធំ ដែលពឹងផ្អែកលើធនធានព្រៃឈើ។

នាង Radha Wagle ដែលជាស្ត្រីទីមួយដែលកាន់តំណែងជាលេខាធិការរួម និងជាប្រធានមជ្ឈមណ្ឌលអនុវត្ត REDD ស្ថិតក្រោមក្រសួងព្រៃឈើ និងបរិស្ថាន ក៏កំពុងធ្វើការងារផងដែរដើម្បីធ្វើឱ្យវិស័យព្រៃឈើមានការរួមបញ្ចូលស្ត្រី និងក្រុមដែលជួបការលំបាកឱ្យកាន់តែខ្លាំងថែមទៀត។ពួកគេបានបញ្ចប់ផែនការសកម្មភាពយេនឌ័រ ដែលកំណត់វិធីនានាដើម្បីធ្វើឱ្យកម្មវិធីព្រៃឈើកាន់តែមានការឆ្លើយតបទៅនឹងតម្រូវការរបស់ស្ត្រី និងលើកទឹកចិត្តឱ្យស្ត្រីចូលរួមនៅគ្រប់កម្រិតរបស់រដ្ឋាភិបាល សង្គមស៊ីវិល និងវិស័យឯកជនដោយមានការគាំទ្រពីមូលនិធិភាពជាដៃគូកាបូនព្រៃឈើ (FCPC) របស់ធនាគារពិភពលោក។ នៅពេលនាង Radha Wagle នៅធ្វើការជាឧទ្យានុរក្សដែលមានវ័យក្មេងនៅតំបន់ភាគខាងកើតប្រទេសនេប៉ាល់ នាងបានដឹងអំពីភាពផ្ទុយស្រឡះគ្នាយ៉ាងខ្លាំងក្នុងការវិស័យប្រើប្រាស់ដី។ ជាមួយនឹងពេលវេលាយ៉ាងច្រើនដែលស្ត្រីបានចំណាយលើការរកអុសសម្រាប់ការប្រើប្រាស់ថាមពល ចំណីសត្វ រុក្ខជាតិថ្មី និងរុក្ខជាតិឱសថ នាងបានឃើញតួនាទីដ៏សំខាន់ដែលស្ត្រីធ្វើនៅក្នុងកសិកម្ម របរចិញ្ចឹមជីវិត និងការគ្រប់គ្រងធនធានធម្មជាតិ។ ប៉ុន្តែនាងក៏បានសង្កេតឃើញ និងបានជួបប្រទះដោយខ្លួនឯងផ្ទាល់ផងដែរអំពីរបៀប ដែលស្ត្រីជួបការលំបាកម្តងហើយម្តងទៀតនៅក្នុងវិស័យដែលគ្របដណ្តប់ដោយបុរសនេះ។ នាង Wagle បានរំឭកថា "អតិថិជនមួយចំនួនស្នើសុំឱ្យឧទ្យានុរក្សបុរសជាអ្នកផ្តល់សេវាកម្មឱ្យពួកគេ ដូចជាបង្កើតផែនការគ្រប់គ្រងព្រៃឈើ ផ្តល់ការគាំទ្របច្ចេកទេសឬសរសេរលិខិតជាដើម។បើទោះជាខ្ញុំបានប្រាប់ពួកគេថា ខ្ញុំអាចធ្វើបានក៏ដោយ ក៏ពួកគេបដិសេធដែរ ហើយរង់ចាំឧទ្យានុរក្សបុរសទំនេរដើម្បីមកផ្តល់សេវាឱ្យពួកគេ"។ ថាតើកត្តានេះបានកំពុងកើតឡើងនៅក្នុងតំបន់នេះឬយ៉ាងណានោះ នាង Wagle បានឱ្យដឹងថា វាបានកំពុងកើតឡើងនៅទូទាំងប្រទេស ហើយនាងបានប្តេជ្ញាចិត្តធ្វើអ្វីមួយអំពីវា។ ក្នុងឆ្នាំ ២០១៥ នាងបានក្លាយជាស្ត្រីដំបូង ដែលកាន់កាប់តំណែងជាលេខាធិការរួមនៅក្រសួងព្រៃឈើ និងបរិស្ថានក្នុងប្រទេសនេប៉ាល់។ នៅក្នុងតួនាទីនេះនាងកំពុងផ្តោតការយកចិត្តទុកដាក់លើកិច្ចប្រឹងប្រែងរបស់នាងលើការបង្កើនការចូលរួមរបស់ស្ត្រីនេប៉ាល់នៅក្នុងការគ្រប់គ្រងព្រៃឈើ។

ប្រភព៖ ដកស្រង់ចេញពី (បទយកការណ៍ដែលផលិតដោយធនាគារពិភពលោក ឆ្នាំ២០១៩)

### ម៉ូឌែលរបរចិញ្ចឹមជីវិតរបស់កម្មវិធី SWaCH សម្រាប់ស្ត្រីជាមួយនឹងការគ្រប់គ្រងសំណល់នៅទីក្រុង Pune ប្រទេសឥណ្ឌា

ទីក្រុង Pune មិនមែនជាទីក្រុងតែមួយដែលតស៊ូទប់ស្កាត់សំណល់របស់ខ្លួននោះទេ។ វាគឺជាបញ្ហារួមគ្នាមួយនៅក្នុងទីក្រុងភាគច្រើនក្នុងតំបន់អាស៊ី ជាទីដែលការកើនឡើងការបោះចោលសំណល់កំពុងក្លាយជាកង្វល់បរិស្ថាន និងអាកាសធាតុដ៏ធំមួយ។ ក្នុងឆ្នាំ២០០០ រដ្ឋាភិបាលថ្នាក់ជាតិឥណ្ឌាបានចេញផ្សាយវិធានគ្រប់គ្រងសំណល់រឹងថ្នាក់ក្រុងជាលើកដំបូងរបស់ខ្លួន ដោយតម្រូវឱ្យរដ្ឋាភិបាលថ្នាក់តំបន់ប្រមូលសំរាមនៅតាមខ្នងផ្ទះ បែងចែកសំរាមដែលអាចកែច្នៃឡើងវិញបានពីសំរាមសើមនិងបញ្ឈប់ការបោះចោលសំរាមដោយគ្មានការបែងចែក។ដូចទៅនឹងទីក្រុងភាគច្រើននៅឥណ្ឌាដែរ ទីក្រុង Pune មានឧបករណ៍មិនគ្រប់គ្រាន់ដើម្បីអនុលោមតាមវិធាននេះឡើយ។ ទោះជាយ៉ាងណាជំនួសឱ្យការប្រើប្រាស់ម៉ូឌែលដែលពឹងផ្អែកក្រុមហ៊ុនជាប់កិច្ចសន្យាឬរោងចក្រប្រព្រឹត្តិកម្មសំណល់ដែលមានភាពសាមញ្ញនោះ ទីក្រុងនេះបានជ្រើសរើសយកការលើកកម្ពស់ជីវភាពរស់នៅសម្រាប់ម៉ូឌែលក្រីក្រ។

គំនិតនេះបានកើតឡើងពីការពិតដែលថា ក្នុងទីក្រុង Pune (ដូចទៅនឹងទីក្រុងភាគច្រើននៅតំបន់អាស៊ីដែរ) ស្ត្រីបានបង្កើតសង្គមអ្នករើសសំរាមដ៏ធំមួយនៅក្នុងទីក្រុងនេះ។ ប៉ុន្តែទីក្រុង Puneមានភាពខុសពីគេពីព្រោះអ្នករើសសំរាមនៅក្នុងទីក្រុងនេះបានបង្កើតជាសហជីពមួយឈ្មោះថា Kagad Kach Patra Kashtakari Panchayat (KKPKP) ហើយចាប់តាំងពីឆ្នាំ ១៩៩៣ មកបាននឹងកំពុងតស៊ូមតិទាមទារសិទ្ធិក្នុងការមានកម្លាំងពលកម្មនេះដែលកន្លងមកបានបែកខ្ញែកគ្នានិងត្រូវបានគេដកហូតសិទ្ធិអំណាច។ ដូច្នេះកម្មវិធី SWaCH ត្រូវបានបង្កើតឡើងក្នុងនាមជាកម្មវិធីសាកល្បងមួយដោយសហជីព KKPKP និងសាលាក្រុង Pune ក្នុងឆ្នាំ២០០៥។

នៅក្នុងកម្មវិធីSWaCHអ្នករើសសំរាមម្នាក់ៗទិញភាគហ៊ុននៅក្នុងសហករណ៍។ អ្នករើសសំរាមធ្វើការជាគូ ដើម្បីប្រមូលសំរាមដោយផ្ទាល់ពីគ្រួសារចំនួនពី ១៥០ ទៅ ៤០០ខ្នងផ្ទះ។ ពួកគេបែងចែងសំរាមទៅតាមប្រភេទ ហើយទុកដាក់សំរាមដែលមិនអាចកែច្នៃឡើងវិញបាននៅចំណុចដាក់សំរាមដែលគ្រប់គ្រងដោយរដ្ឋ ហើយពួកគេទទួលបានប្រាក់ចំណូលពីយកថ្លៃសេវាប្រមូលសំរាមពីអតិថិជននិងពីការលក់សំរាមដែលអាចកែច្នៃឡើងវិញបានទៅកាន់អ្នកទិញសំរាមក្នុងមូលដ្ឋាន។ អ្នករើសសំរាមដែលផ្តល់សេវាដល់គ្រួសារដែលរស់ក្នុងតំបន់សំណង់អាណាធិបតេយ្យ ក៏ទទួលបានការឧបត្ថម្ភធន់ក្នុងមួយគ្រួសារផងដែរពីទីក្រុង ដើម្បីបំពេញបន្ថែមការពិតដែលថាជាធម្មតាមានសំរាមដែលអាចកែច្នៃឡើងវិញបានតិចតួច ត្រូវបានគេបោះចោលនៅក្នុងតំបន់ ដែលមានប្រាក់ចំណូលទាប។ ក្រុមប្រឹក្សាមួយតស៊ូមតិសម្រាប់សិទ្ធិរបស់កម្មករ និងចរចាជាមួយទីក្រុងដើម្បីទទួលបានស្តង់ដារសុខភាពនិងសុវត្ថិភាពការងារអត្ថប្រយោជន៍របស់បុគ្គលិកកម្មករ ឧបករណ៍ សម្ភារបែងចែកប្រភេទសំរាម និងការទទួលបានកែថែទាំសុខភាព។ រហូតមកដល់ពេលនេះ ពួកគេបានចរចាកិច្ចសន្យារយៈពេលវែងចំនួនពីរជាមួយសាជីវកម្មក្រុង Pune (Pune Municipal Corporation) ហើយក្នុងរយៈពេលកិច្ចសន្យាទាំងនេះ កម្មវិធី SWaCH អាចរក្សាប្រតិបត្តិការផ្តាច់មុខលើប្រាក់កម្រៃសេវាអ្នកប្រើប្រាស់។

នៅថ្ងៃនេះ ទីក្រុង Pune មានភាពខុសប្លែងពីមុនធៀបនឹងទសវត្សរ៍ឆ្នាំ១៩៩០។អ្នករើសសំរាមជាង៣.៥០០នាក់បានចូលរួមបម្រើការងារឱ្យកម្មវិធី SWaCH ដែលភាគច្រើនគឺជាស្ត្រីដែលមានវណ្ណៈទាប និងអ្នកមានវណ្ណៈទាបបំផុត "Dalits" ដែលកន្លងមកគេស្គាល់ថាជា"Untouchables"។ពួកគេទទួលខុសត្រូវប្រមូលសំរាម ១.០០០តោនរៀងរាល់ថ្ងៃ និងសម្ភារកែច្នៃឡើងវិញជាង ៧០.០០០តោនក្នុងមួយឆ្នាំ។

Mini Shrinivasan ដែលជាអតិថិជនរបស់កម្មវិធី SWaCH បានថ្លែងថា "មនុស្សគ្រប់គ្នាបានស្គាល់អ្នករើសសំរាមកាន់តែច្បាស់។ យើងបានស្គាល់ជីវិតរបស់ពួកគេច្បាស់ជាងមុនហើយឥឡូវប្រជាជនបានចាប់ផ្តើមគិតពីពួកគេក្នុងនាមជាស្ត្រីដែលធ្វើការងារ"។ ក្រៅពីទទួលបានការគោរពពីទីកន្លែងកាន់តែច្រើននៅក្នុងសង្គម បុគ្គលិកកម្មកររបស់កម្មវិធីSWaCHរកប្រាក់ចំណូលបានច្រើនជាងពីពេលកន្លងមក។ នាង Sonawane និយាយថា នាងរកបានប្រាក់ចំណូល ១៣.០០០រូពី (១៨៨ដុល្លារអាមេរិក) ក្នុងមួយខែ ដែលច្រើនជាងប្រាក់ចំណូលដែលប្តីនាងរកបាន និងទទួលបានប្រាក់ចំណូលបន្ថែមពី ៣០០ ទៅ ៥០០រូពីក្នុងមួយសប្តាហ៍ពីការលក់សំរាមដែលអាចកែច្នៃឡើងវិញបានដែលនាងប្រមូលបាន។ នាងបានថ្លែងថា "ខ្ញុំបានសង់ផ្ទះមួយដោយប្រើប្រាក់សន្សំផ្ទាល់របស់ខ្ញុំ។ខ្ញុំបានទិញសម្ភារក្នុងផ្ទះដែលខ្ញុំត្រូវការហើយក៏បានសន្សំប្រាក់សម្រាប់ការអប់រំរបស់កូនខ្ញុំផងដែរ។ Lakshmi Narayan សហស្ថាបនិកកម្មវិធី SWaCH បានថ្លែងថា "នៅថ្ងៃនេះ អ្នករើសសំរាមក្នុងកម្មវិធី SWaCH គឺជាម្ចាស់សហគ្រាសមួយដែលផ្តល់ជូនអ្នកនូវជីវភាពរស់នៅប្រកបដោយសេចក្តីថ្លៃថ្នូរ។ វាធ្វើឱ្យទីក្រុងមានបរិយាបន្នតាមវិធីជាច្រើន"។

ការរៀបចំនេះក៏ផ្តល់អត្ថប្រយោជន៍ផ្នែកសេដ្ឋកិច្ចដល់ទីក្រុងនេះផងដែរ។កម្មវិធីSWaCHប៉ាន់ប្រមាណថាម៉ូឌែលប្រាក់កម្រៃសេវាអ្នកប្រើប្រាស់បានជួយឱ្យសាជីវកម្មក្រុង Pune សន្សំប្រាក់បាន ១៣លានដុល្លារកាលពីឆ្នាំមុន ធៀបនឹងប្រព័ន្ធប្រមូលសំរាមដែលផ្តល់មូលនិធិដោយពន្ធតាមបែបប្រពៃណី។ ផលចំណេញផ្សេងទៀតនោះគឺថា បច្ចុប្បន្នប្រជាពលរដ្ឋចេះបែងចែកប្រភេទសំរាមស្ងួត និងសំរាមសើមនៅក្នុងផ្ទះរបស់ពួកគេ ដែលជាការផ្លាស់ប្តូរឥរិយាបថដ៏ធំមួយពីទម្លាប់កន្លងមកដែលបោះចោលសំរាមតាមផ្លូវ។លទ្ធផលនេះគឺជាប្រព័ន្ធប្រមូលសំរាមប្រកបដោយប្រសិទ្ធផលកាន់តែខ្លាំងបើមើលជារួម។

ប្រភព៖ ដកស្រង់ចេញពី (ប្លុក WRI ឆ្នាំ២០១៩)

ΣmPower
Women for Climate-Resilient Societies

Sweden
Sverige

arrow
asian-pacific resource & research centre for women

UN WOMEN

# សៀវភៅណែនាំ បណ្តុះបណ្តាលស្តីពី យេនឌ័រនិងភាពធន់នឹង ការប្រែប្រួលអាកាសធាតុ



## ម៉ូឌុល ២៖

## ការបង្កើតគោលនយោបាយ ស្តីពី CCDRR និងផែនការថ្នាក់ជាតិ

2

## ម៉ូឌុល ២៖ ការបង្កើតគោលនយោបាយ CCDDR និងផែនការថ្នាក់ជាតិ

**ផែនការតាមវគ្គ៖**

ម៉ូឌុលនេះត្រូវបានបែងចែងជាពីរវគ្គ។

**វគ្គ ក** : ការស្វែងយល់អំពីទិដ្ឋភាពការបន្សាំនឹងការប្រែប្រួលអាកាសធាតុ និងគោលនយោបាយ DRR

**វគ្គ ខ** : ការបញ្ជ្រាបយេនឌ័រក្នុងគោលនយោបាយ និងផែនការថ្នាក់ជាតិ

ម៉ូឌុលនេះផ្តោតលើការផ្តល់សេចក្តីសង្ខេបអំពីទិដ្ឋភាពគោលនយោបាយអាកាសធាតុ នៅថ្នាក់ពិភពលោក និងថ្នាក់ជាតិ ដែលរំលេចអំពីតួនាទីរបស់រដ្ឋាភិបាលក្នុងការដាក់យេនឌ័រនៅក្នុងក្របខ័ណ្ឌការងារទាំងនេះ និងផ្តល់លទ្ធភាពឱ្យមានដំណើរការពហុភាគី សម្រាប់ការចរចាអំពីសកម្មភាពប្រកបដោយបរិយាបន្ននៅក្នុងគោលនយោបាយអាកាសធាតុនានា។ សេចក្តីសង្ខេបនេះចាប់ផ្តើមជាមួយនឹងទិដ្ឋភាពទូទៅនៃការប្តេជ្ញាចិត្តចំពោះគោលនយោបាយអន្តរជាតិដែលមានស្រាប់ និងក្របខ័ណ្ឌការងារនានាស្តីពី CCDRR និងយេនឌ័រ ដោយផ្តោតការយកចិត្តទុកដាក់លើ UNFCCC និងក្របខ័ណ្ឌការងារទីក្រុងសេនដៃ សម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ។ សេចក្តីសង្ខេបនេះបន្តលើកឡើងអំពីរបៀបដែលក្របខ័ណ្ឌការងារថ្នាក់ពិភពលោកនានាជះឥទ្ធិពលលើយន្តការរៀបចំផែនការថ្នាក់ជាតិនៅក្នុងបរិបទនៃការប្រែប្រួលអាកាសធាតុ (CC) និងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ (DRR)។ មានការផ្តោតការយកចិត្តទុកដាក់ជាពិសេសលើរបៀបដែលផែនការបន្សាំជាតិ (NAPs) កំពុងត្រូវបានបង្កើតឡើង។ បន្ទាប់មក ម៉ូឌុលនេះរំលេចអំពីយុទ្ធសាស្ត្រចំនួនបីសម្រាប់ការបញ្ជ្រាបយេនឌ័រក្នុងគោលនយោបាយ CCDRR និង NAPs ដែលរួមមាន ក) ការលើកកម្ពស់ការវិភាគអំពីស្ថានភាពដែលមានទស្សនៈយេនឌ័រ និងការរកបានទិន្នន័យដែលមានការបែងចែកសម្រាប់ការវិភាគនេះ ខ) ការធានាឱ្យមានតុល្យភាពយេនឌ័រក្នុងការចូលរួម និងភាពជាអ្នកដឹកនាំក្នុងការចរចាអំពីអាកាសធាតុដែលកំពុងធ្វើឡើង និង គ) ការធានាឱ្យមានទំនាក់ទំនង និងការរាយការណ៍ថ្នាក់ជាតិដែលឆ្លើយតបនឹងយេនឌ័រ។ ការផ្តោតត្រូវបានធ្វើឡើងទៅលើវិធីសាស្ត្រប្រតិបត្តិការនានាចំពោះការបញ្ជ្រាបយេនឌ័រ និងតួនាទីរបស់អង្គការសង្គមស៊ីវិល (CSOs) ក្នុងការបញ្ជ្រាបនេះ។

### គោលបំណងនៃម៉ូឌុល៖

> ផ្តល់ទិដ្ឋភាពទូទៅ អំពីទិដ្ឋភាពគោលនយោបាយអាកាសធាតុពិភពលោក និងបទប្បញ្ញត្តិយេនឌ័រក្នុងក្របខ័ណ្ឌការងារថ្នាក់អន្តជាតិដែលមានស្រាប់។

> ស្វែងយល់ពីឧបករណ៍សម្រាប់ការបង្កើតផែនទីវដ្តគោលនយោបាយ និងវេទិកាធ្វើសេចក្តីសម្រេចចិត្ត។ និង

> ផ្តល់ក្របខ័ណ្ឌការងារ និងបញ្ជីត្រួតពិនិត្យសម្រាប់ CSOs ដើម្បីអនុវត្តការប៉ាន់ប្រម៉ាណចំណុចសកម្មភាពសមភាពយេនឌ័រ និងចន្លោះប្រហោងនានានៅក្នុងផែនការសកម្មភាពនិងអនុវត្តយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្នុងផែនការ CCDRR និងដើម្បីជួយកំណត់ចំណុចចាប់ផ្តើមសម្រាប់ការចរចានិងការតស៊ូមតិ។

### សារសំខាន់ៗ៖

> កិច្ចប្រជុំកំពូលស្តីពីផែនដី បានបង្កើតឱ្យមានការផ្លាស់ប្តូរដ៏ធំមួយក្នុងទិដ្ឋភាពគោលនយោបាយពិភពលោកជាមួយនឹងការយល់ដឹងកាន់តែខ្លាំងអំពីតម្រូវការឱ្យមានកិច្ចសហប្រតិបត្តិការសម្រាប់ការប្រែប្រួលអាកាសធាតុដោយសកម្មភាពមនុស្ស។ កិច្ចប្រជុំកំពូលនេះក៏មានការមើលឃើញផងដែរនូវការបង្កើត UNFCCC។ ដំបូង ការចរចា UNFCCC បានអនុម័តវិធីសាស្ត្រមជ្ឈការស្ថិតក្រោមការបង្ហាញផ្លូវពីសកម្មភាពកាត់បន្ថយនិងយន្តការផ្អែកលើទីផ្សារដូចដែលមានបង្ហាញក្នុងពិធីសារក្យូតូ។

> ក្នុងឆ្នាំ២០០១ COP លើកទី៧ ក្នុងទីក្រុង Marrakesh បានក្លាយជាចំណុចរបត់ដ៏សំខាន់មួយ ដោយសារមានសេចក្តីសម្រេចចិត្តពាក់ព័ន្ធនឹងយេនឌ័រលើកដំបូង ៣៦/CP លើកទី៧ ស្តីពីការធ្វើឱ្យប្រសើរឡើងនូវការចូលរួមរបស់ស្ត្រីក្នុងការធ្វើជាតំណាងរបស់ភាគីនានា។ COP លើកទី៧ ក៏បានបង្កើតឱ្យមានយន្តការរៀបចំផែនការថ្នាក់ជាតិដែលដឹកនាំដោយ NUFCCC ជាលើកដំបូង តាមរយៈផែនការសកម្មភាពជាតិបន្សាំនឹងការប្រែប្រួលអាកាសធាតុ (NAPAs) ដែលក៏ត្រូវបានបង្ហាញផ្លូវដោយគោលការណ៍សមភាពយេនឌ័រផងដែរ។

> វិធីសាស្ត្រវិមជ្ឈការ ទទួលបានសម្ទុះនៅក្នុងការចរចាអំពីអាកាសធាតុចាប់តាំងពីមានផែនការសកម្មភាពទីក្រុងបាលី (COP លើកទី១៣ ឆ្នាំ២០០៧) ដោយមានការទទួលស្គាល់កាន់តែខ្លាំងឡើងនូវតម្រូវការក្នុងការធ្វើសមាហរណកម្មយេនឌ័រនៅក្នុងស្ថាប័ត្យកម្មការប្រែប្រួលអាកាសធាតុអន្តរជាតិ។

> កម្មវិធីការងារក្រុងលីម៉ាស្តីពីយេនឌ័រ (LWPG) ដែលត្រូវបានអនុម័តដោយ COP លើកទី២០ នៅក្នុងឆ្នាំ២០១៤ គឺជាវឌ្ឍនភាពដ៏ធំមួយក្នុងការបង្កើតដំណើរការ UNFCCC។

> ការអនុម័តកិច្ចព្រមព្រៀងទីក្រុងប៉ារីស និងការដាក់ជូនការចូលរួមចំណែកដើម្បីអនុវត្តអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តី

ពីការប្រែប្រួលអាកាសធាតុ (INDCs) ក្នុងឆ្នាំ២០១៥ បានបង្ហាញពីកម្រិតចាប់អារម្មណ៍កាន់តែខ្លាំងចំពោះយេនឌ័រ និងការប្រែប្រួលអាកាសធាតុ។

> COP លើកទី២៥ នៅក្នុងឆ្នាំ២០១៩ បានដើរឆ្ពោះទៅមុខដើម្បីបង្កើតផែនការសកម្មភាពយេនឌ័ររយៈពេល ៥ឆ្នាំដែលត្រូវបានពង្រឹងមួយ ដែលផ្តោតលើការកសាងសមត្ថភាព ការគ្រប់គ្រងចំណេះដឹង និងទំនាក់ទំនង តុល្យភាពយេនឌ័រ ការចូលរួម និងភាពជាអ្នកដឹកនាំរបស់ស្ត្រី ការអនុវត្តបទប្បញ្ញត្តិ និងសកម្មភាពពាក់ព័ន្ធនឹងយេនឌ័រប្រកបដោយសសិទ្ធភាព ការអនុវត្តដែលឆ្លើយតបនឹងតម្រូវការយេនឌ័រនិងមធ្យោបាយអនុវត្ត ការតាមដាន និងការរាយការណ៍។

> ទិដ្ឋភាពគោលនយោបាយពិភពលោកស្តីពី DRR មានកម្រិតធ្វើសមាហរណកម្មយេនឌ័រកាន់តែខ្ពស់ជាមួយក្របខ័ណ្ឌការងារយូហ្គូ (Hyogo) ដើម្បីសកម្មភាព និងក្របខ័ណ្ឌការងារទីក្រុងសេនដៃ ដែលទទួលស្គាល់យ៉ាងច្បាស់លាស់ថា ស្ត្រីគឺជាអ្នកដើរតួនាទីដ៏សំខាន់មួយក្នុង DRR។

> ដំណើរការពិភពលោកក៏មានផលប៉ះពាល់ដ៏ធំផងមួយដែរនៅថ្នាក់ជាតិ។ មិនត្រឹមតែមានប្រទេសអភិវឌ្ឍន៍តិចតួច (LDCs) ប៉ុណ្ណោះទេដែលបានបង្កើតនិងដាក់ជូន NAPAs របស់ខ្លួន ប៉ុន្តែថែមទាំងប្រទេសកាន់តែច្រើនឡើងកំពុងបង្កើតគោលនយោបាយ និងផែនការកាប្រែប្រួលអាកាសធាតុ និង DRR ផ្ទាល់របស់ខ្លួន។ ដំណើរការផែនការជាតិបន្សាំ (NAP) នឹងពង្រឹងបន្ថែមទៀតនូវការងារនេះ។

> វាមានសារៈសំខាន់ណាស់ដើម្បីបញ្ជ្រាបយេនឌ័រទៅក្នុងគោលនយោបាយ និងផែនការ CCDRR។ យុទ្ធសាស្ត្រសំខាន់ៗមួយចំនួនឆ្ពោះទៅរកការបញ្ជ្រាបយេនឌ័រនេះរួមមាន ក) តុល្យភាពយេនឌ័រក្នុងការចូលរួម និងភាពជាអ្នកដឹកនាំ ខ) ការបង្កើតយន្តការស្ថាប័នសម្រាប់កំណត់ការទទួលខុសត្រូវសម្រាប់ការញ្ជ្រាបយេនឌ័រ និងការសម្របសម្រួលរវាងទីភ្នាក់ងារនានា គ) ការចែករំលែកចំណេះដឹងនិងការកសាងសមត្ថភាពដែលត្រូវបានផ្តោតការយកចិត្តទុកដាក់ ឃ) ការបង្កើតដំណើរការ NAP ង) ការបង្កើតការចូលរួមចំណែករបស់ជាតិ (NDCs) ច) ការបង្កើតផែនការសកម្មភាពការប្រែប្រួលអាកាសធាតុនិងយេនឌ័រ (CCGAP) ឆ) ការអនុវត្ត ការតាមដាន និងការត្រួតពិនិត្យដែលឆ្លើយតបនឹងតម្រូវការយេនឌ័រ និង ជ) ស្ថិតិយេនឌ័រ និងព័ត៌មានបែងចែកតាមភេទ។

> តួនាទីរបស់រដ្ឋាភិបាលថ្នាក់ជាតិ និង អង្គការសង្គមស៊ីវិល (CSOs) មានសារៈសំខាន់ខ្លាំងសម្រាប់ការបញ្ជ្រាបយេនឌ័រក្នុងគោលនយោបាយ និងផែនការ CCDRR។

## វគ្គ ក ៖ ការស្វែងយល់អំពីទិដ្ឋភាពការបន្សាំនឹងការប្រែប្រួលអាកាសធាតុ និងគោលនយោបាយកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ

| 3:30:00 | សិទ្ធិមនុស្ស មិនមានអ្នកណាម្នាក់ត្រូវ បានទុកចោល និងសមភាពយេនឌ័រ |
|---|---|
| ទិដ្ឋភាពទូទៅ | នៅចុងបញ្ចប់នៃវគ្គនេះអ្នកចូលរួមគួរយល់ដឹងអំពីស្ថាបត្យកម្មអន្តរជាតិសម្រាប់CCDRRនិងបទប្បញ្ញត្តិយេនឌ័រ។ ពួកគេគួរតែអាចភ្ជាប់ទំនាក់ទំនងបទប្បញ្ញត្តិអន្តរជាតិទាំងនេះជាមួយនឹងយន្តការរៀបចំផែនការថ្នាក់ជាតិ និងកំណត់ចំណុចចាប់ផ្តើមសម្រាប់ការបញ្ជ្រាបយេនឌ័រនៅក្នុងដំណើរការថ្នាក់ជាតិ។ |
| មាតិកា | ក) ការប្តេជ្ញាចិត្តនិងក្របខ័ណ្ឌគោលនយោយអន្តរជាតិសម្រាប់ CCDRR<br>ក. អនុសញ្ញាក្របខ័ណ្ឌការងារសហប្រជាជាតិ ស្តីពីការប្រែប្រួលអាកាសធាតុ (UNFCCC)<br>ខ. ក្របខ័ណ្ឌការងារទីក្រុងសេនដៃសម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ<br>ខ) អនុសាសន៍ CCDRR នៃអនុសញ្ញាស្តីពីសមភាពយេនឌ័រ និងសិទ្ធិនារីពហុភាគី<br>គ) ក្របខ័ណ្ឌការងាររៀបចំផែនការថ្នាក់ជាតិសម្រាប់ CCDRR ស្ថិតក្រោម UNFCCC<br>ក. កម្មវិធីសកម្មភាពជាតិបន្សាំនឹងការប្រែប្រួលអាកាសធាតុ (NAPAs)<br>ខ. ផែនការបន្សាំថ្នាក់ជាតិ (NAP)<br>គ. ការចូលរួមចំណែករបស់ជាតិ (NDCs)<br>ឃ) ក្របខ័ណ្ឌការងារជាតិសម្រាប់ CCDRR និងការបញ្ជ្រាបយេនឌ័រនៅថ្នាក់ប្រទេស<br>ក. ករណីសិក្សាអំពីប្រទេស (ប្រទេសបង់ក្លាដែស) |
| ឯកសារ | បទបង្ហាញជា PowerPoint<br>ក្តារខៀន និងប៊ិចហ្វឺតធំ<br>ក្រដាសផ្ទាំងធំ និងប៊ិច<br>សំណៅឯកសារមួយច្បាប់ |

## តារាងពេលវេលា



| រយៈពេល | សកម្មភាព |
|---|---|
| ៥នាទី | > ការចែករំលែកអំពីទិដ្ឋភាពទូទៅ និងមាតិកានៃវគ្គ |
| ៤០នាទី | > "លំហាត់ក្រ័រ (Tic Tac Toe)" ស្ដីពីក្របខ័ណ្ឌការងារ CCDRR អន្តរជាតិ (សូមមើលលំហាត់ទី៩ និងសំណៅឯកសារទី ៧) |
| ៣០នាទី | > បទបង្ហាញជា PowerPoint ស្ដីពី "ក្របខ័ណ្ឌការងារគោលនយោបាយ CCDRR ពិភពលោក (UNFCCC និងក្របខ័ណ្ឌការងារទីក្រុងសេនដៃ) និងការប្ដេជ្ញាចិត្តចំពោះយេនឌ័រ" |
| ៤៥នាទី | > ការពិភាក្សាជាក្រុមស្ដីពី "ការអនុវត្ត UNFCCC និងក្របខ័ណ្ឌទីក្រុងសេនដៃនៅថ្នាក់ជាតិ" (សូមមើលលំហាត់ទី១០ និងសំណៅឯកសារទី ៨) |
| ៤៥នាទី | > បទបង្ហាញជា PowerPoint ស្ដីពី "ក្របខ័ណ្ឌជាតិសម្រាប់ CCDRR និងការបញ្ជ្រាបយេនឌ័រនៅថ្នាក់ប្រទេស" |
| ៤៥នាទី | > ក្រុមការងារទទួលបន្ទុកវិភាគយេនឌ័រនៃ "NAP និង NDC" ដោយប្រើប្រាស់បញ្ជីត្រួតពិនិត្យ (សូមមើលលំហាត់ទី១១និងសំណៅឯកសារទី៩)(ផ្ដល់អនុសាសន៍សម្រាប់វគ្គមូលដ្ឋាន) |
| | ឬ |
| | > ក្រុមការងារទទួលបន្ទុកការបង្កើតរបាយការណ៍ស្រមោលសម្រាប់ "CEDAW និង BPfA" ស្ដីពីស្ថានភាពនៃការបញ្ជ្រាបយេនឌ័រក្នុងគោលនយោបាយ CCDDR ថ្នាក់ជាតិ (សូមមើលលំហាត់ទី១២ និងសំណៅឯកសារទី១០) (ផ្ដល់អនុសាសន៍សម្រាប់វគ្គកម្រិតខ្ពស់) |

## កំណត់សម្គាល់ណែនាំ



ចាប់ផ្ដើមវគ្គនេះតាមរយៈការចែករំលែកគោលបំណងរបស់ម៉ូឌុល និងផែនការតាមវគ្គ។ ចែករំលែកសំណៅឯកសារទី៧ ទៅឱ្យអ្នកចូលរួមទាំងអស់ ហើយផ្ដល់ពេលវេលាដល់ពួកគេរយៈពេល ១០នាទី ដើម្បីអានសំណៅឯកសារនេះ (២០នាទីសម្រាប់វគ្គមូលដ្ឋានគ្រឹះ)។ ឥឡូវបែងចែកពួកគេជាពីរក្រុម ហើយសម្របសម្រួលធ្វើលំហាត់ "ក្រ័រ" (សូមមើលលំហាត់ទី៩ និងសំណៅឯកសារទី៧)។ ធ្វើលំហាត់ម្ដងទៀតសម្រាប់វគ្គមូលដ្ឋានគ្រឹះ ហើយសង្ខេបចំណុចបន្ថែមមួយចំនួនអំពី "ក្របខ័ណ្ឌការងារគោលនយោបាយCCDRRពិភពលោក(UNFCCC និងក្របខ័ណ្ឌការងារទីក្រុងសេនដៃ) និងការប្ដេជ្ញាចិត្តចំពោះយេនឌ័រ"។សម្រាប់វគ្គកម្រិតខ្ពស់ចូរធ្វើបទបង្ហាញជាPowerPointលម្អិតអំពីគោលបំណងរបស់ក្របខ័ណ្ឌការងារទាំងនេះ។ឥឡូវបែងចែកអ្នកចូលរួមជាបួនក្រុម ហើយប្រាប់ពួកគេថា ឥឡូវពួកគេនឹងរុករកវិធីដែលក្របខ័ណ្ឌការងារទាំងនេះអាចត្រូវបានប្រើប្រាស់នៅថ្នាក់ជាតិ។ សម្របសម្រួលការពិភាក្សាជាក្រុមអំពី "ការអនុវត្ត UNFCC និងក្របខ័ណ្ឌទីក្រុងសេនដៃនៅថ្នាក់ជាតិ" (សូមមើលលំហាត់ទី១០ និងសំណៅឯកសារទី៨)។ ប្រសិនបើអ្នកគិតថា មានសម្ភារច្រើនពេកសម្រាប់ក្រុមនីមួយៗ អ្នកក៏អាចបំបែកផ្នែកនីមួយៗទៅជា ២ផ្នែក ហើយបង្កើតជា ៨ក្រុមសម្រាប់ការពិភាក្សា។ ការងារនេះនឹងជានាបាននូវការពិភាក្សាកាន់តែលម្អិតនៅក្នុងពេលវេលាដែលមានកម្រិត ហើយក៏គ្របដណ្ដប់លើរាល់ចំណុចទាំងអស់ផងដែរ។

ឥឡូវធ្វើបទបង្ហាញជា PowerPoint លម្អិតអំពី "ក្របខ័ណ្ឌការងារជាតិសម្រាប់ CCDRR និងការបញ្ជ្រាបយេនឌ័រនៅថ្នាក់ប្រទេស"។យើងបានផ្ដល់ករណីសិក្សាមួយអំពីប្រទេសបង់ក្លាដែសសម្រាប់ធ្វើជាឯកសារយោង។ ចូររួមបញ្ចូលករណីសិក្សានេះនៅក្នុងបទបង្ហាញ។ ទោះជាយ៉ាងណា ប្រសិនបើអ្នកចូលរួមមកពីប្រទេសផ្សេងៗ ចូរប្រើប្រាស់ទម្រង់ករណីសិក្សាអំពីប្រទេសបង់ក្លាដែស ដើម្បីផ្ដល់ជូនពួកគេនូវសេចក្ដីលម្អិតអំពីក្របខ័ណ្ឌការងារ CCDRR នៅក្នុងប្រទេសផ្ទាល់របស់ពួកគេ។ អ្នកអាចសំដៅលើគោលនយោបាយ និងផែនការជាក់លាក់របស់ប្រទេស ដែលមានបង្ហាញក្នុងតារាងទី៤ អំពីការពិនិត្យការបញ្ជ្រាបយេនឌ័រនៃផែនការ CCDRR ក្នុងប្រទេសមួយចំនួននៅតំបន់អាស៊ីសម្រាប់ការងារនេះ។ បញ្ចប់វគ្គនេះជាមួយនឹងការធ្វើការងារជាក្រុមអំពី "ការប៉ាន់ប្រមាណយេនឌ័រនៃ NDCs/NAPs" សម្រាប់វគ្គមូលដ្ឋានគ្រឹះ និង "ការរាយការណ៍ស្រមោល CEDAW ស្ដីពី CCDRR" សម្រាប់វគ្គកម្រិតខ្ពស់។

## ក្របខ័ណ្ឌការងារគោលនយោបាយការប្រែប្រួលអាកាសធាតុនិងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ(CCDRR) សកល

### អនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (UNFCCC)

កង្វល់អំពីបរិស្ថាន និងការប្រែប្រួលអាកាសធាតុបានស្ថិតនៅលើរបៀបវារៈគោលនយោបាយអន្តរជាតិចាប់តាំងពីដើមទសវត្សរ៍ឆ្នាំ១៩៧០មក ដោយចាប់ផ្តើមជាមួយនឹងសន្និសីទអង្គការសហប្រជាជាតិ ស្តីពីបរិស្ថានមនុស្ស (UNCHE) ក្នុងឆ្នាំ១៩៧២ និងសន្និសីទអាកាសធាតុពិភពលោក (WCC) ក្នុងឆ្នាំ១៩៧៩។ ក្រុមការងារអន្តររដ្ឋាភិបាលស្តីពីការប្រែប្រួលអាកាសធាតុ(IPCC) ដំបូងត្រូវបានបង្កើតឡើងក្នុងឆ្នាំ១៩៨៨ ដើម្បីពិនិត្យ និងវាយតម្លៃទិន្នន័យបែបវិទ្យាសាស្ត្រ បច្ចេកទេស និងសង្គមសេដ្ឋកិច្ចអំពីការប្រែប្រួលអាកាសធាតុ។ កិច្ចប្រឹងប្រែងកាន់តែខ្លាំងឡើងក្នុងរយៈពេលជាច្រើនឆ្នាំមកនេះ បានផ្តល់ជាតុចូលដែលត្រូវការយ៉ាងខ្លាំងចំពោះបញ្ហាដែលត្រូវបានលើកឡើងនៅក្នុងសន្និសីទអង្គការសហប្រជាជាតិស្តីពីបរិស្ថាន និងអភិវឌ្ឍន៍ (UNCED) ដែលបានរៀបចំធ្វើឡើងនៅទីក្រុងរីយ៉ូដឺចាណេរ៉ូ (Rio de Janeiro) ប្រទេសប្រេស៊ីលក្នុងឆ្នាំ១៩៩២។ ដោយត្រូវបានគេស្គាល់យ៉ាងទូលំទូលាយថាជា "កិច្ចប្រជុំកំពូលស្តីពីផែនដី" កិច្ចប្រជុំកំពូលនេះ គឺជាទីដែលសហគមន៍អន្តរជាតិបានព្រមព្រៀងគ្នាលើអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិ ស្តីពីការប្រែប្រួលអាកាសធាតុ (UNFCCC)។

UNFCCCបានផ្តល់ក្របខ័ណ្ឌការងារស្របច្បាប់មួយដែលបានផ្តល់លទ្ធភាពឱ្យមានការចរចាកិច្ចព្រមព្រៀងស្តីពីអាកាសធាតុផ្សេងៗរៀងរាល់ឆ្នាំនៅក្នុងសន្និសីទបណ្តាភាគី (COP)។ COP គឺជាអាជ្ញាធរធ្វើសេចក្តីសម្រេចចិត្តខ្ពស់បំផុតរបស់ UNFCCC និងជាវេទិកាដ៏សំខាន់មួយសម្រាប់ព្រឹត្តិការណ៍ ស្តីពីអាកាសធាតុអន្តរជាតិទាំងអស់គិតចាប់តាំងពីឆ្នាំ១៩៩៥មក នៅពេលដែល COP លើកដំបូងត្រូវបានរៀបចំធ្វើឡើង។ UNFCCC មានគោលបំណងចម្បងមួយដើម្បីរក្សាស្ថិរភាពការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ (GHG) ពិភពលោក ដើម្បីបង្ការការប្រែប្រួលអាកាសធាតុដែលបង្កឡើងដោយមនុស្ស។ ដំណើរឆ្ពោះមករកការសម្រេចគោលបំណងនេះ ការចូលរួមចំណែកដ៏សំខាន់បំផុតក្នុងចំណោមការចូលរួមចំណែកផ្សេងៗទៀតរបស់ UNFCCC គឺពិធីសារក្យូតូដែលបានចូលជាធរមានក្នុងឆ្នាំ២០០៥ ផែនការសកម្មភាពទីក្រុងបាលីក្នុង ឆ្នាំ២០០៧ និងកិច្ចព្រមព្រៀងទីក្រុងប៉ារីសឆ្នាំ២០១៥។

ក្នុងរយៈពេលជាច្រើនឆ្នាំមកនេះUNFCCCក៏បានទទួលស្គាល់ភាពងាយរងគ្រោះរបស់ប្រទេសកំពុងអភិវឌ្ឍន៍ទៅនឹងការប្រែប្រួលអាកាសធាតុផងដែរនិងបានទទួលស្គាល់ថាសិទ្ធិរបស់ប្រទេសទាំងនេះក្នុងការទទួលបានការអភិវឌ្ឍនិងកំណើនសេដ្ឋកិច្ចប្រកបដោយនិរន្តរភាពអាស្រ័យលើសកម្មភាពអាកាសធាតុជាសមូហភាព។

> **គន្លឹះសម្រាប់គ្រូឧទ្ទេស**
>
> សម្រាប់វគ្គមូលដ្ឋានគ្រឹះខ្លឹមសារអំពីក្របខ័ណ្ឌអន្តរជាតិ អាចផ្តោតលើការដាក់កម្រិតដល់ការចែករំលែកព័ត៌មានក្នុងអំឡុងវគ្គបញ្ចប់នៃលំហាត់ក្រ៉ូ (Tic Tac Toe)។ ទោះជាយ៉ាងណា ក្របខ័ណ្ឌទាំងនេះនឹងត្រូវការពេលវេលាបន្ថែមទៀតជាងពេលវេលាដែលត្រូវបានស្នើឡើងសម្រាប់អ្នកចូលរួមតាមរយៈសំណៅឯកសារទី៧។ លើសពីនេះទៀត ធ្វើលំហាត់យ៉ាងហោចណាស់ពីរដងសម្រាប់វគ្គមូលដ្ឋានគ្រឹះ។

ទោះជាយ៉ាងណា អ្វីដែលជាវិធីសាស្ត្រមជ្ឈការដ៏ចម្បងបានប្រែក្លាយទៅជាដំណើរការវិមជ្ឈការចាប់តាំងពីមានCOPលើកទី១៣នៅក្នុងទីក្រុងបាលី។ ការផ្លាស់ប្តូរយ៉ាងច្បាស់ក្រឡែតនេះបានកើតមានឡើងបន្ទាប់ពីមានការចូលរួមពីអង្គការសង្គមស៊ីវិលក្នុងការចរចា COP ជាពិសេសអង្គការដែលផ្តោតលើស្ត្រី ដែលបានដឹកនាំឆ្ពោះទៅរកការផ្តោតការយកចិត្តទុកដាក់កាន់តែខ្លាំងឡើងលើសមភាពយេនឌ័រនៅក្នុង UNFCCC។

ដូច្នេះ UNFCCC ដែលមិនមានបទប្បញ្ញត្តិសមភាពយេនឌ័រនៅក្នុងរយៈពេលប៉ុន្មានឆ្នាំដំបូងរបស់ខ្លួននោះ សម្រាប់ជាលើកដំបូងក្នុង COP លើកទី៧ នៅទៅក្រុង Marrakesh បានអនុម័តអត្ថបទដំបូងរបស់ខ្លួនស្តីពីសមភាពយេនឌ័រនិងការចូលរួមរបស់ស្ត្រី រួមជាមួយបទប្បញ្ញត្តិមួយដែលកម្មវិធីសកម្មភាពជាតិបន្សាំនឹងការប្រែប្រួលអាកាសធាតុ (NAPAs) ត្រូវបានបង្ហាញផ្លូវដោយសមភាពយេនឌ័រ។កិច្ចប្រឹងប្រែងបន្ថែមទៀតអស់រយៈពេល៩ឆ្នាំជាចុងក្រោយបានដឹកនាំឆ្ពោះទៅរកការទទួលយកសមភាពយេនឌ័រនិងការចូលរួមរបស់ស្ត្រីថាជាសមាសធាតុមួយសម្រាប់សកម្មភាពប្រកបដោយប្រសិទ្ធភាពលើរាល់ទិដ្ឋភាពទាំងអស់នៃការប្រែប្រួលអាកាសធាតុនៅ COP លើកទី១៦ នៅទីក្រុងដូហា។ ចាប់តាំងពីពេលនោះមក កង្វល់យេនឌ័របាននាំផ្លូវស្ទើរតែរាល់សកម្មភាពទាំងអស់របស់UNFCCCហើយគិតត្រឹមពាក់កណ្តាលឆ្នាំ២០១៥ UNFCCC មានបទប្បញ្ញត្តិជាង ៥០ ស្តីពីសមភាពយេនឌ័រ (Aguilar et al ឆ្នាំ២០១៥)។

សន្និសីទបណ្តាភាគី (COP) បច្ចុប្បន្ននេះមានរបៀបវារៈអចិន្ត្រៃយ៍មួយស្តីពីយេនឌ័រនិងការប្រែប្រួលអាកាសធាតុហើយក្នុងឆ្នាំ២០១២ (COP លើកទី១៨) សន្និសីទនេះក៏បានចាប់ផ្តើមសម្រេចចិត្តរក្សាទុកតុល្យភាពយេនឌ័រនិងការចូលរួមរបស់ស្ត្រីក្នុង COPនិងក្នុងព្រឹត្តិការណ៍ដែលពាក់ព័ន្ធទាំងអស់។កិច្ចព្រមព្រៀងទីក្រុងប៉ារីស ដែលត្រូវបានអនុម័តដោយ COP ចំពោះ UNFCCC ក្នុងឆ្នាំ២០១៥ ក៏បានកត់សម្គាល់នៅក្នុងបុព្វកថារបស់ខ្លួនផងដែរថា "នៅពេលចាត់វិធានការដោះស្រាយការប្រែប្រួលអាកាសធាតុ បណ្តាភាគីគួរគោរព លើកកម្ពស់ និងពិចារណាលើកាតព្វកិច្ចរៀងៗខ្លួនរបស់ពួកគេចំពោះសិទ្ធិមនុស្សសិទ្ធិទទួលបានការថែទាំ

សុខភាពសិទ្ធិរបស់ជនជាតិដើមភាគតិចសហគមន៍មូលដ្ឋានជនអន្តោប្រវេសន៍កុមារជនពិការនិងអ្នកដែលស្ថិតក្នុងស្ថានភាពងាយរងគ្រោះ និងសិទ្ធិទទួលបានការអភិវឌ្ឍ ព្រមទាំងសមភាពយេនឌ័រ ការផ្តល់ភាពអង់អាចដល់ស្ត្រីនិងសមភាពអន្តរជំនាន់(UNFCCC COP លើកទី២១ ឆ្នាំ២០១៤)។ បណ្តាភាគីនៃកិច្ចព្រមព្រៀងទីក្រុងប៉ារីសក៏បានទទួលស្គាល់ផងដែរថា ការបន្សាំរួមទាំងការកសាងសមត្ថភាពសម្រាប់សកម្មភាពកាត់បន្ថយនិងបន្សាំគួរត្រូវតែជាវិធានការដែលឆ្លើយតបនឹងតម្រូវការយេនឌ័រ ដែលមានការចូលរួមនិងមានតម្លាភាពពេញលេញដោយពិចារណាលើក្រុមងាយរងគ្រោះ សហគមន៍ និងប្រព័ន្ធអេកូឡូស៊ី (អង្គការ UN Women ឆ្នាំ២០១៦)។

ទោះជាយ៉ាងណាសេចក្តីសម្រេចចិត្តដ៏គួរឱ្យកត់សម្គាល់ទាក់ទងនឹងយេនឌ័រ បានកើតចេញជារូបរាងក្នុង COP លើកទី២០ ក្នុងឆ្នាំ២០១៤ តាមរយៈការដាក់ដំណើរការកម្មវិធីការងារក្រុងលីម៉ាស្តីពីយេនឌ័រ (LWPG)។ LWPG (ឆ្នាំ២០១៤) បង្កើតកម្មវិធីការងាររយៈពេល ២ឆ្នាំមួយ ដែលរួមមាន៖

> ការពិនិត្យការអនុវត្តបទប្បញ្ញត្តិពាក់ព័ន្ធនឹងយេនឌ័រទាំងអស់ដោយលេខាធិការដ្ឋាន UNFCCC។
> ការបណ្តុះបណ្តាលនិងការបង្កើនការយល់ដឹងសម្រាប់គណៈប្រតិភូទទួលបន្ទុកគោលនយោបាយអាកាសធាតុដែលឆ្លើយតបនឹងតម្រូវការយេនឌ័រ។
> ការបណ្តុះបណ្តាល និងការកសាងសមត្ថភាពសម្រាប់គណៈប្រតិភូស្ត្រី។
> សិក្ខាសាលាក្នុងវគ្គស្តីពីយេនឌ័រចំនួនពីរ(ពាក់ព័ន្ធនឹងការកាត់បន្ថយ បច្ចេកវិទ្យា ការបន្សាំ និងការកសាងសមត្ថភាព) នៅ SBI ៤២ និង ៤៤។
> ការដាក់ជូនកម្មវិធីការងារពីសំណាក់បណ្តាភាគីនៅក្នុងសិក្ខាសាលាទាំងនេះ។
> ឯកសារបច្ចេកទេសរបស់លេខាធិការដ្ឋាន UNFCCC ស្តីពីគោលការណ៍ណែនាំសម្រាប់ការអនុវត្តការពិចារណាលើយេនឌ័រក្នុងសកម្មភាពការប្រែប្រួលអាកាសធាតុ។ និង
> ការតែងតាំងជនបង្គោលជាន់ខ្ពស់ទទួលបន្ទុកយេនឌ័រនៅលេខាធិការដ្ឋាន UNFCCC។

គិតត្រឹមខែកញ្ញា ឆ្នាំ២០២០ ភាគីចំនួន៧៣ភាគី រួមទាំងសហភាពអឺរ៉ុបផងដែរ បានតែងតាំងជនបង្គោលទទួលបន្ទុកយេនឌ័រ ដូចដែលត្រូវបានផ្តល់សិទ្ធិអំណាចដោយ LWPG (គេហទំព័ររបស់ UNFCCC ឆ្នាំ២០២០)។

ក្នុងឆ្នាំ២០១៧ COP លើកទី២៣ បាននាំ LWPG ឱ្យដើរឆ្ពោះទៅមុខជាមួយនឹងការអនុម័តផែនការសកម្មភាពយេនឌ័រ (GAP) ហើយនៅក្នុង COP លើកទី២៥ ឆ្នាំ២០១៩ LWPG និង GAP ដែលត្រូវបានពង្រឹង ត្រូវបានអនុម័ត។ GAP រយៈពេល ៥ឆ្នាំចុងក្រោយបំផុតនេះ (UNFCCC ឆ្នាំ២០១៩) ត្រូវបានព្រមព្រៀងគ្នាជាឯកច្ឆ័ន្ទដោយរដ្ឋាភិបាលនានាដែលបានអំពាវនាវឱ្យមានការដឹកនាំ ឬចូលរួមចំណែកចំពោះសកម្មភាពលើកកម្ពស់សមភាពយេនឌ័រក្នុងដំណើរការ UNFCCC ព្រមទាំងគាំទ្រវាល់សកម្មភាពទាំងអស់។ GAP ត្រូវបានពង្រីកដោយផ្អែកលើ GAP ដំបូង និងដោះស្រាយតម្រូវការក្នុងការពង្រីកកម្មវិធីដំណោះស្រាយអាកាសធាតុសម្រាប់យេនឌ័រ (GJCS) និងការអនុវត្តសកម្មភាពកាន់តែខ្លាំងឡើង។ ការផ្តោតការយកចិត្តទុកដាក់កំពុងធ្វើឡើងទៅលើការពិចារណាលើសិទ្ធិមនុស្សក្នុងសកម្មភាពអាកាសធាតុការរួមបញ្ចូលបញ្ហាប្រឈមប្លែកពីគេដែលជួបប្រទះដោយជនជាតិដើមភាគតិច និងការលើកកម្ពស់សកម្មភាពក្នុងដំណោះស្រាយបច្ចេកវិទ្យាអាកាសធាតុដែលឆ្លើយតបនឹងតម្រូវការយេនឌ័រនិងក្នុងការអភិរក្សចំណេះដឹងប្រពៃណី។

GAP កំណត់គោលបំណង និងសកម្មភាពស្ថិតក្រោមវិស័យអាទិភាពចំនួន៥ ដែលមានបំណងពង្រីកចំណេះដឹង និងការស្វែងយល់សកម្មភាពអាកាសធាតុដែលឆ្លើយតបនឹងតម្រូវការយេនឌ័រនិងការបញ្ជ្រាបប្រកបដោយសិនិទ្ធភាពរបស់ខ្លួនក្នុងការអនុវត្ត UNFCCC និងការងាររបស់បណ្តាភាគី លេខាធិការដ្ឋានអង្គភាពរបស់អង្គការសហប្រជាជាតិនិងភាគីពាក់ព័ន្ធទាំងអស់នៅគ្រប់កម្រិតថ្នាក់ ព្រមទាំងការចូលរួមពេញលេញដោយស្មើភាព និងពោរពេញដោយអត្ថន័យរបស់ស្ត្រីក្នុងដំណើរការ UNFCC។ ទាំងអស់នេះរួមមាន៖

ក. ការកសាងសមត្ថភាព ការគ្រប់គ្រងចំណេះដឹង និងទំនាក់ទំនង។
ខ. តុល្យភាពយេនឌ័រ ការចូលរួម និងភាពជាអ្នកដឹកនាំរបស់ស្ត្រី។
គ. ការអនុវត្តបទប្បញ្ញត្តិ និងសកម្មភាពដែលពាក់ព័ន្ធនឹងយេនឌ័រប្រកបដោយសិនិទ្ធភាព និងសង្គតិភាព។
ឃ. ការអនុវត្តដែលឆ្លើយតបនឹងតម្រូវការយេនឌ័រនិងមធ្យោបាយអនុវត្ត។
ង. ការតាមដាន និងការរាយការណ៍។

## កត្តារុញជំរុញ និងយុទ្ធសាស្ត្រដែលឈានទៅរកការបង្កើត UNFCC

ប្រការសំខាន់ត្រូវស្វែងយល់និងរៀនសូត្រពីកត្តាជំរុញនានាដែលបានចូលរួមចំណែកដល់ការបញ្ជ្រាបយេនឌ័រក្នុង UNFCCC។ កត្តាចូលរួមចំណែកសំខាន់ៗមួយចំនួន រួមមាន៖

ក) ការកើនឡើងឥទ្ធិពលសិទ្ធិមនុស្សដែលកំពុងវិវឌ្ឍ និងក្របខ័ណ្ឌការងារអភិវឌ្ឍន៍ប្រកបដោយចីរភាពក្នុងរយៈពេលដូចគ្នា។
ខ) ការកើនឡើងការយល់ដឹងអំពីតម្រូវការសមភាពយេនឌ័រថាជាផ្នែកដ៏សំខាន់មួយនៃគំរូអភិវឌ្ឍន៍ប្រកបដោយចីរភាពនិងប្រសិទ្ធផល។
គ) កិច្ចប្រឹងប្រែងជាសមូហភាព និងដែលមានការព្រមព្រៀង

ទុកជាមុនរបស់អ្នកគាំទ្រយេនឌ័រដូចជាទីភ្នាក់ងារនានារបស់អង្គការសហប្រជាជាតិអង្គការសង្គមស៊ីវិលអ្នកសិក្សានិងអ្នកស្រាវជ្រាវ រួមទាំងបណ្តាញឈានមុខគ្នានានាដូចជាសម្ព័ន្ធយេនឌ័រ និងអាកាសធាតុសកល (GGCA), GenderCC, LIFE e.V. ។ល។ និង

ឃ) ការកើនឡើងការស្រាវជ្រាវនិងភស្តុតាងអំពីអន្តរទំនាក់ទំនងរវាងយេនឌ័រ និងការប្រែប្រួលអាកាសធាតុ។

ទោះជាយ៉ាងណា អ្វីដែលមានសារៈសំខាន់ដែលត្រូវលើកឡើងផងដែរនោះគឺតួនាទីរបស់យន្តការស្ថាប័នដែលជះឥទ្ធិពលប្រកបដោយយុទ្ធសាស្រ្តលើដំណើរការនេះ។ ទាំងអស់នេះរួមមាន៖

ក) មូលនិធិគណៈប្រតិភូស្រ្តី (WDF)៖ ដោយទទួលស្គាល់តម្រូវការគាំទ្រដល់ការចូលរួមប្រកបដោយសមធម៌និងភាពជាអ្នកដឹកនាំរបស់ស្រ្តីក្នុងការចរចាអំពីអាកាសធាតុរបស់អង្គការសហប្រជាជាតិជាពិសេសពីប្រទេសដែលរងឥទ្ធិពលបំផុតពីការប្រែប្រួលអាកាសធាតុ ក្នុងឆ្នាំ២០០៩ រដ្ឋាភិបាលរបស់ប្រទេសហ្វាំងឡង់បានចាប់ដៃគូធ្វើការងារជាមួយអង្គការស្រ្តីដើម្បីបរិស្ថាន និងអភិវឌ្ឍន៍ (WEDO) ដោយមានការគាំទ្រពី GGCA ដើម្បីដាក់ដំណើរការ WDF។ WDF ធ្វើការងារដើម្បីពង្រឹងការចូលរួមរបស់ស្ត្រីក្នុងប្រតិភូកម្មថ្នាក់ជាតិសម្រាប់ការចរចាអំពីអាកាសធាតុតាមរយៈការផ្តល់ការគាំទ្រការធ្វើដំណើរ ជាពិសេសគណៈប្រតិភូកម្មពីប្រទេសអភិវឌ្ឍន៍តិចតួច (LDCs) ហើយក៏តាមរយៈការកសាងជំនាញភាពជាអ្នកដឹកនាំផងដែរតាមរយៈការកសាងចំណេះដឹងនិងសមត្ថភាពពាក់ព័ន្ធនឹងបញ្ហាបច្ចេកទេសទាក់ទងនឹងការចរចា ប្រព័ន្ធផ្សព្វផ្សាយ និងទំនាក់ទំនង (Aguilar et al ឆ្នាំ២០១៥)។

ខ) សង្គមស្ត្រី និងយេនឌ័រ (WGC)៖ បើទោះជាអង្គការដែលផ្តោតលើស្ត្រីមានភាពសកម្មក្នុង UNFCCC ចាប់តាំងពីចាប់ផ្តើមមកក្តី ក៏ក្នុងរយៈពេល ១៥ឆ្នាំដំបូងនៃការចូលរួមនេះមិនមែនជាការចូលរួមផ្លូវការឡើយ។ ក្នុងឆ្នាំ២០០៨ អង្គការសង្គមស៊ីវិលស្ត្រីដ៏សកម្មនានា បានដាក់ពាក្យសុំឋានៈសង្គមបណ្តោះអាសន្នដើម្បីទទួលបានការទទួលស្គាល់ជាផ្លូវការ និងមានលទ្ធភាពទទួលបានបណ្តាញផ្លូវការនានាដើម្បីផ្តល់ធាតុចូលទៅក្នុងដំណើរការចរចា។ ឋានៈបណ្តោះអាសន្នមួយត្រូវបានផ្តល់ជូនក្នុងឆ្នាំ២០០៩ សម្រាប់ WGC។ WGC បានប្រតិបត្តិការពេញលេញក្នុងឆ្នាំ២០១៥ ហើយអាចមានធ្វើការដាក់ជូនឯកសារនានា និងធ្វើអន្តរាគមនៅនឹងកន្លែងព្រមទាំងចូលរួមក្នុងសិក្ខាសាលាក្នុងវគ្គជាច្រើន និងព្រឹត្តិការណ៍ផ្សេងៗទៀត។ WGC ក៏ធ្វើការងារយ៉ាងជិតស្និទ្ធផងដែរជាមួយសង្គមធំៗផ្សេងទៀតរួមទាំងសង្គមយុវជនជនជាតិដើមភាគតិច សហជីព និងអង្គការមិនមែនរដ្ឋាភិបាល (NGOs) ដែលធ្វើការងារលើបរិស្ថាន (Aguilar et al ឆ្នាំ២០១៥)។

គ) សន្ទុះដើម្បីការផ្លាស់ប្តូរស្រ្តីដើម្បីលទ្ធផល (W4R)៖ ក្នុងឆ្នាំ២០១២ លេខាធិការដ្ឋាន UNFCCC ខ្លួនឯងផ្ទាល់ដោយមានការគាំទ្រពីមូលនិធិ Rockefeller បានដាក់ដំណើរការគំនិតផ្តួចផ្តើមមួយឈ្មោះថា "សន្ទុះដើម្បីការផ្លាស់ប្តូរ" ដែលទទួលស្គាល់ដំណោះស្រាយប្រកបដោយនវានុវត្តន៍ និងការផ្លាស់ប្តូរ ដែលដោះស្រាយទាំងបញ្ហាប្រឈមការប្រែប្រួលអាកាសធាតុ និងបញ្ហាប្រឈមសេដ្ឋកិច្ច សង្គម និងបរិស្ថានកាន់តែទូលំទូលាយ។ ដោយត្រូវបានគេហៅថាសកម្មភាព Lighthouse គម្រោងដែលត្រូវបានជ្រើសរើសថាជាអ្នកឈ្នះនៃការប្រកួតប្រជែងដ៏មានកិត្យានុភាពនេះ បានទៅលើប្រភេទជាក់លាក់នានា ដូចជាគម្រោងដែលមានឈ្មោះថា ស្រ្តីដើម្បីលទ្ធផល (W4R)។ អ្នកឈ្នះមិនត្រឹមតែទទួលបានឱកាសដើម្បីចូលរួម និងបង្ហាញការងាររបស់ពួកគេនៅ COP នាដំណាក់កាលបន្ទាប់ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងទទួលបានលទ្ធភាពជួបអ្នកបង្កើតគោលនយោបាយ និងអ្នកផ្តល់មូលនិធិសក្តានុពលនានាក្នុងអំឡុងសន្និសីទនេះការទទួលស្គាល់ជាសាធារណៈដោយលេខាធិការដ្ឋានការប្រែប្រួលអាកាសធាតុរបស់អង្គការសហប្រជាជាតិ ការគាំទ្រផ្នែកទំនាក់ទំនងសាធារណៈ និងការបណ្តុះបណ្តាលផ្នែកប្រព័ន្ធផ្សព្វផ្សាយសម្ភារធ្វើទីផ្សាររួមទាំងវីដេអូផ្សព្វផ្សាយកន្លែងមួយទំព័រនៅលើគេហទំព័ររបស់យើងដើម្បីរៀបរាប់អំពីគម្រោងរបស់អ្នក និងការថតរូបអាជីព (គេហទំព័ររបស់ UNFCCC)។

### ក្របខ័ណ្ឌការងារទីក្រុងសេនដៃសម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ (DRR)

ក្របខ័ណ្ឌការងារ Hyogo ដើម្បីសកម្មភាព (HFA) ឆ្នាំ២០០៥ដែលជាផែនការរយៈពេល១០ឆ្នាំសម្រាប់ការកាត់បន្ថយហានិភ័យ ត្រូវបានបង្កើតឡើងនៅឯសន្និសីទពិភពលោក ស្តីពីការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយក្នុងទីក្រុងកូបេប្រទេសជប៉ុនសម្រាប់ការកសាងភាពធន់របស់ប្រទេស និងសហគមន៍ទៅនឹងគ្រោះមហន្តរាយ។ ក្របខ័ណ្ឌការងារទីក្រុងសេនដៃសម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ឆ្នាំ២០១៥-២០៣០ គឺជាឧបករណ៍ស្នងបន្តពី HFA ហើយត្រូវបានអនុម័តនៅឯសន្និសីទពិភពលោកអង្គការសហប្រជាជាតិលើកទី៣ ក្នុងទីក្រុងសេនដៃប្រទេសជប៉ុននៅក្នុងឆ្នាំ២០១៥។ លក្ខណៈពិសេសសំខាន់ៗក្នុងចំណោមការផ្តោតការយកចិត្តទុកដាក់ដ៏ខ្លាំងរបស់ក្របខ័ណ្ឌការងារទីក្រុងសេនដៃលើការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយដែលផ្ទុយទៅនឹងការគ្រប់គ្រងគ្រោះមហន្តរាយ ផ្តោតលើការបង្ការការកាត់បន្ថយ ភាពត្រៀមបង្ការ ការឆ្លើយតប ការស្តារឡើងវិញ និងការស្តារនីតិសម្បទាដែលជាផ្នែកមួយនៃការគ្រប់គ្រងហានិភ័យ

គ្រោះមហន្តរាយ ការទទួលស្គាល់ការប្រែប្រួលអាកាសធាតុថាជាគ្រោះមហន្តរាយដែលកំពុងកើតមានកាន់តែខ្លាំងឡើងហើយក៏ថាជាកត្តាដែលបង្កឱ្យមានហានិភ័យគ្រោះមហន្តរាយផងដែរ និងអំពាវនាវឱ្យមានសិនិទ្ធភាពនៃគោលនយោបាយ DRR ការអភិវឌ្ឍប្រកបដោយចីរភាពគោលនយោបាយការប្រែប្រួលអាកាសធាតុ និងគោលនយោបាយផ្សេងទៀតសម្រាប់ការធ្វើឱ្យប្រសើរឡើងនូវភាពសក្តិសិទ្ធិ និងប្រសិទ្ធភាព។ ក្របខ័ណ្ឌការងារទីក្រុងសេនដៃ (UNDRR ឆ្នាំ២០១៥) ក៏មានលទ្ធផលជាក់លាក់ គោលដៅអាទិភាពចំនួន៤និងទិសដៅសកលចំនួន៧ផងដែរដែលត្រូវបានដាក់ចេញនៅក្នុងផ្នែ កខាងក្រោម៖

**លទ្ធផល៖** ការកាត់បន្ថយប្រកបដោយចីរភាពនូវហានិភ័យគ្រោះមហន្តរាយ និងការបាត់បង់ជីវិត របរចិញ្ចឹមជីវិត និងសុខភាព។

**គោលដៅ៖** បង្ការហានិភ័យគ្រោះមហន្តរាយថ្មី និងកាត់បន្ថយហានិភ័យគ្រោះមហន្តរាយដែលមានស្រាប់ តាមរយៈការអនុវត្តវិធានការដែលត្រូវធ្វើសមាហរណកម្មប្រកបដោយបរិយាបន្ន ដែលបង្ការ និងកាត់បន្ថយការប្រឈមនឹងគ្រោះថ្នាក់ និងភាពងាយរងគ្រោះទៅនឹងគ្រោះមហន្តរាយ បង្កើនភាពត្រៀមបង្ការសម្រាប់ការឆ្លើយតប និងការស្តារឡើងវិញ ហើយដូច្នេះវានឹងពង្រឹងភាពធន់។

**អាទិភាព៖**

១៖ ការបង្កើតគោលនយោបាយ និងការអនុវត្ត អំពីការយល់ដឹងហានិភ័យគ្រោះមហន្តរាយក្នុងវិសាលភាពរបស់ខ្លួនទាំងអស់នៃភាពងាយរងគ្រោះ សមត្ថភាព ការប្រឈមរបស់មនុស្ស និងទ្រព្យសម្បត្តិ លក្ខណៈគ្រោះថ្នាក់ និងបរិស្ថាន។

២៖ ពង្រឹងអភិបាលកិច្ចហានិភ័យគ្រោះមហន្តរាយ នៅថ្នាក់ជាតិ តំបន់ និងពិភពលោកសម្រាប់ការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល។ ជាមួយនឹងទស្សនវិស័យច្បាស់លាស់ ផែនការ សមត្ថភាព ការណែនាំ និងការសម្របសម្រួលនៅក្នុងនិងនៅទូទាំងវិស័យនានាព្រមទាំងការចូលរួមរបស់ភាគីពាក់ព័ន្ធទាំងអស់ ត្រូវការជាចាំបាច់។

៣៖ វិនិយោគលើការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយដើម្បីពង្រឹងភាពធន់របស់ សេដ្ឋកិច្ច សង្គម សុខាភិបាល និងវប្បធម៌ របស់មនុស្ស សហគមន៍ ប្រទេស និងទ្រព្យសម្បត្តិរបស់ពួកគេ ព្រមទាំងបរិស្ថានផងដែរ។

៤៖ ពង្រឹងភាពត្រៀមបង្ការទប់ទល់នឹងគ្រោះមហន្តរាយសម្រាប់ការឆ្លើយតបប្រកបដោយប្រសិទ្ធភាពនិងយុទ្ធសាស្ត្រ"កសាងឡើងវិញកាន់តែប្រសើរ (BBB)" ក្នុងការស្តារឡើងវិញ ការស្តារនីតិសម្បទា និងការសាងសង់ឡើងវិញ។ ការផ្តល់ភាពអង់អាចដល់ស្ត្រី និងជនពិការឱ្យដឹកនាំនិងលើកកម្ពស់ជាសាធារណៈនូវយុទ្ធសាស្ត្រឆ្លើយតប ស្តារឡើងវិញ ស្តារនីតិសម្បទា និងសាងសង់ឡើងវិញដែលមានសមភាពយេនឌ័រ និងដែលអាចមានលទ្ធភាពទទួលបានជាលក្ខណៈសកលគឺជាគន្លឹះដ៏សំខាន់។

**ទិសដៅសកលចំនួន ៧៖**

១) កាត់បន្ថយប្រកបដោយចីរភាពនូវមរណភាពដោយសារគ្រោះមហន្តរាយជាសកលនៅត្រឹមឆ្នាំ២០៣០ ដែលមានគោលបំណងកាត់បន្ថយអត្រាមរណភាពជាមធ្យមក្នុងចំណោម ១០០.០០០នាក់ ក្នុងទសវត្សរ៍ឆ្នាំ២០២០-២០៣០ ធៀបនឹងរយៈពេលពី ២០០៥-២០១៥។

២) កាត់បន្ថយប្រកបដោយចីរភាពនូវចំនួនមនុស្សដែលរងផលប៉ះពាល់នៅទាំងពិភពលោកនៅត្រឹម ឆ្នាំ២០៣០ ដែលមានគោលបំណងកាត់បន្ថយតួលេខជាមធ្យមនៅទូទាំងពិភពលោកក្នុងចំណោម១០០.០០០នាក់ក្នុងទសវត្សរ៍ឆ្នាំ២០២០-២០៣០ ធៀបនឹងរយៈពេលពី ២០០៥-២០១៥។

៣) កាត់បន្ថយការខាតបង់ផ្នែកសេដ្ឋកិច្ចដោយសារគ្រោះមហន្តរាយដោយផ្ទាល់ ទាក់ទងនឹងផលិតផលក្នុងស្រុកសរុប (GDP) ពិភពលោកនៅត្រឹមឆ្នាំ២០៣០។

៤) កាត់បន្ថយប្រកបដោយចីរភាពនូវការខូចខាតហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗដោយសារគ្រោះមហន្តរាយនិងការអាក់ខានសេវាជាមូលដ្ឋាននានាដែលក្នុងចំណោមនោះរួមមានឋបនីយភណ្ឌសុខាភិបាល និងអប់រំ រួមទាំងតាមរយៈការបង្កើតភាពធន់របស់ពួកគេនៅត្រឹមឆ្នាំ២០៣០។

៥) បង្កើនប្រកបដោយចីរភាព នូវចំនួនប្រទេសដែលមានយុទ្ធសាស្ត្រកាត់បន្ថយហានិភ័យគ្រោះមហន្តរាយថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាននៅត្រឹមឆ្នាំ២០២០។

៦) ពង្រឹងប្រកបដោយចីរភាពនូវកិច្ចសហប្រតិបត្តិការអន្តរជាតិចំពោះប្រទេសកំពុងអភិវឌ្ឍន៍តាមរយៈការគាំទ្រ គ្រប់គ្រាន់ និងប្រកបដោយនិរន្តរភាព ដើម្បីបំពេញបន្ថែមសកម្មភាពថ្នាក់ជាតិរបស់ប្រទេសទាំងនោះសម្រាប់ការអនុវត្តក្របខ័ណ្ឌការងារបច្ចុប្បន្ននៅត្រឹមឆ្នាំ២០៣០។ និង

៧) បង្កើនប្រកបដោយចីរភាពនូវភាពអាចរកបាន និងលទ្ធភាពទទួលបានសម្រាប់ប្រជាជននូវប្រព័ន្ធប្រកាសអាសន្នពហុគ្រោះថ្នាក់ និងព័ត៌មានហានិភ័យ និងការប៉ាន់ប្រម៉ាណនានានៅត្រឹមឆ្នាំ២០៣០។

HFA មានគោលដៅមួយ ដើម្បីកាត់បន្ថយប្រកបដោយនិរន្តរភាពនូវការបាត់បង់ដោយសារគ្រោះមហន្តរាយនៅត្រឹមឆ្នាំ២០១៥ និងមានបទប្បញ្ញត្តិច្បាស់លាស់មួយដែលថា "ទស្សនៈយេនឌ័រ" គួរត្រូវបានធ្វើសមាហរណកម្មទៅក្នុងគោលនយោបាយ ផែនការ និងដំណើរការធ្វើសេចក្តីសម្រេចចិត្តពាក់ព័ន្ធនឹងការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយទាំងអស់រួមទាំងអ្វីដែលពាក់ព័ន្ធនឹងការ

ប៉ាន់ប្រម៉ាណហានិភ័យការប្រកាសអាសន្នការគ្រប់គ្រងព័ត៌មាន ព្រមទាំងការអប់រំ និងការបណ្តុះបណ្តាល"។

ក្របខ័ណ្ឌការងារទីក្រុងសេនដៃ ពង្រីកវិសាលភាពទាក់ទងនឹងយេនឌ័រ នៅពេលដែលក្របខ័ណ្ឌនេះ៖
**ទទួលស្គាល់ការពិចារណាលើយេនឌ័រថាជាអាទិភាពមួយសម្រាប់ភាពត្រៀមបង្ការទប់ទងនឹងគ្រោះមហន្តរាយដែលត្រូវបានពង្រឹង៖** "ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយតម្រូវឱ្យមានការចូលរួម និងភាពជាដៃគូពីគ្រប់សង្គមទាំងអស់។ វាក៏តម្រូវឱ្យមានការផ្តល់អំណាច និងការចូលរួមប្រកបដោយបរិយាបន្ន មានលទ្ធភាពទទួលបាន និងមិនមានការរើសអើងផងដែរ ដោយផ្តោតការយកចិត្តទុកដាក់ជាពិសេសលើប្រជាជនដែលរងផលប៉ះពាល់យ៉ាងខ្លាំងពីគ្រោះមហន្តរាយ ជាពិសេសប្រជាជនក្រីក្របំផុត។ ទស្សនៈយេនឌ័រ អាយុ ពិការភាព និងវប្បធម៌ គួរត្រូវបានធ្វើសមាហរណកម្មទៅក្នុងគោលនយោបាយនិងការអនុវត្តទាំងអស់ ហើយភាពជាអ្នកដឹកនាំស្ត្រី និងយុវជន គួរត្រូវបានលើកកម្ពស់។ ក្នុងបរិបទនេះការយកចិត្តទុកដាក់ពិសេសគួរត្រូវបានផ្តោតលើការលើកកម្ពស់ការងារស្ម័គ្រចិត្តដែលមានការរៀបចំរបស់ពលរដ្ឋ"។
**ទទួលស្គាល់តួនាទីរបស់ស្ត្រីថាជាភាគីពាក់ព័ន្ធសំខាន់៖** "ស្ត្រី និងការចូលរួមរបស់ស្ត្រីមានសារៈសំខាន់ចំពោះការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ ការបង្កើត ការផ្តល់ធនធាន និងការអនុវត្តគោលនយោបាយផែនការនិងកម្មវិធីកាត់បន្ថយហានិភ័យគ្រោះមហន្តរាយដែលឆ្លើយតបនឹងតម្រូវការយេនឌ័រប្រកបដោយប្រសិទ្ធភាព ហើយវិធានការកសាងសមត្ថភាពគ្រប់គ្រាន់ចាំបាច់ត្រូវធ្វើឡើងដើម្បីផ្តល់ភាពអង់អាចដល់ស្ត្រីសម្រាប់ការត្រៀមបង្ការ ព្រមទាំងដើម្បីកសាងសមត្ថភាពរបស់ពួកគេក្នុងការធានាបាននូវមធ្យោបាយចិញ្ចឹមជីវិតជំនួសក្នុងស្ថានភាពក្រោយគ្រោះមហន្តរាយ"។

ការិយាល័យអង្គការសហប្រជាជាតិទទួលបន្ទុកការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ (UNDRR) ត្រូវបានផ្តល់ភារកិច្ចឱ្យគាំទ្រដល់ការអនុវត្ត តាមដាន និងពិនិត្យក្របខ័ណ្ឌការងារទីក្រុងសេនដៃ។ ក្នុងការបំពេញភារកិច្ចនេះ UNDRR បានដាក់ដំណើរការវេទិកាអនឡាញការប្តេជ្ញាចិត្តដោយស្ម័គ្រចិត្តចំពោះក្របខ័ណ្ឌការងារទីក្រុងសេនដៃ (SFVC) ក្នុង ឆ្នាំ២០១៨ ដោយមានគោលបំណងកៀរគរ ពិនិត្យ និងបូកសរុបការប្តេជ្ញាចិត្តនានាពីភាគីពាក់ព័ន្ធចម្រុះសម្រាប់ការអនុវត្តក្របខ័ណ្ឌនេះ។ ក្នុង ឆ្នាំ២០១៩ UNISDR បានចេញផ្សាយរបាយការណ៍លើកដំបូងស្តីពី SFVC ដែលបានរួមបញ្ចូលគ្នានិងបានវិភាគការប្តេជ្ញាចិត្តដោយស្ម័គ្រចិត្តដែលបានចេញផ្សាយរហូតមកដល់ពេលបច្ចុប្បន្ននេះ។ របាយការណ៍នេះបានលើកឡើងពីគម្លាតក្នុងការអនុវត្តបទប្បញ្ញត្តិយេនឌ័រ។ ជាមួយនឹងការប្តេជ្ញាចិត្តដោយស្ម័គ្រចិត្តចំនួនតែ៦យេនឌ័រមានតែនៅក្នុង ៣% នៃប្រធានបទប៉ុណ្ណោះដែលគ្របដណ្តប់លើការប្តេជ្ញាចិត្តដោយស្ម័គ្រចិត្ត។ ដូចដែលរបាយការណ៍លើកឡើង "ការកើនឡើងការផ្តោតការយកចិត្តទុកដាក់ត្រូវការជាចាំបាច់ទៅលើអាទិភាពសម្រាប់សកម្មភាព ៣ ទិសដៅ ឃ និង ច ប្រធានបទនានាដូចជាកុមារ និងយុវជន យេនឌ័រ និងវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា រួមជាមួយនឹងគ្រោះថ្នាក់នានាដែលមានការពាក់ព័ន្ធនឹងបរិបទដែលការប្តេជ្ញាចិត្តដោយស្ម័គ្រចិត្តកំពុងត្រូវបានអនុវត្ត" (UNDRR ឆ្នាំ ២០១៩)។

## ក្របខ័ណ្ឌថ្នាក់ជាតិនានាសម្រាប់ CCDRR និងការបញ្ជ្រាបយេនឌ័រ

តាមរយៈយន្តការ និងកម្មវិធីផ្សេងៗដែលត្រូវបានកំណត់ស្ថិតក្រោម UNFCCC ប្រទេសនានាមានឱកាសកំណត់តម្រូវការ អាទិភាព យុទ្ធសាស្ត្រ និងសកម្មភាពការប្រែប្រួលអាកាសធាតុតាមមធ្យោបាយជាច្រើន។ អ្វីដែលសំខាន់បំផុតក្នុងចំណោមទាំងអស់នេះគឺជាទំនាក់ទំនងថ្នាក់ជាតិ កម្មវិធីសកម្មភាពជាតិបន្សាំនឹងការប្រែប្រួលអាកាសធាតុ (NAPA) ផែនការបន្សាំថ្នាក់ជាតិ (NAP) និងការចូលរួមចំណែករបស់ជាតិ (NDCs)។ ផ្នែកនេះផ្តល់ជូនទិដ្ឋភាពទូទៅដោយសង្ខេបអំពីការរៀបចំផែនការចំនួនពីរពាក់ព័ន្ធនឹងយន្តការ NAPAs និង NAPs។

### កម្មវិធីសកម្មភាពបន្សាំជាតិ (NAPAs)

COP ឆ្នាំ២០០១ ក្នុងទីក្រុង Marrakesh បានបង្កើតកម្មវិធីការងារប្រទេសអភិវឌ្ឍន៍តិចតួច(LDCs)ដោយមានគោលបំណងផ្តល់ការគាំទ្រដល់ប្រទេសទាំងនេះក្នុងការដោះស្រាយភាពងាយរងគ្រោះរបស់ខ្លួន។ ការណ៍នេះរួមមានកម្មវិធីសកម្មភាពបន្សាំជាតិ (NAPAs) ដែលផ្តល់ជូនដំណើរការមួយសម្រាប់ LDCs ដើម្បីកំណត់សកម្មភាពអាទិភាពនានាដែលឆ្លើយតបទៅនឹងតម្រូវការបន្ទាន់ និងភ្លាមៗទាក់ទងនឹងការន្សាំនឹងការប្រែប្រួលអាកាសធាតុ ដែលការពន្យាពេលការឆ្លើយតបទៅនឹងតម្រូវការទាំងនោះអាចបង្កើនភាពងាយរងគ្រោះឬឈានទៅរកការចំណាយកាន់តែច្រើននៅពេលក្រោយមក (គេហទំព័ររបស់ UNFCCC)។

លក្ខណៈសំខាន់ៗនៃ NAPAs រួមមាន៖

ក) ការកំណត់ភាពងាយរងគ្រោះពាក់ព័ន្ធនឹងអាកាសធាតុជាក់លាក់ និងតម្រូវការបន្សាំភ្លាមៗ និងបន្ទាន់របស់ប្រទេស LCDs។

ខ) វិធីសាស្ត្រពហុវិន័យដែលផ្អែកលើផែនការនិងកម្មវិធីដែលមានស្រាប់ដោយមានគោលបំណងបញ្ជ្រាប NAPAs ទៅក្នុងការរៀបចំផែនការអភិវឌ្ឍ។

គ) មិនមានមូលដ្ឋានលើការស្រាវជ្រាវ ដោយផ្តោតការយកចិត្តទុកដាក់លើដំណើរការដែលមានការចូលរួម។ NAPAs ផ្អែកលើព័ត៌មានដែលមានស្រាប់ដោយមានធាតុចូលសហគមន៍ជាប្រភពដ៏សំខាន់មួយ។

ង) មានបញ្ជីសកម្មភាពនិងគម្រោងបន្សាំអាទិភាពដែលត្រូវបានផ្តល់ចំណាត់ថ្នាក់ ដោយមានប្រូហ្វាល់ខ្លីៗរបស់សកម្មភាព

និងគម្រោងនីមួយៗដើម្បីជួយដល់ការបង្កើតសំណើរសម្រាប់ការអភិវឌ្ឍ។

ច) ផ្តោតលើសកម្មភាព ដោយកត្តាប្រទេស មានភាពបត់បែន និងមានមូលដ្ឋានលើកាលៈទេសៈជាតិ។ និង

ឆ) បង្ហាញក្នុងទម្រង់សាមញ្ញមួយ ដែលងាយស្រួលយល់ទាំងសម្រាប់អ្នកធ្វើសេចក្តីសម្រេចចិត្តកម្រិតគោលនយោបាយ និងសាធារណជន។

នៅពេល NAPA ត្រូវបានដាក់ជូនទៅកាន់លេខាធិការដ្ឋាន UNFCCC ភាគី LDC មានសិទ្ធិទទួលបានមូលនិធិស្ថិតក្រោមមូលនិធិប្រទេសអភិវឌ្ឍន៍តិចតួច(LDCF)ដែលត្រូវបានគ្រប់គ្រងដោយមូលនិធិបរិស្ថានពិភពលោក (GEF) សម្រាប់ការអនុវត្ត NAPA។ គិតត្រឹមខែធ្នូ ឆ្នាំ២០១៧ ប្រទេសចំនួន៥១ បានបញ្ចប់ និងបានដាក់ជូន NAPAs របស់ពួកគេទៅកាន់លេខាធិការដ្ឋាន UNFCCC (UNFCCC ឆ្នាំ២០១៧)។

NAPAsត្រូវបានបង្កើតឡើងសម្រាប់ប្រទេសខាងក្រោមក្នុងតំបន់អាស៊ី៖ អាហ្វហ្គានីស្ថាន (២០០៩) បង់ក្លាដែស (២០០៥ ធ្វើបច្ចុប្បន្នភាពនៅឆ្នាំ២០០៩) ប៊ូតង់ (២០០៦) កម្ពុជា (២០០៧) ឡាវ (២០០៩) ម៉ាល់ឌីវ (២០០៨) មីយ៉ាន់ម៉ា (២០១៣) នេប៉ាល់ (២០១០) ទីម័រខាងកើត (២០១១)។ ទាំងអស់នេះអាចរកបានតាមរយៈគេហទំព័រ https://unfccc.int/topics/resilience/workstreams/national-adaptation-programmes-of-action/napas-received

មូលនិធិUNFPAនិងអង្គការWEDO(ឆ្នាំ២០០៩)បានលើកឡើងថាតើហេតុអ្វីបានជាការតស៊ូមតិរបស់ស្ត្រី ឬយេនឌ័រគួរយកចិត្តទុកដាក់ចំពោះ NAPAs ដោយលើកឡើងពីបញ្ហាដ៏សំខាន់ដែលត្រូវសម្លឹងមើលនៅក្នុង NAPAs ដែលមានស្រាប់៖

> តើភាពងាយរងគ្រោះសំខាន់ៗអ្វីដែលត្រូវបានកំណត់?

• តើអាទិភាព និងកង្វល់របស់ស្ត្រីនៅថ្នាក់ប្រទេសត្រូវបានកំណត់ និងរួមបញ្ចូលឬទេ?

> តើសកម្មភាពអ្វីដែលត្រូវបានកំណត់អាទិភាពនៅក្នុងNAPA របស់ប្រទេសហើយតើអ្នកណានឹងទទួលបានអត្ថប្រយោជន៍ពីសកម្មភាពទាំងនេះ?

•តើជីវភាពរបស់នៅរបស់បុរស និងស្ត្រីនឹងទទួលរងផលប៉ះពាល់យ៉ាងដូចម្តេចពីជម្រើសទាំងនេះ?

• តើកង្វល់អំពីការមិនមានពេលវេលាផ្ទាល់ខ្លួនរបស់ស្ត្រីត្រូវបានរួមបញ្ចូលដែរឬទេ?

> តើធាតុចូលរបស់សហគមន៍ត្រូវបានប្រមូលយ៉ាងដូចម្តេចនៅក្នុងដំណាក់កាលរៀបចំ?

• តើអ្នកណាបានចូលរួមក្នុងដំណើរការនេះ?

• តើស្ត្រី និងបុរសនៅកម្រិតមូលដ្ឋានបានចូលរួមក្នុងដំណើរការពិគ្រោះយោបល់ដែរឬទេ?

### ការប្រតិបត្តិល្អចំពោះការបញ្ជ្រាបយេនឌ័រក្នុង NAPAs

មានកិច្ចប្រឹងប្រែងល្អមួយចំនួននៅថ្នាក់ប្រទេសឆ្ពោះទៅរកកិច្ចការទាំងនេះ។ ឧទាហរណ៍៖

> ប្រទេសបង់ក្លាដែសកំណត់សមភាពយេនឌ័រថាជាលក្ខណៈវិនិច្ឆ័យមួយសម្រាប់ការជ្រើសរើសសកម្មភាពនានា។ ក្នុងចំណោមគម្រោងចំនួន១៥ដែលត្រូវបានដាក់ចេញគម្រោងចំនួន៣ រួមបញ្ចូលស្ត្រីក្នុងចំណោមអ្នកទទួលផល។ ស្ត្រីជនជាតិដើមភាគតិចបានចូលរួមក្នុងដំណើរការ NAPA។

> ក្រុមដែលផ្តោតលើស្ត្រីបានចូលរួមក្នុងការបង្កើត NAPA សម្រាប់ប្រទេសអេរីត្រេ ហើយគ្រួសារដែលមានស្ត្រីជាមេគ្រួសារត្រូវបានកំណត់ទិសដៅយ៉ាងពិសេសដោយគម្រោងមួយក្នុងចំណោមគម្រោងទាំងនេះ។

> ក្នុងប្រទេសម៉ាឡាវីអង្គការមិនមែនរដ្ឋាភិបាលដែលផ្តោតលើស្ត្រីត្រូវបានពិគ្រោះយោបល់ក្នុងអំឡុងពេលរៀបចំ NAPA ហើយយេនឌ័រគឺជាលក្ខណៈវិនិច្ឆ័យមួយក្នុងចំណោមលក្ខណៈវិនិច្ឆ័យចំនួន៨ សម្រាប់ការជ្រើសរើសគម្រោង។ អន្តរាគមន៍ដែលត្រូវបានស្នើឡើង រាប់បញ្ចូលការផ្តល់ភាពអង់អាចដល់ស្ត្រីតាមរយៈលទ្ធភាពទទួលបានមីក្រូហិរញ្ញវត្ថុ ដែលធានាឱ្យមានលទ្ធភាពកាន់តែងាយស្រួលក្នុងការទទួលបានប្រភពទឹក និងថាមពល និងកម្មវិធីអគ្គិសនីភាវូបនីយកម្មជនបទ។ សកម្មភាពអាទិភាពចំនួន៣(ក្នុងចំណោម៥)នឹងបែងចែកអ្នកទទួលផលទៅតាមអាយុ និងភេទ។

ជាអកុសល មិនមែន NAPAs ទាំងអស់រួមបញ្ចូលស្ត្រី ឬឱ្យពួកគេចូលរួមជាភាគីពាក់ព័ន្ធដោយផ្ទាល់នោះទេ។ការបង្កើនការយល់ដឹងក្នុងសហគមន៍អំពីការបែងចែកកម្លាំងពលកម្មតាមយេនឌ័រការបង់ថ្លៃសាលាដើម្បីកុំឱ្យគេបដិសេធផ្តល់ការអប់រំដល់កុមារី ការធ្វើការដោយផ្ទាល់ជាមួយស្ត្រីលើបច្ចេកទេស ឬប្រព័ន្ធប្រមូលប្រកបដោយនិរន្តរភាព ឬសូម្បីតែការកំណត់គំនិតផ្តួចផ្តើមមីក្រូហិរញ្ញវត្ថុសម្រាប់ស្ត្រី និងបុរសដើម្បីបង្កើតមូលនិធិមួយសម្រាប់ការទិញទឹកក្នុងគ្រាអាសន្នដែលអាចត្រូវបានរួមបញ្ចូលក្នុង NAPA ថាជាសកម្មភាពដែលមានរំញោចយេនឌ័រដែលនឹងពង្រឹងប្រសិទ្ធភាពរបស់ខ្លួនផងដែរនោះ មិនមានវត្តមាននោះទេ (UNFPA និង WEDO ឆ្នាំ២០០៩)។

ក្នុងខែមេសា ឆ្នាំ២០០៩ក្រុមប្រឹក្សាយោបល់យេនឌ័រ(GAT) នៅការិយាល័យអង្គការសហប្រជាជាតិទទួលបន្ទុកសម្របសម្រួលកិច្ចការមនុស្សធម៌(OCHA)បានធ្វើការពិនិត្យផែនការចំនួន៣៩ដែលមាន។ក្រុមប្រឹក្សាយោបល់យេនឌ័របានសន្និដ្ឋានថាបើទោះជា NAPAs មួយចំនួនបានលើកឡើងអំពីសមភាពយេនឌ័រ និង

ការផ្តល់ភាពអង់អាចដល់ស្ត្រីថាជាគោលការណ៍ក៏ដោយ ក៏គ្មាន NAPAs ណាមួយបានបង្ហាញពីការប្តេជ្ញាចិត្តច្បាស់លាស់ចំពោះគោលការណ៍ទាំងនេះដោយការបញ្ជ្រាបយេនឌ័រតាមរយៈឯកសារនេះទេ។ មានតែ NAPAs ប្រហែលពាក់កណ្តាលប៉ុណ្ណោះដែលបានកំណត់ផលប៉ះពាល់ដែលមានភាពខុសគ្នាតាមយេនឌ័រពីការប្រែប្រួលអាកាសធាតុ ហើយភាគច្រើននៃ NAPAs ទាំងនេះ បានទទួលស្គាល់ស្ត្រីថាជាក្រុមងាយរងគ្រោះជាពិសេស។

លើសពីនេះទៀត មាន NAPAs តិចតួចបំផុតដែលបង្ហាញពីការប្តេជ្ញាចិត្តចំពោះសមភាពយេនឌ័រតាមរយៈគម្រោងរបស់ពួកគេ បើទោះជាការពិតគឺថា NAPAs មួយចំនួនបានលើកឡើងថាសមភាពយេនឌ័រ និង/ឬការផ្តល់ភាពអង់អាចរបស់ស្ត្រីបានបង្ហាញផ្លូវសម្រាប់គម្រោងនេះក៏ដោយ។ ឧទាហរណ៍ មិនមាន NAPA សម្រាប់ប្រទេសបង់ក្លាដែស ឬសម្រាប់ប្រទេសកម្ពុជា រួមបញ្ចូលស្ត្រីថាជាភាគីពាក់ព័ន្ធ ឬជាតួអង្គ ឬផ្តោតការយកចិត្តទុកដាក់ជាក់លាក់ដល់តួនាទីរបស់ស្ត្រី និងកុមារីក្នុងបរិបទនៃការប្រែប្រួលអាកាសធាតុនោះឡើយ។ ផ្ទុយទៅវិញ ស្ត្រីត្រូវបានកំណត់ថាជាក្រុមងាយរងគ្រោះបំផុត និងស្ថិតក្នុងតម្រូវការឱ្យមានការការពារ (អង្គការ UN Women ឆ្នាំ២០១៦)។

បើទោះជា NAPAs ភាគច្រើនត្រូវបានសរសេររួចហើយក៏ដោយ ក៏មិនមែនគម្រោងទាំងអស់ត្រូវបានអនុម័តនោះទេ ហើយនៅតែមានឱកាសក្នុងការជះឥទ្ធិពលដល់ដំណើរការនោះជាពិសេសនៅថ្នាក់ជាតិ និងនៅក្នុងទីភ្នាក់ងារអនុវត្ត។ ការពិតគឺថា ស្ត្រីត្រូវបានរាប់បញ្ចូលជាប្រចាំថាស្ថិតក្នុងចំណោម "ក្រុមងាយរងគ្រោះបំផុត" ហើយដូច្នេះគួរតែជាទិសដៅចម្បងរបស់គម្រោង NAPA និងផ្តល់ជូនចំណុចចាប់ផ្តើមមួយដើម្បីធានាថា តម្រូវការជាក់លាក់របស់ពួកគេត្រូវបានយកមកពិចារណា។

## ផែនការបន្សាំជាតិ (NAP)

ដំណើរការផែនការបន្សាំជាតិ (NAP) ត្រូវបានបង្កើតឡើងក្នុងឆ្នាំ២០១១ ក្នុងទីក្រុង Durban ហើយក្រោយមកក្នុងឆ្នាំ២០១២ ក្រុមអ្នកជំនាញរបស់ UNFCCC បានបង្កើតបណ្តុំគោលការណ៍ណែនាំបច្ចេកទេស NAP លម្អិតមួយ ដើម្បីជួយដល់ប្រទេសកំពុងអភិវឌ្ឍន៍ ជាពិសេសប្រទេសអភិវឌ្ឍន៍តិចតួច (LDCs) ដែលមានការរៀបចំផែនការបន្សាំ។

ដំណើរការ NAP បង្កើតឡើងដោយឈរលើគោលការណ៍ដែលការរៀបចំផែនការបន្សាំ គឺជាដំណើរការជាបន្តដំណើរកាកំពុងវិវឌ្ឍ និងដំណើរការដដែលៗ (iterative process)។ ដូច្នេះ NAP គឺជាដំណើរការដែលមានភាពបត់បែនមួយ ដែលរួមបញ្ចូលយុទ្ធសាស្ត្រ និងអាទិភាពក្នុងស្រុក រួមជាមួយនឹងគោលការណ៍ណែនាំអន្តរជាតិខាងក្រោម។ ហេតុដូចនេះ ប្រទេសនានាអនុវត្តការរៀបចំផែនការបន្សាំនឹងអាកាសធាតុរយៈពេលមធ្យមនិងរយៈពេលដ៏ទូលំទូលាយដែលមូលដ្ឋានលើសកម្មភាពបន្សាំដែលមានស្រាប់របស់ប្រទេសនីមួយៗ និងជួយធ្វើសមាហរណកម្មការប្រែប្រួលអាកាសធាតុទៅក្នុងការធ្វើសេចក្តីសម្រេចចិត្តថ្នាក់ជាតិ។

ដំណើរការនេះមាន "សមាសធាតុ" សំខាន់ៗចំនួន៤ ដែលសមាសធាតុនីមួយៗមាន ៤ ទៅ ៥ "ជំហាន"។ សមាធាតុ NAP ទាំង៤ នេះរួមមាន៖

ក. បង្កើតមូលដ្ឋាន ពិនិត្យមើលតម្រូវការ ឱកាស ចំណុចចាប់ផ្តើម និងធនធានសំខាន់ៗសម្រាប់ការបន្សាំ។ វាក៏រួមបញ្ចូលផងដែរ នូវក្របខ័ណ្ឌស្ថាប័នថ្នាក់ជាតិមួយសម្រាប់ CCDRR នៅក្នុងប្រទេស រួមជាមួយនឹងបទប្បញ្ញត្តិផ្លូវច្បាប់ឬបទប្បញ្ញត្តិរដ្ឋបាលមួយ ដើម្បីធ្វើឱ្យដំណើរការមានភាពស្របច្បាប់។

ខ. សមាសធាតុដែលមានការចូលរួមដែលមានសកម្មភាពវិភាគដើម្បីបំពេញចន្លោះខ្វះខាតព័ត៌មាន ដែលត្រូវរកឃើញខាងលើ។ ការណ៍នេះអាចរួមបញ្ចូលការអនុវត្តការវាយតម្លៃហានិភ័យ និងភាពងាយរងគ្រោះ ពិនិត្យជម្រើសបន្សាំសមស្រប ការរួមបញ្ចូលគ្នានិងការធ្វើសមាហរណកម្មផែនការបន្សាំដែលមានស្រាប់ពីក្រសួងសាមី ឬរដ្ឋាភិបាលថ្នាក់ក្រោមជាតិ។ល។

គ. យុទ្ធសាស្ត្រអនុវត្តដែលមានមូលដ្ឋានលើព័ត៌មាន និងលក្ខណៈវិនិច្ឆ័យពីសមាសធាតុ ខ (Element B) ដើម្បីកំណត់អាទិភាព និងសម្រេចសកម្មភាពបន្តបន្ទាប់។ យុទ្ធសាស្ត្រទាំងនេះក៏អាចផ្តោតផងដែរលើរបៀបចំណាយសម្រាប់ការបន្សាំកសាងសមត្ថភាពដែលត្រូវការ និងបង្កើតតួនាទី និងការទទួលខុសត្រូវសម្រាប់ការអនុវត្តដែលមានការសម្របសម្រួល។

ឃ. បង្កើតយន្តការរាយការណ៍ តាមដាន និងពិនិត្យ។

### NAPs មិនមែនជា NAPA

NAPAs ប្រើប្រាស់ដំណើរការ ៨ជំហានដែលភាពបត់បែនមួយដែលជួយបង្កើតឱ្យមានបញ្ជីគម្រោងផ្សេងៗគ្នា មិនមែនផែនការរួម។ វាផ្តោតលើតម្រូវការបន្សាំបន្ទាន់បំផុត និងភ្លាមៗរបស់ប្រទេស LDCs និងមានទំនាក់ទំនងមូលនិធិជាមួយមូលនិធិ LDC របស់មូលនិធិ GEF។

ម្យ៉ាងវិញទៀត NAP មានដំណើរការដែលដដែលៗ (iterative process) ច្រើនជាង ដោយផ្តោតលើការបញ្ជ្រាប CCDRR នៅក្នុងក្របខ័ណ្ឌការងាររៀបចំផែនការអភិវឌ្ឍន៍ជាតិបច្ចុប្បន្ននិងសម្លឹងមើលតម្រូវការបន្សាំរយៈពេលមធ្យម និងរយៈពេលវែង។ NAPs មិនមានទំនាក់ទំនងដោយផ្ទាល់ទៅនឹងប្រភពមូលនិធិណាមួយទេ ហើយក្រៅពី LDC ប្រទេសកំពុងអភិវឌ្ឍន៍ក៏ត្រូវបានលើកទឹកចិត្តឱ្យអនុវត្ត NAP ផងដែរ។

ប្រភព៖ មិនមានប្រភពជាក់លាក់

ដំណើរការ NAP មានបទប្បញ្ញត្តិសមភាពយេនឌ័រច្បាស់លាស់មួយ ដែលអះអាងថា ប្រទេសនានា "អនុវត្តតាមវិធីសាស្ត្រដែលជំរុញដោយប្រទេស រំញោចយេនឌ័រ ដែលមានការចូលរួម

## រូបទី១៤៖ លក្ខណៈពិសេសនៃវិធីសាស្ត្រ NAP




*Source: Adapted from McGray (2014).*

និងដែលមានតម្លាភាពពេញលេញដោយពិចារណាលើក្រុមងាយរងគ្រោះ សហគមន៍ និងប្រព័ន្ធអេកូឡូស៊ី”។

ដូច្នេះ ដំណើរការបង្កើត NAPs គឺជាឱកាសដ៏សំខាន់មួយដើម្បីពន្លឿនសមភាពយេនឌ័រនៅក្នុងការរៀបចំផែនការ និងភាពត្រៀមបង្ការទប់ទល់នឹងអាកាសធាតុ។ UNFCCC និងអង្គការយេនឌ័រផ្សេងៗបានបង្កើតវិធីសាស្ត្រ និងឧបករណ៍នានារួចហើយដើម្បីផ្តល់លទ្ធភាពឱ្យការងារទាំងនេះធ្វើទៅបាន (ដែលមានពិពណ៌នាលម្អិតក្នុងវគ្គបន្ទាប់)។

## ការចូលរួមចំណែករបស់ជាតិ (NDCs)

មុនពេលមានកិច្ចព្រមព្រៀងទីក្រុងប៉ារីសក្នុងឆ្នាំ២០១៥ ប្រទេសហត្ថលេខីនីមួយៗ ត្រូវបានអញ្ជើញឱ្យបង្កើតផែនការសកម្មភាពអាកាសធាតុក្នុងស្រុក ដែលប្រទេសទាំងនោះមានបំណងចាត់វិធានការស្ថិតក្រោមកិច្ចព្រមព្រៀងថ្មីនេះ។ផែនការទាំងនេះត្រូវបានគេស្គាល់ថាជាការចូលរួមចំណែកដើម្បីអនុវត្តអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ(INDCs)។ INDCsឆ្លុះបញ្ចាំងពីមហិច្ឆិតារបស់ប្រទេសមួយតាមរយៈការបង្ហាញជំហាននានាដែលរដ្ឋាភិបាលនឹងចាត់វិធានការដើម្បីដោះស្រាយការប្រែប្រួលអាកាសធាតុ និងជំរុញតម្លាភាព គណនេយ្យភាព សុចរិតភាពបរិស្ថាន និងសមត្ថភាព។ គោលបំណងជាគោលការណ៍របស់INDCsគឺដើម្បីលើកទឹកចិត្តឱ្យមានការប្តេជ្ញាចិត្តប្រកបដោយមហិច្ឆិតាទាក់ទងនឹងការកាត់បន្ថយការប្រែប្រួលអាកាសធាតុ ឬការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់។ ទោះជាយ៉ាងណា ភាគីហត្ថលេខី ក៏ត្រូវបានអញ្ជើញឱ្យរួមបញ្ចូលសមាសភាពបន្សាំ និងព័ត៌មានបន្ថែម ដែល “សម្របសម្រួលភាពច្បាស់លាស់ តម្លាភាព និងការយល់ដឹង” អំពី INDC ផងដែរ។

អង្គការ WEDO (ឆ្នាំ២០១៦) បានធ្វើការវិភាគយេនឌ័រមួយទៅលើ INDCs ចំនួន ១៩០ ដែលត្រូវបានដាក់ជូន UNFCCC និងបានរាយការណ៍ថា មានតែ INDCs ចំនួន៦៤ ប៉ុណ្ណោះដែលបានរួមបញ្ចូលការយោងទៅកាន់ស្ត្រីឬយេនឌ័រ។ក្នុងចំណោមនោះ INDCs ចំនួន២៧ បានលើកឡើងអំពីយេនឌ័រនៅក្នុងបរិបទនៃការបន្សាំ INDCs ចំនួន១២ បានលើកឡើងអំពីយេនឌ័រនៅក្នុងបរិបទនៃការកាត់បន្ថយ ហើយមានតែ INDCs ចំនួន២២ប៉ុណ្ណោះដែលលើកឡើងអំពីយេនឌ័រថាជាបញ្ហាឆ្លងវិស័យ។ លើសពីនេះទៀត ជិតពាក់កណ្តាល (៣៤ប្រទេស) បានលើកឡើងអំពីស្ត្រីថាជាប្រភេទងាយរងគ្រោះ INDCs ចំនួនប្រហែល ១៥បានលើកឡើងពីតួនាទីរបស់ស្ត្រីថាជាអ្នកធ្វើសេចក្តីសម្រេចចិត្ត ហើយមាន INDCs ចំនួនតែ៦ ប៉ុណ្ណោះដែលបានសំដៅស្ត្រីថាជាភ្នាក់ងារនៃការផ្លាស់ប្តូរ។

INDCsប្រែក្លាយទៅជាការចូលរួមចំណែករបស់ជាតិ(NDCs) នៅពេលដែលប្រទេសមួយចូលរួមជាផ្លូវការនៅក្នុងកិច្ចព្រមព្រៀងទីក្រុងប៉ារីស។ GGCA និងអង្គការ UNDP (ឆ្នាំ២០១៦) បានកំណត់ប្លុកកសាងស្នូលចំនួន៤ នៅក្នុងដំណើរការ NDC ដែលអាចត្រូវបានប្រើប្រាស់ធ្វើជាចំណុចចាប់ផ្តើមសម្រាប់ការបង្កើត NDCs។ ប្លុកទាំងនេះមានបង្ហាញក្នុងរូបទី៨។

**រូបទី១៥៖ ប្លុកកសាងសម្រាប់ NDCs ដែលឆ្លើយតបនឹងតម្រូវការយេនឌ័រ**

| ការវិភាគ និងការពិគ្រោះយោបល់ថ្នាក់ជាតិ | ក្របខ័ណ្ឌការងារស្ថាប័ន និងយន្តការសម្របសម្រួលជាធរមាន | ការបន្សុីឧបករណ៍គោលនយោបាយនិងរៀបចំផែនការថ្នាក់ជាតិ | ការតាមដាននិងការវាយតម្លៃ |
| --- | --- | --- | --- |
| => វិភាគបរិបទថ្នាក់ជាតិសម្រាប់និន្នាការយេនឌ័រ SADDD<br>=> កំណត់ចំណុចសកម្មភាពតាមវិស័យសំខាន់ៗ | => វាយតម្លៃក្របខ័ណ្ឌសមភាពយេនឌ័រស្ថាប័ន<br>=> ពិនិត្យសមាហរណកម្មនៃការចូលរួម និងភាពជាអ្នកដឹកនាំរបស់ស្ត្រី | => ពិនិត្យការធ្វើសមាហរណកម្មយេនឌ័រក្នុង NAP<br>=> ការពិគ្រោះយោបល់ជាមួយស្ត្រីនិងអង្គការដែលផ្តោតលើស្ត្រី<br>=>គាំទ្រការកសាងសមត្ថភាពអំពីយេនឌ័រ | => ប្រើ SADDD សម្រាប់ការតាមដាន និងការវាយតម្លៃ<br>=>តស៊ូមតិសម្រាប់ GRB និងយន្តការហិរញ្ញវត្ថុដែលឆ្លើយតបនឹងតម្រូវការយេនឌ័រ |

ប្រភព៖ ដកស្រង់ចេញពី (GGCA និងអង្គការ UNDP ឆ្នាំ២០១៦)

ក៏មានបទប្បញ្ញត្តិមួយផងដែរសម្រាប់ការបូកសរុបរយៈពេល ៥ឆ្នាំ និងការធ្វើបច្ចុប្បន្នភាព NDCs។ គិតត្រឹមខែកញ្ញា ឆ្នាំ ២០២០ ភាគីចំនួន១៨៦ ប្រទេសបានដាក់ជូន NDC ដំបូងរបស់ខ្លួន ហើយភាគីចំនួន២ ប្រទេសបានដាក់ជូន NDCs លើកទី២ របស់ខ្លួន (គេហំព័ររបស់ UNFCCC ឆ្នាំ២០២០)។ ដូច្នេះ វដ្តបូកសរុបរយៈពេល ៥ឆ្នាំនៃ NDCs ស្ថិតក្នុងដំណើរការ និងក្នុងពេលវេលាសមស្របសម្រាប់ការធ្វើសមាហរណកម្មសមភាពយេនឌ័រទៅក្នុងការរៀបចំផែនការ និងសកម្មភាពការប្រែប្រួលអាកាសធាតុ រួមជាមួយសុខដុមនីយកម្មការរៀបចំផែនការនិងគោលនយោបាយយេនឌ័រនិងការប្រែប្រួលអាកាសធាតុនៅទូទាំងក្រសួងផ្សេងៗ និងនៅទូទាំងវិស័យរបស់ប្រទេសមួយ (GGCA និង UNDP ឆ្នាំ២០១៦)។

## គោលនយោបាយ និងផែនការ CCDRR ក្នុងស្រុក

ផលប៉ះពាល់ដែលអាចកើតមាននៃការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយលើកំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍប្រកបដោយចីរភាព ត្រូវបានចងក្រងទុកជាឯកសារបានយ៉ាងល្អ។ ដោយដឹងពីការណ៍នេះ ប្រទេសកំពុងអភិវឌ្ឍន៍ជាច្រើនក្នុងតំបន់អាស៊ី ជាពិសេសប្រទេសអភិវឌ្ឍន៍តិចតួច (LDCs) បានបង្កើតគោលនយោបាយជាច្រើនដែលពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ រួមទាំងគោលនយោបាយយុទ្ធសាស្ត្រ និងផែនការការប្រែប្រួលអាកាសធាតុថ្នាក់ជាតិ។ ប្រទេស LDCs ជាច្រើនក៏បានប្តេជ្ញាចិត្តផងដែរថានឹងបញ្ជ្រាបការប្រែប្រួលអាកាសធាតុទៅក្នុងការរៀបចំផែនការ និង ដំណើរការអភិវឌ្ឍន៍។ ឧទាហរណ៍ ប្រទេសប៊ូតុង បានរួមបញ្ចូលភាពធន់អាកាសធាតុ និងគោលដៅអព្យាក្រឹត្យកាបូនធ្វើជាវិស័យលទ្ធផលសំខាន់នៅថ្នាក់ជាតិ និងនៅកម្រិតវិស័យនៅក្នុងផែនការអភិវឌ្ឍន៍ ៥ឆ្នាំលើកទី១១ (ឆ្នាំ២០១៣-២០១៨) (Yangka et al ឆ្នាំ២០១៨)។

បើទោះជាប្រទេសមួយចំនួនបានបង្កើតវឌ្ឍនភាពមួយចំនួនក្តី ក៏ការធ្វើសមាហរណកម្មយេនឌ័រទៅក្នុងគោលនយោបាយ និងផែនការCCDRRថ្នាក់ជាតិទាំងនេះនៅតែជាបញ្ហាប្រឈមដដែល។ ការពិនិត្យមើលឡើងវិញមួយដែលធ្វើឡើងដោយអង្គការ UN Women ទៅលើគោលនយោបាយនិងផែនការ CCDRR សំខាន់ៗទាំងនេះបង្ហាញថា ប្រទេសនានាក្នុងតំបន់អាស៊ីខាងត្បូង និងអាស៊ីអាគ្នេយ៍ ពិតជាបង្ហាញវឌ្ឍនភាពក្នុងការធ្វើសមាហរណកម្មសមភាពយេនឌ័រនៅថ្នាក់គោលនយោបាយ។ យុទ្ធសាស្ត្រ និងគោលនយោបាយជាច្រើនពិពណ៌នាស្ត្រីថាជាជនរងគ្រោះដែលងាយរងគ្រោះនិងចាំបាច់ត្រូវជួយសង្គ្រោះជាជាងថាជាពលរដ្ឋដែលមានសមត្ថភាពនិងស្មើភាពដែលមានសិទ្ធិស្មើគ្នាទៅនឹងបុរស(អង្គការ UN Women ឆ្នាំ២០១៦)។ តារាងទី៤ បង្ហាញ CCDRR និងគោលនយោបាយនិងផែនការថ្នាក់ជាតិសំខាន់ៗក្នុងប្រទេសមួយចំនួននៅតំបន់អាស៊ី រួមជាមួយនឹងសមាសភាពបញ្ជ្រាបយេនឌ័រនៅក្នុង CCDRR និងគោលនយោបាយ និងផែនការថ្នាក់ជាតិទាំងនោះ។

**តារាងទី៤៖ ការពិនិត្យការបញ្ជ្រាបយេនឌ័រនៃផែនការ CCDRR ក្នុងប្រទេសមួយចំនួនក្នុងតំបន់អាស៊ី**

| ប្រទេស | CCDRR និងគោលនយោបាយ/ ផែនការជាតិសំខាន់ៗ | សមាសភាពការបញ្ជ្រាបយេនឌ័រ |
|---|---|---|
| **អាហ្វហ្គានីស្ថាន** | NAPA (ឆ្នាំ២០០៩)<br><br>យុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (ឆ្នាំ២០០៨-២០១៣) | លើកឡើងយ៉ាងសង្ខេបអំពីសេចក្តីអធិប្បាយមួយថា ការប្រែប្រួលអាកាសធាតុជះឥទ្ធិពលលើស្ត្រីផ្សេងៗគ្នាប៉ុន្តែមិនមានភាពច្បាស់លាស់។ |
| **បង់ក្លាដែស*** | NAPA (២០០៥, ធ្វើបច្ចុប្បន្នភាពនៅឆ្នាំ២០០៩)<br><br>យុទ្ធសាស្ត្រ និងផែនការសកម្មភាពការប្រែប្រួលអាកាសធាតុបង់ក្លាដែស (ឆ្នាំ២០០៨) យុទ្ធសាស្ត្រជាតិសម្រាប់ការពន្លឿនការកាត់បន្ថយភាពក្រីក្រ (ឆ្នាំ២០០៩-២០១១) | ធ្វើសមាហរណកម្មទៅក្នុងការបង្កើតគោលនយោបាយ និងគម្រោង។<br><br>ពិភាក្សាយ៉ាងទូលំទូលាយនៅក្នុងឯកសារដោយមានការកំណត់ភាពងាយរងគ្រោះ និងសមត្ថភាពជាក់លាក់។ |
| **ប៊ូតង់** | NAPA (ឆ្នាំ២០០៦)<br><br>ផែនការប្រាំឆ្នាំលើកទី១០ (ឆ្នាំ២០០៨-២០១៣) ផែនការអភិវឌ្ឍន៍ប្រាំឆ្នាំលើកទី១១ (ឆ្នាំ២០០៨-២០១៣) | ការទទួលស្គាល់ភាពងាយរងគ្រោះនិងសមត្ថភាពដែលមានទស្សនៈយេនឌ័រជាក់លាក់នៅមានកម្រិត។<br><br>គម្រោងភាគច្រើនមានគោលបំណងលើហេដ្ឋារចនាសម្ព័ន្ធនិងការកាត់បន្ថយការប្រឈមទៅ ដូច្នេះការផ្តោតលើវិសាលភាពមនុស្សនៅមានកម្រិត។ |
| **កម្ពុជា*** | NAPA (ឆ្នាំ២០០៦)<br><br>ផែនការយុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុកម្ពុជា (២០១៤-២០១៨)<br>ផែនការយុទ្ធសាស្ត្រយេនឌ័រនិងការប្រែប្រួលអាកាសធាតុ (ឆ្នាំ២០១៣-២០២៣)<br>ផែនការយុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុកម្ពុជា (ឆ្នាំ២០១៤-២០២៣) | កំណត់សមភាពយេនឌ័រថាជាគោលការណ៍ណែនាំមួយក្នុងចំណោមគោលការណ៍ណែនាំផ្សេងៗសម្រាប់ការកាត់បន្ថយភាពងាយរងគ្រោះហើយកំណត់គោលបំណងយុទ្ធសាស្ត្រយេនឌ័រ និងការប្រែប្រួលអាកាសធាតុ។ គោលបំណងចំនួនបីក្នុងចំណោមគោលបំណងទាំង៨ នៃ CCCSP ពិចារណាលើបញ្ហាយេនឌ័រឬកំណត់ស្ត្រីថាជាអ្នកទទួលផល។បញ្ហាយេនឌ័រក៏ត្រូវបានធ្វើសមាហរណកម្មនៅក្នុងផ្នែកការតាមដាន និងការវាយតម្លៃផងដែរ។ |
| | ផែនការសកម្មភាពជាតិសម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ (ឆ្នាំ២០១៤-២០១៨)<br>ផែនការយុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុសម្រាប់វិស័យគ្រប់គ្រងគ្រោះមហន្តរាយ ឆ្នាំ២០១៣<br>ច្បាប់ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ (ឆ្នាំ២០១៥) | ផែនការឆ្នាំ២០១៣ មានការលើកឡើងតែមួយប៉ុណ្ណោះអំពីការលើកកម្ពស់ការចូលរួមរបស់ស្ត្រី ប៉ុន្តែផែនការឆ្នាំ២០១៤ ទទួលស្គាល់ផលប៉ះពាល់មិនស្មើគ្នាទៅលើស្ត្រីហើយក៏មានសមាសធាតុយុទ្ធសាស្ត្រមួយផងដែរសម្រាប់ការវាយតម្លៃក្រោយគ្រោះមហន្តរាយដែលបែងចែកតាមយេនឌ័រ។<br><br>មាត្រា ១៨ នៃច្បាប់នេះក៏លើកឡើងផងដែរអំពីតម្រូវការ "យកចិត្តទុកដាក់ខ្ពស់លើតម្រូវការរបស់ស្ត្រី កុមារ ចាស់ជរា ជនពិការ និងជនបាត់បង់លទ្ធភាពពលកម្ម" នៅក្នុងហេតុការណ៍គ្រោះមហន្តរាយ។ |
| **ឥណ្ឌា** | ផែនការសកម្មភាពជាតិស្តីពីការប្រែប្រួលអាកាសធាតុ (NAPCC)<br>ផែនការប្រាំឆ្នាំលើកទី១១ (២០០៧-២០១២) | ផលប៉ះពាល់ផ្សេងៗគ្នានៃការប្រែប្រួលអាកាសធាតុលើស្ត្រីត្រូវបានទទួលស្គាល់ ប៉ុន្តែមិនត្រូវបានពិភាក្សានៅក្នុងឯកសារចម្បងរបស់ NAPCC។ |
| **នេប៉ាល់** | NAPA (ឆ្នាំ២០១០)<br>ផែនការបណ្តោះអាសន្នបីឆ្នាំ (២០០៧-២០១០) | ដោះស្រាយភាពងាយរងគ្រោះ និងសមត្ថភាពដែលមានទស្សនៈយេនឌ័រជាក់លាក់ដែលជាបញ្ហាឆ្លងវិស័យនៅទូទាំងគោលនយោបាយ។<br><br>ការសិក្សាពីភាពងាយរងគ្រោះដែលមានទស្សនៈយេនឌ័រជាក់លាក់ត្រូវបានធ្វើឡើងជាផ្នែកមួយនៃដំណើរការគោលនយោបាយ។ |
| **វៀតណាម** | យុទ្ធសាស្ត្រជាតិស្តីពីការប្រែប្រួលអាកាសធាតុ ឆ្នាំ២០១១ | ទិសដៅជាក់លាក់ដើម្បីរួមបញ្ចូលកង្វល់អាទិភាពរបស់ស្ត្រីទាក់ទង នឹងអាហារ ទឹក សុខភាព និងសមភាពយេនឌ័រសំខាន់បំផុតទៅក្នុងបរិបទនៃការប្រែប្រួលអាកាសធាតុ។ |

ប្រភព៖ ដកស្រង់ចេញពី (អង្គការ UN Women ឆ្នាំ២០១៦) និង (Reggers និង Lim ឆ្នាំ២០១៩)

* ប្រទេសបង់ក្លាដែស និងកម្ពុជា បានបង្កើតផែនការសកម្មភាពការប្រែប្រួលអាកាសធាតុ និងយេនឌ័រ (ccGAP) ដែលត្រូវបានពិភាក្សាក្នុងវគ្គបន្ទាប់។

គោលនយោបាយកាត់បន្ថយហានិភ័យគ្រោះមហន្តរាយមាននិន្នាការពន្លឿនឆ្ពោះទៅរកយេនឌ័រខ្លាំងជាងគោលនយោបាយការប្រែប្រួលអាកាសធាតុ ខណៈដែលយុទ្ធសាស្ត្រអន្តរជាតិអង្គការសហប្រជាជាតិសម្រាប់ការកាត់បន្ថយគ្រោះមហន្តរាយ"បានបោះជំហានជាក់លាក់ដើម្បីរួមបញ្ចូលយេនឌ័រ" ក្នុងផែនការសកម្មភាពកាត់បន្ថយហានិភ័យគ្រោះមហន្តរាយនៅថ្នាក់ជាតិដែលប្រទេសនានា បង្កើតឡើងស្ថិតក្រោមក្របខ័ណ្ឌការងារ Hyogo ដើម្បីសកម្មភាព (Aguilar et al ឆ្នាំ២០១៥)។

## ក្របខ័ណ្ឌ CCDRR ជាតិ នៅប្រទេសបង់ក្លាដែស៖ ការរួមបញ្ចូលគោលនយោបាយ ផែនការ និងយន្តការឃ្លាំមើល

បង់ក្លាដែសជាប្រទេសមួយដែលងាយរងគ្រោះបំផុតទៅនឹងការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយនានា។ ដូច្នេះ ប្រទេសនេះចូលរួមដោយផ្ទាល់គ្រប់ដំណើរការវិវឌ្ឍរបៀបវារៈអាកាសធាតុអន្តរជាតិទាំងអស់ ជាពិសេសក្នុងន័យការរៀបចំផែនការបន្សាំ។ រដ្ឋាភិបាលបង់ក្លាដែសបានអនុម័តនូវជំហានជាច្រើនដើម្បីពង្រឹងវិធីសាស្ត្ររបស់ខ្លួន ក្នុងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ និងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ រួមទាំងការបញ្ជ្រាបយេនឌ័រ និងកង្វល់របស់ស្ត្រីដូចគ្នា។

### ក. យន្តការគោលនយោបាយ

យុទ្ធសាស្ត្រ និងផែនការសកម្មភាពការប្រែប្រួលអាកាសធាតុបង់ក្លាដែស (BCCSAP) បានចូលជាធរមាននៅឆ្នាំ២០០៩ ជាផ្នែកបន្ថែមនៃ NAPA។ ផែនការនេះផ្តោតលើយុទ្ធសាស្ត្ររយៈពេលមធ្យម និងវែងនៅក្នុងផ្នែកពាក់ព័ន្ធចំនួនប្រាំមួយ៖ (១) សន្តិសុខស្បៀង កិច្ចគាំពារសង្គម និងសុខភាព (២) ការគ្រប់គ្រងគ្រោះមហន្តរាយគ្រប់ជ្រុងជ្រោយ (៣) ហេដ្ឋារចនាសម្ព័ន្ធ (៤) ការស្រាវជ្រាវ និងការគ្រប់គ្រងចំណេះដឹង (៥) ការកាត់បន្ថយ និងផលិតកម្មអភិវឌ្ឍន៍កាបូនកម្រិតទាប និង (៦) ការកសាងសមត្ថភាព និងការពង្រឹងស្ថាប័នសម្រាប់ការផ្តល់មូលនិធិអាកាសធាតុ។

ដំបូងឡើយ BCCSAP ផ្តោតតែលើស្ត្រីជាក្រុមដែលងាយរងគ្រោះដោយលើកឡើងថា៖ «តម្រូវការរបស់មនុស្សក្រីក្រ និងងាយរងគ្រោះរួមមានស្ត្រី និងកុមារ នឹងត្រូវផ្តល់អាទិភាពនៅគ្រប់សកម្មភាពទាំងអស់ក្នុងផែនការសកម្មភាព»។ នៅឆ្នាំ២០១៣ ផែនការសកម្មភាពការប្រែប្រួលអាកាសធាតុ និងយេនឌ័របង់ក្លាដែស (ccGAP) ត្រូវបង្កើតឡើងដោយក្រសួងបរិស្ថាន និងរុក្ខាប្រមាញ់ (MoEF)។ CCGAP ក៏បានបង្ហាញនូវគោលបំណងច្បាស់លាស់ សកម្មភាពជាមួយសូនាចករ ដែលអាចផ្ទៀងផ្ទាត់បាននៅក្នុងវិសាលភាពនៃសសរស្តម្ភចំនួន៤ នៃ CCGAP ឆ្នាំ២០០៩និងបានគូសបញ្ជាក់ពីការចូលរួមចំណែកជាក់លាក់ដែលស្ត្រីអាចធ្វើបាន។ ccGAP ត្រូវបានតាក់តែងឡើងយ៉ាងល្អដោយទទួលបានការគាំទ្រពីអង្គការ IUCN និងផ្តល់នូវវិធីដ៏រឹងមាំក្នុងការធានាថា យេនឌ័រត្រូវបានបញ្ជ្រាបនៅក្នុងក្របខ័ណ្ឌគោលនយោបាយដែលមានស្រាប់។ BCCSAP មានផ្នែកជាក់លាក់ចំនួនពីរដែលយេនឌ័រដើរតួនាទីយ៉ាងសំខាន់៖ T1P9៖ កិច្ចការពារជីវភាពរស់នៅនៃក្រុមសង្គមសេដ្ឋកិច្ចដែលងាយរងគ្រោះ(រួមបញ្ចូលស្ត្រី) T6P4៖ ការបញ្ជ្រាបការគិតគូរអំពី យេនឌ័រ នៅក្នុងការគ្រប់គ្រងការប្រែប្រួលអាកាសធាតុ។ ក្នុងចំណោមចំនួន៤៤កម្មវិធីនៃ BCCSAPមានចំនួន២២កម្មវិធីគូសបញ្ជាក់ពីយេនឌ័រជាទស្សនៈដ៏មានសារសំខាន់។

### ខ. យន្តការការផ្តល់មូលនិធិ

BCCSAP ត្រូវបានអនុវត្តតាមរយៈយន្តការការផ្តល់មូលនិធិចំនួនពីរ (ពហុម្ចាស់ជំនួយ) មូលនិធិភាពធន់នឹងការប្រែប្រួលអាកាសធាតុបង់ក្លាដែស (BCCRF) និង មូលនិធិសម្រាប់ការប្រែប្រួលអាកាសធាតុបង់ក្លាដែស (BCCTF)។ CCRF ទទួលបានគាំទ្រដោយសម្ព័ន្ធការប្រែប្រួលអាកាសធាតុសកលបូកការផ្តួចផ្តើម(GCCA+) និង មូលនិធិ៨០% គឺផ្តល់ទៅតាមក្រសួង/នាយកដ្ឋានតាមវិស័យសម្រាប់ការអនុវត្តគម្រោងពាក់ព័ន្ធនឹងអាកាសធាតុ។ BCCTF បានទទួលមូលនិធិរៀងរាល់ឆ្នាំពីក្រសួងហិរញ្ញវត្ថុ និងមូលនិធិផ្តួចផ្តើមដោយរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល (NGOs) និងស្ថាប័នស្រាវជ្រាវផ្នែកការគ្រប់គ្រងការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ។ ទោះបីយ៉ាងណា ការអនុវត្តផែនការសកម្មភាពយេនឌ័រនៅតែមិនពេញលេញដោយសារតែខ្វះទំនាក់ទំនងជាក់លាក់ជាមួយការបែងចែកថវិកាសម្រាប់ក្រសួង ឬទីភ្នាក់ងារនានាមួយចំនួនធំ។

### គ. យន្តការឃ្លាំមើល

ការពិនិត្យស្ថាប័ននិងការចំណាយសាធារណៈលើការងារអាកាសធាតុ (CPEIR) ត្រូវបានធ្វើឡើងនៅក្នុងឆ្នាំសារពើពន្ធ២០១២។ ផ្អែកតាមអនុសាសន៍CPEIRរដ្ឋាភិបាលបានបង្កើតក្របខ័ណ្ឌសារពើពន្ធអាកាសធាតុ (CFF) នៅឆ្នាំ២០១៤ ដើម្បីធាននូវប្រសិទ្ធភាពការប្រើប្រាស់ហិរញ្ញវត្ថុអាកាសធាតុថ្នាក់ជាតិ និងអន្តរជាតិតាមនីតិវិធីថវិកាជាតិ។CFFបង្កើតក្របខ័ណ្ឌឃ្លាំមើលការចំណាយលើអាកាសធាតុ (CETF) ដែលអាចឱ្យតាមដាន និងត្រួតពិនិត្យលើការចំណាយទាក់ទងនឹងអាកាសធាតុមានលក្ខណៈជាប្រព័ន្ធនិងប្រកបដោយតម្លាភាព។នៅឆ្នាំ២០១២CPEIRក៏បានកំណត់នាយកដ្ឋាន និងក្រសួងដ៏ច្រើនរហូតដល់ចំនួន៣៧។ ក្រសួងនីមួយៗត្រូវបានស្នើសុំឱ្យពន្យល់ដោយឡែកពីគ្នា តើគោលបំណងយុទ្ធសាស្ត្រនិងសកម្មភាពទាក់ទងទៅនឹងគោលបំណងនីមួយៗនឹងចូលរួមចំណែកដល់គោលដៅរបស់រដ្ឋាភិបាលយ៉ាងដូចម្តេចក្នុងការ «ការលុបបំបាត់ភាពក្រីក្រ» និងការអភិវឌ្ឍស្ត្រី»។ នេះគឺជាការផ្លាស់ប្តូរដ៏សំខាន់មួយនៅក្នុងការស្វែងយល់ពីរបៀបដែល

មូលនិធិនឹងចូលរួមចំណែកដល់ការអភិវឌ្ឍស្ត្រី។

### ឃ. យន្តការស្ថាប័ន

ក្រសួងបរិស្ថាននិងព្រៃឈើគឺជាទីភ្នាក់ងារសំខាន់របស់រដ្ឋាភិបាលទទួលខុសត្រូវក្នុងការបង្កើតគោលនយោបាយពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ ការសម្របសម្រួល និងការអនុវត្តដោយមានកិច្ចសហការជាមួយតួអង្គជាតិ និងអន្តរជាតិពាក់ព័ន្ធ។ អាជ្ញាធរអាជ្ញាធរ មូលនិធិការប្រែប្រួលអាកាសធាតុបង់ក្លាដែស ( BCFA ) នៅក្នុងក្រសួងនេះ គឺជាស្ថាប័នសម្របសម្រួលដ៏សំខាន់សម្រាប់គម្រោងការប្រែប្រួលអាកាសធាតុនៅក្នុងប្រទេស។ សម្រាប់មូលនិធិភាពធន់ ក្រុមប្រឹក្សាភិបាល គឺជាស្ថាប័នដ៏សំខាន់សម្រាប់ធ្វើសេចក្តីសម្រេច ដែលដឹកនាំដោយរដ្ឋមន្ត្រីក្រសួងបរិស្ថាន និងរុក្ខាប្រមាញ់។ ក្រុមប្រឹក្សាភិបាលរួមបញ្ចូលរដ្ឋមន្ត្រីចំនួនប្រាំមួយរូប និងអ្នកតំណាងចំនួនពីររូបពីដៃគូចូលរួមអភិវឌ្ឍន៍ ដែលអ្នកតំណាងទាំងពីររូបមកពីអង្គការសង្គមស៊ីវិល និងនាយកប្រចាំប្រទេសនៃធនាគារពិភពលោកជាអ្នកអង្កេតការណ៍។ មូលនិធិ Palli Karma-Sahayok - PKSF26 ក្រុមហ៊ុនរដ្ឋមួយ «មិនរកប្រាក់ចំណេញ» ដែលផ្តល់មូលនិធិឱ្យទៅកម្មវិធីឥណទានខ្នាតតូច ត្រូវបានរដ្ឋាភិបាលបង់ក្លាដែសបំពាក់ភារកិច្ចជាមួយការសម្របសម្រួលមូលនិធិ១០ភាគរយដែលទទួលបានតាមរយៈមូលនិធិភាពធននោះទៅឱ្យអង្គការមិនមែនរដ្ឋាភិបាល/អង្គការសង្គមស៊ីវិល/ដៃគូឯកជនអនុវត្តគម្រោង។

ទោះបីយ៉ាងណាការត្រួតពិនិត្យសំខាន់នៃទិដ្ឋភាពគោលនយោបាយ គឺបរាជ័យក្នុងការបង្កើតដែនសមត្ថកិច្ចច្បាប់មួយ និងយន្តការស្ថាប័ន ដើម្បីធានានូវការបញ្ជ្រាបយេនឌ័រនៅក្នុងការអនុម័តគម្រោង ជាពិសេសការបែងចែកថវិកា។ ក្រសួងពាក់ព័ន្ធ ក៏មិនមានយន្តការស្ថាប័ន ដើម្បីសម្របសម្រួល និងធ្វើឱ្យមានភាពសុខដុមកិច្ចអន្តរាគមន៍អន្តរវិស័យនៅក្នុងកម្មវិធីការប្រែប្រួលអាកាសធាតុ។ ដូច្នេះ នាពេលថ្មីៗនេះ មិនមានការអនុវត្ត ccGAP ឡើយ។ ភាពមានកម្រិតដ៏ធំមួយទៀតគឺការអនុវត្តផែនការនៅកម្រិតមូលដ្ឋាន។ ដោយមានកម្រិតការបញ្ជ្រាបយេនឌ័រនៅកម្រិតមូលដ្ឋាននៅតែមិនច្បាស់លាស់ ការបកស្រាយរៅហាសាស្រ្តសមភាពយេនឌ័រពីគោលនយោបាយជាតិទៅក្នុងសកម្មភាពមូលដ្ឋាន នៅតែជាបញ្ហាប្រឈម។

ប្រភព៖ អនុម័តពី ( UN Women ឆ្នាំ២០១៩ ) និង ( Khan, Haque និង Rouf ឆ្នាំ២០១៣

3:00:00

## វគ្គ ខៈ ការបញ្ជ្រាបយេនឌ័រនៅក្នុងគោលនយោបាយ និងផែនការថ្នាក់ជាតិ

**ទិដ្ឋភាពទូទៅ**

ចុងបញ្ចប់នៃផ្នែកនេះ អ្នកចូលរួមគួរតែអាចភ្ជាប់បញ្ហាប្រឈមនានាទៅនឹងការបញ្ជ្រាបយេនឌ័រ និងកំណត់នូវយុទ្ធសាស្ត្រនានា និងបញ្ចូលជាចំណុចៗក្នុងវដ្តគោលនយោបាយ និងផែនការជាតិនៅក្នុងប្រទេសរបស់ពួកគេផ្ទាល់។ អ្នកចូលរួម គួរតែអាចយល់ដឹងពីតួនាទីអង្គការសង្គមស៊ីវិល ក្នុងនាមជាអ្នកតស៊ូមតិផង និងអ្នកសម្របសម្រួលការបញ្ជ្រាបយេនឌ័រផង នៅក្នុងយន្តការការរៀបចំផែនការ CCDRR ជាតិ រួមទាំងនៅក្នុងការទំនាក់ទំនងជាតិទាំងអស់។

**មាតិកា**

ក) ចំណុចខ្វះខាត និងការប្រឈមនានានៅក្នុងការបញ្ជ្រាបយេនឌ័រ
ខ) យុទ្ធសាស្ត្រសម្រាប់ការបញ្ជ្រាបយេនឌ័រ
   ក. តុល្យភាពយេនឌ័រក្នុងអភិបាលកិច្ច និងស្ថាប័ននានា
   ខ. សមាហរណកម្មយេនឌ័រក្នុងការអភិវឌ្ឍ NAP
   គ. ផែនការសកម្មភាពការប្រែប្រួលអាកាសធាតុ និងយេនឌ័រ (ccGAP)
   ឃ. ការតាមដាន និងវាយតម្លៃដែលមានទស្សនៈយេនឌ័រ
   ង. ករណីសិក្សាប្រទេសកម្ពុជា
គ) តួនាទីអង្គការសង្គមស៊ីវិលក្នុងការបញ្ជ្រាបយេនឌ័រនៅក្នុងគោលនយោបាយ និងផែនការជាតិ CCDRR
   ក. ករណីសិក្សាប្រទេសឥណ្ឌា និងប្រទេសស្រីលង្កា

**ឯកសារ**

បទបង្ហាញតាមកម្មវិធីកុំព្យូទ័រ
ក្ដារខៀន និងប៊ិចហ្វឺតធំ
ក្រដាសផ្ទាំងធំ និងប៊ិច
សំណៅឯកសារចំនួន ១ច្បាប់

**តារាងពេលវេលា**

| រយៈពេល | សកម្មភាព |
|---|---|
| ៥នាទី | > ចែករំលែកទិដ្ឋភាពទូទៅ និងរចនាសម្ព័ន្ធ |
| ៤០នាទី | > «Batokas និង Gonkas» ការសម្តែងពីតម្រូវការសម្រាប់ការបញ្ជ្រាបយេនឌ័រទៅក្នុងគោលនយោបាយជាតិ (សូមមើលលំហាត់ ១៣) |
| ៣០នាទី | > បទបង្ហាញតាមកម្មវិធីកុំព្យូទ័រស្តីពី «ចំណុចខ្វះខាត និងការប្រឈមនានាក្នុងការបញ្ជ្រាបយេនឌ័រ» (សម្រាប់វគ្គមូលដ្ឋានគ្រឹះ) |
| | ឬ |
| | > ការពិភាក្សាក្រុមតូចៗពី «ចំណុចខ្វះខាត និងការប្រឈមនានាក្នុងការបញ្ជ្រាបយេនឌ័រ» |
| | (សម្រាប់វគ្គកម្រិតខ្ពស់)<br>បទបង្ហាញតាមកម្មវិធីកុំព្យូទ័រស្តីពី «យុទ្ធសាស្ត្រក្នុងការបញ្ជ្រាបយេនឌ័រៈ អភិបាលកិច្ច និង |
| ៤៥នាទី | > ស្ថាប័ន គោលនយោបាយជាតិ និងផែនការសកម្មភាពជាតិ (NAPs) និងផែនការសកម្មភាពការប្រែប្រួលអាកាសធាតុ និងយេនឌ័រ (ccGAP)» |
| ៦០នាទី | > ការពិភាក្សាផ្អែកលើករណីសិក្សាពី«ការបង្កើតគោលនយោបាយ CCDRR ជាតិៈ ចំណុចចាប់ផ្តើមសម្រាប់អង្គការសង្គមស៊ីវិល (សូមមើលលំហាត់ ១៤ និងសំណៅឯកសារ ១១) |

**កំណត់សម្គាល់ណែនាំ**

ការចាប់ផ្តើមផ្នែកនេះដោយការចែករំលែកនូវទិដ្ឋភាពទូទៅ និងមាតិកា។ បំបែកអ្នកចូលរួមជាពីរក្រុម ហើយសម្របសម្រួលការសម្តែង «Batokas និង Gonkas» (សូមមើលលំហាត់ ១៣)។ ការសម្តែងនេះ ត្រូវការអ្នកចូលរួមដែលចាប់អារម្មណ៍ច្រើននាក់ ដូច្នេះ បែងចែកអ្នកចូលរួមទៅជា២ក្រុម ក្រុមឆេវឆាវ/ឈ្លានពាន និងក្រុមអកម្ម/ដែលត្រូវបានគេឈ្លានពាន ដោយផ្អែកលើឥរិយាបថរបស់ពួកគេអំឡុងពេលបណ្តុះបណ្តាលរហូតមក (ដោយមិនបាច់ប្រាប់ឱ្យពួកគេដឹងខ្លួនឡើយ)។ ឥឡូវនេះ កំណត់តួនាទីឱ្យពួកគេ - ក្រុមអកម្ម/ដែលត្រូវបានគេឈ្លានពាននៅជាមួយ Batokas ហើយក្រុមឆេវឆាវ/ឈ្លានពាននៅខាង Gonkas។ ត្រូវគោរពតាមពេលវេលាកំណត់នៅក្នុងលំហាត់នេះ កុំឱ្យលើស។ អ្នកគ្រាន់តែចង់ឱ្យពួកគេទទួលបានអារម្មណ៍ផ្សេងៗប៉ុណ្ណោះ។

| | |
|---|---|
| កំណត់សម្គាល់ណែនាំ | សម្រាប់វគ្គកម្រិតខ្ពស់ បន្តទៅអនុវត្តពិភាក្សាក្រុមតូចៗដោយបំបែកអ្នកចូលរួមជាប្រាំក្រុម និងផ្តល់ឱ្យក្រុមនីមួយៗនូវប្រធានបទមួយនិងមាតិកាពាក់ព័ន្ធដែលបានមកពីកំណត់ត្រាបច្ចេកទេសសម្រាប់កិច្ចពិភាក្សាបន្ថែម (សូមមើលកគន្លឹះសម្រាប់គ្រូឧទ្ទេស)។ បន្តផ្នែកនេះជាមួយបទបង្ហាញ Power Point ស្តីពី «យុទ្ធសាស្ត្រក្នុងការបញ្ជ្រាបយេនឌ័រ៖ អភិបាលកិច្ចនិងស្ថាប័នគោលនយោបាយជាតិនិងផែនការសកម្មភាពជាតិ (NAPs) និងផែនការសកម្មភាពការប្រែប្រួលអាកាសធាតុ និងយេនឌ័រ (ccGAP)»។ សម្រាប់វគ្គមូលដ្ឋានគ្រឹះ ប្រចាប់បញ្ចូលទាំងពីរផ្នែកទៅជាមួយផ្នែកជាបទបង្ហាញរួមស្តីពី «ចំណុចខ្វះខាត និងការប្រឈម» និង «យុទ្ធសាស្ត្រ និងចំណុចចាប់ផ្តើម» (សូមមើលកគន្លឹះសម្រាប់គ្រូឧទ្ទេស)។យើងមានផ្តល់ករណីសិក្សាមួយពីប្រទេសកម្ពុជាសម្រាប់ជាឯកសារយោង។ ដាក់បញ្ចូលទៅក្នុងបទបង្ហាញ បើសិនអ្នកចូលរួមមកពីប្រទេសដទៃទៀតប្រើករណីសិក្សាប្រទេសបង់ក្លាដែស រៀបចំឱ្យពួកគេលម្អិតពីក្របខ័ណ្ឌការងារ CCDRR នៅក្នុងប្រទេសរបស់ពួកគេផ្ទាល់។ អ្នកអាចសំដៅដល់គោលនយោបាយជាក់លាក់ប្រទេស និងផែនការគូសបញ្ជាក់នៅក្នុងតារាង ៤៖ ការពិនិត្យឡើងវិញការបញ្ជ្រាបយេនឌ័រនៃផែនការCCDRRនៅក្នុងប្រទេសតំបន់អាស៊ីដែលបានជ្រើសរើសសម្រាប់ករណីនេះ។ ចុងបញ្ចប់នៃផ្នែកនេះ ដោយការពិភាក្សាផ្នែកលើករណីសិក្សាស្តីពី «ការបង្កើតគោលនយោបាយ CCDRR ជាតិ- ចំណុចចាប់ផ្តើមសម្រាប់អង្គការសង្គមស៊ីវិល (សូមមើលលំហាត់ ១៤ និងសំណៅឯកសារ ១១)។ ការពិភាក្សានេះផ្តោតលើការបង្កើតផែនការសកម្មភាពស្តីពី តួនាទី និងការទទួលខុសត្រូវនៃអង្គការសង្គមស៊ីវិលក្នុងការបញ្ជ្រាបយេនឌ័រនៅក្នុងគោលនយោបាយ និងកម្មវិធី CCDRR ក៏ដូចជាការកំណត់នូវភាគីពាក់ព័ន្ធដែលមានសក្តានុពល ដើម្បីបង្កើតបណ្តាញរួមបញ្ចូលយេនឌ័រទៅក្នុងគម្រោង CCDRR ទាំងពីរកម្រិតនៅកម្រិតមូលដ្ឋាន និងកម្រិតជាតិ។ |

## គម្លាត និងបញ្ហាប្រឈមក្នុងការបញ្ជ្រាបយេនឌ័រនៅក្នុងគោលនយោបាយ និងផែនការថ្នាក់ជាតិ

ការបញ្ជ្រាបយេនឌ័រទាមទារឱ្យមានសមាហរណកម្មទស្សនៈយេនឌ័រទៅក្នុងដំណើរការនៃការរៀបចំនិងការកសាង ការអនុវត្ត ការត្រួតពិនិត្យ និងការវាយតម្លៃគោលនយោបាយ វិធានការបទប្បញ្ញត្តិនិងកម្មវិធីការចំណាយ។ គោលនយោបាយCCDRRបានធ្វើដំណើរវែងឆ្ងាយហើយចាប់ពីឆ្នាំដំបូង ដែលអង្គការ UNFCCC មិនមានការចូលរួមរបស់ស្ត្រី និងបទប្បញ្ញត្តិយេនឌ័រ រួមទាំង NAPAs ភាគច្រើនមិនមានបញ្ចូលនូវកង្វល់យេនឌ័រឱ្យបានគ្រប់គ្រាន់។ សព្វថ្ងៃ ការមន្ទិលជុំវិញយេនឌ័រ និង CCDRR ត្រូវបានទុកចោល ហើយមានភស្តុតាងដែលត្រូវបានចងក្រងបង្ហាញថា សមភាពយេនឌ័រ និងដំណោះស្រាយអាកាសធាតុ មានអត្ថប្រយោជន៍រួម។ ទោះបីយ៉ាងណា ការទទួលស្គាល់យ៉ាងពេញលេញនៃកិច្ចប្រឹងប្រែងបញ្ជ្រាបយេនឌ័រនៅកម្រិតជាតិនៅតែមានបញ្ហាប្រឈម។ រូបទី៩ គូសបញ្ជាក់បញ្ហាប្រឈមសំខាន់ៗមានបកស្រាយនៅផ្នែកក្រោយទៀត។

### អតុល្យភាពយេនឌ័រនៅក្នុងការចូលរួម និងការធ្វើសេចក្តីសម្រេចចិត្ត

ការផ្តល់អាទិភាពនិងការជ្រើសរើសក្នុងចំណោមជម្រើសផ្សេងៗមានតួនាទីយ៉ាងសំខាន់ក្នុងការសម្រេចចិត្តនៅក្នុងគ្រប់គោលនយោបាយ CCDRR ទាំងអស់។ នរណាទទួលបានអាសនៈនៅតុការធ្វើសេចក្តីសម្រេចទាំងនេះហើយនរណាដែលមានតំណាង គឺកាន់តែមានសារសំខាន់ក្នុងគោលនយោបាយ CCDRR។ គួរឱ្យស្តាយ ស្ត្រីមានចំនួនតំណាងតិចតួចនៅគ្រប់កម្រិតនៃការធ្វើសេចក្តីសម្រេចជាលក្ខណៈស្ថាប័នទាំងអស់ (Dekens និង Daze ឆ្នាំ២០១៩)។

ការពិនិត្យឡើងវិញនៅប្រទេសចំនួន ១៩៣ (Prebble et al, IUCN, EGI និង UN Women ឆ្នាំ២០១៥បានបង្ហាញថា៖

- ការធ្វើសេចក្តីសម្រេចខាងបរិស្ថានចំនួន៦ក្នុងចំណោម៩ ដែលត្រូវបានវិភាគ ស្ត្រីមានវត្តមានតិចជាង ១/៣ នៃអ្នកធ្វើសេចក្តីសម្រេច។
- ក្នុងចំណោមក្រសួងវិស័យបរិស្ថានចំនួន៨៩០ ក្នុងរដ្ឋចំនួន ១៩៣ ជាសមាជិកអង្គការសហប្រជាជាតិ មានតែស្ត្រី ១២% ប៉ុណ្ណោះ។
- ក្នុងចំណោមប្រធានសរុបនៃក្រុមប្រឹក្សាថាមពលពិភពលោក មានតំណាងស្ត្រីតែម្នាក់គត់ក្នុងចំណោមបុរសចំនួន២៨នាក់។
- សម្រាប់ COPs ចុងក្រោយនេះ អនុសញ្ញាស្តីពីជីវចម្រុះ (CBD) មានអត្រានៃការចូលរួមរបស់ស្ត្រីខ្ពស់បំផុតដោយជាមធ្យមចំនួន ៤៣% ជាប្រតិភូរដ្ឋាភិបាល សមាជិកការិយាល័យ និងតំណាងអង្គការមិនមែនរដ្ឋាភិបាល។ UNFCCC មានជាមធ្យម ៣៦% និងចំនួន៣០% សម្រាប់អនុសញ្ញាអង្គការសហប្រជាជាតិប្រយុទ្ធប្រឆាំងវហោស្ថានកម្ម (UNCCD)។
- ស្ត្រីមានវត្តមានតិចជាង ១/៣ នៃជនបង្គោលជាតិ GEF ចំនួន៣០៤។

**រូបទី១៦៖ គម្លាត និងបញ្ហាប្រឈមចំពោះការបញ្ជ្រាបយេនឌ័រនៅក្នុងគោលនយោបាយ CCDRR ថ្នាក់ជាតិ**




និន្នាការនេះបន្តមានក្នុងរចនាសម្ព័ន្ធអភិបាលកិច្ចមូលដ្ឋានរួមបញ្ចូលទាំងការគ្រប់គ្រងដីធ្លី ព្រៃឈើ និងជលផល (បណ្តាញពិភពលោក NAP និង UNFCCC ឆ្នាំ២០១៩)។ ឧទាហរណ៍ ទោះបីមានការសិក្សាជាច្រើននៅប្រទេសឥណ្ឌានិងប្រទេសនេប៉ាល់បង្ហាញថាការចូលរួមរបស់ស្ត្រីនៅក្នុងអភិបាលកិច្ចព្រៃឈើមូលដ្ឋានគឺមិនត្រឹមតែផ្តល់នូវអត្ថប្រយោជន៍សម្រាប់ពួកគេប៉ុណ្ណោះទេ ប៉ុន្តែក៏ធ្វើឱ្យប្រសើរឡើងនូវសុខភាពព្រៃឈើផងដែរ (Agarwal ឆ្នាំ២០០៩) នៅក្នុងកម្មវិធី REDD+ មួយនៅប្រទេសនេប៉ាល់ ស្ត្រីមានចំនួនត្រឹមតែ១៥%ប៉ុណ្ណោះក្នុងចំណោមក្បាលម៉ាស៊ីនដឹកនាំ (Khadka etal ឆ្នាំ២០១៤)។ ការពិនិត្យមើលការសិក្សានានាធ្វើឡើងដោយ WOCAN, UNREDD និង USAID-LEAF (ឆ្នាំ២០១៣) នៅកម្ពុជា ហ្វីលីពីន និងស្រីលង្កា បង្ហាញថា ស្ត្រីជួបនឹងរបាំងជាច្រើនរារាំងដល់ការចូលរួមក្នុងកម្មវិធី REDD+ រួមបញ្ចូលកង្វះការទទួលបានសកម្មភាពជីវភាពរស់នៅមិនពឹងអាស្រ័យលើព្រៃឈើ ស្ត្រីទទួលបានព័ត៌មានបច្ចេកទេសអំពី REDD+ នៅមានកម្រិតទាបពេកនិងបរាជ័យក្នុងការធ្វើសមាហរណកម្មបញ្ហាយេនឌ័រទៅក្នុងសកម្មភាពបង្កើតគោលនយោបាយ REDD+។

លើសពីនេះទៀត ទោះបីជាប្រទេសនានា ដូចជា បង់ក្លាដែស កម្ពុជា ឥណ្ឌា នេប៉ាល់ បានចែងថា ការចូលរួមរបស់ស្ត្រីនៅគ្រប់កម្រិតមូលដ្ឋានតាមរយៈកំណែទម្រង់វិមជ្ឈការ ជាពិសេសនៅក្នុងគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយក្តី ប៉ុន្តែរបាយការណ៍រឹងមាំមកពីកម្រិតសហគមន៍ដែលស្នើឱ្យមានការចូលរួមប្រកបដោយអត្ថន័យរបស់ស្ត្រីនៅក្នុងការធ្វើសេចក្តីសម្រេច នៅតែមានតិចតួចបំផុត និងជាញឹកញាប់ គឺអវត្តមានតែម្តង (UN Women ឆ្នាំ២០១៦)។

ចំណុចទាំងនេះ បង្ហាញឱ្យឃើញការពិតថា មិនមែនត្រឹមតែរបាំងសង្គម-វប្បធម៌ប៉ុណ្ណោះទេ ដែលរារាំងដល់ការចូលរួមរបស់ស្ត្រី ប៉ុន្តែ ត្រូវការនូវក្របខ័ណ្ឌការងារគោលនយោបាយកាន់តែរឹងមាំថែមទៀត ដើម្បីរួមបញ្ចូលសំឡេងស្ត្រីប្រកបដោយប្រសិទ្ធភាពនៅក្នុងការបន្សាំ និងស្ថាប័នការគ្រប់គ្រងគ្រោះមហន្តរាយ និងគណៈកម្មាធិការការធ្វើសេចក្តីសម្រេចនៅកម្រិតមូលដ្ឋាន។

ការវាយតម្លៃទាបចំពោះការចូលរួមចំណែករបស់ស្ត្រីនៅក្នុងវិស័យនេះជាញឹកញាប់បណ្តាលឱ្យពួកគេមិនត្រូវបានគេចាត់ទុកជាភាគីពាក់ព័ន្ធ ដែលនាំឱ្យមានការផាត់ពួកគេចេញពីវេទិកា និងដំណើរការ និងវេទិកានៃការធ្វើសេចក្តីសម្រេចបែបនេះ (Mbow et al ឆ្នាំ២០១៩)។

**គន្លឹះសម្រាប់គ្រូឧទ្ទេស**

សម្រាប់វគ្គកម្រិតខ្ពស់ក្រៅពីបទបង្ហាញគេអាចបំបែកអ្នកចូលរួមជាប្រាំក្រុមដោយចែកជន្យនិងដាក់ប្រធានបទមួយ/បញ្ហាប្រឈមមួយរួមជាមួយសំណេរដូចសំណៅឯកសារហើយស្នើឱ្យជជែកទៅលើស្ថានភាព និងគម្លាតនៅក្នុងការបញ្ជ្រាបយេនឌ័រនៅតំបន់អាស៊ីដោយផ្តោតលើប្រទេសរបស់ពួកគេផ្ទាល់។

សម្រាប់វគ្គមូលដ្ឋានគ្រឹះប្រចាប់បញ្ចូលគ្នាប្រធានបទពីរ«គម្លាត និងបញ្ហាប្រឈម» និង«យុទ្ធសាស្ត្រ និងចំណុចចាប់ផ្តើម» ចូលទៅក្នុងបទបង្ហាញតាមកម្មវិធីកុំព្យូទ័រ។ បង្កើតផ្ទាំងបង្ហាញមួយៗសម្រាប់ចំណុចនីមួយៗដោយប្រើប្រាស់ទម្រង់ខាងក្រោម។

**គម្លាត និងបញ្ហាប្រឈម**

**យុទ្ធសាស្ត្រពាក់ព័ន្ធ**

**ចំណុចចាប់ផ្តើមអង្គការសង្គមស៊ីវិល**

បន្ថែមដំណើរការ NAP និង ccGAP ជាឧទាហរណ៍លម្អិតដ៏សំខាន់

## យន្តការស្ថាប័នទូលាយពេក

របាំងមួយទៀតនៅក្នុងការបញ្ជ្រាបយេនឌ័រនៅក្នុងតំបន់អាស៊ីគឺភាពស្មុគស្មាញនៃយន្តការស្ថាប័ន CCDRR នៅក្នុងរចនាសម្ព័ន្ធរដ្ឋាភិបាល។ ទោះបីជាការដោះស្រាយការប្រែប្រួលអាកាសធាតុស្ថិតនៅក្រោមដែនសមត្ថកិច្ចក្រសួងបរិស្ថាន មានក្រសួងតាមវិស័យ និងនាយកដ្ឋានជាច្រើនទៀត ដែលមានតួនាទីសំខាន់មួយនៅក្នុងដំណើរការនេះ។ សូម្បីតែ DRR ក៏កាន់តែស្មុគស្មាញថែមទៀត ដោយត្រូវបានដាក់ឱ្យស្ថិតនៅក្រោមក្រសួងខុសៗគ្នាអាស្រ័យទៅតាមប្រទេសដូចជាក្រសួងមហាផ្ទៃ(ឥណ្ឌា)ក្រសួងគ្រប់គ្រងគ្រោះមហន្តរាយនិងការសង្គ្រោះ(បង់ក្លាដែស)ឬក្រសួងកសិកម្ម និងអភិវឌ្ឍន៍ជនបទ (វៀតណាម)។ ចំនួនអង្គភាពស្ថាប័នដ៏ច្រើនលើសលប់ដែលដោះស្រាយបញ្ហាស្រដៀងគ្នានៅលើ CCDRR ដោយមិនមានការសម្របសម្រួលត្រឹមត្រូវនោះ រារាំងដល់វឌ្ឍនៈភាពក្នុងការបញ្ជ្រាបយេនឌ័រទូទាំងតំបន់ (UN Women ឆ្នាំ២០១៦)។

បន្ថែមពីនេះទៀត សមភាពយេនឌ័រ និងការផ្តល់ភាពអង់អាចដល់ស្ត្រី ជាញឹកញាប់ត្រូវបានចាត់ទុកថាជាដែនសមត្ថកិច្ច និងការទទួលខុសត្រូវរបស់ក្រសួងកិច្ចការនារី។ ទោះបីយ៉ាងណាពួកគេតែងតែជាក្រសួងទន់ខ្សោយ ខ្វះអំណាចនយោបាយ និងចំណេះដឹងបច្ចេកទេស ដើម្បីបញ្ជ្រាប និងដោះស្រាយបញ្ហាសមភាពយេនឌ័រឱ្យបានគ្រប់គ្រាន់គ្រប់បណ្តាក្រសួងផ្សេងទៀត (នាយកដ្ឋានកិច្ចការសេដ្ឋកិច្ច និងសង្គមអង្គការសហប្រជាជាតិ ឆ្នាំ២០០៧)។ តាមលក្ខណៈបច្ចេកទេស ទោះបីជាមានវិសាលភាព និងករណីសម្រាប់បញ្ជ្រាបយេនឌ័រក្តី ក៏ក្រសួងកិច្ចការនារីមិនអាចនិយាយភាសាបច្ចេកទេសពាក់ព័ន្ធយេនឌ័រដែលងាយឱ្យក្រសួងដទៃទៀតស្តាប់យល់ និងងាយយកទៅអនុវត្តនោះឡើយ (UN Women ឆ្នាំ២០១៦)។

ទោះបីជាភស្តុតាងមានកម្រិតមួយចំនួនកើតឡើងនៅកន្លែងមានការអនុវត្តការបញ្ជ្រាបយេនឌ័រក្តីក៏មិនមានការចែករំលែកព័ត៌មាននេះសម្រាប់ការរៀនសូត្រ និងកែលម្អនោះឡើយ។ ជាមួយគ្នានេះដែរ ការទទួលខុសត្រូវខ្ពស់សម្រាប់ការបញ្ជ្រាបយេនឌ័រ ថែមទាំងរារាំងដល់ការធ្វើសមាហរណកម្មត្រឹមត្រូវទៀត(OCEDឆ្នាំ២០១៥)។
វាមានសារសំខាន់ដែលប្បញ្ញត្តិយេនឌ័រ និង CCDRR ស្ថិតនៅក្រោមក្រសួងយេនឌ័រ និង CCDRR ហើយវាមានសារសសំខាន់ណាស់ដែលយន្តការស្ថាប័នសម្រាប់សម្របសម្រួលរវាងក្រសួងទាំងពីរលើបញ្ហានេះ ត្រូវតែបង្កើតឡើងដោយមានការគាំទ្រខាងផ្នែកបច្ចេកទេសគ្រប់គ្រាន់។

## គម្លាតចំណេះដឹង និងកង្វះសមត្ថភាព

កង្វះដែនសមត្ថកិច្ចធ្វើការលើសមភាពយេនឌ័រនៅក្នុងក្រសួងបរិស្ថាន និង CCDRR ក៏ទាមទារឱ្យមានសមត្ថភាពគ្រប់គ្រាន់នៅក្នុងក្រសួងកិច្ចការនារី ព្រមទាំងក្រសួងដទៃផ្សេងទៀតផងដែរ។ ចំពោះក្រសួងកិច្ចការនារី ចំណុចនេះគឺចង់ឱ្យអ្នកជំនាញបច្ចេកទេស តស៊ូមតិប្រកបដោយជោគជ័យសម្រាប់ការរួមបញ្ចូលវិសាលភាពសមភាពយេនឌ័រក្នុង CCDRR ដែលតែងតែខ្វះខាត។ ម្យ៉ាងទៀតក្រសួងផ្សេងៗមានការយល់ដឹងត្រឹមមូលដ្ឋានគ្រឹះ«យេនឌ័រមានន័យថាស្ត្រី» ដូចនេះ ជាលទ្ធផល គោលនយោបាយ និងយុទ្ធសាស្ត្របង្ហាញយ៉ាងច្រើនថាស្ត្រីជាជនរងគ្រោះ (WEDO ឆ្នាំ ២០១៦)។ទោះបីយ៉ាងណាសមត្ថភាពយល់ដឹងនិងដោះស្រាយនូវទំនាក់ទំនងដ៏ស្មុគស្មាញឱ្យបានទូលំទូលាយរវាងសមភាពយេនឌ័រ និងការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ គឺជាបញ្ហាប្រឈមដ៏ធំដែលស្ថាប័នទាំងនេះជួបប្រទះ។

បញ្ហានេះត្រូវបានដាក់បញ្ចូលបន្ថែមទៀតនៅក្នុងរចនាសម្ព័ន្ធអភិបាលកិច្ចវិមជ្ឈការ ដែលកម្រិតការយល់ដឹងអំពីយេនឌ័រនៅមានកម្រិតនៅឡើយ។ដូច្នេះកង្វល់ធំៗជាច្រើនមានទូទាំងតំបន់ទាក់ទងនឹងការអនុវត្តជាក់ស្តែងនូវគោលនយោបាយដែលមានស្រាប់ និងសកម្មភាពដែលបានគ្រោងទុកនៅកម្រិតមូលដ្ឋាន។ បញ្ហាប្រឈមនេះកាន់តែរីកធំ ដោយសារការចូលរួមមានកម្រិតទាបនៃតួអង្គមិនមែនរដ្ឋាភិបាលនៅកម្រិតមូលដ្ឋាន។ ជាញឹកញាប់ ប្រទេសនៅតំបន់អាស៊ីភាគច្រើន អង្គការសង្គមស៊ីវិលមានកម្មវិធី/គម្រោងជាក់លាក់ ដើម្បីដោះស្រាយការប្រែប្រួលអាកាសធាតុ ឬ DRR និងសមភាពយេនឌ័រ ដែលមានន័យថា ពួកគេក៏សម្បូរនូវព័ត៌មានស្តីពីផលប៉ះពាល់ការប្រែប្រួលអាកាសធាតុនិងគ្រោះមហន្តរាយទៅលើក្រុមសង្គមខុសៗគ្នា។ ទោះជាយ៉ាងណាវេទិកាដែលដំណើរការមានតែពីរបីប៉ុណ្ណោះសម្រាប់សម្របសម្រួលសកម្មភាពប្រកបដោយយុទ្ធសាស្ត្រលទ្ធផលទំនាក់ទំនងឬការចែករំលែកទិន្នន័យឬការអនុវត្តប្រសើរបំផុតដែលរួមបញ្ចូលទាំងសមភាពយេនឌ័រ និង CCDRR។ កង្វះនូវការសម្របសម្រួលក្នុងចំណោមរដ្ឋាភិបាលនិងតួអង្គសង្គមស៊ីវិលធ្វើការលើCCDRRនាំឱ្យខកខានឱកាស ដើម្បីបង្កើតទិន្នន័យកម្រិតសហគមន៍ និងបង្ហាញនូវរូបភាពតែមួយនៃផលប៉ះពាល់លើមនុស្ស និងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ (UN Women ឆ្នាំ ២០១៦)។

## ការអនុវត្តគោលនយោបាយ និង ផែនការដែលគ្មានប្រសិទ្ធភាព

វាត្រូវបានទទួលស្គាល់ទូទាំងតំបន់ថាកិច្ចប្រឹងប្រែងត្រូវបានធ្វើឡើងដើម្បីនាំយកវិសាលភាពយេនឌ័រនៃCCDRRដាក់បញ្ចូលទៅក្នុងគោលនយោបាយ។ ទោះបីយ៉ាងណា ភាពទូលាយពេកនៃការបែងចែកការទទួលខុសត្រូវក្នុងការដោះស្រាយគម្លាតចំណេះដឹងនិងសមត្ថភាពជាញឹកញាប់នាំឱ្យកំណែទម្រង់គោលនយោបាយទទួលបរាជ័យនៅក្នុងការបកស្រាយឱ្យចេញជាសកម្មភាព និងការអនុវត្តនៅកម្រិតមូលដ្ឋានដែលពិតជាអាចបង្កើតការផ្លាស់ប្តូរដ៏មានអត្ថន័យនៅក្នុងជីវិតរស់នៅរបស់ស្ត្រី។
ជាឧទាហរណ៍ នៅប្រទេសបង់ក្លាដែស យុទ្ធសាស្ត្រ និងផែនការ

សកម្មភាពការប្រែប្រួលអាកាសធាតុបង់ក្លាដែស (BCCSAP) ត្រូវបានបង្កើតឡើងនៅឆ្នាំ២០០៩។ ទោះជាយ៉ាងណា សូម្បីតែការផ្តោតខ្លាំងលើ «ស្ត្រីក្នុងនាមជាអ្នកងាយរងគ្រោះ» នៅក្នុងឯកសារគោលនយោបាយ BCCSAP ក្តី ក៏មានតែគម្រោងចំនួនពីរបីប៉ុណ្ណោះដែលទទួលបានជំនួយពី BCCT នោះ បានផ្តោតលើការកាត់បន្ថយភាពងាយរងគ្រោះរបស់ស្ត្រី ដែលជារបៀបវារៈផ្តោតលើយេនឌ័រខ្លាំងជាងគេតែមួយគត់។ ជាការពិត ccGAP បង់ក្លាដែស ទោះបីជាបានបង្កើតឡើងយ៉ាងល្អិតល្អន់ក៏ដោយ ក៏នៅមិនទាន់បានបោះជំហានដល់កម្រិតអនុវត្តនៅឡើយទេ (UN Women ឆ្នាំ២០១៦)។ ស្រដៀងគ្នានេះដែរ ទោះបីជាទិដ្ឋភាពគោលនយោបាយនៅកម្ពុជាមានលក្ខណៈទូលំទូលាយដូចទៅនឹងការបង្កើតក្តី ប៉ុន្តែបញ្ហានានានៅតែបន្តមាននៅក្នុងការអនុវត្ត។ ភាគីពាក់ព័ន្ធផ្សេងៗទៀត និងទីភ្នាក់ងារការអនុវត្ត ខ្វះការយល់ដឹងរួម និងការសម្របសម្រួលនៅក្នុងបរិបទយេនឌ័រ និង CCDRR (Reggers និង Lim ឆ្នាំ២០១៩)។

ស្ថានភាពកាន់តែអាក្រក់នៅក្នុងករណីDRR។ការវិភាគការបែងចែកមូលនិធិដើម្បីការពារនិងបញ្ហាយេនឌ័រនៅក្នុង«ការអំពាវនាវបន្ទាន់» បង្ហាញថា ការដោះស្រាយសមភាពយេនឌ័រនៅក្នុងការឆ្លើយតបគ្រោះមហន្តរាយ មិនត្រូវផ្តល់អាទិភាពដោយសារជាញឹកញាប់តួអង្គមនុស្សធម៌មិនយល់ពីតម្រូវការ ដើម្បីលើកកម្ពស់កិច្ចការពារនិងសមភាពយេនឌ័រនៅក្នុងស្ថានភាពគ្រោះអាសន្នដូចជា «ការគំរាមកំហែងអាយុជីវិត» ដែលជាលក្ខណៈវិនិច្ឆ័យសំខាន់សាកសមសម្រាប់ «ការអំពាវនាវបន្ទាន់» និងមូលនិធិឆ្លើយតបបន្ទាន់នៅថ្នាក់កណ្តាលរបស់អង្គការសហប្រជាជាតិ (CERF) (UN Women ឆ្នាំ២០១៦)។

ជាការពិត ម្ចាស់ជំនួយសំខាន់ៗមួយចំនួន ផ្តល់មូលនិធិមនុស្សធម៌មិនដល់១ភាគរយទៅដល់ការលើកកម្ពស់សមភាពយេនឌ័រនៅក្នុងគ្រាអាសន្ន(របាយការណ៍ជំនួយមនុស្សធម៌ពិភពលោក ឆ្នាំ២០១៤)។ និន្នាការនេះ មាន ដូចគ្នានៅក្នុងតំបន់អាស៊ី។ ឧទាហរណ៍ ការឆ្លើយតបទៅនឹងគ្រោះរញ្ជួយដីចំនួន ២លើកនៅនេប៉ាល់ មូលនិធិត្រឹមតែ ៤ភាគរយ ប៉ុណ្ណោះនៃជំនួយមនុស្សធម៌ដែលទទួលបាននៅក្រោមផែនការ «ការអំពាវនាវបន្ទាន់» ត្រូវបានបែងចែកទៅក្នុងសកម្មភាពយេនឌ័រ និងចង្អោមកិច្ចការពារ (UN Women ឆ្នាំ២០១៦)។

## ការពិនិត្យឡើងវិញ និងការរាយការណ៍យន្តការនានានៅមានកម្រិត

បញ្ហាប្រឈមសំខាន់មួយទៀត គឺថា ការរាយការណ៍ពីវឌ្ឍនភាពស្តីពីយេនឌ័រនៅក្នុងបរិបទការប្រែប្រួលអាកាសធាតុមិនមែនជាចំណងផ្លូវច្បាប់នៅកម្រិតសកលនោះឡើយ។ ដោយផ្តល់សេរីភាពដល់រដ្ឋាភិបាលជាតិនីមួយៗមានការរាយការណ៍តិចតួចប៉ុណ្ណោះអំពីយេនឌ័រនិងការប្រែប្រួលអាកាសធាតុដែលគ្រាន់តែជាផ្នែកមួយនៃ INDCs/NDCs (WEDO ឆ្នាំ២០១៦)។ ទោះបីមានការរាយការណ៍ ជាញឹកញាប់ របាយការណ៍គ្រាន់តែចម្លើយ បាទ ,ចាស/មិនមែន ដោយបន្សល់ទុកវិសាលភាពតិចតួចក្នុងការវាយតម្លៃសមាហរណកម្ម និងលទ្ធផលជាក់ស្តែង។ ឧទាហរណ៍ របាយការណ៍នៅចន្លោះឆ្នាំ២០១៤ និង២០១៥ សម្រាប់ក្របខ័ណ្ឌការងារ Hyogo ដើម្បីសកម្មភាព (HFA) បានបង្ហាញថា ប្រទេសចំនួន ៨ នៅក្នុងចំណោមប្រទេស ១៣ (៦២%) ដែលលើកឡើងពីសកម្មភាពយេនឌ័រ ទោះជាយ៉ាងណា ប្រទេសត្រឹមតែពាក់កណ្តាលប៉ុណ្ណោះក្នុងចំណោមប្រទេសទាំងនេះបានដាក់បញ្ចូលសេចក្តីណែនាំយេនឌ័រនៅក្នុងវិធីសាស្ត្រការវាយតម្លៃតម្រូវការក្រោយគ្រោះមហន្តរាយរបស់ពួកគេ។នេះចង្អុលបង្ហាញឱ្យឃើញការយកចិត្តទុកដាក់នៅមានកម្រិតក្នុងការបោះដៃទៅរកស្ត្រី ប៉ុន្តែ ការពិត មិនបានដោះស្រាយតម្រូវការ និងអាទិភាព «យេនឌ័រ» ឡើយ។ ជាឧទាហរណ៍ បើទោះបីជាប្រទេសថៃបានរាយការណ៍ថា ស្ត្រីជាតួអង្គសំខាន់នៅក្នុង DRR តម្រូវការរបស់បុរស និងស្ត្រី ត្រូវបានសន្មត់ថាមានដូចគ្នា ហើយរដ្ឋាភិបាលបានផ្តល់នូវកញ្ចប់ទូទៅសម្រាប់ការឆ្លើយតប និងការសង្គ្រោះគ្រោះមហន្តរាយ (UN Women ឆ្នាំ២០១៦)។

**ចំណុចពិភាក្សា**

សូមសួរទៅអ្នកចូលរួមថា តើអ្វីខ្លះដែលពួកគេគិតថារដ្ឋាភិបាលជាតិអាចធ្វើបានដើម្បីដោះស្រាយគម្លាតទាំងនេះ ?

### តម្រុយសម្រាប់អ្នកសម្របសម្រួល

> បង្កើតវេទិកាផ្លូវការនិងយន្តការស្ថាប័នសម្រាប់ការចូលរួមរបស់ស្ត្រីនៅគ្រប់កម្រិត។ ឧទាហរណ៍ ផ្តល់កូតា ៣៣% នៅក្នុងរដ្ឋាភិបាលតំបន់ ផ្តល់ការអនុគ្រោះដល់ស្ត្រីនៅក្នុងតំណែងសាធារណៈ

> បង្កើតទីភ្នាក់ងារសម្របសម្រួល និងកន្លែងផ្លូវការសម្រាប់ការចូលរួមអង្គការសង្គមស៊ីវិល

> ចាប់ដៃគូជាមួយតួអង្គនិងអ្នកជំនាញការយេនឌ័រមូលដ្ឋានជាពិសេសការចូលរួមសហគមន៍ ការអភិវឌ្ឍជំនាញដល់ស្ត្រី យេនឌ័រ និងការកសាងសមត្ថភាព CCDRR ការរៀបចំនិងកសាងផែនការ និងការអនុវត្តគម្រោងមូលដ្ឋាន

> ផ្តល់ជំនួយសម្រាប់ការចូលរួមសហគមន៍ ការកសាង សមត្ថភាព និងគាំទ្រសម្រាប់ការអនុវត្ត

## យុទ្ធសាស្ត្រសម្រាប់ការបញ្ជ្រាបយេនឌ័រ និងចំណុចចាប់ផ្តើម/ច្រកចូលសម្រាប់អង្គការសង្គមស៊ីវិល

### តុល្យភាពយេនឌ័រនៅក្នុងអភិបាលកិច្ច និងស្ថាប័ន

តម្រូវការតុល្យភាពយេនឌ័រនៅក្នុងការចូលរួម និងភាពជាអ្នកដឹកនាំក្នុងការធ្វើសេចក្តីសម្រេច CCDRR ត្រូវបានទទួលស្គាល់ទាំងផ្នែកការផ្តល់ទីកន្លែងសម្រាប់ស្ត្រី ដើម្បីលើកឡើងនូវកង្វល់របស់ពួកគេ និងការធានានូវអាទិភាពរបស់ពួកគេត្រូវបានបញ្ចូលទៅក្នុងការសម្រេចចិត្ត ប៉ុន្តែជាការពិត ភាពដឹកនាំរបស់ស្ត្រីក៏ត្រូវបានបង្ហាញពីលទ្ធផលល្អប្រសើរជាងក្នុងការគ្រប់គ្រងបរិស្ថាន និងវិបត្តិ។ យើងធ្លាប់បានពិភាក្សារួចមកហើយអំពីយុទ្ធសាស្ត្រដើម្បីលើកកម្ពស់តុល្យភាពយេនឌ័រនៅកម្រិតសកលក្នុងប្រអប់ ២.១។ ការរៀនសូត្រ និងយុទ្ធសាស្ត្រសំខាន់ៗដែលអាចកែសម្រួលឱ្យសមស្របចំពោះកម្រិតជាតិ រួមមាន៖

ក) ការបង្កើតមូលនិធិការចូលរួមរបស់ស្ត្រីថ្នាក់ជាតិ៖ នៅកម្រិតជាតិ អង្គសង្គមស៊ីវិលដែលមានការគាំទ្រពីទីភ្នាក់ងារអង្គការសហប្រជាជាតិ និងរដ្ឋាភិបាលជាតិនានា អាចបង្កើតនូវមូលនិធិសម្រាប់ផ្តល់ជាមធ្យោបាយដឹកជញ្ជូន និងសម្ភារភ័ស្តុភារសម្រាប់ស្ត្រីមកពីមូលដ្ឋាន ដើម្បីចូលរួមក្នុងដំណើរការរៀបចំកសាងផែនការជាតិ។ មូលនិធិក៏អាចពង្រីកបន្ថែមផងដែរ ដើម្បីគាំទ្រដល់ការអភិវឌ្ឍភាពជាអ្នកដឹកនាំ ការបណ្តុះបណ្តាលការទំនាក់ទំនងចំណេះដឹងបច្ចេកទេស និងការចរចារសម្រាប់អ្នកដឹកនាំជាស្ត្រីនៅមូលដ្ឋាន។ ឧទាហរណ៍មួយថ្ងៃមុនសិក្ខាសាលាជាតិនិងតំបន់កិច្ចប្រជុំស្ត្រីដាច់ដោយឡែកអាចធ្វើឡើង ដើម្បីផ្តល់នូវព័ត៌មានថ្មីៗដល់ពួកគេ ជួយពួកគេដើម្បីវិភាគ និងចាត់អាទិភាពកង្វល់ និងបញ្ហារបស់ពួកគេនិងអាចនិយាយលក្ខណៈជាក្រុមដើម្បីចរចាសិទ្ធិរបស់ពួកគេនៅក្នុងសេចក្តីសម្រេចចុងក្រោយ។

ខ) បណ្តាញជាតិនៃ «ស្ត្រី និង CCDRR»៖ ម៉ូឌែលបណ្តាញអ្នកតំណាងសហព័ន្ធដែលមានវត្តមានស្ត្រីមកពីគ្រប់សារតាមករួមគ្នាទាំងអស់ផ្លាស់ប្តូរចំណេះដឹងនិងព័ត៌មាននិងចូលរួមរួមគ្នាសម្រាប់ការបន្តរបៀបវារៈនៅមូលដ្ឋាន គោលនយោបាយ និងកម្មវិធី CCDRR នៅក្រោមជាតិ និងជាតិ។

នៅកម្ពុជា ឧទាហរណ៍ កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) គ្រប់គ្រងលើសម្ព័ន្ធការប្រែប្រួលអាកាសធាតុនៅកម្ពុជា (CCCA) ដែលបង្កើតឡើងក្រោមការគាំទ្រដោយសហភាពអឺរ៉ុប (EU) សម្ព័ន្ធការប្រែប្រួលអាកាសធាតុសកល (GCCA)។ វាបង្កើតឱ្យមានការសម្របសម្រួលហិរញ្ញវត្ថុមានម្ចាស់ជំនួយពហុភាគីដើម្បីផ្តល់នូវធនធានសម្រាប់ការកសាងសមត្ថភាពការប្រែប្រួលអាកាសធាតុនៅកម្រិតរដ្ឋាភិបាលជាតិ និងមូលដ្ឋាន។ វាក៏ផ្តល់នូវយន្តការសម្រាប់ការចែករំលែកចំណេះដឹង និងការរៀនសូត្រពីការប្រែប្រួលអាកាសធាតុ វេទិកាស្រដៀងគ្នាមួយសម្រាប់ស្ត្រីអាចបង្កើតឡើង។ ឧទាហរណ៍ វេទិកាស្ត្រីបែបនេះក៏មាននៅឥណ្ឌា ក្រោមកម្មវិធីបេសកកម្មជីវភាពរស់នៅជាតិ និងនៅបង់ក្លាដែសក្រោមកម្មវិធី PKSF។ ដៃគូសមត្ថកិច្ច CCDRR អាចរួមបញ្ចូលនៅក្នុងរបៀបវារៈនៃវេទិកាដែលមានស្រាប់បែបនេះ។

វេទិកាបែបនេះក៏អាចក្លាយជាមូលដ្ឋានសម្រាប់កិច្ចប្រឹងប្រែងតស៊ូមតិជាមួយរដ្ឋាភិបាលជាតិ និងគួរតែមានបន្តនូវកិច្ចប្រឹងប្រែងនានាសម្រាប់រដ្ឋាភិបាល ដើម្បីផ្តល់នូវការទទួលស្គាល់ក្រុមបែបនេះជាផ្លូវការនៅគ្រប់ដំណើរការ។

គ) ការប្រកាសយេនឌ័រឆ្នើម និងផ្តល់រង្វាន់លើកទឹកចិត្ត នៅក្នុងការងារ CCDRR៖ វាក៏មានសារសំខាន់ដែរក្នុងការទទួលស្គាល់ការងារគំរូរបស់ស្ត្រីនៅក្នុង CCDRR នៅកម្រិតជាតិ និងថ្នាក់ក្រោមជាតិ។ ការត្រួតពិនិត្យឡើងវិញនូវរង្វាន់ដែលមានស្រាប់នៅកម្រិតជាតិ និងថ្នាក់ក្រោមជាតិដែលទាក់ទងនឹង CCDRR និងការផ្តល់ភាពអង់អាចដល់យេនឌ័រ/ស្ត្រី និងការបង្កើតក្រុមយេនឌ័រ និង CCDRR នៅកម្រិតទាំងពីរនេះ នឹងផ្តល់នូវការចូលរួមចាំបាច់ជាច្រើន។

ឃ) ការបង្កើតឲ្យមានកន្លែង និងឱកាសសម្រាប់មានការចូលរួមរបស់ស្ត្រីនៅក្នុងការធ្វើសេចក្តីសម្រេចចិត្តនៅគ្រប់ស្ថាប័នថ្នាក់មូលដ្ឋាន៖ ប្រទេសជាច្រើននៅតំបន់អាស៊ី កំពុងចាត់វិធានការរួចរាល់ហើយសម្រាប់ការចូលរួមរបស់ស្ត្រីនៅក្នុងគណៈកម្មាធិការមូលដ្ឋាន ជាពិសេស អ្នកទាំងឡាយណាទាក់ទងនឹងការគ្រប់គ្រងគ្រោះមហន្តរាយ (បង់ក្លាដែស កម្ពុជា ឥណ្ឌា នេប៉ាល់) ការគ្រប់គ្រងព្រៃឈើ (ឥណ្ឌា នេប៉ាល់) ការគ្រប់គ្រងទឹក (ឥណ្ឌា) ការអប់រំ សុខភាព និងអាហារូបត្ថម្ភ (ឥណ្ឌា ថៃ)។ល។ វាមានសារសំខាន់ក្នុងការពង្រីកបន្ថែមការចូលរួមនេះលើសពីវិស័យដែលធ្លាប់មាននៅក្នុងកសិកម្ម ធារាសាស្ត្រ ថាមពល ការសាងសង់ផ្ទះសម្បែង និងការអភិវឌ្ឍទីក្រុង ព្រោះមិនមានវិស័យណាមួយមានអព្យាក្រិត្យភាពយេនឌ័រនោះឡើយហើយស្ត្រីត្រូវការធ្វើជាតំណាងនៅគ្រប់វិស័យទាំងអស់។

ទោះបីយ៉ាងណាវាមិនទាន់គ្រប់គ្រាន់ទេបើគ្រាន់តែបញ្ចូលស្ត្រីជាអ្នកចូលរួមនោះស្ត្រីត្រូវបានទទួលតួនាទីជាអ្នកដឹកនាំនិងតួនាទីដែលអាចធ្វើសេចក្តីសម្រេចនៅក្នុងអង្គភាពទាំងនេះ។ ជាមួយគ្នាដែរ តម្រូវការទាំងនេះគាំទ្រយ៉ាងខ្លាំងតាមរយៈការកសាងសមត្ថភាព និងគាំទ្ររួមគ្នាពីអង្គការសង្គមស៊ីវិលសម្រាប់លទ្ធផលប្រកបដោយប្រសិទ្ធភាព។ ទីភ្នាក់ងារអភិវឌ្ឍន៍ដូចជាអង្គការសហប្រជាជាតិដើរតួយ៉ាងសំខាន់នៅក្នុងនេះ។ ឧទាហរណ៍ នៅតំបន់អាស៊ីខាងត្បូង (ឥណ្ឌា ប៊ូតង់ ម៉ាល់ឌីវ និងស្រីលង្កា) អង្គការសហប្រជាជាតិដើម្បីស្ត្រី

ទទួលបានការគាំទ្រដោយរដ្ឋាភិបាលន័វេ បានអនុវត្តកម្មវិធីដោយផ្តោតលើយេនឌ័រនិងកម្មវិធីអភិបាលកិច្ចមូលដ្ឋានដែលផ្តោតលើការកសាងភាពជាអ្នកដឹកនាំនយោបាយដល់ស្ត្រី និងការផ្តល់ភាពអង់អាចដល់ស្ត្រីជាប្រជាពលរដ្ឋដើម្បីចូលរួមនៅក្នុងការរៀបចំ និងកសាងផែនការអភិវឌ្ឍកម្រិតភូមិ។

**ចំណុចពិភាក្សា**

សូមសួរអ្នកចូលរួម តើអ្វីខ្លះដែលពួកគេគិតថា អាចជាតួនាទីរបស់អង្គការសង្គមស៊ីវិលក្នុងការធ្វើឱ្យមានលក្ខណៈដូចខាងលើ? ស្នើសុំឱ្យពួកគេលើកនូវឧទាហរណ៍ជាករណីដែលពួកគេអនុវត្តសកម្មភាពស្រដៀងគ្នានៅក្នុងបរិបទ CCDRR ឬក្នុងវិស័យពាក់ព័ន្ធដទៃផ្សេងទៀត?

**តម្រុយសម្រាប់អ្នកសម្របសម្រួល**

> រួមគ្នាបង្កើតក្របខ័ណ្ឌជាតិមួយស្តីពីយេនឌ័រ និង CCDRR
> ការតស៊ូមតិជាមួយរដ្ឋាភិបាលសម្រាប់ការផ្តល់ទីកន្លែងស្របច្បាប់នៅក្នុងវេទិការៀបចំផែនការនិងការធ្វើសេចក្តីសម្រេច
> ការចែករំលែកព័ត៌មាន និងបទពិសោធន៍ទៀតទាត់
> ធ្វើការវាយតម្លៃ និងសិក្សារួមគ្នា ដែលក្របខ័ណ្ឌការសិក្សា និងវិធីសាស្ត្រត្រូវបានសម្រេចនៅកម្រិតជាតិនិងត្រូវបានប្រើដោយអង្គការសង្គមស៊ីវិល ដើម្បីប្រមូលព័ត៌មាននៅកម្រិតមូលដ្ឋាន។ព័ត៌មានត្រូវចែករំលែកត្រឡប់ទៅវិញនៅកម្រិតថ្នាក់ជាតិ ដើម្បីការវិភាគ និងការផ្ទៀងផ្ទាត់បញ្ចូលទៅក្នុងរបាយការណ៍ជាតិ ព្រមទាំងការសង្ខេបការគាំទ្រសម្រាប់អង្គការសង្គមស៊ីវិលយកទៅប្រើប្រាស់សម្រាប់ការតស៊ូមតិនៅកម្រិតមូលដ្ឋាន។ ដើម្បីប្រើប្រាស់សម្រាប់ការតស៊ូមតិនៅកម្រិតមូលដ្ឋាន។ នេះអាចទាក់ទាញមូលនិធិពីអង្គការសង្គមស៊ីវិលនានាដើម្បីធ្វើការស្រាវជ្រាវធំមួយដែលមានការវិភាគកាន់តែស៊ីជម្រៅ កាន់តែមានតម្លៃក្នុងការតស៊ូមតិ និងជះឥទ្ធិពល ជាជាងរបាយការណ៍តូចៗជាច្រើន ដែលការវិភាគនៅមានកម្រិតនោះ។
> ការប្តេជ្ញាការគាំទ្រ និងកសាងសមត្ថភាពសម្រាប់ស្ត្រីនៅសហគមន៍សម្រាប់ការចូលរួមក្នុងគណៈកម្មាធិការមូលដ្ឋាន

ង) មានតំណាងស្ត្រី/ក្រុមស្ត្រីនៅគ្រប់លំហូរយន្តការស្ថាប័ន៖ ប្រទេសទាំងអស់ មានស្ថាប័នការរៀបចំផែនការជាតិ និងការបង្កើតគោលនយោបាយ ក្រសួងផែនការនៅវៀតណាម និងកម្ពុជាឬគណៈកម្មការផែនការដូចករណីនៅបង់ក្លាដែស។ វាមានសារសំខាន់ក្នុងការផ្តោតទៅលើអង្គភាពស្ត្រី/យេនឌ័រនៅក្នុងស្ថាប័នផែនការខ្ពស់បំផុតនេះនៅក្នុងប្រទេស។ ឧទាហរណ៍ ឥណ្ឌា មានអង្គភាពផ្ទាល់សម្រាប់ស្ត្រី និងផ្នែកអភិវឌ្ឍន៍កុមារនៅក្នុងស្ថាប័នផែនការកំពូលឈ្មោះNitiAayog (គណៈកម្មការរៀបចំផែនការ Erstwhile)

ច) ប្រទេសភាគច្រើនមានបង្កើតគណៈកម្មការដឹកនាំ ដោយជ្រើសរើសរដ្ឋមន្ត្រីជាថ្នាក់ដឹកនាំ សម្រាប់ការបង្កើតគោលនយោបាយ CCDRRរបស់ពួកគេជាពិសេសផែនការបន្សាំជាតិ (NAP)។ ក្រសួងកិច្ចការនារី ឬស្ថាប័នសមមូលដោះស្រាយសមភាពយេនឌ័រគួររួមបញ្ចូលគណៈកម្មការដឹកនាំនេះ ដើម្បីធានាថាសមភាពយេនឌ័រក្លាយជាវិសាលភាពសំខាន់នៃការបង្កើតផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាព។ តួនាទីសំខាន់នៃស្ថាប័ននេះផ្តល់នូវព័ត៌មានពាក់ព័ន្ធនឹងយេនឌ័រនៅក្នុង CCDRR ធានានូវភាពសុខដុមនៃផែនការ NAP ជាមួយនឹងច្បាប់ និងគោលនយោបាយដែលពាក់ព័ន្ធយេនឌ័រនៅក្នុងប្រទេស រួមមានការប្តេជ្ញាចិត្តរបស់អង្គការ CEDAW និង SDG និងគួរតែដើរតួជាស្ពានភ្ជាប់រវាងក្រុមស្ត្រី ទៅនិងស្ថាប័នមូលដ្ឋានដោយធ្វើការលើយេនឌ័រដើម្បីអាចនាំទស្សនៈរបស់ស្ត្រីទៅក្នុងដំណើរការរៀបចំផែនការ CCDRR ថ្នាក់ជាតិ។

ឆ) មានអ្នកជំនាញការយេនឌ័រដោយផ្ទាល់ ឬជាអ្នកជួយគាំទ្រដល់ស្ថាប័នទាំងអស់៖នៅក្នុងប្រទេសនានាដែលក្រុមរៀបចំផែនការឬក្រុមសម្របសម្រួលត្រូវបានបង្កើតឡើង ដើម្បីការអភិវឌ្ឍនិងការអនុវត្តផែនការCCDRRវាមានសារសំខាន់ណាស់ដែលស្ថាប័ននេះត្រូវគាំទ្រដោយអ្នកជំនាញការយេនឌ័រ។ យុទ្ធសាស្ត្រដែលអាចទៅរួចមួយ គឺត្រូវមានអ្នកជំនាញការយេនឌ័រម្នាក់ សម្រាប់ជួយក្នុងដំណើរការរៀបចំផែនការទាំងមូល ដែលអាចកំណត់បន្ថែមនូវស្ថាប័នរដ្ឋាភិបាល និងមិនមែនរដ្ឋាភិបាល ដើម្បីពិគ្រោះយោបល់ជាមួយប្រធានបទនីមួយៗ។ បន្ថែមពីនេះទៀត ដោយសារតែយេនឌ័រជាបញ្ហាឆ្លងវិស័យដែលចាំបាច់ អ្នកជំនាញការយេនឌ័រម្នាក់ ក៏គួរតែមានតួនាទីចូលរួមនៅក្នុងកិច្ចពិភាក្សាជាមួយក្រសួងពាក់ព័ន្ធដទៃទៀត។ ឧទាហរណ៍ នៅបង់ក្លាដែស មានការយល់ដឹងកើនឡើងច្រើននៅក្នុងមូលនិធិសម្រាប់ការប្រែប្រួលអាកាសធាតុបង់ក្លាដែស (BCCT) ដែលស្ត្រីគួរតែរួមបញ្ចូលនៅក្នុងក្រុមការគ្រប់គ្រងគម្រោង និងគណៈកម្មាធិការប្រតិបត្តិ។

ជ) ការបង្កើតជនបង្គោលទទួលបន្ទុកយេនឌ័រសម្រាប់ការបញ្ជ្រាបយេនឌ័រក៏ជាការរៀបចំស្ថាប័នរួមនៅតាមបណ្តាប្រទេសនានាក្នុងតំបន់អាស៊ីផងដែរ។ឧទាហរណ៍នៅប្រទេសបង់ក្លាដែស ក្រសួងនីមួយៗមានជនបង្គោលម្នាក់ខាងការប្រែប្រួលអាកាសធាតុ និងជនបង្គោលស្ត្រីម្នាក់ខាងការអភិវឌ្ឍ ដែលទទួលខុសត្រូវលើការបញ្ជ្រាបការប្រែប្រួលអាកាសធាតុ និងយេនឌ័រនៅក្នុងដំណើរការ និងកម្មវិធីរដ្ឋាភិបាល។ នៅប្រទេសថៃ សេចក្តីសម្រេចរបស់គណៈរដ្ឋមន្ត្រី ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០២១ បញ្ជាទៅក្រសួង និងនាយកដ្ឋាននីមួយៗ ឱ្យមានការចាត់តាំងមន្ត្រីប្រតិបត្តិរបស់ពួកគេដែលត្រូវបានចាត់តាំងជា

ប្រធានសមភាពយេនឌ័រនិងមានធនធានផ្ទាល់ជាជនបង្គោលទទួលបន្ទុកយេនឌ័រ។ យន្តការនេះមានគោលបំណងលើកកម្ពស់ការយល់ដឹងពីយេនឌ័រនៅក្នុងក្រសួងបច្ចេកទេស។ ទោះបីយ៉ាងណា វាមានសារៈសំខាន់ក្នុងការមានមន្ត្រីជាន់ខ្ពស់ និងអ្នកទាំងឡាយណាដែលបានទទួលការបណ្តុះបណ្តាល និងមានជំនាញវិភាគយេនឌ័រជាចាំបាច់ ត្រូវបានតែងតាំងជាជនបង្គោលទទួលបន្ទុកយេនឌ័រ។

ឈ) ការមានស្ថាប័នចាត់តាំងជាក់លាក់មានដែនសមត្ថកិច្ចសម្រាប់ការបញ្ជ្រាបយេនឌ័រ និងតំណាងមកពីគ្រប់វិស័យទាក់ទងនឹង CCDRR៖ កម្ពុជា ទោះបីជាបញ្ហាប្រឈមមួយចំនួនក្តី ប៉ុន្តែ មានវឌ្ឍនភាពបានកើតឡើងដែរតាមរយៈការបង្កើតស្ថាប័នជាក់លាក់ ដើម្បីធ្វើការលើបញ្ហាសមភាពយេនឌ័រ និងការបញ្ជ្រាបយេនឌ័រនៅក្នុង CCDRR។ ក្រសួងកិច្ចការនារី (MoWA) ទទួលខុសត្រូវលើការបញ្ជ្រាបយេនឌ័រតាមរយៈខ្សែរយៈក្រសួងនានា និងគណៈកម្មាធិការយេនឌ័រ និងគ្រប់គ្រងការប្រែប្រួលអាកាសធាតុ (GCCC) ត្រូវបានបង្កើតនៅឆ្នាំ២០១១។ GCCC មានសមាជិកជាបុគ្គលិក ដែលជួបប្រជុំរៀងរាល់ខែ និងមានអនុគណៈកម្មាធិការសម្រាប់ការប្រែប្រួលអាកាសធាតុ DRR ការអភិវឌ្ឍបៃតង និងតំបន់មេគង្គ។ គណៈកម្មាធិការនេះ ក៏មានផែនការមេគោលនយោបាយផ្ទាល់ឆ្នាំ ២០១៤-២០២២។

កម្ពុជាក៏មានក្រុមការងារយេនឌ័រអន្តរក្រសួង ដែលចូលរួមដោយទីភ្នាក់ងាររដ្ឋាភិបាលខុសៗគ្នា ដើរតួជាស្ថាប័នផ្តល់យោបល់និងមានសារសំខាន់យ៉ាងខ្លាំងនៅក្នុងដំណើរការនៃការរួមបញ្ចូលបញ្ហាយេនឌ័រនៅក្នុងការប្រែប្រួលអាកាសធាតុ និង DRR។ នៅប៉ាគីស្ថាន តម្រូវការ និងកង្វល់នានារបស់ក្រុមងាយរងគ្រោះ រួមមានស្ត្រី កុមារ មនុស្សមានអាយុច្រើន និងពិការភាព ត្រូវបានដោះស្រាយដោយអង្គភាពកុមារ និងយេនឌ័រដាច់ដោយឡែកដែលបង្កើតឡើងនៅទីភ្នាក់ងារគ្រប់គ្រងគ្រោះមហន្តរាយជាតិ (NDMA) ជាមួយសមភាគីខេត្តនៅខេត្ត/តំបន់ DMAs។

ញ) កន្លែងសម្រាប់ការចូលរួមរបស់ភាគី និងសង្គមស៊ីវិលពាក់ព័ន្ធ៖ ក៏មានត្រូវការនូវការផ្តល់នូវក្រុមស្ត្រីជាតិ និងមូលដ្ឋានជាមួយទម្រង់សម្រាប់ការសន្ទនា ការផ្លាស់ប្តូរបទពិសោធន៍ និងការបង្កើតការអនុវត្តប្រសើរបំផុត ដែលភ្ជាប់លក្ខណៈយុទ្ធសាស្ត្រជាមួយនឹងសមាសធាតុនៃគោលនយោបាយ និងផែនការ CCDRR ជាតិ។ សំខាន់ជាងនេះទៀត ស្ត្រីសហគមន៍ និងអ្នកធ្វើការសម្រេចចិត្ត មានតម្រូវការសម្របសម្រួលនូវកន្លែងទូលាយសម្រាប់ការសន្ទនាក្នុងន័យស្ថាបនា ដូច្នេះ តម្រូវការរបស់ស្ត្រី ទស្សនៈរបស់ស្ត្រី និងភាពខ្លាំងរបស់ស្ត្រីជាភ្នាក់ងារ និងអ្នកដឹកនាំនៃការផ្លាស់ប្តូរនៅក្នុងសកម្មភាពការប្រែប្រួលអាកាសធាតុត្រូវបានគេយកចិត្តទុកដាក់។ ការបង្កើតការរៀបចំផែនការសកម្មភាព និងគណៈកម្មាធិការអនុវត្តន៍គម្រោងនៅកម្រិតអភិបាលកិច្ចមូលដ្ឋាន គួរតែបង្កើតឡើងដើម្បីផ្តល់នូវកន្លែងផ្លូវការសម្រាប់ស្ត្រីក្នុងដំណើរការអនុវត្ត។

ដ) ការចូលរួមរបស់យុវជន៖ ជំហានសំខាន់មួយនៅក្នុងទិសដៅនេះ គឺជាការចូលរួមរបស់កុមារ ក្មេងស្រីវ័យជំទង់ និងស្ត្រីវ័យក្មេងនៅក្នុងដំណើរការនេះ។ ឧទាហរណ៍ អគ្គលេខាធិការ UNFCCC បង្កើតក្រុមប្រឹក្សា YOUNGO (មណ្ឌលបោះឆ្នោតយុវជន UNFCC) រួមបញ្ចូលនូវអ្នកដឹកនាំវ័យក្មេងដែលអាចផ្តល់នូវទស្សនៈ និងដំណោះស្រាយ ដើម្បីដោះស្រាយវិបត្តិអាកាសធាតុដែលកាន់តែអាក្រក់នៅឥណ្ឌា ឧទាហរណ៍សភាកុមារនៅកម្រិតភូមិដែលត្រូវបានស្គាល់យ៉ាងទូលំទូលាយជា Bal Sabhas កំពុងទទួលបានការលើកកម្ពស់ ដែលក្នុងចំណោមក្រុមប្រឹក្សាដទៃទៀតក៏មានការផ្តោតលើការគ្រប់គ្រងការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយផងដែរ។ នៅក្នុងតំបន់ទីក្រុងផងដែរ អង្គការសង្គមស៊ីវិល ដូចជាមូលនិធិ Mahila Housing Sewa និងមជ្ឈមណ្ឌលសម្រាប់ការអប់រំបរិស្ថាន បានផ្តោតលើការចូលរួមក្មេងស្រីវ័យជំទង់ និងវ័យក្មេងនៅក្នុងការរៀបចំផែនការចូលរួមនិងវេទិកាអភិបាលកិច្ចទីក្រុង។ នៅប្រទេសជាច្រើនទៀតក្នុងតំបន់អាស៊ី កុមារនៅរៀននិងក្មេងជំទង់បានចូលរួមនៅក្នុងសកម្មភាពអាកាសធាតុជាពិសេសពាក់ព័ន្ធនឹងការដាំដើមឈើ ការគ្រប់គ្រងសំណល់ ការឃ្លាំមើលជំងឺ និងប្រសិទ្ធភាពថាមពល។

**ចំណុចពិភាក្សា**

សូមសួរអ្នកចូលរួម តើយន្តការស្ថាប័នបែបណាដែលពួកគេគិតថាសមស្របជាងសម្រាប់ប្រទេសរបស់ពួកគេ និងតើអង្គការសង្គមស៊ីវិលមានតួនាទីអ្វីខ្លះដើម្បីពង្រឹងរចនាសម្ព័ន្ធស្ថាប័នទាំងនោះ?

**គន្លឹះសម្រាប់អ្នកសម្របសម្រួល**

> រក្សាទំនាក់ទំនងជាមួយក្រសួងកិច្ចការនារី/អ្នកជំនាញការយេនឌ័រនៅក្នុងក្រុមការរៀបចំផែនការ និងធ្វើការយ៉ាងជិតស្និតជាមួយពួកគេ (វាជាផ្នែកមួយនៃបណ្តាញជាតិ) ការផ្តល់ឱ្យពួកគេនូវព័ត៌មានសារតា និងទិន្នន័យជំនួយ ឬសូម្បីករណីសិក្សាលើទំនាក់ទំនងយេនឌ័រ និង CCDRR។

> អង្គការសង្គមស៊ីវិលអាចបែងចែកវិស័យផ្សេងៗក្នុងចំណោមពួកគេដោយផ្អែកលើតំបន់ជាគោលដៅរបស់ពួកគេ និងសមត្ថភាពវិភាគ និងបង្កើតអត្ថបទគោលនយោបាយខ្លីៗ និងចែករំលែកជាមួយអ្នកជំនាញការយេនឌ័រសម្រាប់ការ

ចរចារជាមួយរដ្ឋមន្ត្រីតាមវិស័យ។

- ផ្អែកលើទំនាក់ទំនងតាមវិស័យអង្គការសង្គមស៊ីវិលអាចធ្វើការជាមួយរដ្ឋមន្ត្រីតាមវិស័យសម្រាប់ការស្រាវជ្រាវការវិភាគ និងការកសាងសមត្ថភាពស្តីពីយេនឌ័រ និង CCDRR។ ជាញឹកញាប់ រដ្ឋមន្ត្រីតាមវិស័យគឺមានធនធានច្រើនជាង និងក៏មានឱកាសសម្រាប់ការសិក្សាស្រាវជ្រាវតូចៗ។ ការធ្វើការសិក្សាបែបនេះនៅក្នុងពហុវិស័យនឹងមិនត្រឹមតែជួយធ្វើឱ្យប្រសើរឡើងនូវសមាហរណកម្មយេនឌ័រនៅក្នុងវិស័យប៉ុណ្ណោះទេប៉ុន្តែក៏ចូលរួមចំណែកដល់ការពង្រឹងការយល់ដឹងពីយេនឌ័រនៅក្នុងដំណើរការរៀបចំផែនការជាទូទៅផងដែរ។
- ចរចារសម្រាប់កន្លែងផ្លូវការមួយសម្រាប់បណ្តាញនៅក្នុងគណៈកម្មាធិការយេនឌ័រ និងអាកាសធាតុ។ ទោះបីយ៉ាងណា ត្រូវការតុល្យភាពមួយរវាងការរក្សានូវភាពនិរន្តរភាព និងភាពចម្រុះនៅកម្រិតបណ្តាញជាតិសម្រាប់ករណីនេះ។ បើសិនមានតែអង្គការសង្គមស៊ីវិលមួយធ្វើជាតំណាងគ្រប់ពេលវេលា ដូច្នេះអង្គការសង្គមស៊ីវិលផ្សេងទៀតនិងបាត់បង់នូវផលប្រយោជន៍នៅក្នុងបណ្តាញ ម្យ៉ាងទៀត ការផ្លាស់ប្តូរអ្នកតំណាងគ្រប់ពេលវេលានឹងបាត់បង់ភាពជឿជាក់របស់បណ្តាញនៅក្នុងវេទិកា។វាមានសារសំខាន់សម្រាប់បណ្តាញអង្គការសង្គមស៊ីវិលមាននូវប្រព័ន្ធមួយដើម្បីដោះស្រាយករណីនេះ។ប្រព័ន្ធដែលស្នើឡើងគួរតែអាចឱ្យមនុស្សម្នាក់ចូលរួមកិច្ចប្រជុំចំនួនពីរបន្តបន្ទាប់គ្នា បង្កើតកំណត់ត្រាលម្អិតដូចគ្នា និងប្រគល់ឱ្យទៅអ្នកបន្ទាប់។ វិធីបែបនេះ រាល់កិច្ចប្រជុំទាំងអស់ជាមួយអ្នកចូលរួម ទស្សនៈទាំងអស់ត្រូវបានរៀបចំចងក្រងទុកសម្រាប់បណ្តាញដើម្បីត្រួតពិនិត្យនៅពេលក្រោយ។ បន្ថែមពីនេះទៀត មុនពេលរាល់កិច្ចប្រជុំការធ្វើសេចក្តីសម្រេចចិត្តសំខាន់ៗនីមួយៗនៃវេទិកា សមាជិកបណ្តាញគួរមានកិច្ចប្រជុំតូចមួយរបស់ពួកគេផ្ទាល់ និងថ្លែងដោយសង្ខេបប្រាប់ទៅតំណាងអំពីកង្វល់នានា និងរបៀបវារៈដែលបណ្តាញចង់លើកឡើងនៅក្នុងកិច្ចប្រជុំនេះ។ វាកាន់តែសមរម្យក្នុងការដាក់ចំណុចនេះក្នុងកំណត់ហេតុ និងចែករំលែកច្បាប់ចម្លងនៃធាតុចូលរួមគ្នារបស់បណ្តាញជាមួយវេទិកាតាមរយៈតំណាង។
- មន្ត្រីរដ្ឋាភិបាលមូលដ្ឋានមិនភ្ជាប់អង្គការសង្គមស៊ីវិលដោយផ្ទាល់ទៅក្នុងប្រព័ន្ធរៀបចំផែនការនោះឡើយ ប្រសិនបើគ្មានការទាក់ទងស្វែងយល់គ្នាយូរអង្វែងទេ។ ដើម្បីអាចធ្វើបែបនេះទៅបាន ដំបូង សមាជិករដ្ឋាភិបាលមូលដ្ឋានគួរតែត្រូវបានគេអញ្ជើញឱ្យទៅចូលរួមក្នុងកិច្ចប្រជុំរបស់ស្ត្រីនៅសហគមន៍ (អ្នកទាំងឡាយក្រៅពីកម្រិតភូមិ) និងអន្តរកម្មដោយវិជ្ជមានរវាងមេដឹកនាំស្ត្រី និងមន្ត្រី គួរតែត្រូវបានគេជំរុញ។ ស្ត្រីក៏គួរត្រូវបានគេជំរុញឱ្យត្រៀមផែនការសកម្មភាពរបស់ពួកគេផ្ទាល់ ហើយបញ្ជូនទៅមន្ត្រីមូលដ្ឋានសម្រាប់កិច្ចសហការក្នុងការអនុវត្តផែនការ។ នៅពេលទំនាក់ទំនងស្វែងយល់គ្នាកើតឡើងហើយ អន្តរកម្មអាចបង្កើតឡើងជាផ្លូវការហើយ។

ថ) ការកសាងសមត្ថភាពការបញ្ជ្រាបយេនឌ័រនៅក្នុង CCDRR៖ សារសំខាន់នៃការកសាងសមត្ថភាពសម្រាប់ការបញ្ជ្រាបយេនឌ័រនៅក្នុង CCDRR ត្រូវបានគេទទួលស្គាល់យ៉ាងត្រឹមត្រូវ។ ទោះបីយ៉ាងណាជំនួសឱ្យកម្មវិធីការកសាងសមត្ថភាពទូទៅ វាក៏មានសារសំខាន់ផងដែរក្នុងការផ្តោតលើកិច្ចប្រឹងប្រែងកសាងសមត្ថភាព ដើម្បីឱ្យកង្វល់យេនឌ័រត្រូវបានដាក់បញ្ចូលនៅក្នុងគោលនយោបាយ និងផែនការជាតិទាំងអស់។ នៅក្នុងគម្រោងច្នៃប្រឌិតមួយបែបនេះ អង្គការ UN Women បង់ក្លាដែស និងមូលនិធិ សម្រាប់ការប្រែប្រួលអាកាសធាតុបង់ក្លាដែស ឆ្នាំ២០១៥ បានផ្តោតលើការកសាងការយល់ដឹង ចំណេះដឹង និងជំនាញសម្រាប់ជនបង្គោលទទួលបន្ទុកយេនឌ័រស្តីពី វិសាលភាពសមភាពយេនឌ័រនៃការប្រែប្រួលអាកាសធាតុ។ បច្ចុប្បន្ន កម្មវិធីវគ្គបណ្តុះបណ្តាលបែបនេះមិនទាន់មានគេដឹងថាវាមានសារសំខាន់ប៉ុណ្ណាទេក្នុងការបង្កើតការផ្លាស់ប្តូរ។ ទោះបីយ៉ាងណា ការផ្តួចផ្តើមនេះត្រូវបានស្វាគមន៍ដោយមន្ត្រីរដ្ឋាភិបាល និងបង្ហាញឱ្យឃើញនូវផ្លូវអាចទៅរួចមួយសម្រាប់កសាងជំនាញបច្ចេកទេសអំពីការបញ្ជ្រាបយេនឌ័រនៅក្នុងក្រសួងនានារបស់រដ្ឋាភិបាល (UN Women, 2016)។ កិច្ចប្រឹងប្រែងស្រដៀងគ្នា នឹងត្រូវការឱ្យគេកំណត់គោលដៅនៅពហុកម្រិតជាមួយវគ្គបណ្តុះបណ្តាលជាក់លាក់ដូចបានលើកចែករំលែកនៅក្នុងកិច្ចប្រជុំ។

ការផ្លាស់ប្តូរកម្រិតនិងភាគីពាក់ព័ន្ធចម្រុះខុសៗគ្នាអាចជូនដំណឹងដល់ទាំងការបង្កើត និងការអនុវត្តគោលនយោបាយយេនឌ័រ។ ឧទាហរណ៍ វេទិកា DRR ប្រចាំឆ្នាំទទួលការគាំទ្រពីយុទ្ធសាស្ត្រអន្តរជាតិអង្គការសហប្រជាជាតិសម្រាប់ការកាត់បន្ថយគ្រោះមហន្តរាយ (UNISDR) អាចសម្របសម្រួលការធ្វើសមាហរណកម្មសមភាពយេនឌ័រទៅក្នុងគោលនយោបាយនិងការអនុវត្តDRR ដោយការអញ្ជើញអង្គការស្ត្រី និងអង្គការសង្គមស៊ីវិល ដើម្បីចែករំលែកនូវបទពិសោធន៍ និងខ្លឹមសារគោលនយោបាយរបស់ពួកគេ។ វេទិកាស្រដៀងគ្នាផ្សេងៗអាចបង្កើតឡើងសម្រាប់ការបន្សាំនឹងការប្រែប្រួលអាកាសធាតុដូចជា GCCA នៅកម្ពុជា ក៏អាចប្រើសម្រាប់ការបញ្ជ្រាបយេនឌ័រនៅក្នុងគោលនយោបាយការប្រែប្រួលអាកាសធាតុ និងផែនការបន្សាំថ្នាក់ជាតិផងដែរ។

## សមាហរណកម្មយេនឌ័រនៅក្នុងផែនការបន្សាំជាតិ(NAPs)[១]

ដំណើរការ UNFCCC NAP គឺជាយន្តការសំខាន់សម្រាប់ការកំណត់អាទិភាពនិងសកម្មភាពការបន្សាំនឹងការប្រែប្រួលអាកាសធាតុ ការកំណត់ឡើងវិញនូវការរៀបចំផែនការអភិវឌ្ឍន៍ទូទៅ និងការបញ្ជូនធនធាននានាសម្រាប់ភាពធន់ និងការអភិវឌ្ឍដោយនិរន្តរភាព។ ដូច្នេះ ការបង្កើតដំណើរការ NAP មិនត្រឹមតែផ្ដល់នូវឱកាសដើម្បីបញ្ចូលនូវកង្វល់យេនឌ័រនៅក្នុងអាទិភាពបន្សាំ ប៉ុន្តែក៏មាននៅក្នុងការរៀបចំផែនការអភិវឌ្ឍន៍ទូទៅ និងតាមវិស័យផងដែរ។ វាក៏អាចជាយុទ្ធសាស្ត្រសំខាន់មួយ ដើម្បីដោះស្រាយវិសមភាពយេនឌ័រនៅក្នុងប្រទេសមួយដែរ (Dekens និង Daze ឆ្នាំ២០១៩, បណ្ដាញពិភពលោក NAP និង UNFCCC ឆ្នាំ២០១៩)។ ហេតុនេះ ផ្នែកនេះ គូសបញ្ជាក់ចំណុចចាប់ផ្ដើមយេនឌ័រសំខាន់សម្រាប់ភ្ជាប់នឹងដំណើរការ NAP។ វាត្រូវការកត់សម្គាល់តាមរយៈនេះ ប៉ុន្តែ ខណៈដែរ NAP ជាឯកសារផែនការមួយ ចំណុចផ្ដើម អាចត្រូវបានយកទៅប្រើឱ្យបានសមស្របទៅក្នុងដំណើរការរៀបចំផែនការជាតិ និងក្រោមជាតិទាំងអស់។

### ជំហានទី១៖ ដំណាក់កាលរៀបចំ និងសម្ពោធ NAP

ការពិចារណាលើយេនឌ័រគួរនៅកណ្ដាលនៃដំណើរការ NAP ចាប់ពីដើមដំបូង និងផ្ដោតលើនិរន្តរភាពតាមរយៈ

ក) ការប្រើគណៈកម្មាធិការអន្តរជាតិ និងច្បាប់ និងគោលនយោបាយក្នុងស្រុកស្ដីពីការពង្រឹងសមភាពយេនឌ័រដែនសមត្ថកិច្ចសម្រាប់ការឆ្លើយតបយេនឌ័រNAPនិងបង្កើតគណៈកម្មាធិការនយោបាយកម្រិតខ្ពស់ដូចគ្នា។

ខ) កំណត់អ្នកតស៊ូមតិសមភាពយេនឌ័រនិងចងពួកគេជាសម្ព័ន្ធមិត្ត ការបញ្ចូលពួកគេនៅក្នុងដំណើរការ NAP និងការផ្ដល់នូវឱកាសសម្រាប់ពួកគេដើម្បីចែករំលែកទស្សនៈរបស់ពួកគេ។

គ) បញ្ចូលបញ្ហាយេនឌ័រនៅក្នុងឯកសារយុទ្ធសាស្ត្រ ដែលត្រូវបង្កើតឡើងដើម្បីណែនាំពីដំណើរការដូចជាផែនទីបង្ហាញផ្លូវ NAP និង/ឬ ក្របខ័ណ្ឌការងារ NAP។

ឃ) បង្កើតក្រុមសមភាពយេនឌ័រ ដើម្បីសម្របសម្រួលដំណើរការ NAP។

អង្គការសង្គមស៊ីវិល គួរតែរក្សាទំនាក់ទំនងជាប់លាប់ជាមួយជនបង្គោលផ្នែកយេនឌ័រ និងការប្រែប្រួលអាកាសធាតុជាតិ។ ពេលណា NAP ឬ NDC កំពុងត្រូវបានគេពិនិត្យមើល ឬធ្វើបច្ចុប្បន្នពួកគេគួរតែបញ្ចុះបញ្ចូលឱ្យដាក់ចូលជាផ្នែកមួយនៃដំណើរការពិគ្រោះយោបល់។

ត្រួតពិនិត្យមើលគោលនយោបាយ និងយុទ្ធសាស្ត្រយេនឌ័រ និងការប្រែប្រួលអាកាសធាតុជាតិទាំងអស់រួមមានccGAPsដែលត្រូវបានបង្កើតរួចហើយ និងធ្វើបច្ចុប្បន្នភាពស្របនឹងទំនាក់ទំនងថ្មីយន្តការ និងហិរញ្ញវត្ថុរបស់ UNFCCC ។

### ជំហានទី២៖ ការវិភាគស្ថានភាព (ការពិនិត្យមើល និងការវាយតម្លៃ )

ការពិនិត្យមើល និងការវាយតម្លៃ គឺជាផ្នែកមូលដ្ឋាននៃការបង្កើតយុទ្ធសាស្ត្រនិងការដាក់បញ្ចូលការកំណត់អត្តសញ្ញាណបញ្ហា តម្រូវការ និងសក្ដានុពលភាព ដែលតាមរយៈនោះ ផែនការបន្សាំអាចត្រូវបានផ្អែកលើនិងជួយសម្រួលដល់ការអនុម័តលើការសម្រេចចិត្ត។ វាក៏ជាឱកាសមួយក្នុងការធានាឱ្យបានថាដំណើរការផែនការបន្សាំជាតិ បង្កើតឡើងដោយផ្អែកលើព័ត៌មានចំណេះដឹងនិងសមត្ថភាពមានស្រាប់ដែលពាក់ព័ន្ធនឹងយេនឌ័រ។

ក) អនុវត្តការរំលឹកទ្រឹស្ដីដំបូងស្ដីពីយេនឌ័រ និងការប្រែប្រួលអាកាសធាតុនៅក្នុងប្រទេស ដោយពិនិត្យលើការវិភាគយេនឌ័រទិន្នន័យបែងចែកតាមភេទនិងការធ្វើបាយការណ៍តាមផ្នែកផ្សេងៗទៀតដែលពាក់ព័ន្ធដូចជាគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព។

ខ) វិភាគព័ត៌មានដែលអាចរកបានស្ដីពីឌីណាមិកយេនឌ័រ និងភាពខុសគ្នា នៃផលប៉ះពាល់ទាក់ទងនឹងអាកាសធាតុ ភាពងាយរងគ្រោះ និងសមត្ថភាព ព្រមទាំងកំណត់ផ្នែកនៃចំណុចខ្វះខាតនៃព័ត៌មាន។

គ) អនុវត្តការវាយតម្លៃភាពងាយរងគ្រោះដែលមានទស្សនៈយេនឌ័រដើម្បីបំពេញក្នុងចំណុចខ្វះខាតនៃព័ត៌មានជាពិសេសការវិភាគអំពីបញ្ហាជាមូលដ្ឋានដែលធ្វើឱ្យមនុស្សមួយចំនួនងាយរងគ្រោះជាងអ្នកផ្សេង។

ឃ) វាយតម្លៃអំពីរបៀបដែលការពិចារណាលើយេនឌ័រត្រូវបានដាក់បញ្ចូលទៅក្នុងសកម្មភាពបន្សាំមានស្រាប់ និងកាលពីអតីតកាលប្រកបដោយប្រសិទ្ធភាព និងការកំណត់អត្តសញ្ញាណបច្ចេកវិទ្យាឆ្លើយតបនឹងយេនឌ័រ និងដំណោះស្រាយបន្សាំ។

ង) សម្របសម្រួលដំណើរការចូលរួមពីភាគីពាក់ព័ន្ធដែលមានការរួមបញ្ចូល និងមានសមធម៌យេនឌ័រ ដោយឱ្យមានការចូលរួមពីស្ត្រីនិងបុរសរាប់បញ្ចូលទាំងតំណាងមកពីក្រុមជួបការលំបាក ក្នុងការប៉ាន់ប្រម៉ាណភាពងាយរងគ្រោះខាងអាកាសធាតុនិងការកំណត់ជម្រើសនៃការបន្សាំ។

ច) កំណត់ជម្រើសនៃការបន្សាំដែលបានដៅទុកសម្រាប់ស្ត្រីនិងបុរស និងក្រុមជួបការលំបាក ស្របតាមភាពងាយរងគ្រោះ និងសមត្ថភាពរបស់ពួកគេ ដោយគិតលើតួនាទីនិងការទទួលខុសត្រូវដែលអាចទទួលយកបានក្នុងសង្គម។

ធាតុចូលសំខាន់មួយដែលបានមកពីអង្គការសង្គមស៊ីវិល នៅក្នុងផែនការជាតិបន្សាំនិងដំណើរការចូលរួមចំណែករបស់ជាតិអាចត្រូវបានធ្វើឡើង ដោយការប្រើការវាយតម្លៃភាពងាយរងគ្រោះដែលមានទស្សនៈយេនឌ័រ ការសិក្សាអំពីយេនឌ័រដាក់លាក់តាមវិស័យ។ ជាពិសេសការធ្វើផែនទីឌីណាមិកអំណាចយេនឌ័រពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុនិងការប្រើធនធានក្នុងវិស័យដែលគេពុំទាន់រកឃើញ។ ព័ត៌មានអំពីយេនឌ័រ និងការ

ប្រើប្រាស់ធនធានសម្រាប់វិស័យជាច្រើន ដូចជា កសិកម្ម រុក្ខាប្រមាញ់ ទឹក សុខាភិបាល ជីវឧស្ម័ន។ល។ គឺអាចរកបាន។ ទោះបីយ៉ាងណាមានវិស័យជាក់លាក់មួយចំនួនដែលក្នុងនោះឌីណាមិកអំណាចយេនឌ័រមិនទាន់ត្រូវបានគេរកឃើញពេញលេញនៅឡើយ។វិស័យទាំងនេះរួមមានវិស័យបញ្ហាបមានដូចជា ការដឹកជញ្ជូន នគរូបនីយកម្ម ការគ្រប់គ្រងកាកសំណល់ ថាមពលកកើតឡើងវិញ។ល។ ដែលមានទំនាក់ទំនងខ្លាំងទៅនឹងការប្រែប្រួលអាកាសធាតុ បន្តែ ឌីណាមិកយេនឌ័រមិនត្រូវបានគេស្រាវជ្រាវ។ការយកវិស័យទាំងនេះដាក់ជាអាទិភាពបង្កើតបានជាចំណុចចាប់ផ្តើមមួយស្តីពីយេនឌ័រ និងការប្រែប្រួលអាកាសធាតុ និងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ។ បើទោះបីជាវិស័យស្មុលទាក់ទងនឹងយេនឌ័រ ដូចជា សុខភាពផ្លូវភេទ និងបន្តពូជអំពើហិង្សាផ្អែកលើយេនឌ័រនិងទំនាក់ទំនងរវាងវិស័យទាំងនោះ ជាមួយការប្រែប្រួលអាកាសធាតុមិនត្រូវបានស្រាវជ្រាវឱ្យបានល្អនៅឡើយ។

## ការរៀបចំផែនការបន្សាំជាក់លាក់តាមវិស័យ

ប្រសិនបើប្រទេសរបស់អ្នកកំពុងប្រើវិធីសាស្ត្រផ្អែកតាមវិស័យ ដើម្បីវិភាគការរៀបចំផែនការបន្សាំនៃបញ្ហាយេនឌ័រជាក់លាក់តាមវិស័យនិងផលវិបាកសម្រាប់ការបន្សាំក្នុងវិស័យនិងកំណត់ជម្រើសបន្សាំជាក់លាក់តាមយេនឌ័រ ក្នុងវិស័យនានាតាមដែលសមស្របវាមានសារៈសំខាន់ជាពិសេសក្នុងការពិនិត្យមើលលើវិសាលភាពសម្រាប់យុទ្ធសាស្ត្រយេនឌ័រដែលមានទស្សនៈផ្លាស់ប្តូរក្នុងវិស័យនីមួយៗ។

ឧទាហរណ៍ដ៏គួរឱ្យកត់សម្គាល់មួយ គឺមូលនិធិជំនួយឥតសំណងពហុភាគីសម្រាប់អាចេ (Aceh) និងនីអាស (Nias)។ មូលនិធិជំនួយឥតសំណងពហុភាគីធ្លាប់ជាដៃគូរវាងសហគមន៍អន្តរជាតិពោលគឺរដ្ឋាភិបាលនៃប្រទេសឥណ្ឌូណេស៊ីនិងសង្គមស៊ីវិលសម្រាប់គាំទ្រកិច្ចខិតខំប្រឹងប្រែងស្តារឡើងវិញនៅអាចេ និងនីអាស បន្ទាប់ពីគ្រោះរញ្ជួយដី និងរលកយក្សស៊ូណាមិនៅឆ្នាំ២០០៤។ការផ្តល់ភាពអង់អាចដល់ស្ត្រីត្រូវបានដាក់បញ្ចូលទៅក្នុងគម្រោងស្តារសហគមន៍របស់មូលនិធិជំនួយឥតសំណងពហុភាគី។ កិច្ចខិតខំប្រឹងប្រែងក្នុងការសាកល្បងគម្រោង មិនត្រឹមតែបង្កើនការចូលរួមរបស់ស្ត្រីនៅក្នុងសកម្មភាពរៀបចំផែនការសហគមន៍ និងស្វែងរកវិធីដើម្បីធានាថា សម្លេងរបស់ស្ត្រីត្រូវបានគេឮប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងផ្តល់ឱកាសក្នុងការដោះស្រាយវិសមភាពយេនឌ័រនិងវិសមភាពផ្សេងទៀតនៅក្នុងសង្គម។ សកម្មភាពសាកល្បង រួមបញ្ចូលទាំង ការលើកកម្ពស់ការផ្តល់ភាពអង់អាចដល់ស្ត្រីតាមរយៈការលៃថវិកាដោយឡែកសម្រាប់សកម្មភាពដែលស្ត្រីបានជ្រើសរើស។ គម្រោងជាច្រើនក៏បានគាំទ្រការផ្តល់ភាពអង់អាចដល់ស្ត្រី តាមរយៈការផ្តល់ឱកាសមីក្រូហិរញ្ញវត្ថុជាពិសេសសម្រាប់ស្ត្រី។ ពួកគេដើរតួនាទីដ៏សំខាន់មួយក្នុងការលើកកម្ពស់ការយល់ដឹងអំពីសិទ្ធិកាន់កាប់ដីរបស់ស្ត្រី និងតាមរយៈការគាំទ្រការចេញប័ណ្ណកម្មសិទ្ធិរួមគ្នា។ ជិត ៣០% នៃប័ណ្ណកម្មសិទ្ធិដែលចេញក្រោមគម្រោង គឺជាប័ណ្ណកម្មសិទ្ធិរួម ឬមានដាក់ឈ្មោះស្ត្រី។ គម្រោងបានជំរុញលទ្ធភាពទទួលបានការងាររបស់ស្ត្រីនៅក្នុងការងារកសាងឡើងវិញ និងបានបង្កើតឱ្យមានឱកាសសម្រាប់ការចូលរួមរបស់ស្ត្រីនៅក្នុងទីផ្សារការងារនៅតាមតំបន់ ដែលមិនប្រកាន់ខ្ជាប់ប្រពៃណី ដូចជាការងារសំណង់។ ស្ត្រីបានទទួលប្រយោជន៍ពីការប្រកបរបរចិញ្ចឹមជីវិតពីមូលនិធិជំនួយឥតសំណងពហុភាគីនៅក្នុងតួនាទីរបស់ពួកគេជាកសិករ ពាណិជ្ជកម្ម និងសហគ្រិន និងពីការកសាងសមត្ថភាព ព្រមទាំងការបណ្តុះបណ្តាលនៅគ្រប់កម្រិតនៃវិស័យ។ គម្រោងទាំងនេះផ្តល់ម៉ូដែលដ៏គួរឱ្យចាប់អារម្មណ៍មួយអំពីរបៀបដែលវិសមភាពនៃការចូលរួមក្នុងកម្លាំងពលកម្មកាន់តែច្រើន អាចត្រូវបានជំរុញតាមរយៈកម្មវិធីការងារកសាងឡើងវិញ ដូចជា មូលនិធិជំនួយឥតសំណងពហុភាគី។ មេរៀនដែលបានមកពីការធ្វើសមាហរណកម្មយេនឌ័រទៅក្នុងគម្រោងជំរុញសហគមន៍ និងកម្មវិធីត្រៀមបង្ការទប់ទល់នឹងគ្រោះមហន្តរាយនៅអាចេ និងនីអាស ដាក់បញ្ចូលទៅក្នុងកម្មវិធីជាតិសម្រាប់ការសិទ្ធិអំណាចដល់សហគមន៍ និងការរៀបចំកម្មវិធីផ្សេងទៀតនៅអាចេ និងនីអាស និងនៅទូទាំងប្រទេសឥណ្ឌូណេស៊ី (មូលនិធិជំនួយឥតសំណងពហុភាគី ឆ្នាំ២០១២)។ ឧទាហរណ៍មួយផ្សេងទៀតគឺមកពីតំបន់អឺរ៉ុបអាស៊ី (Eurasia)។ បន្ទាប់ពីគ្រោះទឹកជំនន់នៅប្រទេសបូស្នី និងហឺសេហ្គោវីន និងប្រទេសស៊ែបនៅខែឧសភា ឆ្នាំ២០១៤ អង្គការ UNDP បានដាក់បញ្ចូលបញ្ហាយេនឌ័រទៅក្នុងកម្មវិធីស្តារគ្រោះទឹកជំនន់របស់ខ្លួន។ នៅប្រទេសបូស្នី និងហឺសេហ្គោវីន អង្គការ UNDP បានផ្តល់អាទិភាពលើការស្តារនីតិសម្បទាគ្រួសារដែលមានមេគ្រួសារជាស្ត្រីនិងធានាឱ្យបានថាស្ត្រីបានទទួលអត្ថប្រយោជន៍ពីការងារដែលបានប្រាក់ឈ្នួល និងកម្មវិធីទាក់ទងនឹងការងារ។ ស្ថាប័នសាធារណៈសរុបចំនួន ១៣២ ត្រូវបានរៀបចំបង្កើតឡើងវិញដោយបានទទួលការងារសាធារណៈមួយចំនួនធំដែលត្រូវបានកាន់កាប់ភាគច្រើនដោយស្ត្រី។ នៅប្រទេសស៊ែប អង្គការ UNDP បានដាក់បញ្ចូលសមាសភាគយេនឌ័រដ៏រឹងមាំមួយក្នុងលក្ខខណ្ឌវិនិច្ឆ័យជ្រើសរើសសម្រាប់កម្មវិធីបង្កើតការងារ ដោយពង្រីកលទ្ធភាពទទួលបានការប្រកបរបរចិញ្ចឹមជីវិតប្រកបដោយសុវត្ថិភាព និងផលិតភាព។ មួយភាគបីនៃការងារទាំងអស់ដែលបានបង្កើត ត្រូវបានបំពេញដោយស្ត្រី (អង្គការ UNDP ឆ្នាំ២០១៧)។

## ជំហានទី ៣៖ ការវាយតម្លៃផែនការបន្សាំ

នៅពេលជម្រើសនៃការបន្សាំត្រូវបានកំណត់ជាធម្មតាវាមានដំណើរការនៃការផ្តល់អាទិភាពចាំបាច់ដើម្បីកំណត់សកម្មភាពណាមួយដែលជាធនធានចាំបាច់ និងបន្ទាន់បំផុតសម្រាប់ការ

អនុវត្ត។ ដោយពិចារណាលើភាពឆ្លើយតបនៃយេនឌ័រថាជាលក្ខខណ្ឌតម្រូវមួយក្នុងដំណើរការផ្តល់អាទិភាពហើយសកម្មភាពនោះនឹងជួយបង្កើតផែនការដែលឆ្លើយតបទៅនឹងតម្រូវការរបស់ស្ត្រី បុរស និងមនុស្សដែលមានអត្តសញ្ញាណយេនឌ័រផ្សេងទៀត ហើយថាការអនុវត្តសកម្មភាពអាទិភាពនឹងផ្តល់នូវអត្ថប្រយោជន៍ប្រកបដោយសមធម៌។

ក) អនុវត្តវិធីសាស្ត្រដែលមានការចូលរួម និងប្រកបដោយបរិយាប័ន្ន ដើម្បីផ្តល់អាទិភាពលើសកម្មភាពបន្សាំសម្រាប់ការអនុវត្ត (ឧទាហរណ៍ តាមរយៈការរៀបចំសិក្ខាសាលាភាគីពាក់ព័ន្ធសម្រាប់ក្រុមផ្សេងគ្នា និង/ឬផ្នែកផ្សេងៗនៃប្រទេស)។
ខ) សម្របសម្រួលដំណើរការផ្តល់អាទិភាពដាច់ដោយឡែកសម្រាប់ក្រុមមនុស្សដែលមានយេនឌ័រ និងក្រុមមនុស្សផ្សេងគ្នា (ឧទាហរណ៍ តាមរយៈការពិភាក្សាស្របគ្នាក្នុងអំឡុងសិក្ខាសាលាភាគីពាក់ព័ន្ធ)។
គ) ធានាឱ្យមានតម្លាភាពនៅក្នុងដំណើរការផ្តល់អាទិភាពតាមរយៈការរៀបចំឯកសារអំពីរបៀបដែលអាទិភាពត្រូវបានកំណត់និងអ្នកណាខ្លះដែលបានចូលរួមនៅក្នុងដំណើរការ។
ឃ) ឱ្យស្ត្រី និងបុរសចូលរួម រាប់បញ្ចូលទាំងតំណាងក្រុមជួបការលំបាកនៅក្នុងការបង្កើតលក្ខខណ្ឌសម្រាប់ការផ្តល់អាទិភាពនៅកម្រិតផ្សេងគ្នា។
ង) ប្រើ "ការរួមចំណែកចំពោះសមភាពយេនឌ័រ" ថាជាលក្ខខណ្ឌតម្រូវមួយសម្រាប់ការផ្តល់អាទិភាព ដោយផ្សារភ្ជាប់ទៅនឹងលទ្ធផលនៃការវិភាគយេនឌ័រនិងការប៉ាន់ប្រម៉ាណវិសាលភាពដែលជម្រើសនៃការបន្សាំឆ្លើយតបទៅនឹងវិសមភាពយេនឌ័រ។

សម្របសម្រួលសិក្ខាសាលាពិគ្រោះយោបល់ជាមួយមេដឹកនាំជាស្ត្រីនៅក្នុងសហគមន៍ ជាពិសេសអ្នកដែលមកពីក្រុមងាយរងគ្រោះ។ អង្គការសង្គមស៊ីវិលគួរដឹកនាំក្នុងការរៀបចំឱ្យមានមេដឹកនាំ និងក្រុមជាស្ត្រី ដើម្បីបង្ហាញពីកង្វល់របស់ពួកគេ និងតម្រូវការនានានៅមុនពេលចាប់ផ្តើមសិក្ខាសាលានោះ។

**ជំហានទី ៤៖ ការចងក្រង និងការទំនាក់ទំនង**

ឯកសារការរៀបចំផែនការត្រូវបានបង្កើតឡើងតាមរយៈបញ្ហាបន្សាំនៃក្របខ័ណ្ឌដំណើរការផែនការបន្សាំ ជាតិ និងឯកសារអំពីជម្រើសអាទិភាព និងវិធីសាស្ត្រដែលនឹងត្រូវបន្ត ដើម្បីពន្លឿនគោលដៅបន្សាំនៅក្នុងប្រទេស។ ហេតុនេះ វាមានសារៈសំខាន់ដែលថា បញ្ហាយេនឌ័រត្រូវបានដាក់បញ្ចូលនៅគ្រប់ឯកសារការរៀបចំផែនការបន្សាំ។ហេតុដូច្នេះនៅពេលចងក្រងអត្ថបទស្តីពីផែនការបន្សាំនៅថ្នាក់ជាតិត្រូវ៖

ក) ធានាថា ផ្នែកនីមួយៗមានទស្សនវិស័យយេនឌ័រ
ខ) ប៉ាន់ប្រម៉ានថាតើយុទ្ធសាស្ត្រ និងសកម្មភាពដែលបានស្នើឡើងទាំងអស់ លើកកម្ពស់សមភាពយេនឌ័រ ឬធ្វើឱ្យចំណុចខ្វះខាតយេនឌ័រដែលកំពុងកើតមានកាន់តែយ៉ាប់យឺនថែមទៀត។
គ) ប្រើប្រាស់ទិន្នន័យបែងចែកតាមភេទសម្រាប់គ្រប់ការវិភាគ។
ឃ) ប្រើភាសាឆ្លើយតបនឹងយេនឌ័រ និងវាក្យស័ព្ទដូចជា "ស្ត្រី" "បុរស" "កុមារី" និង "កុមារា" នាំពួកគេឱ្យឈានមុនគេ និងបង្ហារភាពខុសគ្នាដ៏គួរឱ្យកត់សម្គាល់ខ្លាំងបើគិតទៅលើឱកាស សិទ្ធិ និងកាតព្វកិច្ច ដោយផ្អែកលើយេនឌ័រ និងអាយុដែលមិនត្រូវបានគេអើពើ។
ង) ធ្វើការយោងទៅលើរដ្ឋធម្មនុញ្ញជាតិ ថាតើសមភាពយេនឌ័រត្រូវបានដាក់បញ្ចូលទៅក្នុង"ច្បាប់ស្តីពីការប្រព្រឹត្តចំពោះដោយស្មើភាព/ការមិនរើសអើង" និងគោលនយោបាយថ្នាក់ជាតិស្តីពីសមភាពយេនឌ័រ រួមបញ្ចូលទាំងសកម្មភាពអតីតកាលនិងកំពុងបន្ត។ វាក៏មានសារៈសំខាន់ផងដែរក្នុងការលើកឡើងអំពីការប្តេជ្ញាចិត្តជាអន្តរជាតិ ដែលត្រូវអនុវត្តដោយប្រទេសនៅក្រោម អនុសញ្ញា CEDAW សេចក្តីប្រកាសទីក្រុងប៉េកាំងនិងវេទិកាដើម្បីសកម្មភាពនិងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព។
ច) ផ្តោតលើការពិតដែលថា យេនឌ័រគឺជាបញ្ហាឆ្លងវិស័យ ហើយថាយេនឌ័រនាំមកនូវការបង្កើនឱ្យមានប្រសិទ្ធផល ប្រសិទ្ធភាព និងចីរភាពនៃការប្រែប្រួលអាកាសធាតុ និងកិច្ចខិតខំប្រឹងប្រែងអភិវឌ្ឍន៍ប្រកបដោយចីរភាពផ្សេងទៀត។បន្ថែមពីលើនេះ វាក៏បញ្ជាក់ថា គោលដៅនៃការបញ្ជ្រាបយេនឌ័រ គឺដើម្បីផ្តល់ភាពអង់អាចដល់ស្ត្រី និងកាត់បន្ថយវិសមភាពដែលកំពុងកើតមាន។

ខណៈពេលដែលអង្គការសង្គមស៊ីវិល ក៏អាចរួមចំណែកក្នុងការបញ្ចប់/ការសរសេរឯកសារ ដែលកន្លែងទំនេរបែបនេះមិនមានសូមប្រើបញ្ជីត្រួតពិនិត្យផែនការជាតិបន្សាំ/ការរួមចំណែករបស់ជាតិ (សំណៅឯកសារទី៩)
ដើម្បីធ្វើការឯកសារវិភាគលើយេនឌ័រ និងចែករំលែកយ៉ាងទូលំទូលាយសម្រាប់ការ

**ចំណុចពិភាក្សា**

ស្នើអ្នកចូលរួមឱ្យសង្ខេបអំពីចំណុចចាប់ផ្តើម/ច្រកចូលនៃយេនឌ័រជាក់លាក់ នៅក្នុងដំណើរការផែនការបន្សុំាថ្នាក់ជាតិ ដែលអង្គការសង្គមស៊ីវិលអាចចូលរួមក្នុងដំណើរការនោះ។ ប្រើរូបនេះដោយយកចេញ ពី weADAP ( Dazé និង Dekens ឆ្នាំ២០១៧ ) ដើម្បីពិភាក្សាលើចំណុចដូចគ្នានេះ។

តម្រុយសម្រាប់អ្នកសម្របសម្រួល

**រូបទី១៧៖ ដំណើរការផែនការបន្សុំាថ្នាក់ជាតិឆ្លើយតបនឹងយេនឌ័រ**




ប្រភព៖ weADAP ( Dazé និង Dekens ឆ្នាំ២០១៧ )

## ផែនការសកម្មភាពការប្រែប្រួលអាកាសធាតុ និងយេនឌ័រ

ផែនការសកម្មភាពការប្រែប្រួលអាកាសធាតុនិងយេនឌ័រដែលត្រូវបានបង្កើតឡើងដោយសហភាពអន្តរជាតិដើម្បីការអភិរក្សធម្មជាតិ ដែលជាផ្នែកមួយនៃកម្មវិធីសម្ព័ន្ធយេនឌ័រ និងអាកាសធាតុសកលបង្ហាញផ្លូវទៅកាន់ការបញ្ជ្រាបយេនឌ័រដែលងាកចេញពីវិធីសាស្ត្រអនុវត្តតាមធម្មតា តាមរយៈការកសាងសមត្ថភាពនៅទូទាំងក្រុមភាគីពាក់ព័ន្ធ ដើម្បីបង្កើតឱ្យមានដំណោះស្រាយសមស្របថ្នាក់ជាតិ ដែលរឹងមាំ អាចអនុវត្តបាន និងមានលក្ខណៈច្នៃប្រឌិត។ វិធីសាស្ត្រផែនការសកម្មភាពការប្រែប្រួលអាកាសធាតុនិងយេនឌ័រផ្តល់ឱកាសមួយដែលផ្លាស់ប្តូរហួសពីការកំណត់ស្ត្រីថាជាជនរងគ្រោះដែលងាយរងគ្រោះនិងផ្ទុយទៅវិញទទួលស្គាល់សមភាពយេនឌ័រថាជាកត្តាជំរុញដែលនាំឱ្យមានការផ្លាស់ប្តូរ។ ជំហានសំខាន់ៗនៃវិធីសាស្ត្រផែនការសកម្មភាពការប្រែប្រួលអាកាសធាតុ និងយេនឌ័រ រួមមាន៖

ក) ការស្វែងយល់អំពីកាលៈទេសៈនយោបាយ អភិបាលកិច្ចសង្គមសេដ្ឋកិច្ច និងបរិស្ថាន៖
ផែនការសកម្មភាពការប្រែប្រួលអាកាសធាតុ និងយេនឌ័រ គឺជាលទ្ធផលនៃធាតុចូលមួយចំនួនដូចជាការស្រាវជ្រាវតាមនៅកន្លែងការងារ ការសម្ភាសជាមួយអ្នកបង្កើតគោលនយោបាយ ការពិគ្រោះជាមួយភាគីពាក់ព័ន្ធ និងការពិនិត្យឡើងវិញ ពីសំណាក់មិត្តភ័ក្ត និងក្នុងចំណោមអ្នកផ្សេងទៀត។ ការផ្តោតការយកចិត្តទុកដាក់គឺទៅលើការកំណត់វិស័យសំខាន់ៗ រួម

## រូបទី១៨៖ លក្ខណៈ: ccGAP

The underlying principle of CCGAPs is the transformative nature of gender interventions. To achieve this the process is based on **seven principles** which IUCN recognizes as the "I's" necessary for, and enhancing successful CCGAP implementation.

### The Seven Principles Necessary for Successful CCGAP Implementation:

**Inclusive**
by ensuring the participation and voices of all groups, irrespective of caste, ethnicity, religion, gender, region, age, or class.

**Innovative**
in their purpose and process for reaching beyond ordinary/traditional solutions and finding new and inspiring tools and techniques while expanding capabilities for a stronger more comprehensive approach to climate change.

Set to **Improve**
the quality of life for women and men in regards to both their basic (e.g. water) and strategic (e.g. land tenure or political participation) needs, but also by recognizing gender-differentiated priorities, roles, and knowledge useful in responding to climate change.

Creating an **Impact**
on the overall goal of climate change response by reducing anthropogenic emissions and providing adaptive resilience opportunities for both women and men to engage at local, regional, and national levels.

Championing Strategies to **Increase**
sustainable development and climate change outcomes by ensuring nature-based solutions are within the limitations of the planet, and more importantly do not exceed local and regional natural resources.

**Inciting**
transformational change, by rearranging how climate change needs to be approached. Providing equal opportunities for women and men to champion the solutions, but also providing the necessary means to build the capacity and capability to secure lives and livelihoods that are equitable for all.

**Inspiring**
actors at all levels to push beyond 'business as usual,' demonstrating that implementing gender and climate change commitments are possible.

ប្រភព៖ (Aguilar ផ្សេងទៀត ឆ្នាំ២០១៥)

មានតែមិនកំហិតត្រឹម ទឹក កសិកម្ម សុខភាព ការកាត់បន្ថយ (រួមមាន ថាមពល និងព្រៃឈើ) ការកាត់បន្ថយហានិភ័យ ហេដ្ឋារចនាសម្ព័ន្ធ ទេសចរណ៍ និងការគ្រប់គ្រងតំបន់ឆ្នេរ។

ខ) ការកសាងសមត្ថភាពលើទិដ្ឋភាពដែលបានដៅទុក គឺជាចំណុចសំខាន់ក្នុងការធានាឱ្យមានការចូលរួមដ៏រឹងមាំនិងភាពជាម្ចាស់កម្មសិទ្ធិ៖
ផ្នែកផ្តោតការយកចិត្តទុកដាក់ចម្បងមួយគឺការកសាងសមត្ថភាពស្ត្រី និងអង្គការរបស់ស្ត្រី ព្រមទាំងស្ថាប័ន និងក្រសួងពាក់ព័ន្ធបរិស្ថាន និងការប្រែប្រួលអាកាសធាតុ លើទំនាក់ទំនងរវាងយេនឌ័រ និងការប្រែប្រួលអាកាសធាតុ។ កិច្ចការនេះត្រូវសម្រេចបានតាមរយៈសិក្ខាសាលាជាច្រើនជាមួយស្ត្រីដែលត្រូវកំណត់ថាជាមេដឹកនាំនៅក្នុងសហគមន៍របស់ពួកគេក៏ដូចជាអង្គភាពតស៊ូមតិរបស់ស្ត្រី ដែលគាំទ្រលើសិទ្ធិ និងការអភិវឌ្ឍរបស់ពួកគេ។

គ) ការសម្របសម្រួលដំណើរការចូលរួមប្រកបដោយអត្ថន័យ និងមានភាគីពាក់ព័ន្ធចម្រុះ៖
ដំណើរការគឺត្រូវតែមានភាគីពាក់ព័ន្ធចម្រុះ និងវិស័យចម្រុះតែមួយគត់ ជាញឹកញាប់តំណាងឱ្យលើកដំបូង នៅពេលដែលបុគ្គលិកបច្ចេកទេសនៃក្រសួងផ្សេងៗគ្នាដូចជាពីនាយកដ្ឋានទឹក ថាមពល ឬកិច្ចការនារី មានឱកាសក្នុងការកសាងសមត្ថភាពទៅវិញទៅមកលើបញ្ហាសំខាន់ៗ ពាក់ព័ន្ធនឹងយេនឌ័រ និងការប្រែប្រួលអាកាសធាតុ។ ការចូលរួមរបស់ម្ចាស់ជំនួយ និងភាគីពាក់ព័ន្ធជាច្រើនក៏ជាបញ្ហាចម្បង ជាពិសេសអង្គការ និងបណ្តាញរបស់ស្ត្រី ទាំងបទពិសោធន៍បច្ចុប្បន្ន ទាំងបទពិសោធន៍ថ្មីចំពោះ "ការប្រែប្រួលអាកាសធាតុ" ដោយសារវាបានរួមចំណែកជាបទពិសោធន៍ និងជំនាញជាក់ស្តែង និងបរិបទនៃការរៀបចំគោលនយោបាយ ក៏ដូចជាគំនិតច្នៃប្រឌិតដើម្បីសកម្មភាពដែលជាញឹកញាប់ធ្វើឡើងដោយអ្នកចូលរួមគម្រោងបច្ចុប្បន្ន។

ឯកសារស្តីពីផែនការសកម្មភាពការប្រែប្រួលអាកាសធាតុនិងយេនឌ័រ បន្ទាប់មកត្រូវបានព្រាងឡើងលើមូលដ្ឋាននៃការវិភាគអំពីគោលនយោបាយថ្នាក់ជាតិបច្ចុប្បន្ន ឧទាហរណ៍គោលនយោបាយ ឬផែនការតាមវិស័យជាក់លាក់ ឬការរាយការណ៍ និងការទំនាក់ទំនងនៅថ្នាក់ជាតិទៅកាន់អង្គការ UNFCCC និងទាញយកបានច្រើនពីការពិភាក្សា និងលទ្ធផលនៃសិក្ខាសាលាពហុភាគីពាក់ព័ន្ធចំនួនពីរ ដែលបានកោះប្រជុំតំណាងមកពីក្រសួង ម្ចាស់ជំនួយ ទីភ្នាក់ងាររដ្ឋាភិបាល អង្គការក្រៅរដ្ឋាភិបាល និងសង្គមស៊ីវិល រួមទាំងអង្គការ និងបណ្តាញរបស់ស្ត្រី។ ខណៈដែលសិក្ខាសាលា ដើម្បីរៀបចំសេចក្តីព្រាងលេខសូន្យនៃផែនការសកម្មភាពការប្រែប្រួលអាកាសធាតុ និងយេនឌ័រ គឺមានពហុវិស័យ និងពហុភាគីពាក់ព័ន្ធដំណើរការសុពលភាពត្រូវបានធ្វើឡើងនៅថ្នាក់តំបន់/ថ្នាក់មូលដ្ឋាន ដើម្បីពង្រឹងឯកសារលទ្ធផលថ្នាក់ជាតិ ជាមួយនឹងបទពិសោធន៍ និងមេរៀនដែលបានរៀននៅទូទាំងវិស័យយេនឌ័រ និងអាកាសធាតុ ផ្តើមចេញពីគម្រោង និងកម្មវិធីជាច្រើនដែលត្រូវបានផ្សព្វផ្សាយនៅពាសពេញប្រទេស ដើម្បីកែលម្អ និងធ្វើអោយមានសុពលភាពដល់ផែនការសកម្មភាពការប្រែប្រួលអាកាសធាតុ និងយេនឌ័រ និងជំរុញការអនុវត្តដ៏ទូលំទូលាយ។

ជាលទ្ធផលនៃ "ខ្ញុំ" ដែលជាផ្នែកសំខាន់មួយនៃផែនការសកម្មភាពការប្រែប្រួលអាកាសធាតុ និងយេនឌ័រនីមួយៗ យុទ្ធសាស្ត្រក៏ទទួលបាននូវលក្ខណៈប្លែកៗ ដែលកំណត់ពួកគេនៅក្នុងរង្វង់ផ្ទាល់ខ្លួនសម្រាប់ការអភិវឌ្ឍ និងការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ តាមរយៈការចូលរួមមិនត្រឹមតែពីស្ត្រីប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងពីសហគមន៍ វិស័យនានា និងរដ្ឋាភិបាលទាំងមូល ដើម្បីបង្កើតវិធីសាស្ត្រកាន់តែមានការចូលរួម និងប្រកបដោយយុត្តិធម៌ ក្នុងការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ។

## ការបញ្ជ្រាបយេនឌ័រក្នុងគោលនយោបាយCCDRRថ្នាក់ជាតិ៖ ករណីសិក្សារបស់ប្រទេសកម្ពុជា

### គោលនយោបាយ និងផែនការក្របខ័ណ្ឌអនុសញ្ញា UNFCCC

រាជរដ្ឋាភិបាលកម្ពុជា បានដាក់ផែនការសកម្មភាពបន្សាំជាតិនឹងការប្រែប្រួលអាកាសធាតុជាលើកដំបូងក្នុងឆ្នាំ២០០៦ ដែលមានគោលបំណងកំណត់អាទិភាពនៃការបន្សាំ តាមរយៈដំណើរការពិគ្រោះយោបល់ និងការផ្តោតលើ "ក្រុមងាយរងគ្រោះ" ដែលជាភាគីពាក់ព័ន្ធសំខាន់ៗ។ទោះបីជាខ្វះការកំណត់អត្តសញ្ញាណច្បាស់នៃអ្នកដែលបង្កើតបានជាក្រុមគោលដៅដែលនាំទៅរកការផ្សព្វផ្សាយមានកម្រិត ផែនការសកម្មភាពបន្សាំនឹងការប្រែប្រួលអាកាសធាតុថ្នាក់ជាតិ មិនបានលើកឡើងពីសមភាពយេនឌ័រជាអាទិភាពហើយស្ត្រីត្រូវបានគេទទួលស្គាល់ថាជាតួអង្គសំខាន់នៅក្នុងវិស័យសុខាភិបាលសម្រាប់ការបង្ការ និងព្យាបាលជំងឺគ្រុនចាញ់តែប៉ុណ្ណោះ។

ប្រទេសកម្ពុជាក៏បានបញ្ជូនរបាយការណ៍ជាតិលើកដំបូងរបស់ខ្លួននៅ ឆ្នាំ២០០២ និងរបាយការណ៍ជាតិលើកទី ២ នៅ ឆ្នាំ២០១៥។ជាថ្មីម្តងទៀតរបាយការណ៍ទាំងនេះមិនបានដាក់បញ្ចូលទិន្នន័យបែងចែកតាមភេទ អាយុ និងពិការភាព និងខ្វះការវិភាគយេនឌ័រ។ជាថ្មីម្តងទៀតស្ត្រីត្រូវបានគេទទួលស្គាល់តែនៅក្នុងបរិបទនៃអន្តរាគមន៍ទាក់ទងនឹងជំងឺគ្រុនចាញ់។ ស្ថានភាពស្រដៀងគ្នានេះត្រូវបានគេសង្កេតឃើញនៅក្នុងការដាក់ជូនការចូលរួមចំណែកដើម្បីអនុវត្តអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិ ស្តីពីការប្រែប្រួលអាកាសធាតុ (INDC) ដែលបានដាក់ជូនក្នុងឆ្នាំ២០១៥បើទោះបីជារបាយការណ៍នោះបានកំណត់អំពី "កាត់បន្ថយភាព ងាយរងគ្រោះនៃយេនឌ័រ" ដែលជាផ្នែកមួយនៃយុទ្ធសាស្ត្រទី ២ របស់ខ្លួនក៏ដោយ របាយការណ៍ត្រួតពិនិត្យការត្រៀមលក្ខណៈនៃក្រប

ខ័ណ្ឌការងារទីក្រុងសេនដៃនៃប្រទេសកម្ពុជាដែលបានដាក់ជូនក្នុងឆ្នាំ ២០១៧ក៏មិនរាយការណ៍អំពីទិន្នន័យបែងចែកតាមភេទ អាយុ និងពិការភាព ឬការវិភាគយេនឌ័រដែរ។

វាគ្រាន់តែមានបង្ហាញនៅក្នុងរបាយការណ៍ប្រចាំគ្រាលើកទី ៤ និងទី ៥ របស់ប្រទេសកម្ពុជា ដែលបានដាក់ជូនក្នុងអនុសញ្ញា CEDAW ក្នុង ឆ្នាំ២០១៣ ថា បញ្ហាប្រឈមចំពោះសិទ្ធិទទួលបានរបស់ស្ត្រីក្នុងការប្រកបរបរចិញ្ចឹមជីវិតក្នុងបរិបទនៃការប្រែប្រួលអាកាសធាតុ និងផលប៉ះពាល់មិនសមាមាត្រនៃការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយធម្មជាតិលើស្ត្រី ត្រូវបានគេលើកឡើង។ ហើយខណៈដែលរបាយការណ៍ប្រចាំគ្រាលើកទី ៦ ដែលបានដាក់ជូនក្នុង ឆ្នាំ២០១៨ បង្ហាញពីកិច្ចខិតខំប្រឹងប្រែងក្នុងការបញ្ជ្រាបយេនឌ័ររបស់ក្រសួងតាមវិស័យផ្សេងៗ ដូចជាក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ល។ វានៅតែមិនផ្តោតលើការបញ្ជ្រាបយេនឌ័រនៅក្នុងក្របខ័ណ្ឌគោលនយោបាយការប្រែប្រួលអាកាសធាតុនិងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ។

ប្រទេសកម្ពុជាក៏បានបដិសេធមិនធ្វើសេចក្តីរាយការណ៍ស្តីពីភាពងាយរងគ្រោះ បែងចែកតាមភេទដែលជាផ្នែកមួយនៃការរាយការណ៍នៅក្នុងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី១៣។

## ផែនការ និងបទប្បញ្ញត្តិក្នុងស្រុក

នៅក្នុងទិដ្ឋភាពក្នុងស្រុក រដ្ឋធម្មនុញ្ញនៃប្រទេសកម្ពុជាបានបង្កើតមូលដ្ឋានគ្រឹះសម្រាប់សមភាពយេនឌ័រ និងសិទ្ធិស្មើគ្នាសម្រាប់ស្ត្រី។ នារីរតនៈទី ៤ (ឆ្នាំ២០១៤-២០១៨) ដែលបានបង្កើតឡើងដោយក្រសួងកិច្ចការនារី គឺជាប្រជាជាតិដែលណែនាំដោយគោលនយោបាយសមភាពយេនឌ័រ និងកំណត់ទំនាក់ទំនងទៅវិញទៅមករវាងយេនឌ័រ និងការប្រែប្រួលអាកាសធាតុ ដែលជាផ្នែកមួយនៃគោលដៅយុទ្ធសាស្ត្រ៣.២ដែលត្រូវបានដាក់បញ្ចូលក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។ ចំពោះបញ្ហានេះក្រសួងកិច្ចការនារីក៏បានបង្កើតនូវគណៈកម្មាធិការយេនឌ័រ និងការប្រែប្រួលអាកាសធាតុ ដើម្បីត្រួតពិនិត្យលើការងារនេះ។

បន្ថែមពីលើនេះជាផ្នែកមួយនៃផែនការយុទ្ធសាស្ត្រការប្រែប្រួលអាកាសធាតុកម្ពុជា (ឆ្នាំ២០១៤-២០១៨) ក្រសួងកិច្ចការនារីក៏បានធ្វើការវិភាគស្ថានភាពលម្អិតសម្រាប់ផែនការសកម្មភាពតាមវិស័យ ដែលបង្ហាញពីទំនាក់ទំនងរវាងវិសមភាពយេនឌ័រ និងភាពងាយរងគ្រោះនៃការប្រែប្រួលអាកាសធាតុ និងគូសបញ្ជាក់ពីផ្នែកនៃសកម្មភាពចំនួន ៦។ ក្រសួងកិច្ចការនារី ក៏បានបង្កើតផែនការសកម្មភាពយេនឌ័រ និងការប្រែប្រួលអាកាសធាតុ (ឆ្នាំ២០១៤-ឆ្នាំ២០១៨) ដើម្បីដំណើរការផែនការយុទ្ធសាស្ត្រដោយបង្ហាញពីចក្ខុវិស័យនិងការប្តេជ្ញាចិត្តពីក្រសួងកិច្ចការនារីនិងក្រសួងបរិស្ថាន។ គោលបំណងសំខាន់នៃផែនការសកម្មភាពនេះ គឺដើម្បីលើកកម្ពស់ការបញ្ជ្រាបយេនឌ័រ និងអន្តរាគមន៍សាកល្បងជាយុទ្ធសាស្ត្រ។

បន្ថែមលើនេះ គណៈកម្មាធិការយេនឌ័រ និងគ្រប់គ្រងការប្រែប្រួលអាកាសធាតុ (កម្ពុជា) ក៏បានបង្កើតផែនការសកម្មភាពយេនឌ័រ និងការប្រែប្រួលអាកាសធាតុ នៅឆ្នាំ២០១៣-២០២៣ ដោយសហការជាមួយក្រសួងបរិស្ថាន និងនាយកដ្ឋានការប្រែប្រួលអាកាសធាតុ។ ទោះបីខ្វះទិន្នន័យបែងចែកតាមភេទ អាយុ និងពិការភាពក៏ដោយ ឯកសារនេះមានការវិភាគយេនឌ័រយ៉ាងល្អិតល្អន់ ទាំងក្នុងបរិបទនៃភាពងាយរងគ្រោះផ្អែកលើយេនឌ័ររួមមានតួនាទីបន្តពូជរបស់ស្ត្រី និងសារៈសំខាន់របស់ពួកគេក្នុងការធ្វើឱ្យសេដ្ឋកិច្ចមានពណ៌បៃតង។ ឯកសារនេះបានប្រមូលផ្តុំនូវយុទ្ធសាស្ត្រយេនឌ័រដែលមានចែងនៅក្នុងផែនការយុទ្ធសាស្ត្រផ្លាស់ប្តូរអាកាសធាតុកម្ពុជា ក៏ដូចជាផែនការតាមវិស័យរបស់ក្រសួងសាមីផ្សេងទៀត។

សមាសធាតុស្នូលនៃផែនការយេនឌ័រទាំងនេះ ដែលអាចត្រូវបានអនុវត្តនៅក្នុងបរិបទប្រទេសអាស៊ីផ្សេងទៀត រួមមាន៖

- លើកកម្ពស់ស្ត្រីក្នុងការសម្រេចចិត្តលើការបន្សាំ និងការកាត់បន្ថយការប្រែប្រួលអាកាសធាតុព្រមទាំងការគ្រប់គ្រងគ្រោះមហន្តរាយធម្មជាតិនៅគ្រប់កម្រិត និងដែនដី។ បង្កើនកម្រិតនៃការយល់ដឹងអំពីយេនឌ័រ និងការប្រែប្រួលអាកាសធាតុ រាប់បញ្ចូលទាំង គ្រោះមហន្តរាយធម្មជាតិនៅក្នុងយន្តការរបស់ស្ត្រី និងការិយាល័យវិមជ្ឈការ និងភាគីពាក់ព័ន្ធ។
- បង្កើនកម្រិតសមត្ថភាពនៃយន្តការរបស់ស្ត្រី និងការិយាល័យវិមជ្ឈការ និងភាគីពាក់ព័ន្ធរបស់ខ្លួន ស្តីពីភាពងាយរងគ្រោះ និងការវាយតម្លៃសមត្ថភាពដែលមានដាក់បញ្ចូលបញ្ហាយេនឌ័រ វិធីសាស្ត្ររៀបចំផែនការសម្រាប់ការបន្សាំនិងការកាត់បន្ថយការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងគ្រោះមហន្តរាយធម្មជាតិ។
- ផ្តល់អន្តរាគមន៍គោលដៅដល់ស្ត្រីដែលមានភាពងាយរងគ្រោះខ្ពស់ ដើម្បីពង្រឹងសមត្ថភាពបន្សាំ និងការកាត់បន្ថយការប្រែប្រួលអាកាសធាតុ និងការផ្តល់សិទ្ធិអំណាចដល់ពួកគេ (ឧទាហរណ៍ សន្តិសុខស្បៀង អាហារូបត្ថម្ភ លទ្ធភាពទទួលបានទឹកស្អាតប្រកបដោយចីរភាពការប្រកបរបរចិញ្ចឹមជីវិតនៅទីក្រុងនិងជនបទការគ្រប់គ្រងកាកសំណល់លទ្ធភាពទទួលបានព័ត៌មាន និងការគាំទ្រការបង្កើតក្រុម)។
- ធ្វើការស្រាវជ្រាវ និងអភិវឌ្ឍន៍ ដើម្បីបង្កើនភាពអាចរកបាននៃទិន្នន័យ និងព័ត៌មានស្តីពីយេនឌ័រ និងការប្រែប្រួលអាកាសធាតុ។
- ទាញយកការអនុវត្ត និងមេរៀនល្អបំផុត ស្តីពីយេនឌ័រ និងការប្រែប្រួលអាកាសធាតុសម្រាប់ការធ្វើឱ្យប្រសើរឡើង ការរៀនសូត្រ និងការចែករំលែកនៅទូទាំងប្រទេស និងតំបន់។

ទោះបីជាយ៉ាងនេះក្តី ឧបករណ៍ថ្នាក់ជាតិសំខាន់មួយ ពោលគឺ ផែនការយុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុកម្ពុជា (ឆ្នាំ២០១៤-២០២៣) ត្រូវបានបង្កើតឡើងដោយមានការបញ្ជ្រាបយេនឌ័រ និងវិធីសាស្ត្រផ្អែកលើសិទ្ធិមនុស្សសម្រាប់ឆ្លើយតបទៅនឹងការប្រែ

ប្រែប្រួលអាកាសធាតុនៅកម្ពុជា។ផែនការនេះទទួលស្គាល់ពីផលប៉ះពាល់មិនសមាមាត្រគ្នាដែលការប្រែប្រួលអាកាសធាតុទៅលើស្ត្រី ហើយថាវាចាំបាច់ត្រូវមានការបញ្ជ្រាបយេនឌ័រទៅក្នុងវិធានការណ៍ និងច្បាប់ ព្រមទាំងគោលនយោបាយនានាឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ។

ផែនការកំណត់សមភាពយេនឌ័រថាជាគោលការណ៍ណែនាំមួយ ដើម្បី "ធានាថា ការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុគឺប្រកបដោយសមធម៌មានការឆ្លើយតបនឹងយេនឌ័រមានតម្លាភាពគណនេយ្យភាពនិងភាពសមស្របតាមវប្បធម៌"និងកាត់បន្ថយភាពងាយរងគ្រោះដល់ស្ត្រីចំពោះការប្រែប្រួលអាកាសធាតុដែលជាគោលដៅមួយរបស់វា។ ផែនការនេះក៏មានគោលដៅយេនឌ័រ យុទ្ធសាស្ត្រ ចំនួន ៣ ផងដែរគឺ៖

ក) ដើម្បីកាត់បន្ថយហានិភ័យភាពងាយរងគ្រោះនៃយេនឌ័រ និងសុខភាពចំពោះផលប៉ះពាល់ដែលបណ្តាលមកពីការប្រែប្រួលអាកាសធាតុតាមវិស័យ តាមតំបន់ និងផ្តល់អាទិភាពដល់តម្រូវការរបស់ស្ត្រីក្នុងសកម្មភាពបន្សុាំ និងការកាត់បន្ថយការប្រែប្រួលអាកាសធាតុ។
ខ) ពង្រឹងសមត្ថភាព ចំណេះដឹង និងការយល់ដឹងសម្រាប់ការផ្តោតលើការផ្លាស់ប្តូរអាកាសធាតុការដៅលើក្រុមងាយរងគ្រោះស្ត្រី កុមារ យុវជន និងជនជាតិភាគតិច។ និង
គ) លើកកម្ពស់កិច្ចគាំពារសង្គមតាមបែបបន្សុាំ និងវិធីសាស្ត្រដែលមានការចូលរួមនិងដាក់បញ្ចូលយេនឌ័រទៅក្នុងការរៀបចំផែនការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ។

ផែនការសកម្មភាពជាតិសម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ (ឆ្នាំ២០១៤-២០១៨) មានគោលបំណងពង្រឹងកិច្ចខិតខំប្រឹងប្រែងក្នុងការបញ្ជ្រាបការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ អភិបាលកិច្ចហានិភ័យគ្រោះមហន្តរាយ ជាពិសេសតាមរយៈកំណែទម្រង់ស្ថាប័ន និងការកសាងសមត្ថភាព។ ផែនការនេះមានសមាសភាគយុទ្ធសាស្ត្រផ្តោតលើយេនឌ័រនិងមានគោលបំណងសម្រេចបាននូវ "ការវាយតម្លៃដ៏ទូលំទូលាយមួយលើការខូចខាតនិងតម្រូវការចាំបាច់ក្រោយគ្រោះមហន្តរាយដោយអនុវត្តជាមួយនឹងព័ត៌មានបែងចែកតាមយេនឌ័រ" ។ ឯកសារគោលនយោបាយផ្សេងទៀត ពោលគឺផែនការយុទ្ធសាស្ត្រការប្រែប្រួលអាកាសធាតុសម្រាប់ការគ្រប់គ្រងគ្រោះមហន្តរាយ (ឆ្នាំ២០១៣) ដែលបានបង្កើតទំនាក់ទំនងរវាងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយនិងការបន្សុាំនឹងការប្រែប្រួលអាកាសធាតុក៏បានបញ្ចូលផងដែរនូវក្របខ័ណ្ឌឆ្លើយតបនឹងយេនឌ័រ ជាក់លាក់មួយដែលទទួលស្គាល់ភាពងាយរងគ្រោះរបស់ស្ត្រី ចំពោះការប្រែប្រួលអាកាសធាតុ និងស្នើឱ្យដាក់បញ្ចូលសូចនាករសមភាពយេនឌ័រក្នុងការត្រួតពិនិត្យ សកម្មភាពគ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុ។

ច្បាប់ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ (ឆ្នាំ២០១៥) មានគោលបំណងកំណត់ការគ្រប់គ្រងគ្រោះមហន្តរាយនៅកម្ពុជា រួមមានការបង្ការ ការបន្សុាំនិងការកាត់បន្ថយនៅមុនពេលមានគ្រោះមហន្តរាយ ការឆ្លើយតបបន្ទាន់ក្នុងអំឡុងពេលគ្រោះមហន្តរាយ និងការស្តារឡើងវិញនៅក្នុងរយៈពេលក្រោយគ្រោះមហន្តរាយ។ ខណៈដែលជាទូទៅមានការទទួលស្គាល់សិទ្ធិក្នុងការការពារអាយុជីវិត សេចក្តីថ្លៃថ្នូរ ទ្រព្យសម្បត្តិ។ល។ សម្រាប់ "បុគ្គលម្នាក់ៗ" មាត្រាទី ១៨ នៃច្បាប់បានចែងយ៉ាងច្បាស់ពីតម្រូវការក្នុងការយកចិត្តទុកដាក់ខ្ពស់លើតម្រូវការរបស់ស្ត្រី កុមារ ចាស់ជរា ជនពិការ និងជនបាត់បង់លទ្ធភាពពលកម្ម" ក្នុងករណីមានគ្រោះមហន្តរាយ។

ប្រភព៖ (Reggers និង Lim ឆ្នាំ២០១៩) (Dankelman ឆ្នាំ២០១៦)

## ការផ្តោតលើការអនុវត្ត ការតាមដាន និងការវាយតម្លៃ

ផែនការតែឯកឯង គឺមានប្រយោជន៍តិចតួច លុះត្រាតែវាត្រូវបានយកមកអនុវត្ត។ ដើម្បីធ្វើឱ្យវាក្លាយជាការពិត វាចាំបាច់ត្រូវយកមកកែលម្អដោយវិធានការជាក់ស្តែង។ផ្អែកលើផែនការដែលឆ្លើយតបនឹងតម្រូវការយេនឌ័រ ក្នុងចំណុចនេះ វាចាំបាច់ក្នុងការកំណត់សកម្មភាពទាំងនោះដែលអាចបំពេញតាមគោលបំណងនៃផែនការបន្សុាំថ្នាក់ជាតិ។ យុទ្ធសាស្ត្រអនុវត្តឆ្លើយតបនឹងតម្រូវការយេនឌ័រទទួលស្គាល់ឱកាសនិងឧបសគ្គជាក់លាក់របស់យេនឌ័រនិងមានគោលដៅកំណត់សកម្មភាពបន្សុាំដែលត្រូវដាក់បញ្ចូលក្រុមងាយរងគ្រោះបំផុតដែលអាចឱ្យពួកគេដឹងពីសក្តានុពលរបស់ពួកគេ ក្នុងនាមជាភ្នាក់ងារនៃការផ្លាស់ប្តូរ នៅក្នុងគ្រួសារ និងក្នុងសហគមន៍របស់ពួកគេ។

ការងារនេះជួយធានាថា សកម្មភាពបន្សុាំត្រូវបានអនុវត្ត នៅកន្លែងដែលណាចាំបាច់បំផុត ហើយថាអត្ថប្រយោជន៍គឺប្រកបដោយសមធម៌។

ក) អនុវត្តដំណើរការចូលរួមប្រកបដោយបរិយាប័ន្ន និងប្រកបដោយសមធម៌ដែលមានលក្ខណៈយេនឌ័រ ដើម្បីបង្កើតយុទ្ធសាស្ត្រអនុវត្ត។
ខ) មានការចូលរួមពីអ្នកដឹកនាំជាស្ត្រីដែលមកពីក្រុមរងផលប៉ះពាល់ និងតួអង្គយេនឌ័រក្នុងការអភិវឌ្ឍយុទ្ធសាស្ត្រអនុវត្ត។
គ) កំណត់សកម្មភាពដែលទាក់ទងដោយផ្ទាល់ទៅនឹងគោលបំណងយេនឌ័រនៃផែនការជាតិបន្សុាំ។
ឃ) ផ្តល់អាទិភាពលើសកម្មភាពដែលលើកកម្ពស់សមភាពយេនឌ័រផ្តល់ភាពអង់អាចដល់ស្ត្រីនិងអាចចូលដំណើរការបានបំផុត
ង) បង្កើតគោលដៅបែងចែកតាមភេទសម្រាប់សកម្មភាពផ្តោតលើផលប្រយោជន៍បុគ្គល។
ច) កន្លែងដែលការរឹតត្បិតក្នុងសង្គម អាចរារាំងស្ត្រីមិនឱ្យក្លាយជាអ្នកទទួលបានផលប្រយោជន៍ដោយស្មើភាព កំណត់អត្ត

សញ្ញាណសកម្មភាពដែលជួយពួកគេឱ្យយកឈ្នះឧបសគ្គសង្គម។ សកម្មភាពទាំងនេះអាចជាទម្រង់នៃសកម្មភាពបន្ថែម ឬផ្លាស់ប្តូររបៀបដែលសកម្មភាពត្រូវបានផ្តល់តាមទម្រង់បច្ចុប្បន្ន។

ឆ) ការពិពណ៌នាអំពីសកម្មភាពនីមួយៗ នៅក្នុងផែនការសកម្មភាព គួរតែរួមបញ្ចូលនូវសមាសធាតុដូចតទៅ៖ ចំណងជើងសកម្មភាពគោលបំណងនៃសកម្មភាពគោលបំណងសមភាពយេនឌ័រ បរិបទ ការពិពណ៌នាស្ថាប័នអនុវត្ត រយៈពេលសកម្មភាពធាតុចូលតួលេខរូបវន្តគោលដៅនិងសមាសភាគយេនឌ័រ។

ជាផ្នែកមួយនៃការតាមដាន និងវាយតម្លៃ ផែនការបន្ស៊ាំថ្នាក់ជាតិ ត្រូវដាក់បញ្ចូលការអភិវឌ្ឍវិធីសាស្ត្រដែលមានការចូលរួមដែលអាចវាយតម្លៃបានទាំងការអភិវឌ្ឍបែបគុណវិស័យ និងបែបបរិមាណវិស័យ និងតាមដានការអនុវត្តប្រកបដោយជោគជ័យ និងធានាថា រាល់បញ្ហាយេនឌ័រត្រូវបានគ្របដណ្តប់បានគ្រប់ជ្រុងជ្រោយ។
ប្រព័ន្ធតាមដាន និងវាយតម្លៃត្រូវបានបង្កើតឡើង ដើម្បីតាមដានវឌ្ឍនភាពដែលបានធ្វើឡើង ទាក់ទងនឹងសមិទ្ធិផលជាក់ស្តែងនៃគោលដៅពោលគឺការគ្របដណ្តប់របស់អ្នកទទួលផលនិងប្រសិទ្ធភាពនៃសកម្មភាព។ការរួមបញ្ចូលការពិចារណារបស់យេនឌ័រទៅក្នុងប្រព័ន្ធតាមដាន និងវាយតម្លៃ អាចជួយធានាថា ភាពខុសគ្នានៃយេនឌ័រនៅក្នុងការចូលរួមក្នុងសកម្មភាពបន្ស៊ាំនិងផលប្រយោជន៍ពីការវិនិយោគក្នុងការបន្ស៊ាំត្រូវបានគេកំណត់ហើយអតុល្យភាពអាចត្រូវបានដោះស្រាយឡើងវិញ។ វាក៏ជួយតាមដានផងដែរនូវវឌ្ឍនភាពលើសមភាពយេនឌ័រ និងការផ្តល់ភាពអង់អាចដល់ស្ត្រី។
សកម្មភាពខាងក្រោមគឺចាំបាច់សម្រាប់ប្រព័ន្ធតាមដាននិងវាយតម្លៃរំញោចយេនឌ័រ៖

ក) បង្កើតសូចនាករជាក់លាក់ទាក់ទងនឹងយេនឌ័រ (SMART) ដូចជា ជាក់លាក់ អាចវាស់វែងបាន អាចសម្រេចបាន ជាប់ពាក់ព័ន្ធ និងពេលវេលាជាក់លាក់

ខ) ប្រមូលទិន្នន័យបែងចែកតាមភេទនិងធ្វើការវិភាគលើទិន្នន័យយេនឌ័រ ដើម្បីវាយតម្លៃសមធម៌យេនឌ័រក្នុងការសម្រេចចិត្ត ក៏ដូចជាលទ្ធភាពទទួលបានអត្ថប្រយោជន៍ និងលទ្ធផលពីសកម្មភាពបន្ស៊ាំ។

គ) វាយតម្លៃផលប៉ះពាល់នៃសកម្មភាពបន្ស៊ាំដែលមានភាពខុសគ្នាខាងយេនឌ័រ ទៅលើស្ត្រី បុរស និងក្រុមជួបការលំបាក។

ឃ) លើកទឹកចិត្តដល់ការវាយតម្លៃដែលមានការចូលរួមនិងការធ្វើសវនកម្មកម្មវិធីយេនឌ័រ។

ការចូលរួមរបស់តួអង្គយេនឌ័រក្នុងការអភិវឌ្ឍក្របខ័ណ្ឌតាមដាន និងវាយតម្លៃ មានសារៈសំខាន់ណាស់សម្រាប់បញ្ហានេះ។ ក្រុមអង្គការសង្គមស៊ីវិលក្នុងស្រុកក្រុមស្ត្រីនិងក្រុមអ្នកសិក្សាក៏ដូចជាសហគមន៍នានា គួរតែចូលរួមនៅក្នុងដំណើរការនេះ ដើម្បីធានាបាននូវការប្រមូលទិន្នន័យដោយត្រឹមត្រូវ និងរឹងមាំ ជាពិសេសព័ត៌មានប្រកបដោយគុណភាព។
ថវិកាគឺជាសូចនាករសំខាន់បំផុតមួយនៃការប្តេជ្ញាចិត្តដែលធ្វើឡើងដោយអ្នកសម្រេចចិត្ត។ ក្នុងការអភិវឌ្ឍផែនការសកម្មភាព ក្រុមរៀបចំផែនការ ត្រូវលះបង់ធនធាន ដើម្បីជំរុញការលើកកម្ពស់សមភាពយេនឌ័រ។ ការធ្វើផែនការថវិការំញោចយេនឌ័រជាដំបូងមានន័យថាជាការវិភាគថវិកាលើសកម្មភាពទាំងអស់ដែលបានស្នើឡើងដើម្បីកំណត់ពីផលប៉ះពាល់ខុសគ្នាលើថវិកាសម្រាប់ស្ត្រី និងបុរស។ បន្ទាប់មក គឺជាការបែងចែកធនធានឡើងវិញ ដើម្បីសម្រេចបាននូវសមភាពយេនឌ័រ ចេញពីសកម្មភាពដែលបានគ្រោងទុក។

# លំហាត់

## លំហាត់ទី ៩៖ ល្បែងក្រ័រ និងល្បែងចងខ្សែ

គោលបំណងសំខាន់នៃលំហាត់នេះ គឺដើម្បីផ្តល់ឱ្យអ្នកចូលរួមនូវការពិនិត្យឡើងវិញ/ការកែប្រែយ៉ាងរហ័សនូវទិដ្ឋភាពគោលនយោបាយសកល ស្តីពីការប្រែប្រួលអាកាសធាតុ និងការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ។

**សម្ភារដែលតម្រូវឱ្យមាន៖** ក្តារខៀន និងប៊ិចហ្វឺត

**ដំណើរការ៖**

**ជំហានទី១៖** ចែកអ្នកចូលរួមជាពីរក្រុម គឺក្រុម "X" និង ក្រុម "O" និងផ្តល់ឱ្យពួកគេនូវសំណៅឯកសារទី១ ចំនួន១ច្បាប់។ សុំឱ្យពួកគេពិនិត្យមើលសំណៅឯកសារទី១ ឱ្យបានឆាប់ក្នុងរយៈពេល ១៥នាទី។ (ក្នុងករណីក្រុមកម្រិតខ្ពស់ អ្នកអាចរំលងជំហាននេះ ហើយរំលងទៅជំហានបន្ទាប់តែម្តង)។

**ជំហានទី២៖** ប្រាប់ពួកគេថា ឥឡូវនេះ អ្នកនឹងលេងល្បែងក្រ័រ និងល្បែងចងខ្សែរវាងក្រុមទាំងពីរ ប៉ុន្តែការលេងអាចមានលក្ខណៈបត់បែន។ គូរម៉ាទ្រិច ដែលមានផ្នែកចំនួន ៩ នៅលើផ្ទាំងក្រដាសធំ ដោយសរសេរពាក្យមួយទាក់ទងនឹងក្របខ័ណ្ឌគោលនយោបាយការប្រែប្រួលអាកាសធាតុ និងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ក្នុងប្រអប់នីមួយៗដូចបង្ហាញខាងក្រោម។

| អនុសញ្ញា UNFCCC | ពិធីសារក្យូតូ | កិច្ចព្រមព្រៀងទីក្រុងប៉ារីស |
|---|---|---|
| ក្របខ័ណ្ឌទីក្រុងសេនដៃ | ការចូលរួមចំណែកដើម្បីអនុវត្តអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ | កិច្ចប្រជុំកំពូលស្តីពីផែនដី |
| ផែនការសកម្មភាពជាតិបន្សាំនឹងការប្រែប្រួលអាកាសធាតុ | ក្រុមការងារអន្តររដ្ឋាភិបាលស្តីពីការប្រែប្រួលអាកាសធាតុ | សន្និសីទបណ្តាភាគី |

**ជំហានទី៣៖** ឥឡូវសូមប្រាប់ក្រុមថា ពួកគេត្រូវជ្រើសរើសវាក្យស័ព្ទមួយនៅពេលដល់វេនពួកគេ និងផ្តល់សេចក្តីលម្អិតលើវាក្យស័ព្ទនោះ។ ក្រុមនេះត្រូវតែផ្តល់ព័ត៌មានលម្អិតយ៉ាងហោចណាស់ពីរ ដែលយ៉ាងហោចណាស់មនុស្សម្នាក់ត្រូវតែមានជាប់ទាក់ទងទៅនឹងមាតិកាចម្បង។ (ហើយថាអ្នកសម្របសម្រួលនឹងវិនិច្ឆ័យថាតើចម្លើយគឺត្រូវ ឬខុស)។ សូមប្រាប់ពួកគេថា សម្រាប់សំណួរនីមួយៗ ក្រុមនឹងត្រូវការតំណាងជាច់ដោយឡែក ដើម្បីឆ្លើយជំនួសពួកគេ។ក្រុមដែលអាចផ្តល់និយមន័យក្នុងចម្លើយត្រឹមត្រូវបីនៅក្នុងបន្ទាត់ត្រង់ ឬអង្កត់ផ្ចិតមួយនៅលើម៉ាទ្រិច គឺជាអ្នកឈ្នះលើការប្រកួតនេះ ។

**ជំហានទី៤៖** អនុញ្ញាតឱ្យក្រុមទីមួយ រើសយកវាក្យស័ព្ទ/ប្រអប់ដោយចៃដន្យ និងពន្យល់អំពីពាក្យនោះ។ ប្រសិនបើចម្លើយត្រឹមត្រូវ សូមគូសសញ្ញា "X" និង "O" របស់ក្រុមនៅក្នុងរាងការ៉េ។ ប្រសិនបើចម្លើយខុស ពួកគេត្រូវប្តូរវេនរបស់ពួកគេ។ ដំណើរការនេះបន្តរហូតទាល់តែក្រុមទទួលបានសញ្ញាបីក្នុងបន្ទាត់ត្រង់ ឬរាងអង្កត់ផ្ចិត នៅលើក្តារខៀន ដូចមានបង្ហាញនៅពេលបន្ទាប់។

| | | |
|---|---|---|
| | | |
| | | |
| X | X | X |

| | | |
|---|---|---|
| | | O |
| | O | |
| O | | |

**ជំហានទី៥៖** សូមបន្តដំណើរការជាមួយនឹងបណ្តុំវាក្យស័ព្ទផ្សេងទៀត។ ប្រសិនបើពុំមានវាក្យស័ព្ទណាដែលអាចយកឈ្នះបាន សូមបន្តល្បែងជាមួយនឹងប្រអប់ដែលនៅសល់ ហើយក្រុមដែលមានសញ្ញាច្រើនជាងគេបំផុតនៅលើក្តារខៀននឹងឈ្នះការប្រកួត។

**ទិន្នផលនៃការរៀនសូត្រ៖** សូមបញ្ចប់ដោយផ្តល់ឱ្យអ្នកចូលរួមជាមួយនឹងតារាងពេលវេលានៃអនុសញ្ញា និងកិច្ចព្រមព្រៀងទាំងនេះ ខណៈដែលបន្ថែមចំណុចសំខាន់ៗដែលពុំបានលើកឡើងនៅក្នុងការពិភាក្សា។

### លំហាត់ទី១០៖ការពិភាក្សាជាក្រុមស្តីពីការអនុវត្តដែលមានទស្សនៈយេនឌ័ររបស់អង្គការ UNFCCC និងក្របខ័ណ្ឌការងារទីក្រុងសេនដៃនៅថ្នាក់ជាតិ

គោលបំណងចម្បងនៃលំហាត់នេះ គឺបង្ហាញអំពីការប្តេជ្ញាចិត្តផ្នែកយេនឌ័ររបស់អង្គការ UNFCCC និងក្របខ័ណ្ឌការងារទីក្រុងសេនដៃទៅក្នុងចំណុចដែលអាចធ្វើសកម្មភាពបាននៅកម្រិតប្រទេស។

**សម្ភារដែលតម្រូវឱ្យមាន៖** សំណៅឯកសារចំនួន៨ច្បាប់ បន្ទាប់ពីដកចេញនូវកំណត់សម្គាល់សម្រាប់អ្នកសម្របសម្រួល។

**ដំណើរការ៖**

**ជំហានទី១៖** ចែកអ្នកចូលរួមជាបួនក្រុម។ ឱ្យក្រុមនីមួយៗនូវផ្នែក ក ឬផ្នែក ខ នៃសំណៅឯកសារទី៨។

**ជំហានទី២៖**ស្នើឱ្យអ្នកចូលរួមពិភាក្សាអំពីសំណួរសំខាន់ៗនៅក្នុងសំណៅឯកសារ ដែលទាក់ទងនឹងចំណុចនីមួយៗដែលបានលើកឡើង។សាកសួរពួកគេឱ្យបែងចែកចំណុចបន្ថែមទៀតរវាងពួកគេដើម្បីឱ្យការពិភាក្សាពេញលេញតាមពេលកំណត់។

**ជំហានទី៣៖**ឥឡូវឱ្យពួកគេចែករំលែកអំពីការឆ្លើយតបរបស់ពួកគេនៅក្នុងក្រុមធំ។ប្រសិនបើភ្លេចចំណុចណាមួយសូមបន្ថែមចម្លើយដោយប្រើព័ត៌មានយកចេញពីកំណត់សម្គាល់សម្រាប់អ្នកសម្របសម្រួលនៅក្នុងឯកសារទី៨។

**លទ្ធផលនៃការរៀនសូត្រ៖** សូមបញ្ចប់ដោយនិយាយថាក្របខ័ណ្ឌទាំងនេះគឺជាឯកសារដែលមានសារៈប្រយោជន៍ខ្លាំងក្នុងការគាំទ្រលើការបញ្ជ្រាបយេនឌ័រទៅក្នុងគោលនយោបាយCCDRRនិងសកម្មភាពនៅកម្រិតក្នុងស្រុក។ ទោះបីយ៉ាងណា វាក៏មានសារៈសំខាន់សម្រាប់អង្គការសង្គមស៊ីវិល ក្នុងការបង្ហាញអំពីព័ត៌មានទៅក្នុងចំណុចដែលអាចធ្វើសកម្មភាពបាន និងបន្តសកម្មភាពជាក់លាក់ដែលអាចជាប់ពាក់ព័ន្ធខ្លាំងនៅកម្រិតប្រទេស។

---

### លំហាត់ទី១១៖ការងារជាក្រុមអំពីការប៉ាន់ប្រម៉ាណដែលមានទស្សនៈយេនឌ័រនៃ NDCs និងផែនការ NAP

គោលបំណងចម្បងនៃលំហាត់នេះគឺការណែនាំឱ្យស្គាល់អំពីបញ្ជីត្រួតពិនិត្យសម្រាប់ការវាយតម្លៃយេនឌ័រនៅក្នុង NDCs និងផែនការNAPនៅកម្រិតប្រទេសនិងផ្តល់ជូនពួកគេនូវបទពិសោធន៍នៃការប្រើប្រាស់ដូចគ្នា។

**សម្ភារដែលតម្រូវឱ្យមាន៖** សំណៅឯកសារចំនួន៩ច្បាប់ ជាមួយ laptop ដែលមានភ្ជាប់អ៊ិនធើណិត។

**ដំណើរការ៖**

**ជំហានទី១៖** ចែកអ្នកចូលរួមជាបួនក្រុម។ ឱ្យក្រុមនីមួយៗនូវផ្នែក ក ឬផ្នែក ខ នៃសំណៅឯកសារទី៩។

**ជំហានទី២៖**ឥឡូវឱ្យពួកគេជ្រើសរើសប្រទេសដែលពួកគេចង់វិភាគពីឯកសារនោះ។ សូមចែករំលែកតំណភ្ជាប់ (link) របស់អង្គការ UNFCCC ជាមួយពួកគេ ដើម្បីអាចចូលមើលឯកសារស្តីពី NDCs/NAP សម្រាប់ប្រទេសនោះ។

NDC link: https://www4.unfccc.int/sites/NDCStaging/Pages/All.aspx

NAP link: https://www4.unfccc.int/sites/NAPC/Pages/national-adaptation-plans.aspx

**ជំហានទី៣៖**ឥឡូវសូមឱ្យពួកគេពិនិត្យឡើងវិញលើឯកសារដោយប្រើប្រាស់បញ្ជីត្រួតពិនិត្យ និងបទពិសោធន៍របស់ពួកគេក្នុងនាមជាក្រុមនៅក្នុងប្រទេស។ សូមប្រាប់ពួកគេឱ្យផ្តោតតែទៅលើសេចក្តីសង្ខេប និងមាតិកាបន្សាំសម្រាប់លំហាត់។ ទុកពេល ២០នាទីឱ្យពួកគេសម្រាប់ធ្វើកិច្ចការនោះ និងស្នើឱ្យពួកគេចែករំលែករបាយការណ៍ជាឯកសារ PowerPoint ឬឯកសារ Word។

**ជំហានទី៤៖** ត្រឡប់មកក្នុងក្រុមធំវិញ សូមប្រាប់ពួកគេថា អ្នកនឹងរៀបចំរបាយការណ៍ និងផ្តល់របាយការណ៍នោះជូនអ្នកចូលរួមដែលជាផ្នែកមួយនៃរបាយការណ៍បណ្តុះបណ្តាល ហេតុនេះ ការពិភាក្សានឹងផ្តោតតែទៅលើបទពិសោធន៍។ស្នើឱ្យពួកគេឆ្លុះបញ្ចាំងអំពីសំណួរខាងក្រោម៖

ក) តើពួកគេយល់ថាបញ្ជីត្រួតពិនិត្យងាយស្រួល/មិនងាយស្រួលយ៉ាងដូចម្តេចខ្លះ?

ខ) តើមានការប្រឈមអ្វីខ្លះ (ក្រៅពីឧបសគ្គពេលវេលាសម្រាប់លំហាត់) ដែលបានជួបប្រទះ នៅពេលប្រើបញ្ជីត្រួតពិនិត្យ?

គ) តើព័ត៌មានអ្វីដែលចាំបាច់ត្រូវការបន្ថែមដើម្បីធ្វើលំហាត់នេះនៅកម្រិតប្រទេស និងបោះផ្សាយរបាយការណ៍ដដែលនេះ?

ឃ) តើរបាយការណ៍អាចយកមកប្រើដោយរបៀបណា?

**លទ្ធផលនៃការរៀនសូត្រ៖** សូមបញ្ចប់ដោយនិយាយថា បញ្ជីត្រួតពិនិត្យទាំងនេះ មានសារៈសំខាន់ក្នុងការវាយតម្លៃការឆ្លើយតបនឹងយេនឌ័រនៃ NDCs និង NAP។ សូមប្រាប់ពួកគេថា លំហាត់ដែលបានផ្តល់ជូនពួកគេ គឺគ្រាន់តែជាផ្នែកមួយនៃឧបករណ៍ប៉ុណ្ណោះ ហើយថាពួកគេនឹងត្រូវធ្វើការវិភាគស៊ីជម្រៅបន្ថែមទៀត សម្រាប់ការបោះផ្សាយរបាយការណ៍ផ្លូវការ។ សូមប្រាប់ពួកគេថា របាយការណ៍នោះ អាចជា

ឧបករណ៍គាំទ្រដ៏សំខាន់សម្រាប់អង្គការសង្គមស៊ីវិលក្នុងការបន្តតម្រូវការក្នុងការបញ្ជ្រាបយេនឌ័រទៅក្នុងគោលនយោបាយ CCDRR និងសម្រាប់ការចែករំលែកជាមួយអង្គការ UNFCCC ដែលជាផ្នែកមួយនៃផែនការសកម្មភាពយេនឌ័ររបស់ពួកគេ។

## លំហាត់ទី១២៖ កិច្ចការជាក្រុមស្តីពី អនុសាសន៍ទូទៅ CEDAW លេខ៣៧ និងសេចក្តីប្រកាស (+២៥) នីក្រុងប៉េកាំងអាស៊ីប៉ាស៊ីហ្វិក

គោលបំណងសំខាន់នៃលំហាត់នេះគឺដើម្បីផ្តល់បទពិសោធដោយផ្ទាល់ដល់អ្នកចូលរួម ដោយប្រើវេទិកាត្រួតពិនិត្យ តាមដំណាក់កាល និងរបាយការណ៍ស្រមោលក្នុង CEDAW និងវេទិការទីក្រុងប៉េកាំងដើម្បីសកម្មភាព (BPfA) សម្រាប់ការលើកកម្ពស់សកម្មភាព CCDRR ដែលឆ្លើយតបនឹងតម្រូវការយេនឌ័រ។

**សម្ភារដែលតម្រូវឱ្យមាន៖** សំណៅឯកសារទី១០ ចំនួនច្រើនច្បាប់។

**ដំណើរការ៖**

**ជំហានទី១៖** បែងចែកអ្នកចូលរួមជាបួនក្រុម។ព្យាយាមរួមបញ្ចូលអ្នកចូលរួមពីប្រទេស/តំបន់ដូចគ្នាទៅក្នុងក្រុមមួយ។ ផ្តល់ជូនក្រុមនីមួយៗនូវផ្នែក ក ឬ ខ នៃសំណៅឯកសារទី១០។

**ជំហានទី២៖** ឥឡូវស្នើពួកគេឱ្យជ្រើសរើសប្រទេសមួយសម្រាប់ការវិភាគនិងស្នើឱ្យពួកគេរៀបចំបទបង្ហាញខ្លីមួយអំពីស្ថានភាពនៃការអនុវត្ត CEDAW/BPfA នៅក្នុងប្រទេសនោះ។ ស្លាយនីមួយៗនៃបទបង្ហាញគួរតែផ្តោតលើទិដ្ឋភាពដូចមានខាងក្រោម៖

ក) តើអ្វីដែលត្រូវបានធ្វើនៅក្នុងប្រទេសរបស់អ្នកដើម្បីអាចឱ្យមានការសម្រេចបានគោលបំណង/កាតព្វកិច្ចនៃអនុសញ្ញា/សេចក្តីប្រកាសទាក់ទងនឹង CCDRR?
ខ) តើអ្វីគឺជាចំណុចខ្វះខាតនៅក្នុងសកម្មភាព/ តើអ្វីដែលមានសារៈសំខាន់ខ្លាំង ប៉ុន្តែមិនត្រូវបានធ្វើ?
គ) តើអ្វីជាចំណុចខ្វះខាតខាងផ្នែកអនុវត្តនិងផ្នែកធនធាន?
ឃ) តើអ្វីគឺជាសកម្មភាពដែលត្រូវបានផ្តល់អនុសាសន៍សំខាន់ៗសម្រាប់រដ្ឋាភិបាលថ្នាក់ជាតិ?
ង) ផ្តល់ករណីជាក់ស្តែងធ្វើជាភស្តុតាងដើម្បីពង្រឹងចំណុចរបស់អ្នក។

**ជំហានទី៣៖** ផ្តល់ពេលវេលា៣០នាទីជូនពួកគេសម្រាប់កិច្ចការនេះ ហើយស្នើឱ្យពួកគេចែករំលែករបាយការណ៍ជា PowerPoint ឬ Ms Word។

**ជំហានទី៤៖** នៅពេលងាកមកធ្វើការជាក្រុមធំវិញ ចូរប្រាប់ពួកគេថា អ្នកនឹងផ្ទៀងផ្ទាត់របាយការណ៍ និងផ្តល់របាយការណ៍ទាំងនេះជូនអ្នកចូលរួមធ្វើជាផ្នែកមួយនៃរបាយការណ៍បណ្តុះបណ្តាល ដូច្នេះការពិភាក្សានឹងត្រឹមតែផ្តោតលើបទពិសោធប៉ុណ្ណោះ។ ស្នើឱ្យពួកគេឆ្លុះបញ្ចាំងសំណួរខាងក្រោម៖

ក) តើអ្វីគឺជាការរៀនសូត្រសំខាន់ៗពីលំហាត់នេះ?
ខ) តើអ្វីជាបញ្ហាប្រឈម (ក្រៅពីឧបសគ្គពេលវេលាសម្រាប់លំហាត់) ដែលជួបប្រទះក្នុងបង្កើតបទបង្ហាញ?
គ) តើពួកគេអាចដោះស្រាយបញ្ហាប្រឈមទាំងនេះដោយរបៀបណាជាពិសេសនៅពេលបង្កើតបទបង្ហាញផ្លូវការមួយ?
ឃ) តើរបាយការណ៍បែបនេះត្រូវបានប្រើប្រាស់យ៉ាងដូចម្តេច?

**លទ្ធផលនៃការរៀនសូត្រ៖** បញ្ចប់វគ្គដោយនិយាយថា ទាំង CEDAW និង BPfA ផ្តល់ជាវេទិកាត្រួតពិនិត្យជាប្រចាំ ដោយមានកន្លែងសម្រាប់ការចូលរួមរបស់អង្គការសង្គមស៊ីវិល ជាពិសេសអង្គការដែលផ្តោតលើស្ត្រី។ វាមានសារៈសំខាន់ ដើម្បីនាំយករបៀបវារៈ CCDRR នៅក្នុងយន្តការត្រួតពិនិត្យទាំងនេះ ជាពិសេសតាមរយៈការបង្កើតការចូលរួមចំណែកដល់របាយការណ៍ស្រមោលរបស់ CEDAW និងឯកសារត្រួតពិនិត្យ BPfA។

## លំហាត់ទី១៣៖ ការសម្តែងជា Batokas និង Gonkas

គោលបំណងសំខាន់នៃលំហាត់នេះ គឺដើម្បីរំញោចអ្នកចូលរួមឱ្យយល់ដឹងអំពីតម្រូវការនៃការរួមបញ្ចូលការពិចារណាលើយេនឌ័រក្នុងការរៀបចំគោលនយោបាយ និងអំពីសារៈសំខាន់នៃការចូលរួមរបស់ក្រុមដែលរងផលប៉ះពាល់ខ្លួនឯងផ្ទាល់ទៅក្នុងការពិភាក្សា និងដំណើរការធ្វើសេចក្តីសម្រេចចិត្ត។

**សម្ភារដែលតម្រូវឱ្យមាន៖** ក្តារខៀន និងប៊ិចហ្វឺត

**ដំណើរការ៖**

**ជំហានទី១៖** បែងចែកអ្នកចូលរួមជា ៣ក្រុម។ ជំនួសឱ្យការបង្កើតជាក្រុមដោយចៃដន្យ ចូរប្រើប្រាស់សិទ្ធិរបស់អ្នក ហើយដាក់អ្នកចូលរួមទាំងអស់ដែលមានអត្តចរិកគ្របលើដទៃឱ្យចូលក្នុងមួយក្រុម ហើយអ្នកចូលរួមដែលភាពអសកម្មឱ្យចូលក្នុងមួយក្រុមទៀត។ ដាក់ឈ្មោះក្រុមគ្របលើអ្នកដទៃថាជាក្រុម Batoka ហើយក្រុមមួយទៀតថាជាក្រុម Gonka។ អ្នកដែលមានការវិភាគខ្លាំងគួរត្រូវបានតែងតាំងឱ្យធ្វើជាអ្នកសង្កេតការ។

**ជំហានទី២៖** ប្រាប់ពួកគេថា ពួកគេនឹងរៀបចំកិច្ចប្រជុំមួយនៅក្នុងភូមិដើម្បីពិភាក្សាអំពីការបង្កើតគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយ

ភូមិ (VDMC) និងកំណត់វិស័យដែលជាក្តីបារម្ភសំខាន់ៗចំនួនបី ដើម្បីឱ្យ VDMC ធ្វើការងារលើបញ្ហាទាំងនេះ។ ចូរផ្តល់ជូនក្រុម Batokas នូវទិដ្ឋភាពទូទៅមួយដោយផ្អែកលើប្រអប់ទី១ និងផ្តល់ជូនក្រុម Gonkas នូវទិដ្ឋភាពទូទៅមួយដោយផ្អែកលើប្រអប់ទី២។ អ្នកសង្កេតការគួរមានទិដ្ឋភាពពេញលេញ។កែសម្រួលកិច្ចការនេះទៅតាមបរិបទក្នុងស្រុកឱ្យបានច្រើនតាមដែលអាចធ្វើទៅបាន។

| ប្រអប់ទី១៖ ក្រុម Batoka | ប្រអប់ទី២៖ ក្រុម Gonka |
|---|---|
| > សមាជិកម្នាក់របស់ក្រុមbatokaជាមន្ត្រីសុខាភិបាលនិងទទួលបានការបណ្តុះបណ្តាលរួចហើយអំពីការគ្រប់គ្រងគ្រោះមហន្តរាយសម្រាប់ជាផ្នែកនៃការតម្រង់ទិសការងារ។<br>> សមាជិកម្នាក់ផ្សេងទៀតគឺជាគ្រូបង្រៀនភូមិវិទ្យា និងទទួលបានការបណ្តុះបណ្តាលឱ្យបង្រៀនសិស្សអំពីគ្រោះមហន្តរាយក្នុងមូលដ្ឋាន។<br>> សមាជិក ៤នាក់ទៀតជាអ្នកធ្វើស្រែដែលទឹកជន់លិចរៀងរាល់ ២ឆ្នាំម្តង។ ពួកគេបាត់បង់មធ្យោបាយចិញ្ចឹមជីវិតដែលពួកគេមាន ដែលបង្កឱ្យប្រឈមនឹងកង្វះស្បៀងអាហារនៅឆ្នាំនោះហើយជួនកាលបានធ្វើចំណាកស្រុកទៅស្វែងរកការងារធ្វើ។<br>> សមាជិក៤នាក់ផ្សេងទៀតបានទទួលរងការបំផ្លាញផ្ទះសម្បែងដោយសារទឹកជំនន់ក្នុងរយៈពេលបីឆ្នាំចុងក្រោយនេះហើយបានបាត់បង់ទ្រព្យសម្បត្តិរបស់ពួកគេយ៉ាងច្រើន។ ពួកគេក៏បានឈប់ធ្វើការងារកាត់ដេរនៅផ្ទះផងដែរដោយសារម៉ាស៊ីនដេរ និងវត្ថុជាតុដើមត្រូវបានបំផ្លាញ។<br>> សមាជិករបស់ក្រុម batoka ភាគច្រើនមិនចេះហែលទឹកទេ។ សមាជិកម្នាក់បានបាត់បង់ជីវិតកូនម្នាក់កាលពីឆ្នាំមុនដោយសារគាត់មិនចេះហែលទឹក ហើយកូនរបស់គាត់ត្រូវបានទឹកនាំយកទៅបាត់។<br>> សមាជិករបស់ក្រុម batoka ទាំងអស់ និងគ្រួសាររបស់ពួកគេប្រឈមនឹងកង្វះទឹកនិងប្រេងឥន្ធនៈក្នុងអំឡុងពេលទឹកជំនន់។<br>> សមាជិកទាំងអស់ត្រូវចំណាយពេល ២សប្តាហ៍នៅឯជំរុំស្តារនីតិសម្បទាក្នុងមូលដ្ឋានកាលពីឆ្នាំមុនក្រោយកើតមានព្យុះស៊ីក្លូនហើយសមាជិក២នាក់ក្នុងចំណោមពួកគេក៏បានប្រឈមនឹងការបៀតបៀនផ្លូវភេទផងដែរនៅទីជម្រកនោះ។ | > សមាជិកម្នាក់របស់ក្រុម gonka គឺជាមេភូមិ ហើយក៏មានទំនាក់ទំនងល្អជាមួយអ្នកនយោបាយក្នុងមូលដ្ឋានផងដែរ។<br>> សមាជិកម្នាក់ផ្សេងទៀតគឺជាអ្នកម៉ៅការក្នុងមូលដ្ឋានហើយទទួលបានគម្រោងនានាដូចជាការសាងសង់ច្រាំងទន្លេ ជញ្ជាំងការពារទឹកជំនន់។ល។<br>> សមាជិក ៤នាក់មានដីស្រែដែលត្រូវជន់លិចរៀងរាល់ពីឆ្នាំម្តង។ ពួកគេទទួលបានសំណងខ្លះសម្រាប់ការជន់លិចនេះ ប៉ុន្តែវាមិនគ្រប់គ្រាន់ដើម្បីគ្របដណ្តប់ការចំណាយទេ។ ពួកគេត្រូវធ្វើចំណាកស្រុកជាមួយគ្រួសាររបស់ពួកគេដើម្បីស្វែងរកការងារធ្វើ។<br>> សមាជិក ៤នាក់ផ្សេងទៀតក៏មានស្រែផ្ទាល់ខ្លួនផងដែរ ប៉ុន្តែស្រែរបស់ពួកគេមិនជន់លិចទេ។បញ្ហាគឺការស្តុកទុកស្រូវបន្ទាប់ពីប្រមូលផលហើយដោយសារមេឃភ្លៀងញឹកញាប់និងការដឹកជញ្ជូនស្រូវទៅលក់នៅផ្សារ។<br>> សមាជិក៤នាក់ផ្សេងទៀតបានទទួលរងការបំផ្លាញផ្ទះសម្បែងរបស់ពួកគេក្នុងអំឡុងពេលមានទឹកជំនន់បីលើកចុងក្រោយនេះ និងបាត់បង់ទ្រព្យសម្បត្តិជាច្រើន។<br>> ក្នុងចំណោមសមាជិកទាំងអស់ មានសមាជិកពីរនាក់មិនចេះហែលទឹក។ |

## សង្ខេបប្រវត្តិរបស់ភូមិឱ្យក្រុមទាំងពីរស្តាប់៖

មានសហគមន៍ចំនួនពីរនៅក្នុងភូមិគឺសហគមន៍ batoka និងសហគមន៍ gonka៖

- សហគមន៍ batoka មានឋានៈសង្គមទាប ហើយសហគមន៍ gonka មានឋានៈសង្គមខ្ពស់ជាង។
- សមាជិកសហគមន៍ gonka កាន់កាប់ដីទាំងអស់ ហើយសមាជិកសហគមន៍ batoka ធ្វើការងារនៅតាមវាលស្រែរបស់សមាជិកសហគមន៍ gonka។
- សមាជិកសហគមន៍ gonka គ្របដណ្តប់លើភាពជាអ្នកដឹកនាំក្នុងភូមិ និងរាល់កិច្ចប្រជុំទាំងអស់ ហើយសមាជិកសហគមន៍ batoka ជាទូទៅមិនត្រូវបានអនុញ្ញាតឱ្យនិយាយនៅក្នុងកិច្ចប្រជុំរបស់ភូមិទេ។
- សមាជិកសហគមន៍batokaក៏ខ្លាចសមាជិកសហគមន៍gonkaផងដែរដោយសារពួកគេមានភាពគ្របដណ្តប់លើខ្លួនខាងផ្នែកសង្គម និងហិរញ្ញវត្ថុ។

<Does it need a figure no.???>

**ជំហានទី៣៖** ផ្តល់ជូនពួកគេរយៈពេល ១០នាទីដើម្បីពិភាក្សា និងបញ្ចប់ការសម្តែងនេះហើយផ្តល់ពេលវេលាជូន ១៥នាទីថែមទៀតដើម្បីប្រជុំ និងសម្រេចថាតើអ្នកណានឹងជាផ្នែកនៃ VDMC និងថាតើអ្វីគឺជាកង្វល់ចំនួនបីដែល VDMC នឹងយកមកធ្វើការ។

**ជំហានទី៤៖** ប្រាប់អ្នកចូលរួមឱ្យងាកមកធ្វើការងារក្នុងក្រុមធំវិញ ហើយសួរពួកគេនូវសំណួរខាងក្រោម៖

> តើក្រុម batoka មានអារម្មណ៍យ៉ាងដូចម្តេច ហើយក្រុម gonka មានអារម្មណ៍យ៉ាងដូចម្តេច?
> តើការសម្រេចចិត្តត្រូវបានធ្វើឡើងយ៉ាងដូចម្តេច?
> តើវិធានត្រូវបានសម្រេចយ៉ាងដូចម្តេច?
> តើអ្នកណាឈ្នះហើយអ្នកណាចាញ់នៅក្នុងដំណើរការនេះ?
> តើការអភិវឌ្ឍនឹងទៅដល់សហគមន៍ទាំងពីរដែរឬទេឬតើគម្លាតនេះនឹងកាន់តែរីកធំដែរឬទេ?

**លទ្ធផលនៃការរៀនសូត្រ៖** បញ្ចប់វគ្គនេះជាមួយនឹងការចែករំលែកថា នេះគឺជាអ្វីដែលកើតឡើងនៅពេលដែលក្រុមមួយត្រូវបានគេទុកចោលឱ្យនៅក្រៅដំណើរការធ្វើសេចក្តីសម្រេចចិត្ត និងថា វាមានសារៈសំខាន់ដែលថា "បុរស ស្ត្រី ព្រមទាំងមនុស្សមកពីអត្តសញ្ញាណយេនឌ័រផ្សេងៗ ចាំបាច់ត្រូវបានរួមបញ្ចូលក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្តទាំងអស់។ការណ៍នេះមិនត្រឹមតែតម្រូវឱ្យមាននៅថ្នាក់ភូមិប៉ុណ្ណោះទេ ប៉ុន្តែនៅគ្រប់កម្រិតថ្នាក់ទាំងអស់ រួមទាំងនៅថ្នាក់ជាតិ និងថ្នាក់ពិភពលោកផងដែរ"។

## លំហាត់ទី១៤៖ការពិនិត្យករណីសិក្សាដើម្បីកំណត់តួនាទីនិងចំណុចចាប់ផ្តើមសម្រាប់អង្គការសង្គមស៊ីវិលឆ្ពោះទៅរកការបញ្ជ្រាបយេនឌ័រក្នុងគោលនយោបាយ CCDRR

គោលបំណងសំខាន់នៃលំហាត់នេះ គឺដើម្បីជួយអង្គការសង្គមស៊ីវិលឱ្យបង្កើតផែនការសកម្មភាពសម្រាប់ការបញ្ជ្រាបយេនឌ័រទៅក្នុងគោលនយោបាយ និងផែនការថ្នាក់ជាតិ និងកំណត់ភាគីពាក់ព័ន្ធសំខាន់ៗសម្រាប់កិច្ចសហប្រតិបត្តិការក្នុងដំណើរការនេះ។

**សម្ភារដែលតម្រូវឱ្យមាន៖** សំណៅឯកសារទី១១ ចំនួនច្រើនច្បាប់ ផ្ទាំងក្រដាសធំ និងប៊ិច

**ដំណើរការ៖**

**ជំហានទី១៖** បែងចែកអ្នកចូលរួមជាក្រុមដែលមានសមាជិកពី ៤ទៅ ៥នាក់ ក្នុងមួយក្រុម ហើយផ្តល់សំណៅឯកសារទី១១ ជូនពួកគេ។ ស្នើឱ្យពួកគេអានករណីសិក្សារួមគ្នា។ ផ្តល់ពេល ១៥នាទីសម្រាប់ធ្វើកិច្ចការនេះ។

**ជំហានទី២៖** ឥឡូវស្នើឱ្យពួកគេពិភាក្សាអំពីលក្ខណៈពិសេសសំខាន់ៗនៃការបញ្ជ្រាបយេនឌ័រនៅក្នុងករណីសិក្សានិងយុទ្ធសាស្ត្រទាំងនេះដែលត្រូវបានប្រើប្រាស់សម្រាប់កិច្ចការនេះ។ ផ្តល់ពេលឱ្យពួកគេ ១៥នាទីដើម្បីពិភាក្សាអំពីកិច្ចការនេះ។

**ជំហានទី៣៖** ឥឡូវស្នើឱ្យពួកគេរៀបរាប់អំពីលក្ខណៈពិសេសទាំងនេះ និងយុទ្ធសាស្ត្រនានានៅក្នុងបរិបទផ្ទាល់របស់ពួកគេ ហើយបន្ថែមការរៀនសូត្រពីវគ្គនេះ និងបទពិសោធផ្ទាល់របស់ពួកគេដើម្បីបង្កើតផែនការសកម្មភាពសម្រាប់ការចូលរួមរបស់អង្គការសង្គមស៊ីវិលក្នុងការបញ្ជ្រាបយេនឌ័រ។ បទបង្ហាញមានទម្រង់ដូចខាងក្រោម។

| គោលដៅ/ គោលបំណង | យុទ្ធសាស្ត្រ | សកម្មភាព | ភាពជាដៃគូជាមួយភាគីពាក់ព័ន្ធផ្សេងៗ |
|---|---|---|---|
| | | | |
| | | | |
| | | | |
| | | | |
| | | | |

តារាងទី១៩៖ គំរូសម្រាប់លំហាត់ទី១៤

**ជំហានទី៤៖** បិទផែនការសកម្មភាពទាំងនេះនៅលើជញ្ជាំង ហើយមើលផែនការទាំងនេះនៅពេលណាដែលត្រូវការនៅវគ្គក្រោយៗ។ អ្នកនឹងត្រូវការផែនការសកម្មភាពទាំងនេះដោយខានមិនបានដើម្បីបង្ហាញថាតើឧបករណ៍ណាមួយដែលនឹងត្រូវយកមកប្រើប្រាស់សម្រាប់

សកម្មភាពណាមួយក្នុងអំឡុងវគ្គ ក ក្នុងម៉ូឌុល ៣ ស្តីពីការបញ្ជ្រាបយេនឌ័រនៅក្នុងវដ្តគម្រោង។

**លទ្ធផលនៃការរៀនសូត្រ៖** នៅចុងបញ្ចប់នៃវគ្គនេះ អ្នកចូលរួមគួរមានក្របខ័ណ្ឌមួយដែលពួកគេអាចប្រើប្រាស់ដើម្បីកំណត់ និងបង្កើតផែនការសកម្មភាពផ្ទាល់របស់ពួកគេ។

**ធ្វើតេស្តចំណេះដឹងរបស់អ្នក**

| ចូរបំពេញសេចក្តីអធិប្បាយ | | ✓ ជ្រើសរើសចម្លើយរបស់អ្នក | | |
|---|---|---|---|---|
| ពីធីសារក្យូតូស្តីពីយន្តការទីផ្សារសម្រាប់បរិស្ថាន | | គឺជាវិធីសាស្រ្តមជ្ឈការ ដែលមិនត្រូវបានបង្កើតឡើងដើម្បីផ្តល់អត្ថប្រយោជន៍ដល់ស្ត្រី។ | | នឹងផ្តល់អត្ថប្រយោជន៍ដល់ស្ត្រីប្រសិនបើត្រូវបានអនុវត្តត្រឹមត្រូវ។ |
| ផែនការបន្សាំជាតិ (NAP) | | គឺជាដូចទៅនឹង NAPA សម្រាប់ប្រទេស LDCs ប៉ុន្តែមិនមែនជាយន្តការសម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍ផ្សេងទៀត។ | | គឺជាដំណើរការមួយដែលជំរុញឱ្យមានការរៀបចំផែនការអភិវឌ្ឍន៍ប្រទេសសម្រាប់ប្រទេស LDCs និងប្រទេសកំពុងអភិវឌ្ឍន៍។ |
| តុល្យភាពយេនឌ័រក្នុងការចូលរួម និងភាពជាអ្នកដឹកនាំមានសារៈសំខាន់ | | ពីព្រោះវាគឺជាបទប្បញ្ញត្តិរបស់ UNFCC និងមានសារៈសំខាន់សម្រាប់ប្រទេសជាតិ។ | | ពីព្រោះស្ត្រីមានសិទ្ធិធ្វើជាតំណាងខ្លួនឯង និងថ្លែងពីក្តីកង្វល់របស់ពួកគេ។ |
| ផែនការ CCDRR សមភាពយេនឌ័រគួរតែ | | ដោះស្រាយភាពងាយរងគ្រោះផ្សេងៗរបស់ស្ត្រីទៅនឹងការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ | | ដោះស្រាយបុព្វហេតុជាមូលដ្ឋានដែលបង្កឱ្យមានសមភាពយេនឌ័រនិងសង្គម។ |
| ការចូលរួមរបស់ស្ត្រីមានសារៈសំខាន់ | | ខ្លាំងនៅថ្នាក់មូលដ្ឋាន ភូមិ និងថ្នាក់ស្រុក។ | | នៅគ្រប់កម្រិតស្ថាប័នទាំងអស់។ |

## អានបន្ថែម


1. Dazé, Angie, and Julie Dekens. 2017. *A Framework for Gender-Responsive National Adaptation Plan (NAP) Processes*. NAP Global Network. Accessed July 23, 2020. https://www.weadapt.org/sites/weadapt.org/files/2017/august/napgn-en-2017-gender-considerations-adaptation-planning1.pdf.
2. Dekens, Julie, and Angie Dazé. 2019. *Conducting Gender Analysis to inform National Adaptation Plan (NAP) Processes: Reflections from six African countries*. NAP Global Network. Accessed July 23, 2020. https://www.iisd.org/system/files/publications/napgn-en-2019-conducting-gender-analysis-to-inform-nap-processes.pdf.
3. Huyer, Sophia. 2016. *Gender Equality in National Climate Action: Planning for Gender Responsive Nationally Determined Contributions*. New York: United Nations Development Programme. https://www.undp.org/content/dam/undp/library/gender/Gender%20and%20Environment/Gender_Equality_in_National_Climate_Action.pdf.
4. NAP Global Network and UNFCCC. 2019. *Toolkit for a Gender-Responsive Process to Formulate and Implement National Adaptation Plans (NAPs): Supplement to the UNFCCC Technical Guidelines for the NAP Process*. Winnipeg: International Institute for Sustainable Development. Accessed August 2020. https://www4.unfccc.int/sites/NAPC/Documents/Supplements/NAPGenderToolkit2019.pdf.
5. UNFCCC. 2019. Draft decision CP.25. *Enhanced Lima work programme on gender and its gender*. United Nations Framework Convention on Climate Change. Accessed November 2020. https://unfccc.int/sites/default/files/resource/cp2019_L03E.pdf.

## TRAINOR'S NOTES

MODULE ____ SESSION PLAN ____ PAGE ____

AGENDA

REMINDERS

# TRAINOR’S GRID NOTES

MODULE ____ SESSION PLAN ____ PAGE ____

AGENDA

REMINDERS

ការបង្កើតគោលនយោបាយ
ស្តីពី CCDRR និងផែនការថ្នាក់ជាតិ

# HANDOUTS

# ម៉ូឌុល ២៖

# 2

## ឯកសារមេរៀនទី៧៖ ក្របខ័ណ្ឌគោលនយោបាយស្តីពីការប្រែប្រួលអាកាសធាតុសកល

| ឈ្មោះ | ទិដ្ឋភាពទូទៅសង្ខេប |
|---|---|
| **កិច្ចប្រជុំកំពូលស្តីពីផែនដី** | សន្និសីទអង្គការសហប្រជាជាតិស្តីពីបរិស្ថាន និងអភិវឌ្ឍន៍ (UNCED) នៅទីក្រុងរីយ៉ូ (ឆ្នាំ១៩៩២) ដែលគេស្គាល់ថាជាកិច្ចប្រជុំកំពូលស្តីពីផែនដី គឺជាសន្និសីទមួយក្នុងចំណោមសន្និសីទដំបូងគេ និងជាប្រវត្តិសាស្ត្រនានា ដែលមានការពាក់ព័ន្ធនឹងការអភិវឌ្ឍប្រកបដោយនិរន្តរភាព។ វាគឺជាកិច្ចប្រជុំកំពូលស្តីពីផែនដី ដែលបានឈានទៅរកការដាក់ដំណើរការ ក) អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីជីវៈចម្រុះ (CBD) ខ) អនុសញ្ញាអង្គការសហប្រជាជាតិដើម្បីប្រយុទ្ធប្រឆាំងវហោស្ថានកម្ម (UNCCD) និង គ) អនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (UNFCCC)។ |
| **IPCC** | ក្រុមការងារអន្តររដ្ឋាភិបាលស្តីពីការប្រែប្រួលអាកាសធាតុ (IPCC) គឺជាស្ថាប័នរបស់អង្គការសហប្រជាជាតិទទួលបន្ទុកការវាយតម្លៃវិទ្យាសាស្ត្រដែលពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ។ ដោយត្រូវបានបង្កើតឡើងក្នុងឆ្នាំ១៩៨៨ គោលបំណងរបស់ IPCC គឺដើម្បីផ្តល់ជូនរដ្ឋាភិបាលគ្រប់កម្រិតថ្នាក់នូវព័ត៌មានបែបវិទ្យាសាស្ត្រដែលរដ្ឋាភិបាលទាំងនោះអាចប្រើប្រាស់បានដើម្បីបង្កើតគោលនយោបាយអាកាសធាតុ។របាយការណ៍វាយតម្លៃ(ARs)របស់IPCCក៏ជាធាតុចូលដ៏សំខាន់មួយផងដែរទៅក្នុងការចរចានានាអំពីការប្រែប្រួលអាកាសធាតុអន្តរជាតិ។ រហូតមកដល់បច្ចុប្បន្ន IPCC បានដាក់ជូនរបាយការណ៍វាយតម្លៃចំនួន ៥ ហើយរបាយការណ៍វាយតម្លៃទី៦ កំពុងរៀបចំធ្វើ។ |
| **UNFCCC** | ខណៈដែលកិច្ចព្រមព្រៀងបរិស្ថានពហុភាគីមួយចំនួន និងក្របខ័ណ្ឌគោលនយោបាយអន្តរជាតិផ្សេងទៀត មានការពាក់ព័ន្ធនឹងការប្រយុទ្ធប្រឆាំង និងដោះស្រាយបញ្ហានៃការប្រែប្រួលអាកាសធាតុ អនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (UNFCCC) ត្រូវបានបង្កើតឡើងដើម្បីដោះស្រាយជាពិសេសនូវបញ្ហាបន្ទាន់នៃការប្រែប្រួលអាកាសធាតុដោយគោលបំណងចុងក្រោយគឺដើម្បីរក្សាស្ថិរភាពការប្រមូលផ្តុំឧស្ម័នផ្ទះកញ្ចក់(GHG)"ឱ្យនៅកម្រិតមួយដែលនឹងបង្ការការជ្រៀតជ្រែកដោយសកម្មភាពមនុស្សដ៏គ្រោះថ្នាក់ជាមួយនឹងប្រព័ន្ធអាកាសធាតុ"។ ខណៈដែលភាគីនានាផ្តល់សច្ចាប័នដល់អនុសញ្ញានេះដូច្នេះការចូលជាធរមានឬការផ្តល់សុពលភាពដល់អនុសញ្ញានេះផ្តល់ជូនក្របខ័ណ្ឌមួយសម្រាប់វិធានការជាបន្ត។ |
| **COP** | សន្និសីទបណ្តាភាគី (COP) គឺជាស្ថាប័នធ្វើសេចក្តីសម្រេចចិត្តជាន់ខ្ពស់របស់អនុសញ្ញា UNFCCC។ COP ជួបប្រជុំរៀងរាល់ឆ្នាំចាប់ពីឆ្នាំ១៩៩៥ មក ដើម្បីពិនិត្យមើលការអនុវត្ត UNFCCC និងឧបករណ៍ច្បាប់ដែលពាក់ព័ន្ធ។ កិច្ចការសំខាន់មួយសម្រាប់ COP ក៏ដើម្បីពិនិត្យមើលទំនាក់ទំនងថ្នាក់ជាតិ និងសន្និធិការបញ្ចេញឧស្ម័នដែលត្រូវបានដាក់ជូនដោយបណ្តាភាគីផងដែរ។ បណ្តារដ្ឋទាំងអស់ដែលជាភាគីរបស់អនុសញ្ញានេះ ត្រូវមានអ្នកតំណាងនៅ COP។ |
| **ពិធីសារក្យូតូ** | ដោយសារលក្ខណៈនៃបញ្ហាប្រឈមការប្រែប្រួលអាកាសធាតុ និងតម្រូវការឱ្យមានសកម្មភាពសម្រេចចិត្ត សហគមន៍អន្តរជាតិបានបង្កើតពិធីសារក្យូតូ (KP) ដែលចងភ្ជាប់កាតព្វកិច្ចផ្នែកច្បាប់ដល់ប្រទេសអភិវឌ្ឍន៍ដែលជាហត្ថលេខីដែលទទួលខុសត្រូវជាចម្បងលើការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ដើម្បីកាត់បន្ថយការបញ្ចេញឧស្ម័នទាំងនោះ។ រយៈពេលប្តេជ្ញាចិត្តលើកទីមួយនៃពិធីសារក្យូតូ គឺពីឆ្នាំ ២០០៨ ដល់ឆ្នាំ២០១២ ហើយរយៈពេលប្តេជ្ញាចិត្តលើកទី២ គឺពីឆ្នាំ២០១៣ ដល់ឆ្នាំ២០២០។ ពិធីសារក្យូតូបានប្រែក្លាយឧស្ម័នផ្ទះកញ្ចក់ (GHGs) ទៅជាទំនិញដែលអាចជួញដូរបាន។ ខណៈដែលប្រទេសនានាត្រូវតែសម្រេចបានទិសដៅកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់របស់ខ្លួន ដែលធ្វើឡើងជាចម្បងតាមរយៈការវាស់វែងថ្នាក់ជាតិ ពិធីសារក្យូតូបានដាក់ចេញយន្តការទីផ្សារដែលមានភាពបត់បែនចំនួនបី ដែលអនុញ្ញាតឱ្យប្រទេសនានាសម្រេចបានទិសដៅរបស់ពួកគេ តាមរយៈការលើកទឹកចិត្តឱ្យកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ដែលចំណាយមានប្រសិទ្ធភាពបំផុតឧទាហរណ៍ដូចក្នុងប្រទេសកំពុងអភិវឌ្ឍន៍ជាដើម។ គោលបំណងគឺដើម្បីកាត់បន្ថយការបញ្ចេញឧស្ម័នជារួមពីបរិយាកាសរបស់ផែនដី ខណៈដែលជំរុញកំណើនសេដ្ឋកិច្ចប្រកបដោយនិរន្តរភាព និងការផ្ទេរបច្ចេកវិទ្យាក្នុងប្រទេសកំពុងអភិវឌ្ឍន៍។ |

## ឯកសារមេរៀនទី៧៖ ក្របខ័ណ្ឌគោលនយោបាយស្តីពីការប្រែប្រួលអាកាសធាតុសកល

| ឈ្មោះ | ទិដ្ឋភាពទូទៅសង្ខេប |
|---|---|
| | យន្តការពិធីសារក្យូតូទាំងបីរួមមាន៖<br><br>»¤ ការជួញដូរការបញ្ចេញឧស្ម័ន<br>»¤ យន្តការអភិវឌ្ឍន៍ស្អាត (CDM)<br>»¤ ការអនុវត្តរួមគ្នា (JI)<br>យន្តការទាំងនេះគឺជាផ្នែកនៃអ្វីដែលត្រូវបានគេស្គាល់ថាជាទីផ្សារកាបូន។ |
| ផែនការសកម្មភាពទីក្រុងបាលី | សំណួរមួយក្នុងចំណោមសំណួរចម្បងៗដែលក្រុមអ្នកចរចាអាកាសធាតុកំពុងប្រឈមខណៈដែលរយៈពេលប្តេជ្ញាចិត្តលើកទី១ គ្រោងនឹងបិទបញ្ចប់នៅឆ្នាំ២០១២ គឺរបៀបផ្លាស់ប្តូរស្ថាបត្យកម្មនៃកិច្ចព្រមព្រៀងការប្រែប្រួលអាកាសធាតុអន្តរជាតិ ដើម្បីរួមបញ្ចូលប្រទេសកំពុងអភិវឌ្ឍន៍ដែលមិនស្ថិតក្នុងឧបសម្ព័ន្ធ១ ប៉ុន្តែគ្មានការចងភ្ជាប់កាតព្វកិច្ចប្រទេសទាំងនោះទៅនឹងទិសដៅមជ្ឈការ និងកាលវិភាគនានា ដែលអាចធ្វើឱ្យការអភិវឌ្ឍយឺតយ៉ាវ។ ចម្លើយចំពោះសំណួរនេះ បានកើតចេញពីការចរចានានានៅ COP លើកទី១៣ ក្នុងទីក្រុងប៉ារីស ប្រទេសឥណ្ឌូនេស៊ី។ ផែនការសកម្មភាពទីក្រុងបាលីដែលជាកិច្ចព្រមព្រៀងសំខាន់កើតចេញពីCOPលើកទី១៣បានរួមបញ្ចូលបទប្បញ្ញត្តិនានាដែលបានអំពាវនាវឱ្យភាគីប្រទេសកំពុងអភិវឌ្ឍន៍ចាត់សកម្មភាពជាតិកាត់បន្ថយសមស្រប(NAMAs)ក្នុងបរិបទអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពជាថ្នូរនឹងហិរញ្ញវត្ថុបច្ចេកវិទ្យា និងការកសាងសមត្ថភាពក្នុងលក្ខណៈដែលអាចវាស់វែងបាន អាចរាយការណ៍បាន និងអាចផ្ទៀងផ្ទាត់បាន។ ផែនការសកម្មភាពទីក្រុងបាលីក៏បង្ហាញពីចំណុចរបត់ដ៏ធំមួយផងដែរនៅក្នុងការចរចា UNFCCC ជាមួយនឹងការផ្លាស់ប្តូរពីវិធីសាស្ត្រមជ្ឈការបច្ចេកវិទ្យាទៅជាវិធីសាស្ត្រវិមជ្ឈការ។ |
| កិច្ចព្រមព្រៀងទីក្រុងប៉ារីស | កិច្ចព្រមព្រៀងទីក្រុងប៉ារីស (ឆ្នាំ២០១៥) គឺជាកិច្ចព្រមព្រៀងបរិស្ថានដ៏សំខាន់មួយដែលត្រូវបានអនុម័តដោយស្ទើរតែគ្រប់ប្រទេសទាំងអស់ក្នុងឆ្នាំ២០១៥ដើម្បីដោះស្រាយការប្រែប្រួលអាកាសធាតុ និងផលប៉ះពាល់អវិជ្ជមានរបស់វា។ កិច្ចព្រមព្រៀងនេះមានបំណងកាត់បន្ថយប្រកបដោយនិរន្តរភាពនូវការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ នៅទូទាំងពិភពលោកនៅក្នុងកិច្ចប្រឹងប្រែងមួយ ដើម្បីកំណត់ការកើនឡើងសីតុណ្ហភាពពិភពលោកនៅក្នុងសតវត្សរ៍នេះត្រឹម២អង្សាសេលើកកម្រិតមុនឧស្សាហកម្មខណៈពេលដែលស្វែងរកមធ្យោបាយនានាដើម្បីដាក់កម្រិតដល់កំណើនសីតុណ្ហភាពនៅត្រឹម ១,៥ដឺក្រេ។ កិច្ចព្រមព្រៀងនេះ រួមបញ្ចូលទាំងការប្តេជ្ញាចិត្តនានាមកពីប្រទេសដែលបញ្ចេញឧស្ម័នធំៗទាំងអស់ដើម្បីកាត់បន្ថយការបំពុលដែលបង្កឱ្យផ្លាស់ប្តូរអាកាសធាតុនិងដើម្បីពង្រឹងការប្តេជ្ញាចិត្តទាំងនោះទៅតាមពេលវេលា។ កិច្ចព្រមព្រៀងទីក្រុងប៉ារីស ផ្តល់ផ្លូវមួយសម្រាប់ប្រទេសអភិវឌ្ឍន៍ ដើម្បីជួយប្រទេសកំពុងអភិវឌ្ឍន៍ក្នុងកិច្ចប្រឹងប្រែងកាត់បន្ថយ និងបន្សាំនឹងអាកាសធាតុរបស់ប្រទេសទាំងនោះ ហើយកិច្ចព្រមព្រៀងនេះបង្កើតក្របខ័ណ្ឌមួយសម្រាប់ការតាមដានប្រកបដោយតម្លាភាព ការរាយការណ៍ និងការបង្កើនគោលដៅអាកាសធាតុបុគ្គលនិងសមូហភាពរបស់ប្រទេសទាំងនោះ។នៅពេលបច្ចុប្បន្នប្រទេសចំនួន១៩៧ បានអនុម័តកិច្ចព្រមព្រៀងទីក្រុងប៉ារីស។ |
| ក្របខ័ណ្ឌការងារ Hyogo | ក្របខ័ណ្ឌការងារ Hyogo ដើម្បីសកម្មភាព (HFA) ឆ្នាំ២០០៥ ត្រូវបានបង្កើតឡើងនៅសន្និសីទពិភពលោកស្តីពីការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ (DRR)។ក្របខ័ណ្ឌការងារនេះផ្តល់គោលការណ៍ណែនាំ និងផែនការលម្អិត ដើម្បីកាត់បន្ថយភាពងាយរងគ្រោះទៅនឹងគ្រោះថ្នាក់ធម្មជាតិ តាមរយៈផែនការសកម្មភាពរយៈពេល ១០ឆ្នាំមួយ។ HFA បានជួយដល់កិច្ចប្រឹងប្រែងរបស់ប្រទេស និងសហគមន៍នានាដើម្បីឱ្យមានភាពធន់ និងដោះស្រាយកាន់តែប្រសើរជាមួយនឹងមុខសញ្ញាគ្រោះថ្នាក់ ដែលគំរាមកំហែងដល់កំណើនអភិវឌ្ឍន៍របស់ពួកគេ។ |

## ឯកសារមេរៀនទី៧៖ ក្របខ័ណ្ឌគោលនយោបាយស្ដីពីការប្រែប្រួលអាកាសធាតុសកល

| ឈ្មោះ | ទិដ្ឋភាពទូទៅសង្ខេប |
|---|---|
| **ក្របខ័ណ្ឌការងារទីក្រុងសេនដៃ** | ក្របខ័ណ្ឌការងារទីក្រុងសេនដៃសម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ឆ្នាំ២០១៥-២០៣០ ត្រូវបានអនុម័តដោយរដ្ឋសមាជិករបស់អង្គការសហប្រជាជាតិនៅថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៥នៅសន្និសីទពិភពលោកអង្គការសហប្រជាជាតិស្ដីពីការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ។ ក្របខ័ណ្ឌការងារនេះមានបំណងសម្រេចបានការកាត់បន្ថយប្រកបដោយនិរន្តរភាពនូវហានិភ័យគ្រោះមហន្តរាយ និងការបាត់បង់ជីវិត របរចិញ្ចឹមជីវិត និងសុខភាព និងការបាត់បង់ទ្រព្យសម្បត្តិសេដ្ឋកិច្ច រូបវន្ត សង្គម វប្បធម៌ និងបរិស្ថានរបស់បុគ្គល ក្រុមហ៊ុនអាជីវកម្ម សហគមន៍ និងប្រទេសនានានៅក្នុងរយៈពេល ១៥ឆ្នាំខាងមុខ។ ក្របខ័ណ្ឌការងារទីក្រុងសេនដៃ គឺជាកិច្ចព្រមព្រៀងចម្បងទីមួយនៃរបៀបវារៈអភិវឌ្ឍន៍ក្រោយឆ្នាំ២០១៥ ដោយមានទិសដៅចំនួន៧ និងអាទិភាពចំនួន៤ សម្រាប់ការចាត់សកម្មភាព។ |
| **NAPs** | ដំណើរការផែនការជាតិបន្សាំ (NAP) ជួយប្រទេសនានាឱ្យអនុវត្តការរៀបចំផែនការបន្សាំរយៈពេលមធ្យម និងរយៈពេលវែងទូលំទូលាយ។ ផែនការសកម្មភាពនេះគឺជាដំណើរការប្រកបដោយភាពបត់បែនមួយ ដែលមានមូលដ្ឋានលើសកម្មភាពបន្សាំដែលមានស្រាប់របស់ប្រទេសនីមួយៗ និងជួយធ្វើសមាហរណកម្មការប្រែប្រួលអាកាសធាតុទៅក្នុងការធ្វើសេចក្ដីសម្រេចចិត្តថ្នាក់ជាតិ។បណ្ដាភាគីរបស់ UNFCCC បានបង្កើតដំណើរការ NAP ក្នុងឆ្នាំ២០១១ ក្នុងទីក្រុង Durban។ |
| **NAPAs** | លទ្ធផលរបស់សន្និសីទបណ្ដាភាគីលើកទី៧ (COP7) ក្នុងទីក្រុង Marrakech បានរួមបញ្ចូលកិច្ចព្រមព្រៀងមួយដែលប្រទេសអភិវឌ្ឍន៍តិចតួច (LDCs) នឹងបង្កើតកម្មវិធីសកម្មភាពជាតិបន្សាំនឹងការប្រែប្រួលអាកាសធាតុ (NAPAs)។ កម្មវិធី NAPAs ផ្ដល់ជូនដំណើរការមួយសម្រាប់ប្រទេសអភិវឌ្ឍន៍តិចតួច ដើម្បីកំណត់សកម្មភាពអាទិភាពនានាដែលឆ្លើយតបទៅនឹងតម្រូវការបន្ទាន់ និងភ្លាមៗរបស់ប្រទេសទាំងនេះ ទាក់ទងនឹងការបន្សាំនឹងអាកាសធាតុ ពោលគឺតម្រូវការទាំងនោះប្រសិនបើមានការពន្យាពេលក្នុងការដោះស្រាយអាចបង្កើនភាពងាយរងគ្រោះឬឈានទៅរកការកើនឡើងការចំណាយនៅដំណាក់កាលក្រោយមក។ |
| **NDCs** | ប្រទេសចំនួន១៨៦ ដែលទទួលខុសត្រូវជាង ៩០ភាគរយនៃការបញ្ចេញឧស្ម័នផ្ទះកញ្ចក់នៅទូទាំងពិភពលោក បានដាក់ជូនទិសដៅកាត់បន្ថយកាបូន ដែលហៅថា "ការចូលរួមចំណែកដើម្បីអនុវត្តអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្ដីពីការប្រែប្រួលអាកាសធាតុ (INDCs)" មុនពេលមានសន្និសីទទីក្រុងប៉ារីស។ ទិសដៅទាំងនេះមានចែងអំពីការប្ដេជ្ញាចិត្តរបស់ប្រទេសនីមួយៗចំពោះការកាត់បន្ថយការបញ្ចេញឧស្ម័ន (រួមទាំងតាមរយៈការអភិរក្សអាងស្រូបកាបូន) រហូតដល់ឆ្នាំ២០២៥ ឬឆ្នាំ២០៣០ រួមទាំងគោលដៅកាត់បន្ថយកាបូននៅទូទាំងសេដ្ឋកិច្ច និងការប្ដេជ្ញាចិត្តជាលក្ខណៈបុគ្គលរបស់ទីក្រុងប្រហែល ២.២៥០ និងក្រុមហ៊ុនចំនួន ២.០២៥។ |
| **NAMAs** | យោងតាមកិច្ចព្រមព្រៀងទីក្រុង Copenhagen ដែលជាលទ្ធផលគ្មានការប្ដេជ្ញាចិត្តនៃសន្និសីទបណ្ដាភាគីលើកទី១៥ ក្នុងឆ្នាំ២០០៩ សកម្មភាពជាតិកាត់បន្ថយសមស្រប (NAMAs) ត្រូវបានកំណត់ដោយបណ្ដាភាគីប្រទេសកំពុងអភិវឌ្ឍន៍របស់ UNFCCC ហើយ "នឹងត្រូវបានកត់ត្រានៅក្នុងបញ្ជីឈ្មោះមួយ រួមជាមួយការគាំទ្រផ្នែកបច្ចេកវិទ្យា ហិរញ្ញវត្ថុ និងការកសាងសមត្ថភាពដែលពាក់ព័ន្ធ"។ |
| **LWPG** | ក្នុងឆ្នាំ២០១៤សន្និសីទបណ្ដាភាគី (COP) នៃអនុសញ្ញាUNFCCCបានអនុម័តកម្មវិធីការងារក្រុងលីម៉ាស្ដីពីយេនឌ័រ (LWPG) ដែលបានបង្កើតផែនការមួយសម្រាប់ "ការលើកកម្ពស់តុល្យភាពយេនឌ័រ និងការសម្រេចគោលនយោបាយអាកាសធាតុដែលឆ្លើយតបនឹងតម្រូវការយេនឌ័រដែលត្រូវបានបង្កើតឡើងសម្រាប់គោលបំណងណែនាំការចូលរួមប្រកបដោយប្រសិទ្ធភាពរបស់ស្ត្រីក្នុងស្ថាប័ននានាដែលត្រូវបានបង្កើតឡើងស្ថិតក្រោមអនុសញ្ញានេះ"។ |

## ឯកសារមេរៀនទី៧៖ ក្របខ័ណ្ឌគោលនយោបាយស្តីពីការប្រែប្រួលអាកាសធាតុសកល

| ឈ្មោះ | ទិដ្ឋភាពទូទៅសង្ខេប |
|---|---|
| **សន្និសីទបណ្តាភាគីស្តីពីយេនឌ័រ (Gender COP)** | ជួនកាលត្រូវបានគេហៅថា "Gender COP" ដោយសារបញ្ហាយេនឌ័រទទួលបានការចាប់អារម្មណ៍ខ្លាំង សន្និសីទបណ្តាភាគីលើកទី១៨ (COP18) ក្នុងឆ្នាំ២០១២ បានបង្កើតសេចក្តីសម្រេចចិត្តមួយដែលលើកកម្ពស់តុល្យភាពយេនឌ័រ ការចូលរួមរបស់ស្ត្រី និងផ្សេងៗទៀត ដែលបានអំពាវនាវឱ្យមានសិក្ខាសាលាបច្ចេកទេសក្នុងវគ្គស្តីពីបញ្ហាយេនឌ័រសម្រាប់ឆ្នាំបន្ទាប់។ |

ប្រភព៖ (គេហទំព័ររបស់ UNFCC)

## ឯកសារមេរៀនទី៨៖ ការអនុវត្តក្របខ័ណ្ឌ CCDRR សកលដែលមានទស្សនៈយេនឌ័រ

**ផ្នែក ក៖ UNFCCC**

| វិស័យសកម្មភាពក្របខ័ណ្ឌ | ចំណុចសំខាន់ៗសម្រាប់សកម្មភាព ថ្នាក់ជាតិដែលត្រូវធ្វើដើម្បីបង្កើតកិច្ចការនេះ[6] | សកម្មភាពជាក់ស្តែងដែលត្រូវបានអនុវត្តនៅកម្រិតប្រទេស |
|---|---|---|
| ពង្រឹងកិច្ចប្រឹងប្រែងការកសាងសមត្ថភាពសម្រាប់រដ្ឋាភិបាល និងភាគីពាក់ព័ន្ធផ្សេងៗក្នុងការបញ្ជ្រាបយេនឌ័រទៅក្នុងការបង្កើត ការតាមដាន ការអនុវត្ត និងការពិនិត្យគោលនយោបាយ និងផែនការប្រែប្រួលអាកាសធាតុថ្នាក់ជាតិ។ | > បង្កើតក្រុមការងារយេនឌ័រ នៅស្ថាប័នបណ្តះបណ្តាល CCDRR ថ្នាក់ជាតិ និងថ្នាក់មូលដ្ឋានទាំងអស់។<br>> បែងចែកមូលនិធិសម្រាប់ការកសាងសមត្ថភាពអំពីយេនឌ័រ និង CCDRR។ | |
| បញ្ចូលក្រុមដែលផ្តោតលើស្ត្រី និងស្ថាប័នស្ត្រីនិងយេនឌ័រថ្នាក់ជាតិក្នុងដំណើរការបង្កើត ការអនុវត្ត និងការធ្វើបច្ចុប្បន្នភាពគោលនយោបាយ ផែនការ យុទ្ធសាស្ត្រ និងសកម្មភាពអាកាសធាតុ។ | > បង្កើតផ្លែតហ្វម និងវេទិកាស្ថាប័នសម្រាប់ការចូលរួមរបស់ក្រុមដែលផ្តោតលើស្ត្រី។<br>> រៀបចំសិក្ខាសាលា និងសិក្ខាសាលាតាមអ៊ីនធឺណិតសម្រាប់ការពិគ្រោះយោបល់ជាមួយក្រុមដែលផ្តោតលើស្ត្រី។ | |
| ពង្រឹងសមត្ថភាពដើម្បីប្រមូល វិភាគ និងអនុវត្តទិន្នន័យបែងចែកតាមភេទនិងការវិភាគយេនឌ័រក្នុងបរិបទនៃការប្រែប្រួលអាកាសធាតុ។ | > ពិនិត្យមើលយន្តការប្រមូលទិន្នន័យបច្ចុប្បន្នសម្រាប់ការធ្វើសមាហរណកម្ម SADDD។ | |
| ពង្រឹងភាពអាចរកបានទិន្នន័យបែងចែកតាមភេទសម្រាប់ការវិភាគយេនឌ័រ។ | > បង្កើតបទប្បញ្ញត្តិច្បាប់/គោលនយោបាយសម្រាប់ការធានាភាពអាចរកបាន SADDD។<br>> រៀបចំធ្វើការអង្កេតថ្មីៗសម្រាប់ការប្រមូល SADDD។ | |
| ពង្រឹងមូលដ្ឋានភស្តុតាងនិងការយល់ដឹងអំពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុដែលមានភាពគ្នាចំពោះបុរសនិងស្រីនិងតួនាទីរបស់ស្ត្រីក្នុងនាមជាភ្នាក់ងារនៃការផ្លាស់ប្តូរ និងផលប៉ះពាល់ទៅលើឱកាសសម្រាប់ស្ត្រី។ | > រៀបចំការសិក្សាស្រាវជ្រាវអំពីវិសាលភាពយេនឌ័រក្នុងវិស័យផ្សេងៗ។<br>> បង្កើតផ្លែតហ្វមចំណេះដឹងសម្រាប់ការផ្ទៀងផ្ទាត់ និងការផ្តល់សុពលភាពដល់ការសិក្សាដែលមានស្រាប់ និងមូលដ្ឋានភស្តុតាងដែលត្រូវបានបង្កើតឡើងនៅថ្នាក់ជាតិ។ | |
| លើកកម្ពស់ការប្រើប្រាស់បណ្តាញទំនាក់ទំនងសង្គមធនធានគេហទំព័រនិងឧបករណ៍ទំនាក់ទំនងប្រកបដោយភាពច្នៃប្រឌិតដើម្បីផ្សព្វផ្សាយប្រកបដោយប្រសិទ្ធភាពអំពីផែនការសកម្មភាពយេនឌ័រ និងសមភាពយេនឌ័រទៅកាន់សាធារណៈជន ជាពិសេសទៅដល់ស្ត្រី។ | > អនុវត្តយុទ្ធនាការIECស្តីពីយេនឌ័រនិងការប្រែប្រួលអាកាសធាតុតាមរយៈការប្រើប្រាស់បណ្តាញទំនាក់ទំនងសង្គមរួមទាំងសិល្បៈប្រពៃណីរបស់អ្នកស្រុក និងវិទ្យុសហគមន៍។ | |

## ឯកសារមេរៀនទី៨៖ ការអនុវត្តក្របខ័ណ្ឌ CCDRR សកលដែលមានទស្សនៈយេនឌ័រ

| វិស័យសកម្មភាពក្របខ័ណ្ឌ | ចំណុចសំខាន់ៗសម្រាប់សកម្មភាព ថ្នាក់ជាតិ ដែលត្រូវធ្វើដើម្បីបង្កើតកិច្ចការនេះ[6] | សកម្មភាពជាក់ស្តែងដែលត្រូវបានអនុវត្ត នៅកម្រិតប្រទេស |
|---|---|---|
| ការកសាងសមត្ថភាពរបស់គណៈប្រតិភូស្ត្រីអំពីភាពជាអ្នកដឹកនាំ ការចរចា និងការសម្របសម្រួល ដើម្បីពង្រឹងការចូលរួមរបស់ស្ត្រី។ | > គាំទ្រសកម្មភាពដំណាក់កាលរៀបចំ សិក្ខាសាលាមុនការពិគ្រោះយោបល់។ល។ រួមទាំងតាមរយៈសិក្ខាសាលាតាមអ៊ីនធឺណិត និងការបណ្តុះបណ្តាលក្នុងវគ្គ។ | |
| លើកកម្ពស់មូលនិធិសម្រាប់ធ្វើដំណើរសម្រាប់ជាមធ្យោបាយដើម្បីគាំទ្រដល់ការចូលរួមដោយស្មើភាពរបស់ស្ត្រីនិងជនជនដើមភាគតិចក្នុងគណៈប្រតិភូថ្នាក់ជាតិទាំងអស់នៅវគ្គ UNFCCC។ | > ផ្តល់មូលនិធិសម្រាប់ធ្វើដំណើរនៅថ្នាក់ជាតិ ដើម្បីគាំទ្រដល់ការចូលរួមសូម្បីតែក្នុងការពិគ្រោះយោបល់ថ្នាក់ជាតិ។<br>> រៀបចំកិច្ចសន្ទនាដើម្បីពិភាក្សាអំពីការពន្លឿនភាពជាអ្នកដឹកនាំរបស់សហគមន៍ក្នុងមូលដ្ឋាន និងស្ត្រី។ | |
| ពង្រឹងការសម្របសម្រួលអំពីយេនឌ័ររវាងស្ថាប័ននានាដែលស្ថិតក្រោមកិច្ចព្រមព្រៀងទីក្រុងប៉ារីស និងអង្គភាពដែលពាក់ព័ន្ធផ្សេងទៀត ជាពិសេសរបៀបវារៈអភិវឌ្ឍន៍ប្រកបដោយចីរភាពឆ្នាំ២០៣០។ | > គាំទ្របាយការណ៍ស្រមោលអំពីយេនឌ័រ និងការប្រែប្រួលអាកាសធាតុធ្វើជាផ្នែកនៃការរាយការណ៍ថ្នាក់ជាតិអំពី CEDAW និង SDG។ | |
| ចែករំលែកបទពិសោធ និងគាំទ្រការកសាងសមត្ថភាពអំពីការរៀបចំថវិកាដែលឆ្លើយតបនឹងតម្រូវការយេនឌ័រ (GRB)។ | > បង្កើតស្ថាប័ន GRB នៅថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងថ្នាក់មូលដ្ឋាន និងពង្រីកវិសាលភាពទៅកាន់ហិរញ្ញវត្ថុអាកាសធាតុអន្តរជាតិ។<br>> ផ្តល់មូលនិធិសម្រាប់ការកសាងសមត្ថភាព និងការស្រាវជ្រាវអំពី GRB។<br>> បញ្ចូលក្រុមដែលផ្តោតលើស្ត្រីឱ្យធ្វើជាអ្នកជំនាញសម្រាប់ GRB នៅក្នុងក្រសួងបច្ចេកទេស។ | |
| បង្កើនការយល់ដឹងអំពីការគាំទ្រហិរញ្ញវត្ថុ និងបច្ចេកទេសដែលមានសម្រាប់ការលើកកម្ពស់ការពង្រឹងការធ្វើសមាហរណកម្មយេនឌ័រទៅក្នុងគោលនយោបាយអាកាសធាតុ។ | > ចេញផ្សាយលំហូរមូលនិធិអាកាសធាតុនៅក្នុងប្រទេសទាំងអស់នៅក្នុងវេទិកាមួយ។<br>> កំណត់ផែនទីក្របខ័ណ្ឌអភិបាលកិច្ចហិរញ្ញវត្ថុអាកាសធាតុរបស់ប្រទេស និងបង្កើតប្រព័ន្ធចូលយកទិន្នន័យអនឡាញ។ | |
| បង្កើនការយល់ដឹងអំពីការអនុវត្តល្អដើម្បីសម្របសម្រួលការទទួលបានហិរញ្ញវត្ថុអាកាសធាតុសម្រាប់អង្គការដែលផ្តោតលើស្ត្រីនៅមូលដ្ឋាននិងជនជាតិដើមភាគតិច និងសហគមន៍មូលដ្ឋាន។ | > បង្កើតសៀវភៅណែនាំដែលមានភាពសាមញ្ញសម្រាប់ប្រព័ន្ធចូលយកមូលនិធិ។<br>> សិក្ខាសាលាសម្រាប់អង្គការមិនមែនរដ្ឋាភិបាលស្តីពីការបង្កើតសំណើសម្រាប់ការប្រែប្រួលអាកាសធាតុ និងស្តីពីយន្តការរៃអង្គាសមូលនិធិ<br>> ចេញផ្សាយករណីសិក្សាអំពីការអនុវត្តដែលមានស្រាប់។ | |
| លើកកម្ពស់ការដាក់ពង្រាយដំណោះស្រាយបច្ចេកវិទ្យាដែលមានការឆ្លើយតបនឹងយេនឌ័រដើម្បីដោះស្រាយការប្រែប្រួលអាកាសធាតុ។ | > កំណត់ និងចេញផ្សាយករណីសិក្សាអំពីដំណោះស្រាយលើកស្ទួយយេនឌ័រ។<br>> បង្កើតប្រព័ន្ធសម្រាប់ផ្តល់សុពលភាព និងការបញ្ជាក់ពីការបង្កើតទស្សនទាននៃដំណោះស្រាយក្នុងមូលដ្ឋាន។ | |

## ឯកសារមេរៀនទី៨៖ ការអនុវត្តក្របខ័ណ្ឌ CCDRR សកលដែលមានទស្សនៈយេនឌ័រ

| វិស័យសកម្មភាពក្របខ័ណ្ឌ | ចំណុចសំខាន់ៗសម្រាប់សកម្មភាព ថ្នាក់ជាតិដែលត្រូវធ្វើដើម្បីបង្កើតកិច្ចការនេះ[6] | សកម្មភាពជាក់ស្តែងដែលត្រូវបានអនុវត្តនៅកម្រិតប្រទេស |
|---|---|---|
| ជំរុញឱ្យមានការចូលរួមពេញលេញរបស់ស្ត្រី និងកុមារី និងភាពជាអ្នកដឹកនាំក្នុងវិទ្យាសាស្ត្រ បច្ចេកវិទ្យា ការស្រាវជ្រាវ និងការអភិវឌ្ឍពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ។ | > ផ្តល់មូលនិធិដល់កម្មវិធីសម្រាប់ការសាកល្បងការបង្កើតរួមគ្នានូវដំណោះស្រាយជាមួយអ្នកស្រាវជ្រាវ សហគមន៍ និងអ្នកផ្តល់សេវាឯកជន។ | |
| គាំទ្រការប្រមូល និងការរួមបញ្ចូលគ្នានូវព័ត៌មាន និងជំនាញយេនឌ័រ និងការប្រែប្រួលអាកាសធាតុក្នុងវិស័យនានា និងវិស័យប្រធានបទ។ | > កំណត់ និងបង្កើតអ្នកជំនាញយេនឌ័រ និងការប្រែប្រួលអាកាសធាតុនៅថ្នាក់ជាតិ។<br>> លើកកម្ពស់ផ្លែតហ្វមចំណេះដឹងអំពីយេនឌ័រ និងការប្រែប្រួលអាកាសធាតុ។ | |
| ពង្រឹងការតាមដាន និងការរាយការណ៍អំពីស្ត្រីក្នុងមុខតំណែងជាអ្នកដឹកនាំនៅក្នុងដំណើរការ UNFCCC | > ចេញផ្សាយស្ថិតិថ្នាក់ជាតិស្តីពីសមាសភាពយេនឌ័រក្នុងគណៈប្រតិភូអន្តរជាតិ និងការចរចា/ការពិគ្រោះយោបល់អំពីអាកាសធាតុថ្នាក់ជាតិ។ | |
| តាមដាន និង រាយការណ៍អំពីការអនុវត្តគោលនយោបាយ ផែនការ យុទ្ធសាស្ត្រ និងសកម្មភាពដែលឆ្លើយតបនឹងតម្រូវការយេនឌ័រ។ | > ចេញផ្សាយវឌ្ឍនភាពការត្រួតពិនិត្យ គោលបំណងយេនឌ័រនៅក្នុងគោលនយោបាយ និងផែនការអាកាសធាតុថ្នាក់ជាតិដែលធ្វើឡើងពីរដងក្នុងមួយឆ្នាំ។ | |
| ប្រភព៖ (UNFCCC ឆ្នាំ២០១៩) | | |
| **ផ្នែកខ៖ ក្របខ័ណ្ឌការងារទីក្រុងសេនដៃ** | | |
| ការប្រមូល ការវិភាគ ការប្រើប្រាស់ និងការផ្សព្វផ្សាយទិន្នន័យដែលពាក់ព័ន្ធដោយពិចារណាលើតម្រូវការនៃប្រភេទផ្សេងៗរបស់អ្នកប្រើប្រាស់ | > ទិន្នន័យទាំងអស់គួរត្រូវបានបែងចែកតាមភេទ និងអាយុ។<br>> ស្វែងយល់ពីឧបសគ្គវប្បធម៌នៃការគ្រប់គ្រងគ្រោះមហន្តរាយក្នុងសង្គម។<br>> តម្រូវការរបស់ស្ត្រី និងកុមារីក្នុងអំឡុងគ្រោះមហន្តរាយ គួរត្រូវបានរាប់បញ្ចូល។ | |
| វាយតម្លៃជាលក្ខណៈប្រព័ន្ធកត់ត្រាចែករំលែកនិងពន្យល់ជាសាធារណៈលើការខាតបង់ដោយសារគ្រោះមហន្តរាយ និងស្វែងយល់អំពីផលប៉ះពាល់សេដ្ឋកិច្ច សង្គម សុខភាព ការអប់រំ។ល។ | > រាប់បញ្ចូលការមិនមានពេលវេលាផ្ទាល់ខ្លួនរបស់ស្ត្រី ដែលបណ្តាលមកពីការកើនឡើងតួនាទី និងការងារក្នុងផ្ទះ និងតួនាទីថែទាំ។<br>> រាប់បញ្ចូលការខាតបង់ប្រាក់ចំណូលរបស់ស្ត្រីពីប្រភពក្រៅផ្លូវការ ដូចជាការងារធ្វើនៅផ្ទះ ការចិញ្ចឹមមាន់នៅទីធ្លាក្រោយផ្ទះ ការចិញ្ចឹមពពែ។ល។ | |
| ចំណេះដឹង និងការកសាងសមត្ថភាពរបស់មន្ត្រីរដ្ឋាភិបាលនៅគ្រប់កម្រិតថ្នាក់ សង្គមស៊ីវិល សហគមន៍ និងអ្នកស្ម័គ្រចិត្ត។ | > សកម្មភាពបណ្តុះបណ្តាល និងការកសាងសមត្ថភាពទាំងអស់ គួររួមបញ្ចូលការធ្វើឱ្យមានរំញោចយេនឌ័រ។<br>> ផលិតផលចំណេះដឹងទាំងអស់គួរមានការវិភាគយេនឌ័រ។ | |
| លើកកម្ពស់យុទ្ធសាស្ត្រជាតិ ដើម្បីពង្រឹងការអប់រំ និងការយល់ដឹងសាធារណៈអំពីការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ | > ការយល់ដឹងជាសាធារណៈគួរត្រូវបានពិចារណាអំពីតម្រូវការជាក់លាក់របស់ស្ត្រី ជាពិសេសចាស់ជរា អ្នកមិនចេះអក្សរ និងជនពិការ | |

## ឯកសារមេរៀនទី៨៖ ការអនុវត្តក្របខ័ណ្ឌ CCDRR សកលដែលមានទស្សនៈយេនឌ័រ

| វិស័យសកម្មភាពក្របខ័ណ្ឌ | ចំណុចសំខាន់ៗសម្រាប់សកម្មភាព ថ្នាក់ជាតិ ដែលត្រូវធ្វើដើម្បីបង្កើតកិច្ចការនេះ[6] | សកម្មភាពជាក់ស្តែងដែលត្រូវបានអនុវត្ត នៅកម្រិតប្រទេស |
|---|---|---|
| | ជាពិសេសអ្នកអ្នកដែលមានបញ្ហាភ្នែក និង ត្រចៀក។ | |
| ដើម្បីចាត់តាំងតួនាទី និងកិច្ចការច្បាស់លាស់ទៅកាន់អ្នកតំណាងរបស់សហគមន៍នៅក្នុងស្ថាប័ននិងដំណើរការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយនិងការធ្វើសេចក្តីសម្រេចចិត្តតាមរយៈក្របខ័ណ្ឌច្បាប់ដែលពាក់ព័ន្ធ។ | > ស្ត្រីគួរជាផ្នែកនៃកិច្ចប្រជុំ និងគណៈកម្មាធិការគ្រប់គ្រង (ហានិភ័យ) គ្រោះមហន្តរាយទាំងអស់នៅគ្រប់កម្រិតថ្នាក់របស់រដ្ឋាភិបាល។ | |
| អនុវត្តការពិគ្រោះយោបល់ជាសាធារណៈ និងនៅសហគមន៍ឱ្យបានទូលំទូលាយក្នុងអំឡុងពេលបង្កើតច្បាប់និងបទប្បញ្ញត្តិ ដើម្បីគាំទ្រដល់ការអនុវត្តច្បាប់និងបទប្បញ្ញត្តិទាំងនេះ។ | > ការចូលរួមដ៏សកម្មរបស់ស្ត្រី ហើយប្រសិនបើចាំបាច់ ការពិគ្រោះយោបល់ដាច់ដោយឡែកជាមួយស្ត្រី និងកុមារី គួរត្រូវបានធ្វើឡើង។ | |
| បង្កើត និង ពង្រឹងវេទិកាសម្របសម្រួលរបស់រដ្ឋាភិបាលដែលមានភាគីពាក់ព័ន្ធផ្សេងៗនៅថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន។ | > តុល្យភាពយេនឌ័រគួរត្រូវបានធានានៅក្នុងគ្រប់វេទិកាទាំងអស់។ | |
| លើកកម្ពស់យន្តការសម្រាប់ការផ្ទេរ និងការធានារ៉ាប់រងហានិភ័យគ្រោះមហន្តរាយការចែករំលែកនិងការរក្សាទុកហានិភ័យ និងការការពារហិរញ្ញវត្ថុ។ | > យន្តការហិរញ្ញវត្ថុសម្រាប់អាជីវកម្មខ្នាតតូច និងក្រៅប្រព័ន្ធដែលមានការចូលរួមពីស្ត្រីក៏គួរត្រូវបានរួមបញ្ចូលផងដែរ។ | |
| លើកកម្ពស់ភាពធន់នឹងហានិភ័យគ្រោះមហន្តរាយរបស់កន្លែងធ្វើការនានាតាមរយៈវិធានការរចនាសម្ព័ន្ធ និងមិនរចនាសម្ព័ន្ធ។ | > ផ្ទះគួរត្រូវបានចាត់ទុកថាជាកន្លែងធ្វើការ ជាពិសេសនៅពេលចំនួនស្ត្រីកាន់តែច្រើនឡើងគឺជាបុគ្គលិកធ្វើការនៅផ្ទះ។ | |
| ពង្រឹងការចងក្រងនិងការអនុវត្តគោលនយោបាយប្រកបដោយបរិយាបន្ន និងយន្តការសំណាញ់សុវត្ថិភាពសង្គម។ | > សម្លឹងមើលកម្មវិធីពង្រឹងជីវភាពរស់នៅទាំងអស់ និងការទទួលបានសេវាថែទាំសុខភាពមូលដ្ឋានរួមទាំងសុខភាពមាតា ទារកទើបកើត និងកុមារ សុខភាពផ្លូវភេទ និងបន្តពូជ សន្តិសុខ ស្បៀង និងអាហារូបត្ថម្ភ លំនៅឋាន និងការអប់រំ ឆ្ពោះទៅរកការកាត់បន្ថយភាពក្រីក្រ ដើម្បីស្វែងរកដំណោះស្រាយសមស្របក្នុងដំណាក់កាលក្រោយកូវីដសម្រាប់ស្ត្រី។ | |
| វិនិយោគលើ បង្កើត រក្សា និងពង្រឹងប្រព័ន្ធព្យាករ និងប្រកាសអាសន្នពហុគ្រោះថ្នាក់ និងពហុវិស័យដែលផ្តោតលើមនុស្ស ហានិភ័យគ្រោះមហន្តរាយ និងយន្តការទំនាក់ទំនងសង្គ្រោះបន្ទាន់។ | > ប្រព័ន្ធប្រកាសអាសន្ននិងទំនាក់ទំនងសង្គ្រោះបន្ទាន់ គួរត្រូវបានធ្វើតេស្តសម្រាប់ភាពរំញោចយេនឌ័រនៅថ្នាក់មូលដ្ឋាន។ | |
| លើកកម្ពស់ភាពធន់របស់ហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗទាំងថ្មី និងដែលមានស្រាប់ ដើម្បីធានាថាហេដ្ឋារចនាសម្ព័ន្ធទាំងនោះនៅមានសុវត្ថិភាព ប្រសិទ្ធភាព និងប្រតិបត្តិការបាននៅក្នុងអំឡុងពេល និងក្រោយគ្រោះមហន្តរាយ។ | > ហេដ្ឋារចនាសម្ព័ន្ធទឹកអនាម័យបរិស្ថាន សុខភាព និងអប់រំ ត្រូវតែរក្សានៅជាអាទិភាពខ្ពស់។ | |

## ឯកសារមេរៀនទី៨៖ ការអនុវត្តក្របខ័ណ្ឌ CCDRR សកលដែលមានទស្សនៈយេនឌ័រ

| វិស័យសកម្មភាពក្របខ័ណ្ឌ | ចំណុចសំខាន់ៗសម្រាប់សកម្មភាព ថ្នាក់ជាតិ ដែលត្រូវធ្វើដើម្បីបង្កើតកិច្ចការនេះ[6] | សកម្មភាពជាក់ស្តែងដែលត្រូវបានអនុវត្ត នៅកម្រិតប្រទេស |
|---|---|---|
| បង្កើតមជ្ឈមណ្ឌលសហគមន៍សម្រាប់ការលើកកម្ពស់ការយល់ដឹងជាសាធារណៈនិងការបង្កើនស្តុកសម្រាប់សម្ភារដែលចាំបាច់ដើម្បីអនុវត្តសកម្មភាពជួយសង្គ្រោះនិងសកម្មភាពផ្តល់ជំនួយ។ | > មជ្ឈមណ្ឌលសហគមន៍បែបនេះអាចត្រូវបានលើកកម្ពស់ដោយមានគោលបំណងទ្វេ គឺបម្រើជាទីតាំងរៀនសូត្រផង និងជាឃ្លាំងសម្រាប់ស្ត្រីនៅក្នុងពេលមិនមានគ្រោះមហន្តរាយផង។ | |
| បណ្តុះបណ្តាលកម្លាំងពលកម្មដែលមានស្រាប់និងបុគ្គលិកស្ម័គ្រចិត្តនៅក្នុងការឆ្លើយតបនឹងគ្រោះមហន្តរាយនិងពង្រឹងសមត្ថភាពបច្ចេកទេសនិងភស្តុភា ដើម្បីធានាបានការឆ្លើយតបកាន់តែប្រសើរក្នុងគ្រាអាសន្ន។ | > ស្ត្រី និងកុមារីគួរជាផ្នែកនៃអ្នកស្ម័គ្រចិត្ត និងគួរត្រូវបានបណ្តុះបណ្តាលក្នុងយន្តការឆ្លើយតបនឹងគ្រោះមហន្តរាយ។ | |
| ប្រភព៖ (សន្និសីទពិភពលោកអង្គការសហប្រជាជាតិស្តីពីការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ឆ្នាំ២០១៥) | | |

## ឯកសារមេរៀនទី៩៖ បញ្ជីត្រួតពិនិត្យសម្រាប់ការពិនិត្យមើលយេនឌ័រ និងការវិភាគ NDCs និង NAPs[7]

ផ្នែក ក៖ ការប៉ាន់ប្រមាណយេនឌ័រក្នុង NDCs

> អត្ថិភាពនៃការយោងណាមួយចំពោះយេនឌ័រ ឬស្ត្រីនៅក្នុងគោលនយោបាយ

- ការកំណត់អត្តសញ្ញាណក្រុមនិងវិស័យដែលរងផលប៉ះពាល់នៅក្នុងប្រទេស ពោលគឺ "តើអ្នកណា" គឺជាភាគីពាក់ព័ន្ធ និងអ្នកទទួលផលសំខាន់ៗ។
- សេចក្តីអធិប្បាយអំពីគោលដៅ ឬទស្សនវិស័យរយៈពេលវែង និងថាតើសមភាពយេនឌ័រត្រូវបានរួមបញ្ចូលឬអត់។
- យុទ្ធសាស្ត្រ គោលនយោបាយ ឬគំនិតផ្តួចផ្តើមជាតិដែលមានស្រាប់ពាក់ព័ន្ធនឹងយេនឌ័រនិងការប្រែប្រួលអាកាសធាតុ ដែល INDC អាចពឹងផ្អែកលើ ឬភ្ជាប់ទំនាក់ទំនងជាមួយ។
- ចំណុចយុទ្ធសាស្ត្រ ឬដៃគូដើម្បីធ្វើឱ្យមានការផ្លាស់ប្តូរឋានៈរបស់ស្ត្រី និងសមភាពយេនឌ័រក្នុងប្រទេស។
- សេចក្តីអធិប្បាយអំពីគម្លាត របាំង និងតម្រូវការរបស់ស្ត្រី និងបុរស។
- ការតាមដាន និងវាយតម្លៃ ដោយប្រើប្រាស់ការវិភាគយេនឌ័រ ទិន្នន័យបែងចែងតាមភេទ ឬសូចនាករយេនឌ័រ។
- សមភាពយេនឌ័រត្រូវបានធ្វើសមាហរកម្មទៅក្នុងគោលនយោបាយ យុទ្ធសាស្ត្រ និងកម្មវិធីការប្រែប្រួលអាកាសធាតុកម្រិតណា។
- សមភាពយេនឌ័រត្រូវបានពិចារណាកម្រិតណាក្នុងសកម្មភាពវិស័យប្រែប្រួលអាកាសធាតុអាទិភាព។ និង
- ការរួមបញ្ចូលស្ត្រីឱ្យក្លាយជាទិសដៅនៃការអភិវឌ្ឍសមត្ថភាព និងរចនាសម្ព័ន្ធនិងយន្តការគាំទ្រ។

> លក្ខណៈនៃការយោងរួមមាន៖

- បរិបទសម្រាប់ការយោង ឧទាហរណ៍ ការប្តេជ្ញាចិត្តចំពោះការកាត់បន្ថយ (M) ការបន្សាំ (A) ការកសាងសមត្ថភាព ការអនុវត្ត ឬថាតើការយោងយេនឌ័រមានភាពឆ្លងវិស័យ ឬអត់។ នៅទីកន្លែងណាដែលរដ្ឋាភិបាលបានអនុវត្តការបញ្ជ្រាបយេនឌ័រឬពិចារណាលើយេនឌ័រនៅទូទាំងសមាសភាពមួយឬច្រើននៃ INDC កត្តានេះត្រូវបានគេកត់សម្គាល់ថាជាវិញ្ញាបយេនឌ័រ (GS)។
- វិធីដែលស្ត្រីត្រូវបានដាក់នៅក្នុង NDC។ កត្តានេះរួមមាន ការដាក់ស្ត្រីឱ្យនៅជាក្រុមមួយដែលងាយរងគ្រោះទៅនឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ (WVG) ជាអ្នកទទួលផលពីគម្រោង ឬគោលនយោបាយ (B) ជាភ្នាក់ងារនៃការផ្លាស់ប្តូរ (AC) ឬជាភាគីពាក់ព័ន្ធ ឧទាហរណ៍ មានចំណែកក្នុងការធ្វើសេចក្តីសម្រេចចិត្តពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ (S)។

> អត្ថិភាពនៃការរៀបចំថវិកាដែលឆ្លើយតបនឹងតម្រូវការយេនឌ័រនៅក្នុង NDC។

> អត្ថិភាពនៃដំណើរការរៀបចំផែនការដែលមានការចូលរួមសម្រាប់ NDC។ និង

> អត្ថិភាពនៃយន្តការ ឬដំណើរការសម្រាប់ការតាមដាន ឬការអនុវត្ត NDC។

ផ្នែក ខ៖ ការវាយតម្លៃយេនឌ័រក្នុងដំណើរការ NAP

បញ្ជីត្រួតពិនិត្យសម្រាប់ការបញ្ជ្រាបយេនឌ័រក្នុងការរៀបចំស្ថាប័ន

> តើការចូលរួមប្រកបដោយសមធម៌របស់ស្ត្រីនៅក្នុងរចនាសម្ព័ន្ធស្ថាប័នត្រូវបានធានាដែរឬទេ?

> តើមានភាពជាតំណាងដែលមានតុល្យភាពរបស់ស្ត្រីនិងបុរស

[7] ប្រភព៖ (WEDO ឆ្នាំ២០១៦) និង (GGCA និង UNDP ឆ្នាំ២០១៦)។

នៅក្នុងថ្នាក់គ្រប់គ្រងជាន់ខ្ពស់ដែរឬទេ?
> តើគណៈកម្មាធិការដឹកនាំ បានបញ្ចូល (១) អ្នកតំណាងរបស់ក្រសួងកិច្ចការនារីឬក្រសួងសមមូល (២) អ្នកតំណាងរបស់អង្គការមិនមែនរដ្ឋាភិបាលធំៗដែលធ្វើការងារលើសមភាពយេនឌ័រ (៣) ចំនួនស្ត្រី និងបុរសប្រកបដោយសមធម៌ដែរឬទេ?
> តើនាយក/អ្នកគ្រប់គ្រង/អ្នកពិគ្រោះយោបល់នាំមុខរបស់គម្រោងថ្នាក់ជាតិ (១) "មានភាពរំញោចយេនឌ័រ" (២) ដែលត្រូវបានគាំទ្រដោយអ្នកជំនាញយេនឌ័រដែរឬទេ?
> តើការបណ្តុះបណ្តាលដែលតម្រូវតាមយេនឌ័រត្រូវបានផ្តល់ជូនបុគ្គលិកដែរឬទេ?

បញ្ជីត្រួតពិនិត្យសម្រាប់ការប៉ាន់ប្រម៉ាណការចូលរួមរបស់ស្ត្រី
> តើភាពជាតំណាងរបស់ស្ត្រីត្រូវបានធានាទាំងនៅសិក្ខាសាលាថ្នាក់ជាតិ និងថ្នាក់តំបន់ដែរឬទេ? ហើយតើអ្នកចូលរួមជាស្ត្រីត្រូវបាននាំយកមកពីរដ្ឋាភិបាលសង្គមស៊ីវិលនិងវិស័យជំនួញដែរឬទេ?
o តើតុល្យភាពយេនឌ័រនៅក្នុងសិក្ខាសាលាត្រូវបានធានាដែរឬទេ?
o តើការចូលរួមរបស់ស្ត្រីទទួលបានការគាំទ្រដែរឬទេ?
> តើសមភាពយេនឌ័រគឺជាលក្ខណៈវិនិច្ឆ័យមួយក្នុងចំណោមលក្ខណៈវិនិច្ឆ័យសំខាន់ៗសម្រាប់ការវាយតម្លៃជម្រើស និងលក្ខខណ្ឌសម្រាប់ការអនុម័តដែរឬទេ?
> តើស្ត្រីចូលរួមក្នុងការកំណត់ជម្រើសដែលអាចមានដើម្បីសម្រេចបានគោលបំណងដែរឬទេ?
> តើតម្រូវការ និងអត្ថប្រយោជន៍ស្ត្រីទទួលបានការពិចារណាដូចគ្នាទៅនឹងតម្រូវការ និងអត្ថប្រយោជន៍របស់បុរសក្នុងការវិភាគអំពីគុណសម្បត្តិ និងគុណវិបត្តិរបស់ជម្រើសនានាដែរឬទេ?
> តើស្ថាប័នខាងក្រោមនេះត្រូវបានអញ្ជើញដែរឬទេ?
o ជនបង្គោលទទួលបន្ទុកយេនឌ័រក្នុងក្រសួងឬនាយកដ្ឋានផ្សេងៗ។
o ដៃគូអភិវឌ្ឍន៍ដែលមានបទប្បញ្ញត្តិសមភាពយេនឌ័រ។
o សេដ្ឋវិទូរបស់រដ្ឋាភិបាល ឬសេដ្ឋវិទូឯករាជ្យដែលមានជំនាញខាងផ្នែកយេនឌ័រ។
o អ្នកតំណាងជាបុរស និងស្ត្រីនៃអត្ថប្រយោជន៍របស់វិស័យឯកជន។
o អង្គការដែលជាឆ័ត្ររបស់អង្គការមិនមែនរដ្ឋាភិបាលដែលផ្តោតលើស្ត្រី។
o អង្គការមិនមែនរដ្ឋាភិបាល ឬក្រុមបណ្តុះបណ្តាលដែលមានជំនាញយេនឌ័រ។
o អង្គការមិនមែនរដ្ឋាភិបាល ឬក្រុមសហគមន៍ណាមួយ ដែលតំណាងឱ្យអត្ថប្រយោជន៍យេនឌ័ររបស់បុរស។
o អង្គការមិនមែនរដ្ឋាភិបាលតាមវិស័យដែលពាក់ព័ន្ធ ឬ "មានអត្ថប្រយោជន៍ពិសេសស" ដែលមានអត្ថប្រយោជន៍ ឬបទពិសោធខាងផ្នែកបញ្ហាយេនឌ័រ។
o ក្រុម ឬអ្នកតស៊ូមតិដើម្បីសិទ្ធិមនុស្ស។
o ក្រុមអ្នកផ្តល់គំនិត (Think-tanks) ឬអ្នកវិភាគគោលនយោបាយដែលមានបទពិសោធ និងជំនាញខាងផ្នែកបញ្ហាយេនឌ័រ។ និង
o អ្នកសិក្សា ឬអ្នកស្រាវជ្រាវពីនាយកដ្ឋានសិក្សាយេនឌ័ររបស់សាកលវិទ្យាល័យ។

**បញ្ជីត្រួតពិនិត្យសម្រាប់ការបញ្ជ្រាបយេនឌ័រនៃការត្រួតពិនិត្យនិងការប៉ាន់ប្រម៉ាណភាពងាយរងគ្រោះ**
> ទិន្នន័យអំពីការប្រើប្រាស់និងការទទួលបានធនធានជីវសាស្ត្រដែលត្រូវបានបែងចែកតាមភេទ អ្វីដែលត្រូវបានប្រើប្រាស់ដោយអ្នកណាម្នាក់ ដោយស្ត្រី ឬបុរស?
> ទិន្នន័យអំពីភាពងាយរងគ្រោះដែលមានភាពខុសគ្នានិងផលប៉ះពាល់នៃគ្រោះមហន្តរាយក្នុងចំណោមស្ត្រី និងបុរស។
> តើទិន្នន័យទាំងអស់អំពីបុគ្គល ដែលត្រូវបានប្រមូល និងបង្ហាញត្រូវបានបែងចែកតាមភេទដែរឬទេ?
> តើកិច្ចប្រឹងប្រែងជាក់លាក់ត្រូវបានធ្វើឡើងដើម្បីកំណត់បញ្ហាយេនឌ័រ និងដើម្បីបង្កើតទស្សនទាន និងនិយមន័យ ដែលឆ្លុះបញ្ចាំងពីភាពខុសគ្នារវាងស្ត្រី និងបុរសនៅក្នុងទិដ្ឋភាពទាំងអស់នៃជីវិតរបស់ពួកគេដែរឬទេ?
> រួមបញ្ចូលចំណេះដឹងបែបប្រពៃណី និងការយល់ឃើញរបស់ស្ត្រីនៅក្នុងការវិភាគ និងការវាយតម្លៃអំពីលក្ខណៈហានិភ័យសំខាន់ៗ។
> កំណត់សមត្ថភាពនិងធនធានដែលមានសម្រាប់ការគ្រប់គ្រងនិងកាត់បន្ថយភាពងាយរងគ្រោះ។

**បញ្ជីត្រួតពិនិត្យសម្រាប់ការប៉ាន់ប្រម៉ាណការបញ្ជ្រាបយេនឌ័រក្នុងឯកសារ NAP**
> តើយេនឌ័រត្រូវរួមបញ្ចូលក្នុង NAP ថាជាបញ្ហាមួយនៃបញ្ហាឆ្លងវិស័យដែរឬទេ?
> តើសប្បុរសធម៌ទស្សនទានយេនឌ័រត្រូវបានធានាដែរឬទេ?
> តើការទាញហេតុផលបែបបណ្តុះបណ្តូលត្រូវបានបង្ហាញដែរឬទេ?

[8] ដកស្រង់ចេញពី (បណ្តាញសកល NAP និង UNFCCC ឆ្នាំ២០១៩) និង (Dekens និង Dazé ឆ្នាំ២០១៩)

## ឯកសារមេរៀនទី១០៖ អនុសញ្ញាយេនឌ័រអន្តរជាតិ និង CCDRR

ផ្នែក ក៖ អនុសាសន៍ទូទៅលេខ៣៧ នៃអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ (CEDAW) អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ (CEDAW) ឆ្នាំ១៩៧៩គឺជាអនុសញ្ញាមួយក្នុងចំណោមសន្ធិសញ្ញាសិទ្ធិមនុស្សស្នូលនានា ដែលរដ្ឋាភិបាលដែលជាហត្ថលេខីត្រូវបានចងភ្ជាប់កាតព្វកិច្ចឱ្យអនុវត្តកាតព្វកិច្ចច្បាប់ដើម្បីលើកកម្ពស់ និងការពារសិទ្ធិរបស់ស្ត្រី។ អនុសញ្ញានេះក៏ជាសន្ធិសញ្ញាមួយក្នុងចំណោមសន្ធិសញ្ញាសិទ្ធិមនុស្សដែលត្រូវបានអនុម័តទូលំទូលាយបំផុតផងដែរដែលត្រូវបានផ្តល់សច្ចាប័នឬព្រមព្រៀងដោយប្រទេសចំនួន១៨៧។

អនុសញ្ញា CEDAW មានការជំពាក់ជំពិនដោយផ្ទាល់សម្រាប់ការបន្សាំនឹងការប្រែប្រួលអាកាសធាតុនិងការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ ខណៈដែលគ្រប់ភាគីទាំងអស់មានកាតព្វកិច្ចអនុវត្តវិធានការសមស្របដើម្បីដោះស្រាយការរើសអើងប្រឆាំងនឹងស្ត្រីក្នុងគោលនយោបាយ និងកម្មវិធី CCDRR។ ក្រៅពីនេះ អនុសញ្ញាCEDAWក៏ធានាផងដែរនូវសិទ្ធិស្ត្រីក្នុងការចូលរួមនៅក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្តទាំងអស់ពាក់ព័ន្ធនឹង CCDRR។ ដោយត្រូវបានអនុម័តក្នុងឆ្នាំ២០០៩ គណៈកម្មាធិការ CEDAW បានបង្ហាញអនុសាសន៍ទូទៅលេខ ៣៧ ស្តីពីវិសាលភាពនៃការកាត់បន្ថយការប្រែប្រួលអាកាសធាតុពាក់ព័ន្ធនឹងយេនឌ័រនៅក្នុងបរិបទនៃការប្រែប្រួលអាកាសធាតុក្នុងឆ្នាំ២០១៨ (CEDAW/C/GC/៣៧)។

ក្នុងចំណោមនោះ អនុសាសន៍ចែងថា បណ្តាភាគីគួរធានាថា គោលនយោបាយ ច្បាប់ ផែនការ កម្មវិធី ថវិកា និងសកម្មភាពផ្សេងៗទាំងអស់ដែលទាក់ទងនឹងការកាត់បន្ថយគ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុ គឺមានការឆ្លើយតបនឹងតម្រូវការយេនឌ័រ និងមានមូលដ្ឋានលើគោលការណ៍ផ្អែកលើសិទ្ធិមនុស្សដែលរួមមាន៖

(ក) សមភាពនិងការមិនរើសអើង៖ ជាមួយនឹងអាទិភាពដែលត្រូវបានផ្តល់ជូនក្រុមស្ត្រីនិងកុមារីដែលជួបការលំបាកបំផុតដូចជាស្ត្រី និងកុមារីមកពីក្រុមជនជាតិដើមភាគតិច ក្រុមពូជសាសន៍ភាគតិច ក្រុមជាតិពន្ធុ និងមាននិន្នាការផ្លូវភេទភាគតិច ស្ត្រី និងកុមារីពិការ ក្មេងជំទង់ ស្ត្រីវ័យចំណាស់ ស្ត្រីនៅលីវ គ្រួសារដែលមានស្ត្រីជាមេគ្រួសារ ស្ត្រីមេម៉ាយ ស្ត្រី និងកុមារីដែលរស់នៅក្នុងភាពក្រីក្រទាំងនៅក្នុងបរិស្ថានជនបទនិងទីក្រុង ស្ត្រីរកស៊ីផ្លូវភេទ ព្រមទាំងស្ត្រីដែលធ្វើចំណាកស្រុកក្នុងប្រទេស ស្ត្រីគ្មានរដ្ឋ ស្ត្រីជាជនភៀសខ្លួន ស្ត្រីស្វែងរកសិទ្ធិជ្រកកោន និងស្ត្រីអន្តោប្រវេសន៍។

(ខ) ការចូលរួម និងការផ្តល់ភាពអង់អាច៖ តាមរយៈការអនុម័តដំណើរការប្រកបដោយប្រសិទ្ធភាព និងការបែងចែកធនធានដែលចាំបាច់ដើម្បីធានាថា ក្រុមស្ត្រីចម្រុះមានឱកាសចូលរួមក្នុងគ្រប់ដំណាក់កាលនៃការបង្កើតគោលនយោបាយ ការអនុវត្តនិងការតាមដាននៅកម្រិតថ្នាក់នីមួយៗរបស់រដ្ឋាភិបាលរាប់ចាប់ពីថ្នាក់មូលដ្ឋានរហូតដល់ថ្នាក់ជាតិ តំបន់ និងអន្តរជាតិ។

(គ) គណនេយ្យភាព និងការទទួលបានយុត្តិធម៌៖ តម្រូវឱ្យមានការផ្តល់ព័ត៌មាន និងយន្តការសមស្របនិងត្រឹមត្រូវ ដើម្បីធានាថារាល់ស្ត្រីនិងកុមារីទាំងអស់ដែលសិទ្ធិរបស់ពួកគេទទួលរងប៉ះពាល់ដោយផ្ទាល់និងប្រយោលពីគ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុ ត្រូវបានផ្តល់ដំណោះស្រាយគ្រប់គ្រាន់ និងទាន់ពេលវេលា។

លើសពីនេះទៀត គណៈកម្មាធិការ CEDAW ក៏បានផ្តល់អនុសាសន៍អំពីគោលការណ៍អនុសញ្ញាជាក់លាក់ផងដែរពាក់ព័ន្ធនឹងការកាត់បន្ថយគ្រោះមហន្តរាយនិងការប្រែប្រួលអាកាសធាតុទាក់ទងនឹងក) ការប៉ាន់ប្រម៉ាណភាពងាយរងគ្រោះនិងការប្រមូលទិន្នន័យ ខ) សិនិទ្ធភាពក្នុងចំណោមគោលនយោបាយស្តីពីសមភាពយេនឌ័រ ការកាត់បន្ថយគ្រោះមហន្តរាយ ការប្រែប្រួលអាកាសធាតុ និងការអភិវឌ្ឍប្រកបដោយនិរន្តរភាព គ) កាតព្វកិច្ចក្រៅដែនដី កិច្ចសហប្រតិបត្តិការអន្តរជាតិ និងការបែងចែកហិរញ្ញវត្ថុ និងធនធានបច្ចេកទេសគ្រប់គ្រាន់ និងប្រកបដោយប្រសិទ្ធភាពសម្រាប់ការបង្ការគ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុដែលឆ្លើយតបនឹងតម្រូវការយេនឌ័រឃ) ការរួមបញ្ចូលអង្គការសង្គមស៊ីវិល និងវិស័យឯកជន និង ង) ផ្តល់លទ្ធភាពឱ្យមានការអភិវឌ្ឍសមត្ថភាព និងការទទួលបានបច្ចេកវិទ្យា។

គណៈកម្មាធិការ CEDAW ក៏លើកឡើងផងដែរអំពីវិស័យកង្វល់ជាក់លាក់ចំនួន៦ សម្រាប់ស្ត្រីនិងកុមារីដូចជា សិទ្ធិរស់រានមានជីវិតដោយគ្មានអំពើហិង្សាទាក់ទងនឹងយេនឌ័រ សិទ្ធិទទួលបានការអប់រំ និងព័ត៌មាន សិទ្ធិធ្វើការ និងទទួលបានការការពារពីសង្គម សិទ្ធិទទួលបានការថែទាំសុខភាព សិទ្ធិទទួលបានស្តង់ដាររស់នៅគ្រប់គ្រាន់ និងសិទ្ធិដើរហើរដោយសេរី។

គណៈកម្មាធិការ CEDAW (អនុសាសន៍ទូទៅលេខ ៣៧ ស្តីពីវិសាលភាពនៃការកាត់បន្ថយការប្រែប្រួលអាកាសធាតុពាក់ព័ន្ធនឹងយេនឌ័រនៅក្នុងបរិបទនៃការប្រែប្រួលអាកាសធាតុក្នុងឆ្នាំ២០១៨) បានលើកឡើងលម្អិតបន្ថែមទៀតអំពីគោលការណ៍នីមួយៗក្នុងចំណោមគោលការណ៍ទាំងនេះនិងវិស័យកង្វល់នានាដែលផ្តល់កាតព្វកិច្ចប្រហែលចំនួន៦៣ សម្រាប់ឱ្យរដ្ឋភាគីអនុវត្ត។ ក្នុងចំណោមនោះ កាតព្វកិច្ចទាំងនេះរួមមាន៖

ក) បង្កើតសូចនាករដែលមានការបែងចែក និងឆ្លើយតបនឹងតម្រូវការយេនឌ័រ និងយន្តការតាមដាន និងបង្កើត ឬកំណត់យន្តការថ្នាក់ជាតិ និងមូលដ្ឋានដែលមានស្រាប់ ដើម្បីប្រមូលវិភាគ គ្រប់គ្រង និងអនុវត្តទិន្នន័យបែងចែកតាមភេទ អាយុ ពិការភាព ជាតិពន្ធុ និងទិន្នន័យបែងចែកតាមតំបន់។

ខ) អនុវត្តការវាយតម្លៃផលប៉ះពាល់យេនឌ័រក្នុងអំឡុងពេលរៀបចំអនុវត្តនិងតាមដានដំណាក់កាលនៃផែនការនិងគោលនយោបាយការកាត់បន្ថយគ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុនិងរួមបញ្ចូលការធ្វើសវនកម្មយេនឌ័រទូលំទូលាយ

នៃគោលនយោបាយ និងកម្មវិធីនៅទូទាំងវិស័យ និងតំបន់ផ្សេងៗ រួមទាំងអាកាសធាតុ ពាណិជ្ជកម្ម និងការវិនិយោគ បរិស្ថាន និងការរៀបចំផែនការ ទឹក ស្បៀង កសិកម្ម បច្ចេកវិទ្យា ការការពារសង្គម ការអប់រំ និងការងារ។

គ) បង្កើនការបែងចែកថវិកា ដែលផ្តោតលើយេនឌ័រ និង CCDRR និងវិនិយោគលើភាពបន្សាំរបស់ស្ត្រីតាមរយៈការកំណត់និងការគាំទ្របរចិញ្ចឹមជីវិតដែលមានភាពធន់ទៅនឹងគ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុដែលមាននិរន្តរភាព និងមានសិទ្ធិអំណាច រួមជាមួយនឹងសេវានានាដែលឆ្លើយតបនឹងតម្រូវការយេនឌ័រ ដែលអាចឱ្យស្ត្រីមានលទ្ធភាពទទួលបាន និងទទួលបានអត្ថប្រយោជន៍ពីបរបចិញ្ចឹមជីវិតទាំងនេះ។

ឃ) បង្កើនការចូលរួមរបស់ស្ត្រីក្នុងការអភិវឌ្ឍផែនការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយនិងការប្រែប្រួលអាកាសធាតុតាមរយៈការគាំទ្រដល់សមត្ថភាពបច្ចេកទេសរបស់ពួកគេ និងការផ្តល់ធនធានគ្រប់គ្រាន់សម្រាប់គោលបំណងនេះ និងបង្កើតស្ថាប័នភាពជាអ្នកដឹកនាំរបស់ស្ត្រីក្នុងការបង្ការគ្រោះមហន្តរាយ ការត្រៀមបង្ការទប់ទល់នឹងគ្រោះមហន្តរាយ (រួមទាំងការបង្កើតនិងការផ្សព្វផ្សាយប្រព័ន្ធប្រកាសអាសន្ន) ការឆ្លើយតបនឹងគ្រោះមហន្តរាយ ការស្តារឡើងវិញ និងការកាត់បន្ថយ និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុនៅគ្រប់កម្រិតថ្នាក់។

ង) ធានាថា ស្ត្រីមានលទ្ធភាពទទួលបានបច្ចេកវិទ្យាសម្រាប់ការបង្ការនិងការកាត់បន្ថយផលវិបាកនៃគ្រោះមហន្តរាយនិងការប្រែប្រួលអាកាសធាតុទៅលើដំណាំ សត្វពាហនៈ ផ្ទះសម្បែង និងអាជីវកម្ម និងធានាថា ពួកគេអាចប្រើប្រាស់ និងទទួលបានអត្ថប្រយោជន៍ផ្នែកសេដ្ឋកិច្ចពីការបន្សាំនឹងការប្រែប្រួលអាកាសធាតុ និងបច្ចេកវិទ្យាកាត់បន្ថយ រួមទាំងបច្ចេកវិទ្យាដែលពាក់ព័ន្ធនឹងថាមពលកកើតឡើងវិញ និងផលិតកម្មកសិកម្មប្រកបដោយនិរន្តរភាព។

ច) បង្កើតគោលនយោបាយនិងកម្មវិធីដើម្បីដោះស្រាយកត្តាហានិភ័យដែលមានស្រាប់ និងថ្មីៗ សម្រាប់អំពើហិង្សាទាក់ទងនឹងយេនឌ័រប្រឆាំងនឹងស្ត្រី ដូចជាអំពើហិង្សាក្នុងគ្រួសារ អំពើហិង្សាផ្លូវភេទ អំពើហិង្សាសេដ្ឋកិច្ច ការជួញដូរមនុស្ស និងអាពាហ៍ពិពាហ៍ដោយបង្ខំ នៅក្នុងបរិបទកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុ និងលើកកម្ពស់ការចូលរួម និងភាពជាអ្នកដឹកនាំរបស់ស្ត្រីនៅក្នុងការអភិវឌ្ឍរបស់ពួកគេ។

ឆ) បង្កើតផែនការ និងគោលនយោបាយដែលមានការចូលរួម ឆ្លើយតបនឹងតម្រូវការយេនឌ័រ និងអភិវឌ្ឍន៍ ដែលធ្វើសមាហរណកម្មវិធីសាស្ត្រផ្អែកលើសិទ្ធិមនុស្ស ដើម្បីធានាបានការទទួលបានប្រកបដោយនិរន្តរភាពនូវលំនៅដ្ឋានគ្រប់គ្រាន់ ទឹកនិងអនាម័យបរិស្ថាន។ អាទិភាពគួរត្រូវបានផ្តល់ជូនដើម្បីធានាបាននូវការទទួលបានសេវាសម្រាប់ស្ត្រីទាំងអស់។ និង

ជ) ផ្តល់ការបណ្តុះបណ្តាល ការធ្វើឱ្យមានរំញោច និងការបង្កើនការយល់ដឹងសម្រាប់អាជ្ញាធរ បុគ្គលិកសេវាសង្គ្រោះបន្ទាន់និងក្រុមផ្សេងៗក្នុងទម្រង់ផ្សេងៗនៃអំពើហិង្សាទាក់ទងយេនឌ័រ សុខភាពនិងសិទ្ធិមនុស្សរបស់ស្ត្រីដែលរីករាលដាលនៅក្នុងស្ថានភាពគ្រោះមហន្តរាយ និងរបៀបបង្ការ និងដោះស្រាយបញ្ហាទាំងនេះ។ ការបណ្តុះបណ្តាលនេះ គួររួមបញ្ចូលទាំងសិទ្ធិ និងតម្រូវការរបស់ស្ត្រី និងកុមារី រួមទាំងស្ត្រីនិងកុមារីមកពីក្រុមជនជាតិដើមភាគតិចនិងក្រុមភាគតិចស្ត្រីពិការនិងមនុស្សស្រីស្រលាញ់ស្រី មនុស្សស្រលាញ់មនុស្សទាំងពីរភេទ ខ្ទើយ និងស្ត្រី និងកុមារីអន្តរភេទ និងព័ត៌មានអំពីរបៀបដែលពួកគេអាចទទួលរងផលប៉ះពាល់ផ្សេងៗ។

ផ្នែក ខ៖ វេទិកាទីក្រុងប៉េកាំងដើម្បីសកម្មភាព (BPfA) ឆ្នាំ១៩៩៥ និងសេចក្តីប្រកាស (+២៥) ទីក្រុងប៉េកាំងអាស៊ីប៉ាស៊ីហ្វិក ឆ្នាំ ២០១៩ សេចក្តីប្រកាស និងវេទិកាក្រុងប៉េកាំងដើម្បីសកម្មភាពឆ្នាំ១៩៩៥ គឺជាក្របខ័ណ្ឌគោលនយោបាយពិភពលោកមួយក្នុងចំណោមក្របខ័ណ្ឌគោលនយោបាយពិភពលោកទូលំទូលាយបំផុត សម្រាប់ការលើកកម្ពស់សមភាពយេនឌ័រ និងការផ្តល់ភាពអង់អាចដល់ស្ត្រី។ ដោយត្រូវបានចុះហត្ថលេខាដោយរដ្ឋាភិបាលចំនួន១៨៩ BPfA គ្របដណ្តប់លើវិស័យកង្វល់សំខាន់ៗចំនួន១២ដោយស្ត្រីនិងបរិស្ថានស្ថិតក្នុងចំណោមវិស័យទាំងនោះ។ ឯកសារនេះរំលេចវិសមភាពយេនឌ័រនៅក្នុងការគ្រប់គ្រងធនធានធម្មជាតិនិងក្នុងការការពារបរិស្ថាននិងអំពាវនាវឱ្យមានការផ្តោតលើការយល់ដឹងអំពីភាពងាយរងគ្រោះទាក់ទងនឹងយេនឌ័រនៃហានិភ័យនិងគ្រោះមហន្តរាយបរិស្ថានហើយក៏ផ្តោតការយកចិត្តទុកដាក់ផងដែរលើតម្រូវការសម្រាប់ ក) ការចូលរួមរបស់ស្ត្រីយ៉ាងសកម្មក្នុងការធ្វើសេចក្តីសម្រេចចិត្តពាក់ព័ន្ធនឹងបរិស្ថាននៅគ្រប់កម្រិត ខ) ការធ្វើសមាហរណកម្មកង្វល់និងទស្សនៈយេនឌ័រទៅក្នុងគោលនយោបាយ និងកម្មវិធីនានាសម្រាប់ការអភិវឌ្ឍប្រកបដោយនិរន្តរភាព និង គ) ពង្រឹង ឬបង្កើតយន្តការនៅថ្នាក់ជាតិ ថ្នាក់តំបន់ និងថ្នាក់អន្តរជាតិ ដើម្បីវាយតម្លៃផលប៉ះពាល់របស់គោលនយោបាយអភិវឌ្ឍន៍ និងបរិស្ថានទៅលើស្ត្រី (BPfA ឆ្នាំ១៩៩៥)។

សេចក្តីប្រកាស និងវេទិកាក្រុងប៉េកាំងដើម្បីសកម្មភាព ក៏ត្រូវបានត្រួតពិនិត្យផងដែរដោយមហាសន្និបាតរបស់អង្គការសហប្រជាជាតិ ដែលត្រូវបានធ្វើឡើងជាពិសេសនៅឆ្នាំ២០០០ (B+5) និងឆ្នាំ២០១៥ (B+20) ជាទីដែលរដ្ឋាភិបាលក៏បានព្រមព្រៀងផងដែរអំពីសកម្មភាពបន្ថែមដើម្បីពន្លឿនការអនុវត្ត។ យន្តការត្រួតពិនិត្យទាំងនេះអាចជាចំណុចចាប់ផ្តើមដ៏ខ្លាំងមួយសម្រាប់អង្គការសង្គមស៊ីវិល ដើម្បីតស៊ូមតិសម្រាប់ការបញ្ជ្រាបយេនឌ័រនៅក្នុងរបៀបវារៈការប្រែប្រួលអាកាសធាតុនៅថ្នាក់តំបន់ និងថ្នាក់ជាតិ។ នៅក្នុងឆ្នាំ២០១៩ រដ្ឋសមាជិករបស់គណៈកម្មការសេដ្ឋកិច្ចអង្គការសហប្រជាជាតិសម្រាប់តំបន់អឺរ៉ុប (UNECE)

បានជួបប្រជុំការត្រួតពិនិត្យថ្នាក់តំបន់នៅក្នុងបរិបទនៃការរៀបចំសម្រាប់ការត្រួតពិនិត្យក្រុងប៉េកាំង+២៥ ពិភពលោកក្នុងឆ្នាំ ២០២០។

កិច្ចប្រជុំត្រួតពិនិត្យអាស៊ីប៉ាស៊ីហ្វិក ត្រូវបានរៀបចំធ្វើឡើងនៅទីក្រុងបាងកកនៅខែវិច្ឆិកា ឆ្នាំ២០១៩ ដើម្បីត្រួតពិនិត្យវឌ្ឍនភាពដែលត្រូវបានធ្វើឡើង បញ្ហាប្រឈមនានាដែលត្រូវដោះស្រាយ និងគោលនយោបាយឆ្ពោះទៅមុខដែលត្រូវអនុម័តដើម្បីពន្លឿនការអនុវត្តសេចក្តីប្រកាស និងវេទិកាក្រុងប៉េកាំងដើម្បីសកម្មភាពក្នុងតំបន់អាស៊ីនិងប៉ាស៊ីហ្វិកនៅក្នុងបរិបទរបៀបវារៈឆ្នាំ២០៣០ (ការត្រួតពិនិត្យ AP B+25 ឆ្នាំ២០១៩)។ បន្ទាប់ពីនេះ ក្នុងខែធ្នូ ឆ្នាំ២០១៩ សេចក្តីប្រកាសស្តីពីការពន្លឿនសមភាពយេនឌ័រនិងការផ្តល់ភាពអង់អាចដល់ស្ត្រីនៅតំបន់អាស៊ីប៉ាស៊ីហ្វិកៈការត្រួតពិនិត្យក្រុងប៉េកាំង+២៥ត្រូវបានអនុម័តដែលក៏បានរួមបញ្ចូលផងដែរនូវវគ្គមួយស្តីពីការអភិរក្សបរិស្ថាន សកម្មភាពអាកាសធាតុ និងការកសាងភាពធន់ ដែលរំលេចតម្រូវការឱ្យមាន"ការធ្វើសមាហរណកម្មនិងការបញ្ជ្រាបទស្សនៈយេនឌ័រទៅក្នុងការអភិរក្ស ការការពារ និងការស្តារនីតិសម្បទាបរិស្ថាននិងការលើកកម្ពស់សកម្មភាពអាកាសធាតុការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយនិងការកសាងភាពធន់ដែលឆ្លើយតបនឹងតម្រូវការយេនឌ័រ ដោយពិចារណាថា ការប្រែប្រួលអាកាសធាតុ ...មានផលប៉ះពាល់ខ្លាំងខុសគ្នាទៅលើស្ត្រីនិងកុមារីទាំងអស់" (UNESCAP ឆ្នាំ២០១៩)។

**សេចក្តីប្រកាសនេះផ្តោតជាពិសេសលើៈ**

ក) តួនាទីរបស់ស្ត្រីក្នុងនាមជាអ្នកមានចំណេះដឹង និងជាភ្នាក់ងារនៃការផ្លាស់ប្តូរ។

ខ) តម្រូវការភាពជាអ្នកដឹកនាំ និងការចូលរួមពេញលេញ និងស្មើភាពរបស់ស្ត្រីនៅគ្រប់កម្រិតថ្នាក់នៃការបង្កើតគោលនយោបាយ និងការធ្វើសេចក្តីសម្រេចចិត្ត។

គ) ការអនុម័ត និងការអនុវត្តយុទ្ធសាស្ត្រស្តីពីការកាត់បន្ថយ និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុដែលឆ្លើយតបនឹងតម្រូវការយេនឌ័រតាមរយៈការលើកកម្ពស់ការទទួលបានដោយស្មើភាពនូវហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗ និងបច្ចេកវិទ្យាកសិកម្មឆ្លាតវៃដែលធន់នឹងអាកាសធាតុថាមពលស្អាតហិរញ្ញប្បទាន និងបច្ចេកវិទ្យាសមស្រប ជំនួយមនុស្សធម៌ ស្បៀង និងអាហារូបត្ថម្ភ ទឹកស្អាតសម្រាប់ផឹក និងអនាម័យបរិស្ថាន ការគ្រប់គ្រងសំណល់ សេវាថែទាំសុខភាព ការអប់រំនិងការបណ្តុះបណ្តាល លំនៅឋានគ្រប់គ្រាន់ និងការងារសមរម្យ សន្តិសុខសង្គមនិងប្រព័ន្ធព្យាករនិងប្រកាសអាសន្នដែលមានរំញោចយេនឌ័រ។

ឃ) ការតាមដាន និងវាយតម្លៃដែលឆ្លើយតបនឹងតម្រូវការយេនឌ័រ។ និង

ង) តម្រូវការផ្តោតលើស្ត្រីដែលជាជនពិការ ស្ត្រីចាស់ជរា និងកុមារី ស្ត្រីដែលរស់នៅទីជនបទ និងតំបន់ដាច់ស្រយាល និងស្ត្រីដែលមកពីសហគមន៍ជនជាតិដើមភាគតិច និងសហគមន៍មូលដ្ឋាន (UNESCAP ឆ្នាំ២០១៩)។

## ឯកសារមេរៀនទី១១ៈ ករណីសិក្សាស្តីពីយុទ្ធសាស្ត្រសម្រាប់ការបញ្ជ្រាបយេនឌ័រ

ការធ្វើឱ្យសំឡេង និងសំឡេងឆ្នោតរបស់ស្ត្រីអាចរាប់បានៈ ករណីសិក្សាយកចេញពី អង្គការ UN Women ប្រទេសឥណ្ឌា ការបង្កើតសំឡេង និងសំឡេងឆ្នោតរបស់ស្ត្រី គឺជាគម្រោងដែលមានរយៈពេល២ឆ្នាំកន្លះ(ឆ្នាំ២០១៣-២០១៥)ដែលគាំទ្រដោយ អង្គការ UN Women និង បេសកកម្មជាតិដើម្បីពង្រឹងភាពអង់អាចដល់ស្ត្រី (រដ្ឋាភិបាលឥណ្ឌា) ក្នុងគោលបំណងកសាងសមត្ថភាពដល់តំណាងជាស្ត្រីដែលបានជាប់ឆ្នោតមកពីស្ថាប័នដែលមានមូលដ្ឋាននៅជនបទ និងការពង្រឹងទំនាក់ទំនងរវាងស្ត្រីដែលបានជាប់ឆ្នោត និងសហករណ៍ជាស្ត្រី សម្រាប់ការបង្កើតសង្គមនយោបាយសម្រាប់ស្ត្រី នៅថ្នាក់មូលដ្ឋាន និងរចនាសម្ព័ន្ធអភិបាលកិច្ចមូលដ្ឋានដែលមានលក្ខណៈឆ្លើយតបនឹងតម្រូវការយេនឌ័រដំណើរការនិងរបៀបវារៈ។គម្រោងនេះមានគោលបំណងប្រើប្រាស់គំរូICTដើម្បីជួយជំរុញដល់ស្ត្រីក្នុងចំនួនដ៏ច្រើនទៅក្នុងអភិបាលកិច្ចមូលដ្ឋានបង្កើតវេទិកាខ្សែផ្តេកសម្រាប់ការគាំទ្រដោយផ្អែកលើមិត្តភក្តិនិងបង្កើតមូលដ្ឋាននៃអភិបាលកិច្ចនិងនយោបាយដែលត្រូវបានជូនដំណឹងតាមរយៈទិដ្ឋភាពនៃសិទ្ធិរបស់ស្ត្រី។

អង្គការសង្គមស៊ីវិលចំនួនបីផ្សេងគ្នាដែលបានមកពីគេហទំព័រចំនួន៣ គឺ IT សម្រាប់ការផ្លាស់ប្តូរនៅ មីស៊ី (កាណាតាកា) គុជម៉ាម៉ាហ៊ីឡា វីកាស សាន់ហ្កាថាន់ នៅគុជ (ហ្កូចារ៉ាត់) និងគំនិតផ្តួចផ្តើមសម្រាប់ការរៀបចំបណ្តាញ និងការអភិវឌ្ឍតំបន់នៅបាណាហ្កានៃរដ្ឋហ្កូចារ៉ាត់ដែលពាក់ព័ន្ធនៅក្នុងគម្រោងដោយប្រើយុទ្ធសាស្ត្រដូចគ្នា យន្តការត្រួតពិនិត្យ និងការរាយការណ៍។ ដែលជួយឱ្យយល់ដឹងពីដែនកំណត់និងការធ្វើមាត្រដ្ឋាននៃគំរូនេះ ។យុទ្ធសាស្ត្របែបនេះមានប្រយោជន៍ជាពិសេសសម្រាប់អង្គការសង្គមស៊ីវិលដែលចូលចិត្តធ្វើការបន្ថែមទៀតក្នុងកម្រិតស៊ីជម្រៅ ប៉ុន្តែក្នុងពេលជាមួយគ្នានេះក៏បើកទូលាយចំពោះកិច្ចសហការនិងការរាយការណ៍ជាប្រព័ន្ធដើម្បីអាចទទួលបានមូលនិធិដោយអាចបង្ហាញពីការចម្លងឡើងវិញ និងសក្តានុពលនៃមាត្រដ្ឋាន។

ក្នុងស្ថានភាពជាក់លាក់ គម្រោងនេះបានធ្វើការឆ្ពោះទៅរកលទ្ធផលចំនួនបីដូចខាងក្រោមៈ

១.បង្កើនការរៀបចំបណ្តាញក្នុងចំណោមតំណាងជាស្ត្រីដែលបានជាប់ឆ្នោត និងជួយសម្រួលដល់ការចូលរួមយ៉ាងសកម្មរបស់ពួកគេរួមជាមួយក្រុមស្ត្រីនៅក្នុងមូលដ្ឋានក្នុងដំណើរការអភិបាលកិច្ចដែលមានលក្ខណៈឆ្លើយតបនឹងតម្រូវការយេនឌ័រ។

២. ការបង្កើនការទទួលស្គាល់ការទាមទារ និងសិទ្ធិទទួលបានដោយស្ត្រីនៅរដ្ឋហ្កូចារ៉ាត់ និងកាណាតាកា។

៣. ការតស៊ូមតិ និងយុទ្ធនាការនៅថ្នាក់មូលដ្ឋាន និងថ្នាក់ស្ថាប័ន

អាចជួយឱ្យមានការផ្លាស់ប្តូរមូលដ្ឋានសាធារណៈនៅថ្នាក់មូលដ្ឋានដែលឆ្ពោះទៅរកសមភាពយេនឌ័រ។

ប្រភព៖ (អង្គការ UN Women ឆ្នាំ២០១៥)

---

## ការរៀបចំបណ្តាញសម្រាប់សំឡេងរបស់ស្ត្រី៖ករណីសិក្សាពីនាពជាដៃគូថ្នាក់សកល ថ្នាក់តំបន់ និងប្រទេស

អង្គការ Women´s Major Group (WMG) ដើម្បីការអភិវឌ្ឍប្រកបដោយចីរភាព(SD)ត្រូវបានបង្កើតឡើងជាលទ្ធផលនៃកិច្ចប្រជុំកំពូលស្តីពីផែនដីក្នុងឆ្នាំ ១៩៩២ ដែលមានអាណត្តិស្នូលនិងទំនួលខុសត្រូវក្នុងការសម្របសម្រួលទិដ្ឋភាពសង្គមស៊ីវិលរបស់ស្ត្រី នៅក្នុងចន្លោះគោលនយោបាយ និងដំណើរការរបស់អង្គការសហប្រជាជាតិទាក់ទងនឹងការអភិវឌ្ឍប្រកបដោយចីរភាព។ អង្គការ WMG គឺជាជនបង្គោលរបស់អង្គការ UN DESA (នាយកដ្ឋានកិច្ចការសេដ្ឋកិច្ច និងសង្គម) សម្រាប់គោលនយោបាយអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់អង្គការសហប្រជាជាតិ រួមទាំង គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពឆ្នាំ២០៣០។ សម្ព័ន្ធភាពបើកចំហដែលក្នុងឆ្នាំ២០១៧ ដែលរួមមានអង្គការ និងបុគ្គលជាង១៣០០ អង្គការ WMG បានផ្តល់នូវបណ្តាញផ្លូវការមួយសម្រាប់ការចូលរួមជារូបវន្តឬជាក់ស្តែងនៅក្នុងកិច្ចប្រជុំថ្នាក់សកល និងថ្នាក់តំបន់សំខាន់ៗ។ ការសង្កេត និងការលើកឡើងនៅក្នុងវគ្គអន្តររដ្ឋាភិបាលជាផ្លូវការ ការចូលរួមក្នុងការតស៊ូមតិដែលមានការសម្របសម្រួល និងយុទ្ធសាស្ត្រជាមួយអ្នកធ្វើសេចក្តីសម្រេចចិត្ត ការរួមចំណែកក្នុងការសម្របសម្រួលការធ្វើសេចក្តីថ្លែងការណ៍អំពីស្ថានភាព ការវិភាគ និងការផ្តល់អនុសាសន៍គោលនយោបាយ ត្រូវបានផ្សព្វផ្សាយនៅលើគេហទំព័ររបស់អង្គការសហប្រជាជាតិសម្រាប់ក្រុមធំ។ ការចូលរួមនៅក្នុងកិច្ចខិតខំប្រឹងប្រែងធ្វើបាយការណ៍ និងគណនេយ្យភាព ការកសាងសមត្ថភាព និងការទទួលបានឯកសារ និងព័ត៌មាន។ (សូមមើលបន្ថែមនៅគេហទំព័រ https://sSustainableevelop-ment.un.org)។

ស្ត្រី និងសង្គមយេនឌ័រ (WGC) ត្រូវបានបង្កើតឡើងក្នុងឆ្នាំ២០០៩។ អង្គការ WGC គឺជាក្រុមមួយក្នុងចំណោមក្រុមភាគីពាក់ព័ន្ធទាំង៩ នៃអនុសញ្ញាក្របខ័ណ្ឌអង្គការសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (UNFCCC)។ អង្គការ WGC តំណាងឱ្យអង្គការសង្គមស៊ីវិលដែលផ្តោតលើស្ត្រី និងបរិស្ថាន និងធ្វើការយ៉ាងសកម្ម ដើម្បីធានាថា សមភាពយេនឌ័រ និងសិទ្ធិមនុស្សរបស់ស្ត្រីគឺជាផ្នែកស្នូលសម្រាប់ការចរចា។ វិធីមួយក្នុងចំណោមវិធីផ្សេងៗគ្នាដែល អង្គការ WGC ប្រើសម្រាប់ការចូលរួមយ៉ាងសកម្មរបស់សមាជិកខ្លួនគឺធ្វើឡើងតាមរយៈក្រុមតាមអ៊ីនធើណែត។ ក្រុម តាមអ៊ិនធើណែតទាំងនេះត្រូវបានប្រើសម្រាប់ការចែករំលែកព័ត៌មាន ការសម្របសម្រួលព្រឹត្តិការណ៍នានា ការរួមចំណែកផ្តល់ធាតុចូលសម្រាប់ការចរចា ការនាំយកបញ្ហាដែលកំពុងកើតមានក្នុងចំណោមបញ្ហាដទៃទៀត។ ការចំណាយទាប និងងាយស្រួលក្នុងការធ្វើប្រតិបត្តិការវេទិកានេះ អាចត្រូវបានប្រើយ៉ាងមានប្រសិទ្ធភាព ដើម្បីប្រមូលផ្តុំបណ្តាញអង្គការសង្គមស៊ីវិល។ ក្រុមទាំងនេះ អាចត្រូវបានប្រើដើម្បីបង្កើតបណ្តាញអង្គការសង្គមស៊ីវិលនៅថ្នាក់តំបន់/ប្រទេស ឬបណ្តាញអង្គការសង្គមស៊ីវិលនៅក្នុងក្រុម/កម្មវិធីការងារជាក់លាក់។ (សូមមើលបន្ថែមនៅ http://womengenderclimate.org

យន្តការការចូលរួមរបស់អង្គការសហប្រជាជាតិនៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក (APRCEM) គឺជាវេទិកាសង្គមស៊ីវិលមួយដែលមានគោលបំណងជំរុញឱ្យមានការសម្របសម្រួលផ្នែកសង្គមកាន់តែច្រើននិងធានាថាសំឡេងនៃអនុតំបន់អាស៊ីប៉ាស៊ីហ្វិកត្រូវបានគេឮ នៅក្នុងដំណើរការអន្តររដ្ឋាភិបាលនៅថ្នាក់តំបន់ និងថ្នាក់សកល។វេទិកានេះត្រូវបានផ្តួចផ្តើមគ្រប់គ្រងនិងដឹកនាំដោយអង្គការសង្គមស៊ីវិល និងស្វែងរក ការចូលរួមជាមួយទីភ្នាក់ងារអង្គការសហប្រជាជាតិ និងរដ្ឋជាសមាជិកនៅក្រោយឆ្នាំ២០១៥ ក៏ដូចជាបញ្ហា/ដំណើរការទាក់ទងនឹងការអភិវឌ្ឍផ្សេងទៀត។ ក្នុងនាមជាយន្តការបើកចំហដែលមានការរួមបញ្ចូលនិងដែលមានភាពបត់បែន RCEM ត្រូវបានបង្កើតឡើង ដើម្បីទៅឱ្យដល់ចំនួនអង្គការសង្គមស៊ីវិលក្នុងចំនួនច្រើនបំផុតនៅក្នុងតំបន់ដែលទទួលបានសំឡេងនៅថ្នាក់មូលដ្ឋាននិងចលនាប្រជាជនដើម្បីជំរុញឱ្យមានភាពយុត្តិធម៌ដែលដោះស្រាយភាពមិនស្មើគ្នានៃទ្រព្យសម្បត្តិ អំណាច ធនធានរវាងប្រទេសនានា រវាងអ្នកមាន និងអ្នកក្រ និងរវាងបុរស និងស្ត្រី។ (សូមមើលបន្ថែមនៅគេហទំព័រ http://asiapacificrcem.org/)។

ក្រុមការងារទទួលបន្ទុកស្ត្រី និងកម្មសិទ្ធិដីធ្លី (WGWLO) គឺជាបណ្តាញក្រៅផ្លូវការនិងមិនបានចុះបញ្ជីនៃក្រុមអង្គការសង្គមស៊ីវិលចំនួន៤០ និងអង្គការផ្អែកលើសហគមន៍នៅរដ្ឋហ្គូចារ៉ាត់ (ប្រទេសឥណ្ឌា)ដោយធ្វើការតាមរយៈលេខាធិការដ្ឋានប្តូរវេណតូចមួយ ចាប់តាំងពីឆ្នាំ២០០២។ មានឥទ្ធិពលលើគោលនយោបាយ និងផែនការនៅថ្នាក់រដ្ឋ និងថ្នាក់ជាតិ។ បណ្តាញនេះរៃអង្គាសប្រាក់រួមគ្នាពីម្ចាស់ជំនួយផ្សេងៗនិងផ្តល់ការគាំទ្រផ្អែកលើសកម្មភាពដល់សមាជិករបស់ខ្លួន។ សមាជិកបណ្តាញនេះ បានចូលរួមចំណែកតាមរយៈការយល់ដឹងសម្រាប់ការស្រាវជ្រាវ និងការប្រើប្រាស់ឯកសារទំនាក់ទំនងទូទៅ។ (សូមមើលបន្ថែមនៅគេហទំព័រ http://wgwlo.org/)។

ការផ្តល់រង្វាន់សម្រាប់ការបំផុសគំនិតស្ត្រីក្នុងភាពជាអ្នកដឹកនាំ (WIL)៖ ប្រទេសបង់ក្លាដែស មានគោលបំណងទទួលស្គាល់ស្ត្រីដែលក្តីប្រាថ្នា និងដឹកនាំគេនៅក្នុងវិស័យសាជីវកម្មនៅប្រទេសបង់ក្លាដែស ក្រោមរូបភាពផ្សេងៗគ្នា ហេតុដូច្នេះហើយការកំណត់នូវគំរូតួនាទីបំផុតគំនិតសម្រាប់ស្ត្រី។លើសពីនេះទៀត WIL កំពុងផ្តល់ការទទួលស្គាល់ដល់អង្គភាពអាជីវកម្ម ដែលមានលក្ខខណ្ឌការងារ និងគោលនយោបាយ ដែលផ្តល់បរិយាកាស

រីករាយដល់ស្ត្រី។ការបែងចែកគំរូតួនាទីនឹងជំរុញឱ្យស្ត្រីដែលមានសេចក្តីប្រាថ្នាផ្សេងទៀត ឱ្យឆ្ពោះទៅមុខ និងដើរតួនាទីរបស់ពួកគេនៅក្នុងចរន្តអភិវឌ្ឍន៍ប្រទេសជាតិ។ ( សូមមើលបន្ថែមទៀតនៅគេហទំព័រ http://bbf.digital/iwa-2020 )។

## ការអនុវត្តវិធីសាស្ត្រផ្អែកលើសិទ្ធិមនុស្សជាមូលដ្ឋាន និងមិនមានអ្នកណាម្នាក់ត្រូវបានទុកចោល ចំពោះការស្តារឡើងវិញនូវរលកយក្សស៊ូណាមិ ៖ ករណីសិក្សាដកស្រង់ចេញពីអង្គការ UNDP ប្រទេសស្រីលង្កា

ខណៈពេលដែលការធានាការបញ្ជ្រាបយេនឌ័រ នៅក្នុងផែនការ CCDRR នោះវាក៏សំខាន់ផងដែរក្នុងការដែលត្រូវមានទិដ្ឋភាព HRBA និង LNOB ដែលបានដាក់បញ្ចូលទៅក្នុងយុទ្ធសាស្ត្រអនុវត្ត និងផែនការសកម្មភាព។ ផ្នែកនេះផ្តល់នូវសេចក្តីសង្ខេបនៃគម្រោងស្តារឡើងវិញនូវរលកយក្សស៊ូណាមិមួយចំនួន ដែលយកចេញពីទិដ្ឋភាព HRBA និង LNOB ដែលគាំទ្រដោយអង្គការ UNDP។

**ការពិគ្រោះយោបល់របស់ប្រជាជន៖** ធ្វើឡើងក្នុងគោលបំណង ដើម្បីធានាថាសំឡេងរបស់ប្រជាជនដែលរងផលប៉ះពាល់ពីរលកយក្សស៊ូណាមិត្រូវបានគេចងក្រងជាឯកសារហើយពួកគេអាចបង្ហាញពីការត្អូញត្អែររបស់ពួកគេទាក់ទងនឹងដំណើរការនៃការស្តារឡើងវិញ ។ អង្គការ UNDP បានធ្វើការពិគ្រោះយោបល់ជាសាធារណៈយ៉ាងទូលំទូលាយនៅគ្រប់ស្រុកដែល រងផលប៉ះពាល់ដោយសាររលកយក្សស៊ូណាមិ។ លទ្ធផលចុងក្រោយ ដែលរាប់បញ្ចូលទាំងរបាយការណ៍ពិគ្រោះយោបល់របស់ប្រជាជន ក៏ដូចជាឯកសារតាមដានចំនួន២ ដែលផ្អែកលើការពិគ្រោះយោបល់ ( ការវិភាគលទ្ធផលរកឃើញនិងការប៉ាន់ប្រម៉ាណភាពងាយរងគ្រោះ ) បានផ្តល់នូវគណនីលម្អិតនៅក្នុងស្រុកនីមួយៗដែលមានកង្វល់ និងអាទិភាពចម្បងរបស់ប្រជាជនដែលរងគ្រោះដោយរលកយក្សស៊ូណាមិ។

**ការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយនៅកម្រិតសហគមន៍ (DRM)៖** សិក្ខាសាលានិងការពិគ្រោះយោបល់ត្រូវបានអនុវត្តក្នុងចំណោមអ្នកពាក់ព័ន្ធ ដើម្បីដាក់ចេញនូវបទប្បញ្ញត្តិសម្រាប់ធានាថា វិធានការ DRM ត្រូវបានប្រើនៅកម្រិតមូលដ្ឋាន។ ការលំហាត់ស្តីពីការរៀបចំផែនការបម្រុងនៅសហគមន៍ត្រូវបានអនុវត្តដោយអ្នកស្ម័គ្រចិត្តមកពីអង្គការ CBOs, NGOs និងផ្នែកនៃ Grama Niladhari ដែលបានជ្រើសរើស ដើម្បីពង្រឹងសមត្ថភាពរបស់ពួកគេ ក្នុងការប្រឈមនឹងគ្រោះមហន្តរាយ។

**ការត្រួតពិនិត្យគម្រោងដោយមានការចូលរួម៖** AidWatch គឺជាផ្នែកមួយនៃគម្រោងដ៏រឹងមាំដែលបានព្យាយាមផ្តល់ភាពអង់អាចដល់អ្នកទទួលផល ឱ្យកាន់តួនាទីជាអ្នកអនុវត្តភារកិច្ច សម្រាប់ជំនួយដែលបានចែកចាយដល់ពួកគេ។ គណៈកម្មាធិការ AidWatch ដែលបានបង្កើតឡើងដោយអ្នកទទួលផល ត្រូវបានបង្កើតឡើងដើម្បីជូនដំណឹងដល់ប្រជាជនអំពីសិទ្ធិទទួលបានជំនួយនិងសិទ្ធិរបស់ពួកគេ ព្រមទាំងជំរុញឱ្យពួកគេត្រួតពិនិត្យជំនួយដែលនឹងទទួលបាន នៅក្នុងសហគមន៍របស់ពួកគេ និងកាន់តួនាទីជាអ្នកអនុវត្តភារកិច្ចជាអ្នកទទួលខុសត្រូវ។វាត្រូវបានសាកល្បងជាមួយអ្នកទទួលផលពីគម្រោងលំនៅដ្ឋានរបស់អង្គការ UNDPដែលជាកន្លែងដែលពួកគេត្រូវបានលើកទឹកចិត្តឱ្យចូលរួមក្នុងការតាមដាន និងសន្ទនាជាមួយអ្នកអ្នកអនុវត្តភារកិច្ចដែលពាក់ព័ន្ធ ។

**លទ្ធភាពទទួលបានព័ត៌មាន៖** គំនិតផ្តួចផ្តើមស្របគ្នាមួយចំនួន ត្រូវបានអនុវត្ត ដើម្បីលើកកម្ពស់តម្លាភាព និងគណនេយ្យភាពនៃកម្មវិធីស្តារឡើងវិញរបស់អង្គការ UNDP។

១ )ក្រុមប្រឹក្សាជូនដំណឹងសហគមន៍ដែលធ្វើការជូនព័ត៌មានដល់សហគមន៍អំពីជំនួយ ដែលផ្តល់ដោយអង្គការ UNDP នៅក្នុងស្រុកនោះ ត្រូវបានដាក់នៅទីតាំងលេចធ្លោ។
២ ) ខិត្តប័ណ្ណគម្រោងពន្យល់អំពីគម្រោង និងផ្តល់នូវការចែកចាយដល់ អ្នកទទួលផល ក៏ដូចជា អ្នកសារព័ត៌មាន និងមន្ត្រីរដ្ឋាភិបាល។
៣ )ការបណ្តុះបណ្តាលស្តីពីសិទ្ធិនិងសិទ្ធិទទួលបានត្រូវបានផ្តល់ដល់សហគមន៍ដែលត្រូវទទួលផល ដើម្បីឱ្យពួកគេបានដឹងអំពីអ្វីដែលបានកើតមានចំពោះពួកគេ។
៤ ) ប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយតាមទម្រង់ផ្សេងៗ ដើម្បីផ្សព្វផ្សាយព័ត៌មានអំពីសេវាដែលអាចរកបានសម្រាប់សហគមន៍ជូនដល់សហគមន៍ដែលរងគ្រោះដោយសាររលកយក្សស៊ូណាមិ។

**ការពង្រឹងសមត្ថភាពអ្នកសារព័ត៌មាន៖** ការបណ្តុះបណ្តាលអំពីលទ្ធភាពទទួលបានព័ត៌មានត្រូវបានផ្តល់ជូនដល់អ្នកសារព័ត៌មាននៅក្នុងតំបន់ ដើម្បីធានាថា ពួកគេអាចតាមដាន និងរាយការណ៍អំពីការផ្តល់ជំនួយនិងកង្វល់ជាក់លាក់នៅតំបន់ដែលរងគ្រោះដោយរលកយក្សស៊ូណាមិរួមទាំង ការបង្ហាញពីភាពខុសគ្នាណាមួយ នៅក្នុងការផ្តល់ជំនួយនិងឱ្យគេចាប់អារម្មណ៍លើបញ្ហាដែលអាចត្រូវបានមើលរំលង។

**ការិយាល័យជំនួយផ្នែកសិទ្ធិមនុស្ស៖** - គឺជាការតាមដានការពិគ្រោះយោបល់របស់ប្រជាជន ការិយាល័យជំនួយ ត្រូវបានបង្កើតឡើងនៅក្នុងតំបន់ដែលរងគ្រោះដោយរលកយក្សស៊ូណាមិជាពិសេសដើម្បីដោះស្រាយបណ្តឹងទាក់ទងនឹងសិទ្ធិមនុស្សដែលកើតចេញមកពីសហគមន៍ដែលទទួលរងផលប៉ះពាល់។ តាមរយៈការធ្វើការជាមួយអង្គភាពតាមដានការសម្រាលគ្រោះមហន្តរាយនៃគណៈកម្មការសិទ្ធិមនុស្សនៃប្រទេសស្រីលង្កា និងដែលមានទីតាំងនៅការិយាល័យមូលដ្ឋានរបស់គណៈកម្មការសិទ្ធិមនុស្ស

(ឬនៅស្រុកចំនួន៣គណៈកម្មការជំនួយផ្នែកច្បាប់)ការិយាល័យជំនួយទាំងនេះបានចុះបញ្ជីបណ្តឹងដែលបានស៊ើបអង្កេតនិងបានផ្តល់អនុសាសន៍លើរបៀបដែលបណ្តឹងគួរតែត្រូវបានដោះស្រាយ។ លើសពីនេះទៀត ពួកគេបានជូនដំណឹងដល់សហគមន៍ អំពីស្តង់ដារនិងសិទ្ធិទទួលបានសិទ្ធិមនុស្សព្រមទាំងការទំនាក់ទំនងជាមួយអង្គការ CBOs, NGOs, INGOs និងមន្ត្រីរដ្ឋាភិបាល ដើម្បីលើកកម្ពស់គោលការណ៍សិទ្ធិមនុស្ស ដើម្បីឱ្យការងារស្តារ និងការងារស្តារនីតិសម្បទាត្រូវបានធ្វើឡើងតាមរបៀបមួយដែលគោរពសិទ្ធិមនុស្ស និងមានការចូលរួម មានសមធម៌ គ្មានការរើសអើងមានតម្លាភាព និងគណនេយ្យភាព។

**វគ្គបណ្តុះបណ្តាលស្តីពីវិធីសាស្ត្រផ្អែកលើសិទ្ធិមនុស្ស៖** ការបណ្តុះបណ្តាលត្រូវបានផ្តល់ដល់អ្នកអនុវត្តភារកិច្ចលើវិធីសាស្ត្រផ្អែកលើសិទ្ធិមនុស្ស (អង្គការ UNDP ក្រសួងគ្រប់គ្រងគ្រោះមហន្តរាយ និងសិទ្ធិមនុស្ស RADA អង្គភាពតាមដានការសម្រាលគ្រោះមហន្តរាយ មន្ត្រីរដ្ឋាភិបាលក្នុងតំបន់។ល។)។

### មិនមានអ្នកណាម្នាក់ត្រូវបានទុកចោល៖ការផ្តល់ភាពអង់អាចដល់ក្រុមងាយរងគ្រោះការអភិវឌ្ឍសហគ្រាសខ្នាតតូច៖

កម្មវិធីអភិវឌ្ឍន៍សហគ្រាសខ្នាតតូច ផ្តោតលើអ្នកទាំងឡាយណាដែលរងផលប៉ះពាល់ដោយរលកយក្សស៊ូណាមិ ជាពិសេសគ្រួសារក្រីក្រនិងគ្រួសារមានប្រាក់ចំណូលមធ្យម(ជាពិសេសស្ត្រីរួមជាមួយក្រុមងាយរងគ្រោះផ្សេងទៀត ដូចជាជនចំណាកស្រុកក្នុងប្រទេស(IDPs)និងអ្នកត្រលប់មកស្រុកវិញអ្នកគ្មានការងារធ្វើនិងជនពិការ)ដោយផ្តល់ឱ្យពួកគេនូវឱកាសដើម្បីស្តារជីវភាពរបស់ពួកគេឡើងវិញ។ កម្មវិធីនេះ បានផ្តល់ប្រាក់កម្ចីខ្នាតតូចដើម្បីជួយស្តារអាជីវកម្មខ្នាតតូចឡើងវិញ(ឧទាហរណ៍អាជីវកម្មក្រណាត់ចង របាំងមុខ សិប្បកម្មអំពៅ ជាដើម) និងផ្សារភ្ជាប់ពួកគេជាមួយសភាពាណិជ្ជកម្មក្នុងស្រុកដើម្បីជួយពួកគេឱ្យបង្កើតសហគ្រាស និងស្វែងរកទីផ្សារទំនិញរបស់ពួកគេដោយខ្លួនឯង។

**ការនេសាទ៖** កម្មវិធីនេសាទផ្តោតលើការស្តារ និងធ្វើឱ្យប្រសើរឡើងនូវជីវភាពរស់នៅ របស់សហគមន៍ រួមទាំង ការកសាងហេដ្ឋារចនាសម្ព័ន្ធខ្នាតតូច(ឧទាហរណ៍មជ្ឈមណ្ឌលសហគមន៍រោងចក្រទឹកកកនិងកន្លែងលក់រាយដែលផ្តោតលើអ្នកនេសាទខ្នាតតូច) ការកសាងសមត្ថភាព និងការអភិវឌ្ឍ (ឧទាហរណ៍ ដើម្បីបង្កើតសហករណ៍នេសាទ) សមភាពយេនឌ័រ និងការផ្តល់ភាពអង់អាចដល់ស្ត្រី (ការបណ្តុះបណ្តាលស្តីពីការយល់ដឹងអំពីយេនឌ័រក៏ដូចជាភាពជាអ្នកដឹកនាំ ការងារ និងជំនាញអាជីវកម្មសម្រាប់ស្ត្រីដែលមានគោលបំណងបន្ថែមក្នុងការកៀរគរក្រុមស្ត្រីនៅក្នុងវិស័យនេសាទ)។

**ការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ៖** ផែនការបម្រុងរបស់សហគមន៍សម្រាប់គ្រោះមហន្តរាយនាពេលអនាគតត្រូវបានយកមកអនុវត្តនៅក្នុងភូមិងាយរងគ្រោះ។ផែនការនេះបានជួយធ្វើផែនទីកំណត់ធនធានផ្លូវថ្នល់ជំនួសក៏ដូចជាទីតាំងដែលមានសុវត្ថិភាពនិងងាយរងគ្រោះ។ យន្តការរៀបចំផែនការគ្រោះអាសន្នបានផ្តល់អំណាចដល់អ្នកភូមិក្នុងការឆ្លើយតបបានល្អគ្រប់ជ្រុងជ្រោយនៅពេលមានគ្រោះអាសន្នកើតឡើង ហើយវាក៏បានជួយជំរុញ ឱ្យអ្នកខាងក្រៅជួយដល់អ្នកភូមិដែលរងផលប៉ះពាល់ប្រកបដោយប្រសិទ្ធភាពផងដែរ។ បន្ថែមពីលើនេះ បុគ្គលសកម្មដែលបានជ្រើសរើសចេញពីអង្គការស្ម័គ្រចិត្ត អង្គការក្រៅរដ្ឋាភិបាលនៅមូលដ្ឋាន និងយុវជនដែលបានជ្រើសរើសនៅថ្នាក់ភូមិ ត្រូវបានបណ្តុះបណ្តាលអំពីសកម្មភាពឆ្លើយតបនឹងគ្រោះអាសន្នដូចជាការសង្គ្រោះបឋមការហែលទឹក ការពន្លត់អគ្គិភ័យ ការជួយសង្គ្រោះជីវិត ការស្វែងរកនិងការជួយសង្គ្រោះ។ល។

ប្រភព៖ (អង្គការ UNDP ប្រទេសស្រីលង្កា)

---

### ការរៀបចំផែនការយុទ្ធនាការដោយមានការបញ្ចូលចំណេះដឹង និងសារគន្លឹះស្តីពី DRR នៅប្រទេសនេប៉ាល់

កម្មវិធីពង្រឹងភាពធន់នៅទីក្រុង និងការចូលរួម(SURE)ត្រូវបានអនុវត្តដោយសមាគមកាកបាទក្រហមនេប៉ាល់(NRCS)ក្នុងភាពជាដៃគូជាមួយកាកបាទក្រហមអង់គ្លេស (BRC) នៅក្នុងក្រុងចំនួន ៧ ដោយកំណត់គោលដៅក្រុមចំនួន ៤ ដែលងាយរងគ្រោះដោយគ្រោះមហន្តរាយក្នុងក្រុងនីមួយៗដើម្បីបង្កើនការយល់ដឹងអំពីហានិភ័យរបស់ពួកគេចំពោះគ្រោះមហន្តរាយផ្សេងៗនិងវិធានការកាត់បន្ថយដែលពួកគេអាចអនុវត្តបាន។ ការរៀនសូត្រពីកម្មវិធីត្រៀមបង្ការទប់ទល់នឹងការរញ្ជួយដីកន្លងមកសម្រាប់សហគមន៍ដែលមានសុវត្ថិភាព (EPS) បានឆ្លុះបញ្ចាំងថា ការផ្សព្វផ្សាយសារទូទៅដល់ប្រជាជនទាំងមូល គឺគ្មានប្រសិទ្ធភាពក្នុងការបង្កើតការផ្លាស់ប្តូរឥរិយាបទ។ ដូច្នេះ កម្មវិធី SUREបានបង្កើតដំណើរការរៀបចំផែនការយុទ្ធនាការដែលមានការចូលរួម (PCP) ដើម្បីស្វែងយល់ថា តើសារ និងមធ្យោបាយទំនាក់ទំនងណាដែលមានប្រសិទ្ធភាពបំផុតជាមួយក្រុមគោលដៅផ្សេងៗគ្នានៃកម្មវិធី។ វិធីសាស្ត្រ PCP ត្រូវបានបង្កើតឡើងដោយក្រុម ទីស្នាក់ការកណ្តាល BRC និង NRCS នៃកម្មវិធី SURE និងត្រូវបានដាក់ឱ្យដំណើរការដោយក្រុមកម្មវិធីនៅក្នុងក្រុងនីមួយៗ។ សិក្ខាសាលារយៈពេលមួយថ្ងៃដាច់ដោយឡែកមួយត្រូវបានធ្វើឡើងជាមួយក្រុមគោលដៅនីមួយៗនៃកម្មវិធីសរុបចំនួន២៨។

សិក្ខាសាលានេះគឺផ្អែកលើសកម្មភាពនិងការចូលរួមព្រមទាំងស្វែងរកការបង្កើត៖

> គ្រោះថ្នាក់ដែលក្រុមគោលដៅមានអារម្មណ៍ថាពួកគេមានហានិភ័យខ្លាំងបំផុត

> ការធ្វើតេស្តសាកល្បងលើសារសំខាន់ៗដែលមានស្រាប់ ដើម្បីស្វែងយល់ថាតើក្រុមគោលដៅគិតថាសារនីមួយៗមានប្រសិទ្ធភាពក្នុងការផ្លាស់ប្តូរឥរិយាបទដែរឬយ៉ាងណា ហើយប្រសិនបើមិនដូច្នេះទេ តើមូលហេតុអ្វី
> បង្កើតផែនទីឧបសគ្គសម្រាប់ការផ្លាស់ប្តូរឥរិយាបទ
> ស្វែងយល់ពីបណ្តាញសង្គមរបស់អ្នកចូលរួម និងស្វែងយល់អំពីឱកាសល្អបំផុតក្នុងការចែករំលែកព័ត៌មាន
> ស្វែងយល់ពីមធ្យោបាយទំនាក់ទំនងដែលមានប្រសិទ្ធភាពបំផុត
> ស្វែងយល់ពីរបៀបដែលក្រុមគោលដៅផ្សេងៗគ្នាចូលចិត្តផ្តល់យោបល់ត្រឡប់

បន្ទាប់ពីសិក្ខាសាលា ការវិភាគលម្អិត ត្រូវបានធ្វើឡើងដោយក្រុមកម្មវិធី ហើយសារសំខាន់ៗ ជាក់លាក់សម្រាប់ក្រុមគោលដៅ ត្រូវបានបង្កើតឡើងសម្រាប់ក្រុមគោលដៅ ដោយផ្អែកលើលទ្ធផលរកឃើញ។ គោលការណ៍សំខាន់ៗដែលបានយកមកអនុវត្តនៅក្នុងគម្រោងរួមមាន៖

ក) ឲ្យមានការចូលរួមពីសង្គមទាំងអស់ ជាពិសេសជនងាយរងគ្រោះបំផុតនៅក្នុងតំបន់ទីក្រុង និងធ្វើការជាមួយពួកគេដើម្បីបង្កើតភាពធន់របស់ពួកគេចំពោះគ្រោះមហន្តរាយ។

ខ) ការផ្តល់សិទ្ធិអំណាចដល់អាជ្ញាធរមូលដ្ឋាន និងសហគមន៍តាមរយៈធនធាន ការលើកទឹកចិត្ត និងការទទួលខុសត្រូវក្នុងការសម្រេចចិត្ត និង

គ) ការធ្វើសេចក្តីសម្រេចចិត្តប្រកបដោយបរិយាបន្ន និងមានការជូនដំណឹងអំពីហានិភ័យ ខណៈដែលប្រើវិធីសាស្ត្រគ្រោះថ្នាក់ចម្រុះ។ ដំណើរការ PCP ពិនិត្យមើលសារពីគ្រោះថ្នាក់ចម្រុះដែលពីមុនត្រូវបានកំណត់ថា ជាហានិភ័យចំពោះប្រជាជនទាំងនោះ ទាំងចំពោះគ្រោះថ្នាក់ដែលបង្កឡើងដោយមនុស្ស និងគ្រោះថ្នាក់ដែលបង្កដោយធម្មជាតិ។ ដំណើរការ PCP អាចត្រូវបានធ្វើឡើងជាមួយក្រុមអក្ខរកម្ម ក្រុមជនពិការ និងមានគោលបំណងដៅចំពោះក្រុមទាំងនោះ ដែលជារឿយៗពួកគេត្រូវបានគេផាត់ចេញ ឬត្រូវបានគេដកចេញពីដំណើរការធ្វើសេចក្តីសម្រេចចិត្ត ដូចជាស្ត្រីនៅលីវ (ស្ត្រីមេម៉ាយ) និងអ្នកគ្មានដីធ្លី។

## មេរៀនសំខាន់ៗបានមកពីសិក្ខាសាលា៖

**ការពិចារណាអំពីប្រាក់ចំណូល៖** អ្នកចូលរួម PCP ជាច្រើន បានគូសបញ្ជាក់ថា ពួកគេក្រីក្រ ហើយខ្វះខាតធនធានដែលចាំបាច់ត្រូវមានដើម្បីធន់នឹងគ្រោះមហន្តរាយ រួមទាំងទ្រព្យសម្បត្តិ និងគ្រឿងបរិក្ខារ។ ដូចនេះសារដែលជំរុញការប្រើប្រាស់ធនធាន ឧទាហរណ៍ ការរៀបចំសម្ភារសង្គ្រោះ និងសាងសង់ផ្ទះតាមលេខកូដអគារ នឹងមិននាំទៅរកការផ្លាស់ប្តូរឥរិយាបទឡើយ។

**ភាពអាចរកបាន៖** ក្នុងករណីដែលសារទាក់ទងនឹងគ្រោះថ្នាក់ចរាចរណ៍ដែលជនពិការបានជំទាស់ថាវានឹងពិបាកក្នុងការធ្វើតាមសារដែលស្នើឱ្យពួកគេដើរលើផ្លូវថ្មើរជើង ដោយសារផ្លូវថ្មើរជើងមិនងាយស្រួលសម្រាប់ជនពិការ។ ស្រដៀងគ្នានេះដែរប្រជាជនដែលរស់នៅតាមច្រាំងទន្លេ បាននិយាយថា សារដែលស្នើឱ្យប្រជាជនផ្លាស់ទីជម្រកបណ្តោះអាសន្នក្នុងពេលមានទឹកជំនន់ គឺពុំមានប្រសិទ្ធភាពអ្វីនោះទេ ពីព្រោះពួកគេពុំមានលទ្ធភាពទទួលបានទីជម្រក។

**លទ្ធភាពទទួលបាន៖** វាក៏មានសារៈសំខាន់ផងដែរ ក្នុងការពិចារណាលើជនពិការ។ ឧទាហរណ៍ ការព្រមានអំពីទឹកជំនន់ដែលផ្សព្វផ្សាយតាមរយៈស៊ីរ៉ែន និងវិទ្យុគឺគ្មានប្រសិទ្ធភាពចំពោះអ្នកដែលមិនអាចស្តាប់ឮបាន។

**ស្ថានភាពសង្គម៖** ក្រុមគោលដៅនៅដាលីត (Dalit) បាននិយាយថា ពួកគេមិនអាចអនុវត្តតាមសារដែលស្នើឱ្យពួកគេទៅកាន់ទីជម្រកដែលមានសុវត្ថិភាពក្នុងកំឡុងពេលមានគ្រោះមហន្តរាយបាន ដោយសារតែពួកគេ ត្រូវបានផាត់ចេញពីសង្គម និងមិនត្រូវបានអនុញ្ញាតឱ្យចូលទៅកាន់កន្លែងដែលគេហៅថាវណ្ណៈខ្ពស់ៗដទៃទៀត។

ប្រភព៖ (សហព័ន្ធ IFRC ឆ្នាំ២០១៨)។

EmPower
Women for Climate-Resilient Societies

Sweden
Sverige

arrow
asian-pacific resource & research centre for women

UN WOMEN



# សៀវភៅណែនាំ បណ្តុះបណ្តាលស្តីពី យេនឌ័រនិងភាពធន់នឹង ការប្រែប្រួលអាកាសធាតុ

## ម៉ូឌុល ៣៖

3

### ឧបករណ៍សម្រាប់ ការបញ្ជ្រាបយេនឌ័រ

## ផែនការតាមវគ្គ៖

ម៉ូឌុលនេះចែកជា ២ វគ្គ ដែលផ្អែកលើប្រធានបទតែមួយ (ក្របខ័ណ្ឌការងារ និងឧបករណ៍បញ្ជ្រាបយេនឌ័រ) ប៉ុន្តែលើកឡើងពីដំណាក់កាលផ្សេងៗនៃវដ្តគម្រោង។ វគ្គទីមួយផ្តោតលើការវិភាគយេនឌ័រ ការរៀបចំ និងការរចនាគម្រោង ចំណែកវគ្គទីពីរផ្តោតលើការអនុវត្ត ការតាមដាន និងការវាយតម្លៃ។

**វគ្គ ក** : ក្របខ័ណ្ឌការងារ និងឧបករណ៍បញ្ជ្រាបយេនឌ័រសម្រាប់អង្គការសង្គមស៊ីវិល
(ការវិភាគ ការវាយតម្លៃ និងការរៀបចំផែនការ)

**វគ្គ ខ** : ក្របខ័ណ្ឌ និងឧបករណ៍បញ្ជ្រាបយេនឌ័រសម្រាប់អង្គការសង្គមស៊ីវិល
(ការអនុវត្ត ការតាមដាន និងវាយតម្លៃ)

## ម៉ូឌុល ៣ ៖ ឧបករណ៍សម្រាប់ការបញ្ជ្រាបយេនឌ័រ

ម៉ូឌុលនេះនឹងបង្ហាញពីឧបករណ៍បញ្ជ្រាបយេនឌ័រផ្សេងៗសម្រាប់ការវិភាគបញ្ហា ដែលមានទស្សនៈយេនឌ័រ ការរៀបចំ និងរចនាគម្រោង ការអនុវត្ត ការពិនិត្យតាមដាន និងវាយតម្លៃ។ ផ្អែកលើក្របខណ្ឌស្ថាប័ននិងរចនាសម្ព័ន្ធអង្គការដែលបានបង្ហាញក្នុងម៉ូឌុលមុន ម៉ូឌុលនេះពិភាក្សាពីឧបករណ៍សម្រាប់ប៉ាន់ប្រម៉ាណភាពស្មុគស្មាញនៃសហគមន៍មូលដ្ឋានចេញពីទស្សនៈយេនឌ័រ ការបង្កើតផែនការសកម្មភាពយេនឌ័រ និងប្រព័ន្ធតាមដាន និងវាយតម្លៃរំញោចយេនឌ័រ។

### គោលបំណងនៃម៉ូឌុល៖

> ផ្តល់ទិដ្ឋភាពរួមស្តីពីឧបករណ៍បញ្ជ្រាបយេនឌ័រសម្រាប់ការវិភាគបញ្ហា ការរចនាគម្រោង ការអនុវត្ត និងការតាមដាន និងវាយតម្លៃ

> ផ្តល់មគ្គុទេសក៍ជាជំហានៗសម្រាប់ការអនុវត្តឧបករណ៍បញ្ជ្រាបយេនឌ័រក្នុងបរិបទ CCDRR និង

> ផ្តល់ការណែនាំលើការអនុវត្ត ដើម្បីជួយដល់ការជ្រើសរើសជម្រើសសមស្របបំផុតសម្រាប់បរិបទមួយ។

### សារសំខាន់ៗ៖

> ការបញ្ជ្រាបយេនឌ័រជា "...ដំណើរការនៃការប៉ាន់ប្រមាណផលវិបាកនៃសកម្មភាពបានគ្រោងឡើងរួមទាំងច្បាប់គោលនយោបាយ ឬកម្មវិធី ចំពោះស្ត្រី និងបុរស នៅគ្រប់ផ្នែក និងគ្រប់កម្រិត" (របាយការណ៍របស់ក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គម ឆ្នាំ១៩៩៧)។ ចំណុចនេះរួមបញ្ចូលកាលទាំង ៤ នៃវដ្តគម្រោង ដូចជា ការកំណត់រកបញ្ហា ការរចនាគម្រោង ការអនុវត្ត និងការតាមដាន និងវាយតម្លៃ។

> ការវិភាគយេនឌ័រ ជាការវិភាគដែលផ្តោតលើការបែងចែក "ធនធាន ឱកាស ឧបសគ្គ និងអំណាចក្នុងបរិបទមួយ" ផ្អែកតាមយេនឌ័រ (SIDA ឆ្នាំ ២០១៥)។ ការវិភាគយេនឌ័រមានគោលបំណងបង្កើតការឆ្លើយតបដើម្បីលុបបំបាត់វិសមភាពផ្អែកតាមយេនឌ័រក្នុងការសម្រេចបានសក្តានុពលពេញលេញរបស់មនុស្ស។

> ការវិភាគយេនឌ័រដែលពាក់ព័ន្ធនឹងការប្រមូលទិន្នន័យពាក់ព័ន្ធបែងចែកតាមភេទ ការកំណត់រកបញ្ហាយេនឌ័រដែលពាក់ព័ន្ធនឹងតួនាទីរបស់បុរស និងស្ត្រី ក៏ដូចជាគោលជំហរ សមត្ថភាព និងវិសមភាពរបស់ពួកគេ គឺជាគន្លឹះនៃការបញ្ជ្រាបយេនឌ័រ។ មានក្របខ័ណ្ឌ និងឧបករណ៍ជាច្រើនសម្រាប់ការវិភាគយេនឌ័រ ជាអាទិ៍ ក្របខ័ណ្ឌ Moser ក្របខ័ណ្ឌវិភាគ Harvard ការវាយតម្លៃភាពងាយរងគ្រោះដែលមានទស្សនៈយេនឌ័រ និងការវាយតម្លៃ"មិនមានអ្នកណាម្នាក់ត្រូវបានទុកចោល-LNOB"។ ការរចនាគម្រោងដែលឆ្លើយតបនឹងតម្រូវការយេនឌ័រទាមទារការវិភាគយេនឌ័រជាមុននិងការដាក់បញ្ចូលលទ្ធផលរកឃើញ ឬតម្រូវការយេនឌ័រទៅក្នុងគោលដៅ លទ្ធផល ទិន្នផល និងសកម្មភាពគម្រោង។ ក្របខ័ណ្ឌបុព្វហេតុ ផលវិបាក និងដំណោះស្រាយនិងក្របខ័ណ្ឌវិភាគសមត្ថភាពនិងភាពងាយរងគ្រោះ សុទ្ធតែជាឧបករណ៍ដ៏មានប្រយោជន៍។

> ការអនុវត្តរំញោចយេនឌ័រ រួមមានការវិភាគអ្នកពាក់ព័ន្ធ និងការចូលរួមប្រកបដោយអត្ថន័យរបស់អ្នកពាក់ព័ន្ធទាំងអស់ ជាពិសេសស្ត្រីការសម្របសម្រួលការបង្កើតផែនការសកម្មភាពនៅសហគមន៍មូលដ្ឋាន និងការធានាទំនាក់ទំនង ការផ្ទេរចំណេះដឹង និងការកសាងសមត្ថភាពសមស្រប។

> អ្វីដែលសំខាន់ផងដែរនោះគឺត្រូវធានាការតាមដានវឌ្ឍនភាពនៃការបញ្ជ្រាបយេនឌ័រ ពាក់ព័ន្ធនឹងដំណើរការ និងលទ្ធផលតាមរយៈវិធីសាស្ត្រផ្អែកលើលទ្ធផលដែលប្រើប្រាស់សូចនាករដែលមានទស្សនៈយេនឌ័រ ឬប្រើប្រាស់សញ្ញាក្រើនរំលឹកក្នុងម៉ាទ្រិចតាមដានយេនឌ័រ។

> គួរចាត់ទុកការបញ្ជ្រាបយេនឌ័រជាដំណើរការបន្តជាប់មិនមែនជាសកម្មភាពដាច់ដោយឡែកមួយនោះទេ។ការធានាការចូលរួមរបស់ស្ត្រីក្នុងនាមជាអ្នកពាក់ព័ន្ធ និងដៃគូស្មើភាពនៅគ្រប់ដំណាក់កាលនៃវដ្តគម្រោងគឺជាឧបករណ៍ដ៏សំខាន់សម្រាប់ការបញ្ជ្រាបយេនឌ័រ។

# ម៉ូឌុល៣ វគ្គ ក៖

**4:00:00**

## ក្របខ័ណ្ឌការងារ និងឧបករណ៍បញ្ជ្រាបយេនឌ័រសម្រាប់អង្គការសង្គមស៊ីវិល (ការវិភាគ ការវាយតម្លៃ និងការរៀបចំផែនការ)

**ទិដ្ឋភាពទូទៅ**

នៅចុងបញ្ចប់នៃវគ្គនេះ អ្នកចូលរួមនឹងមានចំណេះដឹងមូលដ្ឋានស្ដីពីឧបករណ៍ និងបច្ចេកទេសផ្សេងៗសម្រាប់ការបញ្ជ្រាបយេនឌ័រក្នុងវដ្ដគម្រោង។អ្នកចូលរួមនឹងបានដឹងពីដំណើរការជាជំហានៗសម្រាប់ការអនុវត្តឧបករណ៍ទាំងនេះ និងអាចកំណត់ជម្រើសសមស្របបំផុតសម្រាប់ការអនុវត្តក្នុងការងាររបស់ខ្លួន។

**មាតិកា**

ក) ការបញ្ជ្រាបយេនឌ័រក្នុងវដ្ដគម្រោង
ខ) ការវិភាគយេនឌ័រដែលជាគន្លឹះនៃការបញ្ជ្រាបយេនឌ័រ
- ក. ក្របខ័ណ្ឌ Moser
- ខ. ក្របខ័ណ្ឌវិភាគ Harvard
- គ. ម៉ាទ្រិចវិភាគយេនឌ័រ (GAM)

គ) ឧបករណ៍ប៉ាន់ប្រម៉ាណភាពងាយរងគ្រោះដែលមានទស្សនៈយេនឌ័រសម្រាប់គម្រោង CCDRR
- ក.ក្របខ័ណ្ឌវិភាគសមត្ថភាព និងភាពងាយរងគ្រោះ
- ខ.ការប៉ាន់ប្រម៉ាណភាពងាយរងគ្រោះដែលមានទស្សនៈយេនឌ័រ
- គ.សន្ទស្សន៍ភាពជន់របស់ស្ត្រី
- ឃ.ឧបករណ៍ប៉ាន់ប្រម៉ាណការកាត់បន្ថយភាពងាយរងគ្រោះ
- ង.ការប៉ាន់ប្រម៉ាណសម្រាប់វិបត្តិ
- ច.ការសិក្សាកំណត់វិសាលភាពតាមវិស័យ
- ឆ.ការប៉ាន់ប្រម៉ាណ "មិនមានអ្នកណាម្នាក់ត្រូវបានទុកចោល"

ឃ) ការរៀបចំផែនការ ការរៀបចំ និងការរចនាគម្រោងដែលឆ្លើយតបនឹងតម្រូវការយេនឌ័រ
- ក.ឧបករណ៍មាត្រដ្ឋានប៉ាន់ប្រម៉ាណដែលឆ្លើយតបនឹងតម្រូវការយេនឌ័រ (GRAS)
- ខ.ក្របខ័ណ្ឌបុព្វហេតុ ផលវិបាក និងដំណោះស្រាយ (CCS)

**សម្ភារៈ**

ស្លាយ
ក្ដារខៀន និងប៊ិចហ្វឺតធំ
ក្រដាសផ្ទាំងធំ និងប៊ិច
សំណៅឯកសារ ១ ច្បាប់

**តារាងពេលវេលា**

| រយៈពេល | សកម្មភាព |
|---|---|
| ២០ នាទី | >បាឋកថាស្ដីពីការបញ្ជ្រាបយេនឌ័រក្នុងវដ្ដគម្រោង |
| ២០ នាទី | >ស្លាយស្ដីពី "ការវិភាគយេនឌ័រ ៖ តម្រូវការ ដំណើរការ និងជ្រើសរើសឧបករណ៍" |
| ៤០ នាទី | >វគ្គអនុវត្តន៍ "ក្របខ័ណ្ឌ Moser សម្រាប់ការរៀបចំផែនការ" (សូមមើលលំហាត់ទី ១៥) (សម្រាប់វគ្គមូលដ្ឋានគ្រឹះ) |
| | ឬ |
| | >វគ្គអនុវត្តន៍ "ក្របខ័ណ្ឌវិភាគ Harvard" (សូមមើលលំហាត់ទី ១៦) (សម្រាប់វគ្គកម្រិតខ្ពស់) |
| ៦០ នាទី | >ស្លាយស្ដីពី "ឧបករណ៍សម្រាប់ការប៉ាន់ប្រម៉ាណភាពងាយរងគ្រោះដែលមានទស្សនៈយេនឌ័រសម្រាប់គម្រោង CCDRR" (សម្រាប់វគ្គកម្រិតខ្ពស់) |
| ៣០ នាទី | >កិច្ចពិភាក្សាក្រុមតូចស្ដីពី "ឧទាហរណ៍នៃការប៉ាន់ប្រម៉ាណយេនឌ័រ" (សូមមើលលំហាត់ទី ១៧ និងសំណៅឯកសារទី ១២) |
| ៣០ នាទី | >ស្លាយស្ដីពី "ការរៀបចំផែនការ ការរៀបចំ និងការរចនាគម្រោងដែលឆ្លើយតបនឹងតម្រូវការយេនឌ័រ" |
| ៦០ នាទី | >វគ្គអនុវត្តន៍ "ក្របខ័ណ្ឌបុព្វហេតុ ផលវិបាក និងដំណោះស្រាយ" (សូមមើលលំហាត់ទី ១៨) (សម្រាប់វគ្គមូលដ្ឋានគ្រឹះ) |

## កំណត់សម្គាល់ណែនាំ

ចាប់ផ្តើមវគ្គដោយបង្ហាញនិយមន័យនៃការបញ្ជ្រាបយេនឌ័រ និងពិភាក្សាពីទំនាក់ទំនងទៅនឹងវដ្តគម្រោង។ បន្ទាប់មកប្រើរូបទី ១២ ដើម្បីរៀបរាប់ពីវិធីសាស្ត្រនិងឧបករណ៍ផ្សេងៗនៃការបញ្ជ្រាបយេនឌ័រសម្រាប់គម្រោងអាកាសធាតុ។ ព្រីនរូបទី ១២ លើផ្ទាំងបដាដើម្បីងាយស្រួលយកមកបង្ហាញ។ ប្រាប់អ្នកចូលរួមថា ក្នុងម៉ូឌុលទី ២ យើងបានពិភាក្សាពីចំណុចចាប់ផ្តើមសម្រាប់ការបញ្ជ្រាបយេនឌ័រនៅកម្រិតស្ថាប័ន និងកម្រិតគោលនយោបាយ។ សម្រាប់ម៉ូឌុលនេះ យើងនឹងផ្តោតលើចំណុចចាប់ផ្តើមផ្សេងៗនៅកម្រិតកម្មវិធី/កម្រិតគម្រោង។ ប្រាប់អ្នកចូលរួមថា អ្នកនឹងពិភាក្សាពីដំណាក់កាលដំបូង ៣ នៃវដ្តគម្រោងក្នុងវគ្គនេះ ចំណែកដំណាក់កាលផ្សេងទៀតនឹងលើកមកពិភាក្សាក្នុងវគ្គបន្ទាប់។ សួរអ្នកចូលរួមថា តើពួកគេបានដឹងពីក្របខ័ណ្ឌការងារ ឬឧបករណ៍ដែលជួយដល់ការបញ្ជ្រាបយេនឌ័រដែរឬទេ។ លើកទឹកចិត្តឱ្យអ្នកចូលរួមចែករំលែកបទពិសោធន៍នៃការប្រើប្រាស់ឧបករណ៍ទាំងនោះ។ ប្រើរូបទី ១២ ដើម្បីផ្តល់ឧទាហរណ៍នៃរបៀបប្រើប្រាស់ឧបករណ៍បញ្ជ្រាបយេនឌ័រផ្សេងៗក្នុងគម្រោងCCDRR។ ប្រាប់អ្នកចូលរួមថាអ្នកនឹងពិភាក្សាឧបករណ៍មួយចំនួនដើម្បីស្វែងយល់ពីដំណើរការប្រើប្រាស់ រួចទើបអ្នកឱ្យពួកគេអនុវត្តឧបករណ៍ទាំងនោះ។

បង្កើតស្លាយស្តីពី "ការវិភាគយេនឌ័រ ៖ តម្រូវការ ដំណើរការ និងជ្រើសរើសឧបករណ៍" ដោយផ្តោតសំខាន់លើភាពចាំបាច់នៃការវិភាគយេនឌ័រ ក្របខ័ណ្ឌ Moser និងក្របខ័ណ្ឌ Harvard។ ត្រួតពិនិត្យវគ្គអនុវត្តន៍ក្របខ័ណ្ឌណាមួយក្នុងចំណោមក្របខ័ណ្ឌទាំងពីរទៅតាមកម្រិតនៃវគ្គ៖ ក្របខ័ណ្ឌMoserសម្រាប់វគ្គមូលដ្ឋានគ្រឹះ (សូមមើលលំហាត់ទី ១៥) និងក្របខ័ណ្ឌ Harvard សម្រាប់វគ្គកម្រិតខ្ពស់ (សូមមើលលំហាត់ទី ១៦)។ រំលឹកអ្នកចូលរួមពីវគ្គកម្រិតខ្ពស់ដែលពួកគេបានអនុវត្តក្របខ័ណ្ឌ Moser ក្នុងម៉ូឌុលទី ១-វគ្គ គ (លំហាត់ទី ៧)។

សម្រាប់វគ្គកម្រិតខ្ពស់ សូមបង្កើតស្លាយស្តីពី "ឧបករណ៍ប៉ាន់ប្រម៉ាណភាពងាយរងគ្រោះដែលមានទស្សនៈយេនឌ័រសម្រាប់គម្រោង CCDRR"។ បង្ហាញទិដ្ឋភាពរួមដល់អ្នកចូលរួមស្តីពី ឧបករណ៍ដែលមានទាំងអស់ក្នុងម៉ូឌុលនេះ។ សូមកុំរ៉ាយរ៉ាប់លម្អិតអំពីឧបករណ៍ទាំងអស់ ប៉ុន្តែសូមជ្រើសរើសឧបករណ៍ ២ ឬ ៣ ទៅតាមកម្រិត និងចំណាប់អារម្មណ៍របស់អ្នកចូលរួម (ថាតើពួកគេជាអ្នកអនុវត្តន៍គម្រោង ឬផ្តោតលើគោលនយោបាយ/ការស្រាវជ្រាវ។ សូមមើលតារាងទី ៥ ដើម្បីជាត្រីវិស័យសម្រាប់ការជ្រើសរើសឧបករណ៍។

ត្រួតពិនិត្យកិច្ចពិភាក្សាក្នុងក្រុមតូច ស្តីពី "ឧទាហរណ៍នៃការប៉ាន់ប្រម៉ាណយេនឌ័រ" (សូមមើលលំហាត់ទី ១៧ និងសំណៅឯកសារទី ១២)។ សម្រាប់វគ្គមូលដ្ឋានគ្រឹះ សូមរំលងបទបង្ហាញ និងផ្តោតលើលំហាត់តែម្តង ហើយប្រសិនបើអ្នកចង់សម្រាក នេះពេលដែលអ្នកអាចលែលកបាន។

បន្តទៅដំណាក់កាលបន្ទាប់ដោយប្រើស្លាយស្តីពី "ការរៀបចំនិងការរចនាគម្រោងដែលឆ្លើយតបនឹងតម្រូវការយេនឌ័រ"។ សម្រាប់វគ្គកម្រិតខ្ពស់សូមបញ្ចប់វគ្គដោយប្រើស្លាយនេះ។ ប្រាប់អ្នកចូលរួមថាពួកគេនឹងរៀនអនុវត្តឧបករណ៍ GRAS ក្នុងវគ្គ ក នៃម៉ូឌុលទី ៤ ប៉ុន្តែសម្រាប់វគ្គមូលដ្ឋានគ្រឹះ ពួកគេត្រូវរៀនអនុវត្ត "ក្របខណ្ឌបុព្វហេតុ ផលវិបាក និងដំណោះស្រាយ" (សូមមើលលំហាត់ទី ១៨)។

## ការបញ្ជ្រាបយេនឌ័រ និងការវិភាគយេនឌ័រ

### ការបញ្ជ្រាបយេនឌ័រក្នុងវដ្តគម្រោង

ការបញ្ជ្រាបយេនឌ័រជា"...ដំណើរការនៃការប៉ាន់ប្រមាណផលវិបាកនៃសកម្មភាពដែលបានគ្រោងឡើងរួមទាំងច្បាប់ គោលនយោបាយ ឬកម្មវិធី ចំពោះស្ត្រី និងបុរស នៅគ្រប់ផ្នែក និងគ្រប់កម្រិត។ វាជាយុទ្ធសាស្ត្រសម្រាប់ការធ្វើយ៉ាងណាឱ្យក្តីបារម្ភ និងបទពិសោធន៍របស់ស្ត្រី និងបុរសក្លាយជាចំណុចស្នូលនៃការរចនា ការអនុវត្ត ការតាមដាន និងវាយតម្លៃគោលនយោបាយ និងកម្មវិធីក្នុងវិស័យនយោបាយ សេដ្ឋកិច្ច និងសង្គមទាំងអស់ដើម្បីឱ្យស្ត្រីនិងបុរសទទួលបានអត្ថប្រយោជន៍ស្មើគ្នានិងគ្មានវិសមភាពតទៅទៀត" (របាយការណ៍របស់ក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គម ឆ្នាំ ១៩៩៧)។ ចាំបាច់ត្រូវកត់សម្គាល់ថា ភាសាដែលមានន័យពីរផ្លូវ ( binary language ) សម្រាប់ការប៉ាន់ប្រម៉ាណផលវិបាកចំពោះបុរសនិងស្ត្រីចេះតែវិវត្តទៅមុខនិងរួមបញ្ចូលអត្តសញ្ញាណយេនឌ័រផ្សេងទៀត (ក្រុម LGBTIQ)។ ក្រៅពីនេះ ស្ត្រីមិនមែនជាក្រុមឯកពន្ធនោះទេហើយការបញ្ជ្រាបយេនឌ័រត្រូវរួមបញ្ចូលអន្តរវិស័យភាពខាងយេនឌ័រ និងផ្តោតលើក្រុមស្ត្រីជាក់លាក់ ទៅតាមអាយុ សមត្ថភាព (ពិការភាព) ថ្នាក់ ជាតិសាសន៍ ជាតិពន្ធុ ស្ថានភាពសង្គម។ល។

ចាំបាច់ត្រូវពិចារណាពីការបញ្ជ្រាបយេនឌ័រនៅគ្រប់កម្រិត (ស្ថាប័ន គោលនយោបាយ កម្មវិធី/គម្រោង) និងនៅគ្រប់ដំណាក់កាល (ការកំណត់គម្រោង ការវិភាគស្ថានភាព ការវាយតម្លៃ និងការរៀបចំផែនការ ការអនុវត្ត និងការតាមដាន និងវាយតម្លៃ)។ ចំណុចចាប់ផ្តើមនីមួយៗទាមទារយុទ្ធសាស្ត្រផ្សេងមួយដែលកែសម្រួលទៅតាមបរិបទ និងតួអង្គពាក់ព័ន្ធ។

**ចំណុចពិភាក្សា**

ឱ្យអ្នកចូលរួមគិតពីវិធីសាស្ត្រវដ្តគម្រោងរួចបង្ហាញពីរបៀបពិចារណាលើយេនឌ័រនៅដំណាក់កាលនីមួយៗ។

**តម្រុយសម្រាប់អ្នកសម្របសម្រួល**

> ធានាថាការវិភាគយេនឌ័រគឺជាផ្នែកដ៏សំខាន់នៃដំណាក់កាលកំណត់បញ្ហា និងប៉ាន់ប្រម៉ាណហានិភ័យ និងមានការប្រមូលទិន្នន័យបែងចែកតាមភេទ។
> ប៉ាន់ប្រម៉ាណផលវិបាកផ្សេងៗនៃអន្តរាគមន៍ដែលគ្រោងធ្វើឡើងសម្រាប់បុរស ស្ត្រី និងអ្នកដែលមានអត្តសញ្ញាណយេនឌ័រផ្សេងទៀត។ អនុវត្តអន្តរវិស័យភាពខាងយេនឌ័រដើម្បីកំណត់អត្តសញ្ញាណជនងាយរងគ្រោះបំផុត។ ធានាផ្តោតអាទិភាពលើការអនុវត្តដែលលើកឡើងពីសមភាពយេនឌ័រ និងផ្តល់ថវិកាគ្រប់គ្រាន់។
> ធានាថា ស្ត្រីចូលរួមដោយស្មើភាព និងយ៉ាងសកម្មដូចបុរសដែរ និងត្រូវបានផ្តល់ឱកាសឱ្យកាន់តួនាទីដឹកនាំក្នុងវដ្តគម្រោង។ ចំណុចនេះរួមបញ្ចូលការធានាលទ្ធភាពស្មើភាពក្នុងការទទួលបានព័ត៌មាន និងការបណ្តុះបណ្តាល និងទាមទារនូវការបង្កើតអង្គការ ឬគណៈកម្មាធិការស្ត្រី។
> តាមដាន និងវាយតម្លៃការផ្លាស់ប្តូរទំនាក់ទំនងយេនឌ័រដោយប្រើសូចនាកររំញោចយេនឌ័រ។
> ក្រៅពីនេះធានាថាការរៀបចំផ្នែកស្ថាប័នរបស់អង្គការអនុវត្តន៍គាំទ្រសមភាពយេនឌ័រដោយធានាថាមានក្រុមដែលមានតុល្យភាពយេនឌ័រ និងជំនាញយេនឌ័រគ្រប់គ្រាន់នៅគ្រប់កម្រិតក្នុងអង្គការនោះ និងការដោះស្រាយបញ្ហាវប្បធម៌ ដូចជា វប្បធម៌អង្គការ ឥរិយាបថរបស់បុគ្គលិក ប្រព័ន្ធសម្រាប់ការរៀនសូត្រ និងការការពារអ្នកពាក់ព័ន្ធជាស្ត្រីគ្រប់រូបឱ្យរួចផុតពីការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទ។

## រូបទី ២០ ៖ វិធីសាស្ត្រ និងឧបករណ៍នៃការបញ្ជ្រាបយេនឌ័រសម្រាប់គម្រោងអាកាសធាតុ




ប្រភព ៖ ដកស្រង់ចេញពី Glemarec et al ឆ្នាំ ២០១៦

## រូបទី ២១ ៖ សំណួរសំខាន់ៗសម្រាប់ការវិភាគយេនឌ័រ



## ការវិភាគយេនឌ័រដែលជាគន្លឹះនៃការបញ្ជ្រាបយេនឌ័រ

### ភាពចាំបាច់នៃការវិភាគយេនឌ័រ

ការវិភាគយេនឌ័រជា ការវិភាគដែលផ្តោតលើការបែងចែក "ធនធាន ឱកាស ឧបសគ្គ និងអំណាចក្នុងបរិបទមួយ" ផ្អែកតាមយេនឌ័រ (SIDA ឆ្នាំ ២០១៥)។ ការវិភាគយេនឌ័រមានគោលបំណងបង្កើតការឆ្លើយតបដើម្បីលុបបំបាត់វិសមភាពផ្អែកលើយេនឌ័រក្នុងការសម្រេចបានសក្តានុពលពេញលេញរបស់មនុស្ស។

ចាំបាច់ត្រូវធ្វើការវិភាគយេនឌ័រជាជំហានដំបូងមួយនៃការបញ្ជ្រាបយេនឌ័រដើម្បីកំណត់រកតួនាទី តម្រូវការ ផលប្រយោជន៍ និងវិសមភាពយេនឌ័រ។ចំណុចនេះពាក់ព័ន្ធនឹងការប្រមូលទិន្នន័យពាក់ព័ន្ធដែលបែងចែកតាមភេទការកំណត់រកបញ្ហាយេនឌ័រដែលពាក់ព័ន្ធនឹងតួនាទីរបស់បុរស និងស្ត្រី ក៏ដូចជាគោលជំហរសមត្ថភាពនិងវិសមភាពរបស់ពួកគេ។ការវិភាគយេនឌ័រជួយដល់ការយល់ដឹងអំពីការងារយេនឌ័រក្នុងការប្រែប្រួលអាកាសធាតុក៏ដូចជាបញ្ហាសមភាពក្នុងផ្នែកសង្គមសេដ្ឋកិច្ច វប្បធម៌ និងរចនាសម្ព័ន្ធ ដែលបង្កប់ក្នុងផលប៉ះពាល់នៃអន្តរាគមន៍ និងយុទ្ធសាស្ត្របន្សាំ។

១. ការវិភាគយេនឌ័រត្រូវសួរសំណួរខាងក្រោម (រូបទី ២១)៖
តើមានបរិបទសង្គមសេដ្ឋកិច្ច និងបទដ្ឋានវប្បធម៌អ្វីខ្លះដែលពាក់ព័ន្ធនឹងសមភាពយេនឌ័រ?
- វិភាគបរិបទសង្គមសេដ្ឋកិច្ច និងភាពតំណាងយេនឌ័រ
តើអ្វីជាបរិបទប្រជាសាស្ត្រ ច្បាប់ សង្គម និងសេដ្ឋកិច្ច និងបទដ្ឋានដែលពាក់ព័ន្ធនឹងសមភាពយេនឌ័រដែលជះឥទ្ធិពល
- លើឥរិយាបថរបស់មនុស្សក្នុងតំបន់ ឬសហគមន៍?
ប្រសិនបើមានភាពខុសគ្នា ផ្អែកយេនឌ័រនិងសង្គម តើមានកត្តាស្ថាប័ន កត្តាសេដ្ឋកិច្ច និងកត្តាសង្គមអ្វីខ្លះដែលជាមូលដ្ឋាន គាំទ្រ ឬជះឥទ្ធិពលលើ ភាពខុសគ្នាទាំងនោះ?

២.
តើនរណាទទួលខុសត្រូវលើការថែទាំ ការគ្រប់គ្រងធនធាន និងប្រាក់ចំណូល?
- វិភាគតួនាទីយេនឌ័រ និងការទទួលខុសត្រូវ
- តើនរណាធ្វើកិច្ចការអ្វី?
តើមានភាពខុសគ្នារវាងតួនាទីការទទួលខុសត្រូវនិងអាទិភាពរបស់បុរស និងស្ត្រី ក្នុងជីវភាពសាធារណៈ ឬជីវភាពឯកជន
- ឬទេ?
- តើនរណាពាក់ព័ន្ធក្នុងការគ្រប់គ្រងធនធាន?
- តើនរណាប្រើប្រាស់ធនធានដែលផ្តល់ប្រាក់ចំណូល?
តើនរណាពាក់ព័ន្ធក្នុងសកម្មភាពរកទទួលទាន និងចិញ្ចឹម
- ជីវិត?
- តើនរណាជាអ្នកថែទាំក្នុងគ្រួសារ?
- តើអ្វីជាការទទួលខុសត្រូវ តម្រូវការ ផលប្រយោជន៍ និងសមត្ថភាពទាំងសម្រាប់ស្ត្រី និងបុរស?

៣. តើនរណាមានលទ្ធភាពទទួលបាន គ្រប់គ្រង និងកាន់កាប់ធនធាន ទំនិញ និងសេវា?
វិភាគសិទ្ធិយេនឌ័រលើធនធាន
- តើនរណាមានសិទ្ធិ និងសិទ្ធិទទួលបានលើធនធាន និងសេវា?
- តើនរណាកាន់កាប់អ្វី?
- តើនរណាគ្រប់គ្រងអ្វី?
- តើនរណាមានលទ្ធភាពទទួលបានអ្វី?
- តើអ្វីខ្លះជាសិទ្ធិទទួលបាន (ឧ. ការអប់រំ សុខភាព កម្មសិទ្ធិដីធ្លី)? តើនរណាជាអ្នកទទួលបានសិទ្ធិទាំងនោះ?
- តើទំនិញ និងសេវាត្រូវបានបែងចែកដោយរបៀបណា?

៤. តើនរណាជាអ្នកសម្រេចចិត្តគ្រប់បែបយ៉ាងនៅកម្រិតគ្រួសារ និងកម្រិតសហគមន៍?
វិភាគដំណើរការធ្វើសេចក្តីសម្រេចចិត្ត
- តើនរណាពាក់ព័ន្ធក្នុងការដឹកនាំនិងការសម្រេចចិត្តនៅគ្រប់កម្រិត (ចាប់ពីគោលនយោបាយ កិច្ចព្រមព្រៀង និងការបន្សាំនៅកម្រិតមូលដ្ឋាន រហូតដល់កម្រិតអន្តរជាតិ)
- តើនរណាមានលទ្ធភាពទទួលបានព័ត៌មាន?
- តើនរណាជាអ្នកគ្រប់គ្រងការបែងចែកធនធាន?
- តើនរណាជាអ្នកបែងចែកអត្ថប្រយោជន៍?
- តើមានភាពខុសគ្នាក្នុងចំណោមបុរស និងស្ត្រី ឬទេ?
- តើប្រព័ន្ធស្ថាប័ន និងប្រព័ន្ធច្បាប់គាំទ្រសមភាព ឬទេ?

៥. តើនរណាងាយរងគ្រោះជាងទៅនឹងការប្រែប្រួលអាកាសធាតុ និងហានិភ័យគ្រោះមហន្តរាយ?
វិភាគហានិភ័យយេនឌ័រ និងភាពងាយរងគ្រោះ
- តើនរណាខ្លះងាយរងគ្រោះបំផុតទៅនឹងហានិភ័យអាកាសធាតុ និងគ្រោះមហន្តរាយ?
- តើមានហានិភ័យភាពងាយរងគ្រោះសមត្ថភាពបន្សាំនិងភាពធន់ខុសៗគ្នាក្នុងចំណោមស្ត្រី បុរស ក្មេងស្រី និងក្មេងប្រុសនៅគ្រប់កម្រិត ដែរឬទេ?
- តើមានហានិភ័យបន្ថែមទៀតផ្អែកតាមយេនឌ័រ ដោយសារអាយុ ថ្នាក់ ស្ថានភាព ជាតិសាសន៍ វណ្ណៈ ជាតិពន្ធុ ឬសហគមន៍ជនជាតិដើមភាគតិច ឬទេ?
- តើស្ត្រីនិងបុរសមានស្វ័យភាពដូចម្តេចក្នុងការប្រឈមជាមួយហានិភ័យ?

៦. តើគម្រោងនឹងដោះស្រាយវិសមភាពមានស្រាប់ដោយរបៀបណា?

វិភាគការឆ្លើយតបរបស់គម្រោង

- តើគម្រោងនឹងធានានូវការបង្កើតការអនុវត្តនិងការតាមដាន ដែលឆ្លើយតបនឹងតម្រូវការយេនឌ័រដោយរបៀបណា?
- តើមានចំណុចចាប់ផ្តើមអ្វីខ្លះដើម្បីធានាការចូលរួម និងអត្ថប្រយោជន៍ស្មើភាព?
- តើគម្រោងអាចចាត់វិធានការអ្វីខ្លះដើម្បីដោះស្រាយគម្លាត/វិសមភាពយេនឌ័រ និងធានាថា គម្រោងផ្តល់អត្ថប្រយោជន៍ដល់ស្ត្រី និងបុរស?

ជាទូទៅ ការវិភាគយេនឌ័រចែកជា ២ ផ្នែក ៖

ក. ការសិក្សាឯកសារពាក់ព័ន្ធស្តីពីក្របខ័ណ្ឌច្បាប់ សង្គម និងវប្បធម៌

ខ. ការសិក្សាតាមមូលដ្ឋានដើម្បីកំណត់រកតួនាទី ទំនាក់ទំនង និង វិសមភាពយេនឌ័រដែលពាក់ព័ន្ធនឹងគម្រោង ឬគោលនយោបាយគោលដៅ។ការសិក្សាតាមមូលដ្ឋានអាចរួមបញ្ចូលការវាយតម្លៃរហ័ស និងការសិក្សាកំណត់វិសាលភាពតាមរយៈការអង្កេត ឬវិធីសាស្ត្រដែលមានការចូលរួម ដូចជា កិច្ចពិភាក្សាក្រុមគោលដៅ និងការប្រើប្រាស់លំហាត់។

ជាច្រើនឆ្នាំកន្លងមកនេះមានការបង្កើតក្របខ័ណ្ឌជាច្រើន ដែលអាចយកមកប្រើប្រាស់សម្រាប់ការវិភាគយេនឌ័រ។ ក្របខ័ណ្ឌមួយចំនួនត្រូវបានលើកមកពិភាក្សាលម្អិតក្នុងផ្នែកនេះ។

### ក្របខ័ណ្ឌ Moser

ក្របខ័ណ្ឌ Moser ដែលត្រូវបានបង្កើតឡើងដោយ Caroline Moser នៅដើមឆ្នាំ ១៩៨០ មានគោលបំណងធ្វើឱ្យការរៀបចំផែនការយេនឌ័រក្លាយជាលំហាត់ឯករាជ្យមួយ (Oxfam ឆ្នាំ ១៩៩៩)។ ក្របខ័ណ្ឌនេះមានឧបករណ៍ ៦ ដែលផ្អែកលើទស្សនទានសំខាន់ៗ ៣ ៖

ក. ការកំណត់រកតួនាទីយេនឌ័រ និងបន្ទុកត្រីគុណរបស់ស្ត្រី (ការងារទទួលបានប្រាក់កម្រៃ ការងារមិនទទួលបានប្រាក់កម្រៃ និងការងារសហគមន៍)

ខ. តម្រូវការជាក់ស្តែង និងផលប្រយោជន៍យេនឌ័រជាយុទ្ធសាស្ត្រ និង

គ. វិធីសាស្ត្រគោលនយោបាយស្ត្រីក្នុងការអភិវឌ្ឍ (WID) និងវិធីសាស្ត្រគោលនយោបាយយេនឌ័រ និងការអភិវឌ្ឍ (GAD)។

រូបទី ២២ សង្ខេបដំណើរការជាជំហានៗនៃការអនុវត្ត និងការបង្ហាញការវិភាគយេនឌ័រផ្អែកលើក្របខ័ណ្ឌ Moser ក្នុងការរៀបចំផែនការ CCDRR។

## រូបទី ២២ ៖ ការអនុវត្តក្របខ័ណ្ឌ Moser ក្នុងគម្រោង CCDRR

### ឧបករណ៍ទី១៖ ការកំណត់តួនាទីយេនឌ័រ/បន្ទុកត្រីគុណ

| ការងារផ្ទះ/ ការងារមិន រកប្រាក់កម្រៃ | ការងារផលិតកម្ម /ការងារ រកប្រាក់កម្រៃ | ការងារសហគមន៍ |
|---|---|---|
| - ការរៀបចំអាហារ<br>- ដងទឹក<br>- រកអុស<br>- ថែទាំឧុភាព | - កសិកម្ម<br>- រកចំណីសត្វពាហនៈ | - សុខភាពភូមិ និងអនាម័យបរិស្ថាន<br>- ការការពារព្រៃឈើ |

### ឧបករណ៍ទី៣៖ ការបែងចែកការគ្រប់គ្រងធនធាន និងការធ្វើសេចក្ដីសម្រេចចិត្តនៅក្នុងគ្រួសារ

| ធនធាន | ការគ្រប់គ្រង | ការធ្វើសេចក្ដីសម្រេចចិត្ត |
|---|---|---|
| - ដី<br>- ផ្ទះ<br>- ប្រាក់ចំណូល<br>- ស្តុកស្បៀង | - បុរស<br>- បុរស<br>- បុរស<br>- ស្ត្រី | - បុរស<br>- បុរស និងស្ត្រី<br>- បុរស<br>- ស្ត្រី |

### ឧបករណ៍ទី២៖ ការវាយតម្លៃតម្រូវការយេនឌ័រ

តម្រូវការជាក់ស្ដែង

- សន្តិសុខស្បៀង
- ការផ្ដល់ទឹក
- ប្រព័ន្ធជីវឧស្ម័ន
- ការថែទាំសុខភាពបឋម
- សេវាផ្សព្វផ្សាយសម្រាប់ផលិតកម្ម
- ការផ្ដល់ចំណីសត្វ

អត្ថប្រយោជន៍យុទ្ធសាស្ត្រ

- កម្មសិទ្ធិរួមគ្នាលើដីនិងផ្ទះ
- ប្រាក់ចំណូលបន្ថែមសម្រាប់ស្ត្រី
- ការចូលរួមក្នុងការគ្រប់គ្រងគ្រោះមហន្តរាយភូមិ
- ការបន្ថយការរំលោភបំពានផ្លូវភេទ
- អំពើហិង្សាក្នុងគ្រួសារ

### ឧបករណ៍ទី៥៖ ម៉ាទ្រិចគោលនយោបាយ WID/GAD

គោលបំណងរបស់គម្រោង៖

- បង្កើនភាពអង់អាចដល់ស្ត្រី និងកុមារីឱ្យទទួលខុសត្រូវលើជីវិត ទ្រព្យសម្បត្តិ និងធនធានរបស់ពួកគេដែលត្រូវការជាចាំបាច់សម្រាប់សុខុមាលភាពរបស់ខ្លួន។
- ធ្វើសកម្មភាពដែលបង្កើនប្រាក់ចំណូលរបស់ស្ត្រីខណៈពេលដែលកាត់បន្ថយកិច្ចការលំបាក/ការមិនមានពេលវេលាផ្ទាល់ខ្លួន។
- ធានាឱ្យបាននូវការចូលរួម និងភាពជាអ្នកដឹកនាំរបស់ស្ត្រីក្នុងសកម្មភាព CCDRRR ទាំងអស់។

### ឧបករណ៍ទី៤៖ ការរៀបចំផែនការសម្រាប់ការរក្សាតុល្យភាពតួនាទីត្រីគុណ

- បច្ចេកទេសពង្រឹងផលិតភាពកសិកម្ម រួមមានឧបករណ៍កសិកម្មខ្នាតតូចដែលជួយកាត់បន្ថយកិច្ចការលំបាករបស់ស្ត្រី។
- ការកើនឡើងចំនួនសត្វពាហនៈធំៗកើតមានឡើងស្របពេលដែលមានយន្តការអាចស្វែងរកបានចំណីសត្វគ្រប់គ្រាន់។
- បង្កើនប្រាក់សាគុណសម្រាប់អ្នកស្ម័គ្រចិត្តថែទាំសុខភាពបឋម។

### ឧបករណ៍ទី៦៖ ឱ្យស្ត្រី និងអង្គការយេនឌ័រចូលរួមក្នុងការរៀបចំផែនការ

- ស្ត្រីគឺជាផ្នែកនៃការរៀបចំផែនការគម្រោងទាំងអស់ ការប្រតិបត្តិ និងគណៈកម្មាធិការធ្វើសេចក្ដីសម្រេចចិត្ត។
- ក្រុមការងារគម្រោងមានតុល្យភាពផ្នែកយេនឌ័រនៅគ្រប់កម្រិត រួមទាំងនៅថ្នាក់គ្រប់គ្រងជាន់ខ្ពស់ផងដែរ។

*Source: Adapted from March, Smyth and Mukhopadhyay (1999).*

**ឧបករណ៍ទី ១៖** ការកំណត់តួនាទីយេនឌ័រ/បន្ទុកការងារត្រីគុណរបស់ស្ត្រី
ឧបករណ៍នេះជួយកំណត់រកបន្ទុកការងារត្រីគុណរបស់ស្ត្រី ៖

ក. តួនាទីដែលទទួលបានប្រាក់កម្រៃ ដែលពាក់ព័ន្ធនឹងការថែទាំ និងមើលថែផ្ទះសម្បែង និងសមាជិកគ្រួសារ រួមទាំងការបង្កើត និងថែទាំកូន ការរៀបចំអាហារ ការរកទឹក និងឥន្ទនៈ ការសម្អាត និងការបោកគក់ ការដើរផ្សារ និងគេហកិច្ច និងការថែទាំសុខភាពគ្រួសារ

ខ. តួនាទីដែលទទួលបានប្រាក់កម្រៃ ដែលពាក់ព័ន្ធនឹងការផលិតទំនិញ និងសេវាសម្រាប់ការប្រើប្រាស់ និងជួញដូរ (ក្នុងការងារ និងក្នុងការប្រកបរបររកស៊ី និងក្នុងវិស័យក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធ)

គ. ការងារសហគមន៍ ដែលរួមបញ្ចូលការរៀបចំជាសមូហភាពនូវព្រឹត្តិការណ៍ និងសេវាសហគមន៍ ដូចជា ពិធីបុណ្យ និងការប្រារព្ធពិធី សកម្មភាពកែលម្អសហគមន៍ ការចូលរួមក្នុងក្រុម និងអង្គការ សកម្មភាពនយោបាយនៅមូលដ្ឋាន។ល។

**ជំហានក្នុងការគូសផែនទីតួនាទីយេនឌ័រនៅកម្រិតមូលដ្ឋាន**

- រ៉ាយរ៉ាប់ពីទម្លាប់ប្រចាំថ្ងៃ ២៤ ម៉ោងក្នុងជីវិតរស់នៅរបស់ស្ត្រី និងបុរសដាច់ដោយឡែកពីគ្នា នៅសហគមន៍ដែលអ្នកចង់យកជាគោលដៅ
- ធានាថា អ្នកសួរពីអ្វីដែលពួកគេធ្វើជារៀងរាល់ម៉ោង និងព្យាយាមលម្អិតពីសកម្មភាពនីមួយៗ

- បែងចែកការងារទាំងនេះជា ៣ ប្រភេទ ៖ ការងារទទួលបានប្រាក់កម្រៃការងារមិនទទួលបានប្រាក់កម្រៃនិងការងារសហគមន៍
- បន្ថែមការងារផ្សេងទៀតដែលពួកគេធ្វើទៅតាមប្រភេទការងារទាំងនេះ
- លទ្ធផលទទួលបាននឹងជួយឱ្យអ្នកកំណត់ពីតួនាទីត្រីគុណរបស់ស្ត្រី
- ការប្រៀបធៀបតួនាទីរបស់ស្ត្រី និងបុរស ជួយកំណត់ពីតួនាទីយេនឌ័រ។

ស្ត្រី បុរស ក្មេងប្រុស និងក្មេងស្រី សុទ្ធតែងាយប្រឡូកក្នុងការងារទាំង ៣ ប្រភេទខាងលើ ប៉ុន្តែក្នុងសង្គមភាគច្រើន បុរសមិនសូវប្រឡូកក្នុងការងារមិនទទួលបានប្រាក់កម្រៃឡើយ។ ក្រៅពីនេះ ខណៈដែលស្ត្រី និងបុរសសុទ្ធតែអាចប្រឡូកក្នុងការងារដែលទទួលបានប្រាក់កម្រៃ មុខងារ និងការទទួលខុសត្រូវរបស់ពួកគេច្រើនតែខុសគ្នា។ជាញឹកញាប់ការងារដែលទទួលបានប្រាក់កម្រៃរបស់ស្ត្រីត្រូវបានគេមើលរំលង និងមិនសូវមានតម្លៃ ដូចការងារដែលទទួលបានប្រាក់កម្រៃរបស់បុរស។ ក្រៅពីនេះ ស្ត្រីច្រើនតែប្រឡូកក្នុងការងារគ្រប់គ្រងសហគមន៍ដូចជាការគ្រប់គ្រងធនធានទឹក ការអប់រំ និងការថែទាំសុខភាព ខណៈដែលបុរសច្រើនតែចូលរួម និងទទួលបន្ទុកលើនយោបាយក្នុងសហគមន៍ និងដំណើរការធ្វើសេចក្ដីសម្រេចចិត្តផ្លូវការ។

**ឧបករណ៍ទី ២ ៖ ការប៉ាន់ប្រមាណតម្រូវការយេនឌ័រ**

គំនិតនៃការអនុវត្តជាក់ស្ដែង និងជាយុទ្ធសាស្ត្ររបស់ស្ត្រី ត្រូវបានបង្កើតឡើងនៅទសវត្សរ៍ទី ៨០ ដោយ Maxine Molyneux និងក្រោយមកត្រូវបានបង្កើតដោយ Caroline Moser។

ក. តម្រូវការយេនឌ័រជាក់ស្ដែង ជាតម្រូវការដែលប្រសិនបើត្រូវបានបំពេញ នឹងជួយដល់ស្ត្រីក្នុងសកម្មភាពបច្ចុប្បន្នរបស់គាត់ ដោយមិនជេញជោលការបែងចែកពលកម្មតាមយេនឌ័រដែលមានស្រាប់។ តម្រូវការទាំងនេះរួមមានការផ្ដល់ទឹកការផ្ដល់ការថែទាំសុខភាព ឱកាសសម្រាប់ការរកប្រាក់ចំណូលផ្គត់ផ្គង់គ្រួសារការផ្ដល់លំនៅដ្ឋាននិងសេវាមូលដ្ឋានការបែងចែកអាហារ។ល។តម្រូវការទាំងនេះត្រូវបានចែករំលែកដោយសមាជិកគ្រួសារទាំងអស់ ប៉ុន្តែជារឿយៗ ស្ត្រីកំណត់តម្រូវទាំងនេះជាតម្រូវការជាក់លាក់របស់ខ្លួន ព្រោះថា ស្ត្រីនេះហើយដែលជាអ្នកទទួលខុសត្រូវលើការបំពេញលក្ខខណ្ឌតម្រូវរបស់គ្រួសារ។

ខ. ផលប្រយោជន៍យេនឌ័រជាយុទ្ធសាស្ត្រ ជាផលប្រយោជន៍ដែលលេចឡើងដោយសារតែស្ថានភាពចាញ់ប្រៀបរបស់ស្ត្រីក្នុងសង្គម។ ប្រសិនបើបំពេញបាន ផលប្រយោជន៍ទាំងនេះនឹងអាចឱ្យស្ត្រីផ្លាស់ប្ដូរអតុល្យភាពអំណាចមានស្រាប់រវាងស្ត្រីនិងបុរស។ផលប្រយោជន៍ទាំងនេះពាក់ព័ន្ធនឹងការបែងចែកពលកម្ម អំណាច និងការគ្រប់គ្រងតាមយេនឌ័រ និងអាចរួមបញ្ចូលបញ្ហា ដូចជា សិទ្ធិស្របច្បាប់ អំពើហិង្សាក្នុងគ្រួសារ ប្រាក់ឈ្នួលស្មើគ្នា និងភាពម្ចាស់ការរបស់ស្ត្រីលើរាងកាយរបស់ខ្លួន។

**ឧបករណ៍ទី ៣ ៖ ការគ្រប់គ្រងធនធានបែងចែកជាប្រភេទ និងការធ្វើសេចក្ដីសម្រេចចិត្តក្នុងគ្រួសារ**

ឧបករណ៍នេះពាក់ព័ន្ធនឹងការបែងចែកធនធានក្នុងគ្រួសារ (ការបែងចែកក្នុងគ្រួសារ) ដោយមានដំណើរការចរចាដែលកំណត់ការបែងចែកនេះ។ តើនរណាគ្រប់គ្រងលើធនធានអ្វីក្នុងគ្រួសារ? តើនរណាមានអំណាចក្នុងការសម្រេចចិត្ត?

**ឧបករណ៍ទី ៤ ៖ ការរៀបចំផែនការសម្រាប់ការរក្សាតុល្យភាពនៃតួនាទីត្រីគុណ**

ឧបករណ៍នេះផ្ដោតលើផលប៉ះពាល់នៃអន្តរាគមន៍គម្រោងលើបន្ទុកការងារត្រីគុណរបស់ស្ត្រី។ ជាញឹកញាប់ ក្របខ័ណ្ឌនៃការរៀបចំផែនការតាមវិស័យដែលប្រមូលផ្ដុំតែលើតួនាទីមួយ ហាក់មើលរំលងផលប៉ះពាល់លើតួនាទីផ្សេងទៀតរបស់ស្ត្រី។ អ្នកប្រើប្រាស់ក្របខ័ណ្ឌនេះត្រូវបានស្នើឱ្យពិនិត្យថា តើកម្មវិធីដែលបានគ្រោងឡើង ឬគម្រោងមួយនឹងបង្កើនបន្ទុកការងាររបស់ស្ត្រីក្នុងតួនាទីមួយរបស់គាត់ ដែលបង្កអន្តរាយដល់តួនាទីផ្សេងទៀតរបស់គាត់ឬទេ។ ឧ. ការផ្ដល់ទឹកស្រោចស្រព បង្កើនការចូលរួមរបស់ស្ត្រីក្នុងសកម្មភាពកសិកម្ម ប៉ុន្តែវាធ្វើឱ្យស្ត្រីមិនសូវមានពេលសម្រាប់សកម្មភាពក្នុងគ្រួសារឬអាចបង្កើនបន្ទុកការងារនៃការទៅដងទឹកដោយសារការបង្វែរទឹកសាបសម្រាប់ការប្រើប្រាស់ក្នុងគ្រួសារទៅជាការស្រោចស្រព។

**ឧបករណ៍ទី ៥ ៖ ការញែកភាពខុសគ្នារវាងគោលបំណងផ្សេងៗក្នុងការធ្វើអន្តរាគមន៍**

ឧបករណ៍នេះជួយកំណត់កេវិធីសាស្ត្រដែលគម្រោងមួយនឹង ឬបានយកទៅអនុវត្ត(ប្រសិនបើត្រូវបានប្រើប្រាស់សម្រាប់ការវាយតម្លៃ) តាមរយៈការសួរពីកម្រិតដែលវិធីសាស្ត្រផ្សេងៗ បំពេញតម្រូវការយេនឌ័រជាក់ស្ដែងនិង/ឬតម្រូវការយេនឌ័រជាយុទ្ធសាស្ត្រ។ ដូច្នេះ Moser បានបែងចែកវិធីសាស្ត្រគោលនយោបាយជា ៥ ប្រភេទ ៖

ក. វិធីសាស្ត្រសុខុមាលភាព ដែលផ្ដោតលើតម្រូវការយេនឌ័រជាក់ស្ដែងនិងចាត់ទុកស្ត្រីជាអ្នកទទួលផលអកម្មពីអន្តរាគមន៍អភិវឌ្ឍន៍

ខ. វិធីសាស្ត្រសមធម៌ ដែលផ្ដោតលើផលប្រយោជន៍យេនឌ័រជាយុទ្ធសាស្ត្រនិងទទួលស្គាល់ស្ត្រីជាអ្នកចូលរួមយ៉ាងសកម្មក្នុងការអភិវឌ្ឍ

គ. វិធីសាស្ត្រប្រឆាំងភាពក្រីក្រ ដែលផ្តោតលើតម្រូវការយេនឌ័រជាក់ស្តែង និងធានាថាស្ត្រីក្រីក្របំផុតពីភាពក្រីក្រ តាមរយៈការផ្តោតលើការបង្កើនផលិតភាពរបស់ស្ត្រី
ឃ. វិធីសាស្ត្រប្រសិទ្ធផល ដែលកត់សម្គាល់តួនាទីទាំង ៣ ប៉ុន្តែផ្តោតលើតម្រូវការយេនឌ័រជាក់ស្តែងសម្រាប់ការទាញប្រយោជន៍ពីការរួមចំណែកផ្នែកសេដ្ឋកិច្ចរបស់ស្ត្រី និង
ង. វិធីសាស្ត្របង្កើនភាពអង់អាច ដែលផ្តោតលើផលប្រយោជន៍យេនឌ័រជាយុទ្ធសាស្ត្រតាមរយៈការគាំទ្រគំនិតផ្តួចផ្តើមរបស់ស្ត្រី ដែលពង្រឹងភាពម្ចាស់ការរបស់ស្ត្រី។ វិធីសាស្ត្រនេះកត់សម្គាល់ថា ភាពចាញ់ប្រៀបរបស់ស្ត្រីបណ្តាលមកពីការគៀបសង្កត់របស់បុរស និងផលវិបាកនៃការគៀបសង្កត់បែបអាណានិគម និងអាណានិគមថ្មី។

**ឧបករណ៍ទី ៦ ៖** ការជំរុញការចូលរួមរបស់ស្ត្រី និងអង្គការដែលមានទស្សនៈយេនឌ័រ និងអ្នករៀបចំផែនការក្នុងការរៀបចំផែនការ

ចុងបញ្ចប់ ក្របខ័ណ្ឌ Moser ស្នើឱ្យអ្នកប្រើប្រាស់ពិចារណាពីសារៈសំខាន់នៃការជំរុញការចូលរួមរបស់ស្ត្រី អង្គការដែលមានទស្សនៈយេនឌ័រ និងអ្នករៀបចំផែនការក្នុងការរៀបចំផែនការដែលគួរធ្វើឡើងនៅគ្រប់កម្រិត (ការរៀបចំផែនការ ការអនុវត្ត និងការតាមដាន និងវាយតម្លៃ)។

## ក្របខ័ណ្ឌវិភាគ Harvard

ក្របខ័ណ្ឌវិភាគ Harvard សម្រាប់ការវិភាគយេនឌ័រត្រូវបានបង្កើតឡើងនៅឆ្នាំ ១៩៨៥ ក្នុងគោលបំណងបង្ហាញពីករណីសេដ្ឋកិច្ចសម្រាប់ការបែងចែកធនធានដល់ស្ត្រីនិងបុរសនៅពេលដែលមានការប្រើប្រាស់វិធីសាស្ត្រប្រសិទ្ធផលយ៉ាងទូលំទូលាយ (Oxfam ឆ្នាំ ១៩៩៩)។ ក្របខ័ណ្ឌនេះមានសមាសភាគសំខាន់ៗ ៤ (ឧបករណ៍ ៣ សម្រាប់ការវិភាគយេនឌ័រ និងតារាងត្រួតពិនិត្យមួយដើម្បីពិនិត្យសំណើ ឬអន្តរាគមន៍គម្រោងផ្អែកតាមទស្សនៈយេនឌ័រដោយប្រើទិន្នន័យបែងចែកតាមយេនឌ័រនិងទាញយកផលប៉ះពាល់ផ្សេងៗនៃការផ្លាស់ប្តូរសង្គមលើបុរស និងស្ត្រី)។ ខាងក្រោមនេះជាការបង្ហាញដោយសង្ខេបនូវឧបករណ៍ទាំង៣សម្រាប់ការវិភាគយេនឌ័រ។

**ឧបករណ៍ទី ១ ៖** សារពើភ័ណ្ឌសកម្មភាព

ឧបករណ៍នេះកំណត់រកពលកិច្ចការផលិត/រកកម្រៃ និងកិច្ចការបន្តពូជ និងឆ្លើយសំណួរ "តើនរណាធ្វើកិច្ចការអ្វី"? ខ្លឹមសារលម្អិតដែលអ្នកត្រូវការអាស្រ័យលើលក្ខណៈនៃគម្រោងរបស់អ្នក។ គួរបន្ថែមទិដ្ឋភាពពេលវេលាដែលបញ្ជាក់ពីភាគរយពេលវេលាក្នុងការធ្វើសកម្មភាពនីមួយៗ ថាតើសកម្មភាពត្រូវបានឡើងតាមរដូវកាល ឬប្រចាំថ្ងៃ ឬទិដ្ឋភាពជំនាញ និងបច្ចេកវិទ្យា ដែលបញ្ជាក់ថាតើសកម្មភាពពាក់ព័ន្ធតែនឹងកម្លាំង ឬជំនាញ និងឧបករណ៍ជាក់លាក់។ ការវិភាគនេះត្រូវបានបង្ហាញក្នុងទម្រង់ខាងក្រោម។

**រូបទី ២៣ ៖ គំរូក្របខ័ណ្ឌវិភាគ Harvard សម្រាប់ការវិភាគយេនឌ័រ (សារពើភ័ណ្ឌសកម្មភាព)**

| សកម្មភាព | ស្ត្រី/ក្មេងស្រី | បុរស/ក្មេងប្រុស |
|---|---|---|
| សកម្មភាពដែលទទួលបានប្រាក់កម្រៃ<br>• កសិកម្ម<br>  ◦ សកម្មភាពទី ១<br>  ◦ សកម្មភាពទី ២<br>• ការងារផ្ទះ<br>  ◦ សកម្មភាពទី ១<br>  ◦ សកម្មភាពទី ២<br>• សត្វពាហនៈ<br>  ◦ សកម្មភាពទី ១<br>  ◦ សកម្មភាពទី ២ | | |
| សកម្មភាពដែលមិនទទួលបានប្រាក់កម្រៃ<br>• ពាក់ព័ន្ធនឹងទឹក<br>  ◦ សកម្មភាពទី ១<br>  ◦ សកម្មភាពទី ២<br>• ពាក់ព័ន្ធនឹងសុខភាព<br>  ◦ សកម្មភាពទី ១<br>  ◦ សកម្មភាពទី ២<br>• ពាក់ព័ន្ធនឹងឥន្ធនៈ<br>  ◦ សកម្មភាពទី ១<br>  ◦ សកម្មភាពទី ២ | | |
| សកម្មភាពសហគមន៍<br>• សង្គម<br>• ការអភិវឌ្ឍ<br>• នយោបាយ | | |

**ឧបករណ៍ទី ២ ៖** សាវតានៃការទទួលបាន និងការគ្រប់គ្រង (ធនធាន និងអត្ថប្រយោជន៍)

ឧបករណ៍នេះអាចឱ្យអ្នកប្រើប្រាស់រៀបរាប់ពីធនធានដែលមនុស្សប្រើប្រាស់ក្នុងការធ្វើកិច្ចការ ដែលបានកំណត់ក្នុងសាវតាសកម្មភាព។ឧបករណ៍នេះគូសបញ្ជាក់ថាតើស្ត្រីឬបុរសដែលមានលទ្ធភាពទទួលបានធនធាន អ្នកគ្រប់គ្រងការប្រើប្រាស់ធនធានទាំងនេះនិងអ្នកគ្រប់គ្រងអត្ថប្រយោជន៍នៃការប្រើប្រាស់ធនធានរបស់គ្រួសារ (ឬសហគមន៍)។ "ការទទួលបាន" មានន័យថា អ្នកអាចប្រើប្រាស់ធនធានបាន។ អ្នកដែលគ្រប់គ្រងធនធានជាអ្នកដែលអាចសម្រេចចិត្តលើការប្រើប្រាស់ធនធានរួមទាំងថាតើអាចលក់ធនធាននោះបានដែរ ឬទេ។

**រូបទី ២៤ ៖ គំរូក្របខ័ណ្ឌវិភាគ Harvard សម្រាប់ការវិភាគយេនឌ័រ (ការទទួលបាន និងការគ្រប់គ្រង)**

| ធនធាន/អត្ថប្រយោជន៍ | ការទទួលបាន | | ការគ្រប់គ្រង/ការកាន់កាប់ | |
|---|---|---|---|---|
| | ស្ត្រី/ក្មេងស្រី | បុរស/ក្មេងប្រុស | ស្ត្រី/ក្មេងស្រី | បុរស/ក្មេងប្រុស |
| ធនធាន<br>• ដីធ្លី<br>• ពលកម្ម<br>• បរិក្ខារ<br>• ប្រាក់កាក់<br>• ឥណទាន<br>• ការអប់រំ/ការបណ្ដុះបណ្ដាល<br>• ការថែទាំសុខភាព | | | | |
| អត្ថប្រយោជន៍<br>• ភាពចាំបាច់ជាមូលដ្ឋាន (អាហារ សម្លៀកបំពាក់ ជម្រក)<br>• ចំណូលពីខាងក្រៅ/ប្រាក់ចំណូល<br>• ការកាន់កាប់ទ្រព្យសម្បត្តិ<br>• អំណាច និងកិត្យានុភាព | | | | |

**ឧបករណ៍ទី ៣៖** កត្តាជះឥទ្ធិពល

ឧបករណ៍នេះ ជួយរៀបរាប់ពីកត្តាដែលជះឥទ្ធិពលលើភាពខុសគ្នានៃការបែងចែកពលកម្មតាមយេនឌ័រ ការទទួលបាន និងការគ្រប់គ្រង ដូចការរៀបរាប់ក្នុងសាវតា ២ ខាងលើ (ឧបករណ៍ទី ១ និងទី ២)។ កត្តាជះឥទ្ធិពលរួមបញ្ចូលកត្តាទាំងអស់ដែលជះឥទ្ធិពលលើទំនាក់ទំនងយេនឌ័រនិងកំណត់ពីឱកាសនិងឧបសគ្គផ្សេងៗសម្រាប់បុរស និងស្ត្រី។

កត្តាទាំងនេះមានភាពជ្រាលជ្រៅ ទូលំទូលាយ និងប្រទាក់ក្រឡាគ្នា។ឧបករណ៍នេះមានគោលបំណងជួយដល់អ្នកក្នុងការកំណត់រកឧបសគ្គ និងឱកាសខាងក្រៅ ដែលអ្នកគួរពិចារណានៅពេលរៀបចំផែនការអន្តរាគមន៍អភិវឌ្ឍន៍របស់អ្នក។

**រូបទី ២៥ ៖ គំរូក្របខ័ណ្ឌវិភាគ Harvard សម្រាប់ការវិភាគយេនឌ័រ (កត្តាជះឥទ្ធិពល)**

| កត្តាជះឥទ្ធិពល | ឧបសគ្គ | ឱកាស |
|---|---|---|
| • បទដ្ឋានសហគមន៍ និងឋានានុក្រមសង្គម<br>• ការអនុវត្តក្នុងវប្បធម៌ និងជំនឿសាសនា<br>• កត្តាប្រជាសាស្ត្រ<br>• រចនាសម្ព័ន្ធស្ថាប័ន<br>• កត្តាសេដ្ឋកិច្ច<br>• កត្តានយោបាយ<br>• ប៉ារ៉ាម៉ែត្រច្បាប់<br>• ការបណ្ដុះបណ្ដាល<br>• ឥរិយាបថរបស់សហគមន៍ចំពោះបុគ្គលិកអភិវឌ្ឍន៍ | | |

**ដំណើរការជាជំហានៗសម្រាប់ឧបករណ៍ទី១ និងទី២ នៃក្របខ័ណ្ឌ Harvard**

**ឧបករណ៍ទី ១ ៖** សារតាសកម្មភាព

> កំណត់យកវិស័យ ឬសកម្មភាពកម្មវិធីដ៏សំខាន់មួយ (ឧ. ការចិញ្ចឹមគោយកទឹកដោះ)
> រៀបរាប់កិច្ចការដែលត្រូវធ្វើឡើងសម្រាប់សកម្មភាព/កម្មវិធីនោះ (ឧ. រៀបរាប់ពីវដ្តពេញលេញនៃការចិញ្ចឹមគោយកទឹកដោះចាប់ពីការទិញគោរហូតដល់ការលក់ទឹកដោះគោ និងការលក់គោដែលលើសតម្រូវការ)
> សម្រាប់កិច្ចការនីមួយៗ កំណត់បុគ្គលដែលធ្វើការងារភាគច្រើន
> ការរៀបរាប់នេះនឹងផ្តល់ទិដ្ឋភាពច្បាស់លាស់ស្តីពីតួនាទីរបស់ស្ត្រីក្នុងវិស័យនេះ និងជួយកំណត់រកផ្នែកអន្តរាគមន៍ជាមួយស្ត្រីដើម្បីបំពេញតម្រូវការជាក់ស្តែងរបស់ពួកគេ។

**រូបទី ២៦ ៖ គំរូសកម្មភាពចិញ្ចឹមគោយកទឹកដោះក្នុងបរិបទអាស៊ីទក្សិណ (សារតាសកម្មភាព)**

| សកម្មភាពប្រចាំថ្ងៃ | ការងារភាគច្រើនត្រូវបានធ្វើដោយ | |
|---|---|---|
| | បុរស | ស្ត្រី |
| - រៀបចំកម្ចីសម្រាប់ទិញសត្វ | ✓ | |
| - ទិញសត្វ | ✓ | |
| - លាងសម្អាត | | ✓ |
| - ងូតទឹកឱ្យសត្វ | ✓ | ✓ |
| - ផ្តល់ចំណីដល់សត្វ | | ✓ |
| - យកទឹកដោះ | | ✓ |
| - ឃ្វាលសត្វ | ✓ | ✓ |
| - យកចំណីសត្វពីទីវាល | | ✓ |
| - ទិញចំណី | ✓ | |
| - លក់ទឹកដោះ | ✓ | ✓ |
| - ប្រមូលប្រាក់ពីការលក់ទឹកដោះ | ✓ | |
| - ការងាររ៉ាប់រងលើសត្វ | ✓ | |
| - រ៉ាប់រងលើសេវាបសុពេទ្យ | ✓ | |
| - លក់សត្វ | ✓ | |

**ឧបករណ៍ទី ២ ៖** សាវតានៃការទទួលបាន និងការគ្រប់គ្រង

> រៀបរាប់ពីឧបករណ៍ ធនធាន និងការសម្រេចចិត្តចាំបាច់សម្រាប់សកម្មភាពខាងលើ

> កំណត់ថាតើការទទួលបាន ការគ្រប់គ្រង និងការកាន់កាប់ធនធានទាំងនេះ/ការសម្រេចចិត្ត ប្រមូលផ្តុំលើបុរស និង/ឬស្ត្រី

> ចំណុចនេះជួយឱ្យអ្នកកំណត់ពីគោលជំហររបស់ស្ត្រីក្នុងវិស័យនេះ

> កំណត់រកសកម្មភាពដែលនឹងជួយផ្លាស់ប្តូរគោលជំហរនេះទាំងនេះជាតម្រូវការជាយុទ្ធសាស្ត្ររបស់ស្ត្រី។

**រូបទី ២៧ ៖ គំរូសកម្មភាពចិញ្ចឹមគោយកទឹកដោះក្នុងបរិបទអាស៊ីទក្សិណ (ការទទួលបាន និងការគ្រប់គ្រង)**

| ឧបករណ៍/ធនធាន/ការសម្រេចចិត្តដែលតម្រូវឱ្យមាន | ការទទួលបាន | | ការគ្រប់គ្រង/ភាពជាម្ចាស់កម្មសិទ្ធិ | |
|---|---|---|---|---|
| ឧបករណ៍ និងធនធាន | បុរស | ស្ត្រី | បុរស | ស្ត្រី |
| - ឥណទានសម្រាប់គោ | ✓ | | ✓ | |
| - គោ | ✓ | ✓ | ✓ | ✓ |
| - ក្រោលគោ | ✓ | ✓ | ✓ | |
| - សេវាចំណីសត្វ | ✓ | ✓ | ✓ | |
| - សេវាបសុពេទ្យ | ✓ | ✓ | ✓ | |
| - សេវាបញ្ចូលមេជីវិតបង្កាត់ពូជ | ✓ | | ✓ | |
| - ភាពអាចរកបានចំណី | ✓ | ✓ | ✓ | |
| - ដីឃ្វាលសត្វ/ដីរួម | ✓ | ✓ | ✓ | |
| - សេវាផ្សព្វផ្សាយ | ✓ | | ✓ | |
| - សមាជិកភាពសហករណ៍ទឹកដោះគោ | ✓ | ✓ | ✓ | ✓ |
| - អ្នកកាន់កាប់មុខតំណែងសហករណ៍ទឹកដោះគោ | ✓ | | ✓ | |
| - សមាជិកភាពសហជីពសហករណ៍ទឹកដោះគោ (ថ្នាក់ស្រុក) | ✓ | | ✓ | |
| សេចក្តីសម្រេចចិត្តដែលតម្រូវឱ្យមាន | | | | |
| - តើគោពូជអ្វីដែលត្រូវទិញ | ✓ | | ✓ | |
| - ចំនួនគោដែលត្រូវរក្សាទុក | ✓ | | ✓ | |
| - បញ្ចេញគោដែលមិនមានទឹកដោះ | ✓ | | ✓ | |
| - ថែរក្សាដីឃ្វាលសត្វ | ✓ | ✓ | ✓ | |
| - ផលិតកម្មចំណីសត្វនៅលើដីទីវាលផ្ទាល់ខ្លួន | ✓ | | ✓ | |
| - នៅពេលហៅពេទ្យសត្វ និងការព្យាបាលក្នុងមូលដ្ឋាន | ✓ | | ✓ | |
| - លក់កូនគោ/គោ | ✓ | | ✓ | |
| - បរិមាណទឹកដោះគោដែលត្រូវលក់ និងបរិមាណទឹកដោះគោសម្រាប់ទុកបរិភោគក្នុងផ្ទះ | ✓ | ✓ | ✓ | |

## ម៉ាទ្រិចវិភាគយេនឌ័រ (GAM)

ម៉ាទ្រិចវិភាគយេនឌ័រ (GAM) ត្រូវបានបង្កើតឡើងដោយ Rani Parker នៅឆ្នាំ ១៩៩៣ ដើម្បីរិះរកផលប៉ះពាល់ផ្សេងៗនៃអន្តរាគមន៍អភិវឌ្ឍន៍លើស្ត្រីនិងបុរសតាមរយៈការផ្តល់បច្ចេកទេសនៅសហគមន៍មូលដ្ឋានសម្រាប់ការកំណត់រក និងការវិភាគភាពខុសគ្នានៃយេនឌ័រ (Oxfam ឆ្នាំ ១៩៩៩)។ ម៉ាទ្រិចនេះជួយដល់សហគមន៍ក្នុងការកំណត់រក និងដេញដោលការសន្មតស្តីពីតួនាទីយេនឌ័រតាមបែបស្ថាបនា។ ការវិភាគនេះ ធ្វើឡើងនៅកម្រិតទាំង ៤ នៃសង្គម (ស្ត្រី បុរស គ្រួសារ និងសហគមន៍)។ ម៉ាទ្រិចនេះពិនិត្យមើលផលប៉ះពាល់លើផ្នែក ៤ ជាអាទិ៍ ពលកម្ម ពេលវេលា ធនធាន និងកត្តាសង្គមវប្បធម៌។ម៉ាទ្រិចនេះបង្ហាញពីទស្សនទានសំខាន់ៗទាំង២នេះក្នុងម៉ាទ្រិចដែលផ្តោតលើផលប៉ះពាល់នៃអន្តរាគមន៍អភិវឌ្ឍន៍ដែលស្នើឡើង។

**រូបទី ២៨ ៖ គំរូម៉ាទ្រិចវិភាគយេនឌ័រ**

| អន្តរាគមន៍ដែលស្នើឡើង | ពលកម្ម | ពេលវេលា | ធនធាន | វប្បធម៌ |
|---|---|---|---|---|
| បុរស | | | | |
| ស្ត្រី | | | | |
| គ្រួសារ | | | | |
| សហគមន៍ | | | | |

### ឧបករណ៍ទី ១ ៖ ការវិភាគនៅ "កម្រិត" ទាំង ៤ នៃសង្គម

ម៉ាទ្រិចវិភាគយេនឌ័រ អនុញ្ញាតឱ្យមានការវិភាគអន្តរាគមន៍មួយនៅកម្រិត ៤ (បុរស ស្ត្រី គ្រួសារ និងសហគមន៍)។ កម្រិតនៃការវិភាគបង្ហាញក្នុងជួរឈរនៃម៉ាទ្រិចនេះ។

- បុរស៖តំណាងឱ្យបុរសគ្រប់វ័យដែលស្ថិតក្នុងក្រុមគោលដៅ ឬបុរសទាំងអស់ក្នុងសហគមន៍
- ស្ត្រី ៖ តំណាងឱ្យស្ត្រីគ្រប់វ័យដែលស្ថិតក្នុងក្រុមគោលដៅ ឬស្ត្រីទាំងអស់ក្នុងសហគមន៍
- គ្រួសារ៖តំណាងឱ្យស្ត្រីបុរសនិងកុមារទាំងអស់ដែលរស់នៅក្រោមដំបូលតែមួយ (ឬគ្រួសារធំ) ទៅតាមការកំណត់ក្នុងវប្បធម៌
- សហគមន៍ ៖ តំណាងឱ្យមនុស្សគ្រប់រូបក្នុងសហគមន៍។

ការសំខាន់គឺអ្នកសម្របសម្រួលត្រូវរៀបរាប់ពីក្រុមអាយុ ថ្នាក់សមាសភាគជាតិពន្ធ ប្រព័ន្ធសង្គម (វណ្ណៈ) និងអថេរសំខាន់ៗផ្សេងទៀតក្នុងសហគមន៍។

### ឧបករណ៍ទី ២ ៖ ការវិភាគផលប៉ះពាល់

ម៉ាទ្រិចវិភាគយេនឌ័រ ពិនិត្យមើលផលប៉ះពាល់លើផ្នែក ៤ ដែលបង្ហាញឡើងលើជួរដេកក្នុងម៉ាទ្រិចនេះ ៖

<u>ពលកម្ម</u>៖ផ្តោតលើការផ្លាស់ប្តូរកិច្ចការ (តើស្ត្រីរ៉ាប់រងកិច្ចការតាមទីវាល (tasks in the field) របស់បុរស ឬទេ ? ) កម្រិតជំនាញ (ការអប់រំផ្លូវការ ការបណ្តុះបណ្តាល) ដែលត្រូវការជាចាំបាច់ ចំនួនមនុស្សដែលពាក់ព័ន្ធក្នុងសកម្មភាពនេះ និងតម្រូវការពលកម្មបន្ថែម។

<u>ពេលវេលា</u>៖ផ្តោតលើការផ្លាស់ប្តូរពេលវេលាចាំបាច់ក្នុងការបញ្ចប់កិច្ចការជាក់លាក់។

<u>ធនធាន</u>៖ ផ្តោតលើការផ្លាស់ប្តូរ លទ្ធភាពទទួលបានធនធាន (ប្រាក់ចំណូល ដីធ្លី ព័ត៌មានផ្សព្វផ្សាយ) និងកម្រិតនៃការគ្រប់គ្រងធនធាន(កើនឡើងឬថយចុះ)ដោយសារអន្តរាគមន៍មួយ។

<u>កត្តាសង្គមវប្បធម៌</u>៖ ផ្តោតលើការផ្លាស់ប្តូរតួនាទីយេនឌ័រ ឬស្ថានភាព ដោយសារអន្តរាគមន៍មួយ។ កត់សម្គាល់ពីរបាំងវប្បធម៌លើការប្រើប្រាស់អន្តរាគមន៍ដែលស្នើឡើង។

### ដំណើរការនៃម៉ាទ្រិចវិភាគយេនឌ័រ

ម៉ាទ្រិចវិភាគយេនឌ័រត្រូវបានស្នើឡើងសម្រាប់ការប្រើប្រាស់ជាមួយក្រុមសមាជិកសហគមន៍ (ដែលមានភាពតំណាងយេនឌ័រ និង ក្រុមសង្គមគ្រប់គ្រាន់) ក្រោមការសម្របសម្រួលដោយបុគ្គលិកអភិវឌ្ឍន៍។ បន្ទាប់ពីបំពេញម៉ាទ្រិចនេះ ក្រុមនឹងពិភាក្សាពីលទ្ធផលរកឃើញ ដោយសួរសំណួរខាងក្រោម ៖

- តើផលប៉ះពាល់ដែលមានរៀបរាប់ក្នុងម៉ាទ្រិចនេះគួរជាទីគាប់ចិត្ត ឬទេ ? តើផលប៉ះពាល់ទាំងនេះស៊ីសង្វាក់គ្នានឹងគោលដៅរបស់កម្មវិធី ឬទេ ?
- តើអន្តរាគមន៍នេះបង្កផលប៉ះពាល់ដូចម្តេចលើអ្នកដែលមិនចូលរួម ?
- តើលទ្ធផលណាខ្លះដែលខុសពីការរំពឹងទុក ? (លទ្ធផលទាំងនេះនឹងលេចឡើងក្នុងម៉ាទ្រិចដែលបំពេញរួចនៅក្នុងពេល និងក្រោយពេលអនុវត្ត)។

បន្ទាប់ពីបានបំពេញការផ្លាស់ប្តូរដោយសារគម្រោងរួចហើយ សមាជិកក្រុមគួរត្រឡប់ទៅមើលម៉ាទ្រិចរួចបន្ថែមសញ្ញាដូចខាងក្រោម ៖

- <u>សញ្ញាបូក (+)</u> ប្រសិនបើលទ្ធផលទទួលបានស៊ីសង្វាក់គ្នានឹងគោលដៅគម្រោង
- <u>សញ្ញាដក (-)</u> ប្រសិនបើលទ្ធផលទទួលបានផ្ទុយគ្នានឹង

គោលដៅគម្រោង

- សញ្ញាសួរ (?) ប្រសិនបើមិនប្រាកដថាតើលទ្ធផលទទួលបានស៊ីសង្វាក់គ្នា ឬផ្ទុយគ្នា។

សញ្ញាទាំងនេះនឹងផ្តល់ទិដ្ឋភាពរួមស្តីពីផលប៉ះពាល់ផ្សេងៗនៃអន្តរាគមន៍ មិនមែនជាការបូកសរុបដើម្បីកំណត់ពីផលប៉ះពាល់សរុបនោះទេ។

ផ្អែកលើឧបករណ៍នេះ អង្គការសុខភាពពិភពលោក (WHO ឆ្នាំ ២០១១) បានបង្កើតម៉ាទ្រិចវិភាគយេនឌ័រ (GAM) សម្រាប់សុខភាព។ ម៉ាទ្រិចនេះមានកត្តាជីវសាស្ត្រ និងយន្តការផ្សេងៗនៃការគៀបសង្កត់ផ្អែកលើយេនឌ័រ ក្នុងជួរឈរ និងលទ្ធផលសុខភាពក្នុងជួរដេក។

**រូបទី ២៩ ៖ ម៉ាទ្រិចវិភាគយេនឌ័រ (GAM) សម្រាប់សុខភាព**

| | កត្តាជីវសាស្ត្រ | កត្តាសង្គម (រួមមានតួនាទី និងបទដ្ឋានយេនឌ័រ និងការបែងចែកពលកម្មតាមយេនឌ័រ) | ការទទួលបាន និងការគ្រប់គ្រងធនធាន និងការធ្វើសេចក្តីសម្រេចចិត្ត |
|---|---|---|---|
| កត្តាហានិភ័យ និងភាពងាយរងគ្រោះ | | | |
| ការទទួលបាន និងការប្រើប្រាស់សេវាសុខភាព | | | |
| ឥរិយាបថថែទាំសុខភាព | | | |
| បទពិសោធន៍ក្នុងមជ្ឈដ្ឋានថែទាំសុខភាព | | | |
| លទ្ធផល និងផលវិបាកផ្នែកសុខភាព និងសង្គម | | | |

ប្រភព ៖ WHO ឆ្នាំ ២០១១

ប្រអប់នីមួយៗក្នុងម៉ាទ្រិចនេះតំណាងឱ្យសំណួរស្តីពីផលប៉ះពាល់នៃកត្តាជីវសាស្ត្រ ឬយេនឌ័រលើលទ្ធផលសុខភាព។ ឧ. ប្រអប់ទី ២ នៅជួរដេកទីមួយ (ភាពប្រសព្វគ្នានៃកត្តាសង្គម និងកត្តាហានិភ័យ និងភាពងាយរងគ្រោះ តំណាងឱ្យសំណួរ ៖ តើកត្តាហានិភ័យ និងភាពងាយរងគ្រោះដោយសារលក្ខខណ្ឌសុខភាពនេះរងឥទ្ធិពលពីតួនាទី និងបទដ្ឋានយេនឌ័រ ឬការបែងចែកពលកម្មតាមយេនឌ័រ? ឧបមាថា យើងកំពុងធ្វើការវិភាគយេនឌ័រដោយផ្អែកតាមគ្រោះថ្នាក់ចរាចរណ៍។ បន្ទាប់មក យើងនឹងស្វែងរកភស្តុតាងបញ្ជាក់ពីផលប៉ះពាល់នេះ និងរកឃើញថា បុរសងាយប្រឈមនឹងហានិភ័យជាងស្ត្រី ដោយសារតែការផ្សារភ្ជាប់ភាពជាបុរសទៅនឹងឥរិយាបថដែលមានហានិភ័យនៅតាមដងផ្លូវ និងដោយសារតែបុរសច្រើនតែជាអ្នកបើកបរ (ការបែងចែកពលកម្មតាមយេនឌ័រ)។

**ចំណុចពិភាក្សា**

សួរអ្នកចូលរួមអំពីការយល់ឃើញរបស់ពួកគេពាក់ព័ន្ធនឹងគុណសម្បត្តិ និងគុណវិបត្តិនៃក្របខ័ណ្ឌ Moser និងក្របខ័ណ្ឌ Harvard និងម៉ាទ្រិចវិភាគយេនឌ័រ (GAM)។

**រូបទី ៣០ ៖ តម្រុយសម្រាប់អ្នកសម្របសម្រួល-គុណសម្បត្តិ ដែនកំណត់ និងសក្ដានុពលនៃការប្រើប្រាស់ក្របខ័ណ្ឌ Moser និងក្របខ័ណ្ឌ Harvard និងម៉ាទ្រិចវិភាគយេនឌ័រ**

| | គុណសម្បត្តិ | ដែនកំណត់ | សក្ដានុពលនៃការប្រើប្រាស់ |
|---|---|---|---|
| **ក្របខ័ណ្ឌ Moser** | > មានប្រសិទ្ធភាពសម្រាប់ក្រុមដែលមិនសូវមានការយល់ដឹងច្រើនអំពីស្ថានភាពនៅមូលដ្ឋាន ជាពិសេសតួនាទីរបស់ស្ត្រី<br>> មានប្រយោជន៍ក្នុងនាមជាឧបករណ៍ដែលមានការចូលរួមសម្រាប់ជួយដល់ស្ត្រី និងបុរសក្នុងការកំណត់តម្រូវការផ្ទាល់ខ្លួន<br>> ផ្តល់ព័ត៌មានតាមមូលដ្ឋាន និងការរៀបចំផែនការនៅកម្រិតមូលដ្ឋាន ៖ ផ្តល់ទឡ្ហីករណ៍ប្រឆាំងនឹងទ្រឹស្តីដែលកំណត់ថាអ្វីៗបានប្រែប្រួល។ | > ទាមទារការងារចុះវាលនិងប្រហែលជាមិនសុទ្ធតែទាក់ទាញចំណាប់អារម្មណ៍របស់មន្ត្រីរដ្ឋាភិបាលនោះទេ<br>> ភាពលម្អៀងបង្កប់ឬវិធីសាស្ត្រ "ខ្ញុំដឹងគ្រប់យ៉ាង" រាំងស្ទះដល់ការវិភាគគុណភាព<br>> ឧបករណ៍ទី១គ្រាន់តែជួយកំណត់រកសកម្មភាពសម្រាប់តម្រូវការជាក់ស្តែង។ឧបករណ៍សម្រាប់តម្រូវការជាយុទ្ធសាស្ត្រមានភាពស្មុគស្មាញពេកសម្រាប់អ្នកដែលមិនមែនសកម្មជនយេនឌ័រ។ | > សម្រាប់ការវិភាគយេនឌ័រជារួម<br>> សម្រាប់ការបញ្ជ្រាបការយល់ដឹង និងការបណ្តុះបណ្តាល<br>> ដើម្បីគូសបញ្ជាក់ពីតួនាទីដែលមិនទទួលបានប្រាក់ឈ្នួលរបស់ស្ត្រី<br>> ដើម្បីគូសបញ្ជាក់ពីតួនាទីដែលមិនរកប្រាក់កម្រៃរបស់ស្ត្រី និងភាពចាំបាច់នៃការដាក់បញ្ចូលតួនាទីនេះក្នុងការរៀបចំផែនការ។ |
| **ក្របខ័ណ្ឌ Harvard** | > ធ្វើឱ្យការងាររបស់ស្ត្រីមានភាពលេចធ្លោរ<br>> ការអនុវត្តកម្មវិធីនិងចំណុចផ្តោតធ្វើឱ្យអ្នកអនុវត្តន៍ចាប់អារម្មណ៍លើក្របខ័ណ្ឌនេះ<br>> បន្ទាប់ពីត្រូវបានកំណត់សម្រាប់វិស័យមួយក្នុងតំបន់មួយអាចក្លាយជាឯកសារគម្រោងសម្រាប់ការប្រើប្រាស់ទូទៅជាជាងការធ្វើកិច្ចការដដែលឡើងវិញគ្រប់ពេល<br>> ជួយកំណត់រកចំណុចចាប់ផ្តើមដោយផ្អែកលើប្រសិទ្ធផល និងអាចនាំទៅរកការទទួលយកយ៉ាងឆាប់រហ័សចំពោះការបែងចែកធនធាន<br>> ផ្តោតលើតម្រូវការជាក់ស្តែងនិងតម្រូវការជាយុទ្ធសាស្ត្រ<br>> អាចប្រើប្រាស់សម្រាប់ការវាយតម្លៃគម្រោង | > ហាក់ស្មុគស្មាញពីដំបូង<br>> ទាមទារការសម្របសម្រួលយ៉ាងច្រើនដើម្បីកំណត់អត្តសញ្ញាណបុគ្គលដែលធ្វើអ្វីជាញឹកញាប់ ចម្លើយគឺទាំងពីរ។<br>> ខណៈដែលក្របខ័ណ្ឌនេះផ្តល់ទិដ្ឋភាពរួមស្តីពីតម្រូវការជាយុទ្ធសាស្ត្រវាមិនបញ្ជាក់ពីមូលហេតុនោះទេ។<br>> ច្រើនតែផ្អែកលើវិធីសាស្ត្រប្រសិទ្ធផល ជាជាងការបង្កើនភាពអង់អាច។ | > សម្រាប់ការវិភាគតាមវិស័យ ៖ កសិកម្ម ការគ្រប់គ្រងទឹក សុខភាព។ល។<br>> ជួយគូសបញ្ជាក់ពីតួនាទីរបស់ស្ត្រីក្នុងសកម្មភាពជាក់លាក់។<br>> អាចជួយបង្កើនប្រសិទ្ធផល និងកំណត់រកតួនាទីរបស់ស្ត្រីក្នុងនាមជាភ្នាក់ងារនៃផ្លាស់ប្តូរក្នុងវិស័យនោះ។ |
| **GAM** | > មានលក្ខណៈសាមញ្ញ ជាប្រព័ន្ធ និងប្រើទស្សនទានទូទៅ<br>> លើកទឹកចិត្តឱ្យធ្វើការវិភាគ "ក្រោម-លើ" តាមរយៈការចូលរួមរបស់សហគមន៍។<br>> វិធីសាស្ត្រមានលក្ខណៈផ្លាស់ប្តូរ និងបច្ចេកទេសដោយរួមបញ្ចូលការកសាងការយល់ដឹងអំពីវិសមភាពយេនឌ័រ និងការអភិវឌ្ឍជំនាញអនុវត្តន៍<br>> រួមបញ្ចូលបុរសជាប្រភេទមួយនិងអាចប្រើប្រាស់ក្នុងអន្តរាគមន៍ដែលផ្តោតលើបុរស។ | > ចាំបាច់ត្រូវមានអ្នកសម្របសម្រួលដ៏ល្អម្នាក់<br>> ការវិភាគត្រូវធ្វើឡើង ដដែលៗដើម្បីផ្តោតលើការផ្លាស់ប្តូរកន្លងមក។<br>> GAM មិនបង្ហាញច្បាស់ថាតើស្ត្រីណាខ្លះ និងបុរសណាខ្លះដែលងាយប្រឈមនឹងផលប៉ះពាល់វិជ្ជមាន ឬអវិជ្ជមាន។<br>> មិនរួមបញ្ចូលការវិភាគខ្នាតម៉ាក្រូ ឬការវិភាគស្ថាប័ន។<br>> មានប្រយោជន៍ក្នុងនាមជាឧបករណ៍រៀនសូត្រជាប្រចាំ។ | > ការអនុវត្តផ្អែកលើគម្រោង<br>> ច្រើនតែសម្រាប់ការប្រើប្រាស់តាមវិស័យ ដូចជា ក្នុងកសិកម្ម (សន្តិសុខស្បៀង) សុខភាព និងអាហារូបត្ថម្ភ<br>> នៅពេលត្រូវប្រើប្រាស់ដោយទាមទាឲ្យអនុវត្តដោយបុគ្គលិកនៅសហគមន៍មូលដ្ឋាន។ |

## ឧបករណ៍ប៉ាន់ប្រម៉ាណ ភាពងាយរងគ្រោះដែលមានទស្សនៈយេនឌ័រ

ការប៉ាន់ប្រម៉ាណភាពងាយរងគ្រោះគឺជាជំហានសំខាន់ក្នុងការរៀបចំផែនការការប្រែប្រួលអាកាសធាតុនិងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ។វាមានសារសំខាន់ណាស់ក្នុងការធ្វើការប៉ាន់ប្រម៉ាណភាពងាយរងគ្រោះដែលមានទស្សនៈយេនឌ័រដើម្បីផ្តល់ព័ត៌មានដល់អ្នកបង្កើតគោលនយោបាយនានា ពីតម្រូវការរបស់ក្រុមគោលដៅ និងកិច្ចអន្តរាគមន៍គោលនយោបាយណាមួយដែលទំនងជាមានប្រសិទ្ធភាពជាងគេក្នុងការជួយដល់ទាំងបុរស និងស្ត្រីក្នុងការបន្សាំឲ្យកាន់តែល្អប្រសើរទៅនឹងការប្រែប្រួលអាកាសធាតុ (Care International ឆ្នាំ២០១៤)។ ឧបករណ៍ប៉ាន់ប្រម៉ាណភាពងាយរងគ្រោះ ដែលមានទស្សនៈយេនឌ័រមួយចំនួនត្រូវបានបង្កើតឡើង។ ភាគច្រើននៃឧបករណ៍ប៉ាន់ប្រម៉ាណទាំងនេះបង្កើតឡើងដោយផ្អែកតាមព័ត៌មានដែលប្រមូលបានអំឡុងពេលដំណាក់កាលវិភាគយេនឌ័រដោយប្រើឧបករណ៍និងក្របខ័ណ្ឌខុសៗគ្នាហើយផ្តល់នូវវិធីសាស្ត្រមួយដើម្បីភ្ជាប់ឧបករណ៍ទាំងនេះជាមួយភាពងាយរងគ្រោះពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ និងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ។ តារាងទី៥ បង្ហាញពីឧបរកណ៍ប៉ាន់ប្រម៉ាណភាពងាយរងគ្រោះ និងយេនឌ័រផ្សេងៗគ្នាជាមួយការឆ្លុះបញ្ចាំងដ៏ខ្លីទៅលើគោលបំណងរបស់ពួកវានិងពេលវេលាដ៏សាកសមអនុវត្តបំផុតសម្រាប់អង្គការសង្គមស៊ីវិល។

**តារាងទី៥៖ ទិដ្ឋភាពទូទៅនៃឧបករណ៍ប៉ាន់ប្រម៉ាណភាពងាយរងគ្រោះ និងយេនឌ័រ**

| ឧបករណ៍ | គោលបំណងគន្លឹះ | អង្គការសង្គមស៊ីវិលអាចប្រើបាន |
|---|---|---|
| ក្របខ័ណ្ឌការវិភាគសមត្ថភាព និងភាពងាយរងគ្រោះ | ត្រូវបានបង្កើតឡើងជាពិសេសសម្រាប់កិច្ចអន្តរាគមន៍ខាងផ្នែកមនុស្សធម៌ និងភាពត្រៀមបង្ការគ្រោះមហន្តរាយ។ ជំនួយនានាពីខាងក្រៅ ជំនួយផែនការទីភ្នាក់ងារក្នុងគ្រាអាសន្នជាមធ្យោបាយអន្តរាគមន៍ជួយបំពេញតម្រូវការភ្លាមៗ ក៏ដូចជាពង្រឹងការប្រឹងប្រែងនៅមូលដ្ឋាន និងគាំទ្រដល់ការអភិវឌ្ឍសង្គមសេដ្ឋកិច្ចរយៈពេលវែង។ | ការងារឆ្លើយតបគ្រោះមហន្តរាយសម្រាប់ការផ្តល់នូវអាហារ សំលៀកបំពាក់ សម្ភារផ្ទះសម្បែង ទឹក ការគាំទ្រផ្នែកអនាម័យនិងសុខភាពការបង្កើតកម្មវិធីការស្តារនីតិសម្បទាជាពិសេសការស្តារជីវភាពរស់នៅកាន់តែសាកសមសម្រាប់អ្នករៀបចំ និងអ្នកអនុវតន៍គម្រោង |
| ការប៉ាន់ប្រម៉ាណភាពងាយរងគ្រោះដែលមានទស្សនៈយេនឌ័រ | ត្រូវបានបង្កើតឡើងសម្រាប់គូសវាសបង្ហាញភាពងាយរងគ្រោះ និងសមត្ថភាពទៅតាមបរិបទ ដើម្បីបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ ជាពិសេសសម្រាប់បង្កើតការយល់ដឹងពីរបៀបដែលអាកាសធាតុកំពុង និងបន្តជះផលប៉ះពាល់ទៅលើជីវិតរបស់ក្រុមមនុស្សដែលងាយរងគ្រោះ។ | ចំណុចចាប់ផ្តើមដែលល្អសម្រាប់កម្មវិធីការបន្សាំផ្អែកលើសហគមន៍និងការអភិវឌ្ឍ ដែលមានការគិតគូរពីការប្រែប្រួលអាកាសធាតុនិងគ្រោះមហន្តរាយធម្មជាតិ។ សម្រាប់ការវាយតម្លៃចំណេះដឹងសហគមន៍ពីការប្រែប្រួលអាកាសធាតុ។ កាន់តែសាកសមសម្រាប់អ្នករៀបចំ ផែនការគម្រោង និងអ្នកអនុវត្ត ក៏ដូចជាសម្រាប់ការជំរុញការស្រាវជ្រាវ និងគោលនយោបាយនៅកន្លែងដែលមាន SADDD។ |
| សន្ទស្សន៍ភាពធន់របស់ស្ត្រី | ប្រព័ន្ធកុំព្យូទ័របែបអន្តរកម្មផ្តល់នូវព័ត៌មានភាពធន់របស់ស្ត្រីសម្រាប់ជ្រើសរើសប្រទេសនានានៅក្នុងតំបន់អាស៊ីខាងត្បូង។ ធ្វើឡើងដោយផ្អែកលើសំណុំសូចនាករ និងទិន្នន័យ - ជាមូលដ្ឋានដើម្បីដាក់បន្ទុកលើភាពធន់។ | មានប្រយោជន៍សម្រាប់ការប៉ាន់ប្រម៉ាណ បែបបរិមាណ និងសម្រាប់គូសបង្ហាញនូវភាពងាយរងគ្រោះតាមលក្ខណៈវិសាលភាព/តំបន់។កាន់តែសាកសមសម្រាប់ការជំរុញដល់ការស្រាវជ្រាវ និងគោលនយោបាយ។ |
| ការប៉ាន់ប្រម៉ាណយេនឌ័ររហ័សសម្រាប់វិបត្តិ | ជាវិធីសាស្ត្រខ្លីសម្រាប់ការវិភាគយេនឌ័រដោយលម្អិតក្នុងស្ថានភាពអាសន្ននានា។ | ការវាយតម្លៃស្ថានភាពក្រោយគ្រោះមហន្តរាយ និងការរីករាលដាលភ្លាមៗ។<br><br>កាន់តែសាកសមសម្រាប់អ្នករៀបចំនិងអ្នកអនុវតន៍គម្រោង |
| ការសិក្សាកំណត់វិសាលភាពតាមវិស័យ | ការប្រើនូវគម្រោងស្រាវជ្រាវដោយប្រើវិធីសាស្ត្រចម្រុះសម្រាប់ការវិភាគតាមវិស័យ។ | ផ្តល់នូវធាតុចូលក្នុងផែនការជាតិបន្សាំ (តាមវិស័យ)ហើយដើម្បីជំរុញកញ្ចប់ថវិកាតាមវិស័យ។<br><br>កាន់តែសាកសមសម្រាប់ការជំរុញដល់ការស្រាវជ្រាវ និងគោលនយោបាយ។ |
| ការប៉ាន់ប្រម៉ាណមិនមានអ្នកណាម្នាក់ត្រូវបានទុកចោល | សំណុំជំហានទាំងប្រាំសម្រាប់ការវិភាគLNOBសកម្មភាពការត្រួតពិនិត្យ គណនេយ្យភាព និងការចូលរួមប្រកបដោយអត្ថន័យ ដែលអាចអនុវត្តទៅបាននៅក្នុងបរិបទនៃប្រព័ន្ធអង្គការសហប្រជាជាតិ។ | មានប្រយោជន៍សម្រាប់រួមបញ្ចូលជាមួយឧបករណ៍ការប៉ាន់ប្រម៉ាណ ដែលមានស្រាប់តាមទម្រង់សំណួរ ដើម្បីធានាបានថា គ្រប់ក្រុមយេនឌ័រ និងក្រុមដែលងាយរងគ្រោះ ត្រូវបានគិតគូរពិចារណា។ |

## ក្របខ័ណ្ឌការវិភាគសមត្ថភាព និងភាពងាយរងគ្រោះ (CVA)

ក្របខ័ណ្ឌការវិភាគសមត្ថភាព និងភាពងាយរងគ្រោះ (CVA) (UNDP nd) ត្រូវបានបង្កើតឡើងដោយឈរលើសម្មតថា ចំណុចខ្លាំង (ឬសមត្ថភាព) និងចំណុចខ្សោយ (ឬភាពងាយរងគ្រោះ) ដែលមានស្រាប់របស់ក្រុមមនុស្ស បញ្ជាក់នូវផលប៉ះពាល់នៃវិបត្តិមួយ ដែលកើតឡើងលើពួកគេ ក៏ដូចជារបៀបដែលពួកគេឆ្លើយតបទៅនឹងវិបត្តិនោះ។ វាមានសារៈប្រយោជន៍ ជាពិសេសសម្រាប់ការរៀបចំផែនការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ។CVAញែកឱ្យឃើញពីភាពខុសគ្នារវាងប្រភេទចំនួនបីនៃសមត្ថភាពនិងភាពងាយរងគ្រោះនានា ដោយប្រើម៉ាទ្រីកវិភាគខាងក្រោម៖

**តារាងទី ៦៖ ម៉ាទ្រិច CVA៖ សំណួរគន្លឹះនានា និងឧបករណ៍/វិធីសាស្ត្រវិភាគយេនឌ័រ**

| ប្រភេទបីនៃភាពងាយរងគ្រោះ និងសមត្ថភាព | ភាពងាយរងគ្រោះ* | | សមត្ថភាព** | |
|---|---|---|---|---|
| | បុរស | ស្ត្រី | បុរស | ស្ត្រី |
| រូបិយ ឬរូបវន្ត (រួមមាន សណ្ឋាននៃអាកាសធាតុ ដី និងបរិស្ថានដែលមនុស្សរស់នៅ ឬកន្លែងរស់នៅមុនពេលមានវិបត្តិ៖ សុខភាព ជំនាញរបស់ពួកគេ ការងាររបស់ពួកគេ ផ្ទះសម្បែងរបស់ពួកគេ បច្ចេកវិទ្យា ទឹក និងការផ្គត់ផ្គង់ស្បៀងអាហារ ការទទួលបានមូលធន និងធនធានដទៃទៀតរបស់ពួកគេ)៖<br><br>សំណួរគន្លឹះត្រូវពិចារណា៖<br>• តើវិធីសាស្ត្រអ្វីខ្លះអាចជា/គឺជាមធ្យោបាយដែលបុរសនិងស្ត្រីនៅក្នុងសហគមន៍ ធ្លាប់មាន/មាន/អាចមាន ភាពងាយរងគ្រោះខាងផ្នែករូបិយ ឬរូបវន្ត?<br>• តើធនធានផលិតកម្ម ជំនាញ និងមុខសញ្ញាគ្រោះថ្នាក់អ្វីខ្លះ ធ្លាប់មាន/មាន/អាចមាន?<br>• នរណា (បុរស និង/ឬ ស្ត្រី ក្រុមបុរសមួយណា និងក្រុមស្ត្រីមួយណា) ធ្លាប់ជា/ជា/អាចជាអ្នកគ្រប់គ្រងលើធនធានទាំងនេះ? | ១. ការនេសាទនៅដែនសមុទ្រអន្តរជាតិ | ១. ចំនួនមរណៈភាពច្រើនឡើង | ១.ចំណេះដឹងទប់ទល់នឹងទឹកជំនន់ផ្សេងៗ | ១. ការគ្រប់គ្រងទឹកនិងស្បៀងអាហារ |
| សង្គម ឬ អង្គការ (រួមមានគ្រួសារ និងប្រព័ន្ធសហគមន៍ និងរួមមានរចនាសម្ព័ន្ធនយោបាយផ្លូវការ និងប្រព័ន្ធមិនផ្លូវការតាមរយៈក្រុមមនុស្សធ្វើសេចក្ដីសម្រេចចិត្ត បង្កើតភាពជាអ្នកដឹកនាំ ឬរៀបចំសកម្មភាពសេដ្ឋកិច្ចនិងសង្គមផ្សេងៗ)<br><br>សំណួរគន្លឹះត្រូវពិចារណា៖<br>• តើរចនាសង្គមរបស់សហគមន៍មានរូបរាងដូចម្ដេចនៅមុនគ្រោះមហន្តរាយ ហើយតើវាបម្រើដល់ពួកគេយ៉ាងដូចម្ដេចនៅចំពោះមុខគ្រោះមហន្តរាយនេះ?<br>• តើគ្រោះមហន្តរាយបង្កឱ្យមានផលប៉ះពាល់ទៅលើរចនាសម្ព័ន្ធសង្គមដូចម្ដេចខ្លះ?<br>• តើប្រព័ន្ធគ្រោះមហន្តរាយនាពេលអនាគតអាចនឹងជះឥទ្ធិពលទៅលើរចនាសម្ព័ន្ធសង្គមដូចម្ដេចខ្លះ?<br>• តើកម្រិត និងគុណភាពនៃការចូលរួមប៉ុន្មាននៅក្នុងរចនាសម្ព័ន្ធទាំងនេះមានលក្ខណៈដូចម្ដេចខ្លះ? | ១.ចំណាកស្រុកចេញទៅក្រៅរកការងារ | ១.ព័ត៌មានមានកម្រិត | ១.និន្នាការនយោបាយ | ១. គណៈកម្មាធិការព្រៃឈើមូលដ្ឋាន |
| ទឹកចិត្ត និងឥរិយាបថ (រួមមានកត្តាវប្បធម៌និងចិត្តសាស្ត្រ ដែលផ្អែកទៅលើសាសនា ផ្អែកលើប្រវត្តិនៃវិបត្តិនៅក្នុងសហគមន៍ ផ្អែកទៅលើការរំពឹងទុកទទួលបានការសង្គ្រោះបន្ទាន់នៅគ្រាអាសន្ន)៖<br><br>សំណួរគន្លឹះត្រូវពិចារណា៖<br>• តើបុរសនិងស្ត្រីនៅក្នុងសហគមន៍មើលឃើញចំពោះខ្លួនឯងនិងសមត្ថភាពរបស់ពួកគេក្នុងការដោះស្រាយប្រកបដោយប្រសិទ្ធភាពជាមួយបរិស្ថាននយោបាយ/សង្គមរបស់ពួកគេយ៉ាងដូចម្ដេច? | ១. អាកប្បកិរិយាទទួលយកហានិភ័យ | ១. អំពើហិង្សាក្នុងគ្រួសារ | ១. ការទទួលបានឥណទាន | ១. ឱកាសក្នុងការធ្វើសកម្មភាព និងរៀនសូត្រ |

| | | | | |
|---|---|---|---|---|
| • នៅមុនគ្រោះមហន្តរាយ តើក្រុមមនុស្សមានយល់ឃើញ និងមានទឹកចិត្តយ៉ាងដូចម្តេច? ហើយតើគ្រោះមហន្តរាយនេះប៉ះពាល់លើពួកគេយ៉ាងដូចម្តេច? នេះរួមមានជំនឿលើតួនាទី និងទំនាក់ទំនង យេនឌ័រ។<br>• តើប្រជាជនមានអារម្មណ៍ថាពួកគាត់មានសមត្ថភាពគូសវាសជីវិតពួកគាត់ទេ?<br>• តើបុរស និងស្ត្រីមានអារម្មណ៍ថា ពួកគេមានសមត្ថភាពដូចគ្នាទេ? | | | | |

* ពាក្យគន្លឹះនេះសំដៅដល់កត្តារយៈពេលវែង ដែលធ្វើឱ្យចុះខ្សោយដល់សមត្ថភាពរបស់ក្រុមមនុស្សក្នុងការដោះស្រាយជាបឋមជាមួយនឹងគ្រោះមហន្តរាយភ្លាមៗឬជាមួយគ្រាអាសន្នអូសបន្លាយពេលយូរ។ពួកវាធ្វើឱ្យមនុស្សកាន់តែងាយទទួលរងនូវគ្រោះមហន្តរាយ។ភាពងាយរងគ្រោះកើតមានមុនពេលគ្រោះមហន្តរាយចូលរួមចំណែកដល់កម្រិតធ្ងន់ធរនៃគ្រោះមហន្តរាយធ្វើឱ្យកាន់តែពិបាកក្នុងការឆ្លើយតបទៅនឹងគ្រោះមហន្តរាយប្រកបដោយប្រសិទ្ធភាព និងបន្តកើតមានក្រោយគ្រោះមហន្តរាយ។

** ពាក្យគន្លឹះនេះសំដៅដល់ភាពខ្លាំងដែលមានស្រាប់របស់ក្រុមបុគ្គលនិងក្រុមសង្គម។ចំណុចខ្លាំងមានជាប់ទាក់ទងទៅនឹងធនធានរូបិយនិងធនធានរូបវន្តរបស់ក្រុមមនុស្សធនធានសង្គមរបស់ពួកគេ និងជំនឿនិងឥរិយាបថរបស់ពួកគេ។ សមត្ថភាពត្រូវបានបង្កើតដោយសន្សឹមៗ និងកំណត់សមត្ថភាពរបស់ក្រុមមនុស្សដើម្បីដោះស្រាយវិបត្តិ និងស្តារឡើងវិញពីវិបត្តិនោះ។

ប្រភព៖ (UNDP nd)

ម៉ាទ្រិច CVA យេនឌ័រ ជួយឱ្យអ្នកវិភាគអាច «គូសវាសផែនទី» បង្ហាញនូវស្ថានភាពជាក់ស្តែងដ៏ស្មុគស្មាញមួយ និងអាចជួយគូសបង្ហាញនូវទំនាក់ទំនងរវាងកត្តាខុសគ្នាៗ។ ម៉ាទ្រិចនេះវិភាគលើសពីរូបវន្តទៅទៀត និងអាចជួយត្រួតពិនិត្យអន្តរទំនាក់ទំនងសង្គមនៅក្នុងសហគមន៍ (ឧ. ភាពចុះសម្រុងសង្គម និងភាពជាអ្នកដឹកនាំ) និងវិស័យចិត្តសាស្ត្រ (ឧ.ការបាត់បង់ក្តីសង្ឃឹមនាពេលអនាគត)។ CVA មានលក្ខណៈបត់បែន និងអាចយកប្រើមុនពេលអំឡុងពេលនិងក្រោយពេលគ្រោះមហន្តរាយឬការអន្តរាគមន៍ប៉ុន្តែវាមិនមែនជាការជំរុញលើកទឹកចិត្តរយៈពេលខ្លីទេតែវាជាទស្សនៈវិស័យរយៈពេលវែងតាមរយៈការគូសបង្ហាញឱ្យឃើញពីសារសំខាន់ក្នុងការកាត់បន្ថយភាពងាយរងគ្រោះ និងការពង្រឹងសមត្ថភាព។

**ចំណុចពិភាក្សា**

សូមសាកសួរទៅអ្នកចូលរួមពីរបៀបដែលពួកគាត់នឹងបង្កើតព័ត៌មានផ្អែកតាមប្រភេទខាងលើ

តម្រុយសម្រាប់អ្នកសម្របសម្រួល

ឧបករណ៍មួយចំនួនដែលពួកគាត់អាចប្រើសម្រាប់វិភាគ រួមមាន៖
> រូបវន្ត៖ ប្រវត្តិសកម្មភាព ប្រវត្តិការទទួលបាន និងការគ្រប់គ្រង
> សង្គម៖ វិភាគអ្នកពាក់ព័ន្ធ ការបង្កើតផែនទីស្ថាប័ន
> ទឹកចិត្ត៖ ការអង្កេត ការសម្ភាសន៍ដោយប្រើសំណួរបើក និងកិច្ចពិភាក្សា ក្រុមគោលដៅ

## ការប៉ាន់ប្រម៉ាណភាពងាយរងគ្រោះនឹងអាកាសធាតុ និងសមត្ថភាពដែលមានទស្សនៈយេនឌ័រ (GCVCA)

សៀវភៅណែនាំ អ្នកអនុវត្តការប៉ាន់ប្រម៉ាណភាពងាយរងគ្រោះនឹងអាកាសធាតុ និងសមត្ថភាពដែលមានទស្សនៈយេនឌ័រ (GCVCA) (Care International ឆ្នាំ២០១៤) ផ្តល់នូវក្របខ័ណ្ឌមួយសម្រាប់ការវិភាគភាពងាយរងគ្រោះនិងសមត្ថភាពដើម្បីបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ និងកសាងភាពធន់ទៅនឹងគ្រោះមហន្តរាយនៅកម្រិតសហគមន៍ដោយផ្តោតសំខាន់លើសង្គម និងពិសេសលើឌីណាមិចយេនឌ័រ។ ដំណើរការ GCVCA ប្រើ សំណួរណែនាំ ដើម្បីវិភាគព័ត៌មានស្តីពីការប្រែប្រួលអាកាសធាតុ ហានិភ័យគ្រោះមហន្តរាយ និងភាពងាយរងគ្រោះនៅកម្រិតថ្នាក់ជាតិ រដ្ឋាភិបាលមូលដ្ឋាន/សហគមន៍ និងកម្រិតគ្រួសារ/បុគ្គល។ ដំណើរការនេះ អាចប្រព្រឹត្តទៅបានដោយការប្រើឧបករណ៍ដែលមានការចូលរួមក៏ដូចជាការស្រាវជ្រាវដោយប្រើទិន្នន័យបន្ទាប់បន្សំសម្រាប់ការវិភាគគោលនយោបាយ។ ការបង្កើតGCVCAមានប្រាំពីរជំហានសំខាន់ៗដូចមានបង្ហាញក្នុងរូបទី ៣១។

## រូបទី ៣១៖ គំនូសជំហានទាំងប្រាំពីររបស់ GCVCA




ប្រភព៖ (Care international ឆ្នាំ២០១៤)

សំណួរណែនាំគន្លឹះសម្រាប់ GCVCA នៅកម្រិតមូលដ្ឋាន និងឧបករណ៍ដែលអាចផ្តល់ទិន្នន័យត្រូវបានគូសបង្ហាញនៅក្នុងតារាង - បន្ទាប់៖

**តារាងទី៧៖ សំណួរណែនាំគន្លឹះសម្រាប់ GCVCA នៅកម្រិតមូលដ្ឋាន និងឧបករណ៍ដែលអាចប្រើបានសម្រាប់ប្រមូលទិន្នន័យ**

| កម្រិត | គោលបំណង | សំណួរ | ឧបករណ៍ប្រមូលទិន្នន័យ |
|---|---|---|---|
| | | **បរិបទទូទៅ** | |
| ៣. សារសំខាន់ | ក១. បរិបទការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ | • ធាតុអាកាសមានភាពធ្ងន់ធ្ងរ (សីតុណ្ហភាព កំណកអាកាស ព្យុះស៊ីក្លូន ទឹកជំនន់ ភាពរាំងស្ងួត ។ល។) ត្រូវបានចាត់ទុកថាធម្មតា ហើយតើវាមានការប្រែប្រួលដែរឬទេ?<br>• នៅក្នុងរយៈពេលប៉ុន្មានទសវត្សរ៍ និងប៉ុន្មានឆ្នាំថ្មីៗនេះ តើប្រជាជនបានសង្កេតឃើញមានអ្វីប្រែប្រួលក្នុងអាកាសធាតុ និងធាតុអាកាសដូចម្តេចខ្លះ?<br>• តើមុខសញ្ញាគ្រោះថ្នាក់មួយណាកើតឡើងនៅក្នុងតំបន់ តើវាកើតឡើងពេលណា ញឹកញាប់ និងធ្ងន់ធ្ងរកម្រិតណា? នៅពេលមុខសញ្ញាគ្រោះថ្នាក់ទាំងនេះកើតឡើង តើបានសង្កេតឃើញមានការប្រែប្រួលឬទេ (ភាពញឹកញាប់ កម្រិតប្រែប្រួល ។ល។)? | ប្រតិទិនតាមរដូវកាល<br><br>របាប្រវត្តិសាស្ត្រ<br>កិច្ចពិភាក្សាក្រុមគោលដៅ<br><br>ការធ្វើចំណាត់ថ្នាក់បញ្ហាសហគមន៍ |
| | ក២. បរិបទសង្គម | • តើធនធានអ្វីខ្លះដែលសំខាន់សម្រាប់ជីវភាពរស់នៅ ចំពោះក្រុមមនុស្សខុសៗគ្នានៅក្នុងសហគមន៍?<br>• នៅក្នុងសហគមន៍តើក្រុមណាមានជីវភាពល្អប្រសើរជាងហើយក្រុមណាមានជីវភាពយ៉ាប់យឺនជាង? ក្រុមជនជាតិ និងក្រុមសាសនា? តើពួកគេធ្វើអ្វី (ជីវភាពរស់នៅចម្បង) និងមានទ្រព្យសម្បត្តិអ្វីខ្លះ? តើពួកគេរស់នៅដោយរបៀបណា? | ផែនទីធនធាន<br><br>ការធ្វើចំណាត់ថ្នាក់បញ្ហាសហគមន៍ |

## មូលហេតុសំខាន់ៗនៃភាពងាយរងគ្រោះ

| កម្រិត | គោលបំណង | សំណួរ | ឧបករណ៍ប្រមូលទិន្នន័យ |
|---|---|---|---|
| | | **បរិបទទូទៅ** | |
| ១. ចំណុចសំខាន់ដែលបានផ្តល់អោយសហគមន៍ | ខ១. ការទទួលបាន និងការគ្រប់គ្រងលើធនធាននិងសេវាផ្សេងៗ | • តើធនធាន (ឧ.ដីធ្លី សមុទ្រ ទន្លេ ធនធានធម្មជាតិផ្សេងទៀត សត្វពាហណៈ ជាដើម) និងសេវាអ្វីខ្លះជាគន្លឹះសម្រាប់បុរសនិងស្ត្រីមានលទ្ធភាពទប់ទល់នឹងបញ្ហាហួសពីសមត្ថភាពដោះស្រាយ និងបន្សាំទៅនឹងការប្រែប្រួល? ហើយតើពួកគេទទួលបាន និងគ្រប់គ្រងលើធនធានទាំងនេះបានកម្រិតណា (ឧ. អំណាចការធ្វើសេចក្តីសម្រេចចិត្ត)?<br>• តើធនធាន និងសេវាមួយណាក្នុងចំណោមធនធាន និងសេវាទាំងនេះ ស្ថិតនៅក្រោមស្ត្រេសដែលបណ្តាលមកពីវិសមរូបអាកាសធាតុ និងគ្រោះមហន្តរាយ?<br>• តើវិសមភាពនៅក្នុងការទទួលបាន និងគ្រប់គ្រងលើធនធាន និងសេវាទាំងនេះ បានប្រែប្រួលដូចម្តេចកាលពីអតីតកាល ឬកំពុងប្រែប្រួលដូចម្តេចនាពេលថ្មីៗនេះ? ហើយហេតុអ្វី? | ផែនទីធនធាន<br><br>កិច្ចពិភាក្សាក្រុមគោលដៅ<br>ដ្យាក្រាមផ្លិត (Venn diagram)<br><br>ការធ្វើចំណាត់ថ្នាក់បញ្ហាសហគមន៍ |
| | ខ២. ការធ្វើសេចក្តីសម្រេចចិត្ត និងការចូលរួម | • តើដំណើរការការរៀបចំផែនការមូលដ្ឋាន ដំណើរការយ៉ាងដូចម្តេច? នរណាជាប់ពាក់ព័ន្ធឬជះឥទ្ធិពលដល់ការសម្រេចចិត្តនៅកម្រិតសហគមន៍? តើនរណាតំណាងឱ្យផលប្រយោជន៍នៅខាងក្រៅ ឧ. តំណាងឱ្យរដ្ឋាភិបាលមូលដ្ឋាន?<br>• តាមវិធីសាស្ត្រអ្វីខ្លះដែលបុរស និងស្ត្រីចូលរួម ឬធានាថាផលប្រយោជន៍របស់ពួកគេ ត្រូវលើកឡើងនៅក្នុងការធ្វើសេចក្តីសម្រេចចិត្តនៅមូលដ្ឋាន?<br>• ពេលណាវិសមរូបអាកាសធាតុ និងការប្រែប្រួលប៉ះពាល់លើជីវិត និងជីវភាពរស់នៅរបស់ក្រុមមនុស្ស តើនរណាធ្វើសេចក្តីសម្រេចចិត្តលើការប្រែប្រួលក្នុងការបែងចែងធនធាន និងការអនុវត្ត?<br>• នរណាទំនងជាទទួលបានផលប្រយោជន៍ពីសេចក្តីសម្រេចទាំងនេះ ហើយនរណាទំនងជាមិនទទួលបាន?<br>• នរណាមានឥទ្ធិពលនិងសម្រេចលើរបៀបពីការបែងចែកធនធានធម្មជាតិដូចជាដីធ្លី និងទឹក? | ផែនទីធនធាន<br><br>កិច្ចពិភាក្សាក្រុមគោលដៅ<br><br>ការធ្វើចំណាត់ថ្នាក់សហគមន៍<br><br>ដ្យាក្រាមផ្លិត (Venn diagram) |
| | ខ៣.ការបែងចែកពលកម្ម និងការប្រើប្រាស់ពេលវេលា | • នរណា (ស្ត្រី បុរស ក្មេងប្រុស ក្មេងស្រី នៅកាលៈទេសៈណា) ត្រូវបានអនុញ្ញាត ឬរំពឹងថា បំពេញការងារជាក់ស្តែង?<br>• តើឱកាស បញ្ហា និងស្ថានភាពជាក់ស្តែងអ្វីខ្លះ ដែលប្រភេទការងារ និងភារកិច្ចទាំងនេះ មានន័យសម្រាប់បុគ្គល នៃក្រុមយេនឌ័រ និងអាយុខុសៗគ្នា? តើបុរស ស្ត្រី ក្មេងប្រុស និងក្មេងស្រីចំណាយពេលចូលរួមក្នុងភារកិច្ចទាំងនេះច្រើនប៉ុណ្ណា?<br>• តើការបែងចែកពលកម្ម និងការប្រើប្រាស់ពេលវេលាមានប្រែប្រួលដោយសន្សឹមៗដូចម្តេច ហើយហេតុអ្វី? តើមានអ្វីកើតឡើងចំពោះតួនាទីនិងការប្រើប្រាស់ពេលវេលារបស់ក្រុមមនុស្សនៅក្រោមកាលៈទេសៈអាកាសធាតុប្រែប្រួល ឧទាហរណ៍ពេលទឹកជំនន់ និងភាពរាំងស្ងួតកាន់តែញឹកញាប់ និងប្រែប្រួល? | ប្រតិទិនតាមរដូវកាល<br><br>កិច្ចពិភាក្សាក្រុមគោលដៅ<br><br>ការធ្វើចំណាត់ថ្នាក់បញ្ហាសហគមន៍<br><br>ដ្យាក្រាមផ្លិត |

| កម្រិត | គោលបំណង | សំណួរ | ឧបករណ៍ប្រមូលទិន្នន័យ |
|---|---|---|---|
| | | **បរិបទទូទៅ** | |
| | ខ៤. ការគ្រប់គ្រងលើនរណាម្នាក់ | • តើកម្រិតណាមួយដែលស្ត្រី បុរស ក្មេងប្រុស និងក្មេងស្រីគ្រប់គ្រងលើរាងកាយនិងបញ្ហាផ្លូវភេទរបស់ពួកគេការសម្រេចចិត្តលើជីវិតអាពាហ៍ពិពាហ៍ ផែនការគ្រួសារ និងសេរីភាពពីរំលោភបំពាន និងការគេងប្រវ័ញ្ច? <br>• តើកត្តាអ្វីខ្លះជះឥទ្ធិពលលើការសម្រេចចិត្តលើការរៀបអាពាហ៍ពិពាហ៍ ដៃគូរៀបការ ឬ ផែនការគ្រួសារ? <br>• តើគំរាមកំហែងអ្វីខ្លះដែលធ្វើឱ្យការគ្រប់គ្រងលើរាងកាយរបស់ស្ត្រី បុរស ក្មេងប្រុស ឬ ក្មេងស្រី ប្រឈមនឹងគ្រោះថ្នាក់ ហើយតើកត្តាអ្វីខ្លះដែលជំរុញឱ្យមានហានិភ័យទាំងនេះ? <br>• តើមានការប្រែប្រួលណាមួយនៅក្នុងជីវភាពទាំងនេះឬទេ និងហេតុអ្វី? <br>• តើផលប៉ះពាល់អ្វីខ្លះបណ្តាលមកពីវិសមរូបអាកាសធាតុ និងគ្រោះមហន្តរាយមានទៅលើការគ្រប់គ្រងរាងកាយ ឬតើការប្រែប្រួលអាកាសធាតុនិងគ្រោះមហន្តរាយកំពុងជះឥទ្ធិពលយ៉ាងដូចម្តេចទៅលើការគ្រប់គ្រងទៅលើស្ត្រី និងក្មេងស្រីក្នុងការគ្រប់គ្រងរាងការរបស់ពួកគេ? | កិច្ចពិភាក្សាក្រុមគោលដៅ <br><br> ការធ្វើចំណាត់ថ្នាក់បញ្ហាសហគមន៍ |
| | | **ជីវភាពរស់នៅធន់នឹងអាកាសធាតុ** | |
| គ. ចំនុចផ្តោតដែលអាចមាន | គ.១. ជីវភាពរស់នៅ | • តើដំណើរការការរៀបចំផែនការមូលដ្ឋាន ដំណើរការយ៉ាងដូចម្តេច? នរណាជាប់ពាក់ព័ន្ធឬជះឥទ្ធិពលដល់ការសម្រេចចិត្តនៅកម្រិតសហគមន៍? តើនរណាតំណាងឱ្យផលប្រយោជន៍នៅខាងក្រៅ ១. តំណាងឱ្យរដ្ឋាភិបាលមូលដ្ឋាន? <br>• តាមវិធីសាស្ត្រអ្វីខ្លះដែលបុរស និងស្ត្រីចូលរួម ឬធានាថាផលប្រយោជន៍របស់ពួកគេ ត្រូវលើកឡើងនៅក្នុងការធ្វើសេចក្តីសម្រេចចិត្តនៅមូលដ្ឋាន? <br>• ពេលណាវិសមរូបអាកាសធាតុ និងការប្រែប្រួលប៉ះពាល់លើជីវិត និងជីវភាពរស់នៅរបស់ក្រុមមនុស្ស តើនរណាធ្វើសេចក្តីសម្រេចចិត្តលើការប្រែប្រួលក្នុងការបែងចែងធនធាន និងការអនុវត្ត? <br>• នរណាទំនងជាទទួលបានផលប្រយោជន៍ពីសេចក្តីសម្រេចទាំងនេះ ហើយនរណាទំនងជាមិនទទួលបាន? <br>• នរណាមានឥទ្ធិពលនិងសម្រេចលើរបៀបពីការបែងចែកធនធានធម្មជាតិដូចជាដីធ្លី និងទឹក? | ផែនទីធនធាន <br><br> កិច្ចពិភាក្សាក្រុមគោលដៅ <br><br> ការធ្វើចំណាត់ថ្នាក់សហគមន៍ <br><br> ដ្យាក្រាមផ្លិត (Venn diagram) |
| | គ.២. យុទ្ធសាស្ត្រដោះស្រាយនិងការបន្សាំ | • តើយុទ្ធសាស្ត្រអ្វីខ្លះដែលត្រូវបានគេយកទៅប្រើនាពេលថ្មីៗនេះដើម្បីដោះស្រាយជាមួយបញ្ហា និងស្ត្រេសជះឥទ្ធិពលទៅលើជីវភាពរស់នៅរបស់ស្ត្រី និងបុរស? <br>• តើស្ត្រីនិងបុរសដែលស្ថិតក្នុងស្ថានភាពសង្គមខុសគ្នានឹងគ្រប់គ្រងហានិភ័យរៀបចំផែនការនិងវិនិយោគសម្រាប់ពេលអនាគតដោយរបៀបណា? នរណាបង្កើត និងប្រើប្រាស់ព័ត៌មានអាកាសធាតុ | ប្រតិទិនតាមរដូវកាល <br><br> ការធ្វើចំណាត់ថ្នាក់បញ្ហាសហគមន៍ |

| កម្រិត | គោលបំណង | សំណួរ | ឧបករណ៍ប្រមូលទិន្នន័យ |
|---|---|---|---|
| | | **បរិបទទូទៅ** | |
| | | • សម្រាប់ការរៀបចំផែនការ? តើស្ត្រី និងបុរសជាមេគ្រួសារកំពុងអនុវត្តតាមវិធីធ្វើកសិកម្មធន់នឹងអាកាសធាតុឬទេ? បើមាន តើមេគ្រួសារមួយណាប្រើការអនុវត្តបែបនេះ (ស្ថានភាពសង្គម-សេដ្ឋកិច្ច បុរស ឬស្ត្រីជាមេគ្រួសារ ។ល។)? | |
| | | **ជីវភាពរស់នៅធន់នឹងអាកាសធាតុ** | |
| គ. ចំនុចផ្តោតដែលអាចមាន | គ.៣. មុខសញ្ញាគ្រោះថ្នាក់និងការប្រែប្រួល | • តើអ្វីខ្លះជាមុខសញ្ញាគ្រោះថ្នាក់ពាក់ព័ន្ធនឹងអាកាសធាតុសំខាន់បំផុត ហើយអ្វីខ្លះជាមុខសញ្ញាគ្រោះថ្នាក់ផ្សេងទៀតដែលតំបន់និង/ឬ តំបន់អេកូឡូស៊ីជួបប្រទះ? តើមុខសញ្ញាគ្រោះថ្នាក់ទាំងនោះ បានប្រែប្រួលដូចម្តេចខ្លះនៅក្នុងរយៈពេលប៉ុន្មានទសវត្សរ៍និងប៉ុន្មានឆ្នាំកន្លងមកនេះ?ហើយនាពេលបច្ចុប្បន្ននេះ តើមុខសញ្ញាគ្រោះថ្នាក់ទាំងនោះ ប្រែប្រួលដូចម្តេចខ្លះ?<br>• តើមុខសញ្ញាគ្រោះថ្នាក់ទាំងនោះ ជះឥទ្ធិពលដូចម្តេចខ្លះ លើក្រុមខុសៗគ្នានៅក្នុងសហគមន៍? តើក្រុមមួយណាងាយរងគ្រោះបំផុតចំពោះមុខសញ្ញាគ្រោះថ្នាក់មួយណា? ហើយហេតុអ្វី? ក្រុមនីមួយៗ តើស្ត្រីទទួលរងឥទ្ធិពលដូចម្តេចខ្លះ ហើយតើបុរសទទួលរងឥទ្ធិពលដូចម្តេចខ្លះ? ហេតុអ្វី? | ផែនទីធនធាន<br><br>ប្រតិទិនតាមរដូវកាល<br><br>របាប្រវត្តិសាស្ត្រ<br><br>ការធ្វើចំណាត់ថ្នាក់បញ្ហាសហគមន៍ |
| | គ.៤. ព័ត៌មានហានិភ័យគ្រោះមហន្តរាយ | • តើស្ថាប័នមូលដ្ឋាននានាបុរសស្ត្រីក្មេងប្រុសនិងក្មេងស្រីទទួលបានព័ត៌មានហានិភ័យគ្រោះមហន្តរាយអ្វីខ្លះ?ហើយតើវាមានសារៈប្រយោជន៍យ៉ាងដូចម្តេច?<br>• តើប្រព័ន្ធប្រកាសអាសន្នអ្វីខ្លះកំពុងមាន? និងតើវាដំណើរការឬទេ? នរណា (ក្នុងចំណោមស្ត្រី បុរស ក្មេងប្រុស និងក្មេងស្រីក្នុងស្ថានភាពសង្គមខុសៗគ្នា)ចូលទៅប្រើប្រាស់ប្រព័ន្ធប្រកាសអាសន្នទាំងនេះ និងនរណាទទួលបានអត្ថប្រយោជន៍ពីប្រព័ន្ធទាំងនេះ និងនរណាមិនទទួលបានពីប្រព័ន្ធនេះ? | របាប្រវត្តិសាស្ត្រ<br><br>ការធ្វើចំណាត់ថ្នាក់បញ្ហាសហគមន៍<br><br>ដ្យាក្រាមផ្គិត |
| | គ.៥. ការឆ្លើយតបនិងយុទ្ធសាស្ត្រការគ្រប់គ្រងហានិភ័យ | • តើស្ត្រី បុរស ក្មេងប្រុស ក្មេងស្រី ការពារខ្លួនពួកគេ និងធនធានរបស់ពួកគាត់នៅក្នុងហេតុការណ៍គ្រោះមហន្តរាយមួយបៀបណា?<br>• នរណាការពារស្បៀងអាហារត្រៀមបម្រុងនិងធាតុចូលកសិកម្មជម្រកសុវត្ថិភាព និងចល័តភាព ដើម្បីបញ្ចៀស គ្រោះថ្នាក់? ហើយនរណាមិនមានការពារត្រៀមបម្រុង?នរណាអាចស្វែងរកការគាំទ្របាន? | ប្រតិទិនតាមរដូវកាល<br>របាប្រវត្តិសាស្ត្រ<br>ការធ្វើចំណាត់ថ្នាក់បញ្ហាសហគមន៍<br>ដ្យាក្រាមផ្គិត |
| | | **សមត្ថភាពមូលដ្ឋាន និងសហគមន៍** | |
| | គ.៦. ធនធៈផ្ទាល់ខ្លួននិងផលប្រយោជន៍យុទ្ធសាស្ត្រ | • តើធនធៈអ្វីខ្លះដែលបុរសស្ត្រីក្មេងប្រុសនិងក្មេងស្រីមានសម្រាប់ខ្លួនពួកគេ ឬសម្រាប់មនុស្សជំនាន់ក្រោយ?<br>• តើការផ្លាស់ប្តូរអ្វីខ្លះដែលពួកគេចង់ឃើញជុំវិញខ្លួនរបស់ពួកគេដើម្បីបង្កើតនូវធនធៈទាំងនេះដែលអាចទៅរួចបាន-ក្នុងន័យសេវានិងធនធាននានាដែលមាន ច្បាប់សង្គម បរិស្ថានធម្មជាតិ ឬបញ្ហាសុវត្ថិភាព? | របាប្រវត្តិសាស្ត្រ<br>ការធ្វើចំណាត់ថ្នាក់បញ្ហាសហគមន៍<br>ការធ្វើចំណាត់ថ្នាក់បញ្ហាសហគមន៍<br>ដ្យាក្រាមផ្គិត |

| កម្រិត | គោលបំណង | សំណួរ | ឧបករណ៍ប្រមូលទិន្នន័យ |
|---|---|---|---|
| | | **បរិបទទូទៅ** | |
| គ. ចំនុចផ្តោតដែលបានជ្រើសរើស | | • តើស្ត្រី បុរស ក្មេងប្រុស និងក្មេងស្រីយល់ថាអាចគ្រប់គ្រងលើជោគវាសនា និងអនាគត បង្កើតផែនការ និងកំណត់អាទិភាពរបស់គេបានកម្រិតណា? តើពួកគេយល់ថាអាច ប្រឈមនឹងការប្រែប្រួលក្នុងបរិបទនៃនិន្នាការដ៏ធំដែលពួកគេកំពុងមើលឃើញបានកម្រិតណា? | |
| | គ.៧. ចំណេះដឹង ព័ត៌មាន និងបច្ចេកវិទ្យា | • តើស្ត្រី និងបុរស មានចំណេះដឹងប្លែកអ្វីខ្លះ នៅក្នុងសកម្មភាពជីវភាពរស់នៅរបស់ពួកគេ? តើពួកគេមានចំណេះដឹងអ្វីខ្លះ សម្រាប់ការផ្លាស់ប្តូរនាពេលអនាគតដែលត្រូវបានរំពឹងទុក?<br>• នរណាមានចំណេះដឹង ជំនាញ និងធនធាននានា ដើម្បីយកទៅប្រើបង្កើតយុទ្ធសាស្ត្រដែលមានភាពច្នៃប្រឌិតដើម្បីគាំទ្រការបន្សាំ?<br>• តើយុទ្ធសាស្ត្រដែលមានភាពច្នៃប្រឌិតអ្វីខ្លះដែលស្ត្រីនិងបុរសអាចប្រើបានដើម្បីបន្សាំទៅនឹងបរិបទការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ? នរណាអាចទាញយកគុណប្រយោជន៍ពីយុទ្ធសាស្ត្រទាំងនេះ? ហើយនរណាទទួលបានការគាំទ្រពីស្ថាប័នក្នុងការបង្កើតយុទ្ធសាស្ត្រទាំងនេះ ហើយនរណាមិនទទួលបានការគាំទ្រ? នរណាធ្វើសេចក្តីសម្រេចចិត្តលើភាពច្នៃប្រឌិតនានា? | ប្រតិទិនតាមរដូវកាល<br>របាប្រវត្តិសាស្ត្រ<br>ដ្យាក្រាមផ្លិត<br>ការធ្វើចំណាត់ថ្នាក់<br>បញ្ហាសហគមន៍<br>ដ្យាក្រាមផ្លិត |
| | គ.៨. ការធ្វើសេចក្តីសម្រេចចិត្តដ៏ទន់ភ្លន់ និងសម្លឹងឆ្ពោះទៅមុខ | • តើគេព្យាករណ៍យ៉ាងដូចម្តេចពីថ្ងៃអនាគតថាតើពេលណា ឧទាហរណ៍ ការសម្រេចដំណាំអ្វីសម្រាប់ដាំដុះ ឬពេលណាត្រូវលក់គ្រាប់ពូជ ទិន្នផល សត្វ ឬធនធានផ្សេងៗទៀត?<br>• ក្នុងចំណោមស្ត្រី និងបុរសនៅក្នុងសហគមន៍ នរណាធ្វើការព្យាករណ៍ទាំងនេះ? ហើយតើគំនិតរបស់អ្នកណាត្រូវបានគេយកមកពិចារណានៅក្នុងសេចក្តីសម្រេចចិត្តទាំងនេះ?<br>• តើមានព័ត៌មានការព្យាករណ៍ធាតុអាកាស និងអាកាសធាតុអ្វីខ្លះ? ហើយតើព័ត៌មានទាំងនេះ ត្រូវបានផ្សព្វផ្សាយតាមរបៀបណាទៅស្ត្រីបុរសក្មេងស្រីនិងក្មេងប្រុសនៅក្នុងបរិបទសង្គមខុសៗគ្នា? ក្នុងចំណោមពួកគេ នរណាចូលទៅប្រើប្រាស់ព័ត៌មានទាំងនោះច្រើនបំផុត? នរណាទទួលបានអត្ថប្រយោជន៍ពីព័ត៌មានទាំងនោះ? ហើយតើនរណាមិនទទួលបានអត្ថប្រយោជន៍ពីព័ត៌មានទាំងនោះ? | |

ប្រភព៖ (Care Internatinal ឆ្នាំ២០១៤)

## ឧបករណ៍ប៉ាន់ប្រម៉ាណការកាត់បន្ថយភាពងាយរងគ្រោះ

វិធីសាស្ត្រប៉ាន់ប្រម៉ាណការកាត់បន្ថយភាពងាយរងគ្រោះ (VRA) គឺជាឧបករណ៍ដែលមានការចូលរួមមួយ ត្រូវបាន UNDP-GEF ប្រើប្រាស់សម្រាប់កម្មវិធីការបន្សាំដោយផ្អែកលើសហគមន៍ (CBA) (UNDP ឆ្នាំ២០១០)។ វិធីសាស្ត្រនេះត្រូវបានបង្កើតឡើងដើម្បីវាស់វែងភាពងាយរងគ្រោះរបស់សហគមន៍ដែលបណ្តាលមកពីអាកាសធាតុប្រែប្រួលនិងដើម្បីប្រៀបធៀបឆ្លងគម្រោងតំបន់និងបរិបទខុសៗគ្នាបានយ៉ាងទូលំទូលាយដែលអាចឱ្យកំណត់បាន ថាតើគម្រោងមួយអាចទទួលបានជោគជ័យ ឬបរាជ័យក្នុងការកាត់បន្ថយហានិភ័យការប្រែប្រួលអាកាសធាតុ។ VRA ផ្អែកលើសមាសធាតុនៃសំណួរសូចនាករចំនួន៤ សម្រាប់ជំហាន AFP នីមួយៗ (ក្របខ័ណ្ឌគោលនយោបាយបន្សាំ) ត្រូវបានបង្កើតឡើងដើម្បីចាប់យកបញ្ហាដែលទាក់ទងនឹងមូលដ្ឋានដែលជាស្នូលនៃការស្វែងយល់ពីភាពងាយរង

គ្រោះទៅនឹងការប្រែប្រួលអាកាសធាតុ។សំណួរនានាត្រូវបានរំលេចឡើងអំឡុងពេលកិច្ចប្រជុំកម្រិតសហគមន៍៣-៤បន្តបន្ទាប់មួយនៅក្នុងរយៈពេលនៃគម្រោងCBAមួយ។ការឆ្លើយតបទៅនឹងសំណួរធ្វើក្នុងទម្រង់ការដាក់ពិន្ទុជាលេខ ដែលផ្តល់ដោយអ្នកឆ្លើយតបអំឡុងពេលកិច្ចប្រជុំសហគមន៍ទាំងនេះ។ សូចនាករ VRA ចំនួនបួនអមជាមួយសំណួរជាឧទាហរណ៍ រួមជាមួយសមាសភាពយេនឌ័រមួយ មានគូសបញ្ជាក់នៅទីនេះ។

ការវាយតម្លៃម្តងហើយម្តងទៀតនៃទស្សនៈរបស់សហគមន៍ទៅលើប្រសិទ្ធភាពគម្រោង និងហានិភ័យការប្រែប្រួលអាកាសធាតុនានាអាចចង្អុលបង្ហាញឱ្យឃើញការប្រែប្រួលខាងផ្នែកភាពងាយរងគ្រោះ។វាត្រូវបានវាយតម្លៃតាមរយៈកម្រិតនៃការប្រែប្រួលនៅក្នុងពិន្ទុVRAដែលទាក់ទងនឹងតម្លៃគោលបង្កើតជាអាទិភាពដើម្បីការចាប់ផ្តើមសកម្មភាពគម្រោង។ វិធីសាស្ត្រផ្អែកលើទស្សនៈរបស់ VRA ជាផ្នែកសំខាន់មួយសម្រាប់សូចនាករបែបបរិមាណវិស័យក៏អាចប្រើដើម្បីវាស់វែងលទ្ធផលគម្រោងនានា។

**រូបទី ៣២៖ ការបញ្ចូលយេនឌ័រនៅក្នុងឧបករណ៍ការប៉ាន់ប្រម៉ាណភាពងាយរងគ្រោះរបស់អង្គការ UNDP**

| ជំហាន APF | សូចនាករ VRA | សំណួរ VRA (ឧទាហរណ៍សម្រាប់ជាការអនុវត្តចំពោះការបង្កើនហានិភ័យភាពរាំងស្ងួត) | បន្ថែមសមាសធាតុយេនឌ័រ |
|---|---|---|---|
| ការប៉ាន់ប្រម៉ាណភាពងាយរងគ្រោះបច្ចុប្បន្ន | ភាពងាយរងគ្រោះនៃបរបចិញ្ចឹមជីវិត/សុខុមាលភាពទៅនឹងការប្រែប្រួលអាកាសធាតុដែលមានស្រាប់និង/វិសមរូបអាកាសធាតុ | តើអ្វីកើតឡើងនៅពេលមានភាពរាំងស្ងួត? | តើមានភាពខុសគ្នាដែរឬទេរវាងបទពិសោធទាក់ទងនឹងភាពរាំងស្ងួតរបស់បុរសនិងស្ត្រី? ហេតុអ្វី? និងតើខុសគ្នាយ៉ាងដូចម្តេច? |
| ការប៉ាន់ប្រម៉ាណហានិភ័យអាកាសធាតុនាពេលអនាគត | ភាពងាយរងគ្រោះនៃបរបចិញ្ចឹមជីវិត/សុខុមាលភាពទៅនឹងហានិភ័យការប្រែប្រួលអាកាសធាតុដែលកំពុងវិវត្ត | តើអ្វីនឹងកើតឡើងប្រសិនបើភាពរាំងស្ងួតកើនឡើងពីរដងធៀបនឹងធម្មតា? | តើការណ៍នេះនឹងប៉ះពាល់ខុសគ្នាដល់បុរស និងស្ត្រីដែរឬទេ? ប្រសិនបើប៉ះពាល់ តើប៉ះពាល់ដោយរបៀបណា? |
| បង្កើតយុទ្ធសាស្ត្របន្សាំមួយ | វិសាលភាពនៃឧបសគ្គ (ឧបសគ្គស្ថាប័ន គោលនយោបាយ បច្ចេកវិទ្យា ហិរញ្ញវត្ថុ។ល។) ចំពោះការបន្សាំ។ | តើអ្វីជាឧបសគ្គក្នុងដំណើរការបន្សាំនឹងភាពរាំងស្ងួតដែលកំពុងកើនឡើង? តើមធ្យោបាយអ្វីដែលមានដើម្បីគ្រប់គ្រងហេតុការណ៍ដែលកើតមានឡើងកាន់តែញឹកញាប់? | តើអ្វីគឺជាឧបសគ្គខុសគ្នាចំពោះបុរសនិងស្ត្រីក្នុងការបន្សាំនឹងភាពរាំងស្ងួតដែលកំពុងកើនឡើង? តើភាពរាំងស្ងួតដែលកំពុងកើនឡើង នឹងធ្វើឱ្យភាពងាយរងគ្រោះរបស់បុរស និងស្ត្រីកើនឡើងដែរឬទេ? |
| | ទ្រព្យសម្បត្តិដែលមានរបស់សហគមន៍សម្រាប់ការបន្សាំ (អ្នកស្ម័គ្រ ជំនាញ ការប្តេជ្ញាចិត្ត ចំណេះដឹងអំពីសហគមន៍មូលដ្ឋាន ភាពជាអ្នកដឹកនាំសហគមន៍។ល។) | តើទ្រព្យសម្បត្តិអ្វីដែលមានដើម្បីជួយដល់ការបន្សាំនឹងការប្រែប្រួលអាកាសធាតុ? តើអ្នកណាដែលមាន (ឬត្រូវការ) លទ្ធភាពទទួលបានទ្រព្យសម្បត្តិទាំងនេះ? | តើមានស្ត្រីនិងបុរសប៉ុន្មាននាក់ដែលនឹងចូលរួមក្នុងគម្រោងដែលត្រូវបានស្នើឡើង? តើជំនាញ/ចំណេះដឹងជាក់លាក់អ្វីដែលស្ត្រីនិងបុរសមាន? តើបុរសនិងស្ត្រីមានពេលវេលាប៉ុន្មាន ដើម្បីចូលរួមចំណែកក្នុងសប្តាហ៍នីមួយៗ? តើអ្វីដែលអាចបញ្ឈប់ស្ត្រី និងបុរសមិនឱ្យលះបង់ពេលវេលាស្ម័គ្រចិត្តរបស់ពួកគេ? |
| ការបន្តដំណើរការបន្សាំ | លទ្ធភាព និងឆន្ទៈរបស់សហគមន៍ក្នុងការរក្សានិរន្តរភាពអន្តរាគមន៍គម្រោង | ផ្តល់ចំណាត់ថ្នាក់ដល់ទំនុកចិត្តរបស់អ្នកដែលថាសកម្មភាពគម្រោងនឹងបន្តទៅមុខបន្ទាប់ពីបញ្ចប់គម្រោង។ | តើភវនីយភាពនៃការបន្តសកម្មភាពគម្រោងអាចត្រូវបានធ្វើឱ្យប្រសើរឡើងតាមរយៈការដោះស្រាយតម្រូវការរបស់បុរស និងស្ត្រីដោយរបៀបណា (ទាំងតម្រូវការរួម និងតម្រូវការផ្សេងគ្នា)? |

ប្រភព៖ (UNDP ឆ្នាំ២០១០)

## សន្ទស្សន៍ភាពធន់របស់ស្ត្រី

អង្គការ ActionAid បានបង្កើតឧបករណ៍វាស់វែងភាពធន់របស់ស្ត្រី ( The Economist Intelligence Unit ឆ្នាំ២០១៤ ) ក្នុងគោលបំណងដាក់ពិន្ទុភាពធន់រំញោចយេនឌ័ររបស់សហគមន៍មូលដ្ឋាន។ ការវាស់វែងនេះ មានបួនប្រភេទ( សូមមើលខាងក្រោម )ជាមួយសំណុំសូចនាករចំនួន៣៦ដើម្បីវាយតម្លៃទិដ្ឋភាពខុសៗគ្នានៃភាពធន់របស់ក្រុមមនុស្សនៅកម្រិតសហគមន៍នៅក្នុងបរិបទតំបន់អាស៊ីខាងត្បូង។ ឧបករណ៍វាស់វែងនេះ មានកម្រងសំណួរលម្អិតមួយផ្អែកលើសូចនាករទាំងនេះ ដែលគេបែងចែកចំនួនស្ត្រី និងបុរសស្មើគ្នាសម្រាប់សូចនាករនីមួយៗ។ ទិន្នន័យប្រមូលបានពីកម្រងសំណួរទាំងនេះត្រូវបញ្ចូលទៅក្នុងផ្ទាំងសន្លឹកការងារមួយដែលបន្ទាប់អាចគណនានូវពិន្ទុសន្ទស្សន៍តាមកម្រិតមួយ។ មានជម្រើសបន្ថែមកម្រិតទៅលើពិន្ទុផងដែរ ប្រសិនបើចាំបាច់។លទ្ធផល ផ្តល់នូវពិន្ទុភាពធន់ចំនួនពីរ៖ មួយសម្រាប់ស្ត្រី និងមួយទៀតសម្រាប់បុរសដែលបន្ទាប់មកទៀតអាចឱ្យគេប្រៀបធៀបគ្នាបាន ដើម្បីបង្ហាញពីវិសមភាពណាមួយដែលកើតមាន។ ពិន្ទុភាពធន់នេះក៏ត្រូវធ្វើឡើងអមជាមួយកិច្ចពិភាក្សាក្រុមគោលដៅ និងកិច្ចសម្ភាសន៍ជាមួយជនបង្គោលដើម្បីផ្តល់ការវិភាគបែបគុណវិស័យ។ លទ្ធផល ត្រូវបង្ហាញក្នុងទម្រង់ដ្យាក្រាមរ៉ាដាដែលត្រូវបានបង្កើតឡើងដោយស្វ័យប្រវត្តិ។ ( សូមមើលខាងក្រោម )។

**រូបទី ៣៣៖ ទិដ្ឋភាពពីការបង្ហាញអន្តរកម្មដែលបង្ហាញនូវស្ថានភាពនៃភាពធន់របស់ស្ត្រីសម្រាប់ប្រទេសនៅក្នុងតំបន់អាស៊ីខាងត្បូង ដែលត្រូវបានជ្រើសរើសសម្រាប់ការសិក្សា**



### ECONOMIC

Access and control of economic resources makes it easier for people to prepare for and respond to disasters. This category considers the overall economic strength of households, the availability of personal finance and opportunities to access financial instruments. Key indicators in this category also measure people's access to, and control over, natural resources and livestock to support their livelihood options, as well as their engagement in small- and medium-sized business enterprises.



### INFRASTRUCTURE

Reliable infrastructure ensures communities can reduce the initial effects of a disaster, minimize structural damage and allow for evacuation. Thereafter, good infrastructure enables faster recovery. Key indicators in this category measure the extensiveness and reliability of infrastructure for people to access basic services (i.e. safe locations, housing, clean water and sanitation, transport, power and communications technology); and whether there is a functioning early warning system (EWS).



### SOCIAL

Human resources (e.g. people's health status and educational attainment) and social resources (e.g. being able to rely on support from household members or neighbours and belonging to community or religious groups) are critical to the resilience of people in terms of being able to prepare for, cope with and respond to disasters. Key indicators in this category also assess how people's resilience is influenced by migration patterns, the prevalence of gender-based violence and the level of personal disaster preparedness.



### INSTITUTIONAL

This category examines the extent to which people are participating in and leading decision-making processes and whether their perspectives are accounted for by public institutions. Key indicators in this category also measure how effective the government is in the implementation of disaster management plans and activities and whether people trust local government and the media to reflect and respond to their needs.

**Resilience Index** (Equal Weight)




ប្រភព៖ ក្រាបនេះមាននៅលើ http://actionforglobaljustice.actionaid.org/womens-resilience-index/index_m.html

### ការប៉ាន់ប្រម៉ាណយេនឌ័ររហ័សសម្រាប់វិបត្តិ

ខណៈដែលការវិភាគយេនឌ័រលម្អិតមួយ តែងតែងតែមានប្រសិទ្ធភាព និងគួរឱ្យចង់បាននោះ ការវិភាគនេះមិនមែនចេះតែធ្វើទៅបាននោះឡើយនៅក្នុងស្ថានភាពវិបត្តិឬគ្រាអាសន្នជាពិសេសនៅក្រោយគ្រោះមហន្តរាយ។ នៅក្នុងសេណារីយ៉ូបែបនេះ ការប៉ាន់ប្រម៉ាណយេនឌ័ររហ័សចាំបាច់ត្រូវធ្វើ និងបង្កើតឡើងក្នុងទម្រង់សង្ខេប ដើម្បីធានាបានថា ការវាស់វែងការសង្គ្រោះ និងការស្តារនីតិសម្បទាទាំងអស់ត្រូវបានយកចិត្តទុកដាក់នូវកង្វល់របស់ស្ត្រីនិងអ្នកទាំងឡាយណាជាមួយអត្តសញ្ញាណយេនឌ័រដទៃផ្សេងទៀត។

ការប៉ាន់ប្រម៉ាណយេនឌ័ររហ័សបែបនេះគួរតែបញ្ចូលនូវព័ត៌មានពីតួនាទីយេនឌ័រ និងការទទួលខុសត្រូវ សមត្ថភាព និងភាពងាយរងគ្រោះនានារួមជាមួយនឹងអនុសាសន៍នានាពីកម្មវិធី។ ព័ត៌មានទាំងនេះ បានបង្កើតយ៉ាងលឿន ដោយការប្រើនូវព័ត៌មានបឋម និងបន្ទាប់បន្សំ ដើម្បីស្វែងយល់ពីតួនាទី និងទំនាក់ទំនងយេនឌ័រ និងរបៀបនៃតួនាទីនិងទំនាក់ទំនងទាំងនេះប្រែប្រួលអំឡុងពេលវិបត្តិមួយ (Care International ឆ្នាំ២០១២)។ ឧបករណ៍ប៉ាន់ប្រម៉ាណយេនឌ័ររហ័សរបស់អង្គការ Care គូសបញ្ជាក់ពីជំហាននៃការវិភាគចំនួនប្រាំ ដោយមានគោលការណ៍គន្លឹះ ដើម្បីធានាថាតម្រូវការខុសៗគ្នានៃក្រុមយេនឌ័រនិងសង្គមទាំងអស់ត្រូវបានបំពេញ ខណៈដែលមានការធានាថា យើង «មិនបង្កឱ្យមានការឈឺចាប់» (do no harm)។ ដំណាក់កាលទាំងប្រាំ និងជំហានគន្លឹះនៅក្នុងដំណាក់កាលនីមួយៗត្រូវបានដាក់បញ្ចូលរួមគ្នានៅក្នុងក្របខ័ណ្ឌនៅទីនេះ។

**តារាងទី ៨៖ ជំហានការប៉ាន់ប្រម៉ាណយេនឌ័ររហ័ស**

| ដំណាក់កាល | ការពិពណ៌នា | សំណួរគន្លឹះ/ចង្កុលបង្ហាញ |
|---|---|---|
| ១. ស្វែងរកទិន្នន័យដែលបែងចែកតាមភេទនិងអាយុ ហើយធ្វើការវិភាគដែលមានស្រាប់ពីទំនាក់ទំនងយេនឌ័រ។ | ព័ត៌មានបញ្ចូលគ្នាដ៏ល្អទាំងព័ត៌មានបឋមនិងបន្ទាប់បន្សំ និងទិន្នន័យបែបគុណវិស័យ និងបរិមាណវិស័យពីទំនាក់ទំនងយេនឌ័រមានលក្ខណៈដូចម្ដេចនៅមុនគ្រាអាសន្ន។ព័ត៌មាននេះគួរតែទាញបញ្ចូលគ្នា ជាផ្នែកមួយនៃការរៀបចំផែនការការត្រៀមបង្ការគ្រាអាសន្នខ្លឹមសារសង្ខេបដ៏ជាក់លាក់ពីយេនឌ័រប្រចាំប្រទេសមួយ | • នៅមុនពេលមានវិបត្តិ តើចំនួនប្រជាជនជាស្ត្រី បុរស និង ក្រុម LGBTIQ មានប៉ុន្មាននាក់?<br>• តើចំនួនមនុស្សចាស់ ជនពិការ និងកុមារ មានប៉ុន្មាននាក់?<br>• តើទំហំគ្រួសារជាមធ្យមមានកម្រិតណា?<br>• នៅមុនពេលគ្រាអាសន្ន តើទំនាក់ទំនងរវាងស្ត្រី បុរស ក្មេងប្រុស និងក្មេងស្រី មានលក្ខណៈដូចម្ដេចខ្លះ?<br>• តើរចនាសម្ព័ន្ធសង្គម/វប្បធម៌អ្វីខ្លះដែលសហគមន៍ប្រើប្រាស់សម្រាប់ធ្វើសេចក្ដីសម្រេចចិត្ត?<br>• តើស្ត្រីនិងបុរសចូលរួមក្នុងរចនាសម្ព័ន្ធសង្គម/វប្បធម៌យ៉ាងដូចម្ដេច?<br>• តើសាសនា និងវប្បធម៌ ជំនឿ និងស្ថាប័ននានានៅក្នុងសហគមន៍មានតួនាទីអ្វី?<br>• តើការអនុវត្តទាំងនេះជះឥទ្ធិពលលើតួនាទីយេនឌ័រយ៉ាងដូចម្ដេច? |
| ២.ប្រមូលទិន្នន័យបន្ថែមតាមភេទ និងអាយុតាមរយៈការវាយតម្លៃយេនឌ័រ | ប្រមូលព័ត៌មានពីការពិនិត្យឡើងវិញឬការប៉ាន់ប្រម៉ាណនានាតាមវិស័យ។<br>ស្វែងរកប្រភេទកម្មវិធីតាមវិស័យអ្វីខ្លះត្រូវបានរៀបចំទុក និងពិនិត្យមើល បើសិនមានកម្មវិធីអភិវឌ្ឍន៍មុនៗអាចប្រើឬភ្ជាប់ទំនាក់ទំនងបាន។<br>ត្រួតពិនិត្យឡើងវិញនូវប្រភពអនឡាញនិងបោះពុម្ពផ្សាយ ដើម្បីស្វែងយល់ពីនិន្នាការ បើទោះបីជាវាមិនផ្ដោតលើយេនឌ័រជាក់លាក់។<br>ធ្វើការសម្ភាសន៍ជនបង្គោលនិងកិច្ចពិភាក្សាក្រុមគោលដៅដើម្បីស្វែងយល់ពីទំនាក់ទំនងយេនឌ័រដែលមានស្រាប់ហើយរបៀបវាប៉ះពាល់លើស្ត្រីនិងក្រុមមនុស្សជាមួយអត្តសញ្ញាណយេនឌ័រដទៃទៀត។<br><br>វិធីសាស្ត្រស្រាវជ្រាវឯកត្តជនអាចមានដូចជា<br>- ការស្ទាបស្ទង់មតិអនឡាញតាមរយៈបច្ចេកវិទ្យា និងកម្មវិធីបណ្ដាញសង្គមផ្សេងៗ កិច្ច | សម្រាប់ការពិភាក្សាសហគមន៍ និងភាគី ពាក់ ព័ន្ធ<br>• សូមសួររកនរណាទទួលរងផលប៉ះពាល់ដូចជាមរណភាពរងរបួស និងការភៀសខ្លួនជាដើម?<br>• តើអ្វីខ្លះជាការបាត់បង់ចំពោះជីវភាពរស់នៅទ្រព្យសម្បត្តិនិងហេដ្ឋារចនាសម្ព័ន្ធ ជាពិសេសសេវាកម្មហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋាន ដូចជាទឹក អនាម័យ និងសុខភាព?<br>• សូមសួររក តើប្រភេទវិធានការជួយសង្គ្រោះ/ឆ្លើយតបអ្វីខ្លះដែលត្រូវបានផ្ដល់ឱ្យ?ហើយនរណាទទួលបានសេវាពីវិធានការជួយសង្គ្រោះ/ឆ្លើយតបទាំងនេះ?<br><br>សម្រាប់ការស្ទាបស្ទង់មតិគ្រួសារ<br>• សូមសួររកប្រភេទសេវាជួយសង្គ្រោះ/ឆ្លើយតបដែលពួកគាត់ទទួលបាន?<br>• នរណានៅជួរមុខនៃការទទួលបានសេវា ជួយសង្គ្រោះទាំងនេះ?<br>• សូមសួររកនូវបញ្ហាសំខាន់ៗ ពួកគេជួបប្រទះ ដែលកំពុងគំរាមកំហែងដល់ការរស់រានមានជីវិតរបស់ពួកគាត់?<br>• សូមសួរទៅក្រុមមនុស្ស តើតម្រូវការនិងកង្វល់ភ្លាមៗរបស់ |

| តារាងទី ៨៖ ជំហានការប៉ាន់ប្រម៉ាណយេនឌ័ររហ័ស | | |
|---|---|---|
| **ដំណាក់កាល** | **ការពិពណ៌នា** | **សំណួរគន្លឹះ/ចង្អុលបង្ហាញ** |
| | សម្ភាសលក្ខណៈប្រដេញដោយជួបផ្ទាល់/តាមទូរស័ព្ទជាមួយអ្នកផ្តល់ព័ត៌មានសំខាន់ៗមកពីក្រុមងាយរងគ្រោះនានា។ | ពួកគេមានអ្វីខ្លះ?<br>• សូមសួរតើពួកគេត្រូវការអ្វីដើម្បីបន្តជាមួយជីវិតរស់នៅរបស់ពួកគេ?<br>• សូមសាកសួរពីតួនាទីយេនឌ័រលក្ខណៈប្រពៃណីហើយថាតើតួនាទីយេនឌ័រលក្ខណៈប្រពៃណីទទួលផលប៉ះពាល់ដោយសារតែវិបត្តិយ៉ាងដូចម្តេច? សូមសាកសួរថា តើបន្ទុកការងារមានការកើនឡើង ឬមានការបែងចែកគ្នាឬទេ?<br>• សូមសាកសួរពីទំនាក់ទំនងយេនឌ័រ និងមានអ្វីខ្លះប្រែប្រួលចាប់តាំងពីពេលមានវិបិត្ត?<br><br>សូមសួរព័ត៌មានស្ត្រីដោយដាច់ដោយឡែកពីបុរសនិងក្មេងស្រីដោយឡែកពីក្មេងប្រុស។ សូមសួរឱ្យឆ្ងាយតាមដែលអាចធ្វើបាន គ្រប់ព័ត៌មានបន្ថែមទាំងអស់គួរតែបញ្ចូលនូវទិន្នន័យបែងចែកតាមភេទ អាយុ និងពិការភាព (SADDD)។ |
| ៣.ការវិភាគទិន្នន័យបែងចែកតាមភេទអាយុនិងពិការភាពដោយការប្រៀបធៀបព័ត៌មានដែលមានស្រាប់ជាមួយនឹងលទ្ធផលនៃការប៉ាន់ប្រម៉ាណយេនឌ័រ | ការវិភាគយេនឌ័រនៅក្នុងគ្រាអាសន្នត្រួតពិនិត្យពីផលប៉ះពាល់នៃវិបិត្តលើស្ត្រី បុរស ក្មេងស្រី និងក្មេងប្រុស។ វាប្រៀបធៀបពីរបៀបបញ្ហាយេនឌ័រដែលត្រូវផ្តល់អាទិភាពចំពោះវិបត្តិជាមួយបញ្ហាយេនឌ័រផ្លាស់ប្តូរដូចម្តេចចាប់តាំងពីវិបត្តិបានចាប់ផ្តើម ឬកម្មវិធីបានចាប់ផ្តើម។ | • សូមរាយនូវសមត្ថភាព តម្រូវការ និងចំណូលចិត្តប្លែកៗរបស់ស្ត្រី បុរស ក្មេងស្រី និងក្មេងប្រុស។ តើពួកវានៅដដែលចាប់តាំងពីមុនវិបត្តិ ឬពួកវាបានប្រែប្រួល?<br>• សូមសរសេរតួនាទី និងការទទួលខុសត្រូវរបស់ស្ត្រី បុរស ក្មេងស្រី និងក្មេងប្រុស។ តើការបែងចែកបន្ទុកការងារស្មើគ្នាឬទេ? តើការបែងចែកនេះជះឥទ្ធិពលលើសិទ្ធិរបស់ពួកគាត់សម្រាប់ការលូតលាស់ និងឱកាសយ៉ាងដូចម្តេច? នរណាធ្វើសេចក្តីសម្រេចចិត្តលើការប្រើប្រាស់ធនធាន? ហើយតើពួកគេទទួលបានតម្រូវការប្រកបដោយសមធម៌ដែរឬទេ?<br>• សូមរាយនូវឌីណាមិករវាងស្ត្រី បុរស ក្មេងស្រី និងក្មេងប្រុស។ តើស្ត្រី និងបុរសជួយ និងរាំងគ្នាទៅវិញទៅមកដើម្បីបំពេញតម្រូវការ និងសិទ្ធិរបស់ពួកគាត់យ៉ាងដូចម្តេច? នរណាប្រព្រឹត្តអំពើហិង្សាលើនរណា? តើអំពើហិង្សាប្រភេទណាខ្លះកើតឡើង? តើសហគមន៍និងស្ថាប័ននានាដើរតួនាទីអ្វីខ្លះក្នុងការបំពេញនូវតម្រូវការ និងសិទ្ធិ ក៏ដូចជាការដោះស្រាយ នឹងការទប់ស្កាត់អំពើហិង្សា?<br>• តើស្ត្រីដែលងាយរងគ្រោះនិងក្រុមមនុស្សដែលជួបការលំបាកកំពុងប្រឈមនឹងបញ្ហាអ្វីខ្លះដោយសារគ្រោះមហន្តរាយ? តើផលប៉ះពាល់អ្វីខ្លះ ដែលគ្រោះមហន្តរាយមានលើជីវភាពរស់នៅជាប្រចាំរបស់ពួកគាត់ រួមមានអំពើហិង្សាទាក់ទងនិងយេនឌ័រ (GBV) កិច្ចការពារ សិទ្ធិសុខភាពផ្លូវភេទ និងសុខភាពបន្តពូជ (SRHR) ទឹក អនាម័យបរិស្ថាន និងអនាម័យខ្លួនប្រាណ(WASH)មជ្ឈមណ្ឌលទីជម្រកនិងការទទួលបានការជួយសង្គ្រោះ/ឆ្លើយតបផ្សេងៗ។ |
| ៤. សរសេរនូវអនុសាសន៍ដែលអាចអនុវត្តបានសម្រាប់សកម្មភាពមនុស្សធម៌ផ្អែកលើការវិភាគ | ផ្នែកសំខាន់មួយនៃ RGA គឺជាអនុសាសន៍របស់កម្មវិធីនិងអង្គការដែលបានមកពីការវិភាគមួយនៃទិន្នន័យដែលប្រមូលបាន។ ការផ្តល់នូវអនុសាសន៍ច្បាស់លាស់ ដើម្បីធ្វើឱ្យប្រសើរឡើង ឬដោះស្រាយបញ្ហា ឬគម្លាតមួយចំនួន ដែលត្រូវបានកំណត់នៅក្នុងការវិភាគនៃតម្រូវការសមត្ថភាព | • តើគ្រាអាសន្នប៉ះពាល់លើសហគមន៍យ៉ាងដូចម្តេច? តើស្ត្រី បុរស ក្មេងប្រុស និងក្មេងស្រីទទួលរងផលប៉ះពាល់ខុសៗគ្នាឬទេ?<br>• តើកម្មវិធីគួរតែកែសម្រួលយ៉ាងដូចម្តេចដើម្បីបំពេញតម្រូវការខុសៗគ្នារបស់ស្ត្រី បុរស ក្មេងប្រុស និងក្មេងស្រី?<br>• តើកម្មវិធីគោលដៅអ្វីខ្លះ ដែលត្រូវការដើម្បីធានាថាស្ត្រី បុរស |

**តារាងទី ៨៖ ជំហានការប៉ាន់ប្រមាណយេនឌ័ររហ័ស**

| ដំណាក់កាល | ការពិពណ៌នា | សំណួរគន្លឹះ/ចន្លុលបង្ហាញ |
|---|---|---|
| | និងការចូលរួមចំណែកខុសៗគ្នារបស់ស្ត្រី បុរស ក្មេងប្រុសនិងក្មេងស្រី។សូមចាំថាគោលបំណងនៃការប្រមូលព័ត៌មាននេះ គឺដើម្បីធ្វើឱ្យប្រសើរឡើងនូវការប្រឹងប្រែងឆ្លើយតបរបស់អ្នក (និងដៃគូរបស់អ្នកដែលមានឥទ្ធិពលផងដែរ)។ ធានាបានថា អនុសាសន៍ គឺអនុវត្តន៍បាន និងទទួលយកបានយ៉ាងងាយស្រួលដោយមិត្តរួមការងារដែលមិនមែនជាអ្នកជំនាញយេនឌ័រ។ | ក្មេងប្រុសនិងក្មេងស្រីសុទ្ធតែទទួលបានជំនួយនិងអាចបំពេញតម្រូវការរបស់ពួកគេបាន?<br>• តើគ្រាអាសន្នបង្កឱ្យមានហានិភ័យជាក់លាក់អ្វីខ្លះ?<br>• អំឡុងពេលបំពេញការងារជួយសង្គ្រោះនិងស្តារនីតិសម្បទាឡើងវិញ តើសូចនាករសំខាន់អ្វីខ្លះត្រូវការត្រួតពិនិត្យ?<br>• នរណាគួរតែដឹកនាំផែនការ M&E និងគួរតែធ្វើវាតាមរបៀបណា?<br>• តើព័ត៌មានបន្ថែមអ្វីខ្លះ ដែលអ្នកត្រូវការដើម្បីបន្តការវិភាគយេនឌ័ររហ័សរបស់អ្នក?<br>• អនុសាសន៍ចាំបាច់ត្រូវផ្តោតលើភាពងាយរងគ្រោះជាក់លាក់របស់យេនឌ័រដែលកើតឡើងពីគ្រោះមហន្តរាយ។ |
| ៥.ចែករំលែកការវិភាគយេនឌ័ររហ័សជាមួយតួអង្គដទៃទៀត | បន្ទាប់ពីការប្រមូលទិន្នន័យ ព័ត៌មាននេះអាចបង្ហាញដោយការប្រើគំរូ RGA | |

## ការសិក្សាកំណត់វិសាលភាពតាមវិស័យ

ការសិក្សាកំណត់វិសាលភាពគឺជាវិស័យផ្នែកធម្មជាតិនិងជួយបង្កើតចំណេះដឹងនិងការយល់ដឹងលើផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុនៅក្នុងវិស័យ ឬផ្នែកនៃក្តីកង្វល់ជាក់លាក់មួយ។ ការសិក្សានេះ គឺជាចំណុចចាប់ផ្តើមដ៏ល្អមួយសម្រាប់ការស្វែងយល់ពីតួនាទី ការទទួលខុសត្រូវ និងទំនាក់ទំនងយេនឌ័រនៅក្នុងវិស័យ ហើយទាំងអស់នេះរងផលប៉ះពាល់ដោយការប្រែប្រួលអាកាសធាតុដូចម្តេច។ ការសិក្សានេះ មានជាប់ពាក់ព័ន្ធនឹងការបង្កើតការស្រាវជ្រាវដោយវិធីសាស្ត្រចម្រុះ ដែលប្រើទាំងវិធីសាស្ត្របែបបរិមាណវិស័យ និងគុណវិស័យ តាមរយៈការប្រើទិន្នន័យបឋម និងបន្ទាប់បន្សំ។ តារាងបន្ទាប់ដាក់បញ្ចូលរួមគ្នានូវជំហាន និងវិធីសាស្ត្រផ្សេងៗ ដែលត្រូវបានគេប្រើក្នុងការសិក្សាកំណត់វិសាលភាពតាមវិស័យនិងរបៀបដាក់បញ្ចូលយេនឌ័ររួមគ្នាតែមួយ។

**តារាងទី ៩៖ ជំហាន និងវិធីសាស្ត្រផ្សេងៗដែលប្រើនៅក្នុងការសិក្សាកំណត់វិសាលភាពតាមវិស័យ និងសមាហរណកម្មយេនឌ័រនៅក្នុងការសិក្សា**

| ជំហាន/ វិធីសាស្ត្រដែលប្រើ | សមាសភាពស្នូល | សមាហរណកម្មយេនឌ័រ |
|---|---|---|
| ការជ្រើសរើសប្រធានបទសិក្សា | ប្រធានបទការសិក្សា គឺតែងតែត្រូវសម្រួចដើម្បីផ្តោតលើទិដ្ឋភាពជាក់លាក់នៅក្នុងវិស័យដែលត្រូវស្រាវជ្រាវបន្ថែម។ | • វាមានសារសំខាន់ដើម្បីធ្វើការសិក្សាលើផ្នែកនៅក្នុងវិស័យដែលមានជាប់ពាក់ព័ន្ធផ្ទាល់នឹងស្ត្រី។ ឧទាហរណ៍ - សន្តិសុខស្បៀងនៅក្នុងវិស័យកសិកម្មអនុផលព្រៃឈើ (NTFP) ក្នុងវិស័យព្រៃឈើ សិទ្ធិសុខភាពផ្លូវភេទនិងសុខភាពបន្តពូជ (SRHR) និងអំពើហិង្សាលើយេនឌ័រនៅក្នុងវិស័យសុខាភិបាល។ |
| វិធីសាស្ត្របែបបរិមាណវិស័យ | ភាគច្រើនតាមរយៈកម្រងសំណួរធ្វើនៅកម្រិតគ្រួសារ | • ការយកគ្រួសារជាឯកតាសម្រាប់ការប្រមូលទិន្នន័យមិនរំលេចចេញនូវភាពខុសគ្នានៅក្នុងអន្តរគ្រួសារទេ។ វាមានសារៈសំខាន់ទាំងការរក្សានូវតុល្យភាពយេនឌ័រ ក្នុងចំណោមអ្នកឆ្លើយតបបឋមនៅក្នុងគ្រួសារនីមួយៗនិង/ឬក៏មានផ្នែកដោយឡែកមួយសម្រាប់ចាប់យកទស្សនៈរបស់ស្ត្រីក្នុងកម្រងសំណួរ។<br>• កម្រងសំណួរ ក៏ត្រូវបានគេបង្កើតឡើងផងដែរ ដោយរក្សាទុកសំណួរដែលជាប់ទាក់ទងនឹងតួនាទី និងការទទួលខុសត្រូវ និងទំនាក់ទំនងយេនឌ័រនៅក្នុងវិស័យផងដែរ។ |
| វិធីសាស្ត្របែបគុណវិស័យ | តែងតែត្រូវបានប្រើប្រាស់នៅពេលលទ្ធផលដែលចង់បាន មិនស្រួលបង្រួមទៅតាមបច្ចេកទេសការវាស់វែងស្តង់ដារ ឬ ការវិភាគបែបបរិមាណវិស័យ។ ដូច្នេះ ព័ត៌មានដែលប្រមូលបានគឺភាគច្រើនតាមរយៈការសម្ភាសន៍ជនបង្គោល និង កិច្ចពិភាក្សាក្រុមបង្គោល។ | • នៅពេលផ្តោតលើទំនាក់ទំនងយេនឌ័រ ជាញឹកញាប់ អ្នកស្រាវជ្រាវជ្រាវចង់គ្របដណ្តប់លើអន្តរទំនាក់ទំនងទាំងអស់រវាងសុខមាលភាពស្ថានភាពការផ្តល់ភាពអង់អាចនិងច្បាប់សង្គមនានាដែលពិបាកចាប់យកតាមរយៈការប្រើនូវការស្ទាបស្ទង់មតិរួម។ ឧទាហរណ៍ ទស្សនៈនៃ "ការគ្រប់គ្រង" ដីមួយកន្លែងជាមួយការអនុវត្តកសិកម្មជាក់លាក់មួយអាចបញ្ជាក់នូវទស្សនៈផ្សេងច្រើនជាង "ការកាន់កាប់" ដីមួយកន្លែងនោះ។ ដើម្បីទទួលបានជោគជ័យការសិក្សាបែបគុណវិស័យនេះគឺត្រូវធ្វើឡើងដែលអនុញ្ញាតឱ្យអ្នកឆ្លើយតបបង្ហាញនូវគំនិតផ្សេងៗរបស់ពួកគេដោយសេរី ដោយគ្មានការរំខានដែលបណ្តាលមកពីកម្រងសំណួរដែលបានកំណត់ចម្លើយទុកជាមុនឡើយ។<br>• ដូច្នេះ វាមានសារសំខាន់ ដើម្បីកំណត់នូវអ្នកជំនាញយេនឌ័រក្នុងវិស័យ/ផ្នែក ដូចជាជនបង្គោល ដើម្បីស្វែងយល់ទំនាក់ទំនងយេនឌ័រផ្សេងៗ និងបរិបទមូលដ្ឋាន។ |
| វិធីសាស្ត្រដែលមានការចូលរួម | ការប្រើឧបករណ៍ និងលំហាត់នានាជាមួយក្រុមតូចៗក្នុងសហគមន៍ដើម្បីប្រមូលព័ត៌មានដែលមានទស្សនៈប្រកបដោយការវិភាគកាន់តែច្រើន | • ការប្រើវិធីសាស្ត្រដែលមានការចូលរួមបែងចែកតាមយេនឌ័របញ្ជាក់ពីការពាក់ព័ន្ធស្ត្រីក្នុងការកំណត់នូវឧបសគ្គ និងបញ្ហាដែលពួកគេជួបប្រទះ។<br>• វាមានសារៈសំខាន់ ដើម្បីអនុវត្តនូវលំហាត់ទាំងអស់ដាច់ដោយឡែករវាងក្រុមបុរស និងក្រុមស្ត្រី។ ក្រុមស្ត្រីក៏គួរតែមិនមានលក្ខណៈដូចគ្នាពេក ប៉ុន្តែការចូលរួមដ៏មានអត្ថន័យរបស់ស្ត្រីមកពីគ្រប់លក្ខណៈនៃក្រុមអាយុ កម្រិតការអប់រំ សញ្ជាតិ និងជនជាតិ មុខរបរ និងពិការភាពទាំងអស់គួរតែរាប់បញ្ចូល។<br>• វាក៏មានសារៈសំខាន់ដែរ ដើម្បីពិចារណាលើការប្រើប្រាស់ពេលវេលា និងទីតាំងនៃកន្លែងប្រជុំ។ ឧទាហរណ៍ការរៀបចំកិច្ចប្រជុំនៅពេលស្ត្រីភាគច្រើនជាប់រវល់ជាមួយការងារផ្ទះសម្បែង ឬនៅទីវាលនឹងធ្វើឱ្យបាត់ពួកគាត់។ ស្រដៀងគ្នានេះដែរ ការរៀបចំប្រជុំនៅទីកន្លែងគោរពប្រតិបត្តិជំនឿសាសនាអាចធ្វើឱ្យជនជាតិភាគតិច និង/ឬ ស្ត្រី ត្រូវបានផាត់ចេញពីការចូលរួម។ |
| ការបង្ហាញទិន្នន័យ | ទិន្នន័យភាគច្រើនត្រូវបានបង្ហាញនៅកម្រិតគណនា | • មានវិធីជាច្រើនក្នុងការបង្ហាញទិន្នន័យជាមួយនឹងទំនាក់ទំនងគោលនយោបាយនៅកម្រិតគ្រួសារ/បុគ្គលដោយគិតគូរពីយេនឌ័រ។ ក្នុងចំណោមនោះ ប្រភេទវិធីដែលអាចប្រើបាន ទិន្នន័យដែលអាចបែងចែកតាម (1) ស្ត្រី ឬ គ្រួសារដែលមានស្ត្រីជាមេគ្រួសារ (២) បុរស ឬ គ្រួសារដែលបុរសជាមេគ្រួសារ និង (៣) ប្តីប្រពន្ធក្នុងគ្រួសារ |

### ការប៉ាន់ប្រម៉ាណមិនមានអ្នកណាម្នាក់ត្រូវបានទុកចោល (LNOB)

ការអនុវត្ត LNOB ( UNSDG ឆ្នាំ២០១៩ ) បង្ហាញពីវិធីសាស្ត្រមួយ ជាមួយសំណុំនៃជំហានចំនួនប្រាំសម្រាប់វិភាគ LNOB សកម្មភាព ការតាមដាន គណនេយ្យភាព និងការចូលរួមដ៏មានអត្ថន័យ ដែលអាចដំណើរការបាននៅក្នុងបរិបទប្រព័ន្ធអង្គការសហប្រជាជាតិ។ ទោះបីជាយ៉ាងណា ប្រើជាមួយទស្សនៈយេនឌ័រ វាអាចជាឧបករណ៍ដ៏មានសារៈប្រយោជន៍សម្រាប់អង្គការស្ត្រី ដើម្បីធានាថានៅក្នុងផ្នែកនិងសហគមន៍ដែលងាយរងគ្រោះបំផុត ស្ត្រីត្រូវបានរាប់បញ្ចូល។ ជំហានគន្លឹះនៃវិធីសាស្ត្រ LNOB មាន៖

**ជំហានទី ១៖ នរណាត្រូវបានទុកចោល? ការប្រមូលភស្តុតាង**

- រកឱ្យឃើញថា នរណាត្រូវបានគេទុកចោល និងត្រូវបានទុកចោលដោយរបៀបណាហើយក្នុងចំណោមពួកគេតើនរណាទំនងជាក្រុមមនុស្សដែលត្រូវបានគេទុកចោលច្រើនជាងគេ។
- ចុងបញ្ចប់ ស្ថាប័នគួរតែប្រមូល និងវិភាគគ្រប់ទិន្នន័យ និងព័ត៌មានទាំងអស់ដោយបង្ហាញឱ្យឃើញនូវគម្លាតនិងនិន្នាការនៅក្នុងការអនុវត្តរវាងក្រុមប្រជាសាស្ត្រនិង/ឬតំបន់ភូមិសាស្ត្រ។
- ស្វែងរកមតិកែលម្អផ្សេងៗ និងធាតុចូលពីភាគីពាក់ព័ន្ធរួមមានក្រុមមនុស្ស និងប្រជាជនដែលត្រូវបានទុកចោល។

**ជំហានទី ២៖ ហេតុអ្វី? ការចាត់អាទិភាព និងការវិភាគ**

- ធ្វើការវិភាគឬសគល់មូលហេតុ ដើម្បីអាចឆ្លើយតបទៅនឹងឬសគល់ និងការកំណត់មូលហេតុនៃវិសមភាព រួមមានវិសមភាពយេនឌ័រ ភាពងាយរងគ្រោះ ភាពខូចខាត ការរើសអើង ការផ្លាស់ទីកន្លែង និងការផាត់ចេញ ។
- ធ្វើការវិភាគតំរូតួនាទីដើម្បីបង្កើតផែនទីនរណាជាអ្នកទទួលបន្ទុកកិច្ចការ-នរណាទទួលខុសត្រូវសម្រាប់ការចាត់វិធានការ។
- ធ្វើការវិភាគគម្លាតសមត្ថភាពមួយ ដើម្បីស្វែងយល់ពីគម្លាតដែលរារាំងអ្នកទទួលបន្ទុកកិច្ចការពីការបំពេញភារកិច្ចរបស់ពួកគេអ្វីដែលរារាំងអ្នកមានសិទ្ធិមិនឱ្យទាមទារសិទ្ធិរបស់ពួកគេអ្វីដែលជាតម្រូវសម្រាប់ឱ្យក្រុមមនុស្សទាំងពីរចាត់វិធានការ។

**ជំហានទី ៣៖ ជាអ្វី? អ្វីដែលគេគួរធ្វើ**

- ការកំណត់អ្វីគេគួរធ្វើ និងដោយនរណា។
- ការកំណត់សកម្មភាព និងការអន្តរាគមន៍នានា ដើម្បីដោះស្រាយបញ្ហាប្រឈម ឧបសគ្គ និងគម្លាតសមត្ថភាពនានា។ ផ្នែកដែលអាចរាប់បញ្ចូលរួមមាន៖ ការតស៊ូមតិ បរិស្ថានអំណោយផល ការអភិវឌ្ឍសមត្ថភាព និងការគាំទ្រពីសង្គមស៊ីវិល ការផ្តល់អំណាចដល់សហគមន៍ គុណភាព និងការទទួលបានសេវានានា ភាពជាដៃគូរួមបញ្ចូលសង្គមស៊ីវិល។
- ចាត់អាទិភាពសកម្មភាពដោយចងចាំនូវការប្តេជ្ញាចិត្តចំពោះដំណោះស្រាយជាដំបូងគេដល់ក្រុមមនុស្សដែលត្រូវបានគេទុកចោលឱ្យនៅឆ្ងាយពីគេ។

**ជំហានទី ៤៖ របៀបណា? តើវឌ្ឍនៈភាពការតាមដាន និងត្រួតពិនិត្យធ្វើតាមរបៀបណា**

- ជួយកំណត់ឱ្យបាន និងរៀបចំនូវសូចនាករ និងគោលដៅ LNOB ឱ្យទៅជាទស្សនៈ។
- យកមកប្រើនូវវិធីប្រកបដោយការច្នៃប្រឌិតសម្រាប់តាមដានការបង្កើតទស្សនីយភាព និងការចែករំលែកព័ត៌មាន។

**ជំហានទី ៥៖ ការជំរុញគណនេយ្យភាពសម្រាប់ LNOB**

- គាំទ្រគណនេយ្យភាពថ្នាក់ជាតិដល់ក្រុមមនុស្សដែលត្រូវបានទុកចោលដោយការតស៊ូមតិសម្រាប់ទិន្នន័យបែងចែកដែលត្រូវបានប្រមូល និងរាយការណ៍នៅក្នុងទំនាក់ទំនងជាតិទាំងអស់ទាក់ទងនឹងការប្រែប្រួលអាកាសធាតុ សិទ្ធិមនុស្ស សមភាពយេនឌ័រ និងលើ SDGs។

### ការរៀបចំផែនការដែលឆ្លើយតបយេនឌ័រ ការរៀបចំ និងបង្កើតគម្រោង

វាមានសារៈសំខាន់ ដើម្បីធានាថាលទ្ធផលនានានៃការវិភាគយេនឌ័រអាចមាននៅក្នុងផែនការអនុវត្តគម្រោង។ ដំណើរការរៀបចំគម្រោងគួរតែធ្វើតាមវិធីមួយដោះស្រាយមួយដែលបានរកឱ្យឃើញបញ្ហាតាមរយៈការបង្កើតគោលដៅ និងគោលបំណងគម្រោង លទ្ធផល សកម្មភាព និងកញ្ចប់ថវិកា។ ដើម្បីធានាថាមានលក្ខណៈយេនឌ័រ គេត្រូវចោទសួរសំណួរខាងក្រោមនេះ (UNDP ឆ្នាំ២០១០)៖

- អ្វីជាស្ថានភាពរបស់បុរសនិងស្ត្រីនាពេលបច្ចុប្បន្ននៅក្នុងវិស័យនៃកិច្ចអន្តរាគមន៍ដែលបានគ្រោងទុករបស់អ្នក?
- តើគម្រោងដែលបានស្នើឡើងហ្នឹង នឹងចូលរួមចំណែកដល់វិសមភាពដែលមានស្រាប់ក្នុងចំណោមបុរសនិងស្ត្រីឬទេ?
- តើគម្រោងដែលបានស្នើឡើង បានលម្អិត ឬលើកឡើងពីវិសមភាពដែលមានស្រាប់ក្នុងចំណោមបុរស និងស្ត្រីឬទេ?
- តើគម្រោងដែលបានស្នើឡើងហ្នឹង នឹងផ្លាស់ប្តូរទស្សនៈ ឬផ្នត់គំនិតសង្គមអំពីបុរស និងស្ត្រី និងតួនាទីរបស់ពួកគេតាមវិធីណាមួយឬទេ?
- តើជម្រើសមួយណាគួរតែត្រូវបានយកចិត្តទុកដាក់ដើម្បីពង្រឹងទស្សនៈយេនឌ័រ?
- តើគម្រោងដែលបានស្នើឡើងហ្នឹង នឹងចូលរួមចំណែកដល់ការផ្តល់ភាពអង់អាចដល់ស្ត្រីឬទេ? បើមិនចូលរួមទេតើមានកន្លែងណាមួយសម្រាប់កិច្ចអន្តរាគមន៍ចូលរួមចំណែកដល់ការផ្តល់ភាពអង់អាចឬទេដូច្នេះមិនមានភាពខុសគ្នាខ្លាំងរវាងបុរស និងស្ត្រី?

ឧបករណ៍វិភាគយេនឌ័រជាក់លាក់ចំនួនពីរដែលអាចជួយក្នុងការបញ្ជាក់ឱ្យកាន់តែច្បាស់ពីចំណុចខាងលើគឺៈ ក) មាត្រដ្ឋានវាយតម្លៃដែលឆ្លើយតបទៅនឹងតម្រូវការយេនឌ័រ និង ខ) ក្របខ័ណ្ឌមូលហេតុ បញ្ហាប្រឈម និងដំណោះស្រាយ

ការបង្កើតគម្រោង គឺជាដំណើរការយ៉ាងជាក់លាក់នៃបរិបទមួយទោះបីយ៉ាងណាបណ្តុំសកម្មភាពមួយចំនួនអាចចាត់ទុកថាជាផ្នែកសំខាន់នៃការបង្កើតគម្រោងទាំងអស់នេះ (Aguilar et al ឆ្នាំ២០១៥)។ សកម្មភាពទាំងនេះរួមមានៈ

> ផ្តល់នូវការទទួលបាន និងការគ្រប់គ្រងលើធនធាន និងព័ត៌មានស្មើគ្នា ដូចជាវគ្គបណ្តុះបណ្តាលសមស្របទៅនឹងយេនឌ័រ និងអាយុ និងសម្ភារៈទំនាក់ទំនង។
> ផ្តល់នូវសំឡេង និងតំណាងក្នុងការធ្វើសេចក្តីសម្រេចចិត្តស្មើគ្នា ដូចជាកូតាសម្រាប់ស្ត្រីនៅក្នុងក្រុមគ្រប់គ្រងធនធានសហគមន៍។
> កាត់បន្ថយបន្ទុកការងាររបស់ស្ត្រី ដូចជាការណែនាំឱ្យស្គាល់បច្ចេកវិទ្យា និងឧបករណ៍ជួយសន្សំកម្លាំងពលកម្ម។ និងចូលរួមនៅកម្រិតគោលនយោបាយដូចជាការពិនិត្យឡើងវិញ
> នូវគោលនយោបាយតាមវិស័យដែលមានស្រាប់ដើម្បីកំណត់ចំណុចចាប់ផ្តើមសម្រាប់ការផ្តល់ភាពអង់អាចដល់ស្ត្រី។

**មាត្រដ្ឋានការប៉ាន់ប្រម៉ាណដែលឆ្លើយតបទៅនឹងតម្រូវការយេនឌ័រ (GRAS)**

កម្មវិធី GRAS របស់អង្គការ WHO ឬ មាត្រដ្ឋានការប៉ាន់ប្រម៉ាណដែលឆ្លើយតបទៅនឹងតម្រូវការយេនឌ័រ (WHO ឆ្នាំ២០១១) ផ្តល់នូវលក្ខណៈវិនិច្ឆ័យសម្រាប់កម្រិតប៉ាន់ប្រម៉ាណការឆ្លើយតបទៅនឹងតម្រូវការយេនឌ័រ។ដោយផ្អែកទៅលើទស្សនៈរបស់Kabeerទាក់ទងនឹងគោលនយោបាយ និងកម្មវិធីភាពដែលមានទស្សនៈរំញោចយេនឌ័រ មាត្រដ្ឋានបែងចែកគោលនយោបាយ និងកម្មវិធីជាប្រាំកម្រិតផ្សេងគ្នា រាប់ចាប់ពីដែលមានទស្សនៈមិនស្មើភាពផ្នែកយេនឌ័រ រហូតដល់ដែលមានទស្សនៈផ្លាស់ប្តូរយេនឌ័រ។ (សូមមើលរូបទី ១៧)

**រូបទី ៣៤ៈ មាត្រដ្ឋានប៉ាន់ប្រម៉ាណដែលឆ្លើយតបទៅនឹងតម្រូវការយេនឌ័រ**

| | |
|---|---|
| **កម្រិតទី១ៈ ភាពមិនស្មើភាពនៃយេនឌ័រ** | • បន្តរក្សាវិសមភាពយេនឌ័រតាមរយៈការពង្រឹងបទដ្ឋាន តួនាទី និងទំនាក់ទំនងនានាដែលអតុល្យភាព<br>• ផ្តល់បុព្វសិទ្ធិដល់បុរសលើស្ត្រី (ឬផ្ទុយមកវិញ)<br>• ជាញឹកញាប់ នាំឱ្យក្រុមភេទមួយទទួលបានសិទ្ធិ ឬឱកាសច្រើនជាងក្រុមភេទមួយទៀត |
| **កម្រិតទី២ៈ មិនមានទស្សនៈយេនឌ័រ** | • មិនអើពើបទដ្ឋាន តួនាទី និងទំនាក់ទំនងយេនឌ័រ<br>• ជាញឹកញាប់ ពង្រឹងការរើសអើងដោយផ្អែកលើយេនឌ័រ<br>• មិនអើពើភាពខុសគ្នានៅក្នុងការបែងចែកឱកាស និងធនធានសម្រាប់ស្ត្រី និងបុរស<br>• ជាញឹកញាប់ កសាងឡើងដោយផ្អែកលើគោលការណ៍នៃ«ភាពស្មើគ្នា»តាមរយៈការប្រព្រឹត្តទៅលើមនុស្សគ្រប់រូបដូចៗគ្នា |
| **កម្រិតទី៣ៈ មានទស្សនៈ/រំញោចយេនឌ័រ** | • ពិចារណាលើបទដ្ឋានយេនឌ័រ តួនាទី និងទំនាក់ទំនង<br>• មិនដោះស្រាយវិសមភាពបង្កើតដោយបទដ្ឋានមិនស្មើគ្នា តួនាទី ឬទំនាក់ទំនងនានា<br>• បង្ហាញនូវការយល់ដឹងពីយេនឌ័រទោះបីជាញឹកញាប់មិនមានសកម្មភាពដោះស្រាយត្រូវបានបង្កើតឡើង |
| **កម្រិតទី៤ៈ មានទស្សនៈយេនឌ័រជាក់លាក់** | • ពិចារណាលើបទដ្ឋានសង្គម តួនាទី និងទំនាក់ទំនងសម្រាប់ស្ត្រី និងបុរស និងរបៀបដែលពួកវាប៉ះពាល់លើការទទួលបាន និងការគ្រប់គ្រងលើធនធាន<br>• ពិចារណាលើតម្រូវការជាក់លាក់របស់ស្ត្រី និងបុរស<br>• កំណត់គោលដៅ និងផ្តល់ប្រយោជន៍ជាក់លាក់លើក្រុមស្ត្រី និងបុរស ដើម្បីសម្រេចគោលដៅគោលនយោបាយ និងកម្មវិធីពិតប្រាកដ ឬ បំពេញតម្រូវការពិតប្រាកដ<br>• ធ្វើឱ្យមានភាពងាយស្រួលដល់ស្ត្រី និងបុរស ដើម្បីបំពេញតួនាទីដែលត្រូវបានកំណត់ឱ្យពួកគាត់ផ្អែកលើតួនាទីយេនឌ័រ |
| **កម្រិត៥ៈ មានទស្សនៈផ្លាស់ប្តូរផ្នត់គំនិតយេនឌ័រ** | • ពិចារណាលើបទដ្ឋានយេនឌ័រ តួនាទី និងទំនាក់ទំនង សម្រាប់ស្ត្រី និងបុរស ដែលកត្តាទាំងនេះប៉ះពាល់លើការទទួលបាន និងការគ្រប់គ្រងលើធនធាន<br>• ពិចារណាលើតម្រូវការជាក់លាក់របស់ស្ត្រី និងបុរស<br>• ដោះស្រាយមូលហេតុនៃវិសមភាពសុខភាពទាក់ទងនឹងយេនឌ័រ<br>• រួមបញ្ចូលវិធីផ្លាស់ប្តូរលើបទដ្ឋានយេនឌ័រតួនាទីនិងទំនាក់ទំនងរបស់យេនឌ័រប្រកបដោយគ្រោះថ្នាក់<br>• គោលបំណង គឺដើម្បីលើកកម្ពស់សមភាពយេនឌ័រ<br>• បញ្ចូលយុទ្ធសាស្ត្រដើម្បីជំរុញការផ្លាស់ប្តូរជាបន្តបន្ទាប់ក្នុងទំនាក់ទំនងអំណាចរវាងស្ត្រី និងបុរស |

ប្រភពៈ (WHO ឆ្នាំ២០១១)

ដោយត្រូវបានប្រើជាឧបករណ៍បំពេញបន្ថែមមួយទៅដល់ឧបករណ៍វិភាគយេនឌ័រ មាត្រដ្ឋាននេះ ជួយបង្កើតគម្រោងដែលឆ្លើយតបទៅនឹងតម្រូវការយេនឌ័រ។ ឧទាហរណ៍ កម្មវិធីគ្រប់គ្រងពោតរបេង បានអនុម័តទទួលយកយុទ្ធសាស្ត្រស្វែងរកករណីដ៏សកម្ម ជំនួសឱ្យយុទ្ធសាស្ត្រស្វែងរកករណីអកម្ម ពេលណាការវិភាគយេនឌ័របង្ហាញថា ដោយសារតែកង្វះពេលវេលា និងថវិកាសមាមាត្រនៃចំនួនស្ត្រីទៅមណ្ឌលសុខភាពមានកម្រិតទាបមិនគួរឱ្យប្រៀបធៀបបាន។ នេះជាឧទាហរណ៍មួយដែលផ្លាស់ពីកម្មវិធីដែលមិនមានទស្សនៈយេនឌ័រទៅរកកម្មវិធីដែលមានទស្សនៈយេនឌ័រជាក់លាក់ ឬ «ការបញ្ច្រាបដែលមានទស្សនៈយេនឌ័រ» ក្នុងកម្មវិធីការគ្រប់គ្រងពោតរបេង។ ដូច្នេះ ខណៈដែលការវិភាគយេនឌ័រគូសបញ្ជាក់កត្តាសំខាន់ៗជំហាននានាអាចត្រូវបានគេប្រកាន់យកដើម្បីដោះស្រាយបញ្ហាទាំងនេះនៅក្នុងគោលនយោបាយ និងកម្មវិធីពាក់ព័ន្ធ។

## ក្របខ័ណ្ឌបុព្វហេតុ ផលវិបាក និងដំណោះស្រាយ

ក្របខ័ណ្ឌបុព្វហេតុ ផលវិបាក និងដំណោះស្រាយ ជាកំណែថ្មីនៃលំហាត់មែកធាងដំណោះស្រាយបញ្ហាដែលត្រូវបានប្រើយ៉ាងទូលំទូលាយនៅក្នុងការប៉ាន់ប្រម៉ាណនៅជនបទដែលមានការចូលរួម (PRA) និងការរៀនសូត្រ និងសកម្មភាពដែលមានការចូលរួម (PLA)។ នៅឆ្នាំ២០១០ វាត្រូវបានបង្កើតឡើងវិញជាក្របខ័ណ្ឌដែលមានទស្សនៈផ្តេកលើដំណើរការដើម្បីជួយក្នុងការធ្វើសេចក្តីសម្រេចចិត្ត និងគ្រប់គ្រងគម្រោងបន្សាំនានា តាមរយៈការកំណត់សមាសធាតុដំណោះស្រាយបញ្ហាខុសៗគ្នានៃដំណើរការការបន្សាំ។ ដំណើរការនេះមានដំណាក់កាលសំខាន់ៗ ចំនួនពីរ ដូចមានបង្ហាញនៅក្នុងតារាងទី ១០៖

**តារាងទី ១០៖ ការវិភាគបញ្ហា និងដំណោះស្រាយ**

| ដំណាក់កាលការវិភាគបញ្ហា | ដំណាក់កាលវិភាគដំណោះស្រាយ |
|---|---|
| ដំណើរការដំណាក់កាលបញ្ហាមានចរិកលក្ខណៈនិងគោលបំណងរបស់វាគឺដើម្បីរកឱ្យឃើញអ្វីជាបញ្ហា។ដំណើរការនេះធ្វើឡើងដោយការកំណត់នូវហានិភ័យជាប់ពាក់ព័ន្ធនឹងផលប៉ះពាល់ការប្រែប្រួលអាកាសធាតុដែលមានសក្តានុពល និងការចាត់អាទិភាពពួកវា។ គ្រោងដំបូងនាំទៅដល់ក្របខ័ណ្ឌនិងឧបករណ៍ដែលប្រើគឺហានិភ័យ។ ចំណេះដឹងអំឡុងពេលហានិភ័យនេះត្រូវប្រមូល និងធ្វើសំយោគដើម្បីអាចស្វែងយល់ពីភាពជាម្ចាស់ និងការធ្វើសេចក្តីសម្រេចចិត្ត។ | គោលបំណងនៃដំណាក់កាលដោះស្រាយ គឺដោះស្រាយបញ្ហា។ គោលបំណងអាចសម្រេចបានតាមរយៈការបង្កើត និងការអនុវត្តសកម្មភាពការបន្សាំ និងជាដំណាក់កាលសកម្មនៃដំណើរការនេះ រហូតដល់ការវាយតម្លៃចុងក្រោយនៃគម្រោង។ គ្រោងគន្លឹះ នៃដំណាក់កាលនេះគឺការច្នៃប្រឌិត។ ចំណេះដឹងដែលបានប្រមូល និងសំយោគក្នុងដំណាក់កាលបញ្ហាគឺត្រូវបានបញ្ចូលនិងប្រើដើម្បីអនុញ្ញាតឱ្យទីភ្នាក់ងារធ្វើសកម្មភាព រៀនសូត្រ នឹងកែលម្អ។ |
| អ្វីជាបញ្ហា?<br>> នរណារងផលប៉ះពាល់ដោយសារបញ្ហានេះ?<br>> នរណាទទួលខុសត្រូវសម្រាប់បញ្ហានេះ? តើពួកគេរងផលប៉ះពាល់ដោយសារបញ្ហានេះដូចម្តេចខ្លះ?<br>> អ្វីខ្លះជាចំណុចអាទិភាព? | > តើដំណោះស្រាយអ្វីមានតម្លៃខ្ពស់បំផុតសម្រាប់ភាគីពាក់ព័ន្ធ? (ប្រសិទ្ធភាពថ្លៃដើម ផលចំណេញសង្គម ការអភិរក្ស)<br>> នរណាទទួលធ្វើសកម្មភាពនេះ?<br>> នរណាទទួលខុសត្រូវសម្រាប់សកម្មភាពនេះ ហើយពួកគេទទួលខុសត្រូវដូចម្តេច? (នៅកម្រិតបុគ្គលនិងកម្រិតទីភ្នាក់ងារ)<br>> តើធនធានអ្វីខ្លះដែលមានហើយតើអង្គការមានសមត្ថភាពកម្រិតណាក្នុងការធ្វើសកម្មភាពនេះ?<br>> តើហានិភ័យពាក់ព័ន្ធនឹងការធ្វើសកម្មភាពនេះមានអ្វីខ្លះ? តើហានិភ័យត្រូវបានគ្រប់គ្រងយ៉ាងដូចម្តេច? |

ប្រភព៖ (Young និង Jones ឆ្នាំ២០១៤)

ប៉ុន្មានឆ្នាំមកនេះ ក្របខ័ណ្ឌនេះត្រូវបានបង្កើតបន្ថែម ហើយទិដ្ឋភាពរបស់វាត្រូវបានកែលម្អ។ ក្របខ័ណ្ឌនេះអាចជាឧបករណ៍ដ៏មានសារៈប្រយោជន៍មួយនៅក្នុងការបង្កើតការបន្សាំដែលឆ្លើយតបទៅនឹងតម្រូវការយេនឌ័រជាក់លាក់និងគម្រោងកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ។ ជំហានគន្លឹះត្រូវអនុវត្តរួមមាន៖

**ជំហានទី១៖** ការកំណត់បញ្ហាយេនឌ័រស្នូល ( ឬ វិសមភាពយេនឌ័រ) ដែលគម្រោងត្រូវដោះស្រាយ។

**ជំហានទី២៖** គូសមែកធាងបញ្ហាមួយ ដើម្បីស្រាវជ្រាវមូលហេតុដែលអាចមានវិសមភាពយេនឌ័រ។ នេះគួរតែដាក់បញ្ចូលមែកធាងប្រភេទមូលហេតុចំនួនបី-

> មូលហេតុភ្លាមៗ៖ នរណាត្រូវបានទុកចោល? ហេតុអ្វីពួកគេត្រូវបានទុកចោល? តើបុព្វហេតុជាក់ស្តែង និងផ្ទាល់មានអ្វីខ្លះ?

> មូលហេតុសំខាន់៖ ហេតុអ្វីបញ្ហានេះកើតឡើង ? តើបុព្វហេតុសំខាន់ផ្សេងទៀតមានអ្វីខ្លះ ? ហេតុអ្វីសហគមន៍ជាពិសេសអ្នកដែលត្រូវបានគេទុកចោល មិនទទួលបានសេវា ឬឱកាសទាំងនេះស្រដៀងគ្នា ?
> មូលហេតុជាឫសគល់/ជារចនាសម្ព័ន្ធ៖ ហេតុអ្វីបុព្វហេតុបញ្ហាបន្ថែមកើតឡើង ? អ្វីជាឫសគល់នៃបញ្ហានេះ ?

**ជំហានទី៣៖** មែកធាងបញ្ហាគួរតែអាចមើលឃើញព័ត៌មានដែលប្រមូលបានដើម្បីកំណត់ឧបសគ្គសង្គម សេដ្ឋកិច្ច ឬបរិស្ថាន ដែលមានទំនាក់ទំនងនឹងការសម្រេចគោលដៅនៃការកាត់បន្ថយ ឬការបន្សាំ។ (សូមមើលរូបទី ៣៥)

**រូបភាព ៣៥៖ ការបង្កើតដើមឈើបញ្ហា**




**ជំហានទី៤៖** ផ្លាស់ប្តូរមែកធាងបញ្ហាទៅជាសកម្មភាពវិជ្ជមានដើម្បីបង្កើតមែកធាងដំណោះស្រាយ។ បញ្ហានីមួយៗគួរតែមានការកំណត់ដំណោះស្រាយជាក់លាក់។ (សូមមើលរូបភាព ៣៦)

**ជំហានទី៥៖** កំណត់នូវលទ្ធផលនិងផលប៉ះពាល់ដែលបានរំពឹងទុក ហើយផ្លាស់ប្តូរផលប៉ះពាល់និងលទ្ធផលទៅជាគោលបំណងនានា។

**ជំហានទី៦៖** កំណត់នូវវិធីសាស្រ្ត និងសកម្មភាព (កិច្ចអន្តរាគមន៍ និងគោលដៅផែនការយេនឌ័រ) មានសារសំខាន់ដើម្បីសម្រេចលទ្ធផល។ ប៉ាន់ប្រម៉ាណលើដំណោះស្រាយដែលជាជម្រើសល្អបំផុត។

**ជំហានទី៧៖** កំណត់នរណា ឬស្ថាប័នណានឹងទទួលខុសត្រូវសម្រាប់ការអនុវត្តវិធីសាស្រ្ត និងសកម្មភាពដែលបានកំណត់ខាងលើ។ លទ្ធផលចុងក្រោយត្រូវបង្ហាញតាមទម្រង់ខាងក្រោម។

## រូបភាព ៣៦៖ ការវិភាគដើមឈើដំណោះស្រាយ




**គន្លឹះសម្រាប់គ្រូឧទ្ទេស**

វាមានភាពងាយស្រួលក្នុងការផ្តល់បង្ហាញជាលក្ខណៈប្រតិបត្តិនៃឧបករណ៍នេះជាងការពន្យល់នៅក្នុងទ្រឹស្តី។ គ្រូឧទ្ទេសអាចបង្ហាញនូវការជ្រើសរើសបញ្ហាយេនឌ័រណាមួយនៅក្នុងវិស័យនេះ ឬក៏ស្នើទៅអ្នកចូលរួមឱ្យកំណត់ឱ្យបញ្ហាយេនឌ័រមួយដែលភាគច្រើននៃអ្នកចូលរួម សុទ្ធតែធ្លាប់បានដឹង។ ឧទាហរណ៍នៅទីនេះ គ្របដណ្តប់លើ «ឧបទ្ទវហេតុនៃជំងឺឆ្លងតាមភ្នាក់ងារចម្លង»។

ស្នើទៅពួកគាត់ឱ្យចែករំលែកមូលហេតុនៃបញ្ហា។ សូមបន្តបែបនេះរហូតដល់កម្រិត ៣ ដល់កម្រិត ៤ ដោយសួរសំណួរ «ហេតុអ្វីបានរឿងហ្នឹងកើតឡើង ?» កម្រិតទី១ គឺជាមូលហេតុភ្លាមៗ កម្រិតទី២ គឺមូលហេតុសំខាន់ ហើយកម្រិតទី៣ គឺមូលហេតុជាឫសគល់

ឥឡូវនេះត្រឡប់ទៅមូលហេតុស្នូលវិញ ហើយសួរថា «មានអ្វីសំខាន់»។ បន្តទៅកម្រិតចំនួនពីរដោយសារសួរសំណួរនេះដែរ។ កម្រិតទី១ គឺជាផលវិបាកបច្ចុប្បន្នទៅលើសហគមន៍ ហើយកម្រិតទី២ គឺជាផលវិបាកយូរអង្វែងសំខាន់។ ការគូសវាសផែនទីនៃមូលហេតុ និងផលវិបាកនេះ គឺជាដើមឈើបញ្ហារបស់អ្នក។ (រូបភាព ៣៥)

រកឱ្យឃើញដំណោះស្រាយទៅនឹងបញ្ហានីមួយ - មូលហេតុ និងផលវិបាក។ (រូបភាព ៣៦) ការដោះស្រាយមូលហេតុទាំងនោះគួរតែដាក់បញ្ចូលជាទិន្នផលគម្រោង ហើយការដោះស្រាយផលវិបាកបច្ចុប្បន្ន គឺជាលទ្ធផលគម្រោង ហើយការដោះស្រាយផលវិបាកយូរអង្វែង គឺជាគោលដៅគម្រោង

**រូបទី ៣៧៖ ទម្រង់សម្រាប់ទិន្នផលចុងក្រោយ**

| ការពិពណ៌នាបញ្ហា | ការពិពណ៌នាដំណោះស្រាយ | សូចនាករ* | ទីភ្នាក់ងារទទួលខុសត្រូវ |
|---|---|---|---|
| ផលវិបាកការអភិវឌ្ឍ | គោលដៅផលប៉ះពាល់ | | |
| ផលវិបាកភ្លាមៗ | លទ្ធផល | | |
| បញ្ហាស្នូល | គោលបំណង | | |
| មូលហេតុភ្លាមៗ | ទិន្នផល | | |
| មូលហេតុសំខាន់ | សកម្មភាព | | |
| បុព្វហេតុជាឫសគល់ | វិធិសាស្ត្រ ( ឬ ហានិភ័យ ) | | |

*អ្នកក៏អាចកំណត់ទិន្នផល និងលទ្ធផលក្នុងទម្រង់តាមគោលដៅបែបបរិមាណវិស័យ និងគុណវិស័យ និងសូចនាករដែលឆ្លើយតបទៅនឹងតម្រូវការយេនឌ័រ ដើម្បីទទួលបានក្របខ័ណ្ឌតាមដាន និងវាយតម្លៃលម្អិតមួយ។

## ម៉ូឌុល៣ វគ្គ ខ៖

**3:00:00**

**ក្របខ័ណ្ឌការងារការបញ្ជ្រាបយេនឌ័រ និងឧបករណ៍សម្រាប់អន្តរាគមន៍សហគមន៍ស៊ីវិល (ការអនុវត្ត ការតាមដាន និងការវាយតម្លៃ)**

**ទិដ្ឋភាពទូទៅ**

នៅចុងបញ្ចប់នៃវគ្គនេះ អ្នកចូលរួមគួរតែមានចំណេះដឹងមូលដ្ឋានពីផ្នែកឧបករណ៍ការបញ្ជ្រាបយេនឌ័រ និងបច្ចេកទេសដែលអាចអនុវត្តបានពេញលេញក្នុងវដ្តគម្រោង។ ពួកគេគួរតែអាចយល់ដឹងពីដំណាក់កាលជាជំហានៗសម្រាប់ការអនុវត្តឧបករណ៍ទាំងនេះនិងគួរតែអាចកំណត់នូវជម្រើសសមស្របបំផុតសម្រាប់ការអនុវត្តក្នុងការងាររបស់ពួកគេ។

**មាតិកា**

ក) ក) ដំណើរការអនុវត្តដែលមានទស្សនៈយេនឌ័រ
ក. ការវិភាគភាគីពាក់ព័ន្ធ
ខ. ការចូលរួមរបស់ក្រុមមនុស្សដ៏មានអត្ថន័យ និងការកសាងស្ថាប័ន
១. ករណីសិក្សាប្រទេសចិន
គ. ផែនការការបន្សាំផ្អែកលើសហគមន៍ (CBA)
ឃ. ការទំនាក់ទំនង និងការចែករំលែកចំណេះដឹង
ខ) ការតាមដាន និងវាយតម្លៃរញ្ជោចយេនឌ័រ
ខ) ក. សូចនាករដែលមានទស្សនៈយេនឌ័រ
ខ. ម៉ាទ្រិចតាមដានយេនឌ័រ
១. ករណីសិក្សាប្រទេសមីយ៉ាន់ម៉ា

**សម្ភារៈ**

បទបង្ហាញជា Power Point
ក្រដាសផ្ទាំងធំ និងប៊ិច
ផ្ទាំងរូបភាពស្ដីពីឧបករណ៍ដែលមានការចូលរួមដែលយកចេញពីសំណៅឯកសារទី១៣
រូបិយប័ណ្ណក្លែងក្លាយ
ក្ដារខៀនសម្រាប់ភ្ជួរផ្ទាំងរូបភាពនៅកន្លែងចំហ
ឧបករណ៍ចាក់បញ្ចាំងវីដេអូនៅលើ Youtube

**តារាងពេលវេលា**



| រយៈពេល | សកម្មភាព |
|---|---|
| ៥នាទី | > ការចែករំលែកទិដ្ឋភាពទូទៅ និងខ្លឹមសារនៅក្នុងវគ្គ |
| ៥៥នាទី | > បទបង្ហាញជា Power Point ស្តីពី «ដំណើរការអនុវត្តដែលមានទស្សនៈយេនឌ័រ» |
| ៦០នាទី | > ទីផ្សារអភិវឌ្ឍន៍កម្មវិធី (Development Market Place) ស្តីពី «ឧបករណ៍ និងបច្ចេកទេសដែលមានការចូលរួម» (សូមមើលលំហាត់១៩ និងសំណៅឯកសារទី ១៣) |
| ៣០នាទី | > បទបង្ហាញជា Power Point ស្តីពី "ការតាមដាន និងវាយតម្លៃរំញោចយេនឌ័រ" |
| ៣០នាទី | > លំហាត់ផ្តល់ចំណាត់ថ្នាក់កង់សម្រាប់ការតាមដាន «មិនមានអ្នកណាត្រូវបានទុកចោល» (សូមមើលលំហាត់២០ និងសំណៅឯកសារទី ១៤) |

**កំណត់សម្គាល់ណែនាំ**



ចាប់ផ្តើមវគ្គនេះដោយការចែករំលែកទិដ្ឋភាពទូទៅនិងខ្លឹមសារ។ សូមប្រាប់ទៅអ្នកចូលរួមវគ្គនេះនឹងឈានទៅដំណាក់កាលការអនុវត្ត ការតាមដាន និងការវាយតម្លៃវដ្តគម្រោង។ សូមធ្វើបទបង្ហាញជា Power Point ស្តីពី «ដំណើរការអនុវត្តដែលមានទស្សនៈយេនឌ័រ» - រួមមានការវិភាគភាគីពាក់ព័ន្ធ ការចូលរួមដ៏មានអត្ថន័យ ការអភិវឌ្ឍនស្ថាប័នរបស់ក្រុមមនុស្ស ផែនការផ្អែកលើសហគមន៍ ទំនាក់ទំនង និងការចែករំលែកចំណេះដឹង។ ពេលសម្រាកការពិភាក្សាត្រូវបានគូសបង្ហាញខ្លឹមសារដែលផ្តល់នូវឧទាហរណ៍ដែលបានមកពីបញ្ហាជីវិតទូទៅដើម្បីជួយឱ្យអ្នកចូលរួមអាចបង្កើតទំនាក់ទំនងបានកាន់តែល្អប្រសើរ។ សូមធ្វើឱ្យវគ្គនេះកាន់តែមានការចូលរួមដោយការសុំឱ្យអ្នកចូលរួមចែករំលែកនូវបទពិសោធន៍ផ្ទាល់ខ្លួនរបស់ពួកគេនៅក្នុងបរិបទនេះ។ សូមកុំធ្វើការកាត់សេចក្តី លុះត្រាមានលេចចេញនូវខុសពីបរិបទទាំងស្រុង។ សូមជំរុញឱ្យអ្នកចូលរួមគ្រប់រូបនិយាយ - អ្នកត្រូវធានាថានៅចុងបញ្ចប់នៃវគ្គនេះ អ្នកចូលរួមទាំងអស់បានចែករំលែកយ៉ាងតិចបទពិសោធន៍មួយ។ ជាមួយគ្នាដែរ សូមចាក់បញ្ចាំង វីដេអូនៃកម្មវិធីទូរទស្សន៍ Amrai Pari របស់អង្គការ BBC Media Action ដើម្បីសម្រាកពីការធ្វើបទបង្ហាញ។ (សូមគន្លឹះសម្រាប់គ្រូឧទ្ទេស)។ អំឡុងពេលផ្នែកស្តីពីការរៀបចំផែនការផ្អែកលើសហគមន៍ សូមប្រាប់ទៅអ្នកចូលរួមថាពួកគេនឹងជួបប្រទះនូវឧបករណ៍ចំនួនពីរបីទៀតនៅលំហាត់បន្ទាប់។

វគ្គបន្ទាប់នេះ គឺជាលំហាត់ដែលត្រូវចូលរួមច្រើននៃទីផ្សារអភិវឌ្ឍន៍កម្មវិធីស្តីពី «ឧបករណ៍ និងបច្ចេកទេសដែលមានការចូលរួម» (សូមមើលលំហាត់ទី ១៩ និងសំណៅឯកសារទី១៣)។ សូមធានាថាអ្នកបានអានលំហាត់នេះជាមុនរួចរាល់ហើយ និងបានកំណត់អ្នកស្ម័គ្រចិត្តរួចរាល់ដូចគ្នា។ អ្នកស្ម័គ្រចិត្តអាចយកមកពីក្រុម និងអង្គការរៀបចំព្រឹត្តិការណ៍នេះ។ បើសិនអាច ព្យាយាមយកអ្នកចូលរួមពីខាងក្រៅសម្រាប់លំហាត់នេះ ឬរៀបចំតុ និងកៅអីឱ្យស្អាតដែលអាចមានកន្លែងគ្រប់គ្រាន់។ សូមធានាថាផ្ទាំងរូបភាពត្រូវព្រីនជាក្រដាសពណ៌ទំហំ A3 (សូមព្យាយាមធ្វើពួកវាជាក្រដាសសំប៉ែត និងអាចរក្សាទុកបានសម្រាប់ការប្រើប្រាស់នៅពេលក្រោយ)។ ជារឿយៗ វគ្គនេះត្រូវទទួលខុសត្រូវខ្ពស់ ដូច្នេះយកល្អ ដាក់បង្ហាញវាក្រោយពេលអាហារថ្ងៃត្រង់។ វាគ្មានបញ្ហាអីទេក្នុងការបង្ហាញនៅមុនពេលបទបង្ហាញការអនុវត្តដែលមានទស្សនៈយេនឌ័រដើម្បីកែតម្រូវពេលវេលា។

បន្ទាប់មកធ្វើបទបង្ហាញជា Power Point ស្តីពី «ការតាមដាន និងវាយតម្លៃរំញោចយេនឌ័រ» និងលំហាត់កង់វិលជុំវិញសម្រាប់ការតាមដាន "មិនមានអ្នកណាត្រូវបានទុកចោល" (សូមមើលលំហាត់ទី២០ និងសំណៅឯកសារទី ១៤)

## ដំណើរការអនុវត្តដែលមានទស្សនៈយេនឌ័រ

ដំណាក់កាលការអនុវត្ត ឬប្រតិបត្តិគម្រោង គឺតែងតែជាដំណាក់កាលវែង និងសំខាន់បំផុតក្នុងន័យសមាហរណកម្មយេនឌ័រ។ គម្រោងដែលមានទស្សនៈឆ្លើយតបទៅនឹងតម្រូវការយេនឌ័រ ដែលរៀបចំឡើងល្អបំផុត គឺមិនអាចទទួលបានលទ្ធផលដែលចង់បានឡើយ បើសិនដំណើរការការអនុវត្តនានាមិនមានទស្សនៈយេនឌ័រ។ ដំណើរការនេះត្រូវការជំហានគន្លឹះចំនួនបី៖

ក) ថែរក្សាភាពជាដៃគូជាមួយភាគីពាក់ព័ន្ធសំខាន់ៗទាំងអស់ដើម្បីធានាថា «មានភាពម្ចាស់ការ»។

ខ) ចូលរួមប្រកបដោយប្រសិទ្ធភាពទាំងបុរស និងស្ត្រីនៅគ្រប់ដំណើរការទាំងអស់។

គ) ធានានូវការទាក់ទង និងការផ្លាស់ប្តូរចំណេះដឹងល្អសម្រាប់កសាងសមត្ថភាពសម្រាប់បុរស និងស្ត្រី។

## ការវិភាគភាគីពាក់ព័ន្ធ

«ភាគីពាក់ព័ន្ធ» គឺ «បុគ្គល ក្រុម ឬ ស្ថាប័នទាំងឡាយណាដែលមានប្រយោជន៍ផ្តល់ឱ្យក្នុងតំបន់គម្រោងនិង/ឬអ្នកដែលសក្តានុពលនឹងត្រូវជះឥទ្ធិពលលើសកម្មភាពគម្រោងនិងមានអ្វីទទួលបានផលចំណេញ ឬ ខាតបង់ បើសិនលក្ខខណ្ឌប្រែប្រួល ឬ នៅដដែល» (WWFឆ្នាំ២០០៥)។ ការចូលរួមរបស់ភាគីពាក់ព័ន្ធទាំងអស់ត្រូវគិតគូរពិចារណាដើម្បីទទួលបានជោគជ័យគោលដៅគម្រោង។ ការវិភាគភាគីពាក់ព័ន្ធកំណត់គ្រប់ស្ត្រី និងបុរសទាំងអស់ដែលមានប្រយោជន៍ផ្តល់ទៅក្នុងបញ្ហាគម្រោង ឬគោលនយោបាយដែលត្រូវជាប់ពាក់ព័ន្ធ។ជាទូទៅការវិភាគភាគីពាក់ព័ន្ធត្រូវបានប្រើនៅដំណាក់កាលរៀបចំគម្រោងដើម្បីធានាថាការដើរតួនាទីខុសៗគ្នារបស់ស្ត្រី និងបុរសត្រូវបានស្វែងយល់បានយ៉ាងល្អបំផុត។ ទោះបីជាយ៉ាងណាក៏ដោយ ការវិភាគភាគីពាក់ព័ន្ធក៏មានសារៈសំខាន់ខ្លាំងនៅដំណាក់កាលអនុវត្តគម្រោងផងដែរ សម្រាប់៖

ក) ការរុះរើរៀបចំសកម្មភាពឡើងវិញ ដើម្បីធានានូវការចូលរួមប្រកបដោយសមធម៌ និងដ៏មានអត្ថន័យ របស់បុរស និងស្ត្រីនៅគ្រប់កម្រិត។

ខ) បង្កើតប្រព័ន្ធសម្រាប់ទំនាក់ទំនង និងវគ្គបណ្តុះបណ្តាលសម្រាប់ស្ត្រី និងបុរស ដើម្បីមានឱកាសស្មើគ្នាក្នុងការទទួលបានអត្ថប្រយោជន៍ពីគម្រោង។

គ) បង្កើតផែនការផ្អែកលើសហគមន៍ ដើម្បីធានាការចូលរួមចំណែកទាំងស្ត្រី និងបុរស ដែលត្រូវបានទទួលស្គាល់គ្រប់គ្រាន់ក្នុងការកំណត់ការទទួលបាន និងគ្រប់គ្រងលើធនធាន។

ឃ) ការវិភាគនេះភាគច្រើនជួយកំណត់នរណា របៀបណា និងពេលណាភាគីពាក់ព័ន្ធស្ត្រីនិងបុរសគួរតែចូលរួមក្នុងសកម្មភាពគម្រោង។

ខាងក្រោមនេះជាជំហានគន្លឹះចំនួនពីរ ដើម្បីវិភាគភាគីពាក់ព័ន្ធដែលមានរំញោចយេនឌ័រ៖

**ជំហានទី១ - កំណត់ភាគីពាក់ព័ន្ធសំខាន់ៗ និងផលប្រយោជន៍របស់ពួកគាត់៖**

បំផុសគំនិតលើភាគីពាក់ព័ន្ធទាំងអស់ដែលអាចធ្វើទៅបានតាមរយៈការប្រើសំណួរ «នរណាពឹងអាស្រ័យលើធនធានខ្លាំងបំផុតពេលមានបញ្ហា (ស្ត្រី ឬ បុរស)?» ជាសំណួរនាំមុខ។ ស្វែងយល់ពីក្រុមភាគីពាក់ព័ន្ធនីមួយៗឱ្យបានស៊ីជម្រៅតាមដែលអាចធ្វើបាន តាមរយៈការសាកសួរ៖

- នរណាជាអ្នកគ្រប់គ្រងលើធនធាន ហើយមានលទ្ធផលយ៉ាងណា?
- នរណាដែលជាស្ត្រីនិងបុរសដែលមានចំណេះដឹងច្រើន និងមានសមត្ថភាពដោះស្រាយធនធានមានប្រយោជន៍?
- តើសកម្មភាពបន្សាំអ្វីខ្លះដែលបុរសនិងស្ត្រីលើកឡើងខុសៗគ្នា? សកម្មភាពបន្សាំទៅនឹងអ្វី?
- សម្រាប់សកម្មភាពការបន្សាំនិងការកាត់បន្ថយនីមួយៗដែលបានលើកឡើង នរណាជាភាគីពាក់ព័ន្ធ? តើផលប្រយោជន៍របស់ពួកគាត់ធំប៉ុណ្ណា? តើប្រវត្តិទំនាក់ទំនងរបស់ពួកគាត់ជាមួយគ្នាយ៉ាងណាដែរ?
- តើឋានានុក្រមសង្គមមានឬទេ? នរណាត្រូវបានតែងតាំងសម្រាប់មុខតំណែងអំណាចនៅក្នុងឋានានុក្រមសង្គមនោះ?
- តើជម្លោះរវាងភាគីពាក់ព័ន្ធមានឬទេ?តើភាពជាដៃគូមានឬទេ?
- តើភាគីពាក់ព័ន្ធយល់ឃើញខុសៗគ្នាពីហានិភ័យទាក់ទងនឹងការប្រែប្រួលអាកាសធាតុយ៉ាងដូចម្តេច?
- តើពួកគេយល់ឃើញពីអត្ថប្រយោជន៍នៃសកម្មភាពការកាត់បន្ថយ និងការបន្សាំយ៉ាងដូចម្តេច?
- តើគេអាចធ្វើដូចម្តេចដើម្បីរក្សាតុល្យភាពនៃតម្រូវការរយៈពេលខ្លី និងតម្រូវការរយៈពេលវែងរបស់ភាគីពាក់ព័ន្ធខុសៗគ្នា?
- តើបុរស និងស្ត្រីទទួលបានអត្ថប្រយោជន៍ស្មើគ្នាឬទេ?
- តើបុរសនិងស្ត្រីក្នុងក្រុមដែលមានប្រាក់ចំណូលខុសៗគ្នាទទួលបានអត្ថប្រយោជន៍ស្មើគ្នាឬទេ?
- តើការចូលរួមរបស់ស្ត្រីត្រូវបានធានាឬទេ? តើការចូលរួមរបស់ក្រុមដែលជួបការលំបាកបានធានាឬទេ? ធានាដោយនរណា?
- តើការទទួលបានព័ត៌មានត្រូវបានធានាឬទេ?ដោយនរណា?
- តើធ្លាប់មានការផ្តួចផ្តើមស្រដៀងគ្នានៅក្នុងតំបន់ទេ?បើមានតើការផ្តួចផ្តើមនោះជោគជ័យប៉ុណ្ណា? នរណាទទួលខុសត្រូវ? ហើយតើភាគីពាក់ព័ន្ធជាស្ត្រី និងបុរសនៅមូលដ្ឋានឆ្លើយតបយ៉ាងដូចម្តេច?

**ជំហានទី២ - វិភាគភាគីពាក់ព័ន្ធ និងបង្កើតយុទ្ធសាស្ត្រដើម្បីទាញពួកគេចូលរួម**

វិភាគបញ្ជីភាគីពាក់ព័ន្ធ គឺត្រូវដាក់ពួកគេជាក្រុមយោងតាមកម្រិតផលប្រយោជន៍និងឥទ្ធិពលរបស់ពួកគេនៅក្នុងគម្រោង។ជំហានបន្ទាប់មានជាប់ពាក់ព័ន្ធនឹងការកំណត់ពីរបៀបដែលភាគពាក់ព័ន្ធចូលរួម និងទំនាក់ទំនងក្រុមមួយក្នុងចំណោមភាគីពាក់ព័ន្ធទាំងនេះរហូតទៅ។ ភាគីពាក់ព័ន្ធខុសៗគ្នា ត្រូវការទាញឱ្យចូលរួមតាមវិធីផ្សេងៗគ្នាអាស្រ័យទៅលើទីតាំងរបស់ពួកគេនៅក្នុងម៉ាទ្រិចភាគីពាក់ព័ន្ធ។ (រូបទី ២០)

**រូបភាព ៣៨៖ ម៉ាទ្រិចការវិភាគភាគីពាក់ព័ន្ធ**



**គន្លឹះសម្រាប់គ្រូឧទ្ទេស**

វាជាជំនួយផងដែរក្នុងការទទួលយកឧទាហរណ៍ - លើកឡើងពីគម្រោងព្រៃឈើសហគមន៍ និងបង្ហាញនូវការវិភាគជីវិតរស់នៅរបស់ភាគពាក់ព័ន្ធម្នាក់ក្នុងដំណើរការ។ ចាប់ផ្តើមដោយការកំណត់ឱ្យឃើញនូវភាគីពាក់ព័ន្ធសំខាន់ៗ - បុរសជាម្ចាស់ដី ស្ត្រីមកពីគ្រួសារជាម្ចាស់ដី បុរសគ្មានដីធ្លី ស្ត្រីមកពីគ្រួសារគ្មានដីធ្លី មនុស្សចាស់ក្នុងភូមិ សហគមន៍ សហគមន៍ចិញ្ចឹមសត្វ ថ្នាក់ដឹកនាំភូមិ ឆ្មាំយាមត្បាតព្រៃឈើ មន្ត្រីព្រៃឈើ មន្ត្រីប្រមូលចំណូល បុគ្គលិកសុខាភិបាលប្រចាំភូមិ ក្រុមជនជាតិដើមភាគតិច ក្រុមជនជាតិភាគតិច។ល។ ឥឡូវនេះ សូមសាកសួរទៅអ្នកចូលរួមថា តើភាគីពាក់ព័ន្ធមួយនឹងស្ថិតនៅត្រង់ណានៅក្នុងប្រអប់មួយណា ហើយហេតុអ្វី។

## ការចូលរួមប្រកបដោយអត្ថន័យ និងការអភិវឌ្ឍ/បង្កើតស្ថាប័នរបស់ក្រុមមនុស្ស

ការចូលរួមត្រូវបានចាត់ទុកជាការចូលរួមរបស់សហគមន៍នៅក្នុងផែនការ ការធ្វើសេចក្តីសម្រេចចិត្ត ការតាមដាន និងការវាយតម្លៃ។ ជាញឹកញាប់ ដោយត្រូវបានចាត់ទុកជាវេទិកាសម្រាប់ «កសាងបំណងរួមរបស់សហគមន៍»ប៉ុន្តែការចូលរួមកាន់តែមានអត្ថន័យជាការទំនាក់ទំនងពីរវិធីដែលព័ត៌មានត្រូវបានផ្លាស់ប្តូរក្នុងទម្រង់ការសន្ទនា ឬ ការចរចារ និងម្យ៉ាងទៀតដំណើរការត្រូវបានរៀបចំសម្រាប់ «សហសិក្សា ឬសហគ្រប់គ្រង»។ ការចូលរួមប្រកបដោយអត្ថន័យបែបនេះអាចឱ្យការវិភាគ និងការចាត់អាទិភាពដ៏ចាំបាច់កាន់តែល្អប្រសើរគុណភាពព័ត៌មាននិងការធ្វើសេចក្តីសម្រេចចិត្តកាន់តែល្អ និងចុងក្រោយសកម្មភាពឯកភាពកាន់តែត្រូវបានជ្រួតជ្រាប។

ការចូលរួមរបស់ភាគីពាក់ព័ន្ធទាំងអស់ មិនត្រឹមតែបង្កើនទំនុកចិត្តពីសាធារណៈជនប៉ុណ្ណោះទេ ប៉ុន្តែជួយលើកកម្ពស់ការសិក្សាផ្នែកសង្គមកាន់តែស៊ីជម្រៅ និងបង្កើតចំណេះដឹងរួមគ្នាដែរ។ ទោះបីយ៉ាងណា តេស្តដ៏សំខាន់នេះ ជាការកំណត់នូវបណ្តាញនិងវេទិកាត្រឹមត្រូវសម្រាប់ការចូលរួមរបស់គ្រប់ភាគីពាក់ព័ន្ធទាំងអស់។ ស្ថាប័នដំណើរប្រឹក្សាយោបល់របស់ប្រជាជន និងស្ថាប័នរបស់ប្រជាជន ជារឿយៗត្រូវបានចាត់ទុកជាយុទ្ធសាស្ត្រសមស្របបំផុតចំនួនពីរសម្រាប់ការចូលរួមនេះជាពិសេសនៅកម្រិតមូលដ្ឋាន។ យុទ្ធសាស្ត្រទាំងពីរនេះមានលក្ខណៈជាបទដ្ឋាន - ការផ្តល់ឱ្យប្រជាជននូវសិទ្ធិប្រជាធិបតេយ្យក្នុងការចូលរួមធ្វើសេចក្តីសម្រេចចិត្តក៏មានលក្ខណៈជាប្រាកដនិយមដែរ - ការផ្តល់កន្លែងឱ្យមានការចូលរួមបែបស៊ីជម្រៅ និងសម្រេចចិត្តប្រកបដោយគុណភាពខ្ពស់ (សូមមើលប្រអប់)។

សេចក្តីប្រកាសរបស់ទីក្រុងប៉េកាំង និងវេទិកាសកម្មភាព ក៏ដូចជាសន្ធិសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ (CEDAW) បានសង្កត់ធ្ងន់លើតម្រូវការសម្រាប់បរិយាបន្ន និងការចូលរួមរបស់ស្ត្រីគ្រប់ដំណើរការទាំងអស់នៃស្ថាប័នសាធារណៈ។ ទោះយ៉ាងណា ការផ្តល់ឋានៈសង្គមបន្ទាប់បន្សំដល់ស្ត្រីនៅក្នុងសង្គមអាស៊ីភាគច្រើនកិច្ចអន្តរាគមន៍ជាក់លាក់ទាមទារឱ្យបង្កើតបរិយាកាសអំណោយផលសម្រាប់ការធានានូវការចូលរួមប្រកបដោយអត្ថន័យរបស់ស្ត្រីក្នុងការអនុវត្តគម្រោង។

នេះពាក់ព័ន្ធនឹងយុទ្ធសាស្ត្រជាក់លាក់ផ្សេងៗរួមមានការដាក់ចេញនូវផែនការរចនាសម្ព័ន្ធរដ្ឋាភិបាលដែលមានស្រាប់ ដើម្បីសិក្សាពីរបៀបបុរស ស្ត្រី និងក្រុមផ្សេងៗទៀតស្ថិតនៅក្នុងហានិភ័យ ដូចជាក្មេងស្រីវ័យជំទង់ និងស្ត្រី និងក្មេងស្រីពិការភាពចូលរួមក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្ត។ ការប៉ាន់ប្រម៉ាណគួរតែពិនិត្យលើឧបសគ្គ និងឱកាសនានា ដើម្បីបង្កើនការចូលរួមរបស់ស្ត្រីនិងស្រាវជ្រាវរកយុទ្ធសាស្ត្រដែលអាចសម្រួលដល់បញ្ហានេះ។ ថ្វីបើរាល់ការសម្រេចចិត្តទាំងអស់មិនជះឥទ្ធិពលលើជីវិតស្ត្រីប៉ុន្តែគេចាំបាច់ត្រូវយល់ថាការធ្វើសេចក្តីសម្រេចចិត្តទាំងអស់នឹងត្រូវធ្វើឡើងនៅកម្រិតផ្លូវការជាសាធារណៈ។ ដោយមានទស្សនៈខ្វែងគ្នា "ការគាំទ្រការចូលរួម និងភាពជាអ្នកដឹកនាំរបស់ស្ត្រីនៅកម្រិតមូលដ្ឋាន ទាំងការអនុវត្ត និងការធ្វើសេចក្តីសម្រេចចិត្ត គឺមានសារៈសំខាន់ ព្រោះនៅកម្រិតនេះមានសេចក្តីសម្រេចចិត្តជា

**រូបភាព ៣៩៖ យុទ្ធសាស្ត្រនានាដែលអាចឱ្យស្ត្រីចូលរួមប្រកបដោយអត្ថន័យ**

- គូសវាសផែនទីស្ត្រីនិងក្រុមផ្សេងទៀតដែលចូលរួមនៅក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្តដែលមានស្រាប់
- រកឱ្យឃើញរបាំងនានារារាំងដល់ការចូលរួមរបស់ស្ត្រីនិងក្រុមងាយរងគ្រោះនានា
- គាំទ្រការចូលរួមរបស់ស្ត្រីនៅក្នុងប្រព័ន្ធដែលមានស្រាប់នៅកម្រិតមូលដ្ឋាន
- ជំរុញ និង ពង្រឹងតែក្រុមស្ត្រី និងអង្គការស្ត្រី
- ធានាការបញ្ចូលវិស័យងាយរងគ្រោះទាំងអស់ជាតិសាសន៍វណ្ណៈឋានៈអាយុ ពិការភាព ស្ថានភាពអាពាហ៍ពិពាហ៍នៅក្នុងក្រុមស្ត្រីតែប៉ុណ្ណោះ

កម្រិតចំនួន៦នៃការចូលរួមដែលចែងចែកដោយ Agarwal (មិនមានប្រភពជាក់លាក់)៖

1. ការចូលរួមមានតែនាមសំដៅដល់ការគ្រាន់តែមានឈ្មោះជាសមាជិកភាពនៅក្នុងក្រុមមួយដោយមិនមានការចូលរួមណាមួយឡើយ
2. ការចូលរួមបែបអកម្ម សំដៅដល់ស្ថានភាពមួយដែលស្ត្រីចូលរួមកិច្ចប្រជុំនានា ហើយគ្រាន់តែស្តាប់ការសម្រេចចិត្ត ការពិតគ្មានការបញ្ចេញសំឡេង
3. ការចូលរួមបែបប្រឹក្សាយោបល់គឺជាទីដែលមានការស្វែងរកមតិរបស់ស្ត្រីសម្រាប់បញ្ហាជាក់លាក់ដោយមិនមានការធានានូវធាតុចូលរបស់ពួកគេដែលជះឥទ្ធិពលដល់ការសម្រេចចិត្តចុងក្រោយឡើយ
4. ការចូលរួមដោយសកម្មភាពជាក់លាក់សំដៅដល់ស្ថានភាពមួយដែលស្ត្រីត្រូវបានស្នើឱ្យ(ឬស្ម័គ្រចិត្ត) បំពេញកិច្ចការជាក់លាក់
5. ការចូលរួមសកម្ម គឺជាទីដែលស្ត្រីបញ្ចេញគំនិតរបស់ពួកគេ មិនថា គំនិតពួកគេគួរឱ្យទាក់ទាញ ឬក៏អត់នោះទេ ហើយប្រកាន់យកនូវការផ្តួចផ្តើមផ្សេងៗ
6. កម្រិតខ្ពស់បំផុតគឺការចូលរួមប្រកបដោយអន្តរកម្មដែលស្ត្រីមានលទ្ធភាពអាចនិយាយបានបង្កើនឥទ្ធិពលបាននិងអនុវត្តសេចក្តីសម្រេចចិត្តបាន

ច្រើនដែលជះឥទ្ធិពលលើជីវិតស្ត្រីនឹងត្រូវបានធ្វើឡើង”។

ស្ថាប័នរបស់ស្ត្រីដែលមានលក្ខណៈក្រៅផ្លូវការ ជាពិសេស ការជំរុញសកម្មភាពរួមនៅតែសំខាន់កាលពីប៉ុន្មានទសវត្សរ៍កន្លងមកពីព្រោះជាចំណុចចាប់ផ្តើមសំខាន់ក្នុងការដោះស្រាយនិន្នាការការផាត់ចេញប្រឆាំងនឹងស្ត្រី និងផ្នែកងាយរងគ្រោះនៃសហគមន៍។ ការគាំទ្រក្រុមស្ត្រីដែលមានស្រាប់ និងការលើកទឹកចិត្តក្នុងការបង្កើតក្រុមថ្មីមួយ ជួយឱ្យស្ត្រីមានសិទ្ធិចូលទៅក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្ត និងនយោបាយ និងការពង្រឹងការគាំទ្រដល់ស្ត្រីចំពោះគ្នាទៅវិញទៅមកគឺពិតជាសំខាន់ណាស់សម្រាប់សកម្មភាពដែលឆ្លើយតបទៅនឹងតម្រូវការយេនឌ័រ នៅក្នុង CCDRR។

ទោះបីយ៉ាងណាគ្រាន់តែការបង្កើតនិងការពង្រឹងដល់ក្រុមស្ត្រីមិនគ្រប់គ្រាន់ទេ។វាក៏សំខាន់ដែរក្នុងការប្រឹក្សាជាមួយស្ត្រីពីបញ្ហាទាំងអស់ទាក់ទងនឹងគម្រោង ឱ្យពួកគេចូលរួមក្នុងការធ្វើសេចក្តីសម្រេចចិត្ត និងសំខាន់បំផុតនោះគឺ ការកសាងភាពជាអ្នកដឹកនាំនិងជំនាញការចរចារដល់ពួកគេ ដើម្បីប្រើទីភ្នាក់ងារ និងសំឡេងរបស់ពួកគេនៅក្នុងសហគមន៍។

យុទ្ធសាស្ត្រគន្លឹះដែលគួរតែយកមកអនុវត្តជាមួយក្រុមស្ត្រីទាំងនេះ គួរតែជាខ្នាតរង្វាស់មួយសម្រាប់បង្កើនចំណេះដឹង និងជំនាញភាពជាដឹកនាំរបស់ស្ត្រី។ ដូច្នេះ អ្នកដឹកនាំដែលកំពុងរះឡើង គួរតែត្រូវបានបញ្ចូលនៅក្នុងក្រុម និងស្ថាប័នធ្វើសេចក្តីសម្រេចចិត្តនៅមូលដ្ឋានដែលមានប្រជាប្រិយភាព ដើម្បីឱ្យស្ត្រីអាចមានសំឡេង និងមានឥទ្ធិពលលើ CCDRR ទាំងអស់ និងលើការសម្រេចចិត្តគ្រប់គ្រងធនធាននៅកម្រិតមូលដ្ឋាន។

ទស្សនៈសំខាន់បំផុតនៃការចូលរួមប្រកបដោយអត្ថន័យរបស់ស្ត្រី គឺមិនមានអ្នកណាម្នាក់ត្រូវបានទុកចោល។ វាមានសារៈសំខាន់ដែលត្រូវយល់ថា ស្ត្រីមិនមែនជាសហគមន៍ដែលមានលក្ខណៈដូចគ្នា ហើយភាពចម្រុះ និងការបញ្ចូលស្ត្រីដែលជួបការលំបាកដោយមិនគិតពីពូជសាសន៍ វណ្ណៈ អាយុ ពិការភាព ស្ថានភាពអាពាហ៍ពិពាហ៍ ចាំបាច់ត្រូវតែធានាបាន។ ជាពិសេស ក្មេងស្រីវ័យជំទង់ត្រូវតែមាននៅក្នុងការសម្រេចចិត្ត CCDRR ទាំងអស់។ ការរាប់បញ្ចូលស្ត្រីពិការភាពក៏មានសារៈសំខាន់ផងដែរពិសេសក្នុងបរិបទនៃ DRR។ សកម្មភាពជាក់លាក់អាចទាមទារឱ្យមានការសម្របសម្រួលដល់ការចូលរួមរបស់ស្ត្រីពិការភាព។ ឧទាហរណ៍ ទីកន្លែងប្រជុំ/សិក្ខាសាលាដែលងាយទៅដល់ និង/ឬ ការបកប្រែភាសាកាយវិការចាំបាច់ត្រូវមាន។

### ស្ត្រីក្នុងគណៈកម្មាធិការគ្រោះមហន្តរាយភូមិ (VDCs)៖ ករណីសិក្សាប្រទេសចិន

គម្រោងត្រៀមបង្ការគ្រោះមហន្តរាយផ្អែកលើសហគមន៍(CBDP) បានអនុវត្តដោយអនុសាខា Guangxi (GXRC) នៃសង្គមកាកបាទក្រហមចិនត្រូវបានបង្កើតក្នុងក្របខ័ណ្ឌនិងធ្វើឡើងជាដៃគូរជាមួយកាកបាទក្រហមអូស្ត្រាលី (ARC)។ គម្រោងនេះមានគោលបំណងផ្តល់នូវវគ្គបណ្តុះបណ្តាលភាពត្រៀមបង្ការគ្រោះមហន្តរាយ និងសកម្មភាពការកាត់បន្ថយមុខសញ្ញាគ្រោះថ្នាក់រូបវន្ត ក្នុងសេចក្តីសង្ឃឹមដោយធ្វើឱ្យប្រសើរឡើងភាពធន់នៃការចូលរួមរបស់សហគមន៍ភូមិទៅនឹងគ្រោះមហន្តរាយ។គម្រោងនេះសង្កត់ធ្ងន់លើការចូលរួមរបស់ស្ត្រីក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្តនៅក្នុងគម្រោងនឹងមានផលប៉ះពាល់វិជ្ជមានលើទស្សនៈនៃតួនាទីរបស់ស្ត្រីនៅក្នុងសហគមន៍។

នៅក្នុងការបង្កើតគណៈកម្មាធិការគ្រោះមហន្តរាយភូមិ(VDC) ការចូលរួមរបស់ស្ត្រីត្រូវបានលើកទឹកចិត្តដោយទាមទារចាំបាច់ឱ្យមានយ៉ាងតិចតំណាងស្ត្រីចំនួន៤០ភាគរយ។គណៈកម្មាធិការទាំងនេះត្រួតពិនិត្យលើការរៀបចំផែនការ និងការអនុវត្តគម្រោងនិងសមាជិករបស់ខ្លួនដែលបានជ្រើសរើសនៅក្នុងកិច្ចប្រជុំតំណាងអ្នកភូមិ។ ជាលទ្ធផល ការចូលរួមរបស់ស្ត្រីនៅក្នុង VDC ទាំងស្ត្រីនិងបុរសនៅក្នុងភូមិបានធ្វើឱ្យមានការយល់ដឹងកាន់តែច្រើនពីការចូលរួមនានារបស់ស្ត្រីក្នុងវិស័យសាធារណៈ។ ក្នុងអំឡុងកិច្ចពិភាក្សាក្រុមគោលដៅមួយ អ្នកភូមិជាបុរសម្នាក់បានលើកឡើងថា៖ «ជាច្រើនទសវត្សរ៍មកហើយ នៅក្នុងភូមិរបស់ពួកយើងមិនមានថ្នាក់ដឹកនាំភូមិជាស្ត្រីនោះទេ។ អ្នកដឹកនាំជាស្ត្រីចុងក្រោយគឺនៅក្នុងឆ្នាំ១៩៧០ អំឡុងពេលបដិវត្តន៍វប្បធម៌។ ស្ត្រីមានសមត្ថភាពធ្វើជាអ្នកដឹកនាំ។»

ជាមួយគ្នាដែរ ការផ្លាស់ប្តូរបទដ្ឋានយេនឌ័រ និងតួនាទីយេនឌ័រ

បែបប្រពៃណី គឺមិនងាយស្រួលធ្វើនោះទេ។ សមត្ថភាពរបស់ស្ត្រីក្នុងការដើរតួនាទីយ៉ាងសកម្មក្នុងVDCអាស្រ័យលើកម្រិតការអប់រំ បទពិសោធន៍ ទំនាក់ទំនងរបស់ពួកគេជាមួយអ្នកភូមិដ៏ទៃទៀត និងឥរិយាបថនិងការសហការជាមួយសមាជិកដទៃទៀតនៃVDC ។ក្នុងសហគមន៍មួយចំនួនស្ត្រីឈានទៅដល់ការបោះចង់ចោលនូវអាទិភាពអត្តសញ្ញាណផ្ទាល់របស់ពួកគេនៅក្នុងការពិភាក្សាការធ្វើសេចក្តីសម្រេចជាផ្លូវការដោយសារភាពគ្របដណ្តប់បែបប្រពៃណីនៃទស្សនៈបុរស នឹងការអនុវត្តវប្បធម៌។ ក្នុងភូមិមួយចំនួន ស្ត្រីត្រូវបានរៀបចំជាក្រុមបំបែកចេញពីគ្នា - ជាញឹកញាប់ តាមរយៈដំណើរការការប៉ាន់ប្រម៉ាណភាពងាយរងគ្រោះ និងសមត្ថភាព (VCA) - ក្នុងគោលបំណងដើម្បីឱ្យពួកគេមានសំឡេងកាន់តែច្រើន និងដោះស្រាយបញ្ហារបស់ពួកគេ។

វិធីសាស្ត្រសកម្មជាមុនរបស់គម្រោងចំពោះការបង្ហាញសមតុល្យយេនឌ័រកាន់តែច្រើន បានចូលរួមចំណែកកំណត់នូវតួនាទីជាក់លាក់របស់បុរសនិងស្ត្រីក្នុងការឆ្លើយតបទៅនឹងគ្រោះមហន្តរាយ ការបង្កើនឱកាសសម្រាប់ស្ត្រីដើម្បីទទួលជំនាញថ្មីដែលមានគុណតម្លៃអាចផ្តល់នូវអត្ថប្រយោជន៍សម្រាប់គ្រួសារ និងសហគមន៍របស់ពួកគេនិងការទទួលស្គាល់កាន់តែទូលំទូលាយពីតួនាទីដ៏សំខាន់របស់ស្ត្រីនៅក្នុងការគ្រប់គ្រងគ្រោះមហន្តរាយ។ ដើម្បីធានាការចូលរួមប្រកបដោយសមតុល្យយេនឌ័រគោលដៅនៃភាពស្មើគ្នានៃអ្នកតំណាងបុរស និងស្ត្រីជាមេគ្រួសារ ត្រូវបានកំណត់សម្រាប់ការជ្រើសរើសអ្នកស្ម័គ្រចិត្តគម្រោង និងសម្រាប់អ្នកទាំងឡាយណាដែលបានទទួលវគ្គបណ្តុះបណ្តាលភាពត្រៀមបង្ការគ្រោះមហន្តរាយនិងការជួយសង្គ្រោះបឋម។ការចូលរួមស្មើតែសម្រេចបាន ៤០ភាគរយជាស្ត្រី។

អ្នកស្ម័គ្រចិត្តដើរតួនាទីយ៉ាងសំខាន់៖ ពួកគេសម្របសម្រួលវគ្គបណ្តុះបណ្តាល ផ្សព្វផ្សាយការអប់រំ និង សម្ភារទំនាក់ទំនងរៀបចំហាត់សមត្រៀមបង្ការទប់ទល់នឹងគ្រោះមហន្តរាយនិងផ្តល់ការផ្សព្វផ្សាយទៅដល់គ្រួសារនានា។ អ្នកស្ម័គ្រចិត្តស្ត្រី ក៏ដើរតួនាទីសំខាន់ដែរនៅក្នុងការចល័តស្ត្រីផ្សេងទៀតនៅក្នុងសហគមន៍។ VDCចាត់ចែងភារកិច្ចផ្សេងៗដោយជាក់លាក់សម្រាប់អ្នកស្ម័គ្រចិត្តខាងផ្នែកភាពត្រៀមបង្ការទប់ទល់នឹងគ្រោះមហន្តរាយ និងការឆ្លើយតបទៅនឹងគ្រោះមហន្តរាយ អាស្រ័យតាមកម្លាំងពលំ និងជំនាញរបស់ពួកគាត់។ ឧទាហរណ៍ អ្នកស្ម័គ្រចិត្តបុរសមានទំនួលខុសត្រូវផ្នែកសម្របសម្រួលការឆ្លើយតបទៅនឹងគ្រោះអាសន្ន និងការពារមនុស្សចាស់ជរា និងមនុស្សពិការ ចំណែកអ្នកស្ម័គ្រចិត្តស្ត្រីមានទំនួលខុសត្រូវការប្រឹក្សាយោបល់ផ្នែកទំនាក់ទំនងនិងខាងចិត្តសាស្ត្រ។ការបែងចែកការងារនេះត្រូវបានក្លាយជាការឆ្លុះបញ្ចាំងនៃតួនាទីបំពេញបន្ថែមរបស់បុរស និងស្ត្រីក្នុងសហគមន៍។

ស្ត្រីយល់ថាវគ្គបណ្តុះបណ្តាលគម្រោងពិតជាមានលក្ខណៈជាក់ស្តែង និងផ្តល់ចំណេះដឹងថ្មីក្នុងការថែរក្សាគ្រួសាររបស់ពួកគេ និងការបម្រើដល់សហគមន៍។ ក្នុងភូមិមួយ ស្ត្រីបានរៀបចំការប្រកួតប្រជែងសំណួរស្តីពីភាពត្រៀមបង្ការទប់ទល់នឹងគ្រោះមហន្តរាយដើម្បីប្រារព្ធទិវានារីអន្តរជាតិ។ ព្រឹត្តការណ៍នេះបានទាក់ទាញស្ត្រី និងបុរសពីសហគមន៍ និងប្រព័ន្ធផ្សព្វផ្សាយក្នុងតំបន់។ ព្រឹត្តការណ៍ប្រភេទទាំងនេះបានបង្កើនភាពមើលឃើញរបស់ស្ត្រីដែលជាភាគីពាក់ព័ន្ធសហគមន៍។ ទាំងបុគ្គលិកការិយាល័យផ្នែក GXRC និងសមាជិកសហគមន៍ រួមមានថ្នាក់ដឹកនាំភូមិ និងអ្នកភូមិជាបុរសបែរមកទទួលស្គាល់ពីសារៈសំខាន់របស់អ្នកស្ម័គ្រចិត្តជាស្ត្រី។ ទោះបីយ៉ាងណា ស្ត្រីមួយចំនួនបាននិយាយពីភាពចាំបាច់បង្កើតការលើកទឹកចិត្ត និងឱកាសឱ្យកាន់តែច្រើនសម្រាប់ស្ត្រីវ័យចំណាស់ស្ម័គ្រចិត្ត។ ស្ត្រីមាននិន្នាការមិនសកម្មដូចបុរសពីព្រោះពួកគេកាន់តែចាស់ដោយសារទំនួលខុសត្រូវច្រើនលើការងារផ្ទះសម្បែង និងជាអ្នកថែទាំ។

ប្រភព: (IFRC ឆ្នាំ២០២០)

**ចំណុចពិភាក្សា**

សូមសាកសួរអ្នកចូលរួមដើម្បីកំណត់សកម្មភាពសំខាន់ៗនៅក្នុងករណីសិក្សាដែលបានជួយជំរុញលើកទឹកចិត្តការចូលរួមប្រកបដោយអត្ថន័យរបស់ស្ត្រី

តម្រុយសម្រាប់អ្នកសម្របសម្រួល

- ៤០ភាគរយតំណាងឱ្យស្ត្រីនៅក្នុងគណៈកម្មាធិការគ្រោះមហន្តរាយភូមិ (VDCs)
- រៀបចំបំបែកក្រុមតែស្ត្រីផ្សេង
- អ្នកស្ម័គ្រចិត្តជាពិសេសអ្នកស្ម័គ្រចិត្តជាស្ត្រី
- វគ្គបណ្តុះបណ្តាលជាក់ស្តែង និង ឱកាសសម្រាប់ស្ត្រីដើម្បីទទួលបាននូវទិដ្ឋភាពនៃទស្សនីយភាពតំបន់

## ការបង្កើតផែនការផ្អែកលើសហគមន៍

យុទ្ធសាស្ត្រសំខាន់ផ្សេងទៀតដើម្បីបង្កើតការអនុវត្តគម្រោង CCDRR គឺនៅពេលសហគមន៍ ជាពិសេសស្ត្រីត្រូវបានបំពាក់នូវឧបករណ៍សំខាន់ៗ និងត្រូវបានសម្របសម្រួល ដើម្បីធ្វើការប៉ាន់ប្រម៉ាណភាពងាយរងគ្រោះនិងបង្កើតផែនការការបន្សាំនានារបស់ពួកគេផ្ទាល់។ ដំណើរការប្រំដែលមួយនេះអាចធ្វើឱ្យស្ត្រីកាន់តែទទួលការផ្តល់ព័ត៌មានកាន់តែច្រើននិងមានសំឡេងកាន់តែមានអត្ថន័យ និងម្ចាស់ការលើការសម្រេចចិត្តដែលជះឥទ្ធិពលលើជីវិតរបស់ពួកគេ។មានឧបករណ៍ប៉ាន់ប្រម៉ាណភាពងាយរងគ្រោះដែលមានការចូលរួមនិងផែនការការបន្សាំមួយចំនួនដែលអាចប្រើបាន (សូមសំណៅឯកសារទី ១៣)។

ទោះបីយ៉ាងណាអ្វីដែលសំខាន់គឺត្រូវធានាថាដំណើរការរៀបចំផែនការបន្សាំផ្អែកលើសហគមន៍ត្រូវបានបង្កើតឡើង។ នេះត្រូវការការអន្តរាគមន៍ជាក់លាក់ ព្រមទាំងធានានូវ៖

ក) ស្ត្រីត្រូវជាផ្នែកនៃក្រុមសម្របសម្រួលវាយតម្លៃនិងផែនការ។ នេះទាមទារនៅពីរកម្រិត៖ ទីមួយនៅកម្រិតអង្គការ និងទីពីរនៅកម្រិតសហគមន៍។ ជាពិសេស ស្ត្រីមកពីសហគមន៍ក៏ត្រូវការការបណ្តុះបណ្តាលមិនត្រឹមតែឧបករណ៍ និងដំណើរការប៉ុណ្ណោះទេប៉ុន្តែថែមទាំងជំនាញសម្របសម្រួលផងដែរ។

ខ) ក្រុមសម្របសម្រួលទាំងមូលត្រូវបានបណ្តុះបណ្តាលពីយេនឌ័រ។ នេះមានសារសំខាន់មិនមែនត្រឹមតែធានានូវក្រុមសម្របសម្រួលដែលយល់ដឹងពីការធានានូវការចូលរួមប្រកបដោយអត្ថន័យរបស់ស្ត្រីនៅក្នុងដំណើរការប៉ុណ្ណោះទេប៉ុន្តែក៏ត្រូវដឹកនាំដំណើរការដើម្បីនាំយកនូវកង្វល់របស់យេនឌ័រនិងបញ្ហារបស់ស្ត្រីដែលលេចធ្លោដែរ។

គ) ស្ត្រីជាផ្នែកនៃដំណើរការការប្រឹក្សាយោបល់ និងការរៀបចំផែនការ។នេះពាក់ព័ន្ធនឹងការធានាលំហាត់ភាគច្រើនត្រូវធ្វើឡើងដាច់ដោយឡែកពីគ្នាជាមួយក្រុមស្ត្រី។

ង) ការធ្វើការវិភាគយេនឌ័រដោយការប្រើក្របខ័ណ្ឌMoserឬក្របខ័ណ្ឌHarvardជាផ្នែកនៃការប៉ាន់ប្រម៉ាណភាពងាយរងគ្រោះទាំងបុរស និងស្ត្រី ដើម្បីជួយសហគមន៍យល់ដឹងពីកង្វល់របស់យេនឌ័រនៅក្នុង CCDRR និងផែនការក៏ដូចគ្នាដែរ។

ខាងក្រោមជាគោលការណ៍គន្លឹះសម្រាប់ដំណើរការរៀបចំផែនការ CBA និងសមាសភាពយេនឌ័រដូចគ្នា។

**តារាងទី ១១៖ គោលការណ៍គន្លឹះសម្រាប់ដំណើរការការរៀបចំផែនការ CBA**

| គោលការណ៍ | សមាសភាពមូលដ្ឋាន | សមាសភាពយេនឌ័រ |
|---|---|---|
| វិមជ្ឈការ និងការចូលរួម | សហគមន៍ដើរតួរជាផ្នែកសំខាន់មួយនៅក្នុងការវិភាគបញ្ហា ការកំណត់អត្តសញ្ញាណ និងការចាត់អាទិភាពដំណោះស្រាយ | ស្ត្រីជាផ្នែកដែលមានស្រាប់នៅក្នុងសហគមន៍ហើយពួកគេត្រូវតែចូលរួមប្រកបដោយអត្ថន័យនៅក្នុងដំណើរការការរៀបចំផែនការ |
| ការកសាងធនធានមូលដ្ឋាន | វាមានសារសំខាន់ដើម្បីកសាងលើភាពខ្លាំងដែលមានស្រាប់ និងធនធានដែលមានក្នុងសហគមន៍។ | ស្ត្រីមិនត្រឹមតែមានទំនាក់ទំនងជិតស្និតទៅនឹងធនធានធម្មជាតិ និងហេដ្ឋារចនាសម្ព័ន្ធប៉ុណ្ណោះទេ ប៉ុន្តែក៏មានអាទិភាពខុសគ្នាក្នុងការប្រើប្រាស់ និងថែរក្សាដែរ។ |
| ការរួមបញ្ចូលចំណេះដឹងមូលដ្ឋាន និងវិទ្យាសាស្ត្រ និងការបង្កើតរួមគ្នានូវដោះស្រាយ | ការរួមបញ្ចូលចំណេះដឹងមូលដ្ឋានតាម ព័ត៌មានវិទ្យាសាស្ត្រ និងការរកឃើញពីការស្រាវជ្រាវ ជួយធានានូវការកសាងផែនការសកម្មភាពការបន្សាំពាក់ព័ន្ធនឹងមូលដ្ឋានរឹងមាំ។ | ស្ត្រីជាប្រភពដ៏សំខាន់នៃចំណេះដឹងមូលដ្ឋានទាំងសកម្មភាពផលិត/រកប្រាក់កម្រៃ និងរស់រានមានជីវិត។ ពួកគេក៏មានលក្ខណៈវិនិច្ឆ័យខុសៗគ្នាក្នុងការជ្រើសរើស ជម្រើសនៃការបន្សាំដែរ។ |
| ការសន្ទនាបែបសហការ និងការសិក្សាឆ្លង | ធ្វើឱ្យមានលំហរសម្រាប់កិច្ចសន្ទនា និងការសិក្សាពីរបែបរវាងសហគមន៍ និងភាគីពាក់ព័ន្ធ រួមទាំងអាជ្ញាធរមូលដ្ឋាន អ្នកស្រាវជ្រាវ និងសហគ្រិនសង្គម។ | ស្ត្រីគ្រប់អាយុ និងសាវតាសង្គម-សេដ្ឋកិច្ចត្រូវចូលរួមនៅក្នុងដំណើរការនេះ។ វេទិកាផ្តល់សំឡេងសម្រាប់កង្វល់ពាក់ព័ន្ធនឹងយេនឌ័រ |
| ភាពបត់បែន និងបរិបទជាក់លាក់ | ទាក់ទងនឹងភាពពិតជាក់ស្តែងនៅមូលដ្ឋានផែនការត្រូវតែមានបរិបទជាក់លាក់បំផុតនិងងាយស្រួលកែប្រែស្របតាមគោលបំណងជាក់លាក់ការផ្តោតតាមវិស័យដែលបានជ្រើសរើស និងធនធានដែលមានដើម្បីធ្វើដំណើរការនេះ។ | ទាក់ទងនឹងវិស័យដែលដោះស្រាយតម្រូវការជាក់ស្តែងរបស់ស្ត្រី និងការបែងចែកធនធានដូចគ្នា។ ភាពបត់បែននៅកម្រិតមូលដ្ឋានក៏អាចធ្វើឱ្យចំណុចរួមអន្តរវិស័យកាន់តែប្រសើរឡើង មានសារសំខាន់ណាស់សម្រាប់ការដោះស្រាយកង្វល់ពាក់ព័ន្ធនឹងយេនឌ័រ |
| ឯកសារ និងការទំនាក់ទំនង | ភាពពាក់ព័ន្ធនៅមូលដ្ឋានបង្កើនកម្រិតអត្ថប្រយោជន៍ និងថែមទាំងផ្តល់លំហរសម្រាប់ការអះអាងជាថ្មី។ ក្លាយជាចំណុចចាប់ផ្តើមសម្រាប់ការលើកកម្ពស់ការយល់ដឹងនិងសកម្មភាពផ្លាស់ប្តូរឥរិយាបថ។ល។ | អាចទំនាក់ទំនងជាភាសាមូលដ្ឋាននិងមធ្យោបាយមូលដ្ឋាន និងទម្រង់ដែលជួយឱ្យឈានទៅដល់មនុស្សគ្រប់គ្នា ជាពិសេសស្ត្រី និងបុរសអនក្ខរកម្ម និងពិការភាព។ |
| ការតាមដាន និងការវាយតម្លៃ | វាក៏មានសារសំខាន់ដែរក្នុងការកំណត់នូវសូចនាករ និងយន្តការតាមដាន ដើម្បីតាមដានវឌ្ឍនភាពផែនការ។ ប្រព័ន្ធ M&E ចាំបាច់ត្រូវរៀបចំឡើង ដើម្បីព័ត៌មានថ្មីផ្សេងៗ និងការសិក្សានានា ដែលត្រូវដាក់បញ្ចូលទៅក្នុងផែនការ និងសកម្មភាពនានា។ | ការផ្តោតជាក់លាក់មួយគួរតែមានលើការតាមដាននរណាធ្វើសេចក្តីសម្រេចការអនុវត្តសំខាន់ៗនរណាគ្រប់គ្រងលើដំណើរការនរណានឹងទទួលបានអត្ថប្រយោជន៍និងនរណាត្រូវបានចាកចេញអំឡុងពេលអនុវត្តន៍។ ការបញ្ចូលស្ត្រីទាំងអស់ ក្រុម LGBTIQ ដោយមិនគិតពីឋានៈ វណ្ណៈ ជាតិសាសន៍ អាយុ ពិការភាព គួរតែត្រូវបានតាមដាន។ល។ |

ប្រភព៖ យកពី (Care Vietnam ឆ្នាម២០១៥)

## ការទំនាក់ទំនង និងការចែករំលែកចំណេះដឹង

ការស្រាវជ្រាវ (Carmin et al ឆ្នាំ២០១៣) បង្ហាញថាការចូលរួមរបស់ប្រជាជន បរិយាបន្នការចូលរួម និងសមធម៌រួមបញ្ចូលជាមួយការពិភាក្សា និងការបញ្ចុះបញ្ចូលដោយប្រុងប្រយ័ត្ន អាចបង្កើតសកម្មភាពដែលទទួលស្គាល់ស្របច្បាប់ និងប្រកបដោយប្រសិទ្ធភាព នៅពេលជម្រើសមានភាពមិនប្រាកដប្រជា និងស្មុគស្មាញ។ វាទាមទារឱ្យមានការសហការភាគីពាក់ព័ន្ធច្រើន និងក្របខ័ណ្ឌដែលអាចសម្រួលដល់ការផ្ទេរចំណេះដឹងឆ្លងគ្នា ដើម្បីអាចទទួលស្គាល់ស្របច្បាប់ និងធ្វើសេចក្តីសម្រេចចិត្ត។ ក្របខ័ណ្ឌបែបនេះលើកឡើងដោយ (Revi et al ឆ្នាំ២០១៤) និងត្រូវបានអនុម័តដោយ IIED (ឆ្នាំ២០១៥) និងត្រូវបានចែករំលែកនៅក្នុងរូបទី ៤០។

ទោះបីយ៉ាងណា ការផ្ទេរចំណេះដឹង ធម្មតាមិនអាចបណ្តាលឱ្យមានការផ្លាស់ប្តូរឥរិយាបថទេ។ភាពមិនប្រាកដប្រជាទាក់ទិននឹងហានិភ័យអាកាសធាតុ និងបទដ្ឋានយេនឌ័រដែលមានស្រាប់ដែលបានចាក់ឬសនៅក្នុងឥរិយាបថ តាមរយៈលក្ខខណ្ឌសង្គមច្រើនឆ្នាំ បណ្តាលឱ្យមានភាពមិនប្រក្រតីផ្នែកឥរិយាបថជាច្រើន ដែលសូម្បីតែពេលដោះស្រាយដោយហេតុផលក៏មិនមានសកម្មភាព។ ការដោះស្រាយកង្វល់ពាក់ព័ន្ធនឹងយេនឌ័រក្នុង CCDRR ទាក់ទងនឹងការចេញពីការតស៊ូទាំងសកម្មភាពផ្លូវចិត្ត និងផ្លូវកាយរបស់យើងនាពេលបច្ចុប្បន្ន។ ជាពិសេស ការផ្លាស់ប្តូរឥរិយាបថមនុស្សបែបនេះអាចកើតឡើងតែនៅពេលមានការបង្ខិតបង្ខំ ឬ ភ័យខ្លាច ឬនៅកន្លែងមានការលើកទឹកចិត្តផ្សេងៗគ្នាដើម្បីផ្លាស់ប្តូរ។

អង្គការសង្គមស៊ីវិល និងរដ្ឋាភិបាលមូលដ្ឋានត្រូវការអនុវត្តយុទ្ធសាស្ត្រទំនាក់ទំនងច្នៃប្រឌិត ដើម្បីបង្កើតឱ្យមានការផ្លាស់ប្តូរឥរិយាបថពិតប្រាកដ ជាពិសេស នៅកម្រិតសហគមន៍។ នៅទសវត្សរ៍ចុងក្រោយ កំណើនការយល់ដឹងពីទំនាក់ទំនងនៃការផ្លាស់ប្តូរឥរិយាបថពាក់ព័ន្ធនឹងការរីកចម្រើនខាងបច្ចេកវិទ្យាបាននាំមកនូវគំរូជាច្រើនពីការផ្លាស់ប្តូរឥរិយាបថ ជាពិសេសនៅក្នុងទំនាក់ទំនងនៃ CCDRR ដែលត្រូវបានអនុវត្ត ជាពិសេសនៅក្នុងតំបន់អាស៊ីខាងត្បូង និងអាស៊ីអាគ្នេយ៍។ នៅក្នុងតារាងបន្ទាប់ យើងនាំយករួមគ្នានូវឧទាហរណ៍ដែលបានជ្រើសរើស ដែលអាចជួយទៅដល់សហគមន៍ទាំងបុរស និងស្ត្រី ដើម្បីបង្កើតការផ្លាស់ប្តូរឥរិយាបថលើផ្នត់គំនិតសង្គម និងបទដ្ឋានយេនឌ័រ ក៏ដូចជាការផ្លាស់ប្តូរឥរិយាបថសម្រាប់ការគ្រប់គ្រងការប្រែប្រួលអាកាសធាតុ និងហានិភ័យគ្រោះមហន្តរាយនានា។

**រូបភាព ៤០៖ អន្តរទំនាក់ទំនងនៃតួអង្គផ្សេងៗគ្នានៅក្នុងកិច្ចសហការពហុភាគីពាក់ព័ន្ធ**




**គន្លឹះសម្រាប់គ្រូឧទ្ទេស**

ដាក់បញ្ចូលតំណភ្ជាប់វេបសាយនៃឧបករណ៍ដែលត្រូវបានជ្រើសរើសពីតារាងបន្ទាប់ ទៅក្នុងបទបង្ហាញរបស់អ្នក ហើយស្វែងរកវេបសាយរបស់ពួកគេដើម្បីឱ្យអ្នកចូលរួមទទួលបានគំនិតល្អប្រសើរមួយដូចគ្នា។ជាងនេះទៀតវាក៏ល្អផងដែរក្នុងការបង្ហាញទៅអ្នកចូលរួមជាវីដេអូខ្លីមួយ ដែលបង្ហាញពីផលប៉ះពាល់ដូចម្តេចខ្លះនៅលើប្រទេសបង់ក្លាដែស។ កម្មវិធីទូរទស្សន៍ Amrai Pari របស់អង្គការ BBC Media Action មាននៅទីនេះ https://www.youtube.com/watch?v=4aNdQz_LQgI និង/ឬ អំពីកម្មវិធីនេះមាននៅលើបណ្តាញយូធូប https://www.youtube.com/watch?v=d-VJ-UjM1ERk.វីដេអូពន្យល់ពីសារសំខាន់នៃការប្រើប្រាស់បច្ចេកវិទ្យាទំនាក់ទំនង ជាពិសេសឧបករណ៍ទស្សនីយភាពសម្រាប់សកម្មភាពអាកាសធាតុ។

## តារាងទី ១២៖ ឧទាហរណ៍ឧបករណ៍ទំនាក់ទំនង

| ឧបករណ៍ទំនាក់ទំនង | ការពិពណ៌នា | ឧទាហរណ៍សម្រាប់ប្រើ |
|---|---|---|
| ឥទ្ធិពលនៃការសេពគប់មិត្តភក្តិ និងបណ្ដាញដែលជំរុញការផ្លាស់ប្ដូរឥរិយាបថតាមរយៈវិធីសាស្ត្រមជ្ឈមណ្ឌល និងការនិយាយ៖ | និងក្មេងស្រីដែលទទួលបានការបណ្ដុះបណ្ដាលនៅកម្រិតមូលដ្ឋានក្លាយជា «មណ្ឌល» នៃចំណេះដឹងដែលផ្សព្វផ្សាយពាសពេញសហគមន៍នីមួយៗ តាមរយៈការប្រជុំផ្ទាល់និងការបញ្ចុះបញ្ចូលឥតឈប់ឈរ។វិធីសាស្ត្រនេះដំណើរការបាន ពីព្រោះស្ត្រីទាក់ទងដោយផ្ទាល់ទៅនឹងមិត្តភក្តិរបស់ពួកគេទាក់ទងនឹងព័ត៌មាន ដែលអនុវត្តដោយផ្ទាល់ទៅពួកគេ និងអ្នកជិតខាងពួកគេ។ | > ភាពជាដៃគូរភាពធន់សកល Mahila Housing Sewa Trust បង់ក្លាដេស និងនេប៉ាល់ |
| ល្បែងទាក់ទងនឹងការប្រែប្រួលអាកាសធាតុនិងសកម្មភាពភាពធន់៖ | «ការសិក្សាតាមរយៈល្បែងកម្សាន្ត»៖ ភាពច្នៃប្រឌិតផ្ដល់នូវវិធីសាស្ត្រនៃការបង្រៀន-ការរៀនសូត្រ ដែលធ្វើឱ្យមនុស្សពេញវ័យរៀនសូត្រតាមរយៈបទពិសោធន៍ និងការលើកទឹកចិត្ត។ វាក៏អភិវឌ្ឍជំនាញភាពជាអ្នកដឹកនាំរបស់ស្ត្រីផងដែរ ហើយផ្ដល់នូវផ្នត់គំនិតវិជ្ជមានថា «អាចធ្វើបាន»។ ជាពិសេស អាចមានសារៈប្រយោជន៍ក្នុងការជ្រើសរើសក្មេងស្រីជំទង់ និងក្មេងស្រីក្មេងៗ។ | > ការសម្ដែងធ្វើបន្សាំ មជ្ឈមណ្ឌលអាកាសធាតុកាកក្របាទក្រហម<br>> ល្បែងពស់ និងកាំជណ្ដើរ របស់ Mahila Housing Sewa Trust ឥណ្ឌា<br>> ល្បែង Ecofunopoly ឥណ្ឌូនេស៊ី |
| ការឃ្លាំមើលដឹកនាំដោយសហគមន៍/ វិទ្យាសាស្ត្រ និងសារព័ត៌មានពលរដ្ឋ៖ | បង្កើតប្រព័ន្ធនានាក្នុងសហគមន៍ដើម្បីប្រមូលនូវព័ត៌មានធាតុអាកាសទៅតាមពេលវេលាជាក់ស្ដែង និងទិន្នន័យអាកាសធាតុនិងចែករំលែកក្នុងចំណោមពួកគេសម្រាប់តាមដានការប្រែប្រួល ភាពងាយរងគ្រោះ ក៏ដូចជាដើម្បីចាត់វិធានការឱ្យទាន់ពេលវេលា។ អង្គការសង្គមស៊ីវិល បានធ្វើពិសោធជាមួយប្រព័ន្ធនានា ក្រៅពីសីតុណ្ហភាព និងកម្រិតទឹកភ្លៀង ដើម្បីពិនិត្យមើលនូវបរិមាណនិងគុណភាពទឹក ភ្នាក់ងារចម្លងជំងឺ ទឹកជំនន់ និងការលិចលង់ផងដែរ។ | > ប្រព័ន្ធប្រកាសអាសន្នព័ត៌មានសុខភាព (HIEWS) ជាប្រព័ន្ធអនឡាញដើម្បីអនុញ្ញាតមានការរាយការណ៍ប្រកបដោយការចូលរួមសម្រាប់ករណីជំងឺគ្រុនឈាមជាផ្នែកនៃ ACTIVE, Mercy Corps នៅប្រទេសឥណ្ឌូនេស៊ី<br>> វេជ្ជបណ្ឌិតកុមារសម្រាប់ការឃ្លាំមើលវិចទ័រ និងអ្នកដឹកនាំស្ត្រីសម្រាប់ការឃ្លាំមើលគុណភាពទឹករបស់អង្គការ Mahila Housing Sewa Trust ប្រទេសឥណ្ឌា |
| ការទទួលបានព័ត៌មានផ្ទាល់ខ្លួន៖ | ការប្រើការផ្ញើសារតាមទូរស័ព្ទ និងសេវាឆ្លើយតបជាសំឡេង (IVR) បានផ្ដល់ឱកាសដល់ប្រជាជនក្នុងការទទួលបានព័ត៌មានទាក់ទងនឹងការប្រែប្រួលអាកាសធាតុរួមទាំងការទទួលបានព័ត៌មានការបន្សាំនៅលើទូរស័ព្ទរបស់ពួកគាត់។ម៉ូឌែលIVRមួយចំនួនក៏មានកន្លែងហៅត្រឡប់មកវិញផងដែរ ដើម្បីជួយសហគមន៍ចែករំលែកក្ដីកង្វល់ និងការផ្ដល់យោបល់ត្រឡប់របស់ពួកគេ។ | > មជ្ឈមណ្ឌលសហគ្រាសហិរញ្ញវត្ថុខ្នាតតូច និងមជ្ឈមណ្ឌលរបស់ Awaaz De ផ្ដល់នូវវគ្គបណ្ដុះបណ្ដាលហិរញ្ញវត្ថុ និងដំបូន្មានផ្នែកអាជីវកម្មនៅក្នុងប្រទេសឥណ្ឌា។<br>> កម្មវិធី Mobile Vaani សម្រាប់ការប្រែប្រួលអាកាសធាតុ សុខភាព និងក្ដីកង្វល់របស់ជនជាតិភាគតិចនៅក្នុងប្រទេសឥណ្ឌា<br>> កម្មវិធី Farm-stack សម្រាប់កសិករអភិវឌ្ឍឡើងដោយដោយអង្គការ Digital Green នៅប្រទេសឥណ្ឌា និងអេត្យូពី។<br>> កម្មវិធី Samvad សម្រាប់សុខភាព និងអាហារូបត្ថម្ភបង្កើតឡើងដោយអង្គការ Digital Green នៅប្រទេសឥណ្ឌា។<br>> កម្មវិធីព្យាករណ៍ធាតុអាកាសសម្រាប់កសិកម្ម នៅប្រទេសបង់ក្លាដេស។ |
| សារព័ត៌មានសម្រាប់ការកសាងការយល់ដឹង៖ | ការបង្កើតក្រុមស្ម័គ្រចិត្តមួយពីសហគមន៍ ហើយបណ្ដុះបណ្ដាលពួកគេឱ្យប្រើវិធីសាស្ត្រអ្នកសារព័ត៌មាន ដើម្បីបង្កើតកម្មវិធីវិទ្យុ/ទូរទស្សន៍ និងវីឌីអូអនឡាញខ្លីៗ។ បន្ទាប់មកធនធានដែលបានបណ្ដុះបណ្ដាលហើយបង្កើតកម្មវិធីមានមាតិកាព័ត៌មានលក្ខណៈតំបន់ដែលអាចឱ្យសហគមន៍ភ្ជាប់ទំនាក់ទំនងបាន។ការចាក់បញ្ចាំងកម្មវិធីទាំងនេះនៅសហគមន៍ មិនត្រឹមតែបន្ថែមតម្លៃអប់រំប៉ុណ្ណោះ | > កម្មវិធីទូរទស្សន៍ Amrai Pari ជាកម្មវិធីផ្សព្វផ្សាយរបស់អង្គការ BBC Media Action ស្ដីពី CCDRR នៅប្រទេសបង់ក្លាដេស។<br>> កម្មវិធីជីវភាពរស់នៅជនបទថ្នាក់ជាតិ ជាផែនការដ៏ល្អមួយរបស់រដ្ឋាភិបាលសម្រាប់ផ្ដល់ភាពអង់អាចដល់ស្ត្រី និងលុបបំបាត់ភាពក្រីក្រ ដែលត្រូវបានប្រើដើម្បីចែកចាយនូវព័ត៌មានសុខភាព អាហារូបត្ថម្ភ |

**តារាងទី ១២៖ ឧទាហរណ៍ឧបករណ៍ទំនាក់ទំនង**

| ឧបករណ៍ទំនាក់ទំនង | ការពិពណ៌នា | ឧទាហរណ៍សម្រាប់ប្រើ |
|---|---|---|
| | ទេប៉ុន្តែក៏កាន់តែមានប្រសិទ្ធភាពក្នុងការពង្រីកទៅដល់ស្ត្រីផងដែរ។ | និងសេវាកម្មកសិកម្ម តាមរយៈអង្គការ Digital Green នៅប្រទេសឥណ្ឌា។<br>> អង្គការ Earth Journalism Network តំបន់អាស៊ីប៉ាស៊ីហ្វិក<br>> វិទ្យុ KBR ប្រទេសឥណ្ឌូនេស៊ី។ |
| **វេទិកាសារព័ត៌មានសង្គមអនឡាញ** | ការប្រើប្រព័ន្ធអ៊ីនធឺណិតនិងបច្ចេកវិទ្យាអនឡាញដើម្បីជួយធ្វើឱ្យប្រសើរឡើងនូវលំហូរព័ត៌មាននៅថ្នាក់ក្រោម។ | > Ushahidi ដែលជាកម្មវិធីកូដចំហរមួយសម្រាប់យុទ្ធនាការនានាដែលត្រូវបានបង្កើតឡើងនូវផែនទីរញ្ជួយដីប្រើសម្រាប់ជួយភ្ជាប់អ្នកទាំងឡាយណាដែលទទួលរងផលប៉ះពាល់ពីគ្រោះរញ្ជួយដី នៅប្រទេសនេប៉ាល់ ទៅនឹងកិច្ចខិតខំប្រឹងប្រែងផ្តល់ជំនួយកំពុងដំណើរការដែលអនុវត្តដោយរដ្ឋាភិបាល ក្រុមមិនមែនរដ្ឋាភិបាល និងក្រុមអ្នកស្ម័គ្រចិត្តនានា។ |
| **យុទ្ធនាការជាមួយប្រព័ន្ធផ្សព្វផ្សាយ** | ចាក់ផ្សាយនៅលើប្រព័ន្ធផ្សព្វផ្សាយមូលដ្ឋាននិងបណ្តាញប្រព័ន្ធសង្គមដើម្បីបង្កើតយុទ្ធនាការប្រកបដោយភាពច្នៃប្រឌិត ដែលនឹងជំរុញការយល់ដឹង និងសកម្មភាពរួម | > កម្មវិធី Poo2Loo ជាយុទ្ធនាការអនឡាញ របស់អង្គការ UNICEF។<br>> យុទ្ធនាការប្រែប្រួលអាកាសធាតុរបស់សារព័ត៌មាន The Guardian ឈ្មោះថា Keep it in the Ground។<br>> ចលនាព្រះអាទិត្យរះឡើង (The Sunrise Movement)/ចលនាអនឡាញថ្ងៃសុក្រសម្រាប់អនាគត (Fridays for Future)។<br>> កម្មវិធីការផ្តល់ភាពអង់អាចដល់ស្ត្រីវ័យក្មេងក្នុងការធ្វើសេចក្តីសម្រេចនិងការផ្តល់សេវាសាធារណៈប្រកបដោយគណនេយ្យភាព ប្រទេសកម្ពុជា។ |
| **ប្រព័ន្ធផ្សព្វផ្សាយលក្ខណៈប្រពៃណីដូចជាវិទ្យុសហគមន៍ រោងកុន តន្ត្រី និងសិល្បៈ** | | > គម្រោងចក្ខុវិស័យអាកាសធាតុរបស់Greenpeace សហរដ្ឋអាមេរិក។<br>> ការប្រកួតប្រជែងកំណាព្យការប្រែប្រួលអាកាសធាតុរបស់ជែនជីកោះ Fiji និង Kathy Jetnil-Kiiner នៅកោះ Marshall។<br>> ការតាំងឡើងការងារបែបសិល្បៈធ្វើការលើការប្រែប្រួលអាកាសធាតុរបស់ Olafur Eliasson និង Benjamin Wong។ |

## ការតាមដាន និងវាយតម្លៃរំញោចយេនឌ័រ

ការតាមដាននិងវាយតម្លៃរំញោចយេនឌ័រ (M&E) សំដៅដល់ការត្រួតពិនិត្យឡើងវិញនូវដំណើរការ និងផលប៉ះពាល់នៃកម្មវិធីនិងគម្រោងការប្រែប្រួលអាកាសធាតុ ដោយការប្រើទស្សនៈយេនឌ័រ ដែលនឹងទទួលស្គាល់នូវលទ្ធផលខុសគ្នាសម្រាប់ស្ត្រី និងបុរស ថាតើតាមផែនការ ឬអត់។ ដើម្បីបង្កើតផែនការតាមដាន និងវាយតម្លៃរំញោចយេនឌ័រប្រកបដោយប្រសិទ្ធភាពមួយ សហគមន៍ Igbuzor (ឆ្នាំ២០០៦) បានបង្ហាញនូវក្របខ័ណ្ឌមួយដែលដាក់បញ្ចូលទិន្នន័យមូលរំញោចយេនឌ័រ និងសូចនាករវឌ្ឍនភាព និងដំណើរការមួយដែលដាក់បញ្ចូលភាគីពាក់ព័ន្ធទាំងអស់ទាំងបុរសនិងស្ត្រី នៅក្នុងដំណើរការតាមដាន។ កំណែថ្មីក្របខ័ណ្ឌនេះ ត្រូវបានបង្ហាញនៅក្នុងរូបភាព ៤១ (BNRCC ឆ្នាំ២០១១)។

## តារាងទី ១២៖ ឧទាហរណ៍ឧបករណ៍ទំនាក់ទំនង

### តើតាមដានអ្វី?

- ដំណើរការ ទិន្នផល លទ្ធផល ផលប៉ះពាល់
- ការវាស់វែងច្បាស់លាស់លើការចូលរួម និងផលប៉ះពាល់លើស្ត្រី និងបុរស
- ប្រមូលទិន្នន័យបែបគុណភាព និងបរិមាណដែលអាចផ្ទៀងផ្ទាត់បានការបែងចែកភេទ និង អាយុ

### តើត្រូវធ្វើការតាមដាននិងវាយតម្លៃនៅពេលណា

- ការតាមដានត្រូវបានធ្វើឡើងតាមកាល វិភាគជាបន្តបន្ទាប់ ដោយធ្វើឡើងប្រចាំខែ ឬប្រចាំត្រីមាស ការវាយតម្លៃធ្វើឡើងនៅចុងបញ្ចប់របស់គម្រោង

### តើត្រូវធ្វើការតាមដាននិងវាយតម្លៃយ៉ាងដូចម្តេច

- នៅក្នុងលក្ខណៈដែលមានការចូលរួមជាមួយវិធីសាស្ត្រដែលសមស្របសម្រាប់ស្ត្រី និងបុរស មានការចូលរួមពីភាគីពាក់ព័ន្ធ

### តើអ្នកណាជាអ្នកធ្វើការតាមដាននិងវាយតម្លៃ

- ក្រុមការងារអនុវត្តគម្រោង
- ភាគីពាក់ព័ន្ធឯករាជ្យ
- សមាជិកសហគមន៍
- អ្នកបង្កើតគោលនយោបាយ អ្នកជំនាញខាងប្រធានបទយកមកពិភាក្សា

### ត្រូវធ្វើអ្វីជាមួយនឹងការតាមដាននិងវាយតម្លៃ

- វិភាគទិន្នន័យដើម្បីរកឱ្យឃើញភាពភាពជោគជ័យ និងបញ្ហាប្រឈម
- បង្កើតប្រព័ន្ធរក្សាទុកឯកសារ និងទិន្នន័យការវាយតម្លៃគោលនយោបាយដើម្បីកែសម្អរគោលនយោបាយដើម្បីកែតម្រូវអតុល្យភាពយេនឌ័រ

### ការចំណាយដែលពាក់ព័ន្ធ

- ធានាឱ្យបាននូវការរៀបចំថវិកាសមស្របសម្រាប់សកម្មភាពតាមដាននិងវាយតម្លៃ ការផ្តល់សម្ភារនិងភស្តុភា និងរចនាសម្ព័ន្ធតាមដាននិងវាយតម្លៃរំញោចយេនឌ័រប្រកបដោយប្រសិទ្ធភាព

ប្រភព៖ Igbuzor (ឆ្នាំ២០០៦)

## សូចនាករដែលមានទស្សនៈយេនឌ័រ

សមាសភាគស្នូលមួយនៃការតាមដានលទ្ធផលយេនឌ័រ គឺជារូបមន្តនៃសូចនាករទិន្នន័យគណនាតាមភេទនិងសូចនាករដែលមានទស្សនៈយេនឌ័រនៅគ្រប់កម្រិតទាំងអស់នៃលទ្ធផលទិន្នផលនិងសមិទ្ធផល។ សូចនាករ អ្នកទទួលផលគ្រប់កម្រិតទាំងអស់និងគោលបំណង គួរតែបែងចែកតាមភេទ (ព្រមទាំងអាយុ ថ្នាក់ពិការភាព និន្នាការផ្លូវភេទ ប្រភពជាតិសាសន៍។ល។ ដើម្បីកំណត់ក្រុមតូចៗ មានបុរស និងស្ត្រី)។ ឧទាហរណ៍ ជាជាងផ្តោតតែទៅលើស្ត្រី សូចនាករមួយអាចពិនិត្យមើលជាក់លាក់ទៅលើការកែលម្អសម្រាប់ស្ថានភាពស្ត្រីជនជាតិដើមភាគតិចដែលជួបប្រទះនឹងបញ្ហាប្រឈមផ្សេងយ៉ាងខ្លាំង មិនត្រឹមតែកើតចេញពីបុរសជនជាតិដើមភាគតិចដូចគ្នាទេ (ជាប់ទាក់ទងនឹងការបែងចែកពលរដ្ឋតាមយេនឌ័រនៅក្នុងវប្បធម៌ជនជាតិដើមភាគតិច)ប៉ុន្តែក៏កើតចេញពីស្ត្រីដទៃទៀតផងដែរ។ រូបភាព ៤២ ផ្តល់នូវឧទាហរណ៍នៃសូចនាករការបែងចែកទិន្នន័យតាមភេទក្នុងផ្នែកផ្សេងៗ។

លើសពីនេះទៀត កម្មវិធី និងគម្រោងនានា ក៏អាចមានជាសកម្មភាពនានាផងដែរសម្រាប់សម្រេចបាននូវសមភាពយេនឌ័រ ឬការផ្តល់ភាពអង់អាចដល់ស្ត្រីជាសូចនាករដែលលើសពីការបែងចែកតាមភេទរបស់អ្នកទទួលផល។ ឧទាហរណ៍ ខណៈដែលសូចនាករបែងចែកតាមភេទ អាចវាស់វែងចំនួនកសិករជាស្ត្រី និងកសិករជាបុរសដែលទទួលបានវគ្គបណ្តុះបណ្តាលស្តីពីកសិរុក្ខកម្មប្រកបដោយនិរន្តរភាពនោះ វាប្រហែលជាមិនគ្រប់គ្រាន់ដើម្បីកំណត់ថា វគ្គបណ្តុះបណ្តាលនេះ បានឆ្លើយតបទៅនឹងតម្រូវការផ្សេងគ្នាៗរបស់កសិករជាស្ត្រី និងកសិករជាបុរសនោះឡើយ។ ក្នុងករណីនេះ អាចត្រូវការមានសូចនាកររំញោចយេនឌ័រវាយតម្លៃបែបគុណវិស័យថា តើសមត្ថភាពស្ត្រី និងបុរស មានការកើនឡើងឬទេ។

សូចនាករវិធីសាស្ត្ររួមបញ្ចូលយេនឌ័រ ក៏ត្រូវឆ្លុះបញ្ចាំងឱ្យឃើញផងដែរថា គោលនយោបាយថ្នាក់កណ្តាល និងថ្នាក់តំបន់បានដាក់បញ្ចូលទស្សនៈទានយេនឌ័រកម្រិតណា (ឧទាហរណ៍ កំណើនតម្លៃគម្រោងធានារ៉ាប់រងសុខភាពអាស្រ័យតាមដំណើរការជីវិតឬការទទួលបានច្បាប់មាតុភាពនៅកន្លែងការងារ)ឬលក្ខខណ្ឌនានានៅក្នុងសេវាកម្មដែលគេផ្តល់ឱ្យ រួមមាន ការឆ្លើយតបរបស់ពួកគេទៅនឹងសិទ្ធិ និងត្រូវការនៃប្រាក់ចំណូលទាប និង/ឬ ស្ត្រី និងបុរសជនបទ (ឧទាហរណ៍ ចំនួនមន្ទីរពេទ្យនៅជនបទជាមួយនឹងការទទួលបានបណ្តាញអគ្គិសនី សុវត្ថិភាពទឹក និងអនាម័យបរិស្ថាន ឬរថយន្តសង្គ្រោះបន្ទាន់ ឬចំនួនធនាគារនៅជនបទផ្តល់នូវការទទួលបានសេវាកម្មមីក្រូហិរញ្ញវត្ថុ)។

គម្រោងនានា ក៏គួរតែបង្កើតឡើង និងតាមដានផលវិបាកអវិជ្ជមានដែលមិនគ្រោងទុកនៃគោលនយោបាយ និងកម្មវិធីវិសមភាពយេនឌ័រ(ឧទាហរណ៍ស្ត្រីដែលទទួលបានការផ្តល់ភាពអង់អាចផ្នែកសេដ្ឋកិច្ចអាចជួបប្រទះកំណើនអំពើហិង្សាក្នុងគ្រួសារពីប្តីដែលរកចំណូលបានតិចជាងការឧបត្ថម្ភធនសម្រាប់គ្រួសារទំហំធំរួមបញ្ចូលជាមួយនឹងលក្ខខណ្ឌជាក់លាក់សំដៅទៅលើស្ត្រី

អាចបង្កើនបន្ទុកការងារទ្វេដងដល់ស្ត្រី និងកង្វះពេលវេលាផ្ទាល់ខ្លួន)។ វាត្រូវកត់សម្គាល់ឃើញថា លទ្ធផល «អវិជ្ជមាន» អាចមិនមែនបង្ហាញថាកម្មវិធីបរាជ័យនោះទេប៉ុន្តែគួរតែជា«ភស្តុតាងដែលបញ្ជាក់ថា គម្រោងកំពុងដំណើរការ ហើយកំពុងបង្កើតភាពធន់ពីស្ថានភាពធ្លាប់មាន»។

| រូបភាព ៤២៖ ឧទាហរណ៍នៃសូចនាករបែងចែកតាមភេទសម្រាប់គម្រោង GEF | |
|---|---|
| KNOWLEDGE FILTERS | > Number and percentage of men and women actively participating in consultations, workshops and committee meetings.<br>> Number of women and men in decision-making positions relating to the activities or in the project context.<br>> Number and percentage of women and men serving in leadership positions relating to the areas of intervention or in the project context.<br>> Number and percentage of men and women, by social group, consulted about project plans. |
| BENEFIT SHARING | > Number of women and men benefitting from organized workshops and training opportunities within the program or project.<br>> Number of women and men receiving program or project benefits.<br>> Number of women and men benefitting from tools and resources.<br>> Number of women and men benefitting from financial investments due to program interventions.<br>> Number of women and men engaged in benefit-sharing discussions.<br>> Number of poor households that are project beneficiaries; number headed by men/women. |
| ACCESS TO RESOURCES AND SHARING | > Number of men who have ownership of land in their name.<br>> Number of women and men who have access to land, water and forest resources.<br>> Number of women and men who have knowledge of laws relating to areas of intervention.<br>> Number of women and men trained on land-right issues (e.g., land titles and tenure security).<br>> Number of women who have ownership of land in their name (e.g., land titles and tenure security).<br>> Number of women in a leadership position with regard to land, water, forest and other biological. resources (e.g., entrepreneur, manager, lead farmer). |

ប្រភព៖ មិនមានប្រភពជាក់លាក់

## ម៉ាទ្រិចតាមដានយេនឌ័រ

ម៉ាទ្រិចតាមដានយេនឌ័រ (GMMX) គឺជាប្រព័ន្ធតាមដានមួយដែលប្រើសូចនាករនៅក្នុងម៉ាទ្រិចមួយឬទម្រង់តារាង។សូចនាករមួយចំនួន គឺជាសូចនាករបរិមាណវិស័យ ដូចជា តំណាងយេនឌ័រនៅក្នុងព្រឹត្តការណ៍ ឬសកម្មភាព សូចនាករផ្សេងទៀត អាចជាសូចនាករគុណវិស័យ ដូចជា ការសង្ខេបបែបនិទានកថាពីរបៀបដែលស្ត្រី និងបុរសបានចូលរួមចំណែកក្នុងក្រុម។ សូចនាករគុណវិស័យ គឺលំបាកជាងក្នុងការរាយការណ៍ និងត្រូវបានគេរកឃើញ ពួកវាជាញឹកញាប់មិនត្រូវបានគេកត់ត្រាទុកទេ។ ទោះបីយ៉ាងណា វាមានសារសំខាន់ក្នុងការរក្សាការកត់ត្រាទុកដូចជារបៀបស្ត្រី និងបុរសចូលរួមក្នុងព្រឹត្តការណ៍ (មិនមែនតែចំនួនអ្នកចូលរួមទេ)។ឧទាហរណ៍តើស្ត្រីបានលើកឡើងនូវគំនិតរបស់ពួកគេទេហើយតើបុរសគោរពគំនិតរបស់ស្ត្រីឬទេ?ផ្នែកទីមួយនៃឧបករណ៍នេះកំណត់សកម្មភាពតាមដាន កំណត់អ្នកណាគួរធ្វើសកម្មភាពទាំងនេះ និងផ្តល់នូវសញ្ញាព្រមាន ឬបទដ្ឋាននានាដើម្បីឱ្យស្ថានភាពអាចកំណត់បានកន្លែងសកម្មភាពពិសេសដែលត្រូវធ្វើ។ ឧបករណ៍នេះ បត់បែនខ្លាំងដើម្បីប្រើ និងសម្របសម្រួលឱ្យសាកសមទៅតាមតម្រូវការស្ថានភាព។ ផ្នែកទីពីរនៃ GMMX ពន្យល់សកម្មភាពនានាដែលត្រូវការពេលណាកើតឡើងពិតប្រាកដ «សញ្ញាព្រមាន» និងសកម្មភាពអ្វីខ្លះត្រូវធ្វើ បើសិនការចូលរួមទាំងពីរភេទមានភាពខ្វីជាងគោលដៅដែលរំពឹងទុក។

**តារាងទី ១៣៖ ម៉ាទ្រិចតាមដានយេនឌ័រ**

| សកម្មភាព | អ្វីត្រូវស្វែងរក | មធ្យោបាយត្រួតពិនិត្យ | សញ្ញាព្រមាន | របៀបត្រួតពិនិត្យ | ពេលណា | សកម្មភាពដោះស្រាយសញ្ញាព្រមាន | នរណាគួរចាត់វិធានការ |
|---|---|---|---|---|---|---|---|
| ការរៀបចំផែនការផ្អែកលើសហគមន៍ | ចំនួនការចូលរួមរបស់ស្ត្រី | ការថតកិច្ចប្រជុំ CBA ទុក | ចំនួនតិចជាង ២០% នៃចំនួនអ្នកចូលរួម គឺជាស្ត្រី | បុគ្គលដែលសម្រេចចុងក្រោយលើឯកសារផែនការ គួររាយការណ៍ទៅ WS | រៀងរាល់ត្រីមាស | មូលនិធិគម្រោងផ្អែកលើ CBA មិនគួរបញ្ចេញ | ហេរញ្ញិក |
| | ចំនួនលំហាត់ធ្វើជាមួយក្រុមស្ត្រី | ឯកសារ CBA | គ្មានលំហាត់ត្រូវបានធ្វើដោយដាច់ដោយឡែកពីក្រុមរបស់ស្ត្រីនោះឡើយ លទ្ធផលមិនបានកត់ត្រានិងវិភាគដាច់ដោយឡែកនោះឡើយ | | | | |
| | ចំនួនលំហាត់ការវិភាគយេនឌ័របានធ្វើ | ឯកសារ CBA | មិនមានការវិភាគយេនឌ័រ | | | | |

**ចំណុចពិភាក្សា**

ដើម្បីសង្ខេបម៉ូឌុលនេះ សូមសាកសួរអ្នកចូលរួមថា តើឧបករណ៍មួយណាក្នុងចំណោមឧបករណ៍ខាងលើនេះ ដែលពួកគេយល់ថាពាក់ព័ន្ធខ្លាំងទៅនឹងការងាររបស់ពួកគាត់ ហើយហេតុអ្វី?

**តម្រុយសម្រាប់អ្នកសម្របសម្រួល**

> ការវាយតម្លៃយេនឌ័រ អាចធ្វើឡើងតាមរយៈវិធីសាស្ត្រចម្រុះសម្រាប់ការប្រមូលទិន្នន័យ ប៉ុន្តែ សម្រាប់ការវិភាគយេនឌ័រ តាមរយៈក្របខ័ណ្ឌ Moser ឬក្របខ័ណ្ឌ Harvard មានសារសំខាន់បំផុត។ ព័ត៌មានពីក្របខ័ណ្ឌទាំងពីរនេះពិតជាអាចដាក់បញ្ចូលក្នុងការវិភាគសមត្ថភាពនិងភាពងាយរងគ្រោះដែលក្លាយជាការប៉ាន់ប្រម៉ាណភាពងាយរងគ្រោះយេនឌ័រដ៏រឹងមាំមួយ។

> ការប៉ាន់ប្រម៉ាណរហ័សនិងការសិក្សាកំណត់វិសាលភាពអាចមានសារសំខាន់ចំពោះព័ត៌មានបន្ថែមនៃលំហាត់ការប៉ាន់ប្រម៉ាណភាពងាយរងគ្រោះដែលបានធ្វើរួចហើយ ឬដើម្បីស្វែងយល់ពីវិសាលភាពមុនមុជចូលជ្រៅទៅក្នុងការប៉ាន់ប្រម៉ាណភាពងាយរងគ្រោះតាមផ្នែក។

> មូលហេតុបញ្ហា ក្របខ័ណ្ឌដំណោះស្រាយ គឺជាឧបករណ៍មួយដែលគេអាចប្រើឆ្លងវដ្តគម្រោង ប៉ុន្តែ ប្រើជាពិសេសនៅក្នុងដំណាក់កាលរៀបចំគម្រោង។

> ឧបករណ៍ការវិភាគភាគីពាក់ព័ន្ធជួយពង្រឹងបន្ថែមនូវដំណើការអនុវត្តរំញោចយេនឌ័រតាមរយៈការរំលេចឱ្យឃើញនូវតួនាទីរបស់

> ស្ត្រីនិងអាចឱ្យមានតួនាទីមួយដាក់បញ្ចូលក្នុងផែនការផ្អែកលើសហគមន៍និងការសម្រេចសេចក្តីសម្រេចចិត្តព្រមទាំងទំនាក់ទំនងទាំងអស់ និងការចែករំលែកព័ត៌មាន និងវិធានការកសាងសមត្ថភាព។

> ម៉ាទ្រិចតាមដានយេនឌ័រគឺជាឧបករណ៍ដ៏មានសារសំខាន់សម្រាប់វាស់វែងដំណើរការការបញ្ជ្រាបយេនឌ័រនិងការសម្រេចបាននៃគោលដៅលទ្ធផលនៃវិសមភាពយេនឌ័រ។

> ទោះជាយ៉ាងណាក៏មានឧបករណ៍ជាក់លាក់មួយចំនួនសម្រាប់វាស់វែងសន្ទស្សន៍ភាពធន់របស់ស្ត្រីនិងឧបករណ៍ការប៉ាន់ប្រម៉ាណការកាត់បន្ថយភាពងាយរងគ្រោះរបស់កម្មវិធី UNDP-GEF CBA ដែលមានសារសំខាន់សម្រាប់គម្រោង CCDRR។

> ឧបករណ៍ការចូលរួមរួម និងលំហាត់អាចប្រើនៅគ្រប់ដំណាក់កាលទាំងអស់។

# លំហាត់

## លំហាត់ទី១៥៖ ក្របខ័ណ្ឌ Moser សម្រាប់ការវិភាគ និងការរៀបចំផែនការយេនឌ័រ

វត្ថុបំណងសំខាន់នៃលំហាត់នេះ គឺដើម្បីផ្តល់ឱ្យអ្នកចូលរួមនូវបទពិសោធន៍នៃការអនុវត្តដោយផ្ទាល់នូវក្របខ័ណ្ឌ Moser សម្រាប់ការវិភាគយេនឌ័រក្នុងដំណើរការរៀបចំផែនការ។

**សម្ភារដែលតម្រូវឱ្យមាន៖** ក្រដាស និង ហ្វឺត

**ដំណើរការ៖**

**ជំហានទី១៖** បែងចែងអ្នកចូលរួមជាពីរក្រុមចំនួនស្មើៗគ្នា ក្រុមតំណាងបុរស និងស្ត្រី។ បុរសអាចដើរតួនាទីរបស់ស្ត្រីបាន បើសិនជាស្ត្រីមិនមានចំនួនគ្រប់គ្រាន់ និងផ្ទុយមកវិញ។ ស្នើទៅក្រុមនីមួយៗជ្រើសរើសទីតាំង មុខរបរ និងរដូវកាលនៃជម្រើសរបស់ពួកគេ។

**ជំហានទី២៖** ស្នើក្រុមនីមួយៗរាយបញ្ជីសកម្មភាពប្រចាំថ្ងៃរបស់ពួកគេទាំងអស់ ចាប់ពីព្រហាមដល់ព្រលប់ សរសេរសកម្មភាពនីមួយៗភ្ជាប់ជាមួយនឹងម៉ោងជាក់លាក់។ ចន្លោះចាប់ពីម៉ោង ៤.០០ ព្រឹក ដល់ម៉ោង ៥.០០ព្រឹក ចាប់ពីម៉ោង៥.០០ព្រឹកដល់ម៉ោង៦.០០ព្រឹក ...ធ្វើដូចនេះរហូតដល់ចាប់ពីម៉ោង៩.០០យប់ដល់ម៉ោង ១០.០០យប់។ ទាំងពីរក្រុមត្រូវធ្វើលើផ្ទាំងសកម្មភាពដូចគ្នាដោយមានតំណាងម្នាក់ឱ្យក្រុមបុរស និងម្នាក់ទៀតតំណាងឱ្យក្រុមស្ត្រី។

**ជំហានទី៣៖** ពេលធ្វើចប់រួចរាល់ហើយ យកក្រុមបុរសមកផ្ទៀងផ្ទាត់បញ្ជីសកម្មភាពរបស់ក្រុមស្ត្រី និងផ្ទុយមកវិញ។ អំឡុងពេលដំណើរការនៃការផ្ទៀងផ្ទាត់ទិន្នន័យនេះ ការផ្លាស់ប្តូរអាចធ្វើបានបើសិនមានការយល់ព្រមទាំងអស់គ្នា។ សូមពន្យល់ថាពួកគេឥឡូវនេះនឹងធ្វើការវិភាគទិន្នន័យដោយប្រើក្របខ័ណ្ឌ Moser ( ឧបករណ៍ទី១ )។

**រូបទី ៤៣៖ តារាងគំរូក្របខ័ណ្ឌ Moser សម្រាប់លំហាត់ ១៥**

| | សកម្មភាពផលិតកម្ម/ សកម្មភាពបង្កើតប្រាក់ចំណូល | | សកម្មភាពមិនរកប្រាក់កម្រៃ/ ការងារផ្ទះឬក្នុងគ្រួសារ | | តួនាទីសង្គម/ការកម្សាន្ត | |
|---|---|---|---|---|---|---|
| | បុរស | ស្ត្រី | បុរស | ស្ត្រី | បុរស | ស្ត្រី |
| ពេលព្រឹក | | | | | | |
| ពេលរសៀល | | | | | | |
| ពេលល្ងាច | | | | | | |

**ជំហានទី៤៖** សូមគូសក្របខ័ណ្ឌលើក្តារខៀនដូចបង្ហាញខាងលើ និងសូមសួរទៅក្រុមអានសកម្មភាពរបស់ពួកគេម្តងមួយៗ និងប្រាប់ពីកូឡោនមួយណាត្រូវនឹងសកម្មភាពនោះ។ សូមណែនាំអ្នកចូលរួមពីភាពមិនប្រក្រតីនានា។ ជាញឹកញាប់ មានទំនោរដាក់សកម្មភាពកសិកម្ម និងចិញ្ចឹមសត្វពាហនៈដែលមិនទទួលបានប្រាក់កម្រៃរបស់ស្ត្រីជាការងារមិនរកប្រាក់កម្រៃ/ការងារផ្ទះឬការងារក្នុងគ្រួសារ។

**ជំហានទី៥៖** ពេលសកម្មភាពទាំងអស់សរសេរចុះរួចរាល់ហើយ សូមសួរពួកគេឆ្លុះបញ្ចាំងពីតួនាទីយេនឌ័រខុសៗគ្នានៅក្នុងសហគមន៍ និងការប្រែប្រួលអាកាសធាតុប៉ះពាល់លើបុរស និងស្ត្រីខុសគ្នាយ៉ាងដូចម្តេច។ ជាមួយគ្នានឹងដែរ ស្នើសុំពួកគេកត់សម្គាល់នូវបញ្ហាសំខាន់ៗដែលស្ត្រីប្រឈមមុខក្នុងការបំពេញតួនាទីទាំងនោះនាពេលថ្មីៗនេះហើយបញ្ហានោះរឹតតែធ្ងន់ធ្ងរឡើងដោយសារការប្រែប្រួលអាកាសធាតុ ឬអំឡុងពេលគ្រោះមហន្តរាយដូចម្តេចខ្លះ។

**ជំហានទី៦៖** បន្ទាប់មក ស្នើសុំឱ្យអ្នកចូលរួមកត់សម្គាល់នូវសកម្មភាពបន្សាំ និងការគ្រប់គ្រងហានិភ័យ ដែលចាំបាច់ធ្វើដើម្បី៖

ក ) កាត់បន្ថយការងារមិនសូវសំខាន់/បន្ទុកការងាររបស់ស្ត្រី

ខ) បង្កើនការទទួលបាននូវជីវភាពរស់នៅ និងប្រាក់ចំណូលជាសាច់ប្រាក់ដល់ស្ត្រី និង
គ)ជានាស្ត្រីមានការកើនឡើងនូវតួនាទីក្នុងការធ្វើសេចក្ដីសម្រេចនៅកម្រិតសហគមន៍ជាពិសេសទាក់ទងនឹងតួនាទីដែលត្រូវបានជ្រើសរើស។

**ជំហានទី៧៖**បន្ទាប់មកអ្នកចូលរួមគួរធ្វើសេចក្ដីសម្រេចចិត្តលើសកម្មភាពមួយណាមានសារសំខាន់នៅក្នុងគម្រោងដើម្បីជួយដល់សកម្មភាពខាងលើ។ ស្នើសុំពួកគេសម្រេចចុងក្រោយនូវផែនការសកម្មភាព និងធ្វើបង្ហាញការពិភាក្សាពេញលេញក្នុងទម្រង់ខាងក្រោមនេះ៖

**រូបទី ៤៤៖ ទម្រង់ផែនការសកម្មភាពសម្រាប់លំហាត់១៥**

| | តួនាទីទទួលបានប្រាក់កម្រៃ | តួនាទីក្នុងគ្រួសារ | តួនាទីសង្គម |
|---|---|---|---|
| តួនាទីប៉ះពាល់ដោយការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ | | | |
| ផ្នែកបញ្ហាសំខាន់ៗ (ដែលធ្លាប់មាន និងកាន់តែធ្ងន់ធ្ងរដោយការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ) | | | |
| សកម្មភាពការបន្សាំ/ការគ្រប់គ្រងហានិភ័យដែលចាំបាច់៖ | | | |
| ផែនការសកម្មភាព៖ | | | |

*ទិន្នផលនៃការសិក្សា៖* សរុបចុងក្រោយ ដោយការសួរទៅអ្នកចូលរួម តើមានសកម្មភាពផ្សេងៗទៀតទេដែលពួកគេមិនបានលើកមកដាក់ក្នុងការរៀបចំផែនការទេបើសិនការវិភាគសាវតាមិនបានធ្វើ។សូមជម្រាបទៅពួកគេថានេះជាមូលហេតុសំខាន់ក្នុងការធ្វើការវិភាគយេនឌ័រសម្រាប់គម្រោងអភិវឌ្ឍន៍។

## លំហាត់ទី១៦៖ ក្របខ័ណ្ឌ Harvard សម្រាប់ការវិភាគយេនឌ័រ

គោលបំណងសំខាន់របស់លំហាត់នេះគឺដើម្បីផ្ដល់ជូនអ្នកចូលរួមនូវបទពិសោធន៍ផ្ទាល់ភ្លាមៗអំពីការអនុវត្តក្របខ័ណ្ឌ Harward សម្រាប់ការវិភាគយេនឌ័រ។

*សម្ភារដែលតម្រូវឱ្យមាន៖* ក្រដាសតូចដែលមានសរសេរអំពីបរិច្ឆេទជីវិតដែលរៀបចំទុកជាមុន (ឧ. កសិករធ្វើស្រែ អ្នកនេសាទ កសិករដាំពោត អ្នកត្បាញ កម្មករសិប្បកម្ម។ល។។ ចូរធ្វើតាមស្ថានភាពជាក់លាក់ និងទៅតាមបរិបទឱ្យបានច្រើនតាមដែលអាចធ្វើបាន) ផ្ទាំងក្រដាសធំ និងហ្វឺត។

*ដំណើរការ៖*

**ជំហានទី១៖** បែងចែកអ្នកចូលរួមជា ៤ ទៅ ៥ក្រុម ហើយស្នើឱ្យពួកគេជ្រើសរើសក្រដាសតូចដែលមានសរសេរអំពីបរិច្ឆេទជីវិត។ ឥឡូវពន្យល់លំហាត់ទៅកាន់ពួកគេ៖

- ពួកគេត្រូវបំបែកសកម្មភាពនៅវដ្ដជីវិតនៃបរិច្ឆេទជីវិតឱ្យទៅសកម្មភាពតូចៗ។ ឧទាហរណ៍ ប្រសិនបើពួកគេកំពុងត្បាញ ពួកគេត្រូវសរសេរអ្វីទាំងអស់ដែលតម្រូវឱ្យមាន រាប់ចាប់ពីការទិញអំបោះរហូតដល់ការលក់ក្រណាត់។
- ពិភាក្សាថា តើអ្នកណា (បុរស ឬស្ត្រី) ដែលមានការទទួលខុសត្រូវច្រើនបំផុត ហើយថា តើអ្នកណាទទួលរងគ្រោះបំផុត។
- សម្រេចថា តើអ្នកណាមានការទទួលបាននិងគ្រប់គ្រងឧបករណ៍ ធនធាន និងការសម្រេចចិត្តលើសកម្មភាពនីមួយៗ។

**ជំហានទី២៖**ប្រាប់ពួកគេថាពួកគេមានពេល៣០នាទីដើម្បីពិភាក្សាអំពីកិច្ចការនេះហើយបង្ហាញការវិភាគរបស់ពួកគេនៅលើផ្ទាំងក្រដាសធំក្នុងទម្រង់ដូចមានបង្ហាញខាងក្រោម។

**ជំហានទី៣៖** នៅពេលបញ្ចប់កិច្ចការនេះហើយ ចូរស្នើឱ្យក្រុមបិទផ្សាក្រោមរបស់ពួកគេនៅលើជញ្ជាំង ហើយងាកមកធ្វើការងារជាក្រុមធំវិញ។ ស្នើឱ្យពួកគេចែករំលែកការរៀនសូត្ររបស់ពួកគេអំពីដំណើរការនេះ។ ឱ្យពួកគេឆ្លុះបញ្ចាំងដូចខាងក្រោម៖

- តើពួកគេបានចាប់ផ្តើមលំហាត់យ៉ាងដូចម្តេច ហើយតើអ្វីគឺជាបញ្ហាប្រឈមដំបូង?
- តើពួកគេបានកាត់បន្ថយបញ្ហាប្រឈមទាំងនេះយ៉ាងដូចម្តេច?
- តើការរៀនសូត្រសំខាន់ៗពីលំហាត់នេះគឺជាអ្វី?
- តើពួកគេត្រូវធ្វើអ្វីដើម្បីធានាថា ពួកគេមានព័ត៌មានដែលត្រឹមត្រូវកាន់តែច្រើន?

**ទិន្នផលនៃការរៀនសូត្រ៖** បញ្ចប់លំហាត់នេះដោយសួរអ្នកចូលរួមថាតើមានសកម្មភាពណាមួយដែលពួកគេបានខកខានមិនបានពិចារណាក្នុងការរៀបចំផែនការឬអត់ ប្រសិនបើមិនមានការធ្វើការវិភាគអំពីប្រវត្តិ។ ប្រាប់ពួកគេថា នេះគឺជាមូលហេតុដែលថា ការធ្វើការវិភាគយេនឌ័រមានសារៈសំខាន់សម្រាប់ការបង្កើតគម្រោង។

---

## លំហាត់ទី១៧៖ បង្ហាញការវិភាគយេនឌ័រ

គោលបំណងសំខាន់របស់លំហាត់នេះ គឺដើម្បីឱ្យអ្នកចូលរួមងាកមកចាប់អារម្មណ៍លើការអនុវត្តឧបករណ៍ផ្សេងៗ ហើយក៏ដើម្បីស្វែងយល់អំពីរបៀបដែលលទ្ធផលនៃការវិភាគយេនឌ័រត្រូវបានបង្ហាញឱ្យកាន់តែប្រសើរផងដែរ។

**សម្ភារដែលតម្រូវឱ្យមាន៖** សំណៅឯកសារទី១២ ចំនួនច្រើនច្បាប់។

**ដំណើរការ៖**

**ជំហានទី១៖** បែងចែកអ្នកចូលរួមទៅជា៤ក្រុមហើយផ្តល់ជូនពួកគេនូវសំណៅឯកសារទី១២។អ្នកក៏អាចបែងចែកឧទាហរណ៍ក្នុងចំណោមក្រុមផងដែរ ដោយផ្តល់ជូនក្រុមនីមួយៗពី ២ ទៅ ៣ ឧទាហរណ៍សម្រាប់ការពិភាក្សាកាន់តែប្រសើរនៅក្នុងក្របខ័ណ្ឌពេលវេលាដែលត្រូវបានផ្តល់ជូន។

**ជំហានទី២៖** ស្នើឱ្យអ្នកចូលរួមពិភាក្សាអំពីឧទាហរណ៍ក្នុងសំណៅឯកសារ ហើយឆ្លើយសំណួរដូចខាងក្រោម៖

- តើឧបករណ៍វិភាគ/ប៉ាន់ប្រមាណយេនឌ័រអ្វីដែលត្រូវបានយកមកប្រើប្រាស់នៅក្នុងឧទាហរណ៍នីមួយៗ?
- តើលទ្ធផលវិភាគយេនឌ័រអាចត្រូវបានបង្ហាញយ៉ាងដូចម្តេច? តើពួកគេរៀនសូត្របានអ្វីខ្លះពីឧទាហរណ៍ទាំងនេះ?
- សួរពួកគេថា តើឧទាហរណ៍ណាមួយដែលសាកសមបំផុតទៅនឹងការងាររបស់ពួកគេ? ហេតុអ្វី?

**ជំហានទី៣៖** ផ្តល់ពេលជូនពួកគេ ១៥នាទី ដើម្បីឆ្លុះបញ្ចាំងជាក្រុម ហើយក្រោយមកពិភាក្សាអំពីសំណួរទាំងនេះនៅក្នុងក្រុមធំ។

**ទិន្នផលនៃការរៀនសូត្រ៖** ប្រាប់ពួកគេថា វាមិនគ្រប់គ្រាន់ទេត្រឹមតែធ្វើការវិភាគយេនឌ័រ ប៉ុន្តែសំខាន់ត្រូវបង្ហាញ និងផ្សព្វផ្សាយលទ្ធផលរកឃើញរបស់ការវិភាគយេនឌ័រនេះ ដើម្បីឱ្យជះឥទ្ធិពលលើគម្រោង និងគោលនយោបាយ CCDRR នៅក្នុងតំបន់។

---

## លំហាត់ទី១៨៖ ក្របខ័ណ្ឌបុព្វហេតុ ផលវិបាក និងដំណោះស្រាយ

គោលបំណងសំខាន់របស់លំហាត់នេះ គឺដើម្បីផ្តល់ជូនអ្នកចូលរួមនូវបទពិសោធន៍ផ្ទាល់ភ្លាមៗអំពីការអនុវត្តក្របខ័ណ្ឌបុព្វហេតុផលវិបាក និងដំណោះស្រាយ។

**សម្ភារដែលតម្រូវឱ្យមាន៖** ផ្ទាំងក្រដាសផ្ទាំងធំ ប៊ិច និងឧបករណ៍សម្រាប់បញ្ចាំងភាពយន្តខ្លី។

**ដំណើរការ៖**

**ជំហានទី១៖**ចាក់បញ្ចាំងភាពយន្តខ្លីមួយដែលពាក់ព័ន្ធនឹងបញ្ហាសង្គម ឬបញ្ហា CCDRR ណាមួយ ដើម្បីបង្ហាញអ្នកចូលរួម។ ធ្វើឱ្យប្រាកដថាខ្សែភាពយន្តនេះជាខ្សែភាពយន្តនិយាយអំពីបរិបទតំបន់ហើយអ្នកចូលរួមភាគច្រើនស្ថិតក្នុងបរិបទដែលមានលើកឡើងក្នុងភាពយន្តនេះ។

**ជំហានទី២៖** ឥឡូវបែងចែកអ្នកចូលរួមជា៤ឬ៥ក្រុមហើយស្នើឱ្យពួកគេកំណត់បញ្ហាយេនឌ័រសំខាន់មួយពីភាពយន្តខាងលើ។ចូរព្យាយាមឱ្យពួកគេកំណត់បញ្ហាផ្សេងៗគ្នា ប៉ុន្តែនិយាយជាក់លាក់អំពីបញ្ហា។ ឧទាហរណ៍ ជំនួសឱ្យការនិយាយថាជំងឺថយចុះ ចូរឱ្យពួកគេកំណត់ជំងឺជាក់លាក់មួយ ឬជំនួសឱ្យការនិយាយថា ផលិតភាពទាបក្នុងការធ្វើកសិកម្ម ចូរឱ្យពួកគេនិយាយជាក់លាក់អំពីដំណាំ។ លើកទឹកចិត្តឱ្យមានការកំណត់បញ្ហាដែលមានទស្សនៈយេនឌ័រជាក់លាក់។

**ជំហានទី៣៖** ស្នើឱ្យអ្នកចូលរួមសរសេរបុព្វហេតុ និងផលវិបាក (ផលប៉ះពាល់) របស់បញ្ហានីមួយៗនៅលើប័ណ្ណឬក្រដាសតូចៗដាច់ដោយឡែកពីគ្នា។ នៅពេលពួកគេសរសេរបានយ៉ាងហោចណាស់ ១០ក្រដាសតូច/ប័ណ្ណហើយ ចូរស្នើឱ្យពួកគេបិទក្រដាសតូច/ប័ណ្ណនៅលើផ្ទាំងក្រដាសគគី។ ស្នើឱ្យពួកគេធ្វើតាមលំដាប់លំដោយដូចខាងក្រោម ខណៈដែលពួកគេបិទប័ណ្ណទាំងនោះ៖

- ដាក់ប័ណ្ណដែលមានសរសេរបញ្ហាចម្បងនៅចំកណ្តាល។
- ដាក់បុព្វហេតុទាំងអស់នៅខាងក្រោម ហើយផលវិបាកនៅខាងលើប័ណ្ណដែលមានសរសេរបញ្ហាចម្បងទាំងនោះ។

**ជំហានទី៤៖** ឥឡូវ សួរអ្នកចូលរួមថាតើអ្វីដែលបង្កឱ្យមានបុព្វហេតុនេះ ហើយបន្តបិទប័ណ្ណបន្ថែមទៅតាមហ្នឹង។ (អ្នកអាចត្រូវលាយប័ណ្ណច្របល់គ្នាសម្រាប់ការពិភាក្សា)។ ស៊ើបឱ្យកាន់តែស៊ីជម្រៅបន្ថែមទៀតតាមរយៈការសួរសំណួរថា "ហេតុអ្វីបានជាបញ្ហានេះកើតឡើង?" យ៉ាងហោចណាស់ពី ៣ ទៅ ៤ដងសម្រាប់ប័ណ្ណនីមួយៗ។ ធ្វើលំហាត់នេះឡើងវិញសម្រាប់ធ្វើការងារអំពីផលវិបាក។ សួរសំណួរថា "ដូច្នេះអ្វីនឹងកើតឡើងនៅពេលបន្ទាប់មក?"។ លើកទឹកចិត្តឱ្យអ្នកចូលរួមនិយាយអ្វីឱ្យជាក់លាក់តាមដែលអាចធ្វើទៅបាន។ ឧទាហរណ៍"ភាពក្រីក្រ"គឺជាបញ្ហាធំខ្លាំងដែលជាបុព្វហេតុមួយ(ឬផលវិបាកមួយ)ចូរឱ្យពួកគេលើកឡើងអំពីកង្វះខាតប្រាក់ឬកង្វះខាតឱកាស។ ចូរប្រាប់ពួកគេឱ្យបង្កើតដើមឈើបញ្ហាមួយ ដូចដែលពួកគេបានរៀនរួចហើយនៅក្នុងវគ្គមុន។

**ជំហានទី៥៖** ឥឡូវស្នើឱ្យអ្នកចូលរួមកំណត់ដំណោះស្រាយសម្រាប់បញ្ហានីមួយៗដាច់ដោយឡែកពីគ្នា។ ស្នើឱ្យពួកគេត្រលប់ប័ណ្ណ ហើយសរសេរដំណោះស្រាយទាំងនោះចូល។ ពួកគេក៏អាចប្រើប័ណ្ណបន្ថែមទៀតបានផងដែរប្រសិនបើចាំបាច់។ កិច្ចការនេះគួរតែនាំពួកគេឱ្យបង្កើតដើមឈើដំណោះស្រាយមួយ។

**ជំហានទី៦៖** ស្នើឱ្យអ្នកចូលរួមកំណត់អាទិភាពដំណោះស្រាយដោយផ្អែកលើភាពសំខាន់លទ្ធភាពធ្វើនៅក្នុងរយៈពេល២ឆ្នាំនិងប្រសិទ្ធភាពធនធាន។ ទិន្នផលគួរត្រូវបានបង្ហាញនៅក្នុងទម្រង់ខាងក្រោម៖

**រូបទី៤៥៖ គំរូទិន្នផលសម្រាប់លំហាត់ទី១៨**

| បុព្វហេតុ | ដំណោះស្រាយ/ សកម្មភាព | ផលវិបាក | សូនាករតាមដាន |
|---|---|---|---|
| | | | |
| | | | |

**ទិន្នផលនៃការរៀនសូត្រ៖** សង្ខេបលំហាត់នេះតាមរយៈការសួរពួកគេថា តើកិច្ចការនេះអាចត្រូវបានប្រើប្រាស់នៅក្នុងការងារផ្ទាល់របស់ពួកគេដោយរបៀបណានៅពេលពួកគេបង្កើតគម្រោង។ប្រាប់ពួកគេថាវាងាយស្រួលនៅពេលបង្កើតគម្រោងថ្មីមួយដើម្បីបំបែកបញ្ហាស្មុគស្មាញ ... ឱ្យទៅជាបញ្ហាតូចៗសម្រាប់លំហាត់នេះ។ ក្រោយមក ពួកគេអាចភ្ជាប់សកម្មភាពផ្សេងៗ ហើយកំណត់អាទិភាពសកម្មភាពទាំងឡាយណាដែលដោះស្រាយបញ្ហាបានដល់កម្រិតអតិប្បរមា។ ប្រាប់ពួកគេថា បញ្ហាដែលនៅសល់គួរត្រូវបានសន្មត់ថាមានស្ថិរភាព និង/ឬ ត្រូវបានកំណត់ថាជាកត្តាហានិភ័យនៅក្នុងការបង្កើតគម្រោង។ ចូរកុំភ្លេចលើកឡើងថា ខណៈដែលផលវិបាកទាំងអស់នឹងមានសូចនាករតាមដាននៅក្នុងដំណើរការបង្កើតគម្រោង ពួកគេគួរជ្រើសរើសសូចនាករណាដែលពួកគេនឹងអាចទទួលបានទិន្នន័យពីប្រភពដំបូងនិងប្រភពបន្ទាប់បន្សំ។

## លំហាត់ទី១៩៖ ទីផ្សារអភិវឌ្ឍន៍កម្មវិធីជាឧបករណ៍ដែលមានការចូលរួមសម្រាប់ការវិភាគយេនឌ័រនិងការរៀបផែនការបន្សាំផ្អែកលើសហគមន៍

គោលបំណងសំខាន់របស់លំហាត់នេះគឺដើម្បីពិនិត្យមើលយ៉ាងរហ័សទៅលើឧបករណ៍ដែលមានការចូលរួមមួយចំនួន។ គំនិតនេះគឺមិនមែនដើម្បីផ្តល់ជូនវិធីសាស្ត្រជាជំហានៗលម្អិតឆ្ពោះទៅកាន់ឧបករណ៍ទាំងនេះនោះទេដោយសារការធ្វើបែបនេះវានឹងក្លាយជាម៉ូឌុល

បណ្ដុះបណ្ដាលដែលចប់សព្វគ្រប់មួយនៅក្នុងម៉ូឌុលនេះតែម្ដង ប៉ុន្តែដើម្បីបង្កើតចំណាប់អារម្មណ៍របស់អ្នកចូលរួម និងលើកទឹកចិត្តពួកគេឱ្យទទួលបានឧបករណ៍ដែលអាចរកបាន។

**សម្ភារដែលតម្រូវឱ្យមាន៖** បោះពុម្ពផ្ទាំងរូបភាពដែលមានរូបភាពរបស់ឧបករណ៍នីមួយៗ (នៅលើក្រដាសទំហំ A3 និង ៥ ទៅ ៧ប័ណ្ណតូចៗ) និងសំណៅឯកសារទី១៣ ចំនួនច្រើនច្បាប់។ ដាក់ផ្ទាំងរូបភាពទាំងនោះក្នុងទម្រង់បញ្ជរ។ ក្រដាសប្រាក់ក្លែងក្លាយ (បោះពុម្ពពណ៌ក្រដាសប្រាក់ ១០០ដុល្លារអាមេរិក ឬរូបិយប័ណ្ណក្នុងស្រុកចំនួន ២០សន្លឹក និងក្រដាសប្រាក់ ២០ដុល្លារអាមេរិក ឬរូបិយប័ណ្ណក្នុងស្រុកចំនួន ៤០សន្លឹក)។ អំណោយ ឬស្ករសូកូឡាសម្រាប់អ្នកឈ្នះ។

**ការរៀបចំជាមុន៖** មួយថ្ងៃមុនពេលបើកវគ្គនេះ កំណត់រកអ្នកស្ម័គ្រចិត្តចំនួន៦ នាក់ចេញពីក្រុម ដែលមានបទពិសោធក្នុងការប្រើប្រាស់ឧបករណ៍ដែលមានការចូលរួម។ ផ្ដល់ជូនពួកគេម្នាក់ៗនូវខ្លឹមសារនិងផ្ទាំងរូបភាពរបស់ឧបករណ៍ណាមួយពីសំណៅឯកសារទី១៣។ ប្រាប់ពួកគេថាអ្នកនឹងដាក់ដំណើរការផ្សារមួយនៅថ្ងៃស្អែកហើយអ្នកត្រូវការអ្នកស្ម័គ្រចិត្តដើម្បីលក់ផ្ទាំងរូបភាពទាំងនេះ។ចំពោះអ្នកចូលរួមវិញ ឧបករណ៍នីមួយៗ (ប័ណ្ណតូច) មានតម្លៃមូលដ្ឋាន ១០០ដុល្លារអាមេរិក (ឬរូបិយប័ណ្ណក្នុងស្រុក)។ ប៉ុន្តែពួកគេអាចដំឡើងថ្លៃ ឬតថ្លៃបាន ប្រសិនបើពួកគេចង់។ ប្រាប់ពួកគេថា វានឹងប្រៀបដូចទៅនឹងការប្រកួតប្រជែងដូច្នេះដែរ។ អ្នកដែលរកប្រាក់បានច្រើនជាងគេនឹងក្លាយជាអ្នកឈ្នះ។ អ្នកស្ម័គ្រចិត្តសម្រាប់វគ្គនេះគួរតែជាមនុស្សបានសំដី និងមានចរិកប្រកួតប្រជែងពីធម្មជាតិ។ កត្តានេះនឹងធ្វើឱ្យលំហាត់កាន់តែមានភាពចាប់អារម្មណ៍។

**ដំណើរការ៖**

**ជំហានទី១៖** បំបែកអ្នកចូលរួមទៅជាក្រុមតូចៗដែលមានគ្នា ៤នាក់ក្នុងមួយក្រុម ហើយផ្ដល់ជូនពួកគេម្នាក់ៗនូវក្រដាសប្រាក់ក្លែងក្លាយ ១០០ដុល្លារអាមេរិក (ឬរូបិយប័ណ្ណក្នុងស្រុក) ចំនួន ៣សន្លឹក និងក្រដាសប្រាក់ ២០ដុល្លារអាមេរិក (ឬរូបិយប័ណ្ណក្នុងស្រុក) ចំនួន ៥សន្លឹក។ ប្រាប់ពួកគេថា ពួកគេត្រូវបង្កើតគម្រោងមួយជាមួយសហគមន៍របស់ពួកគេដោយប្រើប្រាស់ឧបករណ៍ដែលមានការចូលរួម ប៉ុន្តែច្បាប់ថ្មីមួយដែលដាក់ចេញដោយរដ្ឋាភិបាលបានទទួលស្គាល់ប៉ាតង់សម្រាប់ឧបករណ៍ទាំងនេះ ដូច្នេះពួកគេត្រូវតែទិញឧបករណ៍ទាំងនេះ។

**ជំហានទី២៖** មានផ្សារមួយនៅជិតពួកគេដែលពួកគេអាចទៅទិញឧបករណ៍ទាំងនេះបាន។ ឧបករណ៍នីមួយៗត្រូវបានលក់នៅក្នុងហាងផ្សេងៗគ្នា។ ប្រាប់ពួកគេឱ្យទិញឧបករណ៍ឱ្យបានច្រើនតាមដែលអាចធ្វើបានដោយផ្អែកលើថា តើអ្វីដែលពួកគេយល់ឃើញថានឹងមានប្រយោជន៍បំផុតសម្រាប់ការបង្កើតគម្រោង CCDRR ដែលឆ្លើយតបនឹងតម្រូវការយេនឌ័រដែលមានការចូលរួម ជាមួយនឹងសហគមន៍។ ក្រុមដែលបង្កើតជម្រើសសមហេតុផលបំផុតនឹងក្លាយជាអ្នកឈ្នះ។ដើម្បីទទួលបានជ័យជម្នះពួកគេត្រូវតែមានប័ណ្ណឧបករណ៍មួយនិងអាចមានលទ្ធភាពពន្យល់អំពីគោលបំណង និងដំណើរការរបស់ឧបករណ៍នោះផងដែរ។

**ជំហានទី៣៖** ក្រុមនីមួយៗអាចសម្រេចលើគម្រូថា តើអ្នកណានឹងទិញឧបករណ៍ទាំងនេះ ហើយថា តើនិងពួកគេទិញដោយរបៀបណា។ ផ្ដល់ពេលវេលាឱ្យពួកគេ ៥នាទីដើម្បីសម្រេចចិត្តលើកិច្ចការនេះ ហើយក្រោយមក បើកដំណើរការផ្សារ។ ប្រាប់ពួកគេថា ពួកគេមានពេល ៣០នាទីដើម្បីទិញឧបករណ៍។

**ជំហានទី៤៖** ផ្សារចាប់ផ្ដើមបើកដំណើរការ។ អ្វីៗនឹងដើរទៅមុខយឺតៗក្នុងដំណាក់កាលដំបូង ប៉ុន្តែអាចមានសំឡេងរំខានបន្តិច។ ចូរធ្វើឱ្យប្រាកដថាអ្វីៗស្ថិតនៅក្រោមការគ្រប់គ្រងនិងធានាថាគោលនំណងនិងដំណើរការរបស់ឧបករណ៍ទាំងនេះត្រូវបានពិភាក្សាគ្រប់គ្រាន់។ប្រសិនបើអ្វីៗមិនដូចទៅនឹងការយើងចង់បានរបស់យើងគ្រូឧទ្ទេសគួរនាំមុខក្នុងការសួរដូចគ្នានេះទៅកាន់អ្នកចូលរួមនិងជំរុញពួកគេឱ្យរៀនសូត្របន្ថែមទៀត។

**ជំហានទី៥៖** នៅពេលក្រុមទាំងអស់បានទិញឧបករណ៍របស់ពួកគេរួចហើយ ចូរផ្ដល់ពេលឱ្យពួកគេ ១៥នាទី ដើម្បីពិភាក្សាអំពីរបៀបដែលពួកគេនឹងបង្ហាញលទ្ធផលរកឃើញរបស់ពួកគេ។នាំពួកគេទាំងអស់គ្នាឱ្យងាកមកធ្វើការជាក្រុមធំវិញហើយចាប់ផ្ដើមធ្វើបទបង្ហាញ។ចូរឱ្យក្រុមទាំងអស់ធ្វើបទបង្ហាញខ្លីមួយ។គ្រូឧទ្ទេសរួមជាមួយអ្នកស្ម័គ្រចិត្តនឹងហៅថាតើក្រុមណាជាអ្នកឈ្នះ។គណនាចំនួនទឹកប្រាក់ដែលរកបានដោយអ្នកស្ម័គ្រចិត្តម្នាក់ៗ ហើយសម្រេចរកអ្នកឈ្នះម្នាក់ក្នុងចំណោមពួកគេ។ ចូរព្យាយាមរៀបចំអំណោយតូចៗ ឬស្ករសូកូឡាសម្រាប់អ្នកឈ្នះ។

**លទ្ធផលនៃការរៀនសូត្រ៖** បញ្ចប់លំហាត់នេះតាមរយៈការចែករំលែកថា មានឧបករណ៍ដែលមានការចូលរួមបែបនេះយ៉ាងច្រើនដែលអាចរកបាន ដែលអាចមានប្រយោជន៍ខ្លាំងសម្រាប់ការបង្កើតគម្រោង CCDRR ដែលឆ្លើយតបនឹងតម្រូវការយេនឌ័រដែលមានការចូលរួមជាមួយនឹងសហគមន៍។ អ្នកចូលរួមគួរតែស្វែងយល់បន្ថែមទៀត។ ទោះជាយ៉ាងណា ពួកគេចាំបាច់ត្រូវមានការប្រុងប្រយ័ត្នអំពីរឿងរ៉ាវមួយ ខណៈដែលប្រើប្រាស់ឧបករណ៍ដែលមានការចូលរួមទាំងនេះ។ មិនមែនគ្រប់ឧបករណ៍ទាំងអស់នោះនឹងមានការឆ្លើយតបនឹងតម្រូវការយេនឌ័រនោះទេ។ ឧបករណ៍ខ្លះជួយបង្ហាញតួនាទី របាំង និងភាពខ្លាំងរបស់យេនឌ័រ។ ពួកគេចាំបាច់ត្រូវរួមបញ្ចូលជាក់លាក់នូវឧបករណ៍បែបនេះទៅក្នុងដំណើរការរបស់ពួកគេ។ ឧបករណ៍ផ្សេងទៀតមានប្រយោជន៍ខ្លាំងជាងនេះប្រសិនបើយកមកប្រើប្រាស់ដាច់ដោយឡែកពីគ្នាជាមួយបុរស ស្ត្រី និងអត្តសញ្ញាណយេនឌ័រផ្សេងទៀតក្នុងក្រុមតូចៗ។ ដំណើរការរៀបចំផែនការដែលមានការចូលរួមគួរត្រូវបានបង្កើតឡើងដោយយកចំណុចនេះមកពិចារណា ដើម្បីធានាថា មនុស្សរាល់គ្នាមានការចូលរួមគ្រប់គ្រាន់ក្នុងដំណើរការនេះ។ នៅពេលនោះ ឧបករណ៍ទាំងនេះពិតជានឹងផ្តល់ទិន្នផលដល់ការវិភាគ និងផែនការដែលយើងចង់បាន។

---

## លំហាត់ទី២០៖ លំហាត់ផ្តល់ចំណាត់ថ្នាក់គង់ អំពី "មិនមានអ្នកណាម្នាក់ត្រូវបានទុកចោល"

គោលបំណងសំខាន់របស់លំហាត់នេះ គឺដើម្បីតម្រង់ទិសអ្នកចូលរួមជាមួយនឹងលំហាត់អំពីការតាមដាននិងវាយតម្លៃដែលមានការចូលរួម និងដើម្បីពង្រឹងទស្សនាទាន "មិនមានអ្នកណាម្នាក់ត្រូវបានទុកចោល (LNOB)"។

**សម្ភារៈដែលតម្រូវឱ្យមាន៖** ផ្ទាំងក្រដាស់ធំ ប៊ិច និងសំណៅឯកសារទី១៤ ចំនួនច្រើនច្បាប់។

**ដំណើរការ៖**

**ជំហានទី១៖** បែងចែកអ្នកចូលរួមជាបួនក្រុម ហើយស្នើឱ្យពួកគេបង្កើតសូចនាករចំនួន៥ សម្រាប់តាមដានការធ្វើសមាហរណកម្មវិធីសាស្ត្រ LNOB ទៅក្នុងគម្រោងមួយ។ ស្នើសូចនាករមួយចំនួនដូចជា ក) គណៈកម្មាធិការគ្រប់គ្រងគម្រោងមានការចូលរួមពីគ្រប់ក្រុម ខ) ស្ត្រី និងក្រុមងាយរងគ្រោះផ្សេងទៀតមានសំឡេងក្នុងការធ្វើសេចក្តីសម្រេចចិត្ត គ) សហគមន៍ងាយរងគ្រោះទាំងអស់បានទទួលអត្ថប្រយោជន៍ពីគម្រោងនេះ។ល។

**ជំហានទី២៖** ប្រាប់ពួកគេឱ្យសរសេរសូចនាករទាំង៥នេះនៅលើកង់មួយ ដោយសូនាករនីមួយៗក្លាយជាកាំកង់មួយ ដូចដែលមានបង្ហាញក្នុងរូបទី២៥។ ឥឡូវស្នើឱ្យពួកគេកំណត់ទិសដៅសម្រាប់សូចនាករនីមួយៗ ដែលពួកគេបានកំណត់។ ឧទាហរណ៍ សម្រាប់សូចនាករ "គណៈកម្មាធិការគ្រប់គ្រងគម្រោងមានការចូលរួមពីគ្រប់ក្រុម" ទិសដៅអាចមាន ៥០%-៥០% នៃការចូលរួមពីបុរសនិងស្រីដែលមកពីក្រុមងាយរងគ្រោះ។ ស្នើឱ្យពួកគេកំណត់គោលដៅអតិបរមា ហើយបន្ទាប់មកបំបែកគោលដៅអតិបរមានោះឱ្យទៅជាទិសដៅវឌ្ឍនភាព (Progressive targets)។ គួរតែមានចំណុចរីកចម្រើនចំនួន៥។ ឧទាហរណ៍ ប្រសិនបើ ៥០% គឺជាគោលដៅ ទិសដៅរីកចម្រើនគួរតែមាន ៤០% ៣០% និង ១០% រៀងគ្នា។

**ជំហានទី៣៖** ឥឡូវផ្តល់ជូនសំណៅឯកសារទី១៤ ដល់ក្រុមនីមួយៗម្នាក់មួយច្បាប់។ ស្នើឱ្យពួកគេចាត់ចំណាត់ថ្នាក់ករណីសិក្សាលើសូចនាករនីមួយៗដោយផ្អែកលើទិសដៅដែលសម្រេចបាន។ ប្រាប់ពួកគេថា ពួកគេក៏អាចកែសម្រួលសូចនាករទាំងនេះបានដែរ ប្រសិនចាំបាច់។ ប្រាប់ពួកគេឱ្យផ្លូវផ្គង់ដំណើរការលើសូចនាករនីមួយៗនៅថ្នាក់កម្រិតគោលដៅដែលសម្រេចបានដូចដែលមានបង្ហាញក្នុងរូបទី២៥។ ប្រាប់ពួកគេថា ពួកគេអាចចាត់ចំណាត់ថ្នាក់ ១០ពិន្ទុ សម្រាប់គោលដៅដែលសម្រេចបាន ហើយទម្លាក់ពិន្ទុទៅតាមចំណាត់ថ្នាក់ហ្នឹង។

**ជំហានទី៤៖** នៅពេលក្រុមទាំងអស់បានបញ្ចប់ ស្នើឱ្យពួកគេបង្ហាញកង់របស់ខ្លួននៅក្នុងក្រុមធំ។ ការពិភាក្សាគួរផ្តោតលើភាពសមហេតុផលនៃការផ្តល់ពិន្ទុជាក់លាក់លើសូចនាករណាមួយ។ ប្រសិនបើក្រុមចំនួនពីរមានពិន្ទុដូចគ្នា ចូរលើកទឹកចិត្តឱ្យមានការពិភាក្សាល្អអំពីពិន្ទុនេះ។

**លទ្ធផលនៃការរៀនសូត្រ៖** បញ្ចប់លំហាត់នេះតាមរយៈការលើកឡើងថា ការអនុវត្តលំហាត់នេះនៅដើមដំបូងនៃគម្រោង ហើយក្រោយមកនៅក្នុងកិច្ចប្រជុំបូកសរុប អាចជាឧបករណ៍ល្អមួយសម្រាប់ការតាមដានផ្ទៃក្នុងលើភាពរីកចម្រើន LNOB ក្នុងគម្រោងនានា។

## រូបទី៤៦៖ ដ្យាក្រាមគក់




## ធ្វើតេស្តចំណេះដឹងរបស់អ្នក

| ចូរបំពេញសេចក្តីអធិប្បាយ | ✓ ជ្រើសរើសចម្លើយរបស់អ្នក | | | | | | | |
|---|---|---|---|---|---|---|---|---|
| តើកត្តាណាមួយក្នុងប្រអប់ខាងមុខនេះ គឺជាកត្តាប្រសព្វគ្នានៅក្នុង LNOB? | | អាយុ | | ឋានៈសេដ្ឋកិច្ច | | អមិត្តភាពផ្ទាល់ខ្លួន | | ជាតិពន្ធុ |
| តើសមាសភាពណាមួយក្នុងចំណោមសមាសក្នុងប្រអប់ខាងមុខនេះ គឺជាសមាសភាពនៃបន្ទុកការងារត្រីគុណសម្រាប់ស្ត្រី? | | ការងារក្នុងគ្រួសារ | | ការងារផលិតកម្ម | | ការងារសហគមន៍ | | ការកម្សាន្ត |
| តើភាគីពាក់ព័ន្ធណាមួយក្នុងចំណោមភាគីពាក់ព័ន្ធក្នុងប្រអប់ខាងមុខ គឺជាភាគីពាក់ព័ន្ធក្នុងគម្រោងរបស់អ្នក? | | អ្នកដែលងាយរងគ្រោះ | | អ្នកដែលមិនទទួលរងផលប៉ះពាល់ពីសកម្មភាពភាពធន់ | | អ្នកដែលស្នើសកម្មភាពភាពធន់ | | អ្នកដែលផ្តល់ហិរញ្ញវត្ថុដល់សកម្មភាពភាពធន់ |
| តើសេចក្តីអធិប្បាយណាមួយក្នុងចំណោមសេចក្តីអធិប្បាយក្នុងប្រអប់ខាងមុខដែលទំនងជាខ្លាំងថានឹងត្រូវបានប្រើប្រាស់ធ្វើជាសូចនាករដែលមានទស្សនៈយេនឌ័រ? | | អត្រាមរណភាពមាតា | | ចំនួនបុរសនិងស្ត្រីដែលមានកម្មសិទ្ធិដីធ្លី | | អាយុកាលសង្ឃឹមរស់ជាមធ្យមរបស់បុរស និងស្ត្រី | | អនុបាតឥណទានធៀបនឹងប្រាក់បញ្ញើ |
| តើឧបករណ៍ណាមួយក្នុងចំណោមឧបករណ៍ក្នុងប្រអប់ខាងមុខដែលអ្នកទំនងជាខ្លាំងថានឹងប្រើប្រាស់សម្រាប់ការប៉ាន់ប្រម៉ាណភាពងាយរងគ្រោះ ដើម្បីបង្កើតគម្រោងជំនួយបន្ទាប់ពីកើតមានគ្រោះមហន្តរាយ? | | ការប៉ាន់ប្រម៉ាណយេនឌ័ររហ័សសម្រាប់វិបត្តិ | | សន្ទស្សន៍ភាពធន់របស់ស្ត្រី | | ការវិភាគ Moser | | ក្របខ័ណ្ឌ Harvard |
| គម្លាតយេនឌ័រត្រូវបានបង្ហាញ ដោយការស្រាវជ្រាវថាមានសារៈសំខាន់ខ្លាំងសម្រាប់សេចក្តីអធិប្បាយណាមួយក្នុងចំណោមសេចក្តីអធិប្បាយ ក្នុងប្រអប់ខាងមុខនេះ? | | មរណភាពដោយសាររលកកម្តៅ | | មរណភាពដោយសារជំងឺអាសន្នរោគ | | មរណភាពក្នុងអំឡុងពេលមានទឹកជំនន់ | | មរណភាពក្នុងអំឡុងពេលមានជាតិពុលក្នុងទឹក |

## អានបន្ថែម

1 ) Glemarec, Y., Qayum, S., & Olshanskaya, M. ( 2016 ). Leveraging Co-benefits between Gender Equality and Climate Action for Sustainable Development: Mainstreaming Gender Considerations in Climate Change Projects. UN Women. Retrieved from https://trainingcentre.unwomen.org/pluginfile.php/66830/mod_-folder/intro/LEVERAGING%20CO-BENEFITS%20BETWEEN%20GENDER%20EQUALITY%20AND%20CLIMATE%20ACTION.pdf

2 ) IFRC. ( 2020 ). A practical guide to Gender-sensitive Approaches for Disaster Management. International Federation of Red Cross and Red Crescent Societies ( IFRC ). Retrieved from https://www.ifrc.org/PageFiles/96532/A%20Guide%20-for%20Gender-sensitive%20approach%20to%20DM.pdf

3 ) March, C., Smyth, I., & Mukhopadhyay, M. ( 1999 ). A Guide to Gender Analysis Framework. Oxfam GB. Retrieved from https://oxfamilibrary.openrepository.com/bitstream/handle/10546/115397/bk-gender-analysis-frameworks-010199-en.pdf;jsessionid=4545940CB68685897F61772456BB6411 ?sequence=8

4 ) SIDA. ( 2015 ). Gender Analysis- Principles and Elements. Gender Tool Box, Swedish International Development Cooperation Agency. Retrieved from https://www.sida.se/contentassets/a3f08692e731475db106fdf84f2fb9bd/gender-tool-analysis.pdf

5 ) UN Women. ( 2014 ). Guidance Note: Gender Mianstreaming in Development programming. United Nations Entity for Gender Equality and Empowerment of Women. Retrieved from https://www.unwomen.org/-/media/headquarters/attachments/sections/library/publications/2014/gendermainstreaming-issuesbrief-en%20pdf.pdf ?la=en&vs=747

6 ) WHO. ( 2011 ). Gender mainstreaming for health managers: a practical approach. World Health Organization. Retrieved from https://apps.who.int/iris/bitstream/handle/10665/44516/9789241501071_eng.pdf;jsessionid=0FA6E4E2D905845BE1352BF519B3B24F ?sequence=1

**TRAINOR'S NOTES**

MODULE ____ SESSION PLAN ____ PAGE ____

AGENDA

REMINDERS

## TRAINOR’S GRID NOTES

MODULE ____ SESSION PLAN ____ PAGE ____

AGENDA

REMINDERS

ឧបករណ៍សម្រាប់
ការបញ្ជ្រាបយេនឌ័រ

# HANDOUTS

# ម៉ូឌុល ៣៖

# 3

## ឯកសារមេរៀនទី១២៖ ឧទាហរណ៍នៃការវិភាគ និងការប៉ាន់ប្រម៉ាណយេនឌ័រ

### ឧទាហរណ៍ទី១៖ សន្ទស្សន៍ភាពធន់របស់ស្ត្រី

| វិស័យ/អនុវិស័យ | ប្រទេស៖ | អង្គភាព៖ | ឆ្នាំ៖ |
|---|---|---|---|
| គ្រោះមហន្តរាយ | បង់ក្លាដែស | ជំនួយអូស្ត្រាលី អង្គការ ActionAid | មិនមានទិន្នន័យ |

**ដំណើរការ/សំណួរសំខាន់ៗ**

> ឧបករណ៍សន្ទស្សន៍ភាពធន់របស់ស្ត្រី (WRI) ដែលភាពធន់នៃសហគមន៍ ត្រូវបានវាស់វែងពីទិដ្ឋភាពរបស់ស្ត្រី។

> តាមរយៈការប្រើវិធីសាស្ត្រលាយបញ្ចូលគ្នា WRI បង្កើតពិន្ទុធៀបនឹងសូចនាករចំនួន៣៦ ដែលមានលក្ខណៈជាបរិបទ និងអាចធ្វើការប្រៀបធៀបបានរវាងស្ត្រី និងបុរស។

> នេះរួមបញ្ចូលទាំងកិច្ចពិភាក្សាក្រុមគោលដៅ ដែលមានអ្នកចូលរួម៥១ នាក់ កិច្ចសម្ភាសន៍អ្នកផ្តល់ព័ត៌មានសំខាន់ៗ ១០នាក់ ការស្ទង់មតិសំណួរបុគ្គល ២០០នាក់។ ការសិក្សានេះ ត្រូវបានធ្វើឡើងនៅទីតាំងចំនួន៤ គឺ North Channel, Patharghata, Sadar & Charduani និង Nilgonj។

> សរុបមក អ្នកឆ្លើយសំណួរចំនួន ២៦១នាក់ បានចូលរួមក្នុងការសិក្សា ដែលក្នុងនោះមានបុរសចំនួន ១២៨នាក់ និងស្ត្រីចំនួន ១៣២នាក់។

**ឧទាហរណ៍/ការសង្កេតលទ្ធផលរកឃើញ៖**




ប្រភព៖ អង្គការ ActionAid
ប្រទេសបង់ក្លាដែស ឆ្នាំ២០១៨

### ឧទាហរណ៍ទី២៖ ការប៉ាន់ប្រម៉ាណតម្រូវការយេនឌ័ររហ័ស នៃសហគមន៍ដែលរងផលប៉ះពាល់ដោយសារទឹកជំនន់

| វិស័យ/អនុវិស័យ | ប្រទេស៖ | អង្គភាព៖ | ឆ្នាំ៖ |
|---|---|---|---|
| គ្រោះទឹកជំនន់ | ប៉ាគីស្ថាន | មូលនិធិអភិវឌ្ឍន៍អង្គការសហប្រជាជាតិសម្រាប់ស្ត្រី (UNIFEM) | ២០១០ |

**វិធីសាស្ត្រ**

> តាមរយៈការប្រើគោលការណ៍ណែនាំរបស់គណៈកម្មាធិការអចិន្ត្រៃយ៍អន្តរទីភ្នាក់ងារ (IASC) ដែលជាគំរូការឆ្លើយតបអប្បរមារបាយការណ៍ប៉ាន់ប្រម៉ាណនេះវិភាគអំពីនិន្នាការនិងទិន្នន័យដែលកំពុងមាន ដោយពឹងផ្អែកជាចម្បងលើការវាយតម្លៃតម្រូវការយេនឌ័រ (GNA) យន្តការប៉ាន់ប្រម៉ាណរហ័សពហុចង្កោម (McRAM) ការសិក្សា និងព័ត៌មានបន្ទាប់បន្សំដែលកំពុងកើតមាន។

> មូលនិធិ UNIFEM បានប្រមូលករណីសិក្សាចំនួន ១៤១ករណី ពីទូទាំងប្រទេសប៉ាគីស្ថានភ្លាមៗបន្ទាប់ពីទឹកជំនន់។ ការស្ទង់មតិការប៉ាន់ប្រម៉ាណតម្រូវការយេនឌ័រ ត្រូវបានធ្វើឡើងជាមួយអ្នកឆ្លើយតបចំនួន ២៥៣នាក់ ដោយមានអ្នកឆ្លើយសំណួរជាស្ត្រី ៥៥% និងបុរស ៤៥%។

> វាត្រូវបានរៀបចំឡើងជាពីរប្រភេទធំៗ តាមតម្រូវការជាក់ស្តែង និងយុទ្ធសាស្ត្រយេនឌ័រដែលពាក់ព័ន្ធបំផុត បន្ទាប់ពីមានវិបត្តិមនុស្សធម៌ភ្លាមៗ។

| ឧទាហរណ៍/ការសង្ខេបលទ្ធផលរកឃើញ៖ | ការការពារសិទ្ធិទាក់ទងនឹងភាពចាំបាច់ជាមូលដ្ឋាននៃជីវិត (តម្រូវការជាក់ស្តែង) | ការការពារជីវិត សន្តិសុខ សុចរិតភាព និងសេចក្តីថ្លៃថ្នូរ (តម្រូវការជាយុទ្ធសាស្ត្រ) |
|---|---|---|
| | > ចំពោះបុរស ការប្រាស្រ័យទាក់ទងចំពោះមុខ វិទ្យុ និងទូរគមនាគមន៍ គឺជាប្រភពចម្បងនៃការប្រកាសអាសន្ន/ការទំនាក់ទំនង ខណៈសម្រាប់ស្ត្រី គឺតាមរយៈសាច់ញាតិជាបុរស និងតាមរយៈការជួបជុំនៅសហគមន៍<br>> ដំណើរការនៃការជម្លៀសមនុស្សដែលមិនបានគ្រោងទុក។ មនុស្សភាគច្រើនត្រូវស្វែងរកឧបករណ៍ដោយខ្លួនឯង។<br>> ការសម្រេចចិត្តផ្លាស់ប្តូរទីលំនៅ៖ ចំពោះថា ពេលណា និងកន្លែងណា គឺត្រូវបានធ្វើឡើងដោយមេគ្រួសារជាបុរស។<br>> ដោយសារក្រុមគ្រួសារព្យាយាមប្រមូលផ្តុំគ្នាទីជម្រកបណ្តោះអាសន្នឬការរស់នៅក្រោមលំហមេឃ ធ្វើឱ្យស្ត្រីមានអារម្មណ៍ថា គ្មានការការពារនៅជុំវិញខ្លួន។<br>> ស្ត្រីបានត្អូញត្អែរថា ជាធម្មតា បុរសគឺជាអ្នកដែលអាចទទួលបានការចែកចាយជំនួយនៅពេលពួកគេរុញច្រានផ្លូវរបស់ពួកគេឆ្ពោះទៅមុខ ហើយស្ត្រីត្រូវការកម្លាំងកាយដើម្បីប្រកួតប្រជែងជាមួយពួកគេ។<br>> ទិន្នន័យ GNA បង្ហាញថា នៅពេលខ្វះអាហារ អ្នកឆ្លើយតបពាក់កណ្តាល បានផ្តល់ការអនុគ្រោះតម្រូវការអាហារូបត្ថម្ភដល់ក្មេងប្រុសដែលប្រភេទអាទិភាពបន្ទាប់សម្រាប់ម្តាយ/ប្រពន្ធ គឺស្ថិតនៅឆ្ងាយពីនេះ។ ការយកចិត្តទុក ចំពោះការទទួលទានអាហាររបស់មនុស្សចាស់ គឺមានតិចតួចបំផុត។<br>> នៅពេលដែលការស្ទង់មតិ ត្រូវបានធ្វើឡើង អ្នកឆ្លើយតប ៥៥% អាចមានលទ្ធភាពទទួលបានបង្គន់អនាម័យ និងបន្ទប់ទឹក ខណៈដែល ៤៤% នៅតែមិនទាន់មានលទ្ធភាពទទួលបាន។<br>> ១០% នៃគ្រួសារដែលបានស្ទង់មតិ មានកំណើតសមាជិកគ្រួសារមួយ ឬច្រើននៅក្នុងគ្រួសារ បន្ទាប់ពីគ្រោះទឹកជំនន់។ ៣០% នៃគ្រួសារទាំងអស់ដែលបានស្ទង់មតិជាមធ្យមមានស្ត្រីបំបៅដោះកូនយ៉ាងតិចម្នាក់ ឬច្រើននាក់។ | > អ្នកឆ្លើយតបតិចជាង ៤០% មានអារម្មណ៍ថាមានសុវត្ថិភាពនិងផាសុខភាពក្នុងការប្រើប្រាស់បង្គន់អនាម័យ និងបន្ទប់ទឹក ខណៈដែលអ្នកឆ្លើយតបមួយភាគបួននិយាយថាពួកគេមានអារម្មណ៍ថា មិនមានសុវត្ថិភាពក្នុងការធ្វើដូច្នេះ។ ទិន្នន័យ បង្ហាញថា ១៣% នៃអ្នកឆ្លើយតប បាននិយាយថា អំពើហិង្សាភាគច្រើនកើតឡើងនៅក្នុងតង់ឬទីជម្រក។<br>> អ្នកឆ្លើយតប ១៦% បានកំណត់រួចហើយថាអាពាហ៍ពិពាហ៍កាន់តែឆាប់ ជាបញ្ហាសុវត្ថិភាពចម្បងដែលកុមារី និងស្ត្រីបានប្រឈម។<br>> ៣៤%នៃអ្នកឆ្លើយតបបាននិយាយថាអំពើហិង្សាលើស្ត្រីទំនងជាកើតមានឡើងនៅក្នុងផ្ទះ ចំណែកឯជិត ៣៣% បាននិយាយថាលទ្ធភាពរបស់វាគឺខ្ពស់បំផុតនៅពេលធ្វើដំណើរតែម្នាក់ឯង ឬធ្វើការក្រៅផ្ទះ។<br>> ទម្រង់ភាពងាយរងគ្រោះរបស់ស្ត្រី ប្រែប្រួលទៅតាមអាយុ ស្ថានភាពអាពាហ៍ពិពាហ៍ វត្តមាននៃប្រព័ន្ធគាំពារសង្គមគ្រួសារក្រៅផ្លូវការ និងលក្ខណៈសម្គាល់នៃចំនុចប្រសព្វនៃជាតិពន្ធុ ភាសា សាសនា និងវណ្ណៈ។ ស្ត្រីជាកម្មសិទ្ធិ ត្រកូលវណ្ណៈកម្មករ ផ្នែកកសិកម្មកម្រិតទាប ដែលធ្វើឱ្យពួកគេមានអារម្មណ៍ថា ពួកគេអាចត្រូវបានចាប់ពង្រត់ដោយ "Kalifas" (អ្នកនៅក្រោមបង្គាប់) របស់ម្ចាស់ផ្ទះ។ |

ប្រភព៖ មូលនិធិ UNIFEM ប្រទេសប៉ាគីស្ថាន ឆ្នាំ២០១០)

## ឧទាហរណ៍ទី៣៖ ការវិភាគយេនឌ័រក្នុងការកសាងភាពធន់នឹងអាកាសធាតុនៅទីក្រុង

| វិស័យ/អនុវិស័យ | ប្រទេស៖ | អង្គការ៖ | ឆ្នាំ៖ |
|---|---|---|---|
| ភាពធន់នៅទីក្រុង | ប្រទេសវៀតណាម | មូលនិធិអភិវឌ្ឍន៍អង្គការសហប្រជាជាតិសម្រាប់ស្ត្រី (UNIFEM) | ២០១៦ |
| | | បណ្តាញភាពធន់នឹងការប្រែប្រួលអាកាសធាតុទីក្រុងនៅអាស៊ី (ACCCRN) វិទ្យាស្ថានអន្តរជាតិ ដើម្បីបរិស្ថាន និងអភិវឌ្ឍន៍ (IIED) មូលនិធិ Rockefeller វិទ្យាស្ថាន ដើម្បីផ្លាស់ប្តូរសង្គម និងបរិស្ថាន (ISET) ការិយាល័យសម្របសម្រួលការប្រែប្រួលអាកាសធាតុ (ទីក្រុងដាណាង ប្រទេសវៀតណាម) (CCCO) | |

### សំណួរស្រាវជ្រាវសំខាន់ៗ

> តើតួនាទី និងការទទួលខុសត្រូវរួមរបស់ស្ត្រី និងបុរសក្នុងការកាត់បន្ថយភាពងាយរងគ្រោះ និងការពង្រឹងភាពធន់នឹងអាកាសធាតុគឺជាអ្វី? តើស្ថានភាពប្រៀបធៀបរបស់ពួកគេនៅក្នុងគ្រួសារ និងក្នុងសហគមន៍គឺជាអ្វី? តើតួនាទីរបស់ស្ត្រី និងបុរសបានផ្លាស់ប្តូរដោយរបៀបណានៅប៉ុន្មានឆ្នាំចុងក្រោយនេះ?

> តើអ្វីទៅជាតម្រូវការយេនឌ័រជាយុទ្ធសាស្ត្រ និងចំពោះមុខ និងសមត្ថភាពរបស់ស្ត្រី និងបុរស? ហើយតើអ្វីដែលជាធម្មតាត្រូវបានចាត់ទុកថាជាការវិភាគតម្រូវការ ការបង្កើត និងការអនុវត្តសកម្មភាពលើកកម្ពស់ភាពធន់នឹងអាកាសធាតុ។ តើអ្វីជាផលប៉ះពាល់ ឬផលប៉ះពាល់ជាសក្តានុពល នៃការឆ្លើយតបនឹងតម្រូវការ និងសមត្ថភាពរបស់ស្ត្រី និងបុរស ក្នុងករណីដាច់ដោយឡែក និងរួមគ្នា?

> តើអង្គការក្នុងស្រុកមួយណាដែលចូលរួមក្នុងការបង្កើតភាពធន់នឹងអាកាសធាតុក្នុងទីក្រុង ទទួលខុសត្រូវឬអាចទទួលខុសត្រូវចម្បងក្នុងការលើកកម្ពស់តួនាទីយេនឌ័រនិងការធ្វើឱ្យប្រសើរឡើងនូវទំនាក់ទំនងយេនឌ័រ ជាពិសេសក្នុងការពង្រឹងតួនាទី និងឋានៈរបស់ស្ត្រីក្នុងការពង្រឹងភាពធន់?

> ការពិគ្រោះយោបល់ជាមួយក្រុមបុរស និងស្ត្រីនៅក្នុងសង្កាត់/ឃុំងាយរងគ្រោះ

> សម្ភាសជាមួយតំណាងនាយកដ្ឋានរដ្ឋាភិបាល និងអង្គការសាធារណៈដទៃទៀតនៅថ្នាក់ក្រុង ស្រុក និងឃុំ/សង្កាត់ និង

> ធ្វើកិច្ចសម្ភាសនៅកម្រិតគ្រួសារចំនួន ៦០ ក្នុងនោះពាក់កណ្តាលគឺ "ប្រជាជនក្រីក្រ" ផ្នែកសេដ្ឋកិច្ច និងពាក់កណ្តាលទៀតគឺ "ក្រីក្រមធ្យម"។

> ទាំងស្វាមី ទាំងភរិយា ត្រូវបានអញ្ជើញឱ្យមកផ្តល់សម្ភាស ហើយចំនួនអ្នកឆ្លើយតបជាបុរស និងស្ត្រី នៅក្នុងការស្ទង់មតិគ្រួសារ គឺស្ទើរតែស្មើគ្នា (បុរស៤៧ និង ស្ត្រី៥១)។

### ឧទាហរណ៍/ការសង្ខេបលទ្ធផលរកឃើញ៖

**Number of Men and Women Generating Income from Different Livelihoods in the Interviewed Households**



Degrees of Gendered Consideration in the Design of Public Spaces/Green Parks in Vulnerable Areas




Household Responses to Climate Change and Disasters




ប្រភព៖ (Anh et al ឆ្នាំ២០១៦)

## ឧទាហរណ៍ទី៤៖ ការវិភាគយេនឌ័រនៃខ្សែសង្វាក់ផលិតកម្មអាជីវកម្មកសិកម្មដែលយកចិត្តទុកដាក់ពីអាកាសធាតុ

| វិស័យ/អនុវិស័យ | ប្រទេស៖ | អង្គការ៖ | ឆ្នាំ៖ |
|---|---|---|---|
| កសិកម្ម | កម្ពុជា | ធនាគារអភិវឌ្ឍន៍អាស៊ី | ២០១៨ |

**វិធីសាស្ត្រ**

គម្រោងរងចំនួនបី ត្រូវបានកំណត់នៅក្រោមគម្រោងមេ ហើយការវិភាគយេនឌ័រនៃគម្រោងរងទាំងបី ត្រូវបានអនុវត្តដាច់ដោយឡែកពីគ្នា សម្រាប់ការបញ្ចូលទៅក្នុងផែនការសកម្មភាពយេនឌ័រ។ ប្រភពព័ត៌មានរួមមាន៖

> ទិន្នន័យបន្ទាប់បន្សំ រួមទាំងរបាយការណ៍ស្ទង់មតិសង្គមថ្មីៗ និងការបោះពុម្ពផ្សាយ
> ក្រុមគោលដៅ (ទាំងយេនឌ័រចម្រុះ និងជាមួយស្ត្រីដាច់ដោយឡែកពីគ្នា) ជាមួយអ្នកទទួលផលគោលដៅ។
> ធ្វើសម្ភាសន៍អ្នកផ្តល់ព័ត៌មានសំខាន់ៗ ជាមួយមេឃុំ និងមេភូមិក្នុងតំបន់ និងជនបង្គោលរបស់ស្ត្រី និងកុមារ។
> ធ្វើសម្ភាសទាំងនៅចំពោះមុខ និងតាមទូរស័ព្ទជាមួយអ្នកផ្តល់ព័ត៌មានសំខាន់ៗ
> កិច្ចប្រជុំជាមួយបុគ្គលិកក្រសួងសំខាន់ៗ និងជាមួយអង្គការក្រៅរដ្ឋាភិបាលអន្តរជាតិ អង្គការ Oxfam។

## ឧទាហរណ៍ទី៤៖ ការវិភាគយេនឌ័រនៃខ្សែសង្វាក់ផលិតកម្មអាជីវកម្មកសិកម្មដែលយកចិត្តទុកដាក់ពីអាកាសធាតុ

**ឧទាហរណ៍/ការសង្ខេបលទ្ធផលរកឃើញ៖**

**ប្រវត្តិការងារក្នុងវិស័យកសិកម្ម និងការរៀបចំផលិតកម្មស្រូវ**

> ស្ត្រីចូលរួមក្នុងការរៀបចំដី ឈូសឆាយស្មៅ ការផ្សព្វផ្សាយអំពីស្រូវសម្រាប់គ្រាប់ពូជ ការផ្សព្វផ្សាយអំពីជីកសិកម្ម ការស្ទូងសំណាប ការប្រមូលផលស្រូវដោយដៃ ការច្រូត និងរោយស្រូវ ការប្រមូល និងរក្សាទុកស្រូវ និងការលក់ស្រូវឱ្យទៅអ្នកប្រមូលទិញ។ នៅពេលលក់ស្រូវ ទាំង បុរស ទាំងស្ត្រី ត្រូវសម្រេចចិត្ត និងព្រមព្រៀងគ្នាថា តើតម្លៃណាមួយដែលត្រូវទទួលយករួមគ្នា។ ការដឹកជញ្ជូនស្រូវភាគច្រើន គឺធ្វើឡើងដោយបុរស ហើយគ្រួសារខ្លះជួលកម្លាំងពលកម្ម ដើម្បីដឹក និងដឹកជញ្ជូនស្រូវ។

> មានតែភូមិមួយក្នុងឃុំបច្ចុប្បន្នប៉ុណ្ណោះដែលអាចបង្កបង្កើនផលស្រូវបានចំនួនបីដងក្នុងមួយឆ្នាំ ដោយសារពួកគេមានលទ្ធភាពទទួលបានផ្គត់ផ្គង់ទឹកពេញមួយឆ្នាំ។ នៅភូមិផ្សេងទៀត មានរដូវច្រូតស្រូវតែមួយគត់ក្នុងមួយឆ្នាំ ដោយសារទឹកមិនគ្រប់គ្រាន់។ ពុំមានសមាគមអ្នកប្រើប្រាស់ទឹក ឬសហករណ៍កសិកម្មនៅក្នុងឃុំនោះទេ។ នៅពេលកសិករត្រូវការទឹកសម្រាប់ដាំដុះ ពួកគេសុំការអនុញ្ញាតពីមេភូមិ។ បរិមាណទឹកដែលអាចរកបានគឺមានកំណត់ ហើយការចែកចាយទឹកត្រូវបានកំណត់ដោយមេភូមិ។

> អ្នកប្រមូលទិញស្រូវភាគច្រើននៅក្នុងតំបន់គម្រោងរងទី១ ក្នុងឃុំតានី គឺជាស្ត្រី។ ពួកគេទិញស្រូវពីកសិករនៅមូលដ្ឋានជួសមុខឱ្យអតិថិជនរបស់ពួកគេដែលជាអ្នកលក់ដុំ ទាំងជនជាតិខ្មែរ និងជនជាតិវៀតណាម ដែលជាអ្នកកំណត់តម្លៃទិញ។ អ្នកប្រមូលទិញនៅតាមមូលដ្ឋាននេះ គឺជាស្ត្រីក្នុងមូលដ្ឋានម្នាក់ដែលរស់នៅក្នុងឃុំនេះហើយបានរៀនសូត្រអំពីការជួញដូរនេះពីសមាជិកគ្រួសារម្នាក់។ ស្វាមីរបស់នាងជួយដឹកបាវដែលបានទិញពីចម្ការ។ នៅក្នុងបទសម្ភាសន៍ជាមួយអ្នកប្រមូលទិញស្រូវ ពួកគេបានពន្យល់ថា ដើម្បីឱ្យអាជីវកម្មរបស់ពួកគេរីកចម្រើន ពួកគេត្រូវការស្រូវបន្ថែមទៀត។ ដោយហេតុផលនេះ ពួកគេយល់ឃើញថា គម្រោងរងអំពីទំនើបកម្មប្រព័ន្ធធារាសាស្ត្រដែលបានស្នើឡើង គឺជាការអភិវឌ្ឍបែបវិជ្ជមាន ដែលនឹងបង្កើនបរិមាណផលិតកម្មស្រូវ។ អ្នកប្រមូលស្រូវដែលត្រូវបានសម្ភាស បានពន្យល់ថា ពួកគេមិនផ្តល់កម្ចីដល់កសិករទេ ប៉ុន្តែពួកគេនឹងផ្តល់ប្រាក់ជាមុនឱ្យកសិករទាំងឡាយណាដែលពួកគេទុកចិត្តដោយគ្មានការប្រាក់។

> រោងម៉ាស៊ីនកិនស្រូវរបស់ស្ត្រីនៅមូលដ្ឋាន ផ្តល់ប្រាក់កម្ចីគ្មានការប្រាក់ដល់កសិករចំនួនចាប់ពី ៧៥ ដល់ ១២៥ដុល្លារអាមេរិក ក្នុងរយៈពេល ៤ ទៅ ៥ថ្ងៃ មុនពេលប្រមូលផលស្រូវ។ ក្នុងរដូវនីមួយៗ អ្នកកិនស្រូវបានពន្យល់ថា នាងត្រូវការប្រាក់ចំនួន ១០.០០០ ដុល្លារដើម្បីទិញស្រូវពីកសិករ។ ទោះបីជាយ៉ាងណា ជារឿយៗនាងមិនមានសាច់ប្រាក់គ្រប់គ្រាន់សម្រាប់អាជីវកម្មរបស់នាងទេ ហេតុដូច្នេះ នាងបានខ្ចីប្រាក់ប្រហែល ៥.០០០ដុល្លារពីគ្រឹះស្ថានមីក្រូឥណទាននៅមូលដ្ឋាន។ រោងម៉ាស៊ីនកិនស្រូវ ទិញស្រូវពីកសិករ និងពីអ្នកប្រមូលទិញនៅក្នុងឃុំ ហើយលក់អង្ករនៅក្នុងឃុំវិញ និងឱ្យទៅអតិថិជននៅប្រទេសវៀតណាម។

**ប្រវត្តិការងារក្នុងការផលិតស្វាយ និងការរៀបចំផលិតកម្ម**

> កសិករដាំស្វាយភាគច្រើននៅតំបន់នោះ បានប្រើប្រាស់ចំណូលពីការផលិតស្រូវ ឬការខ្ចីប្រាក់ពីធនាគារ ឬប្រើប្រាស់ប្រាក់បញ្ញើពីកូនៗរបស់ពួកគេ ដើម្បីដាំចំការស្វាយរបស់ពួកគេ ដែលមានមធ្យម មានទំហំប្រមាណ ៥ ទៅ ៧ ហិកតា។ ការដាំដំណាំស្វាយមានតម្លៃថ្លៃសម្រាប់កសិករ ហើយដោយសារតែពួកគេមិនមានដើមទុន កម្លាំងពលកម្ម ឬចំណេះដឹងគ្រប់គ្រាន់ក្នុងការដាំដុះស្វាយ វាជាទម្លាប់ធម្មតារបស់កសិករក្នុងការជួលចម្ការដាំដំណាំរបស់ខ្លួនទៅឱ្យអ្នកម៉ៅការឯកជន ដែលជាធម្មតាគឺជាក្រុមហ៊ុនកម្ពុជា នៅរយៈពេលក្រោយ ៣ ទៅ ៤ ឆ្នាំ នៅពេលដែលដើមឈើ ត្រូវបានដាំ និងចាប់ផ្តើមចេញផ្លែ។ តម្លៃកូនស្វាយមួយដើមគឺប្រហែល ៥០សេនទៅមួយដុល្លារអាមេរិក។ ថ្លៃពលកម្មសម្រាប់ការប្រមូលផលផ្លែស្វាយគឺ ៥ម៉ឺនរៀលក្នុងមួយថ្ងៃ។ ទឹកស្រោចស្រពសម្រាប់ចម្ការ ជាធម្មតា គឺបានមកពីស្រះ ឬទឹកអណ្តូង។

> អាស្រ័យលើការចរចាជាមួយអ្នកម៉ៅការ កសិករអាចទទួលបានពី ៥ ទៅ ១០ ដុល្លារអាមេរិក

## ឧទាហរណ៍ទី៤៖ ការវិភាគយេនឌ័រនៃខ្សែសង្វាក់ផលិតកម្មអាជីវកម្មកសិកម្មដែលយកចិត្តទុកដាក់ពីអាកាសធាតុ

| ឧទាហរណ៍/ការសង្ខេបលទ្ធផលរកឃើញ៖ | |
|---|---|
| | សម្រាប់ការជួលដើមស្វាយមួយដើម។ ការជួលជាធម្មតាសម្រាប់ចម្ការស្វាយ ៧ហិកតា ដែលមានដើមស្វាយអាយុ៤ឆ្នាំ គឺពី ៦.០០០ ទៅ ៧.០០០ ដុល្លារអាមេរិកក្នុងមួយឆ្នាំ។ បន្ទាប់មកអ្នកម៉ៅការមើលថែចម្ការដោយប្រើកម្លាំងពលកម្ម (បុរស) ផ្ទាល់ខ្លួនរបស់គាត់សម្រាប់ការស្រោចទឹក ដាក់ជី និងការដាក់ថ្នាំសម្លាប់សត្វល្អិត ដើម្បីធានាថាដើមស្វាយបង្កបង្កើតផល។ ម្ចាស់ចម្ការពុំមានការទទួលខុសត្រូវ ឬការទាមទារបន្ថែមទៀតចំពោះចម្ការទេ។ ប្រាក់ចំណូលទាំងអស់ដែលបានមកពីការលក់ផ្លែស្វាយឱ្យទៅអ្នកលក់ដុំនៅប្រទេសវៀតណាម ជាធម្មតា បានទៅអ្នកម៉ៅការ។<br>> អ្នកម៉ៅការផ្តល់ការបណ្តុះបណ្តាលដល់កសិករពីរបៀបដាំដើមស្វាយឱ្យបានត្រឹមត្រូវ។ អ្នកផ្គត់ផ្គង់កសិកម្មនៅមូលដ្ឋាន ជាញឹកញាប់ បង្ហាញពីផលិតផលកសិកម្មដែលបានណែនាំដើម្បីប្រើប្រាស់សម្រាប់ការដាំដុះដំណាំស្វាយ ដូចជាថ្នាំសម្លាប់សត្វល្អិត និងជី។ ពួកគេផ្តល់ការបណ្តុះបណ្តាលរយៈពេល ៥ថ្ងៃដល់កសិករ ហើយសិក្ខាកាម គឺជាបុរសទាំងស្រុង។ នៅទីតាំងគម្រោងវងមានកសិករដាំស្វាយជាច្រើនដែលអវត្តមាន។<br>> ភាគច្រើនជាបុរសដែលធ្វើការងារធ្ងន់ក្នុងការដាំស្វាយ។ បុរសប្រហែល ៥០% នៅក្នុងមូលដ្ឋាននេះក៏ចែករំលែកការទទួលខុសត្រូវចំពោះកិច្ចការផ្ទះ ហើយបុរសទទួលខុសត្រូវក្នុងការមើលថែសត្វធំៗ ដូចជា គោ ក្របី។ បុរសខ្លះក៏ជួយស្ត្រីក្នុងការមើលថែក្មេងតូចៗផងដែរ។ សម្រាប់គ្រួសារដែលមេគ្រួសារជាស្ត្រី ដែលកូនក្នុងអាយុពេញវ័យរបស់ពួកគេបានធ្វើចំណាកស្រុក និងទុកចៅៗឱ្យពួកគេមើលថែ បន្ទុកការងាររបស់ស្ត្រីគឺកាន់តែច្រើន។ ក្រៅពីការមើលថែចៅ ស្ត្រីទាំងនេះ គឺជាអ្នកថែរក្សាបសុសត្វ និងគ្រប់គ្រង ព្រមទាំងធ្វើស្រែចម្ការ និងដំណាំ រួមទាំងការជួលកម្មករប្រចាំថ្ងៃ។ ស្ត្រីខ្លះក៏ចូលរួមដោយផ្ទាល់ក្នុងការដាំស្វាយផងដែរ។ ការជួលកម្លាំងពលកម្ម គឺជាការចាំបាច់ ដោយសារតែកង្វះកម្លាំងពលកម្មជាលក្ខណៈគ្រួសារ ដែលជាផលវិបាកនៃការធ្វើចំណាកស្រុក ហើយការផ្ញើប្រាក់របស់ពលករចំណាកស្រុក ត្រូវបានប្រើដើម្បីទូទាត់ប្រាក់ឈ្នួលកម្មករប្រចាំថ្ងៃ។<br>> មានក្រុមអ្នកប្រើប្រាស់ទឹកនៅក្នុងឃុំប៉ុន្តែវាពាក់ព័ន្ធតែជាមួយនឹងការគ្រប់គ្រងទឹកសម្រាប់ផលិតកម្មស្រូវតែប៉ុណ្ណោះ។<br>> នៅពេលសម្ភាស អ្នកម៉ៅការស្វាយក្នុងស្រុកម្នាក់បានពន្យល់ថា គាត់ចំណាយពី ៥ ទៅ ១០ ដុល្លារក្នុងមួយដើមសម្រាប់រយៈពេលមួយឆ្នាំ ហើយគាត់អាចលក់ផ្លែស្វាយមួយគីឡូក្រាមបានក្នុងតម្លៃ ៣៥០០ រៀលដល់អ្នកប្រមូលទិញស្វាយនៅមូលដ្ឋាន។ គាត់និយាយថា គាត់អាចបំពេញតម្រូវការ និងចាត់ចែងការចំណាយរបស់គាត់ដោយមិនចាំបាច់ខ្ចីលុយពីគេ។ អ្នកប្រមូលទិញផ្លែស្វាយក្នុងស្រុកបានពន្យល់ថា ដើម្បីទិញផ្លែស្វាយគាត់ខ្ចីលុយគ្មានការប្រាក់ពីអតិថិជនរបស់គាត់នៅប្រទេសវៀតណាម ហើយចំនួនដែលខ្ចីប្រហាក់ប្រហែល គឺ១០.០០០ ដុល្លារអាមេរិក ដើម្បីទិញផ្លែស្វាយពីអ្នកម៉ៅការប្រចាំរបស់គាត់។ បន្ទាប់មកទៀត អតិថិជនជនជាតិវៀតណាម បានលក់ផ្លែស្វាយទៅឱ្យអតិថិជនរបស់គាត់នៅប្រទេសចិន។ ក្នុងករណីនេះ អ្នកប្រមូលទិញមិនដើរតួជាអ្នកឲ្យខ្ចីប្រាក់នៅមូលដ្ឋានឡើយ ដោយសារថា ទាំងកសិករក្នុងស្រុក ទាំងអ្នកម៉ៅការមិនដែលមករកគាត់ដើម្បីសុំប្រាក់ជាមុន ឬខ្ចីប្រាក់ឡើយ។ |
| ប្រភព៖ ធនាគារ ADB និងមូលនិធិ GEF ឆ្នាំ២០១៨) | |

## ឧទាហរណ៍ទី៥៖ សមតាភាពយេនឌ័រនៅក្នុងកម្មវិធីវិញ្ញាបនប័ត្រព្រៃឈើផ្អែកលើសហគមន៍

| វិស័យ/អនុវិស័យ | ប្រទេស៖ | អង្គការ៖ | ឆ្នាំ៖ |
|---|---|---|---|
| ព្រៃឈើ | នេប៉ាល់ | សាកលវិទ្យាល័យ Freiburg នៃប្រទេសអាឡឺម៉ង់ | ២០១១ |

**សំណួរស្រាវជ្រាវ**

> តើបុរស និងស្ត្រីចូលរួមក្នុងសកម្មភាពផ្សេងៗដែលទាក់ទងនឹងការប្រើប្រាស់ព្រៃឈើដែរឬទេ ?
> តើអ្វីទៅជាផលិតផលព្រៃឈើដែលប្រមូលបានដោយបុរស និងស្ត្រី ៖ មុន និងក្រោយការចេញវិញ្ញាបនប័ត្រ ?
> តើអ្វីជាការចូលរួមរបស់បុរស និងស្ត្រីនៅក្នុងគណៈកម្មាធិការ និងអនុគណៈកម្មាធិការ ?
> តើបុរសនិងស្ត្រីយល់ឃើញយ៉ាងដូចម្តេចចំពោះការអនុវត្តការគ្រប់គ្រងព្រៃឈើស្ថានភាពព្រៃឈើ និងស្ថានភាពរស់នៅរបស់ពួកគេ បន្ទាប់ពីបានអនុវត្តតាមលក្ខខណ្ឌតម្រូវនៃវិញ្ញាបនប័ត្រ ?

**វិធីសាស្ត្រ**

> ការយល់ដឹងអំពីសមភាពយេនឌ័រ ដោយផ្តោតលើការចូលរួមរបស់ស្ត្រីនៅក្នុងគម្រោងវិញ្ញាបនប័ត្រព្រៃឈើ និងកម្រិតយល់ដឹងរបស់អ្នកប្រើប្រាស់ព្រៃឈើ។
> អ្នកជំនាញមកពីគម្រោង និងប្រជាជនក្នុងមូលដ្ឋានត្រូវបានសម្ភាស។ កិច្ចប្រជុំ គណៈកម្មាធិការត្រូវបានរៀបចំឡើង ហើយគ្រួសារចំនួន ៦០គ្រួសារ ត្រូវបានសម្ភាស។
> សមាជិកគណៈកម្មាធិការចំនួន ៣៣% ជាស្ត្រីតាមអាណត្តិគោលនយោបាយ។ ទោះបីជាយ៉ាងណា ជាធម្មតាបុរសមានតួនាទីចម្បង ខណៈដែលសមាជិកស្ត្រីភាគច្រើនមានតួនាទីចម្បងតែនៅក្នុងអនុគណៈកម្មការ។
> បុរសយល់ឃើញថា ពួកគេទទួលបានការជូនដំណឹងអំពីកិច្ចប្រជុំគណៈកម្មាធិការនាពេលខាងមុខ ប្រសើរជាងស្ត្រី។
> នៅស៊ូសប៉ា មានតែស្ត្រី ២១% ប៉ុណ្ណោះដែលបានដឹងថាព្រៃឈើត្រូវបានចេញវិញ្ញាបនបត្រ ហើយ មួយភាគបីនៃពួកគេ បានដឹងអំពីឆ្នាំនៃការចេញវិញ្ញាបនប័ត្រ ប៉ុន្តែអ្នកផ្សេងទៀតពុំបានដឹងទេ។ ក្នុងចំណោមបុរសទាំងអស់ ៥០% បានដឹងអំពីព្រៃឈើដែលត្រូវបានចេញវិញ្ញាបនប័ត្រ។ ពីរភាគប្រាំនៃពួកគេ ដឹងអំពីឆ្នាំនៃការចេញវិញ្ញាបនប័ត្រ។

**Opinions of Respondents in Sushpa and Bhitteri CFUGs on Living Condition After Certification**




ប្រភព៖ ( Lewark et al ឆ្នាំ២០១១ )

## ឧទាហរណ៍ទី៦៖
## ការខកខានមិនបានទទួលសំឡេង៖ បទពិសោធន៍ទឹកជំនន់ និងការប្រកាសអាសន្ន ពីស្ត្រីដែលមិនត្រូវបានគេយកចិត្តទុកដាក់

| វិស័យ/អនុវិស័យ | ប្រទេស៖ | អន្តរាគមន៍៖ | ឆ្នាំ៖ |
|---|---|---|---|
| គ្រោះមហន្តរាយ | នេប៉ាល់ | សកម្មភាពចំពោះមុខ | ២០១៩ |

**វិធីសាស្ត្រ**

- > ការសិក្សាមានគោលបំណងចាប់យកបទពិសោធន៍ និងទិដ្ឋភាព ផ្សេងៗគ្នាលើអន្តរកម្មរវាងយេនឌ័រ និងប្រព័ន្ធប្រកាសអាសន្ន (EWS) នៅក្នុងបរិបទមិនមានអ្នកណាម្នាក់ត្រូវបានទុកចោល។
- > កិច្ចសម្ភាស គោលដៅត្រូវបានធ្វើឡើងជាមួយស្ត្រីជួបការលំបាក រួមមាន ស្ត្រីវ័យចំណាស់ ស្ត្រីពិការ ស្ត្រីជាម្តាយទោល ស្ត្រីប្តូរភេទ ស្ត្រីមានផ្ទៃពោះ ឬមានទារកតូច ស្ត្រីមានកូនតូចៗ និងស្ត្រីពិការភ្នែក។ ឈ្មោះត្រូវបានផ្លាស់ប្តូរដើម្បីរក្សាភាពអនាមិក លុះត្រាតែបុគ្គលណាម្នាក់បានបញ្ជាក់ច្បាស់លាស់ថា ឈ្មោះរបស់ពួកគេអាចយកមកប្រើបាន។
- > កិច្ចខិតខំប្រឹងប្រែងត្រូវបានធ្វើឡើងដើម្បីបង្កើតការជឿទុកចិត្តជាមួយបុគ្គលដែលមកពីក្រុមដែលមិនត្រូវបានគេយកចិត្តទុកដាក់ ដែលច្រើនតែមានទំនាក់ទំនងជាមួយអង្គការសហគមន៍មូលដ្ឋាន (CBO) ឬអន្តរការីដែលអាចទុកចិត្តបាន និងទទួលយកវិធីសាស្ត្រគំរូដុំព្រិល (snowball sampling) ដែលពឹងផ្អែកលើខ្សែសង្វាក់នៃការណែនាំផ្ទាល់ខ្លួនដើម្បីឈានទៅដល់បុគ្គលនានា។
- > ការសម្រេចចិត្តជាយុទ្ធសាស្ត្រ ត្រូវបានធ្វើឡើង ដើម្បីធ្វើការសម្ភាសសំឡេងពីចម្ងាយ តាមរយៈទូរស័ព្ទការស្វែងរកពេលវេលាដែលអ្នកទទួលការសម្ភាសន៍មានអារម្មណ៍ជឿជាក់ក្នុងការនិយាយដោយបើកចំហ ការផ្តល់នូវការធានាកាន់តែច្រើនចំពោះឯកជនភាព និងភាពអនាមិក ព្រមទាំងការផ្តល់បរិយាកាសអំណោយផលជាសក្តានុពលឱ្យអ្នកទទួលការសម្ភាសន៍អាចចែករំលែកទស្សនៈរបស់ពួកគេបានដោយកាន់តែបើកចំហជាងអ្វីដែលពួកគេបានរំពឹងទុកនៅពេលក្រុមសម្ភាសមកពីក្រៅសហគមន៍។

**ឧទាហរណ៍អំពីសំឡេង៖**

### ហ៊ីរ៉ា ទេវី ថារូ *ស្ត្រីវ័យក្មេងពិការភ្នែក នៅផ្នែកខាងលិចនៃប្រទេសនេប៉ាល់

**ហ៊ីរ៉ា បានរៀបការជាមួយបុរសពិការភ្នែកម្នាក់។ ពួកគេមានកូនតូចជាមួយគ្នា ហើយរស់នៅជាមួយគ្រួសារខាងប្តីរបស់នាង។**

ម្តាយក្មេករបស់ខ្ញុំបានប្រាប់ខ្ញុំ និងស្វាមីរបស់ខ្ញុំ នៅមុនពេលទឹកជំនន់បានកើតឡើង។ បន្ទាប់មកម្តាយក្មេកខ្ញុំ បានរៀបចំឱ្យយើងទៅកាន់ទីជម្រក។ វាគួរឱ្យខ្លាចខ្លាំងណាស់ដែលទឹកជំនន់បានបំផ្លាញអ្វីៗទាំងអស់ដែលយើងមានភ្លាមៗ។ ខ្ញុំដឹងច្បាស់ថាប្តីខ្ញុំ [ពិការភ្នែក] និងខ្ញុំ នឹងត្រូវស្លាប់ប្រសិនបើ គ្មានអ្នកណាជួយទេនោះ។ ខ្ញុំស្គាល់ផ្លូវទៅសាលារៀន ហើយទោះបីស្ថិតក្នុងភាពច្របូកច្របល់បែបនេះក៏ដោយក៏ខ្ញុំអាចទៅដល់ទីនោះបានដែរប៉ុន្តែមិនមែនទៅជាមួយកូនស្រីនិងរបស់របររបស់ខ្ញុំទេ។ ខ្ញុំមានការព្រួយបារម្ភខ្លាំង ចំពោះសុវត្ថិភាពរបស់នាង។ ខ្ញុំមិនដែលបានចូលរួមវគ្គបណ្តុះបណ្តាលឬកិច្ចប្រជុំណាមួយទាក់ទងនឹងការត្រៀមបង្ការទប់ទល់នឹងគ្រោះមហន្តរាយឡើយ។ ខ្ញុំមិនដែលគិតថា ខ្ញុំនឹងទទួលបានអត្ថប្រយោជន៍ពីវគ្គបណ្តុះបណ្តាល ឬកិច្ចប្រជុំទាំងនោះ ឬអ្នកផ្សេងទៀតអាចរៀនសូត្រ ឬទទួលបានអត្ថប្រយោជន៍ពីការរួមចំណែករបស់ខ្ញុំចំពោះពួកគេទេ។ ប្រសិនបើនោះជាករណីពិតមែន ខ្ញុំគិតថាខ្ញុំនឹងត្រូវបានស្នើឱ្យចូលរួមហើយ ប៉ុន្តែវាមិនដូច្នោះទេ។

គ្មានអ្នកណាម្នាក់ធ្លាប់សុំយោបល់ពីនាងទេហើយនាងមិនដែលគិតថាចង់ចែករំលែកយ៉ាងសកម្មឱ្យពួកគេ ដោយសារនាងគិតថា គ្មានអ្នកណាខ្វល់ឡើយ។

បញ្ហាប្រឈមដ៏ធំបំផុតនៅក្នុងទីជម្រក គឺការរក្សាសុវត្ថិភាពកូនតូចរបស់ខ្ញុំ និងដែលផ្លូវមនុស្សរត់ចេញ។ ដោយសារកូនខ្ញុំនាងនៅតូច នាងមិនដឹងអំពីព្រំដែនផ្ទាល់ខ្លួន ហើយដោយសារតែនាងនឹងឱ្យខ្លួននាងធូរស្បើយនៅពេលណាដែលនាងមានអារម្មណ៍ថាត្រូវការដូច្នោះ ហើយដោយសារតែខ្ញុំមិនអាចមើលឃើញមនុស្ស ពួកគេបានបដិសេធយើង។ ដូចគ្នាដែរ យើងស្ថិតនៅជាន់ទី២ ហើយក៏គ្មានផ្លូវរទេះរុញ និងក៏គ្មានបង្គន់នៅទីនោះដែរ។ សរុបមកវាជាបទពិសោធន៍មួយដែលពិបាកខ្លាំង និងមិនស្រណុកចិត្តទាល់តែសោះ... វាមិនខុសពីជំងឺប៉ះទង្គិចផ្លូវចិត្តប៉ុន្មានទេ ដោយសារខ្ញុំមានអារម្មណ៍ថា មនុស្សនៅជុំវិញខ្លួនខ្ញុំបានគេចចេញពីរូបខ្ញុំ បើទោះបីមានអ្វីផ្សេងទៀតតិចតួចដែលខ្ញុំ

**ឧទាហរណ៍ទី៦៖**
**ការខកខានមិនបានទទួលសំឡេង៖ បទពិសោធន៍ទឹកជំនន់ និងការប្រកាសអាសន្ន ពីស្ត្រីដែលមិនត្រូវបានគេយកចិត្តទុកដាក់**

| ឧទាហរណ៍/ការសន្ទេបលទ្ធផលរកឃើញ៖ | |
|---|---|
| | អាចជួយខ្លួនឯងបានក៏ដោយ។<br>ក្នុងអំឡុងពេលមិនច្បាស់លាស់ និងច្របូកច្របល់ ដូចជានៅពេលគ្រោះទឹកជំនន់ មនុស្សត្រូវផ្តោតលើការជួយសង្គ្រោះខ្លួនឯង។ នៅក្នុងបរិបទបែបនោះ មនុស្សដូចជាពួកយើង [ងងឹតភ្នែក និងពិការ] ដែលមិនអាចមើលឃើញ មិនអាចស្តាប់បាន និងមិនអាចធ្វើដំណើរបានដោយងាយស្រួល និងដោយមានទំនុកចិត្ត គឺកាន់តែងាយរងគ្រោះ។ យើងគ្មានជម្រើសអ្វីក្រៅពីរង់ចាំរហូតដល់មាននរណាម្នាក់មកជិតយើង និងគិតដល់យើង រហូតទាល់តែពេលមាននរណាម្នាក់ស្ម័គ្រចិត្តជួយយើង។ ជាមួយគ្នានេះ ខ្ញុំគិតថា ស្ត្រីដែលមានផ្ទៃពោះ និងស្ត្រីដែលមានកូនទើបនឹងកើត គឺងាយរងគ្រោះបំផុត។<br><br>ចំប៉ា កាលី មូសាម៉ាន ស្ត្រីប្តូរភេទនៅប្រទេសនេប៉ាល់ភាគខាងលិច<br>**ចំប៉ាចាប់ផ្តើមចូលវ័យ ៥០ឆ្នាំរបស់នាង។ នាងមិនធ្លាប់រៀបការទេ ហើយរស់នៅ និងជួយទ្រទ្រង់គ្រួសាររបស់នាងដែលមានសមាជិក ៩នាក់ រួមទាំងម្តាយចាស់ជរា និងបងថ្លៃស្រីមេម៉ាយ។**<br>ខ្ញុំបាននាំគ្រួសារខ្ញុំទៅកាន់កន្លែងមានសុវត្ថិភាព។យើងចាកចេញបន្ទាប់តែពីទឹកចាប់ផ្តើមចូលក្នុងផ្ទះរបស់យើង។ យើងគ្រាន់តែសង្គ្រោះជីវិតរបស់យើង។ មិនមានអ្វីផ្សេងទៀតទេដែលនៅសល់។ យើងមិនរំពឹងថា ទឹកជំនន់នឹងអាក្រក់ជាងឆ្នាំមុនទេ ប្រសិនបើយើងបានដឹងមុន ខ្ញុំច្បាស់ជានឹងរៀបចំឱ្យបានល្អជាងនេះ និងធ្វើឱ្យប្រាកដថា យើងបានចាកចេញលឿនជាងនេះ។<br>នៅពេលខ្ញុំចាប់ផ្តើមធ្វើដំណើរទៅកាន់ទីខ្ពស់ជាមួយគ្រួសារខ្ញុំផ្សេងទៀតការហៅឈ្មោះបានចាប់ផ្តើមស្ទើរតែភ្លាមៗ។ មនុស្សបានចង្អុលមកកាន់យើង ហើយនិយាយថា "អូហ៎មើលគ្រួសារចាកការ (Chakka) [ពាក្យពេចន៍គួរឱ្យស្អប់ខ្ពើម] ក៏មកដែរ" ខ្ញុំបានរស់នៅដោយបើកចំហអស់រយៈពេលជាច្រើនឆ្នាំ ប្រជាជននៅក្នុងសហគមន៍របស់ខ្ញុំដឹងថា ខ្ញុំជាភេទទីបី ហើយខ្ញុំធ្លាប់ត្រូវបានគេមើលងាយ និងហៅឈ្មោះបង្ខូចកិត្តិយស។ប៉ុន្តែការដែលត្រូវបានគេប្រព្រឹត្តបែបនេះ សូម្បីតែក្នុងអំឡុងពេលមិនច្បាស់លាស់បែបនេះ ធ្វើឱ្យខ្ញុំមានអារម្មណ៍ភ័យខ្លាច។ គ្មាននរណាម្នាក់គិតថា នឹងផ្តល់ជំនួយណាមួយឡើយ បើទោះបីម្តាយខ្ញុំចាស់ណាស់ទៅហើយ ហើយក្មួយស្រី និងក្មួយប្រុសខ្ញុំនៅក្មេងក៏ដោយ។ ផ្ទុយទៅវិញ ពួកគេព្យាយាមគេចចេញពីយើង។ នៅពេលដែលការសើចចំអក និងការតិះដៀល បន្តកើតមានជាច្រើនថ្ងៃ សូម្បីតែកន្លែងដែលយើងកំពុងជ្រកកោន ហើយមនុស្សម្នាបានប្រឹងប្រែងអស់ពីសមត្ថភាព ដើម្បីដាក់ឱ្យយើងនៅដាច់ពីគេ ហើយមិនឱ្យគេឃើញ។ ពេលខ្លះខ្ញុំគិតអំពីការលោតចូលក្នុងទឹកហើយបញ្ចប់អ្វីៗទាំងអស់តែម្តង។អ្វីដែលសំខាន់បំផុតនោះគ្មានកន្លែងឯកជនណាដែលអាចសម្អាត បោកគក់ និងផ្លាស់ប្តូរទេ ហើយបញ្ហានេះធ្វើឱ្យអ្វីៗកាន់តែអាក្រក់ទៅ។<br>ចំប៉ា កាលី ជួយទ្រទ្រង់គ្រួសារនាងតែម្នាក់ឯងពីចំណូលដែលនាងរកបានតាមរយៈការរាំ និងច្រៀងនៅក្នុងព្រឹត្តិការណ៍វប្បធម៌ និងសាសនាផ្សេងៗ។ ហើយដោយសារតែរឿងនេះ នាងមានអារម្មណ៍ថា ភាគច្រើននាងគឺជាសម្រេចចិត្តចុងក្រោយសម្រាប់បញ្ហាគ្រួសារ។ ប៉ុន្តែ នាងក៏មានអារម្មណ៍ថានាងមិនដែលបានចូលរួមកិច្ចប្រជុំ ឬការពិភាក្សាណាមួយឡើយ សូម្បីតែនៅកម្រិតសហគមន៍ក៏ដោយ។ ខ្ញុំមានអារម្មណ៍ថាខ្មាស់អៀនណាស់ និងមិនស្រណុកក្នុងចិត្តទាល់តែសោះ។ ខ្ញុំដឹងថា សហគមន៍មិនទុកចិត្តនិងមិនចូលចិត្តមនុស្សដូចជាខ្ញុំ។ខ្ញុំមិនដែលមានចេតនាដាក់ខ្លួនខ្ញុំនៅក្នុងស្ថានភាពមួយដែលខ្ញុំអាចត្រូវគេមើលងាយដោយបើកចំហបែននេះឡើយ។ លុះត្រាតែខ្ញុំដឹងថា ការប្រជុំមួយត្រូវបានរៀបចំឡើងជាពិសេសសម្រាប់មនុស្សដូចជាខ្ញុំ បើមិនដូច្នោះទេ ខ្ញុំនឹងមិនទៅអង្គុយ និងបញ្ចេញទស្សនៈ នៅពេលដែលអ្នកស្ថិតនៅជុំវិញខ្លួនខ្ញុំ គឺជាបុរស និងស្ត្រីធម្មតា។ |
| ប្រភព៖ (Brown et al ឆ្នាំ២០១៩) | |

## ឧទាហរណ៍ទី៧៖ ការប៉ាន់ប្រម៉ាណរហ័សលើយេនឌ័រសម្រាប់ជំងឺកូវីដ-១៩

| វិស័យ/អនុវិស័យ | ប្រទេស៖ | អង្គការ៖ | ឆ្នាំ៖ |
| --- | --- | --- | --- |
| សុខភាពសាធារណៈ (ជំងឺរាតត្បាត) | អាស៊ី និងប៉ាស៊ីហ្វិ | UN Women | ២០២០ |

**សំណួរស្រាវជ្រាវ**

ការដោះស្រាយបញ្ហាមិនខ្ចប់

> ស្វែងយល់ពីផលប៉ះពាល់ផ្អែកលើយេនឌ័រនៃជំងឺកូវីដ-១៩ ទៅលើការសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព នៅអាស៊ី និងប៉ាស៊ីហ្វិក

> បង្កើតផែនទីផលប៉ះពាល់នៃជំងឺកូវីដ-១៩ ទៅលើការពង្រឹងសិទ្ធអំណាចផ្នែកសេដ្ឋកិច្ចរបស់ស្ត្រី និងបុរស

**វិធីសាស្ត្រ**

> ការស្ទង់មតិប៉ាន់ប្រម៉ាណរហ័សនៅក្នុងប្រទេសអាស៊ីប៉ាស៊ីហ្វិកចំនួន១១ តាមរយៈទូរស័ព្ទដៃ

> កម្រងសំណួរមូលដ្ឋាន (មាន ១៦សំណួរ) នឹងត្រូវបញ្ចប់ក្នុងរយៈពេល ១០នាទី

> ប៉ារ៉ាម៉ែត្រដែលគ្របដណ្តប់ រួមមាន ព័ត៌មានអំពីប្រវត្តិ ប្រភពនៃព័ត៌មានទាក់ទងនឹងជំងឺកូវីដ ស្ថានភាពការងារ និងប្រាក់ចំណូលមុន និងអំឡុងពេលបិទទ្វារ ប៉ះពាល់ដល់ធនធានគ្រួសារ ការងារក្នុងស្រុក និងការងារផ្តល់ការថែទាំក្នុងគ្រួសារ លទ្ធភាពទទួលបានការគាំពារសង្គម។ល។

**ឧទាហរណ៍/ ការសង្ខេបលទ្ធផលរកឃើញ៖**

Proportion of People Whose Time Allocated to Unpaid Domestic and Care Work Increased Since COVID-19, by Sex and Intensity (Percentage)




COVID-19 Multiplied the Workload at Home and Women are Paying the Price




*Women and men were asked whether their partner helps more, so an assumption is made that their partner is of the opposite sex, even though this may not be the case.

Women in Large Cities Were Disproportionately Affected by Public Transit Disruptions




ប្រភព៖ (អង្គការ UN Women ឆ្នាំ២០២០)

## ឯកសារមេរៀនទី១៣៖ ឧបករណ៍ដែលមានការចូលរួមសម្រាប់ការវិភាគយេនឌ័រ និងផែនការបន្សាំផ្អែកលើសហគមន៍

### ធនធាន និងការបង្កើតផែនទីមុខសញ្ញាគ្រោះថ្នាក់

- ដើម្បីបង្ហាញរូបភាពច្បាស់អំពីការប្រឈមនិងភាពរំញោចចំពោះគ្រោះថ្នាក់អាកាសធាតុនៅតំបន់ផ្សេងៗគ្នា ធនធាន និងក្រុមនៅក្នុងសហគមន៍។
- ដើម្បីស្គាល់សហគមន៍និងដឹងថាតើទីកន្លែង/ទីតាំងត្រូវបានយល់ឃើញដោយក្រុមផ្សេងៗគ្នានៅក្នុងសហគមន៍យ៉ាងដូចម្តេច។
- ដើម្បីកំណត់ពីការប្រកបរបរចិញ្ចឹមជីវិតសំខាន់ៗ និងធនធានផ្សេងទៀតនៅក្នុងសហគមន៍។
- ដើម្បីកំណត់តំបន់ មនុស្ស ទ្រព្យសម្បត្តិ និងធនធានដែលមានហានិភ័យ ឬរងផលប៉ះពាល់ពីមុខសញ្ញាគ្រោះថ្នាក់អាកាសធាតុ




បុរស និងស្ត្រី (ព្រមទាំងក្រុមងាយរងគ្រោះផ្សេងទៀត ដូចជា ជនពិការ) មិនត្រូវបានបែងចែកដោយស្មើភាពទៅតាមភូមិសាស្ត្រក្នុងចំណោមសហគមន៍ចំពោះសកម្មភាពសង្គមនិងសេដ្ឋកិច្ចរបស់ពួកគេ និងការទទួលខុសត្រូវក្នុងគ្រួសារ។ល។ ការបង្កើតផែនទីផ្តល់នូវឱកាស ដើម្បីបង្ហាញឱ្យឃើញជាក់ស្តែងពីភាពងាយរងគ្រោះផ្សេងៗគ្នាចំពោះបុរស និងស្ត្រី (និងក្រុមផ្សេងទៀត) ទាក់ទងនឹងការប្រឈម និងការរំញោច/យល់ដឹង។ តំបន់ខ្លះនៅក្នុងភូមិ ត្រូវបានជួបញឹកញាប់ដោយស្ត្រីនិងកុមារ ឧទា. មណ្ឌលសុខភាព សាលារៀន កន្លែងប្រមូលទឹក រោងចក្រកាត់ដេរ កសិដ្ឋានបន្លែ។ល។ ខណៈដែលកន្លែងជាច្រើនផ្សេងទៀតបានជួបញឹកញាប់ដោយបុរស ដូចជា កសិដ្ឋានចិញ្ចឹមបង្គាដើមកោងកាង។ល។

### ប្រតិទិនតាមរដូវកាល

- ដើម្បីស្វែងយល់ពីវដ្តរដូវប្រចាំឆ្នាំនៃសកម្មភាពប្រកបរបរចិញ្ចឹមជីវិតសំខាន់ៗនៅក្នុងសហគមន៍។
- ដើម្បីកំណត់រដូវកាលនៃគ្រោះថ្នាក់ ភាពតានតឹងខាងអាកាសធាតុ ជំងឺ បំណុល សកម្មភាពសង្គម និងសាសនា។ល។ និងផ្សារភ្ជាប់ជាមួយសកម្មភាពប្រកបរបរចិញ្ចឹមជីវិត។
- ដើម្បីកំណត់ និងវិភាគពីការផ្លាស់ប្តូររយៈពេលមធ្យម និងរយៈពេលវែងចំពោះសកម្មភាពប្រកបរបរចិញ្ចឹមជីវិត និងផលប៉ះពាល់នៃធាតុអាកាស និងការប្រែប្រួលអាកាសធាតុទៅលើយុទ្ធសាស្ត្រប្រកបរបរចិញ្ចឹមជីវិត។

នៅពេលធ្វើជាក្រុមដាច់ដោយឡែកពីគ្នា ឬដោយប្រើនិមិត្តសញ្ញា ប្រតិទិនតាមរដូវ អាចជួយកំណត់តួនាទីរបស់បុរសនិងស្ត្រីនៅក្នុងសកម្មភាពសេដ្ឋកិច្ចនិងសង្គមសំខាន់ៗ។អ្នកក៏អាចកំណត់អំពីរបៀបដែលប្រតិទិនតាមរដូវរបស់បុរស និងស្ត្រី បានផ្លាស់ប្តូរកាលពីពេលអតីតកាលក្នុងការឆ្លើយតបទៅនឹងធាតុអាកាស និងការប្រែប្រួល អាកាសធាតុ។ ក្នុងអំឡុងពេលនៃការពិភាក្សា អ្នកអាចកំណត់លទ្ធភាពទទួលព័ត៌មានអាកាសធាតុ និងធនធានផ្សេងៗគ្នា ដែលចាំបាច់សម្រាប់ការប្រកបចិញ្ចឹមជីវិត។ ស្វែងយល់ពីមូលហេតុនៃផលប៉ះពាល់ និងចាប់ផ្តើមស្វែងរកដំណោះស្រាយសម្រាប់ពិភាក្សា។

## ឯកសារមេរៀនទី១៣៖ ឧបករណ៍ដែលមានការចូលរួមសម្រាប់ការវិភាគយេនឌ័រ និងផែនការបន្សាំផ្តោតលើសហគមន៍

| | JAN | FEB | MAR | APR | MAY | JUN | JUL | AUG | SEP | OCT | NOV | DEC |
|---|---|---|---|---|---|---|---|---|---|---|---|---|
| Rainfall | | • | •• | •• | ••• | •••• | ••••• | •••• | • | • | • | • |
| Agricultural Labour | • | •• | ••• | •••••• | ••••••• | •••• | ••• | •• | •••••• | •••••• | •• | •••• |
| Off-farm Labour | • | • | • | • | • | • | • | • | • | • | • | • |
| Food Availability | •••• | ••• | • | | | | •• | •• | •••••• | •••••• | ••••• | •••• |
| Water Availability | • | • | •• | ••• | ••••• | ••••• | ••••• | •••• | • | • | • | • |
| Human Diseases | • | • | • | | | ••• | ••• | | | | | |
| Animal Diseases | ••• | ••• | • | • | ••• | ••• | ••• | • | • | • | ••• | ••• |

### ម៉ាទ្រិចផលប៉ះពាល់

> កំណត់អត្តសញ្ញាណមុខរបរដែលត្រូវបានរងផលប៉ះពាល់កាន់តែច្រើនដោយការប្រែប្រួលអាកាសធាតុនៅក្នុងសហគមន៍។

> ចរិតលក្ខណៈ និងការប្រៀបធៀបថាតើលំដាប់នៃការងារត្រូវបានរងផលប៉ះពាល់ដោយការប្រែប្រួលអាកាសធាតុយ៉ាងដូចបម្តេច?

> កំណត់ហានិភ័យអាកាសធាតុដែលជះឥទ្ធិពលកាន់តែច្រើនដល់សហគមន៍។

| OCCUPATION/ LIVELIHOOD |  |  |  |  |  | TOTAL |
|---|---|---|---|---|---|---|
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| TOTAL | | | | | | |

បុរស និងស្ត្រីជាទូទៅ ត្រូវបានគេផ្តល់ការងារក្នុងប្រភេទផ្សេងៗគ្នា។ លំហាត់នេះជួយឱ្យយើងយល់ដឹងថា តើប្រភេទមុខរបរណាដែលមានការប្រឈម និងភាពរំញោច ចំពោះហានិភ័យអាកាសធាតុកាន់តែខ្លាំង។ ការផ្តោតការយកចិត្តទុកដាក់គួរតែផ្តោតលើការស្វែងយល់ថា មូលហេតុអ្វីបានជាប្រភេទមុខរបរជាក់លាក់មួយ ងាយរងគ្រោះជាងប្រភេទមុខរបរមួយទៀត។ តើវាកើតឡើងដោយសារតែការការប្រឈម ឬភាពរំញោច ហើយតើអ្វីដែលអាចធ្វើបានដើម្បីដោះស្រាយហានិភ័យ។ ក្នុងអំឡុងពេលពិភាក្សា អ្នកក៏អាចកំណត់ថា តើមានមនុស្សប៉ុន្មាននាក់ នៅក្នុង សហគមន៍ ដែលចូលរួមក្នុងមុខរបរនេះ តើអ្វីគឺជាស្ថិរភាពនៃប្រាក់ចំណូលនាពេលបច្ចុប្បន្នដែលបានមកពីមុខរបរ និងជំនាញ។

## ឯកសារមេរៀនទី១៣៖ ឧបករណ៍ដែលមានការចូលរួមសម្រាប់ការវិភាគយេនឌ័រ និងផែនការបន្សាំផ្អែកលើសហគមន៍

### ចត្តុភាគហានិភ័យ

- > កំណត់ហានិភ័យស្របតាមលទ្ធភាពដែលអាចកើតមាន និងកម្រិតនៃផលប៉ះពាល់ដែលវាអាចកើតមានជាបន្តបន្ទាប់ដល់សហគមន៍។
- > សហគមន៍យល់ដឹងអំពី "លទ្ធភាពដែលអាចកើតមាន ឬលទ្ធភាព" និង "ផលប៉ះពាល់" នៃគ្រោះមហន្តរាយ/ហេតុការណ៍។ ឧទា. រលកយក្សស៊ូណាមិ អាចជះឥទ្ធិពលយ៉ាងខ្លាំងដល់ជីវិតមនុស្ស ប៉ុន្តែលទ្ធភាពដែលអាចកើតមាន នៅតំបន់មិនមែនឆ្នេរសមុទ្រគឺគ្មាន។ ដូចគ្នានេះដែរ រលកកម្តៅអាចមានផលប៉ះពាល់ដែលអាចមើលឃើញ តិចជាង ប៉ុន្តែលទ្ធភាពដែលអាចកើតមានគឺខ្ពស់ជាង។




ជួយស្តែងឱ្យឃើញពីការប៉ះទង្គិចគ្នារវាងអាកាសធាតុ "ស្រេ្តស" និងអាកាសធាតុ "ភាពតានតឹង"។ ជារឿយៗស្ត្រីក្រីក្រ រងផលប៉ះពាល់ច្រើនពីស្រេស្ត ដែលបណ្តាលមកពី អាកាសធាតុ ជាងភាពតានតឹងដែលបណ្តាលមកពីអាកាសធាតុ ប៉ុន្តែការធ្វើផែនការបន្សុំ មាននិន្នាការផ្តោតលើភាពតានតឹងជាងស្រេ្តស។

### ការផ្តល់ពិន្ទុសមត្ថភាពបន្សាំ

- > កំណត់សេណារីយ៉ូ/ ស្ថានភាពបច្ចុប្បន្ននៃហេដ្ឋារចនាសម្ព័ន្ធដែលទាក់ទងនឹងសេវា មូលដ្ឋាន និងការបន្សាំនឹងអាកាសធាតុដែលមាននៅក្នុងតំបន់។
- > ជួយធ្វើផែនទីសមត្ថភាពបន្សាំបច្ចុប្បន្នពីទិដ្ឋភាពហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្ម។

តាមរយៈការបញ្ចូលហេដ្ឋារចនាសម្ព័ន្ធនិងសេវាកម្មទាក់ទងនឹងតម្រូវការជាក់ស្តែងរបស់បុរសនិងស្ត្រីអាចនាំមកនូវការពិភាក្សា ដើម្បីដោះស្រាយតម្រូវការហេដ្ឋារចនាសម្ព័ន្ធរបស់ស្ត្រីសម្រាប់ការបន្សុំនឹងការប្រែប្រួលអាកាសធាតុ។

## ឯកសារមេរៀនទី១៣៖ ឧបករណ៍ដែលមានការចូលរួមសម្រាប់ការវិភាគយេនឌ័រ និងផែនការបន្សាំផ្អែកលើសហគមន៍

**To Flooding and Inundation**

| | 1 | 2 | 3 | 4 | 5 |
|---|---|---|---|---|---|
| Well Managed Drainage Networks | No drainage network within slum | Open drainage lines with high blockage and overflowing | **Well managed open drains or partially closed drainages facing frequent breakage** | Overlaid water and sewage lines with breakage causing frequent contamination of drinking water | Proper drainage network with disposal facilities |
| Storm Water Management Systems | No system in place | **Open drains often clogged** | Drains are there but encroached | System in place but not effective | Well managed storm water drainage is there or slum is on highland facing no water logging problems |
| Solid Waste Management Systems | No system of collection of solid waste – visible in dump site | No system of collection of solid waste but garbage truck comes on demand | Irregular collection of solid waste at mouth of slum/ designated area | **Regular collection of solid waste at mouth of slum/ designated area** | **Regular door-to-door collection of solid waste** |
| Regular Cleaning of Drains | No drains | Occasional cleaning but silt dumped outside of the nallas (not ever picked) | **Occasional cleaning of drains but silt not picked regularly** | Cleaning of drains before monsoons and silt is picked within 48 hours | Regular cleaning of drains and silt is picked within 48 hours |
| High Plint Level of Homes | **Very low base and no plint of homes** | Houses are lower than roads | Plint on level of roads but not effective | Adequate plint for normal monsoon but not for heavy downpours | Adequate plint for heavy downpour |

BEST GOOD AVERAGE POOR VERY POOR

**អត្ថិភាពដំណោះស្រាយ**

> ដើម្បីវាយតម្លៃ និងសិក្សាពីចំណង់ចំណូលចិត្តរបស់សហគមន៍ចំពោះដំណោះស្រាយ ឬបច្ចេកវិទ្យាជាក់លាក់ណាមួយលើចំណុចផ្សេងទៀត។

> មានប្រយោជន៍ក្នុងការផ្តល់ជូនសហគមន៍នូវដំណោះស្រាយជាច្រើននិងជួយពួកគេឱ្យជ្រើសរើសដោយផ្អែកលើលក្ខណៈវិនិច្ឆ័យដែលពាក់ព័ន្ធនឹងពួកគេ។

> អាចត្រូវបានប្រើសម្រាប់ការផ្តល់អាទិភាពដល់គម្រោងជាច្រើន ក៏ដូចជាសម្រាប់លម្អិតនៅក្នុងគម្រោង។ ឧទាហរណ៍ដើម្បីជ្រើសរើសរវាងបណ្តាញផ្គត់ផ្គង់ទឹកផឹក និងខ្សែបណ្តាញលូបង្ហូរទឹក ក៏ដូចជា រវាងពូជគ្រាប់ពូជដំណាំដែលធន់នឹងទឹកជំនន់ ឬសម្រាប់ការជ្រើសរើសពូជសម្រាប់ការដាំព្រៃ។

| SI No.: | ITEM | PRIORITIES | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | | VILLAGE PANCHAYAT | EWRs | | | | | | |
| | | | 1 | 2 | 3 | 4 | 5 | 6 | Average |
| 1. | General administration (salaries, sitting charges, TA, DA, Stationery, etc. | 4 | 6 | 5 | 7 | 7 | 5 | 5 | 6 |
| 2. | Social Security | 1 | 1 | 2 | 1 | 3 | 1 | 4 | 1 |
| 3. | Public Infrastructure | 2 | 2 | 3 | 5 | 2 | 3 | 2 | 3 |
| 4. | Public health | 7 | 3 | 4 | 3 | 1 | 4 | 6 | 4 |
| 5. | Civic amenities | 3 | 4 | 1 | 2 | 4 | 2 | 1 | 2 |
| 6. | Education | 8 | 5 | 6 | 6 | 5 | 6 | 3 | 5 |
| 7. | Works under schedule caste and tribes welfare | 6 | 7 | 7 | 4 | 6 | 7 | 7 | 7 |
| 8. | Contribution | 9 | 8 | 8 | 8 | 9 | 8 | 8 | 8 |
| 9. | Debt heads | 5 | 9 | 9 | 9 | 9 | 9 | 9 | 9 |

ធ្វើឡើងដាច់ដោយឡែកពីគ្នាជាមួយបុរសនិងស្ត្រីឬសូម្បីតែនៅក្នុងក្រុមតែមួយប្រសិនបើមានការសម្របសម្រួលត្រឹមត្រូវវាជួយបង្ហាញឱ្យឃើញនូវលក្ខណៈវិនិច្ឆ័យរបស់ស្ត្រីចំពោះការពេញចិត្តជម្រើសជាក់លាក់ជាងចំណុចដទៃ។ វាក៏ជួយឱ្យពួកគេបញ្ចេញគំនិត របស់ពួកគេចំពោះចំណុចដទៃផ្សេងទៀតក្នុងលក្ខណៈវិភាគកាន់តែច្រើនដែលជាលទ្ធផលនាំឱ្យមានការសម្រេចចិត្តកាន់តែប្រសើរ។

ប្រភព៖
(Care ប្រទេសវៀតណាម ឆ្នាំ២០១៥)
(មិនមានប្រភពជាក់លាក់)
(មិនមានប្រភពជាក់លាក់)

## ឯកសារមេរៀនទី១៤៖ករណីសិក្សាសម្រាប់ការតាមដានមិនមានអ្នកណាម្នាក់ត្រូវបានទុកចោល

នៅខែឧសភាឆ្នាំ ២០០៨ ព្យុះស៊ីក្លូនណាហ្គីស បានវាយប្រហារប្រទេសមីយ៉ាន់ម៉ាបណ្តាលឱ្យមានការបំផ្លិចបំផ្លាញយ៉ាងខ្លាំងនៅក្នុងតំបន់អាយ៉ីយ៉ាវ៉ាឌី និងទីក្រុងយ៉ាំងហ្គោន។ វាពុំមែនត្រឹមតែជាព្យុះស៊ីក្លូនដ៏ខ្លាំងបំផុតលើកទី៨ នៅលើពិភពលោករហូតមកដល់ពេលបច្ចុប្បន្ននេះប៉ុណ្ណោះទេ វាក៏ជាគ្រោះធម្មជាតិដ៏អាក្រក់បំផុតដែលប្រជាជនមីយ៉ាន់ម៉ាអាចចងចាំបានផងដែរ។ ចំនួនអ្នកស្លាប់ជាផ្លូវការមានចំនួន ៨៤.៥៣៧ នាក់ និងមនុស្ស ៥៣.៨៣៦ នាក់ផ្សេងទៀតដែលមិនអាចរកឃើញ។ ទីប្រជុំជនចំនួនហាសិប ត្រូវបានរងផលប៉ះពាល់នៅក្នុងការបែងចែកទាំងពីរ រួមមាន ទីក្រុងយ៉ាំងហ្គោនដែលជាទីក្រុងធំបំផុតរបស់ប្រទេស។ ព្យុះស៊ីក្លូនដ៏សាហាវនេះបានបង្កការខូចខាតយ៉ាងធ្ងន់ធ្ងរដល់ផ្ទះសម្បែង និងហេដ្ឋារចនាសម្ព័ន្ធសាធារណៈផ្សេងៗ ដូចជា ផ្លូវថ្នល់ កំពង់ផែ ប្រព័ន្ធទឹកស្អាត ឋបនីយកម្មអនាម័យបរិស្ថាន ប្រព័ន្ធទំនាក់ទំនង និងប្រព័ន្ធអគ្គិសនី។ ផលប៉ះពាល់យូរអង្វែងមួយនៃព្យុះស៊ីក្លូន គឺបានបំផ្លិចបំផ្លាញធនធានសម្រាប់ការប្រកបរបរចិញ្ចឹមជីវិតនៅក្នុងសហគមន៍។តំបន់ដីសណ្តដែលជាកន្លែងផលិតអង្ករខ្នាតធំ បានទទួលរងការខូចខាតយ៉ាងធ្ងន់ធ្ងរដល់ដីស្រែកសិកម្មដោយសារតែការហូរចូលនៃទឹកសមុទ្រ។ ការនេសាទ បសុសត្វ និងសហគ្រាសធុនតូច ផ្សេងទៀតក៏ទទួលរងការខូចខាតក្នុងកម្រិតធ្ងន់ធ្ងរផងដែរ។ ក្នុងនាមជាផ្នែកមួយដែលងាយរងគ្រោះបំផុតរបស់ប្រជាជន ស្ត្រីទទួលអារម្មណ៍ថា រងផលប៉ះពាល់ពីគ្រោះមហន្តរាយនេះយ៉ាងខ្លាំង។យោងតាមទិន្នន័យវាយតម្លៃជនរងគ្រោះដោយសារខ្យល់ព្យុះស៊ីក្លូនភាគច្រើនគឺជាស្ត្រីពោលគឺ៦១ភាគរយនៃអ្នកស្លាប់គឺជាស្ត្រីដែលតួលេខនេះអាចមានចំនួនខ្ពស់ជាងនៅក្នុងភូមិខ្លះ។ ចំនួនស្ត្រីរងគ្រោះក្នុងចំនួនមិនសមាមាត្រគ្នាត្រូវបានបង្ហាញជាពិសេសនៅក្នុងក្រុមអាយុផលិតភាព និងអាយុបន្តពូជសំខាន់ៗក្នុងចន្លោះពី១៨-៦០ឆ្នាំ។

សង្គមកាកបាទក្រហមមីយ៉ាន់ម៉ា (MRCS) ដែលគាំទ្រដោយសហព័ន្ធអន្តរជាតិកាកបាទក្រហម និងអឌ្ឍចន្ទក្រហម (IFRC) បានឆ្លើយតបភ្លាមៗ បន្ទាប់ពីព្យុះស៊ីក្លូន ដោយមានការចែក នូវវត្ថុជំនួយដែលមិនមែនជាអាហារ ដូចជា សម្ភារឧបករណ៍សម្រាប់ទីជម្រក កម្រាលពូក កំប៉ុង សម្ភារអនាម័យខ្លួនប្រាណ មុង ភួយ និងឈុតផ្ទះបាយ។ ជំនួយក្នុងវិស័យសុខាភិបាល ទឹកស្អាត និងអនាម័យបរិស្ថានក៏ត្រូវបានផ្តល់ជូនផងដែរ។ ការផ្តោត ការយកចិត្តទុកដាក់ ក៏ត្រូវបានផ្តល់ទៅឱ្យសកម្មភាពដែលមានគោលបំណងស្តារទំនាក់ទំនងគ្រួសារឡើងវិញ។ ក្នុងដំណាក់កាលជួយសង្គ្រោះ MRCS បានផ្តល់ការចែកជំនួយសង្គ្រោះដល់គ្រួសារជាង ២៦០.០០០ គ្រួសារ ឬប្រហែល ១លាននាក់។

ដើម្បីផ្លាស់ប្តូរពីជំនួយសង្គ្រោះបន្ទាន់មកជាការស្តារឡើងវិញ និងដោះស្រាយតម្រូវការរយៈពេលវែងរបស់អ្នកដែលរងផលប៉ះពាល់ដោយព្យុះស៊ីក្លូន MRCS និង IFRC បានរៀបចំកម្មវិធីស្តារឡើងវិញ ដោយប្រើវិធីសាស្ត្រពហុវិស័យរួមបញ្ចូលគ្នា។ ការផ្តោតសំខាន់របស់កម្មវិធីគឺដើម្បីធានាឱ្យបានថាគ្រួសារដែលងាយរងគ្រោះបំផុតទទួលបានរបៀបរស់នៅប្រកបដោយចីរភាពឯករាជ្យក្រោយពេលគ្រោះមហន្តរាយ។ ដើម្បីសម្រេចបាននូវកិច្ចការនេះ គម្រោងត្រូវបានអនុវត្តនៅក្នុងវិស័យផ្សេងៗគ្នា រួមមាន សុខភាពសង្គមចិត្តសាស្ត្រ ទឹកស្អាត និងអនាម័យបរិស្ថាន ទីជម្រក និងការប្រកបរបរចិញ្ចឹមជីវិត។ កម្មវិធីស្តារឡើងវិញនេះ ក៏បានសង្កត់ធ្ងន់លើការកសាងសមត្ថភាពសហគមន៍ ដើម្បីត្រៀមខ្លួនសម្រាប់គ្រោះមហន្តរាយនាពេលអនាគត។ ដូច្នេះ សមាសភាពសម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ក៏ត្រូវបានរួមបញ្ចូលជាសមាសធាតុសំខាន់នៃដំណាក់កាលស្តារឡើងវិញផងដែរ។MRCSបានកំណត់ការស្តារជីវភាពរស់នៅនៃគ្រួសារដែលងាយរងគ្រោះបំផុតដែលជាគោលដៅដ៏សំខាន់មួយនៃកម្មវិធី។គម្រោងប្រកបរបរចិញ្ចឹមជីវិត រួមមាន ការស្តារទ្រព្យសម្បត្តិ ការកសាងសមត្ថភាព សហគមន៍ ការស្តារធនធានធម្មជាតិ និងការងារប្រាក់ឈ្នួល តាមរយៈសាច់ប្រាក់សម្រាប់គម្រោងការងារ (CFW) ត្រូវបានបង្កើតឡើង។ គម្រោង CFW ត្រូវបានរៀបចំឡើងនៅខែតុលាឆ្នាំ២០០៨ ហើយត្រូវបានបញ្ចប់ដោយជោគជ័យនៅខែឧសភា ឆ្នាំ២០០៩។ គម្រោងនេះត្រូវបានរៀបចំឡើង ដើម្បីបញ្ជ្រាបការយល់ដឹងអំពីយេនឌ័រនៅគ្រប់កម្រិតនៃការអនុវត្ត។

**គោលបំណងចម្បងនៃគម្រោង CFW រួមមាន៖**

- ដើម្បីបង្កើតឱកាសការងាររកប្រាក់ឈ្នួលសម្រាប់គ្រួសារងាយរងគ្រោះបំផុត ដែលរងផលប៉ះពាល់ដោយសារព្យុះស៊ីក្លូន
- ដើម្បីធានាបាននូវភាពអាចរកបាននូវស្បៀងអាហារ និងសន្តិសុខសេដ្ឋកិច្ចក្នុងចំណោមគ្រួសារងាយរងគ្រោះបំផុត ដែលមានការយោងដាក់លាក់ចំពោះស្ត្រី
- ដើម្បីស្តារទ្រព្យសម្បត្តិសហគមន៍ និងហេដ្ឋារចនាសម្ព័ន្ធដែលភ្ជាប់ទៅនឹងប្រព័ន្ធប្រកបរបរចិញ្ចឹមជីវិតរបស់សហគមន៍
- ដើម្បីស្តារធនធានធម្មជាតិ និងបរិស្ថានដែលរងផលប៉ះពាល់ដោយសារព្យុះស៊ីក្លូន នៅកម្រិតសហគមន៍។

ក្នុងដំណាក់កាលទាំងអស់នៃគម្រោងCFWទីក្រុងចំនួន១៣ ដែលរងផលប៉ះពាល់ដោយសារព្យុះស៊ីក្លូនត្រូវបានចូលរួម។គម្រោងនេះបានឈានទៅដល់ភូមិចំនួន៦៧ និងគ្របដណ្តប់ភូមិចំនួន ១៧៨។ អ្នកទទួលផលសរុបចំនួន ៦.៦៤៤ នាក់ត្រូវបានជួយ។ ក្នុងនោះ ៣៣ ភាគរយជាស្ត្រី។ ក្រុមដែលងាយរងគ្រោះផ្សេងទៀត រួមមាន ពលករគ្មានដីធ្លី (៦០ភាគរយ) មេគ្រួសារជាបុរស និងស្ត្រីនៅលីវ (១២ភាគរយ) មនុស្សចាស់ (១០ភាគរយ) គ្រួសារធំ (៤ភាគរយ) និងជនពិការ (២ភាគរយ)។គម្រោងនេះទទួលបានជោគជ័យក្នុងការផ្តល់ជំនួយដល់ពលករធម្មតាគ្មានដីធ្លី ដែលងាយរងគ្រោះបំផុតដែលកំពុងត្រូវការការងារជាបន្ទាន់

បន្ទាប់ពីគ្រោះមហន្តរាយ។

ការប៉ាន់ប្រម៉ាណតាមពហុវិស័យក្នុងភូមិ ត្រូវបានអនុវត្ត ដោយក្រុម MRCS ដែលមានអ្នកស្ម័គ្រចិត្តពី ៣០-៤០ភាគរយ ជាស្ត្រី។ក្រុមនេះបានប្រើវិធីសាស្ត្រដោយមានការចូលរួមផ្សេងៗ គ្នាក្នុងកំឡុងពេលធ្វើការប៉ាន់ប្រម៉ាណ រួមមានការពិភាក្សាក្រុម គោលដៅ និងការសម្ភាសជាមួយគ្រួសារ និងភាគីពាក់ព័ន្ធ។ ស្ត្រី ត្រូវបានលើកទឹកចិត្តឱ្យចូលរួមក្នុងក្រុមគោលដៅ ដោយសារវា បានជួយក្រុមប៉ាន់ប្រម៉ាណ ឱ្យដាក់បញ្ចូលទិដ្ឋភាពយេនឌ័រទៅ ក្នុងការយល់ដឹងអំពីតម្រូវការបន្ទាន់របស់សហគមន៍។ ឧទាហរណ៍ វាមានភាពច្បាស់លាស់ថា ពលករគ្មានដីធ្លីមានការលំបាកក្នុង ការស្វែងរកការងារក្រោយគ្រោះមហន្តរាយ ហើយពួកគេត្រូវការ ការងារដើម្បីអាចបំពេញនូវតម្រូវការគ្រួសារ។សកម្មភាពផ្សេងៗ ដែលត្រូវអនុវត្តនៅថ្នាក់ភូមិដោយគម្រោងCFWក៏ត្រូវបានកំណត់ ផងដែរ។ ការយកចិត្តទុកដាក់ខ្លាំងបំផុត ត្រូវបានធ្វើឡើង ដើម្បី កំណត់សកម្មភាពដែលជួយសម្រួលដល់ការចូលរួមរបស់ស្ត្រី។ កិច្ចការទាំងនេះរួមមាន ការជួសជុលផ្លូវក្នុងភូមិ ការស្តារឡើង វិញនូវទំនប់ទន្លេ ការសម្អាតកម្ទេចកំទីពីវិស័យកសិកម្ម និងការ ជួសជុលប្រឡាយ។ក្រុមMRCSបានបង្កើតគោលការណ៍ណែនាំ សម្រាប់ការអនុវត្តគម្រោងជាក់លាក់សម្រាប់ក្រុមកម្រិតសាខា។ គោលការណ៍ណែនាំបានគ្របដណ្តប់លើទិដ្ឋភាពផ្សេងៗគ្នានៃ គម្រោង រួមមាន៖ ការបង្កើតសំណើសកម្មភាព លក្ខណៈវិនិច្ឆ័យ សម្រាប់ការជ្រើសរើសអ្នកទទួលផល ប្រភេទសកម្មភាពដែល ត្រូវជ្រើសរើស អត្រាប្រាក់ឈ្នួលប្រចាំថ្ងៃ ការអនុវត្ត និងនីតិវិធី តាមដាន និងគ្រប់គ្រងហិរញ្ញវត្ថុ។

- លក្ខណៈវិនិច្ឆ័យនៃការជ្រើសរើសដែលរួមបញ្ចូលគោលដៅនៃ អ្នកទទួលផលជាស្ត្រី ៥០ភាគរយ
- ការដាក់បញ្ចូលសកម្មភាពដែលមិនមានលក្ខណៈបច្ចេកទេស ហួសហេតុ ហេតុដូច្នេះ បានជាស្ត្រីត្រូវបានលើកទឹកចិត្តឱ្យ មានការចូលរួម
- ការទូទាត់ប្រាក់ឈ្នួលស្មើគ្នាចំនួន ២.០០០ គីបមីយ៉ាន់ម៉ា ក្នុងមួយថ្ងៃសម្រាប់អ្នកទទួលផលទាំងបុរស និងស្ត្រី
- ប្រាក់ឈ្នួលដែលបានបង់ជូនអ្នកទទួលផលពិតប្រាកដនៅ កន្លែងការងារ និងមិនមែនសម្រាប់សមាជិកគ្រួសារ

បន្ទាប់ពីការបណ្តុះបណ្តាលចាំបាច់ និងការពង្រឹងសមត្ថភាព ក្រុមអនុវត្តការរៀបចំផែនការគម្រោងកម្រិតសហគមន៍បានចាប់ ផ្តើម។ ក្រុម MRCS បានបង្កើតគណៈកម្មាធិការស្តារភូមិ (VTRC) ដែលមានតំណាងជាស្ត្រីយ៉ាងតិចពីរនាក់ ដើម្បីសម្របសម្រួល កម្មវិធីស្តារឡើងវិញ។ ការកៀរគរសហគមន៍ ត្រូវបានអនុវត្ត តាមរយៈ VTRCs ដើម្បីជួយសហគមន៍ឱ្យស្គាល់ពី CFW។ ព័ត៌មានលម្អិតនៃគម្រោង ត្រូវបានពន្យល់នៅក្នុងកិច្ចប្រជុំសហ គមន៍។ កិច្ចការនេះ ត្រូវបានបន្តដោយការសម្រេចចិត្តទាក់ទង នឹងប្រភេទការងារដែលត្រូវអនុវត្តនិងការជ្រើសរើសអ្នកទទួលផល។ ចំនួនអ្នកទទួលផលដែលបានជ្រើសរើសគឺផ្អែកលើចរិតលក្ខណៈ នៃសកម្មភាពទំហំកម្លាំងពលកម្មដែលត្រូវការនិងត្រូវបានសម្រេច ដោយសហគមន៍។ការចូលរួមរបស់ស្ត្រីត្រូវបានលើកទឹកចិត្តនៅ ដំណាក់កាលនៃដំណើរការរៀបចំផែនការនេះ។ផ្អែកលើផែនការស កម្មភាពកម្រិតសហគមន៍ ក្រុម MRCS បន្ទាប់មក បានបង្កើតសំ ណើ។ លក្ខណៈវិនិច្ឆ័យនៃការជ្រើសរើសអ្នកទទួលផលរួមមាន៖

- មនុស្សចាស់ (អាយុ ៥៥ឆ្នាំ ឬចាស់ជាងនេះ ហើយត្រូវការ ការងារធ្វើ)
- គ្រួសារធំ (គ្រួសារដែលមានអ្នកនៅក្នុងបន្ទុក ៨នាក់ ឬ ច្រើនជាងនេះ)
- ជនពិការ
- ស្ត្រីជាមេគ្រួសារ (រួមទាំងស្ត្រីមេម៉ាយ)
- ពលករជម្នាគ្មានដីធ្លី និងគ្រួសារដែលពឹងផ្អែកលើកម្លាំង ពលកម្ម
- គ្រួសារដែលមានមេគ្រួសារជាបុរសតែម្នាក់គត់(គ្រួសារដែល មានឪពុកម្តាយជាបុរសតែម្នាក់គត់ដែលត្រូវមើលថែអ្នកនៅ ក្នុងបន្ទុក)។

នៅមុនពេលសកម្មភាពណាមួយត្រូវបានចាប់ផ្តើម កិច្ចប្រជុំ រៀបចំបន្ថែម ត្រូវបានធ្វើឡើង ដើម្បីបញ្ចប់ប្រព័ន្ធត្រួតពិនិត្យ និងការអនុវត្តគម្រោង។វាបានបង្ហាញយ៉ាងច្បាស់ថាអ្នកទទួលផល ជាស្ត្រីដែលបានជ្រើសរើស ជាពិសេស អ្នកដែលមានគ្រួសារធំ និងអ្នកទាំងឡាយណាដែលជាមេគ្រួសារ បានជួបការលំបាក ក្នុងការចូលរួមពេញមួយថ្ងៃនៃការងារដោយសារការទទួលខុសត្រូវ របស់ពួកគេនៅកម្រិតគ្រួសារក្នុងការមើលថែសមាជិកគ្រួសារ ដទៃទៀត។ ជាការឆ្លើយតប ក្រុម MRCS បានដាក់បញ្ចូលនូវ សង្គមសមាសធាតុចិត្តសាស្ត្រ ទៅក្នុង CFW។ គ្រឿងបរិក្ខារចាំ បាច់ ត្រូវបានផ្តល់ជូនស្ត្រី ដើម្បីនាំកូនៗរបស់ពួកគេទៅទីកន្លែង ធ្វើការ ដើម្បីឱ្យពួកគេអាចចូលរួមក្នុងគម្រោងនេះប្រកបដោយ ផលិតភាព។ ការរៀបចំចាំបាច់ត្រូវបានធ្វើឡើងផងដែរនៅទី កន្លែងធ្វើការ តាមករណីនីមួយៗ ដើម្បីលើកកម្ពស់ការចូលរួម របស់ស្ត្រី។ ការទូទាត់ប្រាក់ឈ្នួលត្រូវបានធ្វើឡើងចំពោះអ្នក ទទួលផលពិតប្រាកដ ហើយមិនមែនសម្រាប់សមាជិកគ្រួសារ ផ្សេងទៀតទេ។ការងារនេះបានជួយធានាថាស្ត្រីដែលចូលរួមក្នុង CFWបានទទួលប្រាក់ឈ្នួលរបស់ពួកគេដោយផ្ទាល់ដែលអាចឱ្យ ពួកគេប្រើប្រាស់ប្រាក់ ដើម្បីបំពេញតម្រូវការនៅក្នុងគ្រួសាររបស់ ពួកគេ។

CFW គឺជាគម្រោងស្តារឡើងវិញជោគជ័យដំបូង ដែលបាន អនុវត្តជាការឆ្លើយតបទៅនឹងតម្រូវការរបស់គ្រួសារងាយរងគ្រោះ បំផុតដែលរងផលប៉ះពាល់ដោយសារព្យុះស៊ីក្លូន។លទ្ធផលសំខា ន់ៗមួយចំនួននៃគម្រោងគឺ៖

- ឱកាសការងារមានប្រាក់ឈ្នួល ត្រូវបានផ្តល់ជូនគ្រួសារងាយ រងគ្រោះចំនួន ៦.៦៤៤ បន្ទាប់ពីគ្រោះមហន្តរាយនេះ។

## FIGURE 3-28: OVERALL BENEFICIARY COVERAGE AND VULNERABILITY COVERAGE

### OVERALL BENEFICIARY COVERAGE




### OVERALL VULNERABILITY COVERAGE OF CFW PROJECT




- កម្មវិធីនេះទទួលបានជោគជ័យក្នុងការពង្រឹងនិងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ក្នុងភូមិដែលរងការខូចខាតដោយសារគ្រោះធម្មជាតិ។

  ការធានាឱ្យមានការចូលរួមយ៉ាងសកម្មរបស់ស្ត្រីនៅក្នុង CFW ទោះបីជាវាជាបញ្ហាប្រឈមក៏ដោយ។ ក្រុម MRCS កំណត់គោលដៅ ៥០ភាគរយនៃការចូលរួមរបស់ស្ត្រី ប៉ុន្តែតាមការពិត គឺសម្រេចបានតែ ៣៣ភាគរយប៉ុណ្ណោះ។ ទោះបីយ៉ាងណាក៏ដោយស្ត្រីបានតំណាងឱ្យក្រុមងាយរងគ្រោះទាំងអស់ដែលអាចមើលឃើញនៅក្នុងតារាងខាងក្រោម៖

### រូបទី៦៥៖ ប្រវត្តិនៃក្រុមងាយរងគ្រោះ

| BENEFICIARY DETAILS | MALE | FEMALE | TOTAL |
|---|---|---|---|
| Elderly | 415 | 243 | 658 |
| Large family | 170 | 69 | 239 |
| Landless casual labourer | 2,979 | 1,038 | 4,017 |
| Single female-headed household | 0 | 808 | 80 |
| Disabled | 122 | 41 | 163 |
| Single male-headed household | 759 | 0 | 759 |
| **TOTAL** | **4,445** | **2,199** | **6,644** |

ΣmPower Women for Climate-Resilient Societies

Sweden Sverige

arrow asian-pacific resource & research centre for women

UN WOMEN



# សៀវភៅណែនាំ បណ្តុះបណ្តាលស្តីពី យេនឌ័រនិងភាពធន់នឹង ការប្រែប្រួលអាកាសធាតុ

## ម៉ូឌុល ៤៖

## យេនឌ័រក្នុងវិធីសាស្ត្របន្សាំ និងសកម្មភាពតាមវិស័យ

4

# ម៉ូឌុល ៤៖ យេនឌ័រក្នុងវិធីសាស្ត្របន្សាំ និងសកម្មភាពតាមវិស័យ

## ផែនការតាមវគ្គ៖

ម៉ូឌុលនេះត្រូវបានបែងចែងជាពីរវគ្គ៖

**វគ្គ ក** : ម៉ូឌែលបន្សាំ និងយេនឌ័រ

**វគ្គ ខ** : វិសាលភាពយេនឌ័រ និងវិសាលភាព CCDRR ក្នុងវិស័យនានា
ក) កសិកម្ម និងសន្តិសុខស្បៀង
ខ) សុខភាពសាធារណៈ និងការឆ្លងរាលដាលជំងឺ
គ) តំបន់ឆ្នេរ

ម៉ូឌុលនេះនឹងលើកឡើងពីវិធីសាស្ត្រផ្សេងៗសម្រាប់ការរៀបចំផែនការបន្សាំដូចជា វិធីសាស្ត្រផ្អែកលើតំបន់ វិធីសាស្ត្រផ្អែកលើប្រព័ន្ធអេកូឡូស៊ី វិធីសាស្ត្រផ្អែកលើហេដ្ឋារចនាសម្ព័ន្ធ វិធីសាស្ត្រផ្អែកលើសហគមន៍ និងការប្រើប្រាស់វិធីសាស្ត្រគ្មានអ្នកណាម្នាក់ត្រូវបានទុកចោល (LNOB)។ ដោយប្រើប្រាស់ករណីសិក្សាមួយចំនួនពីក្នុងតំបន់ ម៉ូឌុលនេះនឹងជួយអ្នកចូលរួមឱ្យកំណត់ចំណុចខ្វះខាត យុទ្ធសាស្ត្រ និងឧបករណ៍ ដែលអាចត្រូវការសម្រាប់អនុវត្តក្នុងការងារផ្ទាល់របស់ពួកគេ។ម៉ូឌុលនេះក៏ផ្តល់ជូនផងដែរនូវការណែនាំជាជំហានៗដល់ការបន្សាំផ្អែកលើសហគមន៍(CBA) និងវិធីសាស្ត្រកសាងភាពធន់ដោយផ្តោតលើ ក) ក្របខ័ណ្ឌទស្សនទាន និងគោលការណ៍ណែនាំ ខ) កសាងស្ថាប័នរបស់មនុស្សដោយមានស្ត្រីនិងកុមារីជាអ្នកស្ថិតនៅជួរមុខ គ) ផ្តល់លទ្ធភាពឱ្យមានកិច្ចសហប្រតិបត្តិការអន្តរវិន័យ និងនៅក្នុងដំណើរការពហុភាគីពាក់ព័ន្ធយ)ផ្សព្វផ្សាយទស្សនទានអាកាសធាតុនិងចំណេះដឹងវិទ្យាសាស្ត្រទៅដល់ស្ត្រី និង ង) អនុវត្តការវាយតម្លៃភាពងាយរងគ្រោះនិងការរៀបចំផែនការភាពធន់នៅនឹងសហគមន៍មូលដ្ឋាន។ នៅក្នុងដំណើរខាងលើនេះ ត្រូវផ្តោតការយកចិត្តទុកដាក់ ធ្វើយ៉ាងណាផ្តល់ឱកាសឲ្យស្ត្រីអាចចូលរួមក្នុងនាមជាភាគីពាក់ព័ន្ធនិងដៃគូស្មើភាពក្នុងគម្រោង CCDRR។ ជាមួយគ្នានេះ ដើម្បីផ្តល់ការយល់ដឹងផ្សេងៗបន្ថែមទៀតអំពី វិសាលភាពយេនឌ័រនៅក្នុងអនុវិស័យផ្សេងៗពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ ម៉ូឌុលនេះក៏បានគ្រប់ដណ្តប់ផងដែរលើ ព័ត៌មានបច្ចេកទេស និងឧបករណ៍នានាសម្រាប់ការធ្វើអន្តរាគមន៍តាមវិស័យ និងករណីនានាអំពីការអនុវត្តសម្រាប់តែយេនឌ័រនិងដំណោះស្រាយបច្ចេកទេសដែលត្រូវបានអនុវត្តក្នុងវិស័យមួយចំនួនផងដែរ។

### គោលបំណងនៃម៉ូឌុល៖

> យល់ដឹងអំពីវិធីសាស្ត្រនានា ចំពោះការរៀបចំផែនការបន្សាំ និងភាពធន់។
> កំណត់ការធ្វើសមាហរណកម្មយុទ្ធសាស្ត្រនិងឧបករណ៍ទៅក្នុងគម្រោងបន្សាំផ្សេងៗ។
> មានសមត្ថភាពបង្កើតគម្រោងបន្សាំ/ភាពធន់ផ្អែកលើសហគមន៍មូលដ្ឋាន។
> យល់ដឹងអំពីវិសាលភាពយេនឌ័រ និងវិសាលភាព CCDRR នៅក្នុងវិស័យមួយចំនួន។ មានលទ្ធភាពកំណត់ ភាគីពាក់ព័ន្ធសំខាន់ៗ យុទ្ធសាស្ត្រ និងសកម្មភាពសម្រាប់ការបញ្ជ្រាបយេនឌ័រក្នុងវិស័យមួយចំនួន។
> ដើម្បីឆ្លុះបញ្ចាំង និងរៀនសូត្រពីការអនុវត្តដែលឆ្លើយតបនឹងតម្រូវការយេនឌ័រនៅក្នុងតំបន់។ និង
> មានសមត្ថភាពរៀបចំគម្រោង CCDRR ដែលឆ្លើយតបនឹងតម្រូវការយេនឌ័រ។

### សារសំខាន់ៗ៖

> ការបន្សាំនឹងការប្រែប្រួលអាកាសធាតុ ពាក់ព័ន្ធនឹងការស្មានទុកជាមុននូវផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុនិងការចាត់វិធានការសមស្រប ដើម្បីបង្ការឬកាត់បន្ថយការខូចខាតដែលអាចបង្កឡើងដោយការប្រែប្រួលអាកាសធាតុទាំងនោះ។
> នៅទូទាំងពិភពលោក មានប្រភេទវិធីសាស្ត្រផ្សេងៗសម្រាប់អនុវត្តការបន្សាំ ដែលត្រូវបានប្រើប្រាស់។ វិធីសាស្ត្រទាំងនេះរួមមានផែនការសកម្មភាពបន្សាំនៅមូលដ្ឋានផែនការភាពធន់ទីក្រុង ការបន្សាំផ្អែកលើហេដ្ឋារចនាសម្ព័ន្ធ ការបន្សាំផ្អែកលើប្រព័ន្ធអេកូឡូស៊ី ការបន្សាំផ្អែកលើសហគមន៍ និងវិធីសាស្ត្រគ្មានអ្នកណាម្នាក់ត្រូវបានទុកចោល។
> ផែនការសកម្មភាពបន្សាំនៅមូលដ្ឋាន(LAPAs)និងផែនការភាពធន់ទីក្រុង (CRP) គឺជាវិធីសាស្ត្រយល់ដឹងពីទីតាំងភូមិសាស្ត្រ (spatial approaches) សម្រាប់ការរៀបចំផែនការបន្សាំ ដែលជាញឹកញាប់ត្រូវបានរៀបចំនៅរដ្ឋបាលថ្នាក់មូលដ្ឋាន និងផ្តោតលើតំបន់មួយដែលគ្រប់គ្រងដោយអង្គភាពរដ្ឋបាលមូលដ្ឋានតាមបែបរិមជ្ឈការ ឬអង្គភាពណាមួយគ្រប់គ្រងភូមិសាស្ត្រនោះ។
> ការបន្សាំផ្អែកលើប្រព័ន្ធអេកូឡូស៊ី(EbA)សំដៅលើដំណោះស្រាយផ្អែកលើធម្មជាតិ ដើម្បីដោះស្រាយការប្រែប្រួលអាកាស

ធាតុនិងគ្រោះមហន្តរាយ។គម្រោងបែបនេះរួមមានសមាសភាពចំនួនពីរ គឺការថែរក្សាប្រព័ន្ធអេកូឡូស៊ី និងភាពធន់ប្រព័ន្ធអេកូឡូស៊ី។ EbA គឺជាវិធីសាស្ត្រប្រកបដោយបរិយាបន្នខ្លាំងព្រោះត្រូវគិតគូលើក្រុមងាយរងគ្រោះ ដែលជីវភាពរបស់ពួកគេពឹងផ្អែកដោយផ្ទាល់លើធនធានធម្មជាតិ។

> ការបន្ស៊ាំសហគមន៍មូលដ្ឋាន (CBA) គឺជាវិធីសាស្ត្រមួយផ្តោតលើដំណើរការនៃការកសាងសមត្ថភាពបន្ស៊ាំជាជាងសកម្មភាពបន្ស៊ាំ។ សមាសភាពសំខាន់មួយនៃគម្រោង CBA ទាំងអស់ត្រូវតែជាការពង្រឹងចំណេះដឹងរបស់សហគមន៍។

> ប្រភេទផ្សេងៗទាំងអស់នៃវិធីសាស្ត្របន្ស៊ាំ អាចជាវិធីសាស្ត្រផ្អែកលើសហគមន៍ ប៉ុន្តែ LAPAs និង EbAs ត្រូវបានគេមើលឃើញថា បានប្រើប្រាស់វិធីសាស្ត្រនេះច្រើន។CBAs ជាទូទៅត្រូវបានប្រើប្រាស់ច្រើនជាងគេដោយអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក។

> មានតម្រូវជាចាំបាច់ឱ្យមានការធ្វើសមាហរណកម្មយេនឌ័រក្នុងវិធីសាស្ត្របន្ស៊ាំទាំងអស់នៅគ្រប់វិស័យ។

> ការបន្ស៊ាំតាមវិស័យជាពិសេសវិស័យដែលពាក់ព័ន្ធនឹងកសិកម្ម សត្វពាហនៈសន្តិសុខស្បៀងការគ្រប់គ្រងទឹកការគ្រប់គ្រងភាពរាំងស្ងួត សេវាសុខភាពសាធារណៈ ព្យុះស៊ីក្លូននៅតំបន់ឆ្នេរ ទឹកជំនន់ និងនេសាទ មានវិសាលភាពយេនឌ័រខ្លាំង ដែលត្រូវយកមកពិចារណាក្នុងដំណើរការរៀបចំផែនការ និងអនុវត្ត។

> សំខាន់ជាងនេះ ស្ត្រីត្រូវការក្លាយជាផ្នែកមួយនៃសកម្មភាពបន្ស៊ាំទាំងអស់ ហើយដំណោះស្រាយសម្រាប់តែយេនឌ័រត្រូវការការលើកកម្ពស់។

| 3:00:00 | ម៉ូឌុល៤ វគ្គ ក៖ ម៉ូឌែលបន្ស៊ាំ និងយេនឌ័រ |
|---|---|
| ទិដ្ឋភាពទូទៅ  | នៅចុងបញ្ចប់នៃវគ្គនេះអ្នកចូលរួមគួរមានសមត្ថភាពយល់ដឹងអំពីគោលការណ៍ណែនាំនិងដំណើរការនៃវិធីសាស្ត្របន្ស៊ាំនានា។ពួកគេគួរតែមានសមត្ថភាពក្នុងការកំណត់យុទ្ធសាស្ត្រផ្សេងសម្រាប់ការធ្វើសមាហរណកម្មយេនឌ័រនៅក្នុងដំណើរការទាំងនោះ។ |
| មាតិកា  | ក) ផែនការសកម្មភាពបន្ស៊ាំនៅមូលដ្ឋាន (LAPAs)<br>ក. ករណីសិក្សាអំពីប្រទេសនេប៉ាល់<br>ខ) ផែនការភាពធន់ទីក្រុង<br>ក. ករណីសិក្សាអំពីប្រទេសឥណ្ឌូណេស៊ី "Semarang"<br>គ) ការបន្ស៊ាំផ្អែកលើហេដ្ឋារចនាសម្ព័ន្ធ<br>ក. ករណីសិក្សាអំពីប្រទេសចិន<br>ខ. ករណីសិក្សាអំពីប្រទេសបង់ក្លាដែស<br>ឃ) ការបន្ស៊ាំផ្អែកលើប្រព័ន្ធអេកូឡូស៊ី<br>ក. ករណីសិក្សាអំពីប្រទេសវៀតណាម<br>ខ. ករណីសិក្សាអំពីប្រទេសនេប៉ាល់<br>ង) វិធីសាស្ត្របន្ស៊ាំផ្អែកលើសហគមន៍<br>ក. ករណីសិក្សាអំពីប្រទេសវៀតណាម<br>ខ. ករណីសិក្សាអំពីប្រទេសឥណ្ឌា |
| ឯកសារ  | បទបង្ហាញជា PowerPoint<br>ឧបករណ៍ចាក់បញ្ចាំងវីដេអូនៅលើ Youtube<br>ក្តារខៀន និងប៊ិចហ្វឺតធំ<br>ផ្ទាំងក្រដាសធំ និងប៊ិច<br>ឯកសារមេរៀន |

តារាងពេលវេលា 

| រយៈពេល | សកម្មភាព |
|---|---|
| ៥នាទី | > ការចែករំលែកអំពីទិដ្ឋភាពទូទៅ និងមាតិការបស់វគ្គ និងដំណើរការវគ្គ |
| ៨៥នាទី<br>៩០នាទី | > បទបង្ហាញជា (PowerPoint) ស្តីពី "ម៉ូឌែលបន្ស៊ាំ" ដោយលើកជាសំនួរពិភាក្សាក្នុងជាក្រុមធំដើម្បីវាយតម្លៃលើភាពឆ្លើយតបនឹងតម្រូវការយេនឌ័រនៃគម្រោងបន្ស៊ាំ(សូមមើលលំហាត់ទី ២១ និងឯកសារមេរៀនទី១៦ និង ១៧) |
| | > វិធីសាស្ត្រត្រួតពិនិត្យករណីសិក្សា Harvard សម្រាប់ "គម្រោងភាពធន់ទីក្រុងផ្អែកលើសហគមន៍ដែលដឹកនាំដោយស្ត្រី" (សូមមើលលំហាត់ទី ២២ និងឯកសារមេរៀនទី១៨) |

កំណត់សម្គាល់ណែនាំ



ចែកទិដ្ឋភាពទូទៅនិងខ្លឹមសាររបស់វគ្គជាមួយអ្នកចូលរួមហើយប្រាប់ថាវគ្គនេះនឹងខុសប្លែកពីវគ្គមុនៗបន្តិច។ បន្ទាប់មកប្រាប់ថា វគ្គនេះមានគោលបំណងផ្តល់ជូនអ្នកចូលរួមនូវទិដ្ឋភាពទូទៅមួយរបស់ម៉ូឌែលបន្សាំផ្សេងៗ តាមរយៈការធ្វើបទបង្ហាញលម្អិត និងការចែករំលែកឧទាហរណ៍។ អ្នកនឹងកំពុងធ្វើបទបង្ហាញមួយអំពី "ម៉ូឌែលបន្សាំ"ផ្សេងៗ។ក្នុងពេលជាមួយគ្នានោះដែរការពិភាក្សាក្នុងថ្នាក់ស្តីពីការវាយតម្លៃលើភាពឆ្លើយតបនឹងតម្រូវការយេនឌ័ររបស់គម្រោងបន្សាំមួយចំនួនក៏នឹងធ្វើផងដែរ។ ប្រាប់សិក្ខាកាមថា ពួកគេត្រូវតែវាយតម្លៃគម្រោងរបស់ពួកគេដោយផ្អែកលើឧបករណ៍ GRAS ដែលពួកគេបានរៀនក្នុងវគ្គមុន។ (សូមមើលលំហាត់ទី២១ និងឯកសារមេរៀនទី ១៦ និងទី ១៧)។ ចាប់ផ្តើមបទបង្ហាញ និងបន្ទាប់ពីបញ្ចប់ប្រភេទម៉ូឌែលនីមួយៗ សម្រាកបន្តិចដើម្បីចែករំលែកករណីសិក្សាដែលពាក់ព័ន្ធ (សូមមើលគន្លឹះសម្រាប់គ្រូឧទ្ទេស)។

បន្ទាប់ធ្វើកិច្ចការនេះរួចហើយ នឹងមានការអនុវត្តវិធីសាស្ត្រត្រួតពិនិត្យករណីសិក្សា ដើម្បីផ្តល់លទ្ធភាពដល់អ្នកចូលរួមឱ្យរៀនសូត្រអំពីវិធីសាស្ត្របន្សាំផ្អែកលើសហគមន៍និងវិធីសាស្ត្រភាពធន់លម្អិត។ករណីសិក្សាលម្អិតមួយត្រូវបានផ្តល់ជូន ដើម្បីនាំផ្លូវអ្នកចូលរួមតាមរយៈជំហាន និងដំណាក់កាលរៀបចំគម្រោង។ វានឹងបង្ហាញអំពីរបៀបដែលការបង្កើតសកម្មភាព ដែលមានទស្សនយេនឌ័រជាក់លាក់ក្នុងលក្ខណៈដែលមានការចូលរួមដោយធ្វើការងារជាមួយភាគីពាក់ព័ន្ធជាច្រើន (សហគមន៍ ស្ត្រី ទីភ្នាក់ងារម្ចាស់ជំនួយ រដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាលដែលពាក់ព័ន្ធ)។ ការចូលរួមគឺជាគន្លឹះមួយក្នុងជំហានរៀបចំគម្រោងទាំងអស់នេះ រាប់ចាប់ពីការប្រមូលទិន្នន័យ ការកំណត់ឧបសគ្គ តម្រូវការនិងកត្តាបង្កឱ្យមានលទ្ធភាពជាសក្តានុពល រហូតដល់ការបង្កើតសកម្មភាពដែលផ្តោតលើស្ត្រី និងថវិកាដែលពាក់ព័ន្ធ តម្រូវការបុគ្គលិកនិងសូចនាករ។ (សូមមើលលំហាត់ទី២២ និងឯកសារមេរៀនទី១៨)។ ចូរធ្វើឱ្យប្រាកដថាអ្នកបានចែកឯកសារមេរៀនទៅឱ្យអ្នកចូលរួមទាំងអស់ឱ្យបានរួចរាល់ជាមុន ដើម្បីឱ្យពួកគេមានពេលវេលាគ្រប់គ្រាន់ដើម្បីអានវា។ គន្លឹះសម្រាប់គ្រូឧទ្ទេសនៅលំហាត់ទី ២២ ក៏ផ្តល់តំណភ្ជាប់វីដេអូអំពីរបៀបសម្របសម្រួលប្រសើរបំផុតសម្រាប់វគ្គត្រួតពិនិត្យករណីសិក្សាផងដែរ។ គ្រូឧទ្ទេសត្រូវឱ្យមើលវីដេអូទាំងនេះ ព្រមទាំងអានករណីសិក្សានេះឱ្យបានម៉ត់ចត់មុនពេលសម្របសម្រួលវគ្គនេះ។

## ម៉ូឌែលបន្សាំ និងយេនឌ័រ

ការបន្សាំនឹងការប្រែប្រួលអាកាសធាតុត្រូវមានការស្មានទុកជាមុនពីផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុនិងការចាត់វិធានការសមស្រប ដើម្បីបង្ការឬកាត់បន្ថយការខូចខាតដែលផលប៉ះពាល់ទាំងនោះបង្កឡើង។ ការធ្វើបែបនេះមានគោលដៅ កាត់បន្ថយភាពងាយរងគ្រោះ និងការប្រឈមទៅនឹងឥទ្ធិពលគ្រោះថ្នាក់នៃការប្រែប្រួលអាកាសធាតុ (ដូចជាការកើនឡើងកម្ពស់ទឹកសមុទ្រហេតុការណ៍ធាតុអាកាសដែលប្រែប្រួលខ្លាំងឬអសន្តិសុខស្បៀងជាដើម)។វាក៏មានគោលដៅផ្តោតទៅលើការបង្កើតឱកាសឲ្យបានច្រើនជាអតិបរិមានៃឱកាសដែលអាចផ្តល់ផលប្រយោជន៍សក្តានុពលណាមួយ ដែលកើតឡើងពីការប្រែប្រួលអាកាសធាតុ (ឧទាហរណ៍ រដូវដាំដុះវែងជាងមុន ឬបង្កើនទិន្នផលក្នុងតំបន់មួយចំនួន)។

នៅទូទាំងពិភពលោក មានប្រភេទវិធីសាស្ត្រផ្សេងៗសម្រាប់ការអនុវត្តការបន្សាំដែលត្រូវបានយកមកប្រើប្រាស់ក្នុងរយៈពេល ២ ទសវត្សរ៍ចុងក្រោយនេះ។ វិធីសាស្ត្រមួយចំនួនក្នុងចំណោមវិធីសាស្ត្រទាំងនោះ គឺជាវិធីសាស្ត្ររយៈពេលខ្លី (តិចជាង ១០ ឆ្នាំ) សម្រាប់ដោះស្រាយផលប៉ះពាល់ដែលបានកើតឡើងរួចហើយនិងទំនងជានឹងកើនឡើងនៅក្នុងពេលអនាគតឆាប់ៗ។ វិធីសាស្ត្រទាំងនេះជាញឹកញាប់គឺជាវិធានការដោះស្រាយតាមទីតាំងជាក់ស្តែង ដោយសំដៅទៅលើ ហេដ្ឋារចនាសម្ព័ន្ធ ឬសេវាក្នុងមូលដ្ឋានដែលជាញឹកញាប់ផ្តោតទិសដៅឆ្លើយតបឆ្ពោះទៅរកហានិភ័យជាក់លាក់ណាមួយ។ វិធីសាស្ត្រជាច្រើនគឺជាការឆ្លើយតបរយៈពេលមធ្យម ឬរយៈពេលវែង ដែលផ្តោតលើ ការពង្រឹងសមត្ថភាពបន្សាំ ឬសមត្ថភាពជាប្រព័ន្ធមួយ (មនុស្ស ធម្មជាតិ ឬគ្រប់គ្រង) ដើម្បីសម្របខ្លួនទៅនឹងការប្រែប្រួលអាកាសធាតុ។

ផែនការសកម្មភាពបន្សាំនៅក្នុងមូលដ្ឋាន (LAPAs) ការប្រើប្រាស់រួមគ្នានូវវិធីសាស្ត្រពីក្រោមមកលើនិងពីលើចុះក្រោម(Bottom-up and Top Down Approaches)

ផែនការសកម្មភាពបន្សាំនៅមូលដ្ឋាន (LAPAs) គឺជាវិធីសាស្ត្រយល់ដឹងពីទីតាំងភូមិសាស្ត្រ សម្រាប់ការរៀបចំផែនការបន្សាំ។ LAPAs ជាញឹកញាប់ត្រូវបានរៀបចំនៅរដ្ឋបាលថ្នាក់មូលដ្ឋាននិងផ្តោតលើតំបន់មួយដែលគ្រប់គ្រងដោយអង្គភាពរដ្ឋបាលមូលដ្ឋានតាមបែបវិមជ្ឈការឬអង្គភាពណាមួយគ្រប់គ្រងភូមិសាស្ត្រនោះ។ LAPAs អាចត្រូវបានរៀបចំដោយមានឬគ្មានការចូលរួមរបស់សហគមន៍ បើទោះជានៅក្នុងករណីភាគច្រើន LAPAs មានសមត្ថភាពបញ្ជ្រាបដំណើរការដោយមានការចូលរួមក្តី។ LAPAs គឺជាដំណើរការនៃកិច្ចការត្រូវធ្វើជាបន្តបន្ទាប់ឥតឈប់ឈរ ដើម្បីកំណត់ និងដោះស្រាយគោលដៅបន្សាំរយៈពេលមធ្យម និងរយៈពេលវែង។

ការអនុវត្ត LAPA ដំបូងឡើយត្រូវបានផ្តួចផ្តើមគំនិតឡើងនៅក្នុងប្រទេសនេប៉ាល់ ដែលជាផ្នែកមួយនៃដំណើរការបង្កើតកម្មវិធី

សកម្មភាពជាតិបន្សាំនឹងការប្រែប្រួលអាកាសធាតុ (NAPA) (Peniston ឆ្នាំ២០១៣)។ រដ្ឋាភិបាលនេប៉ាល់បានបង្កើត LAPAs នៅក្នុងស្រុកចំនួន១៤ (៨៧ភូមិ និង ៩ក្រុង) ដែលបានជួយបញ្ចូលអាទិភាព តម្រូវការ និងសមត្ថភាពក្នុងមូលដ្ឋានទៅក្នុងការរៀបចំផែនការ គោលនយោបាយ និងសកម្មភាពថ្នាក់ជាតិ (Rattani និង Lama ឆ្នាំ២០១៨)។ ក្រោយការសាកល្បងដំបូង LAPAs ក៏ត្រូវបានរួមបញ្ចូលក្នុងដំណើរការផែនការជាតិបន្សាំ (NAP) ផងដែរ (Daze et al ឆ្នាំ២០១៨)។

ជាពិសេស ក្របខ័ណ្ឌ LAPA (រដ្ឋាភិបាលនេប៉ាល់ ឆ្នាំ២០១១) គាំទ្រ៖

> ការបង្កើតផែនការបន្សាំនៅមូលដ្ឋាន ដែលឆ្លុះបញ្ចាំងពីគ្រោះថ្នាក់និងផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុផ្អែកលើទីតាំងឬតំបន់ជាក់លាក់។ ផែនការទាំងនេះគាំទ្រដល់ជម្រើសនានាក្នុងការបន្សាំ ដែលអាចរកបាននៅក្នុងមូលដ្ឋាន និងដែលអាចប្រើប្រាស់បានដោយសហគមន៍និងគ្រួសារងាយរងគ្រោះបំផុត រួមទាំងស្ត្រីផងដែរ។
> ការធ្វើសមាហរណកម្មអាទិភាពបន្សាំក្នុងមូលដ្ឋានទៅក្នុងដំណើរការរៀបចំផែនការថ្នាក់ភូមិ ក្រុង ស្រុក និងតាមវិស័យស្របតាមច្បាប់ស្តីពីស្វ័យអភិបាលកិច្ចមូលដ្ឋាន។
> ការអនុវត្តផែនការបន្សាំនៅមូលដ្ឋានតាមរយៈការគាំទ្រដល់ការចែកចាយសេវាបន្សាំឱ្យទាន់ពេលវេលានិងប្រកបដោយនិរន្តរភាពទៅកាន់អ្នកដែលងាយរងគ្រោះបំផុតរួមទាំងស្ត្រីផងដែរ។
> ការរៀបចំផែនការបន្សាំត្រូវធ្វើបច្ចុប្បន្នភាពជាប្រចាំ ដោយផ្អែកតាមលទ្ធផលនៃការតាមដានវាយតម្លៃ និងការយោបល់ត្រឡប់ដែលទទួលបានជាបន្តបន្ទាប់។

ក្របខ័ណ្ឌ LAPA ត្រូវបានបង្កើតឡើងនេះមាន ៧ ជំហានសម្រាប់ការធ្វើសមាហរណកម្មភាពធន់នឹងការប្រែប្រួលអាកាសធាតុទៅក្នុងដំណើរការរៀបចំផែនការពីថ្នាក់មូលដ្ឋានរហូតដល់ថ្នាក់ជាតិ។ ជំហានទាំងនេះរួមមាន៖ ក) ការធ្វើឱ្យជ្រួតជ្រាបយល់ដឹងពីស្ថានភាព ខ) ការប៉ាន់ប្រមាណភាពងាយរងគ្រោះនិងការបន្សាំនឹងអាកាសធាតុ គ) ការកំណត់អាទិភាពជម្រើសបន្សាំ ឃ) ការបង្កើតផែនការសកម្មភាពបន្សាំនៅមូលដ្ឋាន ង) ការធ្វើសមាហរណកម្មផែនការសកម្មភាពបន្សាំនៅមូលដ្ឋានទៅក្នុងដំណើរការរៀបចំផែនការសកម្មភាព ច) ការអនុវត្តផែនការសកម្មភាពបន្សាំនៅមូលដ្ឋាន និង ឆ) ការប៉ាន់ប្រមាណវឌ្ឍនភាពផែនការសកម្មភាពបន្សាំនៅមូលដ្ឋាន (Peniston ឆ្នាំ២០១៣)។ ក្នុងជំហាននីមួយៗត្រូវពិចារណាដោយប្រុងប្រយ័ត្ន ថាតើហេតុអ្វីបានជាវាមានសារៈសំខាន់ សកម្មភាពអ្វីខ្លះដែលគួរត្រូវបានធ្វើឡើង ហើយបញ្ជីឧបករណ៍ដោយមានការចូលរួមសមស្របត្រូវរៀបចំបង្កើតឡើង។ ឯកសារមេរៀនទី១៤បានលើកឡើងអំពីដំណើរការនិងឧបករណ៍សំខាន់ៗ ដែលមាននៅក្នុងដំណាក់ការនីមួយៗនៃ LAPA។ ក្របខ័ណ្ឌនេះមានមូលដ្ឋានលើគោលការណ៍ចំនួន៤គឺការរៀបចំផែនការពីក្រោមឡើងមកលើ, បរិយាបន្នមានការឆ្លើយតបនិងមានភាពបទបែន (តារាងទី១៤)

**តារាងទី១៤៖ គោលការណ៍ LAPA**

| | |
|---|---|
| **ការរៀបចំផែនការពីក្រោមឡើងមកលើ** | ការរៀបចំផែនការក្រោមឡើងមកលើ សំដៅដល់ដំណើរការរៀបចំផែនការដែលចាប់ផ្តើមពីប្រជាជននិងអាជ្ញាធរនៅមូលដ្ឋាន ហើយក្រោយមកបញ្ជូនទៅកាន់ថ្នាក់រដ្ឋបាលមូលដ្ឋាន។ បន្ទាប់មក ផែនការបន្សាំត្រូវបានដាក់បញ្ចូលទៅក្នុងថ្នាក់រៀបចំផែនការរដ្ឋបាលដែលមានឋានានុក្រមខ្ពស់ជាងនេះ។ |
| **បរិយាបន្ន** | តម្រូវការរួមបញ្ចូលប្រជាជនចម្រុះ (បុរសនិងស្ត្រីដែលមានមានអាយុវណ្ណៈឬជាតិពន្ធផ្សេងៗ) ខណៈដែលអ្នកធ្វើសេចក្តីសម្រេចចិត្តក្នុងការធ្វើសមាហរណកម្មភាពធន់នឹងការប្រែប្រួលអាកាសធាតុទៅក្នុងដំណើរការរៀបចំផែនការ។ ជាពិសេស យេនឌ័រត្រូវបានធ្វើសមាហរណកម្មនៅទូទាំងដំណើរការ LAPA តាមរយៈយុទ្ធសាស្ត្របរិយាបន្នសមភាពយេនឌ័រនិងសង្គម (GESI) ដែលត្រូវបានបង្កើតឡើងដោយក្រសួងព្រៃឈើនិងអភិវឌ្ឍន៍មូលដ្ឋានក្នុងឆ្នាំ២០០៩។ |
| **មានការឆ្លើយតប** | ជានាថា ដំណើរការរៀបចំផែនការ បង្កើតភាពធន់របស់សហគមន៍និងគ្រួសារងាយរងគ្រោះបំផុតពីអាកាសធាតុ ត្រូវបានយកចិត្តទុកដាក់មុនគេ។ |
| **មានភាពបទបែន** | លទ្ធភាពនៃដំណើរការរៀបចំផែនការត្រូវតែធ្វើជាប្រចាំ (iterative) ទៅតាមវិធីសាស្ត្ររបស់នីមួយៗ ដែលចាំបាច់ ដែលនោះគឺជាក្របខ័ណ្ឌសម្រាប់ធ្វើសេចក្តីសម្រេចចិត្ត និងអនុវត្ត ដែលជាលទ្ធភាពឆ្លើយតបភ្លាមៗទៅនឹងកាលៈទេសៈ និងព័ត៌មានដែលប្រែប្រួលទាំងនោះ។ |

ប្រភព៖ (រដ្ឋាភិបាលនេប៉ាល់ ឆ្នាំ២០១១)

## ការបញ្ជ្រាបយេនឌ័រក្នុង LAPAs

ក្នុងដំណើងការបង្កើត NAPA ក្នុងប្រទេសនេប៉ាល់នៅឆ្នាំ ២០១០ការវិភាគលើការយល់ដឹងពីស្ថានភាពយេនឌ័រដែលរងផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុត្រូវបានធ្វើឡើង ដើម្បីរំលេចភាពងាយរងគ្រោះផ្សេងៗគ្នារបស់ស្ត្រីនៅវិស័យទាំង ៦ នៃ NAPA។ LAPAបានចាត់វិធានការបន្ថែមដោយចាត់ទុកស្ត្រីគឺជាភ្នាក់ងារនៃការផ្លាស់ប្តូរជាពិសេសលើកឡើងពីការពិតចំពោះការធ្វើចំណាកស្រុករបស់បុរសដែលបានធ្វើឱ្យចំនួនគ្រួសារមានស្ត្រីជាមេគ្រួសារកាន់តែច្រើនឡើងនៅក្នុងប្រទេសដែលជាហេតុធ្វើឱ្យមានការកើនឡើងនូវចំនួនស្ត្រីក្នុងវិស័យកសិកម្មនិងភាពពឹងផ្អែករបស់ប្រទេសលើស្ត្រីសម្រាប់ការគ្រប់គ្រងធនធានធម្មជាតិនិងសុខភាព(រដ្ឋាភិបាលនេប៉ាល់ ឆ្នាំ២០១១)។ ហេតុដូចនេះ យេនឌ័រត្រូវបានធ្វើសមាហរណកម្មនៅទូទាំងដំណាក់កាលទាំងអស់នៃLAPA(រូបថទី៤៧)។

ការផ្តោតក៏ត្រូវបានពង្រីកផងដែរ នៅក្នុងការបង្កើត NAP ដែលមាន "បរិយាបន្នយេនឌ័រនិងសង្គម (ក្រុមដែលជួបការលំបាក)" ជាបញ្ហាអន្តរវិស័យ និងជាប្រធានបទដាច់ដោយឡែក (stand-alone theme)។ ការផ្តោតក៏ធ្វើឡើងផងដែរក្នុងការបង្កើតសកម្មភាពបន្សាំផ្សេងៗជាប្រចាំជាមួយគ្នានេះក៏ដើម្បីធានាបាននូវភាពជាតំណាងរបស់ស្ត្រី និងក្រុមងាយរងគ្រោះនៅគ្រប់ក្រុមការងារទាំងអស់ផងដែរ (Daze et al ឆ្នាំ២០១៨)។

**សម្រាកដើម្បីចែក** **រំលែកករណីសិក្សា**

## ផែនការសកម្មភាពភាពធន់ទីក្រុង៖ ការរៀបចំផែនការពហុវិស័យ

និន្នាការនគរូបនីយកម្មយ៉ាងឆាប់រហ័សដែលបានផ្លាស់ប្តូរភពផែនដីពីទីក្រុងដែលមានតែ ៣០% ក្នុងឆ្នាំ១៩៥០ ដល់ជាង ៥៥% ក្នុងពេលសព្វថ្ងៃហើយរំពឹងកើនឡើងទ្វេដងនៅត្រឹមឆ្នាំ២០៥០។ នេះមានន័យថា ប្រជាជនចំនួន ៧ នាក់ ក្នុងចំណោម ១០នាក់នៅក្នុងពិភពលោកនឹងរស់នៅក្នុងទីក្រុង (ធនាគារពិភពលោក ២០២០)។ចំណុចសំខាន់មួយនៃការកើនឡើងនេះនឹងកើតមានឡើងនៅក្នុងតំបន់អាស៊ីខាងត្បូង និងអនុតំបន់អាហ្វ្រិកសាហារ៉ាដែលតំបន់ទាំងពីរនេះមានការប្រឈមកាន់តែខ្លាំងទៅនឹងផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ។ ដូច្នេះការជួយឱ្យមានភាពធន់ទីក្រុងបានក្លាយជារឿងសំខាន់ចំពោះការសម្រេចឱ្យបាននូវរបៀបវារៈអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព។

ដោយទទួលស្គាល់ករណីនេះ ទីក្រុងកាន់តែច្រើនឡើងកំពុងដោះស្រាយភាពងាយរងគ្រោះរបស់ពួកគេដោយសារការប្រែអាកាសធាតុតាមរយៈការបង្កើតផែនការភាពធន់និង/ឬតាមរយៈការកំណត់អាទិភាព CCDRR ក្នុងផែនការមេ និងផែនការតាមវិស័យជាក់លាក់។ ផែនការទាំងនេះជាញឹកញាប់ប្រើប្រាស់យុទ្ធសាស្ត្រជម្រុះ ដើម្បីជួយទីក្រុងនានាឱ្យយល់ដឹងអំពីភាពងាយរងគ្រោះរបស់ខ្លួន និងរៀបចំខ្លួនសម្រាប់ផលប៉ះពាល់អាកាសធាតុ និងគ្រោះមហន្តរាយ។ ភាពធន់ទីក្រុងគឺជាអ្វី ដែលជួយទីក្រុងនានាឱ្យបន្សាំ និងផ្លាស់ប្តូរខ្លួនឯង ក្នុងគ្រាដែលប្រឈមនឹងបញ្ហាទាំងនេះ ដោយជួយទីក្រុងទាំងនេះឱ្យរៀបចំខ្លួនសម្រាប់ទប់ទល់នឹងបញ្ហាទាំងរំពឹងទុក និងឥតរំពឹងទុក។ ទីក្រុងដែលមានភាពធន់ (RC) ចំនួន១០០ កំណត់ភាពធន់ទីក្រុងថាជា "សមត្ថភាពរបស់បុគ្គល សហគមន៍ ស្ថាប័ន អាជីវកម្ម និងប្រព័ន្ធនានានៅក្នុងទីក្រុងមួយដើម្បីរស់បាន បន្សាំ និងរីកចម្រើនដោយមិនថាមានស្ត្រេសរ៉ាំរ៉ៃ និងបញ្ហាស្រួចស្រាលប្រភេទណាកើតឡើងចំពោះពួកគេទេ"។ ការកសាងភាពធន់ទីក្រុងតម្រូវឱ្យសម្លឹងមើលទីក្រុងទាំងមូល៖ ការយល់ដឹងអំពីប្រព័ន្ធនានាដែលបង្កើតបានជាទីក្រុងនិងការពឹងផ្អែកគ្នាទៅវិញទៅមក និងហានិភ័យដែលប្រព័ន្ធទាំងនោះអាចប្រឈមក្នុងពេលអនាគត។ តាមរយៈការពង្រឹងរចនាសម្ព័ន្ធមូលដ្ឋានរបស់ទីក្រុង និងការស្វែងយល់កាន់តែប្រសើរអំពីបញ្ហា និងស្ត្រេសដែលអាចកើតមានដែលទីក្រុងអាចប្រឈមទីក្រុងអាចលើកកម្ពស់គន្លងអភិវឌ្ឍន៍ និងសុខុមាលភាពពលរដ្ឋរបស់ខ្លួន។

ក្របខ័ណ្ឌភាពធន់ទីក្រុង (Arup International និងមូលនិធិRockefeller)ផ្តល់ទស្សនវិស័យមួយដើម្បីជួយឱ្យស្វែងយល់អំពីភាពស្មុគស្មាញរបស់ទីក្រុង ហើយទស្សនវិស័យនេះកំណត់កត្តាជាច្រើនដែលចាំបាច់សម្រាប់ភាពធន់របស់ទីក្រុង។ CRF ពិពណ៌នាអំពីប្រព័ន្ធសំខាន់ៗរបស់ទីក្រុងមួយទាក់ទងនឹងវិសាលភាពចំនួន៤ដែលរួមមានសុខភាពនិងសុខុមាលភាពសេដ្ឋកិច្ចនិងសង្គម ហេដ្ឋារចនាសម្ព័ន្ធនិងបរិស្ថាន និងភាពជាអ្នកដឹកនាំនិងយុទ្ធសាស្ត្រ។វិសាលភាពនីមួយៗមាន "កត្តា" ចំនួន៣មានគោលដៅសរុបចំនួន១២ និងមានសូចនាករចំនួន ៥២ ដែលឆ្លុះបញ្ចាំងអំពីសកម្មភាពនានាដែលទីក្រុងអាចធ្វើឡើងដើម្បីលើកកម្ពស់ភាពធន់របស់ខ្លួន។ ក្របខ័ណ្ឌនេះក៏បង្កើតឡើងផ្អែកលើការស្រាវជ្រាវដែលមានស្រាប់អំពីប្រព័ន្ធភាពធន់ និងកំណត់ចរិកលក្ខណៈចំនួន ៧ ដែលប្រព័ន្ធភាពធន់ទីក្រុងមួយត្រូវការផងដែរ។ គុណភាពទាំង៧ នេះរួមមាន ឆ្លុះបញ្ចាំង រឹងមាំ ច្រើនលើសលុប មានភាពបត់បែន មានធនធានច្រើន បរិយាបន្ន និងធ្វើសមាហរណកម្ម។ ទិដ្ឋភាពបរិយាបន្នផ្តោតជាពិសេសលើតម្រូវការសម្រាប់ការពិគ្រោះយោបល់ពីបរទេស និងការចូលរួមរបស់សហគមន៍រួមទាំងក្រុមដែលងាយរងគ្រោះបំផុត (ARUP ឆ្នាំ២០១៥)។ តារាងទី១៥ ខាងក្រោមបានកំណត់វិសាលភាពយេនឌ័រ ដែលមានសារៈសំខាន់ក្នុងការពិចារណានៅទូទាំងវិសាលភាពទាំង៤ និងគោលដៅទាំង១២។

**គន្លឹះសម្រាប់គ្រូឧទ្ទេស**

ចាក់បញ្ចាំងភាពយន្តខ្លីដែលអាចរកបាននៅគេហទំព័រ https://www.youtube.com/watch?v=hLPcDfDWKes សម្រាប់អ្នកចូលរួមដើម្បីស្វែងយល់អំពីក្របខ័ណ្ឌនិងសូចនាករនានា។

## រូបទី៤៧៖ វដ្ត LAPA ក្នុងប្រទេសនេប៉ាល់

**STEP 1: CLIMATE CHANGE SENSITIZATION (Carried out in all steps)**

- At the outset of LAPA formulation, hold climate change sensitization-related interaction, workshop and seminar at community, village, town and district levels.
- Ensure information flow and awareness raising throughout the LAPA process to support learning and feedback.

Data generation and awareness building on gender and caste issues (gender analysis and mobility mapping)

> Raise awareness around the impacts of climate change and the means to address these impacts.
> Strengthen and establish institutions and organisations that will drive local adaptation.

**STEP 2: VULNERABILITY AND ADAPTATION ASSESSMENT**

- Identify climate vulnerable communities and households
  - Identify vulnerable VDCs, municipalities
  - Identify vulnerable wards
  - Identify vulnerable households/communities
- Identify adaptation practices and actions

**Gender analysis and identification of vulnerable men and women across social groups in the hotspots**

> Identify climate vulnerable VDCs, municipalities, wards and vulnerable communities, households and individuals within these wards;
> Identify adaptation practices and actions that will reduce vulnerability to current and future climate change; and
> Support identification and efficient mobilization of resources planning.

**STEP 3: PRIORITIZATION OF ADAPTATION OPTIONS**

- Identify and prioritize the most urgent and important adaptation actions for the most vulnerable people, community, VDC and municipality;
- Prioritize the actions based on social, environmental, technological and economic costs and benefits.

**Using gender-sensitive multi-criteria ranking/analysis to prioritize the most urgent and important adaptation actions based on gender needs and priorities**

> Prioritize the most urgent and cost-effective adaptation actions for implementation.

**STEP 4: LAPA FORMULATION**

- Base the plan around identified & prioritised adaptation actions;
- Identify areas to implement adaptation actions;
- Identify competent service providers to implement adaptation actions;
- Estimate the costs for identified actions and allocate for the implementation of identified adaptation actions;
- Integrate progress monitoring into the plan for action, and include procedure for monitoring of each action.

**Build roadmap showing the adaptation journey with milestones, targets and monitoring**

> Ensure that decision is made in consultation with women to understand their availability and interest, as also their accessibility to the action sites. Focus on "How to ensure equitable access to the benefits for women?"

**STEP 5: LAPA INTEGRATION INTO PLANNING PROCESS**

- Prepare a plan for settlement and ward level adaptation actions and integrate into a VDC or municipality plan;
- Identify entry points for integrating LAPA into local development planning processes;
- Submit LAPA to the local bodies for necessary ratification (acceptance); and
- Submit feedback and learning regularly to departments, ministries and National Planning Commission to ensure integration of climate adaptation and resilience aspects into national development planning.

**Ensure mechanisms have a system and capacities to ensure gender and social inclusion into the integration process. Adopt Gender-Responsive Budgeting.**

> Support the integration of climate adaptation and resilience into sectoral development plans.
> Support the integration of identified adaptation actions into public, private and NGO planning processes.

**STEP 6: LAPA IMPLEMENTATION**

- Strengthen district and VDC level institution mechanism (Environment, Energy, Climate Change Coordination Committee)
  - Define responsibilities of different institutions for LAPA implementation;
  - Implement the plans logically and sequentially, but ensuring flexible approach that can be responsive to additional information through monitoring and evaluation;
  - Commission and contract the Service Providers through competitive process based on needs, expertise and skills.

**Ensure equity provisions to promote gender equality and inclusion in decision making processes.**

> Implement Local Adaptation Plans for Action.

**STEP 7: LAPA PROGRESS ASSESSMENT**

- Develop and monitor the implementation of a monitoring plan that contains indicators, baselines and targets;
- Develop monitoring information system;
- Develop the provision of periodic participatory evaluation meeting, public audit and public hearing;
- Develop monitoring tools such as score card evaluation for quality assurance of the Service Providers;
- Establish district and VDC level monitoring committee for monitoring adaptation actions and mobilize ward citizen forum for coordination and monitoring at community level.

**M&E is based on disaggregation by gender, age, caste, class and ethnicity**

> Address reflection and learning that will guide responsive and iterative adaptation planning.

## តារាងទី១៥៖ យេនឌ័រក្នុងការរៀបចំផែនការភាពធន់ទីក្រុង

| វិសាលភាពភាពធន់ទីក្រុង | កត្តា/គោលដៅដែលពាក់ព័ន្ធ | ការពិពណ៌នាអំពីគោលដៅ | យេនឌ័រ និងការពិចារណាលើបរិយាបន្ន |
|---|---|---|---|
| **សុខភាពនិងសុខុមាលភាព** | ភាពងាយរងគ្រោះរបស់មនុស្សតិចតួចបំផុត | បង្ហាញតាមរយៈថា តើតម្រូវការជាមូលដ្ឋានរបស់មនុស្សគ្រប់គ្នាត្រូវបានឆ្លើយតបបានកម្រិតណា។ | ការទទួលបានស្បៀងអាហារ ទឹក ទីជម្រក និងទ្រព្យសម្បត្តិជាមូលដ្ឋានសម្រាប់មនុស្សគ្រប់គ្នាជាពិសេសក្រុមងាយរងគ្រោះត្រូវគិតគូជាសំខាន់ |
| | ជីវភាពរស់នៅ និងការងារចម្រុះ | សម្របសម្រួលដោយលទ្ធភាពទទួលបានហិរញ្ញវត្ថុ,លទ្ធភាពសន្សំ,ការបណ្តុះបណ្តាលជំនាញ, ការគាំទ្រធុរកិច្ចនិងសុខុមាលភាពសង្គម។ | វិធីសាស្ត្របរិយាបន្នចំពោះរបរចិញ្ចឹមជីវិតធានាថាពលរដ្ឋទាំងអស់នៅក្នុងទីក្រុងមួយមានលទ្ធភាពដោយគ្មានការរើតបន្តឹងក្នុងការទទួលបានមុខរបរស្របច្បាប់ដោយមិនគិតពីពូជសាសន៍ ជាតិ ពន្ធ យេនឌ័រ ឬនិន្នាការផ្លូវភេទ។ |
| | ការការពារសុខភាពនិងជីវិតមនុស្សប្រកបដោយប្រសិទ្ធភាព | ការពឹងផ្អែកលើមធ្យោបាយគាំពារចម្រុះនិងសេវាសុខភាពនិងសេវាសង្គ្រោះបន្ទាន់ប្រកបដោយការទទួលខុសត្រូវ។ | ការថែទាំសុខភាពបុគ្គលប្រចាំថ្ងៃដែលអាចមានលទ្ធភាពទទួលបាននិងមានតម្លៃសមរម្យព្រមទាំងការអន្តរាគមន៍សមស្រប ដែលស្របតាមតម្រូវការប្រជាជន។ សេវាមធ្យោបាយគាំពារដែលផ្តោតទិសដៅលើក្រុមងាយរងគ្រោះ ដើម្បីធានាថាយុទ្ធសាស្ត្របង្ការនិងឆ្លើយតបមានការរួមបញ្ចូល និងអាចទៅដល់ប្រជាជនទាំងអស់ |
| **សេដ្ឋកិច្ចនិងសង្គម** | អត្តសញ្ញាណរួមនិងការគាំទ្រសហគមន៍ | មានការសង្កេតឃើញថា មានការចូលរួមសកម្មពីសហគមន៍បណ្តាញសង្គមខ្លាំង និងការធ្វើសមាហរណកម្មសង្គម។ | សហគមន៍ដែលមានភាពសកម្មតែងតែទទួលបានបានគាំទ្រយ៉ាងសមស្របដោយរដ្ឋាភិបាលថ្នាក់ក្រុង និងមានទំនាក់ទំនងល្អ ជាមួយសហគមន៍ផ្សេងទៀតដើម្បីរួមចំណែកដល់ការបង្កើតទីក្រុង ដោយមានការចូលរួមពីក្រោមឡើងមកលើ ដោយមានអត្តសញ្ញាណ និងវប្បធម៌ខ្លាំង។ ការអនុវត្តបរិយាបន្នសង្គមក៏ត្រូវបានពង្រឹងឱ្យកាន់ តែខ្លាំងតាមរយៈការធ្វើអន្តរាគមន៍ដល់ហេដ្ឋារចនាសម្ព័ន្ធរូបវន្តដែលជាមធ្យោបាយគាំពារដល់សហគមន៍,ភាពអាចទទួលបានផ្នែកហេដ្ឋារចនាសម្ព័ន្ធរូបវន្ត។ល។ |
| | សន្តិសុខ គ្រប់ជ្រុងជ្រោយ និងនីតិរដ្ឋ | រាប់ទាំងការអនុវត្តច្បាប់ការធ្វើអន្តរាគមន៍ឧក្រិដ្ឋកម្ម យុត្តិធម៌ និងការគ្រប់គ្រងគ្រាអាសន្ន។ | ច្បាប់ដែលត្រូវបានតម្កល់ដោយប្រព័ន្ធប្រកបដោយធនធានគ្រប់គ្រាន់និងបរិយាបន្នសម្រាប់ធ្វើគោលនយោបាយ។ ស្ថិរភាពនិងសន្តិសុខសង្គមក៏ត្រូវបានសម្របសម្រួលដោយការបង្កើតលំហរសាធារណៈប្រកបដោយបរិយាបន្នផងដែរ ដែលជួយឱ្យមានការចៀសវាងនូវការបង្កើតទីកន្លែងដែលឧក្រិដ្ឋកម្មអាចមានការរីកសាយភាយខណៈដែលបង្កើនសុវត្ថិភាពនិងសន្តិសុខរបស់បុគ្គលឱ្យបានជាអប្បរិមា។ |
| | សេដ្ឋកិច្ចប្រកបដោយនិរន្តរភាព | មានសង្កេតឃើញថាមានការគ្រប់គ្រងហិរញ្ញវត្ថុរឹងមាំ លំហូរប្រាក់ចំណូលចម្រុះលទ្ធភាពទាក់ទាញការវិនិយោគធុរកិច្ច ការវិនិយោគគ្រប់គ្រាន់ និងមូលនិធិ សង្គ្រោះបន្ទាន់។ | រដ្ឋាភិបាលថ្នាក់ក្រុងអាចចូលរួមចំណែកក្នុងការគាំទ្រដល់និរន្តរភាពនៃសកម្មភាពសេដ្ឋកិច្ចឯកជន តាមរយៈការផ្តល់អំណាចដល់វិស័យផ្សេងៗនៅក្នុងសេដ្ឋកិច្ច។ |

## តារាងទី១៥៖ យេនឌ័រក្នុងការរៀបចំផែនការភាពធន់ទីក្រុង

| វិសាលភាពភាពធន់ទីក្រុង | កត្តា/គោលដៅដែលពាក់ព័ន្ធ | ការពិពណ៌នាអំពីគោលដៅ | យេនឌ័រ និងការពិចារណាលើបរិយាបន្ន |
|---|---|---|---|
| **ហេដ្ឋារចនាសម្ព័ន្ធ និងបរិស្ថាន** | ការកាត់បន្ថយការប្រឈម និងភាពផុតស្រួយ | មានការចង្អុលបង្ហាញពីអ្នកថែទាំបរិស្ថាន ហេដ្ឋារចនាសមស្រប ការរៀបចំផែនការប្រើប្រាស់ដីប្រកបដោយប្រសិទ្ធភាព និងការអនុវត្តបទប្បញ្ញត្តិស្តីពីការរៀបចំផែនការ។ | ផ្តោតលើការធ្វើសមាហរណកម្មប្រព័ន្ធអេកូឡូស៊ីជាមួយហេដ្ឋារចនាសម្ព័ន្ធដែលមានជាប់មកជាមួយដើម្បីកាត់បន្ថយការប្រឈមរូបវន្ត។ |
| | ការផ្តល់សេវាសំខាន់ៗប្រកបដោយប្រសិទ្ធភាព | មានការចង្អុលបង្ហាញពីបទប្បញ្ញត្តិចម្រុះនិងការគ្រប់គ្រងសកម្មការថែទាំប្រព័ន្ធអេកូឡូស៊ី និងហេដ្ឋារចនាសម្ព័ន្ធនិងការរៀបចំផែនការបម្រុង។ | |
| | ការទំនាក់ទំនងដ៏ទុកចិត្ត និងចល័តភាព | មានការចង្អុលបង្ហាញពីបទប្បញ្ញត្តិចម្រុះ និងការគ្រប់គ្រងសកម្ម ការថែទាំប្រព័ន្ធអេកូឡូស៊ី និងហេដ្ឋារចនាសម្ព័ន្ធ និងការរៀបចំផែនការបម្រុង។ | ភាពអាចរកបានមធ្យោបាយទំនាក់ទំនងដែលអាចទុកចិត្តនិងប្រកបដោយបរិយាបន្នដែលមានសារៈសំខាន់ដើម្បីផ្សព្វផ្សាយព័ត៌មានក្នុងពេលគ្រាអាសន្នជាពិសេសចំពោះប្រជាពលរដ្ឋងាយរងគ្រោះបំផុតនៅក្នុងទីក្រុង ដូចជាអ្នកក្រ និងចាស់ជរា។បណ្តាញគមនាគមន៍ដឹកជញ្ជូនគ្រប់ប្រភេទ ប្រកបដោយបរិយាបន្ន អាចដំណើរប្រកបដោយសុវត្ថិភាពនិងមានតម្លៃសមរម្យនៅគ្រប់តំបន់ជិតខាងទាំងអស់។ |
| **ភាពជាអ្នកដឹកនាំ និងយុទ្ធសាស្ត្រ** | ភាពជាអ្នកដឹកនាំ និងការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព | មានការចូលរួមពីរដ្ឋាភិបាលអាជីវកម្មនិងសង្គមស៊ីវិលនិងកំណត់បុគ្គលដែលទុកចិត្តការពិគ្រោះយោបល់ពីពហុភាគីពាក់ព័ន្ធនិងការធ្វើសេចក្តីសម្រេចចិត្តផ្អែកលើភស្តុតាង។ | ទទួលស្គាល់សារៈសំខាន់របស់ចំណេះដឹងមូលដ្ឋាន និងការពិគ្រោះយោបល់របស់សហគមន៍ដើម្បីដោះស្រាយបញ្ហាទីក្រុង។ |
| | ភាគីពាក់ព័ន្ធដែលត្រូវបានផ្តល់អំណាច | ចង្អុលបង្ហាញពីការអប់រំសម្រាប់ទាំងអស់គ្នា និងការទទួលបានព័ត៌មាន និងចំណេះដឹងថ្មីៗ ដើម្បីផ្តល់លទ្ធភាពឱ្យប្រជាជននិងស្ថាប័ននានាចាត់វិធានការឱ្យបានសមស្រប។ | ការវិនិយោគលើការស្រាវជ្រាវ ការប្រមូលទិន្នន័យ និងការតាមដានហានិភ័យ និងការផ្តល់ការប្រកាសអាសន្ននិងការទទួលបានព័ត៌មានអប់រំសម្រាប់ទាំងអស់គ្នា។ |
| | ការរៀបចំផែនការអភិវឌ្ឍន៍ដែលត្រូវបានធ្វើសមាហរណកម្ម | មានការចង្អុលបង្ហាញពីចក្ខុវិស័យទីក្រុង យុទ្ធសាស្ត្រអភិវឌ្ឍន៍ប្រកបដោយសមាហរណកម្ម និងផែនការដែលត្រូវបានពិនិត្យផ្ទៀងផ្ទាត់និងធ្វើបច្ចុប្បន្នភាពជាប្រចាំដោយក្រុមការងារចម្រុះនាយកដ្ឋានជំនាញ។ | ការយល់ដឹងអំពីនិងការបន្ស៊ីរវាងការលើកទឹកចិត្តរបស់ភាគីពាក់ព័ន្ធផ្សេងៗដែលចូលរួមក្នុងការបង្កើត និងការអនុវត្តគម្រោងនៅក្នុងទីក្រុង។ កិច្ចសហប្រតិបត្តិការ និងដំណើការពិគ្រោះយោបល់ គួរតែមានការរួមបញ្ចូលពិតប្រាកដដោយរួមបញ្ចូលការពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋនិងអ្នកផ្សេងទៀតដែលនឹងជួបប្រទះឥទ្ធិពលរបស់គម្រោងទាំងនោះ។ |

ប្រភព៖ ដកស្រង់ចេញពី (ARUP ឆ្នាំ២០១៥)

សម្រាកដើម្បីចែករំលែកករណីសិក្សា

**ចំណុចពិភាក្សា**

ស្នើឱ្យអ្នកចូលរួមសរសេរបញ្ហាប្រឈមសំខាន់ៗពីទីក្រុងរបស់ពួកគេ និងរបៀបដែលពួកគេមើលឃើញវិធីសាស្ត្រភាពធន់ដោយពិចារណាលើប៉ារ៉ាម៉ែត្រទាំងនេះ។ សួរពួកគេថា តើមានបញ្ហាប្រឈមជាក់លាក់ណាមួយដែលចាំបាច់ត្រូវផ្តោតការយកចិត្តទុកដាក់ស្ថិតក្នុងក្របខ័ណ្ឌនេះដែរឬទេ?

តម្រុយសម្រាប់អ្នកសម្របសម្រួល

> **ផលប៉ះពាល់វិសមាសមាត្រនៃបញ្ហាធ្វើឱ្យភ័យខ្លាចនិងស្ត្រេសទីក្រុងទៅលើប្រជាជនដែលមានប្រាក់ចំណូលទាប និងការតាំងទីលំនៅក្រៅច្បាប់ៗ**
ការកើនឡើងនូវឯកសារសិក្សាពីការប្រែប្រួលអាកាសធាតុ កំពុងទាក់ទាញចំណាប់អារម្មណ៍ ចំពោះកង្វះភាពធន់នៅក្នុងចំណោមប្រជាជនក្រីក្រក្នុងទីក្រុង។ ប្រជាជនក្រីក្រទទួលរងឥទ្ធិពលវិសមាសមាត្រដោយបញ្ហាធ្វើឱ្យភ័យខ្លាចនិងស្ត្រេសនានា មិនត្រឹមតែដោយសារពួកគេជាញឹកញាប់ប្រឈមខ្លាំង (និងមានភាពងាយរងគ្រោះខ្លាំង) ទៅនឹងបញ្ហាពាក់ព័ន្ធនឹងអាកាសធាតុប៉ុណ្ណោះទេ ប៉ុន្តែដោយសារពួកគេមានធនធានតិចជាងគេ និងទទួលបានការគាំទ្រតិចជាងគេសម្រាប់ការបង្ការ ដោះស្រាយ និងបន្សាំទៅនឹងបញ្ហាទាំងនេះថែមទៀតផងដែរ។ ការប្រែប្រួលអាកាសធាតុត្រូវបានរំពឹងថានឹងបណ្តាលឱ្យបញ្ហាធ្វើឱ្យភ័យខ្លាចនិងស្ត្រេសទាំងនេះកើតមានកាន់តែខ្លាំងឡើងហើយរាំងបន្ថែមទៀតដល់កិច្ចប្រឹងប្រែងកាត់បន្ថយភាពក្រីក្រទៀតផង(ខ្វះប្រភពជាក់លាក់)។

> **ស្ត្រីស្ថិតក្នុងចំណោមក្រុមងាយរងគ្រោះបំផុតទៅនឹងការប្រែប្រួលអាកាសធាតុៗ ក្រុមងាយរងគ្រោះផ្សេងទៀតរួមមាន អ្នកក្រ កុមារ ជនពិការ ចាស់ជរា ក្រុម LGBTIQ សហគមន៍ជនជាតិដើមភាគតិចៗលៗ**
នេះគឺដោយសារតែហេតុផលផ្សេងៗ ដូចជា បទដ្ឋានសង្គមបែបប្រពៃណីមិនធ្វើឱ្យមានការយល់ដឹងពីយេនឌ័រ ឬលទ្ធភាពទទួលបានធនធាននៅក្នុងមូលដ្ឋានមានកម្រិត ហើយមួយផ្នែកទៀតក៏ដោយសារតែភាពក្រីក្រមានការទាក់ទងនឹងយេនឌ័រ។ ស្ត្រីជាមេគ្រួសារ ប្រហែល ៤០ ភាគរយនៃគ្រួសារក្រីក្រក្នុងទីក្រុង នៅទូទាំងពិភពលោក (ខ្វះប្រភពជាក់លាក់)។ ក្នុងប្រទេសកំពុងអភិវឌ្ឍន៍មួយចំនួន ភាគរយនេះអាចមានកាន់តែខ្ពស់ ដូចជាក្នុងប្រទេសហ្វីលីពីន ជាទីដែល ៨០ ភាគរយនៃគ្រួសាររស់នៅក្នុងសំណង់អាណាធិបតេយ្យ គឺជាស្ត្រី (ខ្វះប្រភពជាក់លាក់) ក្នុង (Anh et al ឆ្នាំ២០១៦)។

> ឧទាហរណ៍ ក្នុងប្រទេសវៀតណាម ជាពិសេសក្នុងខេត្តដាណាង មិនមានអ្នកណាម្នាក់ដឹងថា តើគ្រួសារដែលមកពីក្រុមក្រីក្របំផុតប៉ុន្មានដែលមានស្ត្រីជាមេគ្រួសារនោះទេ ប៉ុន្តែបើតាមការដកស្រង់ពីគម្រោងសហជីពស្ត្រី (WU) ចំនួនគ្រួសារដែលមានស្ត្រីជាមេគ្រួសារនៅក្នុងក្រុមក្រីក្របំផុតអាចមានចំនួនច្រើនពោលគឺប្រហែលជិតពាក់កណ្តាលនៃគ្រួសារដែលទទួលផលក្នុងគម្រោងផ្ទះសម្បែង WU ដែលផ្តល់មូលនិធិដោយមូលនិធិ Rockefeller គឺគ្រួសារដែលមានស្ត្រីជាមេគ្រួសារ (Anh et al ឆ្នាំ២០១៦)។ ភាពងាយរងគ្រោះកាន់តែខ្លាំងរបស់ស្ត្រី គឺដោយសារតែតួនាទីនិងតម្រូវការរបស់ពួកគេមិនត្រូវបានគេផ្តល់តម្លៃ ឬមិនត្រូវបានអើពើក្នុងការរៀបចំផែនការនិងសកម្មភាពបើទោះជាពួកគេគឺជាកម្លាំងពលកម្មសំខាន់មួយសម្រាប់សកម្មភាពផលិតកម្មនិងអភិវឌ្ឍន៍ភាគច្រើនក្តី (ខ្វះប្រភពជាក់លាក់)។ ទំនាក់ទំនងអំណាច និងតួនាទីយេនឌ័រក្នុងរបរចិញ្ចឹមជីវិត និងសកម្មភាពបង្កើតប្រាក់ចំណូលមានឥទ្ធិពលខ្លាំងលើភាពងាយរងគ្រោះនិងសមត្ថភាពបន្សាំរបស់គ្រួសារនីមួយៗនិងសហគមន៍(ខ្វះប្រភពជាក់លាក់)។

## ការរៀបចំផែនការបន្សាំផ្អែកលើហេដ្ឋារចនាសម្ព័ន្ធ

ផលប៉ះពាល់នៃហេតុការណ៍ដែលពាក់ព័ន្ធនឹងអាកាសធាតុ និងគ្រោះមហន្តរាយ ត្រូវបានរំពឹងថានឹងបង្កើតស្ត្រេសបន្ថែមទៀតទៅលើទឹកដែលសំខាន់សម្រាប់ជីវិត អនាម័យ ការគ្រប់គ្រងស្បៀង ការដឹកជញ្ជូន និងរហេដ្ឋារចនាសម្ព័ន្ធថាមពល។ ការប្រែប្រួលអាកាសធាតុ នឹងដើរតួនាទីកាន់តែសំខាន់ក្នុងការកំណត់កម្រិតសេវា ទីតាំង ការរចនាគំនូសប្លង់ ប្រតិបត្តិការ និងថែរក្សា ការធ្វើសាជាថ្មីឬជម្រើសជួសជុលព្រមទាំងការបោះបង់ចោលនូវសម្បត្តិទាំងនោះនៅដំណាក់កាលចុងក្រោយ។ហេតុដូចនេះវាមានសារៈសំខាន់ដែលអ្នកអនុវត្តត្រូវមានឧបករណ៍ប្រកបដោយប្រសិទ្ធភាពនិងធនធានដើម្បីបង្កើត និងអនុវត្តដំណោះស្រាយភាពធន់នឹងអាកាសធាតុសម្រាប់ហេដ្ឋរចនាសម្ព័ន្ធដែលមានស្រាប់ និងហេដ្ឋារចនាសម្ព័ន្ធថ្មី។

ការរួមបញ្ចូលគោលការណ៍បន្សាំនឹងការប្រែប្រួលអាកាសធាតុទៅក្នុងការរៀបចំផែនការ ការរចនាគំនូស ប្លង់ ឬការធ្វើសាជាថ្មីនូវហេដ្ឋារចនាសម្ព័ន្ធ ជានិច្ចកាលអាចមិនតម្រូវឱ្យមានការផ្លាស់ប្តូរដំណើរការខ្លាំងនោះទេ ប៉ុន្តែតម្រូវឱ្យមានការផ្លាស់ប្តូរខ្លាំងលើវិធីសាស្ត្រនិងគោលការណ៍រចនាគំនូសប្លង់។ជំនួសមកវិញវិធីសាស្ត្រខាងក្រោមមានចែងអំពីការធ្វើសមាហរណកម្មការគិតគូនានាអំពីការប្រែប្រួលអាកាសធាតុទៅក្នុងដំណាក់កាលនីមួយៗនៃការអនុវត្តគម្រោងតាមរយៈ៖

> ការគិតគូលើស្ថានភាពអាកាសធាតុនាពេលអនាគត(រួមជាមួយនឹងស្ថានភាពអាកាសធាតុអតីតកាលនិងបច្ចុប្បន្នកាល )។ ឬ
> ការគិតគូលើភាពមិនប្រាកដប្រជាក្នុងការពិនិត្យមើលនិងការប្រើប្រាស់ទិន្នន័យអាកាសធាតុតាមរយៈការធ្វើតេស្តនូវភាពយល់ដឹង និងការកែសម្រួលការរចនាគំនូសប្លង់ ( ឧទាហរណ៍តាមរយៈកម្រិតសុវត្ថិភាពកាន់តែខ្លាំង ) ឬយ៉ាងហោចណាស់កែសម្រួលការអនុវត្តឬការរំពឹងទុកពីសេវានៃរចនាសម្ព័ន្ធដែលត្រូវបានបង្កើតឡើង។

ឧទាហរណ៍អំពីការកែប្រែការរចនាគំនូសប្លង់វិស្វកកម្មអាចរួមមាន ការស្តារបណ្តាញទឹកខ្យល់ព្យុះ ដើម្បីឱ្យមានសមត្ថភាពកាន់តែខ្លាំង ខណៈដែលមានការរំពឹងថា ហេតុការណ៍កំណកអាកាសខ្លាំងនឹងកើនឡើងក្នុងពេលអនាគត, កសាងជញ្ជាំងការពារឆ្នេរសមុទ្រឬទីតាំងទល់មុខនឹងសមុទ្រ ទំនប់ និងរបាំងទប់ទល់នឹងទឹកជោរ, ការរចនាគំនូសប្លង់គ្រឹះជញ្ជាំងសមុទ្រថ្មីមួយ ដើម្បីឱ្យវាអាចមានកម្ពស់កាន់តែខ្ពស់ក្នុងពេលអនាគតក្នុងការឆ្លើយតបទៅនឹងការកើនឡើងកម្រិតទឹកសមុទ្រ, ការកសាងស្ពានថ្មីនៅកម្រិតកម្ពស់ខ្ពស់ជាងមុនប្រសិនបើរចនាសម្ព័ន្ធដែលមានស្រាប់ត្រូវបានជន់លិចនិងខូចខាតដោយសារជំនន់ទឹកទន្លេជាញឹកញាប់,រចនានិងសាងសង់ទីជម្រកសម្រាប់ជ្រកពីព្យុះស៊ីក្លូន ព្យុះសង្ឃរា និងទឹកជំនន់។ល។

ខណៈដែលគម្រោងទាំងនេះខ្លួនឯងផ្ទាល់អាចហាក់ដូចជាមានអព្យាក្រឹតភាពយេនឌ័រគម្រោងទាំងនេះអាចមិនផ្តល់អត្ថប្រយោជន៍ចម្បងដល់ស្ត្រីផងដែរលុះត្រាតែសិទ្ធិអាទិភាពនិងតម្រូវការរបស់ស្ត្រីត្រូវបានគិតគូ ហើយស្ត្រីត្រូវរួមបញ្ចូល និងធ្វើជាតំណាងពោរពេញដោយអត្ថន័យក្នុងការរៀបចំផែនការ ការរចនាគំនូសប្លង់ និងការគ្រប់គ្រងហេដ្ឋានរចនាសម្ព័ន្ធថ្មី។លើសពីនេះទៀតការទទួលបានដែលមានភាពខុសគ្នាតាមយេនឌ័រនូវ ហេដ្ឋារចនាសម្ព័ន្ធ និងសេវាដែលពាក់ព័ន្ធចាំបាច់ត្រូវយកមកពិចារណាខណៈពេលដែលបង្កើតសេវាបែបនេះបើមិនដូច្នេះទេវាអាចមិនត្រឹមតែបញ្ចប់ស្ត្រីមិនឱ្យទទួលបានសេវាដែលពាក់ព័ន្ធនឹងហេដ្ឋារចនាសម្ព័ន្ធទាំងនេះសម្រាប់ផ្នែកសេដ្ឋកិច្ចឬសង្គមប៉ុណ្ណោះទេ ប៉ុន្តែជួនកាលថែមទាំងបង្កឱ្យបន្សល់ទុកនូវស្ថានភាពកាន់តែអាក្រក់ឡើងដោយសារហេដ្ឋារចនាសម្ព័ន្ធថ្មីនេះ។ ឧទាហរណ៍ ការផ្ទេរទឹកទៅកាន់តំបន់ដែលត្រូវស្តុកទឹក ( តាមរយៈទំនប់ប្រឡាញបង្ហូរទឹកឬបណ្តាញស្រោចស្រព )អាចមានផលវិបាកដោយអចេតនាចំពោះការធ្វើឱ្យថ្ងៃធ្វើការងារផលិតកម្មឬការងារផ្ទះរបស់ស្ត្រីកាន់តែកើនឡើងយូរថ្ងៃ ដោយសារការយកប្រភពទឹកទៅដាក់នៅកន្លែងឆ្ងាយជាងមុន ( Aguilar Revelo ឆ្នាំ២០០៩ )។

ឧទាហរណ៍បែបនេះរំលេចឱ្យឃើញពីតម្រូវការឱ្យមានការពិចារណាសមស្របទៅលើអត្ថប្រយោជន៍ និងការចូលរួមចំណែករបស់សមាជិកសង្គមទាំងអស់ ជាពិសេសស្ត្រី និងក្រុមងាយរងគ្រោះផ្សេងទៀតនៅក្នុងរចនានិងការរៀបចំផែនការរចនាសម្ព័ន្ធភាពធន់នឹងអាកាសធាតុ។ ក្នុងឆ្នាំ២០១៥ អង្គការ USAID បានបង្កើតសៀវភៅណែនាំមួយស្តីពីការរួមបញ្ចូលការបន្សាំនឹងការប្រែប្រួលអាកាសធាតុទៅក្នុងការរៀបចំផែនការ និងការរចនាហេដ្ឋារចនាសម្ព័ន្ធ។ រូបទី៤ខាងក្រោមនេះ លើកឡើងពីជំហានវិធីសាស្ត្រសម្រាប់ការរៀបចំផែនការនិងការរចនាហេដ្ឋារចនាសម្ព័ន្ធភាពធន់នឹងអាកាសធាតុដែលត្រូវបានស្នើឡើងនៅក្នុងក្របខ័ណ្ឌនេះដោយមានការស្នើឱ្យមានសកម្មភាពឆ្លើយតបនឹងតម្រូវការយេនឌ័រនៅក្នុងកិច្ចការដូចគ្នានេះ។

## រូបទី៤៨៖ ការរៀបចំផែនការសម្រាប់ហេដ្ឋារចនាសម្ព័ន្ធភាពធន់នឹងអាកាសធាតុ

STEPS IN THE METHODOLOGY FOR INCORPORA TING CLIMA TE ADAPT A TION IN INFRASTRUCTURE PLANNING AND DESIGN

### STEP 1 Establish Context

**Define Asset**
(e.g., reservoir, transmission line, roadway, water treatment plant)

→ **Identify Climate Impacts**
What are the expected changes in natural hazard and climate change patterns for the region?

### STEP 2 Vulnerability Assessment

**Exposure Analysis**
Is the asset exposed to the anticipated climate change impacts?

→ **NO**
Assessment complete, no further action needed

↓ **YES > Sensitivity Analysis**
To what degree is the asset affected, either adversely or beneficially, by the climate change impacts?

→ **Low Sensitivity or Not Sensitive**
Assessment complete, no further action needed

↓ **Highly or Moderately Sensitive –** The asset is vulnerable to climate change impacts
[ Adaptive Capacity Considerations ]

ការពិនិត្យលើហានិភ័យគួរផ្តល់ការថ្លឹងថ្លែងបន្ថែមទៀតសម្រាប់សមាសធាតុស្នូលនិងសមាសធាតុរងដែលជះឥទ្ធិពលលើការងារផលិតកម្មនិងការងារផ្ទះរបស់ស្ត្រី (ឧទាហរណ៍ ប្រសិនបើគម្រោងមួយគួរពិចារណាលើទឹកក្នុងគ្រួសារ និងទឹកស្រោចស្រព ហើយក៏ពិចារណាផងដែរលើការប្រើប្រាស់ប្រភពទឹកដែលមានជម្លោះ)

### STEP 3 Risk Assessment

**Likelihood Analysis**
What is the probability of and confidence in the occurrence of the anticipated climate change impact?

↓ Rare, unlikely, possible, likely, or almost certain

**Consequence Analysis**
What are the economic, social, or ecological outcomes associated with the climate impact on the asset?

↓ Insignificant, minor, moderate, major, or catastrophic

↓ **Risk Analysis**
Combine likelihood and consequence to rank the risk.

**Risk Evaluation**
Is the risk acceptable?

Extreme, high, or medium risk
↓ The risk requires development of an adaptation strategy

Not significant, or low risk
↓ Assessment complete, no further action needed

ការវិភាគអំពីផលវិបាកលើតួនាទីផលិតកម្មនិងតួនាទីការងារផ្ទះរបស់ស្ត្រី (ឧទាហរណ៍ បរាជ័យប្រព័ន្ធផ្គត់ផ្គង់ទឹកនឹងប៉ះពាល់ដល់ស្ត្រីនិងកុមារីកាន់តែខ្លាំង)។ រួមបញ្ចូលទាំងការប៉ាន់ប្រមាណអំពីការមិនមានពេលវេលាផ្ទាល់ខ្លួនខណៈដែលវាយតម្លៃថ្លៃចំណាយ និងផលចំណេញ។

### STEP 4 Adaptation Startegy

**Development and Comparison of Adaptation Responses**
How should engineering design be adjusted to account for climate change impacts?
What are the optimal (multi-criteria) responses?

**Project Appraisal**
Further refine options (e.g., cost benefit)

**Resource-Base Analysis**
Availability of and access to resources

↓ Selection of the appropriate adaptation strategy

ការឆ្លើយតបនឹងការបន្សាំ ការរចនា ថ្មីៗគួរពិចារណាថែមទៀតលើជម្រើស ផ្តោតលើយេនឌ័រ (ឧទាហរណ៍ ទីជម្រកគួរត្រូវបានសាងសង់ឡើងដោយគិតអំពីតម្រូវការសម្រាប់ឯកជនភាព និងសេចក្តីថ្លៃថ្នូររបស់ស្ត្រី)។

### STEP 5 Implementation

**Best Practices**
Incorporate lessons learned in future design and planning process

**Monitoring and Evaluation**
Monitor and evaluate for change in risk status

ការអនុវត្តប្រសើរបំផុតគួររំលេចអំពីជម្រើសនានាដែលបង្កើតការងារសម្រាប់ស្ត្រី។ គម្រោងទាំងអស់គួរមានទិសដៅច្បាស់លាស់មួយសម្រាប់ការបណ្តុះបណ្តាល និងជួលស្ត្រីឱ្យមកបម្រើការងារ។

COMMUNICATION AND CONSULTATION WITH TECHNICAL EXPERTS, IMPLEMENTING PARTNERS AND STAKEHOLDERS

ប្រភព៖ ដកស្រង់ចេញពី (អង្គការ USAID ឆ្នាំ២០១៥)

## ទិសាលភាពយេនឌ័រក្នុងដំណាក់កាលផ្សេងៗនៃការរៀបចំផែនការហេដ្ឋារចនាសម្ព័ន្ធ៖ ករណីបឹងស្តុកទឹកក្នុងប្រទេសចិន

ករណីនេះដែលដកស្រង់ចេញពីសៀវភៅណែនាំរបស់អង្គការUSAID(ឆ្នាំ២០១៥)អំពីការរៀបចំផែនការហេដ្ឋារចនាសម្ព័ន្ធភាពធន់នឹងអាកាសធាតុ ត្រូវបានផ្តោតលើបឹងស្តុកទឹកសាបក្នុងប្រទេសចិនដីគោក។ ធនធានទឹករបស់អាងស្តុកទឹកនេះ រងការគំរាមកំហែងពីកើនឡើងសីតុណ្ហភាពប្រចាំឆ្នាំជាមធ្យមការប្រែប្រួលគំរូកំណកអាកាសនិងភាពរាំងស្ងួតដែលត្រូវបានព្យាករណ៍។ជំហាននានាដែលត្រូវបានផ្តល់ជូនក្នុងករណីសិក្សានេះរំលេចចំណុចខ្វះខាតនិងឱកាសសម្រាប់ការបញ្ជ្រាបយេនឌ័រ។

## តារាងទី១៦៖ ជំហានក្នុងការរៀបចំផែនការហេដ្ឋារចនាសម្ព័ន្ធភាពធន់នឹងអាកាសធាតុ

**ជំហានទី១៖**

ដើម្បីបង្កើតបរិបទនេះ ទិន្នន័យប្រវត្តិប្រែប្រួលអាកាសធាតុដែលអាចរកបានពីស្ថានីយធាតុអាកាសក្នុងមូលដ្ឋានត្រូវបានវិភាគ ហើយការកំណត់គំរូអាកាសធាតុត្រូវបានប្រើប្រាស់ដើម្បីបញ្ជាក់ថា បឹងនេះត្រូវបានចាត់ទុកថាបានរងផលប៉ះពាល់ដោយសារធាតុអាកាសក្តៅរយៈពេលយូរដ៏គួរឱ្យកត់សម្គាល់។

- វិធីសាស្ត្រយេនឌ័រមួយក៏បានបែងចែងទិន្នន័យជាបីជ្រុងដោយមានគំរូទិន្នន័យ ដែលបានប្រើប្រាស់ជាចំដោយឡែក ដើម្បីស្វែងយល់មិនត្រឹមតែអំពីធាតុអាកាសក្តៅរយៈពេលយូរប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងអំពីរយៈពេលព្រឹត្តការណ៍នៃគ្រោះរាំងស្ងួតធំៗ ដែលបានកើតឡើងទៀងផង។

**ជំហានទី២៖**

ការសិក្សាជាបឋមលើហានិភ័យត្រូវបានធ្វើឡើងតាមរយៈការរៀបចំម៉ាទ្រិចសិក្សាហានិភ័យជាបឋម ដែលបានបង្ហាញពីភាពជាប់ពាក់ព័ន្ធគ្នាមួយចំនួន។នៅផ្នែកខាងឆ្វេងឆ្ងាយពីនេះម៉ាទ្រិចនេះបង្ហាញភាពជាប់ពាក់ព័ន្ធគ្នា រវាងសមាសធាតុស្នូល (ឧ. កសិកម្ម) និងសមាសធាតុបន្ទាប់បន្សំ(ឧ. ផលិតកម្មស្រូវ)។ បន្ទាប់មក ភាពជាប់ពាក់ព័ន្ធគ្នា ត្រូវធ្វើការកំណត់ថា មានភាពខ្លាំង តិចតួច មិនប្រាកដប្រជា នៅឆ្ងាយ ឬមិនកើតមាន។

- ដូចដែលអាចមើលឃើញ សមាសធាតុស្នូល និងសមាសធាតុបន្ទាប់បន្សំ ច្បាស់ណាស់មិនអាចភ្លេចពិនិត្យមើលលើភាពជាប់ពាក់ព័ន្ធគ្នាលើ៖

ក) បរិមាណទឹកសម្រាប់ការប្រើប្រាស់របស់មនុស្ស

ខ) គុណភាពទឹកសម្រាប់ការប្រើប្រាស់របស់មនុស្ស

គ) ផលប៉ះពាល់លើប្រភពទឹកដែលមានស្រាប់ដោយសារការបំពេញទឹកទាបជាងមុនពីបឹង។

| KEY CLIMATE DRIVER | | Extreme Heat | Mean | Extreme Cold | Drought | Mean Rainfall | Extreme Rainfall | Floods |
|---|---|---|---|---|---|---|---|---|
| CORE ELEMENT –SUB-ELEMENT(S) | SUB-ELEMENTS | | | | | | | |
| **AGRICULTURE** - 1, 2, 3, 4, 5, 6 | 1. Pests/Vermin | Uncertain | Uncertain | Uncertain | Uncertain | | | |
| **INDUSTRY** - 6, 7 | 2. Rice Production | Strong | Strong | Strong | Strong | Minor | Minor | Minor |
| **PUBLIC HEALTH** - 8, 9, 10 | 3. Citrus Production | Minor | Strong | Strong | Minor | | | Minor |
| **LIVELIHOODS** - 6, 11, 12, 13 | 4. Forestry | Minor | Minor | Minor | | Minor | Minor | |
| **BIODIVERSITY** - 6, 14 | 5. Fisheries and Aquaculture | | | | Strong | | | |
| **TOURISM** - 14 | 6. Water Resources | Minor | Minor | | Strong | Strong | Minor | Minor |
| | 7. Lake Water Level | Minor | Minor | | Strong | Minor | | |
| | 8. Schistosomiasis | | Strong | | | | Strong | Strong |
| | 9. Cold Spell-Related Facilities | | | Strong | | | | Strong |
| | 10. Heat Wave-Related Facilities | Strong | | | | | | |
| | 11. Water Quality for Human Consumption | | | | | | | |
| | 12. Subsistence Fishing | | | | Strong | | | |
| | 13. Subsistence Agriculture | Strong | Minor | Strong | Strong | Minor | Strong | Minor |
| | 14. Wetland Ecosystems (including migratory birds) | | | | Strong | Minor | Minor | Minor |

Strong Relationship

Minor Relationship

Uncertain Relationship

Distant or No Relationship

**ជំហានទី៣៖**

ដោយផ្អែកលើជំហានសិក្សាបឋមលើភាពងាយរងគ្រោះដែលមានបង្ហាញខាងលើ ហានិភ័យជិត៣០ ត្រូវបានរកឃើញ និងវិភាគ។ ភាគច្រើននៃហានិភ័យទាំងនេះទំនងជាបង្កឱ្យមានផលប៉ះពាល់អវិជ្ជមានខណៈដែលហានិភ័យតិចតួចអាចបង្កផលប៉ះពាល់វិជ្ជមាន(ឱកាស)។ហានិភ័យការប្រែប្រួលអាកាសធាតុសំខាន់ៗដែលត្រូវបានពិចារណាក្នុងយុទ្ធសាស្ត្របន្សាំ រួមមាន៖

## តារាងទី១៦៖ ជំហានក្នុងការរៀបចំផែនការហេដ្ឋារចនាសម្ព័ន្ធភាពធន់នឹងអាកាសធាតុ

> ការកាត់បន្ថយធនធានទឹកលើផ្ទៃដី។
> ការធ្លាក់ចុះទិន្នផលកសិកម្ម (រួមទាំងត្រី និងព្រៃឈើ)។
> ការធ្លាក់ចុះភាពអាចរកបានទឹកសម្រាប់ឧស្សាហកម្មសំខាន់ៗ។
> ផលប៉ះពាល់សុខភាពសាធារណៈជាពិសេសបង្កើនការចម្លងនិងការសាយភាយជំងឺស៊ីស្តូសូមីញ៉ាស៊ីស (ជំងឺឆ្លងតាមភ្នាក់ងារចម្លងដែលទទួលរងឥទ្ធិពលពីគំរូសីតុណ្ហភាព និងទឹកជំនន់) និងកម្តៅខ្លាំង។
> ការរិចរិលដែលអាចកើតមាននៃធនធានធម្មជាតិសំខាន់ៗ (ទឹក និងការធ្វើកសិកម្មសម្រាប់បរិភោគ) សម្រាប់ប្រព័ន្ធរបរចិញ្ចឹមជីវិតនៅមូលដ្ឋាន។ និង
> ការធ្លាក់ចុះដែលអាចកើតមាននូវតម្លៃជីវចម្រុះ (បក្សីដែលផ្លាស់លំនៅតាមរដូវ និងដីសើម)។

‣ ការវាយតម្លៃហានិភ័យដែលត្រូវបានផ្តល់ចំណាត់ថ្នាក់រំលេចផលប៉ះពាល់នៃទឹកដែលអាចរកបានយកមកប្រើប្រាស់នៅក្នុងខេត្តនេះ ប៉ុន្តែមិនមែនរំលេចពីផលប៉ះពាល់ចំពោះការមិនមានពេលវេលាផ្ទាល់ខ្លួនរបស់ស្ត្រីនោះទេ។

| RISK | LIKELIHOOD | CONSEQUENCE | RISK 2050 |
|---|---|---|---|
| Reduced surface water resource as a result of increased frequency and intensity of drought events and increases in mean temperature and extreme heat events.<br><br>Surface water resources account for 96% of total water supply in Jiangxi Province. Increase in the frequency and intensity of drought events, mean temperature and extreme heat all contribute to a decrease in surface water resources.<br><br>Rising mean temperature and increases in the frequency and intensity of extreme heat events increase evaporation rates of surface water, the watershed and water reservoirs. | **4 – LIKELY**<br><br>Mean temperature is likely to increase by 2050, along with the frequency and intensity of extreme heat events, resulting in reduced surface water recharge rates by 2050, particularly during drought<br><br>The trend of droughts out to 2050 is uncertain for the Poyang Lake Basin; however, the potential for increases in frequency and intensity of droughts should be considered. | **4 – MAJOR**<br><br>With surface water resources accounting for 96% of total provincial water supply, a reduction in this resource would have a significant impact causing widespread disruption to water supply in the Province. | **16 – HIGH** |

**ជំហានទី៤ និងទី៥៖**

បញ្ជីមួយដែលអាចមានវិធានការបន្សាំចំនួន១២ត្រូវបានកំណត់ដើម្បីដោះស្រាយហានិភ័យមួយចំនួនក្នុងចំណោមហានិភ័យដែលគំរាមកំហែងខ្លាំងបំផុត។ភាគច្រើននៃវិធានការទាំងនេះផ្តោតលើវិស័យជាក់លាក់ (ទឹក កម្រិតទឹកបឹង កសិកម្ម ឧស្សាហកម្ម) ហើយវិធានការចំនួន ២ ក្នុងចំណោមវិធានការទាំងនេះគឺជាវិធានការទូទៅ (សុខភាពសាធារណៈ និងការយល់ដឹង)។ យុទ្ធសាស្ត្រទឹករួមបញ្ចូលទាំងការរឹតបន្តឹងការប្រើប្រាស់ទឹក (តាមរដូវកាល) ជាអចិន្ត្រៃយ៍ផងដែរ។

‣ ជាការចាប់អារម្មណ៍ ទឹកក្នុងគ្រួសារមិនត្រូវបានចាត់ទុកថាជាផ្នែកធំមួយនោះទេ ពោលគឺវាមានតួនាទីតែមួយគត់ទាក់ទងនឹងសុខភាពសាធារណៈ។មានភស្តុតាងជាឯកសារជាច្រើនដែលបង្ហាញពីផលប៉ះពាល់នៃការរឹតបន្តឹងការប្រើប្រាស់ទឹកលើផលិតភាពរបស់ស្ត្រីនិងសូម្បីតែលើការអប់រំរបស់កុមារីផងដែរ។ ទាំងនេះក៏មិនត្រូវបានដោះស្រាយ សូម្បីតែយកមកពិចារណាផងដែរ។

សម្រាកដើម្បីចែក

រំលែកករណីសិក្សា

## ការបន្សាំផ្អែកលើប្រព័ន្ធអេកូឡូស៊ី

ការបន្សាំផ្អែកលើប្រព័ន្ធអេកូឡូស៊ី (EbA) សំដៅលើការប្រើប្រាស់សម្បត្តិបរិស្ថាននិងវិធានការការពារធម្មជាតិធ្វើជាដំណោះស្រាយដើម្បីដោះស្រាយការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ។ ឧទាហរណ៍ "ព្រៃទំនាបលិចទឹក និងដើមកោងកាងតំបន់ឆ្នេរ ផ្តល់ការការពារពីខ្យល់ព្យុះ ការពារតំបន់ឆ្នេរ និងការបំពេញទឹកឡើងវិញនិងដើរតួរជារបាំងសុវត្ថិភាពទប់ទល់នឹងគ្រោះថ្នាក់ធម្មជាតិនានាដូចជាទឹកទំនន់ ព្យុះសង្ឃរា និងរលកយក្សស៊ូណាមិជាដើម ខណៈដែលដីសើមជួយចម្រោះជាតិពុល និងបម្រើជាតំបន់បំពេញទឹកឡើងវិញ និងជាជម្រកត្រីសម្រាប់អ្នកនេសាទ"។ ការវាយតម្លៃប្រព័ន្ធអេកូឡូស៊ីសហសវត្សរ៍ (MEA ឆ្នាំ ២០០៥) ក៏ប្រើប្រាស់សមាសភាព EbA ចំនួនពីរផងដែរក្នុងការវិភាគរបស់ខ្លួនអំពីថា តើការផ្លាស់ប្តូរប្រព័ន្ធអេកូឡូស៊ី និងសេវារបស់ប្រព័ន្ធទាំងនេះប៉ះពាល់ដល់សុខុមាលភាពរបស់មនុស្សយ៉ាងដូចម្តេច។

ការថែទាំសេវាប្រព័ន្ធអេកូឡូស៊ី៖ ប្រព័ន្ធអេកូឡូស៊ីផ្តល់ជូនសេវាផលិតផលទទួលបានដោយផ្ទាល់ពីប្រព័ន្ធអេកូឡូស៊ី (provisioning services) សេវាអត្ថប្រយោជន៍ទទួលបានពីការគ្រប់គ្រងដំណើរការប្រព័ន្ធអេកូឡូស៊ី (regulating services) សេវាវប្បធម៌និងសេវាគាំទ្រនានា។ នៅក្នុងបរិបទនៃការបន្សាំនឹងការប្រែប្រួលអាកាសធាតុ "សម្បត្តិធម្មជាតិ" ឬ "សេវាប្រព័ន្ធអេកូឡូស៊ី" ទាំងនេះ រួមមានការផ្តល់ទឹក ការការពារការរេចរឹល បទប្បញ្ញត្តិអាកាសធាតុ ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងភាពជីវចម្រុះ។ វាមានសារៈសំខាន់ណាស់ក្នុងការធានាថា ប្រព័ន្ធអេកូឡូស៊ីទាំងនេះមិនរេចរឹល ហើយបន្តផ្តល់សេវាសំខាន់ៗទាំងនេះ។ ហេតុដូចនេះ ទស្សនទានរួមនៃ EbA គឺជាសារៈសំខាន់នៃការទទួលយកវិធីសាស្ត្រចម្រុះរួមមួយចំពោះការថែទាំនិងការបំពេញមុខងាររចនាសម្ព័ន្ធប្រព័ន្ធអេកូឡូស៊ី និងការផ្តល់សេវាកម្មប្រព័ន្ធអេកូឡូស៊ី។

ភាពធន់ប្រព័ន្ធអេកូឡូស៊ី៖ ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុដូចជាការប្រែប្រួលកម្រិតទឹកសមុទ្រ សីតុណ្ហភាពនិងកម្ពស់ទឹកភ្លៀង នឹងជះឥទ្ធិពលដល់មុខងាររបស់ប្រព័ន្ធអេកូឡូស៊ី។ ការប្រែប្រួលបែបនេះអាចមានផលវិបាកផ្នែកសង្គម វប្បធម៌ និងសេដ្ឋកិច្ចខ្លាំង (Jeans ឆ្នាំ២០១៤) ក្នុង (Reid និង Alam វិធីសាស្ត្រផ្អែកលើប្រព័ន្ធអេកូឡូស៊ីចំពោះការបន្សាំ៖ ភស្តុតាងពីទីកន្លែងចំនួនពីរក្នុងប្រទេសបង់ក្លាដែស ឆ្នាំ២០១៦)។ MEA (ឆ្នាំ២០០៥) ទស្សទាថា "នៅចុងសតវត្សរ៍នេះការប្រែប្រួលអាកាសធាតុ និងផលប៉ះពាល់នៃការប្រែប្រួលអាកាធាតុ អាចជាកត្តាផ្ទាល់លើសលុបដែលបង្កឱ្យមានការខាតបង់ជីវចម្រុះ និងការប្រែប្រួលសេវាប្រព័ន្ធអេកូឡូស៊ីនៅទូទាំងពិភពលោក"។ ប្រព័ន្ធអេកូឡូស៊ីមានដែនកំណត់ហួសពីមុខងារដែលប្រព័ន្ធនេះមិនអាចបំពេញតម្រូវការឲ្យបាន។ ដូច្នេះ ទស្សនទាននៃភាពធន់ប្រព័ន្ធអេកូឡូស៊ីមានមូលដ្ឋានលើការបង្កើតនិងការថែរក្សា "សមត្ថភាពរបស់ប្រព័ន្ធមួយដើម្បីទប់ទល់នឹងផលប៉ះពាល់នៃកត្តាជំរុញនានាដោយមិនមានការផ្លាស់ប្តូរលទ្ធផលឬរចនាសម្ព័ន្ធរបស់វាដែលមិនអាចស្តារវិញបាន"។

EbA ជាញឹកញាប់ផ្តល់ឱកាសកាន់តែខ្លាំងក្នុងការផ្តោតលើក្រុមងាយរងគ្រោះដែលជីវភាពរស់នៅរបស់ពួកគេពឹងផ្អែកដោយផ្ទាល់លើធនធានធម្មជាតិ។ EbA ដែលផ្អែកលើសហគមន៍មួយត្រូវបានបង្កើតឡើងដើម្បីពង្រឹងមុខងាររបស់ពួកវាតាមរយៈការផ្តល់អត្ថប្រយោជន៍ចម្រុះ។

ពីទស្សនយេនឌ័រ EbA មានសារៈសំខាន់ខ្លាំង ខណៈដែលស្ត្រីជាទូទៅគឺជាអ្នកថែទាំដ៏ចម្បងនូវចំណេះដឹងក្នុងមូលដ្ឋាននិងចំណេះដឹងប្រពៃណី ដោយសារការភ្ជាប់ខ្លួនយ៉ាងជិតស្និទ្ធ និងទំនាក់ទំនងកាន់តែខ្លាំងជាមួយធនធានធម្មជាតិ (Aguilar et al ឆ្នាំ២០១៥)។ ហេតុដូចនេះ EbA ក៏ផ្តល់លំហរកាន់តែធំផងដែរសម្រាប់ការចូលរួមរបស់ស្ត្រី។ ចំណេះដឹងដែលស្ត្រីមានក្នុងនាមជាអ្នកគ្រប់គ្រងធនធានធម្មជាតិអាចផ្តល់ការយល់ស៊ីជ្រៅដ៏សំខាន់ទៅក្នុងការបង្កើតយុទ្ធសាស្ត្រប្រកបដោយប្រសិទ្ធភាព។ ទោះជាយ៉ាងណា វាមានសារៈសំខាន់ក្នុងការលើកឡើងនៅទីនេះថា ការធ្វើសមាហរណកម្មយេនឌ័រមិនមែនជាដំណើរការដែលមានស្រាប់នៅក្នុង EbA នោះទេ ហើយវាមានសារៈសំខាន់ក្នុងការចាត់វិធានការដែលរួមបញ្ចូលបទពិសោធក្នុងមូលដ្ឋាននិងបទពិសោធទាក់ទងនឹងយេនឌ័រទៅក្នុងដំណើរការរៀបចំផែនការ EbA។ អ្វីដែលសំខាន់ដូចគ្នានោះគឺដើម្បីទទួលបានលទ្ធភាពរបស់ធនធានធម្មជាតិដើម្បីចូលរួមចំណែកដល់ជីវភាពរស់នៅ សុខភាព និងទិដ្ឋភាពផ្សេងទៀតរបស់ស្ត្រីឱ្យក្លាយជាផ្នែកមួយនៃការបង្កើតគម្រោង EbA ណាមួយ។ ជាទូទៅ ទិដ្ឋភាពនេះបាននិងកំពុងខកខាន ដោយសារថា ស្ត្រីមិនយល់ដឹងអំពីអត្ថប្រយោជន៍ ដែលពួកគេអាចសម្រេចបានដោយផ្ទាល់ពីជម្រើសនានា (Aguilar et al ឆ្នាំ២០១៥)។

| គន្លឹះសម្រាប់គ្រូឧទ្ទេស | សម្រាក និងបង្ហាញគម្រោង EbA "Resi-Nam" តាមរយៈវីដេអូអំពីគម្រោងដែលអាចរកបានតាមរយៈគេហទំព័រ៖ https://www.weadapt.org/placemarks/-maps/view/35396 |
|---|---|

**សម្រាកដើម្បីចែករំលែកករណីសិក្សា**

## វិធីសាស្ត្របន្សាំផ្អែកលើសហគមន៍

វិធីសាស្ត្រទាំងអស់ដែលលើកឡើងខាងលើ អាចជាវិធីសាស្ត្រពីលើចុះក្រោម (Top down Approach) ឬវិធីសាស្ត្រផ្អែកលើសហគមន៍។ ពាក្យ "ការបន្សាំផ្អែកលើសហគមន៍ (CBA)" ត្រូវបានកំណត់និយមន័យដោយអ្នកគាំទ្ររបស់កម្មវិធីនេះថាជា "ជាដំណើរការដែលដឹកនាំដោយសហគមន៍ដែលមានមូលដ្ឋានជាអាទិភាព តម្រូវការ ចំណេះដឹង និងសមត្ថភាពរបស់សហគមន៍ដែលគួរផ្ដល់អំណាចដល់ប្រជាជនឱ្យរៀបចំផែនការដោះស្រាយ និងទប់ទល់ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ" (REID et al ឆ្នាំ២០០៩)។ វាគឺជាវិធីសាស្ត្រមួយសម្រាប់ការស្រាវជ្រាវ និងការអនុវត្តការបន្សាំ ដែលជាវិធីសាស្ត្រផ្អែកលើភាពខ្លាំងតាមបែបវិមជ្ឈការ ដើម្បីពង្រឹងសមត្ថភាពបន្សាំកម្រិតសហគមន៍។

CBAក៏ត្រូវបានចាត់ទុកផងដែរដោយមនុស្សមួយចំនួន (Reid និង Huq ឆ្នាំ២០១៧) ថាជា "វិធីសាស្ត្រសំខាន់មួយចំពោះការគំរាមកំហែងដែលការប្រែប្រួលអាកាសធាតុបង្កឡើងចំពោះអ្នកក្រ"។ អ្នកនិពន្ធឯកសារនេះលើកឡើងថា ការដែលគ្រាន់តែផ្ដល់ប្រាក់ទៅឱ្យរដ្ឋាភិបាលក្នុងប្រទេសក្រីក្រ នឹងមិនធានាថា ប្រាក់នោះនឹងធ្លាក់ដល់ដៃអ្នកក្រ និងអ្នកងាយរងគ្រោះនោះទេ ដូច្នេះវាមានសារៈសំខាន់ដែលត្រូវអនុម័ត CBA ដែលមានសក្ដានុពលកាន់តែខ្លាំងមួយដើម្បីឱ្យទៅដល់សហគមន៍ទាំងនេះ។ អ្នកគាំទ្រវិធីសាស្ត្រដែលមានការចូលរួមដូចជាលោក Robert Chambers និងអ្នកផ្សេងទៀត បានលើកឡើងរួចហើយថាវិធីសាស្ត្រ "មជ្ឈការ" ជាញឹកញាប់ជកហូតសិទ្ធិអំណាច និងបង្កឱ្យមានគម្លាតចំពោះអត្ថប្រយោជន៍របស់អ្នកក្រ (Mansuri និង Rao ឆ្នាំ២០១៣)។ សកម្មភាពអាកាសធាតុនានាលើកឡើងថាវិធីសាស្ត្រនេះក៏អនុវត្តផងដែរចំពោះគម្រោងបន្សាំដែលក្រោយមកអាចផ្ដោតលើគម្រោងហេដ្ឋារចនសម្ព័ន្ធរូបវន្តនិងការឆ្លើយតបតាមបច្ចេកវិទ្យាទៅនឹងផលប៉ះពាល់អាកាសធាតុផ្សេងៗគ្នា ជាជាងផ្ដោតលើគំនិតផ្ដួចផ្ដើមនានាដើម្បីពង្រឹងសមត្ថភាពបន្សាំរយៈពេលវែង ដែលមានការរាយការណ៍ថាបានបរាជ័យក្នុងការផ្ដល់ការគាំទ្រដល់ការបន្សាំឱ្យបានគ្រប់គ្រាន់ទៅដល់អ្នកដែលរងគ្រោះបំផុតទៅនឹងការប្រែប្រួលអាកាសធាតុ (Kirkby Williams និង Huq ឆ្នាំ២០១៧)។

ជាទូទៅ CBA ត្រូវបានជំរុញដោយសមាសភាពជាច្រើន។ សមាសភាពសំខាន់ៗមានការពាក់ព័ន្ធនឹងការធ្វើការងារក្នុងភាពជាដៃគូជាមួយសហគមន៍ដែលផ្អែកតាមទីកន្លែង ដើម្បីធ្វើឱ្យប្រសើរឡើងនូវសមត្ថភាពរបស់សហគមន៍ទាំងនោះ ដើម្បីបន្សាំទៅនឹងហានិភ័យ និងផលប៉ះពាល់អាកាសធាតុ។ ទោះជាយ៉ាងណា CBA មានតួនាទីលើសពីគម្រោងទៅទៀត។ វាគឺជាចលនាមួយដោយសារវាមានការពាក់ព័ន្ធនឹងសហគមន៍ដែលមានអត្ថប្រយោជន៍រួមក្នុងការតស៊ូមតិសម្រាប់ការគាំទ្រស្ថាប័ននិងហិរញ្ញវត្ថុសម្រាប់សហគមន៍ងាយរងគ្រោះដើម្បីបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ។ ហេតុដូចនេះ CBA គឺជាទិដ្ឋភាពសង្គមនិងនយោបាយអាទិភាពរបស់អ្នកដែលនឹងទទួលរងឥទ្ធិពលខ្លាំងបំផុត។ គោលបំណងរបស់ CBA គឺដើម្បីផ្ដល់លទ្ធភាពឱ្យសហគមន៍ជំរុញការបន្សាំដោយឯករាជ្យនិងប្រកបដោយចីរភាពផ្ទាល់របស់ពួកគេតាមរយៈការអនុញ្ញាតឱ្យពួកគេកំណត់វិធីសាស្ត្រនិងគោលដៅនៃការបន្សាំសម្រាប់ខ្លួនពួកគេផ្ទាល់ (Dodman និង Mitlin ឆ្នាំ២០១៣)។កិច្ចការនេះត្រូវសម្រេចបានតាមរយៈដំណើរការនៃការផ្ដល់អំណាចដែលមានការពាក់ព័ន្ធនឹងការកៀរគរថាមពលកិច្ចប្រឹងប្រែង ចំណេះដឹង និងបទពិសោធរបស់បុគ្គល និងសហគមន៍ (REID et al ឆ្នាំ២០០៩)។ CBA គឺ "អំពីសហគមន៍ដែលបង្កើតជម្រើសមិនមែនឱ្យសហគមន៍ទៅប្រឈមពីខាងក្រៅទេ"។ ដូច្នេះ គោលនយោបាយ និងការធ្វើអន្តរាគមន៍របស់ CBA គួរឆ្លុះបញ្ចាំងពីគុណតម្លៃ អាទិភាព និងការយល់ឃើញពីសុខុមាលភាពនៅមូលដ្ឋាន ដែលផ្ទុយពីគោលនយោបាយនិងការធ្វើអន្តរាគមន៍របស់តួអង្គពីខាងក្រៅ ហើយ "គួរត្រូវបានធ្វើជាមួយសហគម៍ជាជាងធ្វើដើម្បីសហគមន៍ឬសម្រាប់សហគមន៍" (Warrick ឆ្នាំ២០១១)។

យុទ្ធសាស្ត្រសំខាន់ៗរបស់គំរូ CBA (Kirkby, Williams និង Huq ឆ្នាំ២០១៧) (Reid និង Huq ឆ្នាំ២០១៧) រួមមាន៖

ក) គំរូ CBA ត្រូវបានផ្ដោតលើការកសាងសមត្ថភាពបន្សាំជាជាងលើសកម្មភាពបន្សាំនៅមូលដ្ឋាន។

ខ) ការកៀរគរសហគមន៍ប្រកបដោយចីរភាពដោយមានគោលបំណងកសាងទំនុកចិត្តរវាងខ្លួនពួកគេផ្ទាល់ និងជាមួយភាគីពាក់ព័ន្ធផ្សេងទៀត។

គ) ការទទួលស្គាល់ភាពពិតដ៏ស្មុគស្មាញរបស់សហគមន៍មូលដ្ឋាន ជាពិសេសរចនាសម្ព័ន្ធអំណាចដែលមានស្រាប់ និងការបង្កើតបរិយាកាសអំណោយផល និងយន្តការស្ថាប័នសម្រាប់ក្រុមងាយរងគ្រោះ ដើម្បីចូលរួមក្នុងដំណើរការចែករំលែកអត្ថប្រយោជន៍ ដំណើរការគ្រប់គ្រង និងដំណើរការធ្វើសេចក្ដីសម្រេចចិត្ត។

ឃ) ការកសាងសមត្ថភាពរបស់សហគមន៍ ដើម្បីយល់ដឹងអំពីភាពស្មុគស្មាញនៃការប្រែប្រួលអាកាសធាតុតាមរយៈការចែករំលែកព័ត៌មានវិទ្យាសាស្ត្របែបមជ្ឈការ ខណៈពេលដែលក៏ធានាឱ្យបាននូវការផ្ទេរចំណេះដឹងក្នុងមូលដ្ឋានសម្រាប់ការបង្កើតយុទ្ធសាស្ត្របន្សាំរួមគ្នា។ ដូច្នេះ ការធ្វើសមាហរណកម្មចំណេះដឹងក្នុងមូលដ្ឋាន និងចំណេះដឹងវិទ្យាសាស្ត្រគឺជាគន្លឹះចំពោះ CBA។ ដើម្បីឆ្ពោះទៅរកកិច្ចការនេះ CBA ក៏ធ្វើឱ្យមានភាពចំបាច់ក្នុងការអនុវត្តវិធីសាស្ត្រអន្តរវិន័យផងដែរ។

ង) ផ្ដោតលើការវាយតម្លៃភាពងាយរងគ្រោះផ្អែកលើសហគមន៍ និងវិធីសាស្ត្ររៀបចំផែនការភាពធន់។ផ្ដល់ការយល់ដឹងអំពីការបន្សាំ និងដំណោះស្រាយបន្សាំទៅតាមតម្រូវការ ដើម្បីដោះស្រាយនៅក្នុងបរិបទនៅមូលដ្ឋាន និងបរិបទវប្បធម៌ ដែលកំណត់ភាពងាយរងគ្រោះ (រាំងការបន្សាំ) ដូចជាស្ត្រីដែលគ្មានដីធ្លីមិនមានលំហរនៅក្នុងសេចក្ដីសម្រេចចិត្តលើការគ្រប់គ្រង

**រូបទី៤៩៖ លំដាប់ថ្នាក់ចំណេះដឹងអំពីការបន្សាំ**




មជ្ឈមណ្ឌលអន្តរជាតិដើម្បីការប្រែប្រួលអាកាសធាតុនិងអភិវឌ្ឍន៍ (ICCAD) ប្រទេសបង់ក្លាដែសបានស្នើមាត្រដ្ឋានស្តង់ដារមួយឬ "លំដាប់ថ្នាក់ចំណេះដឹង" ពីសហគមន៍កសិកម្មទៅកាន់រដ្ឋាភិបាលថ្នាក់ជាតិ ដើម្បីកំណត់កម្រិតចំណេះដឹងបន្សាំរបស់ពួកគេ ឃ្លាំមើលកិច្ចប្រឹងប្រែងក្នុងការបង្កើនចំណេះដឹងអំពីបន្សាំក្នុងអំឡុងពេលមួយ និងប្រៀបធៀបវឌ្ឍនភាពទៅនឹងតួអង្គប្រហាក់ប្រហែលគ្នានៅមាត្រដ្ឋានដូចគ្នា។

ប្រភព៖ (សេចក្តីសង្ខេបអំពីគោលនយោបាយ ICCCAD ឆ្នាំ២០១៨)

ធនធានធម្មជាតិ ព្រមទាំងសមត្ថភាពបន្សាំ (ផ្តល់លទ្ធភាពឱ្យមានការបន្សាំ) ដូចជាការយល់ដឹងអំពីសាហគមន៍ និងប្រព័ន្ធនានាសម្រាប់ការស្តារព្រៃឈើ ឬព្រៃកោងកាងជាដើម។

ច) ការចរចាអំពីរបាំងស្ថាប័ន ជាពិសេសរបាំងដែលពាក់ព័ន្ធជាមួយនឹងការគ្រប់គ្រងធនធាន និងអតុល្យភាពអំណាច ហិរញ្ញវត្ថុ ធនធានមនុស្សនិងការសម្របសម្រួលរវាងទីភ្នាក់ងាររដ្ឋាភិបាល

ឆ) វិធីសាស្ត្រ CBA ផ្តោតជាពិសេសលើការដោះស្រាយបុព្វហេតុជាមូលដ្ឋាននៃភាពងាយរងគ្រោះ ដូច្នេះផ្តល់ គំរូដែលលក្ខណៈបានសមាហរណកម្មរួមបញ្ចូលគ្នាមួយដើម្បីបញ្ជ្រាបសកម្មភាពបន្សាំនៅក្នុងដំណើរការអភិវឌ្ឍន៍។

ជ) ផ្តោតលើតម្រូវការរបស់ស្ត្រីនិងសហគមន៍ងាយរងគ្រោះដែលជាផ្នែកដ៏សំខាន់មួយនៃវិធីសាស្ត្រ CBA មិនមែនពីព្រោះតែពួកគេគឺជាក្រុមដែលងាយរងគ្រោះខ្លាំងបំផុតទៅនឹងការប្រែប្រួលអាកាសធាតុប៉ុណ្ណោះទេប៉ុន្តែក៏ពីព្រោះតែពួកគេគឺជាភ្នាក់ងារដ៏សកម្មនៃការផ្លាស់ប្តូរ និងអាចជាអ្នកចូលរួមចំណែកដ៏មានតម្លៃនៅក្នុងការងារបន្សាំផងដែរ។

សមាសភាពសំខាន់មួយនៃគម្រោង CBA ទាំងអស់ ត្រូវតែជាការពង្រឹងចំណេះដឹងរបស់សហគមន៍។ចំណេះដឹងដែលទំនងជាចំណេះដឹងអំពីការប្រែប្រួលអាកាសធាតុនាពេលអនាគតនិងយុទ្ធសាស្ត្របន្សាំផ្តល់សិទ្ធិអំណាចដល់បុគ្គលនិងក្រុមនានាឱ្យសម្រេចចិត្តថាតើនៅពេលណានឹងត្រូវបន្សាំ និងបន្សាំដោយរបៀបណាដើម្បីឱ្យពួកគេអាចមានលទ្ធភាពដោះស្រាយឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុនៅទីកន្លែងជាក់លាក់ ក្នុងរបៀបដែលកំណត់អាទិភាពសម្រាប់គោលដៅរយៈពេលយូររបស់ពួកគេ។ ចំណេះដឹងបន្សាំសំដៅដល់ចំណេះដឹងណាមួយដែលលើកកម្ពស់លទ្ធភាពរបស់បុគ្គលឬក្រុមដើម្បីបន្សាំខ្លួនឯងទៅនឹងការប្រែប្រួលអាកាសធាតុ។ ចំណេះដឹងនេះរួមមានទាំងចំណេះដឹងផ្នែកទ្រឹស្តី និងចំណេះដឹងផ្នែកអនុវត្ត ហើយដូច្នេះកំណត់ថា តើតួអង្គនានាអាចបន្សាំនៅក្នុងឧបសគ្គដែលបង្កឡើង ដោយសារធនធាន និងអំណាចមានកម្រិត (សេចក្តីសង្ខេបអំពីគោលនយោបាយ ICCCAD ឆ្នាំ២០១៨)។ចំណេះដឹងគឺជាស្ថានភាពដែលចាំបាច់ប៉ុន្តែមិនគ្រប់គ្រាន់សម្រាប់ការបន្សាំដោយជោគជ័យ ពោលគឺដោយមិនគិតថាតើតួអង្គនានាមានប្រាក់ឬអំណាចកម្រិតណានោះទេ (Adger et al ឆ្នាំ២០០៤) ពួកគេមិនអាចបន្សាំនឹងគ្រោះថ្នាក់ដែលបង្កឡើងដោយអាកាសធាតុ ឬស្ត្រេសបាននោះទេ លុះត្រាតែពួកគេយល់ដឹងអំពីបញ្ហា ស្វែងយល់ពីការឆ្លើយតបប្រកបដោយសក្តានុពលចំពោះបញ្ហា និងដឹងពីរបៀបអនុវត្តការឆ្លើយតបទាំងនេះប្រកបដោយប្រសិទ្ធភាព។

នៅកម្រិតអនុវត្ត គម្រោង CBA ត្រូវបានគាំទ្រនិងផ្តល់មូលនិធិមួយផ្នែកធំដោយអង្គការមិនមែនរដ្ឋាភិបាល និង/ឬទីភ្នាក់ងាររដ្ឋាភិបាលដោយមានការសហការជាមួយសហគមន៍មូលដ្ឋាន។ទោះជាយ៉ាងណាមានស្ថាប័នផ្សេងទៀតក៏ដើរតួនាទីធំមួយផងដែរក្នុងកិច្ចការនេះ ដូចជាទីភ្នាក់ងារផ្តល់ហិរញ្ញវត្ថុពហុភាគី ទីភ្នាក់ងារសម្របសម្រួល រៀបចំផែនការ ស្រាវជ្រាវ និងតស៊ូមតិជាដើម។

បញ្ហាប្រឈមសំខាន់ៗរបស់វិធីសាស្ត្រ CBA ត្រូវបានរកឃើញថា ដោយដែនកំណត់នៃវិធីសាស្ត្រដែលមានការចូលរួម កង្វះការបង្ហាញប្រសិទ្ធភាពរបស់វិធីសាស្ត្រតាមរយៈយន្តការតាមដាននិងវាយតម្លៃគ្រប់គ្រាន់កម្រិតលទ្ធផលដែលទទួលបាន ( achieving scale ) និងសំខាន់បំផុតនោះ គឺលទ្ធភាពបំបែកសកម្មភាពអភិវឌ្ឍន៍ទូទៅពីសកម្មភាពបន្សាំ។ ជាពិសេស លទ្ធភាពបំបែកសកម្មភាពអភិវឌ្ឍន៍ទូទៅពីសកម្មភាពបន្សាំគឺជាឧបសគ្គធំបំផុតចំពោះការធានាបាននូវលំហូរហិរញ្ញវត្ថុពីមូលនិធិបន្សាំ ខណៈពេលដែលមានតម្រូវការឱ្យបង្ហាញការចូលរួមចំណែកដល់សកម្មភាពអាកាសធាតុ។ ដូច្នេះ គម្រោង CBA ភាគច្រើនត្រូវបានផ្តល់មូលនិធិតាមរយៈជំនួយអភិវឌ្ឍន៍។ ទោះជាយ៉ាងណាមានការផ្តល់មូលនិធិដោយផ្ទាល់ផងដែរសម្រាប់គម្រោង CBA តាមរយៈគម្រោងជំនួយខ្នាតតូច UNDP-GEF មូលនិធិភាពជាដៃគូភាពធន់ពិភពលោក។ល។

## ការបញ្ជ្រាបយេនឌ័រក្នុងគម្រោង CBA

ការបញ្ជ្រាបយេនឌ័រ គឺជាកត្តាដ៏សំខាន់មួយចំពោះភាពជោគជ័យរបស់គម្រោងCBA។ដូចទៅនឹងសហគមន៍ផ្សេងទៀតដែលទទួលរងឥទ្ធិពលខុសៗគ្នាពីផលប៉ះពាល់ការប្រែប្រួលអាកាសធាតុក្រុមផ្សេងៗនៅក្នុងសហគមន៍តែមួយមានភាពងាយរងគ្រោះផ្ទាល់ខ្លួនផ្សេងៗគ្នារបស់ពួកគេ។ វាមានសារៈសំខាន់ជាពិសេសដើម្បីកំណត់ភាពងាយរងគ្រោះទាក់ទងនឹងយេនឌ័រនៅក្នុងសហគមន៍ថា ជាផ្នែកមួយនៃដំណើរការរៀបចំផែនការ CBA។

កិច្ចការនេះតម្រូវឱ្យមានយុទ្ធសាស្ត្រពីរប្រភេទ៖

ក )ធានាថាស្ត្រីគឺជាផ្នែកមួយនៃការពិភាក្សាទាំងអស់អំពីការវាយតម្លៃភាពងាយរងគ្រោះនៅមូលដ្ឋាន។ ការណ៍នេះអាចត្រូវធ្វើឡើងដោយការនាំយកស្ត្រីឱ្យក្លាយជាផ្នែកមួយរបស់ក្រុមសហគមន៍ ឬនៅក្នុងសង្គមនានាជាទីដែលការធ្វើបែបនេះមិនអាចធ្វើទៅបានត្រូវមានការពិភាក្សាដាច់ដោយឡែកជាមួយក្រុមដែលមានតែស្ត្រី ដើម្បីស្វែងយល់ពីភាពរងគ្រោះនៅមូលដ្ឋាន។ ទោះជាយ៉ាងណា វាមានសារៈសំខាន់ក្នុងការធានាថា ស្ត្រីមកពីគ្រប់ថ្នាក់ វណ្ណៈ ពិការភាព អាយុ ភេទ ជាតិពន្ធុ។ល។ ទាំងអស់ គឺជាផ្នែកនៃការពិភាក្សាទាំងនេះ។

ខ )ការអនុវត្តឧបករណ៍វិភាគយេនឌ័រដែលមានការចូលរួមដើម្បីរំលេចតួនាទីយេនឌ័រ និងភាពងាយរងគ្រោះទាក់ទងនឹងយេនឌ័រនៅក្នុងសហគមន៍។ ក្របខ័ណ្ឌ Moser និងក្របខ័ណ្ឌ Harvard ឧបករណ៍វាយតម្លៃ CVA និង GVCA មានប្រយោជន៍យ៉ាងពិសេសក្នុងការបង្ហាញភាពងាយរងគ្រោះយេនឌ័រ និងភាពងាយរងគ្រោះផ្សេងទៀត។ នៅទីនេះជាថ្មីម្តងទៀត វាក៏មានសារៈសំខាន់ផងដែរដើម្បីផ្តោតលើភាពងាយរងគ្រោះដែលប្រឈមដោយស្ត្រីដែលបាត់បង់លទ្ធភាពពលកម្ម និងក្រុមLGBTIQជាពិសេសខណៈពេលដែលរៀបចំផែនការសម្រាប់យុទ្ធសាស្ត្រគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ។

ការរួមបញ្ចូលស្ត្រីទៅក្នុង CBA មានសារៈសំខាន់មិនត្រឹមតែដោយសារស្ត្រីមានភាពងាយរងគ្រោះនោះទេ ប៉ុន្តែពីព្រោះពួកគេអាចជាអ្នកចូលរួមចំណែកដ៏មានតម្លៃទៅនឹងការងារបន្សាំ។ ស្ត្រីអាចជាអ្នកដឹកនាំសហគមន៍ហើយជាញឹកញាប់គឺជាអ្នកគ្រប់គ្រងធនធានធម្មជាតិដែលអាចជួយបង្កើតយុទ្ធសាស្ត្រដើម្បីដោះស្រាយហានិភ័យដែលពាក់ព័ន្ធនឹងអាកាសធាតុ។ ដូច្នេះ វាមានសារៈសំខាន់ដែលថា គម្រោង CBA រួមបញ្ចូលសមាសភាពនៃការធ្វើឱ្យមានយល់ដឹងពីយេនឌ័ររបស់សហគមន៍និងអ្នកដឹកនាំដែលមានស្រាប់ដើម្បីឱ្យពួកគេគាំទ្របន្ថែមទៀតដល់ស្ត្រីក្នុងការទទួលបានមុខតំណែងដឹកនាំនៅក្នុងស្ថាប័នដែលពាក់ព័ន្ធនឹង CCDRR និងនៅក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្ត។ យុទ្ធសាស្ត្រមួយដើម្បីឱ្យកិច្ចការនេះអាចសម្រេចទៅបាន គឺត្រូវផ្តល់ក្របខ័ណ្ឌបទដ្ឋានមួយដល់ការចូលរួមរបស់ស្ត្រី ពោលគឺតម្រូវថា ៣០% ទៅ ៥០% នៃសមាជិកក្នុងស្ថាប័នធ្វើសេចក្តីសម្រេចចិត្តទាំងអស់គឺជាស្ត្រី។ ដើម្បីឱ្យកិច្ចនេះសម្រេចទៅបានបន្ថែមទៀតក្រុមនិងវេទិកាដែលមានតែស្ត្រី ក៏ត្រូវបានគាំទ្រផងដែរ ដែលអាចពិភាក្សាអំពីបញ្ហានិងការធ្វើអន្តរាគមន៍ដែលតម្រូវឱ្យធ្វើឡើងចំពោះពួកគេមុនពេលដាក់បញ្ហានិងអន្តរាគមន៍ទាំងនេះនៅចំពោះមុខស្ថាប័នធ្វើសេចក្តីសម្រេចចិត្តធំ។ ឧទាហរណ៍ ក្នុងប្រទេសឥណ្ឌា មានទស្សនាទាន Mahila Sabha ឬសភា (ភូមិ) របស់ស្ត្រីនៅចំពោះមុខ Gram Sabha ( សភាភូមិ ) ដើម្បីធានាថា ស្ត្រីទាំងអស់មានឱកាសកាន់តែប្រសើរនិងចំហរ ដើម្បីដាក់កង្វល់របស់ពួកគេនៅក្នុងវេទិកាកម្រិតភូមិ។ សេចក្តីសម្រេចដែលត្រូវបានអនុម័តដោយ Mahila Sabha ក្រោយមកត្រូវបានដាក់នៅចំពោះមុខ Gram Sabha (ដែលក៏មានស្ត្រីជាសមាជិកផងដែរប៉ុន្តែពួកគេមិននិយាយចេញមកច្រើនទេនៅក្នុងវេទិកាទាំងនេះ ដោយសារការរឹតបន្តឹងរបស់សង្គម )។ ការធ្វើលំហាត់ដំណោះស្រាយកំណត់អាទិភាពដាច់ដោយឡែកជាមួយបុរសនិងក្រុមដែលផ្តោតលើស្ត្រីហើយបន្ទាប់មកនាំយកលំហាត់ទាំងនោះមកដាក់រួមគ្នាដើម្បីពិភាក្សានៅក្នុងវេទិកាមួយ អាចជាយុទ្ធសាស្ត្រមួយផ្សេងទៀតដើម្បីគាំទ្រដល់ការធ្វើសមាហរណកម្មតម្រូវការរបស់ស្ត្រីទៅក្នុងផែនការសកម្មភាពភាពធន់ និង CCDRR។ យុទ្ធសាស្ត្រដែលមានប្រយោជន៍មួយផ្សេងទៀត គឺការកំណត់ទិសដៅសម្រាប់ការចូលរួមរបស់ស្ត្រីនៅក្នុងសកម្មភាពនានានិងការបែងចែកថវិកាដោយប្រើប្រាស់ក្របខ័ណ្ឌរៀបចំថវិកាដែលឆ្លើយតបនឹងតម្រូវការយេនឌ័រ (GRB)។

អ្វីដែលមានសារៈសំខាន់ស្មើគ្នានោះ គឺការផ្តោតលើការចែករំលែកចំណេះដឹងនិងព័ត៌មាននិងការកសាងសមត្ថភាពរបស់ស្ត្រី។ព័ត៌មាននៅក្នុងសហគមន៍នៅពេលដែលត្រូវបានផ្តល់ជូនក្នុងវេទិកាទូទៅអាចមិនទៅដល់ស្ត្រីទេ។វាមានសារៈសំខាន់ក្នុងការមានបណ្តាញដាច់ដោយឡែកនានាដូចជាអ្នកស្ម័គ្រចិត្តស្ត្រីដែលអាចភ្ជាប់ទំនាក់ទំនងរវាងគម្រោងនិងស្ត្រីទាំងអស់។ព័ត៌មានក៏ចាំបាច់ត្រូវបង្ហាញនិងផ្សព្វផ្សាយតាមវិធីដែលពិចារណាលើកម្រិតអប់រំនៅមូលដ្ឋាន និងឌីណាមិកវប្បធម៌ផងដែរ ដើម្បីធានាថា ព័ត៌មាន

បានទៅដល់ស្ត្រី។ ការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយបែបប្រពៃណី ចម្រៀង ហ្គេម និងលំហាត់ដែលមានការចូលរួម អាចមានប្រយោជន៍ជាពិសេសក្នុងការនាំយកព័ត៌មានទៅដល់ស្ត្រី។ វាក៏មានសារៈសំខាន់ផងដែរក្នុងការធានាថាស្ត្រីទាំងអស់បានដឹងឮពីព្រឹត្តិការណ៍ និងដំណើរការបែបនេះ។ ការរៀបចំកិច្ចប្រជុំនៅទីកន្លែងដែលចំហរសម្រាប់ក្រុមសង្គមទាំងអស់ដែលមានចាស់ជរា និងជនពិការអាចមានលទ្ធភាពចូលរួមបាននិងធ្វើឡើងក្នុងពេលវេលា ដោយបានគិតគូលើពេលវេលាធ្វើការងារផ្ទះ និងធ្វើកិច្ចការផ្សេងទៀតរបស់ស្ត្រី មានសារៈសំខាន់ណាស់។

**សម្រាកដើម្បីចែក រំលែកករណីសិក្សា**

2:30:00

## វគ្គ ខ៖ ការបន្សាំតាមវិស័យ និងយេនឌ័រ

**ទិដ្ឋភាពទូទៅ**

នៅចុងបញ្ចប់នៃវគ្គនេះ អ្នកចូលរួមគួរមានសមត្ថភាពបង្កើតផែនទីវិសាលភាពយេនឌ័រ និង CCDRR ទាំងអស់នៅក្នុងវិស័យដែលផ្តល់ជូន ( មួយចំនួន ) ក៏ដូចជាកំណត់យុទ្ធសាស្ត្រ ការអនុវត្ត និងដំណោះស្រាយឆ្លើយតបនឹងតម្រូវការយេនឌ័រផងដែរ។ វគ្គនេះគួរត្រូវបានរៀបចំឡើងក្នុងទម្រង់ជាការ អនុវត្ត ក្នុងគោលបំណងឱ្យអ្នកចូលរួមមានលទ្ធភាពអនុវត្តការរៀនសូត្រទាំងនេះដោយផ្ទាល់នៅក្នុងការងាររបស់ពួកគេនៅពេលពួកគេវិលពេលត្រលប់ទៅវិញ។

**មាតិកា**

វគ្គនេះមាននៅក្នុងវិស័យជាក់លាក់ចំនួន៣៖

ក ) កសិកម្ម និងសន្តិសុខស្បៀង
ខ ) សុខភាពសាធារណៈ និងការឆ្លងរាលដាលជំងឺ
គ ) តំបន់ឆ្នេរ

គ្រូឧទ្ទេសអាចផ្តល់ជម្រើសមួយដល់អ្នកចូលរួមឱ្យជ្រើសរើសចេញពីវគ្គចំនួនបីដែលដំណើរការស្របពេលគ្នា ប្រសិនបើសម្ភារ ភស្តុភា អនុញ្ញាតឱ្យធ្វើទៅបាន ឬជ្រើសរើសជាមុននូវវិស័យមួយ។
នៅក្នុងវិស័យនីមួយៗ វិសាលភាពខាងក្រោមនេះត្រូវបានគ្របដណ្តប់៖

i ) ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ។
ii ) ភាពងាយរងគ្រោះទាក់ទងនឹងយេនឌ័រ និងជម្រើសការបន្សាំ។
iii ) ឧទាហរណ៍អំពីដំណោះស្រាយដែលឆ្លើយតបនឹងតម្រូវការយេនឌ័រ។

**ឯកសារ**

បទបង្ហាញជា PowerPoint
ក្រដាសតូចបិទកំណត់សម្គាល់ដែលមានពីរពណ៌ខុសគ្នា
ឧបករណ៍ចាក់បញ្ចាំងវីដេអូនៅលើ Youtube
ក្តារខៀន និងប៊ិចហ្វឹតធំ
ផ្ទាំងក្រដាសធំ និងប៊ិច
សំណៅឯកសារមួយច្បាប់

**តារាងពេលវេលា**

| រយៈពេល | សកម្មភាព |
|---|---|
| ១០នាទី | > ចំណុចពិភាក្សាអំពីភាពងាយរងគ្រោះទាក់ទងនឹងយេនឌ័រ និងទិដ្ឋភាពទូទៅរបស់វគ្គ |
| ៥០នាទី | > ក្រាហ្វិកព័ត៌មានអំពីអន្តរទំនាក់ទំនងនៃយេនឌ័រ និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ" ក្នុងវិស័យដែលបានជ្រើសរើស ( សូមមើលលំហាត់ទី២១ និងសំណៅឯកសារទី១៩ ) |
| ៣០នាទី | > បាឋកថាស្តីពី "ភាពងាយរងគ្រោះទាក់ទងនឹងយេនឌ័រ និងជម្រើសការបន្សាំក្នុងវិស័យដែលត្រូវបានជ្រើសរើស" |
| ៦០នាទី | > លំហាត់ផ្តល់ចំណាត់ថ្នាក់ម៉ាទ្រិចសម្រាប់ការកំណត់អាទិភាពនៃ"ដំណោះស្រាយការបន្សាំដែលឆ្លើយតបនឹងតម្រូវការយេនឌ័រ" ( សូមមើលលំហាត់ទី២២ និងសំណៅឯកសារទី២០ ) |

**កំណត់សម្គាល់ណែនាំ**

ចាប់ផ្ដើមវគ្គជាមួយនឹងការពិភាក្សាអំពីភាពងាយរងគ្រោះទាក់ទងនឹងយេនឌ័រនៅក្នុងវិស័យដែលត្រូវបានជ្រើសរើស។ ប្រាប់ពួកគេថា លំហាត់បន្ទាប់នឹងជួយពួកគេឱ្យស្វែងយល់កាន់តែប្រសើរអំពីថា តើវិសាលភាពយេនឌ័រទាំងនេះនៅក្នុងវិស័យនេះនឹងទទួលរងឥទ្ធិពលពីការប្រែប្រួលអាកាសធាតុ និងជម្រើសការបន្សាំដែលពាក់ព័ន្ធដោយរបៀបណា។ (សូមមើលលំហាត់ទី២១ និងសំណៅឯកសារទី១៩)។

តាមដានលំហាត់ជាមួយនឹងបាឋកថាស្ដីពី "ភាពងាយរងគ្រោះទាក់ទងនឹងយេនឌ័រ និងជម្រើសការបន្សាំក្នុងវិស័យដែលត្រូវបានជ្រើសរើស"។អ្នកអាចប្រើប្រាស់មាតិកាបច្ចេកទេសដែលត្រូវបានផ្ដល់ជូននៅក្នុងម៉ូឌុលនេះសម្រាប់ធ្វើបាឋកថាប៉ុន្តែមានការផ្ដល់យោបល់ឱ្យទូរស័ព្ទទៅកាន់អ្នកជំនាញតាមវិស័យនៅក្នុងស្រុកសម្រាប់ការធ្វើបាឋកថានេះ។ ការធ្វើបែបនេះនឹងធានាថា ព័ត៌មានមានភាពជាក់លាក់ទៅតាមបរិបទ និងប្រទេស។

បិទបង្ហាញបាឋកថា និងប្រាប់ពួកគេថា ឥឡូវនេះអ្នកនឹងផ្ដល់ជូនពួកគេនូវឧទាហរណ៍/ព័ត៌មានលម្អិតអំពីដំណោះស្រាយការបន្សាំដែលឆ្លើយតបនឹងតម្រូវការយេនឌ័ររបស់គម្រោងដែលអាចត្រូវបានអនុវត្តក្នុងវិស័យនេះ។ ផ្ដល់ជូនពួកគេនូវឧទាហរណ៍ចំនួន៥ ដែលត្រូវបានជ្រើសរើសជាមុនពីសំណៅឯកសារទី២០។ ចែករំលែកថាឥឡូវពួកគេក៏នឹងរៀនសូត្រអំពីរបៀបកំណត់អាទិភាពដំណោះស្រាយទាក់ទងនឹងយេនឌ័រផងដែរ ដោយប្រើប្រាស់បច្ចេកទេសផ្ដល់ចំណាត់ថ្នាក់ម៉ាទ្រិចដែលមានការចូលរួម។

## វិស័យទី១៖ ការប្រែប្រួលអាកាសធាតុ កសិកម្ម និងសន្តិសុខស្បៀង

**ចំណុចពិភាក្សា**

សួរអ្នកចូលរួមថា តើអ្វីគឺជាវិសាលភាពយេនឌ័រដែលមានស្រាប់នៅក្នុងវិស័យកសិកម្ម និងសន្តិសុខស្បៀង? ផ្ដោតលើការរំលេចតួនាទី និងរបាំងយេនឌ័រនៅក្នុងវិស័យទាំងនេះព្រមទាំងការទទួលបានដែលមានកម្រិតរបស់ស្ត្រីនូវទ្រព្យសម្បត្តិ ធនធាន និងសេវាកម្ម។ ខណៈដែលអ្នកចូលរួមបង្កើតបញ្ជីបញ្ហា ចូរសរសេរបញ្ហាទាំងនេះនៅលើក្ដារខៀនជាពីរតារាងជួរឈរ។

**គម្រូយសម្រាប់អ្នកសម្របសម្រួល**

**តួនាទី និងរបាំងយេនឌ័រ**

- ស្ត្រីផលិត ៦០% ទៅ ៨០% នៃអាហារដែលផលិតក្នុងស្រុក។
- ស្ត្រីជនបទស្ទើរតែទាំងអស់ ពោល គឺ ៩៦% ធ្វើការនៅលើដីស្រែចម្ការគ្រួសារ ដែលផ្ដល់ ៧៥% នៃកម្លាំងពលកម្មធ្វើស្រែចម្ការ និង ៦០% នៃប្រាក់ចំណូលដែលបានពីស្រែចម្ការ
- ដោយសារការកើនឡើងការធ្វើចំណាកស្រុករបស់បុរសស្ត្រីបានពង្រីកតួនាទីផលិតកម្មរបស់ខ្លួនតាមរយៈបច្ចេកទេសបន្សាំដើម្បីបង្កើនទិន្នផល ដើម្បីរកប្រាក់ចំណូល និងធានាបាននូវស្តង់ដាររស់នៅលើកម្រិតរស់រានមានជីវិតតិចតួចសម្រាប់គ្រួសាររបស់ពួកគេ។
- ស្ត្រីប្រឈមនឹងរបាំងដែលពាក់ព័ន្ធនឹងទីផ្សារខ្លាំងជាង។សូម្បីតែក្នុងសង្គមដែលគ្មានវិធានស្បែបិទមុខក៏ដោយបើធៀបនឹងបុរសស្ត្រីក៏មិនសូវទំនងថានឹងមានយានយន្ត និងកង់ផ្ទាល់ខ្លួននោះទេ ដោយពឹងផ្អែកខ្លាំងលើសេវាដឹកជញ្ជូនសាធារណៈ។
- សម្រាប់ស្ត្រីទាំងឡាយណាដែលជីវភាពរបស់ពួកគេពឹងផ្អែកលើការទិញនិងលក់ ឬលក់ដូរក្នុងទីផ្សារនៅក្នុងក្រុង ជាញឹកញាប់ពួកគេប្រឈមនឹងកម្រិតបៀតបៀនកាន់តែខ្លាំង រួមទាំងការបៀតបៀនផ្លូវភេទពីសំណាក់មន្ត្រីនៅពេលទទួលបានលិខិតអនុញ្ញាតិ ឬទីកន្លែងលក់ដូរ។
- ស្ត្រីនិងកុមារីជាទូទៅបរិភោគអាហារក្រោយគេ និងជាមនុស្សដំបូងគេដែលបោះបង់អាហារូបត្ថម្ភក្នុងករណីខ្វះខាតអាហារ។

**ការទទួលបាន និងការគ្រប់គ្រងទ្រព្យសម្បត្តិ ធនធាន និងសេវា**

- កសិករជាស្ត្រីជាញឹកញាប់មិនត្រូវបានទទួលស្គាល់ដោយអាជ្ញាធរថាជា "កសិករ" ទេ។
- ការផ្ដល់អាហារដល់គ្រួសាររបស់ពួកគេ និងការប្រើប្រាស់ដីរបស់ពួកគេជាញឹកញាប់មិនត្រូវបានទទួលស្គាល់ឡើយ ហើយស្ថិតនៅចុងបញ្ចប់នៃឋានានុក្រមរបស់គម្រោងអភិវឌ្ឍន៍កសិកម្ម។
- សេវាផ្សព្វផ្សាយកសិកម្មជាញឹកញាប់សំដៅទៅកាន់បុរសដែលគេចាត់ទុកថាជាកសិករ និងជាមេគ្រួសារ។ ស្ត្រីមានព័ត៌មានបច្ចេកទេសដែលចាំបាច់តិចតួចដើម្បីធ្វើឱ្យប្រសើរឡើងនូវកសិដ្ឋានរបស់ពួកគេ និងដើម្បីគ្រប់គ្រងធនធានទឹក។
- ស្ត្រីក៏ខ្វះខាតការទទួលបានហិរញ្ញវត្ថុ និងការអនុវត្តធុរកិច្ចទំនើបផងដែរ ដើម្បីពង្រឹងការគ្រប់គ្រងស្រែចម្ការ ធាតុចូល និងទិន្នផល
- ស្ត្រីមានអត្រាសមាជិកភាពទាបជាងនៅក្នុងសហករណ៍អ្នកផលិត ឬអាចត្រូវបានរឹតបន្តឹងមិនឱ្យចូលរួម។
- ស្ត្រីនៅតែខ្វះសិទ្ធិស្របច្បាប់ និងសិទ្ធិកាន់កាប់ទ្រព្យសម្បត្តិ។ កង្វះភាពជាម្ចាស់កម្មសិទ្ធិដីធ្លី ឬយ៉ាងហោចណាស់ទទួលបានសិទ្ធិកាន់កាប់ដីធ្លី មានន័យថា ស្ត្រីមិនមានទ្រព្យបញ្ចាំដែលតម្រូវឱ្យមានសម្រាប់ការទទួលបានឥណទាន ឬយន្តការហិរញ្ញវត្ថុផ្សេងទៀតពីគ្រឹះស្ថានហិរញ្ញវត្ថុផ្លូវការ ឬមិនឆ្លើយតបទៅនឹងលក្ខខណ្ឌតម្រូវសម្រាប់ការចូលរួមជាសមាជិកភាពក្នុងសមាគម

អ្នកផលិត សមាគមទីផ្សារ ឬសមាគមអ្នកប្រើប្រាស់ទឹក។ វាក៏មានន័យផងដែរថា នៅក្នុងតំបន់ដែលការទន្ទ្រានដីកំពុងកើតមានឡើងដើម្បីអត្ថប្រយោជន៍កសិកម្មទ្រង់ទ្រាយធំ សិទ្ធរបស់ស្ត្រីស្ថិតក្នុងហានិភ័យកាន់តែខ្លាំង។

> ស្ត្រីជាញឹកញាប់មានភាពជាតំណាងមិនគ្រប់គ្រាន់ក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្តបើទោះជាពួកគេអាចបង្កើតការចូលរួមចំណែកដ៏សំខាន់ចំពោះការពិភាក្សាទាំងនេះក៏ដោយ ដោយសារចំណេះដឹងអំពីស្ថានភាពអេកូឡូស៊ីនិងស្ថានភាពពាក់ព័ន្ធនឹងទឹកដែលបានក្លាយជាកត្តាមួយនៃតួនាទីសង្គមរបស់ពួកគេក្នុងនាមជាអ្នកគ្រប់គ្រងធនធានធម្មជាតិ។

## ភាពងាយរងគ្រោះទាក់ទងនឹងយេនឌ័រ

កសិកម្ម និងសកម្មភាពប្រវាស់មិនត្រឹមតែជាសមាសភាពដ៏ធំនៃប្រព័ន្ធផលិតកម្មស្បៀងរបស់យើងប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជាសកម្មភាពបរចិញ្ចឹមជីវិតដ៏សំខាន់របស់ប្រជាជនក្រីក្រភាគច្រើននៅក្នុងពិភពលោកផងដែរ ដែលរស់នៅដោយសារការធ្វើកសិកម្មសម្រាប់បរិភោគ ពោលគឺធ្វើការជាកម្មករស៊ីឈ្នួលកសិករ អ្នកកែច្នៃខ្នាតតូច ឬពាណិជ្ជករជាដើម។ វាជាការពិតសម្រាប់ប្រទេសនៅតំបន់អាស៊ី ជាទីដែលជាងពាក់កណ្តាលនៃប្រជាជនជាញឹកញាប់ចូលរួមក្នុងសកម្មភាពកសិកម្ម។ ឧទាហរណ៍ក្នុងប្រទេសកម្ពុជា ប្រជាជនប្រហែល ៨,៨លាននាក់ ឬស្មើ ៥៧,៦% នៃប្រជាជនសរុប មានការពាក់ព័ន្ធនឹងសកម្មភាពកសិកម្ម ដែលបានចូលរួមចំណែកដល់ទៅ ៣២,១% នៃផលិតផលក្នុងស្រុកសរុប (GDP) ក្នុងឆ្នាំ២០១១ (មិនមានប្រភពជាក់លាក់)។ ដូចគ្នានេះដែរ ក្នុងប្រទេសវៀតណាម កសិកម្មនៅតែចូលរួមចំណែក ២១% នៃ GDP និងផ្តល់ការងារជាង ៤៧% នៃកម្លាំងពលកម្មរបស់ប្រទេស (CCAFS ឆ្នាំ២០០៧)។

ការប្រែប្រួលសីតុណ្ហភាពនិងគំរូកំណកអាកាសជាពិសេសនឹងមានឥទ្ធិពលលើប្រព័ន្ធអេកូឡូស៊ីកសិកម្ម ដូច្នេះប៉ះពាល់ដល់ផលិតកម្មស្បៀងហើយតំបន់អាស៊ីនឹងទទួលរងផលប៉ះពាល់ពិសេសដោយសារការធ្លាក់ចុះផលិតកម្មកសិកម្ម (IPCC AFOLU ឆ្នាំ២០១៤)។

ស្ត្រីក្រីក្រជនបទជាពិសេសស្ត្រីក្នុងប្រទេសកំពុងអភិវឌ្ឍន៍ពឹងផ្អែកយ៉ាងខ្លាំងលើការធ្វើកសិកម្មសម្រាប់បរិភោគដើម្បីចិញ្ចឹមគ្រួសាររបស់ពួកគេ (Aguilar et al ឆ្នាំ២០១៥)។ ដោយសារការពឹងផ្អែកខ្លាំងរបស់ពួកគេលើកសិកម្ម និងវិសាលភាពយេនឌ័រដែលមានស្រាប់រួចទៅហើយក្នុងវិស័យកសិកម្ម ស្ត្រីទាំងនេះនឹងងាយរងគ្រោះបំផុតទៅនឹងហានិភ័យនៃការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយនៅក្នុងវិស័យកសិកម្ម។ក្នុងចំណោមផ្សេងៗទៀត ផលប៉ះពាល់ធំៗលើស្ត្រីរួមមាន៖

> ការប្រែប្រួលអាកាសធាតុត្រូវបានរំពឹងថានឹងកាត់បន្ថយទិន្នផលជាមធ្យមរបស់ដំណាំភាគច្រើន ជាពិសេសស្រូវ ស្រូវសាលី និងពោត។ ឧទាហរណ៍ នៅក្នុងប្រទេសកម្ពុជា ផលិតកម្មស្រូវអាចធ្លាក់ចុះ ១០ភាគរយសម្រាប់ការកើនឡើងសីតុណ្ហភាពរៀងរាល់ ១អង្សាសេ (RGC ឆ្នាំ ២០១៨)។ ការកើនឡើងកម្រិតទឹកសមុទ្រក៏គំរាមកំហែងតំបន់ឆ្នេរ និងតំបន់ផលិតកម្មស្រូវដីសណ្តនៅក្នុងតំបន់អាស៊ីផងដែរដូចជាតំបន់ក្នុងប្រទេសបង់ក្លាដែសនិងដីសណ្តទន្លេមេគង្គជាដើម។ ឧទាហរណ៍ ប្រហែល ៧% នៃដីកសិកម្មរបស់វៀតណាម អាចជន់លិចដោយសារការកើនឡើងកម្រិតទឹកសមុទ្រ ១ម៉ែត្រ។ ក្នុងប្រទេសមីយ៉ាន់ម៉ា ការហូរចូលទឹកប្រៃដោយសារការកើនឡើង កម្រិតទឹកសមុទ្រក៏អាចធ្វើឱ្យទិន្នផលស្រូវធ្លាក់ចុះផងដែរ (IPCC AR5៖ តំបន់អាស៊ី ឆ្នាំ២០១៤)។ ដូចគ្នានេះដែរ ក្នុងប្រទេសឥណ្ឌា តំបន់ទំនាប Indo-Gangetic ស្ថិតក្រោមការគំរាមកំហែងនៃការធ្លាក់ចុះទិន្នផលស្រូវសាលីខ្លាំង។ តំបន់នេះផលិតស្រូវស្រាលី៩០លានតោនក្នុងមួយឆ្នាំ (ប្រហែល ១៤% ទៅ ១៥% នៃផលិតកម្មស្រូវសាលីពិភពលោក (IPCC AR5៖ តំបន់អាស៊ីឆ្នាំ២០១៤)។ក្នុងសង្គមនានាជាទីដែលសង្គមទាំងនេះចូលរួមជាចម្បងក្នុងផលិតកម្មស្បៀង ជាពិសេសស្រូវ ស្រូវសាលី និងពោត ការធ្លាក់ចុះផលិតភាពដោយសារផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុនឹងបង្កើនភាពងាយរងគ្រោះរបស់ពួកគេ ទាំងកសិករ និងកម្មករស៊ីឈ្នួលក្នុងវិស័យកសិកម្ម។ ឧទាហរណ៍ក្នុងប្រទេសវៀតណាមការប្រែប្រួលអាកាសធាតុកំពុងកាត់បន្ថយទិន្នផលដំណាំបង្កើនបន្ទុកការងាររបស់ស្ត្រីដោយសារពួកគេដាំដំណាំស្រូវឡើងវិញជាញឹកញាប់ ដើម្បីជួសផលិតកម្មដែលបានបាត់បង់ (មិនមានប្រភពជាក់លាក់)។

> ដោយសារការធ្លាក់ចុះទិន្នផល និងផលិតកម្មស្រូវ និងស្រូវសាលីមានការរំពឹងថានឹងមាន "ឱនភាពផលិតកម្មស្បៀង" នៅក្នុងតំបន់។ ការកើនឡើងឱនភាពទាំងនេះនឹងមានស្ថានភាពកាន់តែធ្ងន់ធ្ងរឡើងថែមទៀតក្នុងអំឡុងពេលមានភាពរាំងស្ងួត ដែលជាបុព្វហេតុធ្ងន់ធ្ងរបំផុតបង្កឱ្យមានកង្វះស្បៀង ដោយបង្កឱ្យមាន ៦០% នៃស្បៀងសង្គ្រោះបន្ទាន់ (Aguilar et al ឆ្នាំ២០១៥)។ ស្ត្រីក៏មានការទទួលខុសត្រូវបន្ថែមទៀតផងដែរលើការធានាបាននូវសន្តិសុខស្បៀងនៅក្នុងគ្រួសារនោះនឹងកាន់តែប្រឈមថែមទៀតទៅនឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុដែលជះឥទ្ធិពលលើសន្តិសុខស្បៀង សន្តិសុខអាហារូបត្ថម្ភ និងសុខភាព។ ការរើសអើងសង្គមដែលមានស្រាប់និងការប្រតិបត្តិវប្បធម៌នៅក្នុងសង្គមអាស៊ីជាច្រើនបង្កឱ្យស្ត្រីនិងកុមារីញ៉ាំអាហារក្រោយគេនិងក្លាយជាមនុស្សដំបូងគេដែលបោះបង់អាហារូបត្ថម្ភក្នុងករណីខ្វះខាតអាហារ។ដូច្នេះមិនមានអ្វីដែលគួរឱ្យភ្ញាក់ផ្អើលនោះទេថាប្រហែល ៦០% នៃប្រជាជនដែលអត់ឃ្លាន រ៉ាំរ៉ៃគឺជាស្ត្រី និងកុមារី។ កង្វះអាហារដែលបង្កមកពីការប្រែប្រួលអាកាសធាតុ នឹងធ្វើឱ្យអសន្តិសុខមានភាពធ្ងន់ធ្ងរឡើងបន្ថែមទៀតដែលជះឥទ្ធិពលដល់សុខភាពរបស់ស្ត្រី។

**គន្លឹះសម្រាប់គ្រូឧទ្ទេស**

សម្រាប់វគ្គកម្រិតខ្ពស់ អ្នកអាចចង់ប្រើប្រាស់រូបទី២៣ និងពន្យល់ដូចខាងក្រោម៖ "ការអាក់ខានអាកាសធាតុអាចមានផលប៉ះពាល់ដូចគ្នាលើសន្តិសុខស្បៀងរបស់បុរសនិងស្ត្រី។ ដោយបន្ទាត់ចុចៗធ្លាក់ចុះពីកម្រិត (ក) ទៅកម្រិត (ខ) សម្រាប់កម្រិតសន្តិសុខស្បៀងទាំងបុរសនិងស្ត្រីនឹងស្ថិតនៅពីក្រោយកម្រិតកំណត់ភាពក្រីក្រសម្រាប់អសន្តិសុខ (បន្ទាត់ក្រហមឈរ)។ សំណាញ់សុវត្ថិភាព និងទ្រព្យសម្បត្តិនឹងជួយគ្រួសារឱ្យដើរមុខកម្រិតកំណត់ភាពក្រីក្រ ដូចដែលមើលឃើញក្នុងកម្រិត (គ)។ ទោះជាយ៉ាងណាការណ៍នេះនឹងមិនឈានទៅរកកម្រិតធម្មតាឡើយ ហើយគ្រួសារនឹងត្រូវតែចាត់សកម្មភាពបន្សាំដើម្បីស្តារកម្រិតលំនឹង។ ទោះជាយ៉ាងណា ដោយសារការរើសអើងយេនឌ័រក្នុងគ្រួសារក្នុងសន្តិសុខស្បៀងខណៈដែលបុរសនឹងមានភាពប្រសើរជាងពេលកន្លងមក ស្ត្រីនឹងត្រូវបានគេទុកចោលកាន់តែអាក្រក់ ដូចដែលមើលឃើញនៅកម្រិត (ឃ)"។

ការប្រែប្រួលអាកាសធាតុក៏នឹងបង្កើនស្រ្តេសទឹកផងដែរដែលនឹងបង្កើនបន្ទុកការងារកសិម្មសម្រាប់បរិភោគរបស់ស្ត្រីថែមទៀតដែលពួកគាត់ត្រូវការលទ្ធភាពទទួលបានទឹកសម្រាប់ផលិតកម្មនិងការរៀបចំស្បៀង។ ឧទាហរណ៍ ក្នុងប្រទេសវៀតណាម គ្រួសារដែលមានស្ត្រីជាមេគ្រួសារជួបការលំបាកក្នុងការទទួលបានទឹកគ្រប់គ្រាន់សម្រាប់តម្រូវការកសិកម្ម។ គ្រួសារដែលមានស្ត្រីជាមេគ្រួសាររាយការណ៍ពីការធ្លាក់ចុះទិន្នផលស្រូវ២០%ធៀបនឹងគ្រួសារដែលមានបុរសជាមេគ្រួសារ ដោយសារការផ្គត់ផ្គង់ទឹកមានកម្រិត (មិនមានប្រភពជាក់លាក់)។

> ការប្រែប្រួលអាកាសធាតុនិងជម្រើសបន្សាំជាបន្តបន្ទាប់ក៏អាចជះឥទ្ធិពលដល់ជម្រើសរបរចិញ្ចឹមជីវិតប្រវាស់ផងដែរ ដូចជាការចិញ្ចឹមសត្វពាហនៈជាដើម។ការប្រើប្រាស់ដោយគ្មាននិរន្តរភាពនូវដីវាលស្មៅដែលមានស្រ្តេសដែលបង្កដោយការប្រែប្រួលអាកាសធាតុបាននាំទៅរកការបំផ្លាញគំរបសារព័ន្ធរុក្ខជាតិដោយសារកង្វះទឹកដែលមានផលវិបាកខូចខាតដល់ផលិតកម្មចំណីសត្វ។ដោយសារតួនាទីដ៏សំខាន់របស់ស្ត្រីក្នុងជីវិតឃ្វាលសត្វ និងការចិញ្ចឹមសត្វពាហនៈ ពួកគេត្រូវតែអត់ទ្រាំទៅនឹងការផ្លាស់ប្តូរទាំងនេះភាគច្រើន។

ស្ត្រីក៏មានទំនោរចង់បានសត្វតូចៗជាងដូចជាមាន់ពពែកនិងជ្រូកខណៈដែលបុរសចង់បានសត្វធំជាងនេះជាងដូចជាគោព្រមទាំងបង្កើនពូជសត្វពាហនៈផ្សេងៗ។នៅក្នុងស្ថានភាពមានគ្រោះមហន្តរាយ ស្ត្រីជាញឹកញាប់បាត់បង់ជម្រើសទាំងនេះ ដោយសារកង្វះការជួយសង្គ្រោះ ឬដោយសារការលក់ចេញក្រោយគ្រោះមហន្តរាយ ដើម្បីឆ្លើយតបទៅនឹងតម្រូវការសាច់ប្រាក់របស់គ្រួសារ។ ក្នុងពេលមានគ្រោះទឹកជំនន់នៅប្រទេសមីយ៉ាន់ម៉ានៅឆ្នាំ២០១៥ ស្ត្រីបានបាត់បង់៨០%នៃសត្វទាំងអស់ដែលបានស្លាប់ក្នុងគ្រោះទឹកជំនន់ ខណៈដែលបុរសបានបាត់បង់ ២០% នៃក្របី គោ និងជ្រូក (UN Women ឆ្នាំ២០១៦)។បុរសដែលជាញឹកញាប់បំផុតមានសត្វគោធំៗនិងពូជថ្លៃៗក៏បានទទួលរងប៉ះពាល់ខ្លាំងផងដែរ ដោយសារសត្វគោមានភាពងាយរងគ្រោះពិសេសទៅនឹងឥទ្ធិពលនៃការប្រែប្រែអាកាសធាតុ (Aguilar et al ឆ្នាំ២០១៥)។

**រូបទី៥0៖ សន្តិសុខស្បៀងធៀបនឹងកម្រិតកំណត់ភាពក្រីក្រ (យេនឌ័រ និងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ)**




**A.** households' normal food security level; **B.** impact of climate disruption on food security; **C.** safety nets and assets raising households above the poverty line but not to normality; **D.** household adaptation is needed to return to equilibrium.

**គន្លឹះសម្រាប់គ្រូឧទ្ទេស**

អ្នកក៏អាចបង្ហាញវីដេអូខ្លីអំពីយេនឌ័រនៅក្នុងការបន្សាំនឹងការប្រែប្រួលអាកាសធាតុនេះផងដែរហើយស្នើឱ្យអ្នកចូលរួមរំលេចដំណាក់កាលនៅក្នុងសកម្មភាពបន្សាំ ដែលត្រូវការធ្វើសមាហរណកម្មយេនឌ័រ។ វីដេអូដែលផលិតឡើងដោយអង្គការ FAO ស្តីពី "ការដោះស្រាយកង្វល់យេនឌ័រក្នុងគោលនយោបាយការប្រែប្រួលអាកាសធាតុសម្រាប់កសិកម្ម" ដែលអាចរកមើលបានតាមរយៈគេហទំព័រhttps://www.youtube.com/watch?time_continue=270&v=nsIx-sSOXups&feature=emb_title នឹងមានប្រយោជន៍។

## ស្ត្រីគឺជាភ្នាក់ងារនៃការផ្លាស់ប្តូរ

ទោះជាយ៉ាងណាស្ត្រីមិនមែនត្រឹមតែជាផ្នែកដែលងាយរងគ្រោះមួយរបស់សហគមន៍កសិកម្មដែលចាំបាច់ត្រូវយកចិត្តទុកដាក់ប៉ុណ្ណោះទេ។ ដោយសារតួនាទីដ៏សំខាន់របស់ស្ត្រីក្នុងកសិកម្ម និងសន្តិសុខស្បៀងពួកគេក៏មានសក្តានុពលក្នុងការចាត់វិធានការបន្សាំក្នុងនាមជាភ្នាក់ងារចម្បងនៃការផ្លាស់ប្តូរផងដែរ។ យោងតាមអង្គការFAO(មិនមានប្រភពជាក់លាក់)ដោយមានការទទួលបានស្មើគ្នានូវធនធាន និងសេវា ស្ត្រីអាចបង្កើនទិន្នផលកសិកម្មរបស់ពួកគេរហូតដល់ពី ២០% ទៅ ៣០%។ កត្តានេះនឹងបង្កើនទិន្នផលកសិកម្មសរុបក្នុងប្រទេសកំពុងអភិវឌ្ឍន៍ចំនួនពី ២,៥% ទៅ ៤%។ ទិន្នផលបន្ថែមអាចចិញ្ចឹមមនុស្សបានចំនួនពី ១០០ ទៅ ១៥០លាននាក់បន្ថែមទៀត។ ដូច្នេះ ការដោះស្រាយភាពខុសគ្នារវាងស្ត្រីនិងបុរសក្នុងការទទួលបានធនធានហិរញ្ញវត្ថុនិងធនធានផលិតកម្ម ការធ្វើសេចក្តីសម្រេចចិត្ត ទីផ្សារ និងសេវា ដី និងទឹក និងចំណេះដឹងនិងបច្ចេកវិទ្យា អាចជាយុទ្ធសាស្ត្របន្សាំដ៏ធំមួយដើម្បីបង្កើនផលិតកម្ម។

ស្ត្រីក៏ដើរតួនាទីសំខាន់មួយផងដែរក្នុងនាមជាភ្នាក់ងារនៃការអភិរក្សកសិជីវចម្រុះ និងសន្តិសុខស្បៀងគ្រួសារតាមរយៈសួន ឬដីតូចៗរបស់គ្រួសារ។ខណៈដែលលំហូរចំណាកស្រុកកាត់បន្ថយការចូលរួមរបស់បុរសក្នុងការបង្កបង្កើនផលស្ត្រីដើរតួនាទីកាន់តែសំខាន់ថែមទៀតនៅក្នុងការរក្សាចំណេះដឹងអំពីពូជដំណាំផ្សេងៗព្រមទាំងការសម្រេចចិត្តថាតើដំណាំមួយណាដែលត្រូវដាំ។ ក្នុងប្រទេសហ្វីលីពីន តួនាទីធ្វើស្រែចម្ការរបស់មេគ្រួសារដែលជាស្ត្រីកំពុងផ្លាស់ប្តូរដោយសារកសិកម្មត្រូវបន្សាំទៅនឹងទឹកជំនន់។បទពិសោធធ្វើស្រែចម្ការរបស់ស្ត្រីនិងកម្រិតអប់រំកាន់តែខ្ពស់ធៀបនឹងបុរសនៅក្នុងបរិបទនេះកំពុងផ្តល់លទ្ធភាពដល់ពួកគេឱ្យទទួលខុសត្រូវលើផ្នែកគ្រប់គ្រងកាន់តែខ្លាំងឡើងដែលជម្នះនឹងតួនាទីយេនឌ័របែបប្រពៃណី (មិនមានប្រភពជាក់លាក់)។ដោយមានតួនាទីទ្វេរដងពោល គឺជាកសិករផង និងជាអ្នករៀបចំទុកដាក់ស្បៀងផង ការជ្រើសរើសពូជដំណាំតាមបែបប្រពៃណីរបស់ស្ត្រីនៅក្នុងតំបន់នេះ ជាញឹកញាប់ទទួលរងឥទ្ធិពលពីចំណង់ចំណូលចិត្តបរិភោគដែលចូលរួមចំណែកដល់សន្តិសុខស្បៀង។ស្ថាប័នស្រាវជ្រាវក៏មានការកើនឡើងផងដែរ ដែលរំលេចពីតួនាទីប្លែកពីគេរបស់ស្ត្រីនៅក្នុងការគ្រប់គ្រងភាពចម្រុះនៃដំណាំនៅក្នុងប្រទេសនានា ដូចជាប្រទេសនេប៉ាល់ជាដើម (មិនមានប្រភពជាក់លាក់) និងប្រទេសបង់ក្លាដែស (មិនមានប្រភពជាក់លាក់) ជាញឹកញាប់តាមរយៈការសន្សំ និងដោះដូរគ្រាប់ពូជ និងការថែទាំសួននៅផ្ទះដែលបម្រើជាប្រភពមួយនៃសន្តិសុខស្បៀងគ្រួសារ។

ស្ត្រីនៅក្នុងគ្រួសារជនបទក៏មានយុទ្ធសាស្ត្របែបប្រពៃណីផងដែរសម្រាប់ការធានាបានការផ្គត់ផ្គង់ស្បៀងនៅក្នុងគ្រាដែលមានគ្រោះមហន្តរាយនានាដូចជាទឹកជំនន់ និងភាពរាំងស្ងួតជាដើម។ ស្ត្រីជាញឹកញាប់ទទួលខុសត្រូវលើការរក្សាទុកស្បៀង និងគ្រាប់ពូជ។ ជាទូទៅពួកគេគ្រប់គ្រងសត្វពាហនៈតូចៗ និងកែច្នៃអនុផលរបស់ពួកគេដែលអាចជាប្រភពប្តូរជាសាច់ប្រាក់បានភ្លាមៗនៅក្នុងគ្រាអាសន្ន។ ផលិតផលទឹកដោះ ដែលជាញឹកញាប់ជាការទទួលខុសត្រូវរបស់ស្ត្រី និងផលិតផលសត្វផ្សេងទៀត (ដូចជា ឃ្មុំ ដង្កូវនាង) ផ្តល់ជូនគ្រួសារនូវប្រាក់ចំណូលទៀងទាត់ជាងដំណាំ ឬការលក់សត្វ។ ស្ត្រីអាចបង្កើនការប្រមូលរុក្ខជាតិព្រៃ និងសាច់សត្វព្រៃដល់កម្រិតគ្មាននិរន្តរភាពដើម្បីបំពេញបន្ថែមទៅនឹងការខ្វះខាតដំណាំ និងប្រូតេអ៊ីន។

## ជម្រើសនិងយុទ្ធសាស្ត្របន្សាំដែលឆ្លើយតបនឹងតម្រូវការយេនឌ័រ

ប្រការសំខាន់គឺថាការពិចារណាលើយេនឌ័រទទួលខុសត្រូវក្នុងដំណើរការបន្សាំកសិកម្មទាំងដើម្បីធានាថា ភាពងាយរងគ្រោះបន្ថែមរបស់ស្ត្រីត្រូវបានដោះស្រាយនិងទាំងដើម្បីឱ្យពួកគេចូលរួមក្នុងនាមជាភ្នាក់ងារដ៏សំខាន់នៃការផ្លាស់ប្តូរផងដែរ។លើសពីនេះទៀត ដោយសារស្ថានភាពសមភាពយេនឌ័រដែលមានស្រាប់ និងការរើសអើងប្រឆាំងនឹងស្ត្រី វាមិនទំនងជាខ្លាំងថា វិធានការបន្សាំ"អព្យាក្រិតភាពយេនឌ័រ"អាចផ្តល់លទ្ធផលដែលចង់បាន។ ឧទាហរណ៍ គម្រោង CCA ដែលលើកកម្ពស់ពូជដំណាំថ្មីៗដែលអត់ធន់នឹងភាពរាំងស្ងួត ជាតិប្រៃ និង/ឬទឹកជំនន់ ដើម្បីទប់ទល់នឹងការប្រែប្រួលប្រព័ន្ធអេកូឡូស៊ី អាចធ្វើឱ្យស្ត្រីផ្លាស់ប្តូរទីលំនៅប្រសិនបើពូជដំណាំថ្មីទាំងនេះទទួលបានផលល្អ និងត្រូវបានគ្រប់គ្រងដោយបុរស (Aguilar et al ឆ្នាំ២០១៥)។ កត្តាទាំងនេះក៏អាចបង្កើនតម្រូវការកម្លាំងពលកម្មរបស់ស្ត្រីផងដែរ។ ឧទាហរណ៍ក្នុងប្រទេសនេប៉ាល់ការផ្លាស់ប្តូរទៅដាំរុក្ខជាតិbuck-wheat ដើម្បីឆ្លើយតបទៅនឹងការអាក់ខានអាកាសធាតុ បានបង្កឱ្យស្ត្រីធ្វើការងារច្រើនជាងបុរស ដើម្បីផលិតដំណាំនេះ ដែលកាត់បន្ថយពេលវេលាដែលមានសម្រាប់សកម្មភាពរបរចិញ្ចឹមជីវិតផ្សេងទៀត (មិនមានប្រភពជាក់លាក់)។

**រូបទី៥១៖ការពិចារណាលើយេនឌ័រសក្តានុពលសម្រាប់គម្រោងតាមបែប CSA**

| CSA-SENSITIVE PRACTICES | GENDER IMPACT | REQUIREMENTS FOR ADOPTION PRACTICE | | | | | |
|---|---|---|---|---|---|---|---|
| | Women's Control of Income from Practice | Relative Amount of Time Until Benefits are Realized | Potential for Women to Benefit from Increased Productivity | Female and Youth Labour Availability | Female Access to and Control of Land | Female Access to Water for Agriculture | Female Access to Cash and Ability to Spend It |
| Conservation Agriculture | Low | High | High | Low-Medium | High | Low | Low |
| Improved Home Gardens | High | Low | High | High | High | High | High |
| On-Farm Tree Planting | Low | High | Medium | High Initially, Low Later | High | High | Medium |
| Small-Scale Irrigation | Low-Medium | Low | High | Medium | High | High | Medium |
| Livestock Genetic Improvement | Low-High | High | High | Low-High | Low | High | Medium |

ប្រភព៖ (មិនមានប្រភពជាក់លាក់)។

ជាការពិតគម្រោងជាច្រើនអាចបញ្ចប់ដោយមានការជះឥទ្ធិពលអវិជ្ជមានលើស្ត្រីនិងគ្រួសាររបស់ពួកគេខណៈពេលដែលមានការបង្កើនវិសមភាពយេនឌ័រផងដែរ។ ដូច្នេះ ជម្រើសបន្សាំកសិកម្មចាំបាច់ត្រូវតែពិនិត្យមើលឡើងវិញដើម្បីឱ្យមានការពិចារណាលើយេនឌ័រ។ នេះមានន័យថា តម្រូវការពិសេស អាទិភាព និងភាពពិតប្រាកដរបស់បុរសនិងស្ត្រីត្រូវបានទទួលស្គាល់និងដោះស្រាយគ្រប់គ្រាន់នៅក្នុងការរៀបចំនិងការអនុវត្តកសិកម្មឆ្លាតវៃដែលធន់នឹងអាកាសធាតុ(CSA)ដើម្បីឱ្យទាំងបុរសនិងស្ត្រីអាចទទួលបានអត្ថប្រយោជន៍ស្មើគ្នា។អង្គការ FAO បានស្នើឱ្យមានម៉ាទ្រិចសក្តានុពលមួយសម្រាប់ការពិចារណាលើយេនឌ័រនៅក្នុងគម្រោង CSA។ ការធ្វើការវិភាគបែបនេះនឹងជាជំហានទីមួយចំពោះវិធីសាស្ត្រ CSAដែលឆ្លើយតបនឹងតម្រូវការយេនឌ័រសម្រាប់អ្នកអនុវត្តគម្រោង។

ស្ត្រីក៏ទំនងជាខ្លាំងផងដែរថានឹងទទួលបានអត្ថប្រយោជន៍ពីការធ្វើអន្តរាគមន៍លើរបបចិញ្ចឹមជីវិតដែលត្រូវបានជ្រើសរើស។ ឧទាហរណ៍គម្រោងចិញ្ចឹមសត្វដែលតម្រូវឱ្យមានជាតុចូលមួយចំនួន ដែលជាទូទៅគឺជាគម្រោងចិញ្ចឹមសត្វតូចៗដូចជាជ្រូកឬមាត់ឬពូជគោដែលស៊ាំនឹងអាកាសាធាតុក្នុងស្រុក (មិនមានប្រភពជាក់លាក់) អាចផ្តល់អត្ថប្រយោជន៍ដល់ស្ត្រីជាង (មិនមានប្រភពជាក់លាក់)។ ការលើកកម្ពស់ការធ្វើសួនបន្លែពិសេសនៅលើដីក្នុងបរិវេណផ្ទះជាទីដែលស្ត្រីមានសំឡេង និងការគ្រប់គ្រងខ្លាំងជាង អាចជាការធ្វើអន្តរាគមន៍មួយបែបផ្សេងទៀត។ កត្តាទាំងនេះអាចជួយបានជាពិសេសក្នុងតំបន់នានាដូចជាក្នុងប្រទេសកម្ពុជាដែលជួបប្រទះនឹងទឹកជំនន់ ដែលប៉ះពាល់ដល់ការប្រមូលផលស្រូវ។ ដូច្នេះសួនបន្លែរបស់ស្ត្រីបង្ហាញឱ្យឃើញថាជាជម្រើសជំនួសដ៏ល្អមួយ។ ការសិក្សាថ្មីមួយដែលធ្វើឡើងដោយ Nexus សម្រាប់ការអភិវឌ្ឍបានរកឃើញថានៅក្នុងខេត្តពោធិសាត់ក្នុងប្រទេសកម្ពុជាក៏បានរំលេចផងដែរថា ម៉ាស៊ីនបូមទឹក ឡជីវឧស្ម័ន និងទូរទឹកកក និងម៉ាស៊ីនសម្ងួតដែលដំណើរការដោយថាមពលកកើតឡើងវិញអាចផ្តល់អត្ថប្រយោជន៍យ៉ាងធំធេងដល់កសិករស្ត្រីក្នុងរយៈពេលវែង (Empower ឆ្នាំ២០១៩)។

ទោះជាយ៉ាងណា អ្វីដែលមានសារៈសំខាន់ផងដែរនោះ គឺត្រូវកំណត់អាទិភាពការអនុវត្តទាំងនេះនៅក្នុងការបែងចែកថវិកានិងបន្តធ្វើយ៉ាងសកម្មតាមរយៈយុទ្ធសាស្ត្រអនុវត្តជាពិសេសសេវាផ្សព្វផ្សាយ។ ជាញឹកញាប់ សេវាផ្សព្វផ្សាយ និងការអនុវត្តផ្សេងទៀតត្រូវបានរៀបចំធ្វើឡើងសម្រាប់បុរសជាងសម្រាប់ស្ត្រី ។ប្រការសំខាន់ត្រូវមានការចែកចាយផ្អែកលើយេនឌ័រដោយសារការចែកចាយនេះគឺសម្រាប់ការអនុវត្តឆ្ពោះទៅរកការបញ្ជ្រាបយេនឌ័រ (មិនមានប្រភពជាក់លាក់)។

តារាងទី១៧ ខាងក្រោម លើកឡើងពីយុទ្ធសាស្ត្រ និងការអនុវត្តសំខាន់ៗមួយចំនួនដែលអាចត្រូវបានអនុវត្តដើម្បីលើកកម្ពស់កសិកម្មឆ្លាតវៃដែលធន់នឹងអាកាសធាតុដែលឆ្លើយតបនឹងតម្រូវការយេនឌ័រ។

## តារាងទី១៧៖ យុទ្ធសាស្ត្រ និងការអនុវត្តសម្រាប់កសិកម្មឆ្លាតវៃខាងអាកាសធាតុ

| លើកកម្ពស់របរចិញ្ចឹមជីវិតក្នុងកសិកម្មរបស់ស្ត្រី | លើកកម្ពស់របរចិញ្ចឹមជីវិតក្នុងកសិកម្មរបស់ស្ត្រី | លើកកម្ពស់របរចិញ្ចឹមជីវិតក្នុងកសិកម្មរបស់ស្ត្រី |
|---|---|---|
| > វិភាគផលប៉ះពាល់នៃការប្រើប្រាស់គ្រាប់ពូជថ្មីៗ និងលើកកម្ពស់ការចែកចាយការងារក្នុងគ្រួសារប្រកបសមធម៌កាន់តែខ្លាំង។<br>> បន្សាំការអនុវត្តដែលត្រូវបានលើកកម្ពស់ចំពោះការបែងចែកយេនឌ័រដែលមានស្រាប់សម្រាប់កសិកម្ម និងការគ្រប់គ្រងសត្វពាហនៈ។<br>> ផ្តល់ការបណ្តុះបណ្តាលអំពីការផ្សព្វផ្សាយកសិកម្ម និងកសិកម្មឆ្លាតវៃដែលធន់នឹងអាកាសធាតុទៅដល់ស្ត្រី។<br>> បង្កើតបបនីយកណ្តូទីផ្សារដែលអាចរកបាន។<br>> បង្កើតបទប្បញ្ញត្តិជំនួសសម្រាប់ស្ត្រីនិងក្រុមដែលផ្តោតលើស្ត្រី និងសហករណ៍ដែលមិនមានលទ្ធផលផ្តល់ទ្រព្យបញ្ចាំដែលត្រូវការជាចាំបាច់សម្រាប់ការវាយតម្លៃឥណទានកសិកម្ម។ | > ប្រើប្រាស់ចំណេះដឹងកសិកម្មក្នុងមូលដ្ឋាន/តំបន់ និងរួមបញ្ចូលស្ត្រី និងបុរសដើម្បីធានា ថា ពូជដំណាំតំបន់ (ដំណាំជនជាតិដើម) ត្រូវបានប្រើប្រាស់នៅទីកន្លែងណាដែលអាចធ្វើបាន។<br>> កសាងភាពធន់របស់សហគមន៍ទៅនឹងសន្តិសុខស្បៀងតាមរយៈការបង្កើតធនាគារគ្រាប់ពូជឆ្លាតវៃដែលធន់នឹងអាកាសធាតុដែលកាន់កាប់ និងគ្រប់គ្រងដោយស្ត្រី។<br>> រួមបញ្ចូលស្ត្រី និងបុរសក្នុងការអភិរក្សជីវចម្រុះ។<br>> ផ្តល់អាហារូបត្ថម្ភបំពេញបន្ថែមដាក់លាក់សម្រាប់ស្ត្រី និងកុមារី។ | >សម្របសម្រួលការទទួលបាននិងការគ្រប់គ្រងធនធានប្រកបដោយសមធម៌ព្រមទាំងការបែងចែកអត្ថប្រយោជន៍ (រួមទាំងធនធានផលិតកម្ម ការងារ ការបណ្តុះបណ្តាល និងឥណទាន)។<br>> លើកកម្ពស់សន្តិសុខកម្មសិទ្ធិដីធ្លីរបស់ស្ត្រី។<br>> ជំរុញឱ្យមានសមធម៌ក្នុងការមានលទ្ធភាពទទួលបានភាពជាម្ចាស់កម្មសិទ្ធិដីដែលមានទឹកស្រោចស្រព។<br>> ពង្រីកការទទួលបានឥណទានជានារ៉ាប់រង និងយន្តការហិរញ្ញវត្ថុផ្សេងទៀត។<br>> ពិនិត្យឡើងវិញនូវយុទ្ធសាស្ត្រដែលមានស្រាប់ដែលអាចឱ្យមានលំហូរឥណទានពីធនាគារសាធារណៈ/ធនាគារពាណិជ្ជនិងស្ថាប័នហិរញ្ញវត្ថុនានា ដើម្បីគាំទ្រ និងបង្កើនការទទួលបានឥណទានរបស់ស្ត្រី<br>> បន្សាំការចូលរួម/លក្ខណៈវិនិច្ឆ័យសមាជិកភាព និងកាត់បន្ថយរបាំងដែលរារាំងនាំឲ្យការចូលរួមជំសកម្ម និងភាពជាអ្នកដឹកនាំរបស់ស្ត្រីនៅក្នុងស្ថាប័នធ្វើសេចក្តីសម្រេចចិត្តនៅគ្រប់កម្រិតថ្នាក់ (ឧ. វគ្គាប្រម៉ាញ់ ការគ្រប់គ្រងផ្ទៃជម្រាលទឹក ទឹកសម្រាប់ស្រោចស្រព ការគ្របគ្រងផ្ទេរ ការអភិរក្សជីវចម្រុះ និងគ្រោះមហន្តរាយ)។ |

## វិស័យទី២៖ ការប្រែប្រួលអាកាសធាតុ សុខភាពសាធារណៈ និងការឆ្លងរាលដាលជំងឺ

**ចំណុចពិភាក្សា**

សួរអ្នកចូលរួម ថាតើពួកគេគិតអ្វីអំពីអត្រាប្រេវ៉ាឡង់ និងអាត្រាស្លាប់តាមករណីរបស់បុរស និងស្ត្រី ដោយសារជំងឺកូវីដ-១៩? សួរអ្នកចូលរួមផងដែរថា តើពួកគេគិតថាអ្វីគឺជាផលប៉ះពាល់យេនឌ័រ និងហានិភ័យផ្សេងទៀតដោយសារជំងឺកូវីដ-១៩?

**តម្រុយសម្រាប់អ្នកសម្របសម្រួល**

> បុរស និងស្ត្រីមានប្រេវ៉ាឡង់ជំងឺកូវីដ-១៩ ដូចគ្នា។ ទោះជាយ៉ាងណា ខណៈដែលការសិក្សាមួយនៅប្រទេសចិនបង្ហាញថា បុរសស្ថិតក្នុងហានិភ័យខ្លាំងជាងចំពោះការទទួលលទ្ធផលអាក្រក់ និងស្លាប់ដោយសារជំងឺកូវីដ-១៩ ដោយមិនគិតពីអាយុ (មិនមានប្រភពជាក់លាក់)។ ការវិភាគប្រហាក់ប្រហែលគ្នានានានៅសហរដ្ឋអាមេរិក និងប្រទេសអ៊ីតាលី ក៏បានបង្ហាញផងដែរថា អត្រាស្លាប់មានកម្រិតខ្ពស់ជាងក្នុងចំណោមបុរស។

> ភាពខុសគ្នាទាំងនេះត្រូវបានចាត់ទុកថាដោយសារភាពខុសគ្នាផ្នែកប្រព័ន្ធការពាររាងកាយផ្អែកលើភេទដោយសារអ័រម៉ូនរបស់ស្ត្រី ប្រេវ៉ាឡង់ជក់បារីចំពោះស្ត្រីមានអត្រាទាបជាងស្ថានភាពជំងឺកើតឡើងដំណាលគ្នាដែលកំពុងវិវត្តរបស់បុរសដូចជាជំងឺលើសឈាមដែលកើតឡើងនៅអាយុវ័យក្មេងជាងស្ត្រី។

> ដូច្នេះ នៅក្នុងគ្រាកើតមានជំងឺបែបនេះ បុរសហាក់ដូចជាមានភាពងាយរងគ្រោះទៅនឹងជំងឺកូវីដ-១៩ខ្លាំងជាងស្ត្រី។ ទោះជាយ៉ាងណា មានផលប៉ះពាល់ផ្អែកលើយេនឌ័រផ្សេងទៀតជាច្រើន។

**ដំបូង មានភាពមិនប្រក្រតីផ្នែកប្រជាសាស្ត្រ**

> ឧទាហរណ៍ ប្រទេសឥណ្ឌាបានរាយការណ៍ពីអាត្រាប្រេវ៉ាឡង់កាន់តែខ្ពស់ក្នុងចំណោមបុរស (៦៥% នៃករណីរួម) ប៉ុន្តែអាត្រាមរណភាពក្នុងចំណោមស្ត្រីមានកម្រិតខ្ពស់ជាងក្នុងចំណោមបុរស ដោយស្ត្រីមាន ៣,៣% ធៀបនឹងបុរស ២,៩%។ ក្រោយមកមានអន្តរវិស័យភាពខាងអាយុ។ ក្នុងក្រុមមនុស្សដែលមានអាយុចាប់ពី ៤០ ទៅ ៤៩ឆ្នាំ ៣,២% នៃស្ត្រីដែលឆ្លងជំងឺបានស្លាប់ធៀបនឹងបុរសដែលមាន ២,១%។ ក្នុងក្រុមមនុស្សដែលមានអាយុចន្លោះពី ៥ ទៅ ១៩ឆ្នាំ មានតែស្ត្រីទេដែលបានស្លាប់ (មិនមានប្រភពជាក់លាក់)។

> កត្តាកំណត់សង្គមនានាដូចជាការទទួលបានការថែទាំសុខភាពព្រមទាំងសុខភាពទូទៅនិងស្ថានភាពអាហារូបត្ថម្ភដែលជាទូទៅស្ត្រីមានស្ថានភាពអាក្រក់ ជាងបុរសក្នុងប្រទេសឥណ្ឌា អាចពន្យល់ពីភាពខុសគ្នាទាំងនេះដែលខុសពីនិន្នាការពិភពលោក (មិនមានប្រភពជាក់លាក់)។

**បន្ទាប់មក មានភាពមិនប្រក្រតីផ្នែកការប្រឈម**

> ពីព្រោះស្ត្រីចូលរួម ៧០% នៃបុគ្គលិកផ្នែកសេវាសុខភាព និងសង្គមនៅទូទាំងពិភពលោក (មិនមានប្រភពជាក់លាក់) ហើយចំណែករបស់ស្ត្រីនៅក្នុងបុគ្គលិកថែទាំសុខភាពដែលរងប៉ះពាល់ក៏មានកម្រិតខ្ពស់ផងដែរ ឧទាហរណ៍នៅប្រទេសអេស្ប៉ាញមាន ៧២% និងប្រទេសអ៊ីតាលីមាន ៦៦% (មិនមានប្រភពជាក់លាក់)។

> លើសពីនេះទៀតភាគច្រើននៃអ្នកទាំងនេះស្ថិតនៅជួរមុខនៃការរាតត្បាតជំងឺដោយធ្វើការងារជាមួយសហគមន៍ដោយផ្ទាល់ហើយជាញឹកញាប់ទទួលបានប្រាក់ឈ្នួលទាបជាងបុរស។ ឧទាហរណ៍ ក្នុងប្រទេសឥណ្ឌា បុគ្គលិកសុខភាពជួរមុខ (បុគ្គលិកផ្នែក ASHAs និង Anganwadi) ដែលត្រូវបានផ្តល់ជូនតែប្រាក់សាគុណប៉ុណ្ណោះ និងសូម្បីតែត្រូវបានគេបដិសេធផ្តល់ជូនប្រាក់ឈ្នួលអប្បបរមាទៀតផងនោះបានចូលរួមខ្លាំងបំផុតក្នុងការធ្វើដំណើរទៅកាន់សហគមន៍ដោយបានធ្វើតេស្តនិងតាមដានទំនាក់ទំនងរបស់អ្នកជំងឺ។

អ្នកថែទាំដែលជាមេផ្ទះក៏ប្រឈមខ្លាំងផងដែរទៅនឹងការឆ្លងជំងឺ។សូម្បីតែក្នុងអំឡុងពេលកើតមានការរាតត្បាតជំងឺផ្តាសាយអេស្ប៉ាញក្នុងឆ្នាំ១៩១៨ ក៏ដោយ ក៏ស្ត្រីជាច្រើនក្នុងប្រទេសឥណ្ឌាដែលខ្វះអាហារូបត្ថម្ភ រស់នៅក្នុងទីជម្រកដែលគ្មានអនាម័យ និងគ្មានខ្យល់ចេញចូលល្អ និងថែទាំអ្នកមានជំងឺ បានស្លាប់ច្រើនជាងបុរស (មិនមានប្រភពជាក់លាក់)។

ហើយជាចុងក្រោយគឺភាពមិនប្រក្រតីខាងផ្នែកគ្រប់គ្រងវិបត្តិ៖ យុទ្ធសាស្ត្រគន្លឹះដើម្បីដោះស្រាយវិបត្តិគឺជាការដាក់ចេញវិធានការបិទខ្ទប់។ កត្តានេះបានបង្កឱ្យស្ត្រីទទួលរងគ្រោះខ្លាំងជាងបុរស ជាចម្បងដោយសារការពិតដែលថា៖

> អំពើហិង្សាក្នុងគ្រួសារ អំពើហិង្សាផ្លូវភេទ និងអំពើហិង្សាទាក់ទងនឹងយេនឌ័របានកើនឡើងស្ថិតក្រោមស្ថានភាពធ្វើចត្តាឡីស័ក ឬវិធានការស្នាក់នៅតែក្នុងផ្ទះ។ ស្ត្រី និងកូនៗដែលរស់នៅជាមួយនឹងអំពើហិង្សា និងបុរសដែលមានអំណាចគ្រប់គ្រង ប្រឈមនឹងគ្រោះថ្នាក់កាន់តែខ្លាំងឡើង។ និន្នាការទាំងនេះត្រូវបានគេមើលឃើញនៅទូទាំងពិភពលោក ព្រមទាំងនៅក្នុងប្រទេសក្នុងតំបន់

អាស៊ីផងដែរដូចជាប្រទេសឥណ្ឌា (មិនមានប្រភពជាក់លាក់) និងកម្ពុជា (មិនមានប្រភពជាក់លាក់) ជាដើម។ កុមារា និងកុមារីវ័យក្មេងក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិកបានទទួលរងផលប៉ះពាល់ខ្លាំង (មិនមានប្រភពជាក់លាក់)។ហើយកត្តានេះត្រូវបានគេរំពឹងថាកើតមាននៅក្នុងការរាតត្បាតជំងឺកន្លងមក ដូចជាការផ្ទុះជំងឺវីរុសអេបូឡានៅតំបន់អាហ្វ្រិកខាងលិចជាដើម ហើយក៏កើតមានផងដែរក្នុងការផ្ទុះជំងឺវីរុសស៊ីកា ដែលឈានទៅដល់កម្រិតថ្នាក់តំបន់ ជាទីដែលអំពើហិង្សាក្នុងគ្រួសារបានកើតមានកាន់តែខ្លាំង (មិនមានប្រភពជាក់លាក់)។ ទោះជាយ៉ាងណា វិធានការដើម្បីដោះស្រាយបញ្ហាទាំងនេះមិនសូម្បីតែត្រូវបានលើកយកមកពិចារណា ឬពិភាក្សា។

> ស្ត្រីក៏ត្រូវបានគេទុកចោលឱ្យប្រឈមនឹងវិបត្តិសេដ្ឋកិច្ចផងដែរ។គម្លាតយេនឌ័រក្នុងប្រាក់ឈ្នួលដែលមានស្រាប់រួចទៅហើយនោះការប្រមូលផ្តុំកាន់តែច្រើននៅក្នុងវិស័យក្រៅប្រព័ន្ធ។ល។ អាចមានន័យថា ស្ត្រីអាចបាត់បង់ប្រភពប្រាក់ចំណូលដែលមានស្រាប់របស់ពួកគេ។ ក៏មានភស្តុតាងបង្ហាញផងដែរថា ស្ត្រីជាញឹកញាប់ទទួលរងឥទ្ធិពលយ៉ាងខ្លាំងពីការកាត់បន្ថយ និងជម្រុះបុគ្គល (មិនមានប្រភពជាក់លាក់)។

> សេចក្តីរាយការណ៍របស់ប្រព័ន្ធផ្សព្វផ្សាយនៅខែឧសភា ឆ្នាំ២០២០ បានបង្ហាញថា នៅទូទាំងសហរដ្ឋអាមេរិក ការចំណាយលើការងាររបស់ស្ត្រីមើលឃើញយ៉ាងច្បាស់រួចទៅហើយ។ តួលេខគ្មានការងារធ្វើចុងក្រោយបំផុតបង្ហាញថា ស្ត្រីមានកាន់កាប់ ៥៥% នៃការងារចំនួន២០,៥លានកន្លែងកាលពីខែមុន។ចំណែកនៃការទាមទារអត្ថប្រយោជន៍ពីភាពគ្មានការងារធ្វើរបស់ស្ត្រីដែលបានដាក់ចូលនៅចន្លោះ ខែមីនា ដល់ ថ្ងៃទី១១ ខែមេសា មានចាប់ពី ៥៣% ក្នុងរដ្ឋវ៉ាយអូមីងរហូតដល់ ៦៧% នៅរដ្ឋអាឡាបាម៉ា នេះបើយោងតាមអង្គការ TheFullerProjectដែលជាអង្គការសារព័ត៌មានមិនស្វែងរកប្រាក់ចំណេញ។ដូចគ្នានេះដែរនៅក្នុងប្រទេសកាណាដា ស្ត្រីមានចំណែកដ៏ច្រើននៃការជម្រុះបុគ្គលិក (មិនមានប្រភពជាក់លាក់)។

> ការបិទខ្ទប់ក៏បានបង្កើនបន្ទុកការងាររបស់ស្ត្រី និងកុមារីនៅផ្ទះផងដែរ ដោយសារនៅក្នុងសង្គមភាគច្រើន បើតាមប្រពៃណី ស្ត្រីទទួលខុសត្រូវលើការងារក្នុងផ្ទះដែលចំណាយពេលច្រើនជាងបីដងធៀបនឹងបុរស។ការបិទខ្ទប់ក្នុងប្រទេសជាច្រើនមានន័យថាជាការបិទសេវាក្នុងស្រុកទាំងអស់ ដែលមានទំនាក់ទំនងទៅនឹងផ្សារ ដូចជាភោជនីយដ្ឋាន និងការផ្គត់ផ្គង់អាហារ បោកអ៊ុត សូម្បីតែសេវាគាំទ្រការអប់រំអនឡាញរបស់កុមារ។ ដូច្នេះ បន្ទុកសកម្មភាពទាំងអស់នេះបានធ្លាក់ទៅលើស្ត្រីដែលបង្កើនតួនាទីថែទាំរបស់ពួកគេថែមទៀត (មិនមានប្រភពជាក់លាក់)។

ការផ្តល់សេវាសុខភាពផ្លូវភេទ និងបន្តពូជ រួមទាំងសេវាសុខភាពមាតុភាព និងសេវាដែលពាក់ព័ន្ធនឹងអំពើហិង្សាទាក់ទងនឹងយេនឌ័រ មានសារៈសំខាន់ចំពោះ សុខភាព សិទ្ធិ និងសុខុមាលភាពរបស់ស្ត្រីនិងកុមារី។ ការបង្វែងរការយកចិត្តទុកដាក់ និងធនធានសំខាន់ៗចេញពីការផ្តល់ទាំងនេះអាចបង្កឱ្យមរណភាព និងព្យាធិភាពមាតាមានភាពធ្ងន់ធ្ងរឡើង បង្កើនអត្រាមានផ្ទៃពោះរបស់ក្មេងជំទង់ ជំងឺអេដស៍និងជំងឺកាមរោគ (មិនមានប្រភពជាក់លាក់)។

**លទ្ធផល**

ការរាតត្បាតជំងឺនេះ កំពុងបង្កឱ្យវិសមភាពដែលមានពីមុនមកកាន់តែមានភាពធ្ងន់ធ្ងរឡើង ដែលបង្កឱ្យមានភាពងាយរងគ្រោះក្នុងប្រព័ន្ធសង្គម នយោបាយ និងសេដ្ឋកិច្ច ដែលបន្ទាប់មកធ្វើឱ្យផលប៉ះពាល់នៃការរាតត្បាតជំងឺកាន់តែមានសភាពខ្លាំងឡើង។ ការរាតត្បាតជំងឺក៏នឹងដាក់ការសម្រេចបាននៃរបៀបវារៈឆ្នាំ២០៣០ ឱ្យស្ថិតក្នុងហានិភ័យផងដែរ ជាពិសេសសម្រាប់ស្ត្រី និងកុមារី។ (មិនមានប្រភពជាក់លាក់)

## ភាពងាយរងគ្រោះទាក់ទងនឹងយេនឌ័រ

ការប្រែប្រួលអាកាសធាតុ មិនត្រឹមតែត្រូវបានព្យាករថានឹងបង្កើនការចំណាយចំពោះសុខភាពមនុស្ស (IPCC AR៥ ឆ្នាំ២០១៥) តាមរយៈឥទ្ធិពលផ្ទាល់នៃហេតុការណ៍ដែលកើតមានខ្លាំងក្លានានាដូចជា រលកកម្តៅ ទឹកជំនន់ និងខ្យល់ព្យុះប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងតាមរយៈផ្លូវដ៏ស្មុគស្មាញកាន់តែច្រើនឡើងនៃគំរូជំងឺឆ្លងដែលផ្លាស់ប្តូរនិងឥទ្ធិពលអវិជ្ជមានលើសន្តិសុខស្បៀង និងសន្តិសុខអាហារូបត្ថម្ភ និងកង្វះខាតទឹកក្នុងចំណោមបញ្ហាផ្សេងទៀត។

ជាអកុសលបើទោះជាមានភស្តុតាងមួយចំនួនបង្ហាញថាផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុចំពោះសុខភាព មានភាពខុសគ្នាទៅតាមយេនឌ័រក្តី ក៏អង្គការសុខភាពពិភពលោក (មិនមានប្រភពជាក់លាក់) បានទទួលស្គាល់ថា ការស្រាវជ្រាវនៅមានកម្រិតនៅឡើយអំពីវិសាលភាពសុខភាព និង CCDRR ផ្អែកលើយេនឌ័រ។ ផលប៉ះពាល់សុខភាពសំខាន់ៗលើស្ត្រី ដែលត្រូវបានព្យាករដោយឈរលើមូលដ្ឋានការសិក្សាដែលអាចរកបាន នានានៅក្នុងតំបន់ដែលត្រូវបានជ្រើសរើស បង្ហាញថា៖

> ការប្រែប្រួលអាកាសធាតុកំពុងបង្កើនហានិភ័យនៃផលប៉ះពាល់សុខភាព ដែលពាក់ព័ន្ធនឹងហេតុការណ៍ខ្យល់ព្យុះ និងទឹកជំនន់ ដោយមានភស្តុតាងបង្ហាញថា អត្រាមរណភាពសម្រាប់ស្ត្រី និងកុមារីក្នុងអំឡុងពេលមានហេតុការណ៍ទាំងនេះ មានខ្ពស់ជាងបុរស និងកុមារា (UN Women ឆ្នាម២០១៦)។ ភាគច្រើនការស្លាប់នេះគឺដោយសារការប្រតិបត្តិវប្បធម៌ផ្អែកតាមយេនឌ័រ ដែលពាក់ព័ន្ធនឹងស្បៀបិទមុខ ការរឹតបន្តឹងការធ្វើដំណើរការ ការស្លៀកពាក់មិនសមរម្យ ខ្វះជំនាញហែលទឹកការទទួលបានប្រព័ន្ធប្រកាសអាសន្ននៅមានកម្រិត។ល។

> លើសពីនេះទៀត ខណៈដែលការសិក្សានៅសហរដ្ឋអាមេរិក និងប្រទេសអូស្ត្រាលីមិនបានបង្ហាញពីភាពខុសគ្នានៃយេនឌ័រសំខាន់ៗ (មិនមានប្រភពជាក់លាក់) ការសិក្សាដែលអាចរកបានពីប្រទេសក្នុងតំបន់អាស៊ីបង្ហាញផ្សេងពីនេះ។ ឧទាហរណ៍ អត្រាស្លាប់ក្នុងចំណោមស្ត្រី (ទំនងជាមានការពាក់ព័ន្ធនឹងកម្តៅ) នៅ Ahmedabad (ប្រទេសឥណ្ឌា) ក្នុងអំឡុងរលកកម្តៅឆ្នាំ២០១០ មានកម្រិតខ្ពស់ខ្លាំងជាងសម្រាប់បុរស (មិនមានប្រភពជាក់លាក់)។ ដូចគ្នានេះដែរ ការស្រាវជ្រាវពីប្រទេសកូរ៉េបង្ហាញថា ស្ត្រីស្ថិតក្នុងហានិភ័យ (១៦%)មរណភាពខ្លាំងជាងក្នុងអំឡុងរលកកម្តៅនៅចន្លោះពីឆ្នាំ២០០០ ដល់ឆ្នាំ២០០៧ ខណៈដែលហានិភ័យមរណភាពដែលកើនឡើងរបស់បុរសមានស្ថិតិផ្សេងៗគ្នារាប់ចាប់ពីសូន្យឡើងទៅ (មិនមានប្រភពជាក់លាក់)។ បើទោះជាភាពខុសគ្នាផ្នែកសរីរៈរវាងបុរស និងស្ត្រីនៅក្នុងសមត្ថភាពគ្រប់គ្រងសីតុណ្ហភាពខ្ពស់ យ៉ាងហោចណាស់ទទួលខុសត្រូវមួយផ្នែកលើភាពខុសគ្នានៃយេនឌ័រនៅក្នុងមរណភាពពាក់ព័ន្ធនឹងកម្តៅក្តី (មិនមានប្រភពជាក់លាក់) ក៏និន្នាការភាគច្រើនបង្ហាញថា ការរស់នៅផ្អែកលើយេនឌ័រ និងគំរូរបរចិញ្ចឹមជីវិត ការទទួលបានការព្យាបាលផ្នែកវិជ្ជសាស្ត្រ និងកត្តាអាកាសធាតុក្នុងមូលដ្ឋានទំនងជាសំខាន់ជាងភាពខុសគ្នាផ្នែកជីវសាស្ត្រ។

> ការប្រែប្រួលអាកាសធាតុកំពុងបង្កើនការរីករាលដាលជំងឺឆ្លងតាមទឹក និងជំងឺឆ្លងតាមភ្នាក់ងារចម្លងនៅជុំវិញពិភពលោក (មិនមានប្រភពជាក់លាក់) ដូចជាជំងឺអាសន្នរោគ ជំងឺគ្រុនឈាម ជំងឺគ្រុនចាញ់ និងជំងឺស៊ីស្តូសូមីញ៉ាស៊ីស ដែលមាននិន្នាការដាក់បន្ទុកយ៉ាងខ្លាំងដល់អ្នកក្រកាន់តែខ្លាំងឡើងថែមទៀត ជាពិសេសនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍។ មានការប៉ាន់ប្រមាណថា គ្រាន់តែនៅក្នុងឆ្នាំ២០០០ ការប្រែប្រួលអាកាសធាតុទទួលខុសត្រូវ ២,៤% នៃករណីជំងឺរាករូសនៅទូទាំងពិភពលោក និង ៦% នៃករណីជំងឺគ្រុនចាញ់ (មិនមានប្រភពជាក់លាក់)។ ការវិភាគបែងចែកតាមភេទអំពីបន្ទុកដោយសារជំងឺ បង្ហាញថា បុរសអាចមានភាពងាយរងគ្រោះទៅនឹងជំងឺគ្រុនឈាមជាងស្ត្រីខណៈដែលស្ត្រីជាពិសេសស្ត្រីមានផ្ទៃពោះមានភាពងាយរងគ្រោះខ្លាំងជាងទៅនឹងជំងឺគ្រុនចាញ់ (មិនមានប្រភពជាក់លាក់)។ ជំងឺអាសន្នរោគអាចប្រហែលជះឥទ្ធិពលលើបុរសនិងស្ត្រីស្មើគ្នានៅក្នុងបរិស្ថានជាច្រើន ខណៈដែលការសិក្សាមួយចំនួនបង្ហាញពីការមានខ្ពស់ជាងបន្តិចបន្តួចនៃបន្ទុកដោយសារជំងឺក្នុងចំណោមបុរស និងបន្ទុកផ្សេងទៀតក្នុងចំណោមស្ត្រី (មិនមានប្រភពជាក់លាក់)។

> ទោះជាយ៉ាងណា ការឆ្លងបាក់តេរី និងវីរុសដែលពាក់ព័ន្ធនឹងការប្រឈមទៅនឹងទឹកជំនន់ដែលមានមេរោគ ហាក់ដូចជាជះឥទ្ធិពលដល់ស្ត្រីខ្លាំងជាង។ ភស្តុតាងពីប្រទេសបង់ក្លាដេសបង្ហាញថា ស្ត្រីអាចប្រឈមខ្លាំងទៅនឹងបញ្ហាស្បែកដែលពាក់ព័ន្ធនឹងការប្រឈមទៅនឹងទឹកជំនន់(មិនមានប្រភពជាក់លាក់)។ ខណៈដែលការសិក្សាផ្លូវការនានាមិនអាចរកបាន ការបំពុលដោយជាតិអំបិលដែលត្រូវបានរំពឹងថានឹងកើនឡើងដោយសារការប្រែប្រួលអាកាសធាតុនិងការកើនឡើងកម្រិតទឹកសមុទ្រត្រូវបានបង្ហាញថានឹងប៉ះពាល់ដល់ស្ត្រីមានផ្ទៃពោះក្នុងចំនួនដ៏ច្រើនក្នុងប្រទេសបង់ក្លាដែសដែលប្រឈមនឹងការកើតជំងឺបម្រុងក្រឡាភ្លើង ជំងឺក្រឡាភ្លើង និងជំងឺលើសឈាម (មិនមានប្រភពជាក់លាក់)។ បុគ្គលិកថែទាំសុខភាព ក្នុងមូលដ្ឋានបានរាយការណ៍ថាមានការកើនឡើងនិន្នាការបញ្ហាជំងឺរោគស្ត្រី ដោយសារការប្រើប្រាស់ទឹកដែលគ្មានអនាម័យ និងការដាំទឹក (មិនមានប្រភពជាក់លាក់)។

> ការប្រែប្រួលអាកាសធាតុក៏មានផលប៉ះពាល់ផ្អែកលើយេនឌ័រផងដែរ ដែលប៉ះពាល់លើសុខភាពផ្លូវចិត្ត ការកើតស្ត្រេសបន្ថែម ជាពិសេសនៅក្រោយគ្រោះមហន្តរាយ ដែលជាញឹកញាប់ឈានទៅរកការកើតមានជំងឺធ្លាក់ទឹកចិត្ត និងករណីធ្វើអត្តឃាតធ្ងន់ធ្ងរ។ ទោះជាយ៉ាងណា ខណៈដែលទាំងបុរស និងស្ត្រីមានទំនោរជួបប្រទះបញ្ហាប្រឈមជំងឺផ្លូវចិត្តក្នុងអត្រា

កាន់តែខ្ពស់បន្ទាប់ពីគ្រោះមហន្តរាយ ស្ត្រីជាទូទៅមានភាពងាយរងគ្រោះខ្លាំងជាងទៅនឹងការវិវត្តជំងឺដែលពាក់ព័ន្ធនឹងស្ត្រេស និងជំងឺធ្លាក់ទឹកចិត្ត (មិនមានប្រភពជាក់លាក់)។

• ការសិក្សាធំមួយបន្ទាប់ពីទឹកជំនន់នៅក្នុងខេត្តហ៊ូណាន ប្រទេសចិនបានរកឃើញថាស្ត្រីមានហានិភ័យនៃការកើតមានជំងឺបាក់ស្បាត (PTSD) ច្រើនជាងបុរស ១,២ដង(មិនមានប្រភពជាក់លាក់)។ ការសិក្សាមួយផ្សេងទៀត(មិនមានប្រភពជាក់លាក់)បានរកឃើញថាភាពអាចកើតមានជំងឺបាក់ស្បាតរបស់កុមារីក៏មានច្រើនជាងតិចតួចផងដែរធៀបនឹងកុមារា។ បន្ទាប់ពីកើតមានព្យុះស៊ីក្លូន Nargis ក្នុងប្រទេសមីយ៉ាន់ម៉ា ភាពអាចកើតមានជំងឺបាក់ស្បាតរបស់ស្ត្រីមានខ្ពស់ជាងបុរស ៣,២ដង (មិនមានប្រភពជាក់លាក់)។ ក្នុងប្រទេសនេប៉ាល់ មជ្ឈមណ្ឌលស្តារនីតិសម្បទាស្ត្រី (WOREC) បានរាយការណ៍ថាស្ត្រីដែលផ្លាស់ប្តូរទីជម្រកក្នុងអំឡុងពេលមានទឹកជំនន់ក្នុងស្រុក Dang នៅឆ្នាំ២០១៤ បានជួបប្រទះការប៉ះទង្គិចផ្លូវចិត្ត ហើយកត្តានេះបានបង្កឱ្យពួកគេទទួលរងគ្រោះពីវដ្តរដូវមិនទៀងទាត់ និងការឈឺចុកចាប់ក្នុងពោះ (Singh ឆ្នាំ ២០១៥)។

• ខណៈដែលការសិក្សាអំពីហានិភ័យនៃការធ្វើអត្តឃាតមិនមានភាពច្បាស់លាស់ មានភស្តុតាដែលបង្ហាញថា បុរសទំនងជាធ្វើអត្តឃាតច្រើនជាង។ ឧទាហរណ៍ ក្នុងប្រទេសឥណ្ឌា ការប្រែប្រួលអាកាសធាតុ កំពុងបង្កើនហានិភ័យដល់កសិករដែលមានផ្ទៃដីតូចនៅលើដីដែលស្ទើតែគ្មានតម្លៃកសិកម្ម(ភាគច្រើនគឺបុរស)ដែលងាយរងគ្រោះកាន់តែខ្លាំងទៅនឹងការបរាជ័យក្នុងការដាំដុះដំណាំដោយសារមានលទ្ធភាពតិចតួចក្នុងការកាន់កាប់ភាពជម្រុះនៃដំណាំ ដែលក្រោយមកមានការពាក់ព័ន្ធនឹងការកើនឡើងអត្រាធ្វើអត្តឃាត(Kenedy និង King ឆ្នាំ២០១៤)។

---

កង្វះការទទួលបានសេវាថែទាំសុខភាពដែលមានតម្លៃសមរម្យជាពិសេសការថែទាំងសុខភាពផ្លូវភេទនិងបន្តពូជធ្វើឲ្យមានបញ្ហាកាន់តែធ្ងន់ធ្ងរថែមទៀត។របាំងរារាំងការទទួលបានសេវាទាំងនេះអាចរួមមានទាំងកង្វះពេលវេលាដោយសារម៉ោងធ្វើការវែង ម៉ោងរង់ចាំយូរនៅមណ្ឌលសុខភាពសាធារណៈ ថ្លៃដឹកជញ្ជូន និងកង្វះអំណាចធ្វើសេចក្តីសម្រេចចិត្តដោយសារវិសមភាពយេនឌ័រ។ ឯកជនភាវូនីយកម្មសេវាថែទាំសុខភាព ក៏បានបង្កឱ្យសេវាទាំងនេះមានតម្លៃថ្លៃផងដែរ។លើសពីនេះទៀត សុខភាពផ្លូវភេទ និងបន្តពូជ ជាញឹកញាប់មិនត្រូវបានកំណត់អាទិភាពក្នុងរបៀបវា រៈទីក្រុងថ្មី (NUA) និងការកើនឡើងនៃការប្រែប្រួល អាកាសធាតុ និងធ្វើឲ្យស្ថានភាពកាន់តែអាក្រក់ដល់ស្ត្រី និងកុមារីក្រីក្រនៅតំបន់ទីក្រុង (មិនមាន ប្រភពជាក់លាក់)

ការសិក្សាមួយដោយមូលនិធិ Arrow and Khan ក្នុងប្រទេសបង់ក្លាដែស (ឆ្នាំ២០១៥) បានបង្ហាញថា៖

> ជិត ៩០% នៃអ្នកឆ្លើយតបឆ្លើយថា ការថែទាំនិងសេវាវេជ្ជសាស្ត្រ/មណ្ឌលព្យាបាល មិនអាចរកបានឡើយសម្រាប់ស្ត្រី។

> អ្នកឆ្លើយតបប្រហែលជា ២ភាគ៥ បានលើកឡើងពីអវត្តមានវេជ្ជបណ្ឌិតសង្គ្រោះបន្ទាន់ថាជាបញ្ហាសំខាន់ ខណៈដែលអ្នកឆ្លើយតប ២ភាគ៥ផ្សេងទៀតបានលើកឡើងពីកង្វះថ្នាំចាំបាច់ ផលិតផលអនាម័យបរិស្ថាន និងអនាម័យផ្ទាល់ខ្លួន ហើយ ១ភាគ៥ បានលើកឡើងពីកង្វះការសង្គ្រោះបន្ទាន់ និងឧបករណ៍សម្រាលកូនថាជាបញ្ហាចម្បង។

បញ្ហាទាំងអស់ខាងលើនេះមានផលវិបាកអវិជ្ជមានទៅលើសិទ្ធិទទួលបានការថែទាំសុខភាពផ្លូវភេទនិងបន្តពូជរបស់ស្ត្រីនិងកុមារីជាពិសេសក្នុងអំឡុងពេលមានគ្រោះមហន្តរាយ។ ដូចដែលអ្នកស្រី Mahmuda Begum ដែលជាស្ត្រីមេផ្ទះអាយុ ៣៥ឆ្នាំ និងជាម្តាយម្នាក់ដែលមានកូន ៧នាក់មកពីភូមិ Fakirghona ឃុំ Moheshkhali បានលើកឡើងថា ៖ ក្នុងអំឡុងពេលមានគ្រោះមហន្តរាយ បញ្ហាធំបំផុតដែលស្ត្រីប្រឈមនៅក្នុងសហគមន៍របស់យើងគឺកង្វះការទទួលបានការថែទាំផ្នែកវេជ្ជសាស្ត្រ រួមទាំងសេវានិងមណ្ឌលសុខភាព˝

---

> ការប្រែប្រួលអាកាសធាតុក៏គំរាមកំហែងផងដែរដល់លទ្ធភាពរបស់ស្ត្រីក្នុងការទទួលបានសេវារៀបចំផែនការគ្រួសារ ដែលបង្កឱ្យមានការលំបាកកាន់តែខ្លាំងសម្រាប់ស្ត្រីក្នុងការជ្រើសរើសថាតើ នៅពេលណាដែលពួកគេត្រូវយកកូន។ ខណៈដែលទិន្នន័យមកពីតំបន់អាស៊ីមិនអាចរកបាន ការសិក្សានានានៅតំបន់ផ្សេងទៀតបានបង្ហាញថាគ្រោះមហន្តរាយធម្មជាតិដែលពាក់ព័ន្ធនឹងអាកាសធាតុទំនងជានឹងដាក់បន្ទុកដល់ការទទួលបានការថែទាំសុខភាពបន្តពូជ ដូចដែលបានកើតមានឡើងបន្ទាប់ពីព្យុះទីហ្វុង Hayian និងព្យុះសង្ឃរា Katrina។ លើសពីនេះទៀតផលប៉ះពាល់នៃគ្រោះមហន្តរាយអាចធ្វើឱ្យកាន់តែកើតមានធ្ងន់ធ្ងរឡើងនូវឥទ្ធិពលនៃរបាំងដែលមានស្រាប់ ដូចជាជាតិសាសន៍ និងថ្នាក់ ដែលស្ត្រីជួបប្រទះចំពោះការស្វែងរកសេវាសុខភាពបន្តពូជដូចដែលបានឃើញបន្ទាប់ពីកើតមានព្យុះសង្ឃរា (GGCA ឆ្នាំ២០១៦)។

> ការប្រែប្រួលអាកាសធាតុក៏ទំនងជានឹងបង្កផលប៉ះពាល់ដល់លទ្ធផល និងការថែទាំផ្ទៃពោះផងដែរ។ ស្ត្រីមានផ្ទៃពោះមានភាពប្រឈមកាន់តែខ្លាំងទៅនឹងជំងឺគ្រុនឈាម (Machado et al ឆ្នាំ២០១៣) និងជំងឺគ្រុនចាញ់ (Khan et al ឆ្នាំ ២០១៤)។ ការស្រាវជ្រាវផ្សេងៗ បានភ្ជាប់រលកកម្តៅ (He ឆ្នាំ ២០១៦) និងហេតុការណ៍ទឹកជំនន់/ខ្យល់ព្យុះ (Currie និង Rossin-Slater ឆ្នាំ២០១៣) ទៅនឹងការកើនឡើងហានិភ័យនៃការសម្រាលកូនមិនគ្រប់ខែនិងផលវិបាកទាក់ទងនឹងការមានផ្ទៃពោះ។ ការជ្រាបចូលទឹកប្រៃទៅក្នុងទឹកក្រោមដី ដែលទំនងជាខ្លាំងដោយសារកំណើនកម្រិតទឹកសមុទ្រ និង

ដែលពាក់ព័ន្ធនឹងទឹកជំនន់ ក៏អាចបង្កើនអត្រានៃការកើតជំងឺបម្រុងក្រឡាភ្លើង និងជំងឺលើសឈាមផងដែរក្នុងអំឡុងពេលមានផ្ទៃពោះ (មិនមានប្រភពជាក់លាក់) (Khan et al ឆ្នាំ២០១១)។ ខណៈដែលកត្តាទាំងនេះចង្អុលទៅកាន់វិសាលភាពបន្ថែមទៀតនៃភាពងាយរងគ្រោះសម្រាប់ស្ត្រីមានផ្ទៃពោះ ទាក់ទងនឹងការប្រែប្រួលអាកាសធាតុ ដូច្នេះវាមានសារៈសំខាន់ដែលត្រូវធ្វើសមាហរណកម្មការរៀបចំផែនការគ្រួសារ និងសេវាសុខភាពបន្តពូជ និងផ្លូវភេទទៅក្នុងកម្មវិធីបន្សាំ និងគ្រប់គ្រងគ្រោះមហន្តរាយទាំងអស់។

- ការកើនឡើងបន្ទុកដោយសារជំងឺដែលបង្កឡើងដោយការប្រែប្រួលអាកាសធាតុក៏នឹងជះឥទ្ធិពលដល់តួនាទីថែទាំរបស់ស្ត្រី និងកុមារីផងដែរ ដោយសារពួកគេត្រូវតែថែទាំអ្នកជំងឺនៅក្នុងផ្ទះរបស់ពួកគេ (Brody A ឆ្នាំ២០០៨)។ កត្តានេះបង្កើនបន្ទុកការងារហើយជាញឹកញាប់ព្រងើយកន្តើយទៅនឹងសុខភាព និងសុខុមាលភាពផ្ទាល់របស់ខ្លួនឯង។ កត្តានេះក៏ដាក់កម្រិតដល់ពេលវេលាដែលពួកគេមានសម្រាប់ការបង្កើតប្រាក់ចំណូល និងការអប់រំផងដែរ ពោលគឺនៅពេលដែលមានការគួបផ្សំជាមួយនឹងការកើនឡើងការចំណាយលើវេជ្ជសាស្ត្រពេលមានជំងឺក្នុងគ្រួសារកើនឡើងកម្រិតនៃភាពក្រីក្រដែលជាកត្តាកំណត់ដ៏មានអំណាចចំពោះសុខភាព។វាក៏មានន័យផងដែរថាពួកគេមានពេលវេលាតិចជាងមុនក្នុងការចូលរួមចំណែកដល់ដំណើរការធ្វើសេចក្ដីសម្រេចចិត្តថ្នាក់សហគមន៍ រួមទាំងដំណើរការធ្វើសេចក្ដីសម្រេចចិត្តអំពីការប្រែប្រួលអាកាសធាតុ សុខភាព និងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ។
- ការប្រែប្រួលអាកាសធាតុក៏ត្រូវបានរំពឹងផងដែរថានឹងបង្កើនកង្វះទឹកដែលជំរុញឱ្យគ្រួសារជាច្រើនប្រើប្រាស់ប្រភពទឹកគ្មានសុវត្ថិភាព រួមទាំងអូរ និងត្រពាំង ដែលទំនងជាមានមេរោគ។ កត្តានេះនឹងមិនត្រឹមតែនាំទៅរកការកើនឡើងជំងឺដែលពាក់ព័ន្ធនឹងទឹកដូចជាជំងឺរាករុះ និងជំងឺអាសន្នរោគប៉ុណ្ណោះទេ ប៉ុន្តែថែមទាំជះឥទ្ធិពលដល់ស្ត្រីខ្លាំងជាងបុរស តាមរយៈការកើនឡើងបន្ទុកការងាររបស់ពួកគេ។ ឧទាហរណ៍ នៅក្នុងការសិក្សាមួយអំពីការគ្រប់គ្រងភាពរាំងស្ងួតនៅខេត្ត Ninh Thuan (ប្រទេសវៀតណាម) ៧៤% នៃអ្នកឆ្លើយតបបានជឿថា ស្ត្រីបានទទួលរងប៉ះពាល់ខ្លាំងជាងពីភាពរាំងស្ងួតដោយសារកង្វះទឹកដែលបានបង្ខំឱ្យពួកគេដើរក្នុងរយៈចម្ងាយឆ្ងាយ។ ក៏មានការសិក្សាផ្សេងទៀតផងដែរ ដែលបង្ហាញថា នៅទីជនបទក្នុងប្រទេសឥណ្ឌា ក្នុងអំឡុងរដូវប្រាំង ៣០% ឬខ្ពស់ជាងនេះនៃការប្រើប្រាស់កម្លាំងប្រចាំថ្ងៃរបស់ស្ត្រី ត្រូវបានចំណាយលើការដងទឹក។ការរែកឬយួររបស់ធ្ងន់ក្នុងរយៈពេលយូរ បង្កឱ្យប៉ះពាល់បន្តិចម្ដងៗដល់ជឹងឆ្អឹងខ្នង សាច់ដុំក និងខ្នងផ្នែកខាងក្រោមដូច្នេះឈានទៅរកការបង្កឱ្យឆ្អឹងខ្នងចាស់មុនអាយុ (WHO ឆ្នាំ២០១០)។
- ការខូចខាតបបនីយកណ្ឌអនាម័យបរិស្ថាន និងកង្វះទឹក ជាពិសេសបង្គន់និងបន្ទប់ទឹកដែលមិនមានទឹកម៉ាស៊ីនក៏រឹតបន្តឹងដល់ការអនុវត្តអនាម័យរដូវក្នុងចំណោមស្ត្រីនិងកុមារីផងដែរ។ វិធីធម្មតាសម្រាប់ពួកគេក្នុងការដោះស្រាយបញ្ហានេះគឺការមិនផឹកទឹកដើម្បីចៀសវាងការទៅបន្ទប់ទឹកនៅពេលថ្ងៃដូច្នេះបង្កឱ្យជំងឺរលាកតម្រងនោម និងជំងឺផ្លូវបន្តពូជកាន់តែមានភាពធ្ងន់ធ្ងរឡើង។ ដូចគ្នានេះដែរ កង្វះទឹក និងបបនីយកណ្ឌបន្ទប់ទឹកនៅសាលារៀនចូលរួមចំណែកដល់វត្តមានក្នុងចំណោមកុមារី ហើយកត្តានេះប៉ះពាល់ដល់ការអប់រំរបស់ពួកគេ (មិនមានប្រភពជាក់លាក់)។
- ការប្រែប្រួលអាកាសធាតុក៏គំរាមកំហែងផងដែរដល់ផលិតកម្មដំណាំទាក់ទងនឹងការធ្លាក់ចុះគុណភាព និងបរិមាណដំណាំស្បៀង ដែលបង្កឱ្យមានអសន្តិសុខស្បៀង និងកង្វះអាហារូបត្ថម្ភ។ ការខូចខាតដំណាំនឹងបង្កឱ្យមានការឡើងថ្លៃតម្លៃស្បៀង និងការកើនឡើងដោយប្រយោលនូវការចំណាយលើការរស់នៅ។ កត្តានេះជាចុងក្រោយនឹងប៉ះពាល់ដល់ការបរិភោគអាហាររបស់ស្ត្រី មិនត្រឹមតែដោយសារភាពក្រីក្រប៉ុណ្ណោះទេ ប៉ុន្តែដោយសារឋានានុក្រមបរិភោគអាហារក្នុងគ្រួសារ ដែលនៅតែអនុវត្តក្នុងវប្បធម៌មួយចំនួនក្នុងតំបន់អាស៊ី ជាទីដែលស្ត្រី និងកុមារីត្រូវបានអនុញ្ញាតឱ្យបរិភោគអាហារបន្ទាប់ពីបុរស និងកុមារាបរិភោគរួចហើយ ដែលបង្កឱ្យមានកង្វះអាហារូបត្ថម្ភខ្ពស់ និងបញ្ហាសុខភាពដែលពាក់ព័ន្ធនឹងកង្វះអាហារូបត្ថម្ភ។
- កង្វះអាហារូបត្ថម្ភនឹងមានភាពធ្ងន់ធ្ងរថែមទៀតនៅក្នុងអំឡុងពេលមានហេតុការអាកាសធាតុធ្ងន់ធ្ងរ (Aguilar et al ឆ្នាំ២០១៥)។ បន្ទាប់ពីគ្រោះមហន្តរាយធម្មជាតិក្នុងប្រទេសឥណ្ឌា កុមារីវ័យក្មេងទំនងជានឹងក្រិននិងខ្វះទម្ងន់ជាងកុមារា (មិនមានប្រភពជាក់លាក់)។ ក្នុងការសិក្សាមួយផ្សេងទៀតក្នុងរដ្ឋអាន់ដ្រាប្រាដែស (ប្រទេសឥណ្ឌា) ស្ត្រីក្នុងចំនួនច្រើនរហូតដល់ទៅពីរដងធៀបនឹងបុរស ត្រូវបានរាយការណ៍ថាបរិភោគតិចជាងមុនដោយសារភាពរាំងស្ងួត (មិនមានប្រភពជាក់លាក់)។ការសិក្សាមួយរបស់ប្រទេសបង់ក្លាដែស (មិនមានប្រភពជាក់លាក់) បង្ហាញថា ស្ត្រីនិងកុមារីជាធម្មតាជាមនុស្សដំបូងគេដែលមិនញ៉ាំអាហារប្រសិនបើមានកង្វះអាហារដែលជាញឹកញាប់កើតមានឡើងក្នុងអំឡុងភាពរាំងស្ងួត ទឹកជំនន់ ឬខ្យល់ព្យុះ។ ក្នុងប្រទេសហ្វីលីពីន បន្ទាប់ពីកើតមានព្យុះទីហ្វុងមរណភាពកុមារបានកើនឡើងក្នុងចំណោមកុមារីប៉ុន្តែមិនមែនក្នុងចំណោមកុមារា ដែលអ្នកស្រាវជ្រាវថាមានការពាក់ព័ន្ធនឹងការដណ្ដើមអាហារដែលខ្វះខាតនៅក្នុងគ្រួសារ (មិនមានប្រភពជាក់លាក់)។ ក្នុងប្រទេសវៀតណាម ស្ត្រីទំនងជានឹងមិនបរិភោគអាហារជាងបុរសក្នុងអំឡុងពេលមានកង្វះខាតស្បៀង ដោយសារបទដ្ឋានវប្បធម៌ពាក់ព័ន្ធនឹងសារៈសំខាន់នៃកម្លាំងពលកម្មរាងកាយរបស់បុរស

(មិនមានប្រភពជាក់លាក់)។

> ការសិក្សានានាអំពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុលើកង្វះអាហារូបត្ថម្ភ ក៏បានបង្ហាញផងដែរថា វានឹងបង្កឱ្យមានការកើនឡើងការបាត់បង់ឆ្នាំនៃជីវិតដែលត្រូវបានកែតម្រូវដោយសារពិការភាព (DALY) ក្នុងប្រទេសកំពុងអភិវឌ្ឍន៍។ ស្ត្រីងាយរងគ្រោះខ្លាំងជាងទៅនឹងកង្វះអាហារូបត្ថម្ភធៀបនឹងបុរស ដោយសារលក្ខខណ្ឌតម្រូវអាហារូបត្ថម្ភខុសគ្នារបស់ពួកគេជាពិសេសនៅពេលដែលមានផ្ទៃពោះឬពេលបំបៅកូន។ ឧទាហរណ៍ ក្នុងតំបន់អាស៊ីខាងត្បូង និងអាស៊ីអាគ្នេយ៍ ៤៥% ទៅ ៦០% នៃស្ត្រីស្ថិតក្នុងវ័យបន្តពូជខ្វះទម្ងន់ ហើយ ៨០% នៃស្ត្រីមានផ្ទៃពោះមានកង្វះជាតិដែក។ ដូច្នេះ ពួកគេត្រូវការទទួលទានជាតិដែកបន្ថែមធៀបនឹងបុរស ដោយសារពួកគេប្រឈមកាន់តែខ្លាំងទៅនឹងកង្វះឈាមក្រហម ហើយពួកគេក៏ត្រូវការប្រូតេអ៊ីនបន្ថែមផងដែរ នៅពេលពួកគេមានផ្ទៃពោះ ឬកំពុងបំបៅកូន។ ស្ត្រីមានផ្ទៃពោះ ដែលខ្វះទម្ងន់ស្ថិតក្នុងហានិភ័យខ្ពស់នៃការមានបញ្ហាផ្ទៃពោះនិងបញ្ហាសម្រាលកូនដូចជាកូនក្នុងផ្ទៃលូតលាស់យឺត កូនកើតមុនអាយុ កូនស្លាប់ហើយកើត ទារកដែលមានទម្ងន់ទាបនៅពេលកើត និងមរណភាពក្រោយកើត។ ស្ត្រីខ្វះទម្ងន់អាចរងគ្រោះពីការរាំងរដូវនិងការមិនមានកូនហើយកុមារីមុនគ្រប់ការដែលខ្វះទម្ងន់អាចជួបប្រទះនូវការពន្យាពេលការចាប់ផ្ដើមមានរដូវ (មិនមានប្រភពជាក់លាក់)។

## អំពើហិង្សាទាក់ទងនឹងយេនឌ័រ៖ វិសាលភាពដ៏សំខាន់ក្នុងការប្រែប្រួលអាកាសធាតុ និងការពិចារណាលើសុខភាព

បើទោះជាភស្តុតាងជាក់លាក់នៃផលប៉ះពាល់អាកាសធាតុពាក់ព័ន្ធនឹងគ្រោះមហន្តរាយ និងអំពើហិង្សាទាក់ទងនឹងយេនឌ័រមិនអាចរកបានក្តី ក៏ការសិក្សាមួយចំនួនពីគ្រោះមហន្តរាយផ្សេងទៀត ពិតជាចង្អុលបង្ហាញទៅកាន់ការកើនឡើងអំពើហិង្សាទាក់ទងនឹងយេនឌ័រក្នុងបរិយាកាសក្រោយគ្រោះមហន្តរាយ។ ស្ត្រី និងកុមារីដែលផ្លាស់ប្តូរទីជម្រក ជាញឹកញាប់ត្រូវបានបង្ខំឱ្យដេកក្នុងផ្ទះ និងទីជម្រកដែលគ្មានសុវត្ថិភាព ដែលធ្វើឱ្យពួកគេមានអារម្មណ៍គ្មានសុវត្ថិភាពនិងប្រឈមទៅនឹងការបៀតបៀនផ្លូវភេទ។ ឧទាហរណ៍ បន្ទាប់ពីទឹកជំនន់នៅប្រទេសប៉ាគីស្ថានក្នុងឆ្នាំ២០១០ ស្ត្រីភាគច្រើនបានរាយការណ៍ពីអារម្មណ៍គ្មានសុវត្ថិភាពនៅពេលដេកនៅក្នុងទីកន្លែងចំហរ (UNIFEM ប្រទេសប៉ាគីស្ថាន ឆ្នាំ២០១០)។ ទីជម្រកដែលមិនផ្ដល់ការរៀបចំឱ្យដេកដាច់ពីគ្នារវាងបុរស និងស្ត្រី កន្លែងងូតទឹក និងបោកសម្លៀកបំពាក់ដែលគ្មានភ្លើងបំភ្លឺនិងមិនមានសុវត្ថិភាពដែលសុទ្ធតែអាចបង្កើនហានិភ័យអំពើហិង្សាទាក់ទងនឹងយេនឌ័រសម្រាប់ស្ត្រី និងកុមារី (Hussain ឆ្នាំ២០១៥)។ ស្ត្រី និងកុមារីក៏ប្រឈមនឹងកម្រិតហិង្សាខ្លាំងផងដែរ ប្រសិនបើពួកគេត្រូវធ្វើដំណើរក្នុងរយៈចម្ងាយឆ្ងាយ ដើម្បីទៅយកទឹក រកអុស ឬរកស្បៀងអាហារបន្ទាប់ពីគ្រោះមហន្តរាយ (Nelleman et al ឆ្នាំ២០១១)។

"មនុស្សច្រើនកុះករស្ថានភាពចលាចលកង្វះឯកជនភាពនិងការមិនអាចធ្វើតាមទម្លាប់ជាប្រចាំបាន អាចចូលរួមចំណែកដល់ការបង្កឱ្យមានការខឹងសម្បារ មួម៉ៅ និងអំពើហិង្សា" ដោយកុមារ (ជាពិសេសកុមារី) និងស្ត្រីគឺ ជាបុគ្គលដែលងាយរងគ្រោះបំផុត (Bartlet ឆ្នាំ២០០៨)។ ការកើនឡើងស្ត្រេស និងអារម្មណ៍គ្មានកម្លាំងកំហែង ដោយសារការបាត់បង់អ្វីមួយ ការបង់ទ្រព្យសម្បត្តិ និងការបាត់បង់មុខរបរចិញ្ចឹមជីវិត បញ្ហាសុខភាពផ្លូវចិត្តដូចជាជំងឺបាក់ស្បាត កង្វះការផ្ដល់ជូនជាមូលដ្ឋាន និងកត្តាផ្សេងៗទៀតដែលឈានទៅរកវិបត្តិអនុត្តរភាពបុរស ក៏ចូលរួមចំណែកដល់កម្រិតអំពើហិង្សាដែលមានពីមុនមកក្នុងចំណោមបុរសផងដែរ។ ជាញឹកញាប់ កត្តានេះត្រូវបានគួបផ្សំដោយការបាត់បង់ការការពារពីសមាជិកគ្រួសារដែលបានស្លាប់ ឬបានធ្វើចំណាកស្រុក ព្រមទាំងការជួលរលំនីតិរដ្ឋ។ ឧទាហរណ៍ ការសិក្សាមួយក្នុងប្រទេសបង់ក្លាដែសបានរកឃើញឧប្បត្តិហេតុអំពើហិង្សាខ្ពស់ប្រឆាំងនឹងស្ត្រី បន្ទាប់ពីកើតមានទឹកជំនន់នៅឆ្នាំ ២០០៧ ជាពិសេសក្នុងចំណោមក្រុមបាត់បង់ឱកាសដូចជាអ្នករកស៊ីផ្លូវភេទ និងជនពិការជាដើម (ActionAid Bangladesh ឆ្នាំ ២០០៨)។ ការកើនឡើងអំពើហិង្សាប្រឆាំងនឹងស្ត្រីបន្ទាប់ពីកើតមានគ្រោះមហន្តរាយពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ ក៏ត្រូវបានមើលឃើញផងដែរក្នុងប្រទេសវៀតណាម(មិនមានប្រភពជាក់លាក់)។ ហើយបើទោះជានិន្នាការនានាក្នុងតំបន់អាស៊ីមិនត្រូវបានគេដឹងក្តី ក៏ការសិក្សានានា (anz-Barbero B ឆ្នាំ២០១៨) បានរាយការណ៍ពីការកើនឡើងហានិភ័យនៃអំពើហិង្សាដៃគូរួមភេទបន្ទាប់ពីការកើតមានរលកកម្ដៅរយៈពេលបីថ្ងៃដល់៣៤អង្សាសេនៅក្នុងទីក្រុងម៉ាឌ្រីដ (ប្រទេសអេស្ប៉ាញ)។

ស្ត្រី និងកុមារី ក៏ប្រឈមនឹងហានិភ័យធ្ងន់ធ្ងរកាន់តែខ្លាំងផងដែរ ដោយសារការវាយប្រហារនៃគ្រោះមហន្តរាយដែលបង្កឡើងដោយអាកាសធាតុ ដូចជាអាពាហ៍ពិពាហ៍កុមារ និងការជួញដូរកុមារដែលមានការរៀបចំទុក។ អាពាហ៍ពិពាហ៍កុមារមានការរីករាលដាលខ្លាំងក្នុងប្រទេសបង់ក្លាដែស ហើយថ្មីៗនេះត្រូវបានគេភ្ជាប់ទំនាក់ទំនងទៅនឹងការប្រែប្រួលអាកាសធាតុនិងការកើនឡើងគ្រោះមហន្តរាយធម្មជាតិចំនួន។ស្ត្រីនិងកុមារក៏ស្ថិតក្នុងហានិភ័យខ្លាំងបំផុតផងដែរនៃការជួញដូរក្នុងគ្រាកើតមានគ្រោះមហន្តរាយហើយពួកគេប្រឈមនឹងហានិភ័យខ្លាំងបំផុតនៃការក្លាយជាទិសដៅសម្រាប់ការកេងប្រវ័ញ្ច ដែលបង្កឱ្យក្លាយជាពលកម្មទាសភាព និងពលកម្មផ្លូវភេទ (Nelleman et al ឆ្នាំ២០១១)។ ជាថ្មីម្តងទៀត ខណៈដែលមិនមានទិន្នន័យស្ថិតិដែលអាចរកបាន ការធ្វើការងារជាអ្នករកស៊ីផ្លូវភេទ និងអ្នកសុំទានគឺ ជាកត្តាបង្កគ្រោះថ្នាក់ក្នុងគ្រាដែលមានវិបត្តិបរិស្ថាន និងអាកាសធាតុ (IFRC ឆ្នាំ២០១៥)។ ក្នុងរដ្ឋ West Bengal ក្នុងប្រទេសឥណ្ឌា មានគំរូដែលត្រូវបានសង្កេតឃើញមួយរវាងការជួញដូរស្ត្រី និងកុមារីនិងទឹកជំនន់ប្រចាំឆ្នាំ។ មានការកើនឡើងប្រចាំឆ្នាំនូវការជួញដូរ

មនុស្សដែលកើតមានបន្ទាប់ពីកើតមានទឹកជំនន់ប្រចាំឆ្នាំនៅពេលដែលគ្រួសារគោលដៅប្រែក្លាយជាក្រីក្រ និងអស់សង្ឃឹមចំពោះជីវភាពរស់នៅ។បន្ទាប់ពីកើតមានព្យុះទីហ្វុងហៃយ៉ានក្នុងប្រទេសហ្វីលីពីននៅខែវិច្ឆិកា ឆ្នាំ២០១៣ ភស្តុតាងមួយចំនួនក៏គាំទ្រដល់ការអះអាងថា ការជួញដូរគឺជាកង្វល់ដ៏ធំមួយ។

## ជម្រើស និងយុទ្ធសាស្ត្របន្សាំដែលឆ្លើយតបនឹងយេនឌ័រ

សកម្មភាពបន្សាំនៅក្នុងវិស័យសុខាភិបាលភាគច្រើនជាន់គ្នាជាមួយនឹងយុទ្ធសាស្ត្របន្សាំសម្រាប់គ្រោះមហន្តរាយ ដូចជាការពង្រឹងប្រព័ន្ធប្រកាសអាសន្ន ការធានានូវលទ្ធភាពទទួលបានទឹកស្អាតសម្រាប់ផឹកនិងអនាម័យខ្លួនប្រាណ ការធានានូវកសិកម្មនិងសន្តិសុខស្បៀងសម្រាប់អាហារូបត្ថម្ភ ការកាត់បន្ថយភាពក្រីក្រនិងការធានាការអប់រំ ដើម្បីពង្រីកឱកាស និងការដោះស្រាយបញ្ហាចិត្តសាស្ត្រ និងសុខភាពផ្លូវចិត្ត ដែលទាក់ទងនឹងស្ត្រេសដែលបណ្តាលមកពីការស្តារគ្រោះមហន្តរាយ ការផ្លាស់ប្តូរទីលំនៅ និងការធ្វើចំណាកស្រុកដោយបង្ខំ។ ទោះបីយ៉ាងណាក៏ដោយ វាក៏ចាំបាច់ត្រូវពិនិត្យមើលលើការកែលម្អសេវាថែទាំសុខភាពសាធារណៈទូទៅ ជាពិសេស ការថែទាំសុខភាពផ្លូវភេទ និងសុខភាពបន្តពូជ លទ្ធភាពទទួលបានទឹកស្អាត និងអនាម័យខ្លួនប្រាណដែលស្ថិតនៅក្នុងក្របខ័ណ្ឌអភិវឌ្ឍន៍ដែលជាយុទ្ធសាស្ត្របន្សាំដ៏សំខាន់។ អង្គការសុខភាពពិភពលោក (មិនមានប្រភពច្បាស់លាស់) បានដាក់វិសាលភាពយេនឌ័រនៃការប្រែប្រួលអាកាសធាតុ និងយុទ្ធសាស្ត្របន្សាំ និងអន្តរាគមន៍ដែលអាចកើតមានបញ្ចូលជាមួយគ្នា។ ការគូសបញ្ជាក់សំខាន់ៗអំពីការរួមបញ្ចូលគ្នានេះ ត្រូវបានបង្កើតឡើងវិញនៅក្នុងតារាងទី១៨ បន្ទាប់នេះ។

> **គន្លឹះសម្រាប់គ្រូឧទ្ទេស**
>
> នៅចំណុចនេះវាជាការប្រសើរណាស់ក្នុងការឈប់សម្រាកបន្តិចនិងបង្ហាញខ្សែភាពយន្តខ្លីស្តីពីសម្លេងស្ត្រីមកពីសារ៉ាវ៉ាក់ ដែលបង្ហាញពីបញ្ហាប្រឈមរបស់ពួកគេក្នុងការរស់ជាមួយស្ថានភាពផ្លាស់ប្តូរ។ រឿងនេះជាផ្នែកមួយនៃការស្រាវជ្រាវថ្នាក់តំបន់ស្តីពី "ការបង្កើតសង្គមថ្មីដើម្បីសិទ្ធិសុខភាពផ្លូវភេទ និងសុខភាពបន្តពូជ និងការប្រែប្រួលអាកាសធាតុ ដែលអាចរកបាននៅ គេហទំព័រ៖ https://www.youtube.com/watch?v=2Pr-RN5YLa_U&t=29s

**តារាងទី១៨៖ យុទ្ធសាស្ត្របន្សាំដែលមានការឆ្លើយតបយេនឌ័រ និងការអនុវត្តការបន្សាំនឹងការប្រែប្រួលអាកាសធាតុសម្រាប់វិស័យសុខាភិបាល**

| យុទ្ធសាស្ត្របន្សាំដែលឆ្លើយតបនឹងយេនឌ័រ | ការអនុវត្តការបន្សាំដែលឆ្លើយតបនឹងយេនឌ័រ |
|---|---|
| > ផ្តល់ទីជម្រកនិងផ្ទះសម្បែងដែលមានសុវត្ថិភាពសម្រាប់ទាំងស្ត្រី និងបុរស។<br>> ការបណ្តុះបណ្តាលស្តីពីការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយរំញោចយេនឌ័រ និងប្រព័ន្ធប្រកាសអាសន្ន។<br>> លើកកម្ពស់កម្មវិធីដែលជួយសម្រួលដល់បុរសក្នុងការស្វែងរកជំនួយសម្រាប់បញ្ហាសង្គមចិត្តសាស្ត្រ។<br>> ការផ្តល់អំណាចដល់ស្ត្រីដើម្បីពង្រឹងសមត្ថភាពរបស់ពួកគេក្នុងការស្វែរសំណួរ និងផ្លាស់ប្តូរបទដ្ឋានអាកប្បកិរិយាដែលបង្កគ្រោះថ្នាក់ដល់ពួកគេក្នុងករណីមានហេតុការណ៍ធ្ងន់ធ្ងរ។ | > ការត្រៀមខ្លួនទប់ទល់នឹងគ្រោះមហន្តរាយរំញោចយេនឌ័រ។<br>> ប្រព័ន្ធប្រកាសអាសន្នរំញោចយេនឌ័រ។<br>> ធានាឱ្យមានការចូលរួមរបស់ស្ត្រីដោយឈរលើមូលដ្ឋានស្មើភាពគ្នា នៅក្នុងវដ្តនៃគោលនយោបាយ និងកម្មវិធីទាំងអស់។<br>> កំណត់គោលដៅស្ត្រី និងបុរសខុសៗគ្នា នៅក្នុងយុទ្ធនាការទំនាក់ទំនង និងយុទ្ធសាស្ត្រលើកកម្ពស់សុខភាព ដោយគិតគូរពីបទដ្ឋាន និងតួនាទីយេនឌ័ររបស់ពួកគេ។<br>> អនុម័តយុទ្ធសាស្ត្រនៅគ្រប់កម្រិតនៃការរៀបចំកម្មវិធី ដើម្បីផ្លាស់ប្តូរបទដ្ឋាន និងការអនុវត្តដែលរារាំងស្ត្រី ឬបុរសពីការឆ្លើយតបសមស្រប និងយន្តការដោះស្រាយក្នុងស្ថានភាពគ្រោះមហន្តរាយធម្មជាតិ។ |
| > ទស្សនវិស័យយេនឌ័រ ត្រូវដាក់បញ្ចូលទៅក្នុងការវិភាគ និងការស្រាវជ្រាវជំងឺឆ្លង ដើម្បីកំណត់គោលនយោបាយ និងកម្មវិធីគោលដៅ។<br>> ទិន្នន័យដែលប្រមូលបាន ត្រូវតែបែងចែកតាមភេទ អាយុ ស្ថានភាពសង្គមសេដ្ឋកិច្ច ការអប់រំ ជនជាតិដើមភាគតិច និងទីតាំងភូមិសាស្ត្រ តាមដែលសមស្រប។<br>> ការយល់ដឹងអំពីយេនឌ័រ និងផលប៉ះពាល់របស់វាចំពោះសុខភាពនិងឥរិយាបថស្វែងរកសុខភាពគួរតែត្រូវបានបញ្ចូលទៅក្នុងការបណ្តុះបណ្តាល អ្នកជំនាញផ្នែកសុខភាព និងការអភិវឌ្ឍការឆ្លើយតបផ្នែកសុខភាព។ | > ធានាបាននូវភាពអាចរកបាននិងលទ្ធភាពទទួលបានព្រមទាំងការគាំទ្រពីប្រព័ន្ធសុខភាព ទាំងសម្រាប់ស្ត្រី និងបុរស ប៉ុន្តែជាពិសេសសម្រាប់ស្ត្រីដោយគិតទៅលើតួនាទីមើលថែរបស់ពួកគេ<br>> គាំទ្រសកម្មភាពផ្សព្វផ្សាយដោយប្រើព័ត៌មានរំញោចយេនឌ័រ ការអប់រំ និងយុទ្ធសាស្ត្រទំនាក់ទំនង និងសម្ភារសម្រាប់ការតស៊ូមតិ និងការបណ្តុះបណ្តាល។<br>> លើកកម្ពស់បបនីយភ័ណ្ឌថែទាំកុមារ និងវិធីសាស្ត្រផ្សេងទៀតដើម្បីគាំទ្រតួនាទីថែទាំស្ត្រី ខណៈដែលព្យាយាមផ្លាស់ប្តូរតួនាទី និងបទដ្ឋានទាក់ទងនឹងយេនឌ័រ។ |

## តារាងទី១៨៖ យុទ្ធសាស្ត្របន្សាំដែលមានការឆ្លើយតបយេនឌ័រ និងការអនុវត្តការបន្សាំនឹងការប្រែប្រួលអាកាសធាតុសម្រាប់វិស័យសុខាភិបាល

| យុទ្ធសាស្ត្របន្សាំដែលឆ្លើយតបនឹងយេនឌ័រ | ការអនុវត្តការបន្សាំដែលឆ្លើយតបនឹងយេនឌ័រ |
|---|---|
| > លើកកម្ពស់កម្មវិធីដែលជួយសម្របសម្រួលឱ្យបុរសស្វែងរកជំនួយសម្រាប់បញ្ហាសង្គមចិត្តសាស្ត្រ។<br>> ផ្តល់អំណាចដល់ស្ត្រី ដើម្បីបង្កើនសមត្ថភាពក្នុងការថែទាំខ្លួនឯង និងគ្រួសាររបស់ពួកគេ និងជាពិសេស ក្នុងការប្រើប្រាស់សង្គមដែលអាចរកបាន និងផ្សេងទៀត។<br>> បណ្តាញដើម្បីទប់ទល់នឹងបន្ទុក និងភាពតានតឹងដែលបានកើនឡើង។ | > ដាក់ទិសដៅលើស្ត្រី និងបុរសខុសគ្នា នៅក្នុងការសម្រាលក្រោយគ្រោះមហន្តរាយ ដោយគិតគូរពីបទដ្ឋាន តួនាទី និងទំនាក់ទំនងយេនឌ័រ។ |
| > លើកកម្ពស់ការអនុវត្តការសន្សំសំចៃទឹក ដែលគិតដល់ការប្រើប្រាស់ និងតួនាទីផ្សេងៗគ្នាទាក់ទងនឹងទឹកសម្រាប់ស្ត្រី កុមារី និងបុរស។<br>> ដោះស្រាយភាពកខ្វក់ដោយសារលោយជាតិអំបិលនិងជាតិអាសេនិចនៅក្នុងទឹកដោយស្មើឱ្យមានសកម្មភាពជាក់លាក់ដែលពិចារណាលើលំនាំផ្សេងៗនៃការប្រឈម និងផលប៉ះពាល់លើស្ត្រី និងបុរស។<br>> ប្រឆាំងនឹងការមាក់ងាយក្នុងសង្គមដែលជាប់ទាក់ទងនឹងផលប៉ះពាល់នៃការពុលដោយសារជាតិអាសេនិចចំពោះស្ត្រី និងបុរស។ | > ធានាថាទឹកផឹកត្រូវអាចលៃលកបាន ដោយគិតពីតួនាទី និងតម្រូវការផ្សេងៗរបស់ស្ត្រី និងបុរស<br>> ផ្តល់ភាពអង់អាចដល់ស្ត្រីនិងសម្របសម្រួលឱ្យមានការចូលរួមដោយស្មើភាព ក្នុងការគ្រប់គ្រងធនធានទឹកនៅថ្នាក់ជាតិ ថ្នាក់តំបន់ និងថ្នាក់មូលដ្ឋាន។<br>> បច្ចេកវិទ្យាសមស្របសម្រាប់ធានាថាទឹកស្អាតអាចខិតទៅជិតកន្លែងដែលគ្រួសាររស់នៅ។<br>> ពង្រឹងយន្តការព្រៃឈើនិងការប្រមូលផលទឹកដោយគិតពីតួនាទីតម្រូវការ និងផលប៉ះពាល់ផ្សេងៗគ្នាចំពោះស្ត្រី និងបុរស។<br>> លើកកម្ពស់សិទ្ធិរបស់ស្ត្រីក្នុងការកាន់កាប់ដីធ្លីនិងភាពជាម្ចាស់លើវិញ្ញាបនបត្រប្រើប្រាស់ដីធ្លី<br>> អនុវត្តគោលនយោបាយទឹកប្រកបដោយប្រសិទ្ធភាពដែលគិតគូរពីតម្រូវការ និងតួនាទីផ្សេងៗគ្នារបស់ស្ត្រី និងបុរសសម្រាប់ការប្រើប្រាស់ ការផ្គត់ផ្គង់ និងការប្រើប្រាស់ទឹក។<br>> ធានាលទ្ធភាពទទួលបានធនធានប្រកបដោយសមធម៌ទាក់ទងនឹងការទូទាត់ថ្លៃសេវាបរិស្ថាន។ |
| > ឱ្យស្ត្រី និងបុរសចូលរួមក្នុងការអភិរក្សជីវៈចម្រុះ។ | > បណ្តុះបណ្តាលអំពីការផ្សព្វផ្សាយកសិកម្មសម្រាប់ទាំងស្ត្រីនិងបុរស ផ្តល់អាហារបំប៉នកាន់តែល្អប្រសើរសម្រាប់គ្រួសារដែលខ្វះខាត។<br>> ឋបនីយកណ្ឌទីផ្សារ។<br>> សិទ្ធិដីធ្លីសម្រាប់ស្ត្រី។ |
| > កសាងបណ្តាញរឹងមាំនិងបែបគាំទ្រទាំងសម្រាប់ស្ត្រីនិងបុរស<br>> លើកកម្ពស់ការបណ្តុះបណ្តាលរំញោចយេនឌ័រដើម្បីលុបបំបាត់អំពើហិង្សាលើស្ត្រី កុមារី និងកុមារា។<br>> កសាងសមត្ថភាពនៅក្នុងប្រព័ន្ធសុខាភិបាលដើម្បីធានាការរកឱ្យឃើញនូវអំពើហិង្សាក្នុងគ្រួសារ ឬផ្លូវភេទ។<br>> ឱ្យស្ត្រីចូលរួមក្នុងការគ្រប់គ្រងទីជម្រកនិងសកម្មភាពចែកចាយ | > គំនិតផ្តួចផ្តើមគោលនយោបាយ នៅក្នុងវិស័យសុខាភិបាល ការអប់រំ ហិរញ្ញវត្ថុ និងវិស័យការងារដើម្បីបង្កើតជាផ្នែកមួយនៃកិច្ចប្រឹងប្រែងបង្ការអំពើហិង្សាដែលមានលក្ខណៈស្និតរមួតនៅថ្នាក់ជាតិ/អន្តរជាតិ ដែលរួមបញ្ចូលទាំងស្ត្រី កុមារី បុរស និងកុមារា។<br>> អនុវត្តសេវាសុខាភិបាលសមស្រប ដែលឆ្លើយតបនឹងតម្រូវការជាក់លាក់របស់ស្ត្រី និងបុរសដោយផ្អែកលើតម្រូវការ តួនាទី និងសមត្ថភាពរៀងៗខ្លួន។<br>> រៀបចំប្រព័ន្ធបញ្ជូនមានប្រសិទ្ធភាពសម្រាប់ករណីអំពើហិង្សាក្នុងគ្រួសារ។ រៀបចំប្រព័ន្ធបញ្ជូនសម្រាប់ករណីការបៀតបៀនផ្លូវភេទ។ |

## វិស័យទី៣៖ ការប្រែប្រួលអាកាសធាតុ និងតំបន់ឆ្នេរ

**ចំណុចពិភាក្សា**

ស្នើអ្នកចូលរួម ដែលសកម្មភាពប្រកបរបរចិញ្ចឹមជីវិតលេចធ្លោក្នុងចំណោមសហគមន៍ឆ្នេរ នៅក្នុងតំបន់របស់ពួកគេ ហើយតើបុរស និងស្ត្រីមានតួនាទីអ្វីដូចគ្នា? បន្ថែមពីលើនេះ សូមសាកសួរថា តើពួកគេគិតថានឹងមានផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុអ្វីខ្លះទៅលើការប្រកបរបរចិញ្ចឹមជីវិតនៅតំបន់ឆ្នេរ?

**តម្រុយសម្រាប់អ្នកសម្របសម្រួល**

> ការនេសាទ (ការចិញ្ចឹមជីវិតនៅកម្រិតគ្រួសារ)
> ការនេសាទ (ផ្សារពាណិជ្ជកម្ម/ក្រុងតំបន់/ក្រៅតំបន់)
The cross focus working group consists of representatives from the other five discovery areas working groups. The team conducted study on interconnectedness  of the themes and strategies that could be integrated. Priority strategy was the result of this stage, achieved through various methods. There were 18 city resilience strategies and 53 city resilience initiatives which were under 6 pillars of strategy.




#### MAY

**The City Resilience Strategy Launch**

A comprehensive City Resilience Strategy is officially launched.




ប្រភព៖ (សៀវភៅយុទ្ធសាស្ត្រ Semrang ភាពធន់ ឆ្នាំ២០១៦)

ចំណោមបញ្ហាផ្សេងទៀតគឺជាបញ្ហាដែលទីក្រុងបច្ចុប្បន្នកំពុងដោះស្រាយ។ប្រហែលប្រាំភាគរយនៃប្រជាជននៅទីក្រុងដែលរស់នៅក្នុងភាពក្រីក្រ ត្រូវបានគេចាត់ទុកថាងាយរងគ្រោះបំផុតចំពោះបញ្ហាទាំងនេះ។ រដ្ឋាភិបាលទីក្រុង Semarang រួមជាមួយជាតុផ្សំនៃទីក្រុងទាំងអស់ បានព្យាយាមយកឈ្នះលើបញ្ហាប្រឈមទាំងនេះ តាមរយៈការធ្វើឱ្យប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងមិនមែនរូបវន្ត។ ទីក្រុងសម្រេចបានច្រើន ទោះយ៉ាងណាក៏នៅមានអ្វីជាច្រើនដែលត្រូវធ្វើ។ សម្រាប់ការបញ្ចប់ឯកសារយុទ្ធសាស្ត្រភាពធន់របស់ទីក្រុង Semarang ដែលជាផ្នែកមួយនៃគំនិតផ្តួចផ្តើមទីក្រុងដែលមានភាពធន់ ១០០។ យុទ្ធសាស្ត្រនេះត្រូវបានបង្កើតឡើងតាមរយៈដំណើរការរួមបញ្ចូលគ្នាដែលពាក់ព័ន្ធនឹងផ្នែកជាច្រើននៃទីក្រុង។(រូបទី២១)

**TABLE 4-8: SEMARANG CITY RESILIENCE STRATEGY: PILLARS, STRATEGIES AND INITIATIVES**

មានយុទ្ធសាស្ត្រសសរស្តម្ភចំនួន៦ យុទ្ធសាស្ត្រចំនួន១៨ និងគំនិតផ្តួចផ្តើមចំនួន៥៣ ដែលបានចុះ ក្នុងឯកសារយុទ្ធសាស្ត្រភាពធន់នៃទីក្រុង Semrang ដែលនឹងយកមកចែករំលែកនៅក្នុងតារាងទី២ បន្ទាប់នេះ។

| សសរស្តម្ភ | ទឹក និងថាមពលប្រកបដោយចីរភាព | ឱកាសសេដ្ឋកិច្ចថ្មី | ការត្រៀមខ្លួនទប់ទល់នឹងគ្រោះមហន្តរាយ និងការរាតត្បាតនៃជំងឺ | ចល័តភាពដែលត្រូវបានដាក់បញ្ចូល | ព័ត៌មានសាធារណៈប្រកបដោយតម្លាភាព និងអភិបាលកិច្ច | ធនធានមនុស្សដែលមានការប្រកួតប្រជែង |
|---|---|---|---|---|---|---|
| យុទ្ធសាស្ត្រ | ១. ការពង្រឹងការអនុវត្តការគ្រប់គ្រងទឹកជាមូលដ្ឋាន ២. ការផ្សព្វផ្សាយអំពីការច្នៃប្រឌិតថ្មីនៅក្នុងការផ្តល់ទឹក ៣. លើកកំពស់ឥរិយាបទដែលគិតគូពីបរិស្ថាន | ១. ការផ្សព្វផ្សាយអំពីភាពជាសហគ្រិនដើម្បី បង្កើនការប្រកួតប្រជែងផ្នែកពាណិជ្ជកម្ម និងសេវាកម្ម ២. ការបង្កើតអាជីវកម្មបែបច្នៃប្រឌិតដោយផ្តោតលើសង្គម និងបរិស្ថាន ៣. ការពង្រឹងភាគីពាក់ព័ន្ធចម្រុះ (ការសិក្សា ពាណិជ្ជកម្ម សហគមន៍ រដ្ឋាភិបាល) ភាពជាដៃគូដើម្បីបង្កើតឱកាសការងារ | ១. ការបង្កើតបច្ចេកវិទ្យាសម្រាប់គ្រោះមហន្តរាយ និងការគ្រប់គ្រងជំងឺ ២. ការពង្រឹងសមត្ថភាពរបស់ភាគីពាក់ព័ន្ធនៅក្នុងគ្រោះមហន្តរាយ និងការគ្រប់គ្រងជំងឺ ៣. ការធ្វើឱ្យប្រសើរឡើងនូវការសម្របសម្រួលក្នុងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ | ១. ការលើកទឹកចិត្តការផ្លាស់ប្តូរឥរិយាបថពីការប្រើប្រាស់យានជំនិះឯកជនមកជាមធ្យោបាយធ្វើដំណើរសាធារណៈ ២. ធ្វើឱ្យប្រសើរឡើងនូវការសម្របសម្រួល និងការគ្រប់គ្រងតាមស្ថាប័ននូវមធ្យោបាយដឹកជញ្ជូនសាធារណៈ ៣. ការរួមបញ្ចូលគ្នានូវការរៀបចំផែនការដឹកជញ្ជូន | ១. បង្កើនប្រសិទ្ធភាព Musrenbang (ការអភិវឌ្ឍវេទិកាៀបចំផែនការ) នៅក្នុងដំណើរការរៀបចំផែនការ ២. ធ្វើឱ្យប្រសើរឡើងនូវការរួមបញ្ចូលនៃការរៀបចំផែនការ និងការរៀបចំថវិកាសម្រាប់ទីក្រុង ៣. បង្កើនប្រសិទ្ធភាពរបស់រដ្ឋាភិបាលការសម្របសម្រួលទិន្នន័យការរួមបញ្ចូល និងព័ត៌មានសាធារណៈ | ១. ការរៀបចំកម្លាំងពលកម្មសម្រាប់ទីផ្សារការងារបច្ចុប្បន្ន ២. ការផ្សព្វផ្សាយតម្លៃនៃការបន្តគុណវុឌ្ឍិការសិក្សាកម្រិតខ្ពស់ ៣. ការកែលម្អការអប់រំក្រៅប្រព័ន្ធ |
| ចំនួននៃគំនិតផ្តួចផ្តើម | ៨ | ១១ | ៧ | ១៣ | ៩ | ៥ |

*Source: Semarang City Government (2016).*

### ករណីទី៣៖ ភាពធន់តាមរយៈការផ្តល់សិទ្ធិអំណាចផ្នែក សេដ្ឋកិច្ច ការបន្សាំនឹងអាកាសធាតុភាពជាអ្នកដឹកនាំនិងការរៀនសូត្រ(REE-CALL) ប្រទេសបង់ក្លាដែស

ប្រទេសបង់ក្លាដែស Nari Progati Sangha (BNPS) បាន និងកំពុងអនុវត្តគម្រោង "ភាពធន់តាមរយៈការផ្តល់សិទ្ធិអំណាចផ្នែកសេដ្ឋកិច្ច ការបន្សាំនឹងអាកាសធាតុ ភាពជាអ្នកដឹកនាំ និងការរៀនសូត្រ (REE-CALL)" ដែលគាំទ្រដោយអង្គការ Oxfam GB ចាប់តាំងពីខែសីហា ឆ្នាំ២០១០។ គម្រោងនេះ មានគោលបំណងកសាងសមត្ថភាពសហគមន៍សម្រាប់ការកាត់បន្ថយ និងគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ។ មូលដ្ឋានគ្រឹះសំខាន់នៃគម្រោង គឺការបង្កើតអង្គការដែលមានមូលដ្ឋាននៅសហគមន៍ដ៏រឹងមាំជាមួយមេដឹកនាំបុរសនិងស្ត្រីមកពីភូមិក្នុងមូលដ្ឋានដែលសម្របសម្រួលការកំណត់អន្តរាគមន៍ DRR តាមរយៈការប្រើប្រាស់ដំណើរវិភាគសមត្ថភាព និងភាពងាយ រងគ្រោះដែលមានការចូលរួម (PCVA)។

នៅឆ្នាំ២០១១ CBO ត្រូវបានបង្កើតឡើងនៅក្នុងភូមិ Kurerpar ដែលមានសមាជិក ៩២នាក់ រួមមានទាំងស្ត្រី។ ក្នុងកំឡុងពេល PCVA ជាមួយ CBO វាត្រូវបានគេបង្ហាញថា ភូមិប្រឈមនឹងហានិភ័យទ្វេដងនៃទឹកជំនន់ និងគ្រោះរាំងស្ងួតជារៀងរាល់ឆ្នាំ។ អស់រយៈពេលប្រហែល ៧ខែហើយ ដែលប្រព័ន្ធអេកូនៅតំបន់ដីសើមនៅតែស្ថិតនៅក្រោមទឹកហើយផ្នែកដែលនៅសល់គឺជាដីទាបដែលស្ងួត។ ក្នុងអំឡុងពេលធ្វើលំហាត់ PCVA សមាជិក CBO បានកំណត់ហានិភ័យ ដូចជា គ្រោះទឹកជំនន់ និងប្រព័ន្ធដឹកជញ្ជូនដែលកំពុងអភិវឌ្ឍន៍។ អសន្តិសុខ និងការបាត់បង់ទ្រព្យសម្បត្តិ និងការប្រកបរបរចិញ្ចឹមជីវិត ដោយសារជំនន់ទឹកភ្លៀង ត្រូវបានគូសបញ្ជាក់ថា ជាផលប៉ះពាល់ចម្បងនៃហានិភ័យគ្រោះមហន្តរាយ។ ដូច្នេះសមាជិក CBO មានគម្រោងសាងសង់ជញ្ជាំង (ជញ្ជាំងការពារវណ្ណៅ) នៅក្នុងតំបន់ដែលបានកំណត់ដែលនឹងផ្តល់ផលប្រយោជន៍ដោយផ្ទាល់ដល់គ្រួសារចំនួន ៣០គ្រួសារ។

ទោះបីជាការកំណត់អត្តសញ្ញាណនៃដំណោះស្រាយ មានភាពងាយស្រួលក៏ពិតមែន ក៏ការអនុវត្តមិនមានដែរ។ ក្រៅពីតម្រូវការហិរញ្ញប្បទាន ជំនួយបច្ចេកទេសក៏ជាបញ្ហាផងដែរ។ ដោយសារគម្រោងនេះ មិនអាចទ្រទ្រង់ការចំណាយបានពេញលេញ សមាជិក CBO បានទាក់ទងទៅរដ្ឋបាលមូលដ្ឋានដើម្បីគាំទ្រ។ មន្ត្រីវិស្វករថ្នាក់រងស្រុក និងមន្ត្រីអនុវត្តគម្រោង ត្រូវបានគេចូលជួប ហើយបន្ទាប់ពីការតាមដាន និងការទំនាក់ទំនងជាប្រចាំ ការសាងសង់នេះត្រូវបានបញ្ចប់នៅខែមេសាឆ្នាំ២០១៥។ ក្រៅពី BDT ចំនួន ២២៥ពាន់ ដែលត្រូវបានផ្តល់ដោយគម្រោង RECALL សហគមន៍ខ្លួនឯងក៏បានរួមចំណែកជាថវិកា និងកម្លាំងពលកម្មសម្រាប់ BDT ចំនួន១០០ពាន់ សម្រាប់ការសាងសង់ជញ្ជាំងកម្ពស់ ៥១៧ហ្វីត និងជញ្ជាំងការពារកម្ពស់ ២៩០ហ្វីតស៊ីស៊ី។ ការរួមចំណែករបស់រដ្ឋាភិបាលសម្រាប់ការងារនេះគឺ BDT។ ១១៨ពាន់ដែលត្រូវបានប្រើ គឺដើម្បីសាងសង់ជញ្ជាំងការពារពំនូកមានកម្ពស់ ២២៧ស៊ីស៊ី។ វាគឺជាបទពិសោធន៍ថ្មីទាំងស្រុងសម្រាប់អ្នកភូមិនិងសមាជិកCBOនិងបានគូសបញ្ជាក់ពីសារៈសំខាន់ដែលសហគមន៍គួរតែចូលរួមក្នុងគម្រោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធផងដែរ។

### ករណីទី៤៖ ការបន្សាំផ្អែកលើប្រព័ន្ធអេកូឡូស៊ីតំបន់ទិ្ត ក្នុងប្រទេសនេប៉ាល់៖ ការគ្រប់គ្រងប្រកបដោយនិរន្តរភាព ការអភិរក្ស និងការស្តារប្រព័ន្ធអេកូឡូស៊ីនៅកម្រិតទីជម្រាល

ការផ្តោតលើកម្រិតទីជម្រាលរងតាមរយៈការអន្តរាគមផ្សេងៗ ដូចជាការអភិរក្សទឹក ការស្តានីតិសម្បទាដី ការធ្វើពិពិធកម្មរបរចិញ្ចឹមជីវិត និងការពង្រឹងសមត្ថភាពរបស់ទីភ្នាក់ងាររដ្ឋាភិបាល និងសហគមន៍មូលដ្ឋាន។

ការអនុវត្តនានាដូចជាការអភិរក្សធនធាន និងការសាងសង់ស្រះអភិរក្ស ត្រូវបានផ្តួចផ្តើមឡើងដើម្បីដោះស្រាយបញ្ហាខ្វះទឹក។ ការគ្រប់គ្រងជីវាលស្មៅត្រូវបានធ្វើឡើងតាមរយៈការសាងសង់ជញ្ជាំងថ្មបគ្នាដើម្បីផ្អាកសកម្មភាពស៊ីស្មៅហួសកម្រិតរបស់សត្វពាហនៈ និងការពារប្រព័ន្ធអេកូឡូស៊ីជីវាលស្មៅពីការរេចរឹលបន្ថែមទៀត។ គំនិតផ្តួចផ្តើមអភិរក្សច្រាំងទន្លេមួយចំនួនដែលមានការអនុវត្តវិធានការប្រផេះបែតងដូចជារចនាសម្ព័ន្ធដែលត្រូវបានរចនាឡើងគួបផ្សំនឹងចម្ការឫស្សីត្រូវបានអនុវត្តដើម្បីការពារដីកសិកម្មនៅតាមច្រាំងទន្លេ ដើម្បីកាត់បន្ថយការរេចរឹលកម្ទេចកំណទៅតាមលំហូរទឹកទន្លេ។

គម្រោងត្រូវបានផ្សព្វផ្សាយតាមកម្មវិធីវិទ្យុឈ្មោះថា "Panchase ko Serofero" តាមរយៈវិទ្យុ barahi-99.2 របស់ស្រុក Kaski វិទ្យុ saligram-100.6 របស់ស្រុក Parbat និងវិទ្យុ Syangja FM-89.6 របស់ក្រុង Syangja ដើម្បីបង្កើនការយល់ដឹងកម្រិតមូលដ្ឋានអំពីប្រព័ន្ធអេកូឡូស៊ី និង EbA។ គម្រោងនេះត្រូវបានអនុវត្តដោយនាយកដ្ឋានព្រៃឈើស្ថិតក្រោមក្រសួងព្រៃឈើ និងអភិរក្សដី ហើយត្រូវបានសម្របសម្រួលដោយក្រសួងវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងបរិស្ថាន។ ដូចគ្នានេះដែរ មានទីភ្នាក់ងារអនុវត្តចំនួនបី គឺអង្គការ UNEP អង្គការ UNDP និងអង្គការ IUCN។

### ករណីទី៥៖ ការធ្វើសមាហរណកម្មការបន្សាំផ្អែកលើសហគមន៍នៅតំបន់ដែនដីសណ្តទន្លេមេគង្គ (ICAM) ប្រទេសវៀតណាម

គោលបំណងរួមរបស់គម្រោង ធ្វើសមាហរណកម្មការបន្សាំផ្អែកលើសហគមន៍នៅតំបន់ដែនដីសណ្តទន្លេមេគង្គ (ICAM) គឺដើម្បីបង្កើនភាពធន់របស់សហគមន៍នៅក្នុងតំបន់ដែនដីសណ្តទន្លេមេគង្គ ទៅនឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុដែលមិនអាចចៀសវាងបាន។ គម្រោងនេះមានទិសដៅផ្តោត

លើមនុស្សងាយរងគ្រោះបំផុត ជាពិសេសប្រជាជនដែលគ្មានដី និងមានដីដែលគ្មានដីជាតិដោយផ្តោតការយកចិត្តទុកដាក់ពិសេសលើក្រុមជនជាតិភាគតិចដូចជា ជនជាតិចាម និង ជនជាតិខ្មែរ ដែលរស់នៅក្នុងឃុំចំនួន៥ ក្នុងខេត្តសុកចាង និងខេត្តអានយ៉ាង ដោយមានកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធជាមួយដៃគូនានា។ គម្រោងនេះមានសមាភាពស្នូលចំនួន៤៖

ក) ការកសាងសមត្ថភាពមូលដ្ឋាន ដើម្បីអនុវត្តការវិភាគវិញ្ញាចយេនឌ័រ ដែលត្រូវបានកែលម្អ និងការរៀបចំផែនការសម្រាប់ CBA

**រូបទី៦៧៖ ជំហានដំណើរការដកស្រង់ចេញពីសៀវភៅណែនាំអំពីការរៀបចំផែនការ CBA របស់អង្គការ Care Vietnam**

| **STEPS:** CC/CBA Orientation for Provincial and District Authorities | ACTIVITIES | RESULTS |
|---|---|---|
| **STEP 1** | > Orientation sessions on CC, CBA and gender.<br>> Consensus building on CBA planning process. | > Improved understanding among provincial and district local authorities on CC, CBA and gender.<br>> Approval and commitment of local authorities to CBA planning steps. |
| **STEP 2** | > Establishment and approval of CBA taskforce.<br>> Selection of potential CBA trainers. | > Established group of the main CBA decision-makers in the province.<br>> A gender-balanced list of potential CBA trainers. |
| **STEP 3** | > Training on climate change and DRR.<br>> CBA planning process + tools.<br>> Training and facillitation skills. | > A group of qualified gender-balanced CBA trainers from the province, district (and commune) level that will lead Step 4 to Step 9. |
| **STEP 4** | > Consensus on CBA planning process.<br>> Selection of CBA facillitators. | > Improved understanding among commune and village local authorities on CC (including gender) and CBA.<br>> Approval and commitment of local authorities to CBA planning steps. |
| **STEP 5** | > Training on CBA planning process + tools.<br>> Facillitation skills.<br>> Field testing of CBA tools. | > A group of qualified gender-balanced CBA facillitators from the commune and village that wil help the CBA trainers facillitate Step 7 and 8 (village and commune CBA planning). |
| **STEP 6** | > Developing work plan for Step 7 to Step 9. | > A detailed work plan, including time schedule, jointly developed by the CBA trainers and CBA facillitators to carry out the village and comune plan. |
| **STEP 7** | > Secondary data collection + CVCA exercises.<br>> Visioning and village CBE plan.<br>> Documentation | > Village CBA planning reports, including CVCA report, a common village vision and a gender-responsive inclusive village CBA plan. |
| **STEP 8** | > Present village CBA plans, commune socio-economic development plan (SEDP).<br>> Developing commune CBA plan.<br>> Discuss mainstreaming into SEDP. | > Commune CBA planning reports, including a gender-resposive inclusive commune CBA plan and recommended follow-up actions for mainstreaming into the commune SEDP. |
| **STEP 9** | > Present commune CBA plan + district SEDP.<br>> Orientation on CC mainstreaming.<br>> Discuss mainstreaming into district SEDP. | > Improved understanding of the CBA taskforce on CC mainstreaming into SEDP and the results of the CBA planning.<br>> Agreed follow-up actions for mainstreaming into SEDP/sectoral plans. |
| **STEP 10** | > Discussion by Government, communities, mass organisations, CSOs, NGOs, etc. about implementation. | > Implementation of commune and village CBA plans. |

ប្រភព៖ (CARE ឆ្នាំ២០១៤)

វិធីសាស្ត្រជាជំហានៗ ចំពោះការប៉ាន់ប្រម៉ាណភាពងាយរងគ្រោះ និងការរៀបចំផែនការ CBA ត្រូវបានបង្កើតឡើងដោយប្រើប្រាស់សៀវភៅណែនាំអំពីការប៉ាន់ប្រម៉ាណសមត្ថភាព និងភាពងាយរងគ្រោះទៅនឹងអាកាសធាតុ (CVCA) របស់អង្គការ CARE និងឧបករណ៍ចក្ខុវិស័យសហគមន៍ (សូមមើលឧបករណ៍ក្នុងរូបទី៥)។ បន្ទាប់ពីនេះ គឺជាការវិភាគរួមគ្នាអំពីហានិភ័យអាកាសធាតុ និងជម្រើសបន្សាំរវាងសហគមន៍ និងអាជ្ញាធរមូលដ្ឋានត្រូវបានធ្វើឡើង។ សហគមន៍បានរៀបចំផែនការសម្រាប់អនាគតភាពធន់ដោយរួមបញ្ចូលសេណារីយ៉ូអាកាសធាតុផ្សេងៗ។ ផែនការសកម្មភាពជាលទ្ធផលប្រាប់អំពីវិធីសាស្ត្រនានាចំពោះរបរចិញ្ចឹមជីវិត ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងការផ្លាស់ប្តូរឥរិយាបថ។

**ខ) គាំទ្រការអនុវត្តវិធានការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ (DRR) និងរបរចិញ្ចឹមជីវិតដែលធន់នឹងអាកាសធាតុ**

សកម្មភាព DRR ដូចជាការបណ្តុះបណ្តាលជំនាញហែលទឹក ប្រព័ន្ធប្រកាសអាសន្នទឹកជំនន់ ព័ត៌មានអំពីសុវត្ថិភាពកុមារ និងការដាំដើមឈើសម្រាប់ការបង្ការការរេចរឹលដី កំពុងត្រូវបានផ្តល់មូលនិធិរួមគ្នាដោយគម្រោង និងរដ្ឋាភិបាល។ លើសពីនេះទៀត គម្រោងក៏ផ្តល់ការគាំទ្រសម្រាប់សកម្មភាពរបរចិញ្ចឹមជីវិតដែលធន់នឹងអាកាសធាតុផងដែរដូចជាការចិញ្ចឹមអន្ទង់បែបសរីរាង្គ ការសិប្ផនបណ្តុះផ្សិតក្នុងរោងបែបសរីរាង្គ ការផលិតជីសរីរាង្គពីកាកសំណល់ខ្ទឹមបារាំង បច្ចេកទេសស្រោចស្រពដំណក់ទឹក កន្លែងដេកសម្រាប់ការគ្រប់គ្រងលាមកជ្រូក សួនបន្លែដាំលើទឹក និងការដាំដុះម្ទេស។

**គ) ការតស៊ូមតិ និងការកៀរគរសង្គមដើម្បីដោះស្រាយមូលហេតុនៃភាពងាយរងគ្រោះ**

សមាជិករបស់ក្រុមជនជាតិភាគតិចផ្សេងៗស្ត្រីអ្នកក្រីក្រ និងអ្នកគ្មានដី អ្នកដែលរស់នៅលើទូក ឬក្នុងផ្ទះដែលគ្មានការការពារនៅលើទឹក ត្រូវបានគាំទ្រឱ្យផ្សព្វផ្សាយបទពិសោធ និងកង្វល់របស់ពួកគេតាមរយៈការនិទានរឿងឌីជីថលសហគមន៍។

**ឃ) ការពង្រឹងសង្គមស៊ីវិលនៅដែនដីសណ្តទន្លេមេគង្គ**

ពង្រឹងបណ្តាញសង្គមស៊ីវិល ចែករំលែកព័ត៌មាន រៀនសូត្រនិងសហប្រតិបត្តិការអំពីការប្រែប្រួលអាកាសធាតុតាមរយៈការបង្កើតនិងប្រតិបត្តិការរួមគ្នានូវក្រុមការងារប្រែប្រួលអាកាសធាតុភាគខាងត្បូង (Southern Climate Change Working Group)។ ក្រុមការងារនេះប្រមូលផ្តុំដោយសង្គមស៊ីវិល អង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ វិទ្យាស្ថានស្រាវជ្រាវ និងអង្គការផ្តល់មូលនិធិទ្វេភាគី។

ប្រភព៖ ដកស្រង់ចេញពី (CARE ឆ្នាំ២០១៤), (Care Vietnam ឆ្នាំ២០១៥), (Care Vietnam ឆ្នាំ២០១៩)

## ឯកសារមេរៀនទី១៧ ៖ ឯកសារចំណាត់ថ្នាក់នៃមាត្រដ្ឋានប៉ាន់ប្រម៉ាណដែលឆ្លើយតបនឹងតម្រូវការយេនឌ័រ (GRAS)

កម្រិតទី ១ ៖ ការមិនស្មើភាពផ្អែកយេនឌ័រ

- ធ្វើឱ្យមានវិសមភាពយេនឌ័រតាមរយៈការពង្រឹងបទដ្ឋាន តួនាទី និងទំនាក់ទំនងគ្មានតុល្យភាព។
- ផ្តល់សិទ្ធិដល់បុរសច្រើនជាងស្ត្រី (ឬសិទ្ធិស្ត្រីច្រើនជាងបុរស)។
- ជាញឹកញាប់នាំទៅដល់ការធ្វើឱ្យភេទមួយទទួលបានសិទ្ធិ ឬឱកាសច្រើនជាងភេទមួយផ្សេងទៀត។

កម្រិតទី២ ៖ ការមិនមានទស្សនៈយេនឌ័រ

- មិនអើពើនឹងបទដ្ឋាន តួនាទី និងទំនាក់ទំនងយេនឌ័រ
- ជាញឹកញាប់ពង្រឹងការរើសអើងទាក់ទងនឹងយេនឌ័រ។
- មិនអើពើនឹងភាពខុសគ្នានៃឱកាស និងការបែងចែកធនធានសម្រាប់ស្ត្រី និងបុរស។
- ជាញឹកញាប់ត្រូវបានស្មារឡើងវិញដោយផ្អែកលើគោលការណ៍នៃភាព "មិនលម្អៀង" ដោយការប្រព្រឹត្តស្មើភាពគ្នាចំពោះមនុស្សគ្រប់គ្នា។

កម្រិតទី៣ ៖ រំញោចយេនឌ័រ

- ពិចារណាពីបទដ្ឋាន តួនាទី និងទំនាក់ទំនងយេនឌ័រ។
- មិនបានដោះស្រាយវិសមភាពដែលត្រូវបានបង្កើតឡើងដោយភាពមិនស្មើគ្នាដែលជាទំនៀមទំលាប់ តួនាទី ឬទំនាក់ទំនងផ្សេងៗ ។
- ចង្អុលបង្ហាញពីការយល់ដឹងអំពីយេនឌ័រទោះបីជាញឹកញាប់មិនមានសកម្មភាពដោះស្រាយត្រូវបានបង្កើតឡើងក៏ដោយ។

កម្រិតទី៤ ៖ ទស្សនៈយេនឌ័រជាក់លាក់

- ពិចារណាពីបទដ្ឋាន/ទំនៀមទំលាប់ តួនាទី និងទំនាក់ទំនងយេនឌ័រ សម្រាប់ស្ត្រី និងបុរស និងរបៀបដែលវាជះឥទ្ធិពលដល់ការទទួលបាន និងគ្រប់គ្រងលើធនធាន។
- ពិចារណាពីតម្រូវការជាក់លាក់របស់ស្ត្រី និងបុរស។
- មានចេតនាក្នុងការកំណត់គោលដៅនិងផ្តល់ផលប្រយោជន៍ដល់ក្រុមស្ត្រី ឬបុរសជាក់លាក់ ដើម្បីសម្រេចបាននូវគោលនយោបាយ ឬគោលដៅកម្មវិធីជាក់លាក់ ឬបំពេញតាមតម្រូវការជាក់លាក់។
- បង្កលក្ខណៈងាយស្រួលសម្រាប់ស្ត្រីនិងបុរសក្នុងការបំពេញភារកិច្ចដែលបានកំណត់ឱ្យពួកគេដោយផ្អែកលើតួនាទីយេនឌ័ររបស់ពួកគេ។

កម្រិតទី៥ ៖ ទស្សនៈផ្លាស់ប្តូរផ្នត់គំនិតយេនឌ័រ

- ពិចារណាពីបទដ្ឋាន/ទំនៀមទំលាប់ តួនាទី និងទំនាក់ទំនងយេនឌ័រ សម្រាប់ស្ត្រី និងបុរស ហើយថា កត្តាទាំងនេះប៉ះពាល់ដល់ការទទួលបាន និងគ្រប់គ្រងលើធនធាន។

- ពិចារណាពីតម្រូវការជាក់លាក់របស់ស្ត្រី និង បុរស។
- ដោះស្រាយបុព្វហេតុបង្កឱ្យមានវិសមភាពសុខភាពទាក់ទងនឹងយេនឌ័រ។
- រួមបញ្ចូលវិធីដើម្បីផ្លាស់ប្តូរបទដ្ឋាន/ទំនៀមទំលាប់ តួនាទី និងទំនាក់ទំនងយេនឌ័រដែលបង្កគ្រោះថ្នាក់។
- គោលបំណងគឺជាញឹកញាប់ដើម្បីលើកកម្ពស់សមភាពយេនឌ័រ
- រួមបញ្ចូលទាំងយុទ្ធសាស្ត្រ ដើម្បីជំរុញការផ្លាស់ប្តូរសន្សឹមៗនៅក្នុងទំនាក់ទំនងអំណាចរវាងស្ត្រី និងបុរស។

## ឯកសារមេរៀនទី ១៨៖ ករណីសិក្សាស្តីពីគំរូភាពធន់ ដែលដឹកនាំដោយស្ត្រី

**ផ្នែក ក ៖ សេចក្តីសម្រេចស្តីពីយុទ្ធសាស្ត្រភាពធន់**

អំពីមូលនិធិនៃការផ្តល់ភាពអង់អាចដល់ស្ត្រី ៖

មូលនិធិនៃការផ្តល់ភាពអង់អាចដល់ស្ត្រី ត្រូវបានបង្កើតឡើងក្នុងទសវត្សរ៍ឆ្នាំ ១៩៩០ ដើម្បីជួយសម្រួលដល់ការលើកកម្ពស់ការសាងសង់លំនៅដ្ឋានហេដ្ឋារចនាសម្ព័ន្ធនិងសេវាកម្មដែលពាក់ព័ន្ធសម្រាប់ស្ត្រីនៅហ្គូ ចារ៉ាត។ដោយចាប់ផ្តើមពីក្រុមតូចមួយនៃអ្នកផ្តល់សេវាសង្គម និងវិស្វករ មូលនិធិត្រូវបានអំពាវនាវដោយរដ្ឋាភិបាលទីក្រុងក្នុងមូលដ្ឋានក្នុងឆ្នាំ១៩៩៨ ដើម្បីគាំទ្រដល់ការកៀរគរសហគមន៍នៅក្នុងតំបន់អនាធិបតេយ្យសម្រាប់ការផ្តល់សេវាមូលដ្ឋាន ដូចជា ទឹក អនាម័យបរិស្ថាន លូបង្ហូរទឹកសំណល់ផ្លូវលំ ការគ្រប់គ្រងសំណល់រឹង អំពូលភ្លើងនៅតាមផ្លូវ និងការដាំដើមឈើ។ វិធីសាស្ត្រនៃការអនុវត្តគម្រោងរបស់ពួកគេ បានផ្តោតលើការអភិវឌ្ឍន៍ដែលដឹកនាំដោយស្ត្រី។ គំរូនេះផ្តោតលើការបង្កើតអង្គការសហគមន៍មូលដ្ឋាន (CBOs) ដែលដឹកនាំដោយស្ត្រីនៅក្នុងតំបន់អនាធិបតេយ្យនិងការអភិវឌ្ឍជំនាញភាពជាអ្នកដឹកនាំរបស់ស្ត្រីដើម្បីរៀបចំផែនការនិងអនុវត្តគម្រោងនៅក្នុងតំបន់របស់ពួកគេ។ វិធីសាស្ត្រនេះទទួលបានជោគជ័យយ៉ាងខ្លាំង ហើយនៅចន្លោះឆ្នាំ១៩៩៩-២០០៤ មូលនិធិរួមជាមួយនឹងការគាំទ្រពីរដ្ឋាភិបាលក្រុងមូលដ្ឋាន អាចផ្តល់ជំនួយទៅដល់គ្រួសារក្រីក្រចំនួនជាង ៣៥.០០០ គ្រួសារ សម្រាប់ការគ្របដណ្តប់លើសេវាកម្មទាំងនេះ។

វិធីសាស្ត្រ និងកម្មវិធីរហូតដល់ឆ្នាំ២០១៤ ៖

បន្ទាប់ពីទទួលបានជោគជ័យដំបូង មូលនិធិបន្ទាប់មក ផ្តែកលើបទពិសោធន៍នេះដើម្បីពង្រីកប្រតិបត្តិការរបស់ខ្លួនទាំងខ្សែបណ្តោយ និងខ្សែរទទឹង។ អង្គការនេះបានបង្កើនវិសាលភាពនៃសកម្មភាពរបស់ខ្លួនទៅតាមខ្សែសង្វាក់តម្លៃសេវាកម្មដែលដឹកនាំដោយសហគមន៍។ សកម្មភាពដំបូងរបស់ មូលនិធិនៅក្នុងតំបន់អនាធិបតេយ្យ បានជួយបង្កើត CBOs ហើយមេដឹកនាំជាស្ត្រីត្រូវបានបណ្តុះបណ្តាល និងផ្តល់ភាពអង់អាច ដើម្បីទំនាក់ទំនងនិងធ្វើការយ៉ាងជិតស្និទ្ធជាមួយអាជ្ញាធរមូលដ្ឋាន ដើម្បីទទួលបានការតភ្ជាប់អគ្គិសនីស្របច្បាប់ ការទទួលបាន ផលិតផលថាមពលដែលមានប្រសិទ្ធភាព និងកកើតឡើងវិញ និងប្រាក់កម្ចីសម្រាប់សាងសង់លំនៅដ្ឋានប្រសើរជាងមុន។ ការពង្រីកការងារតាមខ្សែបណ្តោយមានពីរវិធី៖ ទីមួយ មូលនិធិ បានប្រើប្រាស់ការរៀនសូត្ររបស់ខ្លួនពីការងារនៅតាមសហគមន៍ដើម្បីជះឥទ្ធិពលដល់គោលនយោបាយទីក្រុង រដ្ឋ និងថ្នាក់ជាតិ។ ទីពីរ មូលនិធិបានសម្របសម្រួល CBOs ឱ្យចូលរួមជាមួយគ្នានៅកម្រិតទីក្រុងដោយបង្កើតសហព័ន្ធ CBOs ដែលផ្តោតលើស្ត្រីថ្នាក់ទីក្រុង។ ការពង្រីកការងារខ្សែទទឹង រួមមាន ការបង្កើនការងារទៅតាមតំបន់អនាធិបតេយ្យផ្សេងទៀតនៅក្នុងទីក្រុងដោយប្តូរទីលំនៅទៅទីក្រុងផ្សេងទៀតនៅក្រោមរដ្ឋបាលមូលដ្ឋាន (ថ្នាក់ក្រោមជាតិ) និងការប្តូរទីលំនៅទៅនៅក្រោមរដ្ឋបាលផ្សេងៗទៀត។

[12]ដកស្រង់ចេញពីសកម្មភាពរបស់ស្ត្រីឆ្ពោះទៅរកភាពធន់នឹងអាកាសធាតុរបស់អ្នកក្រីក្រក្នុងទីក្រុងនៅអាស៊ី ៖ គម្រោងមួយដោយ Mahila Housing Sewa Trust។ (ឯកសារដែលបានពិនិត្យរួមមាន របាយការណ៍វាយតម្លៃគម្រោង សៀវភៅណែនាំ និងរបាយការណ៍សង្ខេបគោលនយោបាយ)

**ការអភិវឌ្ឍផែនការយុទ្ធសាស្ត្រក្នុងឆ្នាំ២០១៨ ៖**

នៅក្នុងឆ្នាំ ២០១៤ មូលនិធិបានសំរេចអនុវត្តលំហាត់អភិវឌ្ឍន៍ផែនការយុទ្ធសាស្ត្រក្នុងគោលបំណងពិនិត្យ អំពីផលប៉ះពាល់និងការគ្របដណ្តប់លើការងាររបស់ខ្លួនដោយយោងទៅលើរបៀបវារៈអភិវឌ្ឍន៍ប្រកបដោយ ចីរភាពកំពុងលេចធ្លោនិងការផ្តោតការអភិវឌ្ឍ ដែលកំពុងផ្លាស់ប្តូរនៅក្នុងប្រទេស ក៏ដូចជាទិដ្ឋភាពហិរញ្ញវត្ថុសម្រាប់អភិវឌ្ឍន៍ដែលជាជម្រើសផ្សេងទៀត។ លំហាត់នេះ ត្រូវបានសម្របសម្រួលដោយអ្នកពិគ្រោះយោបល់ខាងក្រៅ និងមានការចូលរួមពីថ្នាក់ដឹកនាំជាស្ត្រីក្នុងមូលដ្ឋាននៃសហព័ន្ធទីក្រុង និងបុគ្គលិកកម្មវិធី តាមរយៈសិក្ខាសាលាតាមបែបចូលរួមជាបន្តបន្ទាប់។លំហាត់នេះបាននាំមកនូវយុទ្ធសាស្ត្រសក្តានុពលចំនួន ៣ ដូចខាងក្រោម ៖

ក) ផ្តោតតែលើវិស័យដែលបានជ្រើសរើស ដែលជាគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDGs) ទូទៅ និងរបៀបវារៈរបស់រដ្ឋាភិបាលថ្នាក់ជាតិប៉ុណ្ណោះព្រោះវិស័យទាំងនោះអាចនឹងធានាបាននូវ ហិរញ្ញវត្ថុអភិវឌ្ឍន៍ប្រសើរជាង។ ការងារនេះនឹងរួមបញ្ចូលការផ្តោតលើវិស័យចំនួនបី គឺទឹកអនាម័យបរិស្ថាន និងថាមពល។ មូលនិធិនឹងចាំបាច់ត្រូវរៀបចំសារជាថ្មីនូវធនធានមនុស្សនាពេលបច្ចុប្បន្ននិងផ្តោតលើការលើកកម្ពស់ការងារដើម្បីឈានដល់ប្រជាជនជាងមួយលានគ្រួសារក្នុងរយៈពេលប្រាំឆ្នាំខាងមុខ។

ខ) ផ្លាស់ប្តូរការផ្តោតរបស់ខ្លួនទៅរកសេវាកម្មលំនៅដ្ឋានដែលរកប្រាក់ចំណេញប្រកបដោយវិជ្ជាជីវៈ (ដែលស្របតាមរបៀបវារៈអភិវឌ្ឍន៍របស់រដ្ឋាភិបាលថ្នាក់ជាតិ និងទីក្រុង) ដើម្បីបង្កើតហិរញ្ញវត្ថុ ដែលអាចផ្តល់ហិរញ្ញប្បទានទៅដល់ ការងារមិនរកប្រាក់ចំណេញរបស់ខ្លួនលើការផ្តល់សេវាកម្ម។នេះនឹងរួមបញ្ចូល

ការពង្រឹងការងារបច្ចុប្បន្នរបស់ខ្លួនទៅនឹងទីតាំងភូមិសាស្ត្រផ្សេងទៀត ដែលបានកំណត់ ដោយផ្តោតលើការបង្កើតឱ្យមានប្រសិទ្ធភាពកម្រិតខ្ពស់ទៅលើជីវភាពរស់នៅរបស់ប្រជាជនប្រហែលមួយសែននាក់នៅក្នុងទីក្រុងមួយចំនួន។

គ) ផ្លាស់ប្តូរការផ្តោតពីការផ្តល់សេវាកម្មទៅជាអភិបាលកិច្ច និងការងារតស៊ូមតិដោយកសាងភាពជាអ្នកដឹកនាំនិងសមត្ថភាពបច្ចេកទេស និងអង្គការសហគមន៍របស់ស្ត្រី ដើម្បីផ្តល់ភាពអង់អាចដល់ពួកគេក្នុងការផ្តល់អាទិភាពដល់តម្រូវការអភិវឌ្ឍន៍ផ្ទាល់ខ្លួន និងអាចទទួលបានពីរដ្ឋបាលទីក្រុង និងអ្នកផ្តល់សេវាផ្សេងទៀត។ ដំណើរការនេះនឹងតម្រូវឱ្យមានការផ្លាស់ប្តូរទៅជាដៃគូអន្តរវិន័យ ដោយផ្តោតជាសំខាន់លើការអភិវឌ្ឍសហគមន៍ ដែលកំណត់ភាពងាយរងគ្រោះក្នុងមូលដ្ឋាន និងពង្រឹងភាពធន់នឹងដំណោះស្រាយសមស្របបំផុត ដែលត្រូវបានជ្រើសរើសដោយ CBOs។

**សំណួរសំខាន់ៗ៖**

ក) តើវិធីសាស្ត្រនីមួយៗមានគុណសម្បត្តិ និងគុណវិបត្តិអ្វីខ្លះ?

ខ) តើអ្នកគិតថាវិធីសាស្ត្រណាមួយដែលសាកសមបំផុតសម្រាប់មូលនិធិ?

គ) តើគួរមានលក្ខណៈវិនិច្ឆ័យអ្វីខ្លះសម្រាប់ការជ្រើសរើសវិធីសាស្ត្រត្រឹមត្រូវ?

**ផ្នែក ខ ៖ ការអភិវឌ្ឍគម្រោងភាពធន់នៅសហគមន៍មូលដ្ឋាន**

បន្ទាប់ពីការពិគ្រោះយោបល់រួចមកមូលនិធិបានសម្រេចចិត្តរួមបញ្ចូលគ្នានៃវិធីសាស្ត្រនានា និងបានអនុម័តយុទ្ធសាស្ត្រដូចខាងក្រោម ៖

ក) បញ្ជ្រាបភាពធន់នឹងការប្រែប្រួលអាកាសធាតុទៅក្នុងការងារតាមវិស័យដែលមានស្រាប់តាមរយៈភាពជាដៃគូបច្ចេកទេស និងសហការបង្កើតដំណោះស្រាយបញ្ជ្រាបយេនឌ័រ ប្រកបដោយប្រសិទ្ធភាពដែលអាចពង្រីកតាមរយៈយន្តការផ្អែកលើទីផ្សារ ដើម្បីទៅដល់មនុស្សជាងមួយសែននាក់។

ខ) បន្តផ្តោតទៅលើការកសាងមូលធនសង្គមតាមរយៈការបង្កើត CBO និងការអភិវឌ្ឍភាពជាអ្នកដឹកនាំរបស់ស្ត្រីប៉ុន្តែជំរុញទៅរកដំណោះស្រាយអភិបាលកិច្ចទីក្រុង និងការធ្វើផែនការប្រកបបរិយាបន្នតាមរយៈការផ្តល់ភាពអង់អាចដល់ស្ត្រីដែលជាអ្នកធ្វើឱ្យមានការផ្លាស់ប្តូរ និងដល់ប្រជាជនក្នុងចំនួនច្រើនជាងមុន។

គ) ចាប់ដៃគូជាមួយអង្គការនៅតាមមូលដ្ឋានផ្សេងទៀតសម្រាប់ការចែករំលែកផលិតផលចំណេះដឹង និងយុទ្ធសាស្ត្រ ដើម្បីពង្រីកដល់ទីក្រុងផ្សេងទៀត។ និង

ឃ) ពង្រឹងការងារផ្តល់សេវាកម្មបច្ចុប្បន្នរបស់ខ្លួន ដើម្បីផ្តោតលើការផ្តល់សេវាកម្មចុងក្រោយបង្អស់ដែលផ្តោតលើជនងាយរងគ្រោះ និងជួបការលំបាក ក្នុងចំណោមសហគមន៍អនាធិបតេយ្យ។

គំនិតនៅពីក្រោយយុទ្ធសាស្ត្រនេះ គឺអនុញ្ញាតឱ្យប្រជាជនដែលងាយរងគ្រោះ ជាពិសេសស្ត្រី កំណត់របៀបវារៈ និងគាំទ្រពួកគេឱ្យជម្នះឧបសគ្គចំពោះការអភិវឌ្ឍ។ យុទ្ធសាស្ត្រនេះមានមូលដ្ឋានគ្រឹះរបស់វានៅក្នុងអំណះអំណាងពីរ៖ ទីមួយ ប្រសិនបើអ្នកក្រីក្រក្នុងទីក្រុង ត្រូវបានផ្តល់ជូននូវចំណេះដឹងដែលចាំបាច់ដើម្បីអនុវត្តការវាយតម្លៃអំពីភាពងាយរងគ្រោះ និងហានិភ័យ ហើយបំពាក់ដោយបច្ចេកវិទ្យាភាពធន់ដែលអាចរកបាន ពួកគេនឹងអាចបង្កើត និងអនុវត្តនូវដំណោះស្រាយភាពធន់នឹងអាកាសធាតុ ដែលគាំពារដល់អ្នកក្រីក្រ និងអ្នកពាក់ព័ន្ធនៅតាមមូលដ្ឋាន។ ទីពីរ ប្រសិនបើអ្នកក្រីក្រត្រូវបានផ្តល់ភាពអង់អាច ដើម្បីអនុវត្តផែនការភាពធន់របស់ពួកគេ ហើយយន្តការស្ថាប័ន ដែលតំណាងឱ្យសំឡេងរបស់ពួកគេត្រូវបានរៀបចំទុកនោះ ពួកគេនឹងអាចផ្តល់សំឡេងស្ថាបនានៅក្នុងផែនការទីក្រុង និងអភិបាលកិច្ចស្តីពី ការបន្សាំ និងសកម្មភាពធន់ ដែលគាំទ្រអ្នកក្រីក្រ។ តាមរយៈការប្រើប្រាស់ក្របខ័ណ្ឌយុទ្ធសាស្ត្រនេះ ជាគោលការណ៍ណែនាំ មូលនិធិ បានបង្កើតគម្រោងភាពធន់នឹងអាកាសធាតុជាពិសេសដែលដឹកនាំដោយស្ត្រី។

**ដំណាក់កាលសំខាន់ៗដែលត្រូវអនុវត្តសម្រាប់ការអភិវឌ្ឍគម្រោងរួមមាន៖**

**ដំណាក់កាលទី១៖** គំនិតផ្តួចផ្តើមឯកសារទស្សនទាននៃគម្រោងដំបូងត្រូវបានបង្កើតឡើងសម្រាប់ស្វែងរកការគាំទ្រមូលនិធិដើម្បីធ្វើការប៉ាន់ប្រមាណស៊ីជម្រៅលើបញ្ហា ហើយបន្ទាប់មករៀបចំដំណោះស្រាយចំពោះបញ្ហាទាំងនោះ។ មូលនិធិ ដែលទទួលបានសម្រាប់ការងារនេះត្រូវបានគេប្រើជាឱកាសមួយដើម្បីសាកល្បងយុទ្ធសាស្ត្រ ដែលអាចធ្វើទៅបាន និងតាមការអំណះអំណាង។ ដូច្នេះ គម្រោងនេះត្រូវបានបង្កើតឡើងក្នុងលក្ខណៈចូលរួមដោយផ្តល់ការតម្រង់ទិសដំបូង ដើម្បីជ្រើសរើសមេដឹកនាំសហគមន៍ស្ត្រីដើម្បីស្វែងយល់ពីហានិភ័យនិងភាពងាយរងគ្រោះនៃអាកាសធាតុ។ (សូមមើលការពិព័ណ៌នាសម្រាប់បញ្ហាប្រឈមដំបូងនៅក្នុងវិធីសាស្ត្រដែលមានការចូលរួម)

**ដំណាក់កាលទី២៖** ឧបករណ៍លំហាត់វាយតម្លៃហានិភ័យ និងយេនឌ័រធាប់ហ៊េសមួយ ដោយប្រើក្របខ័ណ្ឌនិន្នាការអ៊ីស្ត្រក្រាម និងម៉ូស៊ីរត្រូវបានដាក់បញ្ចូលគ្នាហើយកម្មករនិងមេដឹកនាំជាស្ត្រីមកពីតំបន់អនាធិបតេយ្យត្រូវបានបណ្តុះបណ្តាលឱ្យអនុវត្តវិធីទាំងនេះ ដើម្បីលើកទឹកចិត្ត ដល់កិច្ចពិភាក្សាក្រុមគោលដៅ (FGDs) លើបញ្ហាសហគមន៍អនាធិបតេយ្យ។ FGDs ទាំង ៥២ ត្រូវបានរៀបចំឡើងនៅក្នុងទីក្រុងចំនួន ៦ ផ្សេងៗគ្នា ក្នុងដំណាក់កាលនេះស្តីពី បញ្ហាទាក់ទងនឹងការប្រែប្រួលអាកាសធាតុ។ ភាពស្រេកសំខាន់ៗនៃកម្តៅ ទឹក គុណភាពទឹក ទឹកជំនន់ និងការជន់លិចនិងការគ្រប់គ្រងភ្នាក់ងារចម្លងជំងឺបានលេចចេញ

ជាបញ្ហាចំបងក្នុងអំឡុងពេល FGDs ទាំងនេះ។ សហគមន៍បានចែករំលែកថា ដោយសារតែពេលរសៀលក្តៅខ្លាំង រយៈពេល ៤ ម៉ោងក្នុងមួយថ្ងៃ បានធ្វើឲ្យខាត់ពេលឥតប្រយោជន៍ ពីព្រោះពួកគេមិនអាចចាប់ផ្តើមសកម្មភាពណាមួយដោយសារកម្តៅខ្លាំងពេក។ ប្រការនេះបណ្តាលឱ្យម៉ោងធ្វើការថយចុះ និងប្រសិទ្ធភាពក៏ធ្លាក់ចុះផងដែរ។ FGDs ក៏បានបង្ហាញផងដែរថា គ្រួសារភាគច្រើនទទួលបានទឹក ២-៣ ម៉ោងក្នុងមួយថ្ងៃ តាមរយៈបណ្តាញទីក្រុងនីមួយៗ ឬតាមរយៈអណ្តូងទឹករួមនៅក្នុងសហគមន៍។ ទោះយ៉ាងណាក៏ដោយ នៅតែមានតំបន់មួយចំនួនដែលទឹកគឺជាបញ្ហាចម្បង ជាពិសេសនៅរដូវក្តៅ។ សហគមន៍ភាគច្រើន ក៏បានរាយការណ៍អំពីទឹកជំនន់នៅតំបន់ឆ្ងាយពីមាត់សមុទ្រ ដែលបណ្តាលឱ្យស្ទះលូទឹកក្រខ្វក់។សហគមន៍ខ្លះក៏បានលើកឡើងផងដែរថា ភ្លៀងធ្លាក់ខ្លាំងក្នុងរយៈពេល ១-២ ម៉ោង បណ្តាលឱ្យមានទឹកជំនន់លេចត្រឹមជង្គង់ ហើយជាមធ្យមធ្វើឱ្យកម្មករខកខានមិនបានធ្វើការ ៤-៥ ថ្ងៃក្នុងមួយខែ ដោយសារតែពួកគាត់ត្រូវធ្វើការស្តារទឹកចេញឬធ្លាក់ខ្លួនឈឺហើយមិនអាចធ្វើការបានដោយសារទឹកជំនន់បង្កឱ្យមានលក្ខខណ្ឌគ្មានអនាម័យ ការកើនឡើងនៃជំងឺគ្រុនឈាម និងករណីនៃជំងឺដែលឆ្លងតាមភ្នាក់ងារចម្លងជំងឺផ្សេងៗទៀត។ដោយផ្អែកលើអន្តរកម្មទាំងនេះព័ត៌មានសហគមន៍កម្រិតទីក្រុង និងព័ត៌មានសហគមន៍អនាធិបតេយ្យលម្អិត ត្រូវបានបង្កើតឡើងសម្រាប់ការតាំងទីលំនៅក្រុមគោលដៅ។

**ដំណាក់កាលទី៣៖** ដោយផ្តល់នូវព័ត៌មានពីការតាំងទីលំអ្នកដឹកនាំជាស្រ្តីបានចូលរួមជាមួយអ្នកជំនាញបច្ចេកទេសតាមរយៈសិក្ខាសាលាដើម្បីធ្វើការវិភាគបញ្ហារួមគ្នា។សិក្ខាសាលាវិភាគដើមឈើបញ្ហា ដែលនាំឱ្យ ដៃគូបច្ចេកទេសនៃគម្រោង ក្រុមការងារអនុវត្តនិងអ្នកដឹកនាំជាស្រ្តីមកពីសហគមន៍អនាធិបតេយ្យនៅក្នុងវេទិកាតែមួយ គឺជាចំណុចសំខាន់នៃដំណាក់កាលអភិវឌ្ឍន៍គម្រោង។ នេះគឺជាប្រភេទអន្តរកម្មទីមួយដែលអ្នកជំនាញ និងសហគមន៍ត្រូវបាននាំយកមកជជែកគ្នា និងពិភាក្សាអំពីស្រ្តេសជាក់លាក់តាមរយៈការយល់ឃើញខុសគ្នារបស់ពួកគេ ដើម្បីរកឲ្យឃើញឫសគុលនៃបញ្ហា។ ដើមឈើបញ្ហានីមួយៗស្តីពីស្រ្តេស កម្តៅកង្វះខាតទឹក ទឹកជំនន់នៅតំបន់ឆ្ងាយពីមាត់សមុទ្រ និងជំងឺដែលឆ្លងតាមទឹក និងឆ្លងតាមភ្នាក់ងារចម្លងជំងឺ ការបាត់បង់ទ្រព្យសម្បត្តិ និងសមត្ថភាពស្ថាប័ន ព្រមទាំងយន្តការដែលត្រូវបានបង្កើតឡើងដែលជាផ្នែកមួយនៃសិក្ខាសាលានេះ ត្រូវបានយកធ្វើជាមូលដ្ឋានដើម្បីបង្កើតក្របខណ្ឌផែនការគម្រោង ដែលបានជួយក្រុមការងារក្នុងការរៀបចំដំណោះស្រាយដោយមានការចូលរួម។ នៅចុងបញ្ចប់នៃសិក្ខាសាលាដែលមានការពិភាក្សាគ្នាយ៉ាងទូលំទូលាយរយៈពេលពីរថ្ងៃនេះ ការធានាបាននូវសុខភាព និងការរស់នៅ បានលេចចេញជាស្នូលនៃក្របខ័ណ្ឌដំណោះស្រាយ។ (សូមមើលការពិព័រណ៍ ខ សម្រាប់ភាពជាដៃគូបច្ចេកទេស)

**ដំណាក់កាលទី៤៖** សិក្ខាសាលានេះក៏បានសម្របសម្រួលកិច្ចសន្ទនារវាងអ្នកជំនាញបច្ចេកទេស និងអ្នកដឹកនាំសហគមន៍ផងដែរ។ បន្ទាប់ពីសិក្ខាសាលានេះអ្នកជំនាញបច្ចេកទេសជាច្រើនបានទៅមើលតំបន់អនាធិបតេយ្យ ដើម្បីស្វែងយល់ពីបញ្ហាកាន់ច្បាស់ដែលអ្នកដឹកនាំជាស្រ្តីបានសម្របសម្រួលការចូលរួម។ ការធ្វើទស្សនកិច្ចនៅតាមមូលដ្ឋានទាំងនេះធ្វើឱ្យប្រសើរឡើងថែមទៀតនូវការរៀបចំគម្រោង។

**ដំណាក់កាលទី៥៖** ក្រោយមកនៅក្នុងដំណាក់កាលនេះ ក៏មានលំហាត់អភិវឌ្ឍន៍សូចនាករមួយដែលត្រូវបានអនុវត្តជាមួយអ្នកដឹកនាំជាស្រ្តីនិងក្រុមងារកៀរគរតាមមូលដ្ឋានដែលត្រូវបញ្ចូលទៅក្នុងដំណើរការវាយតម្លៃភាពងាយរងគ្រោះកម្រិតសហគមន៍នៅក្នុងទម្រង់សិក្ខាសាលា។ ទស្សនៈរបស់ស្រ្តីស្តីពី សំណង់អនាធិបតេយ្យឆ្លាត និងទីក្រុងឆ្លាត ត្រូវបានយកមកសិក្សាស្វែងយល់អំពីទស្សនទានរបស់ពួកគេ ទាក់ទងនឹងភាពងាយរងគ្រោះហានិភ័យនិងការកសាងភាពធន់។ប្រភពព័ត៌មានផ្សេងៗសម្រាប់អ្នកដឹកនាំជាស្រ្តី ក៏ត្រូវបានយកមករៀបចំផែនការ ដើម្បីកំណត់ពីឧបសគ្គដែលបានកើតមាននិងចក្ខុវិស័យអន្តរាគមន៍ទំនាក់ទំនងផ្លាស់ប្តូរឥរិយាបថដែលជាផ្នែកមួយនៃការអនុវត្តគម្រោង។ យុទ្ធសាស្រ្ត/ការអនុវត្តទំនាក់ទំនងប្រភេទផ្សេងៗគ្នា រួមមាន ការសម្តែងតួ និងលំហាត់និទានរឿង ត្រូវបានប្រើនៅតាមមូលដ្ឋានដើម្បីកៀរគរសហគមន៍។ លំហាត់ទាំងមូលមានប្រយោជន៍ក្នុងការបង្កើតយុទ្ធសាស្រ្តទំនាក់ទំនងការផ្លាស់ប្តូរឥរិយាបទសម្រាប់គម្រោង។សិក្ខាសាលានេះក៏មានការចូលរួមពីអ្នកផ្តល់បច្ចេកវិទ្យាទំនាក់ទំនងដែលបានចែករំលែកគំរូរបស់ពួកគេដើម្បីស្វែងយល់ពីលទ្ធភាពនៃកិច្ចសហការ។ ដៃគូទំនាក់ទំនងថ្មីពីរនាក់ត្រូវបានបញ្ចូលក្នុងគម្រោងតាមរយៈសិក្ខាសាលានេះ។

**ដំណាក់កាលទី៦៖** ដើម្បីលើកកម្ពស់ដំណើរការចូលរួមរបស់ភាគីពាក់ព័ន្ធ សិក្ខាសាលាភាគីពាក់ព័ន្ធពហុភាគី ត្រូវបានរៀបចំឡើងនៅថ្នាក់ក្រុង។ ការណ៍នេះបានជួយ ជាពិសេស ក្នុងការទទួលយកភាគីពាក់ព័ន្ធក្នុងតំបន់ ទាំងមន្រ្តី និងតំណាងដែលជាប់ឆ្នោត។ (សូមមើលពិព័រណ៍ គ សម្រាប់ភាពជាដៃគូរបស់រដ្ឋាភិបាល មូលដ្ឋាន )

**ដំណាក់កាលទី៧៖** ក្នុងដំណាក់កាលនេះ អ្នកជំនាញបច្ចេកទេស ក៏បានធ្វើការកំណត់វិសាលភាពនៃដំណោះស្រាយ/បច្ចេកវិទ្យា និងបង្កើតនូវសេចក្តីសង្ខេបតាមវិស័យនៃមុខជំនាញរបស់ពួកគេ។ សេចក្តីសង្ខេបតាមវិស័យទាំងនេះ បានបន្តក្លាយជាមូលដ្ឋានសម្រាប់បង្កើតភ័ស្តុតាងដើម្បីធ្វើឱ្យមានសុពលភាពទ្រឹស្តីនៃការផ្លាស់ប្តូរ និងយុទ្ធសាស្រ្តគម្រោងដែលបានស្នើឡើង។

**ដំណាក់កាលទី៨៖** ទីបំផុត រយៈពេល ៤ ខែក្រោយមក សិក្ខាសាលា

អភិវឌ្ឍន៍ដំណោះស្រាយត្រូវបានរៀបចំជាថ្មីម្តងទៀតដែលបាននាំមកនូវអ្នកជំនាញបច្ចេកទេសនិងអ្នកដឹកនាំជាស្ត្រីដើម្បីឆ្លុះបញ្ចាំងលើគំរូគម្រោងដែលបានស្នើឡើង យុទ្ធសាស្ត្រ និងសកម្មភាពអនុវត្តន៍។

**សំណួរសំខាន់ៗ ៖**

ក) តើអ្វីទៅជាការឆ្លុះបញ្ចាំងរបស់អ្នកអំពីដំណើរការអភិវឌ្ឍន៍គម្រោង ដែលអនុវត្តដោយមូលនិធិ? តើអ្វីទៅគឺជាគុណសម្បត្តិ និងគុណវិបត្តិនៃដំណើរការបែបនេះ?

ខ) ធនធានហិរញ្ញវត្ថុ ជាញឹកញាប់ មានកំណត់។ វាតែងតែមានការដោះដូរក្នុងការចំណាយលើការអភិវឌ្ឍគម្រោងជាមួយនឹងសកម្មភាពជាក់ស្តែងរបស់គម្រោង។ តើអ្នកគិតថាពួកគេអាចមានតុល្យភាពយ៉ាងដូចម្តេច? តើអ្នកគិតថាមូលនិធិរបស់ម្ចាស់ជំនួយអាចមានសម្រាប់សកម្មភាពអភិវឌ្ឍន៍គម្រោងដែរ ឬទេ?

គ) តើអ្វីជាបញ្ហាប្រឈមសំខាន់ៗក្នុងការអភិវឌ្ឍភាពជាដៃគូពហុភាគីអន្តរវិន័យ? តើមានការរៀនសូត្រអ្វីខ្លះពីសកម្មភាពគម្រោងដែលគួរកត់ត្រាទុកនិងប្រើប្រាស់សម្រាប់ការតស៊ូមតិដើម្បីផ្តល់មូលនិធិសម្រាប់សកម្មភាពបែបនេះ?

ឃ) តើភាពជាដៃគូប្រភេទណាដែលអ្នកផ្តល់អនុសាសន៍ឱ្យអនុវត្តជាផ្លូវការ ហើយភាពជាដៃគូណាមួយដែលអាចបន្តបានក្រៅផ្លូវការ? តើអ្នកគិតថា ការបង្កើតសម្ព័ន្ធ ឬបណ្តាញផ្លូវការនឹងសមស្របជាងភាពជាដៃគូក្រៅផ្លូវការដែរឬទេ? ប្រសិនបើដូច្នេះមែន តើហេតុអ្វី?

ង) តើអ្នកសញ្ជឹងមើលតួនាទីរបស់អ្នកនៅក្នុងគម្រោងបែបនេះនៅកន្លែងណា?

**ពិព័រណ៌ ក ៖ បញ្ហាប្រឈមដំបូងនៅក្នុងវិធីសាស្ត្រដែលមានការចូលរួម**

យុទ្ធសាស្ត្រថ្មីនេះគាំទ្រដល់វិធីសាស្ត្រដែលមានការចូលរួម។ ទោះយ៉ាងណាក៏ដោយ ភារកិច្ចនេះបានប្រែក្លាយជាការងារដែលពិបាកបំផុតនៃដំណាក់កាលអភិវឌ្ឍន៍គម្រោង។ ដូចបុគ្គលម្នាក់ដែលបានណែនាំអំពីការប្រែប្រួលអាកាសធាតុជាលើកដំបូងដល់អ្នកដឹកនាំជាស្ត្រី ដោយពិពណ៌នាអំពីវាថា៖

" ការពិភាក្សាមួយដែលខ្ញុំគិតថានឹងងាយស្រួលបានប្រែទៅជាភារកិច្ចមួយដ៏គួរឱ្យភ័យខ្លាចនៅពេលដែលខ្ញុំដឹងថាខ្ញុំកំពុងនិយាយជាមួយស្ត្រីដែលមានការអប់រំតិចតួចឬមិនមានការអប់រំដែលមិនធ្លាប់ដឹងពីការកើនឡើងកម្តៅសកលហើយប៉ុន្តែពួកគេគឺជាមនុស្សដែលខ្ញុំដឹងថានឹងរងផលប៉ះពាល់បំផុតពីឥទ្ធិពលនៃអាកាសធាតុដែលកំពុងប្រែប្រួល។ ខ្ញុំមិនប្រើពាក្យបច្ចេកទេសទេ ដូច្នេះខ្ញុំបានធ្វើអ្វីដែលខ្ញុំដឹងល្អបំផុតហើយបានសួរស្ត្រីទាំងនោះពីអ្វីដែលពួកគេកំពុងជួបប្រទះអំពីស្ថានភាពអាកាសធាតុដែលកំពុងប្រែប្រួល ហើយជាការពិត ស្ត្រីទាំងនោះមិនត្រឹមតែដឹងពីអ្វីដែលកំពុងកើតឡើងនោះទេ ប៉ុន្តែពួកគេកំពុងបង្កើតយន្តការដើម្បីទប់ទល់នឹងវា។ ការណ៍នេះធ្វើឱ្យខ្ញុំគិតថាប្រសិនបើគ្រាន់តែជាបទពិសោធន៍អាចជួយស្ត្រីមួយក្រុមដោះស្រាយបញ្ហាជាច្រើន តើអ្វីដែលពួកគេមិនអាចធ្វើនោះ ប្រសិនបើពួកគេមានចំណេះដឹងវិទ្យាសាស្ត្រ សមត្ថភាព និងបច្ចេកវិទ្យានោះ។ តើនេះអាចជាមធ្យោបាយមួយដើម្បីបង្កើតផែនការបន្សាំដែលអាចអនុវត្តបានឬទេ?"

មូលនិធិ បានចាប់ផ្តើមបញ្ហានៃភាពធន់នឹងអាកាសធាតុជាមួយអ្នកជំនាញបច្ចេកទេសថ្នាក់ទីក្រុង។ ការពិភាក្សាដំបូងត្រូវបានកំណត់ចំពោះការយល់ដឹងអំពីបញ្ហានេះ និងរបៀបដែលវាប៉ះពាល់ដល់ស្ត្រីពីសហគមន៍អនាធិបតេយ្យ។ បន្ទាប់មកមូលនិធិក៏បានរៀបចំវគ្គបណ្តុះបណ្តាលជាក់លាក់ស្តីពីការប្រែប្រួលអាកាសធាតុសម្រាប់អ្នកដឹកនាំជាស្ត្រី ដែលមានគោលបំណងជួយស្ត្រីឱ្យអភិវឌ្ឍចំណេះដឹង និងដើម្បីដោះស្រាយបញ្ហាបានប្រសើរជាងមុនអំពីផលប៉ះពាល់ និងបញ្ហាប្រឈមដែលពួកគេចែករំលែកក្នុងនាមជាសហគមន៍មួយ។

ការផ្ទេរចំណេះដឹងផ្នែកវិទ្យាសាស្ត្រទៅបុគ្គលិកថ្នាក់មូលដ្ឋាន និងអ្នកដឹកនាំជាស្ត្រី គឺពិបាក។ វិទ្យាសាស្ត្រអាកាសធាតុ គឺជាប្រធានបទបច្ចេកទេសសុទ្ធសាធ ហើយដើម្បីបណ្តុះបណ្តាលស្ត្រីដែលបានទទួលការអប់រំ ឬជាញឹកញាប់មិនចេះអក្សរ ត្រូវការវិធីសាស្ត្រ ពិសេសក្នុងការភ្ជាប់បញ្ហាបច្ចេកទេសជាមួយនឹងផលប៉ះពាល់ប្រចាំថ្ងៃ។ វគ្គបណ្តុះបណ្តាលទាំងនេះមិនត្រឹមតែជាលំហាត់សិក្សាប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជាទម្រង់ចូលរួមដើម្បីបង្ហាញពីផលប៉ះពាល់ និងដំណោះស្រាយដែលពាក់ព័ន្ធសម្រាប់ពួកគេ។ ដូច្នេះវិធីសាស្ត្រដែលប្រើក្នុងវគ្គបណ្តុះបណ្តាលក៏ត្រូវដោះស្រាយជាមួយនឹងទស្សនទាន និងអនុញ្ញាតឱ្យសិក្ខាកាមប្រើប្រាស់ការយល់ដឹងជាមួយនឹងភាពស្មុគស្មាញដែលមានស្រាប់នៃការភ្ជាប់ទំនាក់ទំនងនិងអន្តរទំនាក់ទំនងរវាងបញ្ហាផ្សេងៗដើម្បីរកដំណោះស្រាយ។ ដំណោះស្រាយអាកាសធាតុសាមញ្ញនៃការសាងសង់ស្រះបញ្ចូលទឹក អាចស្តាប់ទៅដូចជាដំណោះស្រាយពាក់ព័ន្ធនឹងការបញ្ចូលទឹកក្រោមដី ប៉ុន្តែអាចបាត់បង់ភាពពាក់ព័ន្ធ និងគោលបំណងរបស់វានៅក្នុងរលកកម្តៅខ្លាំង ឬវាអាចបង្កើតបញ្ហានៃជំងឺដែលឆ្លងតាមភ្នាក់ងារចម្លងជំងឺឬវាអាចក្លាយជាប្រភពទឹកក្រខ្វក់ប្រសិនបើភ្ជាប់ទៅនឹងបំពង់បង្ហូរ ប្រសិនបើបញ្ហាសង្គម សេដ្ឋកិច្ច បរិស្ថាន គោលនយោបាយ និងផែនការ ដែលពាក់ព័ន្ធទាំងអស់មិនត្រូវបានពិចារណានៅក្នុងបរិបទអាកាសធាតុនោះ។

**ពិព័រណ៌ ខ៖ ភាពជាដៃគូបច្ចេកទេស**

បញ្ហាប្រឈមនៃការអភិវឌ្ឍ និងការកសាងភាពធន់ ដែលប្រជាជនក្រីក្រនៅទីក្រុងជួបប្រទះ តម្រូវឱ្យមាន ការស្រាវជ្រាវ និងនវានុវត្តន៍ថ្មីៗ។ ទោះយ៉ាងណាក៏ដោយ ការពង្រីកទំហំនវានុវត្តន៍ ជាញឹកញាប់ប្រឈមមុខនឹងឧបសគ្គដែលទាក់ទងនឹងលក្ខណៈពហុវិមាតនិងពហុភាគីនៃបញ្ហាប្រឈមក្នុងសង្គម។ ការដោះស្រាយបញ្ហានេះតម្រូវឱ្យមានវិធីសាស្ត្រថ្មីមួយដែលវឌ្ឍនភាពសង្គម និងបច្ចេកវិទ្យា វិវត្តរួមគ្នាតាមរយៈការសន្ទនាដោយ

ផ្ទាល់រវាងវិទ្យាសាស្រ្តធម្មជាតិ និងសង្គម និងសកម្មភាពរួមគ្នារវាងសហគមន៍ និងអ្នកជំនាញបច្ចេកទេស។

ដោយសារលក្ខណៈពហុវិមាត្រនៃគម្រោង អ្នកជំនាញបច្ចេកទេស ៤ ប្រភេទបានចូលរួមជាផ្នែកមួយនៃគម្រោង ៖

ក) សហគ្រិន និងអាជីវកម្មប្រកបដោយនវានុវត្តន៍ ដែលបានបង្ហាញពីផលិតផល/សេវាកម្មរបស់ពួកគេនៅក្នុងតំបន់អនាធិបតេយ្យ។ ពួកគេបានស្វែងរកជំនួយពី មូលនិធិដើម្បីទទួលបានការចូលទៅក្នុងសហគមន៍និងទទួលបានកន្លែងដើម្បីបង្ហាញពីផលិតផលរបស់ពួកគេ។ ចំណាប់អារម្មណ៍របស់ មូលនិធិក្នុងការសម្របសម្រួលនេះ គឺដើម្បីបង្កើតកញ្ចប់នៃជម្រើសប្រកបដោយប្រសិទ្ធផល និងប្រសិទ្ធភាពសម្រាប់សហគមន៍ក្នុងការជ្រើសរើសដោយផ្អែកលើតម្រូវការ សេចក្តីប្រាថ្នា និងស្ថានភាពហិរញ្ញវត្ថុរបស់ពួកគេ។ ក្នុងកំឡុងពេលនៃគម្រោង ដៃគូជាច្រើនដែលទាក់ទងនឹងដំណោះស្រាយកែលម្អដំបូលផ្ទះ ផលិតផលចម្រោះទឹកបច្ចេកវិទ្យាកំប៉ុសបច្ចេកវិទ្យាសំណង់ជាដើមត្រូវបានស្វែងយល់។

ខ) វិទ្យាស្ថាន-សាកលវិទ្យាល័យសិក្សា និងវិទ្យាស្ថានស្រាវជ្រាវសាធារណៈ ដែលបានបើកដំណើរការ វិធីសាស្រ្តការគិតជាប្រព័ន្ធបានផ្តល់នូវធាតុចូលជាក់លាក់និងវគ្គបណ្តុះបណ្តាលបច្ចេកទេស និងការបង្កើតផលិតផលចំណេះដឹង (សៀវភៅណែនាំបច្ចេកទេស អូឌីយ៉ូ/វីដេអូ ជាដើម)។ វិទ្យាស្ថានសំខាន់ៗដែលចូលរួមក្នុងការគាំទ្រផ្នែកបច្ចេកទេស គឺវិទ្យាស្ថានដែលបានចូលរួមយ៉ាងសកម្មក្នុងការអនុវត្តគម្រោងស្រាវជ្រាវអនុវត្តនៅក្នុងតំបន់ និងវិទ្យាស្ថាន ដែលចង់ដឹកនាំក្នុងការវាយតម្លៃគម្រោងជាទម្រង់ និងបូកសរុប ដើម្បីអាចចងក្រងជាមេរៀនសម្រាប់ផ្សព្វផ្សាយ និងការរៀនសូត្រ។

គ) អង្គការសង្គមស៊ីវិល (CSOs) និងនវានុវត្តន៍សង្គម៖ CSOs នៅតាមមូលដ្ឋានដែលមានការផ្តោត និងជំនាញរៀបចំផ្សេងៗគ្នា ក៏ត្រូវបានចូលរួមនៅក្នុងដំណើរការនេះដែរ។ បុគ្គលសំខាន់ក្នុងចំណោមពួកគេ គឺអ្នកដែលធ្វើការផ្នែកទិដ្ឋភាពទំនាក់ទំនង និងការផ្លាស់ប្តូរឥរិយាបថនៃគម្រោង។ ផ្នែកទាំងនេះរួមបញ្ចូលទាំងអ្នកដែលបានធ្វើការលើការអប់រំបរិស្ថាន និងអាកាសធាតុ ក៏ដូចជាដៃគូបច្ចេកវិទ្យាទំនាក់ទំនង ដូចជា Vaani ចល័ត (សម្រាប់ទំនាក់ទំនងតាមទូរស័ព្ទ)។ ចំណុចលេចធ្លោនៃគម្រោងគឺថា ទីភ្នាក់ងារទាំងនេះមិនបានធ្វើការដាច់ដោយឡែកពីគ្នានោះទេ ប៉ុន្តែបានរួមគ្នា ដើម្បីគាំទ្រគម្រោង និងអភិវឌ្ឍន៍យុទ្ធសាស្រ្តទំនាក់ទំនងសមាហរណកម្ម និងប្រកបដោយប្រសិទ្ធភាព។

ឃ) អ្នកជំនាញលើបញ្ហាប្រធានបទផ្សេងៗគ្នា ដែលបានបង្ហាញចំណាប់អារម្មណ៍ក្នុងការធ្វើការដោយផ្ទាល់ជាមួយសហគមន៍/មូលដ្ឋាន ដើម្បីបណ្តុះបណ្តាលពួកគេ ឬរចនាផលិតផលនិងសេវាកម្មសម្រាប់ពួកគេ។ គម្រោងនេះទទួលបានអត្ថប្រយោជន៍ពីសេវាកម្មអ្នកជំនាញជាង ២០ នាក់ មកពីវិស័យសុខាភិបាល ការគ្រប់គ្រងភ្នាក់ងារចម្លងជំងឺ ការគ្រប់គ្រងគ្រោះមហន្តរាយ ការគ្រប់គ្រងទឹក ការវិភាគការប្រែប្រួលឥរិយាបថ និងការគ្រប់គ្រងហានិភ័យ និងបច្ចេកវិទ្យាព័ត៌មាន។

ការទាក់ទាញដំបូងសម្រាប់ដៃគូបច្ចេកទេសភាគច្រើនដើម្បីសហការគឺសមត្ថភាពរបស់ មូលនិធិ ក្នុងការកៀរគរសហគមន៍អនាធិបតេយ្យ ជាពិសេសស្រ្តី។ វិធីសាស្រ្តរៀបចំគម្រោងអាចឱ្យដៃគូមានទំនាក់ទំនងផ្ទាល់ជាមួយអ្នកដឹកនាំជាស្រ្តី។ឧបសគ្គចម្បងមួយចំពោះនវានុវត្តន៍ និងការផ្ទេរចំណេះដឹងដែលបានកំណត់ដោយគម្រោងគឺជំនាញនិងសមត្ថភាពរបស់អ្នកជំនាញបច្ចេកទេសដើម្បីធ្វើការជាមួយសហគមន៍។ ភាពជាដៃគូបច្ចេកទេស និងការចូលរួមទាំងនេះត្រូវបានរួមបញ្ចូលនៅក្នុងដំណាក់កាលរៀបចំគម្រោង ដែលធ្វើឱ្យដំណើរការនៃការចូលរួមមានភាពងាយស្រួល។

បច្ចុប្បន្ន ការចូលរួមរបស់អ្នកជំនាញជាមួយសហគមន៍កើតឡើងតាមវិធីពីរ ៖

ក) សម្រាប់ការស្រាវជ្រាវ នៅពេលវិទ្យាស្ថានស្រាវជ្រាវបញ្ជូននិស្សិត ឬអ្នកអង្កេតការណ៍របស់ខ្លួនទៅកាន់សហគមន៍អនាធិបតេយ្យដើម្បីទទួលបានទិន្នន័យដែលនឹងជូនដំណឹងដល់គម្រោងស្រាវជ្រាវរបស់ពួកគេ។ នៅទីនេះ តួនាទីរបស់សហគមន៍ត្រូវបានកំណត់ជាចម្បងត្រឹមតែជាអ្នកផ្តល់ព័ត៌មានដោយគ្មានការត្រួតពិនិត្យ ឬត្រួតពិនិត្យតិចតួចលើការវិភាគនិងការសន្និដ្ឋាន។ ក្នុងករណីជាច្រើន លទ្ធផលប្រហែលជាមិនត្រូវបានចែករំលែកជាមួយសហគមន៍ឡើយ។

ខ) សម្រាប់គោលបំណងទីផ្សារ នៅពេលអ្នកធ្វើនវានុវត្តន៍ និងអាជីវកម្មដែលមានផលិតផលបង្កើតឡើងចង់ផ្សព្វផ្សាយផលិតផលរបស់ពួកគេ។នៅក្នុងគំរូទីផ្សារបច្ចុប្បន្នសហគមន៍អនាធិបតេយ្យនៅទីក្រុង គឺជាអ្នកប្រើប្រាស់គោលដៅ ជាពិសេសអ្នកដែលមានកម្រិតជីវភាពខ្ពស់ជាងពីរ៉ាមីតភាពក្រីក្រ។

ទម្រង់នៃការចូលរួមទាំងពីរនេះ មិនគ្រប់គ្រាន់ ដើម្បីដោះស្រាយបញ្ហានៃការប្រែប្រួលអាកាសធាតុដែលជួបប្រទះដោយសហគមន៍អនាធិបតេយ្យដោយសារមូលហេតុជាច្រើន។ ទីមួយ ផលិតផល ឬសេវាកម្មដែលផ្តល់ជូនជាញឹកញាប់ ត្រូវបានរៀបចំឡើងក្នុងលក្ខណៈទូទៅ និងមិនសមស្របសម្រាប់សហគមន៍អនាធិបតេយ្យ។ ផលិតផល ឬសេវាកម្មទាំងនោះ ត្រូវការការរៀបចំ ដែលត្រូវបានគ្រោងទុកសម្រាប់ដង់ស៊ីតេ មានលាយចម្រុះគ្នាឬប្រើបានច្រើនបែប ផ្អែកលើការវិនិយោគដែលមានស្រាប់របស់ពួកគេ គឺចំណាយតិច និងក្នុងពេលតែមួយសមដូចក្តីប៉ងប្រាថ្នា។ ហេតុដូច្នេះ ទោះបីជាមានដំណោះស្រាយធន់នឹងអាកាសធាតុសម្រាប់ភាពធន់នឹងកម្តៅនិងការគ្រប់គ្រងទឹកមានរួចទៅហើយក៏ដោយ ក៏ផលិតផល ឬសេវាកម្មទាំងនោះ តែងតែមិនអាចទទួលបាននិងមិនមានគំរូដើម្បីបំពេញតម្រូវការជាក់លាក់របស់សហគមន៍ទាំងនេះ។ ជាញឹកញាប់ បច្ចេកវិទ្យាដែលផ្តល់ជូនមិនត្រូវគ្នាជាមួយហេដ្ឋារចនាសម្ព័ន្ធដែលមានស្រាប់ឬឧបសគ្គ

លំហរដែលមានស្រាប់។ការណ៍នេះកើតឡើងជាចម្បងដោយសារអ្នកធ្វើនវានុវត្តន៍មិនមានកន្លែងដើម្បីសាកល្បងគំរូដើមនៃផលិតផលដោយផ្ទាល់ជាមួយសហគមន៍នៅតំបន់អនាធិបតេយ្យ ហើយក៏មិនមានការសម្របសម្រួលសម្រាប់ការធ្វើឱ្យគំរូដើមមានសុពលភាពដែរ។ សេវាកម្មដ៏សំខាន់មួយដែល មូលនិធិបាននាំមកក្នុងភាពជាដៃគូនេះ គឺជាការសម្របសម្រួល ដើម្បីសាកល្បង និង ផ្តល់មតិត្រឡប់លើគំរូដើមនិងដើម្បីធ្វើឱ្យដំណោះស្រាយមានសុពលភាព។

ទីពីរ អាជីវកម្មត្រូវមានគំរូខ្សែសង្វាក់ផ្គត់ផ្គង់សមស្របដែលអាចឱ្យពួកគេឈានទៅដល់ការផ្តល់ផលិតផលដល់សហគមន៍ក្នុងបរិមាណច្រើន។ គំរូដែលមានមូលដ្ឋានលើអ្នកចែកចាយនាពេលបច្ចុប្បន្ននៃអាជីវកម្មភាគច្រើនដែលទាមទារឱ្យមានការវិនិយោគខ្ពស់ជាមុន មិនទទួលបានជោគជ័យនៅក្នុងសហគមន៍អនាធិបតេយ្យ ដែលសមត្ថភាពក្នុងការទូទាត់មានកម្រិតទាបហើយចំណូលដំបូង គឺមិនសូវធ្វើឱ្យអាជីវកម្មមានភាពរឹងមាំឡើយ។ ទោះបី មូលនិធិមានការពិបាកក្នុងការធ្វើឱ្យមានការផ្លាស់ប្តូរធំៗនៅក្នុងការងារនេះក៏ដោយក៏អ្នកដឹកនាំជាស្ត្រីអាចធ្វើឱ្យមានភាពលេចធ្លោ តាមរយៈការក្លាយជាភ្នាក់ងារលក់ និងទីផ្សារសម្រាប់ផលិតផលជាច្រើន។ការណ៍នេះជួយផ្សព្វផ្សាយផលិតផលនៅក្នុងសហគមន៍ ហើយក៏ជាប្រភពនៃការប្រកបរបស់ចិញ្ចឹមជីវិតរបស់អ្នកដឹកនាំជាស្ត្រីផងដែរ។

ទីបី ថ្លៃដើមគឺជាបញ្ហាប្រឈម។ នវានុវត្តន៍ភាគច្រើននៅដំណាក់កាលដំបូង គឺចំណាយច្រើន ជាពិសេសដោយសាររោងចក្រមិនអាចសម្រេចបាននូវទំហំសេដ្ឋកិច្ច។នេះធ្វើឱ្យផលិតផលមានតម្លៃថ្លៃហើយជាញឹកញាប់មិនមានអ្នកទិញច្រើនទេនៅកម្រិតអនាធិបតេយ្យ។ ដោយសារអ្នករស់នៅក្នុងតំបន់អនាធិបតេយ្យមានលទ្ធភាពតិចតួចក្នុងការទទួលបានហិរញ្ញវត្ថុជាផ្លូវការពួកគេថែមទាំងមិនមានលទ្ធភាពបង់រំលស់បានទៀតផង។ មូលនិធិបាន និងកំពុងធ្វើការឆ្ពោះទៅរកលទ្ធភាពនេះ ដោយភ្ជាប់អ្នករស់នៅក្នុងតំបន់អនាធិបតេយ្យទៅធនាគារផ្លូវការ និងសហករណ៍ឥណទានក៏ដូចជាដោយមានមូលធនវិលជុំ ដែលបង្កើតជាពិសេសសម្រាប់ផ្តល់ហិរញ្ញប្បទានដល់ផលិតផលទាំងនោះ។ នេះក៏ជាការទាក់ទាញអ្នកធ្វើនវានុវត្តន៍ ក៏ដូចជាអាជីវកម្ម ដើម្បីចាប់ដៃគូជាមួយ MHT។

ទីបួន ទំនាក់ទំនង គឺជាបញ្ហាប្រឈម។ គម្រោង CBA ក៏តម្រូវឱ្យមានការព្យាយាមរៀបចំពីលើចុះក្រោមដើម្បីអប់រំប្រជាជនអំពីហានិភ័យ ផលប៉ះពាល់ និងជម្រើសបច្ចេកវិជ្ជា ដែលមានចំពោះការប្រែប្រួលអាកាសធាតុ។ ជាអកុសល ប្រព័ន្ធចំណេះដឹងវិទ្យាសាស្ត្របច្ចុប្បន្នផ្តោតលើការកាត់បន្ថយផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុចំពោះការផ្លាស់ប្តូរជីវសាស្ត្រជាមួយនឹងសញ្ញាណដែលបានកំណត់ជាមុនអំពីអ្វីដែលគួរ និងអាចធ្វើបាន។ វាមានសារៈសំខាន់ខ្លាំងណាស់ ក្នុងការធ្វើឱ្យការចែករំលែកចំណេះដឹងរវាងសហគមន៍ និងអ្នកជំនាញបច្ចេកទេសកើតមានឡើងដោយស្មើភាពគ្នា។ ទិដ្ឋភាពសំខាន់មួយ នៃគម្រោង គឺដើម្បីជួយសម្រួលដល់ដំណើរការ និងវេទិកាដែលអាចឱ្យសហគមន៍ និងអ្នកជំនាញបច្ចេកទេស (អ្នកវិទ្យាសាស្ត្រសង្គម និងធម្មជាតិ) ធ្វើអន្តរកម្ម និងរួមគ្នាបង្កើតដំណោះស្រាយដែលមានភាពធន់។ឧទាហរណ៍ដ៏ល្អមួយនៃរឿងនេះត្រូវបានគេសង្កេតឃើញនៅពេលដែលដៃគូភូគព្ភសាស្ត្រពិតជាបានអនុវត្តវិធីសាស្ត្រស្រាវជ្រាវ ដែលមានការចូលរួមក្នុងការគ្រប់គ្រងទឹកក្រោមដី ជាលើកដំបូង ហើយថែមទាំងបានដាក់និស្សិតស្រាវជ្រាវមួយអំឡុងពេលនៃរយៈពេលគម្រោងដើម្បីប្រាស្រ័យទាក់ទងនិងធ្វើការដោយផ្ទាល់ជាមួយសហគមន៍។

### ពិព័រណ៍ គ ៖ ភាពជាដៃគូរបស់រដ្ឋាភិបាលមូលដ្ឋាន

មូលនិធិបានទទួលស្គាល់ថាដើម្បីមានប្រសិទ្ធភាពក្នុងការជះឥទ្ធិពលដល់ការធ្វើសេចក្តីសម្រេចចិត្តគោលនយោបាយ"កម្រិតខ្ពស់" អង្គការមូលដ្ឋាន ត្រូវធ្វើការយ៉ាងជិតស្និទ្ធជាមួយរដ្ឋាភិបាលមូលដ្ឋាន។ តាមពិត ទៅគន្លឹះនៃភាពជោគជ័យរបស់ មូលនិធិក្នុងរយៈពេលប៉ុន្មានឆ្នាំមកនេះ ផ្អែកលើការពិតដែលថា មូលនិធិមិនផ្តោតតែលើការកំណត់អត្តសញ្ញាណនៃគម្លាតក្នុងការអនុវត្តកម្មវិធីផ្តោតលើប្រជាជនប៉ុណ្ណោះទេ ប៉ុន្តែធ្វើការរួមគ្នាជាមួយរដ្ឋាភិបាលមូលដ្ឋាន ដើម្បីបង្កើតដំណោះស្រាយដែលគាំទ្រអ្នកក្រីក្រ។ នេះតម្រូវឱ្យមានការទំនាក់ទំនងឥតឈប់ឈរជាមួយមន្ត្រីស៊ីវិល ធ្វើឱ្យពួកគេយល់ពីតម្រូវការរបស់ប្រជាជនខណៈពេលដែលយល់អំពីដំណើរការសកម្មនៃនីតិវិធី ធ្វើចលនាខ្សែអាត់ក្រហម (Manoeuvring Red Tape) ខណៈពេលដែលនៅសេសសល់ក្នុងក្របខ័ណ្ឌបទប្បញ្ញត្តិ ការបង្ហាញពីវិធីសាស្ត្រដែលអាចដំណើរការបាននៅតាមមូលដ្ឋាន និងការបណ្តុះបណ្តាលអង្គភាពនៅមូលដ្ឋានក្នុងទីក្រុង (ULBs) លើវិធីសាស្ត្រទាំងនេះ។

តួនាទីដ៏សំខាន់មួយទៀតរបស់ មូលនិធិគឺការធ្វើឱ្យមានការសម្របសម្រួល និងការប្រមូលផ្តុំរួមគ្នារវាងនាយកដ្ឋានជាច្រើននៃ ULBs។ មានតួអង្គសំខាន់ពីរនៅក្នុងរដ្ឋាភិបាលមូលដ្ឋានដែលត្រូវបានរួមបញ្ចូលជាដៃគូគម្រោង៖

#### សាជីវករក្រុង (ក្រុមប្រឹក្សាក្នុងមូលដ្ឋាន)[13]

តួនាទីរបស់ពួកគេ គឺត្រួតពិនិត្យសកម្មភាពរបស់ស្ថាប័នមូលដ្ឋានក្នុងទីក្រុងក្នុងការផ្តល់សេវាកម្មទីក្រុងទាំងអស់និងធានាប្រសិទ្ធភាពក្នុងតំបន់របស់ពួកគេរៀងៗខ្លួន។ មូលនិធិ បានប្រមូលផ្តុំ និងបណ្តុះបណ្តាលអ្នកដឹកនាំជាស្ត្រីប្រកបដោយជោគជ័យពីសហគមន៍ក្រីក្រ ដើម្បីចូលរួមជាមួយក្រុមប្រឹក្សា និងប្រើប្រាស់ថវិការបស់ពួកគេដើម្បីនាំមកនូវភាពប្រសើរឡើងដល់តំបន់របស់ពួកគេ។ ដោយមានការចូលរួមយ៉ាងសកម្ម និងការគាំទ្រផ្នែកហិរញ្ញវត្ថុពីក្រុមប្រឹក្សាមូលដ្ឋានអ្នកដឹកនាំជាស្ត្រីអាចនាំមកនូវភាពប្រសើរឡើងជាក់ស្តែងនៅក្នុងតំបន់របស់ពួកគេ។

#### បុគ្គលិកបច្ចេកទេសនៃរដ្ឋាភិបាលមូលដ្ឋាន

រួមជាមួយអ្នកតំណាងដែលបានជ្រើសរើសតាមការបោះឆ្នោត សាជីវកម្មក្រុងនៅប្រទេសឥណ្ឌា ក៏មានក្រុមប្រឹក្សាយោបល់ប្រតិបត្តិ ដែលដឹកនាំដោយស្នងការក្រុងផងដែរ។ បន្ទាប់មកសាជីវកម្មទាំងនេះត្រូវបានបែងចែកទៅជាការិយាល័យកម្រិតភូមិភាគ/តំបន់ និងនាយកដ្ឋានមុខងារផ្សេងៗគ្នា ដូចជា សុខភាពសាធារណៈ និងវិស្វកម្មទឹក និងអនាម័យបរិស្ថាន ការអប់រំនៅសាលា។ល។ចំណុចល្អប្លែកពីគេរបស់មូលនិធិគឺការបណ្តុះបណ្តាលអ្នកដឹកនាំជាស្ត្រី និងបុគ្គលិកកម្មវិធី ដើម្បីធ្វើការយ៉ាងជិតស្និទ្ធជាមួយបុគ្គលិកបច្ចេកទេសក្នុងមូលដ្ឋាននៃ ULB ដើម្បីយកឈ្នះឧបសគ្គទាំងនេះដោយផ្តល់អនុសាសន៍កែលម្អ ដំណើរការផ្លាស់ប្តូរគោលនយោបាយ និងគោលការណ៍ណែនាំប្រតិបត្តិការ និងយន្តការជំនួសដើម្បីជួយផ្សព្វផ្សាយគោលនយោបាយនិងកម្មវិធីរបស់ពួកគេដល់ជនក្រីក្រ។

ក្នុងរយៈពេលជាច្រើនឆ្នាំកន្លងមកនេះ មូលនិធិបានធ្វើការដោយជោគជ័យជាមួយរដ្ឋាភិបាលមូលដ្ឋាន និងបានរួមចំណែកយ៉ាងសំខាន់ក្នុងការនាំមកនូវការផ្លាស់ប្តូរគោលនយោបាយ និងកម្មវិធីសំខាន់ៗដែលបានជួយឱ្យជនក្រីក្រទទួលបានសេវាកម្មល្អប្រសើរ។រដ្ឋាភិបាលមូលដ្ឋានក៏ទទួលស្គាល់នូវគុណតម្លៃដែលមូលនិធិនាំមកក្នុងការដោះស្រាយបញ្ហាឧបសគ្គក្នុងការអនុវត្តនៅតាមមូលដ្ឋានផងដែរ។

[13]សាជីវករ/ក្រុមប្រឹក្សាក្រុងបង្កើតជាក្រុមប្រឹក្សាយោបល់ដែលបានជ្រើសរើសតាមការបោះឆ្នោតរបស់រដ្ឋាភិបាលក្នុងប្រទេសឥណ្ឌា

អ្នកដឹកនាំជាស្ត្រីលើភាពជាដៃគូរបស់រដ្ឋា ភិបាល

"ជាដំបូងនៅពេលដែលយើងគិតចង់ធ្វើការជាមួយរដ្ឋាភិបាលក្នុងតំបន់ យើងតែងតែមានអារម្មណ៍ថាវាពិបាក។ ប៉ុន្តែប៉ុន្មានឆ្នាំមកនេះខ្ញុំបានទទួលការបណ្តុះបណ្តាលពីមន្ត្រីទាក់ទងនឹងរចនាសម្ព័ន្ធ និងមុខងារនៃប្រព័ន្ធអភិបាលកិច្ចមូលដ្ឋាន។ យើងអាចផ្លាស់ប្តូរ និងដេញដោលការយល់ឃើញរបស់ប្រជាជនអំពីរដ្ឋាភិបាល"។

មន្ត្រីរដ្ឋាភិបាលលើភាពជាដៃគូសហគមន៍

"ខ្ញុំបានធ្វើការជាមួយអ្នកដឹកនាំជាស្ត្រីទាំងនេះអស់រយៈពេលជាច្រើនឆ្នាំមកហើយ។ ការគាំទ្ររបស់អ្នកដឹកនាំជាស្ត្រីទាំងនេះមានសារៈសំខាន់ក្នុងការអនុវត្តគោលនយោបាយនិងផែនការរបស់រដ្ឋាភិបាលនៅក្នុងតំបន់អនាធិបតេយ្យ។ រដ្ឋាភិបាលមានការខ្វះខាតនៅពេលនិយាយដល់ការបញ្ចុះបញ្ចូលប្រជាជន និងធានាបានការគាំទ្ររបស់ពួកគេចំពោះតម្រូវការអភិវឌ្ឍ។ នេះគឺជាកន្លែងដែល CSOs និងអ្នកដឹកនាំសហ គមន៍បានដើរតួនាទីយ៉ាងសំខាន់ក្នុងការសម្របសម្រួលរវាងសហគមន៍និងរដ្ឋាភិបាល។ តាមវិធីនេះយើងអាចបម្រើតំបន់អនាធិបតេយ្យជាច្រើននៅក្នុងទីក្រុង"។

**ផ្នែក គ ៖ ការប្រតិបត្តិគម្រោងតាពធន់ផ្អែកលើសហគមន៍**

ស្ថាប័នមូលនិធិក៏អាចទទួលបានមូលនិធិគម្រោងសម្រាប់រយៈពេលពីរឆ្នាំ។នេះគឺជាឱកាស និងជាបញ្ហាប្រឈម។គម្រោងផ្អែកលើសហគមន៍ទាមទារឱ្យមានវិធីសាស្ត្រជាបន្តនិងរយៈពេលវែងដើម្បីបង្កើតការជឿទុកចិត្តរវាងភាគីពាក់ព័ន្ធនានាផ្តល់លទ្ធភាពក្នុងការរៀនសូត្រនិងចែករំលែកចំណេះដឹងសម្របសម្រួលការធ្វើផែនការ និងប្រមូលការគាំទ្រសម្រាប់សកម្មភាពភាពធន់ដោយខ្លួនឯង។

ការសម្រេចបានការងារទាំងនេះក្នុងរយៈពេលពីរឆ្នាំ គឺជាមហិច្ឆតាហើយក្នុងពេលជាមួយគ្នានេះដែរក៏ជាឱកាសដើម្បីបង្ហាញពីគំរូការងារនៃសកម្មភាពភាពធន់ដែលដឹកនាំដោយស្ត្រីនៅតំបន់អនាធិប តេយ្យក្នុងទីក្រុងដែលអាចត្រូវបានចម្លងយកមកពង្រីក និងផ្តល់ជាការសិក្សាអំពីដំណើរការរៀបចំគោលនយោបាយនិងផែនការ។ដូច្នេះគម្រោងនេះបានបង្កើតយុទ្ធសាស្ត្រអនុវត្តកម្រិតគ្រួសារ និងតំបន់អនាធិបតេយ្យរួមគ្នាដែលត្រូវអនុវត្តក្នុងរយៈពេលពីរឆ្នាំដូចដែលអាចមើលឃើញក្នុងរូបទី ១។ មូលដ្ឋានគ្រឹះនៃគម្រោងគឺការរៀបចំ និងការកៀរគរស្ត្រីពីសហគមន៍អនាធិបតេយ្យក្រីក្រដើម្បីបង្កើតសហគមន៍ផ្ទាល់ខ្លួន។អង្គការសហគមន៍មូលដ្ឋាន នីមួយៗមានពី២០០ ទៅ២៥០ គ្រួសារ។

ក្រុមដែលមានស្ត្រីពី ១៥ ទៅ ២៥ នាក់ ដែលតំណាងឱ្យគ្រួសារទាំងនេះត្រូវបានបណ្តុះបណ្តាលអំពីសកម្មភាពសហគមន៍ភាពជាអ្នកដឹកនាំនិងអភិបាលកិច្ចទីក្រុង។ជាទូទៅក្រុមដែលមានស្ត្រីពី ១០ ទៅ ១២ នាក់ នឹងលេចចេញជាអ្នកដឹកនាំក្នុងកំឡុងពេលដំណើរការបណ្តុះបណ្តាល។ អ្នកដឹកនាំក្រុមនេះត្រូវបានគេហៅថាក្រុមសកម្មភាពសហគមន៍ ( CAG )។បន្ទាប់មកក្រុមCAG ក្លាយជាប្រព័ន្ធគាំទ្រនៅក្នុងតំបន់អនាធិបតេយ្យសម្រាប់ស្ត្រីក្នុងការធ្វើអន្តរកម្មយ៉ាងសកម្មជាមួយស្ថាប័នរដ្ឋាភិបាល និងសាជីវកម្មក្រុងនិងទទួលបន្ទុកលើដំណើរការកែលម្អតំបន់អនាធិបតេយ្យ។

CAGs បានលើកកម្ពស់មិនត្រឹមតែអ្នកដឹកនាំស្ត្រី ១០ នាក់ដែលបានរួមបញ្ចូលមកពី CBO ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានលើកទឹកចិត្តឱ្យរួមបញ្ចូលក្មេងស្រីជំទង់២នាក់ទៀតផង។ការណ៍នេះត្រូវបានធ្វើឡើងដោយមានបំណងពីរ គឺទីមួយដើម្បីឱ្យមានទស្សនវិស័យសហសម័យ និងអនាគតក្នុងក្រុម ក៏ដូចជាដើម្បីឱ្យ CAGs ទទួលបានអត្ថប្រយោជន៍ជាមួយជំនាញបច្ចេកវិទ្យា ដែលយុវនារីទាំងនេះ នឹងនាំយកមកជាមួយ។ បន្ទាប់មក សមាជិក CAGត្រូវបានបណ្តុះបណ្តាលក្នុងរយៈពេលប្រាំមួយខែលើប្រធានបទដូចខាងក្រោម ៖

១ ) ការតម្រង់ទិសឲ្យយល់ដឹងពីគម្រោង

**រូបទី ៦៨ ៖ ការរៀបចំការអនុវត្ត**




២) សារៈសំខាន់នៃសកម្មភាពរួម និងដំណើរការនៃការបង្កើត CBO/CAG
៣) រចនាសម្ព័ន្ធ និងមុខងាររបស់ ULBs និងទីភ្នាក់ងារសេវាកម្ម (រួមទាំងដំណើរទស្សនកិច្ចទៅកាន់ការិយាល័យ ULB ក្នុងតំបន់) និង
៤) កម្មវិធីអភិវឌ្ឍន៍ទីក្រុង និងសិទ្ធិរបស់ប្រជាជន។

ស្ថាប័នមូលនិធិក៏បានបង្កើតផែនការពង្រីកលទ្ធភាពនៃការបណ្តុះបណ្តាលនេះនៅក្នុងពេលវេលា និងធនធានមូលនិធិមានកំណត់ ប៉ុន្តែក៏សម្រេចបានទំហំដែលចង់បានដោយសម្រេចចិត្តផ្តើអន្តរាគមន៍នៅក្នុងទីក្រុងចំនួន ៧ នៅក្នុងប្រទេសចំនួន ៣។ ទីក្រុងទាំងនេះចែកចេញជាបីប្រភេទ ៖

- ទីក្រុងដែលបានបង្កើតឡើងដោយមានបណ្តាញអ្នកដឹកនាំជាស្ត្រី ដែលបានបង្កើតឡើងយ៉ាងល្អទាំងនៅក្នុងការតាំងទីលំនៅក្រៅផ្លូវការ និងនៅទូទាំងទីក្រុង ដែលលេចចេញពីប្រវត្តិនៃអន្តរាគមន៍យូរអង្វែងរបស់ ស្ថាប័នមូលនិធិ។
- ទីក្រុងលេចធ្លោដែលកំពុងដំណើរការបង្កើតបណ្តាញអ្នកដឹកនាំជាស្ត្រី ទាំងការតាំងទីលំនៅក្រៅផ្លូវការនិងថ្នាក់ក្រុង ដែលលេចចេញពីប្រវត្តិខ្លីជាងមុននៃការធ្វើការរបស់ ស្ថាប័នមូលនិធិនៅក្នុងទីក្រុងទាំងនេះ។
- ទីក្រុងដៃគូដែលមិនមានបណ្តាញអ្នកដឹកនាំជាស្ត្រីដែលបានបង្កើតឡើង ឬ NGO ដែលមានស្រាប់ ដែល មានបទពិសោធន៍ក្នុងការបង្កើតបណ្តាញបែបនេះ ដែលស្ថាប័នមូលនិធិបានការជាមួយអង្គការមូលដ្ឋានក្នុងការចែកបទពិសោធន៍លើគំរូបន្សាំផ្អែកលើសហគមន៍។

យុទ្ធសាស្ត្រនៃការអនុវត្តគម្រោងគឺដើម្បីសាកល្បងការអនុវត្តឧបករណ៍ឬបច្ចេកវិទ្យានៅក្នុងទីក្រុងដែលបានបង្កើតឡើងដោយយកគំរូតាមការផ្លាស់ប្តូរតាមរយៈដំណើរការនៃការរៀនសូត្រជាបន្តបន្ទាប់នៅក្នុងទីក្រុងដែលកំពុងលេចធ្លោ។ ចងក្រងឯកសារភាពខុសប្លែកគ្នានៃការប្រើប្រាស់ការអនុវត្តឧបករណ៍ឬបច្ចេកវិទ្យានៅក្នុងទីក្រុងផ្សេងៗគ្នានិងវិធីកែសម្រួលការងារទាំងអស់នេះទៅនឹងបរិបទក្នុងមូលដ្ឋាន បំប្លែងការងារទាំងនេះទៅជាផលិតផលចំណេះដឹងនិងចែករំលែកជាមួយទីក្រុងដៃគូដើម្បីធ្វើការកែតម្រូវនិងអនុម័តនៅក្នុងវិស័យការងាររបស់ពួកគេ។ ក្រុមការងារដែលផ្តោតលើការគ្រប់គ្រងចំណេះដឹង ត្រូវបានរៀបចំនៅក្នុងការិយាល័យគម្រោងដើម្បីជួយសម្រួលដល់ដំណើរការនេះ។

គម្រោងនេះក៏បានទទួលស្គាល់ផងដែរថា ការផ្ទេរចំណេះដឹងផ្នែកវិទ្យាសាស្ត្រនឹងត្រូវការការបញ្ជូនព័ត៌មានម្តងហើយម្តងទៀត ទាក់ទងនឹងការប្រែប្រួលអាកាសធាតុ និងសកម្មភាពភាពធន់ដោយមិនធ្វើឱ្យបាត់បង់ប្រយោជន៍របស់អ្នកស្រុក។ឆ្ពោះទៅរកគោលដៅនេះវាចាំបាច់ក្នុងការបង្កើតឧបករណ៍ទំនាក់ទំនងប្រកបដោយនវានុវត្តន៍ដែលមានលក្ខណៈជាប្រព័ន្ធ និងមានការវិវត្តយឺតៗយ៉ាងស៊ីជម្រៅ និងលំបាក។

ទិដ្ឋភាពមួយទៀតនៃការរៀបចំគម្រោងគឺថា សហគមន៍ត្រូវធ្វើការវាយតម្លៃពីភាពងាយរងគ្រោះផ្ទាល់ខ្លួន។ នេះគឺជាបញ្ហាប្រឈមព្រោះថាទិន្នន័យនៅកម្រិតតំបន់អនាធិបតេយ្យក្នុងមូលដ្ឋានមិនមានផ្តល់ជូនដោយងាយស្រួលនោះទេ ហើយអ្នកដឹកនាំជាស្ត្រីក៏មិនមានសមត្ថភាព និងការតម្រង់ទិសក្នុងការរៀនពីគំរូ

ស្មុគស្មាញនេះដែរ។ ដើម្បីដោះស្រាយបញ្ហានេះ ដៃគូបានបង្កើតការវាយតម្លៃអំពីភាពងាយរងគ្រោះ ការឃ្លាំមើល និងឧបករណ៍សម្រាប់ការរៀបចំផែនការ។ មានឧបករណ៍ដំណើរការ/ការអនុវត្តចំនួនប្រាំបួន ដែលត្រូវបានកំណត់ក្នុងដំណាក់កាលអភិវឌ្ឍន៍គម្រោង ដែលត្រូវការសាកល្បង និងធ្វើតេស្តសម្រាប់ប្រសិទ្ធភាព និងផលប៉ះពាល់។ ការងារទាំងនេះរួមបញ្ចូល ម៉ូឌុលបណ្តុះបណ្តាល សម្ភារៈអូឌីយ៉ូ និងរូបភាពបោះពុម្ព ហ្គេម ឧបករណ៍វាយតម្លៃភាពងាយរងគ្រោះ សហគមន៍មូលដ្ឋាន និងផែនការភាពធន់ និងការអនុវត្តការឃ្លាំមើលតាមសហគមន៍។ (សូមមើលពិព័រណ៍ ឃ ស្តីពីផលិតផលចំណេះដឹង)។

ការផ្តោតសំខាន់មួយទៀតនៃគម្រោងនេះ គឺដើម្បីផ្តល់ឱ្យសហគមន៍នូវជម្រើសនៃដំណោះស្រាយលើបច្ចេកវិទ្យា ដូច្នេះពួកគេអាចធ្វើសេចក្តីសម្រេចចិត្តដោយខ្លួនឯង ដោយផ្អែកលើអ្វីដែលសមរម្យ និងទាក់ទាញចំពោះពួកគេ។ បច្ចេកវិទ្យាថ្មីនេះត្រូវបានកំណត់តាមរយៈដំណើរទស្សនកិច្ចនិងការអញ្ជើញអ្នកធ្វើនវានុវត្តន៍ និងអ្នកផ្តល់សេវាកម្មបច្ចេកវិទ្យា មកចូលរួមក្នុងសិក្ខាសាលា រួមជាមួយធាតុចូលពីអ្នកជំនាញបច្ចេកទេសគម្រោង។ នេះអមដោយការបង្ហាញពីអន្តរាគមន៍បច្ចេកទេសពាក់ព័ន្ធ។ ការឃើញ និងជួបប្រទះផលិតផលផ្សេងៗដោយផ្ទាល់ ជួយបង្កើតទំនុកចិត្តក្នុងចំណោមសហគមន៍ក្នុងការវិនិយោគលើបច្ចេកវិទ្យាភាពធន់។ ដំណោះស្រាយកម្រិតគ្រួសារចំនួន ២១ និងដំណោះស្រាយកម្រិតសហគមន៍ចំនួន ៩ ត្រូវបានបង្ហាញ។ ទាំងនេះរួមបញ្ចូលទាំងដំបូលត្រជាក់ម៉ូឌុល ស្វ័យប្រវត្តិត្រជាក់ ទិដ្ឋភាពទីក្រុង ប្រព័ន្ធជីកំប៉ុស្តវ៉េមី កុងទ័រទឹក ប្រព័ន្ធប្រមូលទឹកភ្លៀងពីដំបូលផ្ទះ ម៉ាស៊ីនកំប៉ុស និងប្រព័ន្ធផ្គត់ផ្គង់ទឹកដែលគ្រប់គ្រងដោយសហគមន៍។

**សំណួរសំខាន់ៗ៖**

ក) តើអ្នកគិតថាអ្វីជាក្របខ័ណ្ឌពេលវេលាគ្រប់គ្រាន់សម្រាប់គម្រោង CBA? តើអ្វីអាចជាបញ្ហាដែលទាក់ទងនឹងការប្រណាំងនឹងពេលវេលាលើគម្រោងបែបនេះ?

ខ) តើអ្នកគិតថាអ្វីជាឧបសគ្គក្នុងការអនុវត្តគម្រោងដែលមានលក្ខណៈស្មុគស្មាញបែបនេះ? តើវិធីអ្វីខ្លះដែលគម្រោងនេះរំពឹងទុកអំពីបញ្ហាដែលអាចកើតមាន ហើយរួមបញ្ចូលបញ្ហាទាំងនោះនៅក្នុងការរៀបចំការអនុវត្ត?

គ)តើជំហានសំខាន់ៗអ្វីខ្លះដែលត្រូវការនៅកម្រិតអង្គការសម្រាប់ការគ្រប់គ្រងគម្រោងបែបនេះ? តើអ្វីជាអនុសាសន៍របស់ក្រុមប្រឹក្សាភិបាលសម្រាប់ការត្រួតពិនិត្យ និងតុល្យភាព ដើម្បីធានាថាលទ្ធផលគម្រោងទាំងអស់ត្រូវបានផ្តល់ឱ្យទាន់ពេលវេលា ភាពជាដៃគូត្រូវបានគ្រប់គ្រងយ៉ាងល្អ ហើយធនធានហិរញ្ញវត្ថុត្រូវបានប្រើប្រាស់ប្រកបដោយប្រសិទ្ធភាព?

ឃ)តើអ្នកវាយតម្លៃយ៉ាងដូចម្តេចចំពោះយុទ្ធសាស្ត្រពង្រឹងសមត្ថភាព និងឧបករណ៍របស់គម្រោងនេះ?

ង) តើអ្នកគិតថាអ្វីជាចន្លោះប្រហោង/ដែនកំណត់សំខាន់ៗរបស់គម្រោងទាក់ទងនឹងការដោះស្រាយអន្តរ វិស័យភាព និងការធានា LNOB?

## ពិព័រណ៍ ឃ ៖ ផលិតផលចំណេះដឹង

### ម៉ូឌុលនិងឧបករណ៍បណ្តុះបណ្តាលតម្រង់ទិសស្តីពីការប្រែប្រួលអាកាសធាតុ



ម៉ូឌុលបណ្តុះបណ្តាលកម្រិតមូលដ្ឋាននេះ មានគោលបំណងបង្ហាញពីទស្សនទាន នៃការប្រែប្រួលអាកាសធាតុ និងកសាងការយល់ដឹង អំពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុលើប្រជាជនក្រីក្រនៅទីប្រជុំជន ជាពិសេសស្ត្រី។ ម៉ូឌុលនេះជាដំណើរការជាជំហានដែលមាន ៦ វគ្គ។ ២ វគ្គដំបូងមានគោលបំណងបំផុសចំណាប់អារម្មណ៍ចំណែកវគ្គទី៣និងវគ្គទី៤បង្ហាញពីទស្សនទាន ដូចជា ការប្រែប្រួលអាកាសធាតុ និងការកើនឡើងកម្តៅសកល និងការពន្យល់ពីផលប៉ះពាល់របស់វា លើមនុស្សជាតិទាំងមូល ក៏ដូចជាជីវិតរស់នៅប្រចាំថ្ងៃ។ ២វគ្គចុងក្រោយផ្តោតសំខាន់លើសកម្មភាព ដោយវគ្គទី៥បង្ហាញពីល្បែងពស់ និងជណ្តើរ។ ក្នុងល្បែងនេះ កត្តាដែលបង្កឱ្យមានភាពតានតឹងផ្នែកអាកាសធាតុគឺជាពស់ដែលទាញទម្លាក់ស្ត្រីចុះក្រោម ចំណែកសកម្មភាពភាពធន់ជាជណ្តើរដែលជួយឱ្យស្ត្រីឡើងទៅខាងលើ។ វគ្គទី ៦ លើកទឹកចិត្តឱ្យធ្វើស្វ័យឆ្លុះបញ្ចាំង និងបង្ហាញទស្សនទាននៃសកម្មភាពភាពធន់ និងការគិតឆ្ពោះទៅអនាគត។

# ពិព័រណ៌ ឃ ៖ ផលិតផលចំណេះដឹង

## វគ្គបណ្តុះបណ្តាលផ្នែកបច្ចេកទេស

**Materials**

Take only one bead of each colour.

**Directions**

1. Thread the different coloured beads on the string in any order.
2. Place the string around your wrist and tie it.
3. By rotating the beads around your wrist, you have created a water cycle.

វគ្គបណ្តុះបណ្តាលផ្នែកបច្ចេកទេសដែលរៀបចំឡើងដោយអ្នកជំនាញតាមវិស័យផ្តល់ព័ត៌មានកាន់តែស៊ីជម្រៅនិងគ្រប់ជ្រុងជ្រោយស្តីពីប្រធានបទណាមួយដូចជា ការគ្រប់គ្រងទឹក ជំងឺឆ្លងតាមភ្នាក់ងារ ស្រ្តេសកម្តៅ ការគ្រប់គ្រងសុខភាពផ្ទាល់ខ្លួន។ល។ជំនួសឱ្យការផ្តល់វគ្គបណ្តុះបណ្តាលផ្នែកបច្ចេកទេសដូចគ្នាដល់សមាជិកក្រុមសកម្មភាពសហគមន៍ទាំងអស់ វគ្គបណ្តុះបណ្តាលនេះមានគោលបំណងលើកទឹកចិត្តឱ្យសមាជិកម្នាក់ៗយល់ច្បាស់ពីកត្តា ដែលបង្កឱ្យមានភាពតានតឹងពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុមួយក្នុងចំណោមកត្តាដែលបង្កឱ្យមានភាពតានតឹងទាំង ៤។ វគ្គបណ្តុះបណ្តាលនេះផ្តោតជាក់លាក់លើការបង្កើតឧបករណ៍ដែលមានការចូលរួម (ល្បែងនិងលំហាត់សម្រាប់វគ្គបណ្តុះបណ្តាលផ្នែកបច្ចេកទេស)



| | | | |
|---|---|---|---|
| **Yellow** | = | **Solar Energy** | > Energy provided by the sun for the never-ending water cycle. |
| **Clear** | = | **Evaporation** | > Vapour created when the sun heats water in lakes, streams, rivers or oceans. |
| **Green** | = | **Transpiration** | > Vapour created when plants and trees give off moisture. |
| **White** | = | **Condensation** | > Tiny droplets of water formed when vapour rises into the air and cools. |
| **Blue** | = | **Precipitation** | > Moisture released when the clouds become heavy and form rain, snow, hail etc. |
| **Brown** | = | **Percolation** | > Movement of water through the ground. |

## យុទ្ធសាស្ត្រផ្សព្វផ្សាយ

ឧបករណ៍យុទ្ធសាស្ត្រផ្សព្វផ្សាយបែបនវានុវត្តន៍ ដូចជា ល្បែងពស់ និងជណ្តើរ គំនូរជីវចល បដា និងគំនូរលើជញ្ជាំង និងបណ្តាញផ្សព្វផ្សាយបែបប្រពៃណី ត្រូវបានបង្កើតឡើងសម្រាប់ផ្សព្វផ្សាយដល់សហគមន៍ តាមបណ្តាញចម្រុះ។ ឯកសារផ្សព្វផ្សាយ រួមមានការចែកសំណៅឯកសារ ៥០០ ច្បាប់នៃបដាមួយផ្ទាំងៗក្នុងចំណោមបដា ៤ ផ្ទាំងស្តីពីភាពតានតឹងផ្សេងៗ ដែលត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយក្នុងកិច្ចប្រជុំរបស់អង្គការសហគមន៍មូលដ្ឋានទាំងអស់ដែលគ្របដណ្តប់លើក្រុមគោលដៅជាច្រើន។ការផ្សព្វផ្សាយបែបប្រពៃណីត្រូវបានរៀបចំឡើងក្នុងតំបន់សំណង់អនាធិបតេយ្យចំនួន ៣៨ ទីតាំង ស្មើនឹងប្រជាជនជាង ៧.៥០០ នាក់ក្នុងរយៈពេល ១ ខែ។ ល្បែងពស់ និងជណ្តើរត្រូវបានរៀបចំឡើងចំនួន ២២៩ ដង និងមានអ្នកចូលរួមជាង ៣.៥០០ នាក់។ សម្ភារសោតទស្សន៍ខ្លីៗស្តីពីភាពងាយរងគ្រោះរបស់សហគមន៍ អន្តរាគមន៍ និងយោបល់ត្រឡប់របស់សហគមន៍ ក៏ត្រូវបានផលិតឡើងសម្រាប់កសាងការយល់ដឹងរបស់សហគមន៍ផងដែរ។ ក្នុងចំណោមសម្ភារទាំងនេះ គំនូរជីវចលស្តីពី "រឿងរ៉ាវរបស់ Ramaben" បានទាក់ទាញចំណាប់អារម្មណ៍សហគមន៍យ៉ាងខ្លាំង។

# ពិព័រណ៍ ឃ ៖ ផលិតផលចំណេះដឹង

## យុទ្ធសាស្ត្រផ្សព្វផ្សាយ




## សេវាកម្មឆ្លើយតបជាសំឡេង (IVR) និងវិទ្យុសហគមន៍



សេវាកម្មឆ្លើយតបជាសំឡេង (IVRS) ផ្តល់លទ្ធភាពឱ្យបុគ្គលអាចទទួលបានព័ត៌មានពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុនិងមានឱកាសផ្តល់មតិយោបល់លើអន្តរាគមន៍កម្រិតគ្រួសារ។ បណ្តាញផ្សព្វផ្សាយ ដូចជាវិទ្យុសហគមន៍ដែលរាយការណ៍ពីស្ថានភាពក្នុងមូលដ្ឋាន ទស្សនៈអ្នកជំនាញ ការឆ្លើយតបរបស់រដ្ឋាភិបាល និងសំឡេងរបស់ប្រជាពលរដ្ឋ ជួយពង្រីកការផ្សព្វផ្សាយលើសពីសហគមន៍គោលដៅ។ កម្មវិធីវិទ្យុចំនួន ៤៥ វគ្គលើប្រធានបទទូលំទូលាយស្តីពី "ការជំរុញឱ្យមានទីក្រុងបរិយាបន្ន និងមានភាពធន់" ត្រូវបានផ្សព្វផ្សាយតាមប៉ុស្តិ៍វិទ្យុសហគមន៍។ ក្មេងស្រីវ័យជំទង់ ៤ នាក់ដែលជាប្រធានក្រុមសកម្មភាពសហគមន៍ក៏បានចាប់ផ្តើមធ្វើការជាអ្នករាយការណ៍ព័ត៌មានទីក្រុងសម្រាប់ប៉ុស្តិ៍វិទ្យុសហគមន៍ផងដែរ។

## ពិព័រណ៌ ឃ ៖ ផលិតផលចំណេះដឹង

### ឧបករណ៍វាយតម្លៃភាពងាយរងគ្រោះសហគមន៍មូលដ្ឋាន (CBVAT)



CBVAT ជាឧបករណ៍រៀនសូត្របែបចូលរួមដែលប្រើប្រាស់លំហាត់ចំនួន ៦ និងត្រូវបានបង្កើតឡើងសម្រាប់អភិវឌ្ឍការយល់ដឹងរបស់សហគមន៍ ស្តីពីហានិភ័យអាកាសធាតុ និងយុទ្ធសាស្ត្របន្សាំ។ ការវាយតម្លៃមានរយៈពេល ៦-៨ សប្តាហ៍។ ដ្យាក្រាម និងតារាងជាច្រើនត្រូវបានផ្តល់ជូនសមាជិកក្រុមសកម្មភាពសហគមន៍ សម្រាប់ជួយដល់ពួកគេក្នុងការកំណត់រកកត្តាបង្កឱ្យមានភាពតានតឹងដែលបណ្តាលឱ្យសហគមន៍ងាយរងគ្រោះបំផុត និងក្រុមអាជីព/យេនឌ័រដែលងាយរងគ្រោះបំផុត ដើម្បីវាយតម្លៃឫសគល់នៃភាពងាយរងគ្រោះ និងសមត្ថភាពបន្សាំរបស់ពួកគេ ៖

ក. អ៊ីស្តូក្រាម ៖ ដើម្បីគូសផែនទីបញ្ហាប្រឈមពាក់ព័ន្ធនឹងអាកាសធាតុ និងនគរូបនីយកម្មក្នុងរយៈពេល ១០ ឆ្នាំចុងក្រោយនេះ។

ខ. Moser ៖ ដើម្បីស្វែងយល់ពីភាពពាក់ព័ន្ធយេនឌ័រទៅនឹងកត្តាដែលបង្កឱ្យមានភាពតានតឹង និងវិបត្តិ។

គ. ការផ្តល់ចំណាត់ថ្នាក់ម៉ាទ្រិច៖ដើម្បីធ្វើការវិភាគបែបសត្យានុម័តសំដៅកំណត់រកកត្តាបង្កឱ្យមានភាពតានតឹងដែលបង្កផលប៉ះពាល់ខ្លាំងបំផុត និង ក្រុមអាជីពដែលងាយរងគ្រោះខ្លាំងជាងគេ។

ឃ. ចតុភាគមណ្ឌលហានិភ័យ៖ ដើម្បីយល់ពីកត្តាបង្កឱ្យមានភាពតានតឹង និងវិបត្តិ ធៀបនឹងកម្រិតនៃផលប៉ះពាល់ និងភាពញឹកញាប់នៃការកើតឡើង។

ង. ដ្យាក្រាមស្តីពីឥទ្ធិពលនៃបុព្វហេតុ៖ ដើម្បីវិភាគល្អិតល្អន់លើហានិភ័យធំៗ ដែលលេចឡើងក្នុងវគ្គចុងក្រោយ និងកំណត់រកបុព្វហេតុដែលបង្កជាហានិភ័យ និងធ្វើឱ្យស្ថានភាពកាន់តែធ្ងន់ធ្ងរ។













| | | | |
|---|---|---|---|
| | | Access to Shelter During Evacuation | |
| | Grievance Redressal | Flash Flood Warning | Disease Monitoring and Surveillance |
| | Access to City Water Board | Plint Level of Homes | Vector Surveillance |
| Knowledge on Protection Measures | Water Harvesting System | Regular Cleaning of Drains | Water Testing |
| Access to Heat Advisory | Access to Water Tankers | Solid Waste Management System | Water Management System |
| Availability of Green Shade | Adequate Supply | Storm Water Drainage | Access to Information on Preventive Services |
| Availability of Shade | Availability of Water Resources | Well-Managed Drainage | Access to Information During Outbreaks |
| RAIN | WATER SCARCITY | FLOODING | VECTOR-BORNE DISEASES |

## ពិព័រណ៌ ឃ ៖ ផលិតផលចំណេះដឹង

### ឧបករណ៍វាយតម្លៃភាពងាយរងគ្រោះសហគមន៍មូលដ្ឋាន (CBVAT)

ច. ការដាក់ពិន្ទុលើសមត្ថភាពបន្សាំ៖ ដើម្បីវាយតម្លៃភាពអាចរកបាននៃហេដ្ឋារចនាសម្ព័ន្ធចំណេះដឹងនិងមូលធនសង្គមក្នុងសហគមន៍ ដែលនឹងរួមចំណែកដល់ការកសាងភាពធន់របស់ពួកគេ។

CBVAT ផ្តល់ក្របខ័ណ្ឌមួយសម្រាប់កិច្ចសន្ទនាក្នុងសហគមន៍ពាក់ព័ន្ធនឹងការកំណត់រកយុទ្ធសាស្ត្រអនុវត្តន៍ដើម្បីសម្រួលដល់ការបន្សាំនៅសហគមន៍មូលដ្ឋាន ទៅនឹងការប្រែប្រួលអាកាសធាតុ។

ក្រោយបញ្ចប់ការវាយតម្លៃ CBVAT លទ្ធផលត្រូវបានបម្លែងជាបទបង្ហាញ power point និងចែករំលែកជាមួយសមាជិកក្រុមសកម្មភាពសហគមន៍ ក្នុងដំណើរការរៀបចំផែនការបង្កើនភាពធន់។

### ការរៀបចំផែនការសកម្មភាពភាពធន់នៅសហគមន៍មូលដ្ឋាន

នៅពេលក្រុមសកម្មភាពសហគមន៍សហការគ្នាបង្កើតផែនការសកម្មភាពភាពធន់នៅសហគមន៍មូលដ្ឋានពួកគេនឹងពិនិត្យមើលលទ្ធផលនៃការវាយតម្លៃភាពងាយរងគ្រោះឡើងវិញដើម្បីកែលម្អឬទទួលយកលទ្ធផលនោះរួច បង្កើតផែនការសកម្មភាពប្រចាំឆ្នាំសម្រាប់ដោះស្រាយកត្តាបង្កឱ្យមានភាពតានតឹងសំខាន់ៗដែលរកឃើញ រៀបរាប់ពីពេលវេលាចាំបាច់សម្រាប់សកម្មភាពគោលដៅប្រចាំថ្ងៃ/សប្តាហ៍/ខែ មូលនិធិដែលពួកគេត្រូវការ និងអង្គការដែលអាចគាំទ្រដល់សហគមន៍ក្នុងការអនុវត្តផែនការសកម្មភាពទាំងនេះ។

**Solutions Quiz**

Air-lite Ventilation



- ☐ Water Stress
- ☐ Heat Stress
- ☐ Flooding
- ☐ Water Quality
- ☐ Vector-borne Disease

Modular Roof



- ☐ Water Stress
- ☐ Heat Stress
- ☐ Flooding
- ☐ Water Quality
- ☐ Vector-borne Disease

Cool Auto



- ☐ Water Stress
- ☐ Heat Stress
- ☐ Flooding
- ☐ Water Quality
- ☐ Vector-borne Disease

### ការឃ្លាំមើលនៅសហគមន៍មូលដ្ឋាន



ខណៈដែលដំណើរការបង្កើតផែនការប្រចាំឆ្នាំ គឺជាកិច្ចការម្តងម្កាល គម្រោងនេះក៏ពិចារណាផងដែរថា ការកសាងភាពធន់ជាដំណើរការជាប្រចាំ (iterative process) និងចាំបាច់សហគមន៍ត្រូវត្រៀមខ្លួន ជាពិសេសប្រធានក្រុមសកម្មភាពសហគមន៍សម្រាប់ការពិនិត្យតាមដានការប្រែប្រួល និងភាពតានតឹងដែលពាក់ព័ន្ធនឹងអាកាសធាតុ ដើម្បីអាចចាត់វិធានការបានទាន់ពេលវេលា។ ក្នុងន័យនេះ គម្រោងបានបង្កើតប្រព័ន្ធឃ្លាំមើល ២ កម្រិត ៖

ក. ប្រព័ន្ធឃ្លាំមើលតាមរដូវកាល៖ ត្រូវបានផ្តួចផ្តើមឡើងតាមរយៈការជំរុញការចូលរួមរបស់ក្មេងប្រុសនិងក្មេងស្រី (ហៅថាវេជ្ជបណ្ឌិតកុមារ) ក្នុងសហគមន៍សម្រាប់ការប្រមូលទិន្នន័យក្នុងពេលជាក់ស្តែងអំពីវត្តមានជង្គរ និងការធ្វើតេស្តគុណភាពទឹក។

ខ. ប្រព័ន្ធឃ្លាំមើលប្រចាំថ្ងៃ/សប្តាហ៍ ៖ គម្រោងនេះបានអនុវត្តសាកល្បងនូវប្រព័ន្ធប្រមូលព័ត៌មានធាតុអាកាសជាក់ស្តែងនិងទិន្នន័យអាកាសធាតុក្នុងតំបន់សំណង់អនាធិបតេយ្យចំនួន ២៣ ទីតាំង។ ប្រព័ន្ធមានដូចជា ប្រព័ន្ធវាស់សីតុណ្ហភាព សំណើម និងកំណកអាកាស ក៏ដូចជាប្រព័ន្ធពិនិត្យបរិមាណ និងគុណភាពទឹក ភ្នាក់ងារចម្លង ទឹកជំនន់ និងការលិចទឹក។

ផ្នែក ឃ ៖ សមិទ្ធផលសំខាន់ៗ និងការរៀនសូត្រ

គម្រោងអនុវត្តបានដល់៖

- ៣ ប្រទេស
- ៧ ទីក្រុង
- តំបន់សំណង់អនាធិបតេយ្យ ១០៧ ទីតាំង
- ប្រជាជន ១៣៥.០០០ នាក់

**រូបទី ៦៩ ៖ របាយគ្រួសារក្នុងក្រុមងាយរងគ្រោះ (ទិន្នន័យដើមគ្រា និងទិន្នន័យចុងបញ្ចប់)**

Vulnerability Group HHs Distribution Across CAG Category – Baseline




Vulnerability Group HHs Distribution Across CAG Category – Endline




## លទ្ធផលសម្រេចបាន ការថយចុះនៃភាពងាយរងគ្រោះទៅនឹងការប្រែប្រួលអាកាសធាតុ

គម្រោងមានប្រព័ន្ធតាមដាន និងវាយតម្លៃបែបគុណភាពដ៏ល្អដែលបង្ហាញថា ៖

- គ្រួសារប្រមាណ ៣៥% នៃគ្រួសារដែលទទួលបានការព្យាបាលបានបង្ហាញការថយចុះនៃភាពងាយរងគ្រោះរបស់ខ្លួនធៀបនឹងទិន្នន័យដើមគ្រា។
- ភាគរយគ្រួសារងាយរងគ្រោះបំផុត (ក្រុមពណ៌ក្រហម) ថយចុះយ៉ាងខ្លាំងសម្រាប់អ្នកចូលរួមក្នុងគម្រោង ធៀបនឹងក្រុមក្រោមការគ្រប់គ្រង (control group)។
- ការផ្លាស់ចេញពីក្រុមកណ្តាល (ពណ៌លឿង) ទៅក្រុមខាងក្រោម (ពណ៌បៃតង) ក៏មានការកើនឡើងសម្រាប់អ្នកចូលរួម ធៀបនឹងក្រុមក្រោមការគ្រប់គ្រងផងដែរ។
- មានការថយចុះទាំងក្នុងប្រភេទក្រុមសកម្មភាពសហគមន៍ និងប្រភេទមិនមែនក្រុមសកម្មភាពសហគមន៍ដែលគួសបញ្ជាក់ថា ផលប៉ះពាល់នេះមិនកើតមានចំពោះតែក្រុមដឹកនាំស្នូលនោះទេ ប៉ុន្តែបានរីកសាយលើសពីនេះ។

### លទ្ធផលចំណេះដឹង និងការផ្តល់តាពអង់អាច

- គ្រួសារក្នុងការអង្កេតប្រមាណ ៨% បានវិនិយោគយ៉ាងច្រើនលើផ្ទះសម្បែងរបស់ខ្លួនដើម្បីបង្កើនភាពធន់នឹងការប្រែប្រួលអាកាសធាតុ។
- ស្ត្រីក្នុងការអង្កេតចំនួន ៦៤% រាយការណ៍ថា ពួកគាត់មានការយល់ដឹងច្រើនអំពីដំណោះស្រាយភាពធន់។
- ស្ត្រីក្នុងការអង្កេតចំនួន៦៤%រាយការណ៍ថាពួកគាត់មានការយល់ដឹងស្តីពីហានិភ័យអាកាសធាតុ។
- សហព័ន្ធស្ត្រីនៅកម្រិតទីក្រុងត្រូវបានរដ្ឋាភិបាលមូលដ្ឋានអញ្ជើញឱ្យបង្ហាញពីបុព្វហេតុរបស់ពួកគេក្នុងផែនការសកម្មភាពកម្តៅក្នុងទីក្រុង។ ការណ៍នេះធ្វើឱ្យមានការទទួលស្គាល់សហព័ន្ធទាំងនេះជាផ្លូវការថាជាអ្នកពាក់ព័ន្ធក្នុងផែនការសកម្មភាពកម្តៅទីក្រុង និងការដាក់បញ្ចូលជាលើកដំបូងនូវយុទ្ធសាស្ត្រសម្រាប់តំបន់សំណង់អនាធិបតេយ្យក្នុងផែនការនេះ។ នៅឆ្នាំបន្ទាប់ការលាបពណ៌សលើដំបូលផ្ទះរបស់គ្រួសារនៅតំបន់សំណង់អនាធិបតេយ្យត្រូវបានកំណត់យកជាផ្លូវការជាសកម្មភាពគោលមួយ។ ក្នុងទីក្រុងមួយផ្សេងទៀត ប្រព័ន្ធប្រមូលទឹកភ្លៀងលើដំបូលផ្ទះ ត្រូវបានដាក់បញ្ចូលជាផ្នែកចំណាយដ៏សំខាន់មួយនៃគម្រោងអភិវឌ្ឍន៍ឡើងវិញនៅតំបន់សំណង់អនាធិបតេយ្យ ។

ទោះជាយ៉ាងណា ដំណើរការនេះក៏ប្រឈមនឹងបញ្ហាមួយចំនួនផងដែរ

- គម្រោងនេះទាមទារឱ្យមានការកៀរគរគ្រួសារក្នុងទីក្រុងដែល

ទើបកើតឡើងនានាឱ្យសហការជាមួយស្ថាប័នមូលនិធិ។ ដំណើរការនេះចំណាយពេលយូរ ពាក់ព័ន្ធនឹងការចុះជួបជាច្រើនលើក ច្រើនសារ និងចំណាយធនធានច្រើន។ ទោះបីជាវគ្គបណ្តុះបណ្តាលត្រូវបានរៀបចំឡើងដោយពិចារណាពីកាលវិភាគរបស់ស្ត្រីការខាតបង់ក្នុងជីវភាពពិធីបុណ្យសាសនា/វប្បធម៌ និងការចូលរួមផ្សេងទៀតក្តី ក៏ការជំរុញការចូលរួមរបស់ស្ត្រីក្នុងសហគមន៍មួយចំនួនគឺជាការលំបាក។ ស្ត្រី និងបុរសសុទ្ធតែមានមន្ទិលសង្ស័យចំពោះគោលដៅ/លក្ខណៈនៃវគ្គបណ្តុះបណ្តាលទាំងនេះ។

> ការបង្កើតការយល់ដឹង និងចំណាប់អារម្មណ៍លើបញ្ហាប្រែប្រួលអាកាសធាតុ ក្នុងចំណោមស្ត្រីក្រីក្រគឺជាបញ្ហាប្រឈមសំខាន់មួយ។ កិច្ចប្រជុំក្នុងតំបន់មិនសូវទាក់ទាញចំណាប់អារម្មណ៍ និងការយកចិត្តទុកដាក់ច្រើនទេ។ ការប្រើប្រាស់ឧបករណ៍ផ្សព្វផ្សាយដែលបានបង្កើតឡើង បានទាក់ទាញចំណាប់អារម្មណ៍ដំបូងរបស់សហគមន៍ស្តីពីការប្រែប្រួលអាកាសធាតុ និងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ ប៉ុន្តែក្រោយមកទៀត សហគមន៍យល់ថា កម្មវិធីនេះផ្តោតលើការបណ្តុះបណ្តាលខ្លាំងពេក។

> ដើម្បីរក្សាចំណាប់អារម្មណ៍របស់សហគមន៍លើកម្មវិធីនេះ ចាំបាច់ត្រូវ "បង្ហាញសកម្មភាព និងការផ្លាស់ប្តូររូបីនៅមូលដ្ឋាន។ ចាំបាច់ត្រូវផ្លាស់ប្តូរប្រព័ន្ធឃ្លាំមើលនៅសហគមន៍មូលដ្ឋានទៅជាយុទ្ធនាការ ខណៈដែលប្រព័ន្ធនេះមិនទាន់បង្កើតឡើងរួចរាល់។ ដូច្នេះ ប្រព័ន្ធឃ្លាំមើលភ្នាក់ងារចម្លងជំងឺត្រូវបានពង្រីកឱ្យរួមបញ្ចូលគ្រួសារយ៉ាងតិច ៥០% នៅតំបន់សំណង់អនាធិបតេយ្យ ជាកម្រិតលើសពីផែនការដំបូងដែលកំណត់សំណាកគ្រួសារតិចជាងនេះ។ ការណ៍នេះបានជំរុញការចូលរួមរបស់មនុស្សវ័យជំទង់ក្នុងកម្មវិធីនេះ។

> សមាជិកក្រុមនិងអ្នកដឹកនាំជាស្ត្រីជាច្រើននាក់ត្រូវបានបណ្តុះបណ្តាលដើម្បីសម្របសម្រួលដំណើរការវាយតម្លៃភាពងាយរងគ្រោះ។ ទោះជាយ៉ាងណា ដំណើរការនេះមានលក្ខណៈបច្ចេកទេស និងស្មុគស្មាញបន្តិច និងពាក់ព័ន្ធនឹងការពិបាកក្នុងការរៀនសូត្រកាន់តែយូរ។ អ្នកសម្របសម្រួលម្នាក់លើកឡើងថា "ខ្ញុំមានការលំបាកក្នុងការចងចាំពាក្យគន្លឹះទាំងអស់ និងឧបករណ៍ផ្សេងៗ។ ខ្ញុំធ្លាប់ភាន់ច្រលំ និងច្របូកច្របល់។ យើងត្រូវចំណាយពេលយូរដើម្បីសម្របសម្រួល CBVAT ក្នុងតំបន់សំណង់អនាធិបតេយ្យចំនួន ៥-៦ ទីតាំងនៅដំណាក់កាលដំបូង។ យើងយល់ថា ដំណើរការនេះពាក់ព័ន្ធនឹងឯកសារជាច្រើនដែលយើងមិនធ្លាប់ប្រទះ ហើយសហគមន៍ក៏មិនសូវមានចំណាប់អារម្មណ៍ដែរ"។

> អ្នកសម្របសម្រួលម្នាក់លើកឡើងថាដំណើរការCBVAT ច្បាមយកការឆ្លើយតបខុសៗគ្នាពីសហគមន៍ផ្សេងៗ។ ក្នុងសហគមន៍មួយចំនួនដំណើរការនេះទទួលបានជោគជ័យខ្ពស់។ ស្ត្រីបានចូលរួមជាបន្តបន្ទាប់ក្នុងលំហាត់ទាំងអស់ដែលមានរយៈពេលពីរបីសប្តាហ៍។ ពួកគាត់អាចយល់ និងលើកឡើងពីភាពងាយរងគ្រោះផ្ទាល់ខ្លួន។ ក្នុងសហគមន៍ ដែលលេចឡើង មិនសូវមានការលំបាកក្នុងការរក្សាចំណាប់អារម្មណ៍លើដំណាក់កាលដំបូងនៃដំណើរការនេះឡើយ។

> ការធ្វើបង្ហាញបច្ចេកវិទ្យា តម្រូវឱ្យមានការទទួលយកដោយសហគមន៍ តាំងពីនៅដំណាក់កាលដំបូងនៃការធ្វើតេស្តផលិតផល។ ការបង្ហាញប្រព័ន្ធត្រជាក់ដោយស្វ័យប្រវត្តិ (cool-auto) ទាក់ទាញចំណាប់អារម្មណ៍យ៉ាងច្រើនហើយផលិតផលនេះត្រូវបានសាកល្បងជាមួយបច្ចេកវិទ្យាគ្មានអ្នកបើកបរ។ ខណៈដែលអ្នកបើកបររថយន្តចាប់អារម្មណ៍លើផលិតផលនេះ ព្រោះវាជាផលិតផលមិនគិតថ្លៃ ពួកគេមិនវិនិយោគលើការជួសជុលថែទាំឡើយ។ បុគ្គលិកម្នាក់លើកឡើងថា "ដំបូងឡើយគ្មានការរួមចំណែកដល់ Cool auto ទេ ហើយអ្នកទទួលផលដំបូងបានផ្សព្វផ្សាយសារមិនត្រឹមត្រូវ។ ប្រជាជនចាប់ផ្តើមជឿថា Rexine នឹងខូច ហើយនេះជាមូលហេតុចម្បងដែលគេលើកឡើង ជាពិសេសនៅពេលស្នើសុំការរួមចំណែក។ គ្មាននរណាចង់រួមចំណែកទេ។ ទោះជាយ៉ាងណា យើងបានរៀនសូត្រពីចំណុចនេះ ហើយសម្រាប់ការលាបពណ៌ដំបូលសូឡា យើងទទូចឱ្យមានការរួមចំណែក។ ស្ត្រីត្រូវបានបង្កើនភាពអង់អាច និងបានពិនិត្យជាប្រចាំលើបរិមាណថ្នាំលាបដំបូល ដែលបានប្រើប្រាស់ និងការរួមចំណែករបស់ពួកគេ។ បុគ្គលិកធ្វើឱ្យពួកគាត់យល់ពីរបៀបដំណើរការជាក់ស្តែង ហើយពួកគាត់បានយល់ព្រមរួមចំណែក"។

> ការសំខាន់គឺត្រូវមានវិធីសាស្ត្ររយៈពេលវែងដែលរួមបញ្ចូលយុទ្ធសាស្ត្រសម្រាប់ការបង្កើតចំណេះដឹង ដែលជំរុញឱ្យមានការផ្លាស់ប្តូរឥរិយាបថនិងលើកកម្ពស់សកម្មភាពដឹកនាំដោយសហគមន៍។ ទោះជាយ៉ាងណា បទពិសោធន៍គម្រោងបង្ហាញថា ដើម្បីកៀរគរសហគមន៍ឱ្យផ្តោតលើការប្រែប្រួលអាកាសធាតុនិងរក្សាចំណាប់អារម្មណ៍របស់សហគមន៍លើការរៀបចំផែនការបង្កើនភាពធន់ ចាំបាច់ត្រូវបំពេញផលប្រយោជន៍ចំពោះមុខរបស់សហគមន៍ជាមុនសិន។ អ្នកដឹកនាំជាស្ត្រីម្នាក់លើកឡើងថា "ដំបូង នៅពេលខ្ញុំចាប់ផ្តើមរៀបចំកិច្ចប្រជុំក្នុងតំបន់ស្តីពីការប្រែប្រួលអាកាសធាតុក្នុងកិច្ចប្រជុំទាំងអស់ ស្ត្រីតែងចោទសួរថាតើពេលណាទើបបញ្ចប់ការសាងសង់ប្រព័ន្ធបង្ហូរទឹក។ បន្ទាប់ពីចូលរួមក្នុងកម្មវិធីបាន ១ ឆ្នាំ ការសាងសង់ប្រព័ន្ធបង្ហូរទឹកបានចាប់ផ្តើម។ នៅពេលមើលឃើញការផ្លាស់ប្តូរ ស្ត្រីកាន់តែចាប់អារម្មណ៍លើដំណើរការរៀបចំផែនការដែលមានការចូលរួម។ ដំណើរការទាំងនេះបានផ្តល់ឱកាសឱ្យស្ត្រីប្រមូលផ្តុំគ្នានិងសម្រេចយកសកម្មភាពជាសមូហភាពដែលសហគមន៍ចង់អនុវត្តនៅជំហានបន្ទាប់"។

> ការប្រមូលនិងពិនិត្យទិន្នន័យអាកាសធាតុជាក់ស្តែងជំរុញឱ្យមានការផ្លាស់ប្តូរឥរិយាបថក្នុងសហគមន៍ឆ្ពោះទៅរកការធ្វើសេចក្តីសម្រេចចិត្តផ្អែកតាមព័ត៌មានត្រឹមត្រូវ និងផ្តល់ចំណេះ

ដឹងដល់ពួកគេក្នុងការទាមទារឱ្យរដ្ឋាភិបាលផ្ដល់សេវាល្អប្រសើរ។ ដៃគូម្នាក់របស់យើងលើកឡើងថា"យើងបានរៀបចំវគ្គបណ្ដុះបណ្ដាលជាច្រើនតាំងពីដំបូងស្ដីពីការប្រើប្រាស់ធុងចម្រោះទឹក ប៉ុន្តែគ្មាននរណាចង់ប្រើធុងចម្រោះទឹកឡើយ។ នៅពេលយើងធ្វើតេស្តទឹក ទើបស្ត្រីក្នុងសហគមន៍ដឹងថា ទឹកដែលពួកគេពិសារាល់ថ្ងៃមានគុណភាពទាប។ យើងពន្យល់ថាតើការពិសាទឹកដែលមានគុណភាពទាបបង្កបញ្ហាសុខភាពដូចម្ដេច (ឧ. គ្រួសក្នុងតម្រងនោម ជំងឺក្រពះ។ល។)។ បន្ទាប់ពីការជំរុញជាបន្តបន្ទាប់ ប្រជាជនបាននាំគ្នាមកទិញធុងចម្រោះទឹក"។

**សំណួរសំខាន់ៗ ៖**

ក) តើអ្នកពេញចិត្តនឹងលទ្ធផលរបស់គម្រោងឬទេ?តើការចំណាយពេលវេលា និងធនធានកន្លងមក សមស្របទៅនឹងវិសាលភាព និងលទ្ធផល ឬទេ?

ខ) តើអ្នកចង់ឃើញលទ្ធផលអ្វីទៀតចេញពីគម្រោងនេះ?

គ) តើវិសាលភាព និងទំហំគម្រោងគ្រប់គ្រាន់សម្រាប់ការអនុវត្តវិធីសាស្ត្រចម្រុះ ឬទេ? ឬយកល្អគួរអនុវត្តតែយុទ្ធសាស្ត្រណាមួយ (យោងតាមផ្នែក ក)?

ឃ) តើអ្នកមើលឃើញដូចម្ដេចថា គម្រោងពិតជារួមចំណែកដល់អ្វីដែលស្ថាប័នមូលនិធិ បានកំណត់យកជាយុទ្ធសាស្ត្រ? តើស្ថាប័នកំពុងឈានទៅសម្រេចបានយុទ្ធសាស្ត្រដែលចង់បាន ឬទេ?

## ឯកសារទីមេរៀន១៩៖ ចំណុចសំខាន់ៗក្នុងការបន្សាំនឹងការប្រែប្រួលអាកាសធាតុតាមវិស័យ និងយេនឌ័រ

| ផ្នែក ក៖ កសិកម្ម និងសន្តិសុខស្បៀង | |
|---|---|
| ការផ្លាស់ប្ដូរពឹងទុកពាក់ព័ន្ធនឹងអាកាសធាតុ-សីតុណ្ហភាព និងកំណកអាកាស | ការប្រែប្រួលអាកាសធាតុ នឹងធ្វើឱ្យប៉ះពាល់ដល់ប្រព័ន្ធអេកូឡូស៊ីកសិកម្ម។ |
| ទិន្នផលស្រូវជាមធ្យមនឹងថយចុះ។ | នឹងមានការខ្វះខាតក្នុងផលិតកម្មស្បៀង។ |
| ទឹកជំនន់ព្យុះសង្ឃរាព្យុះស៊ីក្លូននិងគ្រោះរាំងស្ងួតនឹងធ្វើឱ្យវិស័យកសិកម្ម និងផលិតកម្មស្បៀងកាន់តែគ្មានស្ថិរភាព។ | ការកើនឡើងនៃនីវ៉ូទឹកសមុទ្រគំរាមកំហែងដល់ផលិតកម្មស្រូវតាមតំបន់ឆ្នេរ និងតំបន់ដីសណ្ដ។ |
| ផ្ទៃដីកសិកម្មអាចលិចលង់ដោយសារនីវ៉ូទឹកសមុទ្រកើនឡើង ១ ម៉ែត្រ។ | ការជ្រៀតចូលនៃទឹកប្រៃដោយសារនីវ៉ូទឹកសមុទ្រកើនឡើងអាចកាត់បន្ថយទិន្នផលស្រូវ។ |
| តំបន់ដាំដុះស្រូវនឹងរំកិលទៅតំបន់លើៗ។ | ទឹកជំនន់នឹងបំផ្លិចបំផ្លាញវាលស្រែ។ |
| គ្រោះរាំងស្ងួតនឹងធ្វើឱ្យខាតបង់ផលដំណាំ។ | ស្ត្រីប្រឈមនឹងឧបសគ្គពាក់ព័ន្ធនឹងទីផ្សារកាន់តែច្រើន។ |
| ស្រូវ និងស្រូវសាលីគឺជាដំណាំសំខាន់បំផុតក្នុងពិភពលោក។ | អាស៊ីជាតំបន់ដែលផលិតស្រូវជាង៩០%នៃផលិតកម្មស្រូវសរុបទូទាំងពិភពលោក។ |
| ស្ត្រីនៅតែមិនសូវមានសិទ្ធិដីធ្លី។ | ការកើនឡើងនៃតម្លៃអាហារ និងវិបត្តិស្បៀងអាហារ |
| ស្ត្រីជនបទជាពិសេសស្ត្រីក្រីក្រពឹងផ្អែកខ្លាំងលើកសិកម្មសម្រាប់បរិភោគ។ | ស្ត្រីជាអ្នកផលិតអាហារក្នុងស្រុកចំនួន ៦០%-៨០%។ |
| ទឹកជំនន់ ព្យុះសង្ឃរា ព្យុះស៊ីក្លូន នឹងធ្វើឱ្យខាតបង់ផលសត្វពាហនៈ។ | ជាទូទៅ ស្ត្រី និងក្មេងស្រីជាអ្នកត្រូវញ៉ាំក្រោយគេ និងជាអ្នកដែលត្រូវតមអាហារមុនគេ នៅពេលខ្វះខាតអាហារ។ |
| ជាញឹកញាប់ អាជ្ញាធរមិនទទួលស្គាល់ស្ត្រីដែលធ្វើកសិកម្ម ជាកសិករ។ | ជារឿយៗ សេវាផ្សព្វផ្សាយកសិកម្មផ្ដោតលើបុរសដែលគេចាត់ទុកជា "កសិករ"។ |
| ក្រៅពីនេះ ស្ត្រីមិនសូវមានលទ្ធភាពទទួលបានហិរញ្ញវត្ថុ និងការអនុវត្តអាជីវកម្មទំនើប។ | ស្ត្រីមិនសូវទទួលបានព័ត៌មានបច្ចេកទេសស្ដីពីការអនុវត្តឆ្លាតវៃខាងអាកាសធាតុ។ |
| ស្ត្រីមិនសូវមានលទ្ធភាពទទួលបានព័ត៌មានធាតុអាកាស និងប្រព័ន្ធប្រកាសអាសន្នព័ត៌មាន។ | ស្ត្រីមិនសូវមានសមាសភាគក្នុងសហករណ៍អ្នកផលិត។ |
| ទិន្នផលស្រូវសាលីក្នុងតំបន់ទំនាប Indo-Gangetic នឹងថយចុះយ៉ាងខ្លាំង។ | ស្ត្រីគាំទ្រការដាំដំណាំចម្រុះ។ |

## ឯកសារទីមេរៀន១៩៖ ចំណុចសំខាន់ៗក្នុងការបន្ស៊ាំនឹងការប្រែប្រួលអាកាសធាតុតាមវិស័យ និងយេនឌ័រ

### ផ្នែក ក៖ កសិកម្ម និងសន្តិសុខស្បៀង

| | |
|---|---|
| វិបត្តិទឹកនឹងកាត់បន្ថយទិន្នផលដំណាំ (ស្រូវ) សម្រាប់មេគ្រួសារជាស្ត្រី។ | វិបត្តិទឹកនឹងបង្កើនបន្ទុកការងាររបស់កសិករជាស្ត្រីដែលធ្វើកសិកម្មសម្រាប់បរិភោគ។ |
| ការប្រែប្រួលអាកាសធាតុនឹងបង្កើនវិបត្តិទឹក។ | ការផលិតចំណីសត្វនឹងរងផលប៉ះពាល់។ |
| នឹងមានការប្រែប្រួលគំរូនៃការប្រើប្រាស់ដី។ | ស្ត្រីងាកទៅរកការចិញ្ចឹមសត្វតូចៗដូចជាមាន់សម្រាប់ជាជម្រើសចិញ្ចឹមជីវិតមួយផ្សេងទៀត ឬចម្រុះ។ |
| ការចិញ្ចឹមសត្វពាហនៈខ្នាតតូចនឹងរងផលប៉ះពាល់កាន់តែខ្លាំងក្នុងពេលមានគ្រោះទឹកជំនន់ និងព្យុះសង្ឃរា។ | ៦០% នៃប្រជាជនដែលអត់ឃ្លានត្រាំត្រែង គឺជាស្ត្រី និងក្មេងស្រី។ |
| ស្ត្រីជាអ្នកទទួលខុសត្រូវលើការចម្អិននិងសន្តិសុខស្បៀងសម្រាប់គ្រួសារ។ | នៅពេលមានសមភាពក្នុងការទទួលបានធនធាន និងសេវា ស្ត្រីអាចបង្កើនទិន្នផលកសិដ្ឋានរហូតដល់ ២០%-៣០%។ |
| ការកើនឡើងទិន្នផលស្បៀងអាហារ ២០%-៣០% អាចចិញ្ចឹមមនុស្សបានរហូតដល់ ១០០-១៥០ លាននាក់បន្ថែមទៀត។ | ជាញឹកញាប់ ស្ត្រីជាអ្នកជ្រើសរើស និងរក្សាទុកគ្រាប់ពូជ។ |
| ស្ត្រីមានចំណេះដឹងជ្រាលជ្រៅស្តីពីសត្វ និងរុក្ខជាតិក្នុងបរិស្ថានរបស់ខ្លួន និងមធ្យោបាយអភិរក្សា។ | ជាធម្មតា ស្ត្រីបានប្រើប្រាស់ធនធានក្នុងសហគមន៍មូលដ្ឋានជាអាហារ ឱសថ និងថាមពល។ |
| ស្ត្រីដើរតួនាទីយ៉ាងសំខាន់ក្នុងនាមជាភ្នាក់ងារអភិរក្សកសិជីវចម្រុះនិងសន្តិសុខស្បៀងគ្រួសារតាមរយៈសួនបន្លែឬក្បាលដីតូចៗ។ | ការដោះស្រាយភាពខុសគ្នារវាងស្ត្រីនិងបុរសលើលទ្ធភាពទទួលបានធនធានហិរញ្ញវត្ថុ និងធនធាន ផលិត ការធ្វើសេចក្តីសម្រេចចិត្តទីផ្សារ និងសេវា ដី និងទឹក ព្រមទាំងចំណេះដឹង និងបច្ចេកវិទ្យាអាចជាយុទ្ធសាស្ត្របន្ស៊ាំដ៏សំខាន់មួយក្នុងការបង្កើនផលិតកម្ម។ |
| ស្ត្រីវិនិយោគប្រាក់ដែលពួកគេទទួលបានពាក់ព័ន្ធនឹងជីវចម្រុះរហូតដល់ ៩០%-៩៥% លើការបង្កើនគុណភាពជីវិតរបស់គ្រួសារ។ | ការបាត់បង់ជីវចម្រុះបង្កផលប៉ះពាល់ខ្លាំងលើសហគមន៍ក្រីក្រនិងសហគមន៍ជនជាតិដើម ជាពិសេសស្ត្រី។ |
| ការធ្វើចំណាកស្រុករបស់បុរសធ្វើឱ្យស្ត្រីកាន់តែច្រើនប្រឡូកក្នុងកសិកម្ម។ | ស្ត្រីមានយុទ្ធសាស្ត្របែបប្រពៃណីសម្រាប់ធានាការផ្គត់ផ្គង់អាហារក្នុងពេលកើតមានគ្រោះមហន្តរាយ ដូចជា ទឹកជំនន់ និងគ្រោះរាំងស្ងួត។ |
| ស្ត្រីទទួលខុសត្រូវលើការរក្សាទុកអាហារ និងគ្រាប់ពូជ។ | ការចិញ្ចឹមសត្វពាហនៈខ្នាតតូច ជាសកម្មភាពដែលងាយផ្តល់ធនធានប្រាក់កាក់ក្នុងគ្រាអាសន្ន។ |
| គម្រោងបន្ស៊ាំនឹងការប្រែប្រួលអាកាសធាតុដែលលើកកម្ពស់ពូជដំណាំថ្មីដែលធន់នឹងគ្រោះរាំងស្ងួត ជាតិប្រៃ និង/ឬទឹកជំនន់ដើម្បីប្រឈមនឹងការប្រែប្រួលប្រព័ន្ធអេកូឡូស៊ី។ | ប្រសិនបើដំណាំថ្មី ឬពូជដំណាំចម្រុះផ្តល់ប្រាក់ចំណេញ និងគ្រប់គ្រងលើសលប់ដោយបុរស វាអាចធ្វើឱ្យស្ត្រីបាត់បង់ដីដែលពួកគាត់ធ្លាប់បង្កបង្កើនផលសម្រាប់បរិភោគ។ |
| ជាញឹកញាប់ ពូជដំណាំ (ថ្មី) ដែលផ្តល់ទិន្នផលខ្ពស់ និងធន់ទាមទារការថែទាំច្រើន។ | បន្ទុកការងាររបស់ស្ត្រីអាចកើនឡើងនៅពេលមានការលើកកម្ពស់ឱ្យប្រើប្រាស់ពូជដំណាំថ្មីដែលផ្តល់ទិន្នផលខ្ពស់ ឬធន់។ |
| ដើម្បីបង្កើនភាពធន់ចាំបាច់ត្រូវផ្តោតសំខាន់លើបច្ចេកវិទ្យាដែលសន្សំសំចៃពេលវេលា និងកម្លាំងពលកម្ម ដែលផ្តល់ប្រយោជន៍ដល់ស្ត្រី។ | ជាញឹកញាប់ ពូជដំណាំថ្មីអាចទាមទារការប្រើប្រាស់ថ្នាំសម្លាប់សត្វល្អិតនិងថ្នាំសម្លាប់រុក្ខជាតិចង្រៃដោយគ្មានការពិចារណាពីផលប៉ះពាល់ផ្អែកតាមយេនឌ័រ ជាពិសេសផលប៉ះពាល់លើស្ត្រីមានផ្ទៃពោះ។ |

## ឯកសារទីមេរៀន១៩៖ ចំណុចសំខាន់ៗក្នុងការបន្សាំនឹងការប្រែប្រួលអាកាសធាតុតាមវិស័យ និងយេនឌ័រ

| | |
|---|---|
| **ផ្នែក ក៖ កសិកម្ម និងសន្តិសុខស្បៀង** | |
| បុរសច្រើនតែចិញ្ចឹមសត្វធំៗដូចជាគោនិងពូជសត្វពាហនៈដែលត្រូវបានកែលម្អ។ | គោក្របីងាយរងគ្រោះដោយសារផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។ |
| ស្ត្រីក៏ដើរតួនាទីសំខាន់ក្នុងការថែទាំគោក្របីផងដែរ។ | គេអាចចិញ្ចឹមសត្វពាហនៈខ្នាតតូច ដូចជា ពពែ និងមាន់ នៅផ្ទះ និងជាញឹកញាប់គឺមិនសូវចំណាយច្រើន និងត្រូវការការថែទាំតិចជាងសត្វពាហនៈធំៗ ដូចជា គោក្របី។ |
| គម្រោងបន្សាំនឹងការប្រែប្រួលអាកាសធាតុលើកកម្ពស់ហេដ្ឋារចនាសម្ព័ន្ធពាក់ព័ន្ធនឹងទឹក (ទំនប់ទឹក បណ្តាញបញ្ជូនទឹក ឬប្រឡាយជាពសាស្ត្រ) សម្រាប់បង្វែរទឹកសាបទៅតំបន់ដែលខ្វះខាតទឹក។ | ជាញឹកញាប់គម្រោងហេដ្ឋារចនាសម្ព័ន្ធដែលពាក់ព័ន្ធនឹងទឹកមិនពិចារណាពីតម្រូវការទឹកសាបរបស់ស្ត្រីសម្រាប់សកម្មភាពផលិត និងសកម្មភាពការងារផ្ទះ។ |
| ស្ត្រីដើរតួនាទីសំខាន់ក្នុងការរៀបចំទឹកពិសានិងទឹកប្រើប្រាស់ក្នុងគ្រួសារ។ | ជារឿយៗស្ត្រីមានចំណាប់អារម្មណ៍ខ្លាំងលើសាកវប្បកម្មឬដើមឈើផ្តល់អុស។ |
| **ផ្នែក ខ៖ សុខភាពសាធារណៈ និងការឆ្លងរាលដាលជំងឺ** | |
| ការប្រែប្រួលអាកាសធាតុ បង្កើនហានិភ័យនៃផលប៉ះពាល់សុខភាព។ | មានភស្តុតាងបង្ហាញពីអត្រាស្លាប់របស់ស្ត្រីនិងក្មេងស្រីក្នុងពេលមានព្យុះសង្ឃរា និងគ្រោះទឹកជំនន់។ |
| ការប្រែប្រួលអាកាសធាតុនឹងបង្កើនហេតុការណ៍ធ្ងន់ធ្ងរ ដូចជា ព្យុះសង្ឃរា និងទឹកជំនន់។ | ជំងឺឆ្លងតាមទឹក និងជំងឺឆ្លងតាមភ្នាក់ងារចម្លង បង្កផលប៉ះពាល់ខ្លាំងលើប្រជាជនក្រីក្រ។ |
| ការប្រែប្រួលអាកាសធាតុនឹងបណ្តាលឱ្យមានរលកកម្តៅ។ | ស្ត្រីប្រឈមនឹងហានិភ័យខ្ពស់នៃការបាត់បង់ជីវិតក្នុងពេលមានរលកកម្តៅ។ |
| ការប្រែប្រួលអាកាសធាតុបង្កើនការឆ្លងរាលដាលជំងឺឆ្លងតាមទឹក និងជំងឺឆ្លងតាមភ្នាក់ងារចម្លង ដូចជា អាសន្នរោគ គ្រុនឈាម គ្រុនចាញ់ និងជំងឺស៊ីស្តូសូមីញ៉ាស៊ីស នៅជុំវិញពិភពលោក។ | ការអនុវត្តក្នុងវប្បធម៌ដែលពាក់ព័ន្ធនឹងស្បៃបិទមុខ (purdah) ការរឹតត្បិតចលនភាព ការស្លៀកពាក់មិនសមស្រប កង្វះជំនាញហែលទឹកកង្វះលទ្ធភាពទទួលបានប្រព័ន្ធប្រកាសអាសន្នព័ត៌មាន។ល។រួមចំណែកធ្វើឱ្យស្ត្រីធ្វើការវាយតម្លៃយឺតពេលដែលនាំទៅកអត្រាស្លាប់កាន់តែខ្ពស់។ |
| បុរសងាយកើតជំងឺគ្រុនឈាមជាងស្ត្រី។ | ស្ត្រី ជាពិសេសស្ត្រីមានផ្ទៃពោះ ងាយកើតជំងឺគ្រុនចាញ់។ |
| ជំងឺអាសន្នរោគអាចបង្កផលប៉ះពាល់ដូចគ្នាលើបុរស និងស្ត្រីក្នុងមជ្ឈដ្ឋានជាច្រើន។ | មិនសូវមានការស្រាវជ្រាវដើម្បីច្បាមយកទិដ្ឋភាពផ្អែកលើយេនឌ័រស្តីពីសុខភាព និង CCDRR ឡើយ។ |
| ទឹកជំនន់ដែលកខ្វក់ នឹងបង្កើនការចម្លងជំងឺដោយសារបាក់តេរី និងវីរុស។ | ទោះជាយ៉ាងណា ការចម្លងជំងឺដោយសារបាក់តេរី និងវីរុសដែលបណ្តាលមកពីការប៉ះពាល់ទឹកជំនន់ដែលកខ្វក់ ហាក់បង្កផលប៉ះពាល់លើស្ត្រីខ្លាំងជាងបុរស។ |
| ស្ត្រីអាចប្រឈមខ្លាំងទៅនឹងបញ្ហាស្បែកដែលបណ្តាលមកពីការប៉ះពាល់ទឹកជំនន់។ | ការបំពុលដោយទឹកប្រៃដែលនឹងកើនឡើងដោយសារការប្រែប្រួលអាកាសធាតុ និងការកើនឡើងនៃកម្រិតនីវ៉ូទឹកសមុទ្រ បង្កផលប៉ះពាល់លើស្ត្រីមានផ្ទៃពោះ ដូចជា ជំងឺបម្រុងក្រឡាភ្លើង ជំងឺក្រឡាភ្លើង ជំងឺលើសឈាម។ |

| ឯកសារទីមេរៀន១៩៖ ចំណុចសំខាន់ៗក្នុងការបន្សាំនឹងការប្រែប្រួលអាកាសធាតុតាមវិស័យ និងយេនឌ័រ | |
|---|---|
| **ផ្នែក ខ៖ សុខភាពសាធារណៈ និងការឆ្លងរាលដាលជំងឺ** | |
| មាននិន្នាការកាន់តែច្រើននៃបញ្ហារោគស្ត្រី ដោយសារការប្រើប្រាស់ទឹកគ្មានអនាម័យ និងបញ្ហាជាំទឹក។ | ការប្រែប្រួលអាកាសធាតុបង្កផលប៉ះពាល់លើសុខភាពផ្លូវចិត្ត ដោយបង្កភាពឱ្យមានតានតឹងបន្ថែមទៀតជាពិសេសក្រោយពេលកើតមានគ្រោះមហន្តរាយដែលជាញឹកញាប់នាំទៅរកការធ្លាក់ទឹកចិត្ត និងការធ្វើអត្តឃាត (ក្នុងករណីធ្ងន់ធ្ងរ)។ |
| គម្រោងបន្សាំនឹងការប្រែប្រួលអាកាសធាតុលើកកម្ពស់ការស្រាវជ្រាវស្តីពីផលប៉ះពាល់ផ្នែកសុខភាពដោយសារការប្រែប្រួលអាកាសធាតុ។ | ជាញឹកញាប់ ស្ត្រីមានតួនាទី "អប់រំ" អំពីរបៀបទប់ស្កាត់ជំងឺទាំងនេះក្នុងគ្រួសារ។ |
| ជាទូទៅ ស្ត្រីងាយប្រឈមនឹងជំងឺដែលពាក់ព័ន្ធនឹងភាពតានតឹង ជាពិសេសជំងឺបាក់ស្បាត និងការធ្លាក់ទឹកចិត្ត។ | បុរសងាយធ្វើអត្តឃាតជាងស្ត្រី។ |
| គ្រោះមហន្តរាយដែលពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុក៏ពាក់ព័ន្ធនឹងការកើនឡើងនៃអំពើហិង្សាទាក់ទងនឹងយេនឌ័រផងដែរ។ | ក្រុម LGBTIQ ជនមានពិការភាព និងក្មេងស្រីវ័យជំទង់ ងាយប្រឈមនឹងការបៀតបៀនផ្លូវភេទ និងអំពើហិង្សាក្នុងគ្រួសារ។ |
| ការជួញដូរស្ត្រី និងក្មេងស្រីដែលមានការរៀបចំ កំពុងលេចឡើងជាហានិភ័យដ៏ធ្ងន់ធ្ងរដែលទាក់ទិននឹងគ្រោះមហន្តរាយពាក់ព័ន្ធនឹងអាកាសធាតុ។ | ស្ត្រីរស់នៅតំបន់ឆ្នេរក៏ប្រឈមនឹងផលប៉ះពាល់ផ្សេងៗដែលពាក់ព័ន្ធនឹងការប្រើប្រាស់ទឹកប្រៃជាពិសេសជំងឺលើសឈាមក្នុងពេលមានផ្ទៃពោះផងដែរ។ |
| ជំងឺដែលបង្កឡើងដោយអាកាសធាតុនឹងនាំទៅរកការខូចខាតហេដ្ឋារចនាសម្ព័ន្ធ និងទ្រព្យសម្បត្តិ។ | សេវាមូលដ្ឋាន ដូចជា ប្រព័ន្ធផ្គត់ផ្គង់ទឹក អាចរងការខូចខាតក្នុងពេលកើតមានគ្រោះមហន្តរាយ។ |
| ការប្រែប្រួលអាកាសធាតុគំរាមកំហែងដល់សមត្ថភាពរបស់ស្ត្រីក្នុងការទទួលបានសេវារៀបចំផែនការគ្រួសារ។ គ្រោះមហន្តរាយធម្មជាតិដែលពាក់ព័ន្ធនឹងអាកាសធាតុនឹងរាំងស្ទះដល់លទ្ធភាពទទួលបានការថែទាំសុខភាពបន្តពូជ។ | ស្ត្រីងាយរងគ្រោះដោយសារភាពខ្វះទឹកដែលបង្ខំឱ្យស្ត្រីដើរកាន់តែឆ្ងាយ និងលីសែង/យួរបន្ទុកធ្ងន់ក្នុងរយៈពេលយូរ។ ចំណុចនេះធ្វើឱ្យខូចឆ្អឹងខ្នងសាច់ដុំកនិងចង្កេះដែលបណ្ដាលឱ្យឆ្អឹងកងធាប់ពុក។ |
| ការប្រែប្រួលអាកាសធាតុងាយបង្កផលប៉ះពាល់លើលទ្ធផលនៃការមានផ្ទៃពោះ និងការថែទាំ។ | ការកើនឡើងនៃបន្ទុកជំងឺដោយសារការប្រែប្រួលអាកាសធាតុនឹងធ្វើឱ្យប៉ះពាល់ដល់តួនាទីថែទាំរបស់ស្ត្រី និងក្មេងស្រី ព្រោះពួកគេត្រូវថែទាំសមាជិកគ្រួសារដែលមានជំងឺ។ |
| ចំណុចនេះនឹងបង្កើនបន្ទុកការងាររបស់ស្ត្រី និងក្មេងស្រី និងជាញឹកញាប់ ធ្វើឱ្យគ្មានការយកចិត្តទុកដាក់លើសុខភាព និងសុខុមាលភាពរបស់ពួកគេផ្ទាល់។ | ការប្រែប្រួលអាកាសធាតុ នឹងបង្កើនភាពខ្វះទឹក ដែលបង្ខំឱ្យគ្រួសារជាច្រើនប្រើប្រភពទឹកដែលគ្មានសុវត្ថិភាព ដូចជា បឹងបួរ និងស្រះ ដែលងាយកខ្វក់។ |
| គ្រោះរាំងស្ងួតដែលកើតឡើងជាច្រើនលើកច្រើនសាធ្វើឱ្យបញ្ហាទឹកកាន់តែធ្ងន់ធ្ងរ។ | ការខូចខាតហេដ្ឋារចនាសម្ព័ន្ធអនាម័យ និងភាពខ្វះទឹក ជាពិសេសបង្គន់អនាម័យ និងបន្ទប់ទឹកដែលគ្មានទឹកម៉ាស៊ីន ក៏រឹតត្បិតការរក្សាអនាម័យនៅពេលមករដូវផងដែរ។ |
| ផលប៉ះពាល់នៃគ្រោះមហន្តរាយអាចបង្កើនផលប៉ះពាល់នៃឧបសគ្គពីមុនមក ដែលរារាំងស្ត្រីមិនឱ្យស្វែងរកសេវាសុខភាពបន្តពូជ។ | ការប្រែប្រួលអាកាសធាតុគំរាមកំហែងដល់ផលិតកម្មដំណាំ ដូចជាការថយចុះគុណភាព និងបរិមាណដំណាំស្បៀង ដែលនាំទៅរកអសន្តិសុខស្បៀង និងកង្វះអាហារូបត្ថម្ភ។ |

| ឯកសារទីមេរៀន១៩៖ ចំណុចសំខាន់ៗក្នុងការបន្សាំនឹងការប្រែប្រួលអាកាសធាតុតាមវិស័យ និងយេនឌ័រ | |
|---|---|
| **ផ្នែក ខ៖ សុខភាពសាធារណៈ និងការឆ្លងរាលដាលជំងឺ** | |
| ជាញឹកញាប់ស្ត្រីនិងក្មេងស្រីត្រូវញ៉ាំក្រោយគេនិងជាអ្នកដែលត្រូវតមអាហារ និងប្រឈមនឹងបញ្ហាអាហារូបត្ថម្ភមុនគេ ក្នុងពេលខ្វះអាហារ។ | ការសិក្សាបង្ហាញថា មរណភាពកុមារបានកើនឡើង ក្រោយការកើតមានព្យុះទីហ្វុងដែលអ្នកស្រាវជ្រាវកំណត់ថាបណ្ដាលមកពីការដណ្ដើមធនធានកម្រក្នុងគ្រួសារ។ |
| ផលប៉ះពាល់នៃការប្រែប្រួលអាកាសលើបញ្ហាកង្វះអាហារូបត្ថម្ភនឹងនាំឱ្យមានឆ្នាំនៃជីវិតដែលត្រូវបានកែតម្រូវដោយសារពិការភាព (DALY) ក្នុងប្រទេសកំពុងអភិវឌ្ឍន៍។ | ស្ត្រីងាយរងគ្រោះដោយសារកង្វះអាហារូបត្ថម្ភជាងបុរស ដោយសារតែលក្ខខណ្ឌតម្រូវផ្នែកអាហារូបត្ថម្ភរបស់ស្ត្រីជាពិសេសក្នុងពេលពរពោះ និងបំបៅដោះកូន។ |
| ក្មេងស្រីប្រឈមនឹងហានិភ័យកាន់តែធ្ងន់ធ្ងរនៃការវាយប្រហារដោយគ្រោះមហន្តរាយដែលបង្កឡើងដោយអាកាសធាតុជាហេតុនាំឱ្យមានអាពាហ៍ពិពាហ៍កុមារកាន់តែច្រើន។ | បុរសងាយស្លាប់ក្នុងពេលកើតមានគ្រោះមហន្តរាយដោយសារតែបទដ្ឋានយេនឌ័រដែលជំរុញការប្រថុយប្រថាន។ |
| ជាញឹកញាប់ស្ត្រីមិនសូវមានឬមានលទ្ធភាពតិចក្នុងការទទួលបានសេវាសុខភាព។ | ស្ត្រីមានសមាសភាគច្រើនលើសលប់ក្នុងចំណោមអ្នកដែលមើលថែអ្នកមានជំងឺ (ទាំងជាអ្នកថែទាំក្នុងគ្រួសារ និងជាបុគ្គលិកសុខភាពជួរមុខ)។ |
| គម្រោងបន្សាំនឹងការប្រែប្រួលអាកាសធាតុស្ដីពីសុខភាពលើកកម្ពស់ប្រព័ន្ធប្រកាសអាសន្នព័ត៌មាន និងប្រព័ន្ធឃ្លាំមើលជំងឺ។ | គម្រោងបន្សាំនឹងការប្រែប្រួលអាកាសធាតុលើកកម្ពស់បច្ចេកវិទ្យាសមស្រប និងបទដ្ឋាននៃការផ្លាស់ប្ដូរឥរិយាបថសម្រាប់ការទប់ស្កាត់ជំងឺ។ |
| **ផ្នែក គ៖ តំបន់ឆ្នេរ** | |
| តំបន់ឆ្នេរមានប្រព័ន្ធអេកូឡូស៊ីសំខាន់ៗដែលសំបូរដោយធនធានសេដ្ឋកិច្ច និងសកម្មភាពសេដ្ឋកិច្ច។ | តំបន់ឆ្នេរមានដង់ស៊ីតេប្រជាជនខ្ពស់ជាងតំបន់ដីគោក។ |
| កំណើនសីតុណ្ហភាពអាចធ្វើឱ្យមានបម្រែបម្រួលការផ្លាស់ទីរបស់ត្រី និងធ្វើឱ្យពូជត្រីដាច់ពូជ។ | របរចិញ្ចឹមជីវិតរបស់សហគមន៍នេសាទនឹងទទួលរងផលប៉ះពាល់ខ្លាំងដោយសារបម្រែបម្រួលចំនួនត្រី។ |
| ខ្យល់ព្យុះ (រួមមាន ខ្យល់ព្យុះត្រូពិច ដូចជា ព្យុះសង្ឃរា និងព្យុះស៊ីក្លូន ព្រមទាំងផ្គររន្ទះ) និងទឹកជំនន់ បង្កឱ្យមានហានិភ័យខ្ពស់ដល់ជីវិតរស់នៅរបស់សហគមន៍តំបន់ឆ្នេរ។ | តំបន់អាស៊ីមានប្រជាជនជាង៩០ភាគរយនៃប្រជាជនពិភពលោកដែលប្រឈមនឹងព្យុះស៊ីក្លូនត្រូពិច។ |
| ប្រព័ន្ធនៅតំបន់ឆ្នេរ និងសមុទ្រកំពុងប្រឈមនឹងសម្ពាធកាន់តែខ្លាំងដោយសារការប្រែប្រួលអាកាសធាតុ។ | បម្រែបម្រួលប្រព័ន្ធអេកូឡូស៊ីតំបន់សមុទ្រ និងគ្រោះមហន្តរាយដែលកើតឡើងញឹកញាប់នឹងបង្កផលប៉ះពាល់ដល់វិស័យទេសចរណ៍។ |
| វិស័យទេសចរណ៍ជាប្រភពដ៏សំខាន់ដែលផ្ដល់ប្រាក់ចំណូលបន្ថែមគ្រួសារដល់ភាគច្រើនដែលរស់នៅតំបន់ឆ្នេរ។ | ការប្រែប្រួលអាកាសធាតុនឹងធ្វើឱ្យខូចខាតប្រព័ន្ធអេកូឡូស៊ីនៅតំបន់ឆ្នេរ។ |
| ការខូចខាតប្រព័ន្ធអេកូឡូស៊ីនៅតំបន់ឆ្នេរនឹងធ្វើឱ្យបាត់បង់របរចិញ្ចឹមជីវិតរបស់ប្រជាជនរាប់លាននាក់ជាពិសេសប្រជាជនក្រីក្រ និងស្ត្រី។ | ដីសើមទឹកសាបនៅតំបន់ឆ្នេរក៏ប្រឈមនឹងការជ្រៀតចូលនៃទឹកប្រៃដោយសារកំណើននីវ៉ូទឹកសមុទ្រផងដែរ។ |
| ធនធានទឹកដែលមានកម្រិតជាតិប្រៃខុសៗគ្នានឹងត្រូវបានបំពុលដោយសារការជ្រៀតចូលនៃទឹកប្រៃ។ | ក្នុងចំណោមប្រជាជន១០នាក់យ៉ាងហោចណាស់មានម្នាក់ដែលរស់នៅជិតតំបន់ឆ្នេរក្នុងតំបន់ទំនាប ភាគច្រើននៅសហរដ្ឋអាមេរិក និងប្រទេសនៅអាស៊ី ដូចជា ចិន ឥណ្ឌា បង់ក្លាដេស វៀតណាម និងឥណ្ឌូនេស៊ី។ |

| ឯកសារទីមេរៀន១៩៖ ចំណុចសំខាន់ៗក្នុងការបន្សាំនឹងការប្រែប្រួលអាកាសធាតុតាមវិស័យ និងយេនឌ័រ | |
|---|---|
| **ផ្នែក គ៖ តំបន់ឆ្នេរ** | |
| ប្រព័ន្ធអេកូឡូស៊ីនៅតំបន់សមុទ្រនឹងរងផលប៉ះពាល់អវិជ្ជមានដោយសារការកើនឡើងនៃជាតិអាស៊ីត និងសីតុណ្ហភាពទឹកក្នុងមហាសមុទ្រ។ | កត្តានេះនឹងធ្វើឱ្យមានការថយចុះជីវៈចម្រុះ ជាពិសេសការបាត់បង់ភ្នាក់ងារពោយលម្អងផ្កាក្នុងតំបន់។ |
| ការបាត់បង់ភ្នាក់ងារពោយលម្អងផ្កានឹងធ្វើឱ្យប៉ះពាល់ដល់ភាពអាចរកបានអាហារសម្រាប់សហគមន៍តាមតំបន់ឆ្នេរ។ | ការជ្រៀតចូលទឹកប្រៃនឹងធ្វើឱ្យប៉ះពាល់ដល់ផលិតកម្មកសិកម្ម ជាពិសេសទិន្នផលស្រូវ។ |
| កំណើននីវ៉ូទឹកសមុទ្រ គួបផ្សំនឹងភាពខ្លាំងក្លានៃខ្យល់ព្យុះស៊ីក្លូន អាចបង្កើនការកើតមានទឹកជំនន់នៅតាមតំបន់ឆ្នេរ។ | តំបន់ឆ្នេរក៏អាចផ្តល់របាំងធម្មជាតិការពារគ្រោះមហន្តរាយ ដូចជា ព្យុះសង្ឃរា និងព្យុះស៊ីក្លូន បានផងដែរ។ |
| ភាពរេចរឹលនៃប្រព័ន្ធអេកូឡូស៊ីតាមតំបន់ឆ្នេរជាពិសេសថ្មប៉ប្រះទឹក និងព្រៃកោងកាង នឹងបង្កើនការបំផ្លាញដោយសាររលកសមុទ្រ។ | កំណើនសីតុណ្ហភាពក្នុងរដូវរងាអាចបង្កឱ្យមានការរីកសាយនៃប្រព័ន្ធអេកូឡូស៊ីព្រៃកោងកាងឆ្ពោះទៅតំបន់ប៉ូល។ |
| ព្យុះសង្ឃរានិងគ្រោះមហន្តរាយដែលបង្កឡើងដោយការប្រែប្រួលអាកាសធាតុ អាចធ្វើឱ្យបាត់បង់ទីជម្រករបស់ប្រជាជននៅតំបន់ឆ្នេររាប់លាននាក់។ | កំណើននីវ៉ូទឹកសមុទ្រត្រូវបានរំពឹងថា នឹងកើនឡើងបន្ថែមទៀត។ |
| កំណើននីវ៉ូទឹកសមុទ្រនឹងបង្កើនការកើតមានគ្រោះទឹកជំនន់នៅតំបន់ឆ្នេរសំណឹកដីនិងការជ្រៀតចូលនៃទឹកប្រៃទៅក្នុងប្រភពទឹកលើដី និងក្រោមដី។ | ដោយសារការកើនឡើងកម្រិតទឹកសមុទ្រ ឆ្នេរសមុទ្រអាចនឹងរេចរឹល ហើយព្រៃកោងកាង តំបន់ដីសើមទឹកប្រៃ និងស្រទាប់ស្មៅសមុទ្រនឹងធ្លាក់ចុះ។ |
| គ្រោះមហន្តរាយដែលបណ្តាលមកពីអាកាសធាតុនឹងបង្កការបំផ្លិចបំផ្លាញធ្ងន់ធ្ងរដល់ហេដ្ឋារចនាសម្ព័ន្ធ និងទ្រព្យសម្បត្តិ។ | សេវាមូលដ្ឋានដូចជាប្រព័ន្ធផ្គត់ផ្គង់ទឹកអាចរងការបំផ្លិចបំផ្លាញក្នុងពេលកើតមានគ្រោះមហន្តរាយ។ |
| សាលារៀនអាចរងការបំផ្លិចបំផ្លាញនិងបិទក្នុងអំឡុងពេលកើតមានគ្រោះមហន្តរាយធំៗ ដូចជា ព្យុះទីហ្វុង។ | ស្ត្រីងាយនឹងស្លាប់ក្នុងពេលកើតមានគ្រោះមហន្តរាយជាងបុរស។ |
| ការអនុវត្តក្នុងសង្គមវប្បធម៌ ដូចជា ស្បៀបិទមុខ ការរិតត្បិតការដើរហើររបស់ស្ត្រី កង្វះលទ្ធភាពទទួលបានព័ត៌មាន និងប្រព័ន្ធប្រកាសអាសន្នព័ត៌មានការតុបតែងខ្លួនបែបប្រពៃណីនិងកង្វះខាតជំនាញហែលទឹក ។ល។ ធ្វើឱ្យស្ត្រីមិនអាចធ្វើការវាយតម្លៃបានលឿនក្នុងពេលកើតមានគ្រោះមហន្តរាយ។ | មានការប៉ាន់ស្មានថា នៅតំបន់ប៉ាស៊ីហ្វិច ស្ត្រីអាចរកបានអាហារប្រហែល ១/៤ នៃអាហារសមុទ្រដែលរកបានសរុប។ នៅប្រទេសកម្ពុជា ឡាវ ថៃ វៀតណាម និងហ្វីលីពីន មានសហគមន៍មួយចំនួនដែលស្ត្រីដើរតួនាទីសំខាន់ជាងបុរសក្នុងផលិតកម្មវារីវប្បកម្ម និងការប្រមូលផលពពួកសត្វតូចៗតាមច្រាំងសមុទ្រ។ |
| គ្រោះមហន្តរាយដែលពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុអាចធ្វើឱ្យអំពើហិង្សាទាក់ទងនឹងយេនឌ័រកើតឡើងកាន់តែច្រើន។ | ក្រុម LGBTIQ ជនមានពិការភាព និងក្មេងស្រីវ័យជំទង់ប្រឈមហានិភ័យខ្ពស់នៃការបៀតបៀនផ្លូវភេទ និងអំពើហិង្សាក្នុងជម្រករបស់ខ្លួន។ |
| ការជួញដូរស្ត្រី និងក្មេងស្រីដែលមានការរៀបចំ កំពុងលេចឡើងជាហានិភ័យដ៏ធ្ងន់ធ្ងរដែលទាក់ទិននឹងគ្រោះមហន្តរាយពាក់ព័ន្ធនឹងអាកាសធាតុ។ | គ្រួសារមេស្ត្រីជាមេគ្រួសារងាយរងគ្រោះទៅនឹងទឹកជំនន់និងផលប៉ះពាល់ផ្សេងទៀតដែលបណ្តាលមកពីខ្យល់ព្យុះ។ |
| ស្ត្រីចូលរួមក្នុងវិស័យនេសាទ ជាពិសេសការកែច្នៃត្រី ការរៀបចំត្រីយកទៅលក់នៅទីផ្សារនិងសកម្មភាពប្រមូលផលខ្ចាតតូចនៅជិតច្រាំងសមុទ្រ។ | ការបាត់បង់ទម្រធនធាននៅជិតច្រាំងសមុទ្រ ធ្វើឱ្យស្ត្រីរងផលប៉ះពាល់កាន់តែខ្លាំង ដោយសារការគំរាមកំហែងលើសន្តិសុខស្បៀង និងអាហារូបត្ថម្ភគ្រួសារ។ |

| ឯកសារទីមេរៀន១៩៖ ចំណុចសំខាន់ៗក្នុងការបន្សាំនឹងការប្រែប្រួលអាកាសធាតុតាមវិស័យ និងយេនឌ័រ | |
|---|---|
| **ផ្នែក គ៖ តំបន់ឆ្នេរ** | |
| បុរសចាកចេញពីសហគមន៍ដើម្បីស្វែងរកការងារទទួលបានប្រាក់ឈ្នួលក្នុងគោលបំណងស្តារជីវភាពឡើងវិញក្រោយការកើតមានគ្រោះមហន្តរាយ។ | លទ្ធផលនៃគ្រោះមហន្តរាយដាក់សម្ពាធធ្ងន់ធ្ងរលើស្ត្រី ពាក់ព័ន្ធនឹងបន្ទុកការងារប្រចាំថ្ងៃ។ |
| ជាញឹកញាប់ ជនជាតិដើមភាគតិច និងស្ត្រីមានសមាសភាពច្រើនលើសលប់ក្នុងការងារទទួលបានប្រាក់ឈ្នួលទាបក្នុងវិស័យទេសចរណ៍។ | ស្ត្រីអាចប្រឈមខ្លាំងទៅនឹងបញ្ហាស្បែកដែលបណ្តាលមកពីការប៉ះពាល់ទឹកជំនន់។ |
| មនុស្សស្រី (ស្ត្រី និងក្មេងស្រី) ងាយប្រឈមនឹងជំងឺបាក់ស្បាតជាងមនុស្សប្រុស។ | ស្ត្រីរស់នៅតាមតំបន់ឆ្នេរប្រឈមនឹងផលប៉ះពាល់ផ្សេងៗដោយសារការប្រើប្រាស់ទឹកប្រៃជាពិសេសការឡើងសម្ពាធឈាមក្នុងអំឡុងពេលពរពោះ។ |
| ការប្រែប្រួលអាកាសធាតុគំរាមកំហែងដល់លទ្ធភាពរបស់ស្ត្រីក្នុងការស្វែងរកសេវាពន្យារកំណើត។គ្រោះមហន្តរាយធម្មជាតិដែលបណ្តាលមកពីអាកាសធាតុរាំងលទ្ធភាពទទួលបានសេវាថែទាំសុខភាពបន្តពូជ។ | ផលប៉ះពាល់នៃគ្រោះមហន្តរាយអាចបង្កើនផលប៉ះពាល់នៃឧបសគ្គពីមុនមកដែលរារាំងស្ត្រីមិនឱ្យស្វែងរកសេវាសុខភាពបន្តពូជ។ |
| ការការពារតំបន់ឆ្នេរក្នុងគម្រោងបន្សាំនឹងការប្រែប្រួលអាកាសធាតុ រួមមាន ការសង់របាំងរូបវន្ត (ដូចជា ជញ្ជាំងសមុទ្រ ជញ្ជាំងការពារឆ្នេរសមុទ្រ របាំងទប់ទឹកការពារឆ្នេរ បង្គោលទប់ទឹករលក និងទ្វារបង្ហូរទឹក)។ | ប្រសិនបើគ្មានគម្រោងសាងសង់ដែលមានទស្សនៈវិស័យយេនឌ័រទេ គម្រោងនឹងផ្តល់ប្រភពការងារជាច្រើនដល់បុរស ចំណែកស្ត្រីមិនមានឱកាសធ្វើការងារទាំងនោះឡើយ។ |
| ជាញឹកញាប់ ស្ត្រីរងគ្រោះ កាន់តែច្រើនដោយសារការរៀបចំគោលនយោបាយស្តីពីផែនការគ្រោះមហន្តរាយមិនបានគិតគូរពីតម្រូវការ និងកង្វល់របស់ស្ត្រី។ | ជារឿយៗស្ត្រីមិនបានចូលរួមក្នុងការរចនាសំណង់ជុំវិញខ្លួនឡើង។ ឧ. ការងារសំណង់ភាគច្រើនគឺជាការងាររបស់បុរស។ |
| ស្ត្រីមិនងាយទទួលបានព័ត៌មានទាក់ទងនឹងមុខសញ្ញាគ្រោះថ្នាក់ឡើយ។ | ស្ត្រី និងបុរសមានការចង់បានខុសគ្នាពាក់ព័ន្ធនឹងការទទួលបានការប្រកាសអាសន្ន ព្រោះជាញឹកញាប់ ស្ត្រីមិនសូវបានស្តាប់វិទ្យុ មើលទូរទស្សន៍ និងប្រើទូរស័ព្ទចល័តដូចបុរសឡើយ។ |
| ស្ត្រីក៏ទទួលរងផលប៉ះពាល់ច្រើនផងដែរ ព្រោះមិនអាចទៅកាន់ជម្រកសុវត្ថិភាពដោយសារផ្លូវឆ្ងាយ។ | ក្នុងសង្គមជាច្រើនបុរសជាអ្នកធ្វើការសម្រេចចិត្តលើការជម្លៀសគ្រួសារទាំងមូល។ |
| ស្ត្រីប្រឈមនឹងឧបសគ្គបន្ថែមទៀតប្រសិនបើជម្រកសុវត្ថិភាពមិនត្រូវបានរៀបចំក្នុងលក្ខណៈមួយដែលផ្តល់ចន្លោះ ឬឯកជនភាពគ្រប់គ្រាន់។ | គម្រោងបន្សាំនឹងការប្រែប្រួលអាកាសធាតុ ជំរុញឱ្យមានការការពារប្រព័ន្ធអេកូឡូស៊ីមានស្រាប់ និងការដាំដើមឈើឡើងវិញនៅជិតបណ្តោយឆ្នេរ។ |
| ការស្តារឡើងវិញនូវប្រព័ន្ធអេកូឡូស៊ីដែលខូចខាតនឹងកាន់តែធ្វើឲ្យមានវិសមភាពយេនឌ័រកាន់តែខ្លាំងតាមរយៈការជំរុញឱ្យមានការងារស្ម័គ្រចិត្ត(គ្មានប្រាក់ឈ្នួល)សម្រាប់ស្ត្រីជាច្រើនក្នុងសកម្មភាពស្តារនីតិសម្បទា និងអភិរក្ស។ | ការនាំយកពូជរុក្ខជាតិ និងសត្វក្នុងតំបន់ និងធន់នឹងអំបិលដើម្បីការពារ/ស្តារតំបន់ឆ្នេរឡើងវិញ ដោយគ្មានការពិគ្រោះយោបល់ជាមួយស្ត្រីនិងគិតគូរពីចំណេះដឹងរបស់ស្ត្រីអាចបង្កផលប៉ះពាល់អវិជ្ជមានលើផលប្រយោជន៍របស់ស្ត្រី។ |
| ដោយសារការផ្តោតលើសកម្មភាពប្រមូលផលបន្ទាប់បន្សំការងាររបស់ស្ត្រីក្នុងវិស័យនេសាទមិនត្រូវបានផ្តល់អាទិភាពក្នុងការវិភាគសេដ្ឋកិច្ច ឬការវិនិយោគធនធានឡើយ។ | ហេតុការណ៍ធ្ងន់ធ្ងរ ដូចជា ព្យុះទីហ្វុង ច្រើនតែបង្កការខូចខាតដល់ហេដ្ឋារចនាសម្ព័ន្ធសេវាសុខាភិបាល។ |

| ឯកសារទីមេរៀន១៩៖ ចំណុចសំខាន់ៗក្នុងការបន្ស៊ាំនឹងការប្រែប្រួលអាកាសធាតុតាមវិស័យ និងយេនឌ័រ | |
|---|---|
| ផ្នែក គ៖ តំបន់ឆ្នេរ | |
| គម្រោងនេសាទភាគច្រើនរៀបចំឡើងសម្រាប់បុរស ហើយការរៀបចំផែនការ កម្មវិធី និងការគ្រប់គ្រងមិនសូវមានការចូលរួមពីស្ត្រីឡើយ។ | ការងារក្នុងវិស័យទេសចរណ៍បង្កើតឡើងវិញនូវបទដ្ឋានបែបប្រពៃណីជុំវិញការបែងចែងការងារតាមភេទ (ដូចជាការជួលស្ត្រីឱ្យធ្វើជាអ្នករៀបចំបន្ទប់ និងចុងភៅ)។ |

## ឯកសារមេរៀនទី ២០៖ ឧទាហរណ៍នៃដំណោះស្រាយឆ្លើយតបយេនឌ័រ

### ឧទាហរណ៍ទី ១៖ ការផ្តល់ភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រីតាមរយៈការធ្វើឱ្យប្រសើរឡើងខ្សែច្រវាក់តម្លៃកសិកម្ម (WEAVE)

| ប្រទេស៖ | អង្គការ៖ | វិស័យ |
|---|---|---|
| វៀតណាម | អង្គការ Oxfam, អង្គការ Care International អង្គការ SNV | កសិកម្ម |

| | |
|---|---|
| ការពិពណ៌នា៖ | WEAVE គាំទ្រការផ្តល់ភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រីជនជាតិភាគតិចនៅក្នុងច្រវាក់តម្លៃនៃសាច់ជ្រូក គ្រឿងទេស និងផ្លែចេក។ ក្នុងច្រវាក់តម្លៃនីមួយៗ សក្តានុពលផលិតករជាស្ត្រី ត្រូវបានរាំងដោយកង្វះការទទួលបានទីផ្សារប្រកបដោយសុវត្ថិភាព ជំនាញបច្ចេកទេស និងហិរញ្ញវត្ថុរួមជាមួយការបែងចែកតួនាទី និងការទទួលខុសត្រូវរវាងស្ត្រី និងបុរស ដែលនាំឲ្យផាត់ស្ត្រីចេញពីការធ្វើសេចក្តីសម្រេចចិត្តនិងនាំឱ្យមានបន្ទុកការងារក្នុងគ្រួសារនិងបន្ទុកការបង្កើតប្រាក់ចំណូលខ្ពស់។ចន្លោះឆ្នាំ២០១៣ទៅឆ្នាំ២០១៥គម្រោងនេះបានគាំទ្រដល់ស្ត្រីជនជាតិភាគតិចនៅតំបន់ដាច់ស្រយាលជាង ១៧២០នាក់ឱ្យបានរៀនសូត្រអំពីសិទ្ធិរបស់ពួកគេនិងការទទួលបានហិរញ្ញវត្ថុសម្រាប់សកម្មភាពបង្កើតប្រាក់ចំណូល តាមរយៈការបង្កើត VSLA របស់ស្ត្រីចំនួន ៤១ និងតាមរយៈការពង្រឹងក្រុមស្ត្រីចំនួន ៣០ ដែលមានស្រាប់។ គម្រោងនេះធ្វើការជាមួយស្ត្រីជនជាតិភាគតិចនៅតំបន់ដាច់ស្រយាលចំនួន ៤២៦ ដោយបណ្តុះបណ្តាលពួកគេពីការប្រែប្រួលអាកាសធាតុនិងជួយពួកគេកំណត់ឱ្យឃើញនិងអនុវត្តជម្រើសជីវភាពរស់នៅថ្មីធន់នឹងអាកាសធាតុ។ |
| យុទ្ធសាស្ត្រយេនឌ័រ/ផលប៉ះពាល់៖<br><br>ប្រភព៖ (អង្គការ Care International, អង្គការ Oxfam និងអង្គការ SNV nd) | ក្រៅពីមានស្ត្រីជាដៃគូអភិវឌ្ឍន៍ស្នូលហើយ គម្រោងនេះមានបំណងលើកកម្ពស់សមភាពរវាងស្ត្រីនិងបុរសនៅក្នុងគ្រួសារ និងក្រុមផលិតករ ពង្រឹងជំនាញផលិតករស្ត្រី និងបុរស និងអំណាចចរចារ និងធ្វើការជាមួយអ្នកជំនួញនិងអ្នកធ្វើសេចក្តីសម្រេចចិត្តរបស់រដ្ឋាភិបាលដើម្បីធ្វើឱ្យប្រសើរឡើងនូវបរិស្ថានគោលនយោបាយក្នុងការគាំទ្រដល់ផលិតករ។តាមរយៈសកម្មភាពនិងការពិភាក្សាជាមួយស្ត្រីនិងបុរស គោលដៅគម្រោងបានគាំទ្រសមភាពរវាងស្ត្រីនិងបុរសដើម្បីឱ្យស្ត្រីអាចរីករាយនឹងផលប្រយោជន៍ដែលបានកើនឡើងពីការងាររបស់ពួកគេនៅក្នុងច្រវាក់តម្លៃផ្លែចេក គ្រឿងទេស និងសាច់ជ្រូក។<br>គម្រោងក៏បានធ្វើការវិភាគយេនឌ័រដែលមានការចូលរួមក្នុងការកំណត់តួនាទីស្ត្រី និងបុរស ការទទួលខុសត្រូវ និងបទដ្ឋានយេនឌ័រប្រកបដោយទុក្ខទោស និងបានធ្វើការជាមួយសហគមន៍ ដើម្បីអភិវឌ្ឍន៍ផែនការសកម្មភាពក្នុងការដោះស្រាយបទដ្ឋានប្រកបដោយទុក្ខទោសណាមួយ។ផែនការនេះក៏បានទាញអ្នកចូលរួមនិងដៃគូគម្រោងជាង៤០០នាក់ឱ្យចូលពាក់ព័ន្ធនៅក្នុងកិច្ចសន្ទនាអំពីអំពើហិង្សាទាក់ទងនឹងយេនឌ័រ ដោយមានអ្នកសម្របសម្រួលក្រុមរបស់ស្ត្រី ដែលបង្ហាញពីការបង្កើនការប្តេជ្ញាចិត្ត ដើម្បីដោះស្រាយបញ្ហានេះ។ កិច្ចសន្ទនានេះរួមបញ្ចូលការធ្វើការជាមួយអាជ្ញាធរជាបុរស ដើម្បីបង្កើតលំហរសម្រាប់សំឡេងស្ត្រីនៅក្នុងវេទិកាការធ្វើសេចក្តីសម្រេចចិត្ត និងការបង្កើតបណ្តាញ «ការចូលរួមរបស់បុរសសម្រាប់សមភាពយេនឌ័រ» ដើម្បីលើកកម្ពស់សិទ្ធិរបស់ស្ត្រី។ |

## ឯកសារមេរៀនទី ២០៖ ឧទាហរណ៍នៃដំណោះស្រាយឆ្លើយតបយេនឌ័រ

### ឧទាហរណ៍ទី ២៖ សួនបន្លែផ្តល់ផលប្រយោជន៍សម្រាប់ស្ត្រីជាប្រចាំ

| ប្រទេស៖ | អន្តរាគារ៖ | វិស័យ |
|---|---|---|
| កម្ពុជា | UNEP UN Women | កសិកម្ម ថាមពល |

**ការពិពណ៌នា៖**

អង្គការ UN Women និងអង្គការ UN Environment ផ្តួចផ្តើមឡើងរួមគ្នានូវគម្រោង EmPower សម្រាប់ការពង្រឹងគោលនយោបាយអាកាសធាតុដែលមានឆ្លើយតបទៅនឹងតម្រូវការយេនឌ័រ និងDRR។ ចន្លោះឆ្នាំ២០១៨ និងឆ្នាំ២០២២ កម្មវិធីនេះផ្តោតលើប្រទេសបង់ក្លាដេស កម្ពុជា និងវៀតណាម រួមជាមួយដៃគូអង្គការរដ្ឋាភិបាល មិនមែនរដ្ឋាភិបាល និងសង្គមស៊ីវិល ឆ្ពោះទៅសម្រេចគោលដៅនេះ។

នៅក្នុងខេត្តពោធិ៍សាត់នៃប្រទេសកម្ពុជាគម្រោងធ្វើឡើងផ្អែកលើការសិក្សារការកំណត់វិសាលភាពដោយគម្រោង EmPower និងគម្រោង Nexus សម្រាប់ការអភិវឌ្ឍដែលគូសបញ្ជាក់ពីរបៀបដែលតំបន់បានប្រឈមនឹងបន្ទុកពីរ មានទាំងទឹកធំ និងទឹកតូច។ ម្យ៉ាងទឹកជំនន់បោកបក់បំផ្លាញផលដំណាំម្យ៉ាងទៀតអំឡុងខែខ្លះក្បាលហុងទឹករីងស្ងួតវាលស្រែក្រៀមស្វិតហើយអ្នកភូមិធ្វើដំណើរដោយថ្មើជើងរហូតដល់ ២០ គីឡូម៉ែត្រដើម្បីទៅរកទឹក។ ដោយមានគោលបំណងជំរុញជីវភាពរស់នៅធន់នឹងអាកាសធាតុគម្រោងនេះលើកទឹកចិត្តនិងគាំទ្រស្ត្រីឱ្យប្រើប្រាស់ម៉ាស៊ីនបូមទឹកដំណើរការដោយថាមពលកកើតឡើងវិញ ឡជីវឧស្ម័ន និងម៉ាស៊ីនសំណើម និងសម្ងួតផលដំណាំ ដែលអាចផ្តល់អត្ថប្រយោជន៍ដល់ស្ត្រីជាកសិករក្នុងរយៈពេលយូរអង្វែង។

តាមរយៈការគាំទ្រពីគម្រោង ស្ត្រីក៏ចាប់ផ្តើមជាមួយសួនបន្លែដាំតាមផ្ទះលក្ខណៈចម្រុះ។ ចាប់ពីផ្កាខាត់ណាផ្កា ទៅជាសាឡាត់ និងឃ្លោក ពហុដំណាំនៅក្នុងសួនបន្លែទាំងនេះមិនត្រឹមជួយរក្សាជីជាតិប៉ុណ្ណោះទេ ប៉ុន្តែក៏ជាប្រភពចំណូលជាប្រចាំមួយដែរ ដោយផ្តល់ចំណូលជិត ៥០០ដុល្លារអាមេរិកក្នុងមួយរដូវៗ។ ទឹកស្រោចស្រពសួនបន្លែ បានមកពីអណ្តូងទឹកក្នុងមូលដ្ឋាន/គ្រួសារមានជំនួយពីម៉ាស៊ីនបូមទឹកអគ្គិសនី និង/ឬ ម៉ាស៊ីនភ្លើងដំណើរការដោយប្រេងម៉ាស៊ូត ដែលអាចធ្វើបានតាមរយៈការលើកកម្ពស់ថាមពលកកើតឡើងវិញនៅក្នុងមូលដ្ឋានដែលការទទួលបានការប្រើប្រាស់បណ្តាញអគ្គិសនីនៅតែជាបញ្ហាប្រឈមមួយ។

**យុទ្ធសាស្ត្រយេនឌ័រ/ ផលប៉ះពាល់៖**

ផ្នែកសំខាន់បំផុតនៃគម្រោងនេះ គឺលើកទឹកចិត្តស្ត្រី និងក្រុមដែលជួបការលំបាកឱ្យចូលរួមនៅក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្ត បង្កើត វិភាគ និងប្រើប្រាស់ភេទ អាយុ និងពិពិធកម្ម ដែលបំបែកទិន្នន័យដើម្បីផ្តល់ព័ត៌មានដល់គោលនយោបាយកែលម្អការឆ្លើយតបយេនឌ័រនៅក្នុងគោលនយោបាយកាត់បន្ថយហានិភ័យអាកាសធាតុ និងគ្រោះមហន្តរាយ អាចឱ្យស្ត្រីប្រើប្រាស់ថាមពលកកើតឡើងវិញធ្វើជាធនធានសេដ្ឋកិច្ចសម្រាប់ជីវភាពរស់នៅប្រកបដោយភាពធន់ និងកែលម្អយន្តការថ្នាក់តំបន់ ដំណើរការ និងចំណេះដឹងអំពី ការប្រែប្រួលអាកាសធាតុ និងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ដើម្បីដាក់បញ្ចូលយេនឌ័រ និងសិទ្ធិមនុស្ស។

ប្រភព៖ (UNEP ឆ្នាំ២០១៩)

## ឯកសារមេរៀនទី ២០៖ ឧទាហរណ៍នៃដំណោះស្រាយឆ្លើយតបយេនឌ័រ

### ឧទាហរណ៍ទី ៣៖ ការលើកកម្ពស់ភាពធន់នឹងអាកាសធាតុសម្រាប់ស្ត្រីតាមរយៈការធ្វើស្រែចម្ការលក្ខណៈជីវសាស្ត្រ និងដំណាំបន្លែរក្សាទឹក

| ប្រទេស៖ | អង្គភាព៖ | វិស័យ |
|---|---|---|
| នេប៉ាល់ | មូលនិធិ Aabash Memorial Foundation | កសិកម្ម |
| **ការពិពណ៌នា៖** | គម្រោងមូលនិធិ Aabash Memorial Foundation (AMF) ផ្តល់ភាពអង់អាចដល់ក្រុមស្ត្រីជួបការលំបាកដែលប្រឈមនឹងការប្រែប្រួលអាកាសធាតុ និងកង្វះទឹកនៅក្នុងសហគមន៍ Khokana ប្រទេសនេប៉ាល់តាមរយៈការវាយតម្លៃជំនាញអនុវត្តនិងការបណ្តុះបណ្តាលពីភាពធន់ខាងបរិស្ថាន។សកម្មភាពនានាត្រូវបានបង្កើតឡើងតាមរយៈការផ្សព្វផ្សាយចំណេះដឹងស្តីពីផលប៉ះពាល់អាកាសធាតុរួមជាមួយនឹងការវាយតម្លៃការអនុវត្ត។<br>គម្រោងនេះ ផ្តោតលើសន្តិសុខស្បៀង និងវត្តមានទឹក ហើយស្ត្រីត្រូវបានផ្តល់ភាពអង់អាចឱ្យទៅជាខ្លួនទីពឹងខ្លួននៅក្នុងន័យនៃការធ្វើសេចក្តីសម្រេចចិត្តពាក់ព័ន្ធនឹងដំណាំបន្លែរក្សាទឹកដើម្បីធ្វើឱ្យប្រសើរឡើងនូវការដាំដំណាំ ចំណេះដឹងប្រព័ន្ធកសិកម្មជីវសាស្ត្រ ផលប៉ះពាល់អាកាសធាតុ និងវិធានការប្រកបដោយនិរន្តរភាពដែលជួយកសាងសមត្ថភាពបន្សាំអំឡុងពេលខ្វះខាតទឹកនៅលើដីកសិកម្មរបស់ពួកគេ។<br>សកម្មភាពនានា រួមមានកម្មវិធីការយល់ដឹងនៅតាមសាលា/មហាវិទ្យាល័យ/ក្រុមស្ត្រី ក្រុមពិភាក្សាបច្ចេកទេស និងការបង្ហាញពីប្រព័ន្ធសឡា។ សូចនាករសំខាន់ៗនៃលទ្ធភាពលៃលកបាន និងនិរន្តរភាពរួមមានការបង្កើនការផ្គត់ផ្គង់ស្បៀងអាហារជាមួយដំណាំរក្សាទឹក កាត់បន្ថយម៉ោងការងារ និងចំណាយពេលវេលាស្រោចស្រព ជម្លោះតិចតួច និងចំណូលបានពីជីកំប៉ុស្តិ៍។ | |
| **យុទ្ធសាស្ត្រយេនឌ័រ/ផលប៉ះពាល់៖**<br>ប្រភព៖ (ដំណោះស្រាយការប្រែប្រួលអាកាសធាតុលើកស្ទួយយេនឌ័រ ឆ្នាំ២០១៧) | ផ្នែកសំខាន់បំផុតនៃគម្រោងនេះ គឺដើម្បីផ្តល់ភាពអង់អាចដល់ស្ត្រី និងក្មេងស្រីដែលរស់នៅក្នុងសហគមន៍មានអត្រាអក្ខរកម្មទាប។ គម្រោងនេះ ក៏មានបំណងផ្តល់ភាពអង់អាចដល់ពួកគេតាម រយៈការបង្រៀនពីផលប៉ះពាល់ការប្រែប្រួលអាកាសធាតុ ដំណោះស្រាយប្រកបដោយនិរន្តរភាព វគ្គបណ្តុះបណ្តាលពីប្រព័ន្ធសឡាប្រព័ន្ធប្រមូលទឹកភ្លៀង។ល។ក្រៅពីនេះស្ត្រីនិងក្មេងស្រីក៏រៀនធ្វើជីកំប៉ុស្តិ៍ជាមួយសំណល់រឹង ហើយពួកគេនឹងលក់ជីកំប៉ុស្តិ៍នោះ ដើម្បីរកប្រាក់ចំណូល។ | |

### ឧទាហរណ៍ទី ៤៖ គម្រោងអភិវឌ្ឍន៍សត្វពាហនៈសហគមន៍ (CLDP)

| ប្រទេស៖ | អង្គភាព៖ | វិស័យ |
|---|---|---|
| នេប៉ាល់ | ធនាគារអភិវឌ្ឍន៍អាស៊ី | សត្វពាហនៈ |
| **ការពិពណ៌នា៖** | គោលដៅនៃគម្រោងអភិវឌ្ឍន៍សត្វពាហនៈសហគមន៍នេប៉ាល់ (CLDP) គឺដើម្បីកាត់បន្ថយភាពក្រីក្រនៅក្នុងសហគមន៍ជនបទតាមរយៈយេនឌ័រនិងការអភិវឌ្ឍប្រកបដោយបរិយាបន្នសង្គម។គម្រោងនេះ មានបំណងធ្វើឱ្យប្រសើរឡើងនូវសន្តិសុខស្បៀង អាហារូបត្ថម្ភ ប្រាក់ចំណូល និងការផ្តល់ការងារដល់គ្រួសារចំនួន១៦៤,០០០គ្រួសារតាមរយៈការបង្កើនផលិតភាពបានមកពីផលិតកម្មចិញ្ចឹមសត្វនិងសហគ្រាសទាក់ទងនឹងការចិញ្ចឹមសត្វពាហនៈខ្នាតតូចនៅក្នុងស្រុកចំនួន ៤៨ នៃស្រុក៧៥ទាំងអស់នៅក្នុងតំបន់ទាំង ៥ នៃប្រទេសនេប៉ាល់។ សមាសភាពសំខាន់ៗនៃគម្រោងនេះ រួមមាន៖<br>> ការបង្កើតក្រុមកសិករចម្រុះចំនួន ៣ ៤៥០ក្រុម (យ៉ាងតិចមានស្ត្រី ៣៥%) ដែលមាន ២០គ្រួសារក្នុងមួយក្រុម ដើម្បីជ្រើសរើសសហគ្រាសមួយនៅក្នុងចំណោមបញ្ជីសហគ្រាសចិញ្ចឹមសត្វចំនួន ១៥ប្រភេទ<br>> ការរកឱ្យឃើញនូវគំរូបកែលម្អការចិញ្ចឹមសត្វ ១៥ប្រភេទថា ជាការវិនិយោគដ៏សាកសម រួមមានការបង្កើតចំណីសត្វ ការចិញ្ចឹមកូនគោ ពពែ ជ្រូក និងបសុបក្សី ដែលមានការចូលរួមពីអ្នកក្រីក្រដូចជាស្ត្រី ក្រុមបាត់បង់ឱកាស និងកសិករដែលគ្មានដីធ្លី។ | |

> ការកែច្នៃខ្នាតតូច និងទីផ្សារសត្វចិញ្ចឹម និងផលិតផលសត្វចិញ្ចឹម ដើម្បីបង្កើតការងារ និងកែលម្អគុណភាពផលិតផលសត្វចិញ្ចឹម។ សហគ្រាស រាប់ចាប់ពីទីផ្សារសត្វចិញ្ចឹមនៅរស់ រហូតទៅដល់មណ្ឌលប្រមូលទឹកដោះគោ មណ្ឌលកែច្នៃទឹកដោះគោ ទីសត្តឃាត ហាងលក់សាច់ និងការអនុវត្តពេទ្យសត្វ។

> ដើម្បីពង្រឹងការបោះដៃទៅរកសហគមន៍នានានៅតំបន់មានរយៈកម្ពស់ខ្ពស់ តាមរយៈការស្ទង់មតិ និងការវាយតម្លៃតាមជនបទប្រកបដោយការចូលរួម ដើម្បីរកឱ្យឃើញតម្រូវការអភិវឌ្ឍន៍ទាំងមូល ព្រមទាំងតម្រូវការពិសេស ដើម្បីកែលម្អការចិញ្ចឹមសត្វពាហនៈនៅក្នុងតំបន់សាកល្បង។

**យុទ្ធសាស្ត្រយេនឌ័រ/ផលប៉ះពាល់៖**

ដោយសារតែភាពគ្របដណ្តប់របស់ស្ត្រីនៅក្នុងវិស័យចិញ្ចឹមសត្វឥទ្ធិពលលទ្ធផលនិងទិន្នផលដែលជាបំណងប្រាថ្នារបស់គម្រោង CLDP រួមបញ្ចូលនូវវត្ថុបំណងផ្តែកលើយេនឌ័រ និងសូចនាករដំណើរការ ហើយគម្រោងនេះត្រូវចាត់ចូលក្នុងមូលបទសមធម៌យេនឌ័រ។ដើម្បីសម្របសម្រួលការបញ្ជ្រាបយេនឌ័រតាមរយៈការអនុវត្តគម្រោងដើម្បីសម្រេចបាននូវលទ្ធផលគម្រោងដែលមានការរួមបញ្ចូលយេនឌ័រនោះ គម្រោងនេះ បានប្រើគ្រប់ការស្ទាបស្ទង់ និងការវាយតម្លៃដែលមានការចូលរួមទាំងអស់ ដើម្បីប្រមូលព័ត៌មានជីវភាពរស់នៅ ផលិតកម្មសត្វពាហនៈ និងសកម្មភាពកែច្នៃ នៅការបង្ហាញនូវបញ្ហាយេនឌ័រតាមរយៈការពិគ្រោះយោបល់ជាមួយទាំងបុរស និងស្ត្រី។

ការវាយតម្លៃផ្នែកសង្គមសេដ្ឋកិច្ចអំឡុងពេលការរៀបចំគម្រោង បានគូសបញ្ជាក់ថា ខណៈដែលសមាមាត្រស្ត្រី និងបុរសក្រីក្រ ទទួលបានការបណ្តុះបណ្តាលផ្នែកធ្វើឱ្យប្រសើរឡើងការថែរក្សាសត្វចិញ្ចឹម ស្ត្រីមានការលំបាកខ្លាំងក្នុងការទទួលបានវគ្គបណ្តុះបណ្តាល និងលំបាករៀបចំចងក្រងក្រុម ព្រោះពួកគេប្រឈមមុខនឹងចំណាយខ្ពស់ជាងដែលបណ្តាលមកពីការពន្យាពេលការទូទាត់ការវិនិយោគទុន។

GAPដែលមិនអាចប្រៀបធៀបបាន ត្រូវបានបង្កើតឡើងអំឡុងដំណាក់កាលបង្កើតគម្រោង៖ ដែលផ្តោតជាអាទិ៍ការធានាថា៣៥%នៃកសិករនៅក្នុងគ្រប់សកម្មភាពទាំងអស់គឺជាស្ត្រី៥០%នៃអ្នកចូលរួមវគ្គបណ្តុះបណ្តាល និងអ្នកទទួលបានកម្ចី គឺជាស្ត្រី ហើយស្ត្រីទាំងនេះ បានទទួលនូវការគាំទ្រចាំបាច់ដើម្បីចូលរួមនៅក្នុងក្រុមកសិករ ក៏ដូចជាគណៈកម្មាធិការសម្របសម្រួលកសិករកម្រិតខ្ពស់សមាគមមូលដ្ឋាន និងក្រុមសហករណ៍។ គម្រោងនេះក៏ផ្តោតលើការលើកកម្ពស់គំរូសហគ្រិនជាស្ត្រីម្នាក់ក្នុងមួយគម្រោងថ្នាក់ស្រុក ដើម្បីបង្កើនការចូលរួមរបស់ស្ត្រីនៅក្នុងការអភិវឌ្ឍសហគ្រាស។

ប្រភព៖ (ADB ឆ្នាំ២០១០)

**ឧទាហរណ៍ទី ៥៖ ការផ្តល់ភាពអង់អាចដល់ស្ត្រីនៅតំបន់ជនបទ ជាមួយនឹងថាមពលពន្លឺព្រះអាទិត្យ និងសហគ្រិនភាពខ្នាតតូច**

| ប្រទេស៖ | អង្គការ៖ | វិស័យ |
|---|---|---|
| ឥណ្ឌា | AIWC– Priyadarshini Mahila Samajam | កសិកម្ម ថាមពល |

**ការពិពណ៌នា៖**

គម្រោងថាមពលបៃតងនេះមានបំណងបង្ហាញនូវនិន្នាការផ្នែកសេដ្ឋកិច្ចនិងផលប៉ះពាល់យេនឌ័រនៃការលក់ផ្លែឈើបន្លែនិងគ្រឿងទេសក្រៀមដោយសារពន្លឺព្រះអាទិត្យ។សហគ្រាសខ្នាតតូចបានបង្កើតឡើង និងគ្រប់គ្រងដោយស្ត្រីចំនួន ៥នាក់ ប្រើម៉ាស៊ីនសម្ងួតពន្លឺព្រះអាទិត្យចំនួន ២គ្រឿង (សមត្ថភាព ៥០គក ក្នុងមួយម៉ាស៊ី) ដើម្បីកែច្នៃ និងបំប្លែងផ្លែឈើ និងបន្លែតាមរដូវកាលក្នុងស្រុកទៅជាផលិតផលម្ហូបអាហារកញ្ចប់ជាមួយនឹងតម្លៃបន្ថែមខ្ពស់។ពួកគេធ្វើការជាមួយនឹងស្ត្រីផ្គត់ផ្គង់ចំនួន ៤៣ នាក់ទៀតដែលទទួលបានប្រាក់ចំណូលបន្ថែមសំខាន់ និងកាត់បន្ថយការខ្ជះខ្ជាយផលិតផល។ អង្គការនេះបណ្តុះបណ្តាលក្រុមស្ត្រីនូវការកែច្នៃផលិតផលក្រៀមតាមរយៈពន្លឺព្រះអាទិត្យ និងជំនាញទីផ្សារ។

**យុទ្ធសាស្ត្រយេនឌ័រ/ផលប៉ះពាល់៖**

ស្ត្រីត្រូវបានផ្តល់ភាពអង់អាចតាមរយៈផលិតផលក្នុងស្រុក និងការលក់ផលិតផលម្ហូបអាហារដែលមានតម្លៃបន្ថែមខ្ពស់។ ការកើនឡើងប្រាក់ចំណូលសម្រាប់បុគ្គលិក និងអ្នកផ្គត់ផ្គង់ជាស្ត្រី (ចាប់ពី ១០$ទៅ៣០$/ខែ អាស្រ័យលើរដូវកាល និងផលិតផល)។ការកាត់បន្ថយបន្ទុកការងារ (២ម៉ោង/ថ្ងៃ) ផ្តល់ពេលវេលាសម្រាប់សកម្មភាពបង្កើតប្រាក់ចំណូលផ្សេងទៀត។ ការចូលរួមនៅក្នុងការសម្រេចចិត្តទិញ និងកែច្នៃ ទីផ្សារ និងការចែករំលែកប្រាក់ចំណូល។ សហគ្រាសធុនតូចចូលរួមក្នុងពិពណ៌ និងបុណ្យនាន ដើម្បីចែករំលែកចំណេះដឹង ផ្តល់នូវការគាំទ្រវគ្គបណ្តុះបណ្តាល។

ប្រភព៖ (ដំណោះស្រាយការប្រែប្រួលអាកាសធាតុលើកស្ទួយយេនឌ័រ ឆ្នាំ២០១៦)

## ឯកសារមេរៀនទី ២០៖ ឧទាហរណ៍នៃដំណោះស្រាយឆ្លើយតបយេនឌ័រ

### ឧទាហរណ៍ទី ៦៖ កសិដ្ឋាន Organik Farm៖ ការផ្ដល់ភាពអង់អាចដល់ស្ត្រី សម្រាប់ផលិតកម្មស្បៀងអាហារប្រកបដោយនិរន្តរភាព ធន់នឹងអាកាសធាតុ

| ប្រទេស៖ | អង្គភាព៖ | វិស័យ |
|---|---|---|
| វៀតណាម | APFSVA – Association Pour la Promotion des Femmes Scientifiques Vietnamiennes | សន្តិសុខស្បៀង |

| | |
|---|---|
| ការពិពណ៌នា៖ | កសិដ្ឋាន Organik (ត្រូវបានបង្កើតឡើងនៅខេត្តដាឡាត់ ប្រទេសវៀតណាម ក្នុងឆ្នាំ២០០៧) គឺជាឧទាហរណ៍ដ៏ល្អឥតខ្ចោះមួយនៃការផ្ដល់ភាពអង់អាចដល់ស្ត្រីតាមរយៈការធ្វើកសិកម្មប្រកបដោយភាពធន់នឹងអាកាសធាតុ និរន្តភាព និងការបែងចែកស្បៀងអាហារ។ ការកែច្នៃរបស់គម្រោង Organik ដោយវាយស្លាកថា«ជីវសាស្ត្រ» បញ្ជាក់ថា បន្លែ និងផ្លែឈើមកពីដីតំបន់ភ្នំនានា។ បន្លែបង្កា ត្រូវបានដាំដុះផ្អែកតាមGAP(ការអនុវត្តកសិកម្មល្អ)និងស្តង់ដារសរីរាង្គ។ផលិតផលត្រូវបានបែងចែកទៅតាមហាងរបស់ពួកគេនៅក្នុងទីក្រុងហូជីមិញ ហាងអនឡាញ បណ្ដាញលក់រាយចម្រុះ រួមទាំងនាំចេញទៅប្រទេសកម្ពុជា និងថៃផងដែរ។ កសិដ្ឋាននេះ ផ្ដល់ការងារដល់ស្ត្រីនៅគ្រប់កម្រិត៖ ការដាំដុះ ការលក់ គណនេយ្យ ការបញ្ជាទិញ និងការគ្រប់គ្រង។ វាផ្ដល់នូវគោលនយោបាយតម្លៃដាក់លាក់សម្រាប់សាលារៀន និងមន្ទីរពេទ្យនានា ដោយធានានូវរបបអហារសរីរាង្គសម្រាប់កុមារ និងអ្នកជំងឺ។<br>កសិដ្ឋាននេះពង្រឹងដល់ប្រព័ន្ធអេកូឡូស៊ីដោយធានានូវវត្តមាននៃសត្វល្អិតដែលមានអត្ថប្រយោជន៍ ធ្វើឱ្យមានភាពចម្រុះក្រោមដី វដ្តជីវជាតិ ការកាត់បន្ថយនូវជំងឺ ការជួសជុលនូវសារជាតុអាសូត។ ដំណើរការរបស់វា មានលក្ខណៈល្អក្នុងការប្រើប្រាស់ថាមពល ការពារដី ប្រសិទ្ធភាពប្រើប្រាស់ទឹក បន្សុទ្ធទឹក បង្កើនសុខភាពដី (ដំណាំវិលជុំ ជីលាមកសត្វ ជីកំប៉ុស្តិ៍) ដោយការបង្ហាញថា កសិដ្ឋានមួយអាចគ្រប់គ្រងធនធានប្រកបដោយនិរន្តរភាព និងការគិតគូពីអាកាសធាតុ។ |
| យុទ្ធសាស្ត្រយេនឌ័រ/ ផលប៉ះពាល់៖<br><br>ប្រភព៖ (ដំណោះស្រាយការប្រែប្រួលអាកាសធាតុលើកស្ទួយយេនឌ័រ ឆ្នាំ២០១៧) | ក្មេងស្រី និងស្ត្រីជនជាតិវៀតណាម នៅតែបន្តទទួលរងនូវអំពើហិង្សាទាក់ទងនឹងយេនឌ័រ និងវិសមភាពយេនឌ័រ។ កសិដ្ឋាន Organik មានបុគ្គលិក៥៥នាក់ ក្នុងនោះមានស្ត្រី៤៤នាក់៖ ៨/១៧ ជាកសិករ ២០/២១ ជាបុគ្គលិកកែច្នៃ ១២/១៤ ជាអ្នកគ្រប់គ្រង និង២/៣ ជាជំនួយការក្នុងហាង។ បុគ្គលិកកើនឡើងយ៉ាងឆាប់រហ័ស។ Organik បណ្ដុះបណ្ដាលស្ត្រីស្ដីពីសរីរាង្គ GAP សុវត្ថិភាពអនាម័យស្បៀងអាហារការចិញ្ចឹមប្រលែងផលិតផលគ្មានជាតិGMOដំណាំវិលជុំគ្រាប់ពូជការគ្រប់គ្រងសត្វល្អិតចង្រៃបែបធម្មជាតិការចិញ្ចឹមសត្វ។ពួកគេក៏កសាងសមត្ថភាពលើការធ្វើសេចក្ដីសម្រេចចិត្តសម្រាប់ការលក់ ការបញ្ជាទិញ និងការសម្របសម្រួលកាលវិភាគទីផ្សារ។ |

### ឧទាហរណ៍ទី ៧៖ កម្មវិធីជីវភាពរស់នៅផ្អែកលើជលផលនៅក្នុងតំបន់សម្រាប់អាស៊ីខាងត្បូង និងអាស៊ីអាគ្នេយ៍ (RFLP)

| តំបន់ | អង្គភាព៖ | វិស័យ |
|---|---|---|
| អាស៊ីខាងត្បូងនិង អាស៊ីអាគ្នេយ៍ | អង្គការស្បៀងអាហារ និង កសិកម្មរបស់អង្គការសហប្រជាជាតិ (FAO) | ជលផល |

| | |
|---|---|
| ការពិពណ៌នា៖ | RFLPគឺជាគម្រោងរយៈពេលបួនឆ្នាំ(២០០៩-២០១៣)សម្រាប់ការពង្រឹងសមត្ថភាពក្នុងចំណោមការចូលរួមសហគមន៍នេសាទខ្នាតតូច ហើយស្ថាប័នគាំទ្ររបស់ពួកគេមាននៅកម្ពុជា ឥណ្ឌូណេស៊ី ហ្វីលីពីនស្រីលង្ការទីម័រខាងកើតនិងវៀតណាម។តាមរយៈការធ្វើបែបនេះRFLPចង់ធ្វើឱ្យប្រសើរឡើងនូវជីវភាពរស់នៅរបស់អ្នកនេសាទ និងគ្រួសាររបស់ពួកគេ ខណៈដែលជំរុញនូវការអនុវត្តការគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តរភាពកាន់តែច្រើនឡើង។ គម្រោងនេះផ្ដោតលើផ្នែកសំខាន់ៗចំនួនប្រាំមួយ៖<br>> យន្តការសហគ្រប់គ្រងសម្រាប់ការប្រើប្រាស់ធនធានជលផលប្រកបដោយនិរន្តរភាព<br>> កែលម្អសុវត្ថិភាពនៅតំបន់សមុទ្រនិងកាត់បន្ថយភាពងាយរងគ្រោះសម្រាប់សហគមន៍អ្នកនេសាទ |

| | |
|---|---|
| | ខ្នាតតូច<br>> កែលម្អគុណភាពផលិតផលជលផល និងចង្វាក់ទីផ្សារ<br>> ពង្រឹង ឬបង្កើតឱកាសប្រាក់ចំណូលចម្រុះសម្រាប់គ្រួសារអ្នកនេសាទ<br>> ទទួលបានសេវាមីក្រូហិរញ្ញវត្ថុកាន់តែល្អប្រសើរ<br>> បង្កើនការចែករំលែកចំណេះដឹង |
| **យុទ្ធសាស្ត្រយេនឌ័រ/ ផលប៉ះពាល់៖**<br><br>ប្រភព៖ (FAO ឆ្នាំ២០១២) | គម្រោងនេះ ផ្តោតសំខាន់លើការវិភាគយេនឌ័រ ដើម្បីស្វែងយល់ពីតួនាទីយេនឌ័រនៅក្នុងសហគមន៍នេសាទ។ គម្រោងនេះធ្លាប់បានផ្តល់នូវវគ្គបណ្តុះបណ្តាលស្តីពីយេនឌ័រដល់បុរស និងស្ត្រីនៅក្នុងសហគមន៍នេសាទនានា។ វគ្គបណ្តុះបណ្តាលគឺជាឱកាសមួយសម្រាប់តួអង្គថ្នាក់កណ្តាលដែលត្រូវយល់ដឹងពី «ទស្សនៈយេនឌ័រ» និង «ផ្នត់គំនិតសង្គមលើយេនឌ័រនៅក្នុងវិស័យជលផល»។ RFLP ក៏ផ្តោតលើកិច្ចប្រឹងប្រែងលើការបង្កើនការចូលរួមរបស់ស្ត្រីនៅក្នុងការធ្វើសេចក្តីសម្រេចចិត្ត រួមមានការចូលរួមរបស់ពួកគេនៅក្នុងយន្តការសហគ្រប់គ្រងការដើរតួនាទីផ្សេងៗនៅក្នុងការអន្តរាគមន៍ការគ្រប់គ្រងជលផល។ នៅហ្វីលីពីន RFLP បានរួមបញ្ចូលយេនឌ័រទៅក្នុងផែនការគ្រប់គ្រងធនធានតំបន់ឆ្នេរ និងធនធានជលផល (CRFM) នៃ LGUs។ ជាលទ្ធផល ស្ត្រីដើរតួរជាអ្នកយាមត្រី អ្នកជំរុញការអនុវត្តច្បាប់ស្តីពីជលផល។ RFLP ក៏ធ្វើការជាមួយសហគមន៍ក្នុងការបង្កើតតំបន់គ្រប់គ្រងដោយស្ត្រីផងដែរ។ នៅស្រីលង្កាការរួមបញ្ចូលតំណាងស្ត្រីនៅក្នុងគណៈកម្មាធិការសម្របសម្រួលសហគ្រប់គ្រងបានបង្កើតនូវដែនសមត្ថកិច្ច ព្រមទាំងរួមបញ្ចូលអ្នកដឹកនាំជាស្ត្រីរយៈពេលយ៉ាងតិច២ឆ្នាំនៅក្នុងសមាគមបណ្តាញហិរញ្ញវត្ថុជលផល។នៅទីម័រខាងកើតស្ត្រីបានចូលរួមក្នុងនាមជាហត្ថលេខីនៃឯកសារដំបូងបង្អស់ដែលមិនធ្លាប់មានឈ្មោះថា Tara Bandu ដែលជាការអនុវត្តការគ្រប់គ្រងធនធានតំបន់ឆ្នេរតាមលក្ខណៈប្រពៃណី។ អាជ្ញាធរមូលដ្ឋាន និងសហគមន៍ត្រូវបានជូនដំណឹងពីតម្រូវការចូលរួមរបស់ស្ត្រីនៅក្នុងការគ្រប់គ្រង និងការឯកភាពលើសំណើ RFLP ដោយរួមបញ្ចូលស្ត្រីជាហត្ថលេខីនៃឯកសារ Tara Bandu។ ការធ្វើបែបនេះមានន័យថា ឥឡូវនេះ ស្ត្រីមានតួនាទីមួយជាផ្លូវការតាមបែបប្រពៃណី និងក្នុងប្រព័ន្ធគ្រប់គ្រងធនធានផ្អែកលើសហគមន៍ ដោយបានក្លាយជាសញ្ញាសំខាន់មួយ តែតួនាទីនេះពួកគេមិនធ្លាប់មានមុនពេលកិច្ចអន្តរាគមន៍របស់RFLPទេ។ក្នុងនាមជាហត្ថលេខីពួកគេចាប់ពីពេលឥឡូវនេះនឹងត្រូវចូលរួមនៅក្នុងកិច្ចប្រជុំការធ្វើសេចក្តីសម្រេចចិត្តទាំងអស់។នៅវៀតណាមRFLPបានគាំទ្រដល់សមាគមជលផលចំនួន១៦ (FAs)នៅក្នុងខេត្ត Quang Nam Quang Tri និងខេត្ត Thua Thien Hue។ FAs គឺជាអង្គការផ្អែកលើសហគមន៍អ្នកនេសាទបុរសជាចម្បង - ក្នុងចំណោម ១៣៣៥សមាជិក មានស្ត្រីតែ៣៦នាក់ប៉ុណ្ណោះ។នៅវៀតណាមវាជារឿងធម្មតាដែលបុសរធ្វើជាតំណាងឱ្យគ្រួសាររបស់ពួកគេនៅក្នុងការចុះបញ្ជីភាគច្រើន។ ហេតុផលអាជ្ញាធរមូលដ្ឋាន គឺថាទោះបីជាស្ត្រីមានឈ្មោះក៏ពួកគេមិនលេចចេញមកនៅក្នុងFAដែរ ហើយពួកគេត្រូវបានចាត់ទុកជាសមាជិក FA។ RFLP ធ្វើការតាមរយៈសមាគមននេះ ដើម្បីបង្កើនសមាជិកភាព FA របស់ស្ត្រី និងជំរុញឱ្យមានការចូលរួមសកម្មរបស់ពួកគេតាមរយៈការលើកទឹកចិត្តរួមមាន៖ ១) ការផ្តល់ជំនួយសម្រាប់ការអនុវត្តគំរូជីវភាពរស់នៅចំពោះតែស្ត្រីដែលជាសមាជិក FA ប៉ុណ្ណោះ និង២) បញ្ជាក់ពីថ្លៃសមាជិកភាពគឺក្នុងមួយគ្រួសារ ជំនួសឱ្យបុគ្គលម្នាក់ - នេះមានន័យថាបើសិនទាំងប្តី និងប្រពន្ធជាសមាជិក ពួកគេត្រូវបង់ថ្លៃសមាជិកភាពតែម្នាក់ប៉ុណ្ណោះ។ |

## ឯកសារមេរៀនទី ២០៖ ឧទាហរណ៍នៃដំណោះស្រាយឆ្លើយតបយេនឌ័រ

### ឧទាហរណ៍ទី ៨៖ ការផ្តល់ភាពអង់អាចដល់ក្រុមស្ត្រីនៅក្នុងតំបន់ប្រឈមនឹងគ្រោះមហន្តរាយ តាមរយៈការគ្រប់គ្រងទឹកប្រកបដោយនិរន្តរភាពផ្អែកលើសហគមន៍

| ប្រទេស៖ | អង្គការ៖ | វិស័យ |
|---|---|---|
| ឥណ្ឌូណេស៊ី | YAKKUM Emergency Unit ( YEU ) | ទឹក |

**ការពិពណ៌នា៖**

ស្រុក Gemawang Kaloran និងស្រុកTemmangung នៅក្នុងតំបន់ភាគកណ្តាលកោះជ្វា ត្រូវបានគំរាមកំហែងដោយសារកង្វះទឹក និងការរអិលបាក់ដីដោយសារការកាប់បំផ្លាញព្រៃឈើ។ គម្រោងនេះផ្តល់ភាពអង់អាចដល់ក្រុមស្ត្រី ដើម្បីកំណត់ និងអនុវត្តយុទ្ធសាស្ត្រការបន្សាំនៅក្នុងសហគមន៍របស់ពួកគេ។ស្ត្រីធ្វើការវាយតម្លៃមូលដ្ឋាននិងការសិក្សាលទ្ធភាពនានាជាមួយអាជ្ញាធរភូមិនិងអ្នកជំនាញខាងទឹក និងជ្រើសរើសបច្ចេកវិទ្យាគ្រប់គ្រងទឹកសមស្រប ដើម្បីបន្សាំទៅនឹងការផ្លាស់ប្តូរ បរិស្ថាន។ ពួកគេប្រើដំណោះស្រាយសន្សំសំចៃទឹក បច្ចេកទេសចម្រោះទឹក និងអនាម័យអេកូឡូស៊ី ដើម្បីកែលម្អជីវភាពរស់នៅក្នុងសហគមន៍របស់ពួកគេ។

ការកាប់បំផ្លាញព្រៃឈើទ្រង់ទ្រាយធំនៅក្នុងតំបន់ភាគកណ្តាលកោះជ្វាបានធ្វើឱ្យការផ្គត់ផ្គង់ទឹកក្រោមដីថយចុះយ៉ាងខ្លាំង និងនាំឱ្យមានភាពរាំងស្ងួតធ្ងន់ធ្ងរ។ ការផ្លាស់ប្តូរមុខងារនៃព្រៃឈើក៏បណ្តាលឱ្យខូចដីធ្ងន់ធ្ងរ និងបង្កើនហានិភ័យនៃការរអិលបាក់ដី។ ក្រុមស្ត្រី និងមនុស្សនៅក្នុងផ្នែកខ្លះនៃភូមិបានធ្វើការរួមគ្នាដើម្បីបង្កើតប្រព័ន្ធគ្រប់គ្រងទឹកប្រកបដោយនិរន្តរភាព ការពារដើមឈើចាស់ៗនិងដាំដើមឈើតូចៗឡើងវិញជុំវិញប្រភពទឹក ដើម្បីទប់ស្កាត់ការរអិលបាក់ដី ក៏ដូចជាការរក្សានូវការផ្គត់ផ្គង់ទឹក តាមរយៈចម្រោះទឹក និងការការពារតុល្យភាពស្ថានប្រព័ន្ធ។ វិធានការទាំងនេះ គឺជាយុទ្ធសាស្ត្របន្សាំទៅនឹងអាកាសធាតុយ៉ាងមានប្រសិទ្ធភាព។

**យុទ្ធសាស្ត្រយេនឌ័រ/ផលប៉ះពាល់៖**

គម្រោងនេះត្រូវបានផ្តួចផ្តើមឡើងដោយស្ត្រី។ ក្រុមស្ត្រីចូលរួមយ៉ាងសកម្មនៅក្នុងការសម្រេចចិត្តលើបច្ចេកវិទ្យាគ្រប់គ្រងទឹក ហើយពួកគេធ្វើការតស៊ូមតិទាំងកម្រិតមូលដ្ឋាន និងតំបន់។ សមាជិក ១០នាក់នៃក្រុមស្ត្រី Muncar Lor's បានចូលរួមក្នុងការវាយតម្លៃទឹកនៅមូលដ្ឋានរបស់អាជ្ញាធរតំបន់។ សមភាពយេនឌ័រក៏ត្រូវបានពង្រឹងដោយសកម្មភាពបង្កើតប្រាក់ចំណូលតាមរយៈការលក់បច្ចេកវិទ្យាទឹក។ប្រាក់ចំណូលថ្មីនេះត្រូវបានប្រើសម្រាប់ការជួសជុលអគារបង្កើតជាមូលនិធិសង្គមនិងការធានានូវការអភិវឌ្ឍខ្លួនឯង។

ប្រភព៖ (ដំណោះស្រាយការប្រែប្រួលអាកាសធាតុលើកស្ទួយយេនឌ័រ ឆ្នាំ២០១៦)

### ឧទាហរណ៍ទី ៩៖ ការផ្តល់ភាពអង់អាចដល់ស្ត្រីជនជាតិភាគតិច

| ប្រទេស៖ | អង្គការ៖ | វិស័យ |
|---|---|---|
| វៀតណាម | CARE International នៅវៀតណាម | ជីវភាពរស់នៅ គ្មានអ្នកណាម្នាក់ត្រូវបានទុកចោល |

**ការពិពណ៌នា៖**

គម្រោងនេះមានបំណងផ្តល់ភាពអង់អាចដល់ស្ត្រីជនជាតិភាគតិចនៅតំបន់ដាច់ស្រយាល ឱ្យមានការចូលរួមយ៉ាងសកម្មនៅក្នុងការរៀបចំផែនការអភិវឌ្ឍន៍សង្គម-សេដ្ឋកិច្ចនិងការធ្វើសេចក្តីសម្រេចចិត្ត។ ដើម្បីសម្រេចបាននូវវត្ថុបំណងនេះ គម្រោងផ្តោតលើសមាសធាតុចំនួនបួន៖ ១) សំឡេងស្ត្រីនៅក្នុងផែនការអភិវឌ្ឍមូលដ្ឋាន ២) ជីវភាពរស់នៅធន់នឹងអាកាសធាតុ ៣) ការពង្រឹងក្រុមស្ត្រី ៤) ប្រយុទ្ធប្រឆាំងអំពើហិង្សាទាក់ទងនឹងយេនឌ័រ។ គម្រោងនេះផ្តោតលើស្ត្រីចំនួន៤៥០០នាក់ និងបុរស ៣០០០នាក់ ដែលជាប្រជាជនរស់នៅតំបន់Thai, Tay, Dzao និងតំបន់Hmong នៅក្នុងតំបន់ភ្នំភាគខាងជើងដាច់ស្រយាល។ ជិត ៩០% នៃក្រុមស្ត្រី មានការយល់ដឹងពីការប្រែប្រួលអាកាសធាតុ និងទំនាក់ទំនងរបស់វាលើសហគមន៍របស់ពួកគេនិង៤៣%នៃស្ត្រីគោលដៅបានបង្កើនប្រាក់ចំណូលរបស់ពួកគេ។

គម្រោងនេះធ្វើការជាមួយសហគមន៍ជនជាតិភាគតិច ក្នុងការវាយតម្លៃភាពងាយរងគ្រោះអាកាសធាតុ

| | |
|---|---|
| | និងសមត្ថភាព ព្រមទាំងស្រាវជ្រាវពីម៉ូឌែលជីវភាពរស់នៅធន់នឹងអាកាសធាតុផងដែរ។ លើកដំបូងក្នុងជីវិតរបស់ពួកគេដែលប្រជាជនមូលដ្ឋានបានធ្វើការឆ្លុះបញ្ចាំងពីការប្រែប្រួលអាកាធាតុនិងផលប៉ះពាល់របស់វា។ ប្រព័ន្ធដាំដុះស្រូវប្រកបដោយនិរន្តរភាព (SRI) ត្រូវបានយកមកប្រើប្រាស់។ ប្រជាជនសន្សំគ្រាប់ពូជបាន៤០% កាត់បន្ថយការប្រើប្រាស់ជីរហូតដល់ ៤០% និងទឹក ៣០%។ ការបញ្ចេញ CO2 ពីការអនុវត្ត SRI ធ្លាក់ចុះ ៧០%។ ម៉ូឌែលនេះជួយកសិករបន្សាំបានល្អប្រសើរទៅនឹងភាពរាំងស្ងួត និងគ្រោះមហន្តរាយ ដោយការកាត់បន្ថយការប្រើប្រាស់ទឹក និងកាត់បន្ថយរយៈពេលបង្កបង្កើនផល។ |
| **យុទ្ធសាស្ត្រយេនឌ័រ/ ផលប៉ះពាល់៖**<br><br>ប្រភព៖ (ដំណោះស្រាយការប្រែប្រួលអាកាសធាតុលើកស្ទួយយេនឌ័រ ឆ្នាំ២០១៦) | គម្រោងនេះបានបង្កើតនូវសំណាញ់កិច្ចគាំពារសង្គមសម្រាប់ស្ត្រីមូលដ្ឋាន តាមរយៈការសន្សំ និងសមាគមប្រាក់កម្ចី។ នេះគឺជាវេទិកាសម្រាប់ស្ត្រីក្នុងការនិយាយស្តី ចែករំលែក ចាប់ផ្តើមសន្សំ និងទទួលបានប្រាក់កម្ចីងាយស្រួល។ វាធ្វើឱ្យល្អប្រសើរឡើងនូវទំនុកចិត្តរបស់ស្ត្រី និងសាមគ្គីភាព។ វគ្គបណ្តុះបណ្តាលបច្ចេកទេសSRIត្រូវបានណែនាំសម្រាប់បុរស និងស្ត្រី។ ការបណ្តុះបណ្តាលបច្ចេកទេសនេះ ជាលើកដំបូង កសាងសមត្ថភាពរបស់ពួកគេខាងចំណេះដឹងបច្ចេកទេស និងកសិកម្ម ដែលតែងតែបុរសត្រួតត្រា។ ជាលទ្ធផល ស្ត្រីបានបង្កើនប្រាក់ចំណូលរបស់ពួកគេចំនួន ៧០$ ក្នុងស្រែមួយអារ។ |

### ឧទាហរណ៍ទី ១០៖ ស្ត្រីជាកត្តាសំខាន់នៃការផ្លាស់ប្តូរសម្រាប់ការប្រើប្រាស់ និងការផលិតម្ហូបអាហារប្រកបដោយនិរន្តរភាព

| ប្រទេស៖ | អង្គការ៖ | វិស័យ |
|---|---|---|
| តៃវ៉ាន់ | Homemakers United Foundation | សន្តិសុខស្បៀង |

| | |
|---|---|
| **ការពិពណ៌នា៖** | បានចាប់ផ្តើមនៅឆ្នាំ២០១២ គម្រោងនេះមានបំណងផ្តល់ភាពអង់អាចដល់ស្ត្រី និងសហគមន៍មូលដ្ឋាន ក្នុងការដោះស្រាយបញ្ហាសន្តិសុខស្បៀងក្រោមការប្រែប្រួលអាកាសធាតុ។ នេះអាចសម្រេចបានតាមវិធីបួនយ៉ាង៖ ១) កៀរគងស្ត្រីឱ្យទទួលយកនូវរបៀបរស់នៅដែលប្រើប្រាស់ម្ហូបអាហារដែលមានជាតិកាបូនទាបតាមរយៈសិក្ខាសាលា ២) គាំទ្រស្ត្រីឱ្យចាប់ផ្តើមធ្វើយុទ្ធនាការការប្រែប្រួលអាកាសធាតុនៅក្នុងសហគមន៍របស់ពួកគេ ៣) ផ្តល់នូវផែនទីអនឡាញឥតគិតថ្លៃមួយដើម្បីលើកកម្ពស់ប្រភពម្ហូបអាហារមូលដ្ឋានមកពី«ចំណុចបៃតង» ៤) ទាក់ទាញនូវការយកចិត្តទុកដាក់របស់រដ្ឋាភិបាលលើការអប់រំពីម្ហូបអាហារនៅក្នុងសហគមន៍ និងសាលារៀន។<br>នៅក្នុងទសវត្សកន្លងមក ចំនួន និងការកើនឡើងខ្លាំងនៃព្យុះស៊ីក្លូនកាន់តែកើនឡើង គំរាមកំហែងដល់ការផ្គត់ផ្គង់ម្ហូបអាហាររបស់តៃវ៉ាន់។ Homemakers United Foundation បានបញ្ចុះបញ្ចូលកសិករខ្នាតតូចចំនួន ៥៨០នាក់ ឱ្យប្រើប្រាស់គ្រាប់ពូជ NON-GMO និងការអនុវត្តកសិកម្មប្រកបដោយនិរន្តរភាព។ ចន្លោះឆ្នាំ២០១២ ដល់ឆ្នាំ២០១៦ កម្មវិធីអប់រំផ្នែកម្ហូបអាហារចំនួន១០០ ត្រូវបានប្រារព្ធធ្វើឡើងនៅទីក្រុង Taipei, Taichung និងទីក្រុង Kaohsiung ជាមួយនឹងអ្នកម្តាយជាង ៤០០០នាក់ និងការចូលរួមពីសមាជិកសហគមន៍មូលដ្ឋាន។ នៅឆ្នាំ២០១៥ «ផែនទីអនឡាញសហគមន៍ ស្បៀងបៃតង» ត្រូវបានដាក់សម្ពោធ ដោយការកៀរគរយុវជនផ្អែកលើសកម្មភាពប្រចាំថ្ងៃ «ប្រឆាំងនឹងការប្រែប្រួលអាកាសធាតុ»។ |
| **យុទ្ធសាស្ត្រយេនឌ័រ/ ផលប៉ះពាល់៖**<br><br>ប្រភព៖ (ដំណោះស្រាយការប្រែប្រួលអាកាសធាតុលើកស្ទួយយេនឌ័រ ឆ្នាំ២០១៦) | តៃវ៉ាន់ស្ត្រីមានការយល់ដឹងពីការប្រែប្រួលអាកាសធាតុនិងយល់ដឹងពីកត្តាដែលធ្វើឱ្យមានការប្រែប្រួល។ Homemakers United Founda¬tion ធ្វើឱ្យស្ត្រីជាង ៧០០នាក់ ចាប់ផ្តើម និងដឹកនាំកម្មវិធីអប់រំពីស្បៀងអាហារនៅក្នុងសាលារៀនបឋមសិក្សា សាកលវិទ្យាល័យនិងសហគមន៍របស់ពួកគេ។ស្ត្រីត្រូវបានផ្តល់ភាពអង់អាច ដើម្បីផ្តួចផ្តើមការផ្លាស់ប្តូរអាកប្បកិរិយាឆ្ពោះទៅរកការប្រើប្រាស់ម្ហូបអាហារ និងផលិតផលប្រកបដោយនិរន្តរភាព(កាត់បន្ថយសំណល់ផ្ទះបាយ ទទួលទានអាហារក្នុងតំបន់និងតាមរដូវកាល រក្សាប្រភពក្នុងស្រុកដើម្បីកសិកម្មទីក្រុង។ល។)។ |

## ឯកសារមេរៀនទី ២០៖ ឧទាហរណ៍នៃដំណោះស្រាយឆ្លើយតបយេនឌ័រ

### ឧទាហរណ៍ទី ១១៖ សេវាព័ត៌មានអាកាសធាតុ-កសិកម្មសម្រាប់ស្ត្រី និងកសិករជនជាតិភាគតិចនៅក្នុងគម្រោងតំបន់អាស៊ីអាស៊ីអាគ្នេយ៍ (ACIS)

| ប្រទេស៖ | អង្គការ៖ | វិស័យ |
|---|---|---|
| វៀតណាម | Care International វៀតណាម | កសិកម្ម |

| | |
|---|---|
| **ការពិពណ៌នា៖** | គម្រោង ACIS ត្រូវបានសហការអនុវត្តដោយអង្គការ CARE International វៀតណាម និងមជ្ឈមណ្ឌលកសិរុក្ខកម្មពិភពលោក (ICRAF) ក្រោមជំនួយពីកម្មវិធីស្រាវជ្រាវផ្នែកការប្រែប្រួលអាកាសធាតុ កសិកម្ម និងសន្តិសុខស្បៀង គ្រប់គ្រងដោយក្រុមទីប្រឹក្សាស្តីពីការស្រាវជ្រាវកសិកម្ម អន្តរជាតិ (CGIAR)។ អង្គការ CARE ប្រើវិធីសាស្រ្តការរៀបចំផែនការសេណារីយ៉ូដែលមានការចូលរួម ដើម្បីធ្វើឱ្យភាគីពាក់ព័ន្ធពីគ្រប់មជ្ឈដ្ឋាន រួមមានផ្នែកឧតុនិយម និងកសិកម្ម ចូលរួមនៅក្នុងការពិភាក្សាជាមួយបុគ្គលិកឃុំ មេភូមិ និងអ្នកតំណាងក្រុមសន្សំភូមិ និងសមាគមប្រាក់កម្ចី (VSLA) ដែលត្រូវបានគ្រប់គ្រងដោយខ្លួនឯង ក្រុមនិរន្តរភាពរបស់ស្ត្រីមានបំណងបង្កើតឱកាស តាមរយៈការសហការហិរញ្ញវត្ថុ។ ការពិភាក្សាទាំងនេះ គឺដើម្បីបង្កើត និងចែករំលែកក្នុងកម្រិតតូច (លម្អិត និងមូលដ្ឋាន ជាជាងតំបន់) ការព្យាករណ៍តាមរដូវមានប្រភពមកពីទាំងវិទ្យាសាស្រ្ត និងចំណេះដឹងមូលដ្ឋាន។ |
| **យុទ្ធសាស្រ្តយេនឌ័រ/ ផលប៉ះពាល់៖**<br><br>ប្រភព៖<br>(VUFO-NGO Centre ឆ្នាំ២០១៧) | ការព្យាករណ៍ទាំងនេះត្រូវបានបកប្រែទៅជាសេវាផ្សព្វផ្សាយផ្នែកកសិកម្ម និងព័ត៌មានដែលអាចអនុវត្តន៍បានដោយការយកចិត្តទុកដាក់ពីបរិបទការធ្វើកសិកម្មនៅក្នុងស្រុកភាសានិងវប្បធម៌។ព័ត៌មានដែលបកប្រែនេះត្រូវបានចែករំលែកជាមួយសមាជិកជាស្ត្រីនៅក្នុងក្រុមVSLAក្នុងកិច្ចប្រជុំប្រចាំខែរបស់ពួកគេ។ សមាជិកជាស្ត្រីមានឱកាសផ្តល់នូវមតិយោបល់ត្រឡប់មកវិញពីរបៀបដែលពួកគេប្រើសេវាផ្សព្វផ្សាយនេះ ហើយវាក៏ជាវេទិកាសម្រាប់ពួកគេលើកនូវតម្រូវការទូទៅ កង្វល់ និងបញ្ហារបស់ពួកគេទៅមន្ត្រីឃុំ និងអាជ្ញាធរកសិកម្មរដ្ឋាភិបាល។ ឧទាហរណ៍ មុនពេលកិច្ចប្រជុំផែនការអភិវឌ្ឍន៍សង្គម-សេដ្ឋកិច្ចប្រចាំឆ្នាំ VSLA បានចូលរួមក្នុងការពិភាក្សាពីបញ្ហារបស់ពួកគេ និងបានលើកឡើងនូវបញ្ហារបស់ពួកគេជាមួយមេភូមិ និងឃុំនៅក្នុងកិច្ចប្រជុំពិគ្រោះយោបល់ប្រឹក្សារបស់ប្រជាជនឃុំ។ ស្ត្រីក៏អាចទទួលបានយោបល់ពីអ្នកធ្វើការផ្សព្វផ្សាយសេវាកសិកម្មទាក់ទងនឹងការអនុវត្តការធ្វើកសិកម្មដូចជាការប្រើប្រាស់ប្រតិទិនរដូវកាល ការបង្កើតរចនាសម្ព័ន្ធដំណាំ និងថ្នាំសម្លាប់សត្វល្អិត ថ្នាំសម្លាប់ស្មៅ និងការគ្រប់គ្រងដី។បុរសនិងក្មេងប្រុសចូលរួមក្នុងការពិភាក្សាជាមួយស្ត្រីពីការបែងចែកបន្ទុកការងារនៅក្នុងសកម្មភាពផលិតនិងសកម្មភាពការងារផ្ទះក៏ដូចជាការធ្វើសេចក្តីសម្រេចចិត្តទាក់ទងនឹងធាតុចូលនានាក្នុងកសិកម្មនៅកម្រិតគ្រួសារ និងការសម្រេចចិត្តផ្សេងៗទៀតនៅកម្រិតសហគមន៍។ |

### ឧទាហរណ៍ទី ១២៖ ការពង្រឹងព័ត៌មានអាកាសធាតុ និងប្រព័ន្ធប្រកាសអាសន្ន

| ប្រទេស៖ | អង្គការ៖ | វិស័យ |
|---|---|---|
| កម្ពុជា | UNDP | ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយកសិកម្ម |

| | |
|---|---|
| **ការពិពណ៌នា៖** | គម្រោងនេះក៏ចាប់ដៃគូជាមួយកម្មវិធី EWS1294 - សេវាទូរសព្ទដៃចល័ត ដែលបង្កើតឡើងដោយអង្គការ People in Need (PIN) នៅកម្ពុជា ក្រោយទឹកជំនន់ធ្ងន់ធ្ងន់នៅឆ្នាំ២០១៣។ ផ្តោតលើការពង្រីកសេវាពីខេត្តដែលមានស្រាប់ចំនួន៥ទៅខេត្តចំនួន៨ជាមួយគោលដៅគ្រប់ដណ្តប់ពាសពេញប្រទេសនៅឆ្នាំ២០២០។ កម្មវិធី EWS1294 ជាវិធីដែលអាចអនុវត្តបានសម្រាប់ប្រជាជនកម្ពុជាក្នុងការទទួលបានសារប្រព័ន្ធប្រកាសអាសន្ន។ យោងតាមការសិក្សាមួយឆ្នាំ២០១៦ ប្រជាជនកម្ពុជាច្រើនជាង ៩៦% មានទូរសព្ទផ្ទាល់ខ្លួន ហើយច្រើនជាង ៩៩% អាចទំនាក់ទំនងតាមរយៈប្រភេទទូរសព្ទមួយចំនួន។ សមាជិកចុះឈ្មោះជាសាធារណៈដោយគ្រាន់តែចុចធម្មតាទៅលេខ ១២៩៤ ហើយបញ្ចូលទីតាំងរបស់ពួកគេ។ នៅក្នុងហេតុការណ៍គ្រាអាសន្នដូចជា ទឹកជំនន់ ឬ ខ្យល់ព្យុះ អ្នកប្រើប្រាស់នៅក្នុងតំបន់រងឥទ្ធិពលទទួលបានសារសំឡេងមួយពីគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយដោយដាស់តឿន |

ពួកគេពីហានិភ័យនិងជំហានក្នុងការចាត់ការការពារខ្លួនរបស់ពួកគេថាតើវាមានកន្លែងជម្លៀសទៅទីតាំងដែលសុវត្ថិភាពជិតបំផុត ការស្នាក់នៅក្នុងផ្ទះ ឬសុវត្ថិភាពសត្វពាហនៈរបស់ពួកគេ។ ចាប់តាំងពីការសាកល្បងនៅឆ្នាំ២០១៣EWS1294បានបញ្ចូលទៅក្នុងយុទ្ធសាស្ត្រគ្រប់គ្រងគ្រោះមហន្តរាយរបស់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ។នៅឆ្នាំ២០១៨អង្គការ UNDP និងអង្គការ PIN ក៏បានធ្វើការរួមគ្នា ដើម្បីដំឡើងស្ថានីយកម្រិតទឹក និងចូលរួមជាមួយសហគមន៍នៅក្នុងខេត្តតំបន់ឆ្នេរមានខេត្តកោះកុង និងខេត្តព្រះសីហនុ ដែលជាខេត្តប្រឈមនឹងទឹកជំនន់។

**យុទ្ធសាស្ត្រយេនឌ័រ/ ផលប៉ះពាល់៖**

នៅក្នុងគម្រោងនេះ អង្គការ UNDP ជាមួយការផ្តោតលើការបង្កើនសមភាពយេនឌ័រនៅក្នុងប្រព័ន្ធប្រកាសអាសន្ន និងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ក៏បានបង្កើតដៃគូរជាមួយអង្គការ Action Aid ក្នុងការបង្កើនតំណាងនៃអង្គការក្នុងស្រុក និងស្ត្រីនៅក្នុងការគ្រប់គ្រងគ្រោះមហន្តរាយ និងការធ្វើសេចក្តីសម្រេចចិត្តពាក់ព័ន្ធនឹងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ ការធានានូវសំឡេងរបស់ពួកគេត្រូវបានស្តាប់លឺជាលក្ខណៈមូលដ្ឋាន និងលក្ខណៈជាតិហើយធានាថាចំណេះដឹង និងការចូលរួមចំណែករបស់ពួកគេមានកម្រិតច្រើនបំផុត។គម្រោងនេះផ្តោតលើការជ្រើសរើសការបណ្តុះបណ្តាល និងការភ្ជាប់ស្ត្រីនៅមូលដ្ឋានជា «ជ័យលាភី DRR» ជាមួយជំនាញនៅក្នុងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយផ្អែកលើសហគមន៍ មុខសញ្ញាគ្រោះថ្នាក់ ការវាយតម្លៃភាពងាយរងគ្រោះ និងសមត្ថភាព និងភាពជាដឹកនាំ និងការតស៊ូមតិ គម្រោងនេះក៏បានបង្កើតនូវសន្ទស្សន៍ភាពធន់របស់ស្ត្រីសម្រាប់កម្ពុជាដែរ។ ស្ត្រីនិងយុវជននឹងត្រូវបានបណ្តុះបណ្តាលនៅក្នុងការប្រមូល និងបញ្ចូលទិន្នន័យជាមួយការវិភាគដោយគាំទ្រដោយអ្នកឯកទេសអន្តរជាតិ។ គម្រោងនេះក៏បង្កើត និងជំរុញស្ត្រី «លក្ខន្តិកៈតម្រូវការ សម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយនិងការបន្សាំការប្រែប្រួលអាកាសធាតុ»។លក្ខន្តិកៈនេះនឹងត្រូវបានបង្កើតឡើងផ្អែកលើទិន្នន័យ និងសិក្ខាសាលាពិគ្រោះយោបល់ ក៏ដូចជាធាតុចូលពីស្ត្រី «ជ័យលាភី DRR» ពីខេត្តចំនួនពីរ។ លក្ខន្តិកៈនេះនឹងផ្តល់ជាមូលដ្ឋានសម្រាប់ការតស៊ូមតិនៅក្នុងកម្រិតថ្នាក់ក្រោមជាតិ និងថ្នាក់ជាតិ ដោយការចាត់សកម្មភាពតាមតំបន់អាទិភាព។

ប្រភព៖ (UNDP GEF n.d.)

## ឧទាហរណ៍ទី ១៣៖ ការកសាងសមត្ថភាពសហគមន៍តាមរយៈវិធីសាស្ត្រជម្រើសថ្មី ផ្អែកតាមការចូលរួមក្នុងការដោះស្រាយជំងឺគ្រុនឈាមនៅ Semarang

## ឧទាហរណ៍ ១៣៖ ការកសាងសមត្ថភាពសហគមន៍ តាមរយៈវិធីសាស្ត្រផ្សេងៗ ផ្អែកលើការចូលរួមនៅក្នុង Handling Dengue Hemorrhagic Fever (DHF) នៅក្នុងតំបន់ Semarang

| ប្រទេស៖ | អង្គការ៖ | វិស័យ |
|---|---|---|
| ឥណ្ឌូណេស៊ី | Mercy Corps Indonesia | សុខាភិបាល |

**ការពិពណ៌នា៖**

កម្មវិធី ACTIVE (ការផ្លាស់ប្តូរសកម្មភាពកើតឡើងដោយជំងឺឆ្លងតាមភ្នាក់ងារចម្លង នៅតំបន់ជាក់លាក់) បានធ្វើឡើងជាមួយរដ្ឋាភិបាលមូលដ្ឋាន Semarang (នាយកដ្ឋានសុខាភិបាល ទីភ្នាក់ងាររៀបចំផែនការអភិវឌ្ឍន៍ ទីភ្នាក់ងារឧតុនិយមអាកាសធាតុ និងទីភ្នាក់ងារភូមិសាស្ត្រ នាយកដ្ឋានអប់រំ) រួមទាំងអ្នកសិក្សានៃសាកលវិទ្យាល័យ Dponegoro។ ផ្តោតលើការកសាងសមត្ថភាពបន្សាំរបស់ទីក្រុងដើម្បីឆ្លើយតបទៅនឹងDHFតាមរយៈការបង្កើនការចូលរួមរបស់ហគមន៍។វិធីសាស្ត្រជាជម្រើសថ្មីៗនៅក្នុងកម្មវិធី ACTIVE គឺជាការប្រែប្រួលនៃវិធីសាស្ត្រដែលបានប្រើជាលំដាប់លំដោយនៅក្នុងសកម្មភាពការកសាងសមត្ថភាពដូចជា ការប្រើប្រាស់នូវហ្គេមដែលមានលក្ខណៈអប់រំ វិធីសាស្ត្រដែលមានការចូលរួមការពិភាក្សាប្រកបដោយអន្តរកម្ម សិក្ខាសាលា ការប្រើប្រាស់ម៉ូឌុលនិង props កិច្ចប្រជុំកៀរគរគណៈកម្មាធិការភាគីពាក់ព័ន្ធវិធីសាស្ត្រសិក្សាបែបមនុស្សពេញវ័យនិងសកម្មភាពតាមដានដែលតែងតែបញ្ចូលសហគមន៍ឱ្យមកពាក់ព័ន្ធ។ តាមរយៈវិធីសាស្ត្រនេះ គម្រោងអាចបង្កើតសេចក្តីរីករាយរបស់សហគមន៍តាមរយៈការចូលរួមនៅក្នុងសកម្មភាពផ្សេងៗចាប់ពីវគ្គបណ្តុះបណ្តាលរហូតដល់ការអនុវត្តនូវអ្វីដែលពួកគេបានរៀនទាក់ទងនឹងការគ្រប់គ្រង និងទប់ស្កាត់ជំងឺគ្រុនឈាមនៅក្នុងជីវិតប្រចាំថ្ងៃ។

បន្ថែមពីនេះទៀតការលើកទឹកចិត្តសហគមន៍វិធីសាស្ត្រដែលជាជម្រើសថ្មីត្រូវបានរំពឹងថាអាចបង្កើតនូវវប្បធម៌របស់សហគមន៍នៅក្នុងការប្រើប្រាស់ឥរិយាបថស្អាត និងសុខភាព។ កម្មវិធី ACTIVE មាន

| | |
|---|---|
| | លំដាប់លំដោយសកម្មភាពចំនួន១០ដែលមានបីដំណាក់នៃកិច្ចប្រឹងប្រែងកសាងសមត្ថភាពសហគមន៍ រួមមាន (១) ការរៀបចំ និងការបណ្តុះបណ្តាល ក្នុងចំណោមការបណ្តុះបណ្តាលគ្រូឧទ្ទេស (TOT) ដទៃទៀតសហគមន៍និងសាលារៀនក្រុមតម្រង់ទិសសកម្មភាព(AOG)ការបណ្តុះបណ្តាលកម្មាភិបាល ការផ្តល់ភាពអង់អាចដល់វេជ្ជបណ្ឌិត (២) ការអនុវត្ត ឧ. ទម្លាប់តាមដានកូនភ្ញាស់ (PJR) ការលុបបំបាត់ទីតាំងពងកូនដង្កូវទឹក (PSN) (៣) ការថែទាំជាប់ជាប្រចាំ តាមរយៈសិក្ខាសាលា និងជំនួយអាទិភាព សម្រាប់ musrenbang (ការពិភាក្សាសហគមន៍ស្តីពីតម្រូវការអភិវឌ្ឍន៍មូលដ្ឋាន) និងការតាមដាន។ |
| **យុទ្ធសាស្ត្រយេនឌ័រ/ ផលប៉ះពាល់៖**<br>ប្រភព៖ (Pratama et al ឆ្នាំ២០១៧) | Mercy Corps ប្រើប្រាស់នូវវិធីសាស្ត្រយេនឌ័រ (មិនមែនវិធីសាស្ត្រស្ត្រី) ព្រោះយើងទទួលស្គាល់ថា ដំណោះស្រាយប្រកបដោយនិរន្តរភាពទៅនឹងបញ្ហានានាដែលបានលើកឡើងខាងលើត្រូវការបុរសនិងក្មេងប្រុសដើរតួនាទីសំខាន់ជាដៃគូអ្នកគាំទ្រ និងការតស៊ូមតិនៃការរួមបញ្ចូលការចូលរួមស្ត្រីនិងក្មេងស្រីនៅក្នុងសហគមន៍នានារបស់ពួកគេ។ |

## ឧទាហរណ៍ទី ១៤៖ វិធីសាស្ត្រប្រជាសាស្ត្រ សុខភាព និងបរិស្ថាន នៅក្នុងគោលនយោបាយការប្រែប្រួលអាកាសធាតុ

| ប្រទេស៖ | អង្គការ៖ | វិស័យ |
|---|---|---|
| ហ្វីលីពីន | PATH Foundation Philippines Inc | សុខាភិបាល |

| | |
|---|---|
| **ការពិពណ៌នា៖** | មូលនិធិ PATH ហ្វីលីពីន Inc. (PFPI)បានអនុវត្តគម្រោងប្រជាសាស្ត្រ សុខភាព និងបរិស្ថាន និងគម្រោងការប្រែប្រួលអាកាសធាតុនៅក្នុងកោះ Verde ហ្វីលីពីន។ កោះ Verde គឺជាតំបន់ជីវចម្រុះសមុទ្រដ៏សំខាន់ដែលរងគំរាមកំហែងដោយការនេសាទហួសកម្រិតការបំពុលនិងការប្រែប្រួលអាកាសធាតុ។គោលបំណងនៃគម្រោងនេះគឺដើម្បីបញ្ជ្រាបសិទ្ធិសុខភាពផ្លូវភេទនិងសុខភាពបន្តពូជ(SRHR) ទៅក្នុងគោលនយោបាយនិងការអនុវត្តការប្រែប្រួលអាកាសធាតុ។គម្រោងបានប្រើវិធីសាស្ត្រដែលមានអភិវឌ្ឍន៍មួយ (PHE) ដោយបង្កើតកិច្ចសហការ និងដៃគូពហុវិស័យ ប្រើនូវកិច្ចអន្តរាគមន៍ច្រើន ដើម្បីដោះស្រាយតម្រូវការ SRHR (ការរៀបចំផែនការគ្រួសារ) ការបាត់បង់ជីវចម្រុះ សុខភាពមិនល្អ និងអសន្តិសុខស្បៀង ដើម្បីបង្កើនសហគមន៍ធន់ទៅនឹងអាកាសធាតុ។<br>ស្ត្រីដើរតួនាទីយ៉ាងសំខាន់ក្នុងការសម្រេចបាននូវភាពធន់ការប្រែប្រួលអាកាសធាតុ។លទ្ធផលការសិក្សាកំណត់វិសាលភាពរបស់PFPIបង្ហាញថាស្ត្រីមានសារសំខាន់ក្នុងការទទួលយកនិងការអនុវត្តដំណោះស្រាយ។ ការរៀបចំផែនការគ្រួសាររបស់ពួកគេ ការគ្រប់គ្រងធនធាន និងការតស៊ូមតិសម្រាប់ pro-health និង pro-environment នៅក្នុងសហគមន៍របស់ពួកគេផ្ទាល់ ដែលនឹងជួយដល់ការកសាងភាពធន់ទៅនឹងអាកាសធាតុ។ដំណោះស្រាយទាំងអស់នេះនឹងចូលរួមចំណែកធ្វើឱ្យអនាគតមានភាពល្អប្រសើរសម្រាប់កូនៗរបស់ពួកគេ។ ស្ត្រីក៏បានបង្ហាញពីកិច្ចសហការ និងការឯកភាពរវាងសហគមន៍នឹងបង្កើតការសហការគ្នានៅក្នុងសកម្មភាព និងលទ្ធផលសហគមន៍។ |
| **យុទ្ធសាស្ត្រយេនឌ័រ/ ផលប៉ះពាល់៖**<br>ប្រភព៖ (ដំណោះស្រាយការប្រែប្រួលអាកាសធាតុលើកស្ទួយយេនឌ័រ ឆ្នាំ២០១៦) | ទំនាក់ទំនងស្នូលនៃប្រជាសាស្ត្រ សុខភាព បរិស្ថាន និងការប្រែប្រួលអាកាសធាតុ គឺជា «ការដាក់បន្ទុកលើស្ត្រី»។ សហគមន៍នេសាទនៅកោះ Verde មានបទពិសោធន៍ការធ្លាក់ចុះផលនេសាទ ការធ្លាក់ចុះទឹកដែលអាចទទួលបាន និងសុខភាពមិនល្អ។ កង្វះជម្រើសជីវភាពរស់នៅ ការបាត់បង់ប្រាក់ចំណូលគ្រួសារ និងសន្តិសុខស្បៀង ធ្វើឱ្យស្ត្រីចូលរួមក្នុងការងារជាច្រើន និងធ្វើការម៉ោងកាន់តែវែង ដើម្បីបំពេញបន្ថែមប្រាក់ចំណូលក្នុងគ្រួសារ។ គម្រោងនេះបង្ហាញពីតម្រូវការ និងសិទ្ធិរបស់ស្ត្រី ក៏ដូចជាការរៀបចំផែនការគ្រួសារនៅក្នុងវិធីសាស្ត្រដែលមាការចូលរួម ការជួយពួកគេនៅក្នុងការកំណត់រកយុទ្ធសាស្ត្រដោះស្រាយផ្សេងៗទៀត។ |

## ឯកសារមេរៀនទី ២០៖ ឧទាហរណ៍នៃដំណោះស្រាយឆ្លើយតបយេនឌ័រ

### ឧទាហរណ៍ ១៥៖ ការថែទាំសុខភាពបន្តពូជនៅក្នុងការឆ្លើយតបនៅពេលគ្រាអាសន្ន

| ប្រទេស៖ | អង្គការ៖ | វិស័យ |
|---|---|---|
| ហ្វីលីពីន | UNFPA | ការគ្រប់គ្រងគ្រោះមហន្តរាយតំបន់ឆ្នេរ |

**ការពិពណ៌នា៖**

ក្រោយពីព្យុះស៊ីក្លូន Haiyan អង្គការ UNFPA បានធ្វើការប៉ាន់ប្រមាណ ស្ត្រីមានផ្ទៃពោះចំនួន ២៣០ ០០០នាក់ មាននៅក្នុងតំបន់ដែលរងឥទ្ធិពល មានស្ត្រី៨៣៥នាក់សម្រាលកូនជារៀងរាល់ថ្ងៃ ជាមួយការទទួលបានការថែទាំដែលទាក់ទងផ្នែកសម្ភពមានកម្រិតបំផុតពេលគ្រាអាសន្ន។ អង្គការ UNFPA រួមគ្នាជាមួយដៃគូ បានផ្តល់នូវសេវាថែទាំសុខភាពមាតាពេលសម្រាល តាមរយៈបន្ទប់មាតុភាពបណ្តោះអាសន្ន បន្ទប់សម្ភពសង្គ្រោះបន្ទាន់ចំនួន២នៅក្នុងកុងទីន័រ និងរថយន្តសង្គ្រោះបន្ទាន់ចំនួន ៣៤គ្រឿង និងម៉ូតូជាច្រើនគ្រឿងទៀត។ស្ត្រីនិងក្មេងស្រីស្ថិតក្នុងវ័យបន្តពូជក៏ត្រូវបានផ្តល់ជូននូវសម្ភារអនាម័យមូលដ្ឋានផងដែរដូចជាសំឡីអនាម័យអាវទ្រនាប់និងសាប៊ូដុំដោយមានការចែកចាយនូវសម្ភារក្សាភាពថ្លៃថ្នូនៅក្នុងមជ្ឈមណ្ឌលជម្លៀសនានា។ សម្ភារបន្ថែមផ្សេងចំនួន១១០ ០០០មុខ សម្រាប់ស្ត្រីមានផ្ទៃពោះ និងស្ត្រីបំបៅកូន។ អង្គការ UNFPA បានផ្តោតលើការធានាបាននូវស្ត្រីចំនួន ៤០០០នាក់ ជារៀងរាល់សប្តាហ៍ទទួលបាននូវសេវាថែទាំសុខភាពបន្តពូជ តាមរយៈការផ្តល់នូវឧបករណ៍ និងការជួសជុលហេដ្ឋារចនាសម្ព័ន្ធនៅក្នុងខេត្តទាំងអស់ចំនួន៨ ដែលរងឥទ្ធិពល។

ក្រោយខ្យល់ព្យុះបន្ទាប់ពីព្យុះស៊ីក្លូនអង្គការUNFPAក៏បានយកចិត្តទុកដាក់ពិសេសចំពោះតម្រូវការរស់ក្រុមមនុស្សវ័យក្មេងដែលរងឥទ្ធិពលដោយគ្រោះមហន្តរាយ។ជាមួយនឹងការចូលរួមដោយផ្ទាល់របស់ពួកគេ និងជំនួយពីដៃគូក្នុងស្រុក អង្គការ UNFPA បានបង្កើតឡើង «ទីតាំងមេត្រីភាពយុវជន» ដែលផ្តល់នូវវគ្គបណ្តុះបណ្តាលការអប់រំវ័យស្របាលគ្នាសម្រាប់អ្នកស្ម័គ្រចិត្តក៏ដូចជាសកម្មភាពផ្សេងៗទៀតសម្រាប់យុវជននៅមូលដ្ឋាន រួមមានវគ្គព័ត៌មានពីបំនិនជីវិត និងឥរិយាបថផ្លូវភេទដែលមានការទទួលខុសត្រូវ។ ក្រុមមនុស្សវ័យក្មេងជាង ២០ ០០០នាក់ ទូទាំងតំបន់ដែលមានការលំបាកខ្លាំងបានចូលរួមក្នុងវគ្គព័ត៌មានសុខភាពដែលគាំទ្រដោយអង្គការ UNFPA ដើម្បីដោះស្រាយបញ្ហាអំពើហិង្សាពាក់ព័ន្ធនឹងយេនឌ័រ អង្គការUNFPA បានបង្កើតទីតាំងមេត្រីភាពស្ត្រីចំនួន១៧ ទូទាំងខេត្តទាំងបួន។ ទីតាំងនេះបម្រើជាកន្លែងចម្បងក្នុងការលើកកម្ពស់ការយល់ដឹងពីអំពើហិង្សាពាក់ព័ន្ធនឹងយេនឌ័រ ការប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស ក៏ដូចជាសម្រាប់ផ្នែកចិត្តសាស្ត្រសង្គមគាំទ្រជាមួយនឹងសេវាផ្តល់អនុសាសន៍ដល់អ្នករស់រានមានជីវិត។ វាក៏មានទំនាក់ទំនងជាមួយនឹងកម្មវិធីការងារដើម្បីលុយផងដែរ។ បន្ថែមពីនេះទៀត អ្នកផ្តល់សេវាចំនួន ២៤០០នាក់ ត្រូវបានណែនាំក្នុងការដោះស្រាយករណីអំពើហិង្សាពាក់ព័ន្ធនឹងយេនឌ័រអំឡុងពេលគ្រាអាសន្ន។

**យុទ្ធសាស្ត្រយេនឌ័រ/ ផលប៉ះពាល់៖**

ដោយសារតម្រូវការកើនឡើងបន្ទាប់ពីព្យុះទីហ្វុង Mangkhut អង្គការUNFPA បានចាប់ផ្តើមធ្វើការជាមួយរដ្ឋាភិបាលហ្វីលីពីន ដើម្បីធានាថាស្ត្រីទទួលរងឥទ្ធិពលដោយព្យុះទីហ្វុង មិនត្រូវបានកាត់ផ្តាច់ចេញពីការជួយសង្គ្រោះអាយុជីវិត ការថែទាំសុខភាពបន្តពូជ - គ្រប់ទីកន្លែងដែលពួកគេស្ថិតនៅ។

ប្រភព៖ (UNFPA ឆ្នាំ២០១៨)

## ឯកសារមេរៀនទី ២០៖ ឧទាហរណ៍នៃដំណោះស្រាយឆ្លើយតបយេនឌ័រ

### ឧទាហរណ៍ទី ១៦៖ ដំបូលត្រជាក់សម្រាប់ទីក្រុងក្រីក្រ

| ប្រទេស៖ | អង្គការ៖ | វិស័យ |
|---|---|---|
| ឥណ្ឌា | គ្រឹះ Mahila Housing Sewa (MHT) | សុខាភិបាល និងជីវភាពរស់នៅ |

**ការពិពណ៌នា៖**

សីតុណ្ហភាពខ្ពស់ខុសប្រក្រតីមិនត្រឹមតែកើនឡើងនូវតម្រូវការថាមពលប៉ុណ្ណោះទេ ប៉ុន្តែក៏ប៉ះពាល់ដល់សុខភាព និងជីវភាពរស់នៅរស់នៅរបស់អ្នកក្រីក្រផងដែរ ជាពិសេសអ្នកទាំងឡាយណាដែលកំពុងរស់នៅក្នុងសំណង់អាណាធិបតេយ្យតំបន់ទីក្រុង។ ដំបូលនៅតាមតំបន់ទីក្រុងជាង ៦០% ត្រូវបានបង្កើតឡើងពីលោហៈធាតុ ក្បឿងasbestos និងបេតុង ដែលស្រូបកម្ដៅនៅក្នុងអគារ។ អ្នកធ្វើការតាមផ្ទះ ភាគច្រើនជាស្ត្រីរងឥទ្ធិពលបំផុតដោយសារដំបូលបែបនេះ ជាមួយនឹងការរាយការណ៍ការធ្លាក់ចុះនូវផលិតភាពរបស់ពួកគេកើនឡើងដល់ ៣០% នារដូវក្ដៅ។ ដើម្បីដោះស្រាយបញ្ហានេះ គ្រឹះ MHT បានសាកល្បងកម្មវិធីមួយស្ដីពីដំបូលត្រជាក់ ឬអ្នកក្រីក្រនៅតំបន់ទីក្រុង ប្រទេសឥណ្ឌា។ ដោយការផ្លាស់ប្ដូរនូវប្រព័ន្ធត្រជាក់ដ៏ធំផ្ទះសម្បែងទាំងនេះអាចបន្សាំបានយ៉ាងល្អប្រសើរទៅនឹងថ្ងៃដែលក្ដៅខ្លាំង ធ្វើឱ្យគ្រួសារងាយរងគ្រោះតិចតួចទៅនឹងផលប៉ះពាលធាតុអាកាសនិងកែលម្អភាពធន់របស់ពួកគេប្រឆាំងនឹងហានិភ័យការប្រែប្រួលអាកាសធាតុ។ដំបូលត្រជាក់មានចំណាំងផ្លាតពន្លឺព្រះអាទិត្យនិងស្រូបយកកម្ដៅតិចតួច។ ផ្អែកលើការដំឡើងនេះ ដំបូលត្រជាក់អាចជួយរក្សាសីតុណ្ហភាពក្នុងផ្ទះសម្បែងឱ្យទាបជាងចន្លោះពី ២ ទៅ ៥ oC (៣,៦ - ៩ oF) បើប្រៀបធៀបទៅនឹងដំបូលបែបបុរាណ។ ដំបូលត្រជាក់មានតម្លៃតិចបំផុត ០០,៥ ក្នុងមួយម៉ែត្រការ៉េសម្រាប់ថ្នាំលាបផ្អែកលើកំបោរធម្មតា កាន់តែថ្លៃសម្រាប់ថ្នាំកូត និងភ្នាសកូត។ ម៉ូដែលដំបូលត្រជាក់សំខាន់ៗចំនួនបីដែលត្រូវបានសាកល្បង៖

ក) «ខ្យល់ចេញចូលតិច» កង្ហាខ្យល់៖ ធ្វើឡើងពីសន្លឹកសរសៃរ កង្ហាខ្យល់ដំបូលមានរាងមូលទាំងនេះមិនត្រឹមតែកែលម្អចលនាខ្យល់ និងកាត់បន្ថយសីតុណ្ហភាពខាងក្នុងប៉ុណ្ណោះទេ ពួកវាថែមទាំងអាចផ្ដល់ពន្លឺដល់ផ្ទះសម្បែងនៅពេលថ្ងៃបានយ៉ាងល្អប្រសើរ។ ដោយហេតុនេះកាត់បន្ថយការប្រើប្រាស់អគ្គិសនី (កង្ហា និងអំពូល) បានស្ទើរតែពាក់កណ្ដាល។ ថែមទាំងជួយដោះស្រាយការបំពុលខ្យល់ក្នុងអគារផងដែរ។

ខ) «ដំបូល Mod» ផ្នែកខាងលើ៖ ធ្វើឡើងពីសំណល់ក្រដាស់ និងស្រកីដូង ដំបូលមិនជ្រាបទឹកទាំងនេះមិនត្រឹមតែកាត់បន្ថយសីតុណ្ហភាពក្នុងផ្ទះសម្បែងបាន ៦-៨ oC ប៉ុណ្ណោះទេ ប៉ុន្តែក៏មានតម្លៃទាប និងផ្ដល់នូវជម្រើសមេត្រីភាពបរិស្ថានចំពោះដំបូល RCC។ ពួកវាក៏ងាយស្រួលរុះរើ និងអាចដំឡើងសារជាថ្មីបន្ទាប់ពីសាងសង់ជាន់បន្ថែម ឬប្ដូរទៅទីតាំងថ្មី។ អត្ថប្រយោជន៍សម្រាប់អ្នកអាស្រ័យនៅតាមសំណង់អាណាធិបតេយ្យដែលមានសិទ្ធិកាន់កាប់ដីធ្លីមិនច្បាស់លាស់។

គ) ថ្នាំលាបឆ្លុះកម្ដៅ៖ ការលាបថ្នាំដំបូលផ្ទះជាមួយនឹងថ្នាំលាបឆ្លុះនឹងកម្ដៅសម្រាប់បន្ថយសីតុណ្ហភាពក្នុងអគារឱ្យទាបជាង ២ oC

គ្រឹះ MHT ក៏បានសហការជាមួយសាកលវិទ្យាធីហ្គាហ្គូ មន្ទីរពិសោធន៍ថាមពល និងបរិស្ថាននៅក្រុងដេលី និងជាមួយនិងទីស្ដីការការស្រាវជ្រាវការពារជាតិ (NDRC) ក្នុងការវាយតម្លៃពីប្រសិទ្ធភាពនៃបច្ចេកវិទ្យាទាំងនេះក្នុងការកាត់បន្ថយសីតុណ្ហភាពក្នុងអគារ។

**យុទ្ធសាស្ត្រយេនឌ័រ/ផលប៉ះពាល់៖**

ដំបូងត្រជាក់មានអត្ថប្រយោជន៍ជាច្រើនសម្រាប់ស្ត្រីដូចមានគូសបញ្ជាក់ពីការសាកល្បង។ ពួកវាជួយកាត់បន្ថយការចំណាយលើថាមពល ទន្ទឹមនឹងនោះក៏ផ្ដល់នូវពេលវេលាថ្ងៃត្រង់ដែលខំទ្រាំអត់ធ្មត់សម្រាប់ស្ត្រីធ្វើការតាមផ្ទះផងដែរ។ គម្រោងនេះក៏កៀរគរស្ត្រីឱ្យបង្កើនការយល់ដឹងពីអត្ថប្រយោជន៍នៃការប្រើប្រាស់ផលិតផល ដោយការបណ្ដុះបណ្ដាលសហគ្រិនស្ត្រី និងបង្កើតផលិតផលកម្មីមួយដើម្បីបង្កើតម៉ូឌែលជំនួញមួយដែលមាននិរន្តរភាព។ដំបូលត្រជាក់ក៏ជួយកសាងភាពធន់របស់សហគមន៍ទៅនឹងកម្ដៅខ្លាំងផងដែរ។ បច្ចុប្បន្ន អង្គការក៏បានលើកយកនូវបទពិសោធន៍នេះ តាមរយៈអ្នកដឹកនាំជាស្ត្រីនៅកម្រិតទីក្រុង និងទីក្រុង Ahmedabad មានកម្មវិធីដំបូលត្រជាក់សម្រាប់ផ្ទះសម្បែងដែលមានប្រាក់ចំណូលទាបជាង ៣០០០ ជាផ្នែកនៃផែនការសកម្មភាពកម្ដៅរបស់គម្រោង។

ប្រភព៖ (បច្ចេកវិទ្យាប្រយុទ្ធនឹងស្ត្រេសកម្ដៅ n.d.)

## ឯកសារមេរៀនទី ២០៖ ឧទាហរណ៍នៃដំណោះស្រាយឆ្លើយតបយេនឌ័រ

### ឧទាហរណ៍ទី ១៧៖ ប្រព័ន្ធបំភ្លឺផ្ទះពន្លឺព្រះអាទិត្យផ្សព្វផ្សាយដោយស្ត្រីមេម៉ាយក្មេងជនជាតិភាគតិច នៅក្នុងសហគមន៍ដែលជាកុលសម្ព័ន្ធរបស់ពួកគេ

| ប្រទេស៖ | អង្គការ៖ | វិស័យ |
|---|---|---|
| ឥណ្ឌា | Rural Agency for Social and Technological Advancement ( RASTA ) | ថាមពល |

| | |
|---|---|
| **ការពិពណ៌នា៖** | គម្រោងនេះ បណ្តុះបណ្តាលស្ត្រីជនជាតិភាគតិចមេម៉ាយក្មេងក្នុងការដំឡើងប្រព័ន្ធថាមពលទាញពីពន្លឺព្រះអាទិត្យសម្រាប់បំភ្លឺក្នុងអគារនៅក្នុងផ្ទះសម្បែងកុលសម្ព័ន្ធនៃតំបន់ព្រៃ Wayanad - ប្រទេសឥណ្ឌា។ RASTA សហការជាមួយមហាវិទ្យាល័យស្ត្រី Barefoot នៃទីក្រុង Rajasthan បណ្តុះបណ្តាលស្ត្រីមេម៉ាយក្មេងពីសហគមន៍កុលសម្ព័ន្ធពីការដំឡើង និងដំណើរការអំពូលថាមពលទាញពីពន្លឺព្រះអាទិត្យ។ បន្ទាប់ពីវគ្គបណ្តុះបណ្តាល ស្ត្រីមេម៉ាយក្មេងធ្វើការដំឡើងនៅក្នុងសហគមន៍របស់ពួកគេ និងជំរុញលើកទឹកចិត្តសហគមន៍ឱ្យចូលរួមចំណែកជាថ្លៃឈ្នួលតិចតួចសម្រាប់បន្តទៅមុខនិងការថែរក្សានាពេលអនាគត។ អ្នកទទួលផលប្រយោជន៍ធំ គឺក្មេងៗនៅតាមសាលារៀន និងស្ត្រី ដូចជាការបំភ្លឺផ្ទះដែលផ្តល់នូវពេលវេលាសម្រាប់ធ្វើការងារផ្ទះសម្បែង និងធ្វើឱ្យសត្វព្រៃនៅឆ្ងាយ។<br>ប្រព័ន្ធទាញថាមពលពីពន្លឺព្រះអាទិត្យ ត្រូវបានដំឡើងនៅផ្ទះសម្បែងចំនួន ១៦៥ នៃតំបន់ព្រៃដែលនៅដាច់ស្រយាល បានកាត់បន្ថយផលប៉ះពាល់អាកាសធាតុនៃសហគមន៍កុលសម្ព័ន្ធប្រមាណ ១៦,៥តោននៃGHG។ការប្រើប្រាស់ប្រេងកាតរបស់ពួកគេត្រូវបានកាត់បន្ថយគួរឱ្យកត់សម្គាល់ប្រហែល ១០ ០០០ លីត្រក្នុងមួយឆ្នាំ។ អាគុយរបស់អំពូលភ្លើងអាច returned កែច្នៃឡើងវិញ និងជួសជុលកែតម្រូវឡើងវិញ ដោយការកាត់បន្ថយនូវផលប៉ះពាល់បរិស្ថានរបស់គម្រោង។ |
| **យុទ្ធសាស្ត្រយេនឌ័រ/ ផលប៉ះពាល់៖**<br><br>ប្រភព៖ ( ដំណោះស្រាយការប្រែប្រួលអាកាសធាតុលើកស្ទួយយេនឌ័រ ឆ្នាំ២០១៦ ) | គណៈកម្មាធិការរបស់គម្រោងមានស្ត្រីចំនួន ៨០% ហើយដំឡើងត្រូវបានធ្វើឡើងដោយក្មេងស្រីកុលសម្ព័ន្ធដែលបានឆ្លងកាត់ការបណ្តុះបណ្តាល។ ដំណើរការដំឡើងនេះបានទាក់ទាញស្ត្រី ដែលត្រូវបានបំពាក់ការងារមួយបែបប្រពៃណីដោយបុរស។ការទទួលស្គាល់ផ្នែកសង្គមនិងស្ថានភាពសេដ្ឋកិច្ចនៃវិស្វករពន្លឺព្រះអាទិត្យដែលជាស្រីត្រូវបានកែលម្អ។ ជាលទ្ធផល ការបោះបង់ការសិក្សារបស់ក្មេងស្រីត្រូវបានកាត់បន្ថយ ហើយស្ត្រីមានទម្លាប់អានកាន់តែល្អប្រសើរឡើង។ |

### ឧទាហរណ៍ទី ១៨៖ ការវាយតម្លៃយេនឌ័រនៃអនុផលព្រៃឈើ និងការកសាងសមត្ថភាព

| ប្រទេស៖ | អង្គការ៖ | វិស័យ |
|---|---|---|
| ឡាវ | សមាគមអភិវឌ្ឍន៍យេនឌ័រ | ព្រៃឈើ |

| | |
|---|---|
| **ការពិពណ៌នា៖** | សមាគមន GDA បានវាយតម្លៃតួនាទីយេនឌ័រនៅក្នុងតំបន់ខ្ពង់រាបភាគខាងជើងនៃប្រទេសឡាវដោយផ្តោតលើអនុផលព្រៃឈើ ( (NTFP)។ គម្រោងនេះបានប្រើទស្សនៈវិស័យការផ្តល់ភាពអង់អាចស្ត្រី ដើម្បីភ្ជាប់ការអនុវត្តការប្រមូលផលបែបបុរាណជាមួយនឹងការផ្តួចផ្តើមជីវភាពរស់នៅប្រកបដោយនិរន្តរភាពនៅក្នុងសហគមន៍គោលដៅ។ អ្នកទទួលអត្ថប្រយោជន៍ពីគម្រោងមានចំនួន ៤៥០០នាក់រួមមានស្ត្រី គ្រួសាររបស់ពួកគេ និងសមាជិកសហគមន៍ សមាជិកជាច្រើននៅក្នុងក្រុមជនជាតិដើមភាគតិច Hmong និង Khmu ដែលជាក្រុមរងការលំបាកជាប្រព័ន្ធនៅក្នុងប្រទេសឡាវ។ គម្រោងបានកំណត់ផ្នែកសំខាន់ៗនិងចងក្រងគោលនយោបាយដើម្បីកែលម្អនិរន្តរភាព។អ្នកដឹកនាំជាស្ត្រីនៅក្នុងសហគមន៍បានចូលរួមក្នុងសិក្ខាសាលាការបណ្តុះបណ្តាលគ្រូឧទ្ទេសជាមួយនឹងគោលដៅក្នុងការបង្កើនសមត្ថភាពរបស់ពួកគេ និងចែករំលែកចំណេះដឹងរបស់ពួកគេ។<br>ភូមិដែលត្រូវបានជ្រើសរើសសម្រាប់ការវាយតម្លៃមានទីតាំងនៅតំបន់ហានិភ័យខ្ពស់ទៅនឹងការបាក់អើលដី។ ហានិភ័យនេះបានកើនឡើងជាច្រើនឆ្នាំកន្លងទៅ ដោយសារការកាប់បំផ្លាញព្រៃឈើពីការប្រមូលផលហួសកម្រិត។ ដោយការគាំទ្រនូវជម្រើសផ្នែកសេដ្ឋកិច្ច និងNTFPs សមាគម GDA ធ្វើការ |

ឆ្ពោះទៅរកការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយធម្មជាតិ។ ពួកគេក៏អភិរក្សធនធានធម្មជាតិតាមរយៈការបណ្តុះបណ្តាល និងការតស៊ូមតិខាងផ្នែកការអនុវត្តប្រមូលផលប្រកបដោយនិរន្តរភាព ជាពិសេសការតស៊ូមតិសម្រាប់កំណែទម្រង់គោលនយោបាយនៅក្នុងផ្នែកនៃការប្រមូលផលនេសាទ ដើមក្រវាញ និងផ្សិតព្រៃ ដែលមិននិរន្តរភាព។

**យុទ្ធសាស្ត្រយេនឌ័រ/ផលប៉ះពាល់៖**

បន្ថែមពីលើការងារពាក់ព័ន្ធនឹងគ្រួសារនិងផ្ទះសម្បែងស្ត្រីនៅក្នុងភូមិគោលដៅក៏ទទួលខុសត្រូវចម្បងសម្រាប់ NTFP ផងដែរ។ ការប្រើក្របខ័ណ្ឌយេនឌ័រផ្អែកលើសិទ្ធិ គម្រោងនេះបានធ្វើការលើកកម្ពស់ការយល់ដឹង និងការបណ្តុះបណ្តាលការគ្រប់គ្រងហិរញ្ញវត្ថុ ដើម្បីលើកកម្ពស់ឯករាជ្យភាពផ្នែកហិរញ្ញវត្ថុ។ តាមរយៈការកសាងសមត្ថភាពដល់ស្ត្រីឱ្យក្លាយជាអ្នកមានចំណេះដឹងក្នុងផ្នែកកសិកម្មនិងបង្កើតប្រាក់ចំណូល គម្រោងមានបំណងបង្កើនការចូលរួម និងឥទ្ធិពលរបស់ពួកគេលើការធ្វើសេចក្តីសម្រេចចិត្តរបស់សហគមន៍។

ប្រភព៖ (ដំណោះស្រាយការប្រែប្រួលអាកាសធាតុលើកស្ទួយយេនឌ័រ ឆ្នាំ២០១៧)

## ឧទាហរណ៍ទី ១៩៖ ការការពារជីវចម្រុះ៖ តួនាទីស្ត្រីនៅក្នុងការស្តារព្រៃកោងកាងឡើងវិញ

| ប្រទេស៖ | អង្គការ៖ | វិស័យ |
|---|---|---|
| ឥណ្ឌូណេស៊ី | Natural Aceh | ប្រព័ន្ធអេកូឡូស៊ីតំបន់ឆ្នេរ |

**ការពិពណ៌នា៖**

នៅក្នុង Aceh នៅក្នុងភូមិតំបន់ឆ្នេរក្រីក្រ បុរសចេញទៅសមុទ្រជាច្រើនថ្ងៃដើម្បីចាប់ត្រី ខណៈដែលស្ត្រីបង្កើនប្រាក់ចំណូលក្នុងគ្រួសារដោយការប្រមូលអយស្ទ័រជុំវិញភូមិ។ តាមរយៈការបណ្តុះបណ្តាល និងការលើកកម្ពស់ការយល់ដឹងរបស់ស្ត្រីនៅមូលដ្ឋានពីសារសំខាន់នៃការស្តារព្រៃកោងកាងឡើងវិញ គម្រោងអាចធ្វើអ្វីមួយធានាបាននូវការកើនឡើងប្រាក់ចំណូលក្នុងគ្រួសារ និងការកាត់បន្ថយការប្រែប្រួលអាកាសធាតុ។ ជាមួយការផ្តោតលើរយៈពេលវែង ការបណ្តុះបណ្តាលជាក់ស្តែងពិនិត្យមើលបច្ចេកទេសបណ្តុះកូនកោងកាង ដាំដុះ និងអេកូឡូស៊ីដែលទ្រទ្រង់ផ្សេងៗ។ តាមរយៈការចូលរួមរបស់សហគមន៍ គម្រោងចូលរួមចំណែកដល់សន្តិសុខស្បៀង និងអាហារូបត្ថម្ភ កែលម្អជម្រកនៃជីវិត ១២៧០កន្លែង។ស្ថិតនៅក្នុងតំបន់ដែលប្រឈមនឹងជម្លោះភាពធន់ផ្នែកសេដ្ឋកិច្ចអាចកាត់បន្ថយជម្លោះដែលអាចកើតមាននាពេលអនាគត។

ការបន្តគេងប្រវ័ញ្ចនិងផលប៉ះពាល់ពីខាងក្រៅនិងជះឥទ្ធិពលលើទីជម្រកអយស្ទ័រដូច្នេះជះឥទ្ធិពលលើប្រាក់ចំណូលអ្នកទាំងឡាយណាដែលពឹងផ្អែកលើភាពដែលអាចរកបានរបស់ពួកគេ។ ប្រព័ន្ធអេកូឡូស៊ីកោងកាង មានឥទ្ធិពលក្នុងការកាត់បន្ថយការបញ្ចេញកាបូន ដោយស្រូបទាញវាទៅក្នុងស្រទាប់របស់សមុទ្រ។ ការដាំដុះកោងកាងកែលម្អគុណភាពខ្យល់ និងទឹក បង្កើនជីវចម្រុះ និងកាត់បន្ថយសីតុណ្ហភាពនៅមូលដ្ឋាន។ជាមួយនឹងវិធីសាស្ត្រការស្តារឡើងវិញត្រឹមត្រូវនិងដើមកោងកាងដែលមានតម្លៃថោក (€០,១៥ - ០,២០ ក្នុងមួយដើម) សហគមន៍អាចទទួលផលប្រយោជន៍នៅក្នុងរយៈពេលវែងផ្នែកបរិស្ថាន និងសេដ្ឋកិច្ច។

**យុទ្ធសាស្ត្រយេនឌ័រ/ផលប៉ះពាល់៖**

ស្ត្រីនៅតំបន់ជនបទជិត ៩០% នៅក្នុងតំបន់ Aceh ជាកសិករអយស្ទ័រ។ ការងារនេះប្រើកម្លាំងខ្លាំង និងជះឥទ្ធិពលលើសុខភាពរបស់ពួកគេ។ គម្រោងបណ្តុះបណ្តាលស្ត្រីនៅក្នុងការស្តារកោងកាងឡើងវិញប្រកបដោយនិរន្តរភាព។ ដើម្បីចៀសវាងការដាក់បន្ទុកបន្ថែមលើស្ត្រី ពួកគេត្រូវបានផ្តល់ប្រាក់ឧបត្ថម្ភប្រចាំថ្ងៃអំឡុងពេលវគ្គបណ្តុះបណ្តាល។ ស្ត្រីនៅក្នុងតំបន់ Aceh ប្រឹងប្រែងតស៊ូដើម្បីបានចូលរួមក្នុងការធ្វើសេចក្តីសម្រេចចិត្តរបស់សហគមន៍ ទោះបីយ៉ាងណា គម្រោងផ្តល់នូវកន្លែងសម្រាប់ស្ត្រីដើម្បីចូលរួមក្នុងការធ្វើសេចក្តីសម្រេចចិត្តនៅមូលដ្ឋានលើបញ្ហាផ្នែកបរិស្ថានដែលជះឥទ្ធិពលមិនល្អលើជីវិតរបស់ពួកគេ។

ប្រភព៖ (ដំណោះស្រាយការប្រែប្រួលអាកាសធាតុលើកស្ទួយយេនឌ័រ ឆ្នាំ២០១៧)

## ឯកសារមេរៀនទី ២០៖ ឧទាហរណ៍នៃដំណោះស្រាយឆ្លើយតបយេនឌ័រ

### ឧទាហរណ៍ទី ២០៖ កសិកម្មដែលផ្តល់ដំណឹងទាក់ទងនឹងធាតុអាកាស និងជលផលពង្រឹង ដល់ការកាត់បន្ថយហានិភ័យអាកាសធាតុ និងភាពធន់ទៅនឹងអាកាសធាតុ

| ប្រទេស៖ | អង្គការ៖ | វិស័យ |
|---|---|---|
| ហ្វីលីពីន | Rice Watch Action network Inc | កសិកម្ម |

**ការពិពណ៌នា៖**

គម្រោងនេះពង្រឹងភាពរំញោចនិងចំណេះដឹងពីអាកាសធាតុនិងលក្ខណៈអាកាសធាតុដល់កសិករចំនួន ១៥ ០០០នាក់។ វាជួយពួកគេរៀបចំទុកមុនពេលភ្លៀងខ្លាំង និងខ្យល់ព្យុះ និងបកប្រែព័ត៌មានធាតុអាកាសក្នុងការធ្វើសេចក្តីសម្រេចចិត្តលើការកែសម្រួលកសិដ្ឋាននិងផែនការដំណាំជាយថាហេតុ។ លក្ខណៈតំបន់ ស្ថានីយធាតុអាកាសស្វ័យប្រវត្តិត្រូវបានដំឡើង និងបុគ្គលិករដ្ឋាភិបាលមូលដ្ឋាន ១៥០នាក់ត្រូវបានបណ្តុះបណ្តាលដើម្បីបកប្រែនិងបង្ហោះទិន្នន័យធាតុអាកាសនិងការណែនាំកសិកម្មចំពោះទីតាំងប្រមូលផ្តុំសម្រាប់សាធារណៈ។ សាលាផ្នែកភាពធន់ទៅនឹងអាកាសធាតុ (CrFS) ត្រូវបានបង្កើតឡើងដើម្បីបណ្តុះបណ្តាលកសិករផ្នែកវិធីសាស្ត្រកសិកម្មបែបអេកូឡូស៊ីក្នុងការជួយពួកគេរៀបចំ និងដោះស្រាយជាមួយភាពមិនអំណោយផលនៃរបបធាតុអាកាសទាំងរយៈពេលខ្លី និងវែង និងការប្រែប្រួលអាកាសធាតុ។

កម្មវិធីឆ្លើយតបរហ័សទៅនឹងគ្រាអាសន្ន ដែលគាំទ្រដោយសាលាក្រុងផ្តល់ព័ត៌មានចំនួន៣០ លុបបំបាត់ការខូចខាតពាក់ព័ន្ធនឹងអាកាសធាតុ ឬការបាត់បង់ជីវភាពរស់នៅ និងទ្រព្យសម្បត្តិរបស់កសិករ។ លើសពីនេះទៀត កម្មវិធីកសាងជីវចម្រុះឡើងវិញជាមួយប្រភេទគ្រាប់ពូជសរីរាង្គថ្មីៗ និងជីសរីរាង្គដែលផលិតពីជីកំប៉ុស្តិ៍ និងរួមបញ្ចូលទាំងការគ្រប់គ្រងសត្វល្អិតចង្រៃនាំមកវិញនូវសត្វល្អិតដែលមានប្រយោជន៍។ បច្ចេកវិទ្យានៃការបញ្ចេញឧស្ម័នទាបដូចជាការបង្កើនទិន្នផលស្រូវដោយការប្រើប្រាស់សំណើម និងសម្ងួតប្រភេទថ្មី ដែលកាត់បន្ថយការបញ្ចេញឧស្ម័នមេតាន ៥០% និងជួយរក្សាកាបូននៅក្នុងដី។

**យុទ្ធសាស្ត្រយេនឌ័រ/ ផលប៉ះពាល់៖**

កម្មវិធីបណ្តុះបណ្តាលភាពធន់ទៅនឹងអាកាសធាតុនៅតាមមូលដ្ឋានអនុវត្តតាមការចុះឈ្មោះចូលរៀនដោយបើកចំហរ រួមបញ្ចូលស្ត្រី និងយុវជន។ កម្មវិធីសិក្សាគឺធ្វើឡើងនៅតាមមូលដ្ឋានផ្ទាល់ ដែលអាចឱ្យមានការចូលរួមពីស្ត្រីដែលជាប់រវល់ច្រើនជាមួយនឹងកិច្ចការផ្ទះ។ ម៉ូឌុលការសិក្សានេះក៏ជំរុញការធ្វើពិពិធកម្មប្រាក់ចំណូល និងប្រភពស្បៀងអាហារ និងកសាងសមត្ថភាពភាពស្ត្រីតាមសកម្មភាពដែលត្រួតត្រាដោយបុរសតាំងពីបុរាណ (ឧ.ជលផល)។ ការធ្វើបែបនេះជួយបង្កើនចំណេះដឹងរបស់ពួកគេឆ្ពោះទៅរកការធ្វើសេចក្តីសម្រេចចិត្តរួមលើទ្រព្យសម្បត្តិ និងជីវភាពរស់នៅរបស់គ្រួសារ។

ប្រភព៖ (ដំណោះស្រាយការប្រែប្រួលអាកាសធាតុលើកស្ទួយយេនឌ័រ ឆ្នាំ២០១៩)

### ឧទាហរណ៍ទី ២១៖ ការបណ្តែត៖ សកម្មភាពអាកាសធាតុឆ្លើយតបនឹងតម្រូវការយេនឌ័រនៅក្នុងភូមិបណ្តែតទឹកកម្ពុជា

| ប្រទេស៖ | អង្គការ៖ | វិស័យ |
|---|---|---|
| កម្ពុជា | អភិរក្សអន្តរជាតិ | ជលផល |

**ការពិពណ៌នា៖**

ការរក្សានិរន្តភាពប្រព័ន្ធអេកូឡូស៊ីបឹងទន្លេសាបដែលប្រឈមមុខនឹងការបាត់បង់ គឺជាបញ្ហាស្លាប់រស់សម្រាប់ប្រជាជនកម្ពុជាចំនួន ៨,០០០នាក់ និងជាបញ្ហាគ្រប់គ្រងដ៏សំខាន់សម្រាប់តំបន់មេគង្គទាំងមូល។ តាមរយៈវិធីសាស្ត្រសមាហរណកម្មដែលផ្តោតលើការកាត់បន្ថយការបញ្ចេញឧស្ម័នតាមរយៈការកែច្នៃត្រីដោយសន្សំសំចៃថាមពល និងការបង្កើនភាពអង់អាចខាងសេដ្ឋកិច្ច និងសង្គមសម្រាប់ស្ត្រីតាមរយៈការបណ្តុះបណ្តាលដើម្បីកែលម្អចំណេះដឹងបរិស្ថាន ការប្រកាន់ខ្ជាប់វិធានការ អនាម័យ ការវេចខ្ចប់ ទីផ្សារ និងការចងក្រងការលក់នោះ គម្រោងនេះកែប្រែវិធីសាស្ត្របុរាណក្នុងការកែច្នៃត្រីឆ្អើដែលគ្មាននិរន្តភាព ទៅជាសកម្មភាពជីវភាពរស់នៅធុននឹងអាកាសធាតុ។ តាមរយៈការផ្លាស់ប្តូរផ្នត់គំនិតអំពីតួនាទីរបស់ស្ត្រី វិធីសាស្ត្រនេះប្រឈមនឹងរចនាសម្ព័ន្ធបែបបិតាធិបតេយ្យ ដើម្បីធានាការសម្រេចចិត្តដ៏ត្រឹមត្រូវផ្នែកយេនឌ័រ ដែលជំរុញនូវការផ្តួចផ្តើមអភិរក្សអេកូឡូស៊ី។

ចង្ក្រានសន្សំសំចៃថាមពល កាត់បន្ថយការបញ្ចេញឧស្ម័នកាបូន និងការប្រើប្រាស់អុស ដោយជួយ

| | |
|---|---|
| | ការពារប្រព័ន្ធអេកូឡូស៊ីដ៏ផុយស្រួយរបស់បឹងទន្លេសាប ដែលផ្អែកទៅលើព្រៃលិចទឹក ដែលជាអាងភ្ញាស់ត្រីធម្មជាតិដ៏ពិសេស។ ការអប់រំនៅតាមសហគមន៍នានាអំពីការប្រែប្រួលអាកាសធាតុជាក់ស្តែងមានឥទ្ធិពលទៅលើបឹងទន្លេសាប និងវិធីដែលអាចកាត់បន្ថយការគំរាមកំហែងទាំងនេះគឺត្រូវបានគាំទ្រដោយការអភិវឌ្ឍនៃគាំទ្រខាងហិរញ្ញវត្ថុតាមរយៈការបង្កើនប្រាក់ចំណូលសម្រាប់ស្ត្រី។ ការបង្កើតក្រុមសន្សំអាចជួយឱ្យមានការវិនិយោគការប្រាក់បានមកពីកម្ចីទៅក្នុងគម្រោងអភិរក្សដែលជួយពង្រឹងដល់ការអនុវត្តតំបន់ការពារ។ |
| **យុទ្ធសាស្ត្រយេនឌ័រ/ ផលប៉ះពាល់៖**<br><br>ប្រភព៖ (ដំណោះស្រាយការប្រែប្រួលអាកាសធាតុលើកស្ទួយយេនឌ័រ ឆ្នាំ២០១៩) | សមភាពយេនឌ័រ និងការផ្តល់ភាពអង់អាចរបស់ស្ត្រី ត្រូវបានជំរុញតាមវិធីជាច្រើន ដែលកាត់បន្ថយបន្ទុករបស់ស្ត្រីតាមរយៈបច្ចេកវិទ្យាឆ្អើត្រីប្រកបដោយប្រសិទ្ធិភាព។ការចុះឈ្មោះចូលរៀនរបស់ក្មេងស្រីមានកំណើន ៦០%។ ជាមួយកំណើននៃការលក់ ៣២%ដោយមិនបន្ថែមសម្ពាធទៅលើវិស័យជលផលអំណាចសេដ្ឋកិច្ច និងទំនុកចិត្តរបស់ស្ត្រី ត្រូវបានបង្កើនឡើង។ ក្រុមសន្សំចំនួន ១៦ នៅក្នុងភូមិចំនួន ៧ បានជំរុញសហគ្រិនភាពរបស់ស្ត្រី។ ចំណុចនេះនាំឱ្យមានស្ត្រីប្រកបដោយការជ្រួតជ្រាបនូវព័ត៌មាន និងមានការសម្តែងមតិចូលរួមក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្តនៅក្នុង គណៈកម្មាធិការជលផលដែលទទួលបានអត្ថប្រយោជន៍ពីការវិនិយោគក្រុមសន្សំហើយត្រូវតែរាយការណ៍អំពីអាទិភាពនិងសកម្មភាពអភិរក្សរបស់ពួកគេ។ |

ΣmPower Women for Climate-Resilient Societies

Sweden Sverige

arrow asian-pacific resource & research centre for women

UN WOMEN

# សៀវភៅណែនាំ បណ្តុះបណ្តាលស្តីពី យេនឌ័រនិងភាពធន់នឹង ការប្រែប្រួលអាកាសធាតុ



## ម៉ូឌុល ៥៖

## ហិរញ្ញវត្ថុអាកាសធាតុ សម្រាប់សកម្មភាពអាកាសធាតុ ដែលឆ្លើយតបនឹងតម្រូវការយេនឌ័រ

5

**ផែនការតាមវគ្គ៖**

ម៉ូឌុលនេះត្រូវបានបែងចែងជាពីរវគ្គ

**វគ្គ ក** : ការស្វែងយល់អំពីស្ថាបត្យកម្មហិរញ្ញវត្ថុអាកាសធាតុសកល និងសមាសធាតុយេនឌ័ររបស់ស្ថាបត្យកម្មនេះ

**វគ្គ ខ** : ការរៀបចំថវិកាដែលឆ្លើយតបនឹងតម្រូវការយេនឌ័រសម្រាប់ហិរញ្ញវត្ថុអាកាសធាតុ

## ម៉ូឌុល ៥ ៖ ហិរញ្ញវត្ថុអាកាសធាតុសម្រាប់សកម្មភាពអាកាសធាតុដែលឆ្លើយតបនឹងតម្រូវការយេនឌ័រ

ម៉ូឌុលនេះ ផ្តល់នូវទិដ្ឋភាពទូទៅស្តីពីស្ថាបត្យកម្មហិរញ្ញវត្ថុអាកាសធាតុសកល ដោយផ្តោតលើហិរញ្ញវត្ថុ ស្ថាប័នពហុភាគី មូលនិធិក្នុងតំបន់ និងថ្នាក់ជាតិ។ វាក៏ពិនិត្យមើលផងដែរលើសមាហរណកម្មយេនឌ័រនៅក្នុងមូលនិធិអាកាសធាតុដែលមានស្រាប់ និងតួនាទីដែលអង្គការសង្គមស៊ីវិល (CSOs) អាចអនុវត្តក្នុងការពង្រឹងបន្ថែមទៀតនូវសមាហរណកម្មសមភាពយេនឌ័រទៅក្នុងដំណើរការទាំងនេះ ជាពិសេសយន្តការពិគ្រោះយោបល់ និងសម្រាប់ការឃ្លាំមើលយេនឌ័រនៅក្នុងហិរញ្ញវត្ថុអាកាសធាតុ។

ដោយផ្អែកលើតម្រូវការចាំបាច់ សម្រាប់ការឃ្លាំមើលយេនឌ័រនៅក្នុងហិរញ្ញវត្ថុអាកាសធាតុ ម៉ូឌុលនេះ ពិនិត្យទៅលើការប្រើប្រាស់ការរៀបចំថវិកាដែលឆ្លើយតបនឹងតម្រូវការយេនឌ័រ (GRB) ជាយុទ្ធសាស្ត្រសម្រាប់បញ្ជ្រាបយេនឌ័រទៅក្នុងហិរញ្ញវត្ថុអាកាសធាតុថ្នាក់ជាតិ។ ការងារនេះត្រូវអនុវត្តក្នុងកម្រិតពីរ ដែលរួមមាន ការវិភាគលើមូលនិធិអាកាសធាតុដែលមានស្រាប់ដោយប្រើទស្សនៈវិស័យផ្អែកយេនឌ័រនិងការចូលរួមជាមួយនាយកដ្ឋានសាមីសំខាន់ៗ ដើម្បីបង្កើតការបែងចែកតាមវិស័យដែលអាចជះឥទ្ធិពលដល់សមត្ថភាពបន្សាំ និងភាពធន់របស់ស្ត្រី។ ការណ៍នេះត្រូវផ្តោតទៅលើការតម្រង់ទិសCSOsជាមួយឧបករណ៍GRBដែលពួកគេអាចប្រើដើម្បីជះឥទ្ធិពល និងផ្តល់ហិរញ្ញប្បទានសម្រាប់អាទិភាពសមភាពយេនឌ័រនៅក្នុងគោលនយោបាយ និងកម្មវិធីសម្រាប់ការបន្សាំនឹងការប្រែប្រួលអាកាសធាតុនិងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ។

**គោលបំណងនៃម៉ូឌុល ៖**

> រៀបចំប្លង់ស្ថាបត្យកម្មហិរញ្ញវត្ថុអាកាសធាតុសកល និងថ្នាក់តំបន់ និងកម្រិតសមាហរណកម្មយេនឌ័រ បច្ចុប្បន្ន។
> កំណត់យុទ្ធសាស្ត្រសម្រាប់ឱ្យ CSOs អាចចូលរួមជាមួយយន្តការហិរញ្ញវត្ថុអាកាសធាតុដែលមានស្រាប់។
> ស្វែងយល់អំពីទស្សនទានរបស់ GRB និងការអនុវត្តនៃទស្សនទាននេះនៅក្នុងវិស័យហិរញ្ញវត្ថុអាកាសធាតុក្នុងស្រុក។ និង
> សិក្សាពីការអនុវត្តក្របខ័ណ្ឌជំហានទាំង ៥ និងឧបករណ៍ GRB សម្រាប់ធ្វើការវិភាគថវិកាយេនឌ័រនៃមូលនិធិអាកាសធាតុជាតិ

**សារសំខាន់ៗ ៖**

> តម្រូវការហិរញ្ញវត្ថុអាកាសធាតុជារួមត្រូវបានប៉ាន់ប្រមាណថានឹងមានរាប់រយពាន់លានដុល្លារអាមេរិក ឬពាន់ពាន់លានដុល្លារជារៀងរាល់ឆ្នាំ បន្ទាប់ពីឆ្នាំ២០២៣។ ទោះយ៉ាងណា វឌ្ឍនភាពលើហិរញ្ញវត្ថុសាធារណៈអន្តរជាតិសម្រាប់ការប្រែប្រួលអាកាសធាតុ ជាពិសេសពីប្រទេសអភិវឌ្ឍន៍ទៅប្រទេសកំពុងអភិវឌ្ឍន៍នៅមានកំរិតទាបនៅឡើយ។
> ហិរញ្ញវត្ថុអាកាសធាតុដែលត្រូវបានឃ្លាំមើលភាគច្រើនបន្តហូរសម្រាប់សកម្មភាពកាត់បន្ថយនិងហិរញ្ញវត្ថុបន្សាំដែលបានបង្កើតឡើងមានត្រឹមតែ៥%ដែលស្មើនឹង៣០ពាន់លានដុល្លារអាមេរិក ក្នុងឆ្នាំ២០១៧-១៨ (CPI ឆ្នាំ២០១៩)។
> មានតែ ០,០១ ភាគរយនៃមូលនិធិទាំងអស់នៅទូទាំងពិភពលោក ដែលគាំទ្រដល់គម្រោងនានា ទាក់ទងនឹងការប្រែប្រួលអាកាសធាតុ និងសិទ្ធិរបស់ស្ត្រី (GGCA, UNDP ឆ្នាំ២០១៦)។
> ប្រភពធំបំផុតនៃមូលនិធិដែលបានអនុម័តសម្រាប់គម្រោងបន្សាំ គឺជាគំនិតផ្តួចផ្តើមផ្តោតលើហិរញ្ញវត្ថុអាកាសធាតុដូចជា មូលនិធិបន្សាំ (AF) កម្មវិធីសាកល្បងសម្រាប់ភាពធន់នឹងអាកាសធាតុ (PPCR) នៃមូលនិធិវិនិយោគលើអាកាសធាតុ (CIFs) របស់ធនាគារពិភពលោក មូលនិធិអាកាសធាតុបៃតង (GCF) និងមូលនិធិប្រទេសអភិវឌ្ឍន៍តិចតួច (LDCF) ដែលគ្រប់គ្រងដោយមូលនិធិបរិស្ថានពិភពលោក (GEF)។
> មូលនិធិបន្សាំសំខាន់ៗដែលមានអាណត្តិយេនឌ័រ ដែលអាចចូលរួមបាន រួមមាន៖ មូលនិធិបន្សាំ (AF) មូលនិធិវិនិយោគលើអាកាសធាតុ (CIFs) មូលនិធិអាកាសធាតុបៃតង (GCF) និងមូលនិធិបរិស្ថានពិភពលោក (GEF)។
> យុទ្ធសាស្ត្រធំៗចំនួនបីសម្រាប់CSOsជាពិសេសអង្គការដែលផ្តោតលើស្ត្រីក្នុងការចូលរួមជាមួយមូលនិធិទាំងនេះរួមមាន ៖

ក) ការដាក់ពាក្យស្នើសុំមូលនិធិដោយផ្ទាល់ក្រោមវិស័យប្រធានបទជំនួយនវានុវត្តន៍មូលនិធិបន្សាំនៃ "ភាពជឿនលឿននៃសមភាពយេនឌ័រ (ការផ្តល់ភាពអង់អាចដល់ស្ត្រី និងក្មេងស្រី)" ឬកម្មវិធីជំនួយខ្នាតតូចរបស់ GEF អនុវត្តដោយអង្គការ UNDP ដែលផ្តល់ការគាំទ្រផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេសរហូតដល់ ៥០.០០០ ដុល្លារ ដោយផ្ទាល់ទៅអង្គការក្នុងស្រុក។

ខ) ការផ្តល់ជំនួយបច្ចេកទេសដល់អង្គភាពអនុវត្តថ្នាក់ជាតិ(NIEs) ដែលមានស្រាប់នៃមូលនិធិបន្សាំ ជនបង្គោល នៃមូលនិធិវិនិយោគលើអាកាសធាតុ (CIFs) និងអាជ្ញាធរជាតិទទួលបន្ទុក (NDA) សម្រាប់មូលនិធិអាកាសធាតុបៃតង (GCF)។ អង្គការដែលផ្តោតលើស្ត្រី គួរព្យាយាមទំនាក់ទំនងជាមួយទីភ្នាក់ងារទាំងនេះនៅក្នុងប្រទេសរបស់ពួកគេដោយផ្ទាល់ និងធ្វើជាដៃគូជាមួយពួកគេ ក្នុងនាមជាអ្នកពិគ្រោះយោបល់ និងជាអ្នកបណ្តុះបណ្តាលយេនឌ័រ។ អង្គការដែលផ្តោតលើស្ត្រីក៏អាចចុះឈ្មោះនៅក្នុងបញ្ជីឈ្មោះអ្នកជំនាញយេនឌ័រនិង/ឬក្លាយជាអ្នកសង្កេតការណ៍ផ្លូវការនៅក្នុងដំណើរការនេះ។

គ) ការជាប់ទាក់ទិនក្នុងការចូលរួមរបស់ភាគីពាក់ព័ន្ធ ក៏ដូចជាការពាំនាំនូវសំឡេងរបស់អ្នកដឹកនាំជាស្ត្រីមកពីសហគមន៍។

> ការឃ្លាំមើលហិរញ្ញវត្ថុក្នុងស្រុកសម្រាប់ការបញ្ជ្រាបយេនឌ័រតាមរយៈការប្រើប្រាស់ការរៀបចំថវិកា ដែលឆ្លើយតបនឹងយេនឌ័រ (GRB) អាចជាយុទ្ធសាស្ត្រដ៏មានប្រសិទ្ធភាពមួយនៅថ្នាក់មូលដ្ឋាន។ GRB វិភាគថវិការបស់រដ្ឋាភិបាល និងហិរញ្ញប្បទានជំនួយ ដើម្បីរៀបចំផែនការផ្សព្វផ្សាយពីភាពផ្សេងៗគ្នានិងផលប៉ះពាល់លើស្ត្រីនិងក្មេងស្រីបើប្រៀបធៀបទៅនឹងបុរស និងក្មេងប្រុស ហើយអាចជាឧបករណ៍ស្រាវជ្រាវនិងតស៊ូមតិដ៏សំខាន់មួយសម្រាប់ CSOs។

> CSOs គួរឃ្លាំមើលជាពិសេសលើការឆ្លើយតបនឹងតម្រូវការយេនឌ័រនៅក្នុងហិរញ្ញវត្ថុអាកាសធាតុតាមរយៈការអភិវឌ្ឍយេនឌ័រ និងរបាយការណ៍ថវិកាអាកាសធាតុ (GCBS)។ ដូចគ្នានេះផងដែរ ផ្ទុយពីគំនិតផ្តួចផ្តើមនៃការរៀបចំថវិកាដែលឆ្លើយតបនឹងយេនឌ័រដទៃទៀត GRB នៅក្នុងហិរញ្ញវត្ថុអាកាសធាតុ មិនគួរត្រូវបានកំណត់ត្រឹមតែថវិការបស់រដ្ឋាភិបាលតែមួយមុខនោះទេ ប៉ុន្តែត្រូវមើលលើមូលនិធិរបស់ម្ចាស់ជំនួយផងដែរ។

| 3:00:00 | **វគ្គ ក ៖ ការស្វែងយល់អំពីស្ថាបត្យកម្មហិរញ្ញវត្ថុអាកាសធាតុសកល និងសមាសធាតុយេនឌ័ររបស់ស្ថាបត្យកម្មនេះ** |
| --- | --- |
| ទិដ្ឋភាពទូទៅ | នៅចុងបញ្ចប់នៃវគ្គនេះ អ្នកចូលរួមគួរយល់ដឹងអំពីស្ថាបត្យកម្មហិរញ្ញវត្ថុអន្តរជាតិសម្រាប់ការកាត់បន្ថយ និងការបន្សាំការប្រែប្រួលអាកាសធាតុ។ មូលនិធិដែលទាក់ទងនឹងការបន្សាំ សមាសភាពយេនឌ័ររបស់ពួកគេ និងចន្លោះទំនេរសម្រាប់ការចូលរួមរបស់អង្គការដែលផ្តោតលើស្ត្រី ក៏ត្រូវបានពិភាក្សាផងដែរ។ |
| មាតិកា | ក) ស្ថាបត្យកម្មហិរញ្ញវត្ថុអាកាសធាតុសកល<br>ខ) លក្ខខណ្ឌតម្រូវហិរញ្ញវត្ថុអាកាសធាតុ<br>គ) លំហូរមូលនិធិហិរញ្ញវត្ថុការប្រែប្រួលអាកាសធាតុសកល<br>ក. ហិរញ្ញវត្ថុអាកាសធាតុនៅអាស៊ី<br>ខ. មូលនិធិបន្សាំ<br>ឃ) យេនឌ័រនៅក្នុងហិរញ្ញវត្ថុអាកាសធាតុសកល<br>ង) មូលនិធិបន្សាំសំខាន់ៗ និងវិសាលភាពសម្រាប់ការចូលរួមរបស់ CSOs<br>ក. មូលនិធិបន្សាំ<br>ខ. មូលនិធិវិនិយោគលើអាកាសធាតុ<br>គ. មូលនិធិអាកាសធាតុបៃតង |
| សម្ភារៈ | បទបង្ហាញជា PowerPoint<br>ឧបករណ៍សម្រាប់មើលខ្សែភាពយន្តនៅលើបណ្តាញយូធូប<br>ក្តារខៀន និងប៊ិចហ្វឺតធំ<br>ផ្ទាំងក្រដាសធំ និងប៊ិច<br>សំណៅឯកសារមួយច្បាប់ |

## តារាងពេលវេលា

| រយៈពេល | សកម្មភាព |
|---|---|
| ៥នាទី | > ការចែករំលែកអំពីទិដ្ឋភាពទូទៅ មាតិកានៃវគ្គ និងដំណើរការ។ |
| ៤០នាទី | > លំហាត់ស្តីពី "ស្ថាបត្យកម្មហិរញ្ញវត្ថុអាកាសធាតុសកល" (សូមមើលលំហាត់ទី ២៣ និងសំណៅឯកសារទី ២១) (គួរអនុវត្តសម្រាប់វគ្គមូលដ្ឋានគ្រឹះ) |
| | ឬ |
| | > បទបង្ហាញជា PowerPoint ស្តីពី ""ស្ថាបត្យកម្មហិរញ្ញវត្ថុអាកាសធាតុសកល" (គួរអនុវត្តសម្រាប់វគ្គកម្រិតខ្ពស់) |
| ៦០នាទី | > បទបង្ហាញជា PowerPoint ស្តីពី "មូលនិធិបន្សាំសំខាន់ៗ និងវិសាលភាពសម្រាប់ការចូលរួមរបស់ CSOs" |
| ៧៥នាទី | > វគ្គអនុវត្តស្តីពី "ការវិភាគគម្រោងបន្សាំ" (សូមមើលលំហាត់ទី២៤ និងសំណៅឯកសារទី ២២) (ផ្តល់អនុសាសន៍សម្រាប់វគ្គកម្រិតខ្ពស់) |

## កំណត់សម្គាល់ណែនាំ

ចែករំលែកទិដ្ឋភាពទូទៅនៃវគ្គសិក្សានិងមាតិកា។សម្រាប់វគ្គមូលដ្ឋានគ្រឹះសូមចាប់ផ្តើមជាមួយនឹងការមើលខ្សែភាពយន្តខ្លីដោយ Heinrich-Böll-Stiftung Washington, DC ស្តីពី "តើអ្វីទៅជាហិរញ្ញវត្ថុអាកាសធាតុ" ដែលអាចរកបានតាមរយៈគេហទំព័រ https://www.youtube.com/watch?v=_Y9vM4e9XaM អមដោយលំហាត់ស្តីពីស្ថាបត្យកម្មហិរញ្ញវត្ថុអាកាសធាតុសកល។ សូមមើលលំហាត់ទី២៣ និងសំណៅឯកសារទី២១ និងខ្សែភាពយន្តស្តីពី "ហិរញ្ញវត្ថុអាកាសធាតុដែលឆ្លើយតបនឹងតម្រូវការយេនឌ័រ" ដែលអាចរកបានតាមរយៈគេហទំព័រ https://www.youtube.com/watch?v=YKmvdiXIDFI។ សម្រាប់វគ្គកម្រិតខ្ពស់ សូមប្រើមាតិកាបច្ចេកទេសដើម្បីធ្វើបទបង្ហាញជា PowerPoint លម្អិតស្តីពី "ស្ថាបត្យកម្មហិរញ្ញវត្ថុអាកាសធាតុសកល"។ ផ្នែកនេះក៏រួមបញ្ចូលផងដែរនូវទិន្នន័យស្តីពីតួលេខមូលនិធិរហូតដល់ឆ្នាំ២០១៩។ គ្រូឧទ្ទេសគួរបន្ថែមតួលេខមូលនិធិដែលបានធ្វើបច្ចុប្បន្នភាពពីឯកសារយោងដើម្បីឲ្យវគ្គសិក្សានេះមានភាពពាក់ព័ន្ធជាងនេះ។ដូចគ្នានេះផងដែរ ប្រសិនបើអ្នកចូលរួមមកពីប្រទេសតែមួយ សូមបញ្ចូលស្លាយស្តីពីស្ថានភាពគម្រោង និងការបែងចែកក្រោមមូលនិធិអាកាសធាតុដ៏សំខាន់សម្រាប់ប្រទេសនោះ។

បន្ទាប់មកទៀត ត្រូវផ្តោតលើ "មូលនិធិបន្សាំសំខាន់ៗ និងវិសាលភាពសម្រាប់ការចូលរួមរបស់ CSOs"។ ជាថ្មីម្តងទៀត ទោះបីជាខ្លឹមសារបច្ចេកទេសនៅទីនេះ ផ្តល់នូវទិដ្ឋភាពទូទៅ និងយុទ្ធសាស្ត្រ សំខាន់ៗសម្រាប់ការចូលរួមរបស់ CSOs ក៏ដោយ ក៏គ្រូឧទ្ទេសគួរធ្វើឱ្យវគ្គសិក្សានេះកាន់តែមានការចូលរួមបន្ថែមទៀតតាមរយៈ៖

ក) ការអញ្ជើញជនបង្គោលរបស់ប្រទេស ឱ្យចែករំលែកអំពីស្ថានភាព ដំណើរការ ឱកាស និងបញ្ហាប្រឈមនៃការប្រើប្រាស់មូលនិធិនៅក្នុងប្រទេសនេះ។ និង

ខ) ស្នើឱ្យអ្នកចូលរួមចែករំលែកបទពិសោធន៍ផ្ទាល់ខ្លួនរបស់ពួកគេ ក្នុងការចូលរួមជាមួយនឹងមូលនិធិទាំងនេះ។ (គ្រូឧទ្ទេសគួរផ្តល់ពេលវេលាបន្ថែមទៀតសម្រាប់ចំណុចពិភាក្សាដែលបានស្នើឡើងនៅចុងបញ្ចប់នៃផ្នែកនេះ)។

បិទបញ្ចប់វគ្គនេះជាមួយនឹង "លំហាត់វិភាគគម្រោងបន្សាំ" (សូមមើលលំហាត់ទី ២៤ និងសំណៅឯកសារទី២២)។លំហាត់នេះគួរតែអនុវត្តសម្រាប់តែវគ្គកម្រិតខ្ពស់ប៉ុណ្ណោះហើយមានគោលបំណងផ្តល់ឱ្យអ្នកចូលរួមយល់ដឹងពីដំណើរការផ្សេងៗគ្នានៃមូលនិធិបន្សាំ និងជំរុញឱ្យពួកគាត់មានចំណាប់អារម្មណ៍គ្រប់គ្រាន់ ក្នុងការស្វែងរកព័ត៌មានលម្អិតបន្ថែមទៀត តាមរយៈគេហទំព័រមូលនិធិ។ ត្រូវប្រាកដថាមាន wifi (ឬអ៊ីនធឺណិត) ដែលអាចប្រើបានសម្រាប់លំហាត់នេះ។

# ទិដ្ឋភាពហិរញ្ញវត្ថុអាកាសធាតុសកល

## ស្ថាបត្យកម្មហិរញ្ញវត្ថុអាកាសធាតុសកល

ហិរញ្ញវត្ថុអាកាសធាតុនៅតែជាចំណុចស្នូលនៃការសម្រេចបាននូវការអភិវឌ្ឍកាបូនទាប និងភាពធន់នឹងអាកាសធាតុ។ ទោះយ៉ាងណា និយមន័យនៃពាក្យ "ហិរញ្ញវត្ថុអាកាសធាតុ" មិនទាន់មានការព្រមព្រៀងគ្នាជាអន្តរជាតិនៅឡើយទេ។ UNFCCC (ឆ្នាំ ២០២០) កំណត់និយមន័យហិរញ្ញប្បទានអាកាសធាតុ ថាជា "ហិរញ្ញប្បទានមូលដ្ឋានថ្នាក់ជាតិឬអន្តរជាតិដែលបានមកពីប្រភពសាធារណៈ ឯកជននិងប្រភពនៃហិរញ្ញប្បទានផ្សេងៗទៀតដែលស្វែងរកការគាំទ្រដល់សកម្មភាពកាត់បន្ថយ និងបន្សាំ ដែលនឹងដោះស្រាយការប្រែប្រួលអាកាសធាតុ"។

យោងតាមមាត្រា ៤.៣ នៃ UNFCCC បណ្តាប្រទេសអភិវឌ្ឍន៍ បានប្តេជ្ញាផ្តល់មូលនិធិសម្រាប់"ថ្លៃចំណាយបន្ថែមពេញលេញដែលបានព្រមព្រៀង" នៃការប្រែប្រួលអាកាសធាតុនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍។ វិស័យមួយក្នុងចំណោមវិស័យ ផ្តោតសំខាន់ៗរបស់ UNFCCC បានឆ្ពោះទៅរកការបង្កើតយន្តការនិងឧបករណ៍សម្រាប់ហិរញ្ញវត្ថុអាកាសធាតុនៅទូទាំងពិភពលោកនិងជានាការផ្ទេរមូលនិធិទាំងនេះពីប្រទេសអភិវឌ្ឍន៍ទៅប្រទេសកំពុងអភិវឌ្ឍន៍។

> នៅក្នុងសន្និសីទបណ្តាភាគី (COP) ទី១៥ (ឆ្នាំ២០០៩) តាម រយៈកិច្ចព្រមព្រៀងកូប៉ិនហាក ប្រទេសអភិវឌ្ឍន៍បានសន្យាផ្តល់ទឹកប្រាក់ ៣០ ពាន់លានដុល្លារជាហិរញ្ញប្បទាន "ចាប់ ផ្តើមរហ័ស" ចាប់ពីឆ្នាំ២០១០-២០១២ ដោយសន្យាបង្កើនហិរញ្ញប្បទានដល់ ១០០ ពាន់លានដុល្លារជារៀងរាល់ឆ្នាំនៅត្រឹមឆ្នាំ២០២០។

> នៅក្នុង COP ទី១៦ គណៈកម្មាធិការអចិន្ត្រៃយ៍ទទួលបន្ទុកហិរញ្ញវត្ថុត្រូវបានបង្កើតឡើងក្រោម UNFCCC ដើម្បីជួយ COP ឱ្យសម្រេចបានគោលបំណងនៃយន្តការហិរញ្ញវត្ថុនៃអនុសញ្ញានេះ។គណៈកម្មាធិការអចិន្ត្រៃយ៍ទទួលបន្ទុកហិរញ្ញវត្ថុមានភារកិច្ច ក្នុងចំណោមការងារផ្សេងៗទៀត ក្នុងការរៀបចំការវាយតម្លៃរៀងរាល់ពីរឆ្នាំម្តងនៃលំហូរហិរញ្ញវត្ថុអាកាសធាតុ ដែលការវាយតម្លៃលើកទី៤ នឹងត្រូវបោះពុម្ពផ្សាយនៅឆ្នាំ២០២០ហើយនឹងផ្តល់ព័ត៌មានលម្អិតអំពីលំហូរពីឆ្នាំ២០១៧-២០១៨។

> នៅក្នុង COP ទី២១ នៅទីក្រុងប៉ារីស (ឆ្នាំ២០១៥) ប្រទេសអភិវឌ្ឍន៍ មិនបានផ្តល់ការសន្យាហិរញ្ញវត្ថុសាធារណៈសំខាន់ថ្មីៗឡើយ។ ទោះយ៉ាងណា ក្រោមកិច្ចព្រមព្រៀងទីក្រុងប៉ារីស គេបានឯកភាពថា នៅឆ្នាំ២០២៥ គោលដៅរួមថ្មីមួយសម្រាប់ហិរញ្ញវត្ថុអាកាសធាតុនៃហិរញ្ញប្បទានគោលចាប់ពីបច្ចុប្បន្នចំនួន ១០០ ពាន់លានដុល្លារអាមេរិកក្នុងមួយឆ្នាំ នឹងត្រូវបានកំណត់។

> សេចក្តីសម្រេចចិត្តដំបូងមួយចំនួនត្រូវបានធ្វើឡើងនៅCOP ទី២៤នៅក្នុងទីក្រុងកាតូវីដែលជាផ្នែកមួយនៃកិច្ចប្រឹងប្រែងក្នុងការព្រមព្រៀងគ្នាលើសៀវភៅវិធានទីក្រុងប៉ារីស (Paris Rulebook)។ ទោះយ៉ាងណាក៏ដោយ ពុំមានកិច្ចព្រមព្រៀងណាមួយត្រូវបានធ្វើឡើង សូម្បីតែនៅ COP ទី២៥ នៅទីក្រុងម៉ាឌ្រីដ (ឆ្នាំ២០១៩) ហើយកិច្ចព្រមព្រៀងដដែលត្រូវបានជំរុញឱ្យពិចារណានៅក្នុង COP ទី២៦ នៅទីក្រុងគ្លាសហ្គូ (ស្កុតឡេន) ដែលគ្រោងធ្វើនៅខែវិច្ឆិកា ឆ្នាំ២០២១។

បន្ទាប់ពីសេចក្តីសម្រេចចិត្តទាំងនេះបណ្តាញមួយចំនួនមានសកម្មភាពរស់រវើកហើយក៏មានលំហូរហិរញ្ញវត្ថុអាកាសធាតុសកលតាមរយៈបណ្តាញទាំងនោះផងដែរ។ ហិរញ្ញវត្ថុទាំងនេះរួមមាន៖

ក) មូលនិធិអាកាសធាតុពហុភាគី ដែលផ្តោតលើការដោះស្រាយបញ្ហាការប្រែប្រួលអាកាសធាតុ។
ខ) ជំនួយអភិវឌ្ឍន៍ទ្វេភាគីបង្កើតឡើងដោយប្រទេសអភិវឌ្ឍន៍មួយចំនួន។
គ) ថវិកាជាតិរបស់រដ្ឋាភិបាល។
ឃ) មូលនិធិអាកាសធាតុដែលត្រូវបានបញ្ជូនជាលក្ខណៈឯកជន។ និង
ង) មូលនិធិថ្នាក់តំបន់ និងថ្នាក់ជាតិ ដែលត្រូវបានបង្កើតឡើងដើម្បីទទួលយកមូលនិធិសកល និងបញ្ជូនមូលនិធិទាំងនេះទៅជុំវិញតំបន់។

រូបភាពទី៣១ បង្ហាញពីទិដ្ឋភាពទូទៅ នៃស្ថាបត្យកម្មហិរញ្ញវត្ថុអាកាសធាតុ ដោយផ្តោតលើយន្តការហិរញ្ញប្បទានសាធារណៈ។ ស្ថាបត្យកម្មហិរញ្ញវត្ថុបន្សាំ រួមមានលំហូរហិរញ្ញវត្ថុ និងយន្តការពីហិរញ្ញវត្ថុឯកជន ហិរញ្ញវត្ថុសាធារណៈ ក៏ដូចជាធនធានពីស្ថាប័នហិរញ្ញវត្ថុអភិវឌ្ឍន៍និងកំណើននៃលំហូរពីយន្តការជានាប៉ាប់រងនិងការប្រមូលផ្តុំហានិភ័យ។ ពណ៌បៃតងនៅក្នុងរូបទី៥៤ បង្ហាញពីមូលនិធិដែលផ្តោតឬមានចំណាប់អារម្មណ៍ខ្ពស់ទៅលើការបន្សាំ។

និយមន័យហិរញ្ញវត្ថុអាកាសធាតុ ត្រូវបានអនុម័តដោយទីភ្នាក់ងារមួយចំនួនដែលកំពុងប្រមូលព័ត៌មានអំពីហិរញ្ញវត្ថុអាកាសធាតុ៖

ការធ្វើបច្ចុប្បន្នភាពហិរញ្ញវត្ថុអាកាសធាតុ (CFU) របស់វិទ្យាស្ថានអភិវឌ្ឍន៍ក្រៅប្រទេស (ODI) និង Heinrich-Böll-Stiftung (HBS) (Watson និង Schaltek CFU b ឆ្នាំ២០២០) កំណត់និយមន័យហិរញ្ញវត្ថុអាកាសធាតុថាជា"ធនធានហិរញ្ញវត្ថុដែលត្រូវបានកៀរគរ ដើម្បីផ្តល់មូលនិធិសម្រាប់សកម្មភាពកាត់បន្ថយ និង បន្សាំទៅនឹងផលប៉ះពាល់ដោយសារការប្រែប្រួលអាកាសធាតុរួមទាំងការប្តេជ្ញាចិត្តផ្នែកហិរញ្ញវត្ថុសាធារណៈដោយប្រទេសអភិវឌ្ឍន៍ក្រោម UNFCCC "។

## រូបទី៥៤ ៖ ស្ថាបត្យកម្មហិរញ្ញវត្ថុអាកាសធាតុអន្តរជាតិសកល




| | |
|---|---|
| AF | មូលនិធិបន្សាំ |
| GCF | មូលនិធិអាកាសធាតុបៃតង |
| GEF | មូលនិធិ បរិស្ថាន ពិភពលោក |
| LDCF | មូលនិធិប្រទេសអភិវឌ្ឍន៍តិចតួច |
| SCCF | មូលនិធិប្រែប្រួលអាកាសធាតុពិសេស |

| | |
|---|---|
| CIF | មូលនិធិវិនិយោគលើអាកាសធាតុ |
| CTF | មូលនិធិ បច្ចេកវិទ្យាស្អាត |
| SCF | មូលនិធិអាកាសធាតុយុទ្ធសាស្ត្រ |
| PPCR | កម្មវិធីសាកល្បងស្តីពីភាពធន់នឹងអាកាសធាតុ |
| SREP | កម្មវិធីពង្រីកថាមពលកកើតឡើងវិញ |
| MDB | ធនាគារអភិវឌ្ឍន៍ពហុភាគី |
| FCPF | មូលនិធិ កាបូនព្រៃឈើ |
| REDD | ការកាត់បន្ថយការបញ្ចេញឧស្ម័នពីការបាត់បង់ និងរេចរឹលព្រៃឈើ |
| ASAP | ការបន្សាំសម្រាប់កម្មវិធីកសិកម្មខ្នាតតូច |

| | |
|---|---|
| NAMA | សកម្មភាពជាតិកាត់បន្ថយសមស្រប |
| GCPF | មូលនិធិភាពជាដៃគូអាកាសធាតុសកល |
| GCCA | សម្ព័ន្ធការប្រែប្រួលអាកាសធាតុសកល |
| GCCI | គំនិតផ្តួចផ្តើម សម្រាប់ការប្រែប្រួលអាកាសធាតុសកល (សហរដ្ឋអាមេរិក) |
| DFAT | នាយកដ្ឋានកិច្ចការបរទេស និងពាណិជ្ជកម្ម (អូស្ត្រាលី) |
| CIDA | ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិកាណាដា |
| DFID | នាយកដ្ឋានអភិវឌ្ឍន៍អន្តរជាតិ |
| GIZ | កិច្ចសហប្រតិបត្តិការបច្ចេកទេសអាល្លឺម៉ង់ |
| KfW | ធនាគារអភិវឌ្ឍន៍ អាល្លឺម៉ង់ |
| USAID | ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ |
| SIDA | ទីភ្នាក់ងារអភិវឌ្ឍន៍និងកិច្ចសហប្រតិបត្តិការអន្តរជាតិស៊ុយ អែត |

ប្រភព៖ ដកស្រង់ចេញពីការធ្វើបច្ចុប្បន្នភាពហិរញ្ញវត្ថុអាកាសធាតុ (CFU) (Watson និង Schalatek, CFU b ឆ្នាំ២០២០) b

អង្គការស្ត្រីដើម្បីបរិស្ថាន និងអភិវឌ្ឍន៍ (WEDO ឆ្នាំ២០១៩) សំដៅទៅលើវាថាជា " វាក្យស័ព្ទដ៏ទូលំទូលាយ ដែលអាចរួមបញ្ចូលលំហូរមូលនិធិសាធារណៈ ឯកជន និងសប្បុរសធម៌ឆ្ពោះទៅរកសកម្មភាពនៃការប្រែប្រួលអាកាសធាតុ ក៏ដូចជាប្រព័ន្ធដែលរៀបចំរចនាសម្ព័ន្ធនៃវិធីដែលមូលនិធិទាំងនេះត្រូវបានចែកចាយ"។

ទិដ្ឋភាពសកលនៃហិរញ្ញវត្ថុអាកាសធាតុ (CPI ឆ្នាំ២០១៩) បានកំណត់និយមន័យការងារហិរញ្ញវត្ថុអាកាសធាតុថា "ហិរញ្ញវត្ថុអាកាសធាតុមានគោលបំណងកាត់បន្ថយការបំភាយឧស្ម័ន និងបង្កើនអាងស្រូបឧស្ម័នផ្ទះកញ្ចក់និងមានគោលបំណងកាត់បន្ថយភាពងាយរងគ្រោះ និងរក្សានិងបង្កើនភាពធន់នៃប្រព័ន្ធអេកូឡូស៊ីរបស់មនុស្សនិងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុអវិជ្ជមាន"។

មានន័យថាជាថ្លៃចំណាយបន្ថែមនៃការផ្លាស់ប្តូរយុទ្ធសាស្ត្រកំណើនសេដ្ឋកិច្ចដែលអាជីវកម្មជាទូទៅពឹងផ្អែកលើឥន្ធនៈផូស៊ីល ទៅជាផ្លូវអភិវឌ្ឍន៍ដែលធន់នឹងអាកាសធាតុនៃការបញ្ចេញឧស្ម័នទាប។

## លក្ខខណ្ឌតម្រូវនៃហិរញ្ញវត្ថុអាកាសធាតុ

តម្រូវការហិរញ្ញវត្ថុអាកាសធាតុរួមត្រូវបានប៉ាន់ប្រមាណថានឹងឈានដល់រាប់រយពាន់លានដុល្លារអាមេរិកជារៀងរាល់ឆ្នាំបន្ទាប់ពីឆ្នាំ២០២៣ (Schalatek ឆ្នាំ២០១៩)។ របាយការណ៍ពិសេសរបស់ IPCC ស្តីពីកំណើនកម្តៅសកលក្នុងកម្រិត ១,៥ អង្សាសេ បានប៉ាន់ស្មានថា តម្រូវការវិនិយោគជាមធ្យមប្រចាំឆ្នាំក្នុងប្រព័ន្ធថាមពលតែមួយមានប្រហែល ២,៤ ពាន់ពាន់លានដុល្លារចាប់ពីឆ្នាំ២០១៦ ដល់ឆ្នាំ២០៣៥ (IPCC SR15 ឆ្នាំ២០១៨)។ គណៈកម្មការសកលទទួលបន្ទុកការបន្សាំ (GCA ឆ្នាំ២០១៩) ប៉ាន់ប្រមាណថា ការវិនិយោគ ១៨០ ពាន់លានដុល្លារជារៀងរាល់ឆ្នាំចាប់ពីឆ្នាំ២០២០ដល់ឆ្នាំ២០៣០នៅក្នុងភាពធន់អាចបង្កើតផលចំណេញផ្នែកសេដ្ឋកិច្ចពាន់ពាន់លានដុល្លារ។ UNEP (ឆ្នាំ ២០១៦) ក៏បានប៉ាន់ស្មានផងដែរថា ថ្លៃចំណាយប្រចាំឆ្នាំនៃការបន្សាំ អាចមានចាប់ពី ១៤០ ទៅ ៣០០ ពាន់លានដុល្លារនៅត្រឹមឆ្នាំ២០៣០។

កន្លងមក UNDP (HDR ឆ្នាំ២០១១) បានព្យាករថាថ្លៃចំណាយលើការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុនៅឆ្នាំ២០៣០ អាចមានចាប់ពី ២៤៩ ពាន់លានដុល្លារទៅ ១,៣៧១ ពាន់លានដុល្លារជារៀងរាល់ឆ្នាំ។ ការសិក្សាមួយទៀតរបស់ធនាគារពិភពលោក (ឆ្នាំ២០១០) បានប៉ាន់ប្រមាណថាថ្លៃចំណាយលើការបន្សាំតែមួយមុខ អាចមានចាប់ពី ៧៥ ពាន់លានដុល្លាររហូតដល់ ១០០ ពាន់លានដុល្លារអាមេរិកក្នុងមួយឆ្នាំ ចាប់ពីឆ្នាំ២០១០រហូតដល់ឆ្នាំ២០៥០។ បច្ចុប្បន្ន ក្នុងរយៈពេលដប់ឆ្នាំបន្ទាប់ពីការវាយតម្លៃទាំងនោះត្រូវបានធ្វើឡើង តម្រូវការហិរញ្ញវត្ថុអាកាសធាតុ គឺខ្ពស់ច្រើនជាងការព្យាករទុកដោយការសិក្សាទាំងនេះ។

## លំហូរមូលនិធិហិរញ្ញវត្ថុអាកាសធាតុសកល

ផ្ទុយនឹងលក្ខខណ្ឌតម្រូវទាំងនេះសម្រាប់ហិរញ្ញវត្ថុអាកាសធាតុ វឌ្ឍនភាពមូលនិធិមានភាពយឺតយ៉ាវជាងតម្រូវការ ដោយសារឧបសគ្គនិងការរំខានឥតឈប់ឈរជាពិសេសរហូតដល់ឆ្នាំ២០១៥។ តាមរយៈការពង្រឹងចំណុចដដែលកិច្ចព្រមព្រៀងទីក្រុងប៉ារីសបានទទួលស្គាល់ថា ប្រទេសអភិវឌ្ឍន៍ត្រូវ បន្តនាំមុខក្នុងការកៀរគរហិរញ្ញវត្ថុអាកាសធាតុ (Schalatek ឆ្នាំ២០១៩)។ ក្រោយកិច្ចព្រមព្រៀងទីក្រុងប៉ារីស ហិរញ្ញវត្ថុអាកាសធាតុបានមើលឃើញពីកំណើនខ្លះជាមួយនឹងការវិនិយោគប្រចាំឆ្នាំលើសពី ៥០០ ពាន់លានដុល្លារជាលើកដំបូងនៅឆ្នាំ២០១៧ និង២០១៨ (រូបទី៣២)។ លំហូរប្រចាំឆ្នាំបានកើនឡើងដល់ ៥៧៩ ពាន់លានដុល្លារ ជាមធ្យម ក្នុងរយៈពេល២ឆ្នាំ គឺនៅឆ្នាំ២០១៧/២០១៨ ដែលបានកើនឡើងចំនួន១១៦ ពាន់លានដុល្លារអាមេរិក (២៥%) ពីឆ្នាំ២០១៥/២០១៦ (CPI ឆ្នាំ២០១៩)។

**គន្លឹះសម្រាប់គ្រូឧទ្ទេស**

ផ្នែកបន្ទាប់ផ្តោតលើលំហូរនៃហិរញ្ញវត្ថុអាកាសធាតុសកលដែលប្រមូលពីរបាយការណ៍ផ្សេងៗ។ តួលេខនេះ ត្រូវបានធ្វើបច្ចុប្បន្នភាពដោយសារអាចរកទិន្នន័យបានរហូតដល់ឆ្នាំ២០១៩។ គ្រូឧទ្ទេសគួរធ្វើបច្ចុប្បន្នភាពលើតួលេខនេះដោយធ្វើបទបង្ហាញពីជម្រើសចុងក្រោយបំផុតនៃតួលេខដែលអាចរកបាន។សូមបង្ហាញតួលេខជាក់លាក់របស់ប្រទេសផងដែរ ប្រសិនបើ អ្នកចូលរួមមកពីប្រទេសតែមួយ។

**រូបទី៥៥៖ លំហូរហិរញ្ញវត្ថុអាកាសធាតុសកលសរុប ឆ្នាំ២០១៣-១៨**




ប្រភព៖ (CPI ឆ្នាំ២០១៩)

[3] ដោយសន្មតថាសីតុណ្ហភាពនៅលើផ្ទៃផែនដីជាមធ្យមនឹងមានកំណើនសីតុណ្ហភាពប្រហែល ២ អង្សាសេនៅត្រឹមឆ្នាំ២០៥០។

[4] ប៉ុន្តែចាំបាច់ត្រូវកត់សម្គាល់នៅត្រង់ចំណុចនេះថាវាគ្រាន់តែជាកំណើនតិចជាងមួយភាគបួននៃហិរញ្ញវត្ថុអាកាសធាតុដែលត្រូវបានឃ្លាំមើលនៅឆ្នាំ២០១៧/២០១៨ដោយសារតែការបញ្ចូលប្រភពទិន្នន័យថ្មីៗទៅក្នុងរូបរួមទាំងការវិនិយោគហេដ្ឋារចនាសម្ព័ន្ធថ្លៃបរិស្ថាន ការវិនិយោគឯកជនលើហេដ្ឋារចនាសម្ព័ន្ធប្រកបដោយចីរភាព និងការប្រើប្រាស់ចំណូលនៃមូលបត្របំណុលដែលចេញដោយវិស័យឯកជន និងរដ្ឋាភិបាលថ្នាក់តំបន់ និងថ្នាក់ក្រុង។

លើសពីនេះទៅទៀត ការប្ដេជ្ញាចិត្តតិចជាងពាក់កណ្ដាលបានមកពីហិរញ្ញវត្ថុអាកាសធាតុសាធារណៈដែលរួមមាន ថវិកា (ជាតិ) របស់រដ្ឋាភិបាល ស្ថាប័នហិរញ្ញវត្ថុក្នុងស្រុក ហិរញ្ញវត្ថុទ្វេភាគី មូលនិធិផ្ដោតលើអាកាសធាតុរបស់ស្ថាប័នហិរញ្ញវត្ថុអភិវឌ្ឍន៍ពហុភាគី ដូចជា មូលនិធិអាកាសធាតុបៃតង (GCF) មូលនិធិបន្សាំ (AF) មូលនិធិបរិស្ថានពិភពលោក (GEF) ។ល។ (សូមមើលរូបទី៥៦ សម្រាប់ការបំបែកនៃលំហូរឆ្នាំ២០១៧-១៨)។

## រូបទី ៥៦៖ ការបំបែកនៃមូលនិធិហិរញ្ញវត្ថុអាកាសធាតុសកលឆ្នាំ២០១៧-១៨




ប្រភព៖ (CPI ឆ្នាំ២០១៩)។
*ពណ៌បៃតងតំណាងឱ្យហិរញ្ញវត្ថុអាកាសធាតុសាធារណៈ និងពណ៌ខៀវតំណាងឱ្យហិរញ្ញវត្ថុអាកាសធាតុឯកជន

នៅក្នុងលំហូរហិរញ្ញវត្ថុអាកាសធាតុសាធារណៈ ហិរញ្ញវត្ថុច្រើនជាងបីភាគបួនត្រូវបង្កើតឡើង និងចំណាយក្នុងស្រុក។ ចំណែកនៃស្ថាប័នហិរញ្ញវត្ថុអភិវឌ្ឍន៍ពហុភាគី ជំនួយទ្វេភាគី និងមូលនិធិផ្ដោតលើអាកាសធាតុ ដែលបង្កើតជាចំណែកដ៏សំខាន់នៃហិរញ្ញវត្ថុអាកាសធាតុដែលបានសន្យាពីប្រទេសអភិវឌ្ឍន៍ដល់ប្រទេសកំពុងអភិវឌ្ឍន៍ គឺមានតិចតួចណាស់។ ដូចបានចែងនៅក្នុងកិច្ចព្រមព្រៀងអាកាសធាតុផ្សេងៗប្រការសំខាន់គឺត្រូវបង្កើនលំហូរហិរញ្ញវត្ថុអាកាសធាតុសាធារណៈអន្តរជាតិពីប្រទេសអភិវឌ្ឍន៍ទៅប្រទេសកំពុងអភិវឌ្ឍន៍។ទោះយ៉ាងជាណាបច្ចុប្បន្នការប៉ាន់ស្មានភាគច្រើនចង្អុលបង្ហាញពីការពិតដែលថា លំហូរនេះស្ថិតក្រោមកម្រិតគោល ១០០ ពាន់លានដុល្លារដែលបានសន្យានៅក្នុងកិច្ចព្រមព្រៀងទីក្រុងប៉ារីស - នៃលំហូរអន្តរជាតិសរុប មានតែ ៧២ ពាន់លានដុល្លារអាមេរិកប៉ុណ្ណោះ ដែលហូរចេញពីអង្គការកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍន៍ (OECD) ទៅប្រទេសមិនមែន OECD ក្នុងឆ្នាំ២០១៧/២០១៨ ដែលស្មើនឹង ១២% នៃហិរញ្ញវត្ថុអាកាសធាតុដែលត្រូវបានឃ្លាំមើល (CPI ឆ្នាំ២០១៩)។

ម្យ៉ាងវិញទៀត សារៈសំខាន់នៃការស្វែងយល់ពីទស្សនៈរបស់សង្គមស៊ីវិលគឺឧបករណ៍ហិរញ្ញវត្ថុអាកាសធាតុ។ក្នុងឆ្នាំ២០១៧-១៨ជំនួយមានចំនួនត្រឹមតែ៥%នៃហិរញ្ញវត្ថុអាកាសធាតុសរុបដែលស្មើនឹង ២៩ ពាន់លានដុល្លារអាមេរិក។ ស្ទើរតែ ៦០% នៃជំនួយដែលត្រូវបានឃ្លាំមើលក្នុងឆ្នាំ២០១៧/២០១៨ ត្រូវបានធ្វើឡើងជាអន្តរជាតិ ហើយ ៤០% គឺទទួលបានពីក្នុងប្រទេស (CPI ឆ្នាំ២០១៩)។ ដែនកំណត់សំខាន់មួយទៀតគឺថា មូលនិធិភាគច្រើនមិនត្រូវបានបង្កើតឡើងដោយពិចារណាដល់ភាគីពាក់ព័ន្ធនៅក្នុងស្រុកឡើយហើយរចនាសម្ព័ន្ធជាទូទៅត្រូវបានគេយកចិត្តទុកដាក់ចំពោះគម្រោងខ្នាតធំនិងចំពោះអង្គភាពដែលអាចបញ្ជូនមូលនិធិទៅស្ថាប័នដទៃទៀត។

បើនិយាយពីការបែងចែកតាមវិស័យការផលិតថាមពលកកើតឡើងវិញនៅតែបន្តទទួលបានអាទិភាពបំផុតដោយមានទឹកប្រាក់៣៣៧ ពាន់លានដុល្លារក្នុងឆ្នាំ២០១៧-១៨ បន្ទាប់មកការដឹកជញ្ជូនកាបូនទាបមានចំនួន ១៤១ ពាន់លានដុល្លារ និងប្រសិទ្ធភាពថាមពល ៣៤ ពាន់លានដុល្លារ។ ក្នុងចំណោមវិស័យបន្សាំ កសិកម្ម និងការប្រើប្រាស់ដី ទទួលបាន ២១ពាន់លានដុល្លារ ចំណែកការគ្រប់គ្រងទឹក និងសំណល់ ក៏មានចំណែកដ៏ធំមួយស្មើនឹង១៣ពាន់លានដុល្លារផងដែរ។ការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ ទទួលបានតែ ៧ ពាន់លានដុល្លារអាមេរិកប៉ុណ្ណោះ (CPI ឆ្នាំ២០១៩)។

## រូបទី ៥៧៖ ការបែងចែកតាមវិស័យ នៃហិរញ្ញវត្ថុអាកាសធាតុក្នុងឆ្នាំ២០១៧-១៨




ប្រភព៖ (CPI ឆ្នាំ២០១៩)

## ហិរញ្ញវត្ថុអាកាសធាតុនៅអាស៊ី

ដោយសារមូលនិធិអាកាសធាតុសាធារណៈអន្តរជាតិនៅមានកម្រិតទាប ប្រការចាំបាច់ត្រូវយល់ដឹងថាតើប្រទេសណាជាប្រទេសដែលទទួលបានការចាប់អារម្មណ៍ខ្លាំងជាងគេជាពិសេសនៅទ្វីបអាស៊ី។ ការត្រួតពិនិត្យទិន្នន័យរបស់ CFU (Watson និង Schalatek ឆ្នាំ២០២០) សម្រាប់ប្រទេសចំនួន ១៨ នៅអាស៊ី បង្ហាញថា ចាប់ពីឆ្នាំ២០០៣ ដល់ ឆ្នាំ២០១៩ មានទឹកប្រាក់សរុបចំនួន ៤,៩ ពាន់លានដុល្លារសម្រាប់គម្រោង និងកម្មវិធីចំនួន ៥៣០ ត្រូវបានអនុម័តដោយមូលនិធិ និងគំនិតផ្តួចផ្តើមអាកាសធាតុពហុភាគីចំនួន ១៨។ ការបរិច្ចាគធំបំផុតគឺមកពីCTFឬមូលនិធិបច្ចេកវិទ្យាស្អាតដែលផ្តោតលើការបង្កើនការជ្រៀតចូលនៃ បច្ចេកវិទ្យាកាបូនទាប និងបាន អនុម័តមូលនិធិសរុបចំនួន១,៧ពាន់លានដុល្លារសម្រាប់គម្រោងចំនួន៣៤ដែលភាគច្រើនជាទម្រង់ប្រាក់កម្ចីសម្បទាន។ អង្គការបច្ចុប្បន្នភាពហិរញ្ញវត្ថុអាកាសធាតុបានចងក្រងលំហូរមូលនិធិនៅអាស៊ីដែលត្រូវបានបង្កើតឡើងវិញនៅក្នុងតារាងទី៩។

ទោះជាយ៉ាងណាក៏ដោយការចែកចាយគឺមិនស្មើគ្នាទេ។ចំនួនទឹកប្រាក់ដ៏ច្រើន ពោលគឺ ៦២% នៃហិរញ្ញវត្ថុ (៣ ពាន់លានដុល្លារ)គឺសម្រាប់គម្រោងកាត់បន្ថយដែលភាគច្រើនទាក់ទងនឹងថាមពលកកើតឡើងវិញខ្នាតធំ ប្រសិទ្ធភាពថាមពល និងការដឹកជញ្ជូន។គម្រោងនិងកម្មវិធីបន្សាំក្នុងតំបន់ទទួលបានប្រមាណជាមួយភាគបី នៃហិរញ្ញប្បទានកាត់បន្ថយដែលស្មើនឹង (១ ពាន់លានដុល្លារ)។

បើនិយាយពីបណ្តាប្រទេស ឥណ្ឌា ឥណ្ឌូនេស៊ី ចិន និងវៀតណាមបានទទួលមូលនិធិរួមគ្នាចំនួន៥៦%នៃមូលនិធិដែលត្រូវបានអនុម័តសម្រាប់តំបន់អាស៊ីចាប់តាំងពីឆ្នាំ២០០៣ មក (សូមមើលរូបទី៣៥)។គម្រោងធំបំផុតនៅក្នុងតំបន់ដែលត្រូវបានអនុម័តរហូតមកដល់បច្ចុប្បន្នគឺកម្មវិធីវិនិយោគការបញ្ជូនថាមពលកកើតឡើងវិញRajasthanដែលអមដោយកម្មវិធីផ្លាំងសូឡានៅលើដំបូល ដែលមានទឹកប្រាក់ចំនួន ១៧៥ លានដុល្លារ និងគាំទ្រដោយ CTF នៅប្រទេសឥណ្ឌា។ ក្នុងឆ្នាំ២០១៩ GCF ក៏បានអនុម័តគម្រោងធំបំផុតរបស់ខ្លួននៅក្នុងឆ្នាំ ២០១៩ ជាមួយទឹកប្រាក់ ១០០ លានដុល្លារនៅប្រទេសចិនសម្រាប់មូលនិធិអភិវឌ្ឍន៍ហិរញ្ញប្បទានបៃតង។

**តារាងទី២១៖ មូលនិធិគាំទ្រអាស៊ី (ឆ្នាំ២០០៣-២០១៩ ជាលានដុល្លារ)**

| FUND OR INITIATIVE | AMOUNT APPROVED (MILLION US$) | PROJECTS APPROVED |
|---|---|---|
| > Clean Technology Fund (CTF) | 1,670.0 | 34 |
| > Green Climate Fund (GCF) | 1,099.1 | 26 |
| > Global Environment Facility (4,5,6,7) | 871.8 | 178 |
| > Pilot Program for Climate Resilience (PPCR) | 284.3 | 20 |
| > Least Developed Countries Fund (LDCF) | 220.9 | 44 |
| > Scaling-Up Renewable Energy Program for Low-Income Countries (SREP) | 144.8 | 11 |
| > Forest Carbon Partnership Facility (FCPF) | 107.6 | 16 |
| > Global Climate Change Alliance (GCCA) | 87.6 | 11 |
| > Adaptation Fund (AF) | 75.3 | 26 |
| > Forest Investment Program (FIP) | 69.4 | 6 |
| > Adaptation for Smallholder Agriculture Programme (ASAP) | 62.2 | 6 |
| > Global Energy Efficiency of Renewable Energy Fund (GEEREF) | 47.8 | 6 |
| > Special Climate Change Fund (SCCF) | 47.2 | 13 |
| > Partnership for Market Readiness (PMF) | 32.3 | 13 |
| > UN-REDD Programme | 29.4 | 8 |
| > MDG Achievement Fund | 25.0 | 3 |
| > BioCarbon Fund | 15.0 | 1 |
| > Indonesia Climate Change Trust Fund (ICCTF) | 14.2 | 63 |

ប្រភព៖ CFU,(Watson និង Schalatek ឆ្នាំ២០២០)

## រូបទី ៥៨ ៖ ប្រទេសទទួលបានហិរញ្ញវត្ថុអាកាសធាតុកំពូលទាំង ១០ នៅអាស៊ី




ប្រភព ៖ CFU ( Watson និង Schalatek ឆ្នាំ២០២០ )

### ហិរញ្ញវត្ថុបន្ស៊ាំ

សមាសធាតុសំខាន់មួយទៀតនៃលំហូរហិរញ្ញវត្ថុអាកាសធាតុសកលគឺថាហិរញ្ញវត្ថុដែលបានឃ្លាំមើលភាគច្រើនបន្តហូរសម្រាប់សកម្មភាពកាត់បន្ថយ។ យោងតាមសន្ទស្សន៍ CPI ( ឆ្នាំ២០១៩ ) ហិរញ្ញវត្ថុកាត់បន្ថយមានចំនួន៩៣%នៃលំហូរសរុបក្នុងឆ្នាំ២០១៧-២០១៨ ឬ ៥៣៧ ពាន់លានដុល្លារជារៀងរាល់ឆ្នាំជាមធ្យម។ ហិរញ្ញវត្ថុបន្ស៊ាំមានត្រឹមតែ ៥% នៃលំហូរហិរញ្ញវត្ថុដែលត្រូវបានឃ្លាំមើលទោះបីជាមានចំនួន៣០ពាន់លានដុល្លារក្នុងឆ្នាំ២០១៧/១៨ដែលបានកើនឡើង ៣៥% ពីមូលនិធិចំនួន ២២ ពាន់លានដុល្លារក្នុងឆ្នាំ២០១៥-២០១៦ ក៏ដោយ។ មូលនិធិចំនួន ១២ ពាន់លានដុល្លារផ្សេងទៀតគឺសម្រាប់គម្រោងគុណប្រយោជន៍ពីរ។

មូលនិធិបន្ស៊ាំស្ទើរតែទាំងអស់គឺបានមកពីហិរញ្ញវត្ថុសាធារណៈ ដោយមានហិរញ្ញវត្ថុបន្ស៊ាំតែ ០,៥ ពាន់លានដុល្លារអាមេរិកប៉ុណ្ណោះមកពីប្រភពឯកជន ( CPI ឆ្នាំ២០១៩ )។ ប្រភពធំបំផុតនៃមូលនិធិដែលបានអនុម័តសម្រាប់គម្រោងបន្ស៊ាំគឺជាគំនិតផ្តួចផ្តើមហិរញ្ញវត្ថុដែលផ្តោតលើអាកាសធាតុ ដូចជា មូលនិធិអាកាសធាតុបៃតង ( GCF ) កម្មវិធីសាកល្បងសម្រាប់ភាពធន់នឹងអាកាសធាតុ (PPCR) នៃមូលនិធិវិនិយោគលើអាកាសធាតុ (CIFs) របស់ធនាគារពិភពលោក មូលនិធិប្រទេសអភិវឌ្ឍន៍តិចតួច ( LDCF ) គ្រប់គ្រងដោយមូលនិធិបរិស្ថានពិភពលោកនិងមូលនិធិបន្ស៊ាំ ( Watson និង Schalatek ឆ្នាំ២០២០ )។

អង្គការធ្វើបច្ចុប្បន្នភាពហិរញ្ញវត្ថុអាកាសធាតុ ( Watson និង Schalatek ឆ្នាំ២០២០ ) បង្ហាញបន្ថែមទៀតពីវិធីដែលការចូលរួមចំណែករបស់បណ្តាប្រទេសអភិវឌ្ឍន៍ដល់មូលនិធិបន្ស៊ាំនៅមានកម្រិតទាប បើប្រៀបធៀបទៅនឹងមូលនិធិដែលគាំទ្រការកាត់បន្ថយ។ ហើយនៅកម្រិតពិភពលោក ការបន្ស៊ាំនៅតែទទួលបានមូលនិធិកម្រិតទាប។បច្ចុប្បន្ននេះប្រហែល២៤% នៃហិរញ្ញប្បទានដែលត្រូវបានអនុម័តចាប់តាំងពីឆ្នាំ២០០៣ ដែលជាលំហូរមូលនិធិរបស់គំនិតផ្តួចផ្តើមហិរញ្ញវត្ថុដែលផ្តោតលើអាកាសធាតុ ដែលអង្គការឃ្លាំមើលរបស់ CFU គាំទ្រដល់ការបន្ស៊ាំ បរិមាណមូលនិធិបន្ស៊ាំនេះគឺបន្តនៅទ្រឹងអស់រយៈពេលជាច្រើនឆ្នាំកន្លងមក។ តារាងទី១០ រំលេចនូវព័ត៌មានលម្អិតនៃមូលនិធិពហុភាគីសំខាន់ៗដែលគាំទ្រការបន្ស៊ាំ។

## តារាងទី២២ ៖ មូលនិធិពហុភាគីដែលគាំទ្រដល់ហិរញ្ញវត្ថុបន្ស៊ាំ ( ឆ្នាំ២០១៣-១៩ គិតជាលានដុល្លារ )

| FUND | PLEDGED | DEPOSITED | APPROVED | PROJECTS APPROVED |
|---|---|---|---|---|
| > Green Climate Fund (GCF) | 10,319.6 | 8,144.7 | 1,288.1 | 52 |
| > Least Developed Countries Fund (LDCF) | 1,463.5 | 1,411.5 | 1,161.0 | 263 |
| > Pilot Program for Climate Resilience (PPCR) | 1,144.8 | 1,144.8 | 988.1 | 67 |
| > Adaptation Fund (AF) | 956.6 | 890.7 | 720.5 | 207 |
| > Adaptation for Smallholder Agriculture Programme (ASAP) | 381.7 | 330.3 | 291.2 | 42 |
| > Special Climate Change Fund (SCCF) | 377.4 | 369.0 | 279.4 | 68 |
| > Global Environment Facility Trust Fund 7 (GEF 7) | 654.2 | 654.1 | 48.3 | 8 |

## ហិរញ្ញវត្ថុបន្ស៊ាំនៅអាស៊ី

ទោះបីព័ត៌មានលម្អិតរួមស្តីពីហិរញ្ញវត្ថុ បន្សាំមិនទាន់អាចរកបានក៏ដោយ ក៏ CFU បានឃ្លាំមើលហិរញ្ញវត្ថុបន្សាំពីមូលនិធិពហុភាគីទាំង អស់។ ទិន្នន័យរបស់ CFU (Watson និង Schalatek ឆ្នាំ២០២០) បង្ហាញថា ស្ទើរតែ ៤២% នៃមូលនិធិទាំងនេះ ត្រូវបានផ្តល់ទៅប្រទេសនៅអនុតំបន់អាហ្វ្រិកសាហារ៉ា ១៦% ទៅអាស៊ីខាងកើត និងប៉ាស៊ីហ្វិក ១៥% ទៅអាមេរិកឡាទីន និងការ៉ាប៊ីន និង ១៤% ទៅអាស៊ីខាងត្បូង។ អង្គការធ្វើបច្ចុប្បន្នភាពហិរញ្ញក៏បានគូសបញ្ជាក់ផងដែរថាប្រទេសទទួលបានហិរញ្ញប្បទានបន្សាំច្រើនជាងគេចំនួន ២០ (ក្នុងចំណោម ១២២ ប្រទេស) ទទួលបាន ៤៥% នៃចំនួនទឹកប្រាក់សរុបដែលបានអនុម័ត។ ប្រទេសទទួលបានមូលនិធិខ្ពស់ជាងគេទាំង ១០ នោះ គឺ បង់ក្លាដែស នីហ្សេ សំប៊ី កម្ពុជា តង់សានី នេប៉ាល់ ម៉ូសំប៊ិក សាម័របូលីវីនិងតាហ្ស៊ីគីស្ថានសុទ្ធតែទទួលបានជាង១០០លានដុល្លារអាមេរិកចាប់តាំងពីឆ្នាំ២០០៣។ គួរឱ្យចាប់អារម្មណ៍បណ្តាប្រទេសទាំងអស់ លើកលែងតែប្រទេស តង់សានី គឺជាប្រទេសដែលទទួលបានមូលនិធិពីកម្មវិធីសាកល្បងសម្រាប់ភាពធន់នឹងអាកាសធាតុ (PPCR)។

នៅក្នុងទ្វីបអាស៊ី បង់ក្លាដែស នេប៉ាល់ កម្ពុជា សាម័រ និងឥណ្ឌា គឺជាប្រទេសទទួលបានហិរញ្ញប្បទានបន្សាំច្រើនជាងគេ។ រូបទី ៣៦ បង្ហាញពីចំណែករបស់បណ្តាប្រទេសអាស៊ីផ្សេងៗគ្នានៅក្នុងហិរញ្ញវត្ថុបន្សាំ។ គម្រោងបន្សាំធំៗបំផុត ត្រូវបានផ្តល់ក្នុងការគាំទ្រដល់កម្មវិធីនៅប្រទេសបង់ក្លាដែស កម្ពុជា និងនេប៉ាល់ តាមរយៈកម្មវិធីសាកល្បងសម្រាប់ភាពធន់នឹងអាកាសធាតុ (PPCR) ក្នុងចំនួនទឹកប្រាក់ដែលបានអនុម័តសរុប ២៨៤ លានដុល្លារ និងមូលនិធិប្រទេសអភិវឌ្ឍន៍តិចតួច ដែលមានទឹកប្រាក់ដែលបានអនុម័តសរុប ២២១ លានដុល្លារ (Watson និង Schalatek ឆ្នាំ២០២០)។

### រូបទី ៥៩ ៖ ហិរញ្ញវត្ថុបន្ស៊ាំនៅអាស៊ី

| COUNTRY | AMOUNT OF FUNDING APPROVED (US$ MILLION) |
|---|---|
| BANGLADESH | 214.6 |
| CAMBODIA | 133.3 |
| NEPAL | 132.2 |
| SAMOA | 122.3 |
| INDIA | 54.2 |
| SRI LANKA | 49.2 |
| PAKISTAN | 44.2 |
| TUVALU | 43.9 |
| BHUTAN | 41.9 |
| MALDIVES | 38.8 |
| VANUATU | 38.1 |
| FIJI | 37.4 |
| MYANMAR | 36.2 |
| LAO PDR | 36.1 |
| PAPUA NEW GUINEA | 35.6 |

**Recipients** (Bubble Chart)




*Source: CFU (n.d.).*

*Funds Covered: Least Developed Countries Fund; Pilot Programme for Climate Resilience; Adaptation Fund; Adaptation for Smallholder Agriculture, Special Climate Change Fund; and MDG Achievement Fund.

## យេនឌ័រនៅក្នុងហិរញ្ញវត្ថុអាកាសធាតុសកល

យេនឌ័រនៅក្នុងយន្តការហិរញ្ញប្បទានអាកាសធាតុសាកល បានរីកចម្រើនតែក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ដែលបណ្តាលមកពីការតស៊ូមតិជាប្រចាំរបស់អង្គការដែលផ្តោតលើស្ត្រី និងកំណើននៃការទទួលស្គាល់នូវតម្រូវការគម្រោងដើម្បីរួមបញ្ចូលយេនឌ័រក្នុងការបង្កើនប្រសិទ្ធផល និងប្រសិទ្ធភាព។ ជាលទ្ធផលយើងបានឃើញការផ្លាស់ប្តូរមួយចំនួន ប៉ុន្តែនៅតែជាផ្លូវដ៏វែងឆ្ងាយមួយក្នុងការបន្តដំណើរទៅមុខទៀត។នៅទូទាំងពិភពលោក ហិរញ្ញវត្ថុអាកាសធាតុមានកំណត់ត្រូវបានរួមបញ្ចូលឬដោះស្រាយសិទ្ធិរបស់ស្ត្រី និង/ឬសមភាពយេនឌ័រ ហើយហិរញ្ញវត្ថុមានកំណត់នោះក៏ស្ថិតនៅក្នុងវិស័យ និងទីតាំងភូមិសាស្ត្រជាក់លាក់ផងដែរ។ ក្នុងចំណោមទឹកប្រាក់ ២៦ ពាន់លានដុល្លារនៃជំនួយអភិវឌ្ឍន៍ក្រៅប្រទេស (ODA) ដែលផ្តោតលើការប្រែប្រួលអាកាសធាតុក្នុងឆ្នាំ២០១៤ មានតែ ៨ ពាន់លាន (៣១%) ប៉ុណ្ណោះដែលគាំទ្រសមភាពយេនឌ័រ។ទោះបីយ៉ាងណាក៏ដោយ ក៏តួលេខនេះគឺជាការកើនឡើងពី ៤,៤ ពាន់លានដុល្លារក្នុងឆ្នាំ២០១០ (រូបទី ៦០) (OECD DAC ឆ្នាំ ២០១៦)។

ការធ្វើសមាហរណកម្មគឺខ្ពស់ជាងគេនៅក្នុងគម្រោងបន្សាំ

តែប៉ុណ្ណោះ (៤១%) ប្រើធៀបនឹងគម្រោងកាត់បន្ថយ (១៨%)។ ក្នុងវិស័យនេះផងដែរ ក៏មានការបែកចាយមិនស្មើគ្នា ដោយផ្តោតខ្លាំងទៅលើសមភាពយេនឌ័រនៅក្នុងវិស័យកសិកម្ម (៥៩%) បន្ទាប់មកគឺទឹក (៣៩%)។ទោះបីគម្រោងថាមពលគឺជាចំណែកធំបំផុតនៃជំនួយអាកាសធាតុទ្វេភាគីទាំងអស់ មានតែ ៨% នៃគម្រោងថាមពល ដែលបានរួមបញ្ចូលយេនឌ័រ (OECD DAC ឆ្នាំ២០១៦)។

និន្នាការទាំងនេះមិនមានលទ្ធផលគួរឱ្យភ្ញាក់ផ្អើលទេបើទោះបីជាអាណត្តិរបស់ UNFCCC បានបង្កើនតុល្យភាពយេនឌ័រក្នុងអភិបាលកិច្ចក៏ដោយក៏តំណាងស្ត្រីនៅក្នុងអង្គភាពគ្រប់គ្រងមូលនិធិអាកាសធាតុសំខាន់គឺជាមធ្យមមានតែ ២២ ភាគរយប៉ុណ្ណោះក្នុងឆ្នាំ ២០១៥ (GGCA, UNDP ឆ្នាំ២០១៦)។

ដែនកំណត់សំខាន់មួយទៀតគឺថា ទោះបី ១៩% នៃជំនួយអាកាសធាតុទ្វេភាគី ដែលឆ្លើយតបនឹងតម្រូវការយេនឌ័រ (១,៤ ពាន់លានដុល្លារ) ត្រូវបានបញ្ជូនតាមរយៈអង្គការសង្គមស៊ីវិលក៏ដោយ ក៏ជំនួយមួយភាគធំ (១៤% ឬ ១ ពាន់លានដុល្លារអាមេរិក) បានទៅដល់អង្គការមិនមែនរដ្ឋាភិបាល ដែលមានមូលដ្ឋាននៅក្នុងប្រទេសម្ចាស់ជំនួយ។ មានតែជំនួយតិចតួចប៉ុណ្ណោះ (២% នៃ ១៣២ លានដុល្លារអាមេរិក) ដែលបានទៅ CSOs ក្នុងប្រទេសកំពុងអភិវឌ្ឍន៍ (OECD DAC ឆ្នាំ២០១៦)។ដូច្នេះប្រការចាំបាច់ត្រូវផ្តោតការយកចិត្តទុកដាក់លើគម្រោងរបស់អង្គការមិនមែនរដ្ឋាភិបាលដែលមានមូលដ្ឋាននៅក្នុងប្រទេសម្ចាស់ជំនួយ ហើយអង្គការទាំងនោះត្រូវទទួលខុសត្រូវចំពោះការបញ្ជ្រាបយេនឌ័រ។

**រូបទី ៦០៖ និន្នាការក្នុងសមាជិក DAC នៃ ODA ទាក់ទងនឹងអាកាសធាតុ ដែលផ្តោតគោលដៅលើសមភាពយេនឌ័រ (គិតជាពាន់លានដុល្លារ)**




ប្រភព ៖ (OECD DAC ឆ្នាំ២០១៦)

ចំណុចតស៊ូមតិដ៏សំខាន់មួយសម្រាប់ការពង្រឹងហិរញ្ញវត្ថុអាកាសធាតុឆ្លើយតបនឹងតម្រូវការយេនឌ័រ ដែលត្រូវបានកៀរគរដោយ OECD DAC គឺតម្រូវការសម្រាប់យន្តការផ្តល់មូលនិធិងាយៗដើម្បីឱ្យអង្គការដែលផ្តោតលើស្ត្រីទទួលបានហិរញ្ញវត្ថុអាកាសធាតុ។ អង្គការដែលផ្តោតលើស្ត្រីគួរយកចំណុចនេះ ធ្វើជាចំណុចតស៊ូមតិនៅគ្រប់វេទិកាហិរញ្ញវត្ថុអាកាសធាតុជាតិ និងអន្តរជាតិ។

## មូលនិធិបន្សាំសំខាន់ៗនិងវិសាលភាពសម្រាប់ការចូលរួមរបស់ CSOs

នៅក្នុងដែនកំណត់ទាំងនេះក្នុងស្ថាបត្យកម្មហិរញ្ញវត្ថុអាកាសធាតុសកល មានវិសាលភាពតិចតួចណាស់សម្រាប់ CSOs ជាពិសេសអង្គការដែលផ្តោតលើស្ត្រី ក្នុងការទទួលបានមូលនិធិដោយផ្ទាល់។ ទោះយ៉ាងណាក៏ដោយ មានវិធីផ្សេងៗទៀតដែល CSOsជាពិសេសអង្គការដែលផ្តោតលើស្ត្រីអាចចូលរួមដើម្បីទទួលបានហិរញ្ញវត្ថុអាកាសធាតុដែលឆ្លើយតបនឹងតម្រូវការយេនឌ័រ។ មូលនិធិបន្សាំសំខាន់ៗមួយចំនួនដែលមានសមាសភាព/ផែនការសកម្មភាពយេនឌ័ររឹងមាំ ត្រូវបានពិភាក្សានៅទីនេះ ដោយបញ្ជាក់ពីវិសាលភាពសម្រាប់CSOsនិងអង្គការដែលផ្តោតលើស្ត្រីក្នុងការចូលរួមដូចគ្នា។

### មូលនិធិបន្សាំ (AF)

បង្កើតឡើងក្នុងឆ្នាំ២០០១ ក្រោមពិធីសារក្យូតូនៃ UNFCCC មូលនិធិបន្សាំមានគោលបំណងបង្កើនសមត្ថភាពបន្សាំនឹងការប្រែប្រួលអាកាសធាតុនៃសហគមន៍ ដែលងាយរងគ្រោះបំផុតនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍។ មូលនិធិនេះផ្តល់ហិរញ្ញប្បទានដល់សកម្មភាពបន្សាំនឹងការប្រែប្រួលអាកាសធាតុ និងភាពធន់ដែលផ្អែកលើតម្រូវការ ទស្សនៈ និងអាទិភាពរបស់ប្រទេស។ មូលនិធិនេះបានដំណើរការយ៉ាងពេញលេញចាប់តាំងពីឆ្នាំ ២០១០ (គេហទំព័រមូលនិធិបន្សាំឆ្នាំ២០១៩)។គិតត្រឹមថ្ងៃទី១ ខែមករា ឆ្នាំ២០១៩ AF បច្ចុប្បន្នផ្តល់អាណត្តិបម្រើឱ្យកិច្ចព្រមព្រៀងទីក្រុងប៉ារីសស្របតាមយុទ្ធសាស្ត្ររយៈពេលមធ្យម៥ គឺពីឆ្នាំ ២០១៨ ដល់ឆ្នាំ ២០២២ ដែលទើបតែត្រូវបានអនុម័តនាពេលថ្មីៗ ដោយផ្អែកលើសសរស្តម្ភនៃសកម្មភាព នវានុវត្តន៏ និងចំណេះដឹង និងការចែករំលែក (Hall, Granat និង Daniel ឆ្នាំ២០១៩)។

មូលនិធិនេះត្រូវបានផ្តល់ហិរញ្ញប្បទានតាមរយៈការយកពន្ធ ២%លើការលក់ឥណទានបំភាយឧស្ម័នពីយន្តការអភិវឌ្ឍន៍ស្អាតនៃពិធីសារក្យូតូ និងមួយផ្នែកទៀត គឺតាមរយៈរដ្ឋាភិបាល និងម្ចាស់ជំនួយឯកជន។ (គេហទំព័រមូលនិធិបន្សាំ ឆ្នាំ ២០១៩)។ ទោះយ៉ាងណា ដោយសារតម្លៃកាបូនទាប បច្ចុប្បន្ន មូលនិធិនេះពឹងផ្អែកយ៉ាងខ្លាំងទៅលើវិភាគទានស្ម័គ្រចិត្តពីរដ្ឋាភិបាល និងម្ចាស់ជំនួយឯកជន។ ប្រភពមូលនិធិស្វ័យប្រវត្តិស្រដៀងគ្នាពី

យន្តការទីផ្សារកាបូនថ្មីបច្ចុប្បន្នកំពុងស្ថិតក្រោមការពិចារណា (Watson និង Schalatek, CFU b ឆ្នាំ២០២០)។

មូលនិធិនេះត្រូវបានគ្រប់គ្រងដោយក្រុមប្រឹក្សាភិបាល AF ដែលជួបប្រជុំគ្នាបីដងក្នុងមួយឆ្នាំ ជាទូទៅនៅ ទីក្រុង Bonn (ប្រទេសអាល្លឺម៉ង់)។ក្រុមប្រឹក្សាភិបាលមានសមាជិកចំនួន១៦ នាក់ និងសមាជិកបម្រុង ១៦ នាក់ដែលតំណាងឱ្យភាគីនៃពិធីសារក្យូតូ។ សមាជិកភាគច្រើន គឺប្រហែល ៦៩ ភាគរយ តំណាងឱ្យប្រទេសកំពុងអភិវឌ្ឍន៍ (គេហទំព័រមូលនិធិបន្សាំ ឆ្នាំ២០១៩)។

មូលនិធិនេះត្រូវបានបង្កើតឡើងសម្រាប់បណ្តាប្រទេសដែលអាចទទួលបានហិរញ្ញប្បទានដោយផ្ទាល់និងគ្រប់គ្រងគ្រប់ទិដ្ឋភាពនៃគម្រោងបន្សាំ និងភាពធន់នឹងអាកាសធាតុ ចាប់ពីការរចនាតាម រយៈការអនុវត្ត រហូតដល់ការត្រួតពិនិត្យ និងវាយតម្លៃ។ បណ្តាប្រទេសនានាអាចទទួលបានមូលនិធិតាមរយៈអង្គភាពអនុវត្ត ដែលត្រូវបានទទួលស្គាល់ ដែលអាចបំពេញបានតាមកិច្ចសន្យាជានាដែលបានព្រមព្រៀងគ្នាព្រមទាំងស្តង់ដារបរិស្ថាន សង្គម និងយេនឌ័រ (មូលនិធិបន្សាំ ឆ្នាំ២០២០)។ អង្គភាពអនុវត្តដែលត្រូវបានទទួលស្គាល់ដោយ AF ទាំងនេះ អាចជាថ្នាក់ជាតិ ថ្នាក់តំបន់ ឬពហុភាគី។ គិតមកដល់ពេលបច្ចុប្បន្ននេះ មានអង្គភាពអនុវត្តថ្នាក់ជាតិ (NIEs) ចំនួន១៧ អង្គភាពអនុវត្តថ្នាក់តំបន់ (RIEs) ចំនួន ៤ និងអង្គភាពអនុវត្តពហុភាគី (MIEs) ចំនួន ១១។

បន្ទាប់ពីក្រុមប្រឹក្សាភិបាលមូលនិធិបន្សាំសំរេចទទួលស្គាល់អង្គភាពដែលពិចារណាលើអនុសាសន៍ ដោយ គណៈកម្មាធិការដែលត្រូវបានទទួលស្គាល់អង្គភាពអាចដាក់សំណើទស្សនទានឬគម្រោងពេញលេញមួយ។ ភាគីដែលស្វែងរកធនធានហិរញ្ញវត្ថុពីមូលនិធិបន្សាំ ត្រូវតែដាក់សំណើគម្រោង និងកម្មវិធីរបស់ពួកគេតាមរយៈអង្គភាពដែលមានការទទួលស្គាល់ថ្នាក់ជាតិ ថ្នាក់តំបន់ ឬពហុភាគី។ សំណើនឹងត្រូវបានត្រួតពិនិត្យ ដោយគោរពតាមលក្ខណៈ

ដំណើរការនៃការទទួលស្គាល់របស់ AF គឺខ្លី និងសាមញ្ញ។ នៅពេលដែលការទទួលស្គាល់ត្រូវបានបញ្ចប់ NIEs អាចបញ្ជូនសំណើសម្រាប់គម្រោង និងកម្ម វិធី។ ជំនួយខ្នាតតូចដែលមានចំនួនតិចជាងមួយលានតាមពិតត្រូវបានអនុម័តតែនៅក្នុងដំណើរការមួយជំហានប៉ុណ្ណោះ។ទោះយ៉ាងណាជម្រើសនេះអាចប្រើបានសម្រាប់តែអង្គការដែលបានជ្រើសរើសប៉ុណ្ណោះ(ប្រសិនបើប្រទេសនេះមិនមាន NIE ហើយមិនបានលើដែនកំណត់ហិរញ្ញប្បទានចំនួន ១០ លានដុល្លារអាមេរិក4)

**រូបទី ៦១៖ ការវិនិយោគលើមូលនិធិបន្សាំតាមវិស័យ (ដុល្លារអាមេរិក)**




ប្រភព ៖ AF APR ឆ្នាំ២០១៩

វិនិច្ឆ័យជាក់លាក់ដែលមាននៅក្នុងគោលនយោបាយប្រតិបត្តិ និងគោលការណ៍ណែនាំ។ សំណើត្រូវបានទទួលយកចំនួនបីដងក្នុងមួយឆ្នាំ៖ ពីរដងមុនការប្រជុំក្រុមប្រឹក្សាភិបាលមូលនិធិបន្សាំ ដែលប្រព្រឹត្តទៅពីរដងក្នុងមួយឆ្នាំនិងមួយទៀតក្នុងកំឡុងពេលវដ្តត្រួតពិនិត្យអន្តរវគ្គ។ (គេហទំព័រមូលនិធិបន្សាំ ឆ្នាំ២០១៩)។ មូលនិធិបន្សាំផ្តល់ការគាំទ្រឆ្លងវិស័យជាច្រើន។រូបទី៦១បង្ហាញពីជំនួយតាមវិស័យដែលបានផ្តល់ក្រោមមូលនិធិបន្សាំ។

បន្ថែមលើជំនួយគម្រោង មូលនិធិបន្សាំក៏គាំទ្រផងដែរនូវជំនួយ ៣ ប្រភេទផ្សេងទៀត ៖

ក)ការផ្តល់ជំនួយសម្រាប់ការត្រៀមខ្លួន-ជំនួយខ្នាតតូចដែលមានក្រោមកម្មវិធីត្រៀមហិរញ្ញវត្ថុអាកាសធាតុដើម្បីជួយអង្គភាពអនុវត្តថ្នាក់ជាតិ (NIEs) ផ្តល់ការគាំទ្រដល់បណ្តាប្រទេសដែលស្វែងរកការទទួលស្គាល់ជាផ្លូវការជាមួយមូលនិធិនេះ និងដើម្បីកសាងសមត្ថភាពសម្រាប់អនុវត្តសកម្មភាពត្រៀមហិរញ្ញវត្ថុអាកាសធាតុផ្សេងៗ។ ជំនួយត្រៀមរបស់ AF គាំទ្រផងដែរដល់អង្គភាពអនុវត្តដើម្បីផ្តល់ជំនួយបច្ចេកទេសក្នុងការកសាងសមត្ថភាពរបស់ពួកគេ

លើយេនឌ័រជាពិសេសដើម្បីគាំទ្រដល់ការធ្វើសមាហរណកម្មយេនឌ័រទៅក្នុងការរៀបចំ និងការអភិវឌ្ឍសំណើ។

អង្គការដែលផ្តោតលើស្ត្រីអាចផ្តល់ជំនួយបច្ចេកទេសដល់ NIEsដែលមានស្រាប់តាមរយៈកម្មវិធីត្រៀមខ្លួន។ទាក់ទងជាមួយ NIEs ដោយផ្ទាល់ និងគាំទ្រការប្រើប្រាស់អង្គការដែលផ្តោតលើស្ត្រីជាអ្នកប្រឹក្សា និងជាគ្រូឧទ្ទេស ដែលជាផ្នែកមួយនៃជំនួយ។

ខ) **ជំនួយនវានុវត្តន៏** រហូតដល់ ២៥០,០០០ ដុល្លារអាមេរិកសម្រាប់ NIEs ដោយចាប់ផ្តើមពីការស្នើសុំ ដំបូងសម្រាប់សំណើមូលនិធិក្រោម ២ លានដុល្លារដែលបានកំណត់ ត្រូវបានដាក់ឱ្យដំណើរការនៅខែធ្នូ ឆ្នាំ ២០១៨។ ជំនួយខ្នាតតូចទាំងនេះត្រូវបានផ្តល់ជូនប្រទេសកំពុងអភិវឌ្ឍន៍ដែលងាយរងគ្រោះតាមរយៈផ្លូវពីរ ៖ ផ្តល់ដោយផ្ទាល់តាមរយៈ NIEs ជាពិសេស បណ្តាប្រទេសដែលមាន NIEs ត្រូវបានទទួលស្គាល់ជាផ្លូវការ និងតាមរយៈយន្តការចែកចាយរួមរបស់ NIEs ដល់អង្គភាពផ្សេងទៀត (អង្គការ ក្រុមសមាគម ស្ថាប័ន អាជីវកម្ម ទីភ្នាក់ងារ។ ល។ ) ដែលមិនត្រូវបានទទួលស្គាល់ជាមួយនឹងមូលនិធិនេះ។ ក្រោមការឧបត្ថម្ភដោយ UNDP និង UNEP ជំនួយចំនួន ៤៥ ដែលមានទឹកប្រាក់រហូតដល់ ២៥០,០០០ ដុល្លារអាមេរិក ត្រូវបានគេរំពឹងថានឹងប្រគល់ជូនអង្គភាពដែលមិនត្រូវបានទទួលស្គាល់នៅជុំទី ២ក្នុងឆ្នាំ ២០២០។

អង្គការដែលផ្តោតលើស្ត្រីអាចដាក់ពាក្យស្នើសុំមូលនិធិដោយផ្ទាល់ ក្រោមជំនួយនវានុវត្តន៏ ក្រោមវិស័យប្រធានបទ "ការលើកកម្ពស់សមភាពយេនឌ័រ (ការផ្តល់ភាពអង់អាចដល់ស្ត្រី និងក្មេងស្រី)"

គ) **ជំនួយសិក្សា** - ជាប្រកមូលនិធិថ្មីមួយសម្រាប់ NIEs ដើម្បីទទួលបានជំនួយសិក្សា។ ជំនួយសិក្សា បង្កើតឡើងដោយផ្អែកលើក្របខ័ណ្ឌនៃគម្រោងគ្រប់គ្រងចំណេះដឹងនិងផែនការសកម្មភាពដែលត្រូវបានកែសម្រួលនាថ្មីៗនេះ (ត្រូវបានអនុម័ត ក្នុងឆ្នាំ ២០១៦)។ ចំនួនទឹកប្រាក់ជំនួយដែល NIE ដែលត្រូវបានទទួលស្គាល់មួយ អាចទទួលបាន គឺរហូតដល់ ១៥០,០០០ ដុល្លារអាមេរិកជាអតិបរមាក្នុងមួយគម្រោង/កម្មវិធី។

ក្នុងឆ្នាំ ២០១១ ជាដំបូង AF បានបង្កើតគោលនយោបាយ និងផែនការសកម្មភាពយេនឌ័រដែលដឹកនាំការងាររបស់ខ្លួន បន្ទាប់មក គោលនយោបាយបរិស្ថាន និងសង្គមថ្មីមួយត្រូវបានបង្កើតឡើងក្នុងឆ្នាំ២០១៣ ដែលមានគោលការណ៍ដាក់លាក់ស្តីពី "សមភាពយេនឌ័រ និងការផ្តល់ភាពអង់អាចដល់ស្ត្រី" (Hall, Granat និង Daniel ឆ្នាំ២០១៩)។ នៅក្នុងឆ្នាំ២០១៥ ការពិនិត្យដែលមានអាណត្តិរបស់ក្រុមប្រឹក្សាភិបាលស្តីពីការធ្វើសមាហរណកម្មនៃការពិចារណាលើយេនឌ័រទៅក្នុងគោលនយោបាយ និងនីតិវិធីនៃមូលនិធិបន្សុំាបានបង្ហាញថាមានវឌ្ឍនភាពមានកំណត់នៅក្នុងវិធីសាស្ត្រសមភាពយេនឌ័រទូលំទូលាយបន្ទាប់ពីបានសម្រេចលើវិធីសាស្ត្រនេះដែលថាមូលនិធិនេះគួរតែអភិវឌ្ឍគោលនយោបាយសមភាពយេនឌ័រផ្ទាល់ខ្លួន (Liane Schalatek ឆ្នាំ២០១៩)។ ដូច្នេះ គោលនយោបាយយេនឌ័រ និងផែនការសកម្មភាពយេនឌ័ររយៈពេលច្រើនឆ្នាំ (សម្រាប់ឆ្នាំ២០១៧-១៩) នៃមូលនិធិបន្សុំាផ្អែកលើសិទ្ធិមនុស្ស ត្រូវបានអនុម័ត បន្ទាប់ពីដំណើរការពិគ្រោះយោបល់នៅក្នុងខែ មីនា ឆ្នាំ ២០១៦ (គោលនយោបាយ AF ឆ្នាំ ២០១៦)។ នៅក្នុង ឆ្នាំ ២០១៧ ឯកសារគោលការណ៍ណែនាំសម្រាប់អង្គភាពអនុវត្តស្តីពីការអនុលោមតាមគោលនយោបាយយេនឌ័រនៃមូលនិធិបន្សុំា ត្រូវបានបង្កើតឡើង ដើម្បីផ្តល់ជូនដល់អង្គភាពអនុវត្តនូវគោលការណ៍ណែនាំជាក់ស្តែងស្តីពីវិធីដើម្បីសម្រេច និងវាយតម្លៃការអនុលោមតាមគោលនយោបាយយេនឌ័រនៃមូលនិធិបន្សុំាពេញមួយវដ្តនៃគម្រោង (គោលការណ៍ណែនាំយេនឌ័រឆ្នាំ២០១៧)។ យុទ្ធសាស្ត្ររយៈពេលមធ្យមនៃមូលនិធិបន្សុំាថ្មី (ឆ្នាំ២០១៨-២០២២) ដែលត្រូវបានអនុម័តនៅក្នុងឆ្នាំ២០១៧ ក៏បានបង្ហាញជាចម្បងផងដែរពីសមភាពយេនឌ័រដែលជាបញ្ហាអន្តរវិស័យ ដើម្បីសម្រេចបាននូវបេសកម្មរបស់មូលនិធិនិងបង្កើតគោលនយោបាយដើម្បីរួមបញ្ចូលនូវប្រកផ្តល់មូលនិធិទាក់ទងនឹងយេនឌ័រថ្មី (AF MTS ឆ្នាំ២០១៨)។

អនុសាសន៍មួយ ក្នុងចំណោមអនុសាសន៍ជាក់ស្តែងសម្រាប់ទីភ្នាក់ងារអនុវត្ត ដែលជាផ្នែកមួយនៃគោលនយោបាយយេនឌ័រផែនការសកម្មភាពយេនឌ័រនិងឯកសារគោលការណ៍ណែនាំគឺជាការពិគ្រោះយោបល់យ៉ាងសកម្មជាមួយទាំងស្ត្រីនិងបុរសហើយតម្រូវការសម្រាប់កិច្ចខិតខំប្រឹងប្រែងជាគោលដៅដើម្បីរួមបញ្ចូលប្រព័ន្ធនៃអង្គការដែលផ្តោតលើស្ត្រី ថ្នាក់ជាតិ (រួមទាំងអង្គការ និងបណ្តាញដែលផ្តោតលើស្ត្រីសហករណ៍ដែលផ្តោតលើស្ត្រីនិងអ្នកជំនាញយេនឌ័រ) ក្នុងការពិគ្រោះយោបល់ទាំងនេះ។

អង្គការដែលផ្តោតលើស្ត្រី អាចយកគោលការណ៍ណែនាំនេះទៅអង្គភាពអនុវត្ត AF នៅក្នុងប្រទេសរបស់ពួកគេ ដើម្បីលើកកម្ពស់ប្រព័ន្ធអង្គការ (និងអង្គការដែលផ្តោតលើស្ត្រី និងការដាក់បញ្ចូលអង្គការទាំងនោះ ជាភាគីពាក់ព័ន្ធនៅគ្រប់ដំណាក់កាលនៃវដ្តគម្រោង / កម្មវិធី។

ផែនការនេះក៏តម្រូវឱ្យលេខាធិការដ្ឋានបង្កើតបញ្ជីឈ្មោះអ្នកពិគ្រោះយោបល់ជំនាញយេនឌ័រផងដែរ។ គិតត្រឹមខែកុម្ភៈ ឆ្នាំ ២០១៩លេខាធិការដ្ឋានកំពុងធ្វើការកំណត់អត្តសញ្ញាណអង្គការដទៃទៀតដើម្បីអភិវឌ្ឍ និងរៀបចំបញ្ជីឈ្មោះសម្រាប់ការប្រើប្រាស់ទូលំទូលាយនៅទូទាំងយន្តការហិរញ្ញវត្ថុអាកាសធាតុ។AF ក៏បានបង្កើតគេហទំព័រដែលផ្តោតលើ ចំណេះដឹង និងប្រធានបទសិក្សាស្តីពីយេនឌ័រ ជាមួយនឹងឯកសារដែលមាន ស្តីពីគោលនយោបាយនិងកម្មវិធីយេនឌ័រការចែករំលែកពីគោលការណ៍ណែ

នាំ និងបទពិសោធក្នុងការអនុវត្តគម្រោង។

បញ្ជីឈ្មោះនេះ នឹងផ្តល់ឱកាសដល់អង្គការក្នុងតំបន់ដែលផ្តោតលើស្ត្រីដើម្បីចូលរួមក្នុងគម្រោង/កម្មវិធីដែលផ្តល់ហិរញ្ញប្បទានដោយមូលនិធិនេះក្នុងការរួមចំណែកដល់ការពិចារណាលើយេនឌ័រពេញមួយវដ្តជីវិតនៃគម្រោង ។

## មូលនិធិវិនិយោគលើអាកាសធាតុ (CIF)

ដោយបានបង្កើតឡើងនៅក្នុងឆ្នាំ២០០៨ មូលនិធិវិនិយោគលើអាកាសធាតុ (CIFs) ត្រូវបានគ្រប់គ្រងដោយធនាគារពិភពលោកក្នុងភាពជាដៃគូជាមួយធនាគារអភិវឌ្ឍន៍ក្នុងតំបន់ចំនួន ៥ រួមមាន ធនាគារអភិវឌ្ឍន៍ អាហ្វ្រិក (AfDB) ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ធនាគារអឺរ៉ុបសម្រាប់ការកសាងឡើងវិញ និងអភិវឌ្ឍន៍ (EBRD) និងធនាគារអភិវឌ្ឍន៍អន្តរអាមេរិក (IDB)។ ជាដំបូង CIFs ត្រូវបានបង្កើតឡើងដើម្បីជំរុញការវិនិយោគ ទាំងនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ និងប្រទេសដែលមានប្រាក់ចំណូលមធ្យម ជាពិសេសផ្តល់អំណាចដល់ "ការលុតលាស់ និងការបំប្លែងអាកាសធាតុវៃឆ្លាត"។ ទឹកប្រាក់សរុបចំនួន ៨ ពាន់លានដុល្លារ ត្រូវបានសន្យាដោយផ្ទាល់ដល់ CIF ដោយប្រទេសអ្នកចូលរួមចំនួន ១៤។ បច្ចុប្បន្ន CIF គាំទ្រដល់ ៧២ ប្រទេសលើវិស័យមួយចំនួនដូចជាថាមពលភាពធន់នឹងអាកាសធាតុការដឹកជញ្ជូន និងរុក្ខាប្រមាញ់ (គេហទំព័រ CIF ឆ្នាំ២០១៨)។
CIF មានមូលនិធិចំនួនពីរគឺ៖

ក) មូលនិធិបច្ចេកវិទ្យាស្អាត (CTF) និង

ខ) មូលនិធិអាកាសធាតុយុទ្ធសាស្ត្រ (SCF) ជាមួយនឹងកម្មវិធីចំនួន ៣ គឺ កម្មវិធីសាកល្បងសម្រាប់ភាពធន់នឹងអាកាសធាតុ (PPCR) កម្មវិធីពង្រីកថាមពលកកើតឡើងវិញ (SREP) នៅក្នុងប្រទេសដែលមានប្រាក់ចំណូលទាប និងកម្មវិធីវិនិយោគលើព្រៃឈើ (FIP)។

តាមរយៈ CIF ដំបូងប្រទេសនានាត្រូវដាក់ពាក្យសុំដើម្បីក្លាយជា "ប្រទេសសាកល្បង" មួយក្នុងចំណោមកម្មវិធីទាំង៤ហើយនៅពេលត្រូវបានអនុម័តប្រទេសនីមួយៗត្រូវតែបង្កើតផែនការវិនិយោគ (IP) សម្រាប់កម្មវិធីនោះ។ ការអភិវឌ្ឍ IP គឺជាដំណើរការមួយដែលជាញឹកញាប់ពាក់ព័ន្ធនឹងការពិគ្រោះយោបល់ជាច្រើនជុំជាមួយភាគីពាក់ព័ន្ធផ្សេងៗគ្នាដើម្បីកំណត់ព័ត៌មានលម្អិតនៃការវិនិយោគ និងបញ្ជាក់យ៉ាងច្បាស់ពីការចូលរួមវិភាគទានដែលរំពឹងទុកពី CIF និងប្រភពផ្សេងទៀត។ IP ត្រូវតែមានការយល់ព្រមពីគណៈកម្មាធិការមូលនិធិត្រឹះ CIF មុនពេលប្រទេសនានាធ្វើការជាមួយ MDBs ដើម្បីអភិវឌ្ឍគម្រោងនានាសម្រាប់ការផ្តល់មូលនិធិ (WEDO ឆ្នាំ២០១៩)។

CIFមិនបានរួមបញ្ចូលអាណត្តិណាមួយសម្រាប់ការពិចារណាលើយេនឌ័រនៅពេលចាប់ផ្តើមនោះឡើយ។ទោះយ៉ាងណាការពិនិត្យមើលយេនឌ័រ CIF ដែលមានលក្ខណៈស៊ីជម្រៅក្នុងឆ្នាំ២០១៣ បានបញ្ជាក់ថា CIFs ចាំបាច់ត្រូវធ្វើការងារច្រើនទៀត ដើម្បីដោះស្រាយការពិចារណាយេនឌ័រជាប្រព័ន្ធ (Liane Schalatek ឆ្នាំ២០១៩)។ ដើម្បីដោះស្រាយបញ្ហានេះ ក្នុងឆ្នាំ ២០១៤ CIF បានជ្រើសរើសអ្នកជំនាញផ្នែកយេនឌ័រ និងបញ្ហាសង្គម។ ជាបន្តបន្ទាប់ CIF បាន នឹងកំពុងរៀបចំផែនការសកម្មភាពយេនឌ័រ (GAP) ដែលបានអនុម័ត និងអនុវត្តនៅទូទាំងបីដំណាក់កាល។ របាយការណ៍វឌ្ឍនភាពយេនឌ័រឆ្នាំ ២០១៧ របស់ CIF បានបង្ហាញពីភាពប្រសើរឡើងនៃ CIF ភាគច្រើន ក្រោមផែនការសកម្មភាពយេនឌ័រ CIF។ ទោះជាយ៉ាងណា ការឆ្លើយតបទៅនឹងតម្រូវការយេនឌ័រ របស់ CIF នៅតែបន្តយឺតយ៉ាវដដែល (Liane Schalatek ឆ្នាំ២០១៩)។ ផែនការសកម្មភាពយេនឌ័រចុងក្រោយនៃដំណាក់កាលទី ៣ (GAP-3) (សម្រាប់ឆ្នាំ ២០២១-២០២៤) ត្រូវបានអនុម័តនៅក្នុងខែមិថុនា ឆ្នាំ២០២០។ GAP-3 នឹងបន្តផ្តោតលើ "ឥទ្ធិពលនៃការបំប្លែងយេនឌ័រនៅក្នុងវិស័យសំខាន់ៗនៃស្ថានភាពទ្រព្យសម្បត្តិ សំឡេង និងស្ថានភាពជីវភាពរស់នៅដែលមានភាពធន់របស់ស្ត្រីតាមរយៈស្ថាប័ននិងទីផ្សារដែលឆ្លើយតបនឹងតម្រូវការ យេនឌ័រ" (CIF GAP ឆ្នាំ២០២០)។ គោលនយោបាយយេនឌ័រ CIF ដែលត្រូវបានអនុម័តក្នុងឆ្នាំ២០១៨ ក៏ផ្តល់ផងដែរនូវក្របខ័ណ្ឌអភិបាលកិច្ចដើម្បី "លើកកម្ពស់ការទទួលបាន និងអត្ថប្រយោជន៍ដោយសមធម៌ពីការវិនិយោគដែលគាំទ្រដោយ CIF សម្រាប់ស្ត្រី និងបុរសនៅក្នុងប្រទេសសាកល្បង CIF" (គោលនយោបាយយេនឌ័រ CIF ឆ្នាំ ២០១៨)។

IPs នៅក្នុងប្រទេស ផ្តល់នូវច្រកចូលសម្រាប់អង្គការដែលផ្តោតលើស្ត្រី ចូលរួមក្នុងដំណើរការនេះ។ នៅក្នុងបណ្តាប្រទេសដែលមាន IP រួចហើយ អង្គការអាចចូលរួមក្នុងកំឡុងពេលធ្វើបច្ចុប្បន្នភាព IPs។

បច្ចុប្បន្ននេះ CIF ក៏រួមបញ្ចូលសមភាពយេនឌ័រជាគុណប្រយោជន៍រួម និងជាលក្ខណៈវិនិច្ឆ័យសំខាន់នៅក្នុង FIP និង SREP ខណៈដែលកម្មវិធី CIF ផ្សេងទៀតត្រូវបានរំពឹងថានឹងវាយតម្លៃវិសាលភាពយេនឌ័រ ក្នុងកំឡុងពេលពិនិត្យបច្ចេកទេសរបស់ពួកគេ។ PPCR និង FIP ក៏បានចង្អុលបង្ហាញយ៉ាងច្បាស់អំពីក្រុមស្ត្រី និងក្រុមដែលផ្តោតលើស្ត្រី ជាភាគីពាក់ព័ន្ធសំខាន់ៗដែលគួរតែត្រូវបានពិគ្រោះយោបល់សម្រាប់ការរៀបចំ IP និងការរៀបចំគម្រោង (Burns និង Burns ឆ្នាំ២០២០)។

អង្គការដែលផ្តោតលើស្ត្រីអាចជាប់ពាក់ព័ន្ធក្នុងការចូលរួមរបស់ភាគីពាក់ព័ន្ធ ក្នុងនាមជាអង្គការសង្គមស៊ីវិល ក៏ដូចជាដើម្បីនាំមកនូវសំឡេង

លើសពីនេះ PPCR ក៏រួមបញ្ចូលទាំងអ្នកជំនាញ យេនឌ័រក្នុង

បេសសកម្មរបស់ប្រទេសឬការផ្សព្វផ្សាយដល់ក្រុមដែលផ្តោតលើស្ត្រី ដែលជាភាគីពាក់ព័ន្ធសំខាន់ៗក្នុងការពិគ្រោះយោបល់ក្នុងដំណាក់កាលរៀបចំផែនការកម្មវិធី (Liane Schalatek ឆ្នាំ២០១៩)។

អង្គការដែលផ្តោតលើស្ត្រីអាចភ្ជាប់ទំនាក់ទំនងដោយផ្ទាល់ជាមួយជនបង្គោលប្រចាំប្រទេសរបស់ CIF ក្នុងដំណើរការបង្កើត IP។ ទំនាក់ទំនងនេះ អាចត្រូវបានពង្រឹងបន្ថែមសម្រាប់ការចូលរួមដែលមានសក្តានុពលនៅក្នុងកិច្ចប្រជុំរបស់ភាគីពាក់ព័ន្ធនៅថ្នាក់តំបន់ និងពិភពលោក។

រចនាសម្ព័ន្ធអភិបាលកិច្ច CIF ក៏រួមបញ្ចូលផងដែរនូវតួនាទីរបស់ "អ្នកសង្កេតការណ៍សកម្ម" នៅទូទាំងកម្មវិធី CIF នីមួយៗ។ ក្រុមអ្នកសង្កេតការណ៍មានអាសនៈមួយនៅក្នុងគណៈកម្មាធិការមូលនិធិត្រឹះ រួមជាមួយម្ចាស់ជំនួយ និងរដ្ឋាភិបាលអ្នកទទួល។ រចនាសម្ព័ននេះមានគោលបំណងជានាថាគណៈកម្មាធិការនីមួយៗមានតំណាងចម្រុះនៃភាគីពាក់ព័ន្ធមកពីសង្គមស៊ីវិល ជនជាតិដើមភាគតិច និងវិស័យឯកជន មកពីប្រទេសអភិវឌ្ឍន៍ និងប្រទេសកំពុងអភិវឌ្ឍន៍។ នៅក្នុង ឆ្នាំ ២០១១ បន្ទាប់ពីអាណត្តិទី១ នៃអ្នកសង្កេតការណ៍ ដំណើរការបោះឆ្នោតសម្រាប់អ្នកសង្កេតការណ៍ថ្មីបានបញ្ជាក់ថា "កិច្ចខិតខំប្រឹងប្រែងពិសេស នឹងត្រូវធ្វើឡើងដើម្បីជ្រើសរើស និងជ្រើសយកអង្គការអ្នកសង្កេតការណ៍ដែលតំណាងដោយស្ត្រី និង/ឬ ដែលផ្តោតលើការចូលរួមរបស់ស្ត្រីក្នុងការដោះស្រាយបញ្ហាប្រឈមនៃការប្រែប្រួលអាកាសធាតុ" (គេហទំព័រ CIF ឆ្នាំ២០១៨)។ គោលនយោបាយយេនឌ័រឆ្នាំ២០១៨ ក៏បានណែនាំប្រភេទថ្មីនៃ "តំណាងយេនឌ័រ" ដល់ CIF សម្រាប់គណៈកម្មាធិការ និងអនុគណៈកម្មាធិការមូលនិធិត្រឹះទាំងអស់ ដែលត្រូវជ្រើសរើសចេញពីក្នុងចំណោមអ្នកសង្កេតការណ៍ CIF ដែលមានស្រាប់ (គោលនយោបាយយេនឌ័រ CIF ឆ្នាំ២០១៨)។ ដំណើរការនៃការចូលរួមរបស់ភាគីពាក់ព័ន្ធ និងអ្នកសង្កេតការណ៍ CIF ត្រូវបានរាយការណ៍ថាមានប្រសិទ្ធភាពក្នុងការធ្វើឱ្យមានការផ្លាស់ប្តូរផែនការវិនិយោគ-IP (វិទ្យាស្ថានធ្វើឲ្យមានការឯកភាពឆ្នាំ២០២០) និងអាចជាឧបករណ៍តស៊ូមតិដ៏រឹងមាំមួយសម្រាប់ CSOs ដើម្បីបង្កើតការវិនិយោគ CIF នៅក្នុងប្រទេស។

អង្គការដែលផ្តោតលើស្ត្រី និងអ្នកជំនាញយេនឌ័រ អាចចូលរួមជាពិសេសនៅក្នុងអភិបាលកិច្ច CIF តាមរយៈការដាក់ពាក្យសុំក្លាយជាអ្នកសង្កេតការណ៍នៃកម្មវិធី CIF មួយឬច្រើន តាមរយៈដំណើរការតែងតាំងនិងបោះឆ្នោត។

នៅក្នុងឆ្នាំ ២០១៥ CIF បានបង្កើតបណ្តាញប្រឹក្សាយោបល់ភាគីពាក់ព័ន្ធ (SAN) ដើម្បី "ពង្រឹងភាពជាដៃគូរបស់អ្នកប្រតិបត្តិមិនមែនរដ្ឋាភិបាលជាមួយនឹងអង្គភាពហិរញ្ញវត្ថុអាកាសធាតុដើម្បីលើកកម្ពស់របៀបវារៈនៃការអភិវឌ្ឍអាកាសធាតុឆ្លាត តាមរយៈកិច្ចសហការ ការស្រាវជ្រាវ ការតស៊ូមតិ ការភ្ជាប់បណ្តាញ និងភាពជាដៃគូ"។ បច្ចុប្បន្ន SANN ត្រូវបានរៀបចំឡើងដោយ CIF ហើយសមាជិកភាពបានបើកចំហដល់ភាគីពាក់ព័ន្ធទាំងអស់ដែលចូលរួមជាអ្នកសង្កេតការណ៍ចំពោះមូលនិធិហិរញ្ញវត្ថុពហុភាគី។ បណ្តាញ SAN ត្រូវបានដឹកនាំដោយគណៈកម្មាធិការគ្រប់គ្រង ដែលបង្កើតឡើងដោយសមាជិកសង្គមស៊ីវិល និងជនជាតិដើមភាគតិច ព្រមទាំងតំណាងវិស័យឯកជន (គេហទំព័រ CIF ឆ្នាំ ២០១៨)។

ឯកសារទេស្សនាទានSANមិនរាប់បញ្ចូលការលើកឡើងជាក់លាក់នៃយេនឌ័រឬស្ត្រីនោះទេប៉ុន្តែអង្គការដែលផ្តោតលើស្ត្រីអាចចូលរួមជាមួយ CIF ក្នុងនាមជាសមាជិក SAN ។

**គន្លឹះសម្រាប់គ្រូឧទ្ទេស**

វាកាន់តែមានប្រយោជន៍បន្ថែមទៀតសម្រាប់ CSOs ដែលបានឮអំពីដំណើរការទាំងនេះដោយផ្ទាល់ពីអ្នកដែលពាក់ព័ន្ធនឹង GCF នៅថ្នាក់ប្រទេស។ជាអនុសាសន៍យើងគួរអញ្ជើញជនបង្គោលអាជ្ញាធរជាតិទទួលបន្ទុកឬតំណាងស្ថាប័នជាតិដែលត្រូវបានទទួលស្គាល់សម្រាប់វគ្គនេះ ដើម្បីចែករំលែកព័ត៌មានអំពីដំណើរការដាក់លាក់របស់ប្រទេស បទពិសោធន៍ ឱកាស និងបញ្ហាប្រឈមសម្រាប់ CSOs។ ការណ៍នេះក៏នឹងផ្តល់ ឱកាសដល់អ្នកចូលរួម ក្នុងការបង្កើតបណ្តាញផងដែរ។ លោកអ្នកអាចចាប់ផ្តើមវគ្គជាមួយនឹងការមើលខ្សែភាពយន្តខ្លីស្តីពីមូលនិធិអាកាសធាតុបៃតងដែលអាចរកបានតាមរយៈhttps://www.youtube.com/watch?v=hiQ-Gs8NW3s អមដោយការពិភាក្សា។

## មូលនិធិអាកាសធាតុបៃតង (GCF)

មូលនិធិអាកាសធាតុបៃតង (GCF) ដែលត្រូវបានបង្កើតឡើងក្នុងឆ្នាំ២០១០បានដំណើរការយ៉ាងពេញលេញជាមួយនឹងគម្រោងដំបូងរបស់ខ្លួនដែលត្រូវបានអនុម័តនៅចុងឆ្នាំ២០១៥។ GCF ដើរតួជាអង្គភាពប្រតិបត្តិនៃយន្តការហិរញ្ញវត្ថុរបស់ UNFCCC និងកិច្ចព្រមព្រៀងទីក្រុងប៉ារីសហើយត្រូវបានរំពឹងថានឹងក្លាយជាប្រព័ន្ធទំនាក់ទំនងដ៏ចម្បង ដែលតាមរយៈប្រព័ន្ធនេះ ហិរញ្ញវត្ថុអាកាសធាតុសាធារណៈអន្តរជាតិនឹងហូរតាមពេលវេលា។ នៅត្រឹមខែធ្នូ ឆ្នាំ២០១៩ ការបំពេញបន្ថែមជាផ្លូវការលើកដំបូងរបស់ GCF (GCF-1) បានធ្វើឱ្យមានការសន្យាពីប្រទេសចំនួន ២៩ ដែលមានមូលនិធិចំនួន ៩,៨ ពាន់លានដុល្លារអាមេរិក (គេហទំព័ររបស់ GCF)។

វិធីសាស្ត្ររបស់ GCF ចំពោះហិរញ្ញវត្ថុអាកាសធាតុស្វែងរក "ការលើកកម្ពស់ការផ្លាស់ប្តូរគំរូទៅនឹងការបញ្ចេញឧស្ម័នទាប និង

ការអភិវឌ្ឍធន់នឹងអាកាសធាតុ... (រួមជាមួយនឹង) ការយកចិត្តទុកដាក់ជាពិសេសចំពោះតម្រូវការរបស់សង្គមដែលងាយរងគ្រោះបំផុតពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ" (គេហទំព័រ GCF)។

ប្រទេសកំពុងអភិវឌ្ឍន៍អាចទទួលបាន GCF តាមរយៈ MDBs ធនាគារពាណិជ្ជកម្មអន្តរជាតិ និងទីភ្នាក់ងារអង្គការសហប្រជាជាតិ ក៏ដូចជាដោយផ្ទាល់តាមរយៈអង្គភាពអនុវត្តថ្នាក់ជាតិ ថ្នាក់តំបន់ និងថ្នាក់ក្រោមជាតិដែលត្រូវបានទទួលស្គាល់។ នៅក្នុងខែតុលា ឆ្នាំ២០២០ បណ្តាញដៃគូអនុវត្តនៃ GCF បានកើនឡើងដល់ ៩៩ អង្គភាពដែលត្រូវបានទទួលស្គាល់ (គេហទំព័រ GCF)។

GCF ក៏ត្រូវបានកំណត់ថាជាមូលនិធិមួយ ក្នុងចំណោមហិរញ្ញវត្ថុធំៗបំផុតនៃគម្រោងបន្សាំ ដោយចំណាយ ៥០% នៃការកៀរគរធនធានដំបូងរបស់ខ្លួនទៅនឹងការបន្សាំ។ មូលនិធិនេះចំនួនពាក់កណ្តាល ត្រូវបានរំពឹងថានឹងផ្តល់ជូន SIDS, LDCs និងបណ្តារដ្ឋអាហ្វ្រិក (គេហទំព័រ GCF)។ GCF ក៏នឹងផ្តោតការយកចិត្តទុកដាក់នៅ អាស៊ីផងដែរ ដែលត្រូវបានឆ្លុះបញ្ចាំងនៅក្នុងការអនុម័តលើគម្រោងចំនួន ២៦ (១,១ ពាន់លានដុល្លារ) និងកម្មវិធីត្រៀមខ្លួនចំនួន ៤៥ (៤៥ លានដុល្លារ) រហូតមកដល់ពេលនេះនៅក្នុងតំបន់។ ការអនុម័ត GCF ឆ្នាំ២០១៩ មានចំនួន ៦២% នៃមូលនិធិចំនួន ៤០០ លានដុល្លារអាមេរិក សម្រាប់ការអនុម័តថ្មីនៅក្នុងតំបន់ ដែលរួមបញ្ចូលទាំងគម្រោងនានាពីមូលនិធិ CTF, មូលនិធិបន្សាំ, GEF និងមូលនិធិប្រទេសអភិវឌ្ឍន៍តិចតួច (Watson និង Schalatek ឆ្នាំ២០២០)។

លក្ខណៈសំខាន់ៗនៃ GCF រួមមាន វិធីសាស្ត្រជំរុញប្រទេសរបស់ខ្លួន។ ប្រទេសនីមួយៗមានអាជ្ញាធរជាតិទទួលបន្ទុក (NDA) ដែលជាញឹកញាប់ ជាក្រសួងហិរញ្ញវត្ថុ ឬបរិស្ថាន ដែលមានជនបង្គោលដែលត្រូវបានចាត់តាំង ដើម្បីធ្វើជាអ្នកតំណាងរវាង NDA និង GCF។ NDAs ដើរតួជា "ស្ថាប័នទំនាក់ទំនងដោយផ្ទាល់" របស់ប្រទេសនីមួយៗជាមួយ GCF និងជាមូលដ្ឋានគ្រឹះនៃដំណើរការមូលនិធិ GCF និងវិធីបំពេញការងារ ចាប់ពីការទទួលបានជំនួយគាំទ្រការត្រៀមខ្លួន រហូតដល់ការចុះហត្ថលេខាលើរាល់សំណើរថវិកា ដែលបានដាក់ជូនក្រុមប្រឹក្សាភិបាល GCF ជាមួយនឹងសកម្មភាពសម្រាប់ប្រទេសនោះ (គេហទំព័រ GCF)។

---

ប្រកចូលសំខាន់មួយសម្រាប់អង្គការដែលផ្តោតលើស្ត្រី គឺត្រូវចូលរួមជាមួយ NDA និង DAEs ។ ការណ៍នេះគួរតែផ្តល់នូវការយល់ដឹងអំពីអ្វីដែលសំណើកំពុងត្រូវបានបង្កើតឡើង និងដើម្បីអាចមានឥទ្ធិពលដូចគ្នា។ អង្គការដែលផ្តោតលើស្ត្រី ក៏អាចធ្វើជាដៃគូជាមួយពួកគេសម្រាប់ជំនួយបច្ចេកទេសនិងជំនួយក្រោមកម្មវិធីត្រៀមខ្លួន។

---

GCF បញ្ចេញថវិកាតាមរយៈប្រព័ន្ធដែលត្រូវបានទទួលស្គាល់ ដែលអង្គការណាមួយដាក់សំណើរសុំ មូលនិធិត្រូវតែជាអង្គភាពដែលត្រូវបានទទួលស្គាល់ (AE) (គេហទំព័រ GCF)។ ប្រព័ន្ធនេះត្រូវបានរៀបចំឡើងដើម្បីធានាថា AEs ជាពិសេស អង្គភាពដែលធ្វើការនៅថ្នាក់ជាតិ "មានប្រភេទចំណេះដឹងនិងបទពិសោធន៍ជំនាញ ដែលអាចប្រើប្រាស់បានល្អបំផុតក្នុងការកៀរគរហិរញ្ញវត្ថុអាកាសធាតុនៅក្នុងប្រទេសរបស់ខ្លួន"។ AE ដែលអាចជាស្ថាប័ន ឯកជន សាធារណៈ មិនមែនរដ្ឋាភិបាល ក្នុងតំបន់ ឬថ្នាក់ជាតិនៅក្នុងវិសាលភាពនិងប្រតិបត្តិការរបស់ពួកគេអាចត្រូវបានចាត់ទុកថាជាផ្នែកមួយនៃប្រភេទពីរផ្សេងគ្នាដូចខាងក្រោម៖

ក) អង្គភាពចូលដំណើរការដោយផ្ទាល់ (DAE) - អង្គការថ្នាក់ក្រោមជាតិ ថ្នាក់ជាតិ ឬថ្នាក់តំបន់ ដែលចាំបាច់ត្រូវតែងតាំងដោយ NDA ឬជនបង្គោលនៃប្រទេសកំពុងអភិវឌ្ឍន៍ ដែលអាចមានសិទ្ធិទទួលបានការគាំទ្រការត្រៀមខ្លួនរបស់ GCF។

ខ) អង្គភាពចូលដំណើរការជាអន្តរជាតិ (IAE) - ទីភ្នាក់ងាររបស់អង្គការសហប្រជាជាតិ ធនាគារអភិវឌ្ឍន៍ ពហុភាគី និងស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ ដែលមិនចាំបាច់ត្រូវបានតែងតាំងដោយ NDA ណាមួយឡើយ។

ជាផ្នែកមួយនៃដំណើរការទទួលស្គាល់ លេខាធិការដ្ឋាន GCF ក៏បានវាយតម្លៃពី "សមត្ថភាពឆ្លើយតបនឹងតម្រូវការយេនឌ័រ" របស់អ្នកដាក់ពាក្យសុំ ដោយធានាថា AEs ទាំងអស់ មានកំណត់ត្រាឃ្លាំមើលត្រឹមត្រូវ និងមានសមត្ថភាពអនុវត្តតាមគោលនយោបាយយេនឌ័រ GCF។

GCF មានគោលជំហរតែមួយគត់ ដែលជា "យន្តការហិរញ្ញវត្ថុអាកាសធាតុដំបូងគេ ក្នុងការបញ្ជ្រាបទស្សនវិស័យយេនឌ័រតាំងពីដំបូងនៃប្រតិបត្តិការរបស់ខ្លួន ដែលជាសមាសធាតុនៃការធ្វើសេចក្តីសម្រេចដ៏សំខាន់សម្រាប់ការដាក់ពង្រាយធនធានរបស់ខ្លួន" (Hall, Granat និង Daniel ឆ្នាំ២០១៩)។ ឧបករណ៍គ្រប់គ្រងសម្រាប់ GCF រួមបញ្ចូលទាំងឯកសារយោងជាច្រើនទាក់ទងនឹងយេនឌ័រនិងស្ត្រីនៅក្នុងអភិបាលកិច្ចរបស់មូលនិធិនិងបែបបទប្រតិបត្តិការ រួមមានការចូលរួមរបស់ភាគីពាក់ព័ន្ធ និងការជំរុញអាណត្តិបញ្ជ្រាបយេនឌ័រឱ្យបានលេចធ្លោក្រោមគោលបំណងផ្តល់មូលនិធិ និងគោលការណ៍ណែនាំ។ ឧបករណ៍នេះតម្រូវឱ្យមានតុល្យភាពយេនឌ័រសម្រាប់បុគ្គលិក និងក្រុមប្រឹក្សាភិបាលរបស់ខ្លួន (Liane Schalatek ឆ្នាំ២០១៩)។

---

អង្គការដែលផ្តោតលើស្ត្រីក៏អាចស្វែងរកការទទួលស្គាល់ ដូច្នេះពួកគេអាចដាក់គម្រោងជា AEs ដែលអាចផ្តល់កម្មសិទ្ធិក្នុងការរៀបចំ និងអនុវត្តគម្រោង ដូច្នេះវាមានភាពបត់បែន កាន់តែច្រើននៅក្នុងវិសាលភាពនៃការស្នើសុំពេលវេលានិងសហប្រតិបត្តិករ។

---

គោលនយោបាយយេនឌ័រនិងផែនការសកម្មភាពយេនឌ័រលើកដំបូង (ឆ្នាំ២០១៥-២០១៧) របស់ GCF ត្រូវបានអនុម័តនៅក្នុងខែមីនា ឆ្នាំ២០១៥។ នៅក្នុងខែវិច្ឆិកា ឆ្នាំ២០១៩ ក្រុមប្រឹក្សាភិបាល GCF ក៏បានអនុម័ត គោលនយោបាយ និងផែនការសកម្ម

ភាពយេនឌ័រ ដែលបានធ្វើបច្ចុប្បន្នភាព (GAP ឆ្នាំ២០២០-២០២៣)។ គោលនយោបាយ (ឆ្នាំ ២០១៩) ពង្រឹងការប្តេជ្ញាចិត្តរបស់ GCF ដើម្បីលើកកម្ពស់សមភាពយេនឌ័រនៅទូទាំងសកម្មភាពនិងក្របខ័ណ្ឌស្ថាប័ន។ ផែនការសកម្មភាពយេនឌ័រ (ឆ្នាំ២០១៩) នេះ បង្ហាញពីវិស័យអាទិភាពចំនួន ៥ សម្រាប់ការបញ្ជ្រាបយេនឌ័រ ដែលគ្របដណ្តប់លើទិដ្ឋភាពដូចខាងក្រោម៖

**វិស័យអាទិភាពទី ១ ៖ អភិបាលកិច្ច**

ធានាឱ្យមានសមភាពយេនឌ័រ និងរួមបញ្ចូលទាំងសមត្ថភាពយេនឌ័រនៅក្នុងស្ថាប័នប្រឹក្សាយោបល់និងការធ្វើការសេចក្តីសម្រេចចិត្តសំខាន់ៗទាំងអស់រួមមានក្រុមប្រឹក្សាដែលត្រូវបានទទួលស្គាល់ ក្រុមប្រឹក្សាបច្ចេកទេសឯករាជ្យ និងលេខាធិការដ្ឋាន។ GCF ក៏នឹងជួយពង្រឹងអាជ្ញាធរជាតិទទួលបន្ទុក (NDAs) និងជនបង្គោល និងអង្គភាពដែលត្រូវបានទទួលស្គាល់ (AEs) សម្រាប់ការបន្ត GAP តាមរយៈកម្មវិធីគាំទ្រការត្រៀមខ្លួន និងការបម្រុងទុក។

GCF មានសមាសភាពកសាងសមត្ថភាព ដែលជាកម្មវិធីត្រៀមខ្លួន និងការបម្រុងទុករបស់ខ្លួន ដើម្បីជួយប្រទេសនានាឱ្យត្រៀមខ្លួន ក្នុងការធានាបាន និងគ្រប់គ្រងហិរញ្ញវត្ថុអាកាសធាតុដែល អាចត្រូវបានប្រើសម្រាប់លើកកម្ពស់ហិរញ្ញវត្ថុអាកាសធាតុដែលឆ្លើយតបនឹងយេនឌ័របានប្រសើរជាងមុន។ នៅក្នុងឆ្នាំ ២០១៧ GCF បានអនុម័តគម្រោងសាកល្បងលើដំណើរការអនុម័តសាមញ្ញ (SAP) សម្រាប់សកម្ម ភាពខ្នាតតូច (១០ លានដុល្លារអាមេរិកឬតិចជាងនេះ បានស្នើសុំពីGCF) និងលើកកម្ពស់ដំណើរការពិនិត្យ និងអនុម័ត។ NDAs ក៏ដូចជា អង្គភាពដែលត្រូវបានទទួលស្គាល់ អាចបញ្ជូនឯកសារទស្សនទាន SAP។

អង្គការដែលផ្តោតលើស្ត្រីអាចជំរុញទំនាក់ទំនងទាំងនេះឱ្យក្លាយជាដៃគូក្នុងការបង្កើតគំនិតផ្តួចផ្តើមដែលមានទំហំតូចជាងនេះ។

**វិស័យអាទិភាពទី ២ ៖ សមត្ថភាព និងការអភិវឌ្ឍន៍សមត្ថភាព**

វិស័យនេះនឹងផ្តោតលើការបង្កើនការយល់ដឹងអំពីគោលនយោបាយយេនឌ័រ និង GAP ព្រមទាំងការបណ្តុះបណ្តាល NDAs/ជនបង្គោល AEs និងដៃគូចែកចាយ អំពីវិធីបកស្រាយ និងដំណើរការឧបករណ៍យេនឌ័រ និងការប្រែប្រួលអាកាសធាតុរបស់ GCF។

អង្គការដែលផ្តោតលើស្ត្រីអាចចូលរួមជាមួយ NDAs / ជនបង្គោល និងអង្គភាពដែលត្រូវបានទទួលស្គាល់ដើម្បីផ្តល់សមត្ថភាព និងជំនាញបច្ចេកទេសស្តីពីយេនឌ័រ ការប្រែប្រួលអាកាសធាតុ និងឆ្ពោះទៅសម្រេចបាន GAP។

**វិស័យអាទិភាពទី ៣ ៖ ការបែងចែកធនធាន លទ្ធភាពទទួលបាន និងការរៀបចំថវិកា**

ជាផ្នែកមួយនៃវិស័យអាទិភាពនេះ GCF នឹងតម្រូវឱ្យ AEs ដាក់សំណើមូលនិធិ ដែលមានការវាយតម្លៃយេនឌ័រ និងផែនការសកម្មភាពយេនឌ័រកម្រិតគម្រោង ដែលរួមមានថវិកាអនុវត្ត។

អង្គការដែលផ្តោតលើស្ត្រីអាចចូលរួមជាមួយអង្គភាពដែលត្រូវបានទទួលស្គាល់សម្រាប់ការធ្វើវិភាគយេនឌ័រនិងផ្តល់សមត្ថភាព និងការរៀបចំ ជំនាញបច្ចេកទេសនៃសំណើគម្រោងដែលឆ្លើយតបនឹងតម្រូវការយេនឌ័រ និង GAP កម្រិតគម្រោង។

**វិស័យអាទិភាពទី ៤ ៖ នីតិវិធីប្រតិបត្តិ**

AEs នឹងតម្រូវឱ្យធ្វើការវាយតម្លៃយេនឌ័រដំបូងជាចាំបាច់ និងបង្កើតផែនការសកម្មភាពយេនឌ័រកម្រិតគម្រោង ដែលបំពេញបន្ថែមទៅនឹងលក្ខខណ្ឌតម្រូវនៃការការពារបរិស្ថាន និងសង្គម (ESS)។

ការពឹងទុកសម្រាប់ការប៉ាន់ប្រម៉ាណយេនឌ័រគឺជាផ្នែកមួយនៃគំរូឯកសារទស្សនទាននិងឯកសារណែនាំគំរូសំណើគម្រោងពេញលេញ។ គំរូសំណើគម្រោង GCF តម្រូវឱ្យអង្គភាពពិពណ៌នាអំពីកម្មវិធីយេនឌ័ររបស់គម្រោង បញ្ជូនការប៉ាន់ប្រម៉ាណយេនឌ័រ និងសង្គមឱ្យបានទូលំទូលាយបានគ្រប់គ្រាន់ដើម្បីបង្ហាញពីតម្រូវការខុសៗគ្នារបស់បុរស និងស្ត្រី និងក្មេងប្រុស និងក្មេងស្រី មនុស្សចាស់និងក្រុមសង្គមដទៃទៀតហើយជាញឹកញាប់រួមមានផែនការសកម្មភាពរួមបញ្ចូលយេនឌ័រ និងសង្គម (GAP)។

លើសពីនេះទៀត ការចូលរួម និងការពិគ្រោះយោបល់អំពីសមភាពយេនឌ័រ និងការរួមបញ្ចូលភាគីពាក់ព័ន្ធ នឹងចាំបាច់ត្រូវធ្វើឡើងនិងចងក្រងជាឯកសារនៅទូទាំងការរៀបចំនិងការអនុវត្តគម្រោង/កម្មវិធី។

អង្គការដែលផ្តោតលើស្ត្រី គួរតែជាផ្នែកមួយ និងជួយសម្រួលដល់ការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធទាំងនោះ។

**វិស័យអាទិភាពទី ៥ ៖ ការបង្កើតចំណេះដឹង និងការទំនាក់ទំនង**

វិស័យអាទិភាពនេះគួរមានការផ្តោតជាពិសេសលើការអភិវឌ្ឍ និងការផ្សព្វផ្សាយពីសម្ភារៈទំនាក់ទំនងស្តីពីយេនឌ័រ និងការប្រែប្រួលអាកាសធាតុសម្រាប់ភាគី ពាក់ព័ន្ធទាំងអស់ រួមទាំងសកម្មភាពផ្សព្វផ្សាយជាសាធារណៈនៅថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន។ GAP ក៏ផ្តោតលើយុទ្ធនាការពហុព័ត៌មានថ្នាក់ជាតិស្តីពីយេនឌ័រ និងការប្រែប្រួលអាកាសធាតុ។

អង្គការដែលផ្តោតលើស្ត្រីអាចចូលរួមជាមួយក្រុមការងារជាក់លាក់របស់ប្រទេស ដែលជាផ្នែកដ៏សកម្មមួយនៃយុទ្ធនាការ និងសកម្មភាពផ្សព្វផ្សាយទាំងនេះ។

GCF ក៏មានក្រុមសង្គមស៊ីវិលជាច្រើនដែលពិនិត្យតាមដានមូលនិធិនេះផងដែរ ហើយធាតុចូលរួមគ្នារបស់ក្រុមទាំងនោះ មាន

ទំងន់ចំពោះអ្នកធ្វើសេចក្តីសម្រេចចិត្តនិងអ្នកអនុវត្ត។ អ្នកសង្កេតការណ៍សកម្មពីររូបដែលត្រូវបានជ្រើសរើសដោយសង្គមស៊ីវិល ដើម្បីតំណាងឱ្យប្រទេសកំពុងអភិវឌ្ឍ និងប្រទេសអភិវឌ្ឍ អាចឡើងថ្លែងការណ៍នៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សាភិបាលបាន។ លើសពីនេះទៀតប្រព័ន្ធអង្គការថ្នាក់ជាតិសម្រាប់ GCF គួរតែពិគ្រោះយោបល់ និងចូលរួមជាមួយសង្គមស៊ីវិល ទោះបីជាបទពិសោធន៍បង្ហាញថាការចូលរួមនេះមានភាពខុសគ្នាយ៉ាងច្រើនទៅតាមប្រទេស (WEDO ឆ្នាំ២០១៧)។

---

អង្គការដែលផ្តោតលើស្ត្រីអាចក្លាយជាអ្នកសង្កេតការណ៍ផ្លូវការរបស់ GCF ដោយដាក់ពាក្យសុំឋានៈជាអ្នកសង្កេតការណ៍នៅពេលមានការអំពាវនាវឱ្យមានការទទួលស្គាល់ជាទៀងទាត់។

---

### អង្គការដែលផ្តោតលើស្ត្រី និងហិរញ្ញវត្ថុអាកាសធាតុ ៖ យុទ្ធសាស្ត្រ និងឧទាហរណ៍បន្ថែមសម្រាប់ការចូលរួម

ទំនាក់ទំនងជាមួយក្រសួងបរិស្ថាន និងក្រសួងប្រែប្រួលអាកាសធាតុ៖ អង្គការដែលផ្តោតលើស្ត្រីជាទូទៅ ចូលរួមជាមួយក្រសួងយេនឌ័រ ឬកិច្ចការនារី។ ទោះយ៉ាងណា អង្គភាពរដ្ឋាភិបាលដែលត្រួតពិនិត្យលើហិរញ្ញប្បទានអាកាសធាតុ និងអ្នកតំណាងឱ្យមូលនិធិ ជាទូទៅ គឺក្រសួងបរិស្ថាន ឬហិរញ្ញវត្ថុ។ វាមានសារៈសំខាន់ណាស់សម្រាប់អង្គការដែលផ្តោតលើស្ត្រីក្នុងការភ្ជាប់ការងាររបស់ពួកគេជាមួយក្រសួងពាក់ព័ន្ធ។

ចូលរួមក្នុងការពិគ្រោះយោបល់សាធារណៈ៖ គោលនយោបាយ និងច្បាប់ស្តីពីបរិស្ថាននៅក្នុងប្រទេស/មូលនិធិជាច្រើនអំពាវនាវឱ្យមានដំណើរការពិគ្រោះយោបល់សាធារណៈ ដែលជាផ្នែកមួយនៃដំណើរការការពារបរិស្ថាន និងសង្គម។ CSOs អាចរៀបចំផែនការដំណើរការបែបនេះនៅក្នុងប្រទេសរបស់ពួកគេជាពិសេសស្វែងយល់អំពីរបៀប និងពេលវេលាដែលការពិគ្រោះយោបល់ត្រូវបានផ្សព្វផ្សាយជាសាធារណៈ។ព័ត៌មាននេះអាចត្រូវបានប្រើដើម្បីផ្សព្វផ្សាយព័ត៌មានអំពីដំណើរការពិគ្រោះយោបល់ក្នុងចំណោមស្ត្រី និងលើកទឹកចិត្តបន្ទាប់មកឱ្យចូលរួមក្នុងដំណើរការទាំងនេះ។ CSOs អាចចូលរួមដោយផ្ទាល់ក្នុងដំណើរការទាំងនេះ និងបង្ហាញពីកង្វល់យេនឌ័រនៅក្នុងគម្រោងនាពេលខាងមុខ។

ចូលរួមជាមួយបណ្តាញអង្គការមិនមែនរដ្ឋាភិបាលនិងវេទិកា CSO ទាក់ទងនឹងមូលនិធិអាកាសធាតុផ្សេងៗគ្នា៖ អង្គការសង្គមស៊ីវិលដែលអនុវត្តការងាររបស់មូលនិធិបន្សាំ បានធ្វើការងារជាផ្លូវការរបស់ខ្លួនតាមរយៈបណ្តាញអង្គការមិនមែនរដ្ឋាភិបាលមូលនិធិបន្សាំ។ នៅក្នុងឆ្នាំ១៩៩៥ បណ្តាញ GEF CSO ត្រូវបានបង្កើតឡើង។ GEF រៀបចំកិច្ចប្រជុំពិគ្រោះយោបល់ជាទៀងទាត់ជាមួយបណ្តាញមុនពេលកិច្ចប្រជុំក្រុមប្រឹក្សា GEF និងបណ្តាញ GEF CSO ក៏មានការប្រជុំថ្នាក់តំបន់ និងសិក្ខាសាលាពង្រីកការងារសង្គម (Expanded Constituency Workshops) ដើម្បីពង្រឹងចំណេះដឹងអ្នកចូលរួមអំពី GEF ផងដែរ។ មានបញ្ជីសំបុត្ររួមរបស់ GCF-CSO ដែលគាំទ្រដល់ CSOs ឱ្យនៅទន្ទឹមគ្នានឹងការអភិវឌ្ឍន៍ GCF និងពិនិត្យ ព្រមទាំងផ្តល់យោបល់លើគោលនយោបាយ និងនីតិវិធីដែលបានស្នើឡើង ក៏ដូចជាសំណើមូលនិធិ និងពាក្យសុំសម្រាប់ការទទួលស្គាល់។ អង្គការដែលផ្តោតលើស្ត្រីគួរចូលរួមក្នុងវេទិកាដែលបានផ្តល់ឱ្យទាំងនេះដើម្បីចាប់ផ្តើម។

ការបង្កើតសហគមន៍ហិរញ្ញវត្ថុអាកាសធាតុ៖ នៅក្នុងខែមេសា ឆ្នាំ២០១៨ មជ្ឈមណ្ឌលធនធាន Prakriti ក្នុងប្រទេសនេប៉ាល់ បានរៀបចំ "កម្មវិធីតម្រង់ទិសស្តីពីយេនឌ័រ និងហិរញ្ញវត្ថុអាកាសធាតុ" ដែលមានសមាជិកសន្ទនាអាកាសធាតុ និងអភិវឌ្ឍន៍។ កម្មវិធីនេះរួមមានព័ត៌មានស្តីពីការប្រែប្រួលអាកាសធាតុនៅប្រទេសនេប៉ាល់ ហិរញ្ញវត្ថុអាកាសធាតុ និង GCF ការរួមបញ្ចូលយេនឌ័រទៅក្នុងការប្រែប្រួលអាកាសធាតុ និងតួនាទី NDA របស់ប្រទេសនេប៉ាល់។ នៅក្នុងខែឧសភា ឆ្នាំ ២០១៩ អង្គការឃ្លាំមើលអាកាសធាតុប្រទេសថៃនិងបណ្តាញអាកាសធាតុប្រទេសថៃ បានជួបជុំគ្នានៅក្នុងកិច្ចពិភាក្សា CSO ជាមួយអាជ្ញាធរជាតិទទួលបន្ទុករបស់ប្រទេសថៃ គឺក្រសួងធនធានធម្មជាតិ និងបរិស្ថាន។ គោលបំណងនៃកិច្ចប្រជុំនេះ គឺដើម្បីពិភាក្សាអំពីយន្តការចូលរួមរបស់ CSO ដើម្បីឱ្យអង្គការសង្គមស៊ីវិល អាចចូលរួមក្នុងការរៀបចំ និងតាមដានគម្រោងរបស់ GCF។ នៅក្នុងខែសីហាឆ្នាំ២០១៨ វេទិកាអាស៊ីប៉ាស៊ីហ្វិកស្តីពីស្ត្រី ច្បាប់ និងការអភិវឌ្ឍ (APWLD) បានអញ្ជើញអង្គការដែលផ្តោតលើស្ត្រីនៅមូលដ្ឋាន ឱ្យដាក់ពាក្យសុំជំនួយរហូតដល់ ៣.០០០ ដុល្លារ ដើម្បីរៀបចំសិក្ខាសាលា/ការសន្ទនា រវាងភាគីពាក់ព័ន្ធថ្នាក់ជាតិរបស់ GCF ជាច្រើន (សមាជិកក្រុមប្រឹក្សាភិបាលរបស់ GCF លេខាធិការដ្ឋានរបស់ GCF ការតាមដាន CSO របស់ GCF អាជ្ញាធរជាតិទទួលបន្ទុក និងជនបង្គោលនៃប្រទេស នាយកដ្ឋាន និងអង្គការ គម្រោងជាក់លាក់ អង្គភាពដែលត្រូវបានទទួលស្គាល់ និងចូលដំណើរការដោយផ្ទាល់របស់ GCF និងអង្គការមិនមែនរដ្ឋាភិបាលពាក់ព័ន្ធដទៃទៀត ដែលគាំទ្រ GCF)។ អ្នកផ្តល់ជំនួយត្រូវបានគាំទ្រដល់ការបណ្តុះបណ្តាលក្នុងតំបន់ដើម្បីជំរុញការងាររបស់ពួកគេ។ ការរៀបចំ ក៏ដូចជាការចូលរួមក្នុងព្រឹត្តិការណ៍បែបនេះអាចជួយបង្កើនការយល់ដឹងនិងសមត្ថភាពរបស់អង្គការសង្គមស៊ីវិលអំពីរបៀបចូលរួមជាមួយ GCF ។

**ចំណុចពិភាក្សា**

សួរអ្នកចូលរួមថាតើពួកគេដឹងអំពីយន្តការហិរញ្ញវត្ថុបន្សាំដែលសកម្មនៅក្នុងប្រទេសរបស់ពួកគេនិងអង្គភាពដែលកំពុងអនុវត្តគម្រោង ក្នុងនាមមូលនិធិ (ជាអង្គភាពដែលត្រូវបានទទួលស្គាល់ជាស្ថាប័នអនុវត្តថ្នាក់ជាតិ។ ល។ យោងតាមមូលនិធិនេះ) ដែរឬទេ។ សួរពួកគេថាតើពួកគេស្គាល់អ្នកណាជាជនបង្គោលយេនឌ័របច្ចុប្បន្ននេះដែរឬទេ ប្រសិនបើពួកគេមានទំនាក់ទំនងគ្នា ឬជាផ្នែកមួយនៃដំណើរការពិគ្រោះយោបល់ណាមួយ? ស្នើពួកគេឱ្យចែករំលែកពីឧទាហរណ៍នៃបទពិសោធន៍ដែលពួកគេមានតាមរយៈការចូលរួមដោយជោគជ័យជាមួយភាគីពាក់ព័ន្ធណាមួយសម្រាប់ការរួមបញ្ចូលយេនឌ័រ?

តម្រុយសម្រាប់អ្នកសម្របសម្រួល

**តារាងទី ២៣ តម្រុយសម្រាប់អ្នកសម្របសម្រួល**

| មូលនិធិ | បង់ក្លាដែស | កម្ពុជា | វៀតណាម | ឥណ្ឌា | ឥណ្ឌូណេស៊ី |
|---|---|---|---|---|---|
| AF- DA | លេខាធិការ ក្រសួងបរិស្ថាន ព្រៃឈើ និងការប្រែប្រួលអាកាសធាតុ | អគ្គនាយករង ក្រសួង បរិស្ថាននៃព្រះរាជាណាចក្រកម្ពុជា | អនុរដ្ឋមន្ត្រី ក្រសួងធនធានធម្មជាតិ និងបរិស្ថាន | លេខាធិការរួម (ការប្រែប្រួលអាកាសធាតុ) ក្រសួងបរិស្ថាន និងព្រៃឈើ | អគ្គនាយកនៃការប្រែប្រួលអាកាសធាតុ ក្រសួងបរិស្ថាន និងរុក្ខាប្រមាញ់សាធារណរដ្ឋឥណ្ឌូនេស៊ី |
| AF-NIE | | | | ធនាគារជាតិសម្រាប់កសិកម្ម និងអភិវឌ្ឍន៍ជនបទ (NABARD) | ភាពជាដៃគូសម្រាប់កំណែទម្រង់អភិបាលកិច្ចនៅក្នុងប្រទេសឥណ្ឌូនេស៊ី (Kemitraan) |
| CIF-ទីភ្នាក់ ងារ | ធនាគារអភិវឌ្ឍន៍អាស៊ី | ធនាគារអភិវឌ្ឍន៍អាស៊ី | ធនាគារអភិវឌ្ឍន៍អាស៊ី | ធនាគារអភិវឌ្ឍន៍អាស៊ី | ធនាគារអភិវឌ្ឍន៍អាស៊ី |
| CIF-ជនបង្គោល | ជនបង្គោល យេនឌ័រនៅក្នុងនាយកដ្ឋាន/ផ្នែកការប្រែប្រួលអាកាសធាតុជាតិ | | | | ជនបង្គោល យេនឌ័រនៅក្នុងនាយកដ្ឋាន / ផ្នែកការប្រែប្រួលអាកាសធាតុជាតិ |
| GCF- NDA | ផ្នែកទំនាក់ទំនងសេដ្ឋកិច្ចក្រសួងហិរញ្ញវត្ថុ | | | ក្រសួងបរិស្ថាន ព្រៃឈើ និងការប្រែប្រួលអាកាសធាតុ | |
| GCF- DAEs | 1. IDCOL<br>2. PKSF | | | 1. NABARD<br>2. SIDBI | |

4:00:00

# វគ្គ ខ៖ ការរៀបចំថវិកាដែលឆ្លើយតបនឹងតម្រូវការយេនឌ័រ (GRB) សម្រាប់ហិរញ្ញវត្ថុអាកាសធាតុ

**ទិដ្ឋភាពទូទៅ**

នៅចុងបញ្ចប់នៃវគ្គនេះអ្នកចូលរួមគួរយល់ដឹងអំពីទស្សនទាននៃការរៀបចំថវិកាដែលឆ្លើយតបនឹងតម្រូវការយេនឌ័រ (GRB) និងភាពអាចអនុវត្តបានរបស់ការរៀបចំនេះនៅក្នុងវិស័យហិរញ្ញវត្ថុអាកាសធាតុក្នុងស្រុក។ ឧបករណ៍ GRB ដែលអាចត្រូវបានអនុវត្តក្នុងវិស័យនេះ នឹងត្រូវបានពិភាក្សាដោយសង្ខេប ខណៈដែលអ្នកចូលរួមគួរមានការយល់ដឹងកាន់តែស៊ីជម្រៅអំពីឧបករណ៍ដែលត្រូវបានជ្រើសរើស ដែលពួកគេអាចអនុវត្តសម្រាប់ការតស៊ូមតិអំពីការប្ដេជ្ញាចិត្តចំពោះគោលនយោបាយបន្សាំនឹងការប្រែប្រួលអាកាសធាតុដែលឆ្លើយតបនឹងតម្រូវការយេនឌ័រ និងថវិកា។

**មាតិកា**

ក) ទិដ្ឋភាពទូទៅនៃការរៀបចំថវិកាដែលឆ្លើយតបនឹងតម្រូវការយេនឌ័រ
ក. ទស្សនទាន និងសារៈសំខាន់នៃការបញ្ជ្រាបយេនឌ័រក្នុងការរៀបចំថវិកា
ខ. វឌ្ឍនភាពស្ដីពី GRB ក្នុងតំបន់អាស៊ី
គ. ការចូលរួមរបស់អង្គការសង្គមស៊ីវិល (CSO) ក្នុងដំណើរការ GRB
ខ) ការអនុវត្ត GRB ក្នុងហិរញ្ញវត្ថុអាកាសធាតុ
ក. សំណួរគន្លឹះ និងយុទ្ធសាស្ត្រសម្រាប់សម្រាប់ CSOs
ខ. ក្របខ័ណ្ឌប្រាំជំហាន
គ) ឧបករណ៍ GRB និងបច្ចេកទេសជាមួយចំណុចចាប់ផ្ដើម/ច្រកចូលសម្រាប់ CSOs
ក. ការវាយតម្លៃគោលនយោបាយ
ខ. របាយការណ៍ថវិកាយេនឌ័រ
គ. ការវាយតម្លៃអ្នកទទួលផលដែលមានទស្សនៈយេនឌ័រនៃការចែកចាយសេវាសាធារណៈ និងអាទិភាពថវិកា
ឃ. ការវិភាគឧប្បត្តិហេតុសាធារណៈដែលមានទស្សនៈយេនឌ័រ
ង. ការវិភាគបែងចែកតាមភេទនៃថវិកាលើការប្រើប្រាស់ពេលវេលា
ច. ការរៀបចំថវិកាដែលមានការចូលរួម
ឃ) GRB សម្រាប់ហិរញ្ញវត្ថុអាកាសធាតុ៖ របាយការណ៍ថវិកាយេនឌ័រ និងអាកាសធាតុ

**ឯកសារ**

បទបង្ហាញជា Power Point
ឧបករណ៍ចាក់បញ្ចាំងវីដេអូនៅលើ Youtube
ក្ដារខៀន និងប៊ិចហ្វឺតធំ
ផ្ទាំងក្រដាសធំ និងប៊ិច
សំណៅឯកសារមួយច្បាប់

**តារាងពេលវេលា**

| រយៈពេល | សកម្មភាព |
|---|---|
| ៥នាទី | > ការចែករំលែកគោលបំណង ទិដ្ឋភាពទូទៅ និងមាតិកាវគ្គ។ |
| ៥នាទី | > វីដេអូស្ដីពី "តើការរៀបចំថវិកាដែលឆ្លើយតបនឹងតម្រូវការយេនឌ័រ (GRB) គឺជាអ្វី?" |
| ២០នាទី | > ចំណោទជា Power Point ស្ដីពី "ទស្សនទា និងសារៈសំខាន់នៃ GRB" (សូមមើលលំហាត់ទី២៥ និងសំណៅឯកសារទី២៣) |
| ២០នាទី | > បទបង្ហាញជា Power Point ស្ដីពី "វឌ្ឍនភាពស្ដីពី GRB ក្នុងតំបន់អាស៊ី"។ |
| ៣០នាទី | > ការពិភាក្សាជាក្រុមស្ដីពី "ការចូលរួមរបស់ CSO ក្នុងដំណើរការ GRB" ដោយប្រើប្រាស់ករណីសិក្សារបស់ប្រទេសឥណ្ឌូណេស៊ី (សូមមើលលំហាត់ទី២៦ និងសំណៅឯកសារទី២៤) |
| ៦០នាទី | > បទបង្ហាញជា Power Point ស្ដីពី "ការអនុវត្ត GRB ក្នុងហិរញ្ញវត្ថុអាកាសធាតុ"។<br>> បទបង្ហាញជា Power Point ស្ដីពី "ក្របខ័ណ្ឌប្រាំជំហានសម្រាប់ GRB"។ |
| ៣០នាទី | > បទបង្ហាញជា Power Point ស្ដីពី "ឧបករណ៍ និងបច្ចេកទេស GRB ជាមួយចំណុចចាប់ផ្ដើម/ច្រកចូលសម្រាប់ CSOs" |
| ១៥នាទី | > បទបង្ហាញជា Power Point ស្ដីពី "GRB សម្រាប់ហិរញ្ញវត្ថុអាកាសធាតុ៖ របាយការណ៍ថវិកាយេនឌ័រ និងអាកាសធាតុ" |
| ៤៥នាទី | > លំហាត់ជាក្រុមស្ដីពី "GRB និងហិរញ្ញវត្ថុសាធារណៈអាកាសធាតុ" (សូមមើលលំហាត់ទី២៧) |

**កំណត់សម្គាល់ណែនាំ**

ចែករំលែកទិដ្ឋភាពទូទៅ និងមាតិការបស់វគ្គ។ បញ្ជាក់បំភ្លឺថា នេះមិនមែនជាការបណ្តុះបណ្តាលស្តីពី GRB ពេញលេញទេ ប៉ុន្តែជាម៉ូឌុលមួយសម្រាប់ការស្វែងយល់ពីការអនុវត្ត GRB នៅក្នុងវិស័យ CCDRR។ ចូរតាមដានជាមួយវីដេអូខ្លីនេះស្តីពី "តើការរៀបចំថវិកាដែលឆ្លើយតបនឹងតម្រូវការយេនឌ័រ (GRB) គឺជាអ្វី?" ដែលផលិតដោយអង្គការUNWomenដែលអាចរកបាននៅលើគេហទំព័រhttps://www.youtube.com/watch?v=mquO-clPJYPs។ បំពេញបន្ថែមជាមួយនឹងចម្លើយ ដែលមានព័ត៌មានបន្ថែមដោយប្រើប្រាស់មាតិកាបច្ចេកទេសអំពី "ទស្សនទាន និងសារៈសំខាន់នៃ GRB" នៅក្នុងទម្រង់ជាបាឋកថា។ សរុបចំណុចពិភាក្សាដោយណែនាំសង្ខេបអំពីតួនាទីរបស់ CSOs នៅក្នុងដំណើរការ GRB (សូមមើលខាងក្រោម)។ ឥឡូវបែងចែកអ្នកចូលរួមជាក្រុមតូចៗ ដែលមានគ្នាពី ៤ ទៅ ៥ នាក់ និងផ្តល់ជូនក្រុមនីមួយៗនូវករណីសិក្សាមួយច្បាប់ដែលមានផ្តល់ជូននៅក្នុងសំណៅឯកសារទី២៤។ ផ្តល់ការណែនាំសម្រាប់ជំហានបន្ទាប់ (សូមមើលលំហាត់ទី២៦ និងសំណៅឯកសារទី២៤)។ ចូរឱ្យអ្នកចូលរួមងាកមកចូលរួមក្នុងក្រុមធំវិញ និងជំរុញឱ្យក្រុមនីមួយៗចែករំលែកចំណុចសំខាន់ៗ/យុទ្ធសាស្ត្រ/ការរៀនសូត្រចំនួនពីរ ដែលពួកគេគិតថាអាចត្រូវបានអនុវត្តនៅក្នុងការងាររបស់ពួកគេ។

ឥឡូវរៀបរាប់ទិដ្ឋភាពទូទៅដោយសង្ខេបរបស់ឧបករណ៍ និងបច្ចេកទេសទាំងអស់តាមរយៈបទ បង្ហាញជា Power Point។ ធ្វើឱ្យមានភាពច្បាស់លាស់ថា គោលបំណងនៅទីនេះ គឺគ្រាន់តែដើម្បីបង្ហាញអ្នកចូលរួមអំពីឧបករណ៍មួយចំនួនហើយមិនមែនដើម្បីរៀនសូត្រអំពីការអនុវត្តឧបករណ៍ទាំងអស់នោះទេ។បញ្ជាក់បំភ្លឺថាពួកគេនឹងរៀនសូត្រអំពីឧបករណ៍ជាក់លាក់មួយនៅចុងបញ្ចប់នៃវគ្គនេះ។ ធ្វើបទបង្ហាញក្នុងរបៀបមួយដែលពន្យល់អំពីឧបករណ៍នោះ ដូចជាឈ្មោះ ការពិពណ៌នា និងបច្ចេកទេស ខណៈដែលលើកទឹកចិត្តពួកគេឱ្យគិតអំពីការអនុវត្តដែលអាចធ្វើបាននៅក្នុងវិស័យ CCDRR។ ចូរកុំដាក់ឧទាហរណ៍នៅក្នុង Power Point។ អាចបន្ថែមឧទាហរណ៍ដោយផ្ទាល់មាត់បាន ដើម្បីបំពេញបន្ថែមជាតុចូលដល់អ្នកចូលរួម។

## ទិដ្ឋភាពទូទៅនៃការរៀបចំថវិកាដែលឆ្លើយតបនឹងតម្រូវការយេនឌ័រ (GRB)

### ទស្សនទាននៃការរៀបចំថវិកាដែលឆ្លើយតបនឹងតម្រូវការយេនឌ័រ

ការរៀបចំថវិកាដែលឆ្លើយតបនឹងតម្រូវការយេនឌ័រ ឬ GRB គឺជាវិធីសាស្ត្រមួយដើម្បីធ្វើសមាហរណកម្មគោលបំណងសមភាពយេនឌ័រជាលក្ខណៈប្រព័ន្ធទៅក្នុងគោលនយោបាយ ការរៀបចំផែនការ ការរៀបចំថវិកា ការតាមដាន ការវាយតម្លៃ និងសវនកម្មរបស់រដ្ឋាភិបាល។ វាមានគោលបំណងដើម្បីរំលេចនូវផលប៉ះពាល់ដែលចូលរួមចំណែកនៃថវិកា (ប្រាក់ចំណូលនិងការចំណាយ) ទៅលើស្ត្រី និងបុរស និងកែសម្រួល [ឬបែងចែងឡើងវិញ] នូវធនធានដើម្បីធានាថា ទាំងបុរស និងស្ត្រីទទួលបានអត្ថប្រយោជន៍ដែលស្មើគ្នាពីធនធានរបស់រដ្ឋាភិបាល (UN Women ឆ្នាំ២០២០)។ កត្តានេះតម្រូវឱ្យមាន៖

**ក) ការបង្កើតថវិកាទូទៅពីទទស្សនៈយេនឌ័រ**

GRBមានមូលដ្ឋានលើសញ្ញាណមួយដែលថាការរៀបចំថវិកាមិនមែនគ្រាន់តែជាលំហាត់គណនេយ្យប៉ុណ្ណោះទេ ប៉ុន្តែវាជាផ្នែកដ៏សំខាន់មួយនៃដំណើរការរៀបចំគោលនយោបាយ និងដំណើរការអនុវត្ត។ GRB ក្តោបវិធីសាស្ត្រគោលនយោបាយទូលំទូលាយ ដើម្បីគាំទ្រដល់រដ្ឋាភិបាលនានាក្នុងការធ្វើសមាហរណកម្មទស្សនៈយេនឌ័រទៅក្នុងថវិកាឱ្យក្លាយជាក្របខ័ណ្ឌសម្រាប់ការចំណាយសាធារណៈ។ GRB សម្លឹងឆ្ពោះទៅជះឥទ្ធិពលដល់គ្រប់កម្រិត និងដំណាក់កាលទាំងអស់នៃដំណើរការរៀបចំថវិកា ដូចជាការបង្កើតការរៀបចំផែនការ/គោលនយោបាយ/កម្មវិធីការវាយតម្លៃតម្រូវការរបស់ក្រុមគោលដៅ ការបែងចែកធនធាន ការអនុវត្តការវាយតម្លៃផលប៉ះពាល់និងការកំណត់អាទិភាពធនធាន។

**ខ) ការវិភាគការចំណាយរបស់រដ្ឋាភិបាលជាក់ស្តែងនិងប្រាក់ចំណូលទៅលើគោលនយោបាយនិងកម្មវិធីដែលឆ្លើយតបនឹងតម្រូវការយេនឌ័រ។ កត្តានេះរួមបញ្ចូលទាំងរបៀបប្រមូលប្រាក់ចំណូល និងប្រមូលប្រាក់ចំណូលពីអ្នកណា និងរបៀបដែលការចំណាយដោះស្រាយតម្រូវការ/អាទិភាពនានារបស់ស្ត្រីនិងកុមារី ធៀបទៅនឹងបុរស និងកុមារា។**

GRB វិភាគថវិកា និងជំនួយហិរញ្ញវត្ថុរបស់រដ្ឋាភិបាលដើម្បីកំណត់ផែនទីការផ្តត់ផ្គង់ជំនួយដល់អ្នកស្ថិតក្នុងតម្រូវការផ្សេងៗ និងផលប៉ះពាល់ល់ស្ត្រីនិងកុមារីធៀបនឹងបុរស និងកុមារា។ វារួមមានទាំងការវិភាគអំពីការបែងចែកថវិកា ការចំណាយសម្រាប់អាទិភាពសមភាពយេនឌ័រ ដូចដែលមានចែងក្នុងគោលនយោបាយ និងកម្មវិធីនានា និងការចំណាយលើស្ត្រី និងកុមារី។ ការណ៍នេះគ្របដណ្តប់លើការឃ្លាំមើលការប្រើប្រាស់ធនធានដែលបានបែងចែក ការវិភាគពីផលប៉ះពាល់ និងការវិភាគការកើតមានផលប្រយោជន៍ពីការចំណាយសាធារណៈ និងគោលនយោបាយពីទស្សនៈយេនឌ័រ។

**គ) ផ្តល់សកម្មភាពជាវិជ្ជមានដើម្បីដោះស្រាយតម្រូវការជាក់លាក់របស់ស្ត្រី និងអត្តសញ្ញាណយេនឌ័រផ្សេងទៀត ប្រសិនចាំបាច់**

GRB រំលេចពីការបែងចែកភេទរបស់កម្លាំងពលកម្ម និងទទួលស្គាល់របៀបដែលស្ត្រី (ជាចម្បង) ចូលរួមចំណែកដល់សេដ្ឋកិច្ចតាមរយៈការងារមិនទទួលបានប្រាក់ឈ្នួលរបស់ពួកគេក្នុងការផលិត ចិញ្ចឹម និងថែទាំ។ ដូចនេះ GRB មានបំណងធ្វើឱ្យមើលឃើញយ៉ាងច្បាស់នូវតម្រូវការ អត្ថប្រយោជន៍ និងការចូលរួមចំណែកសេដ្ឋកិច្ចរបស់បុគ្គលពីក្រុមសង្គមផ្សេងៗ ហើយធានាបានថាបញ្ហាទាំងអស់នេះត្រូវបានដោះស្រាយនៅក្នុងថវិកា។

ការរៀបចំថវិកាដែលឆ្លើយតបនឹងតម្រូវការយេនឌ័រគឺជាចំណុចចុងក្រោយនៃដំណើរការវិភាគនេះ។ វាគឺជា ថវិកាដែលទទួលស្គាល់វិសមភាពយេនឌ័រ និងគំរូនានានៅក្នុងសង្គម ហើយក្រោយមកបែងចែកប្រាក់ដើម្បីអនុវត្តគោលនយោបាយ និងកម្មវិធីដែលនឹងកែតម្រូវបញ្ហាទាំងនេះឆ្ពោះទៅរកសង្គមមួយដែលកាន់តែមានសមភាពយេនឌ័រ។

GRB អាចជាការស្រាវជ្រាវ និងឧបករណ៍តស៊ូមតិដ៏សំខាន់មួយសម្រាប់CSOsដើម្បីកំណត់ផែនទីការឆ្លើយតបនឹងតម្រូវការយេនឌ័ររបស់មូលនិធិអាកាសធាតុដែលមានស្រាប់នៅថ្នាក់ជាតិ ហើយក៏វិភាគការប្តេជ្ញាចិត្តចំពោះគោលនយោបាយបន្សាំនឹងការប្រែប្រួលអាកាសធាតុជារួមនិងតាមវិស័យចំពោះយេនឌ័រផងដែរ និងធានាថាថវិការត្រូវបានបែងចែកសម្រាប់កិច្ចការនេះនៅក្នុងក្របខ័ណ្ឌការចំណាយសាធារណៈថ្នាក់ជាតិ។

**CSOs អាចប្រើប្រាស់ GRB ដើម្បីឆ្លើយសំណួរសំខាន់ៗទាំងបីនេះ**

១. តើអាទិភាព CCDRR របស់ស្ត្រី និងក្រុមងាយរងគ្រោះផ្សេងទៀត(ជាពិសេសអ្នកដែលត្រូវបានទទួលស្គាល់ដោយគោលនយោបាយអាកាធាតុជាតិ) ក៏ត្រូវបានទទួលស្គាល់ថាជាអាទិភាពថវិកានៅក្នុងវិស័យហិរញ្ញវត្ថុអាកាសធាតុដែរឬទេ?
២. តើថវិកាដែលត្រូវបានបែងចែកសម្រាប់ស្ត្រី និងក្រុមងាយរងគ្រោះបានទៅដល់ពួកគេស្មើគ្នាដែរឬទេ?
៣. បើទោះជាប្រាក់នោះបានទៅដល់ពួកគេក្តី តើវាបានផ្លាស់ប្តូរជាវិជ្ជមាននូវតួនាទីយេនឌ័រ និង/ឬឆ្លើយតបទៅនឹងតម្រូវការនិងអាទិភាពរបស់ស្ត្រីដែរឬទេ?

## GRB៖ **មិនកំណត់ត្រឹមថវិការដ្ឋាភិបាល**

ការអនុវត្តការរៀបចំថវិកាដែលឆ្លើយតបនឹងតម្រូវការយេនឌ័រទទួលស្គាល់ថា ថវិការដ្ឋាភិបាល "គ្រប់គ្រងធនធានសំខាន់ៗ និងថារដ្ឋគឺជាកម្លាំងដ៏មានឥទ្ធិពលមួយតាមរយៈថវិការបស់ខ្លួនក្នុងការបង្កើតទិន្នផលយេនឌ័រទាំងដោយផ្ទាល់ និងដោយប្រយោល" (Sharpឆ្នាំ១៩៩៩)។GRBត្រូវបានគេមើលឃើញផ្តោតការយកចិត្តទុកដាក់លើថវិការដ្ឋាភិបាលដោយផ្អែកលើសនិទានភាពថា៖ ក)ថវិការដ្ឋាភិបាលប្រើប្រាស់ប្រាក់សាធារណៈដូច្នេះខ)ត្រូវមានគណនេយ្យភាពសាធារណៈ និង គ) ត្រូវប្រើប្រាស់សម្រាប់ប្រយោជន៍សាធារណៈ ជាពិសេសដើម្បីជួយអ្នកដែលអត់ជាងគេ និងមានតម្រូវការធនធាន/សេវាសាធារណៈជាងគេ។ ថវិការដ្ឋាភិបាលមានតួនាទីដ៏សំខាន់មួយនៅក្នុងការរបៀបចំផែនការ និងការគ្រប់គ្រងសកម្មភាពសេដ្ឋកិច្ចនិងសារពើពន្ធ។ថវិការដ្ឋាភិបាលមានមុខងារជាច្រើន ប៉ុន្តែមុខងារផ្អែកសេដ្ឋកិច្ចនិងគោលនយោបាយសារពើពន្ធថ្នាក់កណ្តាលចំនួនបីរ រួមមាន៖

- ការបែងចែកធនធាន៖ ឥទ្ធិពល និងការប្តេជ្ញាចិត្តចំពោះការផ្តល់ទំនិញនិងសេវាសាធារណៈនិងមានផលប៉ះពាល់ដ៏ធំលើថាតើតម្រូវការរបស់ស្ត្រីត្រូវបានកំណត់ថាជាអាទិភាព និងត្រូវបានផ្តល់ហិរញ្ញវត្ថុតាមរយៈថវិកាសាធារណៈឬយ៉ាងណា។
- ការបែងចែកប្រាក់ចំណូល និងទ្រព្យសម្បត្តិ៖ ការសម្រេចចិត្តអំពីថវិការដ្ឋាភិបាលមានសក្តានុពលខ្ពស់ដើម្បីផ្តល់លទ្ធភាពឱ្យមានការបែងចែក "ដោយយុត្តិធម៌" នូវប្រាក់ចំណូល និងទ្រព្យសម្បត្តិរវាងក្រុមមនុស្សផ្សេងៗ ហើយស្ត្រីក្រីក្រចាំបាច់ត្រូវស្ថិតនៅចំណុចកណ្តាលនៃការបែងចែកជាថ្មីនេះ។
- ការរក្សាស្ថិរភាពសេដ្ឋកិច្ច៖ ថវិការដ្ឋាភិបាល ជាញឹកញាប់ណែនាំនិងផ្តល់ទិសដៅឆ្ពោះទៅរកការបង្កើតការងារស្ថិរភាពថ្លៃកំណើនសេដ្ឋកិច្ចនិរន្តរភាពបរិស្ថាននិងតុល្យភាពខាងក្រៅក្នុងកម្រិតមួយ។

ដោយសារមុខងារដ៏សំខាន់ទាំងនេះនៃថវិការដ្ឋាភិបាល GRB រហូតមកដល់ពេលនេះ បានផ្តោតជាចម្បងលើថវិកាសធារណៈ បើទោះជាមានហេតុផលនានាជាទីដែលការបែងចែក និងការចូលរួមចំណែកពីធនធានផ្សេងៗគួរត្រូវបានយកពិចារណាក៏ដោយ។ ក្នុងបរិបទហិរញ្ញវត្ថុអាកាសធាតុ វាអាចមានភាពសមស្របដើម្បីបែងចែកឱ្យខុសគ្នារវាងទម្រង់ផ្សេងៗនៃមូលនិធិបរទេសដូចជាមូលនិធិមកពីមូលនិធិកម្រិតពិភពលោកនិងមូលនិធិដែលចូលមកតាមរយៈទីភ្នាក់ងារទ្វេភាគី និងពហុភាគី រួមជាមួយនឹងជំនួយអភិវឌ្ឍន៍ក្រៅបរទេស (ODA)។ កត្តានេះមានសារៈសំខាន់ខ្លាំងដោយសារថា ជំនួយបរទេសជាញឹកញាប់ត្រូវបានបង្កើតឡើងក្នុងនាមជាមូលនិធិដាច់ដោយឡែកពីគ្នា។ទាំងនេះគឺជាបណ្តាញដាច់ដោយឡែកពីគ្នាដែលត្រូវបានបង្កើតឡើងសម្រាប់លំហូរមូលនិធិរបស់ម្ចាស់ជំនួយហើយមូលនិធិមិនត្រូវបានឆ្លុះបញ្ចាំងនៅក្នុងថវិការដ្ឋាភិបាលស្តង់ដារទេ។ ឧទាហរណ៍ ប្រទេសបង់ក្លាដែសបានបង្កើតបណ្តាញដាច់ដោយឡែកមួយសម្រាប់មូលនិធិដែលពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុផ្ទាល់របស់ខ្លួន។ ប្រសិនបើ GRB ត្រូវបានកំណត់ត្រឹមមូលនិធិរដ្ឋាភិបាល នៅពេលនោះផ្នែកដ៏ធំនៃមូលនិធិអាកាសធាតុអាចមិនត្រូវបានគ្របដណ្តប់ស្ថិតក្រោមការវិភាគ GRB។ ដូច្នេះនៅក្នុងករណីនៃការឃ្លាំមើលហិរញ្ញវត្ថុអាកាសធាតុ វាមានសារៈសំខាន់ដែលថា វិសាលភាព GRBត្រូវបានពង្រីកដល់ការវិនិយោគនិងការចំណាយសាធារណៈទាំងអស់ដោយមិនគិតពីប្រភព។

## វឌ្ឍនភាព GRB នៅតំបន់អាស៊ី

ក្នុងតំបន់អាស៊ី គំនិតផ្តួចផ្តើម GRB នានាអាចត្រូវបានរកឃើញយ៉ាងហោចណាស់នៅក្នុងប្រទេសចំនួន២២ នៅថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ ឬថ្នាក់ឃុំ។ ប្រទេសមួយចំនួនដូចជាប្រទេសបង់ក្លាដែស នេប៉ាល់ ហ្វីលីពីន ឥណ្ឌា និងឥណ្ឌូណេស៊ី មានវិធីសាស្ត្រ GRB ប្រកបដោយនិរន្តរភាពសម្រាប់រយៈពេលច្រើនជាង ១០ឆ្នាំ ខណៈដែលប្រទេសផ្សេងទៀតគឺជាប្រទេសដែលទើបចាប់ផ្តើម GRB ថ្មីថ្មោង (UNESCAP ឆ្នាំ២០១៨) (UN Women ឆ្នាំ២០១៦)។តារាងទី១១បង្ហាញបន្ទាត់ពេលវេលានៅពេលដែលប្រទេសផ្សេងៗក្នុងតំបន់អាស៊ីខាងត្បូងនិងតំបន់អាស៊ីអាគ្នេយ៍បានអនុម័ត GRB។

ការពិនិត្យមើលរបស់អង្គការ UN Women ទៅលើ GRB ក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក (Kanwar ឆ្នាំ២០១៦) ផ្តល់ព័ត៌មានបន្ថែមអំពីតំបន់ដែលមានវឌ្ឍនភាព និងបញ្ហាប្រឈមរហូតមកដល់ពេលនេះនៅក្នុងការអនុវត្ត GRB។ ទាំងនេះរួមមាន៖ "ភស្តុតាងដ៏ច្បាស់លាស់នៃGRBដែលធ្វើឱ្យប្រសើរឡើងទាំងបរិមាណនិងគុណភាពនៃការបែងចែកថវិកាសមភាពយេនឌ័រ"។ សំខាន់ជាងនេះ ការងារ GRB បានធ្វើឱ្យមានភាពប្រសើរឡើងនូវប្រព័ន្ធនានាដើម្បីឃ្លាំមើលការបែងចែកនានាសម្រាប់សមភាពយេនឌ័រទៅតាមពេលវេលា"។ ប្រទេសជាច្រើនជាពិសេសក្នុងតំបន់អាស៊ីខាងត្បូងនិងអាស៊ីអាគ្នេយ៍បានមើលឃើញវឌ្ឍនភាពខ្លាំងចំពោះ GRB៖

> ប្រទេសបង់ក្លាដែស ឥណ្ឌូណេស៊ី ឥណ្ឌា និងនេប៉ាល់ មានលទ្ធភាពអាចបង្កើន GRB នៅទូទាំងវិស័យជាច្រើនតាមរយៈការរួមបញ្ចូលឧបករណ៍ជាក់លាក់នានានៅក្នុងក្របខ័ណ្ឌថវិកាដែលមានស្រាប់។ ប្រទេសទាំងនេះ ក៏បានប៉ុនប៉ងពង្រឹងយន្តការគណនេយ្យភាពផងដែរតាមរយៈការអនុម័តប្រព័ន្ធជាច្រើននិងការភ្ជាប់ថវិកាយេនឌ័រទៅនឹងយុទ្ធសាស្ត្រសវនកម្ម។

**តារាងទី២៤៖ ការអនុវត្ត GRB ក្នុងតំបន់អាស៊ីខាងត្បូង និងតំបន់អាស៊ីអាគ្នេយ៍**

| ឆ្នាំ | តំបន់អាស៊ីអាគ្នេយ៍ | តំបន់អាស៊ីខាងត្បូង |
|---|---|---|
| មុនឆ្នាំ ២០០០ | ហ្វីលីពីន (១៩៩១)<br>ស្រីលង្កា (១៩៩៧)<br>វៀតណាម (២០០០)<br>ឥណ្ឌូណេស៊ី (២០០០) | |
| មុនឆ្នាំ ២០១០ | កម្ពុជា (២០០២)<br>ម៉ាឡេស៊ី (២០០៣)<br>ឡាវ (២០០៥)<br>ទីម័រខាងកើត (២០០៨) | បង់ក្លាដែស (២០០០)<br>ប៉ាគីស្ថាន (២០០១)<br>ឥណ្ឌា (២០០២)<br>នេប៉ាល់ (២០០២)<br>អាហ្វហ្គានីស្ថាន (២០០៥) |
| ក្រោយឆ្នាំ ២០១០ | មីយ៉ាន់ម៉ា (២០១៣)<br>ថៃ | ប៊ូតង់ (២០១២)<br>ម៉ាល់ឌីវ |

> ប្រទេសហ្វីលីពីនបានដាក់ចេញបទប្បញ្ញត្តិសំខាន់មួយគឺថវិកាយេនឌ័រ និងអភិវឌ្ឍន៍ (GAD) ៥% ហើយចាប់តាំងពីពេលនោះមក ប្រទេសនេះបានពិនិត្យមើលឡើងវិញ និងកំណត់វិធីសាស្ត្រ GRB ស្នូលរបស់ខ្លួនជាបន្តបន្ទាប់ ដើម្បីបង្កើនការបែងចែកនានាសម្រាប់សមភាពយេនឌ័រ និងដើម្បីបង្កើនថវិកាឱ្យលើសពី ៥% ដើម្បីជះឥទ្ធិពល និងបញ្ជ្រាបយេនឌ័រទៅក្នុងថវិកាសាធារណៈ ៩៥% ផ្សេងទៀត។

> ក្នុងប្រទេសវៀតណាម វិស័យដែលពាក់ព័ន្ធត្រូវបានតម្រូវឱ្យបង្កើតផែនការសកម្មភាពសម្រាប់ការអនុវត្តយុទ្ធសាស្ត្រជាតិស្តីពីសមភាពយេនឌ័រហើយមូលនិធិបន្ថែមត្រូវបានបែងចែកសម្រាប់ការអនុវត្តផែនការទាំងនេះ។

ម្យ៉ាងវិញទៀតបញ្ហាប្រឈមចម្បងៗមួយចំនួនបានផ្តោតលើភាពអាចរកបាន និងប្រសិទ្ធភាពរបស់យន្តការស្ថាប័ន និងគម្លាតសមត្ថភាពរបស់វិស័យសំខាន់ៗ ព្រមទាំងកត្តាបរិបទសំខាន់ៗរួមទាំងតម្លាភាពថវិកា និងបរិយាកាសនយោបាយ។ បើទោះជាមានការកំណត់ទិន្នន័យក្តីក៏ប្រទេសជាច្រើននៅតែបែងចែកថវិកាតិចជាង១%នៃថវិកាជាតិទៅឱ្យយន្តការរបស់ស្ត្រីបើទោះជាមានបទប្បញ្ញត្តិប្រកបដោយនិរន្តរភាពស្តីពីសមភាយេនឌ័ររបស់ប្រទេសទាំងនោះក្តី (UN Women ឆ្នាំ២០១៦)។

**គន្លឹះសម្រាប់គ្រូឧទ្ទេស**

ប្រសិនបើមានពេលវេលាហើយអ្នកចូលរួមមកពីប្រទេសតែមួយ អ្នកអាចចង់ពិភាក្សាលម្អិតជាងនេះអំពីក្របខ័ណ្ឌ និងស្ថានភាព GRB ក្នុងប្រទេសនោះ។ (សូមមើលឧបសម្ព័ន្ធរបស់ប្រទេសជាក់លាក់សម្រាប់កិច្ចការដូចគ្នានេះពី "ការរៀបចំថវិកាដែលឆ្លើយតបនឹងតម្រូវការយេនឌ័រក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក៖របាយការណ៍ស្តីពីស្ថានភាព" ដែលត្រូវបានបោះពុម្ពផ្សាយដោយអង្គការ UN Women ឆ្នាំ២០១៦ ដែលអាចរកបានតាមរយៈគេហទំព័រ https://www2.unwomen.org/-/media/field%20office%20eseasia/docs/publications/2016/12/grb_report-for-web-s.pdf?la=en&vs=1520))។ ការណ៍នេះនឹងមានប្រយោជន៍ពិសេសសម្រាប់វគ្គកម្រិតខ្ពស់។

**ចំណុចពិភាក្សា**

សួរអ្នកចូលរួមថា៖ តើពួកគេដឹងទេថា គំនិតផ្ដួចផ្ដើម GRB អ្វីដែលកំពុងត្រូវបានអនុវត្តក្នុងប្រទេសរបស់ពួកគេ? តើពួកគេគិតថា សង្គមស៊ីវិលអាចដើរតួនាទីអ្វីបាននៅក្នុងដំណើរការនេះ?

**តម្រុយសម្រាប់អ្នកសម្របសម្រួល**

សូមមើល "ការរៀបចំថវិកាដែលឆ្លើយតបនឹងតម្រូវការយេនឌ័រក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិកៈ របាយការណ៍ស្ដីពីស្ថានភាព" ដែលចេញផ្សាយដោយអង្គការ UN Women (ឆ្នាំ២០១៦) ដែលអាចរកបាននៅគេហទំព័រ https://www2.unwomen.org/-/media/field%20office%20eseasia/docs/publications/2016/12/grb_report-for-web-s.pdf?la=en&vs=1520)

អង្គការសង្គមស៊ីវិល (CSOs) មានតួនាទីសំខាន់មួយដែលត្រូវធ្វើក្នុងការលើកកម្ពស់GRB ជាពិសេសនៅកម្រិតតាមវិស័យ និងកម្រិតមូលដ្ឋាន/សហគមន៍។

> CSOs អាចធ្វើការវិភាគថវិកាក្រោយហេតុការណ៍ពីទស្សនៈយេនឌ័រ និងផ្សព្វផ្សាយវាក្នុងទម្រង់សាមញ្ញមួយសម្រាប់ការលើកទឹកចិត្តឱ្យមានការពិភាក្សាជាសាធារណៈកាន់តែទូលំទូលាយ។

> CSOs អាចបណ្ដុះបណ្ដាលមន្ត្រីរដ្ឋាភិបាលអំពីការអនុវត្តឧបករណ៍និងបច្ចេកទេសសម្រាប់ការអនុវត្ត GRB។

> CSOs អាចធ្វើការងារជាមួយមន្ត្រីរដ្ឋាភិបាលតាមរយៈការផ្ដល់ព័ត៌មានមូលដ្ឋាន និងការរំលេចអំពីតម្រូវការយេនឌ័រ និងអាទិភាពរបស់ស្ត្រីសម្រាប់ការរួមបញ្ចូលក្នុងថវិកា ហើយក៏ផ្ដល់ការគាំទ្របច្ចេកទេសស្ដីពី GRB ផងដែរ។

> CSOs អាចគាំទ្រ/អនុវត្តសវនកម្មគណនេយ្យភាពសង្គម ដែលអាចពិនិត្យមើលថា តើធនធានសាធារណៈពិតជាបានទៅដល់អ្នកទទួលដោយរបៀបណា និងថាតើកិច្ចការទាំងនេះមានភាពចាំបាច់កម្រិតណានៅក្នុងសេវាសាធារណៈដែលចាំបាច់នានាសម្រាប់ស្ត្រី និងបុរស។

> CSOsអាចសហការ/ទាក់ទងជាមួយសមាជិកសភា ដើម្បីចែករំលែកការវិភាគថវិកាយេនឌ័រ និងគាំទ្រដល់ការពិនិត្យពិច័យរបស់សភាទៅលើថវិកាមកពីទស្សនៈយេនឌ័រ។

ប្រទេសឥណ្ឌូណេស៊ីគឺជាឧទាហរណ៍មួយដែល CSOs បានបង្ហាញសារៈសំខាន់របស់ខ្លួនក្នុងការអនុវត្ត GRB។ មូលនិធិអាស៊ីបាននាំមុខដ៏សំខាន់មួយក្នុងការសហការជាមួយ CSOs និងទីភ្នាក់ងាររដ្ឋាភិបាលមូលដ្ឋាន ដើម្បីពន្លឿន GRB ជាពិសេសនៅថ្នាក់ក្រោមជាតិ។ ក្រុមដែលផ្ដោតលើស្ត្រីដូចជា Koalisi និង Komnas Perempuan បានធ្វើការងារតស៊ូមតិ ដើម្បីស្នើសុំឱ្យមានការបែងចែកថវិកាជាក់លាក់និងដើម្បីកែទម្រង់វិស័យសុខាភិបាលយុត្តិធម៌និងវិស័យផ្សេងទៀតដែលរងផលប៉ះពាល់។វេទិកាឥណ្ឌូណេស៊ីដើម្បីតម្លាភាពថវិកាបានបោះពុម្ពផ្សាយការពិពណ៌នាលម្អិតនិងឧទាហរណ៍អំពីរបៀបប្រើប្រាស់ផែនការសកម្មភាពយេនឌ័រ (GAP) និងរបាយការណ៍ថវិកាយេនឌ័រ (UN Women ឆ្នាំ២០១៦)។

## ការអនុវត្ត GRB ក្នុងហិរញ្ញវត្ថុអាកាសធាតុក្នុងស្រុក

### សំណួរនិងយុទ្ធសាស្ត្រសំខាន់ៗសម្រាប់ការចូលរួមរបស់អង្គការសង្គមស៊ីវិល (CSO)

GRBបង្ហាញថាបញ្ហាយេនឌ័រអាចត្រូវបានរកឃើញ "នៅគ្រប់ទីកន្លែង" និងបង្ហាញថាមិនមានវិស័យនិងកម្មវិធីណាមួយដែលជាអព្យាក្រិតយេនឌ័រពិតប្រាកដឡើយ។ ក្នុងគោលនយោបាយ និងកម្មវិធី CCDRR ដែលមានកិច្ចព្រមព្រៀងមួយ ដែលត្រូវបានបង្កើតឡើងរួចហើយនោះពាក់ព័ន្ធនឹងតម្រូវការនិងអាទិភាពផ្សេងគ្នារបស់ស្ត្រី និងបុរស ដូច្នេះការអនុវត្ត GRB មិនត្រឹមតែមានការពាក់ព័ន្ធប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងមានភាពចាំបាច់ខ្លាំងផងដែរ។

ទោះជាយ៉ាងណា នៅពេលដំបូង វាមាសារៈសំខាន់ដែលត្រូវលើកឡើងថា ពាក្យ GRB គ្របដណ្ដប់លើសកម្មភាពដ៏ទូលំទូលាយដែលមានគោលបំណង និងការប្រើប្រាស់ផ្សេងៗគ្នា។ ដូច្នេះ មុនពេលអនុវត្ត GRB ក្នុងហិរញ្ញវត្ថុអាកាសធាតុ វាមានសារៈសំខាន់ដែលត្រូវយល់ដឹងអំពីសមាសភាពសំខាន់នៃ GRB និងរបៀបដែលវាមានការពាក់ព័ន្ធទៅនឹងហិរញ្ញវត្ថុអាកាសធាតុ។ តារាងទី២៥ ខាងក្រោម លើកឡើងពីសំណួរសំខាន់ៗដែលចាំបាច់ត្រូវឆ្លើយមុនពេលអនុវត្តការងារ GRB នៅក្នុងវិស័យហិរញ្ញវត្ថុអាកាសធាតុ។

| តារាងទី២៥៖ សំណួរ និងយុទ្ធសាស្ត្រសំខាន់ៗសម្រាប់ការចូលរួមរបស់ CSO | |
|---|---|
| **សំណួរគន្លឹះ៖ តើអ្វីនឹងជាគោលបំណងស្នូលរបស់ការងារ GRB?** | |
| **ចំណុចត្រូវពិចារណា** | **ឧទាហរណ៍អំពីយុទ្ធសាស្ត្រសម្រាប់ CSOs អនុវត្ត GRB ក្នុងវិស័យហិរញ្ញវត្ថុអាកាសធាតុក្នុងស្រុក** |
| បង្កើនការបែងចែកសម្រាប់ស្ត្រីនិងអនុក្រុមផ្សេងៗ | > អនុវត្តការវិភាគយេនឌ័រនៃវិស័យជាក់លាក់និងសកម្មភាពដែលពាក់ព័ន្ធនឹងអាកាសធាតុរបស់ពួកគេ និងកំណត់តម្រូវការជាក់លាក់របស់ក្រុមផ្សេងៗរបស់ស្ត្រី និងបុរសនៅក្នុងសហគមន៍<br>> កំណត់អាទិភាពដំណោះស្រាយលើកស្ទួយយេនឌ័រ ដែលអាចដោះស្រាយតម្រូវការ។<br>> កំណត់កម្មវិធី/ផែនការបច្ចុប្បន្នដែលអាចផ្តល់មូលនិធិដល់ដំណោះស្រាយ និងធ្វើការតស៊ូមតិជាមួយរដ្ឋាភិបាលសម្រាប់ការបង្កើនមូលនិធិ (ឬប្រសិនបើមិនមានផែនការនៅពេលនោះសម្រាប់ផែនការថ្មី ហើយក្រោយមកផ្តល់ហិរញ្ញប្បទានស៊ីគ្នាសម្រាប់ផែនការទាំងនេះ)។ |
| ធានាថា ការបែងចែកហិរញ្ញវត្ថុអាកាសធាតុដែលមានស្រាប់ត្រូវបានកំណត់ទិសដៅចំពោះគោលនយោបាយ និងកម្មវិធីដែលលើកកម្ពស់សមភាពយេនឌ័រ និងគាំទ្រដល់ក្រុមសង្គមផ្សេងៗ។ | > កំណត់ផែនទីស្ថាបត្យកម្មហិរញ្ញវត្ថុអាកាសធាតុក្នុងស្រុកថ្នាក់ជាតិ។<br>> កំណត់ក្រសួងតាមវិស័យដែលកាន់កាប់មូលនិធិភាគច្រើន ដែលទទួលបានតាមរយៈម្ចាស់ជំនួយ ឬនៅក្នុងថវិកាកម្មវិធីដែលមានស្រាប់។<br>> អនុវត្តការវាយតម្លៃដែលមានទស្សនៈយេនឌ័រនៃលំហូរមូលនិធិរបស់កម្មវិធីទាំងនេះ។<br>> កំណត់វិស័យដែលមានគម្លាត និងតស៊ូមតិជាមួយក្រសួងតាមវិស័យ ដើម្បីចាត់វិធានការវិជ្ជមានដើម្បីធានាបាននូវការចែករំលែកអត្ថប្រយោជន៍ប្រកបដោយសមធម៌។ |
| ការប៉ាន់ប្រម៉ាណផលប៉ះពាល់នៃការបែងចែកនានាលើអាទិភាពយេនឌ័រផ្សេងៗនិងតម្រូវការនានាជាពិសេសអំពីថាតើវាលើកកម្ពស់សមភាពយេនឌ័រដោយរបៀបណា។ | > កំណត់កម្មវិធីអាកាសធាតុដែលមានការបែងចែកប្រចាំឆ្នាំខ្ពស់ពី ២ ទៅ ៣ កម្មវិធី។<br>> អនុវត្តការវាយតម្លៃផលប៉ះពាល់ដែលមានទស្សនៈយេនឌ័រ<br>> ធ្វើឱ្យសាធារណៈជនអាចស្វែងរកបានការប៉ាន់ប្រម៉ាណផលប៉ះពាល់យេនឌ័រ និងប្រើប្រាស់ការប៉ាន់ប្រម៉ាណនេះដើម្បីតស៊ូមតិឱ្យមានការកែលម្អគោលនយោបាយ កម្មវិធី និងការបែងចែកថវិកាយេនឌ័រ។ |
| **សំណួរគន្លឹះ៖ តើអ្នកនឹងជាភាគីពាក់ព័ន្ធសំខាន់បំផុតដែលត្រូវចូលរួម?** | |
| **ចំណុចត្រូវពិចារណា** | **ឧទាហរណ៍អំពីយុទ្ធសាស្ត្រសម្រាប់ CSOs អនុវត្ត GRB ក្នុងវិស័យហិរញ្ញវត្ថុអាកាសធាតុក្នុងស្រុក** |
| អង្គភាពក្បាលម៉ាស៊ីនស្ត្រីថ្នាក់ជាតិ<br>> មានបទប្បញ្ញត្តិយេនឌ័រប៉ុន្តែមិនសូវមានតួនាទីខ្លាំងសម្រាប់ជះឥទ្ធិពលលើហិរញ្ញវត្ថុអាកាសធាតុ | > ធ្វើការងារជាមួយអង្គភាពក្បាលម៉ាស៊ីនស្ត្រីថ្នាក់ជាតិដើម្បីនាំយកបញ្ហា និងតម្រូវការយេនឌ័រដាក់ក្នុងរបៀបវារៈរៀបចំផែនការនិងរៀបចំថវិកា និងក្របខ័ណ្ឌ CCDRR។<br>> ចូលរួមអនុវត្ត និងរាយការណ៍អំពីអនុសាសន៍ទូទៅអនុសញ្ញា CEDAW-៣៧ (ពាក់ព័ន្ធនឹង CCDRR)។ |
| ក្រសួងហិរញ្ញវត្ថុ<br>> មានឥទ្ធិពលខ្លាំងជាង ប៉ុន្តែការយល់ដឹងអំពីយេនឌ័រ និង/ឬ CCDRR នៅមានកម្រិត។ | > ចូលរួមក្នុងការវិនិយោគអាកាសធាតុដែលមានស្រាប់ និង យន្តការត្រួតពិនិត្យការចំណាយសាធារណៈ (CIPER) ក្នុងប្រទេស និងពង្រឹងសមត្ថភាពរបស់យន្តការទាំងនេះ ដើម្បីអនុវត្តការវិភាគថវិកាយេនឌ័រ។<br>> អនុវត្តការត្រួតពិនិត្យមើលការបែងចែកដែលមានស្រាប់ និងទស្សនៈវិស័យការប្រែប្រួលអាកាសធាតុ និងបង្កើតរបាយការណ៍ថវិកាយេនឌ័រ និងអាកាសធាតុប្រចាំឆ្នាំ។ បង្ហាញការវិភាគក្នុងទម្រង់សាមញ្ញសម្រាប់ការជជែកដេញដោលសាធារណៈ ដើម្បីជះឥទ្ធិពលដល់ក្រសួងឱ្យពិចារណាក្នុងដំណើរការអនុម័តថវិកា។<br>> ធ្វើការងារជាមួយក្រសួងដើម្បីជះឥទ្ធិពលលើដំណើរការធ្វើសេចក្តីសម្រេចចិត្តអំពីថវិកាដែលមានស្រាប់ ដើម្បីធានាថា ទស្សនៈយេនឌ័រ និង CCDRR ត្រូវបានដាក់បញ្ចូលក្នុងការពិចារណា ហើយក្តីបារម្ភត្រូវបានដោះស្រាយក្នុងដំណាក់កាលរៀបចំផែនការ និងអនុវត្ត។<br>> តស៊ូមតិឱ្យមានការផ្តល់ជូនលំហស្ថាប័នសម្រាប់ការចូលរួមរបស់សាធារណៈជនក្នុងដំណើរការរៀបចំថវិកា និងការអនុម័តការរៀបចំថវិកាដែលមានការចូលរួម ដោយមានភាពជាអ្នកតំណាងយេនឌ័រដែលមានតុល្យភាព។ |

**តារាងទី២៥៖ សំណួរ និងយុទ្ធសាស្ត្រសំខាន់ៗសម្រាប់ការចូលរួមរបស់ CSO**

**សំណួរគន្លឹះ៖ តើអ្នកនឹងជាភាគីពាក់ព័ន្ធសំខាន់បំផុតដែលត្រូវចូលរួម?**

| ចំណុចត្រូវពិចារណា | ឧទាហរណ៍អំពីយុទ្ធសាស្ត្រសម្រាប់ CSOs អនុវត្ត GRB ក្នុងវិស័យហិរញ្ញវត្ថុអាកាសធាតុក្នុងស្រុក |
|---|---|
| ក្រសួងបរិស្ថាន និងក្រុមប្រឹក្សាប្រម៉ាញ់ និង/ឬការប្រែប្រួលអាកាសធាតុ<br>> មានបទប្បញ្ញត្តិការប្រែប្រួលអាកាសធាតុប៉ុន្តែការយល់ដឹងអំពីយេនឌ័រ នៅមានកម្រិត។ | > ប្រសិនបើបទប្បញ្ញត្តិថ្នាក់ជាតិមួយ និងយន្តការស្ថាប័នសម្រាប់ GRB មាននៅក្នុងប្រទេស ចូរចូលរួមក្នុងការកសាងសមត្ថភាពរបស់ក្រសួងអំពីកិច្ចការដូចគ្នានេះ។<br>> អនុវត្តការស្រាវជ្រាវ បង្កើតសេចក្តីសង្ខេបអំពីគោលនយោបាយ និងឧបករណ៍សម្រាប់ការជះឥទ្ធិពលលើការសម្រេចចិត្តអំពីថវិកា។<br>> ប្រសិនបើធនធានអាចរកបានចូលផ្តល់ជំនួយបច្ចេកទេសនិងការគាំទ្រផ្នែកបង្វឹក/បង្ហាត់បង្ហាញដោយផ្ទាល់សម្រាប់ការអនុវត្ត GRB និង/ឬ ផែនការសកម្មភាពការប្រែប្រួលអាកាសធាតុ និងយេនឌ័រ (ccGAP)។<br>> ចូលរួមក្នុងការរាយការណ៍អំពីការបែងចែកនានាសម្រាប់ផែនការសកម្មភាពយេនឌ័រUNFCCC |
| ក្រសួងសាមីតាមវិស័យ<br>> ទទួលខុសត្រូវលើការរៀបចំផែនការ ការរៀបចំថវិកា និងការអនុវត្តកម្មវិធីភាគច្រើន ដែលប៉ះពាល់ដល់យេនឌ័រ និង CCDRR ប៉ុន្តែសមត្ថភាពនៅមានកម្រិតក្នុងការធ្វើសមាហរណកម្មទស្សនៈវិស័យទាំងនេះ។<br>> ដូចគ្នានេះដែរមានក្រសួងសាមីមួយចំនួនដែលត្រូវបានទទួលស្គាល់នៅក្នុងក្របខ័ណ្ឌយេនឌ័រ និង CCDRR។ | > កំណត់ក្រសួងតាមវិស័យសំខាន់ៗដែលមានថវិកាសរុបច្រើនជាងគេ និងមានការពាក់ព័ន្ធខ្លាំងជាងគេក្នុងការដោះស្រាយបញ្ហា CCDRR។<br>> ចូលរួមជាមួយក្រសួងដែលត្រូវបានជ្រើសរើសសម្រាប់ការវិភាគថវិកានិងការកសាងសមត្ថភាពពីទស្សនៈយេនឌ័រ និង CCDRR ។ |
| សមាជិកសភា<br>> អាចដើរតួនាទីយ៉ាងសំខាន់ក្នុងការលើកឡើងបញ្ហាក្នុងការជជែកដេញដោលអំពីថវិកាព្រមទាំងក្នុងការតាមដានថវិកាយេនឌ័រតាមរយៈគណៈកម្មាធិការឯកទេស។ | > រំញោចសមាជិកសភាឱ្យយល់ដឹងអំពីតម្រូវការឱ្យមានការរៀបចំថវិកាដែលឆ្លើយតបនឹងតម្រូវការយេនឌ័រ ជាពិសេសក្នុងវិស័យ CCDRR។<br>> ផ្តល់ជូនសមាជិកសភានូវការធ្វើបច្ចុប្បន្នភាពអំពីការវិភាគថវិកានិងយេនឌ័រដើម្បីចាត់វិធានការជាបន្តនៅក្នុងការពិភាក្សាអំពីថវិកា និងគោលនយោបាយថ្នាក់ជាតិ។ |

**សំណួរគន្លឹះ៖ ឧបករណ៍ណាមួយដែលត្រូវបានប្រើប្រាស់ ហើយអ្នកណានឹងធ្វើអ្វី?**

| ចំណុចត្រូវពិចារណា | ឧទាហរណ៍អំពីយុទ្ធសាស្ត្រសម្រាប់ CSOs អនុវត្ត GRB ក្នុងវិស័យហិរញ្ញវត្ថុអាកាសធាតុក្នុងស្រុក |
|---|---|
| មានឧបករណ៍ GRB និងចំណុចចាប់ផ្តើមជាច្រើន (ដែលត្រូវបានពិភាក្សាក្នុងវគ្គបន្ទាប់) ដែលអាចត្រូវបានអនុវត្តដោយគិតពីបរិបទក្នុងប្រទេស។ ការសម្រេចចិត្តមួយត្រូវតែធ្វើឡើងអំពីថាតើឧបករណ៍ណាមួយត្រូវអនុវត្តអ្វីដែលនឹងត្រូវបង្កើតឡើង ហើយតើអ្នកណានឹងអនុវត្តការវិភាគ។ | > គោលបំណងស្នូលរបស់អ្នកនិងភាគីពាក់ព័ន្ធសំខាន់ៗជាទូទៅនឹងកំណត់ថាតើឧបករណ៍ណាមួយដែលសាកសមបំផុត។<br>> ឧបករណ៍គោលនយោបាយដែលមានទស្សនៈយេនឌ័រមានប្រសិទ្ធភាពបំផុតដើម្បីចាប់ផ្តើមធ្វើដោយសារហេតុផលចំនួនពីរ៖ ទី១ គឺថា CSOs មានបទពិសោធរួចហើយក្នុងការវិភាគគោលនយោបាយ ការអនុវត្តទស្សនៈវិស័យ GRB ពង្រឹងកិច្ចការដូចគ្នានេះជាមួយនឹងព័ត៌មានថវិកា។ ទី២គឺថាប្រទេសជាច្រើនមានគោលនយោបាយ/យុទ្ធសាស្ត្រ/ផែនការការប្រែប្រួលអាកាសធាតុសម្រាប់រយៈពេលជាក់លាក់ ហើយវាមានភាពងាយស្រួលជាងក្នុងការចូលរួម និងជះឥទ្ធិពលលើដំណើរការធ្វើបច្ចុប្បន្ន ប្រសិនបើការវិភាគអំពីប្រវត្តិត្រូវបានធ្វើឡើងរួចហើយ។<br>> CSOs ក៏អាចចូលរួមក្នុងការវាយតម្លៃផលប៉ះពាល់យេនឌ័រជាមុន ដែលប៉ាន់ប្រម៉ាណលើការឆ្លើយតបនឹងតម្រូវការយេនឌ័ររបស់គោលនយោបាយដែលស្នើឡើង មុនពេលអនុវត្តវា។<br>> ទោះជាយ៉ាងណា ប្រសិនបើឧបករណ៍គោលនយោបាយដែលមានទស្សនៈយេនឌ័រត្រូវបានអនុម័ត វានឹងមានសារៈសំខាន់ក្នុងការពិចារណាថាតើអ្នកណានឹងធ្វើការវិភាគ តើវានឹងជាកិច្ចការជំរុញអ្នកពិគ្រោះយោបល់ឬជាដំណើរការដែលមានការចូលរួមដោយមានការចូលរួមពីអ្នកបង្កើតគោលនយោបាយ តើការវិភាគនឹងត្រូវបានធ្វើឡើងដោយរបៀបណា តើនឹងប្រើប្រាស់ |

វិធីសាស្ត្របញ្ជីត្រួតពិនិត្យដែលមានភាពសាមញ្ញជាង ឬវិធីសាស្ត្រពិគ្រោះយោបល់លម្អិតជាង ហើយតើលទ្ធផលនៃការវិភាគនឹងត្រូវបានបង្កើតឡើងយ៉ាងដូចម្តេចសម្រាប់អ្នកអានកាន់តែទូលំទូលាយដើម្បីឆ្លុះបញ្ចាំងពីការវិភាគនេះ។

> របាយការណ៍ថវិកាយេនឌ័រ និងអាកាសធាតុ អាចត្រូវបានប្រើប្រាស់ជាជំហានទី២ ដើម្បីស្វែងយល់អំពីលំហូរមូលនិធិសម្រាប់ការប្តេជ្ញាចិត្តយេឌ័រក្នុងគោលនយោបាយ CCDRR។ របាយការណ៍បែបនេះ ផ្តល់ ជូនជាកម្រិតម៉ាក្រូ និងមីក្រូ និងមានសក្តានុពលខ្លាំងបំផុតដើម្បីអាចឱ្យប្រព័ន្ធផ្សព្វផ្សាយ និងសាធារណៈជនជជែកដេញដោលជុំវិញបញ្ហានេះ។ ទោះជាយ៉ាងណា ប្រសិនបើរបាយការណ៍ថវិកាយេនឌ័រ និងអាកាសធាតុ គឺជាឧបករណ៍ដែលត្រូវបានអនុម័ត បុគ្គលម្នាក់ឬស្ថាប័នមួយនឹងចាំបាច់ត្រូវពិចារណាថាតើអ្នកណាជាអ្នកបង្កើតកូដ ( coding ) តើអ្នកណាផ្តល់ព័ត៌មានសម្រាប់ការបង្កើតកូដ តើទម្រង់អ្វីនឹងត្រូវបានប្រើប្រាស់ និងតើពេលណាដែលរបាយការណ៍នឹងត្រូវបានធ្វើឡើង។

> ការពិចារណាមួយផ្សេងទៀតនៅទីនេះ នឹងជាការស្វែងយល់អំពីថាតើកិច្ចការនេះនឹងមានការពាក់ព័ន្ធនឹងការចេញផ្សាយរបាយការណ៍នៅក្នុងកន្លែងផ្ទុកឯកសារសាធារណៈ និងថាតើកិច្ចការនេះនឹងត្រូវបានចេញផ្សាយជារបាយការណ៍ស្រមោល ឬរក្សាទុកក្នុងប្រព័ន្ធរបស់រដ្ឋាភិបាល។ ការចេញផ្សាយជារបាយការណ៍ស្រមោលឬរក្សាទុកក្នុងប្រព័ន្ធរបស់រដ្ឋាភិបាលធ្វើឱ្យរបាយការណ៍ក្លាយជាឧបករណ៍ខ្លាំងមួយដែលនាំមកនូវតម្លាភាពចំពោះថវិកាយេនឌ័រ។

> សម្រាប់អង្គការដែលតូចជាងនេះ និង/ឬអង្គការសហគមន៍មូលដ្ឋាន ឧបករណ៍រៀបចំថវិកាដែលមានការចូលរួម នឹងមានការពាក់ព័ន្ធខ្លាំងជាងនេះ។

## ក្របខ័ណ្ឌប្រាំជំហានស្តីពីការរៀបចំថវិកាដែលឆ្លើយតបនឹងតម្រូវការយេនឌ័រ (GRB)

ក្របខ័ណ្ឌប្រាំជំហានស្តីពី GRB ដែលបង្កើតឡើងដោយ Debbie Budlender ( ឆ្នាំ២០០០ ) ត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយ (និងត្រូវបានយកមកកែសម្រួលដើម្បីប្រើប្រាស់) ក្នុងប្រទេសជាច្រើននៅជុំវិញពិភពលោក។ ខណៈដែលវាគឺជាក្របខ័ណ្ឌដែលមានប្រយោជន៍សម្រាប់គំនិតផ្តួចផ្តើមរបស់រដ្ឋាភិបាលនៅក្នុងប្រទេសនានា ដែលកំពុងអនុវត្តកម្មវិធី ឬការរៀបចំថវិកាផ្អែកលើប្រតិបត្តិការ វាក៏អាចជាឧបករណ៍ដ៏មានប្រយោជន៍ផងដែរ សម្រាប់ CSOs ខណៈដែលអនុវត្តការវិភាគ GRB របស់វិស័យជាក់លាក់មួយ ឬក្រសួងសាមី។ ក្នុងការអនុវត្ត ចំណុចខ្សោយក្នុងវិធីសាស្ត្រនេះគឺលទ្ធភាពនៅមានកម្រិតក្នុងការចាត់វិធានការឱ្យហួសពីជំហានទី២។ជាទូទៅអ្នកស្រាវជ្រាវដែលពាក់ព័ន្ធបានអនុវត្តការពិពណ៌នាអំពីស្ថានភាពនិងពិភាក្សាអំពីគោលនយោបាយ ប៉ុន្តែផ្នែកថវិកាមានភាពសង្ខេប ហើយជាញឹកញាប់មិនល្អ។

### ជំហានទី១៖ ការវិភាគស្ថានភាពរបស់ស្ត្រី បុរស កុមារី និងកុមារា ក្នុងវិស័យដែលត្រូវបានផ្តល់ជូន

ចំណុចស្នូលនៃក្របខ័ណ្ឌប្រាំជំហាន គឺជាការកំណត់ផែនទីស្ថានភាពរបស់ស្ត្រី បុរស កុមារី និងកុមារា នៅក្នុងវិស័យដែលត្រូវបានផ្តល់ជូនណាមួយ ឬអ្នកដែលត្រូវបានបម្រើដោយគោលនយោបាយឬក្រសួងជាក់លាក់មួយ។ ការប្រមូលព័ត៌មានបែបបរិមាណអាចត្រូវបានធ្វើឡើងតាមរយៈការរួមបញ្ចូលគ្នានៃប្រភពជាតិ ( ក្នុងស្រុក ) និងអន្តរជាតិដែលរួមបញ្ចូលទាំងកម្រងឯកសារអន្តរជាតិ ទិន្នន័យស្ថិតិឆ្លងប្រទេសផែនការអភិវឌ្ឍន៍ជាតិឯកសារគោលនយោបាយរដ្ឋាភិបាល ស្ថិតិរដ្ឋាភិបាលផ្លូវការ ទិន្នន័យរដ្ឋបាលនិងការស្រាវជ្រាវឯករាជ្យ។ការជ្រើសរើសឧបករណ៍វិភាគយេនឌ័រដែលត្រូវបានពិភាក្សាក្នុងម៉ូឌុល ៣ ក៏អាចត្រូវបានប្រើប្រាស់ដោយ CSOs ផងដែរសម្រាប់ការប្រមូលព័ត៌មានបែបបរិមាណអំពីភាពលំអៀងយេនឌ័រ និងឧបសគ្គ/របាំងយេនឌ័រ។ វាក៏មានសារៈសំខាន់ផងដែរថា ព័ត៌មានទិន្នន័យយេនឌ័រអំពីវិសាលភាពនៃគុណវិបត្តិផ្សេងទៀត (អាយុ លទ្ធភាព ជាតិពន្ធុ ថ្នាក់ ក្រុមសង្គម។ល។) ក៏ត្រូវបានពិចារណាផងដែរនៅពេលប្រមូលព័ត៌មាន ដើម្បីប៉ាន់ប្រម៉ាណពីស្ថានភាពយេនឌ័រ។

វាមានសារៈសំខាន់សម្រាប់ CSOs ដើម្បីកំណត់វិសាលភាពរបស់វិសយ/ក្រសួង ខណៈដែលធ្វើការវិភាគ។ វិសាលភាពដែលមានកម្រិតជួយបង្កើតទិន្នន័យដែលមានគុណភាពកាន់តែប្រសើរ និងបង្កើតព័ត៌មានដែលមានការផ្តោតការយកចិត្តទុកដាក់កាន់តែខ្លាំង។ វិធានអនុវត្តជាក់ស្តែងសាមញ្ញមួយអាចត្រូវបានប្រើប្រាស់ដើម្បីកំណត់ក្រុមគោលដៅរបស់គោលនយោបាយ/ក្រសួងដែលទទួលខុសត្រូវ។កំណត់បញ្ហាដែលជួបប្រទះដោយក្រុមគោលដៅ និងប្រើគោលដៅបុព្វហេតុ ផលវិបាក និងក្របខ័ណ្ឌដំណោះស្រាយសម្រាប់កំណត់

### ជំហានទី២៖ ការប៉ាន់ប្រម៉ាណការឆ្លើយតបនឹងតម្រូវការយេនឌ័ររបស់គោលនយោបាយ

គោលបំណងនៃជំហាននេះគឺដើម្បីវាយតម្លៃថាតើគោលនយោបាយឬកម្មវិធីជាក់លាក់មួយទំនងជាធ្វើឱ្យវិសមភាពយេនឌ័រកើន

ឡើងដូចដែរមានពិពណ៌នានៅក្នុងជំហានកន្លងមករក្សានៅដដែល ឬបន្ថយវិសមភាពយេនឌ័រ។ ប្រទេសមួយចំនួន មានគោលនយោបាយយេនឌ័ររួម ដែលចែងអំពីរបៀបដែលពួកគេមើលឃើញវិសមភាពយេនឌ័រនៅក្នុងប្រទេសនិងអ្វីដែលពួកគេអាចរៀបចំផែនការដើម្បីដោះស្រាយវិសមភាព។ ប្រទេសមួយចំនួនប្រឹងប្រែងបន្ថែមទៀតដើម្បីបង្កើនគោលនយោបាយយេនឌ័រផ្តោតលើវិស័យជាក់លាក់ដែលមានមុខងារប្រហាក់ប្រហែលគ្នាមួយសម្រាប់វិស័យជាក់លាក់នោះ។ មិនថាមានគោលនយោបាយយេនឌ័រ ឬអត់នោះទេ ប្រកាសសំខាន់គឺត្រូវសម្លឹងមើលជាទូទៅ បញ្ជ្រាបគោលនយោបាយនានាទាំងសម្រាប់វិស័យនោះ និងសម្រាប់ការអភិវឌ្ឍទាំងមូល។ គោលនយោបាយបញ្ជ្រាប ត្រូវតែមានការពិនិត្យមើលទៅលើអ្វីដែលគោលនយោបាយទាំងនោះចែងអំពីយេនឌ័រមិនថាមានចែងច្បាស់លាស់ឬមិនច្បាស់លាស់នោះទេ។ គោលនយោបាយទាំងនេះក៏ត្រូវសម្លឹងមើលផងដែរដើម្បីមើលថាតើគោលនយោបាយទាំងនេះផ្ទុយពីគោលនយោបាយយេនឌ័រក្នុងរបៀបណាមួយ។

សម្លឹងមើលគោលបំណងរបស់គោនយោបាយ/កម្មវិធី និងកំណត់គោលដៅ យេនឌ័រជាក់លាក់ និងចាំបាច់ត្រូវកែប្រែឡើងវិញដើម្បីរួមបញ្ចូលកង្វល់យេនឌ័រដែលត្រូវបានកំណត់ក្នុងជំហានទី១ ខាងលើ។ បន្សុីសកម្មភាពក្នុងឯកសារគោលនយោបាយ/កម្មវិធី និងធ្វើការប៉ាន់ប្រម៉ាណថាតើគោលបំណងយេនឌ័រត្រូវបានបំពេញក្នុងផែនការសកម្មភាពចាំបាច់ដែរឬទេ។ បង្កើតទំនាក់ទំនងខ្លាំងមួយរវាងសកម្មភាព និងការបែងចែកធនធានជាពិសេសលើវិស័យដែលមានសកម្មភាពវិជ្ជមាន។

## ជំហានទី៣៖ ការវាយតម្លៃការបែងចែកថវិកា

គោលបំណងចម្បងនៅក្នុងជំហាននេះគឺដើម្បីមើលថាតើការបែងចែកថវិកាមានភាពគ្រប់គ្រាន់ដើម្បីអនុវត្តគោលបំណង និងសកម្មភាពរបស់គោលនយោបាយ/កម្មវិធីដែលឆ្លើយតបនឹងតម្រូវការយេនឌ័រដែលត្រូវបានកំណត់នៅក្នុងជំហានទី២ឬយ៉ាងណា។ ភាពគ្រប់គ្រាន់ចាំបាច់ត្រូវវិភាគតាមរបៀបពីរយ៉ាង៖

ក )តើបរិមាណទឹកប្រាក់ដែលត្រូវបានបែងចែកសម្រាប់សកម្មភាព គ្រប់គ្រាន់ដើម្បីសម្រេចបានចំនួនទិសដៅដូចដែលចង់បានដោយគោលនយោបាយ/កម្មវិធីដែរទេ ?

ខ )តើការចំណាយក្នុងមួយឯកតាសម្រាប់កម្មភាពគ្រប់គ្រាន់ដើម្បីធានាថា សកម្មភាពត្រូវបានអនុវត្តក្នុងលក្ខណៈមួយប្រកបដោយប្រសិទ្ធភាពដែរទេ ?

ប្រភពចម្បងសម្រាប់ព័ត៌មានេះ គឺថវិកាផ្ទាល់ ជាពិសេស ប្រសិនបើពួកគេមានព័ត៌មានអំពីគោលបំណង និងសូចនាការនានា។ រដ្ឋាភិបាលមួយចំនួន ក៏ចេញផ្សាយឯកសារនានា (របាយការណ៍ប្រចាំឆ្នាំ/ថវិកាផ្អែកលើប្រតិបត្តិការ/ថវិកាផ្អែកលើលទ្ធផល) ដែលពិភាក្សាអំពីលទ្ធផលរបស់ក្រសួងផ្សេងៗក្នុងរយៈពេលមួយឆ្នាំកន្លងមក និងរៀបចំផែនការសម្រាប់ឆ្នាំខាងមុខ។ ទាំងនេះ រួមជាមួយនឹងសុន្ទរកថាអំពីថវិកា ជួយដល់ការវិភាគអំពីតួលេខថវិកា។

ប៉ារ៉ាម៉ែត្រសំខាន់មួយផ្សេងទៀតដើម្បីវាយតម្លៃនៅទីនេះ គឺការចំណាយជាក់ស្តែងដែលបានធ្វើឡើងក្នុងឆ្នាំកន្លងទៅធៀបនឹងការបែងចែកថវិកា។ ជាញឹកញាប់ សកម្មភាពដែលមានទស្សនៈយេនឌ័រជាក់លាក់ មិនទទួលបានចំណាប់អារម្មណ៍ជាក់លាក់ក្នុងដំណាក់កាលអនុវត្តនោះទេ ហើយថវិកាដែលត្រូវបានទុកចោលមិនប្រើប្រាស់រហូតដល់ឃើតពេលនៅក្នុងឆ្នាំអាចឈានទៅរកបញ្ហាមួយផ្សេងទៀត។ ការរុករកហេតុផលសម្រាប់ការមិនប្រើប្រាស់ថវិកានេះក៏នឹងជួយថែមទៀតផងដែរក្នុងការកំណត់គម្លាតនៅក្នុងការអនុវត្ត និងបញ្ហាប្រឈមក្នុងការផ្តល់សេវា។

វាមានសារៈសំខាន់ដើម្បីប៉ាន់ប្រម៉ាណភាពគ្រប់គ្រាន់នៃថវិកាទាក់ទងនឹងបរិមាណនៃការបែងចែក ដោយសារជាញឹកញាប់ការបែងចែកសរុបអាចមានភាពតិចខ្លាំងធៀបនឹងតម្រូវការជាក់ស្តែងដើម្បីដោះស្រាយកង្វល់របស់ប្រជាជនជាច្រើន។ លើសពីនេះទៀតវាក៏មានសារៈសំខាន់ផងដែរដើម្បីពិនិត្យមើលការចំណាយក្នុងមួយឯកតា ជាពិសេសដើម្បីស្វែងយល់អំពីការបែងចែកមិនគ្រប់គ្រាន់សម្រាប់ការងារដែលមិនទទួលបានប្រាក់ឈ្នួលរបស់ស្ត្រី។ កម្មវិធីជាច្រើន មិនពិចារណាលើការចូលរួមចំណែកនៃការងារដែលមិនទទួលបានប្រាក់ឈ្នួលរបស់ស្ត្រី ដើម្បីធានាបាននូវការអនុវត្តប្រកបដោយប្រសិទ្ធភាពនោះទេ។ វាមានសារៈសំខាន់ដែលថាកត្តានេះត្រូវបានរៀបចំថវិកាជូននិងប៉ះប៉ូវជូនវិញ។

## ជំហានទី៤៖ ការតាមដានការចំណាយ និងការផ្តល់សេវា

ប្រភេទទិន្នន័យដែលត្រូវការសម្រាប់ការវិភាគថវិកាយេនឌ័រអាចត្រូវបានបែងចែកជាប្រភេទពីរធំៗ៖

- ធាតុចូលវាស់វែងអ្វីដែលត្រូវបានដាក់បញ្ចូលទៅក្នុងដំណើរការ (ឧ. បរិមាណទឹកប្រាក់ដែលផ្តល់ ឬបុគ្គលិកដែលត្រូវបានផ្តល់សម្រាប់អនុវត្តកម្មវិធី ឬគម្រោងជាក់លាក់មួយ)។
- ទិន្នផលវាស់វែងផលិតផលផ្ទាល់របស់កម្មវិធីឬគម្រោងជាក់លាក់មួយ (ឧ.ចំនួនអ្នកទទួលផលដែលទទួលសេវាវេជ្ជសាស្ត្រ ឬចំនួនគ្លីនិកដែលត្រូវបានសាងសង់)។

ប៉ាន់ប្រម៉ាណថាតើថវិកាដែលត្រូវបានបែងចែកជូនត្រូវបានប្រើប្រាស់ប្រកបដោយប្រសិទ្ធភាពដែរឬយ៉ាងណា ដើម្បីសម្រេចបានលទ្ធផលដែលគ្រោងទុក។ ពិនិត្យមើលសមិទ្ធផលរូបវន្ត និងហិរញ្ញវត្ថុធៀបនឹងផែនការហើយថាតើប្រាក់ត្រូវបានចំណាយទៅតាមការចង់បានដែរឬអត់។ជាពិសេសពិនិត្យមើលសមាសមាត្រអ្នកទទួលផលពីយេនឌ័រ និងក្រុមសង្គមផ្សេងៗ ដើម្បីមើលថាតើវាស្របតាមប៉ារ៉ាម៉ែត្រគោលនយោបាយនិងប្រជាជនដែរឬអត់។ប្រសិនបើផ្នែកណាមួយមិនត្រូវបានគ្របដណ្តប់គ្រប់គ្រាន់ចូលវិភាគអំពីបុព្វហេតុដែល

បង្កឱ្យមានបញ្ហានេះ ខណៈដែលជាញឹកញាប់វាអាចបង្ហាញស៊ីជម្រៅដែលទាមទារឱ្យមានការកែប្រែថវិកាឡើងវិញ។

## ជំហានទី៥៖ ការវាយតម្លៃផលប៉ះពាល់/លទ្ធផល

លទ្ធផលវាស់វែងលទ្ធផលគោលនយោបាយ ឬកម្មវិធី (ឧ. កម្រិតសុខភាពអប់រំដែលកើនឡើងនិងភាពអាចមានពេលវេលា)។ ខណៈដែលការណ៍នេះមានការលំបាកក្នុងរយៈពេលខ្លី ចូរផ្ទៀងផ្ទាត់ថាតើគោលបំណងយេនឌ័រ/លទ្ធផលរបស់គោលនយោបាយ/កម្មវិធី ដែលមានកំណត់ក្នុងជំហានទី២ ត្រូវសម្រេចបានឬអត់។ តារាងទី២៦ បង្ហាញឧទាហរណ៍អំពីការអនុវត្តក្របខ័ណ្ឌប្រាំជំហាននៅក្នុងវិស័យទឹក ដែលលើកឡើងពីឧទាហរណ៍នៃសូចនាករ/ប៉ារ៉ាម៉ែត្រ ដែលចាំបាច់ត្រូវប៉ាន់ប្រម៉ាណសម្រាប់ជំហាននីមួយ។

**តារាងទី២៦៖ ក្របខ័ណ្ឌប្រាំជំហានស្តីពី GRB**

| | |
|---|---|
| ការវិភាគ ស្ថានប័ន | • តើវិសាលភាពយេនឌ័រនៃគំរូប្រើប្រាស់ទឹកគឺជាអ្វី(ប្រើប្រាស់សម្រាប់ផលិតកម្ម/ក្នុងផ្ទះ)នៅក្នុងគ្រួសារនិងនៅភូមិ/ទីក្រុង)?<br>• តើមានវិសាលភាពយេនឌ័រណាមួយសម្រាប់កិច្ចការដូចគ្នានេះដែរឬទេ?<br>• តើពេលវេលាជាមធ្យមដែលត្រូវបានចំណាយដោយបុរសនិងស្ត្រីកុមារានិងកុមារនៅទូទាំងក្រុមសង្គមផ្សេងៗទៅលើការដកទឹកមានរយៈពេលប៉ុន្មាន?<br>• តើអ្វីគឺជាការកើតមានជំងឺឆ្លងតាមទឹកក្នុងចំណោមបុរសនិងស្ត្រី? |
| ការវិភាគគោលនយោបាយ/កម្មវិធី | • តើគោលនយោបាយទឹកទទួលស្គាល់គំរូយេនឌ័រក្នុងការប្រើប្រាស់ទឹកដែរឬទេ?<br>• តើគំរូប្រើប្រាស់ទឹកមួយណាដែលត្រូវបានកំណត់អាទិភាពសម្រាប់ការធ្វើអន្តរាគមន៍នៅក្នុងគោលនយោបាយ?<br>• ដោយផ្អែកលើគំរូប្រើប្រាស់ទឹកដែលមានស្រាប់ តើកង្វល់ទឹករបស់អ្នកណាដែលទំនងជាត្រូវបានដោះស្រាយ? តើវាមានគោលបំណងដើម្បីកាត់បន្ថយពេលវេលាដែលចំណាយលើការដឹកជញ្ជូនទឹកដែរទេ?<br>• តើដំណោះស្រាយគ្រប់គ្រងទឹកអ្វីដែលត្រូវបានកំណត់នៅក្នុងគោលនយោបាយនេះ?<br>• តើមានដំណោះស្រាយគ្រប់គ្រាន់ដែរឬទេសម្រាប់ការប្រើប្រាស់ទឹកសម្រាប់ផលិតកម្មនិងក្នុងផ្ទះសម្រាប់ទាំងយេនឌ័រនិងនៅទូទាំងក្រុមសង្គម?<br>• តើសកម្មភាពអ្វីដែលត្រូវបានរៀបចំធ្វើនៅក្នុងគោលនយោបាយដែលនឹងកាត់បន្ថយវិសមភាពយេនឌ័រនៅក្នុងវិស័យទឹក?<br>• តើមានការប្តេជ្ញាចិត្តគោលនយោបាយណាមួយចំពោះតុល្យភាពយេនឌ័រនៅក្នុងស្ថាប័នគ្រប់គ្រងទឹកដែរឬទេ?<br>• តើមានវិសាលភាពយេនឌ័រណាមួយនៅក្នុងគំរូប្រើប្រាស់ទឹកដែលប្រែប្រួល គោលនយោបាយតម្លៃអ្នកប្រើប្រាស់ ឬគោលនយោបាយឯកជនីយកម្មដែរឬទេ? |
| ការវិភាគថវិកា | • តើចំណែក (ភាគរយ) នៃការបែងចែកថវិកាអ្វីដែលត្រូវបានអនុម័តនៅទូទាំងគំរូប្រើប្រាស់ទឹកផ្សេងៗ?<br>• តើថវិកាត្រូវបានបែងចែកគ្រប់គ្រាន់ដើម្បីដោះស្រាយភាពខុសគ្នានៃយេនឌ័រនិងតម្រូវការសង្គមនានាដែរឬទេ?<br>• តើអ្វីគឺជាការបែងចែករវាងហេដ្ឋារចនាសម្ព័ន្ធសកម្មភាពគ្រប់គ្រងនិងថែទាំហើយតើអ្នកនឹងទទួលបានអត្ថប្រយោជន៍ច្រើនជាងគេពីស្ថានភាពបែងចែកបច្ចុប្បន្ន?<br>• តើអ្វីគឺជាការបែងចែងសម្រាប់សកម្មភាពដែលត្រូវបានកំណត់ខាងលើដែលនឹងដោះស្រាយកង្វល់យេនឌ័រនិងកង្វល់សង្គម?<br>• ប្រសិនបើមានការបែងចែកជាក់ស្តែងដូចដែលមានបំណងធ្វើនៅគោលនយោបាយនេះ?<br>• តើប្រាក់ដែលត្រូវបានបែងចែកត្រូវបានចំណាយលើសកម្មភាពដែលចង់បានដែរឬទេ? ប្រសិនបើមិនបានចំណាយ តើអ្វីដែលជាបុព្វហេតុដែលបង្កឱ្យធ្វើដូច្នោះ?<br>• តើមានការបែងចែកថវិកាគ្រប់គ្រាន់សម្រាប់សកម្មភាពដែលដោះស្រាយតម្រូវការរបស់ស្ត្រីនិងក្រុមសង្គមផ្សេងទៀតដែរឬទេ?<br>• តើមានការបែងចែកថវិកាណាមួយសម្រាប់ទំនាក់ទំនងដែលសំដៅដល់ការដោះស្រាយការផ្លាស់ប្តូរតួនាទីយេនឌ័រនៅក្នុងវិស័យទឹកដែរទេ?<br>• តើថវិកាសម្រាប់ទំនាក់ទំនងត្រូវបានកំណត់ទិសដៅសម្រាប់ការផ្លាស់ប្តូរតួនាទីយេនឌ័រនិងត្រូវបានចំណាយទៅតាមការផ្លាស់ប្តូរហ្នឹងដែរឬទេ?<br>• តើថវិកាថែទាំត្រូវបានបែងចែក បញ្ចេញ និងចំណាយដែរឬទេ? តើអ្នកណាបានទទួលប្រាក់ តើជាអ្នកដែលមានការចូលរួមពិតប្រាកដនៅក្នុងការថែទាំ ឬគណៈកម្មាធិការគ្រប់គ្រង?<br>• តើស្ត្រីនៅក្នុងគណៈកម្មាធិការគ្រប់គ្រងទឹកមានសំឡេងគ្រប់គ្រាន់នៅក្នុងការបែងចែកថវិកាដែរឬទេ?<br>• តើស្ត្រីបានទទួលឱកាសស្មើគ្នានិងប្រកបដោយយុត្តិធម៌សម្រាប់ការងារក្នុងអំឡុងពេលអនុវត្តដែរទេ? តើអ្វីចំណែកប្រាក់ឈ្នួលរបស់បុរស និងស្ត្រីមានប៉ុន្មាន? |
| ការវិភាគទិន្នផល | • តើចំនួនគ្រួសារដែលត្រូវបានផ្តល់លទ្ធភាពទទួលបានទឹក (សម្រាប់ផលិតកម្ម/ប្រើប្រាស់ក្នុងផ្ទះ) មានចំនួនប៉ុន្មានគ្រួសារ?<br>• តើអ្វីគឺជាកម្រិតពេញចិត្តរបស់បុរសនិងស្ត្រីនៅទូទាំងក្រុមសង្គមដែលទទួលបានគុណភាពនៃសេវាផ្គត់ផ្គង់ទឹក? |
| ការវិភាគលទ្ធផល | • តើវាបានកាត់បន្ថយពេលវេលាដែលស្ត្រី និងបុរសបានចំណេញទៅលើការដឹកជញ្ជូនទឹកដែរទេ?<br>• តើវាបានផ្តល់អត្ថប្រយោជន៍ផ្នែកសេដ្ឋកិច្ចចំពោះស្ត្រី និងបុរសដែរឬទេ? |

### ឧបករណ៍និងបច្ចេកទេស GRB ជាមួយនឹងចំណុចចាប់ផ្តើម/ច្រកចូលសម្រាប់អង្គការសង្គមស៊ីវិល (CSOs)

មានឧបករណ៍និងបច្ចេកទេសជាច្រើនដែលត្រូវបានប្រើប្រាស់ជាផ្នែកមួយនៃការវិភាគ GRB។ ឧករណ៍ដែលត្រូវបានគេប្រើប្រាស់ញឹកញាប់បំផុតគឺឧបករណ៍ចំនួន ៧ដែលត្រូវបានស្នើឡើងដោយ Diane Elson។ នៅក្នុងវគ្គខាងមុខបញ្ជីឧបករណ៍មួយចំនួនដែលមានឧទាហរណ៍/ការអនុវត្តសក្តានុពលនៅក្នុងវិស័យហិរញ្ញវត្ថុអាកាសធាតុ ត្រូវបានពិភាក្សាដោយសង្ខេប។

**គន្លឹះសម្រាប់គ្រូឧទ្ទេស**

សម្រាប់វគ្គកម្រិតខ្ពស់ ចូរស្នើឱ្យអ្នកចូលរួមជ្រើសរើសប្រធានបទមួយផ្សេងទៀត ហើយពិភាក្សាបំផុសគំនិតអំពីសូចនាករ/ប៉ារ៉ាម៉ែត្រតាមដែលអាចធ្វើបានដើម្បីយកមកវាយតម្លៃសម្រាប់ដំហាននីមួយៗក្នុងចំណោមដំហានទាំង៥?

[5] ផ្នែកនេះពឹងផ្អែកយ៉ាងខ្លាំង (Budlender និង Sharp, របៀបធ្វើការវិភាគថវិកាដែលរំញោចយេនឌ័រ៖ ការស្រាវជ្រាវ និងការអនុវត្តសហសម័យ ឆ្នាំ១៩៩៨)

**តារាងទី២៧៖ ឧបករណ៍និងបច្ចេកទេស GRB**

| ឧបករណ៍ GRB | ការពិពណ៌នា | បច្ចេកទេស | ការអនុវត្តក្នុង CCDRR |
|---|---|---|---|
| ការវាយតម្លៃគោលនយោបាយដែលមានទស្សនៈយេនឌ័រ | ពាក់ព័ន្ធនឹងការវិភាគដែលឆ្លុះបញ្ចាំងការយល់ដឹងអំពីភាពជំពាក់ជំពិនយេនឌ័ររបស់គោនយោបាយតាមរយៈ៖<br>> កំណត់បញ្ហាយេនឌ័រដែលច្បាស់លាស់ និងមិនច្បាស់លាស់។<br>> កំណត់ការបែងចែកធនធានប្រវាស់។<br>> បង្កើតទំនាក់ទំនងខ្លាំងរវាងគោលនយោបាយនិងការបែងចែកធនធាន។ និង<br>> ប៉ាន់ប្រម៉ាណថាតើគោលនយោបាយនឹងបន្ត ឬផ្លាស់ប្តូរវិសមភាពដែលមានស្រាប់រវាងបុរសនិងស្ត្រី (និងក្រុមបុរស និងក្រុមស្ត្រី) និងគំរូទំនាក់ទំនងយេនឌ័រដែរ ឬអត់។ | > បញ្ជីត្រួតពិនិត្យសំណួរសម្រាប់ការវាយតម្លៃគោលនយោបាយរួមទាំងការពិនិត្យការសន្មត់គោលនយោបាយប្រឆាំងនឹងភស្តុតាងទាក់ទងនឹងយេនឌ័រ។<br>> ការពិភាក្សាអំពីហេតុការណ៍ សកម្មភាព និងការបែងចែកថវិកាដែលពាក់ព័ន្ធដែលត្រូវបានបង្កើតឡើងដោយគោលនយោបាយនេះ។ និង<br>> ពិនិត្យមើលគោលនយោបាយប្រឆាំងនឹងគោលបំណង និងវត្ថុបំណងប្រតិបត្តការដែលមានចែងរបស់ខ្លួន។ | ប្រទេសជាច្រើនមានច្បាប់ គោលនយោបាយ ឬឯកសារយុទ្ធសាស្ត្រស្តីពី CCDRR។ បើទោះជាមិនមានទាំងអស់នេះក្តីក៏មានការប្តេជ្ញាចិត្តចំពោះគោលនយោបាយផ្សេងៗដែលត្រូវបានធ្វើឡើងជាផ្នែកនៃNDCs,SDGsនិងក្របខ័ណ្ឌទីក្រុងសេនដៃ។ ការវិភាគគោលនយោបាយដែលមានទស្សនៈយេនឌ័រនឹងជួយរំលេចការប្តេជ្ញាចិត្តចំពោះយេនឌ័រ (ឬកង្វះ) នៅក្នុងការប្តេជ្ញាចិត្តទាំងនេះ ខណៈពេលដែល ជួយឃ្លាំមើលថាតើការប្តេជ្ញាចិត្តមួយណាដែលនៅមាននៅលើឯកសារហើយមួយណាត្រូវបានគាំទ្រដោយការបែងចែកធនធានគ្រប់គ្រាន់។ |
| របាយការណ៍ថវិកាយេនឌ័រ | របាយការណ៍ថវិកាយេនឌ័រ ជាធម្មតាត្រូវបានពិពណ៌នាថាជាឯកសារគណនេយ្យភាពដែលមានទស្សនៈយេនឌ័រជាក់លាក់ដែលត្រូវបានបង្កើតឡើងដោយទីភ្នាក់ងាររដ្ឋាភិបាលមួយ ដើម្បីបង្ហាញថាតើអ្វីដែលកម្មវិធីនិងថវិការបស់ខ្លួនកំពុងធ្វើទាក់ទងនឹងយេនឌ័រ។ របាយការណ៍បែបនេះជាធម្មតាត្រូវបានដាក់ជូនសភា ដែលជាញឹកញាប់ត្រូវបានដាក់ជូនដោយអមជាមួយនឹងឯកសារថវិកាស្តង់ដារ។ ឯកសារទាំងនេះមានន័យថាជាការជូនដំណឹងអំពីការកំណត់អាទិភាពថវិកា។ របាយការណ៍ទាំងនេះអាចរកបានជាសាធារណៈពេញលេញឬអាចបង្ហាញត្រឹមតែជាព័ត៌មានសង្ខេបនៅក្នុងឯកសារដែលចាក់ជូនទៅកាន់សភាឬអាចបង្ហាញជាសាធារណៈតាម | របាយការណ៍ GB អាចជារបាយការណ៍បែបបរិមាណនិងគុណភាព។ ជាទូទៅរបាយការណ៍នេះគឺជាគំរូមួយដែលត្រូវបានភ្ជាប់ទៅនឹងសារាចរសម្រាប់ក្រសួង និងនាយកដ្ឋានសាមីដើម្បីផ្តល់ព័ត៌មានអំពីថវិកាយេនឌ័រ។ របាយការណ៍ GB មួយចំនួនត្រូវបានបង្កើតឡើងដើម្បីរួមបញ្ចូលសំណួរអំពីកង្វល់យេនឌ័រនិងអាទិភាពនានានៅក្នុងក្រសួង/នាយកដ្ឋាន ខណៈដែលរបាយការណ៍ផ្សេងទៀតរួមបញ្ចូលការកំណត់ប្រភេទការប៉ាន់ប្រមាណ/ការបែងចែក/ការចំណាយថវិការបស់រដ្ឋាភិបាល ឬរួមបញ្ចូលទាំងពីរប្រភេទនេះ។ | គំរូ និង ការកំណត់ប្រភេទរបាយការណ៍ថវិកាយេនឌ័រ អាចត្រូវបានអនុវត្តយ៉ាងងាយស្រួលចំពោះហិរញ្ញវត្ថុCCDRRនៅក្នុងប្រទេស ជាពិសេសឯកសារបូកសរុបការវិនិយោគលើអាកាសធាតុ និងការចំណាយសាធារណៈ (CIPER)។ |

| តារាងទី២៧៖ ឧបករណ៍និងបច្ចេកទេស GRB | | | |
|---|---|---|---|
| **ឧបករណ៍ GRB** | **ការពិពណ៌នា** | **បច្ចេកទេស** | **ការអនុវត្តក្នុង CCDRR** |
| | របៀបផ្សេងៗ។ក្នុងប្រទេសមួយចំនួនព័ត៌មាននៅក្នុងរបាយការណ៍ថវិកាយេនឌ័រទាំងនេះអាចមិនបង្ហាញជាសាធារណៈទាល់តែសោះ។ | | |
| ការប៉ាន់ប្រម៉ាណអ្នកទទួលផលដែលមានទស្សនៈយេនឌ័រនៃការផ្តល់សេវាសាធារណៈ និងអាទិភាពថវិកា | ឧបករណ៍នេះមានបំណងប្រមូល និងវិភាគមតិរបស់ស្ត្រី និងបុរសទៅលើថាតើគោលនយោបាយ កម្មវិធី និងសេវារបស់រដ្ឋាភិបាលឆ្លុះបញ្ចាំងអាទិភាព និងឆ្លើយតបទៅនឹងត្រូវការរបស់ពួកគេបានកម្រិតណា។ ការឆ្លើយតបទាំងនេះត្រូវបានវិភាគ ដើម្បីវាយតម្លៃថាតើថវិកាបច្ចុប្បន្នរបស់រដ្ឋាភិបាលឆ្លើយតបទៅនឹងអាទិភាពរបស់ស្ត្រី និងបុរសបានកម្រិតណា។ សំខាន់ជាងនេះ អ្នកចូលរួមជាស្ត្រី និងបុរសក្នុងការសិក្សាអំពីអ្នកទទួលផលត្រូវបាន "សួរថាតើពួកគេនឹងបែងចែកថវិកាដោយរបៀបណាប្រសិនបើពួកគេគឺជារដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ"។ ឧទាហរណ៍ ការយល់ឃើញរបស់ស្ត្រីនិងបុរសទាក់ទងនឹងគុណភាពរបស់សេវាដែលត្រូវបានផ្តល់ជូនពួកគេតាមរយៈអនុមណ្ឌលឬមណ្ឌលសុខភាពបឋមក្នុងប្លុក/ស្រុកអាចត្រូវបានបញ្ជាក់ដោយប្រើប្រាស់ឧបករណ៍នេះ។ ភាពមានកម្រិតរបស់ឧបករណ៍នេះគឺថា វាចាប់យកតែការយល់ឃើញរបស់អ្នកទទួលផលមិនមែនជាអ្នកមិនប្រើប្រាស់ ឬអ្នកផ្តល់សេវា។ វាប្រើប្រាស់ពេលវេលាច្រើន ហើយជាធម្មតាវាដោះស្រាយតែសេវាមួយប៉ុណ្ណោះក្នុងពេលម្តង។ | > ការបោះឆ្នោតស្ទង់មតិ<br>> ការអង្កេតអាកប្បកិរិយា<br>> ការប៉ាន់ប្រម៉ាណរហ័សដែលមានការចូលរួម<br>> កិច្ចពិភាក្សាក្រុមគោលដៅ<br>> ការសម្ភាសបែបសន្ទនា<br>> ការចាត់ចំណាត់ថ្នាក់ចំណង់ចំណូលចិត្ត និងការដាក់ពិន្ទុ | ការប៉ាន់ប្រម៉ាណអ្នកទទួលផលដែលមានទស្សនៈយេនឌ័រ ក៏អាចក្លាយជាឧបករណ៍ដ៏សំខាន់មួយផងដែរជាពិសេសសម្រាប់ស្ថាប័នស្រាវជ្រាវ ដែលធ្វើការងារលើ CCDRR។ ការស៊ើបអង្កេតជាប្រចាំអំពីការយល់ឃើញរបស់មនុស្ស (ដែលបែងចែកតាមភេទ) ចំពោះការបែងចែកថវិកាដែលត្រូវបានធ្វើឡើងសម្រាប់ CCDRR ជាពិសេសអ្នកដែលបានរាយការណ៍ក្នុង CIPER (បូកសរុបការវិនិយោគលើអាកាសធាតុ និងការចំណាយសាធារណៈ) អាចក្លាយជាឧបករណ៍តស៊ូមតិខ្លាំងមួយសម្រាប់ការបង្កើតធនធានថវិកាសម្រាប់ CCDRR។ |

| តារាងទី២៧៖ ឧបករណ៍និងបច្ចេកទេស GRB | | | |
|---|---|---|---|
| **ឧបករណ៍ GRB** | **ការពិពណ៌នា** | **បច្ចេកទេស** | **ការអនុវត្តក្នុង CCDRR** |
| ការវិភាគការកើតមានការចំណាយសាធារណៈដែលមានទស្សនៈយេនឌ័រ | គោលបំណងរបស់ឧបករណ៍នេះ គឺដើម្បីវិភាគថាតើបុរសនិងស្ត្រីទទួលបានអត្ថប្រយោជន៍ពីការចំណាយលើសេវាសាធារណៈក្នុងកម្រិតណា។ ការវិភាគស្ថិតិត្រូវបានធ្វើឡើងដើម្បីកំណត់ការបែងចែកការចំណាយរវាងបុរស ស្ត្រី កុមារី និងកុមារា។ការវិភាគនេះអាចត្រូវបានធ្វើឡើងសម្រាប់វិស័យ ឬកម្មវិធីណាមួយ។ វិធីសាស្ត្រនេះតម្រូវឱ្យមានការគណនាការចំណាយក្នុងមួយឯកតានៃការផ្តល់សេវា( ឧ.ការចំណាយលើការគ្រប់គ្រងសាលាបឋមសិក្សាសម្រាប់រយៈពេលមួយឆ្នាំ) ការគណនាចំនួនកុមារីនិងកុមារាដែលបានទទួលអត្ថប្រយោជន៍ និងការគណនាការកើតមានផលប្រយោជន៍តាមរយៈការគុណការចំណាយក្នុងមួយឯកតាជាមួយនឹងចំនួនកុមារី ហើយគុណម្តងទៀតជាមួយចំនួនកុមារា។ | ឧបករណ៍បរិមាណនេះបង្ហាញថាតើអ្វីគឺជាប្រវត្តនៃការបែងចែងដែលមានទស្សនៈយេនឌ័រជាក់លាក់នូវអត្ថប្រយោជន៍ពីសេវាសាធារណៈ។ វាមានតម្លៃពិសេសសម្រាប់ការបង្កើតខ្សែគោល និងបង្កើតប្រព័ន្ធតាមដាន។ កិច្ចការនេះតម្រូវឱ្យមានការវាស់វែង៖<br>i) ការចំណាយក្នុងមួយឯកតាលើការផ្តល់សេវាជាក់លាក់។ ឧ. ការចំណាយលើការផ្តល់ទីកកន្លែងសាលាបឋមសិក្សាសម្រាប់រយៈពេលមួយឆ្នាំ។<br>ii) ចំនួនឯកតាដែលត្រូវបានប្រើប្រាស់ដោយបុរសនិងស្ត្រី កុមារា និងកុមារី។<br>ការកើតមានផលប្រយោជន៍នៅពេលនោះអាចត្រូវបានគណនាថាជាតម្លៃនៃការចំណាយក្នុងមួយឯកតាគុណនឹងចំនួនឯកតាដែលត្រូវបានប្រើប្រាស់ដោយបុគ្គលដែលពាក់ព័ន្ធ។ ការកើតមានផលប្រយោជន៍អាស្រ័យលើ i) ការបែងចែងការចំណាយសាធារណៈលើការផ្តល់សេវាសាធារណៈ ii) ឥរិយាបថរបស់គ្រួសារក្នុងការប្រើប្រាស់សេវាសាធារណៈ។ ឧទាហរណ៍ ការកើតមានផលប្រយោជន៍ពីការចំណាយសាធារណៈទៅលើការអប់រំបឋមសិក្សា គឺ i) សម្រាប់កុមារី តម្លៃនៃការចំណាយសាធារណៈលើការអប់រំបឋមសិក្សាគុណនឹងអត្រាចុះឈ្មោះរបស់កុមារីនៅសាលាបឋមសិក្សាធៀបនឹងអត្រាចុះឈ្មោះសរុបនៅសាលាបឋមសិក្សា ii) សម្រាប់កុមារា តម្លៃនៃការចំណាយសាធារណៈលើការអប់រំបឋមសិក្សាគុណនឹងអត្រាចុះឈ្មោះរបស់កុមារាធៀបនឹងអត្រាចុះឈ្មោះសរុបនៅសាលាបឋមសិក្សា។ កម្រិតកំណត់របស់ឧបករណ៍នេះគឺថា វាសម្មត់ថា ការ | ការវិភាគការកើតមានការចំណាយសាធារណៈដែលមានទស្សនៈយេនឌ័រគឺជាឧបករណ៍បច្ចេកទេសមួយប៉ុន្តែអាចត្រូវបានអនុវត្តបានយ៉ាងល្អដើម្បីផ្តល់ថាមពលដល់គម្រោងប្រព័ន្ធប្រកាសអាសន្នព័ត៌មាន។ល។ ដែលចំនួនអ្នកប្រើប្រាស់ចុងក្រោយអាចត្រូវបានគណនា។ |

| តារាងទី២៧៖ ឧបករណ៍និងបច្ចេកទេស GRB | | | |
|---|---|---|---|
| **ឧបករណ៍ GRB** | **ការពិពណ៌នា** | **បច្ចេកទេស** | **ការអនុវត្តក្នុង CCDRR** |
| | ចំណាយរបស់សេវាសម្រាប់បុរស និងស្ត្រី អ្នកមាន និងអ្នកក្រជនបទ និងទីក្រុងគឺដូចគ្នា។វាក៏អាចត្រូវបានធ្វើបានផងដែរប៉ុន្តែត្រឹមតែសម្រាប់សេវានានាដែលផ្តោតលើអ្នកទទួលផលជាបុគ្គលប៉ុណ្ណោះ។ | | |
| ការវិភាគថវិការធៀបនឹងការប្រើប្រាស់ពេលវេលាដែលបែងចែកតាមភេទ | ឧបករណ៍នេះមានបំណងបង្ហាញទំនាក់ទំនងរវាងថវិការបស់រដ្ឋាភិបាល (ក្នុងវិស័យជាក់លាក់មួយ ឧ. ការផ្គត់ផ្គង់ទឹកទៅកាន់ភូមិ)និងរបៀបដែលសមាជិកសហគមន៍ស្ត្រីនិងបុរសចំណាយពេលវេលារបស់ពួកគេទាក់ទងនឹងវត្តមាន ឬអវត្តមានរបស់សេវាកម្មនោះ (ឧ. ការជញ្ជូនទឹកសម្រាប់គ្រួសារ)។ ការណ៍នេះជួយប្រៀបធៀបតម្លៃមិនចំហរនៃការងារដែលមិនទទួលបានប្រាក់ឈ្នួលជាមួយនឹងបរិមាណថវិកា។ ឧទាហរណ៍វាអាចឱ្យមានការប្រៀបធៀបការចំណាយលើការផ្តល់ការផ្គត់ផ្គង់ទឹកទៅកាន់ភូមិ/តំបន់មួយទៅតាមបរិមាណថវិកានិងការចំណាយមិនចំហរលើការជញ្ជូនទឹក។ ឧបករណ៍នេះ ក៏ជួយផងដែរក្នុងការធានាថា ពេលវេលាដែលត្រូវបានចំណាយលើការងារដែលមិនទទួលបានប្រាក់ឈ្នួលរបស់ស្ត្រី ត្រូវបានយកមកពិចារណាក្នុងការវិភាគគោលនយោបាយ ។ការប្រមូលព័ត៌មានអំពីរបៀបដែលសមាជិកគ្រួសារប្រើប្រាស់ពេលវេលាតាមរយៈការអង្កេតគ្រួសារ ទិន្នន័យប្រើប្រាស់ពេលវេលាដែលបែងចែកតាមភេទ (និងអាយុ) នៅពេលនោះអាចត្រូវបានប្រើប្រាស់ដើម្បីបង្ហាញទំនាក់ទំនងរវាងថវិការបស់រដ្ឋាភិបាល និងថវិកានិងពេលវេលារបស់គ្រួសារ។ | > ការគណនា "បន្ទុកការងារផ្ទះ" ត្រូវបានកំណត់ថាជាសមាសមាត្រនៃពេលវេលារបស់មនុស្សម្នាក់ដែលចំណាយលើការងារផ្ទះដែលមិនទទួលបានប្រាក់ឈ្នួល ដើម្បីរក្សាសង្គម។ ការប្រែប្រួលបន្ទុកការងារផ្ទះ ក្រោយមកអាចមានទំនាក់ទំនងទៅនឹងការប្រែប្រួលបន្ទុកការងារផ្សេងទៀត។<br>> ការគណនាម៉ាទ្រិចធាតុចូល និងទិន្នផលរបស់វិស័យសង្គមមួយដែលរួមបញ្ចូលទាំងការងារថែទាំដែលមិនទទួលបានប្រាក់ឈ្នួលថាជាធាតុចូលនិងទិន្នផលព្រមទាំងការចំណាយសាធារណៈរបស់វិស័យសង្គមមួយ។<br>> ការគណនាការចំណាយរបស់គ្រួសារលើពេលវេលានិងការចំណាយលើសេវានានារួមទាំងសេវាសុខភាព អប់រំ អនាម័យបរិស្ថាន ដឹកញ្ជូន។ ការប្រែប្រួលការចំណាយពេលវេលាក្រោយមកអាចមានទំនាក់ទំនងទៅនឹងការប្រែប្រួលការចំណាយសាធារណៈ។ | ដោយពិចារណាថា ការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយមានឥទ្ធិពលខ្លាំងលើការមិនមាន ពេលវេលាផ្ទាល់ខ្លួនរបស់ស្ត្រី ការវិភាគអំពីការប្រើប្រាស់ពេលវេលាបែងចែកតាមភេទ នឹងជាឧបករណ៍ដ៏សំខាន់មួយសម្រាប់ការកំណត់បរិមាណនៃការចូលរួមចំណែករបស់ស្ត្រី និងកុមារីនៅក្នុងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ ព្រមទាំងក្នុងការស្តារនីតិសម្បទាពីគ្រោះមហន្តរាយ។ ឧទាហរណ៍ មនុស្សម្នាក់អាចគណនាពេលវេលាបន្ថែមដែលត្រូវបានចំណាយដោយស្ត្រីនិងកុមារីសម្រាប់ការដឹកជញ្ជូនទឹក និងដាក់វាចូលក្នុងលក្ខខណ្ឌសេដ្ឋកិច្ច ដើម្បីបង្កើតករណីមួយសម្រាប់គម្រោងផ្គត់ផ្គង់ទឹកដែលជាផ្នែកមួយនៃការស្តារនីតិសម្បទាពីគ្រោះមហន្តរាយ។ ដូចគ្នានេះដែរ តួនាទីថែទាំរបស់ស្ត្រីអាចត្រូវបានកំណត់បរិមាណដើម្បីបង្កើតករណីមួយសម្រាប់ការបង្កើនការបែងចែកសម្រាប់សុខភាព។ |

### ការរៀបចំថវិកាដែលមានការចូលរួម

ការរៀបចំថវិកាដែលមានការចូលរួមគឺជាដំណើរការមួយដែលអនុញ្ញាតឱ្យប្រជាពលរដ្ឋសម្រេចចិត្តថាតើមូលនិធិថវិកាមួយចំនួនត្រូវបានបែងចែកដោយរបៀបណា។ តាមរយៈ ការរួមបញ្ចូលសាធារណៈជន ទៅក្នុងការធ្វើសេចក្តីសម្រេចចិត្ត ការរៀបចំថវិកាដែលមានការចូលរួមមានសក្តានុពលក្នុងការក្លាយជាភ្នាក់ងារមួយនៃគណនេយ្យភាព ដែលជួយបើកកកាយថវិការដ្ឋាភិបាល ដើម្បីប្រែក្លាយម្ចាស់ឆ្នោតទៅជាអ្នកចូលរួមចំណែកដ៏សកម្ម និងការតាមដានដែលយល់ដឹងច្បាស់នៃវឌ្ឍនភាពរបស់រដ្ឋាភិបាលនិងដើម្បីគ្រាំដល់កិច្ចប្រឹងប្រែងសម្រាប់ការបង្ហាញថវិកាបុរេសកម្ម។ ដូចដែលមាននៅថ្ងៃនេះការរៀបចំថវិកាដែលមានការចូលរួមជួយសហគមន៍ឱ្យរុករកឱកាសជាច្រើនក្នុងចំណោមឱកាសទាំងនេះ ហើយវាបម្រើជាច្រកទ្វារដ៏សំខាន់មួយចំពោះការចូលរួមជាមួយរដ្ឋាភិបាលមូលដ្ឋានសម្រាប់ក្រុមប្រជាពលរដ្ឋកាន់តែទូលំទូលាយ ជាពិសេសក្រុមដែលជាធម្មតាគ្មានអ្នកតំណាងគ្រប់គ្រាន់។វាគឺជាដំណើរការផ្លាស់ប្តូរមួយ ពោលគឺដំណើរការមួយដែលស្ទើរតែមិនបណ្តាលឱ្យរដ្ឋាភិបាលចំណាយអ្វីបន្តិចឡើយ ដោយសារវាគ្រាន់តែបែងចែងមូលនិធិដែលមានស្រាប់ឡើងវិញ។ នៅក្នុងពិភពលោកមានទម្រង់រៀបចំថវិកាដែលមានការចូលរួមមួយចំនួន ប៉ុន្តែទម្រង់នីមួយៗមានបំណងជានាបាននូវការចូលរួមរបស់ពលរដ្ឋក្នុងការបែងចែកមូលនិធិសាធារណៈ។

មានដំណើរការផ្សេងៗគ្នាដែលអាចត្រូវបានប្រើប្រាស់សម្រាប់ការរៀបចំថវិកាដែលមានការចូលរួម៖

> រដ្ឋាភិបាលបែងចែកថវិកាជាភាគរយមួយចំនួនទៅដល់ក្រុម ឬភូមិសាស្រ្តដែលត្រូវបានផ្តល់ជូន ដើម្បីរៀបចំផែនការ និងស្នើសកម្មភាពនៅក្នុងកម្រិតថវិកានោះ។

> រដ្ឋាភិបាលអញ្ជើញឱ្យមានការដាក់សំណើរ និងការទាមទារពីពលរដ្ឋ មុនពេលអនុវត្តការរៀបចំថវិការបស់ខ្លួន ហើយការផ្តោតការយកចិត្តទុកដាក់គ្រប់គ្រាន់ត្រូវបានធ្វើឡើងទៅលើការរួមបញ្ចូលការទាមទាររបស់ប្រជាជន។

ការរៀបចំថវិកាដែលមានការចូលរួមអាចត្រូវបានរួមបញ្ចូលជាពិសេសជាផ្នែកមួយនៃកិច្ចការផែនការបន្សាំនៅមូលដ្ឋាន និងកិច្ចការរៀបចំផែនការភាពធន់ទីក្រុង។ ប្រការសំខាន់ ត្រូវកត់សម្គាល់ថា មិនមែនគំនិតផ្តួចផ្តើមការរៀបចំថវិកាដែលមានការចូលរួមទាំងអស់មានការឆ្លើយតបនឹងតម្រូវការយេនឌ័រនិងផ្តោតលើការចាប់យកស្ត្រីជាភាគីពាក់ព័ន្ធក្នុងដំណើរការនេះដែលផ្តល់ជូនពួកគេនូវវេទិកា និងលំហរមួយដើម្បីលើកឡើងពីការទាមទាររបស់ពួកគេ ហើយការកំណត់អាទិភាពនៃតម្រូវការរបស់ពួកគេនៅក្នុងដំណើរការរៀបចំថវិកាដែលមានការចូលរួមត្រូវបានតម្រូវឱ្យធ្វើឡើងជាចាំបាច់។

### ការរៀបចំថវិកាដែលឆ្លើយតបនឹងតម្រូវការយេនឌ័រ (GRB) សម្រាប់ហិរញ្ញវត្ថុអាកាសធាតុ៖ របាយការណ៍ថវិកាយេនឌ័រ និងអាកាសធាតុ

ឧបករណ៍ GRB សំខាន់មួយទៀតដែលអាចប្រើក្នុងហិរញ្ញវត្ថុអាកាសធាតុ គឺរបាយការណ៍ថវិកាយេនឌ័រ (GBS)។ GBS ត្រូវបានប្រើ ដើម្បីបែងចែកការចំណាយដែលបានគ្រោងទុក ទៅក្នុងប្រភេទដែលពាក់ព័ន្ធនឹងយេនឌ័រ។ នេះគឺពាក់ព័ន្ធនឹងការបញ្ជាក់អំពីផលប៉ះពាល់នៃយេនឌ័រដែលបានរំពឹងទុកនៃថវិកាជាតិសរុប (ការចំណាយសាធារណៈ និងពន្ធដារ) និង/ឬផលប៉ះពាល់យេនឌ័រនៃការចំណាយរបស់ក្រសួងតាមវិស័យ។ សេចក្តីថ្លែងការណ៍អាចត្រូវបានបង្កើតឡើងដោយផ្អែកលើឧបករណ៍ណាមួយខាងលើ។ វាក៏អាចត្រូវបានបង្កើតឡើងតាមប្រភេទដែលបានកំណត់ទុកជាមុនផងដែរ។ ឧទាហរណ៍ខ្លះនៃ GBS នៅអាស៊ី ត្រូវបានគូសបញ្ជាក់ខាងក្រោម (អង្គការ UN Women ឆ្នាំ២០១៥)៖

**ចំណាត់ថ្នាក់មាត្រដ្ឋានទាំងប្រាំរបស់រដ្ឋាភិបាលបង់ក្លាដែស (GOB)**

GoB តម្រូវឱ្យទីភ្នាក់ងារវាយតម្លៃកម្មវិធី និងគម្រោងរបស់រដ្ឋាភិបាលទាំងអស់ធៀបនឹងការចូលរួមចំណែកដែលបានរំពឹងទុកចំពោះលក្ខណៈវិនិច្ឆ័យបួន ដែលតំណាងឱ្យទិដ្ឋភាពផ្សេងគ្នានៃការផ្តល់ភាពអង់អាចដល់ស្ត្រី ដូចជា៖

១. សិទ្ធិ និងសម្លេងនៅក្នុងសង្គម
២. ការងារ
៣. ផលិតភាព និង
៤. លទ្ធភាពទទួលបានធនធាន សេវាកម្ម និងព័ត៌មាន។

កម្មវិធីនិងគម្រោងដែលត្រូវបានវាយតម្លៃថាមានផលប៉ះពាល់ដោយផ្ទាល់ទៅលើការផ្តល់ភាពអង់អាចដល់ស្ត្រីបន្ទាប់មកត្រូវបានវាយតម្លៃចំពោះភាពខ្លាំងនៃផលប៉ះពាល់ទៅលើមាត្រដ្ឋាននៃ "អវិជ្ជមាន" "សូន្យ" "ទាប" "មធ្យម" និង "ខ្ពស់"។ សេចក្តីណែនាំត្រូវបានផ្តល់ជូនក្រសួងនៅក្នុងថវិកា ហៅថាសាពចរ រួមមាន "ស្តង់ដារ" (ឬលក្ខណៈវិនិច្ឆ័យ) សម្រាប់វាយតម្លៃផលប៉ះពាល់យេនឌ័រ និងកំណត់ភាគរយមួយ។

ទន្ទឹមនឹងចំណាត់ថ្នាក់បែបបរិមាណនេះ របាយការណ៍ថវិកាយេនឌ័រ ក៏អនុវត្តតាមក្របខ័ណ្ឌដែលបានរៀបចំយ៉ាងល្អ ដើម្បីដោះស្រាយបញ្ហាដូចខាងក្រោម៖

o តួនាទី និងការទទួលខុសត្រូវរបស់ក្រសួង / អគ្គនាយកដ្ឋាន
o តើសកម្មភាពរបស់ក្រសួង/អគ្គនាយកដ្ឋានមានឥទ្ធិពលយ៉ាងដូចម្តេចចំពោះការជឿនលឿន និងសិទ្ធិរបស់ស្ត្រី។
o តើអ្នកណាទទួលបានអត្ថប្រយោជន៍ ឬអាចទទួលបានអត្ថប្រយោជន៍ពីសកម្មភាពទាំងនេះ និង របៀបបែងចែកតាម

យេនឌ័រ

- o របៀបដែលគោលដៅយុទ្ធសាស្ត្ររបស់ក្រសួង/អគ្គនាយកដ្ឋានពាក់ព័ន្ធ ទាក់ទងទៅនឹងភាពជឿនលឿននិងសិទ្ធិរបស់ស្ត្រី។
- o ព័ត៌មានស្តីពីការបែងចែកថវិការបស់ក្រសួង/អគ្គនាយកដ្ឋានដែលបែងចែកតាមយេនឌ័រ
- o ការពិពណ៌នាអំពីជោគជ័យរបស់ក្រសួង/អគ្គនាយកដ្ឋាន ក្នុងការដោះស្រាយភាពជឿនលឿនរបស់ស្ត្រី។ និង
- o អនុសាសន៍ស្តីពីការពង្រឹងតួនាទីរបស់ក្រសួង/អគ្គនាយកដ្ឋាននានា ក្នុងការធ្វើសកម្មភាពសម្រាប់ការជំរុញភាពជឿនលឿនរបស់ស្ត្រី។

ក្រសួងនីមួយៗ ដាក់ស្នើថវិការបស់ខ្លួន ហើយក្រសួងហិរញ្ញវត្ថុ ដាក់តារាងវិភាគក្រោមចំណងជើងថា "ភាពជឿនលឿន និងសិទ្ធិរបស់ស្ត្រី" រួមជាមួយថវិកាប្រចាំឆ្នាំ។ របាយការណ៍ពិនិត្យឡើងវិញនូវរបៀបដែលក្រសួងបានដោះស្រាយចំពោះបញ្ហាភាពជឿនលឿន និងសិទ្ធិរបស់ស្ត្រីនៅក្នុងថវិកាដែលមានផ្នែកផ្សេងៗគ្នាបង្ហាញពីវឌ្ឍនភាពរួមសម្រាប់ក្រសួងដែលពាក់ព័ន្ធ។ផ្នែកទី១នៃរបាយការណ៍រួម ពិភាក្សាអំពីថវិការបស់ក្រសួងចំនួនប្រាំពីរក្រោមចំណងជើងថា "ការផ្តល់ភាពអង់អាចដល់ស្ត្រី និងការលើកកម្ពស់សេចក្តីថ្លៃថ្នូរក្នុងសង្គមរបស់ពួកគេ"។ ផ្នែកទី២ ពិភាក្សាអំពីថវិការបស់ក្រសួងចំនួនប្រាំបួន ដែលបានដាក់ជាក្រុមក្រោមចំណងជើងថា "ការលើកកម្ពស់ផលិតភាព និងការចូលរួមរបស់ស្ត្រីក្នុងទីផ្សារការងារ"។ ចុងបញ្ចប់ ផ្នែកទី៣ ពិភាក្សាអំពីថវិការបស់ក្រសួងចំនួន ២៤ ដែលបានដាក់ជាក្រុមក្រោមចំណងជើងថា "ការពង្រីកលទ្ធភាពទទួលបានរបស់ស្ត្រីក្នុងការទទួលបានសេវាសាធារណៈទូទៅ និងសកម្មភាពបង្កើតប្រាក់ចំណូល"។ របាយការណ៍ថវិកាយេនឌ័ររបស់ក្រសួងនីមួយៗក៏អាចរកបាននៅលើគេហទំព័ររបស់ក្រសួងហិរញ្ញវត្ថុផងដែរ។

**ការធ្វើចំណាត់ថ្នាក់ពីរប្រភេទនៃរដ្ឋាភិបាលឥណ្ឌា (GOI)**

បច្ចុប្បន្ននេះ GOI តម្រូវឱ្យមន្ត្រីរដ្ឋាភិបាលប្រើទម្រង់ពីប្រភេទដែលជាមូលដ្ឋាននៃការបង្ហាញនៅក្នុងសេចក្តីថ្លែងការណ៍ស្តីពីថវិកាយេនឌ័រនៅក្នុងថវិកាសហភាព។ ប្រភេទទាំងពីររួមមាន៖

១. ការបែងចែកដាក់លាក់សម្រាប់ស្ត្រី ដែល ១០០% នៃការបែងចែកគឺសម្រាប់ស្ត្រី

២. ការបែងចែកដើម្បីគាំទ្រដល់ស្ត្រី ដែលចន្លោះពី ៣០ ទៅ ៩៩% នៃការបែងចែក គឺសម្រាប់ស្ត្រី

កម្មវិធីនិងរបបនានាត្រូវបានចាត់ថ្នាក់ជាពីរប្រភេទតាមក្រសួង/មន្ទីរពាក់ព័ន្ធរៀងៗខ្លួន និង ត្រូវបញ្ជូនទៅក្រសួងហិរញ្ញវត្ថុ។ បន្ទាប់មក វាត្រូវបានរៀបចំជារបាយការណ៍ថវិកាយេនឌ័រដាច់ដោយឡែក និងដាក់នៅចំពោះមុខសភារួមជាមួយថវិកាសហភាព។

**លំហាត់ដាក់ពិន្ទុរបស់រដ្ឋាភិបាលនេប៉ាល់ (GON)**

ការវាយតម្លៃ GRB របស់ប្រទេសនេប៉ាល់ ផ្តល់ឱ្យក្រសួងនូវតម្លៃនៃការបែងចែកមួយសម្រាប់មាត្រដ្ឋានពី 0-១០០ ពិន្ទុ យោងទៅតាមវិសាលភាពដែលពួកគេបានជំរុញសមភាពយេនឌ័រ។ ផលប៉ះពាល់បីប្រភេទ ត្រូវបានប្រើប្រាស់៖

១. ការចំណាយ ដែលផ្តល់អត្ថប្រយោជន៍ដោយផ្ទាល់ដល់ស្ត្រី (ពិន្ទុពី៥០ ទៅ ១០០ពិន្ទុ)

២. ការចំណាយ ផ្តល់អត្ថប្រយោជន៍ដោយប្រយោលដល់ស្ត្រី (ពិន្ទុដាក់ចន្លោះពី ២០ ដល់ ៥០) និង

៣. ការចំណាយ អព្យាក្រឹត (ប្រសិនបើកម្មវិធី/គំនិតផ្តួចផ្តើមទទួលបានពិន្ទុក្រោម ២០)។

សូចនាករទាំង៥ ដែលនីមួយៗមានទម្ងន់២០% និងតម្រូវឱ្យមានពិន្ទុនៃភាពរំញោចយេនឌ័រ ចន្លោះពី១ ដល់ ២០ សម្រាប់កម្មវិធីនីមួយៗ ដែលត្រូវបានប្រើ ដើម្បីគណនាសមាមាត្រនៃការចំណាយក្នុងប្រភេទនីមួយៗ៖

> ការកសាងសមត្ថភាពស្ត្រី
> ការចូលរួមរបស់ស្ត្រីក្នុងកម្មវិធីផែនការ និងការអនុវត្ត
> ការចែករំលែកផលប្រយោជន៍ដល់ស្ត្រី
> ការកើនឡើងនូវឱកាសការងារ និងការបង្កើតប្រាក់ចំណូលសម្រាប់ស្ត្រី។ និង
> ការថយចុះនូវបន្ទុកការងារ និងការប្រើប្រាស់ពេលវេលារបស់ស្ត្រី។

សូចនាករគុណភាពដែលពាក់ព័ន្ធនឹង GRB នេះ និងពិន្ទុដែលពាក់ព័ន្ធត្រូវបានដាក់បញ្ចូលទៅក្នុងឧបករណ៍ថវិកាអេឡិចត្រូនិច។ ការដាក់ពិន្ទុត្រូវបានធ្វើឡើងដោយអង្គភាពរៀបចំផែនការនៅក្នុងក្រសួងនីមួយៗ រួមជាមួយក្រសួងហិរញ្ញវត្ថុ។ ដើម្បីជួយមន្ត្រីក្នុងការងាររបស់ពួកគេ ក្របខ័ណ្ឌសង្ខេបនៃសូចនាករ GRB ទូទៅ និងសូចនាកររង ត្រូវបានបង្កើតឡើង ហើយសៀវភៅណែនាំ (ជាភាសានេប៉ាល់) ត្រូវបានបង្កើតឡើង ដើម្បីពន្យល់ពីសូចនាករនិងសូចនាកររង និងមានជាឧទាហរណ៍។

**របាយការណ៍ GBS នៅប្រទេសឥណ្ឌូណេស៊ី**

វិធីសាស្ត្ររបាយការណ៍GBSនៅប្រទេសឥណ្ឌូណេស៊ីត្រូវបានបង្កើតឡើងដោយផ្អែកលើប្រព័ន្ធរៀបចំថវិកា ដែលបានដាក់បញ្ចូលទៅក្នុងរដ្ឋាភិបាលកណ្តាល នៅប្រទេសឥណ្ឌូណេស៊ី ក្នុងឆ្នាំ២០១០។ សម្រាប់របាយការណ៍ GRB ក្រសួងនីមួយៗត្រូវជ្រើសរើសសកម្មភាពមួយចំនួន (kegiatan) ឬសកម្មភាពរងដែលត្រូវបានចាត់ទុកថាមានសារៈសំខាន់ជាពិសេសផ្តើមចេញពីទិដ្ឋភាពយេនឌ័រ និងដើម្បីពិពណ៌នាអំពីទិដ្ឋភាពទាំងនោះដោយប្រើទម្រង់គំរូដែលបានកំណត់។ ចំណងជើងសម្រាប់ទម្រង់គំរូគឺជាសកម្មភាពរង គោលបំណង ការវិភាគស្ថានភាព សកម្មភាពដែលបានគ្រោងទុក ថវិកាសម្រាប់សកម្មភាព និងធាតុចូល ទិន្នផល និងសូចនាករលទ្ធផល។ ចំណងជើងត្រូវអនុលោមតាម

ធាតុចូលស្តង់ដារយ៉ាងជិតស្និទ្ធ ដែលមានចែងនៅក្នុងឯកសារថវិកាចម្បង។ សកម្មភាពដែលបានជ្រើសរើស គួរតែស្ថិតក្នុងចំណាត់ថ្នាក់មួយក្នុងចំណោមប្រភេទចំនួនពីរ៖ ក) ការផ្តល់សេវាកម្មដែលក្រសួងបច្ចេកទេសទទួលខុសត្រូវជាចម្បង ឬ ខ) ការកសាងសមត្ថភាព និងការតស៊ូមតិយេនឌ័រដែលជាទំនួលខុសត្រូវចម្បងរបស់ក្រសួងសម្របសម្រួល។ប្រភេទទី២ត្រូវបានរាប់បញ្ចូលដូចជាក្រសួងផ្សេងទៀត ដូចជាក្រសួងធនធានទឹក និងឧតុនិយម និងក្រសួងហិរញ្ញវត្ថុ។

បណ្តាប្រទេសអាស៊ីជាច្រើន ដូចជា ប្រទេសបង់ក្លាដែស និង ប្រទេសនេប៉ាល់ បានទទួលយកក្របខ័ណ្ឌ GBS ចំពោះការវិនិយោគលើអាកាសធាតុ និងការពិនិត្យការចំណាយសាធារណៈ។ ហេតុនេះ របាយការណ៍ថវិកាយេនឌ័រ និងអាកាសធាតុ (GCBS) មានសក្តានុពលច្រើនបំផុតដែលត្រូវបានអនុម័តជាចំណុចចាប់ផ្តើមដំបូងដើម្បីចូលរួមជាមួយហិរញ្ញវត្ថុអាកាសធាតុនៅក្នុងវិស័យក្នុងស្រុក។

**ចំណុចពិភាក្សា**

ស្នើឱ្យអ្នកចូលរួម ឆ្លុះបញ្ចាំងពីអ្វីដែលអាចជាឯកសារល្អបំផុត ដើម្បីចាប់ផ្តើមការវិភាគ GCBS នៅក្នុងប្រទេសរៀងៗខ្លួន

**គម្រុយសម្រាប់អ្នកសម្របសម្រួល**

វាជាការប្រសើរបំផុតសម្រាប់អង្គការសង្គមស៊ីវិល ជាពិសេស អង្គការដែលផ្តោតលើស្ត្រី ដើម្បីប្រើប្រាស់ឯកសារវិនិយោគអាកាសធាតុ និងការត្រួតពិនិត្យឡើងវិញលើការចំណាយសាធារណៈ (CIPER) ដើម្បីអភិវឌ្ឍ GCBS។ CIPERs ភាគច្រើនត្រូវបានវាយតម្លៃអំពីទំនាក់ទំនងអាកាសធាតុហើយចំណុចមួយអាចចាប់ផ្តើមបានដោយការធ្វើចំណាត់ថ្នាក់កម្មវិធីដែលបានកំណត់រួចហើយ និងការបែងចែកថវិកាទាក់ទងនឹងការឆ្លើយតបនឹងតម្រូវការយេនឌ័រ។ ការវិភាគយ៉ាងហោចណាស់មួយ អាចពិនិត្យមើលលើកម្មវិធីដែលបានគ្របដណ្តប់និងត្រូវធ្វើចំណាត់ថ្នាក់ពួកគេជាបីប្រភេទពោលគឺប្រភេទដែលឆ្លើយតបទៅនឹងតម្រូវការយេនឌ័រជាក់ស្តែង ប្រភេទដែលឆ្លើយតបទៅនឹងតម្រូវការយេនឌ័រជាយុទ្ធសាស្ត្រ និងប្រភេទដែលផលប៉ះពាល់/ភាពជាប់ពាក់ព័ន្ធមិនអាចបង្កើតបាន ដោយសារប្រភេទដែលត្រូវដាក់ចូលក្នុងប្រភេទនៃការវិភាគស៊ីជម្រៅ ដូចមានចែងក្នុងប្រអប់ខាងលើ អាចយកមកវិភាគបាន។

វិធីមួយទៀតនៃការធ្វើដូចនេះ គឺការចាប់ផ្តើមវិស័យដែលបានជ្រើសរើស ពោលគឺពី ១០ ទៅ ១២ក្រសួងសាមី ដែលត្រូវបានកំណត់ដោយផ្អែកលើលក្ខណៈវិនិច្ឆ័យពីរគឺភាពពាក់ព័ន្ធរបស់ពួកគេ(ឬភាពងាយស្រួលនៃការវិភាគ)សម្រាប់តម្រូវការនិងអាទិភាពរបស់ស្ត្រី ហើយសំខាន់ជាងនេះទៀត គឺការចែករំលែកថវិកា និងការវិនិយោគអាកាសធាតុ។ ការធ្វើការជាមួយវិស័យដែលបានជ្រើសរើស (ជាពិសេស អ្នកទាំងឡាយណាដែលអង្គការមានការយល់ឃើញ និងមានជំនាញ) ជួយធ្វើការវិភាគ GRB ផ្សេងៗបន្ថែមទៀត។

# លំហាត់

## លំហាត់ទី២៣៖ ការបង្កើតផែនទីស្ថាបត្យកម្មហិរញ្ញវត្ថុអាកាសធាតុសកល

គោលបំណងសំខាន់នៃលំហាត់នេះ គឺដើម្បីផ្តល់ឱ្យអ្នកចូលរួមនូវទិដ្ឋភាពទូទៅនៃមូលនិធិហិរញ្ញវត្ថុអាកាសធាតុផ្សេងៗគ្នា ដែលមានមុខងារនៅថ្នាក់ជាតិ ថ្នាក់តំបន់ និងថ្នាក់សកល។

សម្ភារៈ ក្តារខៀន ប៊ិចហ្វឺត សំណៅឯកសារទី២១ ។

ដំណើរការ៖

**ជំហានទី១៖** ចាប់ផ្តើមជាមួយនឹងការមើលខ្សែភាពយន្តខ្លីដោយលោក Heinrich-Böll-Stiftung នៃទីក្រុងវ៉ាស៊ីនតោន ស្តីពី "តើអ្វីជាហិរញ្ញវត្ថុអាកាសធាតុ" ដែលអាចរកបាននៅគេហទំព័រ៖ https://www.youtube.com/watch?v=_Y9vM4e9XaM,

**ជំហានទី២៖** ឥឡូវ ចែកអ្នកចូលរួមជាគូដែលមានគ្នាពីរនាក់។ ផ្តល់ព័ត៌មានលម្អិតអំពីមូលនិធិនីមួយៗដល់គូនីមួយៗ ដោយឱ្យពួកគេម្នាក់ៗនូវចំណុចលម្អិតដែលយកចេញពីសំណៅឯកសារទី២១។ ស្នើឱ្យពួកគេធ្វើដូចគ្នា ហើយពិភាក្សា។ ផ្តល់ពេលវេលាឱ្យពួកគេ ១០នាទីសម្រាប់កិច្ចការនេះ។

**ជំហានទី៣៖** ឥឡូវប្រាប់ពួកគេឱ្យស្រមៃថា ពួកគេគឺជាអ្នកតំណាងមូលនិធិ ហើយនឹងត្រូវបង្ហាញអំពីមូលនិធិរបស់ពួកគេនៅក្នុងកិច្ចប្រជុំថ្នាក់ជាតិស្តីពីហិរញ្ញវត្ថុអាកាសធាតុ។ ផ្តល់ពេលវេលាឱ្យពួកគេ ៥នាទីទៀត ដើម្បីរៀបចំកិច្ចការនេះ។

**ជំហានទី៣៖** ឱ្យអ្នកចូលរួមទាំងអស់ចូលរួមប្រជុំក្រុមធំ ហើយស្នើឱ្យគូនីមួយៗចែករំលែកអំពីចំណុចសំខាន់ៗនៃមូលនិធិរបស់ពួកគេ។ នៅចុងបញ្ចប់សូមឱ្យអ្នកចូលរួមឆ្លុះបញ្ចាំងពីចំណុចដូចខាងក្រោម៖

> តើមូលនិធិអាកាសធាតុ ត្រូវបានផ្តល់ដល់អ្នកណា?
> តើថវិកាមួយណាដែលផ្តោតការយកចិត្តទុកដាក់លើការបន្សាំ ហើយតើមួយណាទៀតដែលផ្តោតច្រើនលើការកាត់បន្ថយ?
> តើថវិកាមួយណាដែលមានវិសាលភាពច្រើនបំផុតសម្រាប់ការចូលរួមរបស់អង្គការសង្គមស៊ីវិល?

**ជំហានទី៤៖** បញ្ចាំងខ្សែភាពយន្តស្តីពី "ហិរញ្ញវត្ថុអាកាសធាតុឆ្លើយតបនឹងយេនឌ័រ" ដែលមាននៅគេហទំព័រ https://www.youtube.com/watch?v=YKmvdiXlDFI។ សូមសាកសួរសិក្ខាកាមឱ្យឆ្លុះបញ្ចាំងថា "តើមូលនិធិមួយណា ដែលពួកគេគិតថាមានសក្តានុពលច្រើនសម្រាប់ការបញ្ជ្រាបយេនឌ័រ" ។

លទ្ធផលនៃការរៀនសូត្រ៖ សូមបញ្ចប់វគ្គជាមួយនឹងការសរុបឡើងវិញយ៉ាងឆាប់នូវថវិកាទាំងអស់។

## លំហាត់ទី២៤៖ ការវិភាគយេនឌ័រក្នុងគម្រោងបន្សាំ

គោលបំណងសំខាន់នៃលំហាត់នេះគឺដើម្បីផ្តល់ឱ្យអ្នកចូលរួមនូវអារម្មណ៍មួយអំពីរបៀបដែលប្រភេទផ្សេងៗគ្នានៃមុខងារមូលនិធិបន្សាំនិងធ្វើឱ្យពួកគេចាប់អារម្មណ៍គ្រប់គ្រាន់ក្នុងការស្វែងរកគេហទំព័រមូលនិធិឱ្យកាន់តែលម្អិត។លំហាត់នេះក៏ផ្តល់ឱកាសដល់អ្នកចូលរួមឱ្យស្វែងយល់អំពីរបៀបដែលអង្គការដែលផ្តោតលើស្ត្រី អាចចូលរួមជាអ្នកសង្កេតការណ៍ និងអ្នកត្រួតពិនិត្យ។

សម្ភារៈ ក្តារខៀន និងប៊ិចហ្វឺត

ដំណើរការ៖

**ជំហានទី១៖** ចែកអ្នកចូលរួមជាក្រុមដែលមានគ្នាពី ៥ ទៅ ៦នាក់ និងផ្តល់ជូនក្រុមនីមួយៗនូវសំណៅឯកសារទី២ (ឧទាហរណ៍នៃគម្រោងបន្សាំនឹងការប្រែប្រួលអាកាសធាតុ)។

**ជំហានទី២៖** ស្នើឱ្យពួកគេអានសំណៅឯកសារនិងស្វែងយល់អំពីលំហាត់ដែលបានដាក់ជូន។ប្រាប់ពួកគេថាពួកគេនឹងត្រូវប្រើចំណេះដឹង

ផ្ទាល់ខ្លួន និងត្រូវស្វែងរកក្នុងអ៊ីនធើណិតសម្រាប់ព័ត៌មានបន្ថែម។

**ជំហានទី៣៖** ផ្តល់ពេលប្រមាណ ៣០នាទី សម្រាប់អ្នកចូលរួមធ្វើការងារនេះជាក្រុម។ ពិភាក្សាពីចម្លើយនៅក្នុងក្រុមធំ ដោយរក្សានូវការពិចារណាដូចខាងក្រោម៖

> ស្នើឱ្យក្រុមមួយឆ្លើយសំណួរណាមួយ ដោយឱ្យក្រុមផ្សេងទៀតបន្ថែមព័ត៌មាន។
> ផ្តោតការយកចិត្តទុកដាក់បន្ថែមទៀតលើការសង្កេតយេនឌ័រ។
> កុំចំណាយពេលច្រើនលើការពិចារណាអំពីចម្លើយ។ គោលបំណងនៃលំហាត់គឺមិនមែនទទួលបានចម្លើយត្រឹមត្រូវទេ តែដើម្បីឱ្យពួកគេយល់ពីដំណើរការនេះ។

**ជំហានទី៤៖** នៅពេលដែលចម្លើយបានពិភាក្សារួចហើយ។ សាកសួរពួកគេពីអ្វីដែលពួកគេបានរៀនពីដំណើរការនេះ។ ផ្តោតការពិភាក្សាជុំវិញចំណុចដូចខាងក្រោម៖

ក) តើគេហទំព័រណាមួយដែលពួកគេអាចរកទីតាំង និងស្វែងរកឃើញយ៉ាងងាយស្រួល ហើយតើមួយណាដែលពិបាក?
ខ) តើផ្នែកអ្វីខ្លះនៃគេហទំព័រដែលមានប្រយោជន៍បំផុត?
គ) តើពួកគេបានរកឃើញព័ត៌មានបន្ថែមអំពីមូលនិធិណាមួយ ដែលមិនត្រូវបានបញ្ចូលទៅក្នុងបទបង្ហាញ?
ឃ) តើមូលនិធិណាខ្លះដែលពួកគេមើលឃើញថា អង្គការរបស់ពួកគេមានទំនាក់ទំនងកាន់តែច្រើន ហើយតើអ្វីទៅជាមធ្យោបាយនៃការចូលរួមដែលអាចមាន?

**លទ្ធផលនៃការរៀនសូត្រ៖** បញ្ចប់វគ្គនេះដោយមានការឆ្លើយតបហ័សពីអ្នកចូលរួមទាំងអស់ អំពីអ្វីដែលអ្នកចូលរួមបានរៀនសូត្រពីករណីសិក្សា និងដំណើរការដែលយកមកអនុវត្តបាននៅក្នុងការងាររបស់ពួកគេ។

---

## លំហាត់ទី២៥៖ ចំណោទស្តីពី GRB ជា PowerPoint

គោលបំណងសំខាន់នៃលំហាត់នេះ គឺដើម្បីសរុបឡើងវិញនូវគំនិត GRB ដែលអ្នកចូលរួមបានយល់ឃើញ នៅក្នុងខ្សែភាពយន្តខ្លីស្តីពី GRB ក៏ដូចជាបង្កើនការយល់ដឹងរបស់ពួកគេលើគំនិតផ្សេងៗទៀតមួយចំនួន។

**សម្ភារ៖** បទបង្ហាញជា PowerPoint (សូមមើលសំណៅឯកសារទី១)

**ដំណើរការ៖**

**ជំហានទី១៖** ចែកអ្នកចូលរួមជាពីរក្រុមគឺ ក្រុម "ផ្លែប៉ោម" និង "ផ្លែក្រូច" (គួរធ្វើយ៉ាងណាដែលមិនឱ្យរំខានដល់ការរៀបចំកន្លែងអង្គុយ)។

**ជំហានទី២៖** សូមប្រាប់ពួកគេថា ពេលនេះពួកគេនឹងត្រូវល្បែងចំណោទ។ អ្នកនឹងត្រូវបង្ហាញសំណួរទាក់ទងនឹងខ្សែភាពយន្តដែលពួកគេទើបតែបានឃើញនៅលើស្លាយថ៍ PowerPoint ហើយបន្ទាប់មកជាជម្រើស ក្រុមនីមួយៗនឹងត្រូវឆ្លើយសំណួរ។

**ជំហានទី៣៖** ប្រាប់ពួកគេថា ចំណោទនឹងមានជម្រើសពីរ។ ក្រុមនឹងទទួលបាន ២៥ពិន្ទុសម្រាប់ចម្លើយត្រឹមត្រូវនីមួយៗ ប្រសិនបើពួកគេជ្រើសរើសជម្រើសទី១ និង ១០ពិន្ទុសម្រាប់ចម្លើយត្រឹមត្រូវនីមួយៗ ប្រសិនបើពួកគេជ្រើសរើសជម្រើសទី២ ។ ជម្រើសទាំងពីរគឺ៖

**ជម្រើសទី១៖** ឆ្លើយសំណួរដោយមិនមើលតម្រុយ និងជម្រើស
**ជម្រើសទី២៖** ឆ្លើយដោយមានជំនួយពីតម្រុយ និងជម្រើស
ក្រុមអាចជ្រើសរើសជម្រើសមួយបន្ទាប់ពីបានឃើញសំណួរ។ ប្រសិនបើសំណួរមួយត្រូវប្រគល់ឱ្យទៅក្រុមបន្ទាប់ ពួកគេក៏ទទួលបាន ១០ពិន្ទុដូចគ្នាដែរ។

**ជំហានទី៤៖** ពិនិត្យមើលស្លាយថ៍នីមួយៗដោយសួរសំណួរនិងដាក់ពិន្ទុនៅលើក្តារខៀន។ នៅពេលដែលអ្នកចូលរួមឆ្លើយសូមបន្ថែមចម្លើយដែលមានព័ត៌មាន និងការពន្យល់បន្ថែម។ សូមគណនាពិន្ទុសរុប និងប្រកាសក្រុមដែលឈ្នះ។

**ទិន្នផលនៃការរៀនសូត្រ៖** សន្និដ្ឋានដោយពិនិត្យឡើងវិញនូវគំនិតរបស់ GRB ដោយផ្អែកលើកំណត់សម្គាល់បច្ចេកទេស។ "GRB គឺជាវិធីសាស្ត្រក្នុងការដាក់បញ្ចូលគោលបំណងសមភាពយេនឌ័រជាប្រព័ន្ធ ទៅក្នុងគោលនយោបាយការរៀបចំផែនការ ការរៀបចំថវិកា ការត្រួតពិនិត្យ ការវាយតម្លៃ និងការធ្វើសវនកម្ម។ វាមានគោលបំណងបង្ហាញពីផលប៉ះពាល់នៃការបែងចែកថវិកា (ចំណូល និងចំណាយ) ទៅលើស្ត្រី និងបុរស និងកែសម្រួល [ឬផ្លាស់ប្តូរទីតាំង] ដើម្បីធានាថា ទាំងស្ត្រី ទាំងបុរសទទួលបានផលប្រយោជន៍ធនធានពីរដ្ឋាភិបាលដោយស្មើភាព (អង្គការ UN Women ឆ្នាំ២០២០)។

## លំហាត់ទី២៦៖ ករណីសិក្សាស្តីពីការចូលរួមរបស់អង្គការសង្គមស៊ីវិលនៅក្នុង GRB

គោលបំណងសំខាន់នៃលំហាត់នេះ គឺដើម្បីឱ្យអ្នកចូលរួម អាចកំណត់យុទ្ធសាស្ត្រ និងវិសាលភាពនៃការចូលរួមរបស់អង្គការសង្គមស៊ីវិលនៅក្នុងការងារ GRB។

**សម្ភារៈ** សំណៅឯកសារទី២

**ដំណើរការ៖**

**ជំហានទី១៖** បែងចែកអ្នកចូលរួមជាក្រុមដែលមានគ្នាពី៤ ទៅ៥នាក់។ ប្រសិនបើមកពីប្រទេសផ្សេងគ្នា អ្នកចូលរួមមកពីប្រទេសដូចគ្នាគួរតែដាក់ពួកគេជាមួយគ្នា។

**ជំហានទី២៖** ផ្តល់ជូនក្រុមនីមួយៗនូវសំណៅឯកសារទី២ ហើយស្នើឱ្យពួកគេទៅពិភាក្សាលើចំណុចដូចគ្នា។ ផ្តល់ពេលវេលាប្រហែល ៥នាទី ដើម្បីឱ្យពួកគេអានករណីសិក្សា និងការពិភាក្សាជាទូទៅ។

**ជំហានទី៣៖** ឱ្យពួកគេពិភាក្សាជាពិសេសលើចំណុចដូចខាងក្រោម៖

ក) តើយុទ្ធសាស្ត្រសំខាន់ណាខ្លះដែលត្រូវបានគេយកមកប្រើ សម្រាប់ការចូលរួមរបស់អង្គការសង្គមស៊ីវិលនៅក្នុងដំណើរការ GRB?
ខ) តើនរណាជាតួអង្គសំខាន់ ហើយតើភាពជាដៃគូប្រភេទណាខ្លះដែលត្រូវបានបង្កើត?
គ) តើពួកគេគិតថា អ្វីដែលជាកត្តាជំរុញ និងកត្តាប្រឈម ដែលអាចប្រឈមដោយអង្គការសង្គមស៊ីវិលក្នុងការអនុវត្តលំហាត់នេះ?

**ជំហានទី៤៖** ផ្តល់ឱ្យក្រុមនីមួយៗនូវពេលវេលាប្រហែល ១៥នាទី ដើម្បីពិភាក្សាអំពីសំណួរទាំងនេះ។ នាំពួកគេទៅកាន់ក្រុមធំ ហើយស្នើឱ្យក្រុមនីមួយៗចែករំលែកនូវចំនុចសំខាន់មួយដែលទាក់ទងនឹងសំណួរនីមួយៗ។

**លទ្ធផលនៃការរៀនសូត្រ៖** បញ្ចប់វគ្គដោយស្នើឱ្យពួកគេចែករំលែកនូវចំណុចរៀនសូត្រសំខាន់ៗពីករណីសិក្សាដែលពួកគេគិតថាអាចយកមកអនុវត្តបាននៅក្នុងការងាររបស់ពួកគេ។

## លំហាត់ទី២៧៖ GRB និងការវិភាគហិរញ្ញវត្ថុសាធារណៈអាកាសធាតុ

គោលបំណងសំខាន់នៃលំហាត់នេះ គឺឱ្យអ្នកចូលរួមប្រើប្រាស់ GRB ដើម្បីគូសផែនទីបង្ហាញពីទិដ្ឋភាពនៃការផ្តល់មូលនិធិក្នុងស្រុកនៅក្នុងប្រទេសរបស់ពួកគេ និងអនុវត្តទស្សនវិស័យ GRB ទៅលើហិរញ្ញវត្ថុសាធារណៈអាកាសធាតុ ដែលជាផ្នែកមួយនៃការងារតស៊ូមតិរបស់ពួកគេ។

**សម្ភារៈ** ក្រដាសពណ៌ស និងក្រដាសស្អិត កុំព្យូទ័រយួរដៃ (មួយសម្រាប់ក្រុមនីមួយៗ) សម្រាប់វិភាគទិន្នន័យ

**ដំណើរការ៖**

**ជំហានទី១៖** បែងចែកអ្នកចូលរួមទៅជាក្រុមដែលមានគ្នាពី ៥ ទៅ ៦នាក់។ ប្រសិនបើពួកគេមកពីប្រទេសផ្សេងគ្នាសូមឱ្យអ្នកចូលរួមដែលមកពីប្រទេសតែមួយនៅជាមួយគ្នា។

**ជំហានទី២៖** ផ្តល់ជូនក្រុមនីមួយៗនូវឯកសារថវិកាកម្មវិធីរបស់ក្រសួងណាមួយពីប្រទេសរបស់ខ្លួនក្នុងទម្រង់ជាឯកសារ excel (សូមមើលឯកសារថវិការបស់ប្រទេស នៅក្នុងគេហទំព័រ)។

**ជំហានទី៣៖** ស្នើឱ្យក្រុមកត់សម្គាល់នូវរាល់កម្មវិធី ដែលពួកគេមានព័ត៌មាន ឬការយល់ដឹងខ្លះៗនៅលើក្រដាសស្អិត។ (ក្រដាសស្អិតមួយ គួរតែមានកម្មវិធីតែមួយប៉ុណ្ណោះ)។

**ជំហានទី៤៖** ស្នើឱ្យក្រុមចាត់ចំណាត់ថ្នាក់កម្មវិធីទាំងអស់ស្តីពីម៉ាទ្រិចផលប៉ះពាល់អាកាសធាតុ និងយេនឌ័រ ដូចមានបង្ហាញខាងក្រោម៖

**រូបទី៦២៖ គំរូម៉ាទ្រិចផលប៉ះពាល់លើយេនឌ័រ**




**ជំហានទី៥៖** ផ្តល់ពេលវេលាប្រហែល ១៥នាទី សម្រាប់លំហាត់នេះ ហើយបន្ទាប់មកស្នើឱ្យអ្នកចូលរួមចាត់ចំណាត់ថ្នាក់ថវិកាក្រសួងទៅតាមប្រភេទទាំងបី ៖
**ពាក់ព័ន្ធខ្លាំង** ៖ អ្នកទាំងឡាយណាដែលស្ថិតនៅក្រោមអាកាសធាតុកម្រិតខ្ពស់ និងផលប៉ះពាល់នៃយេនឌ័រ។
**ពាក់ព័ន្ធ៖** អ្នកទាំងឡាយណាដែលស្ថិតនៅក្រោមអាកាសធាតុកម្រិតខ្ពស់ ប៉ុន្តែផលប៉ះពាល់នៃយេនឌ័រទាប ឬយេនឌ័រខ្ពស់ ប៉ុន្តែផលប៉ះពាល់អាកាសធាតុទាប
**មិនពាក់ព័ន្ធ** ៖ អ្នកទាំងឡាយណាដែលស្ថិតនៅក្រោមយេនឌ័រទាប និងផលប៉ះពាល់អាកាសធាតុទាប។

**ជំហានទី៦៖** ឥឡូវនេះស្នើឱ្យពួកគេកំណត់កម្មវិធីចំនួន២ ដែលមានការបែងចែកថវិកាកម្រិតខ្ពស់បំផុតពីប្រភេទនីមួយៗ និងកំណត់អាកាសធាតុ និងភាពពាក់ព័ន្ធនៃយេនឌ័រ ដោយប្រើតារាងត្រួតពិនិត្យខាងក្រោម៖

សំណួរទី១ តើមានទំនាក់ទំនងដោយផ្ទាល់នៃកម្មវិធីទៅនឹងគោលនយោបាយអាកាសធាតុថ្នាក់ជាតិដែរឬទេ? បាទ/ចាស/ទេ
សំណួរទី២ តើកម្មវិធីនេះនឹងដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុដោយផ្ទាល់ដែរឬទេ? បាទ/ចាស/ទេ
សំណួរទី៣ តើសកម្មភាពនេះនឹងកាត់បន្ថយបន្ទុកការងារ និងភាពខ្វះខាតនៃពេលវេលារបស់ស្ត្រីដែរឬទេ? បាទ/ចាស/ទេ
សំណួរទី៤ តើវានឹងបង្កើនប្រាក់ចំណូល និងជីវភាពរស់នៅរបស់ស្ត្រីដែរឬទេ? បាទ/ចាស/ទេ
សំណួរទី៥ តើស្ត្រីត្រូវបានរួមបញ្ចូលនៅក្នុងការរៀបចំផែនការ ការធ្វើសេចក្តីសម្រេចចិត្ត ឬការកសាងសមត្ថភាពដែរឬទេ? បាទ/ចាស/ទេ

**ជំហានទី៧៖** ឱ្យពួកគេចាត់ចំណាត់ថ្នាក់កម្មវិធីទាំងនេះ ទៅតាមភាពទាក់ទងនឹងយេនឌ័រ និង CCDRR។ ប្រសិនបើមានចំនួន៣ ឬលើសពីនេះ គឺត្រូវកំណត់ថា "ពាក់ព័ន្ធខ្លាំង"។ ប្រសិនបើឆ្លើយថា បាទ/ចាសចំនួន ២ នោះ"គឺ "ពាក់ព័ន្ធ" ហើយប្រសិនបើតិចជាង ២ នោះគឺ "មិនពាក់ព័ន្ធ"។

**ជំហានទី៨៖** ឥឡូវនេះស្នើឱ្យពួកគេវាយតម្លៃឡើងវិញនូវថវិកាសរុបជាបីប្រភេទ៖ ពាក់ព័ន្ធខ្លាំង ពាក់ព័ន្ធ និងមិនពាក់ព័ន្ធ។

**ជំហានទី៩៖** សាកសួរពួកគេឱ្យវិភាគអំពីភាពខុសគ្នានៃការបែងចែកចំណាត់ថ្នាក់ជាពីរប្រភេទ និងអ្វីដែលពួកគេបានរៀនពីចំណុចដូចគ្នា។

**ទិដ្ឋផលនៃការរៀនសូត្រ៖** សន្និដ្ឋានដោយប្រាប់ពួកគេថា ទាំងនេះគឺគ្រាន់តែជាវិធីសាមញ្ញនៃការធ្វើចំណាត់ថ្នាក់ ហើយពួកគេអាចបង្កើតដំណើរការ ដើម្បីធ្វើការវិភាគស៊ីជម្រៅនៅក្នុងនាយកដ្ឋានដែលបានជ្រើសរើស ដើម្បីបង្កើតរបាយការណ៍ថវិកាយេនឌ័រ និងអាកាសធាតុ។

## ធ្វើតេស្តចំណេះដឹងរបស់អ្នក

| បំពេញឃ្លា | ✓ ដោយគូសធីកលើចម្លើយជ្រើសរើសរបស់អ្នក | | | |
|---|---|---|---|---|
| តាមរយៈកិច្ចព្រមព្រៀងទីក្រុងកូប៉ែនហាន់ ប្រទេសអភិវឌ្ឍន៍បានសន្យា | | ៣០ពាន់លានដុល្លារអាមេរិក ជារៀងរាល់ឆ្នាំ ត្រឹមឆ្នាំ២០២០ | | ១០០ពាន់លានដុល្លារអាមេរិក ជារៀងរាល់ឆ្នាំ ត្រឹមឆ្នាំ២០២០ |
| គណៈកម្មាធិការអចិន្ត្រៃយ៍ផ្នែកហិរញ្ញវត្ថុត្រូវបានប្រគល់ភារកិច្ចឱ្យ | | រៀបចំការវាយតម្លៃរៀងរាល់២ឆ្នាំម្តងនៃលំហូរហិរញ្ញវត្ថុអាកាសធាតុ | | រៀបចំការវាយតម្លៃប្រចាំឆ្នាំនៃលំហូរហិរញ្ញវត្ថុអាកាសធាតុ |
| យន្តការផ្តល់មូលនិធិអាកាសធាតុដែលបានប្រគល់ឱ្យដោយអង្គការ UNFCCC មានអាណត្តិលើ | | ការផ្តល់ថវិកាកាន់តែច្រើនសម្រាប់ការធ្វើចំណាកស្រុក | | ផ្តល់ហិរញ្ញវត្ថុសម្រាប់ការបន្សាំ និងការធ្វើចំណាកស្រុក |
| ការបង្កើតហិរញ្ញវត្ថុអាកាសធាតុតម្រូវឱ្យមាន | | ការគិតគូរពីតម្រូវការចំណេះដឹងបទពិសោធន៍ និងអាទិភាពដែលមានលក្ខណៈខុសគ្នារបស់ស្ត្រីជាលក្ខណៈប្រព័ន្ធ | | ការផ្តល់មូលនិធិសម្រាប់ការបន្សាំនឹងការប្រែប្រួលអាកាសធាតុដែលផ្តោតលើស្ត្រី |
| ការត្រៀមខ្លួនរួចរាល់ គំនិតច្នៃប្រឌិត និងជំនួយឥតសំណងសម្រាប់ការរៀនសូត្រអាចត្រូវបានប្រើប្រាស់ដើម្បី | | ពង្រឹងសមត្ថភាពអង្គភាពអនុវត្តនៅថ្នាក់ជាតិ ក្នុងការទទួល និងគ្រប់គ្រងហិរញ្ញប្បទានអាកាសធាតុ | | ការផ្ទេរអត្ថប្រយោជន៍ដោយផ្ទាល់ទៅអ្នកប្រើប្រាស់ថាមពលកកើតឡើងវិញ |
| ការរៀបចំថវិកាដែលឆ្លើយតបនឹងតម្រូវការយេនឌ័រ (GRB) | | គឺជាការធ្វើសមាហរណកម្មជាប្រព័ន្ធនៃគោលបំណងសមភាពទៅក្នុងគោលនយោបាយផែនការ និងថវិការបស់រដ្ឋាភិបាល | | គឺជាការអនុវត្តគណនេយ្យភាពដែលបែងចែកថវិការវាងបុរស និងស្ត្រីដោយស្មើភាព |
| GRB ត្រូវបានអនុម័តដោយ | | ប្រទេសជាង ២០នៅអាស៊ី | | ប្រទេសជាង ១០នៅអាស៊ី |

** Items in red are the incorrect answers.*

## អានបន្ថែម


1) ADB. (2016). Building Gender into Climate Finance: ADB Experience with Climate Investment Funds. Asian Development Bank. Retrieved from https://www.adb.org/sites/default/files/publication/186020/gender-climate-finance.pdf

2) Buchner, B., Clark, A., Falconer, A., Macquarie, R., Meattle, C., Tolentino, R., & Wetherbee, C. (2019). Global Landscape of Climate Finance . Climate Policy Initiative. Retrieved from https://www.climatepolicyinitiative.org/wp-content/uploads/2019/11/2019-Global-Landscape-of-Climate-Finance.pdf

3) Budlender, D., & Sharp, R. (1998). How to do a gender-sensitive budget analysis: Contemporary research and practice. The Commonwealth Secretariat. Retrieved from https://www.femtech.at/sites/default/files/How_to_do_a_gender-sensitive_budget_analysis.pdf

4) Hall, L. C., Granat, M., & Daniel, T. (2019). Women's Organizations and Climate Finance: Engaging in processes and accessing resources. Women's Environment and Development Organization (WEDO). Retrieved from https://wedo.org/wp-content/uploads/2019/06/WomensOrgsClimateFinance_EngaginginProcesses.pdf

5) Kanwar, S. (2016). Gender Responsive BUdgeting in the Asia-Pacific Region: A Status Report. UN Women. Retrieved from https://asiapacific.unwomen.org/-/media/field%20office%20eseasia/docs/publications/2016/12/grb_report-for-web-s.pdf?la=en&vs=1520

# TRAINOR’S NOTES

MODULE ____ SESSION PLAN ____ PAGE ____

AGENDA

REMINDERS

# TRAINOR’S GRID NOTES

MODULE ____ SESSION PLAN ____ PAGE ____

AGENDA

REMINDERS

# ហិរញ្ញវត្ថុអាកាសធាតុ
# សម្រាប់សកម្មភាពអាកាសធាតុ
# ដែលឆ្លើយតបនឹងតម្រូវការយេនឌ័រ

# HANDOUTS

## ម៉ូឌុល ៥៖

# 5

## ឯកសារមេរៀនទី ២១៖ ទិដ្ឋភាពទូទៅសង្ខេបនៃយន្តការហិរញ្ញវត្ថុអាកាសធាតុផ្សេងៗ

**បណ្តាញពហុភាគីសម្រាប់ហិរញ្ញវត្ថុអាកាសធាតុ៖**

> តែងតែបំបែកចេញពីរចនាសម្ព័ន្ធអភិបាលកិច្ចគ្របដណ្តប់ដោយប្រទេសជាអ្នកចូលរួមវិភាគទាន ជាពិសេសនៅក្នុងផ្នែកអភិវឌ្ឍស្ថាប័នហិរញ្ញវត្ថុ។

> ផ្តល់សំឡេងកាន់តែខ្លាំងដល់រដ្ឋាភិបាលប្រទេសកំពុងអភិវឌ្ឍន៍ និងតំណាងនៅក្នុងការធ្វើសេចក្តីសម្រេចចិត្ត។

> ប៉ុន្មានឆ្នាំមកហើយ ជំហានផ្សេងៗក្នុងការបង្កើនបរិយាបន្ន និងគណនេយ្យភាពនៅក្នុងអភិបាលកិច្ចមូលនិធិអាកាសធាតុពហុភាគីត្រូវបានធ្វើឡើង រួមបញ្ចូលទាំងការបង្កើតនូវតួនាទីសម្រាប់ភាគីពាក់ព័ន្ធដែលមិនមែនរដ្ឋាភិបាលជាអ្នកសង្កេតការណ៍ចំពោះកិច្ចប្រជុំមូលនិធិនានា។

| ក. មូលនិធិបរិស្ថានសកល (GEF) | |
|---|---|
| **ប្រភេទ**<br>យន្តការហិរញ្ញវត្ថុ UNFCCC គាំទ្រអនុសញ្ញាជាច្រើន តួអង្គធ្វើសេចក្តីសម្រេចចិត្តរបស់អនុសញ្ញា គឺក្រុមប្រឹក្សា GEF។ បច្ចុប្បន្នមណ្ឌលGEFមានអ្នកតំណាងពិសមាជិករដ្ឋាភិបាលចំនួន១៨២នាក់ និងធ្វើការជាមួយដៃគូអនុវត្តចំនួន ១៨ ដែលដើរតួជាលេខាធិការក្នុងការផ្តល់ប្រាក់ទៅអង្គការនានា។ មណ្ឌល GEF ក៏ផ្តល់មូលនិធិសម្រាប់គម្រោងផ្នែកបរិស្ថានផ្សេងៗទៀតដូចជាជីវចម្រុះនិងការប្រើប្រាស់ដី រួមជាមួយការប្រែប្រួលអាកាសធាតុ | **មូលដ្ឋានមូលនិធិ និងទំហំ**<br>ការបំពេញបន្ថែមលើកទី ៦ (ឆ្នាំ២០១៤-២០១៨)៖ ប្រទេសម្ចាស់ជំនួយចំនួន៣០ បានសន្យាផ្តល់ប្រាក់ចំនួន ១,២៦ ពាន់លានដុល្លារអាមេរិកសម្រាប់ការប្រែប្រួលអាកាសធាតុ<br><br>ការបំពេញបន្ថែមលើកទី ៧ (ឆ្នាំ២០១៩-២០២២)៖ ប្រទេសម្ចាស់ជំនួយចំនួន៣០ បានសន្យាផ្តល់ប្រាក់ចំនួន ៦៥៤ លានដុល្លារអាមេរិកសម្រាប់ការប្រែប្រួលអាកាសធាតុ |
| **ឆ្នាំ ១៩៩១** | **គម្រោងគាំទ្រដោយ**<br>គម្រោងអនុម័តដោយ GEF ទៅតាមទំហំ ចាប់ពី១លានដុល្លារអាមេរិកឡើងសម្រាប់«សកម្មភាពដែលអាចដំណើរការបាន» ចន្លោះពី ១-២ លាន សម្រាប់គម្រោង «ទំហំកណ្តាល» និងលើសពី ២លាន សម្រាប់ «ទំហំពេញលេញ»។ គិតត្រឹមខែធ្នូ ឆ្នាំ២០១៩ តាមរយៈមូលនិធិលើកទី៤ ៥ ៦ និងលើកទី៧ GEF អនុម័តជាង៧៥០គម្រោងនៅក្នុងផ្នែកគោលដៅនៃការប្រែប្រួលអាកាសធាតុដែលមានចំនួនប្រាក់២,៨ពាន់លានដុល្លារអាមេរិក ។ |

| ក១. មូលនិធិប្រទេសអភិវឌ្ឍន៍តិចតួច (LDCF) | |
|---|---|
| **ប្រភេទ**<br>យន្តការ UNFCCC គ្រប់គ្រងដោយ GEF ដើម្បីគាំទ្រដល់ការបង្កើត និងការអនុវត្តផែនការជាតិបន្សាំ ទោះបីភាគច្រើនតាមរយៈគម្រោងខ្នាតតូចនានា<br><br>**ឆ្នាំ ២០០១** | **មូលដ្ឋានមូលនិធិ និងទំហំ**<br>ពិដានមូលនិធី ២០លានដុល្លារអាមេរិករបស់ប្រទេស<br><br>**គម្រោងគាំទ្រដោយ**<br>គិតត្រឹមខែធ្នូ ឆ្នាំ២០១៩ LDCF បានធ្វើការផ្ទេរប្រាក់ចំនួន ៥៣៤លានដុល្លារអាមេរិក ទៅគម្រោងនានា |

## ក២. មូលនិធិការប្រែប្រួលអាកាសធាតុពិសេស (SCCF)

**ប្រភេទ**

យន្តការ UNFCCC គ្រប់គ្រងដោយ GEF ដើម្បីគាំទ្រដល់ការបង្កើត និងការអនុវត្តផែនការជាតិបន្សាំ ទោះបីភាគច្រើនតាមរយៈគម្រោងខ្នាតតូចនានា

**ឆ្នាំ ២០០១**

**មូលដ្ឋានមូលនិធិ និងទំហំ**

មូលនិធិខ្ពស់បំផុត ២០លានដុល្លារអាមេរិករបស់ប្រទេស

**គម្រោងគាំទ្រដោយ**

គិតត្រឹមខែធ្នូ ឆ្នាំ២០១៩ SCCF បានធ្វើការផ្ទេរប្រាក់ចំនួន ១៨១លានដុល្លារអាមេរិក

## ខ. មូលនិធិការបន្សាំ (AF)

**ប្រភេទ**

យន្តការ UNFCCC ដែលគិតត្រឹមថ្ងៃទី១ ខែមករា ឆ្នាំ២០១៩ ក៏បានចាប់ផ្តើមធ្វើកិច្ចព្រមព្រៀងទីក្រុងប៉ារីស ស្របតាមយុទ្ធសាស្ត្ររយៈពេលមធ្យម ៥ឆ្នាំ ២០១៨-២០២២ ដែលធ្វើអនុម័តថ្មី ផ្តែកលើសសរស្តម្ភនៃសកម្មភាព នាវានុវត្តន៍ និងចំណេះដឹង និងការចែករំលែក។

មូលនិធិនេះគ្រប់គ្រងដោយក្រុមប្រឹក្សាភិបាលAFដែលជួបប្រជុំពីរដងក្នុងមួយឆ្នាំ។

ផ្តល់ការទទួលបានហិរញ្ញប្បទានដោយផ្ទាល់សម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍តាមរយៈអង្គភាពអនុវត្តថ្នាក់ជាតិដែលត្រូវបានទទួលស្គាល់ដែលអាចបំពេញបានតាមការឯកភាពគ្នាដូចជាផ្នែកបរិស្ថាន សង្គម និងស្តង់ដារយេនឌ័រ។[1]

**ឆ្នាំ ២០១១**

**មូលដ្ឋានមូលនិធិ និងទំហំ**

ហិរញ្ញប្បទានតាមរយៈការយកពន្ធ ២% លើការលក់ឥណទានការបញ្ចេញឧស្ម័នពីយន្តការអភិវឌ្ឍន៍ស្អាតនៃពិធីសារក្យូតូរួមជាមួយការចូលរួមវិភាគទានផ្តល់ជំនួយពីប្រទេសអភិវឌ្ឍន៍។

**គម្រោងគាំទ្រដោយ**

គិតត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩ គម្រោងចំនួន៨៤ សម្រាប់ចំនួនប្រាក់ ៥៦០,៦លានដុល្លារអាមេរិក ត្រូវបានអនុម័តសម្រាប់ការផ្តល់មូលនិធិ។ បន្ថែមពីនេះទៀត ក្រុមប្រឹក្សាភិបាលបានអនុម័តជំនួយដល់ការបង្កើតគម្រោងចំនួន៥៦ទៀត ដែលមានប្រាក់សរុប ២,៣លានដុល្លារអាមេរិក។ បច្ចុប្បន្ននេះ គម្រោង ចំនួន ៦០ កំពុងអនុវត្តសម្រាប់ចំនួនប្រាក់ជំនួយសរុប ៣៨៤,៨លានដុល្លារអាមេរិក។ ប្រាក់សរុបចំនួន ៣៥០,២០លានដុល្លារអាមេរិកត្រូវបានផ្ទេររួចរាល់ ដើម្បីការអនុវត្តតាមអង្គភាព (៦២,៨% សម្រាប់ចំនួនទឹកប្រាក់ដែលបានយល់ព្រម)។

## គ. មូលនិធិអាកាសធាតុបៃតង (GCF)

**ប្រភេទ**

យន្តការUNFCCCក៏មានដែនសមត្ថកិច្ចធ្វើកិច្ចព្រមព្រៀងទីក្រុងប៉ារីស។ ត្រូវបានរំពឹងថាជាបណ្តាញសំខាន់សម្រាប់ហិរញ្ញវត្ថុអាកាសធាតុសាធារណៈអន្តរជាតិ។ មូលនិធិធំបំផុតតាមទឹកប្រាក់ដែលមាន និងការផ្តល់មូលនិធិដែលរំពឹងទុកការប្តេជ្ញាចិត្តចំពោះតុល្យភាព៥០:៥០ រវាងការបន្សាំ និងការកាត់បន្ថយ។

ប្រទេសកំពុងអភិវឌ្ឍន៍អាចចូលទៅប្រើប្រាស់ GCF ទាំងតាម MDBs ធនាគារពាណិជ្ជអន្តរជាតិ និងទីភ្នាក់ងារអង្គការសហប្រជាជាតិ និងដោយផ្ទាល់តាមរយៈអង្គភាពអនុវត្តថ្នាក់ជាតិ តំបន់ និងថ្នាក់ក្រោមជាតិដែលត្រូវបានទទួលស្គាល់។GCFត្រូវបានផ្តល់មូលនិធិដោយផ្តោតខ្លាំងលើគោលការណ៍ភាពជាម្ចាស់ប្រទេសហើយប្រទេសនីមួយៗមានអាជ្ញាធរជាតិទទួលបន្ទុកមួយ (NDA) ជាញឹកញាប់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឬក្រសួងបរិស្ថាន ជាមួយជនបង្គោលទទួលបន្ទុកម្នាក់ ដើម្បីធ្វើការជាអ្នកតំណាងរវាង NDA និង GCF។

**ឆ្នាំ ២០១០**

**មូលដ្ឋានមូលនិធិ និងទំហំ**

ការបំពេញបន្ថែមលើកទី ១ (ឆ្នាំ២០២០-២០២៣)៖ ប្រទេសម្ចាស់ជំនួយចំនួន២៩ បានសន្យាផ្តល់ប្រាក់ចំនួន ៩,៧៨ ពាន់លានដុល្លារអាមេរិកសម្រាប់ការប្រែប្រួលអាកាសធាតុ

**គម្រោងគាំទ្រដោយ**

គិតត្រឹមខែតុលា ឆ្នាំ២០១៩ បណ្តាញដៃគូអនុវត្ត នៃGCF បានកើនឡើងដល់៩៥អង្គភាពដែលត្រូវបានទទួលបានស្គាល់។ GCF បានគាំទ្រប្រទេសកំពុងអភិវឌ្ឍន៍ចំនួន ១២៦ រួចមកហើយ ក្នុងការកសាងការត្រៀមខ្លួន ដើម្បីអនុវត្តហិរញ្ញវត្ថុអាកាសធាតុ និងប្តេជ្ញាផ្តល់ ៥,២១ពាន់លានដុល្លារដល់គម្រោង១១១ នៅក្នុងប្រទេសចំនួន៩៩។

គម្រោងសរុបចំនួន៦៥មានតម្លៃ២,៨២ពាន់លានដុល្លារអាមេរិក នៅក្នុងការផ្តល់មូលនិធិ GCF កំពុងស្ថិតក្រោមការអនុវត្ត និងការជួយដល់ប្រទេសកំពុងអភិវឌ្ឍន៍ក្នុងការផ្លាស់ប្តូរមហិច្ឆតាអាកាសធាតុរបស់ពួកគេទៅជាសកម្មភាព

## ឃ. មូលនិធិវិនិយោគលើអាកាសធាតុ (CIFs)

**ប្រភេទ**
យន្តការមិនមែន UNFCCC គ្រប់គ្រងដោយធនាគារពិភពលោក។

ប្រតិបត្តិការជាដៃគូជាមួយធនាគារអភិវឌ្ឍន៍តំបន់រួមមាន៖
- ធនាគារអភិវឌ្ឍន៍អាហ្រ្វិក (AfDB)
- ធនាគារអភិវឌ្ឍន៍អាស៊ី (ADB)
- ធនាគារអឺរ៉ុបសម្រាប់ការសាងសង់ឡើងវិញ និងការអភិវឌ្ឍន៍(EBRD)
- ធនាគារអភិវឌ្ឍន៍អន្តរទ្វីបអាមេរិក (IDB)

ផ្តល់មូលនិធិដល់កិច្ចអន្តរាគមន៍កម្មវិធីនៅតាមប្រទេសកំពុងអភិវឌ្ឍន៍ ដោយមានគោលបំណងស្វែងយល់ពីរបៀបដែលហិរញ្ញវត្ថុសាធារណៈ បែងចែកយ៉ាងល្អបំផុត ដើម្បីជួយដល់គន្លងអភិវឌ្ឍន៍ប្រកបដោយការផ្លាស់ប្តូរ។

មានឃ្លាមួយនិយាយពីកាលបរិច្ឆេទផុតកំណត់ ដែលត្រូវបានពន្យារពេលយ៉ាងត្រឹមត្រូវនៅក្នុងឆ្នាំ២០១៩។
**ឆ្នាំ ២០០៨**

**មូលដ្ឋានមូលនិធិ និងទំហំ**
ទំហំប្រាក់សរុបចំនួន ៨,៣ពាន់លានដុល្លារអាមេរិក ដែលជាការសន្យាចូលរួមចំណែកដោយប្រទេសចំនួន១៤។

ដោយសារវាដំណើរការផ្អែកលើចនាសម្ព័ន្ធសហហិរញ្ញវត្ថុវារំពឹងថាគម្រោងជាង ៣០០របស់វា រកបានហិរញ្ញវត្ថុបន្ថែម ៥៨ពាន់លានដុល្លារ ជាសហហិរញ្ញវត្ថុ (co-finance)។

**គម្រោងគាំទ្រដោយ**
ផ្តល់ធនធាននានាដល់ប្រទេសចំនួន៧២

## ឃ១. មូលនិធិបច្ចេកវិទ្យាស្អាត

**ប្រភេទ**
ផ្តល់ឱ្យប្រទេសមានប្រាក់ចំណូលមធ្យមជាមួយធនធានសម្បទានយ៉ាងច្រើន ដើម្បីពង្រីកការបង្ហាញ ការអភិវឌ្ឍ និងផ្ទេរបច្ចេកវិទ្យាកាបូនទាបទៅក្នុងថាមពលកកើតឡើងវិញ ប្រសិទ្ធភាពថាមពល និងការដឹកជញ្ជូនដែលមាននិរន្តរភាព។

**ឆ្នាំ ២០០៨**

**មូលដ្ឋានមូលនិធិ និងទំហំ**
ទំហំប្រាក់សរុបចំនួន៥,៤ពាន់លានដុល្លារអាមេរិកដែលជាការចូលរួលចំណែក

**គម្រោងគាំទ្រដោយ**
នៅត្រឹមខែធ្នូ ឆ្នាំ២០១៩ សាច់ប្រាក់ចំនួន ១,៦៥ពាន់លានដុល្លារអាមេរិក ផ្ទេរទៅគម្រោងរហូតដល់បច្ចុប្បន្ននេះ

## ឃ២. មូលនិធិអាកាសធាតុយុទ្ធសាស្រ្ត (SCF)

**ប្រភេទ**
គាំទ្រដល់កម្មវិធីសាកល្បងសម្រាប់ភាពធន់នឹងអាកាសធាតុ (PPCR) កម្មវិធីពង្រីកថាមពលកកើតឡើងវិញនៅក្នុងកម្មវិធីប្រទេសដែលមានប្រាក់ចំណូលទាប (SREP) និងកម្មវិធីវិនិយោគព្រៃឈើ (FIP)។

**ឆ្នាំ ២០០៨**

**មូលដ្ឋានមូលនិធិ និងទំហំ**
ទំហំប្រាក់សរុបចំនួន ២,៦១ ពាន់លានដុល្លារអាមេរិក ដែលជាការចូលរួលចំណែក

**គម្រោងគាំទ្រដោយ**
គិតត្រឹមខែធ្នូ ឆ្នាំ២០១៩ សាច់ប្រាក់ចំនួន ៨១៨ពាន់លានដុល្លារអាមេរិកផ្ទេរទៅគម្រោង

## ឃ.២.១ កម្មវិធីសាកល្បងសម្រាប់ភាពធន់នឹងអាកាសធាតុ (PPCR)

**ប្រភេទ**
ជួយប្រទេសកំពុងអភិវឌ្ឍន៍ឲ្យបញ្ចូលភាពធន់នឹងអាកាសធាតុទៅក្នុងការរៀបចំផែនការអភិវឌ្ឍន៍ និងផ្តល់នូវសម្បទាន និងមូលនិធិជំនួយដើម្បីគាំទ្រដល់ការវិនិយោគវិស័យឯកជន និងវិស័យសាធារណៈសម្រាប់ការអនុវត្ត។

**មូលដ្ឋានមូលនិធិ និងទំហំ**
ទំហំប្រាក់សរុបចំនួន១,២ពាន់លានដុល្លារអាមេរិក

**គម្រោងគាំទ្រដោយ**
PPCR បានគាំទ្រដល់ SIDS ជាមួយទំហំប្រាក់ ២៥០លានដុល្លារ សម្រាប់តំបន់ការ៉ាប៊ីន ចំនួន៩ និងប្រទេសកោះ

## ឃ.២.១ កម្មវិធីសាកល្បងសម្រាប់ភាពធន់នឹងអាកាសធាតុ (PPCR)

PPCR វិនិយោគនៅក្នុងប្រទេសដែលងាយរងគ្រោះបំផុតមួយចំនួននៅលើពិភពលោក។ ស្ថិតនៅជួរមុខនៃការប្រែប្រួលអាកាសធាតុ គឺផ្តោតលើរដ្ឋកំពុងអភិវឌ្ឍន៍លើកោះតូចៗ (SIDS)។

ឆ្នាំ ២០០៨

ប៉ាស៊ីហ្វិក ២០% នៃធនធាន PPCR។ PPCR ក៏បានវិនិយោគជាង ២០០លានដុល្លារសម្រាប់ប្រទេសដែលរងគ្រោះបំផុតក្នុងការកែលម្អទិន្នន័យអាកាសធាតុនិងសេវាសម្រាប់ការរៀបចំគម្រោងឆ្លាតខាងអាកាសធាតុ។

## ឃ.២.២ កម្មវិធីវិនិយោគលើព្រៃឈើ (FIP)

**ប្រវត្តិ**
គាំទ្រដល់កិច្ចប្រឹងប្រែងរបស់ប្រទេសកំពុងអភិវឌ្ឍន៍ ដើម្បីកាត់បន្ថយការបាត់បង់ព្រៃឈើ និងការរេចរិលព្រៃឈើ ហើយជំរុញការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាពឆ្ពោះទៅរកការកាត់បន្ថយការបញ្ចេញឧស្ម័ន និងការបង្កើនការបង្ខាំងកាបូនព្រៃឈើ (REDD+)។ យន្តការផ្តល់ជំនួយសម្រាប់ក្រុមជនជាតិភាគតិច និងសហគមន៍មូលដ្ឋាន (DGM) ក៏មានអនុវត្តស្ថិតនៅក្រោមកម្មវិធីនេះដែរ ដែលផ្តល់ជំនួយខ្នាតតូចដោយផ្ទាល់ទៅអង្គការសង្គមស៊ីវិលជាជាងតាមរយៈរដ្ឋាភិបាលថ្នាក់ជាតិ។

ឆ្នាំ ២០០៨

**មូលដ្ឋានមូលនិធិ និងទំហំ**
ទំហំប្រាក់សរុប៧៧៥លានដុល្លារអាមេរិក

**គម្រោងគាំទ្រដោយ**
កន្លងមក DGM បានឯកភាពនូវទំហំប្រាក់ ៥១លានដុល្លារអាមេរិក នៅក្នុងគម្រោងខុសៗគ្នាចំនួនដប់នៅទូទាំងពិភពលោក ប៉ុន្តែនៅតំបន់អាស៊ីប៉ាស៊ីហ្វិក កំពុងដំណើរការសម្រាប់ប្រទេសសាកល្បងរបស់វាតែប៉ុណ្ណោះ រួមមានឥណ្ឌូណេស៊ី នេប៉ាល់ និងឡាវ។

## ឃ.២.៣ កម្មវិធីពង្រីកថាមពលកកើតឡើងវិញសម្រាប់ប្រទេសដែលមានប្រាក់ចំណូលទាប (SREP)

**ប្រវត្តិ**
ជួយដាក់ឱ្យប្រើប្រាស់ដំណោះស្រាយថាមពលកកើតឡើងវិញ សម្រាប់បង្កើនការទទួលបានការប្រើប្រាស់ថាមពលនិងកំណើនសេដ្ឋកិច្ចនៅក្នុងប្រទេសក្រីក្របំផុតនៅក្នុងពិភពលោក។

ឆ្នាំ ២០០៨

**មូលដ្ឋានមូលនិធិ និងទំហំ**
ទំហំប្រាក់សរុប៧២០លានដុល្លារអាមេរិក

**គម្រោងគាំទ្រដោយ**
SREP គឺជាម្ចាស់ជំនួយសកលធំជាងគេមួយនៃបណ្តាញអគ្គិសនីតូចៗមានទឹកប្រាក់ជាង២០០លានដុល្លារសម្រាប់គម្រោងនានាក្នុងប្រទេសចំនួន១៤។

## ខ. ធនាគារអភិវឌ្ឍន៍ពហុភាគី (MDBs)

## ខ១. មូលនិធិដៃគូកាបូនព្រៃឈើ (FCPF)

**ប្រវត្តិ**
គ្រប់គ្រងដោយធនាគារពិភពលោក ដើម្បីស្វែងរកពីរបៀបប្រាក់ចំណូលពីទីផ្សារកាបូនអាចយកមកប្រើប្រាស់បាន ដើម្បីកាត់បន្ថយការបញ្ចេញឧស្ម័នពីការបាត់បង់ព្រៃឈើ និងការរេចរិលព្រៃឈើ ការអភិរក្សព្រៃឈើ ការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាពនិងការបង្កើនការបង្ខាំងកាបូនព្រៃឈើ (REDD+)។

ឆ្នាំ ២០០៨

**មូលដ្ឋានមូលនិធិ និងទំហំ**
ទំហំប្រាក់សរុប១,៣ពាន់លានដុល្លារអាមេរិក ពីម្ចាស់ជំនួយ១៧

**គម្រោងគាំទ្រដោយ**
FCPF គាំទ្រដល់កិច្ចប្រឹងប្រែង REDD+ តាមរយៈមូលនិធិការត្រៀមរបស់វា (ចំនួន ៤០០លានដុល្លារអាមេរិក) និងមូលនិធិកាបូន (ចំនួន ៩០០លានដុល្លារអាមេរិក) នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ចំនួន៤៧ ទូទាំងតំបន់អាហ្វ្រិក អាស៊ី និងអាមេរិកខាងត្បូង និងតំបន់ការ៉ាប៊ីន។

## ខ. ធនាគារអភិវឌ្ឍន៍ពហុភាគី (MDBs)

### ១២. ភាពជាដៃគូសម្រាប់ការត្រៀមចូលទីផ្សារ (PMR)

**ប្រភេទ**
គ្រប់គ្រងដោយធនាគារពិភពលោក។PMRមានបំណងជួយប្រទេសកំពុងអភិវឌ្ឍន៍បង្កើតយន្តការផ្អែកលើទីផ្សារក្នុងការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ

**ឆ្នាំ ២០១០**

**មូលដ្ឋានមូលនិធិ និងទំហំ**
គិតត្រឹមថ្ងៃទី៣១ខែមីនាឆ្នាំ២០១៥ចំនួនទឹកប្រាក់វិភាគទានដែលសន្យាប្រមាណ ១២៦,៥លានដុល្លារ ខណៈដែលទឹកប្រាក់វិភាគទានដែលទទួលបានសរុបស្មើនឹងចំនួន១២៧លានដុល្លារអាមេរិក។

**គម្រោងគាំទ្រដោយ**
PMR បានប្រមូលផ្តុំរួមគ្នាជាង ៣០ប្រទេស អង្គការអន្តរជាតិផ្សេងៗនិងអ្នកជំនាញការបច្ចេកទេសដើម្បីជួយសម្របសម្រួលការផ្លាស់ប្តូរប្រទេសមួយទៅប្រទេសមួយ និងការចែករំលែកចំណេះដឹង ហើយអាចជួយបង្កើនកិច្ចសហប្រតិបត្តិការ និងការច្នៃប្រឌិត។

### ១៣.គំនិតផ្តួចផ្តើមមូលនិធិភាបូនជីវឧស្ម័នសម្រាប់ទេសភាពព្រៃឈើប្រកបដោយនិរន្តរភាព (ISFL)

**ប្រភេទ**
គ្រប់គ្រងដោយធនាគារពិភពលោកវាគឺជាភាពជាដៃគូសាធារណៈនិងឯកជន។វាជំរុញការកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ពីផ្នែកដីធ្លីក្នុងនោះរួមមានកិច្ចខិតខំប្រឹងប្រែងដើម្បីកាត់បន្ថយការហិនហោចព្រៃឈើនិងកាប់បំផ្លាញព្រៃឈើនៅតាមបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ (REDD+) កសិកម្មប្រកបដោយនិរន្តភាព ព្រមទាំងផែនការប្រើប្រាស់ដីប្រកបដោយភាពឆ្លាតវៃជាងមុន គោលនយោបាយ និងការអនុវត្ត។

**ឆ្នាំ ២០១៣**

**មូលដ្ឋានមូលនិធិ និងទំហំ**
ទំហំប្រាក់សរុប ៣៥៥លានដុល្លារអាមេរិក

**គម្រោងគាំទ្រដោយ**
បច្ចុប្បន្ននេះ ISFL គាំទ្រកម្មវិធីនៅក្នុងប្រទេសកូឡុំប៊ី អេត្យូពី ឥណ្ឌូណេស៊ី ម៉ិចស៊ិកូ និងប្រទេសហ្សំប៊ី។

### ១៤. មូលនិធិការប្រែប្រួលអាកាសធាតុ (CCF)

**ប្រភេទ**
គ្រប់គ្រងដោយធនាគារអភិវឌ្ឍន៍អាស៊ី។CCFជួយសម្របសម្រួលការវិនិយោគនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ជាសមាជិក (DMCs) ដើម្បីដោះស្រាយប្រកបដោយប្រសិទ្ធភាពនូវបុព្វហេតុ និងផលវិបាកនៃការប្រែប្រួលអាកាសធាតុដោយការពង្រឹងគាំទ្រការអភិវឌ្ឍកាបូនទាប និងភាពធន់នឹងអាកាសធាតុ នៅក្នុង DMCs។

**ឆ្នាំ ២០០៨**

**មូលដ្ឋានមូលនិធិ និងទំហំ**
ទំហំប្រាក់ ៧៤លានដុល្លារអាមេរិក

**គម្រោងគាំទ្រដោយ**
ត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ ទំហំប្រាក់ចំនួន ៧១,៦លានដុល្លារអាមេរិក នៃទំហំប្រាក់មូលនិធិសរុបចំនួន ៧៤លានដុល្លារអាមេរិក (ប្រាក់សន្សំសុទ្ធ) ត្រូវបានបែងចែកទៅ ១១៨គម្រោង - ៤៤គម្រោងលើការបង្កើត CE ៦៦គម្រោងលើការបន្សាំ ១១គម្រោងលើ REDD+ និងការប្រើប្រាស់ដី និង១គម្រោងលើការត្រៀមខ្លួនហិរញ្ញអាកាសធាតុ។

### ១៥. មូលនិធិការប្រែប្រួលអាកាសធាតុអាស៊ីប៉ាស៊ីហ្វិក (ACliFF)

**ប្រភេទ**
ស្ថាប័ណមូលនិធិពហុម្ចាស់ជំនួយគ្រប់គ្រងដោយធនាគារអភិវឌ្ឍន៍អាស៊ី ដើម្បីគាំទ្រដល់ការអភិវឌ្ឍ និងការអនុវត្តផលិតផលគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ ដែលអាចជួយបើកដើមទុនសម្រាប់ការវិនិយោគ

**មូលដ្ឋានមូលនិធិ និងទំហំ**
ទំហំប្រាក់៣៣,៣លានដុល្លារអាមេរិក

**គម្រោងគាំទ្រដោយ**
គ្មាន

នានានិងកែលម្អភាពធន់នឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។

ឆ្នាំ ២០១៧

### ខ៦. មូលនិធិភាពធន់នឹងការប្រែប្រួលអាកាសធាតុតំបន់ទីក្រុង (UCCRTF)

**ប្រភេទ**

មូលនិធិពហុម្ចាស់ជំនួយគ្រប់គ្រងដោយធនាគារអភិវឌ្ឍន៍អាស៊ី ដើម្បីគាំទ្រដល់ទីក្រុងរីកលូតលាស់លឿននៅក្នុងតំបន់អាស៊ីក្នុងការកាត់បន្ថយហានិភ័យរបស់អ្នកក្រីក្រ និងប្រជាជនដែលងាយរងគ្រោះប្រឈមនឹងទឹកជំនន់ ខ្យល់ព្យុះ និងភាពរាំងស្ងួតតាមរយៈការជួយរៀបចំផែនការ និងរៀបចំហេដ្ឋារចនាសម្ព័ន្ធឱ្យកាន់តែល្អប្រសើរឡើង ដើម្បីវិនិយោគប្រឆាំងនឹងផលប៉ះពាល់ទាំងនេះ។

ឆ្នាំ ២០១៣

**មូលដ្ឋានមូលនិធិ និងទំហំ**

ទំហំប្រាក់ចំនួន១៥០លានដុល្លារអាមេរិក

**គម្រោងគាំទ្រដោយ**

គិតត្រឹមខែធ្នូ ឆ្នាំ២០១៩ ទំហំប្រាក់ចំនួន ១៣០លានដុល្លារអាមេរិកត្រូវបានបញ្ជូនពីមូលនិធិនេះទៅទីក្រុងផ្សេងៗនៅក្នុងប្រទេសបង់ក្លាដេស ឥណ្ឌា ឥណ្ឌូណេស៊ី មីយ៉ាន់ម៉ា នេប៉ាល់ ប៉ាគីស្ថាន ហ្វីលីពីន និងប្រទេសវៀតណាម។

## ច. ទីភ្នាក់ងារអង្គការសហប្រជាជាតិ

### ច១. កម្មវិធីជំនួយខ្នាតតូចរបស់ UNDP GEF

**ប្រភេទ**

គ្រប់គ្រងដោយអង្គការ UNDP ផ្តល់ការគាំទ្រផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេសដល់គម្រោងដែលអភិរក្សនិងស្តារបរិស្ថានឡើងវិញទន្ទឹមនឹងការបង្កើនសុខមាលភាពរបស់ប្រជាជន និងជីវភាពរស់នៅ។ កម្មវិធីនេះផ្តល់ជំនួយរហូតដល់ ៥០០០០ដុល្លារ ដោយផ្ទាល់ទៅសហគមន៍មូលដ្ឋានរួមមានប្រជាជនជនជាតិភាគតិចអង្គការផ្អែកលើសហគមន៍និងគម្រោងជាក្រុមដែលមិនមែនរដ្ឋាភិបាលផ្នែកជីវចម្រុះការកាត់បន្ថយនិងការបន្ស៊ាំទៅនឹងការប្រែប្រួលអាកាសធាតុ ការរេចរិលដី និងការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព សមុទ្រអន្តរជាតិ និងការប្រើជីគីមី។

ឆ្នាំ ១៩៩២

**មូលដ្ឋានមូលនិធិ និងទំហំ**

ទំហំប្រាក់ចំនួន៥២៦លានដុល្លារអាមេរិក

**គម្រោងគាំទ្រដោយ**

គម្រោងចំនួន ៥៣៩១ ជាមួយប្រាក់ជំនួយសរុបចំនួន ១៥៩លានដុល្លារអាមេរិក ត្រូវបានឧបត្ថម្ភសម្រាប់ការកាត់បន្ថយការប្រែប្រួលអាកាសធាតុ។

គម្រោង ៧៩៨ ដែលមានប្រាក់ចំនួន ២៤លានដុល្លារអាមេរិកត្រូវបានឧបត្ថម្ភសម្រាប់ការបន្ស៊ាំទៅនឹងការប្រែប្រួលអាកាសធាតុផ្អែកលើសហគមន៍

### ច២. កម្មវិធី UN-REDD

**ប្រភេទ**

គ្រប់គ្រងដោយអង្គការ UNDP អង្គការ UNEP និងអង្គការ FAO ដើម្បីគាំទ្រដល់សកម្មភាព REDD+ ជាមួយរចនាសម្ព័ន្ធអភិបាលកិច្ចដែលផ្តល់សំឡេងជាផ្លូវការទៅតំណាងនៃអង្គការសង្គមស៊ីវិល និងអង្គការជនជាតិដើមភាគតិច។

ឆ្នាំ ២០០៨

**មូលដ្ឋានមូលនិធិ និងទំហំ**

គ្មាន

**គម្រោងគាំទ្រដោយ**

ក្នុងរយៈពេលជាងមួយទសវត្សកន្លងមកកម្មវិធីនេះបានធ្វើការជាមួយប្រទេសជាដៃគូចំនួន៦៤ ដើម្បីសម្រេចជោគជ័យនូវអាកាសធាតុល្អ ព្រៃឈើ និងគោលដៅអភិវឌ្ឍន៍។

### ច២. កម្មវិធី UN-REDD

**ប្រភេទ**

គ្រប់គ្រងដោយមូលនិធិអន្តរជាតិសម្រាប់អភិវឌ្ឍន៍កសិកម្ម (IFAD) ដើម្បីគាំទ្រដល់កសិករខ្នាតតូចនៅក្នុងការបង្កើនការបន្ស៊ាំទៅនឹងការប្រែប្រួលអាកាសធាតុនៅក្នុងកម្មវិធីអភិវឌ្ឍន៍តំបន់ជនបទ។

**មូលដ្ឋានមូលនិធិ និងទំហំ**

ASAP ១ (ឆ្នាំ២០១២ - ១៧)៖ ទំហំប្រាក់ ៣១៦,២លានដុល្លារអាមេរិក

ASAP២៖ ទំហំប្រាក់ចំនួន ១០០លានដុល្លារអាមេរិក

| | |
|---|---|
| ឆ្នាំ ២០១២ | **គម្រោងគាំទ្រដោយ**<br>គិតត្រឹមខែសីហា ឆ្នាំ២០១៨ គម្រោងចំនួន៤២ ត្រូវបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងរបស់រដ្ឋាភិបាល គម្រោងចំនួន៣៧ត្រូវបានអនុម័តនិងចាប់ផ្តើមផ្តល់ទៅឱ្យដែលមានទំហំថវិកាសរុបចំនួន៨០លានដុល្លារអាមេរិក។ ទំហំថវិកាចំនួន២៩២,៦លានដុល្លារអាមេរិកត្រូវបានបញ្ជូនទៅកសិករខ្នាតតូចយ៉ាងតិចចំនួន៨លានដុល្លារអាមេរិកដើម្បីកសាងភាពធន់របស់ពួកគេទៅនឹងបញ្ហា និងស្ត្រេសពាក់ព័ន្ធនឹងអាកាសធាតុ។ |

## បណ្តាញទ្វេភាគីសម្រាប់ហិរញ្ញវត្ថុអាកាសធាតុ

- លំហូរដោយផ្ទាល់នៃមូលនិធិពីប្រទេសអភិវឌ្ឍន៍ទៅប្រទេសកំពុងអភិវឌ្ឍន៍ក្នុងទម្រង់ជាជំនួយអភិវឌ្ឍន៍ក្រៅប្រទេសឬជំនួយអន្តរជាតិ។
- គ្រប់គ្រងដោយទីភ្នាក់ងារអភិវឌ្ឍន៍ដែលមានស្រាប់ ទោះបីប្រទេសមួយចំនួន បានបង្កើតមូលនិធិអាកាសធាតុទ្វេភាគីពិសេសហើយក្តី

| ក. គំនិតផ្តួចផ្តើមអាកាសធាតុអន្តរជាតិ | |
|---|---|
| **ប្រភេទ**<br>គាំទ្រដោយប្រទេសអាល្លឺម៉ង់ សម្រាប់គម្រោងការកាត់បន្ថយ ការបន្សាំ និងគម្រោង REDD+។ គំនិតផ្តួចផ្តើមនេះត្រូវបានផ្តល់ហិរញ្ញប្បទានប្រកបដោយភាពច្នៃប្រឌិតមួយផ្នែក តាមរយៈការលក់វិញ្ញាណបនបត្រការបញ្ចេញឧស្ម័នដែលអាចធ្វើពាណិជ្ជកម្មបានថ្នាក់ជាតិ ដែលផ្តល់ហិរញ្ញវត្ថុបន្ថែមដ៏ធំទៅលើការប្តេជ្ញាចិត្តផ្តល់ហិរញ្ញវត្ថុអភិវឌ្ឍន៍ដែលមានស្រាប់។<br><br>**ឆ្នាំ ២០០៨** | **មូលនិធិលម្អិត**<br>ផ្តល់ទំហំថវិកាជាង ៤ពាន់លានដុល្លារអាមេរិក សម្រាប់ការកាត់បន្ថយ ការបន្សាំ និង REDD+ ជាង ៧០០គម្រោង |

| ខ. មូលនិធិអាកាសធាតុអន្តរជាតិ | |
|---|---|
| **ប្រភេទ**<br>គាំទ្រដោយរដ្ឋាភិបាលអង់គ្លេស<br><br>**ឆ្នាំ ២០១៦** | **មូលនិធិលម្អិត**<br>សន្យាផ្តល់ថវិកាទំហំ ៥,៨ពាន់លាន ចាប់ពីឆ្នាំ២០១៦ ដល់ឆ្នាំ២០២១ |

| គ. មូលនិធិសកម្មភាពជាតិកាត់បន្ថយសមស្រប | |
|---|---|
| **ប្រភេទ**<br>គាំទ្រដោយប្រទេសអាល្លឺម៉ង់ ដាណឺម៉ាក រាជាណាចក្រអង់គ្លេស និង EC សម្រាប់សកម្មភាពកាត់បន្ថយសមស្របថ្នាក់ជាតិ (NAMAs) នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍និងសេដ្ឋកិច្ចកំពុងរីកចម្រើនដែលចង់អនុវត្តវិធានការកាត់បន្ថយដែលធំហួសប្រមាណ។ | **មូលនិធិលម្អិត**<br>នៅខែមករា ឆ្នាំ២០២០ មូលនិធិ NAMA បានប្រកាសសន្យាផ្តល់មូលនិធិថ្មីរហូតដល់៦០លានអឺរ៉ូពីប្រទេសអាល្លឺម៉ង់និងព្រះរាជាណាចក្រអង់គ្លេស ជាការគាំទ្រដល់ការអំពាវនាវឱ្យដាក់ពាក្យលើកទី៧ នៃគ្រោង NPS។ បន្ថែមពីនេះទៀត ដោយទទួលស្គាល់ចំណុចខ្លាំងនៃលំហូរគម្រោងមូលនិធិ NAMA និងការសន្យារបស់ប្រទេសចំពោះមូលនិធិ NAMA ព្រះរាជាណាចក្រអង់គ្លេសបានប្រកាសផ្តល់វិភាគទានបន្ថែមរហូតដល់ចំនួន ៣៨លានអឺរ៉ូ ចំពោះមូលនិធិ NAMA ដើម្បីគាំទ្រ NSPs ចាប់ពីការអំពាវនាវកាលពីមុន និងការអំពាវនាវពេលខាងមុខ។ |

## ឃ. គំនិតផ្តួចផ្តើមអាកាសធាតុ និងព្រៃឈើអន្តរជាតិ

| ប្រភេទ | មូលនិធិលម្អិត |
|---|---|
| គាំទ្រដោយប្រទេសន័រវែស តាមរយៈដៃគូទ្វេភាគី បណ្តាញពហុភាគី និងសង្គមស៊ីវិល។<br><br>ឆ្នាំ ២០០៨ | បានសន្យាផ្តល់ថវិកាទំហំ ៣៥០លានដុល្លារអាមេរិករៀងរាល់ឆ្នាំ។ ការសន្យាទៅតាមទំហំដែលបានធ្វើឡើងសម្រាប់សកម្មភាព REDD+ នៅប្រទេសប្រេស៊ីល ឥណ្ឌូណេស៊ី តង់ហ្សានី និងប្រទេសហ្គុយយ៉ាណា។ |

**បណ្តាញថ្នាក់តំបន់ និងបណ្តាញថ្នាក់ជាតិ ហើយនិងមូលនិធិការប្រែប្រួលអាកាសធាតុ**

> បង្កើតឡើងដោយប្រទេសកំពុងអភិវឌ្ឍន៍នៅកម្រិតតំបន់ និង/ឬ កម្រិតជាតិ ជាមួយទម្រង់ និងមុខងារផ្សេងៗគ្នា ដែលផ្តល់ធនធានតាមរយៈហិរញ្ញវត្ថុអន្តរជាតិ និង/ឬ ការបែងចែកកញ្ចប់ថវិកាក្នុងស្រុក ហើយនិងវិស័យឯកជនក្នុងស្រុក។

## ក. មូលនិធិត្រឹះការប្រែប្រួលអាកាសធាតុឥណ្ឌូណេស៊ី (ICCTF)

| ប្រភេទ | មូលនិធិលម្អិត |
|---|---|
| អង្គភាពផ្តល់មូលនិធិថ្នាក់ជាតិដែលមានបំណងបង្កើតវិធីដែលមានការច្នៃប្រឌិត ដើម្បីភ្ជាប់ទំនាក់ទំនងប្រភពហិរញ្ញវត្ថុអន្តរជាតិជាមួយយុទ្ធសាស្ត្រវិនិយោគថ្នាក់ជាតិ។ ដែលបង្កើតឡើងដោយរដ្ឋាភិបាលឥណ្ឌូណេស៊ី (GOI) វាដើរតួជាការតាលីករមួយស្រូបទាញនូវការវិនិយោគ និងដើម្បីអនុវត្តយន្តការផ្តល់ហិរញ្ញវត្ថុបែបផ្សេងៗតាមលំដាប់លំដោយសម្រាប់កម្មវិធីការកាត់បន្ថយនិងការបន្សាំការប្រែប្រួលអាកាសធាតុ។<br><br>ឆ្នាំ ២០០៩ | ICCTFទទួលបានវិភាគទានដែលមិនអាចដកយកមកវិញបានពីម្ចាស់ជំនួយទ្វេភាគី និងពហុភាគី។ យន្តការផ្តល់មូលនិធិសំខាន់នៃICCTFគឺ«មូលនិធិការច្នៃប្រឌិត»ដែលផ្តល់ជំនួយតាមបណ្តាញក្រសួង ដើម្បីគាំទ្រគម្រោងពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុទៅតាម GOI។ ជាមួយគម្រោងនានាដែលគ្រប់គ្រងដោយអង្គការ UNDP ដើរតួជាអ្នកគ្រប់គ្រងមូលនិធិបណ្តោះអាសន្ន ក្នុងរយៈពេលគម្រោងដែលបានជ្រើសរើសត្រូវបានកំណត់មួយឆ្នាំ ខណៈដែលកញ្ចប់ថវិកាគម្រោង ត្រូវបានកំណត់ត្រឹម ៣លានដុល្លារអាមេរិក។ |

## ខ. មូលនិធិការប្រែប្រួលអាកាសធាតុបង់ក្លាដេស (BCCTF)

| ប្រភេទ | មូលនិធិលម្អិត |
|---|---|
| មូលនិធិថ្នាក់ជាតិបានបង្កើតឡើងតាមរយៈការអនុម័តច្បាប់ស្តីពីស្ថាប័នការប្រែប្រួលអាកាសធាតុ នៅឆ្នាំ២០១០។<br><br>គ្រប់គ្រងដោយមូលនិធិ Palli Karma-Sahayak (PKSF) សម្រាប់ការផ្តល់មូលនិធិដល់អង្គការ NGOs មូលដ្ឋាន សម្រាប់ការធ្វើចម្ការអនាម័យសន្តិសុខស្បៀងការកសាងសមត្ថភាពនិងប្រភេទសកម្មភាពស្រាវជ្រាវ ផ្សេងៗ។<br><br>ឆ្នាំ ២០១០ | ស្ថិតក្នុងជំហ៊ានមួយក្នុងចំណោមជំហ៊ានដំបូងៗ រដ្ឋាភិបាលបង់ក្លាដេស (GOB) កំណត់ដាក់មួយឡែកនៅឆ្នាំ FY ២០០៩ - ១០ ការបែងចែកកញ្ចប់ថវិកាចំនួន ៧ ០០០ ០០០ ០០០ តាកា(Taka) (ស្មើនឹង ៨៧,៥លានដុល្លារអាមេរិក) ពីធនធានផ្ទាល់ខ្លួនសម្រាប់មូលនិធិនេះ។ ហិរញ្ញវត្ថុរបស់ប្រទេសបង់ក្លាដែស បែងចែកជាទៀងទាត់ប្រមាណ ១ ០០០ ០០០ ០០០តាកា (ប្រហែល ១២,៥លានដុល្លារអាមេរិក) ជារៀងរាល់ឆ្នាំ ដើម្បីផ្តល់មូលនិធិដល់គំនិតផ្តួចផ្តើមនានារបស់រដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល (NGOs) និងអង្គភាពស្រាវជ្រាវផ្នែកការគ្រប់គ្រងការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ។ រដ្ឋាភិបាលបន្តគាំទ្រដល់មូលនិធិនេះ និងនៅឆ្នាំ២០១៦បានបែងចែកស្មើនឹងប្រមាណ៤០០លានដុល្លាអាមេរិក ដើម្បីភាពជឿជាក់។<br><br>នៅត្រឹមថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៦ PKSF បានផ្តល់ថវិកាចំនួន ២៣៨ ៥០០ ០០០ (ប្រហែល ២.៩៨លានដុល្លារអាមេរិក) ទៅដល់អង្គការមិនមែនរដ្ឋាភិបាលចំនួន ៦១។ |

## គ. មូលនិធិសម្ព័ន្ធការប្រែប្រួលអាកាសធាតុកម្ពុជា (CCCA)

| ប្រភេទ | មូលនិធិលម្អិត |
|---|---|
| មូលនិធិCCCAជាមូលនិធិពហុម្ចាស់ជំនួយដែលត្រូវបានបង្កើតឡើងដោយម្ចាស់CCCAនិងរដ្ឋាភិបាលដើម្បីអនុវត្តវិធីសាស្ត្រដែលកាន់តែជាប់ទាក់ទងគ្នាក្នុងការគាំទ្រដល់ការប្រែប្រួលអាកាសធាតុសម្រាប់កម្ពុជា។ CCCA ត្រូវបានអនុវត្តតាមលំដាប់លំដោយនៃជំនួយ ដែលសកម្មភាពហិរញ្ញវត្ថុនេះមានបំណងដោះស្រាយបញ្ហាប្រឈមការប្រែប្រួលអាកាសធាតុរបស់កម្ពុជា។ កម្មវិធី CCCA គាំទ្រដល់ការកសាងសមត្ថភាព និងការពង្រឹង ស្ថាប័ន ដែលត្រូវបានអនុវត្តដោយមូលនិធិជំនួយមួយ។ សមាសភាពជំនួយដំបូងបង្អស់ ត្រូវបានផ្តោតលើការកសាងភាពធន់នឹងការប្រែប្រួលអាកាសធាតុនៅតំបន់ឆ្នេរនិងការពង្រឹងការយល់ដឹងអំពីការប្រែប្រួលអាកាសធាតុ ហើយនិងការអប់រំក៏ដូចជាព័ត៌មានសាធារណៈ។<br><br>ឆ្នាំ ២០០៦ | មូលនិធិ CCCA ជាមូលនិធិសន្សំទុក ដែលមូលនិធិទាំងអស់មានសន្យានិងត្រូវចំណាយប្រាក់នៅចុងថេរវេលានៃគម្រោងដែលព្រមព្រៀង។ ការរៀបចំដំបូងគឺសម្រាប់រយៈពេល៣ឆ្នាំ (២០១០-២០១២) និងប្រហែល ចំនួន៨,៩លានដុល្លារអាមេរិក ត្រូវបានសន្យាសម្រាប់រយៈពេលនេះ។ វិភាគទានរបស់ម្ចាស់ជំនួយទៅក្នុងមូលនិធិនេះ ត្រូវបានបូកបញ្ចូលគ្នា និងមានត្រូវបានបម្រុងទុកតាមវិធីណាក៏ដោយ។ មូលនិធិនេះ គឺបើកសម្រាប់វិភាគទានបន្ថែមពីម្ចាស់ជំនួយថ្មី និងម្ចាស់ជំនួយដែលមានស្រាប់។ មូលនិធិ នេះគ្រប់គ្រងដោយអង្គការ UNDP និងប្រតិបត្តិការមូលនិធិនេះ ត្រូវបានអនុវត្តស្របតាមច្បាប់ និងនីតិវិធីរបស់អង្គការ UNDP។ |

## ឯកសារមេរៀនទី ២២៖ ឧទាហរណ៍នៃគម្រោងការប្រែប្រួលអាកាសធាតុដែលបានអនុម័តតាមរយៈមូលនិធិផ្សេងៗ

**លំហាត់៖**

ទីភ្នាក់ងារអន្តរជាតិ នឹងធ្វើការវាយតម្លៃដែលមានការចូលរួមមួយលើការឆ្លើយតបទៅនឹងតម្រូវការយេនឌ័រនៃគម្រោងបន្សាំនឹងការប្រែប្រួលអាកាសធាតុផ្សេងៗនៅក្នុងប្រទេសរបស់អ្នក។ ផ្នែកមួយនៃដំណើរការនេះ ក្រុមការងាររបស់អ្នកត្រូវបានជ្រើសរើស ដើម្បីផ្តល់ធាតុចូលសម្រាប់គម្រោងដែលត្រូវបានជ្រើសរើសនៅក្នុងប្រទេសរបស់អ្នកពីទស្សនៈយេនឌ័រ។ របាយការណ៍សម្រាប់គម្រោងនីមួយៗត្រូវផ្តល់ក្នុងទម្រង់ដូចខាងក្រោម៖

| ឈ្មោះគម្រោង៖ | ទីភ្នាក់ងារអនុវត្ត៖ | ប្រភពមូលនិធិ៖ |
|---|---|---|
| វត្ថុបំណងសំខាន់របស់គម្រោង៖ | វត្ថុបំណងយេនឌ័ររបស់គម្រោង៖ | លទ្ធផលសំខាន់ៗជាមួយការផ្តោតសំខាន់លើសមភាពយេនឌ័រនិងលទ្ធផលការផ្តល់ភាពអង់អាចដល់ស្ត្រី៖ |
| ធ្វើឱ្យគម្រោងនេះសមស្របនឹងបទប្បញ្ញត្តិយេនឌ័ររបស់ Fund (សូមពន្យល់ដោយសង្ខេប) | ដំណើរការពាក់ព័ន្ធនឹងយេនឌ័រទាំងអស់អនុវត្តតាមគម្រោង (សូមពន្យល់ដោយសង្ខេប) | តើគម្លាតយេនឌ័រសំខាន់ៗមានអ្វីខ្លះ៖ (សូមពន្យល់ដោយសង្ខេប) |

អ្នកត្រូវបានផ្តល់នូវរបាយការណ៍សង្ខេបមួយនៃគម្រោង ប៉ុន្តែវាមានលក្ខណៈមិនល្អិតល្អន់ទេ ដូច្នេះអ្នកអាចប្រើប្រាស់បទពិសោធន៍និងការយល់ដឹងរបស់អ្នកផ្អែកលើព័ត៌មានដែលបានផ្តល់ឆ្លើយតបសំណួរខាងលើ។ដើម្បីធ្វើការងារនេះបានល្អអ្នកក៏នឹងត្រូវការស្វែងយល់លម្អិតបន្ថែមទៀតពីអ៊ីនធឺណែតពីព័ត៌មានទាក់ទងនឹងគម្រោង។ ផែកមើលដោយសេរីតាមរយៈគេហទំព័រ ស្តីពីមូលនិធិការប្រែប្រួលអាកាសធាតុផ្សេង និងទីភ្នាក់ងារអនុវត្ត ដើម្បីទទួលបានព័ត៌មានបន្ថែមអំពីគម្រោងនានា ដើម្បីអាចផ្តល់នូវការពិនិត្យកាន់តែល្អិតល្អន់ថែមទៀត។

### គម្រោងទី ១៖ មូលនិធិការបន្សាំបង់ក្លាដេស៖ គំនិតផ្តួចផ្តើមការបន្សាំសម្រាប់កោះតូចៗតាមឆ្នេរសមុទ្រ និងតំបន់ដែសមុទ្រ ដែលងាយរងគ្រោះនឹងអាកាសធាតុ (UNDP)

គម្រោងនេះស្តីពី «គំនិតផ្តួចផ្តើមការបន្សាំសម្រាប់កោះតូចៗតាមតំបន់ឆ្នេរ និងតំបន់ដែសមុទ្រ ដែលងាយរងគ្រោះទៅនឹងអាកាសធាតុនៅប្រទេសបង់ក្លាដេស» អនុវត្តដោយកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) ក្នុងគោលបំណងបង្កើនភាពធន់នឹងអាកាសធាតុរបស់

សហគមន៍ដែលងាយរងគ្រោះនានាដែលរស់នៅតាមប្រជុំកោះតូចៗ នៅក្នុងទន្លេនានានិងឈូងសមុទ្របេងហ្គាល់ដែលជាពិសេសស្ថិតក្រោមហានិភ័យនៃការប្រែប្រួលអាកាសធាតុ។ គម្រោងនេះមានបំណងបង្កើនភាពធន់របស់គ្រួសារតាមរយៈការសាងសង់ផ្ទះធន់នឹងអាកាសធាតុ ប្រភពថាមពលកកើតឡើងវិញនៃអគ្គិសនី និងការផ្តល់ទឹកបរិភោគសុវត្ថិភាព។វាក៏មានបំណងបង្កើនភាពធន់នឹងអាកាសធាតុរបស់សហគមន៍ផងដែរ តាមរយៈការបង្កើតផែនទីហានិភ័យអាកាសធាតុ ព្យុះស៊ីក្លូន និងការត្រៀមបង្ការទឹកជំនន់ និងហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋានដែលមានភាពធន់នឹងព្យុះស៊ីក្លូន និងទឹកជំនន់និងធ្វើឱ្យប្រសើរឡើងនៃប្រាក់ចំណូលនិងសន្តិសុខស្បៀងសម្រាប់គ្រួសារដែលងាយរងគ្រោះដោយការច្នៃប្រឌិតនិងការណែនាំអំពីការអនុវត្តជីវភាពរស់នៅដែលធន់នឹងអាកាសធាតុដែលសមស្របលក្ខណៈមូលដ្ឋាន។ ចុងក្រោយ វាមានបំណងបង្កើនចំណេះដឹង និងសមត្ថភាពរបស់សហគមន៍រដ្ឋាភិបាលនិងអ្នកបង្កើតគោលនយោបាយ ដើម្បីលើកកម្ពស់ការបង្កើតភាពធន់នឹងអាកាសាធាតុតាមទន្លេ និងកោះតាមតំបន់ឆ្នេរ។ តាមការប៉ាន់ប្រមាណ ប្រជាជន ៣៤១ ០០០នាក់ កំពុងរស់នៅតាមច្រាំងទន្លេនៅទីក្រុង Rangpur និង Bhola ដែលត្រូវបានរំពឹងថាទទួលបានអត្ថប្រយោជន៍ពីព្យុះស៊ីក្លូន និងផ្ទះសម្បែងដែលទប់ទល់នឹងទឹកជំនន់ លើកកម្ពស់ជីវភាពរស់នៅ និងធ្វើប្រសើរឡើងនូវការត្រៀមបង្ការនឹងអាកាសធាតុនិងការប្រកាសអាសន្ន។

គំនិតផ្តួចផ្តើមនេះ នឹងបង្កើនភាពធន់នឹងអាកាសធាតុនៃគ្រួសារដែលដឹកនាំដោយស្ត្រីចំនួន៩០០គ្រួសារ តាមរយៈការសាងសង់ផ្ទះសម្បែងដែលធន់នឹងអាកាសធាតុការផ្គត់ផ្គង់អគ្គិសនី និងទឹកដែលបន្សាំទៅនឹងអាកាសធាតុ។ បន្ថែមពីនេះទៀត គម្រោងនឹងសាងសង់បណ្តុំផ្ទះសម្រាប់ក្រុមគ្រួសារងាយរងគ្រោះជាពិសេសដែលនឹងមានមុខងារជាទីជម្រកពេលគ្រាអាសន្នអំឡុងពេលទឹកជំនន់ និងព្យុះស៊ីក្លូននានា។ បណ្តុំផ្ទះនេះ នឹងត្រូវបានរចនាឡើងមានលក្ខណៈគិតគូរពីជាពិសេសសម្រាប់ស្ត្រី និងកុមារ នឹងរួមបញ្ចូលនូវទឹក អនាម័យបរិស្ថាន និងអគារអនាម័យខ្លួនប្រាណ និងមានបំពាក់អំពូលភ្លើងពន្លឺព្រះអាទិត្យ។កម្មវិធីការត្រៀមបង្ការនឹងព្យុះស៊ីក្លូននេះ នឹងត្រូវបានធ្វើឡើងដោយឆ្លើយតបទៅនឹងតម្រូវការយេនឌ័រតាមរយៈការព្យាយាមបង្កើនស្ត្រីនៅក្នុងអង្គភាពអ្នកស្ម័គ្រចិត្ត ២៥%។ ជារួម ការផ្លាស់ប្តូរជីវភាពរស់នៅរបស់ស្ត្រីទៅតាមជម្រើសភាពធន់នឹងអាកាសធាតុនឹងកាត់បន្ថយតម្រូវការចំណាយលើការពារសង្គម និងសុវត្ថិភាពសង្គម។

### គម្រោងទី ២៖ PPCR បង់ក្លាដេស៖ គម្រោងហេដ្ឋារចនាសម្ព័ន្ធបរិស្ថានទីក្រុងតំបន់ឆ្នេរនិងគម្រោងហេដ្ឋារចនាសម្ព័ន្ធភាពធន់ទៅនឹងអាកាសធាតុតំបន់ឆ្នេរ (ADB)

គម្រោងហេដ្ឋរចនាសម្ព័ន្ធបរិស្ថានទីក្រុងតំបន់ឆ្នេរបង់ក្លាដេស និងគម្រោងហេដ្ឋារចនាសម្ព័ន្ធភាពធន់នឹងអាកាសធាតុតំបន់ឆ្នេរ កំពុងអនុវត្តដោយធនាគារពិភពលោក (ADB) តាមរយៈមូលនិធិ PPCR។

គម្រោងទីមួយ ប្រើវិធីសាស្ត្រដែលមានការរួមបញ្ចូលឆ្ពោះរកការកែលម្អសេវាទីក្រុង ដើម្បីពង្រឹងភាពធន់នឹងអាកាសធាតុ និងភាពត្រៀមបង្ការទប់ទល់នឹងអាកាសធាតុនៅក្នុងទីក្រុងតំបន់ឆ្នេរដែលងាយរងគ្រោះចំនួនប្រាំបី (ទីក្រុងកម្រិតទីពីរ) ដែលខ្វះខាតនូវសេវាមូលដ្ឋានទីក្រុងនិងងាយរងគ្រោះខ្លាំងទៅនឹងផលប៉ះពាល់អវិជ្ជមាននៃការប្រែប្រួលអាកាសធាតុ ហើយនិងត្រូវបានផ្តោតជាពិសេសលើស្ត្រី និងគ្រួសារក្រីក្រជាអ្នកទទួលអត្ថប្រយោជន៍។ ទិន្នផលសំខាន់របស់គម្រោងគឺហេដ្ឋារចនាសម្ព័ន្ធទីក្រុងដែលមានភាពធន់ទប់ទល់នឹងអាកាសធាតុរួមមានការផ្គត់ផ្គង់ទឹកអនាម័យបរិស្ថានប្រព័ន្ធបង្ហូរទឹកសំណល់និងមធ្យោបាយដឹកជញ្ជូនបន្ថែមពីលើផ្លូវ និងស្ពានទីក្រុង ការគ្រប់គ្រងសំណល់រឹង និងការកែលម្អសំណង់អាណាធិបតេយ្យ។ ការទទួលបានសេវាទីក្រុងកាន់តែល្អប្រសើរដែលអាចធ្វើឱ្យកាន់តែមានភាពជឿជាក់ និងភាពធន់នឹងអាកាសធាតុស្ថិតក្រោមគម្រោង ត្រូវបានមើលឃើញចំពោះការលើកកម្ពស់សុខភាពល្អក្នុងចំណោមប្រជាជននៃទីប្រជុំជនតំបន់ឆ្នេរ។ រដ្ឋាភិបាលមូលដ្ឋានក៏ត្រូវពង្រឹង ជាមួយការបង្កើនសមត្ថភាពមូលដ្ឋានសម្រាប់ការផ្តល់សេវាប្រកបដោយនិរន្តរភាព ការរៀបចំផែនការទីក្រុង និងភាពត្រៀមបង្ការទប់ទល់នឹងគ្រោះមហន្តរាយធម្មជាតិ ដែលស្ថិតនៅលើគេក្នុងចំណោមចំណុចកែលម្អទាំងមូលខាងផ្នែកអាកាសធាតុ និងភាពធន់នឹងគ្រោះមហន្តរាយ។ ដោយសារបទពិសោធទូលំទូលាយរបស់ពួកគេនៅក្នុងការគ្រប់គ្រងគម្រោងទីក្រុងនានាដែលគាំទ្រដោយ ADB នាយកដ្ឋានវិស្វកម្មរដ្ឋាភិបាលមូលដ្ឋានត្រូវធ្វើការងារជាទីភ្នាក់ងារប្រតិបត្តិ និងនាយកដ្ឋានវិស្វកម្មសុខភាពសាធារណៈ ជាទីភ្នាក់ងារប្រតិបត្តិរួមគ្នា សម្រាប់គម្រោងនេះ។

គម្រោងទីពីរ នឹងលើកកម្ពស់ជីវភាពរស់នៅនៃសហគមន៍ទាំងនេះ ដោយការធ្វើឱ្យប្រសើរឡើងនូវផ្លូវតំបន់ជនបទ ទីផ្សារ និងទីជម្រកគ្រោះមហន្តរាយទៅនឹងស្តង់ដាដែលមានភាពធន់នឹងអាកាសធាតុនិងបង្កើនសមត្ថភាពនៃប្រជាជនដែលនៅតំបន់ទទួលបានអត្ថប្រយោជន៍ ដើម្បីបន្សាំនឹងការប្រែប្រួលអាកាធាតុ។ ការតភ្ជាប់ផ្លូវនឹងត្រូវកែលម្អតាមរយៈការធ្វើឱ្យប្រសើរឡើងនៃផ្លូវស្រុកប្រវែង ១៣០គីឡូម៉ែត្រ ក្រោមគម្រោងនេះ ហើយប្រវែងផ្លូវ ៤០៧គីឡូម៉ែត្របន្ថែម នៃផ្លូវទីប្រជុំជន និងផ្លូវភូមិក្រោមគំនិតផ្តួចផ្តើមបំពេញបន្ថែមដែលផ្តល់មូលនិធិដោយមូលនិធិអន្តរជាតិដើម្បីអភិវឌ្ឍន៍កសិកម្ម (IFAD)។ សេវាទីផ្សារត្រូវបានរំពឹងថាកែលម្អដោយធ្វើឱ្យប្រសើរនូវមជ្ឈមណ្ឌលរីកចម្រើនចំនួន៨៨និងទីផ្សារធំៗក្រោមគម្រោងនេះ និងកែលម្អទីផ្សារសហគមន៍ចំនួន ១៨៦ក្រោមគំនិតផ្តួចផ្តើមបំពេញបន្ថែមរបស់IFAD។ ទីផ្សារ និងមជ្ឈមណ្ឌលរីកចម្រើនទាំងនេះនីមួយៗ នឹងមានកន្លែងដែលអនុញ្ញាតសម្រាប់សកម្មភាពដែលទាក់ទងនឹងទីផ្សាររបស់ស្ត្រី។ លើសពីនេះទៀត ទីតាំងកន្លែងឡើងទូកចំនួន៣៧ នឹងត្រូវសាងសង់តាមស្តង់ដារសមស្របទៅនឹងការប្រែប្រួលអាកាសធាតុ។

សមត្ថភាពបន្សាំរបស់រដ្ឋាភិបាលមូលដ្ឋានទៅនឹងការប្រែប្រួលអាកាសធាតុតាមវិធីពីរយ៉ាង៖ (១) តាមរយៈការពង្រឹងប្រព័ន្ធស្រូបយក និងចែករំលែកចំណេះដឹង ជាពិសេសប្រព័ន្ធព័ត៌មានភូមិសាស្ត្រ នៃនាយកដ្ឋានវិស្វកម្មរដ្ឋាភិបាលមូលដ្ឋាន និងការបង្កើតបណ្តាញមួយដើម្បីបម្រើដល់ទីភ្នាក់ងាររដ្ឋាភិបាលមូលដ្ឋានទាំងអស់ដែលជាប់ពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ និង(២)តាមរយៈការបណ្តុះបណ្តាលបុគ្គលិករដ្ឋាភិបាលមូលដ្ឋានផ្នែកភាពធន់នឹងអាកាសធាតុការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយនិងសកម្មភាពពាក់ព័ន្ធនានា។នៅក្នុងគំនិតផ្តួចផ្តើមស្របគ្នារដ្ឋាភិបាលអាល្លឺម៉ង់ ដែលជាម្ចាស់នៃធនាគារអភិវឌ្ឍន៍ KfW នឹងផ្តល់ហិរញ្ញប្បទានដល់ការពង្រីកទីជម្រកព្យុះស៊ីក្លូនដែលមានពហុគោលបំណងចំនួន១៥ កែលម្អទីជម្រកដទៃទៀតចំនួន១០ និងធ្វើឱ្យប្រសើរឡើងនូវផ្លូវប្រវែង១៥គីឡូម៉ែត្រ ដែលចូលទៅកាន់ទីជម្រកទាំងនេះដូច្នេះនឹងធ្វើឱ្យប្រសើរឡើងនូវជីវភាពរស់នៅក្នុងស្រុកតំបន់ឆ្នេរជនបទដែលទទួលបានអត្ថប្រយោជន៍ទាំងនេះ។

គម្រោងនេះ រួមបញ្ចូលនូវតំបន់ដាច់ដោយឡែកសម្រាប់ស្ត្រីនិងបុរសនៅក្នុងទីជម្រកព្យុះស៊ីក្លូននិងកែលម្អមជ្ឈមណ្ឌលទីផ្សារជាមួយនឹងយុទ្ធសាស្ត្រការបែងចែកដែលអាចធ្វើបានសម្រាប់ស្ត្រីតាមរយៈដំណើរការផ្លូវដែលធន់នឹងអាកាសធាតុ។សេវាទាំងនេះដែលផ្តល់ឱ្យស្ត្រីនិងបុរសក្នុងនាមជាអ្នកទទួលបានអត្ថប្រយោជន៍ដោយសារសេវានេះបានសាងភាពធន់នឹងអាកាសធាតុសម្រាប់ស្ត្រី និងបុរស ត្រូវបានគាំទ្រអំឡុងពេលសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ប្រទេសនិងកិច្ចសម្ភាសតាមដានដែលធ្វើឡើងជាមួយអ្នកគ្រប់គ្រងគម្រោងនានាក្នុងប្រទេស។ អ្នកចូលរួមសិក្ខាសាលាពិគ្រោះយោបល់នេះ និងអ្នកគ្រប់គ្រងគម្រោង បានរាយការណ៍អំពីបទពិសោធន៍របស់ពួកគេដែលជាកិច្ចប្រឹងប្រែងរបស់គម្រោង PPCRបានជះឥទ្ធិពលអត្ថប្រយោជន៍ដោយផ្ទាល់លើការផ្តល់ភាពអង់អាចផ្នែកសេដ្ឋកិច្ចរបស់ស្ត្រី។

## គម្រោងទី ៣៖ ការជំរុញជីវភាពរស់នៅដែលមានភាពធន់ ការស្តារខ្សែក្រវាត់បៃតង និងការពង្រឹងការប្រកាសអាសន្នតាមតំបន់ឆ្នេរនៃប្រទេសបង់ក្លាដេស

ចាប់ពីឆ្នាំ២០១៥ ដោយមានការគាំទ្រពីមូលនិធិប្រទេសអភិវឌ្ឍន៍តិចតួច (LDCF) របស់មូលនិធិបរិស្ថានសកលនាយកដ្ឋានព្រៃឈើបង់ក្លាដេស និងអង្គការ UNDP បានធ្វើការងារជាមួយ Upazila (ស្រុក) នៅតាមតំបន់ឆ្នេរចំនួនប្រាំបីនៅក្នុងស្រុកដែលងាយរងគ្រោះខ្ពស់រួមមានស្រុកBhola,Barguna, Patuakhali, Noakhali, និងស្រុក Pirojpur។ ការប្រើវិធីសាស្ត្រមូលដ្ឋាន គម្រោង ICBA-AR បានផ្តោតលើការផ្តល់ឱ្យប្រជាជននូវជីវភាពរស់នៅធន់នឹងអាកាសធាតុ ការស្តារឡើងវិញខ្សែក្រវាត់បៃតង និងការពង្រឹងការប្រកាសអាសន្ន និងភាពត្រៀមបង្ការទប់ទល់នឹងគ្រោះមហន្តរាយនានា។

**ការលើកកម្ពស់ភាពធន់ និងជីវភាពរស់នៅ ដែលមានលក្ខណៈច្នៃប្រឌិត ៖** ដោយផ្តល់ឱ្យក្រុមគ្រួសារនានាកាន់តែមានភាពធន់ ជីវភាពរស់នៅដែលមាននិរន្តរភាព គម្រោងនេះ ជួយដល់ក្រុមគ្រួសារនានាមានអាហារសម្រាប់បរិភោគនិងបង្កើនប្រាក់ចំណូលរបស់ពួកគេទន្ទឹមនឹងនោះក៏កាត់បន្ថយសំពាធលើព្រៃឈើផងដែរ។ ក្រោមគម្រោងនេះ ២៣០០គ្រួសារទទួលបានការគាំទ្រសម្រាប់ការទទួលយកជីវភាពកាន់តែមានភាពធន់ ភាពច្នៃប្រឌិត និងជីវភាពរស់នៅផ្អែកលើធម្មជាតិរួមបញ្ចូលការដាំដុះស្រូវដែលធន់នឹងជាតិប្រៃ វប្បធម៌ sorjone បន្លែបណ្តែតទឹក ចម្ការផ្លែឈើចម្រុះ និងគ្រាប់សណ្តែក ហើយការដាំស្រូវ-ចិញ្ចឹមត្រីវិលជុំ។ ជាង ២៥០០គ្រួសារ ត្រូវបានបណ្តុះបណ្តាល និងទទួលបានការគាំទ្រក្នុងការចិញ្ចឹមសត្វពាហនៈដូចជាការចិញ្ចឹមទា និងការប្រើប្រាស់ស្មៅជលសាស្ត្រវប្បកម្ម-ខណៈដែល២២០០គ្រួសារទៀតទទួលបានការគាំទ្រក្នុងការបង្កើតផ្នែកជលផល រួមមានការចិញ្ចឹមតាមប៉ែរ និងការចិញ្ចឹមបំប៉នសាច់ក្តាម។ គ្រួសារចំនួន១៤០បន្ថែមទៀត ត្រូវបានណែនាំពីគំរូការធ្វើស្រែចម្ការផ្អែកលើប្រព័ន្ធអេកូឡូស៊ីដែលមានលក្ខណៈច្នៃប្រឌិត រួមទាំងការឈ្នះពានរង្វាន់ «ព្រៃឈើ-ផ្លែឈើ-ជលផល» ដែលជាម៉ូឌែល (៣FV) ដែលត្រូវបានអនុវត្តនៅលើផ្ទៃដី ២៨ហិកតា នៃដីព្រៃដែលរេចរិល។ ដើម្បីគ្រប់គ្រងការបង្ហូរទឹក និងការពារវាលស្រែពីការរំលោភចូលជាតិប្រៃ គម្រោងនេះបានជីកកកាយដីប្រឡាយទឹកប្រវែង ២,៩ គីឡូម៉ែត្រ និងការជួសជុលទ្វារទឹក។ ជាលទ្ធផល គ្រួសារប្រហែល ៥០០ ០០០គ្រួសារ នៅក្នុងស្រុក Bhola បានឃើញនូវការរីកចម្រើនផលិតផលកសិកម្ម។ តារាងអណ្តូងស្នប់ចំនួន១៥០ត្រូវបានលើកឡើងឱ្យខ្ពស់ជាងកម្រិតទឹកជំនន់ ខណៈដែលស្រះទឹកថ្មីចំនួន១៤០ក៏នឹងជួយធានាបាននូវទឹកផឹកប្រកបដោយសុវត្ថិភាពសម្រាប់សហគមន៍ និងការកាត់បន្ថយពេលវេលាទៅប្រមូលទឹករបស់ស្ត្រី។ គម្រោងនេះបានសាងសង់នូវរោងចិញ្ចឹមសត្វខ្ពស់ជាងផ្ទៃដីដែលអាចផ្តល់ជម្រកដល់សត្វចិញ្ចឹមប្រហែល១៥០០០ក្បាល អំឡុងពេលមានគ្រោះមហន្តរាយ។

**ការការពារសហគមន៍ តាមរយៈខ្សែក្រវាត់បៃតងកាន់តែរឹងមាំ៖** ការស្តារឡើងវិញ និងការថែរក្សាព្រៃកោងកាង - ត្រូវបានចាត់ទុកជាខ្សែបន្ទាត់ទីមួយក្នុងការការពារប្រឆាំងនឹងគ្រោះមហន្តរាយអាកាសធាតុ - ដែលជាសមាសភាគស្នូលមួយនៃគម្រោង ICBA-AR។ ចាប់តាំងពីចាប់ផ្តើមគម្រោងនេះមក ប្រភេទកូនកោងកាងជាង៥៧២០០០ដែលធន់នឹងអាកាសធាតុត្រូវបានបណ្តុះនៅក្នុងថ្នាលរបស់វា។ គម្រោងនេះក៏ធ្វើការពង្រីកប្រភេទចម្រុះនៅក្នុងដីទំហំ៦៥០ហិកតា នៃចម្ការដែលមានវប្បធមដាំប្រភេទតែមួយពីមុន ព្រមទាំងការបង្កើតគម្រោងវាយតម្លៃមួយ ដើម្បីកំណត់នូវប្រសិទ្ធភាពនៃការធ្វើពិពិធកម្ម។ គណៈកម្មាធិការសហគ្រប់គ្រងត្រូវបានបង្កើតឡើងនៅក្នុងស្រុកទាំង៨ ក្រោមគម្រោងនេះដែលគាំទ្រដល់ការការពារព្រៃឈើ និងការគ្រប់គ្រងធនធាននានា និងការសម្របសម្រួលកិច្ចសន្ទនារវាងសហគមន៍ និងរដ្ឋាភិបាលមូលដ្ឋាន។ អ្នកក្រក្រីខ្លាំង រស់នៅពឹងផ្អែកលើព្រៃឈើចំនួន

៦០០នាក់ដែលភាគច្រើនជាស្ត្រីបច្ចុប្បន្នជាសមាជិកក្រុមការពារធនធានព្រៃឈើ (FRPG) ដែលបានបង្កើតឡើងក្រោមគម្រោងដើម្បីគ្រប់គ្រងរួមគ្នា និងការពារចម្ការកោងកាង។ សមាជិក FRPGsដើរតួជាអ្នកកាន់កាប់ព្រៃឈើរួមបញ្ចូលការល្បាតជាមួយនាយកដ្ឋានព្រៃឈើនិងការលើកកម្ពស់ការយល់ដឹងប្រឆាំងនឹងការផ្តួលរលំដើមឈើខុសច្បាប់។

**ការជួយសង្គ្រោះជីវិតតាមរយៈការពង្រឹងការប្រកាសអាសន្ន៖** ដោយមានការកើតឡើងគ្រោះមហន្តរាយច្រើនតាមសហគមន៍ គម្រោងក៏បានផ្តោតលើការពង្រឹងសមត្ថភាពការប្រកាសអាសន្ននៅមូលដ្ឋាន។ដោយគាំទ្រដល់កម្មវិធីភាពត្រៀមបង្ការទប់ទល់នឹងព្យុះស៊ីក្លូនរបស់រដ្ឋាភិបាល គម្រោងនេះបានចែកនូវក្បាលមេក្រូស៊ីរ៉ែនដៃ ទង់ផ្តល់សញ្ញា អាវពោង និងម៉ូតូទៅស្ថាប័ននៅមូលដ្ឋាន។ អ្នកស្ម័គ្រចិត្តកម្មវិធីភាពត្រៀមបង្ការទប់ទល់នឹងព្យុះស៊ីក្លូនប្រមាណ៦០០០នាក់ត្រូវបានបំពាក់បំប៉នដើម្បីផ្សព្វផ្សាយការប្រកាសអាសន្ន និងធ្វើការជួយសង្គ្រោះ។ អ្នកឃ្លាំមើលសហគមន៍ស្ត្រីចំនួន៨នាក់ ត្រូវបានតែងតាំងដើម្បីធ្វើការងារជិតស្និតជាមួយគ្រួសារនានា ក្នុងការផ្តល់ភាពអង់អាចដល់ស្ត្រី និងជួយសម្របសម្រួលការទទួលយកជីវភាពរស់នៅដែលធន់នឹងអាកាសធាតុ។ អ្នកស្ម័គ្រចិត្តកម្មវិធីត្រៀមបង្ការទប់ទល់នឹងព្យុះស៊ីក្លូនដែលបានបណ្តុះបណ្តាលក្រោមគម្រោងនេះ ដើរតួយ៉ាងសំខាន់នៅក្នុងការផ្សព្វផ្សាយការយល់ដឹង និងជួយដល់មូលដ្ឋានដើម្បីកាត់បន្ថយការបាត់បង់ និងខូចខាតឱ្យមកនៅកម្រិតទាបនៅពេលព្យុះស៊ីក្លូ Fani, Bulbul និងព្យុះស៊ីក្លូន Amphan វាយប្រហារប្រទេសបង់ក្លាដេស។ បច្ចុប្បន្ននេះ អ្នកស្ម័គ្រចិត្ត និងបុគ្គលិកកំពុងធ្វើការងារលើកកម្ពស់ការយល់ដឹងក្នុងចំណោមអ្នករស់នៅកោះតំបន់អំពីការទប់ស្កាត់ជំងឺកូវីដ-១៩។

**មិនមានអ្នកណាម្នាក់ត្រូវបានទុកចោល៖** បច្ចុប្បន្ន គម្រោង ICBA-AR ផ្តោតលើការចម្លងគំរូ (៣FV) ព្រៃឈើ-ផ្លែឈើ-ត្រី-បន្លែនៅកម្រិតតាមផ្ទះសម្បែង ការបង្កើតកិច្ចព្រមព្រៀងមួយរវាងនាយកដ្ឋានព្រៃឈើ និងក្រុមការពារធនធានព្រៃឈើសម្រាប់ការអភិរក្សព្រៃឈើ និងបង្កើនការសាងសង់ « killa» សម្រាប់ការពារសត្វពាហនៈអំឡុងពេលព្យុះស៊ីក្លូន និងជំនន់ទឹកសមុទ្រ។ មជ្ឈមណ្ឌលបណ្តុះបណ្តាលការបន្ស៊ាំនឹងអាកាសធាតុគឺស្ថិតនៅក្រោមការអនុវត្តនៅកម្រិតមូលដ្ឋានដែលភ្ជាប់ទៅនឹងមជ្ឈមណ្ឌលបន្ស៊ាំថ្នាក់តំបន់នាពេលខាងមុខនេះនៅក្នុងរាជធានី Dhaka ក្រោមក្រសួងបរិស្ថាន ព្រៃឈើ និងការប្រែប្រួលអាកាសធាតុបង់ក្លាដេស។ ព្រមទាំងបន្តគាំទ្រដល់ការទទួលយកជីវភាពរស់នៅដែលកាន់តែមានភាពធន់ គម្រោងនេះកំពុងបង្វែរទៅគំនិតផ្តួចផ្តើមការបន្ស៊ាំដទៃផ្សេងទៀតដូចជាកែលម្អចង្ក្រានចម្អិនម្ហូបអាហារ អណ្តូងស្នប់ «ធន់នឹងអាកាសធាតុ» ការប្រមូលទឹកភ្លៀងទុកនិងថាមពលពន្លឺព្រះអាទិត្យក្នុងការស្តារភូមិឡើងវិញសម្រាប់ជនភៀសខ្លួនដោយសារអាកាសធាតុ។

### គម្រោងទី ៤៖ ការបង្កើនភាពធន់របស់អ្នកក្រីក្រ អ្នកដែលជួបការលំបាក និងសហគមន៍ដែលងាយរងគ្រោះទៅនឹងអាកាសធាតុនៅក្នុងតំបន់ប្រឈមនឹងទឹកជំនន់ នៃប្រទេសបង់ក្លាដេស

ខ្សែក្រវ៉ាត់តំបន់ឆ្នេរបង់ក្លាដេស គឺងាយរងគ្រោះទៅនឹងព្យុះស៊ីក្លូន ជំនន់ទឹកសមុទ្រ និងកំណើននីវ៉ូទឹកសមុទ្រ ដែលបច្ចុប្បន្ននេះត្រូវបានសង្កេតឃើញថាកាន់តែធ្ងន់ធ្ងរឡើង។កំណើននៃការកើនឡើងនៃមុខសញ្ញាគ្រោះថ្នាក់ទាំងនេះនឹងពន្លឿនការជ្រៀតចូលទឹកប្រៃទៅក្នុងធនធានទឹកសាបតាមបណ្តោយឆ្នេរបង់ក្លាដេស។ គម្រោងនេះផ្តោតលើការបន្ស៊ាំដែលដឹកនាំដោយសហគមន៍ និងដែលមានទស្សនៈរំញោចយេនឌ័រ។តាមស្រុកដែលស្ថិតនៅតំបន់ងាយប្រឈមនឹងទឹកជំនន់ទាំងប្រាំវានឹងផ្តល់អាទិភាពដល់គ្រួសារដែលស្ត្រីជាមេគ្រួសារ។ វាផ្អែកលើម៉ូឌែលការបន្ស៊ាំពិគ្រោះយោបល់ដែលបង្ហាញពីភាពជោគជ័យ។

ការពង្រឹងសមត្ថភាពបន្ស៊ាំនៅក្នុងគម្រោងនេះ ត្រូវបានព្យាករណ៍ដើម្បីកាត់បន្ថយផលប៉ះពាល់ដែលមិនល្អទៅលើជីវភាពរស់នៅ ដែលអាស្រ័យលើកសិកម្មដែលពឹងផ្អែកលើទឹកសាប និងដើម្បីដោះស្រាយកង្វះខាតទឹកបរិភោគប្រកបដោយគុណភាពនៅក្នុងសហគមន៍ដែលងាយរងគ្រោះ។ វិធីសាស្ត្រផ្អែកលើសហគមន៍នៅក្នុងការរៀបចំផែនការ និងការគ្រប់គ្រងការផ្គត់ផ្គង់ទឹកដែលធន់នឹងអាកាសធាតុមានគោលដៅក្រុមដែលងាយរងគ្រោះខ្ពស់ ជាពិសេសស្ត្រី និងក្មេងស្រី។

ការផ្តល់ទីជម្រកព្យុះស៊ីក្លូន និងផ្លូវសំខាន់ៗដែលមានការការពារអាចទទួលបានការការពារជីវិតនៅក្នុងតំបន់ឆ្នេរនៅទីជនបទនៃបង់ក្លាដេស។ ការបង្កើតហេដ្ឋារចនាសម្ព័ន្ធទីក្រុង និងអ្នករស់នៅតំបន់ទីក្រុងដែលងាយរងគ្រោះមានការការពារពីរហានិភ័យអាកាសធាតុ។ ការបង្កើតមជ្ឈមណ្ឌលថ្នាក់ជាតិនៃឧត្តមភាពសម្រាប់ហេដ្ឋារចនាសម្ព័ន្ធភាពធន់នឹងអាកាសធាតុដើម្បីផ្តល់ព័ត៌មាននិងណែនាំដល់ការបង្កើតហេដ្ឋារចនាសម្ព័ន្ធនាពេលខាងមុខទូទាំងប្រទេស។

បង់ក្លាដេស ជាប្រទេសមួយដែលងាយរងគ្រោះបំផុតទៅនឹងហានិភ័យអាកាសធាតុ ជាពិសេសទៅនឹងព្យុះស៊ីក្លូន និងទឹកជំនន់។ ស្រុកនានាតាមតំបន់ឆ្នេរ ស្ថិតនៅក្នុងហានិភ័យពីអាកាសធាតុធ្ងន់ធ្ងរ ហានិភ័យនឹងកាន់តែធ្ងន់ធ្ងន់ដោយសារផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុដូចជាកំណើនភាពប្រែប្រួលរដូវកាលកម្រិតទឹកភ្លៀងកាន់តែខ្ពស់និងកំណើននីវ៉ូទឹកសមុទ្រ។ស្រុកចំនួនបីដែលងាយរងគ្រោះបំផុត និងស្រុកតំបន់ឆ្នេរនានាដែលក្រីក្ររបស់ប្រទេសនេះត្រូវបានកំណត់ជាតំបន់គោលដៅរបស់គម្រោង៖ ស្រុក Bhola ស្រុក Barguna និងស្រុក Satkhira។

គម្រោងនេះបង្កើតឡើងនៅមជ្ឈមណ្ឌលថ្នាក់ជាតិឧត្តមភាពមួយដើម្បីប្រមូល បង្កើត និងចែករំលែកចំណេះដឹងហេដ្ឋារចនាសម្ព័ន្ធភាពធន់នឹងអាកាសធាតុ។ ការបង្កើតហេដ្ឋារចនាសម្ព័ន្ធតំបន់ជនបទនឹងត្រូវបានគាំទ្រតាមរយៈការសាងសង់ទីជម្រកព្យុះស៊ីក្លូនថ្មីចំនួន៤៥និងស្តារឡើងវិញទីជម្រកដែលមានស្រាប់ចំនួន២០។

ទីជម្រកសាងសង់ឡើងក្រោមគម្រោងនេះ នឹងត្រូវប្រើប្រាស់ជាសាលារៀនបឋមសិក្សានៅម៉ោងធម្មតា ដែលផ្ដល់នូវសាលារៀនបន្ថែមចំនួន៤៥ និងជួយអប់រំដល់កុមារចំនួន ១៨ ៥៩០នាក់។ ការកែលម្អផ្លូវសំខាន់ៗទៅកាន់ទីជម្រកតំបន់ជនបទចម្ងាយ ៨០គីឡូម៉ែត្រ ក៏នឹងត្រូវអនុវត្តផងដែរ ដើម្បីទទួលបានការប្រើប្រាស់ប្រកបដោយសុវត្ថិភាពអំឡុងពេលធាតុអាកាសធ្ងន់ធ្ងរ និងពង្រីកសមត្ថភាពបន្សាំរបស់សហគមន៍មូលដ្ឋាន។ គម្រោងសាកល្បងហេដ្ឋារចនាសម្ព័ន្ធទីក្រុងដែលមានភាពធន់នឹងអាកាសធាតុ ក៏នឹងត្រូវបានអនុវត្តនៅក្នុងទីក្រុង Satkhira។

ដឹកនាំដោយក្រសួងកិច្ចការនារីនិងកុមារបង់ក្លាដេសគម្រោងនេះផ្ដោតលើការពង្រឹងសមត្ថភាពបន្សាំរបស់សហគមន៍តំបន់ឆ្នេរ ជាពិសេសស្ត្រីនិងក្មេងស្រីវ័យជំទង់ក្នុងការដោះស្រាយជាមួយផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ - ដែលបង្កឱ្យមានជាតិប្រៃលើជីវភាពរស់នៅរបស់ពួកគេ និងសុវត្ថិភាពទឹក។ គម្រោងមានរយៈពេល៦ឆ្នាំ (២០១៨-២០២៤) ផ្ដោតលើស្រុកតំបន់ឆ្នេរនៅប៉ែកនិរតីរួមមានស្រុក Khulna និងស្រុក Satkhira ស្រុកទាំងពីរមានបទពិសោធន៍ញឹកញាប់ជាមួយនឹងព្យុះស៊ីក្លូន និងទឹកជំនន់លំនាចនិងជួបប្រទះកង្វះទឹកបរិភោគយ៉ាងធ្ងន់ធ្ងរដោយសារជាតិប្រៃ។ ក្រោមគម្រោងនេះ សហគមន៍នឹងត្រូវផ្ដល់ភាពអង់អាចជា «ភ្នាក់ងារនៃការផ្លាស់ប្ដូរ» ដើម្បីរៀបចំផែនការ អនុវត្ត និងគ្រប់គ្រងជីវភាពរស់នៅដែលមានភាពធន់និងដំណោះស្រាយទឹកបរិភោគ។គម្រោងនេះនឹងជំរុញនូវវិធីផ្លាស់ប្ដូរដែលមានលក្ខណៈជាប្រព័ន្ធមួយពីការផ្ដោតលើការឆ្លើយតបរយៈពេលខ្លីនិងកិច្ចអន្តរាគមន៍ដែលដឹកនាំបច្ចេកវិទ្យាចំពោះដំណោះស្រាយសហគមន៍កណ្ដាលដែលកសាងភាពជាម្ចាស់និងសមត្ថភាពទូទាំងពហុភាគីពាក់ព័ន្ធ ដើម្បីរក្សា និងបង្កើនការឆ្លើយតបលក្ខណៈបន្សាំក្នុងការការពារជីវភាពរស់នៅ និងសុវត្ថិភាពទឹក។ ប្រជាជនប្រមាណ ៧១៩ ២២៩នាក់ (ប្រហែលចំនួន ២៤៥ ៥១៦នាក់ ដោយផ្ទាល់ និងចំនួន ៤៧៣ ៧១៣ ដោយប្រយោល) ទទួលបាននូវអត្ថប្រយោជន៍ពីគម្រោងនេះ។

## គម្រោងទី ៥៖ កម្មវិធីការបន្សាំផ្អែកលើសហគមន៍បង់ក្លាដេស (CBA)

កម្មវិធីបន្សាំដែលផ្អែកលើសហគមន៍ (CBA) គឺត្រូវបានអនុវត្តនៅប្រទេសបង់ក្លាដេសដោយអង្គការUNDPនិងរដ្ឋាភិបាលបង់ក្លាដេស រួមជាមួយអង្គការសង្គមស៊ីវិលក្នុងមូលដ្ឋាននានា។ គម្រោងនេះគាំទ្រដោយមូលនិធិបរិស្ថានសកល (GEF) និងនាយកដ្ឋានអភិវឌ្ឍន៍អន្តរជាតិព្រះរាជាណាចក្រអង់គ្លេស(DFID)។ គោលបំណងនៃកម្មវិធីយុទ្ធសាស្ត្រជាតិប្រទេសបង់ក្លាដេសCBA គឺ«ការអនុវត្តការគ្រប់គ្រងធនធានធម្មជាតិដែលល្អប្រសើរនៅក្នុងប្រទេសបង់ក្លាដេសដើម្បីកាត់បន្ថយភាពងាយរងគ្រោះទៅនឹងផលប៉ះពាល់ការប្រែប្រួលអាកាសធាតុ និងការបង្កើនសមត្ថភាពសហគមន៍ និងប្រព័ន្ធអេកូឡូស៊ីសំខាន់ៗ ដើម្បីបន្សាំនឹងការប្រែប្រួលអាកាសធាតុ»។ការសម្រេចបាននូវគោលបំណងនេះនឹងត្រូវបានវាស់វែងដោយសូចនាករផលប៉ះពាល់ខាងក្រោម៖

- ភាគរយផ្លាស់ប្ដូរក្នុងក្រុមជីវភាពរស់នៅដែលចូលរួមក្នុងការអនុវត្តការគ្រប់គ្រងធនធានប្រកបដោយនិរន្តរភាព
- ភាគរយផ្លាស់ប្ដូរនៅក្នុងភាគីពាក់ព័ន្ធដែលរីករាយជាមួយអត្ថប្រយោជន៍ប្រកបដោយនិរន្តរភាពពីគំនិតផ្ដួចផ្ដើមផ្អែកលើសហគមន៍
- ការកើនឡើងគួរឱ្យកត់សម្គាល់នៅក្នុងការយល់ដឹងរបស់សហគមន៍អំពីផលប៉ះពាល់ការប្រែប្រួលអាកាសធាតុ

គម្រោង M&E ផ្អែកលើប្រព័ន្ធសូចនាករចំនួនបី៖ ការប៉ាន់ប្រម៉ាណការកាត់បន្ថយភាពងាយរងគ្រោះ (VRA) ប្រព័ន្ធការប៉ាន់ប្រម៉ាណផលប៉ះពាល់កម្មវិធីជំនួយខ្នាតតូចនិងក្របខ័ណ្ឌសូចនាករការបន្សាំនឹងការប្រែប្រួលអាកាសធាតុរបស់អង្គការ UNDP។ កម្មវិធីមានគម្រោងចំនួនប្រាំ៖

១. គម្រោងគ្រប់គ្រងតំបន់ដីសើមផ្អែកលើសហគមន៍ (BIRAM)៖ ប្រជាជនជនជាតិដើមភាគតិច Chakma (ប្រជាជន ~ ២០០០នាក់) នៅក្នុងភូមិចំនួនប្រាំនៃតំបន់ Borkona Godabanne Chora Adam ជួបប្រទះនូវបញ្ហាការថយចុះបរិមាណទឹកភ្លៀងការកើនឡើងសីតុណ្ហភាពនិងការធ្លាក់ចុះកម្រិតទឹកដោយសារការប្រែប្រួលអាកាសធាតុ។ តំបន់ក្បែរខ្សែទឹក Godabanne Chora គឺជាប្រភពសំខាន់នៃប្រព័ន្ធធារាសាស្ត្រ និងកសិដ្ឋានចិញ្ចឹមនៅក្នុងតំបន់នោះ ប៉ុន្តែការព្យាករណ៍ការប្រែប្រួលអាកាសធាតុបានព្យាករណ៍ថាការផ្លាស់ប្ដូរអាកាសធាតុបច្ចុប្បន្ននេះនឹងនៅតែបន្តឆ្ពោះទៅរកលក្ខខណ្ឌកាន់តែក្ដៅហើយស្ងួត-ជាមួយនឹងបញ្ហាប្រឈមអវិជ្ជមានចំពោះទាំងប្រព័ន្ធអេកូឡូស៊ី និងជីវភាពរស់នៅ។ គម្រោងនេះនឹងបង្កើនសមត្ថភាពរបស់សហគមន៍ដើម្បីបន្សាំនឹងលក្ខខណ្ឌអាកាសធាតុដែលមិនល្អ និងការគ្រប់គ្រងតំបន់ដីសើមដែលមាននិរន្តរភាព។ វាផ្ដោតលើការលើកកម្ពស់ប្រភេទពូជដំណាំប្រកបដោយនិរន្តរភាព កែលម្អការអនុវត្តកសិកម្ម និងកែលម្អការប្រមូលទឹក។ គម្រោងនេះក៏នឹងបណ្ដុះបណ្ដាលសមាជិកសហគមន៍នៅក្នុងសកម្មភាពបង្កើតប្រាក់ចំណូលតាមជម្រើសផ្សេងៗ ដើម្បីកាត់បន្ថយសំពាធលើធនធានធម្មជាតិ និងប្រភពប្រាក់ចំណូលចម្រុះ។ ការអភិរក្សជីវចម្រុះ គឺជាសមាសភាគសំខាន់មួយនៃគម្រោងនេះ ហើយគណៈកម្មាធិការសហគមន៍នឹងត្រូវបានបង្កើតឡើង ដើម្បីការពារ និងថែរក្សាប្រព័ន្ធអេកូឡូស៊ីនេះ។

២. ការពង្រឹងភាពធន់ សហគមន៍នៅក្នុងតំបន់ឆ្នេរប៉ែកនិរតី (សកម្មភាពអនុវត្ត)៖ ដោយសារកម្រិតភាពក្រីក្រខ្ពស់ និងជិតទៅនឹងទឹកខ្លាំង តំបន់ Atulia Union ដែលស្ថិតនៅក្នុងតំបន់ឆ្នេរប៉ែកនិរតីនៃបង់ក្លាដេស ត្រូវបានចាត់តុកជាតំបន់ដែលងាយរងគ្រោះបំផុតមួយទៅនឹងការប្រែប្រួលអាកាសធាតុ។ ពីរបីទសវត្សចុងក្រោយនេះ ទាំងកសិដ្ឋាន និង

សកម្មភាពវារីវប្បកម្មថយចុះផលិតភាពដោយសារដីសឹករេចរិល ទឹកមានជាតិប្រៃ និងការប្រកួតប្រជែងសម្រាប់ធនធានកើនឡើង។ បច្ចុប្បន្ន ប្រជាជនជាង ៦៥ភាគរយ នៃតំបន់នេះខ្វះខាតស្បៀងអាហារ សម្រាប់រយៈពេលចាប់ពី ២ខែ ទៅ៦ខែ ជារៀងរាល់ឆ្នាំ។ បន្ទាប់ពីរងការខូចខាតធ្ងន់ធ្ងរដោយព្យុះស៊ីក្លូន Aila ឆ្នាំ២០០៩ ដី និងប្រព័ន្ធអេកូឡូស៊ីទឹកតំបន់នេះធ្លាក់ចុះ ដូច្នេះហើយ គឺកាន់តែងាយរងគ្រោះទៅនឹងផលប៉ះពាល់អាកាសធាតុជាបន្តបន្ទាប់។ ភូមិនានាក្នុងតំបន់នេះក៏រងខូចខាតផ្នែកហេដ្ឋារចនាសម្ព័ន្ធ ការបាត់បង់ទ្រព្យសម្បត្តិ និងការបាត់បង់ជីវភាពរស់នៅអំឡុងពេលព្យុះស៊ីក្លូន។ គម្រោងនេះ មានបំណងកែលម្អភាពធន់នៃសហគមន៍តំបន់ឆ្នេរបង់ក្លាដេស តាមរយៈការពង្រឹងមុខងារប្រព័ន្ធអេកូឡូស៊ី និងការការពារជីវភាពរស់នៅ។ សហគមន៍នឹងទទួលបានផលប្រយោជន៍ពីការកែលម្អការអនុវត្តវារីវប្បកម្ម និងការកាត់បន្ថយសំពាធអវិជ្ជមានលើវារីសត្វទឹកធម្មជាតិ ដែលបណ្តាលឱ្យមានការបង្កើនឱកាសជីវភាពរស់នៅ។ ម៉ូឌែលរីកចម្រើនមួយនៃការអភិវឌ្ឍប្រកបដោយនិរន្តរភាព នឹងកែលម្អភាពធន់របស់សហគមន៍ - និងប្រព័ន្ធអេកូឡូស៊ីមូលដ្ឋាន-ទៅនឹងផលប៉ះពាល់ការប្រែប្រួលអាកាសធាតុនានា។

៣. សាកល្បងគំនិតផ្តួចផ្តើមការអភិវឌ្ឍភាពធន់នឹងអាកាសធាតុ (CNRS)៖ Char Kazul គឺជាតំបន់កោះទន្លេមួយដែលមានភូមិចំនួន៤ ស្ថិតនៅចន្លោះទន្លេ Bura Gaurango និងទន្លេ Tetulia rivers នៅក្នុងប្រទេសបង់ក្លាដេស។ អំឡុងពេលរដូវខ្យល់មូសុង ទន្លេ Bura Gaurango អាចហក់ឡើងដល់ទទឹង ១០គក ដែលធ្វើឱ្យមានការពិបាកដល់ប្រជាជនទៅកាន់ទីគោក ដើម្បីធ្វើពាណិជ្ជកម្ម និងសេវាកម្មផ្សេងៗ។ ម៉ូឌែលការប្រែប្រួលអាកាសធាតុព្យាករណ៍ថាព្យុះស៊ីក្លូនកាន់តែញឹកញាប់ជាងរដូវកាលកាន់តែវែងដែលនឹងបង្កើនការកើតឡើងនូវជំនន់ទឹកសមុទ្រ ការច្រោះដាច់ដីច្រាំងទន្លេ ការជ្រៀតចូលជាតិប្រៃ ទឹកជោរខ្ពស់ខុសពីធម្មតា លក្ខខណ្ឌធាតុអាកាសសមុទ្រមិនទៀងទាត់និងភ្លៀងធ្លាក់មិនទៀងទាត់។ ការផ្លាស់ប្តូររបបធាតុអាកាសនិងសំពាធសង្គមបានបណ្តាលឱ្យមានការរីករាលដាលការសឹករេចរិលដីបង្កបង្កើនផលក៏ដូចជាផលប៉ះពាល់អវិជ្ជមានលើរុក្ខជាតិ និងសត្វនៅមូលដ្ឋាន។ គម្រោងនេះ (កក្កដា ២០១១ - ធ្នូ ២០១២) កែលម្អសមត្ថភាពបន្សាំផ្អែកលើសហគមន៍ ដោយអនុវត្តន៍កសិកម្មដែលមាននិរន្តរភាពសាកល្បង និងជំរុញការអភិរក្សដី។ ការបង្ហាញ និងការលើកកម្ពស់ប្រភេទពូជស្រូវដែលធន់នឹងជាតិប្រៃ ដំណាំចម្រុះ និងដំណាំប្រពលវប្បកម្ម នឹងធ្វើឱ្យប្រសើរឡើងនូវផលិតផលកសិកម្ម ទន្ទឹមនឹងការកាត់បន្ថយផលប៉ះពាល់នៃហានិភ័យពាក់ព័ន្ធនឹងអាកាសធាតុ។ បន្ថែមពីនេះទៀត គម្រោងនេះនឹងបង្កើនសមត្ថភាពដោះស្រាយមុខសញ្ញាគ្រោះថ្នាក់ធាតុអាកាសធម្មជាតិដោយការស្តារឡើងវិញនូវព្រៃកោងកាង និងការជួសជុលកែលម្អផ្ទះ និងរចនាសម្ព័ន្ធទូកឡើងវិញ។

៤. ការដោះស្រាយហានិភ័យអាកាសធាតុដោយការផ្តល់ភាពអង់អាចដល់ស្ត្រីនៅតំបន់ឆ្នេរ (GBSS)៖ គម្រោងនេះមានបំណងកាត់បន្ថយភាពងាយរងគ្រោះរបស់ប្រជាជនរស់នៅក្នុងភូមិដែលបានលើកឡើងទាំង៤ នៃស្រុក Dash mina upazila នៅក្នុងប្រទេសបង់ក្លាដេស តាមរយៈការបង្កើតមជ្ឈមណ្ឌលធនធានស្ត្រី (WRC) ដែលនឹងជំរុញវិធីសាស្ត្រសហគមន៍ចំពោះការយល់ដឹងការប្រែប្រួលអាកាសធាតុ និងការរៀបចំផែនការបន្សាំ។ ទីតាំងគោលដៅនេះបានជួបប្រទះនឹងសំណឹកធនធានធម្មជាតិ និងជីវចម្រុះហើយនិងអាចរងការខូចខាតដោយសារព្យុះស៊ីក្លូន ទឹកជោរកើនឡើង និងការព្យាករណ៍ នូវកំណើនភាពរាំងស្ងួត។ តាមរយៈការផ្តល់ភាពអង់អាចដល់ស្ត្រីដែលជួបការលំបាក គម្រោងនេះនឹងបង្កើនការទទួលប្រើប្រាស់នូវធនធានរបស់ពួកគេ សកម្មភាពជីវភាពរស់នៅចម្រុះ តម្រូវការសុខភាព និងអនាម័យ និងផលិតផលកសិកម្ម។ ក្រុមស្ត្រីចន្លោះពី ១៨-២០នាក់ នឹងទទួលខុសត្រូវសម្រាប់ការបង្កើត និងការអនុវត្តធនាគារគ្រាប់ពូជ ការបណ្តុះកូនឈើ ការកសាងសួនបន្លែ ការចិញ្ចឹមសត្វពាហនៈ និងការសម្របសម្រួលយុទ្ធនាការការយល់ដឹងអំពីការប្រែប្រួលអាកាសធាតុ។ Gram Bikash Shohayak Shangstha (GBSS) ការសម្របសម្រួល NGO នឹងធានាបានថា ស្ត្រីទទួលបានសម្ភារសមរម្យនិងមូលនិធិដោយការបង្កើតទំនាក់ទំនងជាមួយរដ្ឋាភិបាល NGO និងថ្នាក់ដឹកនាំសហគមន៍។

៥. ការលើកកម្ពស់សកម្មភាពផ្អែកលើកសិកម្មចម្រុះនៅស្រុក Jamalpur (RDOP)៖ នៅតំបន់កូនភ្នំនៃតំបន់ Bakshi gani Upazila សហគមន៍ Adibash ជួបប្រទះនឹងកំណើនភ្លៀងធ្លាក់យ៉ាងខ្លាំង និងភាពរាំងស្ងួតកាន់តែញឹកញាប់។ តំបន់នេះប្រើបច្ចេកទេសកសិកម្មបែបប្រពៃណីតាមជម្រាលភ្នំ ដែលហៅថាការដាំដុះ jhum ធ្វើឱ្យបរិស្ថានតាមជម្រាលភ្នំកាន់តែអាក្រក់ឡើងបន្តបន្ទាប់ ដែលធ្វើឱ្យមានកំណើនហានិភ័យនៃទឹកជំនន់គំហុកនិងការរំកិលដីផ្សេងៗការព្យាករណ៍ការប្រែប្រួលអាកាសធាតុធ្វើឱ្យហានិភ័យនេះកាន់តែធ្ងន់ធ្ងរឡើង កាត់បន្ថយដីដែលអាចធ្វើកសិកម្មបាន និងគំរាមកំហែងដល់ជីវភាពរស់នៅ។ គម្រោងការបន្សាំផ្អែកលើសហគមន៍ ធ្វើការងារកាត់បន្ថយការសឹករេចរិលដី និងបង្កើនសមត្ថភាពបន្សាំនៃភូមិតាមតំបន់កូនភ្នំដែលងាយរងគ្រោះទាំងប្រាំពីរ ដែលពឹងផ្អែកលើធនធានធម្មជាតិបាននឹងកំពុងធ្លាក់ចុះយ៉ាងរហ័ស។ ការដាំដុះបន្លែចម្រុះ ការដាំដុះផ្លែឈើ ផលិតកម្មជលផលនៅតាមផ្ទះសម្បែង និងបច្ចេកទេសដាំថ្នាក់ៗ នឹងត្រូវបានជំរុញទៅជាជម្រើសផ្សេងៗ ចំពោះវិធី

សាស្ត្រ jhum ជាវិធីមួយដើម្បីបញ្ឈប់ការរេចរឹលដី និងប្រាក់ចំណូលចម្រុះ។ សកម្មភាពការយល់ដឹង នឹងបង្កើនបន្ថែមនូវការយល់ដឹងរបស់សហគមន៍អំពីការប្រែប្រួលអាកាសធាតុ បំពាក់បំប៉នពួកគេបន្សាំទៅនឹងផលប៉ះពាល់ការប្រែប្រួលអាកាសធាតុឱ្យកាន់តែប្រសើរឡើងថែមទៀត។

## ឯកសារមេរៀនទី ២៣៖ កំណត់ត្រាលំហាត់ GRB បញ្ចាំងតាមកុំព្យូទ័រ

**តើអ្វីជាកញ្ចប់ថវិកាឆ្លើយតបទៅនឹងតម្រូវការយេនឌ័រ?**

- o បំបែកកញ្ចប់ថវិកាដោយឡែកសម្រាប់បុរស និងស្ត្រី
- o មូលនិធិសាធារណៈបែងចែកដើម្បីដោះស្រាយតម្រូវការបុរស និងស្ត្រីខុសៗគ្នា

**តើកញ្ចប់ថវិកាឆ្លើយតបទៅនឹងតម្រូវការយេនឌ័រប្រើប្រាស់ដូចម្ដេច?**

- o នៅពេលកញ្ចប់ថវិការដ្ឋាភិបាលកំពុងបង្កើត
- o គ្រប់ដំណាក់កាលទាំងអស់នៃការរៀបចំផែនការ ការរៀបចំថវិកា ការអនុវត្ត និងការត្រួតពិនិត្យ

**សូមលើកឧទាហរណ៍នៃកញ្ចប់ថវិកាឆ្លើយតបទៅនឹងតម្រូវការយេនឌ័រ?**

- o ជំនួយផ្នែកសេដ្ឋកិច្ចសម្រាប់គ្រួសារដែលខ្វះខាត
- o មជ្ឈមណ្ឌលថែទាំកុមារ
- o ការដាក់អំពូលភ្លើងតាមផ្លូវ
- o ការសាងសង់ផ្ទះសម្បែងសម្រាប់ស្ត្រីមេម៉ាយ
- o ទាំងអស់ខាងលើ

**តើកញ្ចប់ថវិកាឆ្លើយតបទៅនឹងតម្រូវការយេនឌ័រចាប់ផ្តើមជាមួយអ្វី?**

- o គោលនយោបាយសមភាពយេនឌ័រ
- o ការវិភាគយេនឌ័រ
- o ការបោះពុម្ពផ្សព្វផ្សាយកញ្ចប់ថវិកាយេនឌ័រ

**សូមសរសេរឈ្មោះតួអង្គសំខាន់ៗចំនួនបីពាក់ព័ន្ធក្នុងការរៀបចំកញ្ចប់ថវិកាឆ្លើយតបទៅនឹងតម្រូវការយេនឌ័រ?**

- o មន្ត្រីរដ្ឋាភិបាល
- o អង្គការសង្គមស៊ីវិល
- o សមាជិកសភា
- o អ្នកតស៊ូមតិយេនឌ័រ
- o អ្នកសិក្សា
- o សហគមន៍មូលដ្ឋាន

**តើការរៀបចំកញ្ចប់ថវិកាឆ្លើយតបទៅនឹងតម្រូវការយេនឌ័រត្រូវបានអនុវត្តបានល្អបំផុតនៅក្នុងកម្រិតណានៃរដ្ឋាភិបាល?**

- o កម្រិតជាតិ
- o កម្រិតក្រោមជាតិ
- o កម្រិតមូលដ្ឋាន
- o គ្រប់កម្រិតទាំងអស់

**តើការរៀបចំកញ្ចប់ថវិកាដែលឆ្លើយតបទៅនឹងតម្រូវការយេនឌ័រ និងកញ្ចប់ថវិកាឆ្លើយតបទៅនឹងតម្រូវការយេនឌ័រខុសគ្នាយ៉ាងម៉េច?**

- o ការរៀបចំកញ្ចប់ថវិកាយេនឌ័រទាក់ទងនឹងការចូលរួមរបស់ប្រជាជនកញ្ចប់ថវិកាយេនឌ័រមិនទាក់ទងនឹងការចូលរួមរបស់សហគមន៍ទេ ប៉ុន្តែជាការធ្វើការងារជាមួយរដ្ឋាភិបាលតែប៉ុណ្ណោះ
- o ការរៀបចំកញ្ចប់ថវិកាយេនឌ័រគឺជាដំណើរការ កញ្ចប់ថវិកាយេនឌ័រជាដំណាក់កាលចុងក្រោយនៃដំណើរការរៀបចំនេះ

សូមបំប្លែងឯកសារសំណៅនេះទៅជាបទបង្ហាញបញ្ចាំងលើកុំព្យូទ័រដោយមួយសំណួរក្នុងស្លាយ។ សូមប្រើគំនូរជីវចល ដើម្បីធានាថាតែសំណួរដំបូងប៉ុណ្ណោះត្រូវបង្ហាញឱ្យឃើញនៅលើអេក្រង់។បើសិនជាអ្នកចូលរួមស្នើសុំតម្រុយឬជម្រើសគួរតែមានជម្រើសផ្សេងទៀតលើកយកមកបង្ហាញ។ សូមធានាថាជម្រើសទាំងនេះលើកចេញមកមួយៗ មិនមែនទាំងអស់ទេ។

## ឯកសារមេរៀនទី ២៤៖ ករណីសិក្សាពីការចូលរួមរបស់អង្គការសង្គមស៊ីវិលក្នុងដំណើរការ GRB

ឥណ្ឌូណេស៊ី គឺជាប្រទេសមួយដែលមានចលនាថវិកាសង្គមស៊ីវិលរឹងមាំ។អង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិនិងអង្គការសង្គមស៊ីវិលជាច្រើនធ្វើការងារលើការជំរុញការចូលរួមរបស់សហគមន៍នៅក្នុងដំណើរការកញ្ចប់ថវិកាមូលដ្ឋាននិងក្នុងការងារការតស៊ូមតិថវិកា។

អង្គការសហប្រជាជាតិដើម្បីស្ត្រីធ្វើការយ៉ាងជិតស្និតជាមួយក្រសួងហិរញ្ញវត្ថុ (MoF) និង Bppennas លើការរៀបចំថវិកាដែលឆ្លើយតបទៅនឹងតម្រូវការយេនឌ័រ។យុទ្ធសាស្ត្រសំខាន់ៗយកទៅអនុវត្តដោយអង្គការសហប្រជាជាតិដើម្បីស្ត្រីរួមមាន- ក) ការប្រើប្រាស់របាយការណ៍យេនឌ័រជាចំណុចចាប់ផ្តើមរបស់ការរៀបចំថវិកាដែលឆ្លើយតបទៅនឹងតម្រូវការយេនឌ័រ ខ) ផ្តល់ការគាំទ្របច្ចេកទេសដល់រដ្ឋាភិបាលថ្នាក់ជាតិតាមរយៈទីប្រឹក្សា គ) ការបង្កើត និងការណែនាំឧបករណ៍អនុវត្តសម្រាប់ការរៀបចំថវិកាដែលឆ្លើយតបទៅនឹងតម្រូវការយេនឌ័រនៅក្នុងដំណើរការរៀបចំកញ្ចប់ថវិកា ឃ) ការបង្កើតយុទ្ធសាស្ត្រថ្នាក់ជាតិសម្រាប់ការរៀបចំផែនការ និងការរៀបចំកញ្ចប់ថវិកា និង ង) ការបង្កើតក្រុមអ្នកជំនាញការមួយលើការរៀបចំថវិកាដែលឆ្លើយតបទៅនឹងតម្រូវការយេនឌ័ររួមមានអ្នកជំនាញការអន្តរជាតិដូចជា Debbie Budlenderនិងអ្នកឯកទេសខាងរៀបចំថវិកាដែលឆ្លើយតបទៅនឹងតម្រូវការយេនឌ័ររបស់អង្គការសហប្រជាជាតិដើម្បីស្ត្រី សម្រាប់តំបន់អាស៊ីប៉ាស៊ីហ្វិក។

មូលនិធិអាស៊ីធ្វើការងារជាមួយនឹងអ្នកជំនាញការថ្នាក់ជាតិដូចជា Pattiro វេទិកាសម្រាប់តម្លាភាពថវិកាឥណ្ឌូណេស៊ី (Fitra) អង្គការសង្គមស៊ីវិលមូលដ្ឋាន និងទីភ្នាក់ងាររដ្ឋាភិបាលមូលដ្ឋានក្នុងស្រុកចំនួន២៥ និងក្រុងចំនួន៨ លើការរៀបចំថវិកាដែលឆ្លើយតបទៅនឹងតម្រូវការយេនឌ័រនិងការរៀចចំកញ្ចប់ថវិកាគាំទ្រអ្នកក្រ សម្រាប់កែលម្អសេវាសាធារណៈនានា។ ជាមួយគ្នាដែរពួកគេអាចជួយឱ្យមានការវិនិយោគនូវទឹកប្រាក់មួយពាន់លានដុល្លារលើកម្មវិធីចំនួនបី ១) កម្មវិធីអភិវឌ្ឍន៍ Kecamatan ដែលគ្រប់គ្រងដោយក្រសួងមហាផ្ទៃ ២) កម្មវិធីភាពក្រីក្រតំបន់ទីក្រុងដែលគ្រប់គ្រងដោយក្រសួងមុខងារសាធារណៈ និង ៣) កម្មវិធីសុខមាលភាពគ្រួសារដែលគ្រប់គ្រងដោយក្រសួងសុខាភិបាល។ កម្មវិធីទាំងនេះត្រូវបានដំណើរការជាមួយវិធីសាស្ត្រអភិវឌ្ឍន៍ជំរុញសហគមន៍ក្រោមឆ័ត្រនៃកម្មវិធី Nasional Pemberdayaan Masyarakat (កម្មវិធីផ្តល់ភាពអង់អាចដល់សហគមន៍)។ ក្រុមស្ត្រីដូចជា Koalisi និងក្រុម Komnas Perempuan បានតស៊ូមតិសម្រាប់ការបែងចែកជាក់លាក់សម្រាប់សុខភាព និងយុត្តិធម៌ជាពិសេសនៅក្នុងបរិបទនៃអំពើហិង្សាក្នុងគ្រួសារ។

ក្រុមផ្សេងៗទៀតក៏បានធ្វើការលើតម្លាភាពថវិកានិងអក្ខរកម្មដែរ។ សម្ព័ន្ធភាពក្រីក្រតំបន់ទីក្រុង ដែលសមាជិករួមមានអ្នករស់នៅតំបន់អាណាធិបតេយ្យតំបន់ទីក្រុងអ្នកលក់ដូរតាមចញ្ចើមថ្នល់ និងអ្នកបើកបរតាក់ស៊ី ដែលផ្តោតលើតម្លាភាពថវិកា ដោយការប្រើប្រាស់ដំណើរការច្បាប់ដើម្បីពង្រឹងដល់បញ្ហាធំៗនៅទីក្រុងយ៉ាកាតាចំពោះការបង្ហាញព័ត៌មាននៃការបែងចែកការចំណាយសម្រាប់ជនរងគ្រោះដោយសារទឹកជំនន់ (Austrian Development Agency ឆ្នាំ២០០៩)។ Koalisi ក៏បានធ្វើការងារលើការកសាងមូលដ្ឋានអក្ខរកម្មថវិកានៅក្នុងការងារអប់រំប្រជាពលរដ្ឋដែរ។ វេទិកាឥណ្ឌូណេស៊ីសម្រាប់តម្លាភាពថវិកាបានលេចឡើងជាមួយនឹងការបោះពុម្ពមួយដែលបានពន្យល់លម្អិតជាមួយនឹងឧទាហរណ៍នៃរបៀបប្រើប្រាស់ផែនការសកម្មភាពយេនឌ័រ (GAP) ហើយនិងរបាយការណ៍ថវិកាយេនឌ័រ និងការជំរុញអង្គការសង្គមស៊ីវិលដើម្បីប្រើប្រាស់ឧបករណ៍ទាំងនេះដែលអាចឱ្យមានការរៀបចំថវិកាដែលឆ្លើយតបទៅនឹងតម្រូវការយេនឌ័រនៅកម្រិតមូលដ្ឋាន (Hasan and Azis ឆ្នាំ២០១៣)។ ឧទាហរណ៍ផ្សេងទៀត គឺឈ្មោះថា បង្ហាញប្រាក់នោះដល់ខ្ញុំ៖ ការតស៊ូមតិថវិកានៅក្នុងឥណ្ឌូណេស៊ី ដែលសហការបោះពុម្ពផ្សាយនៅខែឧសភា ឆ្នាំ២០១១ ដោយ IBP និងអង្គការសង្គមស៊ីវិលឥណ្ឌូណេស៊ី។ វាចងក្រងនូវបទពិសោធន៍របស់ពួកគេនៃការធ្វើការងាររៀបចំថវិកាដែលឆ្លើយតបទៅនឹងតម្រូវការយេនឌ័រនិងពណ៌នាពីម៉ូឌែលតស៊ូមតិរបស់ពួកគេ ក៏ដូចជាបញ្ហាដែលពួកគេបានដោះស្រាយ។

យុទ្ធសាស្ត្រសំខាន់ៗដទៃទៀត គឺការសហការរវាងអង្គការស្ត្រី និង អង្គការដែលមិនផ្តោតលើយេនឌ័រ ដើម្បីគាំទ្រដល់ការចូលរួមរបស់ប្រជាពលរដ្ឋនិងនាំយកតម្រូវការរបស់ស្ត្រីទៅក្នុងទិសដៅនយោបាយ (Austrian Development Agency ឆ្នាំ២០០៩)។ ស្រដៀងគ្នានេះដែរ អង្គការដទៃទៀតមួយចំនួនក៏បានចាប់ដៃគូជាមួយរដ្ឋាភិបាលមូលដ្ឋាន ដើម្បីធ្វើវគ្គបណ្តុះបណ្តាល និងគាំទ្រដល់ការកសាងសមត្ថភាពលើការរៀបចំថវិកាដែលឆ្លើយតបទៅនឹងតម្រូវការយេនឌ័រ។ ករណីសិក្សាដែលត្រូវបានចងក្រងជាច្រើនរបស់អង្គការសង្គមស៊ីវិលធ្វើជាមួយនឹងសហគមន៍ ដើម្បីសម្របសម្រួលការចូលរួមសកម្មភាព GRB។ កិច្ចប្រឹងប្រែងដទៃទៀតរួមបញ្ចូលការចូលរួមរបស់ស្ត្រីនៅក្នុងការរៀបចំផែនការរបស់ស្រុក ការចូលរួមប្រឆាំងនឹងកញ្ចប់ថវិកាមូលដ្ឋានដែលមិនគាំទ្រអ្នកក្រនិងកង្វល់ថវិកានៃក្រុមបញ្ចុះបញ្ចូលសម្រាប់សិទ្ធិជនពិការ។

ΣmPower
Women for Climate-Resilient Societies
Sweden
Sverige
arrow
asian-pacific resource & research centre for women
UN WOMEN



# សៀវភៅណែនាំ បណ្តុះបណ្តាលស្តីពី យេនឌ័រនិងភាពធន់នឹង ការប្រែប្រួលអាកាសធាតុ

## វគ្គបញ្ចប់

## ការអនុវត្តការរៀនសូត្រ៖ ការបង្កើតគម្រោង CCDRR ដែលឆ្លើយតបនឹងតម្រូវការយេនឌ័រ

គោលបំណងនៃលំហាត់នេះ គឺដើម្បីឱ្យអ្នកចូលរួមសង្ខេបឡើងវិញនូវការរៀនសូត្រពីការបណ្តុះបណ្តាល និងអនុវត្តការរៀនសូត្រនេះក្នុងការបង្កើតគម្រោង CCDRR ដែលឆ្លើយតបនឹងតម្រូវការយេនឌ័រ។

1) បែងចែកអ្នកចូលរួមជាក្រុមដែលមានសមាជិកពី ៤ ទៅ ៥នាក់ក្នុងមួយក្រុម។ ផ្តល់ជូនពួកគេនូវសំណៅឯកសារទី២៥ មួយច្បាប់។ ប្រាប់ពួកគេឱ្យអានករណីសិក្សា។ ករណីសិក្សាផ្តល់ជូនពួកគេនូវព័ត៌មានចំនួនអំពីភូមិសន្មត់មួយនៅក្នុងប្រទេស X។
2) ដោយប្រើប្រាស់ព័ត៌មាននេះ ក្រុមនីមួយៗត្រូវបង្កើតគម្រោង CCDRR ដែលឆ្លើយតបនឹងតម្រូវការយេនឌ័រមួយ។ ពួកគេអាចបង្កើតគម្រោងដែលត្រូវបានធ្វើសមាហរណកម្មគម្រោងផ្អែកលើសហគមន៍ឬការធ្វើអន្តរាគមន៍តាមវិស័យដែលផ្អែកលើអ្វីដែលក្រុមសម្រេចចិត្ត។ សមាជិកក្រុមមានសិទ្ធិសេរីភាពក្នុងការធ្វើការសន្មត់ដែលគួរឱ្យជឿ ដោយផ្អែកលើបទពិសោធរបស់ពួកគេក្នុងវិស័យ។
3) ប្រការសំខាន់គឺថា ក្រុមនីមួយៗ អនុវត្តឱ្យបានច្រើនតាមដែលអាចធ្វើបាននូវការរៀនសូត្រពីការបណ្តុះបណ្តាលទៅក្នុងការងារនេះ។ សំណើគម្រោងគួរត្រូវបានបង្កើតឡើងដោយចងចាំក្នុងចិត្តពីបញ្ជីត្រួតពិនិត្យដែល បានផ្តល់ជូននៅក្នុងសំណៅឯកសារទី២៦។
4) ក្រុមនីមួយៗត្រូវជ្រើសរើសអ្នកស្ម័គ្រចិត្តម្នាក់ដែលនឹងបង្ហាញគម្រោងរបស់ពួកគេទៅក្នុងក្រុមធំ។ គម្រោងចាំបាច់ត្រូវតែបង្ហាញក្នុងទម្រង់ដូចខាងក្រោម៖

   តារាងទី៦៣៖ គំរូសម្រាប់សមាសភាពគម្រោង

| | | |
|---|---|---|
| ចំណងជើងគម្រោង | គោលដៅគម្រោង | គោលបំណង |
| ហានិភ័យសំខាន់ៗ | ទ្រឹស្តីនៃការផ្លាស់ប្តូរ | យុទ្ធសាស្ត្រ |
| ការវិភាគយេនឌ័រ | លទ្ធផល | ទិន្នផល/លទ្ធផល |
| ការវិភាគភាពងាយរងគ្រោះ | សកម្មភាព | ផែនការតាមដាន និងវាយតម្លៃ |

5) ប្រាប់ពួកគេថា គម្រោងនឹងត្រូវបានផ្តល់ចំណាត់ថ្នាក់ដោយផ្អែកលើប៉ារ៉ាម៉ែត្រចំនួន៣៖ ការប្រើប្រាស់ឧបករណ៍វិភាគយេនឌ័រ ការឆ្លើយតបនឹងតម្រូវការយេនឌ័រ និងគុណភាពគម្រោងដែលត្រូវបានបង្កើតឡើង និងការផ្សព្វផ្សាយលទ្ធផល។

# លំហាត់

## លំហាត់ទី២៨៖ ផ្ទាំងទស្សនីយភាពដោយដើរមើល (Gallery Walk) សម្រាប់បទបង្ហាញ

គោលបំណងសំខាន់នៃលំហាត់នេះគឺដើម្បីផ្តល់ជូនអ្នកចូលរួមនូវឱកាសរហ័សមួយដើម្បីបង្ហាញការវិភាគរបស់ពួកគេ និងការរៀនសូត្រពីគ្នាទៅវិញទៅមក។

**សម្ភារដែលតម្រូវឱ្យមាន៖** ជញ្ជាំង ស្កុតក្រដាស នាឡិកាកំណត់ម៉ោង និងម៉ោងរោទិ៍

**ដំណើរការ៖**

**ជំហានទី១៖** ស្នើក្រុមទាំងអស់ឱ្យបង្ហាញការងាររបស់ពួកគេនៅលើជញ្ជាំង។ ប្រើប្រាស់ជញ្ជាំងផ្សេងៗសម្រាប់ធ្វើបទបង្ហាញផ្សេងៗ។ ប្រាប់ពួកគេថា អ្នកធ្វើបទបង្ហាញមកពីក្រុមនីមួយៗមានពេល ៥នាទី ដើម្បីធ្វើបទបង្ហាញ និងមានពេល ២នាទីសម្រាប់វគ្គសំណួរ និងចម្លើយ។

**ជំហានទី២៖** បែងចែកអ្នកចូលរួមផ្សេងៗជា ៤ក្រុម គឺក្រុមអ្នកធ្វើការក្នុងការិយាល័យអ្នកតំណាងរបស់ក្រុមដែលផ្តោតលើស្ត្រីអ្នកពិគ្រោះយោបល់ផ្នែកគ្រប់គ្រង និងអ្នកតំណាងសហគមន៍។ ស្នើឱ្យក្រុមនីមួយៗផ្តល់ចំណាត់ថ្នាក់បទបង្ហាញដោយផ្អែកលើប៉ារ៉ាម៉ែត្រចំនួន៣ គឺការប្រើប្រាស់ឧបករណ៍វិភាគយេនឌ័រ ការឆ្លើយតបនឹងតម្រូវការយេនឌ័រ និងគុណភាពរបស់គម្រោងដែលត្រូវបានបង្កើតឡើង ព្រមទាំងការផ្សព្វផ្សាយលទ្ធផល។

**ជំហានទី៣៖** សមាជិកនីមួយៗរបស់ក្រុមថ្មី នឹងដើរជុំវិញដើម្បីស្តាប់បទបង្ហាញឆ្ងាយពីគ្នា។ (អ្នកធ្វើបទបង្ហាញម្នាក់ៗនឹងមានវគ្គមាន ៤ដង)។ កំណត់ម៉ោងកំណត់ពេល និងម៉ោងរោទិ៍ ដើម្បីធានាថា ក្រុមទាំងអស់ធ្វើការងារភ្លាមៗ និងមិនចំណាយពេលច្រើនជាងពេលដែលផ្តល់ជូន។

**ជំហានទី៤៖** នៅពេលបទបង្ហាញចប់ ពិភាក្សាអំពីការវិភាគ និងការរៀនសូត្រគន្លឹះនៅក្នុងក្រុមធំ។

**លទ្ធផលនៃការរៀនសូត្រ៖** បញ្ចប់លំហាត់នេះដោយនិយាយថា "ការវិភាគយេនឌ័រនិងការឆ្លើយតបនឹងតម្រូវការយេនឌ័រក្នុងគម្រោងនានាមានសារៈសំខាន់ខ្លាំង។ ជាញឹកញាប់ដោយពិចារណាលើសកម្មភាពដាច់ដោយឡែកមួយ ជាក់ស្តែងគួរតែធ្វើសមាហរណកម្មសកម្មភាពបញ្ច្រាបទាំងអស់ដែលពាក់ព័ន្ធនឹងគម្រោង។ កត្តានេះនឹងមិនត្រឹមតែជួយគម្រោងឱ្យកាន់តែមានការឆ្លើយតបនឹងតម្រូវការយេនឌ័រប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងថា ការប្រើប្រាស់ឧបករណ៍វិភាគនឹងអាចធ្វើឱ្យគម្រោងកាន់តែមានភាពរឹងមាំក្នុងការរៀបចំ និងកាន់តែមានប្រសិទ្ធផលនៅក្នុងវិធីសាស្ត្ររបស់ខ្លួន"។

## ឯកសារមេរៀនទី ២៥៖ ករណីសិក្សាពីការបង្កើតគម្រោងឆ្លើយតបនៅនឹងតម្រូវការយេនឌ័រ CCDRR

### សាវតា

Nikgramគឺជាស្រុកជនបទដែលស្ថិតនៅតាមជើងភ្នំនៃតំបន់ភ្នំ រដ្ឋ Uttar Desha។ ស្រុកនេះមានទីតាំងទស្សនីយភាពជាច្រើនដែលត្រូវបានកំណត់ដោយរដ្ឋាភិបាលជាតិជាមួយនឹងសក្តានុពលខ្ពស់សម្រាប់ទេសចរណ៍។ ទោះបីយ៉ាងណា កង្វះនូវអគារហេដ្ឋារចនាសម្ព័ន្ធ និងតំណភ្ជាប់ខ្សត់ខ្សោយ មានន័យថាប្រជាជននៅក្នុងស្រុកនៅតែក្រីក្រនិងពឹងផ្អែកលើការធ្វើកសិកម្មសម្រាប់បរិភោគ។ ប្រាក់ចំណូលប្រចាំឆ្នាំជាមធ្យមរបស់គ្រួសារភាគច្រើនប្រហែល ២៥០០ ដុល្លារអាមេរិក។ ប្រហែល ៣០% នៃគ្រួសារក្នុងស្រុកស្ថិតនៅក្រោមបន្ទាត់ក្រីក្រ។

ស្រូវ និងបន្លែ គឺជាដំណាំសំខាន់ពីរដែលត្រូវបានដាំដុះនៅក្នុងតំបន់នេះ។ក្នុងចំណោមប្រជាជន៦០០០០នាក់ចូលរួមក្នុងកសិកម្ម ជាងមួយភាគបីនៃប្រជាជនទាំងនេះ ក៏ធ្វើការងារជាកម្មករកសិកម្មដែលគ្មានដីឬមានដីតិចជាង០,៥ហិកតាដែលមិនអាចផ្តល់នូវអាហារគ្រប់គ្រាន់សម្រាប់គ្រួសារ។ គ្រួសារកសិកម្មចំនួនតែ ២% ប៉ុណ្ណោះ ដែលមានដីកាន់កាប់ទំហំធំ។ គ្រួសារកសិកម្មដែលមានដីធំទាំងនេះទទួលបានការប្រើប្រាស់បច្ចេកវិទ្យាកសិកម្មល្អប្រសើរការទទួលបានទីផ្សារនិងផលិតស្រូវនិងដំណាំដែលមានតម្លៃជាប្រាក់ផ្សេងៗទៀត។

ដីកសិកម្មស្ទើតែ ៨០% ត្រូវបានកាន់កាប់ដោយបុរស និងវប្បធម៌កំណត់ថាពួកគេទទួលខុសត្រូវទាំងស្រុងសម្រាប់ការរកប្រាក់ចំណូល និងគ្រប់គ្រងហិរញ្ញវត្ថុសម្រាប់គ្រួសារ។ ដូច្នេះ ការសម្រេចចិត្តខាងហិរញ្ញវត្ថុភាគច្រើន ជាពិសេសពាក់ព័ន្ធនឹងកសិកម្ម គឺត្រូវបានធ្វើឡើងដោយបុរស។ នៅលើក្រដាស់ បុរស និងស្ត្រីទាំងពីរនាក់មានការទទួលបានស្មើគ្នាពាក់ព័ន្ធនឹងទីផ្សារ តែជាក់ស្តែងប្តីជាអ្នកតែងតែសម្រេចចិត្តថាទៅពេលណា កន្លែងណា និងនរណាដែលត្រូវលក់ដំណាំឱ្យ។ ស្ត្រីមានការទទួលខុសត្រូវខាងការថែទាំ និងជាញឹកញាប់ធ្វើការក្នុងការងារដែលមិនទទួលបានប្រាក់កម្រៃ/ទទួលបានប្រាក់កម្រៃទាប ដើម្បីផ្គត់ផ្គង់គ្រួសាររបស់ពួកគេ។

នៅទសវត្សចុងក្រោយនេះ រដ្ឋាភិបាលវិនិយោគនៅក្នុងការបង្កើតចង្វាក់តម្លៃស្រូវនៅក្នុងមូលដ្ឋាន ហើយបច្ចុប្បន្ន ម្ចាស់ដីធំៗមួយចំនួន បាននឹងកំពុងធ្វើការជាសហគ្រិនដូចជាអ្នកប្រមូលទិញស្រូវ/ឈ្មួលកណ្តាលនិងរោងមាស៊ីនកិនស្រូវនានា។សហគ្រិនទាំងនេះភាគច្រើន គឺជាបុរស និងចូលចិត្តលក់ដូរជាមួយបុរសដែលជាអតិថិជននៅមូលដ្ឋាន។ ជាមួយនឹងដែរ ការសម្រេចចិត្តភាគច្រើនត្រូវបានធ្វើឡើងនៅក្នុងកិច្ចប្រជុំសង្គមសហការកសិករស្រូវដែលអនុញ្ញាតឱ្យមានតែម្ចាស់ដីជាសមាជិកប៉ុណ្ណោះ។ សូម្បីតែបុគ្គលិកផ្សព្វផ្សាយកសិកម្មមូលដ្ឋាន គឺសុទ្ធតែបុរស និងចូលចិត្តដោះស្រាយជាមួយបុរស។ ទោះបីជាប៉ុន្មានឆ្នាំថ្មីៗនេះរដ្ឋាភិបាលបានផ្លាស់ប្តូរគោលនយោបាយដើម្បីជ្រើសរើសស្ត្រីជាបុគ្គលិកផ្សព្វផ្សាយវិញ ប៉ុន្តែចំនួនបុគ្គលិកផ្សព្វផ្សាយជាស្ត្រីទាំងនេះគឺមានតែ៣នាក់ប៉ុណ្ណោះផ្ទុយនឹងបុគ្គលិកផ្សព្វផ្សាយជាបុរសប្រហែលជាងមួយរយនាក់។

បុគ្គលិកផ្សព្វផ្សាយជាស្ត្រីចំនួនបីនាក់ធ្វើការសកម្មល្មមនៅក្នុងមូលដ្ឋាននៃសេវាការងារពីរឆ្នាំរបស់ពួកគេ។ការងារផ្សព្វផ្សាយរបស់ពួកគេ ជាញឹកញាប់ជួបប្រទះនូវបញ្ហាខាងផ្នែករដ្ឋបាលសង្គម និងវប្បធម៌។ ទោះបីជាមានឧបសគ្គក៏ដោយ ពួកគេអាចជំរុញដល់បច្ចេកវិទ្យាដាំដុះស្រូវឆ្លាតវៃដែលធន់នឹងអាកាសធាតុនិងបច្ចេកទេសកសិកម្មលក្ខណៈគ្រួសារដទៃទៀត។ បច្ចុប្បន្នស្ត្រីចំនួន១៥នាក់នៅក្នុងស្រុកបានរកប្រាក់ចំណូលបន្ថែមលើប្រាក់ចំណូលរបស់ពួកគេ តាមរយៈការរៀបចំសួនបន្លែនៅទីធ្លារខាងក្រោយផ្ទះ ការចិញ្ចឹមបសុបក្សី និងពពែ។

ក្រៅពីបញ្ហាភាពខុសគ្នាយេនឌ័រ បញ្ហាប្រឈមការប្រែប្រួលអាកាសធាតុក៏មានច្រើននៅក្នុងតំបន់នេះដែរ។ ស្រុកមានបទពិសោធន៍កង្វះទឹកខ្លាំង។ ប្រព័ន្ធធារាសាស្ត្រជាច្រើនមិនអាចផ្គត់ផ្គង់ទឹកពេញមួយឆ្នាំនៅក្នុងស្រុក។ជាញឹកញាប់អ្នកកាន់កាប់ដីធំៗទាញយកទឹកក្រោមដីនិងមួយចំនួនទៀតបានវិនិយោគនៅក្នុងប្រព័ន្ធគ្រប់គ្រងទឹកផ្ទាល់ខ្លួនរបស់ពួកគេ ដើម្បីទទួលបានទឹកស្រោចស្រពពេញមួយឆ្នាំ។ កសិករដីតូចៗពឹងផ្អែកលើទឹកភ្លៀង។ ពួកគេជួបប្រទះការខ្វះខាតទឹកនៅក្នុងរដូវប្រាំង និងទឹកជំនន់នៅក្នុងរដូវវស្សា។ ប៉ុន្មានឆ្នាំចុងក្រោយនេះ បញ្ហាបន្ថែមនៃជាតិប្រៃបានបូកបន្ថែមទៅក្នុងបញ្ជីបញ្ហានៃកសិករដែលមានដីតូចៗនិងកសិករដែលជួបការលំបាក។ការទាញយកទឹកក្រោមដីហួសកម្រិតសម្រាប់កសិកម្មដំណាំស្រូវគឺបន្ទុកដ៏ធំនៃបញ្ហានេះ។ បញ្ហានៃហេតុការណ៍កង្វះទឹកខ្លាំងកើតឡើងដដែលៗ ប៉ុន្តែបច្ចេកវិទ្យាការគ្រប់គ្រងទឹកនៅមិនទាន់ជ្រាបចូលនៅក្នុងស្រុកនៅឡើយ។

### គ្រោះមហន្តរាយ

ទឹកជំនន់ដ៏ធំនៅឆ្នាំមុនអំឡុងពេលរដូវវស្សា ផ្តល់ផលប៉ះពាល់អវិជ្ជមានយ៉ាងខ្លាំងលើផលិតកម្មកសិកម្ម។ភូមិតំបន់ឆ្នេរដែលនៅតាមតំបន់ទំនាបត្រូវបានជន់លិចរយៈពេលជាងបួនខែពេលដែលទឹកសមុទ្រឡើងលិចតំបន់ទាំងនេះដែលជាទីតាំងផ្ទះសម្បែង។ ការជ្រៀតចូលទឹកប្រៃ ក៏ជះឥទ្ធិពលលើជីជាតិដី ហើយដូច្នេះការធ្លាក់ចុះថេរនូវផលិតផលស្រូវត្រូវបានមើលឃើញ។ គ្រួសារជាច្រើនត្រូវបានជាប់គាំងនៅក្នុងវដ្តបំណុល ដែលបណ្តាលមកពីការខ្ចីប្រាក់ជាយុទ្ធសាស្ត្រដោះស្រាយអំឡុងពេលមានគ្រោះធម្មជាតិ និងគ្រោះអាសន្ន។

សេដ្ឋកិច្ចដែលផ្អែកលើកសិកម្មរបស់ស្រុក រងការខូចខាតពីការធ្លាក់ចុះនូវផលិតកម្ម គ្រួសារដែលរង ផលប៉ះពាល់ខ្លាំងក៏ជួបប្រទះនឹងភាពអត់ឃ្លានរយៈពេលពីរទៅបីខែផងដែរជាមួយគ្នានេះស្ត្រីទទួលរងផលប៉ះពាល់ខ្លាំងជាងគេ។ ជាពិសេស ទិន្នផលស្រូវបានធ្លាក់ចុះដោយសារការជ្រាតចូលទឹកប្រៃ និងបច្ចុប្បន្ន ដីមានកាន់តែតិចសម្រាប់ដាំដុះបន្លែ។ លក្ខខណ្ឌផ្លូវខូច និងស្ពាន

រងការបំផ្លិចបំផ្លាញបន្ថែមបានធ្វើឱ្យស្រុកដាច់ឆ្ងាយពីទីរួមខេត្ត ដែលបណ្តាលឱ្យតម្លៃដំណាំកាន់តែទាប។ បច្ចុប្បន្ននេះ វាជាខែវិច្ឆិកា ហើយហេដ្ឋារចនាសម្ព័ន្ធនៅមិនទាន់សាងសង់ឡើងវិញនៅឡើយ។

ហេដ្ឋារចនាសម្ព័ន្ធដែលខូចខាតក៏បានពន្យាពេល និងរារាំងយ៉ាងខ្លាំងដល់ជំនួយសង្គ្រោះបន្ទាន់ និងប្រតិបត្តិការការជួយសង្គ្រោះ។ មជ្ឈមណ្ឌលសុខភាពដែលមានស្រាប់នៅក្នុងស្រុកតែមួយប៉ុណ្ណោះក៏រងការខូចខាត។ទោះបីយ៉ាងនេះក្តីមជ្ឈមណ្ឌលនេះមិនត្រូវបានបំពាក់យ៉ាងល្អ ដើម្បីដោះស្រាយជាមួយករណីវេជ្ជសាស្ត្រធ្ងន់ធ្ងរ និងសម្រាប់ភាពស្មុគស្មាញអំឡុងពេលមានផ្ទៃពោះ គ្រោះថ្នាក់ និងជំងឺធំៗទេ ប្រជាជនត្រូវទៅទីរួមខេត្ត។ការថែទាំងអំឡុងពេលសម្រាលកូនត្រូវបានគ្រប់គ្រងនៅក្នុងភូមិនិងជំងឺទូទៅត្រូវបានព្យាបាលដោយការប្រើបច្ចេកទេសការព្យាបាលបែបបុរាណ។ការរៀបចំផែនការគ្រួសារទោះបីជាមានការណែនាំអស់ជាច្រើនឆ្នាំកន្លងទៅ មិនត្រូវយកមកអនុវត្តដោយ គូរស្វាមីភិរិយា ដូច្នេះហើយតំបន់នេះមានអត្រាកំណើតខ្ពស់ណាស់។

ពីរ បីខែចុងក្រោយនេះ គ្រួសារមួយចំនួនមានបុរសធ្វើចំណាកស្រុកទៅស្រុកជិតខាងដើម្បីរកការងារជាកម្មករប្រាក់ឈ្នួលប្រចាំថ្ងៃ ឬកម្មករគ្មានជំនាញនៅក្នុងឧស្សាហកម្ម។ កត្តាមួយនៃកត្តាដែលបង្កឱ្យមានការចំណាកស្រុក ត្រូវបានរាយការណ៍ថា បំណុលគ្រួសារ និងកង្វល់ពីការសងឥណទានទាំងផ្លូវការ និងក្រៅផ្លូវការ។ គ្រួសារទាំងនេះមួយចំនួន ត្រូវបានកំណត់លក្ខណៈដោយស្ត្រីវ័យចំណាស់រួមទាំងមិនមានជំនាញគ្រប់ដើម្បីធ្វើកសិកម្ម និងទទួលបន្ទុកយ៉ាងធំក្នុងការមើលថែកុមារតូចជាច្រើន។ ប្រាក់បញ្ញើរពីក្មេងៗវ័យជំទង់ គឺញឹកញាប់មិនគ្រប់គ្រាន់សម្រាប់ការចំណាយរបស់គ្រួសារនោះទេដូច្នេះហើយជីដូនក៏ស្វែងរកការងារធ្វើដែរ។

## គម្រោង

អង្គការ ក្នុងមូលដ្ឋាន បាននឹងងកំពុងធ្វើការនៅក្នុងស្រុកជិតខាងលើជីវភាពរស់នៅរបស់ស្ត្រី និងបញ្ហាការផ្តល់ភាពអង់អាចដល់ស្ត្រី។ ទីភ្នាក់ងារពហុម្ចាស់ជំនួយ ចង់វិនិយោគនៅក្នុងស្រុក Nikgram លើការអនុវត្តកសិកម្មដែលធន់នឹងអាកាសធាតុដែលឆ្លើយតបទៅនឹងតម្រូវការយេនឌ័រ។ គម្រោងនេះនឹងត្រូវបានអនុវត្តជាដៃគូជាមួយរដ្ឋាភិបាលថ្នាក់ជាតិហើយរដ្ឋបាលមូលដ្ឋាននឹងចូលរួមយ៉ាងសកម្ម។ វាគឺជាគម្រោងតម្លៃរាប់លានដុល្លារ ហេតុដូចនេះការប្រកួតប្រជែងមួយត្រូវបានប្រកាសសម្រាប់អង្គការនៅក្នុងប្រទេសដើម្បីដាក់សំណើរបស់ពួកគេ។

ម្ចាស់ជំនួនបានចាត់តាំងក្រុមហ៊ុនទីប្រឹក្សាមួយ ដើម្បីសម្របសម្រួលលើផ្នែកនេះ។ ក្រុមហ៊ុនត្រូវបានទទួលស្គាល់ពីជំនាញរបស់ពួកគេនៅក្នុងជំនាញជាក់លាក់ចំនួនពីរ៖

ក ) ការវិភាគយេនឌ័រ និងដំណើរដែលមានការចូលរួម

ខ ) ការគ្រប់គ្រងផ្អែកលើលទ្ធផល

ដំណាក់កាលទី១នៃការប្រកួតប្រជែងគឺជាការប្រកួតប្រជែងផ្ទាំងរូបភាពដែលទីភ្នាក់ងារប្រកួតប្រជែងទាំងអស់តម្រូវឱ្យបង្ហាញនូវសំណើរបស់ពួកគេ។អ្នកត្រូវរៀបចំផ្ទាំងរូបភាពមួយលើសំណើរគម្រោងរបស់អ្នកសម្រាប់តំបន់នេះ។

| ឯកសារមេរៀនទី ២៦៖ បញ្ជីផ្ទៀងផ្ទាត់ការបង្កើតសំណើគម្រោង | | |
|---|---|---|
| **ប្រធានបទគម្រោង** | > ប្រធានបទគម្រោងគួរតែគួរឱ្យចាប់អារម្មណ៍ ប៉ុន្តែក៏មានទំនាក់ទំនងជាមួយនឹងភាពងាយរងគ្រោះអាកាសធាតុសំខាន់ៗដែលត្រូវដោះស្រាយ និងអាចទៅដល់លក្រុមគោលដៅ។ | រកមើលផ្នែក - នៃម៉ូឌុលដើម្បីដាក់ចំណងជើងនៅក្នុងបរិបទCCDRR, HBRA, LNOB និងយេនឌ័រ។ |
| **គោលបំណងគម្រោង** | > វត្ថុបំណងគម្រោងគួរតែមានទំនាក់ទំនងច្បាស់លាស់ជាមួយនឹងយុទ្ធសាស្ត្រមួយក្នុងចំណោមផ្នែកយុទ្ធសាស្ត្រទាំងបួនដែលSGPផ្តោតលើ<br>> វាក៏គួរតែកំណត់ឱ្យបានច្បាស់លាស់ ថាវានឹងអនុវត្តតាមវិធីសាស្ត្របន្សាំផ្អែកលើសហគមន៍ និងវិធីសាស្ត្រផ្អែកលើប្រព័ន្ធអេកូឡូស៊ី ម៉ូឌែល REDD បូក និង/ឬ ផ្តោតលើការគ្រប់គ្រងចំណេះដឹង និងការកសាងសមត្ថភាព។<br>> ទស្សនៈបរិយាបន្នផ្នែកសង្គមគួរតែរំលេចចេញឱ្យច្បាស់។<br>> គូសបញ្ជាក់វត្ថុបំណងនានាដែលមានការផ្លាស់ប្តូរពីលក្ខណៈធម្មជាតិ ជាពិសេសពីទស្សនៈយេនឌ័រ។ | រកមើលផ្នែក - នៃម៉ូឌុលដើម្បីដាក់វត្ថុបំណងនៅក្នុងគោលដៅអន្តរជាតិរួម និងសូចនាករ ព្រមទាំងជាគោលនយោបាយជាតិ។ |
| **ទ្រឹស្តីនៃការផ្លាស់ប្តូរ និងផ្លូវផលប៉ះពាល់** | > បង្ហាញពីទំនាក់ទំនងនៃសកម្មភាពគម្រោងជាមួយគោលបំណងដើម្បីបង្កើតទ្រឹស្តីមួយនៃការផ្លាស់ប្តូរមួយ។ វិធីសាមញ្ញក្នុងការធ្វើមាន៖<br>> បើសិនគម្រោងអនុវត្ត (សកម្មភាពទាំងនេះ) បន្ទាប់ជា (លទ្ធផល) ដែលត្រូវសម្រេចបាន។<br>> បើសិន (លទ្ធផល) នេះសម្រេចបាន បន្ទាប់ជា (គោលបំណង) ដែលត្រូវសម្រេចបាន។<br>> បង្កើតដ្យាក្រាមផ្លូវផលប៉ះពាល់សម្រាប់គម្រោងរបស់អ្នក ដែលអាចជួយអ្នកដទៃទៀតឱ្យយល់ដឹងពីអន្តរទំនាក់ទំនងរវាងសកម្មភាពផ្សេងៗទៀត និងវត្ថុបំណង។ | សូមប្រើក្របខ័ណ្ឌបុព្វហេតុ - ផលវិបាកនិងក្របខ័ណ្ឌដំណោះស្រាយពីផ្នែក - នៃម៉ូឌុលនេះដើម្បីបង្កើតទ្រឹស្តីនៃការផ្លាស់ប្តូរ និងផ្លូវផលប៉ះពាល់។ |
| **ផែនការសកម្មភាព** | > ផ្តោតលើសកម្មភាពដែលអាចធ្វើបាននៅក្នុងថេរវេលាដែលត្រូវបានផ្តល់ឱ្យ។<br>> បង្កើតសកម្មភាពដែលត្រូវធ្វើដោយសហគមន៍ផ្ទាល់ តាមរយៈគម្រោងរដ្ឋាភិបាលដែលមានស្រាប់។<br>> សកម្មភាពទាំងអស់ គួរតែមានទំនាក់ទំនងច្បាស់លាស់ទៅនឹងលទ្ធផល។<br>> គូសបញ្ជាក់សកម្មភាពដែលចូលរួមចំណែកដោយផ្ទាល់ក្នុងការផ្តល់ភាពអង់អាចដល់យេនឌ័រ និងសមភាពយេនឌ័រ។ | រកមើលផ្នែក - នៃម៉ូឌុលនេះដើម្បីកំណត់នូវដំណោះស្រាយ និងសកម្មភាពឆ្លើយតបទៅនឹងតម្រូវការយេនឌ័រ។ |
| **យុទ្ធសាស្ត្រ** | > គូសបញ្ជាក់វិធីរបស់អ្នកនៃការធ្វើការកៀរគរសហគមន៍ជាពិសេសស្ត្រី និងសហគមន៍ដែលងាយរងគ្រោះ។ សូមរក្សាភាសាបែបសាមញ្ញ និងងាយស្រួលយល់។<br>> គូសបញ្ជាក់នូវយុទ្ធសាស្ត្រការបញ្ជ្រាបយេនឌ័ររបស់អ្នក។<br>> ពន្យល់ពីរបៀបដែលគម្រោងរបស់អ្នកនឹងមាននិរន្តភាព ហើយនិងបន្តទៅមុខទៀតក្នុងអំឡុងពេលគម្រោង។ | សូមប្រើឧបករណ៍វិភាគយេនឌ័រនៅក្នុងផ្នែក - នៃម៉ូឌុលនេះ ដើម្បីគូសវាសគម្លាតសំខាន់ៗ និងដាក់យុទ្ធសាស្ត្រនៅក្នុងបរិបទការវិភាគយេនឌ័រ។ |

| ឯកសារមេរៀនទី ២៦៖ បញ្ជីផ្ទៀងផ្ទាត់ការបង្កើតសំណើគម្រោង | | |
|---|---|---|
| **ការតាមដាន និងការវាយតម្លៃ** | > បង្កើត log frame របស់គម្រោងជាមួយនឹងភាពច្បាស់លាស់ និងសូចនាករដែលអាចវាស់វែងបាន (សំដៅដល់ប្រព័ន្ធទិន្នន័យសូចនាករលទ្ធផលSGPនិងប្រើសូចនាករច្រើនតាមតែអាចធ្វើបាន)។<br>> សូចនាករទាំងអស់គួរតែបែងចែកតាមភេទ។<br>> រួមបញ្ចូលសូចនាករការយល់ដឹងអំពីយេនឌ័រ។<br>> មានផែនការច្បាស់លាស់ពីរបៀបទិន្នន័យពាក់ព័ន្ធនឹងសូចនាករនឹងត្រូវបានប្រមូល (លុះត្រាអ្នកអាចធ្វើការស្ទាបស្ទង់មតិមួយ - សូចនាករជាច្រើនមានការលំបាកក្នុងការវាយតម្លៃ។ ត្រូវប្រាកដនិយម)។ | រកមើលផ្នែក-នៃម៉ូឌុលនេះក្នុងការគាំទ្រដល់ការបង្កើតសូចនាករដែលមានការយល់ដឹងអំពីយេនឌ័រ។ |
| **ការបង្ហាញនៅក្នុងបណ្តុំអ្នកជំនាញ** | > រៀបចំបញ្ជីគម្រោងស្រដៀងគ្នាដែលត្រូវបានអនុវត្តជាមួយការផ្តល់មូលនិធិ និងលទ្ធផលសម្រិត។<br>> ផ្តោតលើការកៀរគរសហគមន៍របស់អង្គការ និងការចូលរួមធ្វើការដោយសង្កត់ធ្ងន់លើការងារដែលបានធ្វើជាមួយស្ត្រី និងការកៀរគរធនធានជាសាច់ប្រាក់ ឬជាវត្ថុ។<br>> គូសបញ្ជាក់ពីទំនាក់ទំនងនៃអង្គការក្នុងស្រុក តំបន់ និងរដ្ឋាភិបាលជាតិ បើសិនមាន។ | |

# ឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធទី ១៖ បញ្ជីផ្ទៀងផ្ទាត់សម្រាប់ការជ្រើសរើសវគ្គ និងលំហាត់

| វគ្គ/លំហាត់ | អង្គការស្ត្រី (សិទ្ធមនុស្ស) | អង្គការស្ត្រី(ផ្តោតលើជីវភាពរស់ និង សេដ្ឋកិច្ច) | អង្គការស្ត្រី (ផ្តោតលើសុខភាព និង ផ្នែកសង្គម) | អង្គការសង្គមស៊ីវិល (ផ្តោតលើជីវភាពរស់នៅនិង សេដ្ឋកិច្ច) | អង្គការសង្គមស៊ីវិល(ផ្តោតលើសុខភាពនិង សង្គម) | CCDRR ដែលផ្តោតលើអង្គការសង្គមស៊ីវិល | ការអនុវត្តនៅមូលដ្ឋាន | ការផ្តោតលើការស្រាវជ្រាវ និងការវិភាគគោលនយោបាយ | ការបណ្តុះបណ្តាលនិងការកសាងសមត្ថភាព |
|---|---|---|---|---|---|---|---|---|---|
| សិទ្ធិមនុស្ស និងវិធីសាស្ត្រ ផ្អែកលើសិទ្ធិមនុស្សជាមូលដ្ឋាន(HRBA)មិនមានអ្នកណាម្នាក់ត្រូវបានទុកចោល (LNOB) និងសមភាពយេនឌ័រ និងភាពចម្រុះប្រសព្វ | ● | ● | ● | ● | ● | ● | ● | ● | ● |
| «សិទ្ធិមនុស្ស» លំហាត់ស្តីពីការបង្កើតភាពប្រទាក់ប្រឡា | | ● | ● | ● | ● | | | ● | ● |
| ហ្គេម «Power Walk» | | | | | | ● | ● | | |
| ក្រដាស់តូចៗ «ទស្សនៈយេនឌ័រ» | | | | ● | ● | ● | ● | | |
| ហានិភ័យអាកាសធាតុសកល ការការបន្សាំ កសាងភាពធន់ និងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ | ● | ● | ● | ● | ● | | ● | ● | ● |
| «អ៊ីស្តក្រាម» អំពីការប្រែប្រួលអាកាសធាតុ | ● | ● | ● | ● | ● | | ● | ● | ● |
| ទស្សនៈភាពធន់ | ● | ● | ● | ● | ● | ● | ● | ● | ● |
| វិសាលភាពយេនឌ័រនៃ CCDRR | ● | | | ● | ● | ● | | ● | |
| ក្របខ័ណ្ឌ Moser សម្រាប់ការបង្កើតផែនទីហានិភ័យអាកាសធាតុដែលមានទស្សនៈយេនឌ័រ | | ● | ● | | | | | | ● |
| ប័ណ្ណផ្គូផ្គងស្តីពីតួនាទីយេនឌ័រនិងផលប៉ះពាល់ខុសៗគ្នា | | | | | | ● | ● | | |
| ស្ត្រីជាភ្នាក់ងារការផ្លាស់ប្តូរ៖ មើលករណីសិក្សាឡើងវិញ | | | | ● | ● | | ● | | |
| ក្របខ័ណ្ឌគោលនយោបាយ CCDRR សកល (UNFCCC និងក្របខ័ណ្ឌទីក្រុងសេនដៃ) និងការប្តេជ្ញាចិត្តយេនឌ័រ | ● | | | | | ● | | ● | |
| លំហាត់ក្រវ៉ | | ● | ● | ● | ● | | ● | | ● |
| ការពិភាក្សាក្រុមពីទំនាក់ទំនងនៃក្របខ័ណ្ឌការងារUNFCCC និងក្របខ័ណ្ឌការងារទីក្រុងសេនដៃនៅកម្រិតថ្នាក់ជាតិ | ● | | | | | ● | | ● | |
| ក្របខ័ណ្ឌការងារថ្នាក់ជាតិសម្រាប់ CCDRR និងការបញ្ជ្រាបយេនឌ័រនៅកម្រិតប្រទេស | ● | ● | ● | ● | ● | ● | ● | ● | ● |
| ក្រុមការងារទទួលបន្ទុកវិភាគយេនឌ័រ «NAP និង NDC» | | | | ● | ● | ● | | | ● |
| ក្រុមការងារទទួលបន្ទុកបង្កើតរបាយការណ៍ស្រមោលសម្រាប់«CEDAW និង BPfA» ស្តីពីស្ថានភាពការបញ្ជ្រាបយេនឌ័រនៅក្នុងគោលនយោបាយថ្នាក់ជាតិ | ● | ● | ● | | | | | ● | |
| ចំណុចខ្វះខាតនិងការប្រឈមនិងយុទ្ធសាស្ត្រសម្រាប់ការបញ្ជ្រាបយេនឌ័រនៅក្នុងគោលនយោបាយ CCDRRថ្នាក់ជាតិ | ● | ● | ● | ● | ● | ● | ● | ● | ● |

## ឧបសម្ព័ន្ធទី ១៖ បញ្ជីផ្ទៀងផ្ទាត់សម្រាប់ការជ្រើសរើសវគ្គ និងលំហាត់

| វគ្គ/លំហាត់ | អង្គការស្ត្រី (សិទ្ធមនុស្ស) | អង្គការស្ត្រី(ផ្តោតលើជីវភាព រស់ និង សេដ្ឋកិច្ច) | អង្គការស្ត្រី (ផ្តោតលើសុខភាព និង ផ្នែកសង្គម) | អង្គការសង្គមស៊ីវិល (ផ្តោតលើជីវភាពរស់នៅនិង សេដ្ឋកិច្ច) | អង្គការសង្គមស៊ីវិល(ផ្តោតលើសុខភាពនិង សង្គម) | CCDRR ដែលផ្តោតលើអង្គការសង្គមស៊ីវិល | ការអនុវត្តនៅមូលដ្ឋាន | ការផ្តោតលើការស្រាវជ្រាវ និង ការវិភាគគោលនយោបាយ | ការបណ្តុះបណ្តាលនិងការកសាងសមត្ថភាព |
|---|---|---|---|---|---|---|---|---|---|
| ការសម្តែងតួ «Batokas និង Gonkas» | | | | ● | ● | ● | ● | | ● |
| ករណីសិក្សាស្តីពីការបង្កើតគោលនយោបាយ CCDRR ថ្នាក់ជាតិ - ចំណុចចាប់ផ្តើម/ច្រកចូលសម្រាប់អង្គការសង្គមស៊ីវិល | ● | ● | ● | | | | | ● | |
| ការបញ្ជ្រាបយេនឌ័រទូទាំងវដ្តគម្រោង៖ ដំណើរការ និងឧបករណ៍ជ្រើសរើសសម្រាប់ការវិភាគយេនឌ័រ | ● | ● | ● | ● | ● | ● | ● | ● | ● |
| ក្របខ័ណ្ឌ Moser សម្រាប់ការរៀបចំផែនការ | | | | ● | ● | ● | ● | | |
| ក្របខ័ណ្ឌវិភាគ Harvard | ● | ● | ● | | | | | ● | ● |
| ឧបករណ៍ប៉ាន់ប្រម៉ាណភាពងាយរងគ្រោះដែលមានទស្សនៈយេនឌ័រ ឧបករណ៍សម្រាប់គម្រោង CCDRR | | | | | | ● | | ● | |
| ឧទាហរណ៍ការប៉ាន់ប្រម៉ាណយេនឌ័រ | ● | ● | ● | ● | ● | | ● | | ● |
| ការរៀបចំផែនការឆ្លើយតបទៅនឹងតម្រូវការយេនឌ័រ ការរៀបចំ និងការបង្កើតគម្រោង | ● | ● | ● | ● | ● | ● | | ● | ● |
| ក្របខ័ណ្ឌបុព្វហេតុ ផលវិបាកនិងដំណោះស្រាយ | | | | | | | ● | | |
| ដំណើរការអនុវត្តដែលមានការយល់ដឹងអំពីយេនឌ័រ | ● | ● | ● | ● | ● | ● | ● | | |
| ទីផ្សារកម្មវិធីស្តីពីឧបករណ៍ដែលមានការចូលរួម និងបច្ចេកទេស | | | | | | | ● | | |
| ការតាមដាន និងការវាយតម្លៃដែលមានទស្សនៈរំញោចយេនឌ័រ | ● | ● | ● | ● | ● | ● | ● | ● | ● |
| លំហាត់ផ្តល់ចំណាត់ថ្នាក់កង់អំពីមិនមានអ្នកណាម្នាក់ត្រូវបានទុកចោល LNOB | ● | | | | | | | ● | ● |
| ម៉ូឌែលការបន្សាំ និងប៉ាន់ប្រម៉ាណ គម្រោងបន្សាំដែលឆ្លើយតបទៅនឹងតម្រូវការយេនឌ័រ | ● | ● | ● | | | | | | |
| ការពិភាក្សាជាក្រុមគ្រាប់ | | | | ● | ● | ● | ● | ● | ● |
| វិធីសាស្ត្រត្រួតពិនិត្យឡើងវិញពីករណីសិក្សា Harvard សម្រាប់គម្រោងភាពធន់ទីក្រុងផ្អែកលើសហគមន៍ដែលដឹកនាំដោយស្ត្រី | ● | ● | ● | ● | ● | ● | ● | ● | ● |
| អន្តរទំនាក់ទំនងនៃយេនឌ័រនិងការបន្សាំនឹងការប្រែប្រួលនៅក្នុងវិស័យដែលបានជ្រើសរើស | ● | ● | ● | ● | ● | ● | | ● | ● |
| ក្រាហ្វិចព័ត៌មានការអភិវឌ្ឍ | ● | ● | ● | ● | ● | | ● | ● | ● |
| លំហាត់ផ្តល់ចំណាត់ថ្នាក់ម៉ាទ្រិចសម្រាប់ការចាត់អាទិភាពដំណោះស្រាយការបន្សាំដែលឆ្លើយតបទៅនឹងតម្រូវការយេនឌ័រ | | | | | | ● | ● | | |

## ឧបសម្ព័ន្ធទី ១៖ បញ្ជីផ្ទៀងផ្ទាត់សម្រាប់ការជ្រើសរើសវគ្គ និងលំហាត់

| វគ្គ/លំហាត់ | អង្គការស្ត្រី (សិទ្ធមនុស្ស) | អង្គការស្ត្រី (ផ្តោតលើជីវភាពរស់នៅ និង សេដ្ឋកិច្ច) | អង្គការស្ត្រី (ផ្តោតលើសុខភាព និង ផ្នែកសង្គម) | អង្គការសង្គមស៊ីវិល (ផ្តោតលើជីវភាពរស់នៅនិង សេដ្ឋកិច្ច) | អង្គការសង្គមស៊ីវិល (ផ្តោតលើសុខភាពនិង សង្គម) | CCDRR ដែលផ្តោតលើអង្គការសង្គមស៊ីវិល | ការអនុវត្តនៅមូលដ្ឋាន | ការផ្តោតលើការស្រាវជ្រាវ និងការវិភាគគោលនយោបាយ | ការបណ្តុះបណ្តាលនិងការកសាងសមត្ថភាព |
|---|---|---|---|---|---|---|---|---|---|
| ផែនទីស្ថាបត្យកម្មហិរញ្ញវត្ថុអាកាសធាតុសកល | | | | | | ● | | ● | ● |
| ការងារជាក្រុម | ● | ● | ● | ● | ● | | | | |
| មូលនិធិការបន្សាំសំខាន់ៗសម្រាប់ការចូលរួមអង្គការសង្គមស៊ីវិល | ● | ● | ● | ● | ● | | ● | ● | |
| វគ្គអនុវត្តពីការវិភាគគម្រោងបន្សាំ | ● | ● | ● | | | | | ● | ● |
| ការរៀបចំកញ្ចប់ថវិកាឆ្លើយតបទៅនឹងតម្រូវការយេនឌ័រ៖ ទស្សនៈ សារសំខាន់និងវឌ្ឍនៈភាពនៅតំបន់អាស៊ី | ● | ● | ● | | | | | ● | |
| វីឌីអូ និងសំណួរ | | | | ● | ● | ● | ● | | ● |
| ករណីសិក្សានៅឥណ្ឌូណេស៊ីស្តីពីការចូលរួមរបស់អង្គការសង្គមស៊ីវិលនៅក្នុងដំណើរការ GRB | ● | ● | ● | | | | | ● | ● |
| ការអនុវត្ត GRB នៅក្នុងហិរញ្ញវត្ថុអាកាសធាតុ៖ ក្របខ័ណ្ឌជំហានទាំងប្រាំ និងឧបករណ៍ផ្សេងៗទៀត | ● | ● | ● | | | | | ● | ● |
| GRB សម្រាប់ហិរញ្ញវត្ថុអាកាសធាតុ៖ យេនឌ័រ និងរបាយការណ៍កញ្ចប់ថវិកាអាកាសធាតុ | ● | | | | | | | ● | ● |
| ការបង្កើតគម្រោង CCDRR ដែលឆ្លើយតបទៅនឹងតម្រូវការយេនឌ័រ | | ● | ● | ● | ● | ● | ● | | |

## ឧបសម្ព័ន្ធទី ២៖ កាលវិភាគគំរូសម្រាប់វគ្គមូលដ្ឋានគ្រឹះរយៈពេល៤ថ្ងៃ

| ចំនួនវគ្គ | ម៉ោង | ប្រធានបទ | មាតិកា | វិធីសាស្ត្រ |
|---|---|---|---|---|
| ចាប់ផ្តើម | ៩:០០-៩:១៥ | ការកំណត់បរិបទ | > ការរំពឹងទុករបស់អ្នកចូលរួម<br>> ការចែករំលែករបៀបវារៈ | ការពិភាក្សាដោយបើកចំហរ |
| ១ក. | ៩:១៥-១១:១៥ | | > សិទ្ធិមនុស្ស និងវិធីសាស្ត្រផ្អែកលើសិទ្ធិមនុស្សជាមូលដ្ឋាន(HRBA)<br>> មិនមានអ្នកណាម្នាក់ត្រូវបានទុកចោល (LNOB)<br>> យេនឌ័រ និងអន្តរវិស័យភាព | បទបង្ហាញនិងលំហាត់ជាក្រុម (ដោយអ្នកណាមួយ)<br>•ការបង្កើតភាពប្រទាក់ក្រឡាគ្នារបស់សិទ្ធិមនុស្ស (លំហាត់ទី ១)<br>•ហ្គេម Power Walk (លំហាត់ទី២)<br>•ក្រដាស់តូចៗ ពីទស្សនៈយេនឌ័រ (លំហាត់ទី ៣) |
| | ១១:១៥-១១:៣០ | | សម្រាក | |
| ១ខ. | ១១:៣០-១៣:០០ | ការប្រែប្រួលអាកាសធាតុនិងហានិភ័យដែលជាប់ទាក់ទងទៅនឹងភាពធន់និងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ | > ហានិភ័យអាកាសធាតុសកល ការបន្សាំការកសាងភាពធន់និងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ<br>> ការប្រែប្រួលអាកាសធាតុ និងផលប៉ះពាល់ដែលបានអង្កេត | ការចាក់បញ្ចាំងវីឌីអូ និងលំហាត់ជាក្រុម<br>• អ៊ីស្តូក្រាមអំពីការប្រែប្រួលអាកាសធាតុ (លំហាត់ទី ៤)<br>• វីឌីអូស្តីពីរបាយការណ៍ប៉ាន់ប្រម៉ាណរបស់ IPCC លើកទី៥ (AR5)<br>• ការពិភាក្សាជាក្រុម ដោយប្រើឯកសារមេរៀនទី ៣ |
| | ១៣:០០-១៤:០០ | | សម្រាក | |
| ១គ. | ១៤:០០-១៥:៤៥ | ទំនាក់ទំនងរវាងយេនឌ័រ ការប្រែប្រួលអាកាសធាតុនិងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ | > វិសាលភាពយេនឌ័រនៃ CCDRR<br>> ការបញ្ចូលយេនឌ័រនៅក្នុង CCDRR | បទបង្ហាញ និងលំហាត់ជាក្រុម<br>• បទបង្ហាញផ្ទាំងរូបភាពដោយប្រើរូបភាពទី ៥<br>• ប័ណ្ណផ្តុំផ្គងតួនាទីយេនឌ័រ និងផលប៉ះពាល់ខុសៗគ្នា (លំហាត់ទី ៦ និងឯកសារមេរៀនទី ៥) |
| | ១៥:៤៥-១៦:០០ | | សម្រាក | |
| ២ក. | ១៦:០០-១៧:៣០ | ការយល់ដឹងអំពីការបន្សាំនឹងការប្រែប្រួលអាកាសធាតុនិងទិដ្ឋភាពគោលនយោបាយ DRR | > ក្របខ័ណ្ឌគោលនយោបាយ CCDRR សកល (UNFCCC និង Sendai) និងការប្តេជ្ញាចិត្តយេនឌ័រ<br>> ការអនុវត្តក្របខ័ណ្ឌ UNFCCC និងក្របខ័ណ្ឌការងារទីក្រុងសេនដៃនៅកម្រិតថ្នាក់ជាតិ | បទបង្ហាញ និងលំហាត់ជាក្រុម<br>• «លំហាត់ក្រវ៉» ស្តីពីក្របខ័ណ្ឌ CCDRR អន្តរជាតិ (លំហាត់ទី ៩ និងឯកសារមេរៀនទី ៧)<br>• ការពិភាក្សាក្រុម (លំហាត់ទី ១០ និង ឯកសារមេរៀនទី ៨) |
| | ៩:០០-៩:១៥ | | រំលឹកមេរៀន | |
| ២ខ. | ៩:១៥-១០:៤៥ | ការបញ្ជ្រាបយេនឌ័រនៅក្នុងគោលនយោបាយ និងផែនការជាតិ | > ក្របខ័ណ្ឌជាតិសម្រាប់ CCDRR និងការបញ្ជ្រាបយេនឌ័រនៅកម្រិតប្រទេស<br>> ផែនការជាតិបន្សាំ (NAP) និងការចូលរួមចំណែករបស់ជាតិ(NDCs) | បទបង្ហាញ និងលំហាត់ជាក្រុម<br>• ការវិភាគយេនឌ័រ NAP និង NDC ដោយការប្រើបញ្ជីផ្ទៀងផ្ទាត់(លំហាត់ទី ១១ និងសំណៅឯកសារមេរៀនទី ៩) |
| | ១០:៤៥-១១:០០ | | សម្រាក | |
| ២ខ. | ១១:០០-១៣:០០ | | > តម្រូវការសម្រាប់ការបញ្ជ្រាបយេនឌ័រនៅក្នុងគោលនយោបាយជាតិ<br>> ចំណុចខ្វះខាត និងការប្រឈមក្នុងការបញ្ជ្រាបយេនឌ័រ<br>> ការបង្កើតគោលនយោបាយជាតិ CCDRR - ចំណុចចាប់ផ្តើម/ច្រកចូលសម្រាប់អង្គការសង្គមស៊ីវិល | បទបង្ហាញ និងលំហាត់ជាក្រុម<br>• ការសម្តែងតួ «Batokas and Gon kas» (លំហាត់ទី ១៣)<br>• ការពិភាក្សាផ្អែកលើករណីសិក្សា (លំហាត់ទី ១៤ និង ឯកសារមេរៀនទី ១១) |

| ឧបសម្ព័ន្ធទី ២៖ កាលវិភាគគំរូសម្រាប់វគ្គមូលដ្ឋានគ្រឹះរយៈពេល៤ថ្ងៃ | | | | |
|---|---|---|---|---|
| **ចំនួនវគ្គ** | **ម៉ោង** | **ប្រធានបទ** | **មាតិកា** | **វិធីសាស្ត្រ** |
| | ១៣:០០-១៤:០០ | | សម្រាក | |
| ៣ក. | ១៤:០០-១៥:៣០ | ក្របខ័ណ្ឌការបញ្ច្រាបយេនឌ័រ និងឧបករណ៍ | > ការបញ្ច្រាបយេនឌ័រទូទាំងវដ្តគម្រោង<br>> ការវិភាគយេនឌ័រ៖ តម្រូវការដំណើរការ និងឧបករណ៍ដែលជ្រើសរើស | ការបង្រៀន/បទបង្ហាញ និងលំហាត់ជាក្រុម<br>• ក្របខ័ណ្ឌ Moser សម្រាប់ការរៀបចំផែនការ (សូមមើលលំហាត់ទី ១៥) |
| | ១៥:៣០-១៥:៤៥ | | សម្រាក | |
| | ១៥:៤៥-១៧:៣០ | | > ឧទាហរណ៍កាប៉ាន់ប្រម៉ាណយេនឌ័រ<br>> ការរៀបចំផែនការឆ្លើយតបទៅនឹងតម្រូវការយេនឌ័រ ការរៀបចំ និងបង្កើតគម្រោង | បទបង្ហាញ និងលំហាត់ជាក្រុម<br>• ការពិភាក្សាជាក្រុមតូច (សូមមើលលំហាត់ទី ១៧ និងសំណៅឯកសារទី ១២)<br>• ក្របខ័ណ្ឌបុព្វហេតុ ផលវិបាក និងដំណោះស្រាយ (លំហាត់ទី ១៨) |
| | ៩:០០-៩:១៥ | | រំលឹកមេរៀន | |
| ៤ក. | ៩:១៥-៩:៤៥ | វិធីសាស្ត្រការបន្សាំនិងគម្រោងភាពធន់ដែលដឹកនាំដោយសហគមន៍ | > ម៉ូឌែលការបន្សាំ<br>> ការប៉ាន់ប្រម៉ាណគម្រោង បន្សាំដែលឆ្លើយតបទៅនឹងតម្រូវការយេនឌ័រ | បទបង្ហាញ និងលំហាត់ជាក្រុម<br>• ការពិភាក្សាជាក្រុមគ្រាប់ (លំហាត់ទី ២១ និងឯកសារមេរៀនទី ១៦ និង ១៧) |
| | ១០:៤៥-១១:០០ | | សម្រាក | |
| | ១១:០០-១២:៣០ | | > គម្រោងភាពធន់ ទីក្រុងផ្អែកលើសហគមន៍ដែលដឹកនាំដោយស្ត្រី | វិធីសាស្ត្រត្រួតពិនិត្យករណីសិក្សា Harvard (លំហាត់ទី ២២ និងឯកសារមេរៀនទី ១៨) |
| | ១២:៣០-១៣:៣០ | | សម្រាក | |
| ៤ខ. | ១៣:៣០-១៥:៣០ | វិសាលភាពយេនឌ័រ និង CCDRR តាមវិស័យ | > អន្តរទំនាក់ទំនងនៃយេនឌ័រ និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុនៅក្នុងវិស័យដែលបានជ្រើសរើស<br>> ភាពងាយរងគ្រោះទាក់ទងនឹងយេនឌ័រនិងជម្រើសការបន្សាំនៅក្នុងវិស័យដែលបានជ្រើសរើស | ការបង្រៀន/បទបង្ហាញ និងលំហាត់ជាក្រុម<br>• លំហាត់ក្រាហ្វិកព័ត៌មានការអភិវឌ្ឍ (លំហាត់ទី ២១ និង ឯកសារមេរៀនទី ១៩) |
| | ១៥:៣០-១៥:៤៥ | | សម្រាក | |
| | ១៥:៤៥-១៧:៣០ | | > ដំណោះស្រាយការបន្សាំដែលឆ្លើយតបទៅនឹងតម្រូវការយេនឌ័រ | ការធ្វើចំណាត់ថ្នាក់ម៉ាទ្រិច (លំហាត់ទី ២២ និងឯកសារមេរៀនទី ២០) |
| ៥ក. | ៩:១៥-១០:៤៥ | ហិរញ្ញវត្ថុអាកាសធាតុនិងយេនឌ័រ | > ស្ថាបត្យកម្មហិរញ្ញវត្ថុអាកាសធាតុសកល | ការចាក់បញ្ចាំងវីឌីអូ និងលំហាត់ជាក្រុម<br>• ការងារជាក្រុម (លំហាត់ទី ២៣ និង ឯកសារមេរៀនទី ២១) |
| | ១០:៤៥-១១:០០ | | សម្រាក | |
| | ១១:០០-១២:០០ | | > មូលនិធិការបន្សាំសំខាន់ៗ និងការកំណត់វិសាលភាពសម្រាប់ការចូលរួមរបស់អង្គការសង្គមស៊ីវិល | បទបង្ហាញ និងការពិភាក្សា |

## ឧបសម្ព័ន្ធទី ២៖ កាលវិភាគគំរូសម្រាប់វគ្គមូលដ្ឋានគ្រឹះរយៈពេល៤ថ្ងៃ

| ចំនួនវគ្គ | ម៉ោង | ប្រធានបទ | មាតិកា | វិធីសាស្ត្រ |
|---|---|---|---|---|
| ៥ខ. | ១២:០០-១៣:៣០ | ការរៀបចំកញ្ចប់ថវិកាឆ្លើយតបទៅនឹងតម្រូវការយេនឌ័រ និង CCDRR | > ទស្សនៈ និងសារសំខាន់នៃការរៀបចំកញ្ចប់ថវិកាឆ្លើយតបទៅនឹងតម្រូវការយេនឌ័រ (GRB)<br>> ដំណើរការ GRB នៅតំបន់អាស៊ី<br>> ការចូលរួមរបស់អង្គការសង្គមស៊ីវិលនៅក្នុងដំណើរការ GRB | បទបង្ហាញ និងលំហាត់ជាក្រុម<br>• វីឌីអូ និងសំណួរបញ្ជាំងតាមកុំព្យូទ័រ (លំហាត់ទី ២៥ និង ឯកសារទីមេរៀន ២៣)<br>• ការពិភាក្សាជាក្រុមដោយប្រើករណីសិក្សានៅឥណ្ឌូណេស៊ី (លំហាត់ទី ២៦ និងឯកសារមេរៀនទី ២៤) |
| | ១៣:៣០-១៤:៣០ | | សម្រាក | |
| បញ្ចប់ | ១៤:៣០-១៦:០០ | ការបង្កើតសំណើ CCDRR | > លំហាត់ជាក្រុមពីការបង្កើតផ្ទាំងរូបភាពគម្រោងនិងផ្ទាំងទស្សនីយភាព | |
| | ១៣:៣០-១៤:៣០ | | សម្រាក | |
| | ១៦:១៥-១៧:០០ | ការពិនិត្យឡើងវិញ និង ផែនការបន្ទាប់ | > ការបំផុសគំនិតលើការពិនិត្យឡើងវិញនៃការបង្រៀននិងផែនការបន្ទាប់<br>> ការវាយតម្លៃវគ្គបណ្តុះបណ្តាល (ការបំពេញទម្រង់) | បទបង្ហាញ និងលំហាត់ជាក្រុម |

## ឧបសម្ព័ន្ធទី ៣៖ កាលវិភាគគំរូសម្រាប់វគ្គកម្រិតខ្ពស់ចំនួន៥ថ្ងៃ

| ចំនួនវគ្គ | ម៉ោង | ប្រធានបទ | មាតិកា | វិធីសាស្ត្រ |
|---|---|---|---|---|
| ចាប់ផ្តើម | ៩:០០-៩:១៥ | ការកំណត់បរិបទ | > ការរំពឹងទុករបស់អ្នកចូលរួម<br>> ការចែករំលែករបៀបវារៈ | ការពិភាក្សាដោយបើកចំហរ |
| ១ក. | ៩:១៥-១០:១៥ | សេចក្តីផ្តើមអំពីសិទ្ធិមនុស្ស មិនមានអ្នកណាម្នាក់ត្រូវបានទុកចោល និងសមភាពយេនឌ័រ | > សិទ្ធិមនុស្ស និងវិធីសាស្ត្រផ្អែកលើសិទ្ធិមនុស្សជាមូលដ្ឋាន (HRBA) | ការបង្រៀន និងលំហាត់ជាក្រុមស្តីពីការបង្កើតភាពប្រទាក់ក្រឡាគ្នា របស់សិទ្ធិមនុស្ស (លំហាត់ទី ១) |
| | ១០:១៥-១១:៣០ | | សម្រាក | |
| | ១០:៣០-១២:៣០ | | > មិនមានអ្នកណាម្នាក់ត្រូវបានទុកចោល (LNOB)<br>> សមភាពយេនឌ័រនិងអន្តរវិស័យភាព | បទបង្ហាញ និងលំហាត់ជាក្រុម<br>• ហ្គេម Power Walk (លំហាត់ទី២)<br>• ក្រដាស់តូចៗពីទស្សនៈយេនឌ័រ (លំហាត់ទី៣និងឯកសារមេរៀនទី១) |
| | ១២:៣០-១៣:៣០ | | សម្រាក | |
| ១ខ. | ១៣:៣០-១៥:៣០ | ការប្រែប្រួលអាកាសធាតុ និងហានិភ័យដែលជាប់ទាក់ទង ភាពធន់ និង ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ | > ហានិភ័យអាកាសធាតុសកល ការបន្សាំ ការកសាងភាពធន់ និងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ<br>> ការអង្កេត CCDRR<br>> ទស្សនៈភាពធន់ | បទបង្ហាញ និងលំហាត់ជាក្រុម<br>• អ៊ីស្លក្រាមអំពីការប្រែប្រួលអាកាសធាតុ (លំហាត់ទី ៤)<br>• ទស្សនៈភាពធន់ (លំហាត់ទី ៥ និង ឯកសារមេរៀនទី ៤) |
| | ១៥:៣០-១៥:៤៥ | | សម្រាក | |
| ១គ. | ១៥:៤៥-១៨:០០ | ទំនាក់ទំនងរវាងយេនឌ័រ ការប្រែប្រួលអាកាសធាតុ និងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ | > វិសាលភាពយេនឌ័រនៃ CCDRR<br>> ការបញ្ចូលយេនឌ័រនៅក្នុង CCDRR<br>> ស្ត្រីជាភ្នាក់ងារការផ្លាស់ប្តូរ | បទបង្ហាញ និងលំហាត់ជាក្រុម<br>• ក្របខ័ណ្ឌ Moser សម្រាប់ការបង្កើតផែនទីហានិភ័យ អាកាសធាតុ (លំហាត់ទី ៧)<br>• ការពិនិត្យ ករណីសិក្សាឡើងវិញ (លំហាត់ទី៨និងឯកសារមេរៀនទី៦) |

## ឧបសម្ព័ន្ធទី ៣៖ កាលវិភាគគំរូសម្រាប់វគ្គកម្រិតខ្ពស់ចំនួន៥ថ្ងៃ

| ចំនួនវគ្គ | ម៉ោង | ប្រធានបទ | មាតិកា | វិធីសាស្ត្រ |
|---|---|---|---|---|
| | ៩:០០-៩:១៥ | | រំលឹកមេរៀន | |
| ២ក. | ៩:១៥-១០:០០ | ការយល់ដឹងអំពីការបន្សាំការប្រែប្រួលអាកាសធាតុនិងទិដ្ឋភាពគោលនយោបាយ DRR | > ក្របខ័ណ្ឌគោលនយោបាយ CCDRR សកល (ក្របខ័ណ្ឌ UNFCCC និងក្របខ័ណ្ឌការងារ Sendai) និងការប្តេជ្ញាចិត្តយេនឌ័រ<br>> ការអនុវត្តក្របខ័ណ្ឌ UNFCCC និងក្របខ័ណ្ឌការងារទីក្រុងសេនដៃនៅកម្រិតជាតិ | បទបង្ហាញ និងលំហាត់ជាក្រុម<br>• Cross and Knots or Tic Tac Toe (លំហាត់ទី៩និងឯកសារទីមេរៀន៧)<br>• ការពិភាក្សាជាក្រុម (លំហាត់ទី១០ និងឯកសារមេរៀនទី ៨) |
| | ១១:១៥-១១:៣០ | | សម្រាក | |
| | ១១:៣០-១៣:០០ | | > ក្របខ័ណ្ឌជាតិសម្រាប់ CCDRR និងការបញ្ជ្រាបយេនឌ័រនៅកម្រិតប្រទេស<br>> ស្ថានភាពនៃការបញ្ជ្រាបយេនឌ័រនៅក្នុងគោលនយោបាយ CCDDR ថ្នាក់ជាតិដោយការប្រើ CEDAW និងទស្សនៈវិស័យ BPfA | បទបង្ហាញ និងលំហាត់ជាក្រុម<br>• ការបង្កើតរបាយការណ៍ស្រមោលសម្រាប់ CEDAW និង BPfA (លំហាត់ទី ១២ និង ឯកសារមេរៀនទី ១០) |
| | ១៣:០០-១៤:០០ | | សម្រាក | |
| ២ខ. | ៩:១៥-៩:៤៥ | ការបញ្ជ្រាបយេនឌ័រនៅក្នុងគោលនយោបាយ និងផែនការថ្នាក់ជាតិ | > តម្រូវការសម្រាប់ការបញ្ជ្រាបយេនឌ័រនៅក្នុងគោលនយោយបាយថ្នាក់ជាតិ<br>> ចំណុចខ្វះខាត និងការប្រឈមក្នុងការបញ្ជ្រាបយេនឌ័រ | លំហាត់ជាក្រុម<br>• ការសម្តែងតួ «Batokas and Gonkas» (លំហាត់ទី ១៣)<br>• ការពិភាក្សាជាក្រុមតូច |
| | ១៥:៣០-១៥:៤៥ | | សម្រាក | |
| | ១៥:៤៥-១៨:០០ | | > យុទ្ធសាស្ត្រក្នុងការបញ្ជ្រាបយេនឌ័រ៖ អភិបាលកិច្ច និងស្ថាប័ន គោលនយោបាយ និងផែនការជាតិបន្សាំ (NAPs) និងផែនការសកម្មភាពប្រែប្រួលអាកាសធាតុ និងយេនឌ័រ (ccGAP)<br>> ការបង្កើតគោលនយោបាយ CCDRR ថ្នាក់ជាតិ - ចំណុចចាប់ផ្តើម/ច្រកចូលសម្រាប់អង្គការសង្គមស៊ីវិល | បទបង្ហាញ និងលំហាត់ជាក្រុម<br>• ការពិភាក្សាផ្តែកលើករណីសិក្សា (លំហាត់ទី ១៤ និង ឯកសារមេរៀនទី ១១) |
| | ៩:០០-៩:១៥ | | រំលឹកមេរៀន | |
| ៣ក. | ៩:១៥-១០:៤៥ | ឧបករណ៍និងក្របខ័ណ្ឌការបញ្ជ្រាបយេនឌ័រ | > ការបញ្ជ្រាបយេនឌ័រទូទាំងវដ្តគម្រោង<br>> ការវិភាគយេនឌ័រ៖ តម្រូវការ ដំណើរការ និងឧបករណ៍ដែលជ្រើសរើស | ការបង្រៀន/បទបង្ហាញនិងលំហាត់ជាក្រុម<br>• វគ្គអនុវត្តក្របខ័ណ្ឌវិភាគ Harvard (លំហាត់ទី ១៦) |
| | ១០:៤៥-១១:០០ | | សម្រាក | |
| | ១១:០០-១៣:០០ | | > ឧបករណ៍សម្រាប់ការប៉ាន់ប្រម៉ាណភាពងាយរងគ្រោះដែលមានទស្សនៈយេនឌ័រ ឧបករណ៍សម្រាប់គម្រោង CCDRR<br>> ឧទាហរណ៍នៃការប៉ាន់ប្រម៉ាណយេនឌ័រ<br>> ការរៀបចំផែនការឆ្លើយតបទៅនឹងតម្រូវការយេនឌ័រ ការរៀបចំ និងការបង្កើតគម្រោង | បទបង្ហាញ និងលំហាត់ជាក្រុម<br>• ការពិភាក្សាជាក្រុមតូច (លំហាត់ទី ១៧ និងឯកសារមេរៀនទី ១២) |

## ឧបសម្ព័ន្ធទី ៣៖ កាលវិភាគគំរូសម្រាប់វគ្គកម្រិតខ្ពស់ចំនួន៥ថ្ងៃ

| ចំនួនវគ្គ | ម៉ោង | ប្រធានបទ | មាតិកា | វិធីសាស្ត្រ |
|---|---|---|---|---|
| | ១៣:០០-១៤:០០ | | សម្រាក | |
| ៣ខ. | ១៤:០០-១៦:១៥ | ឧបករណ៍និងក្របខ័ណ្ឌការបញ្ជ្រាបយេនឌ័រ | > ដំណើរការអនុវត្តដែលមានទស្សនៈយេនឌ័រ<br>> ឧបករណ៍ដែលមានការចូលរួមនិងបច្ចេកទេស | បទបង្ហាញ និងលំហាត់ជាក្រុម<br>• ទីផ្សារកម្មវិធី (លំហាត់ទី ១៩ និងឯកសារមេរៀនទី ១៣) |
| | ១៦:១៥-១៦:៣០ | | សម្រាក | |
| | ១៦:៣០-១៧:៣០ | | > ការតាមដាន និងវាយតម្លៃដែលមានទស្សនៈយេនឌ័រ | បទបង្ហាញ និងលំហាត់ជាក្រុម<br>• លំហាត់ផ្តល់ចំណាត់ថ្នាក់ជាកង់ (Wheel Ranking) (លំហាត់ទី ២០ និងឯកសារមេរៀនទី ១៤) |
| | ៩:០០-៩:១៥ | | រំលឹកមេរៀន | |
| ៤ក. | ៩:១៥-១០:៤៥ | វិធីសាស្ត្រការបន្សាំ និងគម្រោងភាពធន់ដែលដឹកនាំដោយសហគមន៍ | > ម៉ូឌែលការបន្សាំ និងការប៉ាន់ប្រម៉ាណគម្រោងបន្សាំដែលឆ្លើយតបទៅនឹងតម្រូវការយេនឌ័រ | បទបង្ហាញ និងលំហាត់ជាក្រុម<br>• ការពិភាក្សាជាក្រុមគ្រាប់ (លំហាត់ទី ២១ និងឯកសារមេរៀនទី ១៦ និង១៧) |
| | ១០:៤៥-១១:០០ | | សម្រាក | |
